# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៥៨

បាលីប្រែ ៧០ - ៧១

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

និង

# សទ្ធម្មប្បកាសិនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ

# បដិសម្ភិទាមគ្គ

# ទុតិយភាគ~តតិយភាគ

# ៥៨

# បាលីប្រែ ៧០~៧១

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៥៨

# សុត្តន្តបិដក

# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

# ទុតិយភាគ

# មហាវគ្គ ឥន្ទ្រិយកថា

[ ១៣១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ។ ភិក្ខុទាំងនោះទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ។ ឥន្ទ្រិយទាំង ៥ តើអ្វីខ្លះ ។ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឥន្ទ្រិយ ៥ យ៉ាង ។

[ ១៣២ ] ឥន្ទ្រិយទាំង ៥ នេះ បរិសុទ្ធដោយអាការប៉ុន្មាន ។ ឥន្ទ្រិយទាំង ៥ នេះ បរិសុទ្ធដោយអាការ ១៥ ដូច្នេះ សទ្ធិន្ទ្រិយបរិសុទ្ធដោយអាការ ៣ នេះ គឺ បុគ្គលវៀរបុគ្គលដែលឥតសទ្ធា ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានសទ្ធា ១ ពិចារណាព្រះសូត្រដែលជាទីជ្រះថ្លា ១ វីរិយិន្ទ្រិយបរិសុទ្ធដោយអាការ ៣ នេះ គឺ បុគ្គលវៀរបុគ្គលដែលខ្ជិលច្រអូស ១ សេពគប់ គប់រក ចូលទៅអង្គុយជិត បុគ្គលដែលមានសេចក្តី

ព្យាយាម ១ ពិចារណាសម្មប្បធាន ១ សតិន្ទ្រិយបរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលភ្លេចស្មារតី ១ សេពគប់ គប់រកចូលទៅអង្គុយជិត បុគ្គលដែលមានស្មារតីតម្កល់មាំ ១ ពិចារណាសតិប្បដ្ឋាន ១ សមាធិន្ទ្រិយបរិសុទ្ធដោយអាការ ៣ នេះគឺ បុគ្គលវៀរបុគ្គលដែលមានចិត្តមិននឹងធឹង ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានចិត្តនឹងធឹង ១ ពិចារណាឈាននិងវិមោក្ខ ១ បញ្ញិន្ទ្រិយបរិសុទ្ធដោយអាការ ៣ នេះគឺ បុគ្គលវៀរបុគ្គលដែលអាប់ឥតបញ្ញា ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គលដែលមានបញ្ញា ១ ពិចារណានូវញាណចរិយាដ៏ជ្រៅ ១ នេះឯងឥន្ទ្រិយទាំង ៥ បរិសុទ្ធិដោយអាការ ១៥ នេះ គឺ បុគ្គលវៀរបុគ្គល ៥ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គល ៥ ពិចារណាកងព្រះសូត្រ ៥ ដូចពោលមកនេះឯង ។

[ ១៣៣ ] ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនដោយអាការប៉ុន្មានយ៉ាង ការចម្រើននៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង ។

ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនដោយអាការ ១០ យ៉ាង ការចម្រើននៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ១០ យ៉ាងដែរ គឺបុគ្គលកាលលះនូវអស្សទ្ធិយៈ(ការណ៍មិនជឿ) ឈ្មោះថា ចម្រើនសទ្ធិន្ទ្រិយ ១ កាលចម្រើននូវសទ្ធិន្ទ្រិយ ឈ្មោះថា លះអស្សទ្ធិយៈ ១ កាលលះនូវសេចក្តីខ្ជិលច្រអូស ឈ្មោះថាចម្រើនវីរិយិន្ទ្រិយ ១ កាលចម្រើនវីរិយិន្ទ្រិយ ឈ្មោះថាលះសេចក្តីខ្ជិលច្រអូស ១ កាលលះនូវសេចក្តីប្រមាទ ឈ្មោះថាចម្រើនសតិន្ទ្រិយ ១

កាលចម្រើនសតិន្ទ្រិយ ឈ្មោះថាលះសេចក្តីប្រមាទ ១ កាលលះនូវសេចក្តីរាយមាយ ឈ្មោះថា ចម្រើនសមាធិន្ទ្រិយ ១ កាលចម្រើនសមាធិន្ទ្រិយ ឈ្មោះថា លះសេចក្តីរាយមាយ ១ កាលលះអវិជ្ជា ឈ្មោះថាចម្រើនបញ្ញិន្ទ្រិយ ១ កាលចម្រើនបញ្ញិន្ទ្រិយ ឈ្មោះថាលះអវិជ្ជា ១ នេះឯងឥន្ទ្រិយទាំង ៥ ដែលបុគ្គលចម្រើនដោយអាការ ១០ យ៉ាង នេះឯងការចម្រើននៃឥន្ទ្រិយទាំង ៥ ដោយអាការ ១០ យ៉ាង ។

[ ១៣៤ ] ឥន្ទ្រិយទាំង ៥ បុគ្គលបានចម្រើន ចម្រើនល្អហើយ ដោយអាការប៉ុន្មានយ៉ាង ។ ឥន្ទ្រិយទាំង ៥ បុគ្គលបានចម្រើន ចម្រើនល្អហើយ ដោយអាការ ១០ យ៉ាងគឺ សទ្ធិន្ទ្រិយបុគ្គលបានចម្រើន ចម្រើនល្អហើយ ព្រោះបានលះបង់ លះបង់ល្អហើយ នូវអស្សទ្ធិយៈ ១ អស្សទ្ធិយៈបុគ្គលបានលះបង់ លះបង់ល្អហើយ ព្រោះបានចម្រើន ចម្រើនល្អហើយ នូវសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយបុគ្គលបានចម្រើន ចម្រើនល្អហើយ ព្រោះបានលះបង់ លះបង់ល្អហើយ នូវសេចក្តីខ្ជិលច្រអូស ១ សេចក្តីខ្ជិលច្រអូសបុគ្គលបានលះបង់ លះបង់ល្អហើយ ព្រោះបានចម្រើន ចម្រើនល្អហើយ នូវវីរិយិន្ទ្រិយ ១ សតិន្ទ្រិយ បុគ្គលបានចម្រើន ចម្រើនល្អហើយ ព្រោះបានលះបង់ លះបង់ល្អហើយ នូវសេចក្តីប្រមាទ ១ សេចក្តីប្រមាទដែលបុគ្គលបានលះបង់ លះបង់ល្អហើយ ព្រោះបានចម្រើន ចម្រើនល្អហើយ នូវសតិន្ទ្រិយ ១ សមាធិន្ទ្រិយបុគ្គលបានចម្រើន ចម្រើនល្អហើយ ព្រោះបានលះបង់ លះបង់ល្អហើយ នូវឧទ្ធច្ចៈ ១ ឧទ្ធច្ចៈបុគ្គលបានលះបង់ លះបង់ល្អហើយ ព្រោះ

បានចម្រើន ចម្រើនល្អហើយនូវសមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយបុគ្គលបានចម្រើន ចម្រើនល្អហើយ ព្រោះបានលះបង់ លះបង់ល្អហើយ នូវអវិជ្ជា អវិជ្ជាបុគ្គល បានលះបង់ លះបង់ល្អហើយ ព្រោះបានចម្រើន ចម្រើនល្អហើយនូវបញ្ញិន្ទ្រិយ ១ នេះឥន្ទ្រិយទាំង ៥ បុគ្គលបានចម្រើន ចម្រើនល្អហើយ ដោយអាការ ១០ យ៉ាង ។

[ ១៣៥ ] ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនដោយអាការប៉ុន្មានយ៉ាង ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផង ដោយអាការប៉ុន្មានយ៉ាង ។ ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនដោយអាការ ៤ យ៉ាង ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផង ក៏ដោយអាការ ៤ យ៉ាងដែរ គឺ ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនក្នុងខណៈនៃសោតាបត្តិមគ្គ ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផងក្នុងខណៈនៃសោតាបត្តិផល ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនក្នុងខណៈនៃសកទាមិមគ្គ ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផងក្នុងខណៈនៃសកទាគាមិផល ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនក្នុងខណៈនៃអនាគាមិមគ្គ ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផងក្នុងខណៈនៃអនាគាមិផល ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនក្នុងខណៈនៃអរហត្តមគ្គ ឥន្ទ្រិយទាំង

៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អហើយផងក្នុងខណៈនៃអរហត្តផល ។

មគ្គវិសុទ្ធិ ៤ យ៉ាង ផលវិសុទ្ធិ ៤ យ៉ាង សមុច្ឆេទវិសុទ្ធិ ៤ យ៉ាង បដិប្បស្សទ្ធិវិសុទ្ធិ ៤ យ៉ាង ដោយប្រការដូច្នេះ នេះឯងឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនដោយអាការ ៤ យ៉ាង នេះឯងឥន្ទ្រិយទាំង ៥ ដែលបុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ស្ងប់រម្ងាប់ហើយផង ស្ងប់រម្ងាប់ល្អ-ហើយផង ដោយអាការ ៤ យ៉ាង ។

[ ១៣៦ ] បុគ្គលប៉ុន្មានពួក កំពុងមានការអប់រំឥន្ទ្រិយ បុគ្គលប៉ុន្មានពួក មានឥន្ទ្រិយអប់រំហើយ ។ បុគ្គល ៨ ពួក កំពុងមានការអប់រំឥន្ទ្រិយ បុគ្គល ៣ ពួក មានឥន្ទ្រិយអប់រំហើយ ។

បុគ្គល ៨ ពួក កំពុងមានការអប់រំឥន្ទ្រិយ តើដូចម្តេចខ្លះ ។ សេក្ខ-បុគ្គល ៧ និងកល្យាណបុថុជ្ជន ១ បុគ្គលទាំង ៨ ពួកនេះ កំពុងមានការអប់រំឥន្ទ្រិយ ។ បុគ្គល ៣ ពួក ( មានឥន្ទ្រិយអប់រំហើយ ) តើដូចម្តេចខ្លះ ។ សាវ័ករបស់ព្រះតថាគត ជាព្រះខីណាស្រព មាននាមថាពុទ្ធ: ដោយអំណាចលោកជាអ្នកមានឥន្ទ្រិយអប់រំហើយ ឈ្មោះថាមានឥន្ទ្រិយអប់រំហើយ ១ ព្រះបច្ចេកពុទ្ធ ដោយអត្ថថា ត្រាស់ដឹងឯង ឈ្មោះថាមានឥន្ទ្រិយអប់រំហើយ ១ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ដោយអត្ថថា មានគុណរាប់មិនបាន ឈ្មោះថាមានឥន្ទ្រិយអប់រំហើយ ១ នេះឯង បុគ្គល ៣ ពួក ដែលមានឥន្ទ្រិយអប់រំហើយ បុគ្គល ៨ ពួកនេះ កំពុងមានការអប់រំឥន្ទ្រិយ បុគ្គល ៣ ពួកនេះ មានឥន្ទ្រិយអប់រំហើយ ដូចពោលមកនេះឯង ។

# សាវត្ថីនិទាន

[ ១៣៧ ] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ យ៉ាង ឥន្ទ្រិយ ៥ យ៉ាងតើអ្វីខ្លះ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមពិតនូវការកើតឡើងផង នូវសេចក្ដីវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង របស់ឥន្ទ្រិយទាំង ៥ នេះទេ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនុ៎ះ គេមិនសន្មតថាជាសមណៈក្នុងពួកសមណៈ មិនសន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទេ មិនតែប៉ុណ្ណោះ សមណព្រាហ្មណ៍ដ៏មានអាយុទាំងនោះ រមែងមិនធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផល ឬព្រហ្មញ្ញផល ដោយបញ្ញាដ៏ឧត្ដម របស់ខ្លួនឯងក្នុងបច្ចុប្បន្ននេះបានឡើយ ។

ម្នាលភិក្ខុទាំងឡាយ លុះតែសមណៈឬព្រាហ្មណ៍ឯណានីមួយដឹងច្បាស់តាមពិតនូវការកើតឡើងផង នូវសេចក្ដីវិនាសផង នូវអានិសង្សផង នូវទោសផង នូវការរលាស់ចេញផង របស់ឥន្ទ្រិយទាំង ៥ នេះ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនោះ ទើបគេសន្មតថា ជាសមណៈក្នុងពួកសមណៈ សន្មតថា ជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍មែន មិនតែប៉ុណ្ណោះ សមណព្រាហ្មណ៍ដ៏មានអាយុទាំងនោះ រមែងធ្វើឲ្យជាក់ច្បាស់ សម្រេចនូវសាមញ្ញផល ឬព្រហ្មញ្ញផលដោយបញ្ញាដ៏ឧត្ដមរបស់ខ្លួនឯង ក្នុងបច្ចុប្បន្ន

បាន ។

[ ១៣៨ ] ការកើតនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង បុគ្គលដឹងច្បាស់នូវការកើតនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង សេចក្តីវិនាសនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង បុគ្គលដឹងច្បាស់នូវសេចក្តីវិនាសនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង អានិសង្សនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង បុគ្គលដឹងច្បាស់នូវអានិសង្សនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង ទោសនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង បុគ្គលដឹងច្បាស់នូវទោសនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង ការរលាស់ចេញនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង បុគ្គលដឹងច្បាស់នូវការរលាស់ចេញនៃឥន្ទ្រិយទាំង ៥ ដោយអាការប៉ុន្មានយ៉ាង ។ ការកើតនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង បុគ្គលដឹងច្បាស់នូវការកើតនៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ៤០ យ៉ាងដែរ សេចក្តីវិនាសនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង បុគ្គលដឹងច្បាស់នូវសេចក្តីវិនាសនៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ៤០ យ៉ាងដែរ អានិសង្សនៃឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង បុគ្គលដឹងច្បាស់នូវអានិសង្សនៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ២៥ យ៉ាងដែរ ទោសនៃឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង បុគ្គលដឹងច្បាស់នូវទោសនៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ២៥ យ៉ាងដែរ ការរលាស់ចេញនៃឥន្ទ្រិយទាំង ៥ ដោយអាការ ១៨០ បុគ្គលដឹងច្បាស់នូវការរលាស់ចេញនៃឥន្ទ្រិយទាំង ៥ ក៏ដោយអាការ ១៨០ ដែរ ។

[ ១៣៩ ] ការកើតនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង តើអ្វីខ្លះ ។ បុគ្គលដឹងច្បាស់នូវការកើតនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង តើអ្វីខ្លះ ។ ការកើតនៃការពិចារណាដើម្បីប្រយោជន៍ដល់ការជឿស៊ប់ ឈ្មោះថាការកើតនៃសទ្ធិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថា ការកើតនៃសទ្ធិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថា ការកើតនៃសទ្ធិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា ការកើតនៃសទ្ធិន្ទ្រិយ ១ ការកើតនៃការពិចារណាដើម្បីប្រយោជន៍ដល់ការផ្គង ឈ្មោះថា ការកើតនៃវីរិយិន្ទ្រិយ ១ ការកើតនៃឆន្ទៈដោយអំណាចនៃការផ្គង ឈ្មោះថា ការកើតនៃវីរិយិន្ទ្រិយ ១ ការកើតនៃមនសិការៈដោយអំណាចនៃការផ្គង ឈ្មោះថា ការកើតនៃវីរិយិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃវីរិយិន្ទ្រិយ ឈ្មោះថា ការកើតនៃវីរិយិន្ទ្រិយ ១ ការកើតនៃការពិចារណាដើម្បីប្រយោជន៍ដល់ការប្រុងស្មារតី ឈ្មោះថា ការកើតនៃសតិន្ទ្រិយ ១ ការកើតនៃឆន្ទៈដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថា ការកើតនៃសតិន្ទ្រិយ ១ ការកើតនៃមនសិការៈដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថាការកើតនៃសតិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសតិន្ទ្រិយ ឈ្មោះថា ការកើតនៃសតិន្ទ្រិយ ១ ការកើតនៃការពិ-ចារណាដើម្បីប្រយោជន៍ដល់ការមិនរាយមាយ ឈ្មោះថា ការកើតនៃសមា-ធិន្ទ្រិយ ១ ការកើតនៃឆន្ទៈដោយអំណាចនៃការមិនរាយមាយ ឈ្មោះថា ការ

កើតនៃសមាធិន្ទ្រិយ ១ ការកើតនៃមនសិការៈដោយអំណាចនៃការមិនរាយមាយ ឈ្មោះថា ការកើតនៃសមាធិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថា កាកើតនៃសមាធិន្ទ្រិយ ១ ការកើតនៃការពិចារណាដើម្បីប្រយោជនដល់ការឃើញ ឈ្មោះថា ការកើតនៃបញ្ញិន្ទ្រិយ ការកើតនៃឆន្ទៈដោយអំណាចនៃការឃើញ ឈ្មោះថា ការកើតនៃបញ្ញិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាចនៃការឃើញ ឈ្មោះថា ការកើតនៃបញ្ញិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃបញ្ញិន្ទ្រិយ ឈ្មោះថា ការកើតនៃបញ្ញិន្ទ្រិយ ១ ការកើតនៃការពិចារណាដើម្បីប្រយោជន៍ដល់ការជឿស៊ប់ ឈ្មោះថា ការកើតនៃសទ្ធិន្ទ្រិយ ១ ការកើតនៃការពិចារណាដើម្បីប្រយោជន៍ដល់ការផ្គង ឈ្មោះថា ការកើតនៃវីរិយិន្ទ្រិយ ១ ការកើតនៃការពិចារណាដើម្បីប្រយោជន៍ដល់ការប្រុងស្មារតី ឈ្មោះថា ការកើតនៃសតិន្ទ្រិយ ១ ការកើតនៃការពិចារណាដើម្បីប្រយោជន៍ដល់ការមិនរាយមាយ ឈ្មោះថា ការកើតនៃសមាធិន្ទ្រិយ ១ ការកើតនៃការពិចារណាដើម្បីប្រយោជន៍ដល់ការឃើញ ឈ្មោះថា ការកើតនៃបញ្ញិន្ទ្រិយ ១ ការកើតនៃឆន្ទៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថា ការកើតនៃសទ្ធិន្ទ្រិយ ១ ការកើតនៃឆន្ទៈដោយអំណាចនៃការផ្គង ឈ្មោះថា ការកើតនៃវីរិយិន្ទ្រិយ ១ ការកើតនៃឆន្ទៈដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថា ការកើតនៃសតិន្ទ្រិយ ១ ការកើតនៃឆន្ទៈដោយអំណាចនៃការមិនរាយមាយ ឈ្មោះថា ការកើតនៃសមាធិន្ទ្រិយ ១ ការកើតនៃឆន្ទៈដោយ

អំណាចនៃការឃើញ ឈ្មោះថា ការកើតនៃបញ្ញិន្ទ្រិយ ១ ការកើតនៃមនសិការៈដោយអំណាចនៃការជឿស៊ប់ ឈ្មោះថា ការកើតនៃសទ្ធិន្ទ្រិយ ១ ការកើតនៃមនសិការៈដោយអំណាចនៃការផ្គង ឈ្មោះថា ការកើតនៃវីរិយិន្ទ្រិយ ១ ការកើតនៃមនសិការៈដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថា ការកើតនៃសតិន្ទ្រិយ ១ ការកើតនៃមនសិការៈ ដោយអំណាចនៃការមិនរាយមាយ ឈ្មោះថាការកើតនៃសមាធិន្ទ្រិយ ១ ការកើតនៃមនសិការៈដោយអំណាចនៃការឃើញ ឈ្មោះថា ការកើតនៃបញ្ញិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា ការកើតនៃសទ្ធិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃវីរិយិន្ទ្រិយ ឈ្មោះថា ការកើតនៃវីរិយិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសតិន្ទ្រិយ ឈ្មោះថា ការកើតនៃសតិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថា ការកើតនៃសមាធិន្ទ្រិយ ១ ការប្រាកដនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃបញ្ញិន្ទ្រិយ ឈ្មោះថា ការកើតនៃបញ្ញិន្ទ្រិយ ១ នេះឯងការកើតនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង នេះឯងបុគ្គលដឹងច្បាស់នូវការកើតនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង ។

[ ១៤០ ] សេចក្ដីវិនាសនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង តើអ្វីខ្លះ បុគ្គលដឹងច្បាស់នូវសេចក្ដីវិនាសនៃឥន្ទ្រិយទាំង ៥ ដោយអាការៈ ៤០ យ៉ាង តើអ្វីខ្លះ ។ សេចក្ដីវិនាសនៃការពិចារណាដើម្បីប្រយោជន៍ដល់

ការជឿស៊ប់ ឈ្មោះថា ការវិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថា ការវិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈដោយអំណាចនៃការជឿស៊ប់ ឈ្មោះថា ការវិនាសនៃសទ្ធិន្ទ្រិយ ១ ការមិនប្រាកដនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា ការវិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណាដើម្បីប្រយោជន៍ដល់ការផ្គងឈ្មោះថា ការវិនាសនៃវីរិយិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាចនៃការផ្គង ឈ្មោះថា ការវិនាសនៃវីរិយិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈដោយអំណាចនៃការផ្គង ឈ្មោះថា ការវិនាសនៃវីរិយិន្ទ្រិយ ១ ការមិនប្រាកដនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃវីរិយិន្ទ្រិយ ឈ្មោះថា ការវិនាសនៃវីរិយិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណាដើម្បីប្រយោជន៍ដល់ការប្រុងស្មារតី ឈ្មោះថា ការវិនាសនៃសតិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថា ការវិនាសនៃសតិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថា ការវិនាសនៃសតិន្ទ្រិយ ១ ការមិនប្រាកដឡើងនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃសតិន្ទ្រិយ ឈ្មោះថា ការវិនាសនៃសតិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការមិនរាយមាយ ឈ្មោះថា ការវិនាសនៃសមាធិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈដោយអំណាចនៃការមិនរាយមាយ ឈ្មោះថា ការវិនាសនៃសមាធិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈដោយអំណាចនៃការមិនរាយមាយ ឈ្មោះថា ការវិនាសនៃ

សមាធិន្ទ្រិយ ១ ការមិនប្រាកដនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃ សមាធិន្ទ្រិយ ឈ្មោះថា ការវិនាសនៃសមាធិន្ទ្រិយ ១ សេចក្តីវិនាសនៃការ ពិចារណាដើម្បីប្រយោជន៍ដល់ការឃើញ ឈ្មោះថា ការវិនាសនៃបញ្ញិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាចនៃការឃើញ ឈ្មោះថា ការវិនាស នៃបញ្ញិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈ ដោយអំណាចនៃការឃើញ ឈ្មោះថា ការវិនាសនៃបញ្ញិន្ទ្រិយ ១ ការមិនប្រាកដនៃចិត្តមានអារម្មណ៍តែ មួយដោយអំណាចនៃបញ្ញិន្ទ្រិយ ឈ្មោះថា ការវិនាសនៃបញ្ញិន្ទ្រិយ ១ សេចក្តី វិនាសនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការជឿស៊ប់ ឈ្មោះថា ការ វិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណាដើម្បីប្រយោជន៍ដល់ ការផ្គង ឈ្មោះថា ការវិនាសនៃវិរិយិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចា-រណាដើម្បីប្រយោជន៍ដល់ការប្រុងស្មារតី ឈ្មោះថា ការវិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណា ដើម្បីប្រយោជន៍ដល់ការមិនរាយមាយ ឈ្មោះថា ការវិនាសនៃសមាធិន្ទ្រិយ ១ សេចក្តីវិនាសនៃការពិចារណាដើម្បី ប្រយោជន៍ដល់ការឃើញ ឈ្មោះថា ការវិនាសនៃបញ្ញិន្ទ្រិយ ១ សេចក្តី វិនាសនៃឆន្ទៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថា ការវិនាសនៃសទ្ធិ-ន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈ ដោយអំណាចនៃការផ្គង ឈ្មោះថា ការ វិនាសនៃវិរិយិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថា ការវិនាសនៃសតិន្ទ្រិយ ១ សេចក្តីវិនាសនៃឆន្ទៈដោយអំណាច នៃការមិនរាយមាយ ឈ្មោះថា ការវិនាសនៃសមាធិន្ទ្រិយ ១ សេចក្តីវិនាស

នៃឆន្ទៈដោយអំណាចនៃការឃើញ ឈ្មោះថា ការវិនាសនៃបញ្ញិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈ ដោយអំណាចនៃការជឿស៊ប់ ឈ្មោះថា ការវិនាសនៃសទ្ធិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈដោយអំណាចនៃការផ្គង ឈ្មោះថា ការវិនាសនៃវីរិយិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈ ដោយអំណាចនៃការប្រុងស្មារតី ឈ្មោះថា ការវិនាសនៃសតិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈដោយអំណាចនៃការមិនរាយមាយ ឈ្មោះថា ការវិនាសនៃសមាធិន្ទ្រិយ ១ សេចក្តីវិនាសនៃមនសិការៈដោយអំណាចនៃការឃើញ ឈ្មោះថា ការវិនាសនៃបញ្ញិន្ទ្រិយ ១ ការមិនប្រាកដនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា ការវិនាសនៃសទ្ធិន្ទ្រិយ ១ ការមិនប្រាកដនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃវីរិយិន្ទ្រិយ ឈ្មោះថា ការវិនាសនៃវីរិយិន្ទ្រិយ ១ ការមិនប្រាកដនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសតិន្ទ្រិយ ឈ្មោះថា ការវិនាសនៃសតិន្ទ្រិយ ១ ការមិនប្រាកដនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថា ការវិនាសនៃសមាធិន្ទ្រិយ ១ ការមិនប្រាកដនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃបញ្ញិន្ទ្រិយ ឈ្មោះថា ការវិនាសនៃបញ្ញិន្ទ្រិយ ១ នេះឯងសេចក្តីវិនាសនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង នេះឯងបុគ្គលដឹងច្បាស់នូវសេចក្តីវិនាសនៃឥន្ទ្រិយទាំង ៥ ដោយអាការ ៤០ យ៉ាង ។

[ ១៤១ ] អានិសង្សរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង តើអ្វីខ្លះ បុគ្គលដឹងច្បាស់នូវអានិសង្សរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ

២៥ យ៉ាង តើអ្វីខ្លះ ។ ការមិនប្រាកដនៃសេចក្ដីមិនជឿ ឈ្មោះថាអានិសង្ស របស់សទ្ធិន្ទ្រិយ ១ ការមិនប្រាកដនៃសេចក្ដីក្ដៅក្រហាយព្រោះការមិនជឿ ឈ្មោះថា អានិសង្សរបស់សទ្ធិន្ទ្រិយ ១ សេចក្ដីក្លៀវក្លានៃការប្រព្រឹត្តិតាមជំនឿ ឈ្មោះថា អានិសង្សរបស់សទ្ធិន្ទ្រិយ ១ ការស្ងប់ក្ដី ការបានទូវវិហារធម៌ក្ដី ឈ្មោះថា អានិសង្សរបស់សទ្ធិន្ទ្រិយ ១ សុខនិងសោមនស្ស កើតឡើងព្រោះអាស្រ័យសទ្ធិន្ទ្រិយឯណា នេះឈ្មោះថាអានិសង្សរបស់សទ្ធិន្ទ្រិយ ១ ការមិនប្រាកដនៃសេចក្ដីខ្ជិលច្រអូស ឈ្មោះថាអានិសង្សរបស់វីរិយិន្ទ្រិយ ១ ការមិនប្រាកដនៃសេចក្ដីក្ដៅក្រហាយ ព្រោះការខ្ជិលច្រអូស ឈ្មោះថា អានិសង្សនៃវីរិយិន្ទ្រិយ ១ សេចក្ដីក្លៀវក្លានៃការប្រព្រឹត្តិនូវការផ្គងឡើងឈ្មោះថា អានិសង្សរបស់វីរិយិន្ទ្រិយ ១ ការស្ងប់រម្ងាប់ក្ដី ការបានទូវវិហារធម៌ក្ដី ឈ្មោះថា អានិសង្សរបស់វីរិយិន្ទ្រិយ ១ សុខនិងសោមនស្សកើតឡើងព្រោះអាស្រ័យវីរិយិន្ទ្រិយឯណា នេះឈ្មោះថា អានិសង្សរបស់វីរិយិន្ទ្រិយ ១ ការមិនប្រាកដឡើងនៃសេចក្ដីប្រមាទ ឈ្មោះថា អានិសង្សរបស់សតិន្ទ្រិយ ១ ការមិនប្រាកដនៃសេចក្ដីក្ដៅក្រហាយព្រោះការប្រមាទ ឈ្មោះថា អានិសង្សរបស់សតិន្ទ្រិយ ១ សេចក្ដីក្លៀវក្លានៃការប្រព្រឹត្តិប្រុងស្មារតី ឈ្មោះថា អានិសង្សនៃសតិន្ទ្រិយ ១ ការស្ងប់រម្ងាប់ក្ដី ការបានទូវវិហារធម៌ក្ដី ឈ្មោះថា អានិសង្សរបស់សតិន្ទ្រិយ ១ សុខនិងសោមនស្សកើតឡើងព្រោះអាស្រ័យសតិន្ទ្រិយឯណា នេះឈ្មោះថា អានិសង្សរបស់សតិន្ទ្រិយ ១ ការមិនប្រាកដនៃឧទ្ធច្ចៈ ឈ្មោះថាអានិសង្សរបស់សមាធិន្ទ្រិយ ១ ការមិនប្រាកដនៃសេចក្ដី

ក្តៅក្រហាយព្រោះឧទ្ធច្ចៈ ឈ្មោះថា អានិសង្សរបស់សមាធិន្ទ្រិយ ១ សេចក្តីក្លៀវក្លានៃការប្រព្រឹត្តិមិនរាយមាយ ឈ្មោះថា អានិសង្សរបស់សមាធិន្ទ្រិយ ១ ការស្ងប់រម្ងាប់ក្តី ការបាននូវវិហារធម៌ក្តី ឈ្មោះថា អានិសង្សរបស់សមា-ធិន្ទ្រិយ ១ សុខ និងសោមនស្សកើតឡើងព្រោះអាស្រ័យសមាធិន្ទ្រិយឯណា នេះឈ្មោះថាអានិសង្សរបស់សមាធិន្ទ្រិយ ១ ការមិនប្រាជកនៃអវិជ្ជា ឈ្មោះថា អានិសង្សរបស់បញ្ញិន្ទ្រិយ ១ ការមិនប្រាកដនៃសេចក្តីក្តៅក្រហាយព្រោះអវិជ្ជា ឈ្មោះថា អានិសង្សរបស់បញ្ញិន្ទ្រិយ ១ សេចក្តីក្លៀវក្លានៃការប្រព្រឹត្តិដោយការឃើញ ឈ្មោះថា អានិសង្សរបស់បញ្ញិន្ទ្រិយ ១ ការស្ងប់រម្ងាប់ក្តី ការបាននូវវិហារធម៌ក្តី ឈ្មោះថា អានិសង្សរបស់បញ្ញិន្ទ្រិយ ១ សុខនិងសោមនស្សកើតឡើងព្រោះអាស្រ័យបញ្ញិន្ទ្រិយឯណា នេះឈ្មោះថាអានិសង្សរបស់បញ្ញិន្ទ្រិយ ១ នេះឯងអានិសង្សរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង នេះឯងបុគ្គលដឹងច្បាស់នូវអានិសង្សរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង ។

[ ១៤២ ] ទោសរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង តើអ្វីខ្លះ បុគ្គលដឹងច្បាស់នូវទោសរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង តើអ្វីខ្លះ ។ ការប្រាកដនៃសេចក្តីមិនជឿ ឈ្មោះថា ទោសរបស់សទ្ធិន្ទ្រិយ ១ ការប្រាកដនៃសេចក្តីក្តៅក្រហាយព្រោះការមិនជឿ ឈ្មោះថា ជាទោសរបស់សទ្ធិន្ទ្រិយ ១ ទោសរបស់សទ្ធិន្ទ្រិយដោយអត្ថថាមិនទៀង ១ ទោសរបស់សទ្ធិន្ទ្រិយដោយអត្ថថាជាទុក្ខ ១ ទោសរបស់សទ្ធិន្ទ្រិយ ដោយអត្ថថាមិន

មែនខ្លួន ១ ការប្រាកដនៃសេចក្ដីខ្ជិលច្រអូស ឈ្មោះថា ទោសរបស់វីរិយិន្ទ្រិយ ១ ការប្រាកដនៃសេចក្ដីក្ដៅក្រហាយព្រោះការខ្ជិលច្រអូស ឈ្មោះថា ទោសរបស់វីរិយិន្ទ្រិយ ១ ទោសរបស់វីរិយិន្ទ្រិយដោយអត្ថថាមិនទៀង ១ ទោសរបស់វីរិយិន្ទ្រិយដោយអត្ថថាជាទុក្ខ ១ ទោសរបស់វីរិយិន្ទ្រិយដោយអត្ថថាមិនមែនខ្លួន ១ ការប្រាកដនៃសេចក្ដីប្រមាទ ឈ្មោះថា ទោសរបស់សតិន្ទ្រិយ ១ ការប្រាកដនៃសេចក្ដីក្ដៅក្រហាយ ព្រោះការប្រមាទ ឈ្មោះថា ទោសរបស់សតិន្ទ្រិយ ១ ទោសរបស់សតិន្ទ្រិយដោយអត្ថថាមិនទៀង ១ ទោសរបស់សតិន្ទ្រិយដោយអត្ថថាជាទុក្ខ ១ ទោសរបស់សតិន្ទ្រិយដោយអត្ថថាមិនមែនខ្លួន ១ ការប្រាកដនៃឧទ្ធច្ចៈ ឈ្មោះថា ទោសរបស់សមាធិន្ទ្រិយ ១ ការប្រាកដនៃសេចក្ដីក្ដៅក្រហាយព្រោះឧទ្ធច្ចៈ ឈ្មោះថា ទោសរបស់សមាធិន្ទ្រិយ ១ ទោសរបស់សមាធិន្ទ្រិយដោយអត្ថថាមិនទៀង ១ ទោសរបស់សមាធិន្ទ្រិយដោយអត្ថថាជាទុក្ខ ១ ទោសរបស់សមាធិន្ទ្រិយ ដោយអត្ថថាមិនមែនខ្លួន ១ ការប្រាកដនៃអវិជ្ជា ឈ្មោះថា ទោសរបស់បញ្ញិន្ទ្រិយ ១ ការប្រាកដនៃសេចក្ដីក្ដៅក្រហាយព្រោះអវិជ្ជា ឈ្មោះថា ទោសរបស់បញ្ញិន្ទ្រិយ ១ ទោសរបស់បញ្ញិន្ទ្រិយដោយអត្ថថាមិនទៀង ១ ទោសរបស់បញ្ញិន្ទ្រិយដោយអត្ថថាជាទុក្ខ ១ ទោសរបស់បញ្ញិន្ទ្រិយដោយអត្ថថាមិនមែនខ្លួន ១ នេះឯងទោសរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង នេះឯងបុគ្គលដឹងច្បាស់នូវទោសរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ២៥ យ៉ាង ។

[ ១៨៣ ] ការរលាស់ចេញរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ១៨០

តើអ្វីខ្លះ បុគ្គលដឹងច្បាស់នូវការរលាស់ចេញរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ១៨០ តើអ្វីខ្លះ ។ សទ្ធិន្ទ្រិយដោយអត្ថថាជឿស៊ប់រលាស់ចាកសេចក្តីមិនជឿ ១ រលាស់ចាកសេចក្តីក្តៅក្រហាយព្រោះការមិនជឿ ១ រលាស់ចាកពួកកិលេសដែលប្រព្រឹត្តទៅតាមសេចក្តីក្តៅក្រហាយព្រោះការមិនជឿនោះនិងចាកពួកខន្ធ ១ រលាស់ចាកនិមិត្តទាំងពួងពួដ៏ខាងក្រៅ ១ រលាស់ចាកសទ្ធិ-ន្ទ្រិយមុនបង្អស់ព្រោះកិរិយាបាននូវសទ្ធិន្ទ្រិយដ៏ឧត្តមជាងនោះ ១ វីរិយិន្ទ្រិយដោយអត្ថថាផ្គងឡើងរលាស់ចាកសេចក្តីខ្ជិលច្រអូស ១ រលាស់ចាកសេចក្តីក្តៅក្រហាយព្រោះការខ្ជិលច្រអូស ១ រលាស់ចាកពួកកិលេសដែលប្រព្រឹត្តទៅតាមសេចក្តីក្តៅក្រហាយព្រោះការខ្ជិលច្រអូសនោះ និងចាកពួកខន្ធ ១ រលាស់ចាកនិមិត្តទាំងពួងពួដ៏ខាងក្រៅ ១ រលាស់ចាកវីរិយិន្ទ្រិយមុនបង្អស់ព្រោះកិរិយាបាននូវវីរិយិន្ទ្រិយដ៏ឧត្តមជាងនោះ ១ សតិន្ទ្រិយដោយអត្ថថាប្រុងស្មារតីរលាស់ចាកសេចក្តីប្រមាទ ១ រលាស់ចាកសេចក្តីក្តៅក្រហាយព្រោះការប្រមាទ ១ រលាស់ចាកពួកកិលេសដែលប្រព្រឹត្តទៅតាមសេចក្តីក្តៅក្រ-ហាយព្រោះការប្រមាទនោះនិងចាកពួកខន្ធ ១ រលាស់ចាកនិមិត្តទាំងពួងពួ-ដ៏ខាងក្រៅ ១ រលាស់ចាកសតិន្ទ្រិយមុនបង្អស់ព្រោះកិរិយាបាននូវសតិន្ទ្រិយដ៏ឧត្តមជាងនោះ ១ សមាធិន្ទ្រិយដោយអត្ថថាមិនរាយមាយរលាស់ចាកឧទ្ធច្ចៈ ១ រលាស់ចាកសេចក្តីក្តៅក្រហាយព្រោះឧទ្ធច្ចៈ ១ រលាស់ចាកពួកកិលេសដែលប្រព្រឹត្តទៅតាមសេចក្តីក្តៅក្រហាយព្រោះឧទ្ធច្ចៈនោះ និងចាកពួកខន្ធ ១ រលាស់ចាកនិមិត្តទាំងពួងពួដ៏ខាងក្រៅ ១ រលាស់ចាកសមាធិន្ទ្រិយមុនបង្អស់

ព្រោះកិរិយាបាននូវសមាធិន្ទ្រិយដ៏ឧត្តមជាងនោះ ១ បញ្ញិន្ទ្រិយដោយអត្ថថាឃើញរលាស់ចាកអវិជ្ជា ១ រលាស់ចាកសេចក្តីក្តៅក្រហាយព្រោះអវិជ្ជា ១ រលាស់ចាកពួកកិលេស ដែលប្រព្រឹត្តទៅតាមសេចក្តីក្តៅក្រហាយព្រោះអវិជ្ជានោះនិងចាកពួកខន្ធ ១ រលាស់ចាកនិមិត្តទាំងពួងពួងដ៏ខាងក្រៅ ១ រលាស់ចាកបញ្ញិន្ទ្រិយមុនបង្អស់ ព្រោះកិរិយាបាននូវបញ្ញិន្ទ្រិយដ៏ឧត្តមជាងនោះ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចបឋមជ្ឈានរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងបុព្វភាគ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចទុតិយជ្ឈានរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងបឋមជ្ឈាន ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចតតិយជ្ឈានរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងទុតិយជ្ឈាន ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចចតុត្ថជ្ឈានរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងតតិយជ្ឈាន ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចអាកាសានញ្ចាយតនសមាបត្តិរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងចតុត្ថជ្ឈាន ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចវិញ្ញាណញ្ចាយតនសមាបត្តិរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអាកាសានញ្ចាយតនសមាបត្តិ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចអាកិញ្ចញ្ញាយតនសមាបត្តិរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងវិញ្ញាណញ្ចាយតនសមាបត្តិ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចនេវសញ្ញានាសញ្ញាយតនសមាបត្តិរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចអនិច្ចានុបស្សនារលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចទុក្ខានុបស្សនារលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអនិច្ចានុបស្សនា

១ ឥន្ទ្រិយទាំង ៥ ដោយអំណាចអនត្តានុបស្សនាវលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងទុក្ខានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចនិព្វិទានុបស្សនាវលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអនត្តានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចវិរាគានុបស្សនាវលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងនិព្វិទានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចនិរោធានុបស្សនាវលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងវិរាគានុ-បស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចបដិនិស្សគ្គានុបស្សនា វលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងនិរោធានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចខយានុបស្សនាវលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងបដិនិស្សគ្គានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចវយានុបស្សនាវលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងខយានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចវិបរិណាមានុបស្សនាវលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងវយានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចអនិមិត្តានុបស្សនាវលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងវិបរិណាមានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចអប្បណិហិតានុបស្សនា វលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអនិមិត្តានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចសុញ្ញតានុបស្សនាវលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអប្បណិហិតានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចអធិប្បញ្ញាធម្មវិបស្សនា វលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងសុញ្ញតានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចយថាភូតញ្ញាណទស្សនៈ វលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអធិប្បញ្ញាធម្មនុ-បស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចអាទីនវានុបស្សនាវលាស់ចាក

ឥន្ទ្រិយទាំង ៥ ក្នុងយថាភូតញ្ញាណទស្សនៈ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាច បដិសង្ខានុបស្សនារលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអាទីនវានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចវិវដ្ដនានុបស្សនារលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងបដិសង្ខានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចសោតាបត្តិមគ្គ រលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងវិវដ្ដនានុបស្សនា ១ ឥន្ទ្រិយទាំង ៥ ដោយ អំណាចសោតាបត្តិផលសមាបត្តិ រលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងសោតា បត្តិមគ្គ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចនៃសកទាគាមិមគ្គ រលាស់ចាក ឥន្ទ្រិយទាំង ៥ ក្នុងសោតាបត្តិផលសមាបត្តិ ១ ឥន្ទ្រិយទាំង ៥ ដោយ អំណាចនៃសកទាគាមិផលសមាបត្តិរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងសកទាគា មិមគ្គ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចនៃអនាគាមិមគ្គរលាស់ចាកឥន្ទ្រិយ ទាំង ៥ ក្នុងសកទាគាមិផលសមាបត្តិ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចនៃ អនាគាមិផលសមាបត្តិរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអនាគាមិមគ្គ ១ ឥន្ទ្រិយ ទាំង ៥ ដោយអំណាចនៃអរហត្តមគ្គរលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអនាគា-មិផលសមាបត្តិ ១ ឥន្ទ្រិយទាំង ៥ ដោយអំណាចនៃអរហត្តផលសមាបត្តិ រលាស់ចាកឥន្ទ្រិយទាំង ៥ ក្នុងអរហត្តមគ្គ ១ ឥន្ទ្រិយទាំង ៥ ក្នុងនេក្ខម្មៈ រលាស់ចាកកាមច្ឆន្ទៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងអព្យាបាទៈរលាស់ចាកព្យាបាទៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងអាលោកសញ្ញារលាស់ចាកថីនមិទ្ធៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងអវិក្ខេបៈរលាស់ចាកឧទ្ធច្ចៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងការកំណត់នូវធម៌ រលាស់ចាកវិចិកិច្ឆា ១ ឥន្ទ្រិយទាំង ៥ ក្នុងញាណរលាស់ចាកអវិជ្ជា ១

ឥន្ទ្រិយទាំង ៥ ក្នុងបាមោជ្ជៈ ( បីតិដែលមានកម្លាំងទន់ ) រលាស់ចាកអរតិ ( សេចក្តីមិនត្រេកអរ ) ១ ឥន្ទ្រិយទាំង ៥ ក្នុងបឋមជ្ឈានរលាស់ចាកពួកនីវរណៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងទុតិយជ្ឈានរលាស់ចាកវិតក្កៈនិងវិចារៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងតតិយជ្ឈានរលាស់ចាកបីតិ ១ ឥន្ទ្រិយទាំង ៥ ក្នុងចតុត្ថជ្ឈានរលាស់ចាកសុខនិងទុក្ខ ១ ឥន្ទ្រិយទាំង ៥ ក្នុងអាកាសានញ្ចាយតនសមាបត្តិរលាស់ចាករូបសញ្ញា បដិឃសញ្ញា និងនានត្តសញ្ញា ១ ឥន្ទ្រិយទាំង ៥ ក្នុងវិញ្ញាណញ្ចាយតនសមាបត្តិរលាស់ចាកអាកាសានញ្ចាយតនសញ្ញា ១ ឥន្ទ្រិយទាំង ៥ ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិរលាស់ចាកវិញ្ញាណញ្ចាយតនសញ្ញា ១ ឥន្ទ្រិយទាំង ៥ ក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិរលាស់ចាកអាកិញ្ចញ្ញាយតនសញ្ញា ១ ឥន្ទ្រិយទាំង ៥ ក្នុងអនិច្ចានុបស្សនារលាស់ចាកនិច្ចសញ្ញា ១ ឥន្ទ្រិយទាំង ៥ ក្នុងទុក្ខានុបស្សនារលាស់ចាកសុខសញ្ញា ១ ឥន្ទ្រិយទាំង ៥ ក្នុងអនត្តានុបស្សនារលាស់ចាកអត្តសញ្ញា ១ ឥន្ទ្រិយទាំង ៥ ក្នុងនិព្វិទានុបស្សនារលាស់ចាកនន្ទិ ១ ឥន្ទ្រិយទាំង ៥ ក្នុងវិរាគានុបស្សនារលាស់ចាករាគៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងនិរោធានុបស្សនារលាស់ចាកសមុទ័យ ១ ឥន្ទ្រិយទាំង ៥ ក្នុងបដិនិស្សគ្គានុបស្សនារលាស់ចាកអាទានៈ ( សេចក្តីប្រកាន់ ) ១ ឥន្ទ្រិយទាំង ៥ ក្នុងខយានុបស្សនារលាស់ចាកឃនសញ្ញា ( សេចក្តីសម្គាល់ថារឹងប៉ឹង ) ១ ឥន្ទ្រិយទាំង ៥ ក្នុងវយានុបស្សនារលាស់ចាកអាយុហនធម៌ ( ការប្រមូលមក ) ១ ឥន្ទ្រិយទាំង ៥ ក្នុងវិបរិណាមានុបស្សនារលាស់ចាកធុវសញ្ញា ( សេចក្តីសម្គាល់

ជាទៀង ) ១ ឥន្ទ្រិយទាំង ៥ ក្នុងអនិមិត្តានុបស្សនារលាស់ចាកនិមិត្ត ១ ឥន្ទ្រិយទាំង ៥ ក្នុងអប្បណិហិតានុបស្សនា រលាស់ចាកបណិធិ ( ការតម្កល់ ) ១ ឥន្ទ្រិយទាំង ៥ ក្នុងសុញ្ញតានុបស្សនា រលាស់ចាកអភិនិវេសៈ ( សេចក្ដីប្រកាន់ស្អិត ) ១ ឥន្ទ្រិយទាំង ៥ ក្នុងអធិប្បញ្ញាធម្មវិបស្សនា រលាស់ចាកសារាទានាភិនិវេសៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងយថាភូតញ្ញាណទស្សនៈរលាស់ចាកសម្មោហាភិនិវេសៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងអាទីនវានុបស្សនារលាស់ចាកអាលយាភិនិវេសៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងបដិសង្ខានុបស្សនារលាស់ចាកអប្បដិសង្ខា ( ការមិនត្រួតត្រា ) ១ ឥន្ទ្រិយទាំង ៥ ក្នុងវិវដ្ដនានុបស្សនារលាស់ចាកសញ្ញោគាភិនិវេសៈ ១ ឥន្ទ្រិយទាំង ៥ ក្នុងសោតាបត្តិមគ្គរលាស់ចាកពួកកិលេសដែលតាំងនៅក្នុងចិត្តមួយជាមួយនឹងទិដ្ឋិ ១ ឥន្ទ្រិយទាំង ៥ ក្នុងសកទាគាមិមគ្គរលាស់ចាកពួកកិលេសដ៏គ្រោតគ្រាត ១ ឥន្ទ្រិយទាំង ៥ ក្នុងអនាគាមិមគ្គ រលាស់ចាកពួកកិលេសដ៏ល្អិត ១ ឥន្ទ្រិយទាំង ៥ ក្នុងអរហត្តមគ្គ រលាស់ចាកពួកកិលេសទាំងពួង ១ ឥន្ទ្រិយទាំង ៥ ក្នុងធម៌នោះៗរបស់ព្រះខីណាស្រពទាំងអស់រលាស់ហើយផង រលាស់ល្អហើយ ស្ងប់រម្ងាប់ហើយ ស្ងប់រម្ងាប់ល្អហើយ នេះឯងការរលាស់ចេញរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ១៨០ នេះឯងបុគ្គលដឹងច្បាស់នូវការរលាស់ចេញរបស់ឥន្ទ្រិយទាំង ៥ ដោយអាការ ១៨០ ។

**ចប់ ភាណវារៈ ។**

# សារត្ថនិធាន

[ ១៨៤ ] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ឥន្ទ្រិយ ៥ តើដូចម្តេចខ្លះ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។

ម្នាលភិក្ខុទាំងឡាយ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញក្នុងធម៌ណា សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ នុ៎ះ ។

ម្នាលភិក្ខុទាំងឡាយ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញក្នុងធម៌ណា វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញក្នុងសម្មប្បធានទាំង ៤ នុ៎ះ ។

ម្នាលភិក្ខុទាំងឡាយ សតិន្ទ្រិយ បុគ្គលគប្បីឃើញក្នុងធម៌ណា សតិន្ទ្រិយ បុគ្គលគប្បីឃើញក្នុងសតិប្បដ្ឋានទាំង ៤ នុ៎ះ ។

ម្នាលភិក្ខុទាំងឡាយ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញក្នុងធម៌ណា សមាធិន្ទ្រិយ បុគ្គលគប្បីឃើញក្នុងឈានទាំង ៤ នុ៎ះ ។

ម្នាលភិក្ខុទាំងឡាយ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញក្នុងធម៌ណា បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញក្នុងអរិយសច្ចទាំង ៤ នុ៎ះ ។

[ ១៨៥ ] ក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការប៉ុន្មាន ក្នុងសម្មប្បធានទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការប៉ុន្មាន ក្នុងសតិប្បដ្ឋានទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃសតិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការប៉ុន្មាន ក្នុងឈានទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការប៉ុន្មានក្នុងអរិយសច្ចទាំង ៤

ឥន្ទ្រិយ ៥ ដោយអំណាចនៃបញ្ញិន្ទ្រិយបុគ្គលគប្បីឃើញដោយអាការប៉ុន្មាន ។ ក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ក្នុងសម្មប្បធានទាំង៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ក្នុងសតិប្បដ្ឋានទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃសតិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ក្នុងឈានទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ក្នុងអរិយសច្ចទាំង៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ។

[ ១៤៦ ] ក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ដូចម្តេចខ្លះ ។ ក្នុងអង្គនៃសោតាបត្តិមគ្គ គឺសប្បុរិសសំសេវៈ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញដោយអត្ថថា មានការជឿស៊ប់ជាអធិបតី ១ ដោយអំណាចសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញដោយអត្ថថា ផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញដោយអត្ថថា ប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញដោយអត្ថថា មិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ ក្នុងអង្គនៃសោតាបត្តិមគ្គ គឺសទ្ធម្មស្សវនៈ ក្នុងអង្គនៃសោតាបត្តិមគ្គ គឺយោនិសោមនសិការៈ ក្នុងអង្គនៃសោតាបត្តិមគ្គ គឺធម្មានុធម្មប្បដិបត្តិ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញដោយអត្ថថាមានការជឿស៊ប់ជាអធិបតី ១ ដោយអំណាចនៃសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញដោយអត្ថថាផ្គងឡើង ១ សតិ-

ន្ទ្រិយ បុគ្គលគប្បីឃើញដោយអត្ថថាប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ ក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ នេះឯង ។

[ ១៤៧ ] ក្នុងសម្មប្បធានទាំង ៤ តើឥន្ទ្រិយ ៥ ដោយអំណាចនៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ដូចម្តេចខ្លះ ។ ក្នុងសម្មប្បធាន ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមកដែលមិនទាន់កើតមិនឲ្យកើតឡើង វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការផ្គងឡើងជាអធិបតី ១ ដោយអំណាចនៃវីរិយិន្ទ្រិយ សតិន្ទ្រិយបុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ ក្នុងសម្មប្បធានដើម្បីលះពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ។បេ។ ក្នុងសម្មប្បធាន ដើម្បីញុំាងពួកកុសលធម៌ដែលមិនទាន់កើតឲ្យកើតឡើង ។បេ។ ក្នុងសម្មប្បធាន ដើម្បីតាំងនៅ មិនវិនាស ចម្រើនក្រៃលែង ទូលំទូលាយ ចម្រើនពេញបរិបូណ៌នៃកុសលធម៌ដែលកើតហើយ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមានការផ្គងជាអធិបតី ១ ដោយអំណាចនៃវីរិយិន្ទ្រិយ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ បញ្ញិន្ទ្រិយបុគ្គលគប្បីឃើញ ដោយអត្ថថាឃើញ ១

សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជឿស៊ប់ ១ ក្នុងសម្មប្បធាន ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ នេះឯង ។

[ ១៤៨ ] ក្នុងសតិប្បដ្ឋានទាំង ៤ តើឥន្ទ្រិយ ៥ ដោយអំណាចនៃសតិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ដូចម្ដេចខ្លះ ។ ក្នុងកាយេកាយានុបស្សនាសតិប្បដ្ឋាន សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការប្រុងប្រយ័ត្នជាអធិបតី ១ ដោយអំណាចនៃសតិន្ទ្រិយ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ ក្នុងវេទនាសុវេទនានុបស្សនាសតិប្បដ្ឋាន ។បេ។ ក្នុងចិត្តេចិត្តានុបស្សនាសតិប្បដ្ឋាន ក្នុងធម្មេសុធម្មានុបស្សនាសតិប្បដ្ឋាន សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការប្រុងប្រយ័ត្នជាអធិបតី ១ ដោយអំណាចសតិន្ទ្រិយ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ ក្នុងសតិប្បដ្ឋាន ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ នេះឯង ។

[ ១៤៩ ] ក្នុងឈានទាំង ៤ តើឥន្ទ្រិយ ៥ ដោយអំណាចនៃសមាធិ-

ន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ដូចម្តេចខ្លះ ។ ក្នុងបឋមជ្ឈាន សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមានការមិនរាយមាយជាអធិបតី ១ ដោយអំណាចនៃសមាធិន្ទ្រិយ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាប្រុងប្រយ័ត្ន ១ ក្នុងទុតិយជ្ឈាន ។បេ។ ក្នុងតតិយជ្ឈាន ក្នុងចតុត្ថជ្ឈាន សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការមិនរាយមាយជាអធិបតី ១ ដោយអំណាចនៃសមាធិន្ទ្រិយ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ ក្នុងឈានទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ នេះឯង ។

[ ១៥០ ] ក្នុងអរិយសច្ចទាំង ៤ តើឥន្ទ្រិយ ៥ ដោយអំណាចនៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ដូចម្តេចខ្លះ ។ ក្នុងទុក្ខអរិយសច្ច បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមានការឃើញជាអធិបតី ១ ដោយអំណាចនៃបញ្ញិន្ទ្រិយ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គល

គប្បីឃើញ ដោយអត្ថថាមិនរាយមាយ ១ ក្នុងទុក្ខសមុទយអរិយសច្ច។បេ។ ក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមានការឃើញជាអធិបតី ១ ដោយអំណាចនៃបញ្ញិន្ទ្រិយ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមិនរាយមាយ ១ ក្នុងអរិយសច្ចទាំង ៤ ឥន្ទ្រិយ ៥ ដោយអំណាចនៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ នេះឯង ។

[ ១៥១ ] ក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ តើចរិយា ( ការប្រព្រឹត្តិ ) នៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការប៉ុន្មាន ក្នុងសម្មប្បធានទាំង ៤ ។បេ។ ក្នុងសតិប្បដ្ឋានទាំង ៤ ។បេ។ ក្នុងឈានទាំង ៤ ។បេ។ ក្នុងអរិយសច្ចទាំង ៤ តើចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការប៉ុន្មាន ។ ក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ ចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ ក្នុងសម្មប្បធានទាំង ៤ ។បេ។ ក្នុងសតិប្បដ្ឋានទាំង ៤ ក្នុងឈានទាំង ៤ ក្នុងអរិយសច្ចទាំង ៤ ចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ ។

[ ១៥២ ] ក្នុងអង្គនៃសោតាបត្តិមគ្គ ៤ តើចរិយានៃឥន្ទ្រិយទាំង ៥

ដោយអំណាចនៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ ដូចម្តេចខ្លះ ។ ក្នុងអង្គនៃសោតាបត្តិមគ្គ គឺសប្បុរិសសំសេវៈ ចរិយានៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមានការជឿស៊ប់ជាអធិបតី ១ ដោយអំណាចនៃសទ្ធិន្ទ្រិយ ចរិយានៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាផ្គងឡើង ១ ចរិយានៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាប្រុងប្រយ័ត្ន ១ ចរិយានៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ ចរិយានៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ ក្នុងអង្គនៃសោតាបត្តិមគ្គ គឺសទ្ធម្មស្សវនៈ ។បេ។ ក្នុងអង្គនៃសោតាបត្តិមគ្គ គឺយោនិសោមនសិការៈ ក្នុងអង្គនៃសោតាបត្តិមគ្គ គឺធម្មានុធម្មប្បដិបត្តិ ចរិយានៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការជឿស៊ប់ជាអធិបតី ១ ដោយអំណាចនៃសទ្ធិន្ទ្រិយ ចរិយានៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ ចរិយានៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ ចរិយានៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមិនរាយមាយ ១ ចរិយានៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា យល់ឃើញ ១ ក្នុងអង្គនៃសោតាបត្តិមគ្គទាំង ៤ ចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ នេះឯង ។

[ ១៥៣ ] ក្នុងសម្មប្បធានទាំង ៤ តើចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ ដូចម្តេចខ្លះ ។ ក្នុងសម្មប្បធាន ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតមិន

ឲ្យកើតឡើង ចរិយានៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការផ្គងឡើងជាអធិបតី ១ ដោយអំណាចនៃវីរិយិន្ទ្រិយ ចរិយានៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាប្រុងប្រយ័ត្ន ១ ។បេ។ ចរិយានៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ ក្នុងសម្មប្បធាន ដើម្បីលះបង់នូវពួកអកុសលធម៌ ដ៏លាមកដែលកើតឡើងហើយ ។បេ។ ក្នុងសម្មប្បធាន ដើម្បីញុំាងពួកកុសលធម៌ដែលមិនទាន់កើតឲ្យកើតឡើង ។បេ។ ក្នុងសម្មប្បធាន ដើម្បីតាំងនៅ មិនឲ្យវិនាស ចម្រើន ក្រៃលែង ធំទូលាយ ចម្រើនពេញ-បរិបូណ៌នៃកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ចរិយានៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការផ្គងឡើងជាអធិបតី ១ ដោយអំណាចនៃវីរិយិន្ទ្រិយ ចរិយានៃសតិន្ទ្រិយ ។បេ។ ចរិយានៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ ក្នុងសម្មប្បធានទាំង ៤ ចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ នេះឯង ។

[ ១៥៤ ] ក្នុងសតិប្បដ្ឋាន ៤ តើចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំ-ណាចនៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ ដូចម្តេចខ្លះ ។ ក្នុងកាយេកាយានុបស្សនាសតិប្បដ្ឋាន ចរិយានៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការប្រុងប្រយ័ត្នជាអធិបតី ១ ដោយអំណាចនៃសតិន្ទ្រិយ ចរិយានៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ ចរិយានៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ ចរិយានៃ

សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជឿស៊ប់ ១ ចរិយានៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ ក្នុងវេទនាសុវេទនានុបស្សនាសតិប្បដ្ឋាន ។បេ។ ក្នុងចិត្តេចិត្តានុបស្សនាសតិប្បដ្ឋាន ។បេ។ ក្នុងធម្មេសុធម្មានុបស្សនាសតិប្បដ្ឋាន ចរិយានៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការប្រុងប្រយ័ត្នជាអធិបតី ១ ដោយអំណាចនៃសតិន្ទ្រិយ ។បេ។ ចរិយានៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ ក្នុងសតិប្បដ្ឋានទាំង ៤ ចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃសតិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ នេះឯង ។

[ ១៥៥ ] ក្នុងឈានទាំង ៤ តើចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញដោយអាការ ២០ ដូចម្តេចខ្លះ ។ ក្នុងបឋមជ្ឈាន ចរិយានៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការមិនរាយមាយជាអធិបតី ១ ដោយអំណាចនៃសមាធិន្ទ្រិយ ចរិយានៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ ចរិយានៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជឿស៊ប់ ១ ចរិយានៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ ចរិយានៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ ក្នុងទុតិយជ្ឈាន ។បេ។ ក្នុងតតិយជ្ឈាន ។បេ។ ក្នុងចតុត្ថជ្ឈាន ចរិយានៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការមិនរាយមាយជាអធិបតី ១ ដោយអំណាចនៃសមាធិន្ទ្រិយ ។បេ។ ចរិយានៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាប្រុងប្រយ័ត្ន ១ ក្នុងឈានទាំង

៤ ចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ នេះឯង ។

[ ១៥៦ ] ក្នុងអរិយសច្ច ៤ តើចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ ដូចម្ដេចខ្លះ ។ ក្នុងទុក្ខ-អរិយសច្ច ចរិយានៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការឃើញជាអធិបតី ១ ដោយអំណាចនៃបញ្ញិន្ទ្រិយ ចរិយានៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ ចរិយានៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាផ្គងឡើង ១ ចរិយានៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាប្រុងប្រយ័ត្ន ១ ចរិយានៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមិនរាយមាយ ១ ក្នុងទុក្ខសមុទយអរិយសច្ច ។បេ។ ក្នុងទុក្ខនិរោធអរិយសច្ច ក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ចរិយានៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមានការឃើញជាអធិបតី ១ ដោយអំណាចនៃបញ្ញិន្ទ្រិយ ចរិយានៃសទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ ចរិយានៃវីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាផ្គងឡើង ១ ចរិយានៃសតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាប្រុងប្រយ័ត្ន ១ ចរិយានៃសមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមិនរាយាមាយ ១ ក្នុងអរិយសច្ចទាំង ២ ចរិយានៃឥន្ទ្រិយទាំង ៥ ដោយអំណាចនៃបញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអាការ ២០ នេះឯង ។

[ ១៥៧ ] ការប្រព្រឹត្តិក្ដី ការនៅក្ដី ឈ្មោះថា ការត្រាស់ដឹងតាម ឈ្មោះ

ថាការចាក់ធ្លុះ ពួកវិញ្ញូជន ជាសព្រហ្មចារី គប្បីកំណត់នូវបុគ្គល កាល ប្រព្រឹត្តយ៉ាងណា កាលនៅយ៉ាងណា ក្នុងឋានៈទាំងឡាយដ៏ជ្រាលជ្រៅថា លោកមានអាយុនេះ ពិតជាសម្រេចហើយ ឬនឹងសម្រេច ។

ពាក្យថា ការប្រព្រឹត្តិ បានដល់ ការប្រព្រឹត្ត គឺចរិយា ៨ គឺឥរិយា-បថចរិយា ១ អាយតនចរិយា ១ សតិចរិយា ១ សមាធិចរិយា ១ ញាណ-ចរិយា ១ មគ្គចរិយា ១ បត្តិចរិយា ១ លោកត្ថចរិយា ១ ។

ចរិយា ក្នុងឥរិយាបថទាំង ៤ ឈ្មោះថា ឥរិយាបថចរិយា ។ ចរិយា ក្នុងអាយតនខាងក្នុងនិងខាងក្រៅ ៦ ឈ្មោះថាអាយតនចរិយា ។ ចរិយាក្នុង សតិប្បដ្ឋានទាំង ៤ ឈ្មោះថាសតិចរិយា ។ ចរិយាក្នុងឈានទាំង ៤ ឈ្មោះ ថាសមាធិចរិយា ។ ចរិយាក្នុងអរិយសច្ចទាំង ៤ ឈ្មោះថាញាណចរិយា ។ ចរិយាក្នុងអរិយមគ្គទាំង ៤ ឈ្មោះថា មគ្គចរិយា ។ ចរិយាក្នុងសាមញ្ញ-ផលទាំង ៤ ឈ្មោះថាបត្តិចរិយា ។ ចរិយាក្នុងព្រះតថាគតជាអរហន្តសម្មា-សម្ពុទ្ធទាំងឡាយ ក្នុងព្រះបច្ចេកពុទ្ធទាំងឡាយ ដោយចំណែកខ្លះ ក្នុងសាវក ទាំងឡាយ ដោយចំណែកខ្លះ ឈ្មោះថាលោកត្ថចរិយា ។ ឥរិយាបថចរិយា របស់បុគ្គលទាំងឡាយដែលបរិបូរណ៍ដោយឥរិយាបថស្រគត់ស្រគំ អាយតន ចរិយារបស់បុគ្គលទាំងឡាយ ដែលមានទ្វារគ្រប់គ្រងហើយ ក្នុងឥន្ទ្រិយទាំង ឡាយ សតិចរិយារបស់បុគ្គលទាំងឡាយ ដែលនៅដោយសេចក្តីមិនប្រមាទ សមាធិចរិយារបស់បុគ្គលទាំងឡាយដែលប្រកបរឿយ ៗ នូវអធិចិត្ត ញាណ ចរិយារបស់បុគ្គលទាំងឡាយ ដែលបរិបូរណ៍ដោយប្រាជ្ញា មគ្គចរិយារបស់

បុគ្គលទាំងឡាយដែលប្រតិបត្តិដោយប្រពៃ បត្តិចរិយារបស់បុគ្គលទាំងឡាយដែលមានផលសម្រេចហើយ លោកត្ថចរិយារបស់ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធទាំងឡាយ របស់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ដោយចំណែកខ្លះ របស់សាវកទាំងឡាយ ដោយចំណែកខ្លះ នេះឈ្មោះថា ចរិយា ៨ ។

ចរិយា ៨ ដទៃទៀត គឺបុគ្គលកាលចុះចិត្តស៊ប់ ឈ្មោះថាប្រព្រឹត្តដោយសទ្ធា ១ កាលផ្គងឡើង ឈ្មោះថាប្រព្រឹត្តដោយវីរិយៈ ១ កាលប្រុងប្រយ័ត្ន ឈ្មោះថា ប្រព្រឹត្តដោយសតិ ១ កាលធ្វើមិនឲ្យរាយមាយ ឈ្មោះថាប្រព្រឹត្តដោយសមាធិ ១ កាលដឹងច្បាស់ ឈ្មោះថាប្រព្រឹត្តដោយប្រាជ្ញា ១ កាលដឹងផ្សេងៗ ឈ្មោះថាប្រព្រឹត្តដោយវិញ្ញាណ ១ បុគ្គលប្រតិបត្តិយ៉ាងនេះរមែងបាននូវគុណវិសេស ហេតុនោះ ឈ្មោះថា ប្រព្រឹត្តដោយវិសេសចរិយា ១ កុសលធម៌ទាំងឡាយ របស់បុគ្គលដែលប្រតិបត្តិយ៉ាងនេះ រមែងប្រព្រឹត្តក្បៀវក្បា ហេតុនោះ ឈ្មោះថា ប្រព្រឹត្តដោយអាយតនៈចរិយា ១ នេះឈ្មោះថាចរិយា ៨ ។

ចរិយា ៨ ដទៃទៀត គឺ ទស្សនចរិយារបស់សម្មាទិដ្ឋិ ១ អភិរោបនចរិយារបស់សម្មាសង្កប្បៈ ១ បរិគ្គហចរិយារបស់សម្មាវាចា ១ សមុដ្ឋានចរិយារបស់សម្មាកម្មន្តៈ ១ វោទានចរិយារបស់សម្មាអាជីវៈ ១ បគ្គហចរិយារបស់សម្មាវាយាមៈ ១ ឧបដ្ឋានចរិយារបស់សម្មាសតិ ១ អវិក្ខេបចរិយារបស់សម្មាសមាធិ ១ នេះឈ្មោះថា ចរិយា ៨ ។

[ ១៥៨ ] ពាក្យថា ការនៅ សេចក្តីថា បុគ្គលកាលជឿស៊ប់ ឈ្មោះ

ថា នៅដោយសទ្ធា កាលផ្គងឡើង ឈ្មោះថា នៅដោយវីរិយៈ កាលប្រុងប្រយ័ត្ន ឈ្មោះថា នៅដោយសតិ កាលធ្វើមិនឲ្យរាយមាយ ឈ្មោះថា នៅដោយសមាធិ កាលដឹងច្បាស់ ឈ្មោះថា នៅដោយប្រាជ្ញា ។

ពាក្យថា ការត្រាស់ដឹងតាម សេចក្តីថា អត្ថថាជឿស៊ប់នៃសទ្ធិន្ទ្រិយ ឈ្មោះថា ការត្រាស់ដឹងតាម អត្ថថាផ្គងឡើងនៃវីរិយិន្ទ្រិយ ឈ្មោះថា ការត្រាស់ដឹងតាម អត្ថថាប្រុងប្រយ័ត្ននៃសតិន្ទ្រិយ ឈ្មោះថា ការត្រាស់ដឹងតាម អត្ថថា មិនរាយមាយនៃសមាធិន្ទ្រិយ ឈ្មោះថា ការត្រាស់ដឹងតាម អត្ថថា ឃើញនៃបញ្ញិន្ទ្រិយ ឈ្មោះថា ការត្រាស់ដឹងតាម ។

ពាក្យថា ការចាក់ធ្លុះ សេចក្តីថា អត្ថថាជឿស៊ប់នៃសទ្ធិន្ទ្រិយ ឈ្មោះថា ការចាក់ធ្លុះ អត្ថថាផ្គងឡើងនៃវីរិយិន្ទ្រិយ ឈ្មោះថា ការចាក់ធ្លុះ អត្ថថាប្រុងប្រយ័ត្ននៃសតិន្ទ្រិយ ឈ្មោះថា ការចាក់ធ្លុះ អត្ថថាមិនរាយមាយនៃសមាធិន្ទ្រិយ ឈ្មោះថាការចាក់ធ្លុះ អត្ថថាឃើញនៃបញ្ញិន្ទ្រិយ ឈ្មោះថាការចាក់ធ្លុះ ។

ពាក្យថា កាលប្រព្រឹត្តយ៉ាងណា គឺបុគ្គលកាលប្រព្រឹត្តដោយសទ្ធាយ៉ាងនេះ កាលប្រព្រឹត្តដោយវីរិយៈយ៉ាងនេះ កាលប្រព្រឹត្តដោយសតិយ៉ាងនេះ កាលប្រព្រឹត្តដោយសមាធិយ៉ាងនេះ កាលប្រព្រឹត្តដោយប្រាជ្ញាយ៉ាងនេះ ។

ពាក្យថា កាលនៅយ៉ាងណា គឺកាលនៅដោយសទ្ធាយ៉ាងនេះ កាលនៅដោយវីរិយៈយ៉ាងនេះ កាលនៅដោយសតិយ៉ាងនេះ កាលនៅដោយ

សមាធិយ៉ាងនេះ កាលនៅដោយប្រាជ្ញាយ៉ាងនេះ ។

ពួកជនអ្នកដឹង អ្នកសម្តែង អ្នកមានយោបល់ អ្នកប្រាជ្ញ អ្នកបរិបូរណ៍ដោយប្រាជ្ញា ឈ្មោះថា វិញ្ញូជន ។

បុគ្គលមានការងារតែមួយ មានឧទ្ទេសតែមួយ មានការសិក្សាស្មើគ្នា ឈ្មោះថា សព្រហ្មចារី ។

ពាក្យថា ក្នុងឋានទាំងឡាយដ៏ជ្រាលជ្រៅ សេចក្តីថា ឈាន វិមោក្ខ សមាធិ សមាបត្តិ មគ្គ ផល អភិញ្ញា និងបដិសម្ភិទា លោកហៅថា ឋានទាំងឡាយដ៏ជ្រាលជ្រៅ ។

ពាក្យថា គប្បីកំណត់ គឺគប្បីជឿ គប្បីចុះចិត្តស៊ប់ ។

ពាក្យថា ពិតជា នេះជាពាក្យពោលដាច់ខាត នេះជាពាក្យពោលដោយមិនមានសេចក្តីសង្ស័យ នេះជាពាក្យពោលដោយមិនមានសេចក្តីស្ទាក់ស្ទើរ នេះជាពាក្យមិនមានពីរ នេះជាពាក្យមិនបែកជាពីរ នេះជាពាក្យសម្រាប់ស្រោចស្រង់ នេះជាពាក្យមិនខុស ពាក្យថា ពិតជា នេះ ជាពាក្យកំណត់ដាច់ស្រេច ។

ពាក្យថា លោកមានអាយុ នេះ ជាពាក្យពោលដោយសេចក្តីស្រឡាញ់ នេះជាពាក្យពោលដោយសេចក្តីគោរព ពាក្យថា លោកមានអាយុ នេះ ជានាមរបស់បុគ្គលអ្នកដែលមានគេគោរពក្រោតក្រែង ។

ពាក្យថា សម្រេចហើយ គឺត្រាស់ដឹងហើយ ។ ពាក្យថា នឹងសម្រេច គឺនឹងត្រាស់ដឹង ។

**ចប់ បរិបុណ្ណនិទាន ។**

[ ១៥៩ ] ម្នាលភិក្ខុទាំងឡាយ ឥន្ទ្រិយនេះមាន ៥ ឥន្ទ្រិយ ៥ តើដូចម្តេចខ្លះ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ម្នាលភិក្ខុទាំងឡាយ នេះឯងឥន្ទ្រិយ ៥ ។

ឥន្ទ្រិយទាំង ៥ នេះ បុគ្គលគប្បីឃើញដោយអាការៈប៉ុន្មាន ។ ឥន្ទ្រិយទាំង ៥ នេះ បុគ្គលគប្បីឃើញដោយអាការ ៦ ។ ឥន្ទ្រិយទាំង ៥ បុគ្គលគប្បីឃើញ ដោយអត្ថថាដូចម្តេច ។ ឥន្ទ្រិយទាំង ៥ បុគ្គលគប្បីឃើញ ដោយអត្ថថា ជាអធិបតី ដោយអត្ថថា ជម្រះក្នុងខាងដើម ដោយអត្ថថា ក្រៃលែង ដោយអត្ថថា អធិដ្ឋាន ដោយអត្ថថា ការគ្របសង្កត់ ដោយអត្ថថា តម្កល់ស៊ប់ ។

[ ១៦០ ] ឥន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជាអធិបតី តើដូចម្តេចខ្លះ ។ កាលបុគ្គលលះបង់សេចក្តីមិនជឿ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការជឿស៊ប់ជាអធិបតី ១ ដោយអំណាចនៃសទ្ធិន្ទ្រិយ វីរិ-យិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ កាលបុគ្គលលះបង់នូវកោសជ្ជៈ ( សេចក្តីខ្ជិល ) វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការផ្គងឡើងជាអធិបតី ១ ដោយអំណាចនៃវីរិយិន្ទ្រិយ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ បញ្ញិន្ទ្រិយ

បុគ្គលគប្បីឃើញ ដោយអត្ថថាឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ កាលបុគ្គលលះបង់នូវបមាទៈ ( សេចក្តីធ្វេសប្រហែស ) សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមានការប្រុងប្រយ័ត្នជាអធិបតី ១ ដោយអំណាចនៃសតិន្ទ្រិយ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ កាលបុគ្គលលះបង់នូវឧទ្ធច្ចៈ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការមិនរាយមាយជាអធិបតី ១ ដោយអំណាចនៃសមាធិន្ទ្រិយ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ កាលបុគ្គលលះបង់នូវអវិជ្ជា បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការឃើញជាអធិបតី ១ ដោយអំណាចនៃបញ្ញិន្ទ្រិយ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ កាលបុគ្គលលះបង់នូវកាមច្ឆន្ទៈ សទ្ធិន្ទ្រិយ ដោយអំណាចនៃនេក្ខម្មៈ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការជឿស៊ប់ជាអធិបតី ១ ដោយអំណាចនៃសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ

បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ កាលបុគ្គលលះបង់នូវកាមច្ឆន្ទៈ វីរិយិន្ទ្រិយ ដោយអំណាចនៃនេក្ខម្មៈ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការផ្គងឡើងជាអធិបតី ១ ដោយអំណាចនៃវីរិយិន្ទ្រិយ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ កាលបុគ្គលលះបង់នូវកាមច្ឆន្ទៈ សតិន្ទ្រិយ ដោយអំណាចនៃនេក្ខម្មៈ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការប្រុងប្រយ័ត្នជាអធិបតី ១ ដោយអំណាចនៃសតិន្ទ្រិយ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាមិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ កាលបុគ្គលលះបង់កាមច្ឆន្ទៈ សមាធិន្ទ្រិយ ដោយអំណាចនៃនេក្ខម្មៈ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការមិនរាយមាយជាអធិបតី ១ ដោយអំណាចនៃសមាធិន្ទ្រិយ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា

ប្រុងប្រយ័ត្ន ១ កាលបុគ្គលលះបង់កាមច្ឆន្ទៈ បញ្ញិន្ទ្រិយ ដោយអំណាចនៃនេក្ខម្មៈ បុគ្គលគប្បីឃើញ ដោយអត្ថថាមានការឃើញជាអធិបតី ១ ដោយអំណាចនៃបញ្ញិន្ទ្រិយ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ កាលបុគ្គលលះបង់ព្យាបាទ សទ្ធិន្ទ្រិយ ដោយអំណាចនៃព្យាបាទ ។បេ។ កាលបុគ្គលលះបង់ថីនមិទ្ធៈ សទ្ធិន្ទ្រិយ ដោយអំណាចនៃអលោកសញ្ញា ។បេ។ កាលបុគ្គលលះបង់កិលេសទាំងពួង សទ្ធិ-ន្ទ្រិយ ដោយអំណាចនៃអរហត្តមគ្គ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការជឿស៊ប់ជាអធិបតី ១ ដោយអំណាចនៃសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ សតិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថាប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ បញ្ញិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឃើញ ១ ។បេ។ កាលបុគ្គលលះបង់នូវកិលេសទាំងពួង បញ្ញិន្ទ្រិយ ដោយអំណាចនៃអរហត្តមគ្គ បុគ្គលគប្បីឃើញ ដោយអត្ថថា មានការឃើញជាអធិបតី ១ ដោយអំណាចនៃបញ្ញិន្ទ្រិយ សទ្ធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជឿស៊ប់ ១ វីរិយិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ផ្គងឡើង ១ សតិ-ន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា ប្រុងប្រយ័ត្ន ១ សមាធិន្ទ្រិយ បុគ្គលគប្បីឃើញ ដោយអត្ថថា មិនរាយមាយ ១ ឥន្ទ្រិយទាំងឡាយ បុគ្គល គប្បី

ឃើញ ដោយអត្ថថា ជាអធិបតី យ៉ាងនេះឯង ។

[ ១៦១ ] ឥន្ទ្រិយទាំងឡាយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជម្រះក្នុងខាងដើម តើដូចម្តេច ។ សទ្ធិន្ទ្រិយ ដោយអត្ថថា ជឿស៊ប់ ចាត់ជាសីលវិសុទ្ធិ ដោយអត្ថថារាំងនូវសេចក្តីមិនជឿ ឈ្មោះថា ជាគ្រឿងជម្រះក្នុងខាងដើមនៃសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ ដោយអត្ថថា ផ្គងឡើង ចាត់ជាសីលវិសុទ្ធិ ដោយអត្ថថា រាំងនូវសេចក្តីខ្ជិល ឈ្មោះថា ជាគ្រឿងជម្រះក្នុងខាងដើមនៃវីរិយិន្ទ្រិយ សតិន្ទ្រិយ ដោយអត្ថថាប្រុងប្រយ័ត្ន ចាត់ជាសីលវិសុទ្ធិ ដោយអត្ថថា រាំងនូវបមាទៈ ឈ្មោះថា ជាគ្រឿងជម្រះក្នុងខាងដើមនៃសតិន្ទ្រិយ សមាធិន្ទ្រិយ ដោយអត្ថថា មិនរាយមាយ ចាត់ជាសីលវិសុទ្ធិ ដោយអត្ថថា រាំងនូវឧទ្ធច្ចៈ ឈ្មោះថា ជាគ្រឿងជម្រះក្នុងខាងដើមនៃសមាធិន្ទ្រិយ បញ្ញិ-ន្ទ្រិយដោយអត្ថថា ឃើញ ចាត់ជាសីលវិសុទ្ធិដោយអត្ថរាំងនូវអវិជ្ជា ឈ្មោះថាជាគ្រឿងជម្រះក្នុងខាងដើមនៃបញ្ញិន្ទ្រិយ ឥន្ទ្រិយទាំង ៥ ក្នុងនេក្ខម្មៈ ចាត់ជាសីលវិសុទ្ធិ ដោយអត្ថថារាំងនូវកាមច្ឆន្ទៈ ឈ្មោះថា ជាគ្រឿងជម្រះ ក្នុងខាងដើមនៃឥន្ទ្រិយទាំង ៥ ឥន្ទ្រិយទាំង ៥ ក្នុងអព្យាបាទ ចាត់ជាសីលវិសុទ្ធិ ដោយអត្ថថា រាំងនូវព្យាបាទ ឈ្មោះថា ជាគ្រឿងជម្រះក្នុងខាងដើមនៃឥន្ទ្រិយទាំង ៥ ។បេ។ ឥន្ទ្រិយទាំង ៥ ក្នុងអរហត្តមគ្គ ចាត់ជាសីលវិសុទ្ធិ ដោយអត្ថថា រាំងនូវកិលេសទាំងពួង ឈ្មោះថា ជាគ្រឿងជម្រះក្នុងខាងដើមនៃឥន្ទ្រិយទាំង ៥ ឥន្ទ្រិយទាំងឡាយ បុគ្គលគប្បីឃើញ ដោយអត្ថថា ជាគ្រឿងជម្រះក្នុងខាងដើម យ៉ាងនេះឯង ។

[ ១៦២ ] ឥន្ទ្រិយទាំងឡាយ បុគ្គលគប្បីឃើញ ដោយអត្ថថា ក្រៃលែង តើដូចម្តេច ។ ឆន្ទៈកើតឡើង ដើម្បីអប់រំនូវសទ្ធិន្ទ្រិយ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវអស្សទ្ធិយៈ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវសេចក្តីក្តៅក្រហាយព្រោះសេចក្តីមិនជឿ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេសទាំងឡាយដែលតាំងនៅក្នុងទីមួយជាមួយនឹងទិដ្ឋិ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេសទាំងឡាយដ៏គ្រោតគ្រាត ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេសទាំងឡាយដ៏ល្អិត ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេសទាំងពួង សទ្ធិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃឆន្ទៈ និងដោយអំណាចនៃសទ្ធា បាមុជ្ជៈកើតឡើង ដោយអំណាចនៃឆន្ទៈ សទ្ធិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃបាមុជ្ជៈ និងដោយអំណាចនៃសទ្ធា បីតិកើតឡើង ដោយអំណាចនៃបាមុជ្ជៈ សទ្ធិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃបីតិ និងដោយអំណាចនៃសទ្ធា បស្សទ្ធិកើតឡើង ដោយអំណាចនៃបីតិ សទ្ធិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃបស្សទ្ធិ និងដោយអំណាចនៃសទ្ធា សុខៈ កើតឡើងដោយអំណាចនៃបស្សទ្ធិ សទ្ធិន្ទ្រិយ ជាធម្មជាតិដ៏ក្រៃលែងដោយអំណាចនៃសុខៈ និងដោយអំណាចនៃសទ្ធា ឱភាស( ពន្លឺ ) កើតឡើង ដោយអំណាចនៃសុខៈ សទ្ធិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃឱភាស និងដោយអំណាចនៃសទ្ធា សង្វេគកើតឡើង ដោយអំណាចនៃឱភាស សទ្ធិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃសង្វេគ និងដោយអំណាចនៃសទ្ធា ចិត្តតក់ស្លុតហើយ រមែងតម្កល់មាំ សទ្ធិ-

ន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃសមាធិ និងដោយអំណាចនៃសទ្ធា ចិត្តដែលបុគ្គលតម្កល់មាំហើយ ដូច្នោះ រមែងផ្គងឡើងដោយប្រពៃ សទ្ធិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការផ្គងឡើង និងដោយអំណាចនៃសទ្ធា ចិត្តដែលបុគ្គលផ្គងឡើងហើយ ដូច្នោះ រមែងព្រងើយកន្តើយដោយប្រពៃ សទ្ធិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃសេចក្តីព្រងើយកន្តើយ និងដោយអំណាចនៃសទ្ធា ចិត្តរួចស្រឡះចាកកិលេសផ្សេងៗ ដោយអំណាចនៃសេចក្តីព្រងើយកន្តើយ សទ្ធិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការរួចស្រឡះ និងដោយអំណាចនៃសទ្ធា ធម៌ទាំងឡាយនោះ មានរសតែមួយ ព្រោះការរួចស្រឡះ សទ្ធិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអត្ថថា មានរសតែមួយ ដោយអំណាចនៃការអប់រំ និងដោយអំណាចនៃសទ្ធា ធម៌ទាំងឡាយវិលទៅរកធម៌ដ៏ថ្លៃថ្លា ជាងធម៌នោះ ព្រោះធម៌ទាំងនោះ ខ្លួនបានអប់រំហើយ សទ្ធិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការវិលទៅ និងដោយអំណាចនៃសទ្ធា ធម៌ទាំងឡាយលះបោលធម៌ទាំងនោះ ព្រោះធម៌ទាំងនោះវិលទៅហើយ សទ្ធិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការលះបោល និងដោយអំណាចនៃសទ្ធា ធម៌ទាំងឡាយរមែងរលត់ចាកធម៌ទាំងនោះ ព្រោះធម៌ទាំងនោះ គឺខ្លួនលះបោលហើយ សទ្ធិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការរលត់ និងដោយអំណាចនៃសទ្ធា ។ ការលះបោល ដោយអំណាចនៃការរលត់មាន ២ យ៉ាង គឺការលះបោលដោយការលះបង់ ១ ការលះបោលដោយការស្ទុះទៅ ១ ។

សភាវៈណា លះបង់នូវកិលេសនិងខន្ធ សភាវៈនោះ ឈ្មោះថា ការលះបោលដោយការលះបង់ ចិត្តស្ទុះទៅក្នុងនិរោធនិព្វានធាតុ ឈ្មោះថា ការលះបោលដោយការស្ទុះទៅ នេះ ការលះបោលដោយអំណាចនៃការរលត់ ២ យ៉ាង ។

[ ១៦៣ ] ឆន្ទៈកើតឡើងដើម្បីអប់រំនូវវីរិយិន្ទ្រិយ ឆន្ទៈកើតឡើងដើម្បីលះបង់នូវកោសជ្ជៈ ឆន្ទៈកើតឡើងដើម្បីលះបង់នូវសេចក្តីក្តៅក្រហាយព្រោះកោសជ្ជៈ ឆន្ទៈកើតឡើងដើម្បីលះបង់នូវកិលេសទាំងឡាយដែលតាំងនៅក្នុងទីមួយជាមួយនឹងទិដ្ឋិ ។បេ។ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេសទាំងពួង ។បេ។ ឆន្ទៈកើតឡើងដើម្បីអប់រំនូវសតិន្ទ្រិយ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវបមាទៈ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវសេចក្តីក្តៅក្រហាយព្រោះបមាទៈ ។បេ។ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេសទាំងពួង ។បេ។ ឆន្ទៈកើតឡើង ដើម្បីអប់រំនូវសមាធិន្ទ្រិយ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវឧទ្ធច្ចៈ ឆន្ទៈកើតឡើងដើម្បីលះបង់នូវសេចក្តីក្តៅក្រហាយព្រោះឧទ្ធច្ចៈ ។បេ។ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេសទាំងពួង ។បេ។ ឆន្ទៈកើតឡើង ដើម្បីអប់រំនូវបញ្ញិន្ទ្រិយ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវអវិជ្ជា ឆន្ទៈកើតឡើង ដើម្បីលះបង់នូវសេចក្តីក្តៅក្រហាយព្រោះអវិជ្ជា ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេសទាំងឡាយ ដែលតាំងនៅក្នុងទីមួយជាមួយនឹងទិដ្ឋិ ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេសទាំងឡាយដ៏គ្រោតគ្រាត ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេសទាំងឡាយដ៏ល្អិត ឆន្ទៈកើតឡើង ដើម្បីលះបង់នូវកិលេស

ទាំងពួង បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃឆន្ទៈ និងដោយអំណាចនៃបញ្ញា បាមុជ្ជៈ កើតឡើងដោយអំណាចនៃឆន្ទៈ បញ្ញិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃបាមុជ្ជៈ និងដោយអំណាចនៃបញ្ញា បីតិកើតឡើង ដោយអំណាចនៃបាមុជ្ជៈ បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃបីតិ និងដោយអំណាចនៃបញ្ញា បស្សទ្ធិកើតឡើង ដោយអំណាចនៃបីតិ បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃបស្សទ្ធិ និងដោយអំណាចនៃបញ្ញា សុខៈកើតឡើង ដោយអំណាចនៃបស្សទ្ធិ បញ្ញិន្ទ្រិយ ជាធម្មជាតិដ៏ក្រៃលែង ដោយអំណាចនៃសុខៈ និងដោយអំណាចនៃបញ្ញា ឱភាសកើតឡើង ដោយអំណាចនៃសុខៈ បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃឱភាស និងដោយអំណាចនៃបញ្ញា សង្វេគកើតឡើង ដោយអំណាចនៃឱភាស បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃសង្វេគ និងដោយអំណាចនៃបញ្ញា ចិត្តតក់ស្លុតហើយរមែងតម្កល់មាំ បញ្ញិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃសមាធិ និងដោយអំណាចនៃបញ្ញា ចិត្តដែលបុគ្គលតម្កល់មាំហើយ ដូច្នោះ រមែងផ្គងឡើងដោយប្រពៃ បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការផ្គងឡើង និងដោយអំណាចនៃបញ្ញា ចិត្តដែលបុគ្គលផ្គងឡើងហើយ ដូច្នោះ រមែងព្រងើយកន្តើយដោយប្រពៃ បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃសេចក្តីព្រងើយកន្តើយ និងដោយអំណាចនៃបញ្ញា ចិត្តរមែងរួចស្រឡះចាកកិលេសផ្សេង ៗ ដោយអំណាចនៃសេចក្តីព្រងើយកន្តើយ បញ្ញិន្ទ្រិយ ជា

ធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការរួបស្រឡះ និងដោយអំណាចនៃបញ្ញា ធម៌ទាំងឡាយនោះ មានរសតែមួយ ព្រោះរួបស្រឡះ បញ្ញិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអត្ថថា មានរសតែមួយ ដោយអំណាចនៃការអប់រំ និងដោយអំណាចនៃបញ្ញា ធម៌ទាំងឡាយ រមែងវិលទៅរកធម៌ដ៏ថ្លៃថ្លា ជាងធម៌ទាំងនោះ ព្រោះធម៌ទាំងនោះ ខ្លួនបានអប់រំហើយ បញ្ញិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការវិលទៅ និងដោយអំណាចនៃបញ្ញា ធម៌ទាំងឡាយរមែងលះបោលធម៌ទាំងនោះ ព្រោះធម៌ទាំងនោះវិលទៅហើយ បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការលះបោល និងដោយអំណាចនៃបញ្ញា ធម៌ទាំងឡាយរមែងរលត់ចាកធម៌ទាំងនោះ ព្រោះធម៌ទាំងនោះ លះបោលហើយ បញ្ញិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការរលត់ និងដោយអំណាចនៃបញ្ញា ។ ការលះបោល ដោយអំណាចនៃការរលត់មាន ២ យ៉ាង គឺការលះបោលដោយលះបង់ ១ ការលះបោលដោយការស្ទុះទៅ ១ ។ សភាវៈណាលះបង់នូវកិលេសនិងខន្ធ សភាវៈនោះឈ្មោះថា ការលះបោលដោយការលះបង់ ចិត្តស្ទុះទៅក្នុងនិរោធនិព្វានធាតុ ឈ្មោះថា ការលះបោលដោយការស្ទុះទៅ នេះការលះបោលដោយអំណាចនៃការរលត់ ២ យ៉ាង ។ ឥន្ទ្រិយទាំងឡាយ បុគ្គលគប្បីឃើញដោយអត្ថថា ក្រៃលែង យ៉ាងនេះឯង ។

**ចប់ ភាណវារៈ ។**

[ ១៦៤ ] ឥន្ទ្រិយទាំងឡាយ បុគ្គលគប្បីឃើញដោយអត្ថថា អធិដ្ឋាន ( ការតាំងមាំ ) តើដូចម្តេច ។ ឆន្ទៈកើតឡើង ដើម្បីអប់រំនូវសទ្ធិន្ទ្រិយ សទ្ធិន្ទ្រិយតាំងមាំដោយអំណាចនៃឆន្ទៈ និងដោយអំណាចនៃសទ្ធា បាមុជ្ជៈកើតឡើង ដោយអំណាចនៃឆន្ទៈ សទ្ធិន្ទ្រិយតាំងមាំដោយអំណាចនៃបាមុជ្ជៈ និងដោយអំណាចនៃសទ្ធា ។បេ។ ឥន្ទ្រិយទាំងឡាយ បុគ្គលគប្បីឃើញដោយអត្ថថា តាំងមាំ យ៉ាងនេះឯង ។

[ ១៦៥ ] ឥន្ទ្រិយទាំងឡាយបុគ្គលគប្បីឃើញដោយអត្ថថា គ្របសង្កត់ តើដូចម្តេច ។ សទ្ធិន្ទ្រិយដោយអត្ថថា ជឿស៊ប់ រមែងគ្របសង្កត់នូវអស្សទ្ធិយៈ រមែងគ្របសង្កត់នូវសេចក្តីក្តៅក្រហាយព្រោះអស្សទ្ធិយៈ វីរិយិន្ទ្រិយដោយអត្ថថាផ្គងឡើង រមែងគ្របសង្កត់នូវកោសជ្ជៈ រមែងគ្របសង្កត់នូវសេចក្តីក្តៅក្រហាយ ព្រោះកោសជ្ជៈ សតិន្ទ្រិយ ដោយអត្ថថា ប្រុងប្រយ័ត្ន រមែងគ្របសង្កត់នូវបមាទៈ រមែងគ្របសង្កត់នូវសេចក្តីក្តៅក្រហាយព្រោះបមាទៈ សមាធិន្ទ្រិយ ដោយអត្ថថា មិនរាយមាយ រមែងគ្របសង្កត់នូវឧទ្ធច្ចៈ រមែងគ្របសង្កត់នូវសេចក្តីក្តៅក្រហាយព្រោះឧទ្ធច្ចៈ បញ្ញិន្ទ្រិយ ដោយអត្ថថា ឃើញ រមែងគ្របសង្កត់នូវអវិជ្ជា រមែងគ្របសង្កត់នូវសេចក្តីក្តៅក្រហាយព្រោះអវិជ្ជា ឥន្ទ្រិយ ៥ ក្នុងនេក្ខម្មៈ រមែងគ្របសង្កត់នូវកាមច្ឆន្ទៈ ឥន្ទ្រិយ ៥ ក្នុងការមិនព្យាបាទ រមែងគ្របសង្កត់នូវព្យាបាទ ឥន្ទ្រិយ ៥ ក្នុងអាលោកសញ្ញា រមែងគ្របសង្កត់នូវថីនមិទ្ធៈ ឥន្ទ្រិយ ៥ ក្នុងការមិនរាយមាយ រមែងគ្របសង្កត់នូវឧទ្ធច្ចៈ ។បេ។ ឥន្ទ្រិយ ៥ ក្នុងអរហត្តមគ្គ រមែងគ្របសង្កត់នូវកិលេសទាំងពួង ឥន្ទ្រិយទាំងឡាយ បុគ្គលគប្បីឃើញ ដោយអត្ថថា គ្រប

សន្កត់ យ៉ាងនេះឯង ។

[ ១៦៦ ] ឥន្ទ្រិយទាំងឡាយ បុគ្គលគប្បីឃើញដោយអត្ថថា ឲ្យតម្កល់ស៊ប់ តើដូចម្តេច ។ បុគ្គលមានសទ្ធា រមែងញុំាងសទ្ធិន្ទ្រិយឲ្យតម្កល់ស៊ប់ក្នុងការជឿស៊ប់ សទ្ធិន្ទ្រិយ រមែងញុំាងបុគ្គលមានសទ្ធា ឲ្យតម្កល់ស៊ប់ក្នុងការជឿស៊ប់ បុគ្គលមានព្យាយាម រមែងញុំាងវីរិយិន្ទ្រិយ ឲ្យតម្កល់ស៊ប់ក្នុងការផ្គងឡើង វីរិយិន្ទ្រិយ រមែងញុំាងបុគ្គលមានព្យាយាមឲ្យតម្កល់ស៊ប់ក្នុងការផ្គងឡើង បុគ្គលមានស្មារតី រមែងញុំាងសតិន្ទ្រិយឲ្យតម្កល់ស៊ប់ក្នុងការប្រុងប្រយ័ត្ន សតិន្ទ្រិយ រមែងញុំាងបុគ្គលមានស្មារតីឲ្យតម្កល់ស៊ប់ ក្នុងការប្រុងប្រយ័ត្ន បុគ្គលមានចិត្តនឹងធឹង រមែងញុំាងសមាធិន្ទ្រិយ ឲ្យតម្កល់ស៊ប់ក្នុងការមិនរាយមាយ សមាធិន្ទ្រិយ រមែងញុំាងបុគ្គលមានចិត្តនឹងធឹង ឲ្យតម្កល់ស៊ប់ក្នុងការមិនរាយមាយ បុគ្គលមានបញ្ញា រមែងញុំាងបញ្ញិន្ទ្រិយឲ្យតម្កល់ស៊ប់ក្នុងការឃើញ បញ្ញិន្ទ្រិយ រមែងញុំាងបុគ្គលមានបញ្ញាឲ្យតម្កល់ស៊ប់ក្នុងការឃើញ យោគាវចរ រមែងញុំាងឥន្ទ្រិយ ៥ ឲ្យតម្កល់ស៊ប់ក្នុងនេក្ខម្មៈ ឥន្ទ្រិយ ៥ រមែងញុំាងយោគាវចរឲ្យតម្កល់ស៊ប់ក្នុងនេក្ខម្មៈ យោ-គាវចរ រមែងញុំាងឥន្ទ្រិយ ៥ ឲ្យតម្កល់ស៊ប់ក្នុងអព្យាបាទ ឥន្ទ្រិយ ៥ រមែងញុំាងយោគាវចរឲ្យតម្កល់ស៊ប់ក្នុងអព្យាបាទ យោគាវចរ រមែងញុំាងឥន្ទ្រិយ ៥ ឲ្យតម្កល់ស៊ប់ក្នុងអាលោកសញ្ញា ឥន្ទ្រិយ ៥ រមែងញុំាងយោគាវចរ ឲ្យតម្កល់ស៊ប់ក្នុងអាលោកសញ្ញា យោគាវចរ រមែងញុំាងឥន្ទ្រិយ ៥ ឲ្យតម្កល់ស៊ប់ក្នុងការមិនរាយមាយ ឥន្ទ្រិយ ៥ រមែងញុំាងយោគាវចរឲ្យ

តម្កល់ស៊ប់ក្នុងការមិនរាយមាយ ។បេ។ យោគាវចរ រមែងញុំាងឥន្ទ្រិយ ៥ ឲ្យតម្កល់ស៊ប់ក្នុងអរហត្តមគ្គ ឥន្ទ្រិយ ៥ រមែងញុំាងយោគាវចរឲ្យតម្កល់ស៊ប់ក្នុងអរហត្តមគ្គ ឥន្ទ្រិយទាំងឡាយ បុគ្គលគប្បីឃើញ ដោយអត្ថថា ឲ្យតម្កល់ស៊ប់ យ៉ាងនេះឯង ។

[ ១៦៧ ] បុថុជ្ជនកាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយអាការប៉ុន្មាន សេក្ខបុគ្គលកាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយអាការប៉ុន្មាន បុគ្គលប្រាសចាករាគៈ កាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយអាការប៉ុន្មាន ។ បុថុជ្ជនកាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយអាការ ៧ សេក្ខបុគ្គលកាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយអាការ ៨ បុគ្គលប្រាសចាករាគៈ កាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយអាការ ១០ ។

[ ១៦៨ ] បុថុជ្ជនកាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយអាការ ៧ តើដូចម្តេចខ្លះ ។ បុថុជ្ជន ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវអារម្មណ៍ ព្រោះអារម្មណ៍ដែលខ្លួនបានពិចារណាហើយ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវសមថនិមិត្ត ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវបគ្គហនិមិត្ត ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវសេចក្តីមិនរាយមាយ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវពន្លឺ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវសេចក្តីរីករាយ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុក នូវសេចក្តីព្រងើយកន្តើយ ១

បុថុជ្ជនកាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ៧ នេះឯង ។

សេក្ខបុគ្គលកាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ៨ តើដូចម្តេចខ្លះ ។ សេក្ខបុគ្គល ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវអារម្មណ៍ព្រោះអារម្មណ៍ដែលខ្លួនបានពិចារណាហើយ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវសមថនិមិត្ត ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវបគ្គហនិមិត្ត ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវសេចក្តីមិនរាយមាយ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវពន្លឺ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវសេចក្តីរីករាយ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវសេចក្តីព្រងើយកន្តើយ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវភាពនៃចិត្តមានអារម្មណ៍តែមួយ ១ សេក្ខបុគ្គលកាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ៨ នេះឯង ។

បុគ្គលប្រាសចាករាគៈ កាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ១០ តើដូចម្តេចខ្លះ ។ បុគ្គលប្រាសចាករាគៈ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវអារម្មណ៍ព្រោះអារម្មណ៍ដែលខ្លួនបានពិចារណាហើយ ១ ។បេ។ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវភាពនៃចិត្តមានអារម្មណ៍តែមួយ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវញាណ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវចិត្ត ១ បុគ្គលប្រាសចាករាគៈ កាលចម្រើនសមាធិ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ១០ នេះឯង ។

[ ១៦៩ ] បុថុជ្ជនកាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយអាការប៉ុន្មាន ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុក ដោយអាការប៉ុន្មាន សេក្ខបុគ្គល កាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការប៉ុន្មាន ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុក ដោយការប៉ុន្មាន បុគ្គលប្រាសចាករាគៈ កាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការប៉ុន្មាន ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុក ដោយអាការប៉ុន្មាន ។ បុថុជ្ជនកាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ៩ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកដោយអាការ ៩ សេក្ខបុគ្គលកាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយអាការ ១០ ជាអ្នក មិនឈ្លាសក្នុងការតម្កល់ទុកដោយអាការ ១០ បុគ្គលប្រាសចាករាគៈ កាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ១២ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកដោយអាការ ១២ ។

[ ១៧០ ] បុថុជ្ជនកាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ៩ តើដូចម្តេចខ្លះ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកដោយអាការ ៩ តើដូចម្តេចខ្លះ ។ បុថុជ្ជន ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាមិនទៀង ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាទៀង ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាជាទុក្ខ ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាជាសុខ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាមិនមែនខ្លួន ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាខ្លួន ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាអស់ទៅ ១ ជាអ្នក

មិនឈ្លាសក្នុងការតម្កល់ទុកថាជាដុំ ( រីងប៉ឹង ) ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាសូន្យ ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាប្រមូលមក ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាប្រែប្រួល ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាទៀង ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាមិនមាននិមិត្ត ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាមាននិមិត្ត ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាមិនមានទីតម្កល់ ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាមានទីតម្កល់ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាសូន្យ ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាប្រកាន់ស្អិត ១ បុថុជ្ជនកាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ៩ នេះឯង ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកដោយអាការ ៩ នេះឯង ។

សេក្ខបុគ្គល កាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ១០ តើដូចម្តេចខ្លះ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុក ដោយអាការ ១០ តើដូចម្តេចខ្លះ ។ សេក្ខបុគ្គល កាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាមិនទៀង ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាទៀង ១ ។បេ។ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាសូន្យ ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាប្រកាន់ស្អិត ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវញាណ ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកនូវអញ្ញាណ ១ សេក្ខបុគ្គល កាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយអាការ ១០ នេះឯង ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុក ដោយអាការ ១០ នេះឯង ។

បុគ្គលប្រាសចាករាគៈ កាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ១២ តើដូចម្តេចខ្លះ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកដោយអាការ ១២ តើដូចម្តេចខ្លះ ។ បុគ្គលប្រាសចាករាគៈ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកថាមិនទៀង ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកថាទៀង ១ ។បេ។ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវញាណ ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកនូវអញ្ញាណ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវការប្រាសចាកសំយោជនៈ ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកនូវសំយោជនៈ ១ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវនិរោធ ១ ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកនូវសង្ខារ ១ បុគ្គលប្រាសចាករាគៈ កាលចម្រើនវិបស្សនា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយអាការ ១២ នេះឯង ជាអ្នកមិនឈ្លាសក្នុងការតម្កល់ទុកដោយអាការ ១២ នេះឯង បុគ្គលប្រាសចាករាគៈ រមែងប្រជុំនូវឥន្ទ្រិយទាំងឡាយ ដោយអំណាចនៃសេចក្តីឈ្លាស ក្នុងការតម្កល់ទុកនូវអារម្មណ៍ ព្រោះអារម្មណ៍ទាំងនោះខ្លួនបានពិចារណាហើយ ទាំងដឹងច្បាស់នូវគោចរផង ចាក់ធ្លុះនូវអត្ថនៃការស្ងប់ផង ។បេ។ រមែងប្រជុំនូវធម៌ទាំងឡាយ ទាំងដឹងច្បាស់នូវគោចរផង ចាក់ធ្លុះនូវអត្ថនៃការស្ងប់ផង ។

[ ១៧១ ] សំណួរត្រង់ពាក្យថា ប្រជុំនូវឥន្ទ្រិយទាំងឡាយ តើប្រជុំនូវឥន្ទ្រិយទាំងឡាយ ដូចម្តេច ។ បុគ្គលប្រជុំនូវសទ្ធិន្ទ្រិយ ដោយអត្ថថាជឿស៊ប់ ។បេ។ ប្រជុំនូវឥន្ទ្រិយទាំងឡាយ ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកនូវសមថនិមិត្ត ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់

ទុកនូវបគ្គហនិមិត្ត ដោយអំណាចនៃសេចក្តីឈ្លាស ក្នុងការតម្កល់ទុកនូវសេចក្តីមិនរាយមាយ ដោយអំណាចនៃសេចក្តីឈ្លាស ក្នុងការតម្កល់ទុកនូវសេចក្តីរីករាយ ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកនូវឧបេក្ខា ដោយអំណាចនៃសេចក្តីឈ្លាស ក្នុងការតម្កល់ទុកនូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកនូវញាណ ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកនូវចិត្ត ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកថាមិនទៀង ដោយអំណាចនៃសេចក្តីមិនឈ្លាសក្នុងការតម្កល់ទុកថាទៀង ដោយអំណាចនៃសេចក្តីឈ្លាស ក្នុងការតម្កល់ទុកថាជាទុក្ខ ដោយអំណាចនៃសេចក្តីមិនឈ្លាសក្នុងការតម្កល់ទុកថាជាសុខ ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកថាមិនមែនខ្លួន ដោយអំណាចនៃសេចក្តីមិនឈ្លាសក្នុងការតម្កល់ទុកថាជាខ្លួន ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកថាអស់ទៅដោយអំណាចនៃសេចក្តីមិនឈ្លាសក្នុងការតម្កល់ទុកថាជាដុំ ( រឹងប៉ឹង ) ដោយអំណាចនៃសេចក្តីឈ្លាស ក្នុងការតម្កល់ទុកថាសូន្យ ដោយអំណាចនៃសេចក្តីមិនឈ្លាសក្នុងការតម្កល់ទុកនូវការប្រមូលមក ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកនូវសេចក្តីប្រែប្រួល ដោយអំណាចនៃសេចក្តីមិនឈ្លាសក្នុងការតម្កល់ទុកថាទៀង ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកថាមិនមាននិមិត្ត ដោយអំណាចនៃសេចក្តីមិនឈ្លាសក្នុងការតម្កល់ទុកនូវនិមិត្ត ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកនូវការមិនតម្កល់មាំ ដោយអំណាចនៃសេចក្តីឈ្លាស ក្នុងការ

តម្កល់ទុកនូវការតម្កល់មាំ ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកនូវការសូន្យ ដោយអំណាចនៃសេចក្តីមិនឈ្លាស ក្នុងការតម្កល់ទុកនូវការប្រកាន់ស្អិត ដោយអំណាចនៃសេចក្តីឈ្លាស ក្នុងការតម្កល់ទុកនូវញាណ ដោយអំណាចនៃសេចក្តីមិនឈ្លាស ក្នុងការតម្កល់ទុកនូវអញ្ញាណ ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកនូវការប្រាសចាកសំយោជនៈ ដោយអំណាចនៃសេចក្តីមិនឈ្លាសក្នុងការតម្កល់ទុកនូវសំយោជនៈ ដោយអំណាចនៃសេចក្តីឈ្លាសក្នុងការតម្កល់ទុកនូវនិរោធ បុគ្គលរមែងប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ទាំងដឹងច្បាស់នូវគោចរផង ចាក់ធ្លុះនូវអត្ថនៃការស្ងប់ផង ។

[ ១៧២ ] បញ្ញា គឺភាពស្ទាត់របស់ឥន្ទ្រិយ ៣ ដោយអាការ ៦៤ ឈ្មោះថាអាសវក្ខយញ្ញាណ ឥន្ទ្រិយទាំង ៣ តើដូចម្តេចខ្លះ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ ។

អនញ្ញាតញ្ញស្សាមីតិន្ទ្រិយដល់នូវឋានប៉ុន្មាន អញ្ញិន្ទ្រិយដល់នូវឋានប៉ុន្មាន អញ្ញាតាវិន្ទ្រិយដល់នូវឋានប៉ុន្មាន ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយដល់នូវឋាន ១ គឺសោតាបត្តិមគ្គ អញ្ញិន្ទ្រិយដល់នូវឋាន ៦ គឺសោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អញ្ញាតាវិន្ទ្រិយ ដល់នូវឋាន ១ គឺអរហត្តផល ។

[ ១៧៣ ] ក្នុងខណៈនៃសោតាបត្តិមគ្គ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយមានសទ្ធិន្ទ្រិយដែលមានការជឿស៊ប់ជាបរិវារ មានវីរិយិន្ទ្រិយដែលមានការផ្គងឡើងជាបរិវារ មានសតិន្ទ្រិយដែលមានការប្រុងប្រយ័ត្នជាបរិវារ មានស-

មាធិន្ទ្រិយដែលមានការមិនរាយមាយជាបរិវារ មានបញ្ញិន្ទ្រិយដែលមានការឃើញជាបរិវារ មានមនិន្ទ្រិយ ដែលមានការដឹងច្បាស់ជាបរិវារ មានសោមនស្សិន្ទ្រិយដែលមានការរីករាយជាបរិវារ មានជីវិតិន្ទ្រិយដែលមានតំណនៃការប្រព្រឹត្តិទៅជាអធិបតីជាបរិវារ ធម៌ទាំងឡាយដែលកើតហើយក្នុងខណៈនៃសោតាបត្តិមគ្គ វៀរលែងតែចិត្តសមុដ្ឋានរូបចេញ សុទ្ធតែជាកុសលទាំងអស់ សុទ្ធតែមិនមានអាសវៈទាំងអស់ សុទ្ធតែជានិយ្យានិកធម៌ទាំងអស់ សុទ្ធតែជាធម៌ដល់នូវការមិនសន្សំនូវវដ្ដៈទាំងអស់ សុទ្ធតែជាលោកុត្តរៈទាំងអស់ សុទ្ធតែជាធម៌មានព្រះនិព្វានជាអារម្មណ៍ទាំងអស់ ក្នុងខណៈនៃសោតាបត្តិមគ្គ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយមានឥន្ទ្រិយទាំង ៨ នេះជាសហជាតបរិវារ ជាអញ្ញមញ្ញបរិវារ ជានិស្សយបរិវារ ជាសម្បយុត្តបរិវារ ជាគុណជាតទៅជាមួយគ្នា កើតជាមួយគ្នា លាយឡំជាមួយគ្នា ប្រកបជាមួយគ្នា ធម៌ទាំងនោះឯង ជាអាការផង ជាបរិវារផង របស់អនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។ ក្នុងខណៈនៃសោតាបត្តិមគ្គ ។បេ។

ក្នុងខណៈនៃអរហត្តផល អញ្ញាតាវិន្ទ្រិយ មានសទ្ធិន្ទ្រិយដែលមានការជឿស៊ប់ជាបរិវារ ។បេ។ មានជីវិតិន្ទ្រិយ ដែលមានតំណនៃការប្រព្រឹត្តិទៅជាអធិបតីជាបរិវារ ។ ធម៌ទាំងឡាយដែលកើតហើយ ក្នុងខណៈនៃអរហត្តផល សុទ្ធតែជាអព្យាក្រឹតទាំងអស់ វៀរលែងតែចិត្តសមុដ្ឋានរូបចេញ សុទ្ធតែមិនមានអាសវៈទាំងអស់ សុទ្ធតែជាលោកុត្តរៈទាំងអស់ សុទ្ធតែជាធម៌មានព្រះនិព្វានជាអារម្មណ៍ទាំងអស់ ។ ក្នុងខណៈនៃអរហត្តផល អញ្ញាតា-

វិន្ទ្រិយ មានឥន្ទ្រិយទាំង ៨ នេះ ជាសហជាតបរិវារ ។បេ។ ធម៌ទាំងនោះឯង ជាអាការផង ជាបរិវារផង របស់អញ្ញាតាវិន្ទ្រិយនោះ ឥន្ទ្រិយប្រាំបីៗដងនេះ ដូចសេចក្តីដែលអធិប្បាយមកនេះ ត្រូវជា ៦៤ ។

[ ១៧៤ ] សំណួរត្រង់ពាក្យថា អាសវៈទាំងឡាយ តើ អាសវៈទាំងឡាយនោះ ដូចម្តេចខ្លះ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។

អាសវៈទាំងឡាយនោះរមែងអស់ក្នុងធម៌ដូចម្តេច ។ ទិដ្ឋាសវៈ រមែងអស់ឥតមានសេសសល់ កាមាសវៈនាំសត្វទៅកាន់អបាយរមែងអស់ ភវាសវៈនាំសត្វទៅកាន់អបាយរមែងអស់ អវិជ្ជាសវៈនាំសត្វទៅកាន់អបាយរមែងអស់ ដោយសោតាបត្តិមគ្គ អាសវៈទាំងឡាយនុ៎ះរមែងអស់ក្នុងធម៌នុ៎ះឯង ។ កាមាសវៈដ៏គ្រោតគ្រាតរមែងអស់ ភវាសវៈដែលតាំងនៅក្នុងទីមួយជាមួយនឹងកាមាសវៈនោះរមែងអស់ អវិជ្ជាសវៈដែលតាំងនៅក្នុងទីមួយ ជាមួយនឹងភវាសវៈនោះរមែងអស់ដោយសកទាគាមិមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ។ កាមាសវៈ រមែងអស់ ឥតមានសេសសល់ ភវាសវៈដែលតាំងនៅក្នុងទីមួយជាមួយនឹងកាមាសវៈនោះរមែងអស់ អវិជ្ជាសវៈដែលតាំងនៅក្នុងទីមួយជាមួយគ្នានឹងភវាសវៈនោះរមែងអស់ ដោយអនាគាមិមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ។ ភវាសវៈរមែងអស់ឥតមានសេសសល់ អវិជ្ជាសវៈ រមែងអស់ឥតមានសេសសល់ ដោយអរហត្តមគ្គ អាសវៈទាំងឡាយនុ៎ះរមែងអស់ក្នុងធម៌នុ៎ះឯង ។

ធម្មជាតតិចតួចក្នុងលោកនេះ ដែលព្រះតថាគតនោះមិនបាន

ឃើញហើយ មិនដឹងហើយ មិនគប្បីដឹងមិនមានឡើយ ធម្ម-
ជាតណាដែលព្រះតថាគតគប្បីដឹង ព្រះតថាគតបានដឹងធម្មជាត
នោះទាំងអស់ហើយ ហេតុនោះ ទើបព្រះតថាគតឈ្មោះថា
សមន្តចក្ខុ ។

សំណួរត្រង់ពាក្យថាសមន្តចក្ខុ តើសមន្តចក្ខុ ដោយអត្ថថាដូចម្តេច ។ ពុទ្ធញាណ ១៤ គឺសេចក្តីដឹងក្នុងទុក្ខ ឈ្មោះថាពុទ្ធញាណ ១ សេចក្តីដឹងក្នុងទុក្ខសមុទ័យ ឈ្មោះថាពុទ្ធញាណ ១ ។បេ។ សេចក្តីដឹងសព្វឥតចន្លោះ ឈ្មោះថាពុទ្ធញាណ ១ សេចក្តីដឹងឥតមានអ្វីរាំង ឈ្មោះថាពុទ្ធញាណ ១ នេះពុទ្ធញាណ ១៤ បណ្តាពុទ្ធញាណ ១៤ នេះ ញាណ ៨ ទូទៅដល់សាវ័ក ញាណ ៦ មិនទូទៅដល់សាវ័កទាំងឡាយទេ ។

[ ១៧៥ ] ទុក្ខសច្ច មានអត្ថថាលំបាកទាំងប៉ុន្មាន ព្រះតថាគតដឹងហើយ ទុក្ខសច្ច មានអត្ថថាលំបាក ព្រះតថាគតមិនបានដឹងហើយ មិនមានឡើយ ហេតុនោះ ព្រះតថាគតឈ្មោះថាសមន្តចក្ខុ ធម្មជាតណាជាសមន្តចក្ខុ ធម្ម-ជាតនោះក៏គឺបញ្ចិន្ទ្រិយ សទ្ធិន្ទ្រិយដោយអត្ថថាជឿស៊ប់ វីរិយិន្ទ្រិយដោយអត្ថថាផ្គងឡើង សតិន្ទ្រិយដោយអត្ថថាប្រុងប្រយ័ត្ន សមាធិន្ទ្រិយដោយអត្ថថាមិនរាយមាយ ( មានឡើង ) ដោយអំណាចនៃបញ្ចិន្ទ្រិយ ទុក្ខសច្ចមានអត្ថថាលំបាកទាំងប៉ុន្មាន ព្រះតថាគតឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់-ច្បាស់ហើយ ប៉ះពាល់ហើយដោយប្រាជ្ញា ទុក្ខសច្ចមានអត្ថថាលំបាក ព្រះតថាគតមិនបានប៉ះពាល់ហើយដោយប្រាជ្ញាមិនមានឡើយ ហេតុនោះ ព្រះ

តថាគតឈ្មោះថាសមន្តចក្ខុ ធម្មជាតណាជាសមន្តចក្ខុ ធម្មជាតនោះ ក៏គឺបញ្ញិន្ទ្រិយ សទ្ធិន្ទ្រិយដោយអត្ថថាជឿស៊ប់ វីរិយិន្ទ្រិយដោយអត្ថថាផ្គងឡើង សតិន្ទ្រិយដោយអត្ថថាប្រុងប្រយ័ត្ន សមាធិន្ទ្រិយដោយអត្ថថាមិនរាយមាយ ( មានឡើង ) ដោយអំណាចនៃបញ្ញិន្ទ្រិយ សមុទយសច្ចមានអត្ថថាកើតឡើងទាំងប៉ុន្មាន ។បេ។ និរោធសច្ចមានអត្ថថារលត់ទាំងប៉ុន្មាន មគ្គសច្ចមានអត្ថថាជាផ្លូវទាំងប៉ុន្មាន អត្ថប្បដិសម្ភិទា មានអត្ថថាបែកធ្លាយនូវអត្ថទាំងប៉ុន្មាន ។បេ។ ធម្មប្បដិសម្ភិទាមានអត្ថថាបែកធ្លាយនូវធម៌ទាំងប៉ុន្មាន និរុត្តិប្បដិសម្ភិទាមានអត្ថថាបែកធ្លាយនិរុត្តិទាំងប៉ុន្មាន បដិភាណប្បដិសម្ភិទាមានអត្ថថាបែកធ្លាយបដិភាណទាំងប៉ុន្មាន ឥន្ទ្រិយបរោបរិយត្តញ្ញាណទាំងប៉ុន្មាន សត្តានុសយញ្ញាណទាំងប៉ុន្មាន យមកប្បាដិហិរញ្ញាណទាំងប៉ុន្មាន មហាករុណាសមាបត្តិញ្ញាណទាំងប៉ុន្មាន ។បេ។ ធម្មជាតដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ឃើញ ឮ ហិត ដឹងច្បាស់ សម្រេច ស្វែងរក ត្រាច់ទៅតាមហើយដោយចិត្ត ព្រះតថាគតទ្រង់ដឹង ឃើញ ជ្រាបច្បាស់ ធ្វើឲ្យជាក់ច្បាស់ ប៉ះពាល់ហើយដោយប្រាជ្ញា ព្រះតថាគតមិនប៉ះពាល់ហើយដោយប្រាជ្ញា មិនមានទេ ហេតុនោះ ព្រះតថាគតឈ្មោះថាសមន្តចក្ខុ ធម្មជាតណាជាសមន្តចក្ខុ ធម្មជាតនោះក៏គឺបញ្ញិន្ទ្រិយ សទ្ធិន្ទ្រិយដោយអត្ថថាជឿស៊ប់ វីរិយិន្ទ្រិយដោយអត្ថថាផ្គងឡើង សតិន្ទ្រិយដោយអត្ថថាប្រុងប្រយ័ត្ន សមាធិន្ទ្រិយដោយអត្ថថាមិនរាយមាយ ( មានឡើង ) ដោយ

អំណាចនៃបញ្ចិន្ទ្រិយ បុគ្គលកាលជឿឈ្មោះថាផ្គងឡើង កាលផ្គងឡើង ឈ្មោះថាជឿ កាលជឿឈ្មោះថាប្រុងប្រយ័ត្ន កាលប្រុងប្រយ័ត្នឈ្មោះថាជឿ កាលជឿឈ្មោះថាតម្កល់មាំ កាលតម្កល់មាំឈ្មោះថាជឿ កាលជឿឈ្មោះថាដឹងច្បាស់ កាលដឹងច្បាស់ឈ្មោះថាជឿ កាលផ្គងឡើងឈ្មោះថាប្រុងប្រយ័ត្ន កាលប្រុងប្រយ័ត្នឈ្មោះថាផ្គងឡើង កាលផ្គងឡើងឈ្មោះថាតម្កល់មាំ កាលតម្កល់មាំឈ្មោះថាផ្គងឡើង កាលផ្គងឡើងឈ្មោះថាដឹងច្បាស់ កាលដឹងច្បាស់ឈ្មោះថាផ្គងឡើង កាលផ្គងឡើងឈ្មោះថាជឿ កាលជឿឈ្មោះថាផ្គងឡើង កាលប្រុងប្រយ័ត្នឈ្មោះថាតម្កល់មាំ កាលតម្កល់មាំឈ្មោះថាប្រុងប្រយ័ត្ន កាលប្រុងប្រយ័ត្នឈ្មោះថាដឹងច្បាស់ កាលដឹងច្បាស់ឈ្មោះថាប្រុងប្រយ័ត្ន កាលប្រុងប្រយ័ត្នឈ្មោះថាជឿ កាលជឿឈ្មោះថាប្រុងប្រយ័ត្ន កាលប្រុងប្រយ័ត្នឈ្មោះថាផ្គងឡើង កាលផ្គងឡើងឈ្មោះថាប្រុងប្រយ័ត្ន កាលតម្កល់មាំឈ្មោះថាដឹងច្បាស់ កាលដឹងច្បាស់ឈ្មោះថាតម្កល់មាំ កាលតម្កល់មាំឈ្មោះថាជឿ កាលជឿឈ្មោះថាតម្កល់មាំ កាលតម្កល់មាំឈ្មោះថាផ្គងឡើង កាលផ្គងឡើងឈ្មោះថាតម្កល់មាំ កាលតម្កល់មាំឈ្មោះថាប្រុងប្រយ័ត្ន កាលប្រុងប្រយ័ត្នឈ្មោះថាតម្កល់មាំ កាលដឹងច្បាស់ឈ្មោះថាជឿ កាលជឿឈ្មោះថាដឹងច្បាស់ កាលដឹងច្បាស់ឈ្មោះថាផ្គងឡើង កាលផ្គងឡើងឈ្មោះថាដឹងច្បាស់ កាលដឹងច្បាស់ឈ្មោះថាប្រុងប្រយ័ត្ន កាលប្រុងប្រយ័ត្នឈ្មោះថាដឹងច្បាស់ កាលដឹងច្បាស់ឈ្មោះថាតម្កល់មាំ កាលតម្កល់មាំឈ្មោះថាដឹងច្បាស់ ចិត្តដែលបុគ្គលផ្គងឡើងហើយព្រោះជឿ ធម្មជាតដែលបុគ្គលជឿហើយព្រោះ

ផ្គងឡើង ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយព្រោះជឿ ធម្មជាតិដែលបុគ្គលជឿហើយព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលតម្កល់មាំហើយព្រោះជឿ ធម្មជាតិដែលបុគ្គលជឿហើយព្រោះតម្កល់មាំ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយព្រោះជឿ ធម្មជាតដែលបុគ្គលជឿហើយព្រោះដឹងច្បាស់ ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយព្រោះផ្គងឡើង ចិត្តដែលបុគ្គលផ្គងឡើងហើយព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលតម្កល់មាំហើយព្រោះផ្គងឡើង ចិត្តដែលបុគ្គលផ្គងឡើងហើយព្រោះតម្កល់មាំ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះផ្គងឡើង ចិត្តដែលបុគ្គលផ្គងឡើងហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលជឿហើយព្រោះផ្គងឡើង ចិត្តដែលបុគ្គលផ្គងឡើងហើយព្រោះជឿ ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយព្រោះតម្កល់មាំ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលជឿហើយ ព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយព្រោះជឿ ចិត្តដែលបុគ្គលផ្គងឡើងហើយព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយ ព្រោះផ្គងឡើង ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយព្រោះតម្កល់មាំ ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលជឿហើយ ព្រោះតម្កល់មាំ ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះជឿ ចិត្តដែលបុគ្គលផ្គងឡើងហើយ ព្រោះតម្កល់មាំ ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះផ្គងឡើង ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយ ព្រោះតម្កល់មាំ ចិត្តដែល

បុគ្គលតម្កល់មាំហើយ ព្រោះប្រុងប្រយ័ត្ន ធម្មជាតដែលបុគ្គលជឿហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះជឿ ចិត្តដែលបុគ្គលផ្គងឡើងហើយព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះផ្គងឡើង ចិត្តដែលបុគ្គលប្រុងប្រយ័ត្នហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះប្រុងប្រយ័ត្ន ចិត្តដែលបុគ្គលតម្កល់មាំហើយ ព្រោះដឹងច្បាស់ ធម្មជាតដែលបុគ្គលដឹងច្បាស់ហើយ ព្រោះតម្កល់មាំ ធម្មជាតណាដែលជាពុទ្ធចក្ខុ ធម្មជាតនោះក៏គឺពុទ្ធញ្ញាណ ធម្មជាតណាដែលជាពុទ្ធញ្ញាណ ធម្មជាតនោះគឺពុទ្ធចក្ខុ ព្រះតថាគតទ្រង់ឃើញដោយចក្ខុណានូវសត្វទាំងឡាយដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការមិនល្អ គួរឲ្យត្រាស់ដឹងបានដោយងាយ គួរឲ្យត្រាស់ដឹងបានដោយក្រ ពួកខ្លះឃើញភ័យចំពោះទោសក្នុងបរលោក ពួកខ្លះឃើញភ័យចំពោះទោសក្នុងបរលោក ( ចក្ខុនោះក៏គឺពុទ្ធញ្ញាណ ) ។

[ ១៧៦ ] ពាក្យថា មានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក គឺ បុគ្គលមានសទ្ធាឈ្មោះថាមានធូលីតិចក្នុងភ្នែក បុគ្គលមិនមានសទ្ធាឈ្មោះថាមានធូលីច្រើនក្នុងភ្នែក បុគ្គលមានព្យាយាមប្រារព្ធហើយឈ្មោះថាមានធូលី

តិចក្នុងភ្នែក បុគ្គលខ្ជិលច្រអូសឈ្មោះថាមានធូលីច្រើនក្នុងភ្នែក បុគ្គលមានស្មារតីតម្កល់មាំ ឈ្មោះថាមានធូលីតិចក្នុងភ្នែក បុគ្គលមានស្មារតីភ្លេចភ្លាំងឈ្មោះថាមានធូលីច្រើនក្នុងភ្នែក បុគ្គលមានចិត្តតម្កល់ខ្ជាប់ឈ្មោះថាមានធូលីតិចក្នុងភ្នែក បុគ្គលមានចិត្តមិនតម្កល់ខ្ជាប់ ឈ្មោះថាមានធូលីច្រើនក្នុងភ្នែក បុគ្គលមានប្រាជ្ញា ឈ្មោះថាមានធូលីតិចក្នុងភ្នែក បុគ្គលឥតប្រាជ្ញាឈ្មោះថាមានធូលីច្រើនក្នុងភ្នែក ។

ពាក្យថា មានឥន្ទ្រិយក្លៀវក្លា មានឥន្ទ្រិយទន់ គឺបុគ្គលមានសទ្ធាឈ្មោះថា មានឥន្ទ្រិយក្លៀវក្លា បុគ្គលមិនមានសទ្ធាឈ្មោះថា មានឥន្ទ្រិយទន់ ។បេ។ បុគ្គលមានប្រាជ្ញាឈ្មោះថា មានឥន្ទ្រិយក្លៀវក្លា បុគ្គលឥតប្រាជ្ញាឈ្មោះថា មានឥន្ទ្រិយទន់ ។

ពាក្យថា មានអាការល្អ មានអាការមិនល្អ គឺបុគ្គលមានសទ្ធាឈ្មោះថា មានអាការល្អ ។បេ។ បុគ្គលមានប្រាជ្ញាឈ្មោះថា មានអាការល្អ បុគ្គលឥតប្រាជ្ញា ឈ្មោះថា មានអាការមិនល្អ ។

ពាក្យថា គួរឲ្យត្រាស់ដឹងបានដោយងាយ គួរឲ្យត្រាស់ដឹងបានដោយក្រ គឺបុគ្គលមានសទ្ធាឈ្មោះថា គួរឲ្យត្រាស់ដឹងបានដោយងាយ បុគ្គលមិនមានសទ្ធាឈ្មោះថា ឲ្យត្រាស់ដឹងបានដោយក្រ ។បេ។ បុគ្គលមានប្រាជ្ញា

ឈ្មោះថា គួរឲ្យត្រាស់ដឹងបានដោយងាយ បុគ្គលឥតប្រាជ្ញាឈ្មោះថា គួរឲ្យត្រាស់ដឹងបានដោយក្រ ។

ពាក្យថា ពួកខ្លះឃើញភ័យចំពោះទោសក្នុងបរលោក ពួកខ្លះមិនឃើញភ័យចំពោះទោសក្នុងបរលោក គឺបុគ្គលមានសទ្ធាឈ្មោះថាឃើញភ័យចំពោះទោសក្នុងបរលោក បុគ្គលមិនមានសទ្ធាឈ្មោះថា មិនឃើញភ័យ ចំពោះទោសក្នុងបរលោក បុគ្គលមានព្យាយាមប្រារព្ធហើយ ឈ្មោះថាឃើញភ័យចំពោះទោសក្នុងបរលោក បុគ្គលខ្ជិលច្រអូស ឈ្មោះថាមិនឃើញភ័យចំពោះទោសក្នុងបរលោក ។បេ។ បុគ្គលមានប្រាជ្ញាឈ្មោះថា ឃើញភ័យចំពោះទោសក្នុងបរលោក បុគ្គលឥតប្រាជ្ញាឈ្មោះថា មិនឃើញភ័យចំពោះទោសក្នុងបរ-លោក ។

ពាក្យថា លោក បានដល់ខន្ធលោក ធាតុលោក អាយតនលោក វិបត្តិភវលោក វិបត្តិសម្ភវលោក សម្បត្តិភវលោក សម្បត្តិសម្ភវលោក ។ លោក ១ គឺសត្វទាំងអស់ដែលតាំងនៅបានដោយសារអាហារ ។ លោក ២ គឺនាម ១ រូប ១ ។ លោក ៣ គឺវេទនា ៣ ។ លោក ៤ គឺអាហារ ៤ ។ លោក ៥ គឺឧបាទានក្ខន្ធទាំង ៥ ។ លោក ៦ គឺអាយតនៈខាងក្នុងទាំង ៦ ។ លោក ៧ គឺវិញ្ញាណដ្ឋិតិ ៧ ។ លោក ៨ គឺលោកធម៌ ៨ ។ លោក ៩

គឺសត្តាវាស ៩ ។ លោក ១០ គឺអាយតនៈ ១០ ។ លោក ១២ គឺអាយ-តនៈ ១២ ។ លោក ១៨ គឺធាតុ ១៨ ។

ពាក្យថា ទោស គឺកិលេសទាំងអស់ឈ្មោះថាទោស ( ទោសដែលបុគ្គលគួរវៀរ ) ទុច្ចរិតទាំងអស់ឈ្មោះថាទោស អភិសង្ខារទាំងអស់ឈ្មោះថាទោស ភវគាមិកម្ម ( កម្មដែលនាំសត្វកាន់ភព ) ទាំងអស់ឈ្មោះថាទោស ព្រោះហេតុនោះ សេចក្ដីសម្គាល់ក្នុងលោកនេះ និងក្នុងទោសនេះថាជាភ័យ យ៉ាងខ្លាំងក្លា រមែងតាំងឡើងប្រាកដ ដូចជាពេជ្ឈឃាតដែលយារដាវឡើង ( ប្រុងប្រហារ ) ព្រះតថាគតទ្រង់ជ្រាប ឃើញ ត្រាស់ដឹង ចាក់ធ្លុះ នូវឥន្ទ្រិយ ៥ នេះ ដោយអាការ ៥០ នេះឯង ។

**ចប់ តតិយភាណវារៈ ។**

**ចប់ ឥន្ទ្រិយកថា**

# អដ្ឋកថា ឥន្ទ្រិយកថា
# បឋមសុត្តន្តនិទ្ទេស

[ ១៣១ ] ឥឡូវនេះ ដល់កាលពណ៌នាសេចក្តីដែលមិនធ្លាប់ពណ៌នា ក្នុងឥន្ទ្រិយកថា ដែលពោលក្នុងលំដាប់អានាបានស្សតិកថា ។

ពិតណាស់ ឥន្ទ្រិយកថានេះ លោកពោលក្នុងលំដាប់អានាបានស្សតិ-កថា ដើម្បីសម្តែងវិធីជម្រះឥន្ទ្រិយដែលជាឧបការៈដល់អានាបានស្សតិនោះជាដើម ព្រោះកាលឥន្ទ្រិយទាំងឡាយដែលជាឧបការៈដល់អានាបានស្សតិ-ភាវនាមិនមាន អានាបានស្សតិភាវនាក៏មានមិនបាន ម្យ៉ាងទៀត ព្រះសារី-បុត្តត្ថេរ បំណងនឹងពោលឥន្ទ្រិយកថា ដែលគួរពោលនោះ ដោយអំណាចនៃការធ្វើទេសនាដែលមានមកក្នុងព្រះសូត្រ ដែលមានពាក្យអធិប្បាយប្រាកដច្បាស់ហើយ ដែលជាទេសនាដែលខ្លួនបានស្តាប់មកចំពោះព្រះភក្ត្រព្រះមានព្រះភាគឲ្យជាខាងដើម ហើយប្រកាសអត្ថនោះ ទើបពោលពាក្យថា **ឯវំ មេ សុតំ** ជាដើមមុន ។

ក្នុងបទទាំងនោះ បទថា **ឯវំ** ជានិបាត ។ បទទាំងឡាយមានបទថា **មេ** ជាដើមជានាមបទ ។ បទថា **វិ** ក្នុងបទថា **វិហរតិ** នេះ ជាបទឧបសគ្គ ។ បទថា **ហរតិ** ជាបទអាខ្យាត ។ គប្បីជ្រាបការចែកបទដោយន័យនេះដោយប្រការដូច្នេះ ។

តែដោយអត្ថ **ឯវំ** សព្ទ មកក្នុងអត្ថថា ការកំណត់ពាក្យដែលជាឧបមា ការអាង ពាក្យតិះដៀល ពាក្យសរសើរ អាការ និទស្សនៈនិងអវធារណៈ

**ឯវំ** សព្ទក្នុងទីនេះ រមែងប្រាកដក្នុងអត្ថនៃនិទស្សនៈ ( ការចង្អុលបង្ហាញ ) និងក្នុងអត្ថនៃអវធារណៈ ( ការទទួល ) ។

**ឯវំ** សព្ទ ក្នុងទីនេះ វិញ្ញូជនបញ្ញត្តចុះក្នុងអត្ថនៃអាការ និងក្នុងអត្ថនៃនិទស្សនៈ យ៉ាងនោះឯង ប្រើក្នុងអត្ថនៃអវធារណៈក៏បាន ។

ក្នុងអត្ថទាំងនោះ លោកសម្តែងសេចក្តីនេះដោយ **ឯវំ** សព្ទ ដែលមានអាការជាអត្ថ ( ប្រែថា ដោយអាការយ៉ាងនេះ ) អ្នកណាអាចដឹងច្បាស់ព្រះតម្រាស់របស់ព្រះមានព្រះភាគនោះ ដែលមានន័យផ្សេងៗល្អិតល្អន់ មានអធ្យាស្រ័យមិនតិចជាសមុដ្ឋាន សម្បូណ៌ដោយអត្ថនិងព្យញ្ជនៈ មានបាដិហារិយៈច្រើនយ៉ាង ជ្រាលជ្រៅដោយហេតុផល ទេសនា និងបដិវេធដែលមកកាន់គន្លងសោតៈ ដោយសមគួរដល់ភាសារៀងៗខ្លួននៃសត្វទាំងពួងបានដោយគ្រប់ប្រការ សូម្បីខ្ញុំជាស់នូវចំណង់ដែលនឹងស្តាប់ឲ្យកើតដោយកម្លាំងទាំងអស់ក៏បានស្តាប់មកហើយយ៉ាងនេះ គឺសូម្បីខ្ញុំក៏ស្តាប់មកហើយ ដោយអាការមួយ ។

ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងខ្លួនថា ខ្ញុំមិនមែនព្រះសយម្ភូ វត្ថុនេះខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ដោយ **ឯវំ** សព្ទ ដែលមាននិទស្សនៈជាអត្ថ ទើបសម្តែងសូត្រទាំងអស់ដែលគួរពោលក្នុងឥឡូវនេះថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ គឺសូម្បីខ្ញុំ ក៏ស្តាប់មកហើយយ៉ាងនេះ ។ ដោយ **ឯវំ** សព្ទ ដែលមានអវធារណៈជាអត្ថ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងកម្លាំងនៃការចងចាំរបស់ខ្លួនដែលសមគួរដែលព្រះមានព្រះភាគទ្រង់សរសើរ ( ទុកក្នុងអង្គុត្តរ-

និកាយឯកនិបាត ) ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកមានប្រាជ្ញាច្រើនដែលជាសាវករបស់តថាគតស្រេចនឹងសារីបុត្ត ប្រសើរជាងគេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញបុគ្គលដទៃ សូម្បីតែបុគ្គលម្នាក់ អ្នកញុំាងធម្មចក្កដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅតាមដោយត្រឹមត្រូវដូចសារីបុត្តនេះសោះ ម្នាលភិក្ខុទាំងឡាយ មានតែសារីបុត្តទើបញុំាងធម្មចក្កដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅតាមដោយត្រឹមត្រូវបាន ។ ទើបញុំាងភាវៈជាអ្នកប្រាថ្នានឹងស្ដាប់ ឲ្យកើតដល់សត្វទាំងឡាយថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ព្រះសូត្រនោះ ឯងមិនខ្វះចន្លោះ មិនលើសដោយអត្ថ ឬដោយព្យញ្ជនៈ គប្បីយល់ឃើញយ៉ាងនេះប៉ុណ្ណោះ មិនគប្បីយល់ឃើញជាយ៉ាងដទៃ ។

**មេ** សព្ទ រមែងប្រាកដក្នុងអត្ថនៃតតិយាវិភត្តិ ចតុត្ថីវិភត្តិនិងឆដ្ឋីវិភត្តិ ។ តែក្នុងទីនេះរមែងគួរក្នុងអត្ថពីរថា **មយា សុតំ** ដែលខ្ញុំស្ដាប់ហើយនិង **មម សុតំ** ការស្ដាប់របស់ខ្ញុំ ដូច្នេះ ។ សព្ទថា **សុតំ** នេះ ទាំងមានឧបសគ្គនិងមិនមានឧបសគ្គរមែងប្រាកដក្នុងអត្ថថា ប្រាកដ ការទៅ ការសរសើរ ការសន្សំ ការប្រកប ការដឹងច្បាស់តាមត្រចៀកនិងរមែងប្រាកដក្នុងអត្ថថា ដឹងច្បាស់ដោយការស្ទុះទៅតាមសោតទ្វារ ។ តែក្នុងទីនេះ **សុត** សព្ទនោះមានអត្ថថា ចូលទៅទ្រទ្រង់ទុកឬការចូលទៅទ្រទ្រង់ទុកដោយស្ទុះទៅតាមសោត-ទ្វារ ។

កាល **មេ** សព្ទ មានអត្ថថា **មយា** រមែងគួរថា ដែលខ្ញុំស្ដាប់ហើយ

យ៉ាងនេះ គឺចូលទៅទ្រទ្រង់ទុកដោយស្មុះទៅតាមសោតទ្វារ ។ កាលមានអត្ថថា **មម** រមែងគួរថា ការស្តាប់ គឺការចូលទៅទ្រទ្រង់ទុកដោយស្មុះទៅតាមសោតទ្វាររបស់ខ្ញុំយ៉ាងនេះ ។

ម្យ៉ាងទៀត ព្រះសារីបុត្តត្ថេរ កាលមិនទទួលថាខ្លួនឯងធ្វើឲ្យកើតឡើង បើកផ្សារការស្តាប់ ដែលមានមកអំពីមុនថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ រមែងទម្លាយនូវការមិនជឿក្នុងធម៌នេះថា ព្រះតម្រាស់របស់ព្រះមានព្រះភាគអង្គនោះ ដែលទ្រង់ក្លៀវក្លាដោយវេសារជ្ជធម៌ ៤ ដែលទ្រទ្រង់នូវកម្លាំង ១០ ដែលតាំងនៅក្នុងឋានៈអង់អាច ដែលបន្លឺសីហនាទ ដែលឧត្តមជាងសត្វទាំងពួង ដែលជាធំក្នុងធម៌ ដែលជាធម្មរាជា ដែលជាធម្មាធិបតី ដែលជាធម្មទីប ដែលជាធម្មសរណៈ ដែលជាចក្កពត្តិនៃព្រះសទ្ធម្មដ៏ប្រសើរ ដែលត្រាស់ដឹងប្រពៃដោយព្រះអង្គឯងនេះ ដែលខ្ញុំទទួលមកហើយចំពោះព្រះភក្ត្រ ក្នុងព្រះតម្រាស់នេះ អ្នកទាំងឡាយមិនគួរធ្វើនូវការសន្ទិះសង្ស័យក្នុងអត្ថ ក្នុងធម៌ ក្នុងបទ ក្នុងព្យញ្ជនៈឡើយ គប្បីញុំាងសទ្ធាសម្បទាឲ្យកើត ដោយហេតុនោះ ទើបលោកពោលថា

> សាវករបស់ព្រះគោតម កាលពោលយ៉ាងនេះថា ខ្ញុំបានស្តាប់
> មកហើយយ៉ាងនេះ រមែងទម្លាយនូវកាមិនមានសទ្ធា រមែង
> ធ្វើសទ្ធាក្នុងពាក្យប្រៀនប្រដៅឲ្យចម្រើនឡើង ។

បទថា **ឯកំ** សម្តែងកំណត់ចំនួន ។ បទថា **សមយំ** សម្តែងវត្ថុដែលកំណត់ ។ បទថា **ឯកំ សមយំ** សម្តែងការមិនពិតប្រាកដ ។ **សមយ**

សព្ទ ក្នុងបទនោះ រមែងប្រាកដក្នុងអត្ថថា

ក្នុងការប្រជុំ ខណៈ កាល ពួក ហេតុ ទិដ្ឋិ ការបាន ការលះ និងការបាក់ធ្លុះ ។

តែក្នុងទីនេះ **សមយ** សព្ទនោះ មានអត្ថថា កាល ។ ដោយពាក្យនោះ រមែងសម្ដែងថា សម័យមួយក្នុងសម័យទាំងឡាយ ដែលជាប្រភេទនៃកាល មានឆ្នាំ រដូវ ខែ កន្លះខែ យប់ ថ្ងៃ ព្រឹក ថ្ងៃត្រង់ ល្ងាច បឋមយាម មជ្ឈិមយាម បច្ឆិមយាម និងមួយស្របក់ជាដើម ។

ក្នុងបទនោះ ក្នុងសម័យទាំងឡាយ មានឆ្នាំជាដើមទាំងនេះ ព្រះមានព្រះភាគ ត្រាស់ព្រះសូត្រណាៗ ក្នុងឆ្នាំ រដូវ ខែ បក្ខ ពេលយប់ឬពេលថ្ងៃណាៗ ព្រះសូត្រទាំងអស់នោះ ព្រះថេរៈដឹងហើយយ៉ាងល្អ កំណត់ហើយយ៉ាងល្អដោយបញ្ញាក៏ពិត តែព្រោះកាលព្រះថេរៈពោលយ៉ាងនេះថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះក្នុងឆ្នាំនោះ រដូវនោះ ខែនោះ បក្ខនោះ ពេលយប់នោះឬពេលថ្ងៃនោះ បុគ្គលណាមួយមិនអាចចាំបាន នឹងលើកឡើងសម្ដែងបាន ឬនឹងឲ្យអ្នកដទៃលើកឡើងសម្ដែងបានងាយ ចាំបាច់នឹងត្រូវពោលឲ្យច្រើន ហេតុនោះទើបព្រះសារីបុត្តត្ថេរ ប្រមូលសេចក្ដីនោះចូលក្នុងបទតែមួយប៉ុណ្ណោះហើយពោលថា **ឯកំ សមយំ** ។

ម្យ៉ាងទៀត ក្នុងសម័យទាំងឡាយ របស់ព្រះមានព្រះភាគ ដែលមានប្រភេទច្រើន ដែលគេដឹងយ៉ាងល្អក្នុងទេវតានិងមនុស្សទាំងឡាយ គឺសម័យចុះកាន់គភ៌ សម័យប្រសូត សម័យកើតសង្វេគ សម័យទ្រង់ផ្នួស សម័យ

ទ្រង់បំពេញទុក្ករកិរិយា សម័យឈ្នះមារ សម័យត្រាស់ដឹង សម័យសោយសុខក្នុងទិដ្ឋធម៌ សម័យទេសនា សម័យបរិនិព្វាន ព្រះថេរៈរមែងសម្តែងថា សម័យមួយ គឺសម័យទេសនា ។ លោកពោលថា សម័យមួយ សំដៅដល់សម័យណាមួយ គឺក្នុងសម័យដែលទ្រង់បំពេញកិច្ចដោយព្រះបញ្ញានិងព្រះ-ករុណា សំដៅដល់សម័យដែលទ្រង់បំពេញកិច្ចដោយព្រះករុណា ក្នុងសម័យដែលទ្រង់បដិបត្តិដើម្បីប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ សំដៅដល់សម័យដែលទ្រង់បដិបត្តិ ដើម្បីប្រយោជន៍អ្នកដទៃ ក្នុងសម័យដែលទ្រង់បំពេញករណីកិច្ច ២ យ៉ាង ដល់ពុទ្ធបរិស័ទដែលមកប្រជុំគ្នា សំដៅដល់សម័យដែលត្រាស់ធម្មីកថា ក្នុងសម័យនៃទេសនានិងការបដិបត្តិ សំដៅដល់សម័យនៃទេសនា ។

ម្យ៉ាងទៀត ព្រោះបទថា **ឯកំ សមយំ** ជាអច្ចន្តសំយោគ គឺជាទុតិយា-វិភត្តិចុះក្នុងអត្ថថា អស់ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះសូត្រនេះ ឬព្រះសូត្រដទៃអស់សម័យណា ទ្រង់នៅដោយព្រះករុណាវិហារអស់សម័យនោះរហូតដល់ទីបំផុតនោះឯង ហេតុនោះដើម្បីធ្លុះបញ្ចាំងសេចក្តីនោះ ក្នុងទីនេះ ទើបលោកធ្វើឲ្យជាទុតិយាវិភត្តិ ។

ដោយហេតុនោះទើបលោកពោលគាថាព័ន្ធនេះថា

លោកសម្លឹងដល់អត្ថនោះៗហើយ ទើបពោល **សមយ** សព្ទ
ក្នុងទីដទៃ ដោយសត្តមីវិភត្តិនិងតតិយាវិភត្តិ ក្នុងទីនេះដោយ
ទុតិយាវិភត្តិ ។

ចំណែកបុរាណាចារ្យទាំងឡាយពណ៌នាថា **សមយ** សព្ទនេះមានសេចក្តីផ្សេងគ្នាត្រឹមតែពាក្យនិយាយថា **តស្មឹ សមយេ** ( ក្នុងសម័យនោះ ) **តេន សមយេន** ( ដោយសម័យនោះ ) ឬ **តំ សមយំ** ( អស់សម័យនោះ ) ក្នុងទីទាំងពួងមានសេចក្តីជាសត្តមីវិភត្តិទាំងអស់ ព្រោះហេតុនោះសូម្បីកាលពោលថា **ឯកំ សមយំ** ក៏គប្បីជ្រាបសេចក្តីថា **ឯកស្មឹ សមយេ** ( ក្នុងសម័យមួយ ) ។

បទថា **ភគវា** បានដល់ គ្រូ ព្រោះជនទាំងឡាយក្នុងលោកហៅគ្រូថា **ភគវា** ម្យ៉ាងទៀត ព្រះមានព្រះភាគអង្គនេះជាគ្រូរបស់សព្វសត្វ ព្រោះជាអ្នកប្រសើរដោយគុណទាំងពួង ព្រោះហេតុនោះ គប្បីជ្រាបថា **ភគវា** ។ សូម្បីបុរាណាចារ្យទាំងឡាយក៏ពោលទុកថា

> ពាក្យថា ភគវា ជាពាក្យប្រសើរបំផុត ពាក្យថា ភគវា ជាពាក្យខ្ពង់ខ្ពស់បំផុត ព្រះតថាគតនោះ ទ្រង់ជាអ្នកគួរដល់សេចក្តីគោរពកោតក្រែង ដោយហេតុនោះ ទើបទ្រង់ព្រះនាមថា ភគវា ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីពិស្តារនៃបទនោះដោយគាថានេះថា

> ព្រោះហេតុដែលព្រះពុទ្ធទ្រង់មានភាគ្យធម៌ ១ ទ្រង់មានភគ្គធម៌ ១ ទ្រង់ប្រកបដោយភគធម៌ ១ ទ្រង់ចែកធម៌ ១ ទ្រង់មានបុគ្គលភក្តី ១ ទ្រង់ជាអ្នកខ្ជាក់ចោលនូវហេតុដែលនាំទៅក្នុងភពទាំងឡាយ ១ ហេតុនោះ ទើបបានទទួលព្រះនាមថា

ភគវា ។

ពិតណាស់ ព្រះមានព្រះភាគអង្គនោះ លោកពោលទុកក្នុងពុទ្ធានុស្សតិនិទ្ទេស ក្នុងវិសុទ្ធិមគ្គហើយ ។

ដោយហេតុត្រឹមតែប៉ុណ្ណេះ ក្នុងនិទ្ទេសនេះលោកសម្ដែងទេសនាសម្បត្តិដោយពាក្យថា **ឯវំ** សម្ដែងសាវកសម្បត្តិដោយពាក្យថា **មេ សុតំ** សម្ដែងកាលសម្បត្តិដោយពាក្យថា **ឯកំ សមយំ** សម្ដែងទេសកសម្បត្តិដោយពាក្យថា **ភគវា** ។

ម្យ៉ាងទៀត ក្នុងបទថា **សាវត្ថិយំ** នេះ នគរដែលជាលំនៅរបស់សវត្ថឥសី ឈ្មោះថាសាវត្ថី បទថា **កាកន្ទី មាកន្ទី** យ៉ាងណា អ្នកអក្សរសាស្ត្រពោលសាវត្ថីទុកក៏យ៉ាងនេះ ។ តែព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលថាឈ្មោះថា សាវត្ថី ព្រោះជានគរដែលមនុស្សទាំងឡាយមានគ្រឿងឧបភោគបរិភោគគ្រប់យ៉ាង និងឈ្មោះថាសាវត្ថីព្រោះក្នុងវេលាប្រកបពួករទេះ កាលមានអ្នកសួរថា មានទំនិញអ្វីខ្លះ ក៏បាននូវពាក្យឆ្លើយថា មានសព្វយ៉ាង ។

> គ្រឿងឧបករណ៍គ្រប់ប្រភេទ រួមនៅក្នុងក្រុងសាវត្ថី មានគ្រប់
> កាល ព្រោះហេតុនោះ អាស្រ័យគ្រឿងឧបករណ៍ទាំងអស់
> ទើបហៅថា សាវត្ថី ។

ជិតក្រុងសាវត្ថីនោះ ។ ពាក្យនោះជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។ បទថា **វិហរតិ** នេះ ជាពាក្យសម្ដែងការដល់ព្រមនៃការនៅឯណានីមួយបណ្ដាការនៅដោយឥរិយាបថវិហារ ការនៅដោយទិព្វវិហារ ការនៅដោយ

ព្រហ្មវិហារ និងការនៅដោយអរិយវិហារ ដោយមិនវិសេស តែក្នុងទីនេះ សម្តែងដល់ការប្រកបដោយឥរិយាបថ ឯណានីមួយ បណ្តាឥរិយាបថទាំងឡាយដែលមានប្រភេទ គឺឈរ ដើរ អង្គុយ និងដេក ។ ដោយហេតុនោះ ព្រះមានព្រះភាគសូម្បីទ្រង់ឈរ ទ្រង់យាង ទ្រង់គង់ ទ្រង់ផ្ទុំ ក៏គប្បីជ្រាបថា គង់នៅនោះឯង ។ ព្រះមានព្រះភាគអង្គនេះ ទ្រង់ផ្លាស់ប្តូរឥរិយាបថមួយដោយឥរិយាបថដទៃ ទ្រង់សម្រាកនិងផ្លាស់ប្តូរអត្តភាព មិនឲ្យទ្រុឌទ្រោម ព្រោះហេតុនោះទើបពោលថា គង់នៅ ។

បទថា **ជេតវនេ** នេះ ឈ្មោះថា **ជេត** ព្រោះទ្រង់ឈ្នះជនជាសត្រូវរបស់ព្រះអង្គ ឬឈ្មោះថា **ជេត** ព្រោះកើតក្នុងកាលព្រះរាជាដែលជាបិតា ទ្រង់ឈ្នះសត្រូវរបស់ព្រះអង្គ ឬឈ្មោះថា **ជេត** ព្រោះដាក់ឈ្មោះយ៉ាងនេះដល់ព្រះរាជកុមារព្រោះធ្វើឲ្យជាមង្គល ។ ឈ្មោះថា **វន** ព្រោះដឹកនាំឲ្យប្រាថ្នាសេចក្តីថា ព្រោះធ្វើសត្វទាំងឡាយឲ្យសេពគប់ដោយសម្បត្តិរបស់ខ្លួន អធិប្បាយថា ញុំាងសេចក្តីស្នេហាឲ្យកើតក្នុងខ្លួន ឬឈ្មោះថា **វន** ព្រោះបបួល អធិប្បាយថា ដូចហៅសត្វទាំងឡាយថា អ្នកទាំងឡាយចូរមកប្រើប្រាស់ខ្ញុំចុះ ដោយដើមឈើ មែកឈើ ប្រគាបឈើ លំពង់ឈើ ស្លឹកឈើ ដែលខ្យល់ស្រទន់បក់ឲ្យកម្រើក ដែលមានក្លិនផ្កាច្រើនប្រភេទ និងមានសំឡេងតាវ៉ៅជាដើម ដែលបបួលឲ្យត្រេកអរ ។

សួនរបស់ស្តេចជេត ឈ្មោះថា **ជេតវន** ដ្បិតថាសួននោះព្រះរាជកុមារព្រះនាមថា **ជេត** ទ្រង់ដាំធ្វើឲ្យលូតលាស់ ទ្រង់មើលថែរក្សាយ៉ាងល្អ ម្យ៉ាង

ទៀត ព្រះរាជកុមារជេតនោះ ជាម្ចាស់របស់សួននោះ ព្រោះហេតុនោះទើបហៅថា **ជេតវន** ។ ក្នុងជេតវននោះ ។ ឈ្មោះថា **វន** មាន ២ យ៉ាង គឺសួនដាំនិងសួនកើតឯង ។ ជេតវននេះនិងវេឡុវនជាដើមជាសួនដែលដាំ ។ អន្ធវននិងមហាវនជាដើម ជាព្រៃដែលកើតឯង ។

បទថា **អនាថបិណ្ឌិកស្ស អារាមេ** គហបតីនោះ ឈ្មោះថា សុទត្ត ដោយឈ្មោះដែលមាតាបិតាដាក់ឲ្យ ។ ម្យ៉ាងទៀត ព្រោះជាអ្នកសម្បូរដោយបំណងគ្រប់ប្រការ ព្រោះប្រាសចាកសេចក្ដីកំណាញ់និងព្រោះដល់ព្រមដោយគុណ មានករុណាជាដើម បានបរិច្ចាគដុំបាយដល់មនុស្សអនាថា អស់កាលជានិច្ច ដោយហេតុនេះទើបឈ្មោះថា អានាថបិណ្ឌិក ។ ឈ្មោះថា អារាម ព្រោះជាទីមកត្រេកអររបស់សត្វឬដោយចំពោះបព្វជិត ។ បព្វជិតទាំងឡាយមកអំពីទីផ្សេងៗ រមែងត្រេកអរ រមែងត្រេកអរក្រៃលែង ព្រោះអារាមនោះលម្អដោយផ្កាឈើនិងផ្លែឈើជាដើម និងព្រោះដល់ព្រមដោយអង្គនៃសេនាសនៈ ៥ យ៉ាង មានមិនឆ្ងាយពេក មិនជិតពេកជាដើម សេចក្ដីថា ជាអ្នកមិនអផ្សុកក្នុងការអាស្រ័យនៅ ។ ម្យ៉ាងវិញទៀត ឈ្មោះថា អារាម ព្រោះនាំជនដែលទៅក្នុងទីផ្សេងៗឲ្យមករកខ្លួន ហើយឲ្យត្រេកអរដោយសម្បត្តិមានប្រការដូចពោលហើយ ។ អារាមនោះ អនាថបិណ្ឌិកគហបតី ទិញដោយប្រាក់ ១៨ កោដិ អំពីព្រះហស្តរបស់ព្រះរាជកុមារជេត ដោយក្រាលផែនដី ហើយឲ្យសាងសេនាសនៈដោយប្រាក់ ១៨ កោដិ ឆ្លងវិហារឲ្យសម្រេចដោយប្រាក់ ១៨ កោដិ ហើយវេរថ្វាយភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយ

បរិច្ចាគប្រាក់ ៥៤ កោដិ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបហៅថា អារាមរបស់អនាថបិណ្ឌិក ។ ក្នុងអារាមរបស់អនាថបិណ្ឌិកនោះ ។

ម្យ៉ាងទៀត ក្នុងបទទាំងនោះ បទថា **ជេតវនេ** ជាពាក្យប្រកាសឈ្មោះរបស់ម្ចាស់ដើម ។ ពាក្យថា **អនាថបិណ្ឌិកស្ស អារាមេ** ជាពាក្យប្រកាសឈ្មោះរបស់ម្ចាស់ក្រោយ ។ ប្រយោជន៍អ្វី ក្នុងការប្រកាសជនទាំងនោះ ។ ជាការកាន់យកទិដ្ឋានុគតិរបស់អ្នកប្រាថ្នាបុណ្យទាំងឡាយ ។ ក្នុងវិហារនោះ ព្រះអង្គម្ចាស់ជេតទ្រង់បរិច្ចាគប្រាក់ ១៨ កោដិ ដែលបានអំពីការលក់ដីនោះ បានសាងខ្លោងទ្វារនិងប្រាសាទ និងបរិច្ចាគដើមឈើ មានតម្លៃច្រើនកោដិ អនាថបិណ្ឌិកសេដ្ឋីបរិច្ចាគទ្រព្យ ៥៤ កោដិ ។ ហេតុនោះដោយការប្រកាសឈ្មោះជនទាំងនោះ ព្រះសារីបុត្តត្ថេរកាលនឹងសម្តែងថា អ្នកប្រាថ្នាបុណ្យទាំងឡាយ រមែងធ្វើបុណ្យយ៉ាងនេះ រមែងបបួលអ្នកប្រាថ្នាបុណ្យពួកដទៃ ក្នុងការកាន់យកជាទិដ្ឋានុគតិរបស់លោកទាំងនោះ ។

ក្នុងសេចក្តីនោះ បើមានអ្នកពោលថា ប្រសិនបើព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី ក៏មិនគួរពោលថា ក្នុងវិហារជេតពនអារាមរបស់អានាថបិណ្ឌិកសេដ្ឋី កាលគង់នៅក្នុងវត្តជេតពននោះ មិនគួរពោលថា ក្នុងក្រុងសាវត្ថី ព្រោះសម័យមួយមិនអាចគង់នៅក្នុងទីពីរកន្លែងបាន ។ មិនគួរឃើញយ៉ាងនោះ ខ្ញុំបានពោលទុកហើយមិនមែនឬថា បទថា **សាវត្ថិយំ** ជាសត្តមីវិភត្តិចុះក្នុងអត្ថថា ជិត គឺជិតក្រុងសាវត្ថី ។

ព្រោះហេតុនោះ ដូចហ្វូងគោទាំងឡាយត្រាច់ទៅជិតស្ទឹងគង្គា និងស្ទឹង

យមុនាជាដើម ក៏ហៅថា ហ្វូងគោត្រាច់ទៅជិតស្ទឹងគង្គា ត្រាច់ទៅជិតស្ទឹងយមុនា យ៉ាងណាសូម្បីសេចក្តីនេះ ក៏យ៉ាងនោះ វត្តជេតពនអារាមរបស់អនាថបិណ្ឌិកសេដ្ឋីនៅជិតក្រុងសាវត្ថី កាលព្រះសាស្តាគង់នៅក្នុងទីនោះ ក៏ពោលថា គង់នៅក្នុងព្រះវិហារជេតពន អារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ព្រោះពាក្យថាក្រុងសាវត្ថីរបស់បទនោះ ដើម្បីសម្តែងដល់គោចរគាម ពាក្យដ៏សេសដើម្បីសម្តែងដល់លំនៅដ៏សមគួរដល់បព្វជិត ។

ក្នុងបទទាំងនោះ ព្រះសារីបុត្តត្ថេរ សម្តែងដល់ការធ្វើសេចក្តីអនុគ្រោះគ្រហស្ថរបស់ព្រះមានព្រះភាគដោយប្រកាសឈ្មោះក្រុងសាវត្ថី សម្តែងដល់ការធ្វើសេចក្តីអនុគ្រោះបព្វជិត ដោយប្រកាសឈ្មោះជេតពនជាដើម ម្យ៉ាងទៀត ដោយពាក្យមុន សម្តែងដល់ការវៀរនូវការប្រកបក្នុងអត្តកិលមថានុយោគ ព្រោះបានទទួលបច្ច័យ ដោយពាក្យក្រោយ សម្តែងដល់ឧបាយជាគ្រឿងវៀរចាកការប្រកបនូវកាមសុខល្លិកានុយោគ ព្រោះលះវត្ថុកាម ។

ម្យ៉ាងវិញទៀត ដោយពាក្យមុន សម្តែងដល់ការប្រកបធម្មទេសនា ដោយពាក្យក្រោយ សម្តែងដល់ការបង្អោនទៅដើម្បីវិវេក ។ ដោយពាក្យមុន សម្តែងដល់ការយាងចូលទៅដោយព្រះករុណា ដោយពាក្យក្រោយ សម្តែងដល់ការយាងចេញទៅដោយព្រះបញ្ញា ។ ដោយពាក្យមុន សម្តែងដល់ភាពជាអ្នកបង្អោនទៅដើម្បីញុំាងប្រយោជន៍និងសេចក្តីសុខ ឲ្យសម្រេចដល់សត្វទាំងឡាយ ដោយពាក្យក្រោយ សម្តែងដល់ការមិនចូលទៅជាប់ក្នុងការធ្វើប្រយោជន៍និងសេចក្តីសុខដើម្បីអ្នកដទៃ ។ ដោយពាក្យមុន សម្តែងដល់ការ

នៅជាសុខ មានការមិនលះបង់សុខដែលប្រកបដោយធម៌ជានិមិត្ត ដោយពាក្យក្រោយ សម្តែងដល់ការនៅជាសុខ មានការប្រកបធម៌ដ៏កំពូលរបស់មនុស្ស ។ ដោយពាក្យមុន សម្តែងដល់ភាពជាអ្នកមានឧបការៈច្រើនដល់មនុស្សទាំងឡាយ ដោយពាក្យក្រោយ សម្តែងដល់ភាពជាអ្នកមានឧបការៈច្រើនដល់ពួកទេវតា ។ ដោយពាក្យមុន សម្តែងដល់ភាពដែលទ្រង់ឧប្បត្តិកឡើងក្នុងលោក ជាអ្នកចម្រើនក្នុងលោក ដោយពាក្យក្រោយ សម្តែងដល់ភាពជាអ្នកមិនត្រូវលោកបូកលាប ។ ដោយពាក្យមុន សម្តែងដល់ប្រយោជន៍ដែលព្រះមានព្រះភាគទ្រង់កើតឡើងហើយ ព្រោះព្រះបាលី ( ក្នុងអង្គុត្តរនិកាយឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកកាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីជាគុណដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ បុគ្គលឯក តើគឺនរណាគឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ដោយពាក្យក្រោយ សម្តែងដល់ការនៅដ៏សមគួរក្នុងទីដែលព្រះមានព្រះភាគទ្រង់ឧប្បត្តិហើយ ។ ពិតណាស់ព្រះមានព្រះភាគ ទ្រង់ឧប្បត្តិក្នុងព្រៃទាំងនោះ ទាំងលោកិយឧប្បត្តិនិងលោកុត្តរឧប្បត្តិ គឺគ្រាដំបូង ទ្រង់ឧប្បត្តិក្នុងលុម្ពិនីវ័ន គ្រាទីពីរ ទ្រង់ឧប្បត្តិក្នុងពោធិមណ្ឌល ដោយហេតុនោះគប្បីជ្រាបការប្រកបសេចក្តីក្នុងបទនេះដោយន័យជាដើមយ៉ាងនេះថា ព្រះសារីបុត្តត្ថេរ រមែងសម្តែងដល់ការគង់នៅរបស់ព្រះមានព្រះភាគក្នុងព្រៃទាំងនោះ ។

បទថា **តត្រ** ជាពាក្យសម្តែងដល់ទេសៈនិងកាលៈ ។ ពាក្យនោះរមែងសម្តែងថា ក្នុងសម័យដែលគង់នៅ និងក្នុងព្រះវិហារជេតវ័ន ដែលគង់នៅ ឬសម្តែងដល់ទេសៈនិងកាលៈ ដែលគួរពោល ។ ពិតណាស់ ព្រះមានព្រះភាគ ទ្រង់មិនសម្តែងធម៌ក្នុងទេសៈ ឬកាលៈ ដែលមិនសមគួរ ដូចក្នុងសេចក្តីនេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះជាកាលមិនគួរ ដូច្នេះ ។

បទថា **ខោ** ជានិបាតចុះក្នុងអត្ថនៃអវធារណៈ ឬក្នុងអត្ថនៃពេលផ្តើមដែលត្រឹមតែធ្វើបទឲ្យពេញ ។ បទថា **ភគវា** ជាពាក្យសម្តែងដល់គ្រូនៃលោក ។

បទថា **ភិក្ខូ** ជាពាក្យពោលដល់បុគ្គល ដែលគួរស្តាប់ព្រះតម្រាស់ ។ ម្យ៉ាងវិញទៀត ក្នុងពាក្យនេះ គប្បីជ្រាបអត្ថនៃពាក្យ ដោយន័យជាដើមថា ឈ្មោះថា ភិក្ខុ ព្រោះជាអ្នកសូម ឈ្មោះថា ភិក្ខុ ព្រោះប្រកបការត្រាច់ដើម្បីសូមភិក្ខា ។ បទថា **អាមន្តេសិ** បានដល់ ត្រាស់ហៅ ទ្រង់ត្រាស់ជាស់តឿនឲ្យដឹង នេះជាសេចក្តីក្នុងពាក្យនេះ ។ តែក្នុងទីដទៃប្រព្រឹត្តទៅក្នុងការឲ្យដឹងខ្លះ ក្នុងការហៅខ្លះ ។ បទថា **ភិក្ខវោ** ជាពាក្យសម្តែងអាការហៅ ។ ដោយបទនោះ ព្រះមានព្រះភាគ កាលនឹងទ្រង់ប្រកាសដល់ការប្រព្រឹត្តិដែលមនុស្សអាក្រក់ និងមនុស្សល្អសេពគប់គ្នា ដោយព្រះតម្រាស់ដែលសម្រេចដោយការប្រកបគុណ មានសភាពជាអ្នកសូមជាប្រក្រតី ភាពជាអ្នកសូមជាធម្មតានិងភាពជាអ្នកធ្វើសេចក្តីល្អក្នុងការសូមជាដើមរបស់ភិក្ខុទាំងនោះ ទើបទ្រង់ធ្វើការគ្រុបសង្កត់ភាពជាអ្នករាយមាយ និងការតក់ស្លុត ។ ម្យ៉ាងទៀត

ព្រះមានព្រះភាគ ទ្រង់ធ្វើភិក្ខុទាំងនោះ ឲ្យបែរមុខមករកព្រះអង្គដោយព្រះ-តម្រាស់ដែលជាប្រធាន ដោយទឹកព្រះទ័យដ៏ត្រជាក់ ពេញប្រៀបទៅដោយព្រះករុណានិងខ្សែព្រះនេត្រដ៏ស្រទន់នេះថា **ភិក្ខវោ** ទ្រង់ញ៉ាំងភិក្ខុទាំងនោះឲ្យកើតនូវការដាក់ចិត្តប្រាថ្នានឹងស្តាប់ ដោយព្រះតម្រាស់ដែលសម្តែងដល់ភាពជាអ្នកបំណងនឹងត្រាស់នោះឯង ។

ម្យ៉ាងទៀត ទ្រង់ដឹកនាំភិក្ខុទាំងនោះក្នុងការធ្វើទុកក្នុងចិត្ត ក្នុងការតាំងចិត្តស្តាប់ដោយល្អ ដោយព្រះតម្រាស់ដែលមានអត្ថថា ដាស់តឿននោះឯង ។ ពិតណាស់ ការសម្បូរនៃពាក្យប្រៀនប្រដៅ ទាក់ទងដោយការធ្វើទុកក្នុងចិត្តក្នុងការស្តាប់ដោយល្អ ។

បើមានពាក្យសួរថា កាលមានទេវតានិងមនុស្សពួកដទៃនៅជាមួយផងព្រោះហេតុអ្វីទើបព្រះមានព្រះភាគត្រាស់ហៅចំពោះភិក្ខុទាំងឡាយប៉ុណ្ណោះ ។ ឆ្លើយថា ព្រោះភិក្ខុទាំងឡាយ ជាអ្នកចម្រើនបំផុត ប្រសើរបំផុត ជាអ្នកអង្គុយជិត ជាអ្នកត្រៀមហើយគ្រប់កាល និងដូចជាភាជនៈ ។ ពិតហើយព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ទូទៅដល់បរិស័ទទាំងពួង ។ ម្យ៉ាងទៀត ភិក្ខុទាំងឡាយ ឈ្មោះថា ជាអ្នកចម្រើនបំផុតក្នុងបរិស័ទ ព្រោះកើតឡើងមុន ឈ្មោះថា ជាអ្នកប្រសើរបំផុត ព្រោះជាអ្នកធ្វើដំណើរតាមព្រះ-ចរិយារបស់ព្រះសាស្តា តាំងអំពីភាពជាអ្នកមិនគ្រប់គ្រងផ្ទះជាដើមនិងព្រោះជាអ្នកទទួលពាក្យប្រៀនប្រដៅទុកទាំងអស់ ឈ្មោះថា ជាអ្នកនៅជិត ព្រោះកាលអង្គុយក្នុងទីនោះ ក៏នៅជិតព្រះសាស្តា ឈ្មោះថា ជាអ្នកត្រៀមហើយ

សព្វកាល ព្រោះជាអ្នកត្រាច់ទៅក្នុងសំណាក់របស់ព្រះសាស្តា និងឈ្មោះថា ដូចជាកាជនៈទ្រទ្រង់ព្រះធម្មទេសនា ព្រោះជាអ្នកព្រមបដិបត្តិតាមពាក្យប្រៀនប្រដៅ ។

ក្នុងសេចក្តីនោះគប្បីមានអ្នកនិយាយថា ក៏ព្រះមានព្រះភាគ កាលទ្រង់សម្តែងធម៌ ត្រាស់ហៅភិក្ខុទាំងឡាយមុន ហេតុអ្វីទ្រង់មិនសម្តែងធម៌តែម្តងទៅ ឆ្លើយថា ដើម្បីឲ្យប្រុងសតិ ព្រោះភិក្ខុទាំងឡាយក្នុងទីប្រជុំ អង្គុយគិតរឿងដទៃខ្លះ ចិត្តរាយមាយខ្លះ ពិចារណាធម៌ខ្លះ មនសិការកម្មដ្ឋានខ្លះ ភិក្ខុទាំងនោះ កាលព្រះមានព្រះភាគមិនត្រាស់ហៅ ហើយទ្រង់សម្តែងធម៌តែម្តងទៅ ក៏មិនអាចកំណត់បានថា ទេសនានេះ មានអ្វីជានិទាន មានអ្វីជាបច្ច័យ ព្រះមានព្រះភាគ ទ្រង់សម្តែងដោយមានអត្ថុប្បត្តិហេតុដូចម្តេច គប្បីដល់នូវការរាយមាយ ឬគប្បីកាន់យកខុស ដោយហេតុនោះ ដើម្បីឲ្យភិក្ខុទាំងនោះប្រុងសតិទើបត្រាស់ហៅមុនហើយទ្រង់សម្តែងធម៌ក្នុងកាលជាខាងក្រោយ ។

បទថា **ភទន្តេ** នេះ ជាពាក្យសម្តែងសេចក្តីគោរពឬជាការឲ្យពាក្យឆ្លើយចំពោះព្រះសាស្តា ។ ម្យ៉ាងទៀត បទថា **ភទន្តេ** នេះ ព្រះមានព្រះភាគកាលត្រាស់ថា **ភិក្ខវោ** ឈ្មោះថា ត្រាស់ហៅភិក្ខុទាំងឡាយនោះ ។ ភិក្ខុទាំងនោះកាលទូលថា **ភទន្តេ** ឈ្មោះថា ទូលទទួលព្រះមានព្រះភាគ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់ថា **ភិក្ខវោ** ភិក្ខុទាំងឡាយនោះទទួលថា **ភទន្តេ** ព្រះមានព្រះភាគ ទ្រង់ឲ្យភិក្ខុទាំងឡាយទទួលដោយពាក្យថា **ភិក្ខវោ** ភិក្ខុទាំងឡាយទូលទទួលដោយពាក្យថា **ភទន្តេ** ។ បទថា **តេ ភិក្ខូ** គឺភិក្ខុដែលព្រះ

មានព្រះភាគត្រាស់ហៅ ។ បទថា **ភគវតោ បច្ចស្សោសុំ** បានដល់ ភិក្ខុទាំងឡាយ ទូលទទួលការត្រាស់ហៅរបស់ព្រះមានព្រះភាគ អធិប្បាយថា ភិក្ខុទាំងឡាយបែរមុខស្តាប់ ទទួលកាន់យក ។ បទថា **ភគវា ឯតទវោច** បានដល់ ព្រះមានព្រះភាគបានត្រាស់ព្រះសូត្រទាំងអស់នោះដែលគួរត្រាស់ក្នុងឥឡូវនេះ ។

ម្យ៉ាងទៀត ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះសារីបុត្តត្ថេរពោលដល់និទានណា ដែលប្រដាប់ដោយការអាងដល់កាលៈ ទេសៈ អ្នកសម្តែង និងបរិស័ទ ដើម្បីយល់បានងាយនូវព្រះសូត្រនេះ ដែលសម្បូរដោយអត្ថនិងព្យញ្ជនៈ ដែលធ្លុះបញ្ចាំងដល់ភាពជ្រាលជ្រៅនៃទេសនា និងញាណរបស់ព្រះពុទ្ធទាំងឡាយ ដូចកំពង់ទឹកដែលជាភូមិភាគដ៏ស្អាត ដេរដាសដោយខ្សាច់ដូចគ្នានឹងក្រាលទុកដោយបណ្តាញកែវមុក្តា មានជណ្តើរដ៏ល្អ រំលេចដោយផ្ទាំងថ្មរាបស្មើ ចូលទៅបានងាយក្នុងស្រះបោក្ខរណី ដែលមានទឹកមានរសឆ្ងាញ់ ថ្លាស្អាតដេរដាសទៅដោយផ្កាឈូកនិងគុម្ពឈូក ដូចជណ្តើរដ៏ល្អស្អាតរុងរឿង ដែលកើតអំពីពន្លឺនៃកែវមណី ដែលចងដោយវល្លិមាសក្ជាប់ត្រង់បន្ទះក្តារដែលល្អិត ធ្វើដោយភ្លុក ដើម្បីឡើងងាយស្រួល កាន់ប្រាសាទដ៏ប្រសើរ ព័ទ្ធដោយជញ្ជាំងដែលចាត់ចែងទុកយ៉ាងល្អ និងវេទិកាដ៏វិចិត្រដែលខ្ពស់ត្រកាល ហាក់បីដូចនឹងមានបំណងប៉ះពាល់នូវផ្លូវនៃផ្កាយនក្ខត្តឫក្ស ដូចទ្វារធំដែលមានសន្ទះទ្វារទូលាយ ប្រកបទុកយ៉ាងមាំទាំ ភ្លឺរុងរឿង បរិសុទ្ធិដោយមាស ប្រាក់ កែវមណី កែវមុក្តា និងកែវប្រពាលជាដើម ដើម្បីងាយ

ចូលទៅកាន់ផ្ទះធំដែលស្រស់ល្អដោយឥស្សរិយសម្បត្តិ ដែលរុងរឿង កុះករដោយជនក្នុងផ្ទះ បន្លឺសំឡេងពីរោះ ទន់ភ្លន់ និយាយសើច លាយឡំទៅដោយសំឡេងប៉ះខ្ទប់នៃកងដៃនិងកងជើងមាសជាដើម ការពណ៌នាសេចក្តីនៃនិទាននោះបរិបូរណ៍ហើយ ។

បទថា **បញ្ច** ក្នុងព្រះសូត្រ ជាការកំណត់ចំនួន ។ បទថា **ឥមានិ ឥន្ទ្រិយានិ** ជាពាក្យបង្អុលបង្ហាញធម៌ដែលកំណត់ទុកហើយ ។ អត្ថនៃឥន្ទ្រិយ ខ្ញុំធ្លាប់ពោលទុកហើយ ។

[ ១៣២ ] ព្រះសារីបុត្តត្ថេរកាលសម្តែងព្រះសូត្រនេះហើយ ឥឡូវនេះ មានបំណងនឹងសម្តែងវិធីចម្រើនឲ្យបរិសុទ្ធដល់នូវការអប់រំហើយ និងដល់នូវការស្ងប់រម្ងាប់នៃឥន្ទ្រិយទាំងឡាយ ដូចដែលបានត្រាស់ទុកក្នុងព្រះសូត្រនេះ ទើបពោលពាក្យថា **ឥមានិ បញ្ចិន្ទ្រិយានិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **វិសុជ្ឈន្តិ** បានដល់ វមែងដល់នូវការបរិសុទ្ធិ ។ បទថា **អស្សទ្ធេ** បានដល់ ដែលប្រាសចាកការជឿ ក្នុងព្រះរតនត្រ័យ ។ បទថា **សទ្ធេ** បានដល់ ដែលដល់ព្រមដោយសទ្ធា ក្នុងព្រះរតនត្រ័យ ។ បទថា **សេវតោ** បានដល់ សេពគប់ដោយចិត្ត ។ បទថា **ភជតោ** បានដល់ ចូលទៅរក ។ បទថា **បយិរុបាសតោ** បានដល់ ចូលទៅអង្គុយជិតដោយសេចក្តីគោរព ។

បទថា **បសាទនីយេ សុត្តន្តេ** បានដល់ ព្រះសូត្រដែលប្រកបដោយគុណនៃព្រះរតនត្រ័យ ដែលឲ្យកើតសេចក្តីជ្រះថ្លា ។

បទថា **កុសីតេ** មានវិគ្គហៈថា ឈ្មោះថា **កុសីទ** ព្រោះលិចចុះដោយអាការដែលគួរផ្ញៀស **កុសីទ** នោះឯងជា **កុសីត** ។ នូវបុគ្គលអ្នកខ្ជិលច្រអូសទាំងនោះ ។

បទថា **សម្មប្បធានេ** បានដល់ ព្រះសូត្រដែលប្រកបដោយសេចក្តីព្យាយាម ដែលឲ្យសម្រេចកិច្ច ៤ យ៉ាង ។ បទថា **មុដ្ឋស្សតិ** បានដល់អ្នកមានសតិវិនាសទៅ ។ បទថា **សតិប្បដ្ឋានេ** បានដល់ ព្រះសូត្រដែលពោលដោយសតិប្បដ្ឋាន ។ បទថា **ឈានវិមោក្ខេ** បានដល់ ព្រះសូត្រដែលពោលដោយចតុត្ថជ្ឈាន វិមោក្ខ ៨ និងវិមោក្ខ ៣ ។ បទថា **ទុប្បញ្ញោ** បានដល់ មិនមានបញ្ញា ឬឈ្មោះថា ទុប្បញ្ញា ព្រោះអត្ថថា ជាអ្នកមានបញ្ញាថោកថយ ព្រោះមិនមានបញ្ញា ។ នូវបុគ្គលដែលជាអ្នកមានបញ្ញាថោកថយទាំងនោះ ។

បទថា **គម្ភីរញាណចរិយំ** បានដល់ ព្រះសូត្រដែលប្រកបដោយអរិយសច្ចៈ ៤ និងបដិច្ចសមុប្បាទ ជាដើម ឬដូចគ្នានឹងញាណកថា ។ បទថា **សុត្តន្តក្ខន្ធេ** បានដល់ ចំណែកនៃព្រះសូត្រ ។

[ ១៣៣ ] ក្នុងបទថា **អស្សទ្ធិយំ** ជាដើម មានវិនិច្ឆ័យដូចតទៅនេះថា ពាក្យថា **អស្សទ្ធិយំ** បានដល់ ភាពជាអ្នកមិនមានសទ្ធា ។ បុគ្គលឃើញទោសក្នុងការមិនមានសទ្ធា លះការមិនមានសទ្ធា រមែងចម្រើនសទ្ធិន្ទ្រិយបាន បុគ្គលឃើញអានិសង្សក្នុងសទ្ធិន្ទ្រិយ ចម្រើនសទ្ធិន្ទ្រិយ រមែងលះភាពជាអ្នកមិនមានសទ្ធា ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

បទថា **កោសជ្ជំ** បានដល់ ភាពជាអ្នកខ្ជិលច្រអូស ។ បទថា **បមាទំ** បានដល់ ការនៅប្រាសចាកសតិ ។ បទថា **ឧទ្ធច្ចំ** បានដល់ ភាពជាអ្នករាយមាយ អធិប្បាយថា ចិត្តរាយមាយ ។

[ ១៣៤ ] បទថា **បហីនត្តា** បានដល់ ព្រោះលះនូវការមិនជឿជាដើមបានដោយការពេញនៃឈាន ដោយអំណាចនៃអប្បនា ។ បទថា **សុប្បហី-នត្តា** បានដល់ ព្រោះលះនូវការមិនជឿជាដើមបានដោយល្អ ដោយការពេញនៃវិបស្សនា ដោយអំណាចនៃវុដ្ឋានគាមិនីបដិបទា ។ បទថា **ភាវិតំ ហោតិ សុភាវិតំ** គប្បីប្រកបតាមលំដាប់ ដូចដែលពោលហើយនោះឯង ។ ពិតណាស់ ត្រូវពោលថា **សុប្បហីនត្តា** ព្រោះលះបានហើយដោយអំណាចនៃធម៌ផ្ទុយដោយវិបស្សនា ព្រោះហេតុនោះ ការពោលថា **សុភាវិតំ** ក៏ដោយវិបស្សនា មិនមែនដោយឈាន ។ ម្យ៉ាងទៀត ព្រោះភាវនាសម្រេចបានដោយការលះវត្ថុដែលគួរលះ និងការសម្រេចនូវការលះវត្ថុដែលគួរលះមានបាន ក៏ដោយការសម្រេចនៃភាវនា ហេតុនោះទើបលោកសម្តែងឲ្យជាគូគ្នា ។

[ ១៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបដិបស្សទ្ធិវារៈដូចតទៅនេះថា បទថា **ភាវិតានិ ចេវ ហោន្តិ សុភាវិតានិ ច** លោកពោលដល់ភាពដែលឥន្ទ្រិយ ៥ ដែលបុគ្គលចម្រើនហើយនោះឯង ជាឥន្ទ្រិយដែលអប់រំល្អហើយ ។

ដោយបទថា **បដិប្បស្សទ្ធានិ ច សុប្បដិប្បស្សទ្ធានិ ច** លោកពោលដល់ភាពដែលឥន្ទ្រិយ ៥ រម្ងាប់ហើយនោះឯង ជាឥន្ទ្រិយដែលរម្ងាប់ល្អហើយ ។ គប្បីជ្រាបភាពដែលឥន្ទ្រិយ ៥ ដែលបុគ្គលចម្រើនហើយ និង

រម្ងាប់ហើយ ដោយអំណាចនៃការកើតនូវកិច្ចរបស់មគ្គក្នុងខណៈនៃផល ។ បទថា **សមុច្ឆេទ វិសុទ្ធិយោ** បានដល់ មគ្គវិសុទ្ធិនោះឯង ។ បទថា **បដិប្បស្សទ្ធិវិសុទ្ធិយោ** បានដល់ ផលវិសុទ្ធិនោះឯង ។

[ ១៣៦ ] ឥឡូវនេះព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងប្រកបឥន្ទ្រិយ មានវិធីដូចពោលហើយយ៉ាងនោះ ដោយអំណាចនៃការកៈបុគ្គល ទើបពោលពាក្យជាដើមថា **កតីនំ បុគ្គលានំ** ។ ក្នុងបទទាំងនោះ បទថា **ភាវិតិន្ទ្រិយ វសេន ពុទ្ធោ** សេចក្តីថា បុគ្គលត្រាស់ដឹង គឺបុគ្គលដឹងអរិយសច្ចៈ ៤ ដោយការស្តាប់ធម្មកថា អំពីព្រះសម្មាសម្ពុទ្ធ ។ នេះជាពាក្យនិយាយដល់ហេតុនៃភាពជាអ្នកចម្រើនឥន្ទ្រិយហើយ ព្រោះថាក្នុងខណៈនៃផលឈ្មោះថាជាអ្នកចម្រើនឥន្ទ្រិយហើយ ព្រោះជាអ្នកត្រាស់ដឹងមគ្គ ដោយអំណាចការសម្រេចភាវនា ។ ព្រះសារីបុត្តត្ថេរ កាលសម្តែងដល់អ្នកតាំងនៅក្នុងអរ-ហត្តផលប៉ុណ្ណោះឲ្យវិសេសឡើងទៅ ព្រោះអរិយបុគ្គលទាំងឡាយ ៨ ក៏ជាព្រះសាវករបស់ព្រះតថាគត ទើបពោលថា **ខីណាសវោ** ។

ព្រោះព្រះខីណាស្រពប៉ុណ្ណោះ លោកពោលថា **ភាវិតិន្ទ្រិយោ** ដោយការសម្រេចកិច្ចទាំងពួង ។ ចំណែកព្រះអរិយបុគ្គលក្រៅអំពីនោះ ក៏ជាអ្នកចម្រើនឥន្ទ្រិយហើយដូចគ្នាដោយអម ព្រោះសម្រេចកិច្ចដោយមគ្គនោះៗ ព្រោះហេតុនោះ ក្នុងខណៈនៃផល ៤ ទើបលោកពោលថា ឥន្ទ្រិយទាំង ៥ បុគ្គលចម្រើនហើយផង ចម្រើនល្អហើយផង ។ម្យ៉ាងទៀត ព្រោះការចម្រើនឥន្ទ្រិយរបស់អរិយបុគ្គលទាំងនោះនៅមាននោះឯង ដើម្បីប្រយោជន៍

ដល់មគ្គខាងលើ ហេតុនោះ ទើបព្រះអរិយបុគ្គលទាំងនោះ មិនឈ្មោះថាជាអ្នកចម្រើនឥន្ទ្រិយហើយដោយត្រង់ ។

បទថា **សយម្ភូតដ្ឋេន** បានដល់ ជាអ្នកមិនមានអាចារ្យជា **ភគវា** ដោយអត្ថថា កើតហើយក្នុងអរិយៈជាតិឯង ។ ពិតណាស់ សូម្បីព្រះបច្ចេកពុទ្ធនោះក៏ឈ្មោះថាសយម្ភូក្នុងខណៈនៃផល ដោយអំណាចនៃការសម្រេចការ-នា ។ ក្នុងខណៈនៃផល ឈ្មោះថាមានឥន្ទ្រិយអប់រំហើយ ដោយអត្ថថា ជាអ្នកដឹងឯង ដោយប្រការដូច្នេះ ។ បទថា **អប្បមេយ្យដ្ឋេន** បានដល់ ដោយអត្ថថាបុគ្គលណាមួយ មិនអាចប្រមាណបាន ព្រោះទ្រង់ប្រកបដោយអនន្តគុណ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះគុណប្រមាណមិនបាន ព្រោះទ្រង់សម្រេចដោយការនាក្នុងខណៈនៃផល ។ ព្រោះហេតុនោះឯង ទើបទ្រង់ជាអ្នកចម្រើនឥន្ទ្រិយហើយ ។

## អដ្ឋកថា បឋមសុត្តន្តនិទ្ទេស ចប់

# ទុតិយសុត្តន្តនិទ្ទេស

[ ១៣៧ ] ព្រះសារីបុត្តត្ថេរ បំណាំងនឹងលើកព្រះសូត្រដទៃមកទុកទៀត ហើយចង្អុលបង្ហាញដល់ការកំណត់ឥន្ទ្រិយ ទើបសម្តែងព្រះសូត្រថា **បញ្ចិមានិ ភិក្ខវេ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **យេ ហិ កេចិ** ជាពាក្យកាន់យកដោយមិនមានសល់ ។ **ហិ** អក្ខរៈជានិបាតចុះក្នុងអត្ថត្រឹមតែធ្វើបទឲ្យពេញ ។

បទថា **សមណា វា ព្រាហ្មណា វា** លោកពោលដោយអំណាចលោកវោហារ ។ បទថា **សមុទយំ** បានដល់ នូវបច្ច័យ ។ បទថា **អត្ថង្គមំ** បានដល់ ដល់នូវការមិនមាននៃឥន្ទ្រិយដែលកើតហើយ ឬការមិនកើតនៃឥន្ទ្រិយ ដែលមិនទាន់កើត ។ បទថា **អស្សាទំ** បានដល់ អានិសង្ស ។ បទថា **អាទីនវំ** បានដល់ ទោស ។ បទថា **និស្សរណំ** បានដល់ ឧបាយជាគ្រឿងនាំចេញទៅ ។ បទថា **យថាភូតំ** បានដល់ តាមសេចក្តីពិត ។ បទថា **សមណេសុ** បានដល់ លោកអ្នកស្ងប់បាបហើយ ។ បទថា **សមណសម្មតា** បានដល់ តថាគតមិនបានទទួលថាជាសមណៈ ។ កាលពោលថា **សម្មតា** ដោយអំណាចនៃបច្ចុប្បន្នកាល ជាការពោលឆ្លីវិកត្តិក្នុងបទថា **មេ** នេះ ដោយអំណាចនៃលក្ខណៈរបស់សព្ទ ។

បទថា **ព្រាហ្មណេសុ** បានដល់ លោកអ្នកបន្សាត់បាបហើយ ។ បទថា **សាមញ្ញត្ថំ** បានដល់ ផលនៃភាពជាសមណៈ ។ បទថា **ព្រហ្មញ្ញត្ថំ** បានដល់ផលនៃភាពជាព្រាហ្មណ៍ ។ ដោយបទទាំងពីរលោកពោលដល់អរហត្ត-

ផលនោះឯង ។

ម្យ៉ាងវិញទៀត បទថា **សាមញ្ញត្ថំ** បានដល់ ផល ៣ ខាងក្រោម ។ បទថា **ព្រហ្មញ្ញត្ថំ** បានដល់ អរហត្តផល ។ ពិតហើយ ទាំងសាមញ្ញផល និងព្រហ្មញ្ញផល ក៏គឺអរិយមគ្គនោះឯង ។ បទថា **ទិដ្ឋេវ ធម្មេ** បានដល់ ក្នុងអត្តភាពដែលប្រចក្សហើយនេះឯង ។ បទថា **សយំ អភិញ្ញា សច្ឆិកត្វា** បានដល់ ធ្វើឲ្យប្រចក្សដោយបញ្ញាដ៏ក្រៃលែង ដោយខ្លួនឯងនោះឯង ។ បទថា **ឧបសម្បជ្ជ** បានដល់ ដល់ហើយ ឬឲ្យសម្រេចហើយ ។

[ ១៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេស ដូចតទៅនេះថា ព្រះសារីបុត្តត្ថេរ សួរដល់ចំនួនប្រភេទរបស់ហេតុកើតនៃឥន្ទ្រិយជាដើមមុនហើយ ឆ្លើយចំនួននៃប្រភេទតទៅ ។ ក្នុងបទទាំងនោះ បទថា **អសីតិសតំ** បានដល់ ១០០ លើស ៨០ ។ យោជនាថាថា ដោយអាការដែលបណ្ឌិតពោលថា ១៨០ ។

[ ១៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគណនានិទ្ទេស ដែលជាចំណែកខាងដើមនៃការសួរចំនួនប្រភេទទៀត ដូចតទៅនេះថា បទថា **អធិមោក្ខត្ថាយ** ដើម្បីប្រយោជន៍ដល់ការបង្អោនចិត្តជឿ ដើម្បីប្រយោន៍ដល់ការជឿ ។ បទថា **អាវជ្ជនាយ សមុទយោ** បានដល់ ការកើតនៃមនោទ្វារាវជ្ជនចិត្ត ។ បទថា **សទ្ធិន្ទ្រិយស្ស សមុទយោ** បានដល់ បច្ច័យនៃសទ្ធិន្ទ្រិយ ។ ការពិចារណាដល់ចំណែកខាងដើមថា អាត្មាអញនឹងញ៉ាំងសទ្ធាឲ្យកើត ជាឧបនិស្សយប្បច្ច័យ ដល់សទ្ធិន្ទ្រិយ ការនឹកគិតដល់ជវននៃសទ្ធិន្ទ្រិយ ជាអនន្តរប្បច្ច័យដល់

ជវនចិត្តដួងដំបូង ជាឧបនិស្សយប្បច្ច័យ ដល់ជវនចិត្តដួងទី ២ ជាដើម ។ បទថា **អធិមោក្ខវសេន** បានដល់ ដោយអំណាចការបង្អោនចិត្តជឿ ដែលសម្បយុត្តដោយឆន្ទៈ ។ បទថា **ឆន្ទស្ស សមុទយោ** បានដល់ ការកើតនៃធម្មឆន្ទៈ ដែលជាយោវាបនកធម៌ ដែលសម្បយុត្តដោយអធិមោក្ខ ដែលកើតឡើងព្រោះការនឹកគិតដល់ចំណែកខាងដើមជាបច្ច័យ ។ ហេតុកើតនោះ ជាបច្ច័យនៃសទ្ធិន្ទ្រិយ ដោយអំណាចនៃសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ និងជាអធិបតិប្បច្ច័យ ក្នុងកាលដែលមានឆន្ទៈជាធំ ការកើតនៃអាវជ្ជនៈនោះឯង ជាបច្ច័យដល់ការកើត ( នៃធម្មឆន្ទៈ ) ទី ២ ដោយអំណាចនៃអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ អនន្តរូបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។ គប្បីធ្វើការប្រកបសូម្បីមនសិការដោយន័យនេះឯង ។

សេចក្តីពិត ក្នុងទីនេះ បទថា **មនសិការោ** នេះ គឺមនសិការដែលជាយោវាបនកធម៌ ដែលមានការឲ្យស្ទុះទៅជាលក្ខណៈតែម្យ៉ាង ។ មនសិការនោះមិនជាអធិបតិប្បច្ច័យ ។ ក្នុងសម្បយុត្តធម៌ទាំងឡាយ ការប្រារព្ធចំពោះធម៌ទាំងពីរយ៉ាងនេះ គប្បីជ្រាបថា ព្រោះជាពលវប្បច្ច័យ ( បច្ច័យដែលមានកម្លាំង ) ។ បទថា **សទ្ធិន្ទ្រិយស្ស វសេន** បានដល់ ដោយអំណាចនៃសទ្ធិន្ទ្រិយ ដែលដល់ភាពជាឥន្ទ្រិយ ព្រោះការចម្រើនក្រៃលែងនៃភាវនា ។ បទថា **ឯកត្តុបដ្ឋានំ** បានដល់ ឋានៈដ៏ក្រៃលែងដោយការមិនញាប់ញ័រក្នុងអារម្មណ៍មួយ រមែងជាបច្ច័យក្រៃលែងឡើងដល់សទ្ធិន្ទ្រិយ ។ គប្បីជ្រាប

ឥន្ទ្រិយដ៏សេសដោយន័យដូចពោលហើយក្នុងសទ្ធិន្ទ្រិយនោះឯង ។ ឥន្ទ្រិយនីមួយៗ មានហេតុកើត ៤ ព្រោះហេតុនោះ ឥន្ទ្រិយ ៥ ទើបមានហេតុកើត ២០ ដោយប្រការដូច្នេះ ។ លោកប្រកបឥន្ទ្រិយទាំង ៥ ចូលក្នុងហេតុកើតនីមួយៗរបស់ហេតុកើតទាំង ៤ ទៀត ហើយពោលហេតុកើត ២០ ។

អាចារ្យទាំងឡាយពោលថា គប្បីឃើញហេតុកើត ២០ ទី ១ ដោយអំណាចនៃមគ្គផ្សេងៗ ហេតុកើត ២០ ទី ២ ដោយអំណាចនៃមគ្គ ១ រួមជាអាការ ៤០ ដោយប្រការដូច្នេះ ។

[ ១៤០ ] សូម្បី **អត្ថង្គមវារ** ក៏គប្បីជ្រាបដោយន័យនេះឯង ។ ការរលត់នោះ ជាការរលត់ការបានចំពោះនូវឥន្ទ្រិយដែលមិនទាន់បាននៃបុគ្គលដែលមិនប្រកបការចម្រើនឥន្ទ្រិយ ជាការរលត់ គឺការវិនាសចាកឥន្ទ្រិយដែលបានហើយនៃបុគ្គល ដែលវិនាសចាកការចម្រើនឥន្ទ្រិយ ជាការរលត់ដោយការស្ងប់រម្ងាប់នៃបុគ្គលដែលសម្រេចផលហើយ ។ បទថា **ឯកត្តំ អនុបដ្ឋានំ** បានដល់ ការមិនប្រាកដក្នុងធម៌តែមួយ ។

## អស្សាទនិទ្ទេស

[ ១៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអស្សាទនិទ្ទេសដូចតទៅនេះថា បទថា **អស្សទ្ធិយស្ស អនុបដ្ឋានំ** បានដល់ ការមិនប្រាកដនៃភាពជាអ្នកមិនមានសទ្ធា រមែងមានដល់បុគ្គលដែលវៀរបុគ្គលដែលមិនមានសទ្ធា គប់រកបុគ្គល

ដែលមានសទ្ធា ពិចារណាសូត្រដែលនាំឲ្យមានសទ្ធា ធ្វើយោនិសោមនសិ-ការក្នុងសូត្រនោះឲ្យច្រើន ។

ក្នុងបទថា **អស្សទ្ធិយបរិឡាហស្ស អនុបដ្ឋានំ** នេះ កាលការពោលរឿងសទ្ធាកំពុងប្រព្រឹត្តទៅ សេចក្ដីទុក្ខទោមនស្សរមែងកើតឡើងដល់បុគ្គលមិនមានសទ្ធា នេះឈ្មោះថាការក្ដៅក្រហាយព្រោះភាពជាអ្នកមិនមានសទ្ធា ។ បទថា **អធិមោក្ខចរិយាយ វេសារជ្ជំ** បានដល់ ភាពជាអ្នកក្លៀវក្លាដោយអំណាចនៃវត្ថុដែលជាទីតាំងនៃសទ្ធា ឬដោយការប្រព្រឹត្តិទៅនៃសទ្ធា របស់បុគ្គលដែលដល់នូវការជំនាញក្នុងការនោ ។ បទថា **សន្តោ ច វិហារាធិគមោ** បានដល់ ការបានសមថៈ ឬវិបស្សនា ។ បទថា **សោមនស្ស** ក្នុងបទថា **សុខំ សោមនស្សំ** នេះ ដើម្បីសម្ដែងដល់សេចក្ដីសុខផ្លូវចិត្ត ។ បុគ្គលមានកាយដែលរូបប្រណីត ដែលកើតឡើងព្រោះសទ្ធិន្ទ្រិយពាល់ត្រូវហើយ រមែងបានសេចក្ដីសុខផ្លូវកាយទីងគ្នា ។ ព្រោះសុខសោមនស្សជាគុណដែលជាប្រធាន ទើបលោកពោលឲ្យវិសេសថា **អយំ សទ្ធិន្ទ្រិយស្ស អស្សាទោ** ។ សូម្បីគុណនៃឥន្ទ្រិយដ៏សេស បណ្ឌិតគប្បីប្រកបហើយជ្រាបដោយន័យនេះឯង ។

អដ្ឋកថាអស្សាទនិទ្ទេស ចប់

## អាទីនវនិទ្ទេស

[ ១៤២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាទីនវនិទ្ទេសដូចតទៅនេះថា បទថា **អនិច្ចដ្ឋេន** បានដល់ ព្រោះអត្ថថា សទ្ធិន្ទ្រិយមិនទៀង ។ មានពាក្យអធិប្បាយថា ការមិនទៀងនោះជាទោសនៃសទ្ធិន្ទ្រិយ ។ ក្នុងបទពីរក្រៅអំពីនេះ ( បទថាទុក្ខនិងអនត្តា ) ក៏ន័យនេះដូចគ្នា ។ ហេតុកើត ការរលត់ គុណ និងទោសទាំងនេះ គប្បីជ្រាបថា ជារបស់ឥន្ទ្រិយដែលជាលោកិយៈនោះឯង ។

### អដ្ឋកថាអាទីនវនិទ្ទេស ចប់

## និស្សរណនិទ្ទេស

[ ១៤៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិស្សរណនិទ្ទេសដូតទៅនេះថា

ក្នុងបទថា **អធិមោក្ខដ្ឋេន** លោកធ្វើអត្ថ ៥ ក្នុងឥន្ទ្រិយនីមួយៗ សម្តែងឥន្ទ្រិយ ៥ មានឧបាយជាគ្រឿងរលាស់ចេញ ២៥ ដោយអំណាចមគ្គ និងផល ។

ក្នុងឧបាយជាគ្រឿងរលាស់ចេញទាំងនោះ បទថា **តតោ បណីតតរ-សទ្ធិន្ទ្រិយស្ស បដិលាភា** បានដល់ ដោយអំណាចការបានសទ្ធិន្ទ្រិយដែលប្រណីតជាងក្នុងខណៈនៃមគ្គ ជាងសទ្ធិន្ទ្រិយដែលប្រព្រឹត្តទៅហើយក្នុងខណៈនៃវិបស្សនានោះ ។ បទថា **បុរិមតរសទ្ធិន្ទ្រិយា និស្សដំ ហោតិ** បានដល់

សទ្ធិន្ទ្រិយក្នុងខណៈនៃមគ្គនោះ ចេញទៅហើយចាកសទ្ធិន្ទ្រិយ ដែលប្រព្រឹត្ត ទៅក្នុងខណៈនៃវិបស្សនា ដែលមានមុន ។ ដោយន័យនេះឯង គប្បីប្រកប សូម្បីសទ្ធិន្ទ្រិយ ក្នុងខណៈនៃផលនិងសទ្ធិន្ទ្រិយដ៏សេស ក្នុងខណៈទាំងពីរ នោះ ។

បទថា **បុព្វភាគេ បញ្ចហិ ឥន្ទ្រិយេហិ** បានដល់ ឧបាយជាគ្រឿង រលាស់ចេញ ៨ ដោយអំណាចនៃសមាបត្តិ ៨ មានបឋមជ្ឈានជាដើម ចាកឥន្ទ្រិយ ៥ ក្នុងឧបចារៈនៃបឋមជ្ឈាន ឧបាយជាគ្រឿងរលាស់ចេញ ១៨ ដោយអំណាចនៃមហាវិបស្សនា ១៨ មានអនិច្ចានុបស្សនាជាដើម ឧបាយ ជាគ្រឿងរលាស់ចេញ ដែលជាលោកុត្តរៈ ៨ ដោយអំណាចសោតាបត្តិមគ្គ ជាដើម ។ លោកសម្ដែងឧបាយជាគ្រឿងរលាស់ចេញ ៣៤ ដោយអំណាច នៃឈានសមាបត្តិ មហាវិបស្សនានិងមគ្គផល ដោយការឈានកន្លងឥន្ទ្រិយ មុនៗដោយប្រការដូច្នេះ ។ បទថា **នេក្ខម្មេ បញ្ចិន្ទ្រិយានិ** ជាដើម លោក សម្ដែងឧបាយ ជាគ្រឿងរលាស់ចេញ ៣៧ ដោយវត្ថុជាបដិបក្ខ ដោយ អំណាចការលះវត្ថុជាបដិបក្ខ ។ ក្នុងបទនោះ លោកពោលឧបាយជាគ្រឿង រលាស់ចេញ ៧ ក្នុងធម៌ ៧ មាននេក្ខម្មៈជាដើមដោយអំណាចនៃឧបចារភូមិ តែលោកមិនបានពោលដល់ផល ព្រោះមិនមានការលះធម៌ដែលជាបដិបក្ខ ។ បទថា **ឯកដ្ឋកាដ្ឋេហិ** មានវិគ្គហៈថា ឈ្មោះថា **ឯកដ្ឋកាដ្ឋេហិ** ព្រោះតាំងនៅ ក្នុងបុគ្គលម្នាក់ព្រមជាមួយទិដ្ឋិ រហូតដល់សោតាបត្តិមគ្គ ។ ចាកកិលេស ទាំងនោះ ដែលតាំងនៅក្នុងឋានៈតែមួយជាមួយទិដ្ឋិ ។ បទថា **ឱឡារិកេហិ**

បានដល់ ចាកកាមរាគៈ និងព្យាបាទៈដែលគ្រោតគ្រាត ។ បទថា **អណុ-សហគតេហិ** បានដល់ ចាកកាមរាគៈនិងព្យាបាទៈនោះឯងដែលជាចំណែកល្អិត ។ បទថា **សព្វកិលេសេហិ** បានដល់ចាកកិលេស មានរូបរាគៈជាដើម ដ្បិតថាកាលលះកិលេសទាំងនោះបានហើយក៏ឈ្មោះថា លះកិលេសទាំងពួងបាន ព្រោះហេតុនោះ ទើបលោកពោលថា **សព្វកិលេសេហិ** ។ តែក្នុងនិទ្ទេសនេះ បទទាំងឡាយដែលមានសេចក្ដីនៅមិនទាន់បានពោលទុកក៏មានន័យដូចពោលហើយនោះឯង ។

បទថា **សព្ពេសញ្ញេវ វីណាសវានំ តត្ថ តត្ថ បញ្ចិន្ទ្រិយានិ** បានដល់ ឥន្ទ្រិយ ៥ ក្នុងឋានៈនោះៗ បណ្ដាឋានៈទាំងឡាយ ដែលពោលទុកហើយក្នុងកាលមុនថា **អធិមោក្ខដ្ឋេន** ជាដើម ជាគុណជាតិដែលព្រះខីណាស្រពទាំងឡាយ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកទាំងឡាយរលាស់ចេញហើយចាកឋានៈនោះៗ តាមដែលប្រកបបាន ។ ក្នុងវារៈនេះលោកពោលដល់ន័យដែលបានពោលហើយក្នុងគ្រាដំបូង ដោយអំណាចនៃព្រះខីណាស្រព តាមដែលប្រកបបាន ។

និស្សរណៈទាំងនេះមាន ១៨០ តើដូចម្ដេច ។ លោកពោលទុកដូច្នេះថា ក្នុងបឋមវារៈ មាននិស្សរណៈទាំងអស់ ៩៦ គឺដែលលោកពោលទុកដោយអំណាចនៃមគ្គនិងផល ២៥ ដោយអំណាចការឈានកន្លង ៣៤ ដោយអំណាចជាបដិបក្ខ ៣៧ ។ ក្នុងទុតិយវារៈ កាលនាំនិស្សរណៈចេញ ១២ ដោយអំណាចនៃព្រះខីណាស្រពទាំងឡាយ និស្សរណៈទាំងនេះក៏មាន ៨៤ ។

និស្សរណៈដែលមានក្នុងកាលមុន ៩៦ និងនិស្សរណៈទាំងនេះ ៨៤ ទើបរួមជា ១៨០ ដោយប្រការដូច្នេះ ។

សម្រាប់ព្រះខីណាស្រព តើនិស្សរណៈ ១២ ពួកណា ដែលគប្បីនាំចេញនិស្សរណៈដែលគប្បីនាំចេញទាំង ១២ នេះ គឺបណ្តានិស្សរណៈដែលពោលហើយដោយការឈានកន្លងនិស្សរណៈ ៨ ដែលពោលដោយអំណាចនៃមគ្គនិងផល បណ្តានិស្សរណៈដែលពោលហើយដោយជាបដិបក្ខ និស្សរណៈ ៤ ដែលពោលដោយអំណាចនៃមគ្គ ។

ប្រសិនបើសួរថា ព្រោះហេតុអ្វី និស្សរណៈដែលពោលហើយ ដោយអំណាចនៃអរហត្តផលគប្បីនាំចេញ ឆ្លើយថា ព្រោះការបាននិស្សរណៈ ២៥ ដែលពោលទុកក្នុងកាលមុនបង្អស់ ដោយអំណាចនៃមគ្គនិងផលទើបឈ្មោះថា លោកពោលនិស្សរណៈដោយអំណាចនៃអរហត្តផលនោះឯង ។ ផលសមាបត្តិខាងលើៗ មិនចូលដល់ផលសមាបត្តិខាងក្រោមៗ ព្រោះហេតុនោះទើបមិនបានផលសូម្បី ៣ ក្នុងខាងក្រោមនោះឯង ។ម្យ៉ាងទៀត ឈានសមាបត្តិ វិបស្សនានិងនេក្ខម្មៈជាដើម ដែលព្រះខីណាស្រពរមែងបានដោយអំណាចនៃកិរិយាចិត្ត ។ ឥន្ទ្រិយទាំង ៥ នេះ រលាស់ចេញចាកធម៌ដែលជាបដិបក្ខ ព្រោះធម៌ដែលជាបដិបក្ខទាំងឡាយ ស្ងប់មុនហើយ ដោយប្រការដូច្នេះ ។

អដ្ឋកថា និស្សរណនិទ្ទេស ចប់

អដ្ឋកថា ទុតិយសុត្តន្តនិទ្ទេស ចប់

# តតិយសុត្តន្តនិទ្ទេស

[ ១៨៤-១៨៥ ] ព្រះសារីបុត្តត្ថេរ បំណងនឹងលើកព្រះសូត្រដទៃទៀត ហើយចង្អុលបង្ហាញដល់ការកំណត់ឥន្ទ្រិយ ទើបពោលពាក្យថា **បញ្ចិមានិ ភិក្ខវេ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **សោតាបត្តិយង្គេសុ** មានវិនិច្ឆ័យដូចតទៅនេះថា អរិយមគ្គមានអង្គ ៨ ឈ្មោះថា **សោត** ការដល់នូវការសម្រេចយ៉ាងបរិបូណ៌នូវសោតៈ ឈ្មោះថា **សោតាបត្តិ** អង្គ គឺសម្ភារៈនៃ **សោតាបត្តិ** ឈ្មោះថា អង្គនៃសោតាបត្តិ អង្គនៃការបានក្នុងចំណែកខាងដើមដោយភាពជាសោតាបន្ន បានដល់ អង្គនៃសោតាបត្តិ ៤ យ៉ាង ទាំងនេះគឺ ការសេពគប់សប្បុរសជាអង្គនៃសោតាបត្តិ ១ ការស្ដាប់សទ្ធម្មជាអង្គនៃសោតាបត្តិ ១ យោនិសោមនការជាអង្គនៃសោតាបត្តិ ១ ការបដិបត្តិធម៌សមគួរដល់ធម៌ជាអង្គនៃសោតាបត្តិ ១ ។ បទដ៏សេស ខ្ញុំធ្លាប់ពោលទុកហើយនោះឯង ។

ម្យ៉ាងទៀត បទនេះលោកពោលដើម្បីសម្ដែងភាពដែលឥន្ទ្រិយទាំងនេះជាធំក្នុងវិស័យរបស់ខ្លួន ។ ប្រៀបដូចសេដ្ឋីបុត្ត ៤ នាក់ កាលសម្លាញ់មានព្រះរាជាដែលជាធំជាគម្រប់ ៥ ដើរទៅតាមផ្លូវ ដោយគិតថានឹងលេងនក្ខត្តឫក្ស កាលទៅដល់ផ្ទះរបស់សេដ្ឋីបុត្តទី ១ ជន ៤ នាក់ទៀតក្រៅពីនោះអង្គុយព្រងើយ ម្ចាស់ផ្ទះប៉ុណ្ណោះចាត់ចែងថា ពួកអ្នកចូរឲ្យខាទនីយៈភោជនីយៈដល់សម្លាញ់ទាំងនេះ ពួកអ្នកចូរឲ្យគ្រឿងក្រអូប ផ្កានិងគ្រឿង

ប្រដាប់ជាដើម ដល់សម្លាញ់ទាំងនេះ ហើយដើរត្រួតពិនិត្យក្នុងផ្ទះ កាលទៅដល់ផ្ទះជនទី ២ ទី ៣ ទី ៤ ជន ៤ នាក់ទៀតក្រៅពីនោះអង្គុយព្រងើយ ម្ចាស់ផ្ទះប៉ុណ្ណោះ ចាត់ចែងថា ពួកអ្នកចូរឲ្យខាទនីយៈ ភោជនីយៈដល់សម្លាញ់ទាំងនេះ ពួកអ្នកចូរឲ្យគ្រឿងក្រអូប ផ្កានិងគ្រឿងប្រដាប់ជាដើមដល់សម្លាញ់ទាំងនេះហើយដើរត្រួតពិនិត្យក្នុងផ្ទះ ។ កាលទៅដល់ព្រះរាជដំណាក់របស់ព្រះរាជាជាខាងក្រោយ ព្រះរាជាជាធំក្នុងទីទាំងពួងក៏ពិត តែក្នុងកាលនោះ ក៏ទ្រង់ចាត់ចែងថា ពួកអ្នកចូរឲ្យខាទនីយៈ ភោជនីយៈ ដល់សម្លាញ់ទាំងនេះ ចូរឲ្យគ្រឿងក្រអូប ផ្កានិងគ្រឿងប្រដាប់ដល់សម្លាញ់ទាំងនេះហើយ ទ្រង់យាងត្រួតពិនិត្យក្នុងព្រះរាជដំណាក់របស់ព្រះអង្គយ៉ាងណា កាលឥន្ទ្រិយទាំង ៥ មានសទ្ធាជាដើមកើតឡើងក្នុងអារម្មណ៍តែមួយ ដូចកាលសម្លាញ់ទាំងនោះដើរទៅតាមផ្លូវរួមគ្នា កាលដល់ផ្ទះជនទី ១ ជន ៤ នាក់ទៀតក្រៅអំពីនោះអង្គុយព្រងើយ ម្ចាស់ផ្ទះប៉ុណ្ណោះដើរត្រួតពិនិត្យយ៉ាងណា សទ្ធិន្ទ្រិយមានលក្ខណៈបង្អោនចិត្តជឿ ដែលសម្រេចអង្គនៃសោតាបត្តិហើយ រមែងជាធំ ជាប្រធានក៏យ៉ាងនោះ ឥន្ទ្រិយដ៏សេសរមែងអនុលោមតាមសទ្ធិន្ទ្រិយទៅ ។

កាលដល់ផ្ទះជនទី ២ ជន ៤ នាក់ទៀតក្រៅអំពីនោះអង្គុយព្រងើយ ។ ម្ចាស់របស់ផ្ទះប៉ុណ្ណោះដើរត្រួតពិនិត្យ យ៉ាងណា វីរិយិន្ទ្រិយប៉ុណ្ណោះ ដែលមានលក្ខណៈផ្គងទុក ដែលសម្រេចសម្មប្បធានហើយរមែងជាធំ ជាប្រធានយ៉ាងនោះ ឥន្ទ្រិយដ៏សេសអនុលោមតាមវីរិយិន្ទ្រិយទៅ ។

កាលដល់ផ្ទះជនទី ៣ ជន ៤ នាក់ទៀតក្រៅអំពីនោះអន្ទុយព្រងើយ ។ ម្ចាស់របស់ផ្ទះប៉ុណ្ណោះដើរត្រួតពិនិត្យ យ៉ាងណា សតិន្ទ្រិយប៉ុណ្ណោះ មានលក្ខណៈប្រាកដ ដែលសម្រេចសតិប្បដ្ឋានហើយ រមែងជាធំ ជាប្រធាន ក៏យ៉ាងនោះ ឥន្ទ្រិយដ៏សេសអនុលោមតាមសតិន្ទ្រិយទៅ ។

កាលដល់ផ្ទះជនទី ៤ ជន ៤ នាក់ទៀតក្រៅអំពីនោះ អន្ទុយព្រងើយ ម្ចាស់របស់ផ្ទះប៉ុណ្ណោះដើរត្រួតពិនិត្យ យ៉ាងណា សមាធិន្ទ្រិយប៉ុណ្ណោះដែលមានលក្ខណៈមិនរាយមាយ ដែលសម្រេចឈានហើយរមែងជាធំ ជាប្រធាន យ៉ាងនោះ ឥន្ទ្រិយដ៏សេសអនុលោមសតាមសមាធិន្ទ្រិយទៅ ។

ក្នុងកាលទៅដល់ព្រះរាជដំណាក់របស់ព្រះរាជា ជន ៤ នាក់ ទៀតក្រៅអំពីនោះ អន្ទុយព្រងើយ ព្រះរាជាប៉ុណ្ណោះទ្រង់យាងត្រួតពិនិត្យ យ៉ាងណា បញ្ញិន្ទ្រិយប៉ុណ្ណោះ មានលក្ខណៈដឹងទូទៅ ដែលសម្រេចអរិយសច្ចៈហើយ រមែងជាធំ ជាប្រធាន ក៏យ៉ាងនោះ ឥន្ទ្រិយដ៏សេសអនុលោមតាមបញ្ញិន្ទ្រិយទៅ ដោយប្រការដូច្នេះ ។

## បភេទគណននិទ្ទេស

[ ១៤៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបភេទគណននិទ្ទេស ដែលជាខាងដើមនៃពាក្យសួរដល់ចំនួនប្រភេទនៃព្រះសូត្រ ដូចតទៅនេះថា បទថា **សប្បុរិស-សំសេវេ** បានដល់ ក្នុងការសេពគប់មនុស្សល្អដោយប្រពៃ ។ បទថា **អធិ-**

**មោក្ខាធិបតេយ្យដ្ឋេន** បានដល់ ដោយអត្ថថា សទ្ធាជាធំក្នុងឥន្ទ្រិយដ៏សេស ពោលគឺការបង្អោនចិត្តជឿ អធិប្បាយថា ដោយអត្ថ គឺជាប្រធាននៃឥន្ទ្រិយដ៏សេស ។ បទថា **សទ្ធម្មសវនេ** មានវិគ្គហៈថា ធម៌របស់សប្បុរសឬធម៌ស្អាត ព្រោះហេតុនោះទើបឈ្មោះថា ធម៌របស់លោក ( សប្បុរស ) ក្នុងការស្តាប់ធម៌របស់លោកនោះ ។ បទថា **យោនិសោមនសិការេ** បានដល់ការធ្វើទុកក្នុងចិត្តដោយឧបាយ ។ ក្នុងបទថា **ធម្មានុធម្មប្បដិបត្តិយា** គប្បីជ្រាបសេចក្តីដូច្នេះថា ធម៌ដែលចូលដល់លោកុត្តរធម៌ ៩ ឈ្មោះថា **ធម្មា-នុធម្ម** ការបដិបត្តិ គឺការបំពេញនូវធម្មានុធម្មៈ ដែលបានដល់សីល សមាធិ បញ្ញា ឈ្មោះថា **ធម្មានុធម្មប្បដិបត្តិ** ។ ក្នុង **សម្មប្បធាន** ជាដើម ក៏មានន័យនេះដូចគ្នា ។

*អដ្ឋកថា បភេទគណននិទ្ទេស ចប់*

# ចរិយាវារ

[ ១៤៧-១៥៦ ] ក្នុងចរិយាវារៈ គប្បីជ្រាបសេចក្តីដោយន័យនេះដូចគ្នា ។ លោកពោលបឋមវារៈដោយអំណាចនៃវេលាកើតឡើងនៃឥន្ទ្រិយទាំងឡាយតែម្យ៉ាង លោកពោលចរិយាវារៈ ដោយអំណាចនៃវេលាសេពនិងដោយអំណាចនៃវេលាបរិបូណ៌នៃឥន្ទ្រិយទាំងឡាយ ដែលកើតហើយ ។

ពិតណាស់ ពាក្យថា ចរិយា បកតិ ឧស្សន្នតា ( ការប្រព្រឹត្តប្រក្រតីភាព ធម៌ដែលច្រើនក្នុងចិត្ត ) ដោយសេចក្តីក៏ដូចគ្នានោះឯង ។

## អដ្ឋកថា ចរិយាវារៈ ចប់

# ចារវិហារនិទ្ទេស

[ ១៥៧ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរបំណងចង្អុលបង្ហាញការកំណត់ឥន្ទ្រិយ ដោយបរិយាយដទៃ ដោយអំណាចនៃការចង្អុលបង្ហាញការប្រព្រឹត្តនិងវិហារធម៌ដែលសម្ពន្ធជាមួយចរិយានោះឯង ទើបលើកមាតិកាថា **ចារោ ច វិហារោ ច** ជាដើម ហើយពោលចង្អុលបង្ហាញមាតិការនោះ ។ ក្នុងបទទាំងនោះ ជាបឋមក្នុងឧទ្ទេសគប្បីជ្រាបសម្ពន្ធនៃឧទ្ទេសថា សព្រហ្មចារីដែលដឹងច្បាស់ ជឿមាំក្នុងបុគ្គលដែលប្រព្រឹត្ត ក្នុងឋានៈដែលជ្រាលជ្រៅថា បុគ្គលនេះសម្រេចហើយឬថានឹងសម្រេចដោយពិត យ៉ាងណា ការប្រព្រឹត្តនិងវិហារធម៌របស់បុគ្គលដែលដល់ព្រមដោយឥន្ទ្រិយក៏ឈ្មោះថាសព្រហ្មចារីដែលដឹងច្បាស់ ត្រាស់ដឹងហើយ ចាក់ធ្លុះហើយក៏យ៉ាងនោះ ។

ចរិយាក្នុងឧទ្ទេសនិងនិទ្ទេស ក៏គឺការប្រព្រឹត្តនោះឯង ពាក្យថា **ចារោ** និង **ចរិយា** ដោយអត្ថក៏ដូចគ្នានោះឯង ព្រោះហេតុនោះក្នុងនិទ្ទេសនៃពាក្យថា **ចារោ** លោកពោលថា **ចរិយា** ។ បទថា **ឥរិយាបថចរិយា** បានដល់

ការប្រព្រឹត្តិ អធិប្បាយថា ការប្រព្រឹត្តទៅនៃឥរិយាបថទាំងឡាយ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ចំណែកសេចក្ដីផ្សេងគ្នាមានដូច្នេះថា អាយតនចរិយា គឺការប្រព្រឹត្តិនៃសតិសម្បជញ្ញៈក្នុងអាយតនៈទាំងឡាយ ។ បទថា **បត្តិ** បានដល់ ផល ។ ពិតហើយ ផលទាំងនោះ ដែលបុគ្គលរមែងសម្រេច ព្រោះហេតុនោះទើបហៅថា **បត្តិ** ។ ប្រយោជន៍ក្នុងបច្ចុប្បន្ន និងក្នុងកពខាងមុខរបស់សត្វលោក ឈ្មោះថា **លោកត្ថ** ។

ឥឡូវនេះព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងភូមិរបស់ចរិយាទាំងនោះទើបលោកពោលពាក្យថា **ចតូសុ ឥរិយាបថេសុ** ជាដើម ។ បទថា **សតិប្ប-ដ្ឋានេសុ** បានដល់ ក្នុងអារម្មណ៍ដែលជាសតិប្បដ្ឋាន ។ កាលពោលដល់សតិប្បដ្ឋាន លោកក៏ពោលធ្វើពាក្យមិនឲ្យដទៃអំពីសតិ ឲ្យដូចជាដទៃដោយអំណាចនៃវោហារ ។

បទថា **អរិយសច្ចេសុ** លោកពោលដោយអំណាចការកំណត់កាន់យកសច្ចៈញែកចេញមក ដោយលោកិយសច្ចញាណដែលជាចំណែកខាងដើម ។ បទថា **អរិយមគ្គេសុ សាមញ្ញផលេសុ** លោកពោលដោយអំណាចនៃវោ-ហារប៉ុណ្ណោះ ។ បទថា **បទេសេ** បានដល់ ជាឯកទេសក្នុងការប្រព្រឹត្តិកិច្ចដែលជាប្រយោជន៍ដល់លោក ។ ពិតណាស់ ព្រះពុទ្ធទាំងឡាយរមែងទ្រង់ធ្វើលោកត្ថចរិយា ដោយមិនមានចំណែកខ្វះ ។ ព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងចរិយាទាំងនោះទៀត ដោយអំណាចនៃការកបុគ្គល ទើបពោលពាក្យថា **បណិធិសម្បន្នានំ** ជាដើម ក្នុងបទនោះ លោកអ្នកមានឥរិយាបថមិន

កម្រើក ដល់ព្រមដោយការឃុំគ្រងឥរិយាបថ ព្រោះឥរិយាបថស្ងប់ គឺដល់ព្រមដោយឥរិយាបថដែលស្ងប់ សមគួរដល់ភាវៈជាភិក្ខុ ឈ្មោះថា ដែលបរិបូរណ៍ដោយឥរិយាបថស្រគត់ស្រគំ ។ បទថា **ឥន្ទ្រិយេសុ គុត្តទ្វារានំ** មានវិគ្គហៈថា ឈ្មោះថា ដែលមានទ្វារគ្រប់គ្រងហើយ ព្រោះអត្ថថា កាលឥន្ទ្រិយ ៦ មាន ចក្ខុន្ទ្រិយជាដើម ប្រព្រឹត្តទៅហើយក្នុងវិស័យរៀងៗខ្លួន បុគ្គលគ្រប់គ្រងទ្វារ ដោយអំណាចនៃទ្វារនីមួយៗ ។ របស់លោកអ្នកមានទ្វារគ្រប់គ្រងហើយទាំងនោះ ។ ក្នុងពាក្យថា ទ្វារ នេះ បានដល់ ចក្ខុជាដើម ដោយអំណាចនៃទ្វារដែលកើតឡើង ។ បទថា **អប្បមាទវិហារីនំ** បានដល់ ដែលនៅដោយការមិនប្រមាទក្នុងសីលជាដើម ។ បទថា **អធិចិត្តមនុយុត្តានំ** បានដល់ អ្នកបំពេញសមាធិដែលបានដល់អធិចិត្ត ដោយភាពជាបាទនៃវិបស្សនា ។ បទថា **ពុទ្ធិសម្បន្នានំ** បានដល់ អ្នកដល់ព្រមដោយញាណ ដែលប្រព្រឹត្តទៅហើយ តាំងអំពីកំណត់នាមរូប រហូតដល់គោត្រភូ ។ បទថា **សម្មាបដិបន្នានំ** បានដល់ ក្នុងខណៈនៃមគ្គ ៤ ។ បទថា **អធិគតផលានំ** បានដល់ ក្នុងខណៈនៃផល ៤ ។ បទថា **អធិមុច្ចន្តោ** បានដល់ អ្នកធ្វើការបង្អោនចិត្តជឿ ។ បទថា **សទ្ធាយ ចរតិ** បានដល់ ប្រព្រឹត្តទៅដោយអំណាចនៃសទ្ធា ។ បទថា **បគ្គណ្ហន្តោ** បានដល់ តាំងទុកដោយសេចក្តីព្យាយាម គឺ សម្មប្បធាន ៤ ។ បទថា **ឧបដ្ឋាបេន្តោ** បានដល់ ចូលទៅតាំងអារម្មណ៍ ទុកដោយសតិ ។ បទថា **អវិក្ខេបំ ករោន្តោ** បានដល់ មិនធ្វើសេចក្តីរាយមាយ ដោយអំណាចនៃ

សមាធិ ។ បទថា **បជានន្តោ** បានដល់ ដឹងច្បាស់ដោយបញ្ញាជាគ្រឿង ដឹងច្បាស់អរិយសច្ចៈ ៤ ។ បទថា **វិជានន្តោ** បានដល់ ដឹងច្បាស់អារម្មណ៍ ដោយអាវជ្ជនចិត្តដែលជាប្រធាននៃជវនចិត្តដែលសម្បយុត្តដោយឥន្ទ្រិយ ។ បទថា **វិញ្ញាណចរិយាយ** បានដល់ ដោយអំណាចនៃការប្រព្រឹត្តិដោយ អាវជ្ជនចិត្ត ។ បទថា **ឯវំ បដិបន្នស្ស** បានដល់ របស់អ្នកបដិបត្តិដោយ ការប្រព្រឹត្តិនៃឥន្ទ្រិយព្រមដោយជវនចិត្ត ។ បទថា **កុសលា ធម្មា អា-យាបេន្តិ** បានដល់ កុសលធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅហើយ ដោយ អំណាចនៃសមថៈ និងវិបស្សនា រមែងញ៉ាំងផលដែលគួរប្រាថ្នាក្រៃលែងឲ្យ ប្រព្រឹត្តទៅ អធិប្បាយថា រមែងប្រព្រឹត្តទៅ ។ បទថា **អាយតនចរិយាយ** បានដល់ ប្រព្រឹត្តដោយសេចក្ដីព្យាយាមដ៏កំពូលនៃកុសលធម៌ទាំងឡាយ ។ លោកពោលអធិប្បាយថា ប្រព្រឹត្តដោយការបន្ត ដោយការប្រព្រឹត្តិទៅ ។ បទថា **វិសេសមធិគច្ឆតិ** បានដល់ សម្រេចគុណវិសេសដោយអំណាចនៃ វិក្ខម្ភនប្បហាន តទង្គប្បហាន សមុច្ឆេទប្បហាន និងបដិប្បស្សទ្ធិប្បហាន ។ បទថា **ឧស្សនចរិយា** ជាដើម មានសេចក្ដីដូចពោលហើយនោះឯង ។

[ ១៥៨ ] ក្នុងបទថា **សទ្ធាយ វិហរតិ** ជាដើម គប្បីឃើញការនៅ ដោយឥរិយាបថ របស់បុគ្គលដែលដល់ព្រមដោយសទ្ធាជាដើម ។ បទថា **អនុពុទ្ធោ** បានដល់ ដោយការដឹងដែលគិតស្មាន ។ បទថា **បដិវិទ្ធោ** បាន ដល់ ដោយការដឹងប្រចក្សច្បាស់ ។ ព្រោះកាលការបង្អោនចិត្តជឿជាដើម ដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ការប្រព្រឹត្តិនិងវិហារធម៌ ឈ្មោះ

ថា ត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ហេតុនោះ ការបង្អោនចិត្តជឿជាដើម ក្នុងការត្រាស់ដឹងនិងការចាក់ធ្លុះ ឈ្មោះថា លោកសម្តែងហើយ ។ បទថា **ឯវំ** ក្នុងបទថា **ឯវំ សន្តាយ ចរន្តំ** ព្រះសារីបុត្តត្ថេរ កាលចង្អុលបង្ហាញដល់ប្រការដូចពោលហើយ រមែងចង្អុលដល់អត្ថនៃ **យថា** សព្វ ។ សូម្បីក្នុងបទថា **វិញ្ញូ** ជាដើម មានវិគ្គហៈដូច្នេះថា ឈ្មោះថា **វិញ្ញូ** ព្រោះដឹងតាមសភាវៈពិត ។ ឈ្មោះថា **វិភាវី** ព្រោះញុំាងសភាវៈដែលដឹងហើយឲ្យជាក់ច្បាស់ គឺ ធ្វើឲ្យប្រាកដ ។ ឈ្មោះថា **មេធា** ព្រោះអត្ថថា ទម្លាយ គឺបៀតបៀនកិលេស ដូចរន្ទះទម្លាយភ្នំថ្មដូច្នោះ ឬឈ្មោះថា **មេធា** ព្រោះអត្ថថា ចងចាំទុកបានរហ័ស ឈ្មោះថា **មេធាវី** ព្រោះអត្ថថា ជាអ្នកមានបញ្ញាទម្លាយកិលេស ។ ឈ្មោះថា **បណ្ឌិតា** ព្រោះដល់ទៅ ប្រព្រឹត្តទៅដោយញាណគតិ ។ ឈ្មោះថា **ពុទ្ធិសម្បន្នា** ព្រោះជាអ្នកដល់ព្រមដោយពុទ្ធិ-សម្បទា ។ ឈ្មោះថា **សព្រហ្មចារិនោ** ព្រោះប្រព្រឹត្តព្រហ្មចរិយៈ គឺបដិបទាដ៏ខ្ពង់ខ្ពស់រួមគ្នា ។

កម្ម ៤ យ៉ាង មានអបលោកនកម្មជាដើម ឈ្មោះថា **ឯកំ កម្មំ** ដោយអំណាចធ្វើរួមគ្នា ។

ដូចគ្នានេះដែរឧទ្ទេសនៃបាតិមោក្ខ ៥ យ៉ាង ឈ្មោះថា **ឯកុទ្ទេសោ** ។

ឈ្មោះថា **សមសិក្ខា** ព្រោះមានការសិក្សាស្មើគ្នា ភាពជាអ្នកមានការសិក្សាស្មើគ្នា ឈ្មោះថា **សមសិក្ខតា** អាចារ្យពួកខ្លះ ពោលថា **សម-សិក្ខាតា** ក៏មាន ។ លោកអធិប្បាយថា អ្នកមានកម្មដូចគ្នា មានឧទ្ទេស

ដូចគ្នា មានការសិក្សាស្មើគ្នា ឈ្មោះថា **សព្រហ្មចារី** ។ កាលគួរពោលថា **ឈានានិ** លោកធ្វើលិង្គវិបល្លាសជា**ឈានា** ។ បទថា **វិមោក្ខា** បានដល់ វិមោក្ខ ៣ ឬវិមោក្ខ ៨ ។ បទថា **សមាធិ** បានដល់ សមាធិ ៣ មាន វិតក្កៈមានវិចារៈ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មិនមានវិតក្កៈមិនមាន វិចារៈ ។ បទថា **សមាបត្តិយោ** បានដល់ សុញ្ញតសមាបត្តិ អនិមិត្ត-សមាបត្តិ និងអប្បណិហិតសមាបត្តិ ។ បទថា **អភិញ្ញាយោ** បានដល់ អភិញ្ញា ៦ ។ ឈ្មោះថា **ឯកំសោ** ព្រោះជាចំណែកម្ខាង គឺចំណែកមួយ មិនមានចំណែកទី ២ ។ ពាក្យពោលដល់ប្រយោជន៍ចំណែកមួយ ឈ្មោះថា **ឯកំសវចនំ** ។ ក្នុងបទដ៏សេស គប្បីធ្វើការប្រកបយ៉ាងនេះ ។ តែដោយ ពិសេស ឈ្មោះថា **សំសយោ** ព្រោះទៅ គឺប្រព្រឹត្តទៅស្មើឬដោយជុំវិញ ។ ឈ្មោះថា **និស្សំសយោ** ព្រោះមិនជាទីសង្ស័យ ។ ឈ្មោះថា **កង្ខា** ព្រោះ រឿងមួយក៏កាត់សម្រេចមិនបាននៅសន្ទិះសង្ស័យ សូម្បីរឿងដទៃ ។ ឈ្មោះ ថា **និក្កង្ខា** ព្រោះមិនជាទីសន្ទិះសង្ស័យ ។ ភាពជាចំណែក ២ ឈ្មោះថា **ទ្វេជ្ឈំ** ។ ឈ្មោះថា **អទ្វេជ្ឈា** ព្រោះជាទីមិនមានចំណែក ២ ។ ឈ្មោះថា **ទ្វេឡ្ហកំ** ព្រោះកម្រើកញាប់ញ័រ ញាប់ញ័រដោយពីរចំណែក ។ ឈ្មោះថា **អទ្វេឡ្ហកោ** ព្រោះមិនមានការញាប់ញ័រជាពីរចំណែក ។

ការពោលដោយចង្អុលបង្ហាញដោយស្រោចស្រង់ ឈ្មោះថា **និយោគ-វចនំ** អាចារ្យពួកខ្លះពោលថា **និយ្យោគវចនំ** ក៏មាន ។ ពាក្យពោលអត្ថ ដែលកំណត់មិនខុស មិនភ្លាំងភ្លាត់ ឈ្មោះថា **អបណ្ណកវចនំ** ។ បទថា

**អវត្ថាបនវចនំ** បានដល់ ពាក្យកាត់ផ្តាច់ ។ ពាក្យទាំងអស់នោះជាវេវចនៈរបស់សេចក្តីសង្ស័យ ។

ឈ្មោះថា **បិយវចនំ** ព្រោះជាពាក្យពោលគួរស្រឡាញ់ ដោយមានប្រយោជន៍គួរស្រឡាញ់ ។ បទថា **គរុវចនំ** ក៏មានន័យដូចគ្នា ។ ពាក្យពោលប្រព្រឹត្តទៅដោយការគោរព គឺដោយសេចក្តីគោរព ឈ្មោះថា **ស-គារវំ** ។ ការកោតក្រែង ឈ្មោះថា **បតិស្សវ** អធិប្បាយថា មិនដេកមិនអង្គុយ ព្រោះធ្វើសេចក្តីគោរពអ្នកដទៃ ។ ម្យ៉ាងទៀត ការទទួលពាក្យឈ្មោះថា **បតិស្សវ** អធិប្បាយថា ស្តាប់ពាក្យអ្នកដទៃ ព្រោះប្រព្រឹត្តឱនលំទោន ។ ដោយប្រការទាំង ២ ពាក្យនេះ ជាឈ្មោះរបស់ភាពជាធំនៃអ្នកដទៃ ។ ឈ្មោះថា **សគារវំ** ព្រោះប្រព្រឹត្តទៅដោយសេចក្តីគោរព ។ ឈ្មោះថា **សប្បតិស្សយំ** ព្រោះប្រព្រឹត្តទៅដោយការកោតក្រែងឬការស្តាប់បង្គាប់ ។ ម្យ៉ាងទៀត កាលគួរពោលថា **សប្បតិស្សវំ** លោកពោលថា **សប្បតិស្សំ** ព្រោះលុប **យ** អក្ខរៈ ឬ **វ** អក្ខរៈ ។ ពាក្យដែលពីរោះជាង ឈ្មោះថា **អធិវចនំ** ។ ឈ្មោះថា **សគារវសប្បតិស្សំ** ព្រោះមានការគោរពនិងមានការកោតក្រែង ។ ពាក្យពោលមានការគោរពកោតក្រែង ឈ្មោះថា **សគារវសប្បតិស្សាធិវចនំ** ។ ក្នុងបទទាំងពីរនេះ លោកពោលថា **ឯតំ** ម្តងហើយម្តងទៀត ដោយអំណាចសេចក្តីផ្សេងគ្នានៃការកំណត់វេវចនៈ ។ បទថា **បត្តោ វា ធាបុណិស្សតិ វា** បានដល់ នូវឈានជាដើមនោះឯង ។

អដ្ឋកថា ចារវិហារនិទ្ទេស ចប់

អដ្ឋកថា តតិយសុត្តន្តនិទ្ទេស ចប់

# ចតុត្ថសុត្តន្តនិទ្ទេស

[ ១៥៩ ] ព្រះសារីបុត្តត្ថេរ កាលលើកព្រះសូត្រទី ១ មកហើយ ទើបចង្អុលបង្ហាញឥន្ទ្រិយទាំងឡាយ ដោយអាការដទៃទៀត ។ ក្នុងបទទាំងនោះ បទថា **កតិហាការេហិ កេនដ្ឋេន ទដ្ឋព្វានិ** បានដល់ គប្បីឃើញដោយអាការប៉ុន្មាន ។ ដោយបទថា **កេនដ្ឋេន ទដ្ឋព្វានិ** ព្រះសារីបុត្តត្ថេរសួរដល់អាការដែលគប្បីឃើញនិងអត្ថដែលគប្បីឃើញ ។ បទថា **ឆហា-ការេហិ កេនដ្ឋេន ទដ្ឋព្វានិ** បានដល់ គប្បីឃើញដោយអាការ ៦ គប្បីឃើញដោយអត្ថ ពោលគឺអាការ ៦ នោះឯង ។ បទថា **អាធិបតេយ្យដ្ឋេន** បានដល់ ដោយអត្ថថា ភាពជាធំ ។ បទថា **អាទិវិសោធនដ្ឋេន** បានដល់ ដោយអត្ថថា ជាគ្រឿងជម្រះសីលដែលជាខាងដើមនៃកុសលធម៌ទាំងឡាយ ។ បទថា **អធិមត្តដ្ឋេន** បានដល់ ដោយអត្ថថា មានកម្លាំង ពិតហើយ វត្ថុដែលមានកម្លាំង លោកហៅថា **អធិមត្តំ** ព្រោះមានប្រមាណក្រៃលែង ។ បទថា **អធិដ្ឋានដ្ឋេន** បានដល់ ដោយអត្ថថា ប្រតិស្ឋានមាំទាំ ។ បទថា **បរិយាទានដ្ឋេន** បានដល់ ដោយអត្ថថា អស់ទៅ ។ បទថា **បតិដ្ឋា-បកដ្ឋេន** បានដល់ ដោយអត្ថថា ឲ្យតាំងនៅ ។

# អាធិបតេយ្យដ្ឋនិទ្ទេស

[ ១៦០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាធិបតេយ្យដ្ឋនិទ្ទេស ដូចតទៅនេះថា ការពោលដល់ការលះធម៌ដែលជាបដិបក្ខនៃឥន្ទ្រិយនីមួយៗ មាន **អស្សទ្ធិយំ បជហតោ** ជាដើម លោកពោលដើម្បីការសម្រេចភាពជាអធិបតី ក្នុងការសម្រេចកិច្ចនៃការលះធម៌ជាបដិបក្ខរៀងៗខ្លួន សូម្បីក្នុងខណៈមួយ ។

លោកពោលដល់ឥន្ទ្រិយ ៤ ដ៏សេស ធ្វើឲ្យសម្បយុត្តដោយឥន្ទ្រិយនោះឯង ។ ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលធ្វើឥន្ទ្រិយនីមួយៗឲ្យជាធុរៈក្នុងខណៈផ្សេងៗគ្នា ហើយធ្វើឥន្ទ្រិយនោះៗ ឲ្យជាធំជាងធម៌ ដែលជាបដិបក្ខនោះៗ ហើយធ្វើឥន្ទ្រិយដ៏សេសឲ្យអនុលោមតាមឥន្ទ្រិយនោះទៅ ។ ចំណែកបទថា **កាមច្ឆន្ទំ បជហតោ** ជាដើម លោកពោលដោយអំណាចនៃខណៈមួយនោះឯង ។

អដ្ឋកថា អាធិបតេយ្យដ្ឋនិទ្ទេស ចប់

# អាធិវិសោធនដ្ឋនិទ្ទេស

[ ១៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាទិវិសោធនដ្ឋនិទ្ទេស ដូចតទៅនេះថា បទថា **អស្សទ្ធិយសំវរដ្ឋេន សីលវិសុទ្ធិ** បានដល់ ឈ្មោះថា សីលវិសុទ្ធិ ព្រោះជាគ្រឿងជម្រះមន្ទិលនៃសីលដោយអត្ថថា ហាម គឺដោយអត្ថថា វៀរនូវការមិនមានសទ្ធា ។

បទថា **សទ្ធិន្ទ្រិយស្ស អាធិវិសោធនា** បានដល់ ជាគ្រឿងជម្រះសីលដែលជាខាងដើម ដោយអំណាចជាឧបនិស្សយប្បច្ច័យដល់សទ្ធិន្ទ្រិយ ។ គប្បីជ្រាបឥន្ទ្រិយដ៏សេសនិងឥន្ទ្រិយ ដែលជាហេតុនៃការសង្រួមកាមច្ឆន្ទៈជាដើមដោយន័យនេះ ។

*អដ្ឋកថា អាទិវិសោធនដ្ឋនិទ្ទេស ចប់*

# អធិមត្តដ្ឋនិទ្ទេស

[ ១៦២-១៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអធិមត្តដ្ឋនិទ្ទេស ដូចតទៅនេះថា បទថា **សទ្ធិន្ទ្រិយស្ស ភាវនាយ ឆន្ទោ ឧប្បជ្ជតិ** បានដល់ ធម្មច្ឆន្ទៈដែលជាកុសល រមែងកើតក្នុងសទ្ធិន្ទ្រិយ ព្រោះស្តាប់ធម៌ដែលបដិសំយុត្ត ដោយសទ្ធារបស់បុគ្គលអ្នកមានសទ្ធាឬព្រោះឃើញគុណនៃការចម្រើនសទ្ធិន្ទ្រិយ ។ បទថា **បាមោជ្ជំ ឧប្បជ្ជតិ** បានដល់ បីតិស្រទន់ រមែងកើតឡើងព្រោះឆន្ទៈកើត ។ បទថា **បីតិ ឧប្បជ្ជតិ** បានដល់ បីតិ មានកម្លាំងរមែងកើតឡើងព្រោះបាមោជ្ជៈ ។ បទថា **បស្សទ្ធិ ឧប្បជ្ជតិ** បានដល់ កាយបស្សទ្ធិនិងចិត្តបស្សទ្ធិរមែងកើតឡើងព្រោះការឆ្អែតដោយបីតិ ។ បទថា **សុខំ ឧប្បជ្ជតិ** បានដល់ សេចក្តីសុខផ្លូវចិត្ត រមែងកើតឡើង ព្រោះកាយនិងចិត្តស្ងប់ ។ បទថា **ឱភាសោ ឧប្បជ្ជតិ** បានដល់ ពន្លឺគឺបញ្ញា រមែងកើតឡើង ព្រោះជោរជន់ដោយសេចក្តីសុខ ។ បទថា **សំវេគោ ឧប្បជ្ជតិ** បានដល់ សេចក្តីសង្វេគព្រោះការប្រែប្រួលនៃសង្ខារ រមែងកើតឡើងព្រោះដឹងច្បាស់នូវទោសនៃសង្ខារដោយពន្លឺគឺបញ្ញា ។ បទថា **សំវេជេត្វា ចិត្តំ សមាទហតិ** បានដល់ បុគ្គលធ្វើសេចក្តីសង្វេគឲ្យកើតឡើងហើយ ធ្វើចិត្តឲ្យជាសមាធិ ដោយសេចក្តីសង្វេគនោះឯង ។ បទថា **សាធុកំ បគ្គណ្ហាតិ** បានដល់ ដោះនូវការរួញរានិងការរាយមាយចេញបានហើយ រមែងផ្គងទុកដោយល្អ ។ បទថា **សាធុកំ អជ្ឈុបេក្ខតិ** បានដល់ ព្រោះសេចក្តីព្យាយាមប្រព្រឹត្តទៅយ៉ាងស្មើ បុគ្គលកាលមិនធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងការប្រកបសេចក្តីព្យាយាមស្មើទៀត

ឈ្មោះថា រមែងព្រងើយកន្តើយដោយប្រពៃ ដោយអំណាចតត្រមជ្ឈត្តុបេក្ខា ។ បទថា **ឧបេក្ខាវសេន** បានដល់ ដោយអំណាចតត្រមជ្ឈត្តុបេក្ខាដែលមានការនាំទៅស្មើជាលក្ខណៈ ។ បទថា **នានត្តកិលេសេហិ** បានដល់ ចាកកិលេសដែលមានសភាពផ្សេងៗ ដែលជាបដិបក្ខដល់វិបស្សនា ។ បទថា **វិមោក្ខាវសេន** បានដល់ ដោយអំណាចនៃការរួចផុតចាកកិលេសផ្សេងៗ តាំងអំពីភង្គានុបស្សនា ។ បទថា **វិមុត្តត្តា** បានដល់ ព្រោះចិត្តរួចផុតចាកកិលេសផ្សេងៗ ។ បទថា **តេ ធម្មា** បានដល់ ធម៌ទាំងឡាយ មានឆន្ទៈជាដើម ។ បទថា **ឯករសា ហោន្តិ** បានដល់ មានរសតែមួយ ដោយវិមុត្តិរស ។ បទថា **ភាវនាវសេន** បានដល់ ដោយអំណាចនៃការនាមានរសតែមួយ ។ បទថា **តតោ បណីតតរេ វិវដ្ដន្តិ** បានដល់ ព្រោះហេតុនោះ ធម៌ទាំងឡាយ មានឆន្ទៈជាដើម ទើបចៀសចេញចាកអារម្មណ៍ គឺវិបស្សនា ទៅកាន់ក្នុងអារម្មណ៍ គឺព្រះនិព្វានដែលប្រណីតជាងដោយគោត្រភូញាណ ពោលគឺវិវដ្ដនានុបស្សនា ( ការពិចារណាឃើញការចៀសចេញទៅ ) អធិប្បាយថា ធម៌ទាំងឡាយចៀសចេញចាកអារម្មណ៍ ដែលជាសង្ខារ ហើយប្រព្រឹត្តទៅក្នុងអារម្មណ៍គឺព្រះនិព្វាន ។ បទថា **វិវដ្ដនាវសេន** បានដល់ ដោយអំណាចការចៀសចេញទៅចាកអារម្មណ៍ដែលជាសង្ខារ ក្នុងខណៈគោត្រភូញាណយ៉ាងនេះ ។ បទថា **វិវដ្ដិតត្តា តតោ វោស្សជ្ជតិ** បានដល់ ព្រោះចិត្តចៀសចេញទៅហើយដោយអំណាចការចេញទៅចាកធម៌ទាំងពីរក្នុងខណៈមគ្គកើតនោះឯង បុគ្គលដែលដល់ព្រមដោយមគ្គ ទើបលះ

បោលនូវកិលេសនិងខន្ធ ដោយហេតុនោះ ៗ ឯង ។ បទថា **ចោសជ្ជិតត្តា តតោ និរុជ្ឈន្តិ** បានដល់ ព្រោះចិត្តលះបោលនូវកិលេស និងខន្ធក្នុងខណៈមគ្គកើតឡើងនោះឯង ទើបកិលេសរំលត់ទៅ ដោយអំណាចការរំលត់ គឺការមិនកើតឡើងដោយហេតុនោះៗឯង ។ ម្យ៉ាងទៀត បទថា **ចោសជ្ជិតត្តា** លោកធ្វើឲ្យជាពាក្យពោលដែលពិតក្នុងសេចក្ដីប្រាថ្នា ។ កាលមានការរំលត់កិលេស លោកក៏ពោលដល់ការរំលត់ខន្ធព្រោះការប្រាកដនៃការរំលត់ខន្ធ ។ បទថា **និរោធវសេន** បានដល់ ដោយអំណាចការរំលត់ តាមដែលពោលហើយ ។ ព្រះសារីបុត្តត្ថេរ បំណងនឹងសម្ដែងដល់ការលះបង់ ២ ប្រការក្នុងខណៈដែលមគ្គនោះកើតឡើង ទើបពោលបទថា **និរោធវសេន ទ្វេ ចោ-សគ្គា** ជាដើម ។ ការលះបង់សូម្បី ២ ប្រការ ក៏មានអត្ថដូចពោលហើយក្នុងខាងដើមនោះឯង ។

សូម្បីក្នុងបទថា **អស្សទ្ធិយស្ស បហានាយ ឆន្ទោ ឧប្បជ្ជតិ** ក៏គប្បីជ្រាបអត្ថដោយពិស្ដារ ដោយន័យនេះឯង ។ សូម្បីក្នុងវារៈដែលមានវីរិយិន្ទ្រិយជាដើមជាមូល ក៏មានន័យនេះដូចគ្នា ។

## អដ្ឋកថា អធិមត្តដ្ឋនិទ្ទេស ចប់

## អធិដ្ឋានជ្ជនិទ្ទេស

[ ១៦៤ ] *សូម្បីអធិដ្ឋានជ្ជនិទ្ទេស ក៏គប្បីជ្រាបដោយសេចក្តីពិស្តារដោយន័យនេះដូចគ្នា ។ តែក្នុងនិទ្ទេសនេះបទថា* **អធិដ្ឋាតិ** *ជាសេចក្តីផ្សេងគ្នាតែមួយ អធិប្បាយថា រមែងតាំងនៅ ។*

*អដ្ឋកថា អធិដ្ឋានជ្ជនិទ្ទេស ចប់*

# បរិយាទានជួបតិដ្ឋាបកជួនិទ្ទេស

[ ១៦៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិយាទានជួនិទ្ទេស ដូចតទៅនេះថា បទថា **បរិយាទិយតិ** បានដល់ រមែងឲ្យអស់ទៅ ។

[ ១៦៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបតិដ្ឋាបកជួនិទ្ទេស ដូចតទៅនេះថា បទថា **សទ្ធោ សទ្ធិន្ទ្រិយំ អធិមោក្ខេ បតិដ្ឋាបេតិ** បានដល់ ដែលដល់ព្រមដោយសទ្ធា បង្អោនចិត្តជឿថា សង្ខារទាំងពួងមិនទៀង ជាទុក្ខ ជាអនត្តា រមែងឲ្យសទ្ធិន្ទ្រិយតាំងនៅក្នុងការបង្អោនចិត្តជឿ ។ ដោយបទនេះ លោកសម្តែងសេចក្តីវិសេសនៃការអប់រំឥន្ទ្រិយ ដោយសេចក្តីវិសេសនៃបុគ្គល ។

បទថា **សទ្ធស្ស សទ្ធិន្ទ្រិយំ អធិមោក្ខេ បតិដ្ឋាបេតិ** បានដល់ សទ្ធិន្ទ្រិយរបស់បុគ្គលអ្នកដល់ព្រមដោយសទ្ធា រមែងញុំាងសទ្ធានោះ ឲ្យតាំងនៅ ។ ម្យ៉ាងទៀត រមែងញុំាងបុគ្គលអ្នកបង្អោនចិត្តជឿ ឲ្យតាំងនៅក្នុងការបង្អោនចិត្តជឿ ។ ដោយបទនេះ លោកសម្តែងសេចក្តីវិសេសរបស់បុគ្គល ដោយសេចក្តីវិសេសនៃការអប់រំឥន្ទ្រិយ ។

គប្បីជ្រាបការប្រកបក្នុងបទដ៏សេសយ៉ាងនេះថា កាលផ្គងចិត្តទុក រមែងឲ្យវីរិយិន្ទ្រិយតាំងនៅក្នុងការផ្គង កាលតាំងសតិទុក រមែងឲ្យសតិន្ទ្រិយតាំងនៅក្នុងការប្រាកដ កាលតាំងចិត្តទុកមាំ រមែងឲ្យសមាធិន្ទ្រិយតាំងនៅក្នុងភាពមិនរាយមាយ កាលឃើញថាមិនទៀង ជាទុក្ខ ជាអនត្តា រមែងឲ្យបញ្ញិន្ទ្រិយតាំងនៅក្នុងការឃើញ ។

បទថា **យោគាវចរោ** មានវិគ្គហៈថា ឈ្មោះថា **យោគាវចរោ**

ព្រោះ**ត្រាច់ទៅ**ក្នុងសមថយោគៈ ឬក្នុងវិបស្សនាយោគៈ ។ ពាក្យថា **ត្រាច់ទៅ** បានដល់ ចូលទៅត្រាច់ទៅ ។

អដ្ឋកថា បរិយាទានដ្ឋបតិដ្ឋាបកដ្ឋនិទ្ទេស ចប់

អដ្ឋកថា ចតុត្ថសុត្តន្តនិទ្ទេស ចប់

# ឥន្ទ្រិយសមោធាន

[ ១៦៧ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរបំណងនឹងសម្តែងដល់ការប្រជុំឥន្ទ្រិយរបស់អ្នកចម្រើនសមាធិ និងរបស់អ្នកចម្រើនវិបស្សនា ដើម្បីចង្អុលបង្ហាញប្រភេទនៃភាពជាអ្នកឈ្លាស ក្នុងការតាំងទុកជាលំដាប់ដំបូងមុន ទើបពោលពាក្យថា **បុថុជ្ជនោ សមាធឹ ភាវេន្តោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បុថុជ្ជនោ សមាធឹ ភាវេន្តោ** បានដល់ បុថុជ្ជនចម្រើនសមាធិដែលជាចំណែកនៃការត្រាស់ដឹង ។ ចំណែកសមាធិខាងលោកុត្តរៈ រមែងមានដល់ព្រះសេក្ខៈនិងដល់អ្នកប្រាសចាកកាគៈ ។

[ ១៦៨-១៧១ ] បទថា **អាវជ្ជិតត្តា** បានដល់ ព្រោះបង្អោនទឹកដល់កសិណនិមិត្តជាដើម មានពាក្យអធិប្បាយថា ព្រោះធ្វើបរិកម្មមានកសិណជាដើម ហើយធ្វើនិមិត្តក្នុងបរិកម្មនោះ ។ បទថា **អារម្មណូបដ្ឋានកុសលោ** បានដល់ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវនិមិត្ត ដែលឲ្យកើតនោះឯង ។

បទថា **សមថនិមិត្តូបដ្ឋានកុសលោ** បានដល់ កាលបើចិត្តរាយមាយដោយភាពជាអ្នកផ្តើមសេចក្តីព្យាយាមខ្លាំងពេកជាដើម ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវនិមិត្ត ដែលធ្វើចិត្តឲ្យស្ងប់ដោយអំណាចនៃការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈ សមាធិសម្ពោជ្ឈង្គៈ និងឧបេក្ខាសម្ពោជ្ឈង្គៈ ។

បទថា **បគ្គហនិមិត្តូបដ្ឋានកុសលោ** បានដល់ កាលបើចិត្តរួញរាដោយភាពជាអ្នកមានសេចក្តីព្យាយាមធូរថយពេកជាដើម ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវនិមិត្ត ដែលផ្គងចិត្តដោយអំណាចនៃការចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ វីរិយសម្ពោជ្ឈង្គៈ និងបីតិសម្ពោជ្ឈង្គៈ ។ បទថា **អវិក្ខេបូបដ្ឋានកុសលោ** បានដល់ ជាអ្នកឈ្លាសក្នុងការតាំងទុកនូវសមាធិ ដែលសម្បយុត្តដោយចិត្តមិនរាយមាយនិងចិត្តមិនរួញរា ។ បទថា **ឱភាសូបដ្ឋានកុសលោ** បានដល់ កាលចិត្តមិនត្រេកអរព្រោះភាពជាអ្នកទន់ខ្សោយក្នុងការប្រើបញ្ញា ជាអ្នកឈ្លាសក្នុងការតាំងទុកនូវពន្លឺ គឺបញ្ញា ព្រោះធ្វើចិត្តឲ្យសង្វេគ ដោយការពិចារណាសង្វេគវត្ថុ ៨ ។ សង្វេគវត្ថុ ៨ គឺសង្វេគវត្ថុ ៤ យ៉ាង គឺជាតិ ជរា ព្យាធិ មរណៈ អបាយទុក្ខជាគម្រប់ ៥ វដ្តមូលកទុក្ខក្នុងអតីត ១ វដ្តមូលកទុក្ខក្នុងអនាគត ១ ទុក្ខព្រោះការស្វែងរកអាហារក្នុងបច្ចុប្បន្ន ១ ។

បទថា **សម្បហំសនូបដ្ឋានកុសលោ** បានដល់ កាលចិត្តមិនត្រេកអរព្រោះមិនទាន់សម្រេចសុខ គឺសេចក្តីស្ងប់ ធ្វើចិត្តឲ្យជ្រះថ្លាដោយការរឭកដល់ពុទ្ធគុណ ធម្មគុណ និងសង្ឃគុណ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវ

*សេចក្តីរីករាយ ។ បទថា* **ឧបេក្ខុបដ្ឋានកុសលោ** *បានដល់ កាលចិត្តប្រាស ចាកទោស មានការរាយមាយជាដើម ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវ ឧបេក្ខា ដោយការធ្វើការមិនខ្វល់ខ្វាយក្នុងការសង្កត់ និងការផ្គងជាដើម ។*

*បទថា* **សេក្ខោ** *មានវិគ្គហៈថា ឈ្មោះថា* **សេក្ខោ** *ព្រោះសិក្សាត្រៃ- សិក្ខា ។ បទថា* **ឯកត្តុបដ្ឋានកុសលោ** *បានដល់ ជាអ្នកឈ្លាសក្នុងការ តម្កល់ទុកនូវភាពជាធម៌តែមួយ មាននេក្ខម្មៈជាដើម ព្រោះលះសក្កាយទិដ្ឋិ ជាដើមបានហើយ ។ បទថា* **វីតរាគោ** *បានដល់ ដែលប្រាសចាករាគៈ ព្រោះលះរាគៈបានហើយ ដោយប្រការទាំងពួង គឺបុគ្គលដែលអស់អាសវៈ ហើយ ។ បទថា* **ញាណូបដ្ឋានកុសលោ** *បានដល់ ព្រះអរហន្ត ឈ្មោះ ថា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវញាណ គឺការមិនវង្វេងក្នុងធម៌នោះៗ ព្រោះលោកប្រាសចាកការវង្វេងក្នុងធម៌ទាំងឡាយ ។ បទថា* **វិមុត្តុបដ្ឋាន- កុសលោ** *បានដល់ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវវិមុត្តិគឺអរហត្តផល ។ ពិតណាស់ ក្នុងពាក្យថា វិមុត្តិ លោកបំណងយកវិមុត្តិគឺអរហត្តផល ។ ព្រោះ ផុតចាកកិលេសទាំងពួង ។*

*គប្បីជ្រាបបទថា* **អឆិច្ចតោ** *ជាដើម និងបទថា* **ឆិច្ចតោ** *ជាដើម ក្នុង ការតម្កល់ទុកនិងការមិនតម្កល់ទុកនូវវិបស្សនាភាវនា ដោយន័យដូចពោល ហើយក្នុងសីលកថានោះឯង ។ តែដោយបាលីគប្បីធ្វើការកាត់សមាសដោយ ឆដ្ឋីវិភត្តិក្នុងបទទាំងនេះ គឺជាអ្នកឈ្លាសក្នុងការមិនតម្កល់ទុកនៃការប្រមូល មក ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនៃការប្រែប្រួល ជាអ្នកឈ្លាសក្នុងការ*

តម្កល់ទុកនៃសភាពមិនមាននិមិត្ត ជាអ្នកឈ្លាសក្នុងការមិនតម្កល់ទុកនៃសភាពមាននិមិត្ត ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនៃសភាពមិនមានទីតាំង ជាអ្នកឈ្លាសក្នុងការមិនតម្កល់ទុកនៃសភាពមានទីតាំង ជាអ្នកឈ្លាសក្នុងការមិនតម្កល់ទុកនៃការប្រកាន់មាំ ។ ចំណែកក្នុងបទដ៏សេសគប្បីធ្វើបាលីដោយបញ្ចមីវិភត្តិ ។ ក្នុងបទថា **សុញ្ញតូបដ្ឋានកុសលោ** នេះ គប្បីធ្វើការកាត់បទថា **សុញ្ញតោ ឧបដ្ឋានកុសលោ** ឬ **សុញ្ញតាយ ឧបដ្ឋានកុសលោ** ។ ម្យ៉ាងទៀត ព្រោះមហាវិបស្សនាទាំង ៨ នេះ គឺនិព្វិទានុបស្សនា ១ វិរាគានុបស្សនា ១ និរោធានុបស្សនា ១ បដិនិស្សគ្គានុបស្សនា ១ អធិប្បញ្ញាធម្មវិបស្សនា ១ យថាភូតញាណទស្សន ១ បដិសង្ខានុបស្សនា ១ វិវដ្តនានុបស្សនា ១ ជាមហាវិបស្សនាវិសេស ដោយភាពពិសេសតាមសភាវៈរបស់ខ្លួន មិនមែនពិសេសដោយភាពពិសេសនៃអារម្មណ៍ ហេតុនោះពាក្យថា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយភាពជារបស់គួរនឿយណាយជាដើម ទើបមិនគួរដល់មហាវិបស្សនា ៨ ទាំងនោះ ដូចពាក្យថា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកដោយភាពជារបស់មិនទៀង ព្រោះហេតុនោះ ទើបលោកមិនប្រកបមហាវិបស្សនាទាំង ៨ នេះទុក ។

ចំណែកអាទីនវានុបស្សនា ឈ្មោះថា លោកប្រកបហើយថា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនៃភាពជាទោស ជាអ្នកឈ្លាសក្នុងការមិនតម្កល់ទុកនៃការប្រកាន់មាំដោយសេចក្តីអាល័យ ដោយអត្ថដោយពាក្យគូនេះថា ជាអ្នកឈ្លាសក្នុងការតម្កល់ទុក ដោយភាពជាសភាពសូន្យ ជាអ្នកឈ្លាសក្នុង

ការមិនតម្កល់ទុកនៃការប្រកាន់មាំ ព្រោះហេតុនោះ ដោយសរុបទើបលោកមិនប្រកបទុក ។

ដោយប្រការដូច្នេះ គប្បីជ្រាបថា ក្នុងមហាវិបស្សនា ១៨ លោកមិនប្រកបមហាវិបស្សនាទាំង ៩ នេះ គឺមហាវិបស្សនា ៨ ដែលទើបតែពោលមកខាងលើនេះ និងអាទីនវានុបស្សនានេះ ហើយប្រកបមហាវិបស្សនា ៩ ទៀតក្រៅអំពីនេះទុក ។

បទថា **ញាណូបដ្ឋានកុសលោ** បានដល់ ព្រះសេក្ខៈ ឈ្មោះថា ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវញាណ ដោយការចម្រើនវិបស្សនា ព្រោះមិនមានវិបស្សនូបក្កិលេស តែលោកមិនបានពោលព្រះសេក្ខ ព្រោះការជាប់ចិត្តក្នុងការចម្រើនសមាធិ ហើយជាអ្នកឈ្លាសក្នុងការតម្កល់ទុកនូវញាណ ។ បទថា **វិសញ្ញោគូបដ្ឋានកុសលោ** បានដល់ ជាអ្នកឈ្លាសក្នុងការតម្កល់ទុកនៃការប្រាសចាកសំយោជនៈ ដែលលោកពោលទុក ៤ យ៉ាង គឺកាមយោគវិសញ្ញោគៈ ១ ភវយោគវិសញ្ញោគៈ ១ ទិដ្ឋិយោគវិសញ្ញោគៈ ១ អវិជ្ជាយោគវិសញ្ញោគៈ ១ ។

បទថា **សញ្ញោគានុបដ្ឋានកុសលោ** បានដល់ ជាអ្នកឈ្លាសក្នុងការមិនតម្កល់ទុកនៃយោគៈដែលលោកពោលទុក ៤ យ៉ាង គឺកាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១ ។ បទថា **និរោធូបដ្ឋានកុសលោ** បានដល់ លោកអ្នកអស់អាសវៈហើយនោះឯង ឈ្មោះថា អ្នកឈ្លាសក្នុងការតម្កល់ទុកនៃនិព្វាន ពោលគឺការរំលត់ព្រោះមានចិត្តបង្អោន

ទៅកាន់និព្វាន ដោយអំណាចកម្លាំងនៃបុគ្គលដែលអស់អាសវៈហើយ ដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយទសកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ[1] មួយទៀត ភិក្ខុជាខីណាស្រព មានចិត្តឱនទៅកាន់និព្វាន ឈមទៅរកនិព្វាន ទោរទន់ទៅរកនិព្វាន[2] ឋិតនៅក្នុងវិវេក ត្រេកអរក្នុងការចេញចាកកាម ជាចិត្តវិនាសចាកធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈដោយប្រការទាំងពួង ដូច្នេះ ។

បទថា **កុសលំ** ក្នុងបទថា **អារម្មណូបដ្ឋានកុសលវសេន** ជាដើម បានដល់ ញាណ ។ ពិតណាស់ សូម្បីញាណក៏ឈ្មោះថា កុសល ព្រោះប្រកបក្នុងបុគ្គលអ្នកឈ្លាស ដូចពាក្យ ( ក្នុងអភិធម្មធម្មសង្គណិ ) ថា ពួកធម៌បណ្ឌិត ព្រោះប្រកបក្នុងបុគ្គលជាបណ្ឌិត ព្រោះហេតុនោះ ទើបមានសេចក្តីថា ដោយអំណាចនៃភាពជាអ្នកឈ្លាស ។

[ ១៧២ ] ឥឡូវនេះ បទថា **ចតុសដ្ឋិយា អាការេហិ** ជាដើម លោកពោលទុកហើយក្នុងញាណកថា តែលោកក៏នៅនាំមកពោលទុកក្នុងទីនេះព្រោះទាក់ទងនឹងឥន្ទ្រិយកថា គប្បីជ្រាបពាក្យនោះ ដោយន័យដែលធ្លាប់ពោលទុកហើយនោះឯង ។

[ ១៧៤ ] ព្រះសារីបុត្តត្ថេរ ប្រាថ្នានឹងពោលប្រភេទរបស់ឥន្ទ្រិយ ដែលទាក់ទងនឹងសមន្តចក្ខុទៀត ទើបពោលបទថា **ន តស្ស អទ្ទិដ្ឋមិធត្ថិ កិញ្ចិ**

---

១-បិដកខ្មែរជាបពិត្រព្រះអង្គដ៏ចម្រើន ។

២-បិដកខ្មែរជាវិវេក ។

ជាដើម ។

ក្នុងបទទាំងនោះ បទថា **សមន្តចក្ខុ** បានដល់ ព្រះសព្វញ្ញុតញ្ញាណ ។

[ ១៧៥ ] ភាពដែលឥន្ទ្រិយ ៥ មិនប្រាសចាកគ្នាដោយបទថា **បញ្ចិ-ន្ទ្រិយស្ស វសេន** ជាដើម ។

លោកសម្តែងភាពដែលឥន្ទ្រិយ ៥ មានរសតែមួយ និងជាបច្ច័យដល់គ្នានឹងគ្នា ក្នុងវេលាប្រកបការបង្អោនទៅ ឬក្នុងខណៈនៃមគ្គដោយចតុក្កៈ ៥ មានឥន្ទ្រិយនីមួយៗជាមូលថា **សទ្ធូហាន្តា បគ្គណ្ហាតិ** ជាដើម ។

លោកសម្តែងភាពដែលឥន្ទ្រិយ ៥ មានរសតែមួយ នឹងជាបច្ច័យដល់គ្នានឹងគ្នា ក្នុងវេលាកើតឬក្នុងវេលានៃផលដោយចតុក្កៈ ៥ ដែលមានឥន្ទ្រិយនីមួយៗជាមូលថា **សទ្ធហិតត្តា បគ្គហិតំ** ជាដើម ។

ព្រះសារីបុត្តត្ថេរបំណាននឹងពោលការកំណត់ឥន្ទ្រិយ ដោយទាក់ទងនឹងពុទ្ធចក្ខុទៀតទើបពោលពាក្យថា **យំ ពុទ្ធចក្ខុ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **ពុទ្ធចក្ខុ** បានដល់ ឥន្ទ្រិយបរោបរិយត្តញ្ញាណ និងអាសយានុសយញ្ញាណ ។ម្យ៉ាងទៀត បទថា **ពុទ្ធញ្ញាណំ** នេះ បានដល់ ញាណទាំងពីរនោះដូចគ្នា ។ បទដ៏សេស មានសេចក្តីដូចពោលទុកហើយក្នុងខាងដើមនោះឯង ។

**អដ្ឋកថាឥន្ទ្រិយសមោធាន ចប់**

**អដ្ឋកថា ឥន្ទ្រិយកថា ចប់**

# សុត្តន្តបិដក

## មហាវគ្គ វិមោក្ខកថា

## បរិបុណ្ណនិទាន

[ ១៧៧ ] ម្នាលភិក្ខុទាំងឡាយ វិមោក្ខនេះមាន ៣ យ៉ាង វិមោក្ខ ៣ យ៉ាងតើដូចម្តេច គឺសុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ ម្នាលភិក្ខុទាំងឡាយ នេះវិមោក្ខ ៣ យ៉ាង ។

មួយ៉ាងទៀត វិមោក្ខមាន ៦៨ យ៉ាង គឺសុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ អជ្ឈត្តវុដ្ឋានវិមោក្ខ ១ ពហិទ្ធាវុដ្ឋានវិមោក្ខ ១ ទុភតោវុដ្ឋានវិមោក្ខ ១ អជ្ឈត្តវុដ្ឋានវិមោក្ខ ៤ ពហិទ្ធាវុដ្ឋានវិមោក្ខ ៤ ទុភតោវុដ្ឋានវិមោក្ខ ៤ អជ្ឈត្តវុដ្ឋានានុលោមវិមោក្ខ ៤ ពហិទ្ធាវុដ្ឋានានុលោមវិមោក្ខ ៤ ទុភតោវុដ្ឋានានុលោមវិមោក្ខ ៤ អជ្ឈត្តវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤ ពហិទ្ធាវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤ ទុភតោវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤ រូបី រូបានិ បស្សតីតិ វិមោក្ខ ( បុគ្គលមានរូបឃើញរូបហៅថាវិមោក្ខ ) ១ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធារូបានិ បស្សតីតិ វិមោក្ខ ( បុគ្គលមានសេចក្តីសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាងក្រៅ ហៅថាវិមោក្ខ ) ១ សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខ ( បុគ្គលមានចិត្តចុះស៊ប់ក្នុងទីបំផុតនៃអារម្មណ៍ដ៏ល្អហៅថាវិមោក្ខ ) ១ អាកាសានញ្ចាយតនសមាបត្តិវិមោក្ខ ១ វិញ្ញាណញ្ចាយតនសមាបត្តិវិមោក្ខ ១ អាកិញ្ចញ្ញាយតនសមាបត្តិវិមោក្ខ ១ នេវសញ្ញានាសញ្ញាយតនសមាបត្តិវិមោក្ខ ១ សញ្ញាវេទយិតនិរោធសមាបត្តិវិមោក្ខ ១

សមយវិមោក្ខ ១ អសមយវិមោក្ខ ១ សាមយិកវិមោក្ខ ១ អសាមយិក-វិមោក្ខ ១ កុប្បវិមោក្ខ ១ អកុប្បវិមោក្ខ ១ លោកិយវិមោក្ខ ១ លោកុត្តរ-វិមោក្ខ ១ សាសវវិមោក្ខ ១ អនាសវវិមោក្ខ ១ សាមិសវិមោក្ខ ១ និរា-មិសវិមោក្ខ ១ និរាមិសតរវិមោក្ខ ១ បណិហិតវិមោក្ខ ១ អប្បណិហិតវិ-មោក្ខ ១ បណិហិតប្បដិប្បស្សទ្ធិវិមោក្ខ ១ សញ្ញុត្តវិមោក្ខ ១ វិសញ្ញុត្ត-វិមោក្ខ ១ ឯកត្តវិមោក្ខ ១ នានត្តវិមោក្ខ ១ សញ្ញាវិមោក្ខ ១ ញាណ-វិមោក្ខ ១ សីតិសិយាវិមោក្ខ ១ ឈានវិមោក្ខ ១ អនុបាទាចិត្តវិមោក្ខ ១ ។

[ ១៧៨ ] សុញ្ញតវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះទៅនៅក្នុងព្រៃក្តី ទៅនៅក្រោមម្លប់ឈើក្តី ទៅនៅក្នុងផ្ទះស្ងាត់ក្តី រមែងពិចារណាដូច្នេះថា នេះជារបស់សូន្យចាកខ្លួន ឬចាកបរិក្ខារជារបស់នៃខ្លួន ភិក្ខុនោះមិនធ្វើនូវសេចក្តីប្រកាន់មាំក្នុងខ្លួន ឬក្នុងបរិក្ខារជារបស់នៃខ្លួននោះទេ ហេតុនោះទើបឈ្មោះថា សុញ្ញតវិមោក្ខ នេះសុញ្ញតវិមោក្ខ ។

អនិមិត្តវិមោក្ខ តើដូចម្តេច ភិក្ខុក្នុងសាសនានេះ ទៅនៅក្នុងព្រៃក្តី ទៅនៅក្រោមម្លប់ឈើក្តី ទៅនៅក្នុងផ្ទះស្ងាត់ក្តី រមែងពិចារណាដូច្នេះថា នេះជារបស់សូន្យចាកខ្លួន ឬចាកបរិក្ខារជារបស់នៃខ្លួន ភិក្ខុនោះមិនធ្វើនូវនិមិត្តក្នុងខ្លួន ឬក្នុងបរិក្ខារជារបស់នៃខ្លួននោះទេ ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ នេះអនិមិត្តវិមោក្ខ ។

អប្បណិហិតវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ទៅនៅក្នុងព្រៃក្តី ទៅនៅក្រោមម្លប់ឈើក្តី ទៅនៅក្នុងផ្ទះស្ងាត់ក្តី រមែងពិចារណាដូច្នេះ

ថា នេះជារបស់សូន្យចាកខ្លួន ឬចាកបរិក្ខារជារបស់នៃខ្លួន ភិក្ខុនោះមិនធ្វើនូវសេចក្តីប្រាថ្នាក្នុងខ្លួន ឬក្នុងបរិក្ខារជារបស់នៃខ្លួននោះទេ ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ នេះអប្បណិហិតវិមោក្ខ ។

អជ្ឈត្តវុដ្ឋានវិមោក្ខ តើដូចម្តេច ។ ឈានទាំង ៤ នេះអជ្ឈត្តវុដ្ឋានវិមោក្ខ ។

ពហិទ្ធាវុដ្ឋានវិមោក្ខ តើដូចម្តេច ។ អរូបសមាបត្តិទាំង ៤ នេះពហិទ្ធាវុដ្ឋានវិមោក្ខ ។

ទុភតោវុដ្ឋានវិមោក្ខ តើដូចម្តេច ។ អរិយមគ្គទាំង ៤ នេះទុភតោវុដ្ឋានវិមោក្ខ ។

[ ១៧៩ ] អជ្ឈត្តវុដ្ឋានវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ បឋមជ្ឈានចេញចាកនីវរណៈទាំងឡាយ ១ ទុតិយជ្ឈានចេញចាកវិតក្កៈនិងវិចារៈទាំងឡាយ ១ តតិយជ្ឈានចេញចាកបីតិ ១ ចតុត្ថជ្ឈានចេញចាកសុខនិងទុក្ខទាំងឡាយ ១ នេះអជ្ឈត្តវុដ្ឋានវិមោក្ខ ៤ ។

ពហិទ្ធាវុដ្ឋានវិមោក្ខ ៤ តើដូចម្តេច ។ អាកាសានញ្ចាយតនសមាបត្តិចេញចាករូបសញ្ញា បដិឃសញ្ញា និងនានត្តសញ្ញា ១ វិញ្ញាណញ្ចាយតនសមាបត្តិចេញចាកអាកាសានញ្ចាយតនសញ្ញា ១ អាកិញ្ចញ្ញាយតនសមាបត្តិចេញចាកវិញ្ញាណញ្ចាយតនសញ្ញា ១ នេវសញ្ញានាសញ្ញាយតនសមាបត្តិចេញចាកអាកិញ្ចញ្ញាយតនសញ្ញា ១ នេះពហិទ្ធាវុដ្ឋានវិមោក្ខ ៤ ។

ទុភតោវុដ្ឋានវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ សោតាបត្តិមគ្គចេញចាក

សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ទិដ្ឋានុស័យ និងវិចិកិច្ឆានុស័យ ចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមសក្កាយទិដ្ឋិជាដើមនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួង ជាខាងក្រៅផង ១ សកទាគាមិមគ្គ ចេញចាកកាមរាគៈសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏គ្រោតគ្រាត ចាកកាមរាគានុស័យ បដិឃានុស័យដ៏គ្រោតគ្រាត ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមកាមរាគសញ្ញោជនៈជាដើមនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួង ជាខាងក្រៅផង ១ អនាគាមិមគ្គ ចេញចាកកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏ល្អិត ចាកកាមរាគានុស័យ បដិ-ឃានុស័យដ៏ល្អិត ចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមកាម-រាគសញ្ញោជនៈជាដើមនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងជាខាងក្រៅផង ១ អរហត្តមគ្គចេញចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមរូបរាគៈជាដើមនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងជាខាងក្រៅផង ១ នេះទុកតោវុដ្ឋានវិមោក្ខ ៤ ។

[ ១៨០ ] អជ្ឈត្តវុដ្ឋានានុលោមវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ វិតក្កៈ វិចារៈ បីតិ សុខៈ ចិត្តេកគ្គតាប្រព្រឹត្តទៅដើម្បីបានទូវបឋមជ្ឈាន ១ វិតក្កៈ វិចារៈ បីតិ សុខៈ ចិត្តេកគ្គតាប្រព្រឹត្តទៅដើម្បីបានទូវទុតិយជ្ឈាន ១ ដើម្បីបានទូវតតិយជ្ឈាន ១ ដើម្បីបានទូវចតុត្ថជ្ឈាន ១ នេះអជ្ឈត្តវុដ្ឋានានុលោ-មវិមោក្ខ ៤ ។

ពហិទ្ធាវុដ្ឋានានុលោមវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ វិតក្កៈ វិចារៈ បីតិ សុខៈ ចិត្តេកគ្គតាប្រព្រឹត្តទៅដើម្បីបាននូវអាកាសានញ្ចាយតនសមាបត្តិ ១ វិតក្កៈ វិចារៈ បីតិ សុខៈ ចិត្តេកគ្គតា ប្រព្រឹត្តទៅដើម្បីបាននូវវិញ្ញា-ណញ្ចាយតនសមាបត្តិ ១ នូវអាកិញ្ចញ្ញាយតនសមាបត្តិ ១ នូវនេវសញ្ញា-នាសញ្ញាយតនសមាបត្តិ ១ នេះពហិទ្ធាវុដ្ឋានានុលោមវិមោក្ខ ៤ ។

ឧភតោវុដ្ឋានានុលោមវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ អនិច្ចានុបស្ស-នា ទុក្ខានុបស្សនា និងអនត្តានុបស្សនាប្រព្រឹត្តទៅដើម្បីបាននូវសោតាបត្តិមគ្គ ១ អនិច្ចានុបស្សនា ទុក្ខានុបស្សនានិងអនត្តានុបស្សនាប្រព្រឹត្តទៅដើម្បីបាន នូវសកទាគាមិមគ្គ ១ ដើម្បីបាននូវអនាគាមិមគ្គ ១ ដើម្បីបាននូវអរហត្ត-មគ្គ ១ នេះឧភតោវុដ្ឋានានុលោមវិមោក្ខ ៤ ។

[ ១៨១ ] អជ្ឈត្តវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ ការបាននូវបឋមជ្ឈានឬវិបាករបស់បឋមជ្ឈាន ១ ការបាននូវទុតិយជ្ឈាន ឬ វិបាករបស់ទុតិយជ្ឈាន ១ ការបាននូវតតិយជ្ឈាន ឬវិបាករបស់តតិយជ្ឈាន ១ ការបាននូវចតុត្ថជ្ឈាន ឬវិបាករបស់ចតុត្ថជ្ឈាន ១ នេះអជ្ឈត្តវុដ្ឋានប្ប-ដិប្បស្សទ្ធិវិមោក្ខ ៤ ។

ពហិទ្ធាវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ ការបាននូវ អាកាសានញ្ចាយតនសមាបត្តិ ឬវិបាករបស់អាកាសានញ្ចាយតនសមាបត្តិ ១ ការបាននូវវិញ្ញាណញ្ចាយតនសមាបត្តិ ឬវិបាករបស់វិញ្ញាណញ្ចាយតន-សមាបត្តិ ១ ការបាននូវអាកិញ្ចញ្ញាយតនសមាបត្តិ ឬវិបាករបស់អាកិញ្ច-

ញ្ញាយតនសមាបត្តិ ១ ការបាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឬវិ-
បាករបស់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ១ នេះពហិទ្ធាវុដ្ឋានប្បដិប្ប-
ស្សទ្ធិវិមោក្ខ ៤ ។

ទុកតោវុដ្ឋានប្បដិប្បស្សទ្ធិវិមោក្ខ ៤ យ៉ាង តើដូចម្តេច ។ សោតាបត្តិ-
ផល របស់សោតាបត្តិមគ្គ ១ សកទាគាមិផល របស់សកទាគាមិមគ្គ ១
អនាគាមិផល របស់អនាគាមិមគ្គ ១ អរហត្តផល របស់អរហត្តមគ្គ ១
នេះទុកតោវុដ្ឋានប្បដិបស្សទ្ធិវិមោក្ខ ៤ ។

[ ១៨២ ] រូបី រូបានិ បស្សតីតិ វិមោក្ខ តើដូចម្តេច ។ បុគ្គលពួកខ្លះ
ក្នុងលោកនេះ ធ្វើទុកក្នុងចិត្តនូវនិមិត្តមានពណ៌ខៀវដ៏ប្រាកដ ជានិមិត្តខាងក្នុង
តែងបាននូវសេចក្តីសម្គាល់ក្នុងពណ៌ខៀវ បុគ្គលនោះក៏ធ្វើនូវនិមិត្តនោះ ឲ្យ
ជានិមិត្ត គឺខ្ជួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្ត គឺ
ខ្ជួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជួនកំណត់
ទុកដោយប្រពៃ លុះបុគ្គលនោះធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនកាន់យក
ដោយប្រពៃ ពិចារណានូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជួនពិចារណាដោយប្រពៃ
កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនកំណត់ទុកដោយប្រពៃហើយ ក៏
ប្រមូលចិត្តទៅក្នុងនិមិត្ត មានពណ៌ខៀវជានិមិត្តខាងក្រៅ តែងបាននូវសេចក្តី
សម្គាល់ក្នុងពណ៌ខៀវ បុគ្គលនោះធ្វើនូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជួនកាន់យក
ដោយប្រពៃ ពិចារណានូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជួនពិចារណាដោយប្រពៃ
កំណត់ទុកនូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជួនកំណត់ទុកដោយប្រពៃ លុះបុគ្គល

នោះធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជូនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជូនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជូនកំណត់ទុកដោយប្រពៃហើយក៏សេព ចម្រើន ធ្វើឲ្យច្រើន ( នូវនិមិត្តនោះ ) បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា រូបខាងក្នុងនិងរូបខាងក្រៅទាំងពីរនេះ ឈ្មោះថារូប ( ដូចគ្នា ) បុគ្គលនោះឈ្មោះថាអ្នកមានសេចក្តីសម្គាល់ក្នុងរូប បុគ្គលខ្លះក្នុងលោកនេះធ្វើទុកក្នុងចិត្តនូវនិមិត្តមានពណ៌លឿង នូវនិមិត្តមានពណ៌ក្រហម នូវនិមិត្តមានពណ៌ស ដ៏ប្រាកដជានិមិត្តខាងក្នុង តែងបាននូវសេចក្តីសម្គាល់ក្នុងពណ៌ស បុគ្គលនោះធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជូនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជូនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជូនកំណត់ទុកដោយប្រពៃ លុះបុគ្គលនោះធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជូនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជូនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជូនកំណត់ទុកដោយប្រពៃហើយក៏ប្រមូលចិត្តទៅក្នុងនិមិត្តមានពណ៌ស ជានិមិត្តខាងក្រៅ តែងបាននូវសេចក្តីសម្គាល់ក្នុងពណ៌ស បុគ្គលនោះក៏ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជូនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជូនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជូនកំណត់ទុក ដោយប្រពៃ លុះបុគ្គលនោះធ្វើទុកនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជូនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជូនពិចារណាដោយប្រពៃកំណត់

ទុកនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនកំណត់ទុកដោយប្រពៃហើយ ក៏សេព ចម្រើន ធ្វើឲ្យច្រើននូវនិមិត្តនោះ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា រូបខាងក្នុងនិងរូបខាងក្រៅទាំងពីរនេះ ឈ្មោះថារូបដូចគ្នា បុគ្គលនោះឈ្មោះថា ជាអ្នកមានសេចក្តីសម្គាល់ក្នុងរូប យ៉ាងនេះឯង ឈ្មោះថា រូបី រូបានិ បស្សតីតិ វិមោក្ខ ។

[ ១៨៣ ] អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតីតិ វិមោក្ខ តើដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ មិនធ្វើទុកក្នុងចិត្តនូវនិមិត្តមានពណ៌ខៀវដ៏ប្រាកដ ជានិមិត្តខាងក្នុង មិនបាននូវសេចក្តីសម្គាល់ក្នុងពណ៌ខៀវទេ តែប្រមូលចិត្តទៅក្នុងនិមិត្តមានពណ៌ខៀវ ជានិមិត្តខាងក្រៅ បាននូវសេចក្តីសម្គាល់ក្នុងពណ៌ខៀវ បុគ្គលនោះក៏ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនកំណត់ទុកដោយប្រពៃ លុះបុគ្គលនោះធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនកាន់យកដោយប្រពៃ ពិ-ចារណានូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជួនកំណត់ទុកដោយប្រពៃហើយក៏សេព ចម្រើន ធ្វើឲ្យច្រើននូវនិមិត្តនោះ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អរូបគឺរបស់ឥតរូបខាងក្នុងនេះឯង ជារូបខាងក្រៅ បុគ្គលនោះឈ្មោះថាជាអ្នកមានសេចក្តីសម្គាល់ក្នុងរូប បុគ្គលខ្លះក្នុងលោកនេះ មិនធ្វើទុកក្នុងចិត្តនូវនិមិត្តមានពណ៌លឿង នូវនិមិត្តមានពណ៌ក្រហម នូវនិមិត្តមានពណ៌ស ដ៏ប្រាកដ

ជានិមិត្តខាងក្នុង មិនបានទូវសេចក្តីសម្គាល់ក្នុងពណ៌ស តែប្រមូលចិត្តទៅក្នុងនិមិត្ត មានពណ៌សជានិមិត្តខាងក្រៅ បានទូវសេចក្តីសម្គាល់ក្នុងពណ៌ស បុគ្គលនោះធ្វើនូវនិមិត្តនោះឲ្យជានិមិត្ត គឺខ្ជួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនកំណត់ទុកដោយប្រពៃ លុះបុគ្គលនោះធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនកាន់យកដោយប្រពៃ ពិចារណានូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនពិចារណាដោយប្រពៃ កំណត់ទុកនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្ជួនកំណត់ទុកដោយប្រពៃហើយក៏សេព ចម្រើន ធ្វើឲ្យច្រើននូវនិមិត្តនោះ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អរូបគឺរបស់ឥតរូបខាងក្នុងនេះ ឯងជារូបខាងក្រៅ បុគ្គលនោះឈ្មោះថាជាអ្នកមានសេចក្តីសម្គាល់ក្នុងរូប ។ យ៉ាងនេះឯងឈ្មោះថាអជ្ឈត្តំ អរូបសញ្ញី ពហិទ្ធារូបានិ បស្សតីតិ វិមោក្ខ ។

[ ១៨៤ ] សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា តាមទំនងនេះ សូម្បីទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ រកប្រមាណមិនបាន ជាចិត្តឥតចងពៀរ ឥតព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះហេតុប្រៀបផ្ទឹមខ្លួនឲ្យស្មើនឹងសត្វទាំងអស់ក្នុងទិសទាំងពួង សត្វទាំងឡាយដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនមេត្តា ភិក្ខុមានចិត្តប្រកបដោយករុណាផ្សាយទៅកាន់ទិសទី ១ ។បេ។ សត្វ

ទាំងឡាយ ដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនករុណា ភិក្ខុមានចិត្តប្រកបដោយមុទិតា ។បេ។ សត្វទាំងឡាយ ដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនមុទិតា ភិក្ខុមានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ។បេ។ សត្វទាំងឡាយដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនឧបេក្ខា យ៉ាងនេះឯងឈ្មោះថា សុភន្តេវ អធិមុត្តោ ហោតីតិ វិមោក្ខ ។

[ ១៨៥ ] អាកាសានញ្ចាយតនសមាបត្តិវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈានដោយបរិកម្មថា អាកាសមិនមានទីបំផុត នេះឈ្មោះថា អាកាសានញ្ចាយតនសមាបត្តិវិមោក្ខ ។

វិញ្ញាណញ្ចាយតនសមាបត្តិវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ កន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត នេះឈ្មោះថា វិញ្ញាណញ្ចាយតនសមាបត្តិវិមោក្ខ ។

អាកិញ្ចញ្ញាយតនសមាបត្តិវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ កន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា អ្វីតិចតួចមិនមាន នេះឈ្មោះថា អាកិញ្ចញ្ញាយតនសមាបត្តិវិមោក្ខ ។

នេវសញ្ញានាសញ្ញាយតនសមាបត្តិវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសា-

សនានេះ កន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះឈ្មោះថា នេវសញ្ញានាសញ្ញា-យតនសមាបត្តិវិមោក្ខ ។

សញ្ញាវេទយិតនិរោធសមាបត្តិវិមោក្ខ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ កន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួងហើយចូលកាន់សញ្ញាវេទយិតនិរោធ ( សេចក្តីរលត់នៃសញ្ញានិងវេទនា ) នេះឈ្មោះថា សញ្ញាវេទយិតនិរោធសមាបត្តិវិមោក្ខ ។

[ ១៨៦ ] សមយវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះឈ្មោះថា សមយវិមោក្ខ ។

អសមយវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះឈ្មោះថា អសមយវិមោក្ខ ។

សាមយិកវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះឈ្មោះថា សាមយិកវិមោក្ខ ។

អសាមយិកវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះឈ្មោះថា អសាមយិកវិមោក្ខ ។

កុប្បវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះឈ្មោះថា កុប្បវិមោក្ខ ។

អកុប្បវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះឈ្មោះថា អកុប្បវិមោក្ខ ។

លោកិយវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះឈ្មោះថា លោកិយវិមោក្ខ ។

លោកុត្តរវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះឈ្មោះថា លោកុត្តរវិមោក្ខ ។

សាសវវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះឈ្មោះថា សាសវវិមោក្ខ ។

អនាសវវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះឈ្មោះថា អនាសវវិមោក្ខ ។

[ ១៨៧ ] សាមិសវិមោក្ខ តើដូចម្តេច ។ វិមោក្ខប្រកបព្រមដោយរូប នេះឈ្មោះថា សាមិសវិមោក្ខ ។

និរាមិសវិមោក្ខ តើដូចម្តេច ។ វិមោក្ខមិនប្រកបព្រមដោយរូប នេះឈ្មោះថា និរាមិសវិមោក្ខ ។

និរាមិសតរវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះឈ្មោះថា និរាមិសតរវិមោក្ខ ។

បណិហិតវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះឈ្មោះថា បណិហិតវិមោក្ខ ។

អប្បណិហិតវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះឈ្មោះថា អប្បណិហិតវិមោក្ខ ។

បណិហិតប្បដិប្បស្សទ្ធិវិមោក្ខ តើដូចម្តេច ។ ការបាននូវបឋមជ្ឈានឬ

វិបាករបស់បឋមជ្ឈាន ។បេ។ ការបានទូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឬវិបាករបស់នេវសញ្ញានាសញ្ញាយតនសមាបត្តិ នេះឈ្មោះថា បណិហិតប្បដិប្បស្សទ្ធិវិមោក្ខ ។

សញ្ញុត្តវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះឈ្មោះថា សញ្ញុត្តវិមោក្ខ ។

វិសញ្ញុត្តវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះឈ្មោះថា វិសញ្ញុត្តវិមោក្ខ ។

ឯកត្តវិមោក្ខ តើដូចម្តេច ។ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះឈ្មោះថា ឯកត្តវិមោក្ខ ។

នានត្តវិមោក្ខ តើដូចម្តេច ។ ឈាន ៤ អរូបសមាបត្តិ ៤ នេះឈ្មោះថា នានត្តវិមោក្ខ ។

[ ១៨៨ ] សញ្ញាវិមោក្ខ តើដូចម្តេច ។ សញ្ញាវិមោក្ខ ១ បែកចេញជាសញ្ញាវិមោក្ខ ១០ សញ្ញាវិមោក្ខ ១០ រួមមកជាសញ្ញាវិមោក្ខ ១ វិញ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន ។

សំណួរត្រង់ពាក្យថា ក៏មាន តើក៏មាន ដូចម្តេច ។ អនិច្ចានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញថាមិនទៀង ) ផុតស្រឡះចាកសេចក្តីសម្គាល់ថា ទៀង ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខ ទុក្ខានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញថាជាទុក្ខ ) ផុតស្រឡះចាកសេចក្តីសម្គាល់ថាជាសុខ ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខ អនត្តានុប-

ស្សនាញាណ (ញាណជាគ្រឿងពិចារណាឃើញថា មិនមែនខ្លួន) ផុតស្រឡះចាកសេចក្ដីសម្គាល់ថាជាខ្លួន ហេតុនោះ ឈ្មោះថា សញ្ញាវិមោក្ខ និព្វិទានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញថាគួរនឿយណាយ ) ផុតស្រឡះចាកសេចក្ដីសម្គាល់ក្នុងការត្រេកអរ ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខ វិរាគានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងប្រាសចាករាគៈ ) ផុតស្រឡះចាកសេចក្ដីសម្គាល់ថារាគៈ ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខ និរោធានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញនូវសេចក្ដីរលត់ ) ផុតស្រឡះចាកសេចក្ដីសម្គាល់ថា កើតឡើង ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខ បដិនិស្សគ្គានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងរលាស់ចេញ ) ផុតស្រឡះ ចាកសេចក្ដីសម្គាល់ថាគួរប្រកាន់ ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខ អនិមិត្តានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញនូវធម៌មិនមាននិមិត្ត ) ផុតស្រឡះ ចាកសេចក្ដីសម្គាល់ថាជានិមិត្ត ហេតុនោះ ឈ្មោះថា សញ្ញាវិមោក្ខ អប្បណិហិតានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញនូវធម៌មិនមានតម្កល់ទុក ) ផុតស្រឡះ ចាកសេចក្ដីសម្គាល់ថាតម្កល់ទុក ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខ សុញ្ញតានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញថាសូន្យ ) ផុតស្រឡះ ចាកសេចក្ដីសម្គាល់ថាគួរប្រកាន់ស្អិត ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខយ៉ាងនេះឯង សញ្ញាវិមោក្ខ ១ បែកចេញជាសញ្ញាវិមោក្ខ ១០ សញ្ញាវិមោក្ខ ១០ រួមមកជាសញ្ញា-

វិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន អនិច្ចានុបស្សនា-ញាណ ( ញាណជាគ្រឿងពិចារណាឃើញថាមិនទៀង ) ក្នុងរូប ផុតស្រឡះចាកសេចក្តីសម្គាល់ថាទៀង ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខ ។បេ។ សុញ្ញតាវិបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញថាសូន្យ ) ក្នុងរូប ផុតស្រឡះ ចាកសេចក្តីសម្គាល់ដោយការប្រកាន់ស្អិត ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខយ៉ាងនេះឯង សញ្ញាវិមោក្ខ ១ បែកចេញជាសញ្ញា-វិមោក្ខ ១០ សញ្ញាវិមោក្ខ ១០ រួមមកជាសញ្ញាវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន ។ អនិច្ចានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញថាមិនទៀង ) ក្នុងវេទនា ។បេ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ផុតស្រឡះចាកសេចក្តីសម្គាល់ថាទៀង ហេតុនោះឈ្មោះថាសញ្ញាវិមោក្ខ ។បេ។ សុញ្ញតានុបស្សនាញាណ ( ញាណជាគ្រឿងពិចារណាឃើញថាសូន្យ ) ក្នុងជរាមរណៈ ផុតស្រឡះចាកសេចក្តីសម្គាល់ ថាគួរប្រកាន់ស្អិត ហេតុនោះឈ្មោះថា សញ្ញាវិមោក្ខយ៉ាងនេះឯង សញ្ញាវិមោក្ខ ១ បែកចេញជាសញ្ញាវិមោក្ខ ១០ សញ្ញា-វិមោក្ខ ១០ រួមមកជាសញ្ញាវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន នេះសញ្ញាវិមោក្ខ ។

[ ១៨៩ ] ញាណវិមោក្ខ តើដូចម្តេច ។ ញាណវិមោក្ខ ១ បែកចេញជាញាណវិមោក្ខ ១០ ញាណវិមោក្ខ ១០ រួមមកជាញាណវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន ។

សំណួរត្រង់ពាក្យថា ក៏មាន តើក៏មានដូចម្តេច ។ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញថា មិនទៀង ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹងថាទៀង ហេតុនោះ ឈ្មោះថា ញាណវិមោក្ខ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញថាជាទុក្ខ ផុតស្រឡះចាកសេចក្តីវង្វេងចាកសេចក្តីមិនដឹងថាជាសុខ ហេតុនោះឈ្មោះថា ញាណវិមោក្ខ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញថា មិនមែនខ្លួន ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាជាខ្លួន ហេតុនោះឈ្មោះថា ញាណវិមោក្ខ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញនូវធម៌ ជាគ្រឿងនឿយណាយ ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ក្នុងសេចក្តីត្រេកអរ ហេតុនោះឈ្មោះថា ញាណវិមោក្ខ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងប្រាសចាកតម្រេក ផុតស្រឡះចាកសេចក្តីវង្វេងចាកសេចក្តីមិនដឹងថា រាគៈ ហេតុនោះឈ្មោះថា ញាណវិមោក្ខ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងរលត់ ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹងថាកើតឡើង ហេតុនោះឈ្មោះថា ញាណវិមោក្ខ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញនូវធម៌ ជាគ្រឿងរលាស់ចេញ ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាគួរប្រកាន់មាំ ហេតុនោះឈ្មោះថា ញាណវិមោក្ខ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញនូវធម៌មិនមាននិមិត្ត ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាមាននិមិត្ត ហេតុនោះឈ្មោះថា ញាណវិមោក្ខ សេចក្តីដឹងតាមពិត ជាគ្រឿង

ពិចារណាឃើញនូវធម៌មិនមានការតម្កល់ទុក ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ក្នុងការតម្កល់ទុក ហេតុនោះឈ្មោះថា ញាណវិមោក្ខ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញថា សូន្យ ផុតស្រឡះចាក សេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាគួរប្រកាន់មាំ ហេតុនោះ ឈ្មោះថា ញាណវិមោក្ខ យ៉ាងនេះឯង ញាណវិមោក្ខ ១ បែកចេញជាញាណវិមោក្ខ ១០ ញាណវិមោក្ខ ១០ រួមមកជាញាណវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញថា មិនទៀងក្នុងរូប ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹងថាទៀង ហេតុនោះឈ្មោះថា ញាណវិមោក្ខ ។បេ។ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញថាសូន្យក្នុងរូប ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹងថាគួរប្រកាន់ស្អិត ហេតុនោះឈ្មោះថា ញាណវិមោក្ខ យ៉ាងនេះឯង ញាណវិមោក្ខ ១ បែកចេញជាញាណវិមោក្ខ ១០ ញាណវិមោក្ខ ១០ រួមមកជាញាណវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញថា មិនទៀងក្នុងវេទនា ។បេ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹងថា ទៀង ហេតុនោះឈ្មោះថា ញាណវិមោក្ខ ។បេ។ សេចក្តីដឹងតាមពិត ជាគ្រឿងពិចារណាឃើញថាសូន្យក្នុងជរាមរណៈ ផុតស្រឡះចាកសេចក្តីវង្វេង ចាកសេចក្តីមិនដឹង ថាគួរប្រកាន់មាំ ហេតុនោះឈ្មោះថា ញាណវិមោក្ខ យ៉ាងនេះឯង ញាណវិមោក្ខ

១ បែកចេញជាញាណវិមោក្ខ ១០ ញាណវិមោក្ខ ១០ រួមមកជាញាណ-វិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន នេះញាណវិមោក្ខ ។

[ ១៩០ ] សីតិសិយាវិមោក្ខ តើដូចម្តេច ។ សីតិសិយាវិមោក្ខ ១ បែកចេញជាសីតិសិយាវិមោក្ខ ១០ សីតិសិយាវិមោក្ខ ១០ រួមមកជាសី-តិសិយាវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។

សំណួរត្រង់ពាក្យថា ក៏មាន តើក៏មានដូចម្តេច ។ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ ថាមិនទៀង ផុតស្រឡះចាក សេចក្តីក្តៅក្រហាយ សេចក្តីរោលរាលនិងសេចក្តីក្រវល់ក្រវាយ ថាទៀង ហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ ថាជាទុក្ខ ផុតស្រឡះចាកសេចក្តីក្តៅក្រហាយ សេចក្តីរោលរាលនិងសេចក្តីក្រវល់ក្រវាយ ថាជាសុខ ហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ ថាមិនមែនខ្លួន ផុតស្រឡះចាកសេចក្តីក្តៅក្រហាយ សេចក្តីរោលរាលនិងសេចក្តីក្រវល់ក្រវាយថាខ្លួន ហេតុនោះឈ្មោះថា សីតិ-សិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញថា គួរនឿយណាយ ផុតស្រឡះចាកសេចក្តីក្តៅក្រហាយ សេចក្តីរោលរាលនិងសេចក្តីក្រវល់ក្រវាយក្នុងសេចក្តីត្រេកអរ ហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ សេចក្តីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារ-ណាឃើញនូវធម៌ ជាគ្រឿងប្រាសចាករាគៈ ផុតស្រឡះចាករាគៈ ដែលជា

សេចក្ដីក្ដៅក្រហាយ សេចក្ដីរោលរាលនិងសេចក្ដីក្រវល់ក្រវាយ ហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ សេចក្ដីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញនូវធម៌ ជាគ្រឿងរលត់ ផុតស្រឡះចាកហេតុជាដែនកើត ដែលជាសេចក្ដីក្ដៅក្រហាយ សេចក្ដីរោលរាល និងសេចក្ដីក្រវល់-ក្រវាយ ហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ សេចក្ដីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងរលាស់ចេញ ផុតស្រឡះចាកសេចក្ដីប្រកាន់ ដែលជាសេចក្ដីក្ដៅក្រហាយ សេចក្ដីរោលរាលនិងសេចក្ដីក្រវល់ក្រវាយ ហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ សេចក្ដីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញនូវធម៌ មិនមាននិមិត្ត ផុតស្រឡះចាកធម៌មាននិមិត្ត ដែលជាសេចក្ដីក្ដៅក្រហាយ សេចក្ដីរោលរាលនិងសេចក្ដីក្រវល់ក្រវាយ ហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ សេចក្ដីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញនូវធម៌មិនមានការតម្កល់ទុក ផុតស្រឡះ ចាកការតម្កល់ទុក ដែលជាសេចក្ដីក្ដៅក្រហាយ សេចក្ដីរោលរាលនិងសេចក្ដីក្រវល់ក្រវាយ ដោយហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ សេចក្ដីដឹងដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញជាសូន្យ ផុតស្រឡះចាកការប្រកាន់ ដែលជាសេចក្ដីក្ដៅក្រហាយ សេចក្ដីរោលរាល និងសេចក្ដីក្រវល់ក្រវាយ ហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ ។ យ៉ាងនេះឯង សីតិសិយាវិមោក្ខ ១ បែកចេញជាសីតិសិយាវិមោក្ខ ១០ សីតិសិយាវិមោក្ខ ១០ រួមមកជាសីតិសិយា-

វិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។ សេចក្តីជីនដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញ ថាមិនទៀងក្នុងរូប ផុតស្រឡះចាកការទៀន ដែលជាសេចក្តីក្តៅក្រហាយ សេចក្តីពេលពាល និងសេចក្តីក្រវល់ក្រវាយ ហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ ។បេ។ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ។ សេចក្តីជីនដ៏ប្រសើរ មានភាពដ៏ត្រជាក់ ជាគ្រឿងពិចារណាឃើញថាមិនទៀងក្នុងវេទនា ។បេ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ផុតស្រឡះចាកការទៀនដែលជាសេចក្តីក្តៅក្រហាយ សេចក្តីពេលពាល និងសេចក្តីក្រវល់-ក្រវាយ ហេតុនោះឈ្មោះថា សីតិសិយាវិមោក្ខ ។បេ។ យ៉ាងនេះឯង សី-តិសិយាវិមោក្ខ ១ បែកចេញជាសីតិសិយាវិមោក្ខ ១០ សីតិសិយាវិមោក្ខ ១០ រួមមកជាសីតិសិយាវិមោក្ខ ១ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន នេះសីតិសិយាវិមោក្ខ ។

[ ១៩១ ] ឈានវិមោក្ខ តើដូចម្តេច ។ នេក្ខម្មកើតឡើង ឈ្មោះថា ឈាន ធម្មជាតដុតនូវកាមឆន្ទៈ ឈ្មោះថា ឈាន សភាវៈកាលកើតឡើង ផុតស្រឡះ ( ចាកកិលេសទាំងឡាយ ) ឈ្មោះថា ឈានវិមោក្ខ សភាវៈ កាលដុត ផុតស្រឡះ ( ចាកកិលេសទាំងឡាយ ) ឈ្មោះថាឈានវិមោក្ខ ធម៌ទាំងឡាយកើតឡើង សភាវៈដុត ( នូវកិលេសទាំងឡាយ ) សភាវៈ ជីននូវកិលេសទាំងឡាយដែលកើតឡើងផង នូវកិលេសទាំងឡាយ ដែល ឆេះផង ឈ្មោះថា ឈានវិមោក្ខ ការមិនមានព្យាបាទកើតឡើង ឈ្មោះថា

ឈាន ធម្មជាតដុតនូវព្យាបាទ ឈ្មោះថា ឈាន សភាវៈកាលកើតឡើង ផុតស្រឡះ ( ចាកកិលេសទាំងឡាយ ) ឈ្មោះថា ឈានវិមោក្ខ សភាវៈ កាលដុត ផុតស្រឡះ ( ចាកកិលេសទាំងឡាយ ) ឈ្មោះថា ឈានវិមោក្ខ ធម៌ទាំងឡាយ កើតឡើង សភាវៈកាលដុត ( នូវកិលេសទាំងឡាយ ) សភាវៈដឹងនូវកិលេសទាំងឡាយដែលកើតឡើងផង នូវកិលេសទាំងឡាយ ដែលឆេះផង ឈ្មោះថា ឈានវិមោក្ខ អាលោកសញ្ញាកើតឡើង ឈ្មោះ ថា ឈាន ធម្មជាតដុតនូវថីនមិទ្ធៈ ឈ្មោះថា ឈាន ការមិនរាយមាយ កើតឡើង ឈ្មោះថា ឈាន ធម្មជាតដុតនូវឧទ្ធច្ចៈ ឈ្មោះថា ឈាន ការ កំណត់នូវធម៌កើតឡើង ឈ្មោះថា ឈាន ធម្មជាតដុតនូវវិចិកិច្ឆា ឈ្មោះថា ឈាន ញាណកើតឡើង ឈ្មោះថា ឈាន ធម្មជាតដុតនូវអវិជ្ជា ឈ្មោះថា ឈាន បាមុជ្ជៈកើតឡើង ឈ្មោះថា ឈាន ធម្មជាតដុតនូវសេចក្តីមិន ត្រេកអរ ឈ្មោះថា ឈាន បឋមជ្ឈានកើតឡើង ឈ្មោះថា ឈាន ធម្ម-ជាតដុតនូវនីវរណធម៌ ឈ្មោះថា ឈាន ។បេ។ អរហត្តមគ្គ កើតឡើង ឈ្មោះថា ឈាន ធម្មជាតដុតនូវកិលេសទាំងពួង ឈ្មោះថា ឈាន សភាវៈ កាលកើតឡើងផុតស្រឡះ ( ចាកកិលេសទាំងឡាយ ) ឈ្មោះថា ឈាន-វិមោក្ខ សភាវៈកាលដុត ផុតស្រឡះ ( ចាកកិលេសទាំងឡាយ ) ឈ្មោះ ថា ឈានវិមោក្ខ ធម៌ទាំងឡាយកើតឡើង សភាវៈដុត ( នូវកិលេស ទាំងឡាយ ) សភាវៈដឹងនូវកិលេសទាំងឡាយ ដែលកើតឡើងផង នូវ កិលេសទាំងឡាយដែលឆេះផង ឈ្មោះថា ឈានវិមោក្ខ នេះឈានវិមោក្ខ ។

[ ១៩២ ] អនុបាទាចិត្តវិមោក្ខ ( ការរួចនៃចិត្តមិនមានសេចក្ដីប្រកាន់ ) តើដូចម្ដេច ។ អនុបាទាចិត្តវិមោក្ខ ១ បែកចេញជាអនុបាទាចិត្តវិមោក្ខ ១០ អនុបាទាចិត្តវិមោក្ខ ១០ រួមមកជាអនុបាទាចិត្តវិមោក្ខ ១ វិញ ដោយបរិ-យាយ ដោយអំណាចនៃវត្ថុ ក៏មាន ។

ពាក្យថា ក៏មាន តើក៏មានដូចម្ដេច ។ ញាណជាគ្រឿងពិចារណាឃើញ ជាមិនទៀង ផុតស្រឡះចាកការទៀង ដែលជាសេចក្ដីប្រកាន់ ឈ្មោះថា អនុបាទាចិត្តវិមោក្ខ ញាណជាគ្រឿងពិចារណាឃើញ ថាជាទុក្ខ ផុតស្រឡះ ចាកសេចក្ដីសុខ ដែលជាសេចក្ដីប្រកាន់ ឈ្មោះថា អនុបាទាចិត្តវិមោក្ខ ញាណជាគ្រឿងពិចារណាឃើញ ថាមិនមែនខ្លួន ផុតស្រឡះចាកខ្លួន ដែលជាសេចក្ដីប្រកាន់ ឈ្មោះថា អនុបាទាចិត្តវិមោក្ខ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងនឿយណាយ ផុតស្រឡះចាកសេចក្ដីត្រេកអរ ដែលជាសេចក្ដីប្រកាន់ ឈ្មោះថា អនុបាទាចិត្តវិមោក្ខ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងប្រាសចាករាគៈ ផុតស្រឡះចាករាគៈ ដែលជាសេចក្ដីប្រកាន់ ឈ្មោះថា អនុបាទាចិត្តវិមោក្ខ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងរំលត់ ផុតស្រឡះ ចាកហេតុជាដែនកើត ដែលជាសេចក្ដីប្រកាន់ ឈ្មោះថា អនុបាទាចិត្តវិមោក្ខ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងរលាស់ ផុតស្រឡះចាកការប្រកាន់ ដែលជាសេចក្ដីប្រកាន់ ឈ្មោះថា អនុបាទាចិត្តវិមោក្ខ ញាណជាគ្រឿងពិចារណាឃើញនូវធម៌មិនមាននិមិត្ត ផុតស្រឡះចាកធម៌មាននិមិត្ត ដែលជាសេចក្ដីប្រកាន់ ឈ្មោះថា

អនុបាទាចិត្តវិមោក្ខ ញាណជាគ្រឿងពិចារណា ឃើញនូវការមិនតម្កល់ទុក ផុតស្រឡះចាកការតម្កល់ទុក ដែលជាសេចក្តីប្រកាន់ ឈ្មោះថា អនុបាទា-ចិត្តវិមោក្ខ ញាណជាគ្រឿងពិចារណាឃើញថាសូន្យ ផុតស្រឡះចាកការប្រកាន់ស្អិត ដែលជាសេចក្តីប្រកាន់ ឈ្មោះថា អនុបាទាចិត្តវិមោក្ខ ។ យ៉ាងនេះឯង អនុបាទាចិត្តវិមោក្ខ ១ បែកចេញជាអនុបាទាចិត្តវិមោក្ខ ១០ អនុ-បាទាចិត្តវិមោក្ខ ១០ រួមមកជាអនុបាទាចិត្តវិមោក្ខ ១ វិញ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន ។ ញាណជាគ្រឿងពិចារណាឃើញថា មិនទៀងក្នុងរូប ផុតស្រឡះចាកការទៀងដែលជាសេចក្តីប្រកាន់ ឈ្មោះថា អនុបាទា-ចិត្តវិមោក្ខ ។បេ។ ញាណជាគ្រឿងពិចារនាឃើញថា សូន្យក្នុងរូប ផុតស្រឡះចាកការប្រកាន់ស្អិតដែលជាសេចក្តីប្រកាន់ ឈ្មោះថា អនុបាទាចិត្តវិមោក្ខ ។ យ៉ាងនេះឯង អនុបាទាចិត្តវិមោក្ខ ១ បែកចេញជាអនុបាទាចិត្តវិមោក្ខ ១០ អនុបាទាចិត្តវិមោក្ខ ១០ រួមមកជាអនុបាទាចិត្តវិមោក្ខ ១ វិញ ដោយបរិយាយ ដោយអំណាចនៃវត្ថុក៏មាន ។ ញាណជាគ្រឿងពិចារណាឃើញថាមិនទៀងក្នុងវេទនា ។បេ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ផុតស្រឡះចាកការទៀង ដែលជាសេចក្តីប្រកាន់ ឈ្មោះថា អនុ-បាទាចិត្តវិមោក្ខ ។បេ។ ញាណជាគ្រឿងពិចារណាឃើញថាសូន្យ ក្នុងជរាមរណៈ ផុតស្រឡះចាកការប្រកាន់ស្អិត ដែលជាសេចក្តីប្រកាន់ ឈ្មោះថា អនុបាទាចិត្តវិមោក្ខ ។ យ៉ាងនេះឯង អនុបាទាចិត្តវិមោក្ខ ១ បែកចេញជាអនុបាទាចិត្តវិមោក្ខ ១០ អនុបាទាចិត្តវិមោក្ខ ១០ រួមមកជាអនុបាទាចិត្តវិ-

មោក្ខ ១ វិញ ដោយបរិយាយ ដោយអំណាចនៃវត្ថុ ក៏មាន ។

[ ១៩៣ ] ញាណជាគ្រឿងពិចារណាឃើញថា មិនទៀង ផុតស្រឡះចាកឧបាទានប៉ុន្មាន ញាណជាគ្រឿងពិចារណាឃើញថាជាទុក្ខ ផុតស្រឡះចាកឧបាទានប៉ុន្មាន ញាណជាគ្រឿងពិចារណាឃើញថា មិនមែនខ្លួន ផុតស្រឡះចាកឧបាទានប៉ុន្មាន ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងនឿយណាយ ។បេ។ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ ជាគ្រឿងប្រាសចាករាគៈ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ ជាគ្រឿងរំលត់ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ ជាគ្រឿងរលាស់ ញាណជាគ្រឿងពិចារណាឃើញនូវធម៌មិនមាននិមិត្ត ញាណជាគ្រឿងពិចារណាឃើញនូវធម៌មិនមានការតម្កល់ទុក ញាណជាគ្រឿងពិចារណាឃើញថាសូន្យ ផុតស្រឡះចាកឧបាទានប៉ុន្មាន ។ ញាណជាគ្រឿងពិចារណាឃើញថាមិនទៀង ផុតស្រឡះចាកឧបាទាន ៣ ញាណជាគ្រឿងពិចារណាឃើញថាជាទុក្ខ ផុតស្រឡះចាកឧបាទាន ១ ញាណជាគ្រឿងពិចារណាឃើញថាមិនមែនខ្លួន ផុតស្រឡះចាកឧបាទាន ៣ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងនឿយណាយ ផុតស្រឡះចាកឧបាទាន ១ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងប្រាសចាករាគៈ ផុតស្រឡះចាកឧបាទាន ១ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងរំលត់ ផុតស្រឡះចាកឧបាទាន ៤ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងរលាស់ ផុតស្រឡះចាកឧបាទាន ៤ ញាណជាគ្រឿងពិចារណាឃើញនូវធម៌មិនមាននិមិត្ត ផុតស្រឡះចាកឧបាទាន ៣

ញាណជាគ្រឿងពិចារណាឃើញនូវធម៌ មិនមានការតម្កល់ទុក ផុតស្រឡះចាកឧបាទាន ១ ញាណជាគ្រឿងពិចារណាឃើញថាសូន្យ ផុតស្រឡះចាកឧបាទាន ៣ ។

[ ១៩៤ ] ញាណជាគ្រឿងពិចារណាឃើញថា មិនទៀង ផុតស្រឡះចាកឧបាទាន ៣ តើដូចម្តេច ។ ញាណជាគ្រឿងពិចារណាឃើញថាមិនទៀង ផុតស្រឡះចាកឧបាទាន ៣ នេះ គឺទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។

ញាណជាគ្រឿងពិចារណាឃើញថាជាទុក្ខ ផុតស្រឡះចាកឧបាទាន ១ តើដូចម្តេច ។ ញាណជាគ្រឿងពិចារណា ឃើញថាជាទុក្ខ ផុតស្រឡះចាកឧបាទាន ១ នេះ គឺកាមុបាទាន ។

ញាណជាគ្រឿងពិចារណា ឃើញថាមិនមែនខ្លួន ផុតស្រឡះចាកឧបាទាន ៣ តើដូចម្តេច ។ ញាណជាគ្រឿងពិចារណាឃើញថា មិនមែនខ្លួន ផុតស្រឡះចាកឧបាទាន ៣ នេះ គឺទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។

ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងនឿយណាយ ផុតស្រឡះចាកឧបាទាន ១ តើដូចម្តេច ។ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងនឿយណាយ ផុតស្រឡះចាកឧបាទាន ១ នេះ គឺកាមុបាទាន ។

ញាណជាគ្រឿងពិចារណាឃើញ នូវធម៌ជាគ្រឿងប្រាសចាករាគៈ ផុតស្រឡះចាកឧបាទាន ១ តើដូចម្តេច ។ ញាណជាគ្រឿងពិចារណាឃើញនូវ

ធម៌ជាគ្រឿងប្រាសចាករាគៈ ផុតស្រឡះចាកឧបាទាន ១ នេះ គឺកាមុបា-
ទាន ។

ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងរំលត់ ផុតស្រឡះចាក ឧបាទាន ៤ តើដូចម្ដេច ។ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ ជាគ្រឿងរំលត់ ផុតស្រឡះចាកឧបាទាន ៤ នេះ គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។

ញាណជាគ្រឿងពិចារណាឃើញនូវធម៌ ជាគ្រឿងរលាស់ ផុតស្រឡះ ចាកឧបាទាន ៤ តើដូចម្ដេច ។ ញាណជាគ្រឿងពិចារណាឃើញនូវធម៌ជាគ្រឿងរលាស់ ផុតស្រឡះចាកឧបាទាន ៤ នេះ គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។

ញាណជាគ្រឿងពិចារណា ឃើញនូវធម៌មិនមាននិមិត្ត ផុតស្រឡះចាក ឧបាទាន ៣ តើដូចម្ដេច ។ ញាណជាគ្រឿងពិចារណាឃើញនូវធម៌មិនមាន និមិត្ត ផុតស្រឡះចាកឧបាទាន ៣ នេះ គឺទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។

ញាណជាគ្រឿងពិចារណា ឃើញនូវធម៌មិនមានការតម្កល់ទុក ផុត ស្រឡះចាកឧបាទាន ១ តើដូចម្ដេច ។ ញាណជាគ្រឿងពិចារណាឃើញនូវ ធម៌មិនមានការតម្កល់ទុក ផុតស្រឡះចាកឧបាទាន ១ នេះ គឺកាមុបាទាន ។

ញាណជាគ្រឿងពិចារណាឃើញថាសូន្យ ផុតស្រឡះចាកឧបាទាន ៣ តើដូចម្ដេច ។ ញាណជាគ្រឿងពិចារណា ឃើញថាសូន្យ ផុតស្រឡះចាក

ឧបាទាន ៣ នេះ គឺទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។

អនិច្ចានុបស្សនាញាណ ១ អនត្តានុបស្សនាញាណ ១ អនិមិត្តានុបស្សនាញាណ ១ សុញ្ញតានុបស្សនាញាណ ១ ញាណទាំង ៤ នេះ ផុតស្រឡះចាកឧបាទាន ៣ គឺទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ ទុក្ខានុបស្សនាញាណ ១ និព្វិទានុបស្សនាញាណ ១ វិរាគានុបស្សនាញាណ ១ អប្បណិហិតានុបស្សនាញាណ ១ ញាណទាំង ៤ នេះ ផុតស្រឡះចាកឧបាទាន ១ គឺកាមុបាទាន ។ និរោធានុបស្សនាញាណ ១ បដិនិស្សគ្គានុបស្សនាញាណ ១ ញាណទាំង ២ នេះ ផុតស្រឡះចាកឧបាទាន ៤ គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ នេះអនុបាទាចិត្តវិមោក្ខ ។

## ចប់ វិមោក្ខកថា បឋមភាណវារៈ ។

[ ១៩៥ ] ក៏ឯវិមោក្ខមុខនេះមាន ៣ យ៉ាង តែងប្រព្រឹត្តទៅដើម្បីចេញចាកលោក គឺប្រព្រឹត្តទៅដើម្បីកិរិយាស៊ុះទៅនៃចិត្ត ក្នុងអនិមិត្តធាតុ ព្រោះកិរិយាពិចារណាឃើញនូវសង្ខារទាំងពួងថា ជាកិរិយាកំណត់នូវដែន នឹងជាផ្លូវ ១ ដើម្បីកិរិយាស៊ុះទៅនៃចិត្ត ក្នុងអប្បណិហិតធាតុ ព្រោះកិរិយាញ៉ាំងចិត្តឲ្យអាចហាន ក្នុងសង្ខារទាំងពួង ១ ដើម្បីកិរិយាស៊ុះទៅនៃចិត្តក្នុងសុញ្ញតធាតុ ព្រោះកិរិយាពិចារណាឃើញនូវធម៌ទាំងពួងថា ជាចំណែកដទៃ ១ នេះ វិមោក្ខមុខ ៣ យ៉ាង តែងប្រព្រឹត្តទៅដើម្បីចេញចាកលោក ។

[ ១៩៦ ] កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង សង្ខារទាំងឡាយ ប្រាកដឡើងដូចម្ដេច កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ សង្ខារទាំងឡាយ ប្រាកដឡើងដូចម្ដេច កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន សង្ខារទាំងឡាយ ប្រាកដឡើងដូចម្ដេច ។ កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង សង្ខារទាំងឡាយប្រាកដឡើង ថាអស់ទៅ កាលធ្វើទុកក្នុងចិត្តថាជាទុក្ខ សង្ខារទាំងឡាយប្រាកដឡើង ថាជាភ័យ កាលធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន សង្ខារទាំងឡាយប្រាកដឡើង ថាសូន្យ ។

កាលព្រះយោគាវចរធ្វើទុកក្នុងចិត្តថាមិនទៀង ចិត្តច្រើនដោយអ្វី កាលលោកធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ចិត្តច្រើនដោយអ្វី កាលលោកធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ចិត្តច្រើនដោយអ្វី ។ កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ចិត្តច្រើនដោយអធិមោក្ខ កាលលោកធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ចិត្តច្រើនដោយបស្សទ្ធិ កាលលោកធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ចិត្តច្រើនដោយវេទៈ ។

ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្តថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ តើបាននូវឥន្ទ្រិយដូចម្ដេច កាលធ្វើទុកក្នុងចិត្តថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ តើបាននូវឥន្ទ្រិយដូចម្ដេច កាលធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ តើបាននូវឥន្ទ្រិយដូចម្ដេច ។ ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្តថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខរមែងបាននូវសទ្ធិន្ទ្រិយ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិរមែងបាននូវសមា-

ធិន្ទ្រិយ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ រមែង
បាននូវបញ្ញិន្ទ្រិយ ។

[ ១៩៧ ] កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើន
ដោយអធិមោក្ខ តើឥន្ទ្រិយណាជាអធិបតី ក្នុងភាវនាមានឥន្ទ្រិយប៉ុន្មានប្រ-
ព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ
និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថា
ដូចម្តេច បុគ្គលណាចម្រើន កាលបុគ្គលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នក
ច្រើនដោយបស្សទ្ធិ តើឥន្ទ្រិយណាជាអធិបតី ក្នុងភាវនាមានឥន្ទ្រិយប៉ុន្មាន
ប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញ-
ប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយ
អត្ថថាដូចម្តេច បុគ្គលណាចម្រើន កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថា
មិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ តើឥន្ទ្រិយណាជាអធិបតី ក្នុងភាវនា
មានឥន្ទ្រិយប៉ុន្មានប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាត-
ប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ច
តែមួយ ភាវនាដោយអត្ថថាដូចម្តេច បុគ្គលណាចម្រើន ។ កាលព្រះយោ-
គាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ សទ្ធិន្ទ្រិយ
ជាអធិបតី ក្នុងភាវនាមានឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ
ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្ប-
ច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថា មានកិច្ចតែមួយ បុគ្គលណាជា

អ្នកប្រតិបត្តិត្រូវ បុគ្គលនោះឈ្មោះថា ចម្រើន ឯបុគ្គលជាអ្នកប្រតិបត្តិខុស មិនមានការចម្រើននូវឥន្ទ្រិយឡើយ កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ សមាធិន្ទ្រិយជាអធិបតី ក្នុងភាវនាមានឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថា មានកិច្ចតែមួយ បុគ្គលណាជាអ្នកប្រតិបត្តិត្រូវ បុគ្គលនោះឈ្មោះថា ចម្រើន ឯបុគ្គលអ្នកប្រតិបត្តិខុស មិនមានការចម្រើននូវឥន្ទ្រិយឡើយ កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ បញ្ញិន្ទ្រិយជាអធិបតី ក្នុងភាវនាមានឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថា មានកិច្ចតែមួយ បុគ្គលណាជាអ្នកប្រតិបត្តិត្រូវ បុគ្គលនោះឈ្មោះថា ចម្រើន បុគ្គលដែលប្រតិបត្តិខុស មិនមានការចម្រើននូវឥន្ទ្រិយឡើយ ។

[ ១៩៨ ] កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ តើឥន្ទ្រិយណាជាអធិបតី ក្នុងភាវនាឥន្ទ្រិយប៉ុន្មានប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ ( មានកិច្ចតែមួយ ) ក្នុងកាលជាទីត្រាស់ដឹង តើឥន្ទ្រិយណាជាអធីបតី ក្នុងការត្រាស់ដឹង មានឥន្ទ្រិយប៉ុន្មានប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញ-

ប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ការនាដោយអត្ថជាដូចម្តេច ការត្រាស់ដឹងដោយអត្ថជាដូចម្តេច ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ តើឥន្ទ្រិយណាជាអធិបតី ក្នុងការនាមានឥន្ទ្រិយប៉ុន្មានប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ ( មានកិច្ចតែមួយ ) ក្នុងកាលជាទីត្រាស់ដឹង តើឥន្ទ្រិយណាជាអធិបតី ក្នុងការត្រាស់ដឹងមានឥន្ទ្រិយប៉ុន្មាន ប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ការនាដោយអត្ថជាដូចម្តេច ការត្រាស់ដឹងដោយអត្ថជាដូចម្តេច ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ តើឥន្ទ្រិយណាជាអធិបតី ក្នុងការនាមានឥន្ទ្រិយប៉ុន្មានប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្ស-យប្បច្ច័យ សម្បយុត្តប្បច្ច័យ ( មានកិច្ចតែមួយ ) ក្នុងកាលជាទីត្រាស់ដឹង តើឥន្ទ្រិយណាជាអធិបតីក្នុងការត្រាស់ដឹងមានឥន្ទ្រិយប៉ុន្មាន ប្រព្រឹត្តទៅតាមឥន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យមានកិច្ចតែមួយ ការនាដោយអត្ថជាដូចម្តេច ការត្រាស់ដឹងដោយអត្ថជាដូចម្តេច ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តថាមិនទៀង ជាអ្នកច្រើនដោយអធិ-

មោក្ខ សទ្ធិន្ទ្រិយជាអធិបតី ក្នុងភាវនាមានឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមសទ្ធិន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ ( មានកិច្ចតែមួយ ) ក្នុងកាលជាទីត្រាស់ដឹង បញ្ញិន្ទ្រិយជាអធិបតីក្នុងការត្រាស់ដឹង ឥន្ទ្រិយ ៤ រមែងប្រព្រឹត្តទៅតាមបញ្ញិន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យមានកិច្ចតែមួយ ភាវនាដោយអត្ថថាមានកិច្ចតែមួយ ការត្រាស់ដឹងដោយអត្ថថាឃើញ ។ យ៉ាងនេះឯង ព្រះយោគាវចរ កាលត្រាស់ដឹង ឈ្មោះថាចម្រើនក៏បាន កាលចម្រើន ឈ្មោះថាត្រាស់ដឹងក៏បាន ។

កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ សទ្ធិន្ទ្រិយជាអធិបតី ក្នុងភាវនាមានឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមសមាធិន្ទ្រិយដែលជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ ( មានកិច្ចតែមួយ ) ក្នុងកាលជាទីត្រាស់ដឹង បញ្ញិន្ទ្រិយជាអធិបតី ក្នុងការត្រាស់ដឹង មានឥន្ទ្រិយ ៤ រមែងប្រព្រឹត្តទៅតាមបញ្ញិន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថាមានកិច្ចតែមួយ ការត្រាស់ដឹងដោយអត្ថថាឃើញ ។ យ៉ាងនេះឯង ព្រះយោគាវចរ កាលត្រាស់ដឹង ឈ្មោះថាចម្រើនក៏បាន កាលចម្រើន ឈ្មោះថាត្រាស់ដឹងក៏បាន ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ បញ្ញិន្ទ្រិយជាអធិបតី ក្នុងការនាមានឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមបញ្ញិន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យមានកិច្ចតែមួយ ក្នុងការត្រាស់ដឹង បញ្ញិន្ទ្រិយជាអធិបតី ក្នុងការត្រាស់ដឹងឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមបញ្ញិន្ទ្រិយជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យមានកិច្ចតែមួយ ការនាដោយអត្ថថា មានកិច្ចតែមួយ ការត្រាស់ដឹងដោយអត្ថថា ឃើញ ។ យ៉ាងនេះឯង ព្រះយោគាវចរ កាលត្រាស់ដឹង ឈ្មោះថាចម្រើនក៏បាន កាលចម្រើន ឈ្មោះថាត្រាស់ដឹងក៏បាន ។

[ ១៩៩ ] កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង តើឥន្ទ្រិយណាដ៏ក្រៃលែង ព្រះយោគាវចរជាសទ្ធាធិមុត្ត តើព្រោះមានឥន្ទ្រិយណាដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តើឥន្ទ្រិយណាដ៏ក្រៃលែង ព្រះយោគាវចរជាកាយសក្ខិ តើព្រោះមានឥន្ទ្រិយណាដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន តើឥន្ទ្រិយណាដ៏ក្រៃលែង ព្រះយោគាវចរជាទិដ្ឋិប្បត្តៈ តើព្រោះមានឥន្ទ្រិយណាដ៏ក្រៃលែង ។ កាលព្រះយោគាចរធ្វើទុកក្នុងចិត្តថាមិនទៀង សទ្ធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាសទ្ធាធិមុត្ត ព្រោះមានសទ្ធិន្ទ្រិយដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ សមាធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាកាយសក្ខិព្រោះមានសមាធិន្ទ្រិយដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន បញ្ញិន្ទ្រិយជាគុណជាតដ៏ក្រែ

លែង ព្រះយោគាវចរជាទិដ្ឋិប្បត្តៈ ព្រោះមានបញ្ញិន្ទ្រិយដ៏ក្រៃលែង ។

[ ២០០ ] បុគ្គលកាលជឿ ឈ្មោះថា ចុះចិត្តស៊ប់ ហេតុនោះបុគ្គលនោះឈ្មោះថា សទ្ធាធិមុត្ត បុគ្គលធ្វើឲ្យជាក់ច្បាស់ព្រោះគុណដែលខ្លួនពាល់ត្រូវហើយ ហេតុនោះ បុគ្គលនោះឈ្មោះថា កាយសក្ខិ បុគ្គលដល់ហើយព្រោះខ្លួនឃើញត្រូវ ហេតុនោះ បុគ្គលនោះឈ្មោះថា ទិដ្ឋិប្បត្តៈ បុគ្គលកាលជឿចុះចិត្តស៊ប់ ហេតុនោះបុគ្គលនោះឈ្មោះថា សទ្ធាធិមុត្ត បុគ្គលពាល់ត្រូវជាដំបូងនូវឈានផស្សៈ ខាងក្រោយទើបធ្វើឲ្យជាក់ច្បាស់នូវនិរោធ គឺនិព្វាន ហេតុនោះបុគ្គលនោះឈ្មោះថា កាយសក្ខិ ញាណ គឺធម្មជាតដែលខ្លួនឃើញហើយ ដឹងច្បាស់ហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញាថា សង្ខារទាំងឡាយជាទុក្ខ និរោធជាសុខ ហេតុនោះបុគ្គលនោះឈ្មោះថា ទិដ្ឋិប្បត្តៈ បុគ្គលណាជាសទ្ធាធិមុត្តក្តី បុគ្គលណាជាកាយសក្ខិក្តី បុគ្គលណាជាទិដ្ឋិប្បត្តៈក្តី បុគ្គលទាំង ៣ ពួកនេះ ឈ្មោះថា សទ្ធាធិមុត្តក៏បាន ឈ្មោះថាកាយសក្ខិក៏បាន ឈ្មោះថាទិដ្ឋិប្បត្តៈក៏បាន ដោយអំណាចនៃវត្ថុ ដោយបរិយាយ ក៏មាន ។

ពាក្យថា ក៏មាន តើក៏មានដូចម្តេច ។ កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តថាមិនទៀង សទ្ធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរឈ្មោះថាសទ្ធាធិមុត្ត ព្រោះមានសទ្ធិន្ទ្រិយដ៏ក្រៃលែង កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាជាទុក្ខ សទ្ធិន្ទ្រិយ ជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាសទ្ធាធិមុត្ត ព្រោះមានសទ្ធិន្ទ្រិយដ៏ក្រៃលែង កាលព្រះយោគាវចរធ្វើទុកក្នុង

ចិត្ត ថាមិនមែនខ្លួន សទ្ធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាសទ្ធាធិមុត្ត ព្រោះមានសទ្ធិន្ទ្រិយដ៏ក្រៃលែង បុគ្គលទាំង ៣ ពួកនេះឈ្មោះថា សទ្ធាធិមុត្ត ដោយអំណាចនៃសទ្ធិន្ទ្រិយ យ៉ាងនេះឯង ។

កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាជាទុក្ខ សមាធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាកាយសក្ខិ ព្រោះមានសមាធិន្ទ្រិយដ៏ក្រៃលែង កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន សមាធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាកាយសក្ខិ ព្រោះមានសមាធិន្ទ្រិយដ៏ក្រៃលែង កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង សមាធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាកាយសក្ខិ ព្រោះមានសមាធិន្ទ្រិយដ៏ក្រៃលែង បុគ្គលទាំង ៣ ពួកនេះឈ្មោះថា កាយសក្ខិ ដោយអំណាចនៃសមាធិន្ទ្រិយ យ៉ាងនេះឯង ។

កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន បញ្ញិន្ទ្រិយជាគុណ-ជាតដ៏ក្រៃលែង ព្រះយោគាវចរជាទិដ្ឋិប្បត្តៈ ព្រោះមានបញ្ញិន្ទ្រិយដ៏ក្រៃលែង កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង បញ្ញិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាទិដ្ឋិប្បត្តៈព្រោះមានបញ្ញិន្ទ្រិយដ៏ក្រៃលែង កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាជាទុក្ខ បញ្ញិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាទិដ្ឋិប្បត្តៈព្រោះបញ្ញិន្ទ្រិយដ៏ក្រៃលែង បុគ្គលទាំង ៣ ពួកនេះឈ្មោះថា ទិដ្ឋិប្បត្តៈដោយអំណាចនៃបញ្ញិន្ទ្រិយ ។ បុគ្គលណាជាសទ្ធា-ធិមុត្តក្តី បុគ្គលណាជាកាយសក្ខិក្តី បុគ្គលណាជាទិដ្ឋិប្បត្តៈក្តី បុគ្គលទាំង ៣

ពួកនេះឈ្មោះថា សទ្ធាធិមុត្តក៏បាន ឈ្មោះថា កាយសក្ខិក៏បាន ឈ្មោះថា ទិដ្ឋិប្បត្តៈក៏បាន ដោយអំណាចនៃវត្ថុ ដោយបរិយាយក៏មាន យ៉ាងនេះឯង ។

បុគ្គលណាជាសទ្ធាធិមុត្តក្តី បុគ្គលណាជាកាយសក្ខិក្តី បុគ្គលណាជាទិដ្ឋិប្បត្តៈក្តី ( បុគ្គល ៣ ពួកនេះតែងមាន ) ឯសទ្ធាធិមុត្តបុគ្គលដោយឡែក កាយសក្ខិបុគ្គលដោយឡែក ទិដ្ឋិប្បត្តបុគ្គលដោយឡែក ។ កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង សទ្ធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាសទ្ធាធិមុត្ត ព្រោះមានសទ្ធិន្ទ្រិយដ៏ក្រៃលែង កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាជាទុក្ខ សមាធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាកាយសក្ខិ ព្រោះមានសមាធិន្ទ្រិយដ៏ក្រៃលែង កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន បញ្ញិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរជាទិដ្ឋិប្បត្តៈ ព្រោះមានបញ្ញិន្ទ្រិយដ៏ក្រៃលែង ។ បុគ្គលណាជាសទ្ធាធិមុត្តក្តី បុគ្គលណាជាកាយសក្ខិក្តី បុគ្គលណាជាទិដ្ឋិប្បត្តៈក្តី បុគ្គលទាំង ៣ ពួកនេះ ( តែងមាន ) ឯសទ្ធាធិមុត្តបុគ្គលដោយឡែក កាយសក្ខិបុគ្គលដោយឡែក ទិដ្ឋិប្បត្តបុគ្គលដោយឡែក យ៉ាងនេះឯង ។

[ ២០១ ] កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង សទ្ធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរបាននូវសោតាបត្តិមគ្គ ព្រោះមានសទ្ធិន្ទ្រិយដ៏ក្រៃលែង ហេតុនោះព្រះយោគាវចរនោះ លោកហៅថា សទ្ធានុសារីបុគ្គល ឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមសទ្ធិន្ទ្រិយដ៏ក្រៃលែងនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ

ការអប់រំនូវឥន្ទ្រិយទាំង ៤ រមែងមានដោយអំណាចនៃសទ្ធិន្ទ្រិយ ព្រោះថា ព្រះយោគាវចរទាំងឡាយណាបាននូវសោតាបត្តិមគ្គ ដោយអំណាចសទ្ធិន្ទ្រិយ ព្រះយោគាវចរទាំងអស់នោះឈ្មោះថា សទ្ធានុសារីបុគ្គល កាលព្រះយោ-គាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង សទ្ធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ឯសោតាបត្តិផលជាផល គឺព្រះយោគាវចរនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះមានសទ្ធិន្ទ្រិយដ៏ក្រៃលែង ហេតុនោះលោកហៅថា សទ្ធាធិមុត្តបុគ្គល ឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមសទ្ធិន្ទ្រិយដ៏ក្រៃលែងនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ ឥន្ទ្រិយ ៤ ជាឥន្ទ្រិយ គឺព្រះយោគាវចរនោះបានអប់រំ អប់រំប្រពៃហើយ ដោយអំណាចនៃសទ្ធិន្ទ្រិយ មួយទៀត ព្រះយោគាវចរទាំងឡាយណាមួយ បានធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ដោយអំណាចនៃសទ្ធិន្ទ្រិយ ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា សទ្ធាធិមុត្តបុគ្គល កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង សទ្ធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរ បានចំពោះនូវសកទាគាមិមគ្គ ព្រោះមានសទ្ធិន្ទ្រិយដ៏ក្រៃលែង ។បេ។ សកទាគាមិផលជាផល គឺព្រះយោគាវចរនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះយោគាវចរ បានចំពោះនូវអនាគាមិមគ្គ ឯអនាគាមិផលជាផល គឺព្រះយោគាវចរនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះយោគាវចរបានចំពោះនូវអរហត្តមគ្គ ឯអរហត្ត-ផលជាផល គឺព្រះយោគាវចរនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ហេតុនោះ ព្រះយោគាវចរនោះ លោកហៅថា សទ្ធាធិមុត្តបុគ្គល ឥន្ទ្រិយ ៤ ប្រព្រឹត្ត

ទៅតាមសទ្ធិន្ទ្រិយដ៏ក្រៃលែងនោះ ។បេ។ ជាសម្បយុត្តប្បច្ច័យ ឥន្ទ្រិយ ៤ ជាឥន្ទ្រិយ គឺព្រះយោគាវចរនោះបានអប់រំ អប់រំប្រពៃហើយ ដោយអំណាចនៃសទ្ធិន្ទ្រិយ ព្រះយោគាវចរទាំងឡាយណា បានធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ដោយអំណាចនៃសទ្ធិន្ទ្រិយ ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា សទ្ធាធិមុត្តបុគ្គល ។

[ ២០២ ] កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាជាទុក្ខ សមាធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរបាននូវសោតាបត្តិមគ្គ ព្រោះមានសមាធិន្ទ្រិយដ៏ក្រៃលែង ហេតុនោះព្រះយោគាវចរនោះ លោកហៅថា កាយសក្ខិបុគ្គល ឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមសមាធិន្ទ្រិយនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ កាលអប់រំ ឥន្ទ្រិយ ៤ រមែងមានអំណាចនៃសមាធិន្ទ្រិយ ព្រោះថាព្រះយោគាវចរទាំងឡាយណា បាននូវសោតាបត្តិមគ្គ ដោយអំណាចនៃសមាធិន្ទ្រិយ ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា កាយសក្ខិបុគ្គល កាលព្រះយោគាវចរធ្វើទុកក្នុងចិត្តថាជាទុក្ខ សមាធិន្ទ្រិយជាគុណជាតដ៏ក្រៃលែង សោតាបត្តិផលជាផល គឺព្រះយោគាវចរនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះមានសមាធិន្ទ្រិយដ៏ក្រៃលែង ។បេ។ ព្រះយោគាវចរបាននូវសកទាគាមិមគ្គ ឯសកទាគាមិផលជាផល គឺព្រះយោគាវចរនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះយោគាវចរបាននូវអនាគាមិមគ្គ ឯអនាគាមិផលជាផល គឺព្រះយោគាវចរនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះយោគាវចរបាននូវអរហត្តមគ្គ ឯអរហត្តផល

ជាផល គឺ ព្រះយោគាវចរនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ហេតុនោះ ព្រះយោគាវចរនោះ លោកហៅថា កាយសក្ខិបុគ្គល ឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមសមាធិន្ទ្រិយដ៏ក្រៃលែងនោះ ទាំងជាសហជាតបច្ច័យ អញ្ញមញ្ញបច្ច័យ និស្សយបច្ច័យ សម្បយុត្តបច្ច័យ ឥន្ទ្រិយទាំង ៤ ជាឥន្ទ្រិយដែលព្រះយោគាវចរនោះ បានអប់រំ អប់រំប្រពៃហើយ ដោយអំណាចនៃសមាធិន្ទ្រិយ ព្រះយោគាវចរទាំងឡាយណា បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តដោយអំណាចនៃសមាធិន្ទ្រិយ ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា កាយសក្ខិបុគ្គល ។

[ ២០៣ ] កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន បញ្ញិន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរ បាននូវសោតាបត្តិមគ្គ ព្រោះមានបញ្ញិន្ទ្រិយដ៏ក្រៃលែង ព្រោះហេតុនោះ ព្រះយោគាវចរនោះ លោកហៅថា ធម្មានុសារីបុគ្គល ឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមបញ្ញិន្ទ្រិយដ៏ក្រៃលែងនោះ ។បេ។ ជាសម្បយុត្តបច្ច័យ ការអប់រំនូវឥន្ទ្រិយ ៤ រមែងមានដោយអំណាចនៃបញ្ញិន្ទ្រិយ ព្រះយោគាវចរទាំងឡាយណា បាននូវសោតាបត្តិមគ្គដោយអំណាចនៃបញ្ញិន្ទ្រិយ ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា ធម្មានុសារីបុគ្គល កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន បញ្ញិន្ទ្រិយជាគុណជាតដ៏ក្រៃលែង សោតាបត្តិផលជាផល គឺព្រះយោគាវចរនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ព្រោះមានបញ្ញិន្ទ្រិយដ៏ក្រៃលែង ហេតុនោះ ព្រះយោគាវចរនោះ លោកហៅថា ទិដ្ឋិប្បត្តបុគ្គល ឥន្ទ្រិយ ៤ ប្រព្រឹត្តទៅ

តាមបញ្ញិន្ទ្រិយដ៏ក្រៃលែងនោះ ។បេ។ ជាសម្បយុត្តប្បច្ច័យ ឥន្ទ្រិយ ៤ ជាឥន្ទ្រិយ គឺព្រះយោគាវចរនោះបានអប់រំ អប់រំប្រពៃហើយ ដោយអំណាចនៃបញ្ញិន្ទ្រិយ ព្រះយោគាវចរទាំងឡាយណា បានធ្វើឲ្យជាក់ច្បាស់នូវសោ-តាបត្តិផលដោយអំណាចនៃបញ្ញិន្ទ្រិយ ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា ទិដ្ឋិប្បត្តបុគ្គល កាលព្រះយោគាវចរធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន បញ្ញិ-ន្ទ្រិយជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរបាននូវសកទាគាមិមគ្គ ព្រោះមានបញ្ញិន្ទ្រិយដ៏ក្រៃលែង ។បេ។ ឯសកទាមិផលជាផល គឺព្រះយោគាវចរនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះយោគាវចរ បាននូវអនាគាមិមគ្គ ឯអនាគាមិផលជាផល គឺព្រះយោគាវចរនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះយោគាវចរបាននូវអរហត្តមគ្គ ឯអរហត្តផលជាផល គឺព្រះយោគាវចរនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ហេតុនោះព្រះយោគាវចរនោះ លោកហៅថា ទិដ្ឋិប្បត្តបុគ្គល ឥន្ទ្រិយ ៤ ប្រព្រឹត្តទៅតាមបញ្ញិន្ទ្រិយដ៏ក្រៃលែងនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ ឥន្ទ្រិយ ៤ ជាឥន្ទ្រិយ គឺព្រះយោគាវចរនោះបានអប់រំ អប់រំប្រពៃហើយ ដោយអំណាចនៃបញ្ញិន្ទ្រិយ ព្រះយោគាវចរទាំងឡាយណា បានធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ដោយអំណាចនៃបញ្ញិន្ទ្រិយ ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា ទិដ្ឋិប្បត្តបុគ្គល ។

[ ២០៤ ] ពួកព្រះយោគាវចរណាមួយ បានអប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី នូវនេក្ខម្ម បានត្រាស់ដឹងហើយក្តី កំពុងត្រាស់ដឹងក្តី នឹង

ត្រាស់ដឹងក្តី ( នូវនេក្ខម្ម ) បានដល់ហើយក្តី កំពុងដល់ក្តី នឹងដល់ក្តី ( នូវនេក្ខម្ម ) បានហើយក្តី កំពុងបានក្តី នឹងបានក្តី ( នូវនេក្ខម្ម ) ចាក់ធ្លុះហើយក្តី កំពុងចាក់ធ្លុះក្តី នឹងចាក់ធ្លុះក្តី ( នូវនេក្ខម្ម ) បានធ្វើឲ្យជាក់ច្បាស់ហើយក្តី កំពុងធ្វើឲ្យជាក់ច្បាស់ក្តី នឹងធ្វើឲ្យជាក់ច្បាស់ក្តី ( នូវនេក្ខម្ម ) បានពាល់ត្រូវហើយក្តី កំពុងពាល់ត្រូវក្តី នឹងពាល់ត្រូវក្តី ( នូវនេក្ខម្ម ) បានដល់នូវការស្ទាត់ហើយក្តី កំពុងដល់ក្តី នឹងដល់ក្តី ( នូវការស្ទាត់ក្នុងនេក្ខម្ម ) ដល់នូវបារមីហើយក្តី កំពុងដល់ក្តី នឹងដល់ក្តី ( នូវនេក្ខម្មបារមី ) ដល់ហើយនូវសេចក្តីក្លៀវក្លាក្តី កំពុងដល់ក្តី នឹងដល់ក្តី ( នូវសេចក្តីក្លៀវក្លាក្នុងនេក្ខម្ម ) ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា សទ្ធាធិមុត្ត ដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃសមាធិន្ទ្រិយឈ្មោះថា ទិដ្ឋិប្បត្តៈ ដោយអំណាចនៃបញ្ញិន្ទ្រិយ ។

[ ២០៥ ] ពួកព្រះយោគាវចរណាមួយ ( អប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ) នូវអព្យាបាទ ។បេ។ នូវអាលោកសញ្ញា សេចក្តីមិនរាយមាយ ការកំណត់ធម៌ ញាណ បាមុជ្ជៈ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ អនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា និព្វិទានុបស្សនា វិរាគានុបស្សនា និរោធានុបស្សនា បដិនិស្សគ្គានុបស្សនា ខយានុបស្សនា វយានុបស្សនា វិបរិណាមានុបស្សនា អនិមិត្តានុបស្សនា អប្បណិហិតា

នុបស្សនា សុញ្ញតានុបស្សនា អធិប្បញ្ញាធម្មវិបស្សនា យថាភូតញ្ញាណ-ទស្សនៈ អាទីនវានុបស្សនា បដិសង្ខានុបស្សនា វិវដ្ដនានុបស្សនា សោ-តាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ ។

ពួកព្រះយោគាវចរណា ( បានអប់រំហើយក្ដី កំពុងអប់រំក្ដី នឹងអប់រំក្ដី ) នូវសតិប្បដ្ឋានទាំង ៤ សម្មប្បធានទាំង ៤ ឥទ្ធិបាទទាំង ៤ ឥន្ទ្រិយទាំង ៥ ពលៈទាំង ៥ ពោជ្ឈង្គទាំង ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ពួកព្រះយោគាវចរណាមួយ បានអប់រំហើយក្ដី កំពុងអប់រំក្ដី នឹងអប់រំក្ដី នូវវិមោក្ខទាំង ៨ បានត្រាស់ដឹងហើយក្ដី កំពុងត្រាស់ដឹងក្ដី នឹងត្រាស់ដឹងក្ដី ( នូវវិមោក្ខទាំង ៨ ) ដល់ហើយក្ដី កំពុងដល់ក្ដី នឹងដល់ក្ដី ( នូវវិមោក្ខទាំង ៨ ) បានហើយក្ដី កំពុងបានក្ដី នឹងបានក្ដី ( នូវវិមោក្ខទាំង ៨ ) ចាក់ធ្លុះហើយក្ដី កំពុងចាក់ធ្លុះក្ដី នឹងចាក់ធ្លុះក្ដី ( នូវវិមោក្ខទាំង ៨ ) ធ្វើឲ្យជាក់ច្បាស់ហើយក្ដី កំពុងធ្វើឲ្យជាក់ច្បាស់ក្ដី នឹងធ្វើឲ្យជាក់ច្បាស់ក្ដី ( នូវវិមោក្ខទាំង ៨ ) ពាល់ត្រូវហើយក្ដី កំពុងពាល់ត្រូវក្ដី នឹងពាល់ត្រូវក្ដី ( នូវវិមោក្ខទាំង ៨ ) ដល់ហើយនូវការស្ទាត់ក្ដី កំពុងដល់ក្ដី នឹងដល់ក្ដី ( នូវការស្ទាត់ក្នុងវិមោក្ខទាំង ៨ ) ដល់ហើយនូវបារមីក្ដី កំពុងដល់ក្ដី នឹងដល់ក្ដី ( នូវបារមីក្នុងវិមោក្ខទាំង ៨ ) ដល់ហើយនូវសេចក្ដីក្លៀវក្លាក្ដី កំពុងដល់ក្ដី នឹងដល់ក្ដី ( នូវសេចក្ដីក្លៀវក្លាក្នុងវិមោក្ខទាំង ៨ ) ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា សទ្ធាធិមុត្ត ដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថា ទិដ្ឋិប្បត្តៈ

ដោយអំណាចនៃបញ្ញិន្ទ្រិយ ។

[ ២០៦ ] ពួកព្រះយោគាវចរណាមួយ បានដល់ហើយក្តី កំពុងដល់ក្តី នឹងដល់ក្តី នូវបដិសម្ភិទាទាំង ៤ ។បេ។ ព្រះយោគាវចរ ទាំងអស់នោះ ឈ្មោះថា សទ្ធាធិមុត្ត ដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថា ទិដ្ឋិប្បត្តៈ ដោយអំណាចនៃបញ្ញិ-ន្ទ្រិយ ។

ពួកព្រះយោគាវចរណាមួយ ចាក់ធ្លុះហើយក្តី កំពុងចាក់ធ្លុះក្តី នឹងចាក់ធ្លុះក្តី នូវវិជ្ជាទាំង ៣ ។បេ។ ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា សទ្ធា-ធិមុត្ត ដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា កាយសក្ខិ ដោយអំណាច នៃសមាធិន្ទ្រិយ ឈ្មោះថា ទិដ្ឋិប្បត្តៈ ដោយអំណាចនៃបញ្ញិន្ទ្រិយ ។

ពួកព្រះយោគាវចរណាមួយ សិក្សាហើយក្តី កំពុងសិក្សាហើយក្តី នឹង សិក្សាក្តី នូវសិក្សាទាំង ៣ ធ្វើឲ្យជាក់ច្បាស់ហើយក្តី កំពុងធ្វើឲ្យជាក់ច្បាស់ ក្តី នឹងធ្វើឲ្យជាក់ច្បាស់ ( នូវសិក្ខាទាំង ៣ ) ពាល់ត្រូវហើយក្តី កំពុង ពាល់ត្រូវក្តី នឹងពាល់ត្រូវក្តី ( នូវសិក្ខាទាំង ៣ ) ដល់ហើយនូវការ ស្ទាត់ក្តី កំពុងដល់ក្តី នឹងដល់ក្តី ( នូវការស្ទាត់ក្នុងសិក្ខាទាំង ៣ ) ដល់ហើយនូវ បារមីក្តី កំពុងដល់ក្តី នឹងដល់ក្តី ( នូវបារមីក្នុងសិក្ខាទាំង ៣ ) ដល់ហើយ នូវសេចក្តីក្លៀវក្លាក្តី កំពុងដល់ក្តី នឹងដល់ក្តី ( នូវសេចក្តីក្លៀវក្លា នូវសិក្ខា ទាំង ៣ ) ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា សទ្ធាធិមុត្ត ដោយ អំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃសមាធិន្ទ្រិយ

ឈ្មោះថា ទិដ្ឋិប្បត្តៈ ដោយអំណាចនៃបញ្ញិន្ទ្រិយ ។

ពួកព្រះយោគាវចរណាមួយកំណត់ដឹងនូវទុក្ខ លះបង់នូវសមុទយ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ អប់រំនូវមគ្គ ព្រះយោគាវចរទាំងអស់នោះ ឈ្មោះថា សទ្ធាធិមុត្ត ដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថា ទិដ្ឋិប្បត្តៈ ដោយអំណាចនៃបញ្ញិន្ទ្រិយ ។

[ ២០៧ ] ការត្រាស់ដឹងនូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង បុគ្គលត្រាស់ដឹងនូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង ។ ការត្រាស់ដឹងនូវសច្ចៈដោយអាការ ៤ យ៉ាង បុគ្គលត្រាស់ដឹងនូវសច្ចៈ ដោយអាការ ៤ យ៉ាង គឺត្រាស់ដឹងនូវទុក្ខសច្ចៈដែលជាបរិញ្ញាបដិវេធៈ ១ ត្រាស់ដឹងនូវសមុទយសច្ចៈដែលជាបហានប្បដិវេធៈ ១ ត្រាស់ដឹងនូវនិរោធសច្ចៈ ដែលជាសច្ឆិកិរិយាបដិវេធៈ ១ ត្រាស់ដឹងនូវមគ្គសច្ចៈ ដែលជាភាវនាបដិវេធៈ ១ នេះឯងការត្រាស់ដឹងនូវសច្ចៈ ដោយអាការ ៤ យ៉ាងនេះឯង បុគ្គលកាលត្រាស់ដឹងនូវសច្ចៈ ដោយអាការ ៤ យ៉ាង ដែលឈ្មោះថា សទ្ធាធិមុត្ត ដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថា ទិដ្ឋិប្បត្តៈ ដោយអំណាចនៃបញ្ញិន្ទ្រិយ ។

ការត្រាស់ដឹងនូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង បុគ្គលត្រាស់ដឹងនូវសច្ចៈទាំងឡាយ ដោយអាការប៉ុន្មានយ៉ាង ។ ការត្រាស់ដឹងនូវសច្ចៈដោយអាការ ៩ បុគ្គលត្រាស់ដឹងនូវសច្ចៈទាំងឡាយ ដោយអាការ ៩ យ៉ាង គឺត្រាស់នូវទុក្ខសច្ចៈដែលជាបរិញ្ញាបដិវេធៈ ១ ត្រាស់ដឹងនូវសមុទយសច្ចៈ

ដែលជាបហានប្បដិវេធៈ ១ ត្រាស់ដឹងនូវនិរោធសច្ចៈ ដែលជាសច្ឆិកិរិយា-បដិវេធៈ ១ ត្រាស់ដឹងនូវមគ្គសច្ចៈដែលជាភាវនាបដិវេធៈ ១ ការត្រាស់ដឹងដោយកិរិយាអប់រំនូវធម៌ទាំងពួង ( ភាវនាបដិវេធៈ ) ១ ការត្រាស់ដឹងដោយកិរិយាកំណត់នូវសង្ខារពួង ( បរិញ្ញាបដិវេធៈ ) ១ ការត្រាស់ដឹងដោយការលះបង់នូវកុសលទាំងពួង ( បហានប្បដិវេធៈ ) ១ ការត្រាស់ដឹងដោយកិរិយាអប់រំនូវមគ្គទាំង ៤ ( ភាវនាបដិវេធៈ ) ១ ការត្រាស់ដឹងដោយកិរិយា ធ្វើឲ្យជាក់ច្បាស់នូវនិរោធ ( សច្ឆិកិរិយាបដិវេធៈ ) ១ នេះឯងការត្រាស់ដឹងនូវសច្ចៈ ដោយអាការ ៩ យ៉ាង នេះឯងបុគ្គលកាលត្រាស់ដឹងនូវសច្ចៈទាំងឡាយ ដោយអាការ ៩ យ៉ាង ដែលឈ្មោះថាសទ្ធាធិមុត្ត ដោយអំណាចនៃសទ្ធិន្ទ្រិយ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃសមាធិន្ទ្រិយ ឈ្មោះថា ទិដ្ឋិប្បត្តៈ ដោយអំណាចនៃបញ្ញិន្ទ្រិយ ។

## ចប់ ទុតិយភាណវារៈ ។

[ ២០៨ ] កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង សង្ខារទាំងឡាយប្រាកដឡើងដូចម្តេច កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ សង្ខារទាំងឡាយប្រាកដឡើងដូចម្តេច កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន សង្ខារទាំងឡាយប្រាកដឡើងដូចម្តេច ។ កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង សង្ខារទាំងឡាយប្រាកដឡើង ថាអស់ទៅកាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ

សង្ខារទាំងឡាយប្រាកដឡើង ថាជាភ័យ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន សង្ខារទាំងឡាយប្រាកដឡើង ថាសូន្យ ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ចិត្តច្រើនដោយអ្វី កាលលោកធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ចិត្តច្រើនដោយអ្វី កាលលោកធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ចិត្តច្រើនដោយអ្វី ។ កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ចិត្តច្រើនដោយអធិមោក្ខ ( សេចក្ដីជឿស៊ប់ ) កាលលោកធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ចិត្តច្រើនដោយបស្សទ្ធិ ( សេចក្ដីស្ងប់ ) កាលលោកធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ចិត្តច្រើនដោយវេទៈ ។

ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ តើនឹងបាននូវវិមោក្ខដូចម្ដេច កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ តើនឹងបាននូវវិមោក្ខដូចម្ដេច កាលធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ តើនឹងបាននូវវិមោក្ខដូចម្ដេច ។ ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ រមែងបាននូវអនិមិត្តវិមោក្ខ កាលធ្វើទុកក្នុងចិត្តថាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ រមែងបាននូវអប្បណិហិតវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ រមែងបាននូវសុញ្ញតវិមោក្ខ ។

[ ២០៩ ] កាលព្រះយោគាវចរធ្វើទុកក្នុងចិត្តថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ តើមានវិមោក្ខដូចម្ដេច ជាអធិបតី ។ ក្នុងភាវនា វិមោក្ខប៉ុន្មានប្រព្រឹត្តទៅតាមវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញ-

មញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថាដូចម្តេច បុគ្គលណាចម្រើន ។

កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបសទ្ធិ តើវិមោក្ខអ្វីជាអធិបតី, ក្នុងភាវនាមានវិមោក្ខប៉ុន្មានប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថាដូចម្តេច បុគ្គលណាចម្រើន ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទ តើ វិមោក្ខអ្វីជាអធិបតី ក្នុងភាវនាមានវិមោក្ខប៉ុន្មាន ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថាដូចម្តេច បុគ្គលណាចម្រើន ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ អនិមិត្តវិមោក្ខជាអធិបតី, ក្នុងភាវនាមានវិមោក្ខពីរប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ចយ មានកិច្ចតែមួយ ភាវនាដោយអត្ថថា មានកិច្ចតែមួយ បុគ្គលណាប្រតិបត្តិត្រូវ បុគ្គលនោះ ឈ្មោះថា ចម្រើន ឯបុគ្គលដែលប្រតិបត្តិខុស មិនមានការចម្រើននូវវិមោក្ខទេ ។

កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ជាអ្នកច្រើនដោយបសទ្ធិ

អប្បណិហិតវិមោក្ខជាអធិបតី, ក្នុងភាវនាមានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថា មានកិច្ចតែមួយ បុគ្គលណាប្រតិបត្តិត្រូវ បុគ្គលនោះ ឈ្មោះថា ចម្រើន ឯបុគ្គលដែលប្រតិបត្តិខុស មិនមានការចម្រើននូវវិមោក្ខទេ ។

កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ សុញ្ញតវិមោក្ខជាអធិបតិ, ក្នុងភាវនាមានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ ភាវនាដោយអត្ថថាមានកិច្ចតែមួយ បុគ្គលណាប្រតិបត្តិត្រូវ បុគ្គលនោះឈ្មោះថា ចម្រើន ឯបុគ្គលដែលប្រតិបត្តិខុស មិនមានការចម្រើននូវវិមោក្ខទេ ។

[ ២១០ ] កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ជាអ្នកច្រើនដោយអធិមោក្ខ តើវិមោក្ខអ្វីជាអធិបតី, ក្នុងភាវនា មានវិមោក្ខប៉ុន្មានប្រព្រឹត្តទៅតាមនូវវិមោក្ខ ជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថា មានកិច្ចតែមួយ, ក្នុងកាលជាទីត្រាស់ដឹង តើវិមោក្ខអ្វីជាអធិបតី, ក្នុងការត្រាស់ដឹង មានវិមោក្ខប៉ុន្មានប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថាដូចម្តេច ការត្រាស់ដឹង ដោយ

អត្ថជាដូចម្តេច ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តជាជាទុក្ខ ជាអ្នកច្រើនដោយបស្សទ្ធិ តើវិមោក្ខអ្វីជាអធិបតី ក្នុងភាវនាមានវិមោក្ខប៉ុន្មានប្រព្រឹត្តទៅ តាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនា ដោយអត្ថជា មានកិច្ចតែមួយ ក្នុងកាលជាទីត្រាស់ដឹង តើវិមោក្ខអ្វីជាអធិបតី ក្នុងការត្រាស់ដឹង តើវិមោក្ខប៉ុន្មាន ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថជាដូចម្តេច ការត្រាស់ដឹងដោយអត្ថជាដូចម្តេច ។

កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ជាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ តើវិមោក្ខអ្វីជាអធិបតី ក្នុងភាវនាមានវិមោក្ខប៉ុន្មាន ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និ-ស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថជា មានកិច្ចតែមួយ ក្នុងកាលជាទីត្រាស់ដឹង តើវិមោក្ខអ្វីជាអធិបតី ក្នុងការត្រាស់ដឹង វិមោក្ខប៉ុន្មានប្រព្រឹត្តទៅតាមនូវវិមោក្ខ ជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថជាដូចម្តេច ការត្រាស់ដឹង ដោយអត្ថជាដូចម្តេច ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តជាមិនទៀង ជាអ្នកច្រើនដោយអធិ-

មោក្ខ អនិមិត្តវិមោក្ខជាអធិបតី, ក្នុងភាវនាមានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ សូម្បីក្នុងកាលជាទីត្រាស់ដឹង ក៏មានអនិមិត្តវិមោក្ខជាអធិបតីដែរ ក្នុងការត្រាស់ដឹង មានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថា មានកិច្ចតែមួយ ការត្រាស់ដឹងដោយអត្ថថា ឃើញ យ៉ាងនេះឯង ព្រះយោគាវចរកាលត្រាស់ដឹង ឈ្មោះថា ចម្រើនក៏បាន កាលចម្រើនឈ្មោះថា ត្រាស់ដឹងក៏បាន ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តថាជាទុក្ខ ជាអ្នកច្រើនដោយបសទ្ធិ អប្បណិហិតវិមោក្ខជាអធិបតី, ក្នុងភាវនាមានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ សូម្បីក្នុងកាលជាទីត្រាស់ដឹង ក៏មានអប្បណិហិតវិមោក្ខជាអធិបតីដែរ, ក្នុងការត្រាស់ដឹង មានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ភាវនាដោយអត្ថថា មានកិច្ចតែមួយ ការត្រាស់ដឹងដោយអត្ថថា ឃើញ យ៉ាងនេះឯង ព្រះយោគាវចរ កាលត្រាស់ដឹង ឈ្មោះថា ចម្រើនក៏បាន កាលចម្រើន ឈ្មោះថា ត្រាស់ដឹងក៏បាន ។

កាលព្រះយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ជាអ្នកច្រើនដោយវេទៈ សុញ្ញតវិមោក្ខជាអធិបតី, ក្នុងការនាមានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ សូម្បីក្នុងកាលជាទីត្រាស់ដឹង ក៏មានសុញ្ញតវិមោក្ខជាអធិបតីដែរ ក្នុងការត្រាស់ដឹង មានវិមោក្ខ ២ ប្រព្រឹត្តទៅតាមនូវវិមោក្ខ ជាអធិបតីនោះ ទាំងជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ មានកិច្ចតែមួយ ការនាដោយអត្ថថា មានកិច្ចតែមួយ ការត្រាស់ដឹងដោយអត្ថថា ឃើញ យ៉ាងនេះឯង ព្រះយោគាវចរ កាលត្រាស់ដឹង ឈ្មោះថា ចម្រើនក៏បាន កាលចម្រើន ឈ្មោះថា ត្រាស់ដឹងក៏បាន ។

[ ២១១ ] កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង តើវិមោក្ខអ្វីដ៏ក្រៃលែង ព្រះយោគាវចរឈ្មោះថា សទ្ធាធិមុត្ត តើព្រោះមានវិមោក្ខអ្វីដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តើវិមោក្ខអ្វីដ៏ក្រៃលែង ព្រះយោគាវចរ ឈ្មោះថា កាយសក្ខិ តើព្រោះមានវិមោក្ខអ្វីដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តើវិមោក្ខអ្វីដ៏ក្រៃលែង ព្រះយោគាវចរ ឈ្មោះថា ទិដ្ឋិប្បត្តៈ តើព្រោះមានវិមោក្ខអ្វីដ៏ក្រៃលែង ។

កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង អនិមិត្តវិមោក្ខ ជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរ ឈ្មោះថា សទ្ធាធិមុត្ត ព្រោះមានអនិមិត្តវិមោក្ខដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ អប្បណិហិតវិមោក្ខ

ជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរ ឈ្មោះថា កាយសក្ខិ ព្រោះមានអប្បណិហិតវិមោក្ខដ៏ក្រៃលែង កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន សុញ្ញតវិមោក្ខ ជាគុណជាតដ៏ក្រៃលែង ព្រះយោគាវចរឈ្មោះថា ទិដ្ឋិប្បត្តៈ ព្រោះមានសុញ្ញតវិមោក្ខដ៏ក្រៃលែង ។

[ ២១២ ] ព្រះយោគាវចរកាលជឿ ចុះចិត្តស៊ប់ ហេតុនោះឈ្មោះថា សទ្ធាធិមុត្តបុគ្គល ព្រះយោគាវចរធ្វើឲ្យជាក់ច្បាស់ ព្រោះពាល់ត្រូវ ( នូវឈាន ) ហេតុនោះឈ្មោះថា កាយសក្ខិបុគ្គល ព្រះយោគាវចរសម្រេចហើយព្រោះយល់ត្រូវ ហេតុនោះឈ្មោះថា ទិដ្ឋិប្បត្តបុគ្គល ព្រះយោគាវចរកាលជឿ ចុះចិត្តស៊ប់ ហេតុនោះឈ្មោះថា សទ្ធាធិមុត្តបុគ្គល ព្រះយោគាវចរ ពាល់ត្រូវជាដំបូងនូវឈានផស្សៈ ក្នុងកាលខាងក្រោយ ទើបធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ជាទីរលត់ ( កិលេស ) ហេតុនោះឈ្មោះថា កាយសក្ខិបុគ្គល ញាណ គឺជាធម្មជាតដែលខ្លួនឃើញហើយ ដឹងហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា ថាសង្ខារជាទុក្ខ និរោធជាសុខ ហេតុនោះឈ្មោះថា ទិដ្ឋិប្បត្តបុគ្គល ។

យោគាវចរណាមួយ អប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តីនូវនេក្ខម្មៈ ។បេ។ យោគាវចរទាំងអស់នោះ ឈ្មោះថា សទ្ធាធិមុត្ត ដោយអំណាចនៃអនិមិត្តវិមោក្ខ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃអប្បណិហិតវិមោក្ខ ឈ្មោះថា ទិដ្ឋិប្បត្តៈ ដោយអំណាចនៃសុញ្ញតវិមោក្ខ ។ យោគាវចរណាមួយ ( អប់រំហើយក្តី កំពុងអប់រំក្តី នឹងអប់រំក្តី ) នូវអព្យាបាទ ។បេ។ នូវ

អាលោកសញ្ញា នូវអវិក្ខេប ។បេ។

យោគាវចរណាមួយកំណត់ដឹងនូវទុក្ខ លះបង់នូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ អប់រំនូវមគ្គ យោគាវចរទាំងអស់នោះ ឈ្មោះថា សទ្ធាធិមុត្ត ដោយអំណាចនៃអនិមិត្តវិមោក្ខ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃអប្បណិហិតវិមោក្ខ ឈ្មោះថា ទិដ្ឋិប្បត្តៈដោយអំណាចនៃសុញ្ញតវិមោក្ខ ។

[ ២១៣ ] ការត្រាស់ដឹងនូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង បុគ្គលត្រាស់ដឹងនូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង ។ ការត្រាស់ដឹងនូវសច្ចៈដោយអាការ ៤ យ៉ាង បុគ្គលត្រាស់ដឹងនូវសច្ចៈ ក៏ដោយអាការ ៤ យ៉ាងដែរ គឺបុគ្គលត្រាស់ដឹងនូវទុក្ខសច្ច ដែលជាបរិញ្ញាបដិវេធៈ ១ ត្រាស់ដឹងនូវសមុទយសច្ចៈដែលជាបហានប្បដិវេធៈ ១ ត្រាស់ដឹងនូវនិរោធសច្ចដែលជាសច្ឆិកិរិយាបដិវេធៈ ១ ត្រាស់ដឹងនូវមគ្គសច្ចដែលជាភាវនាបដិវេធៈ ១ នេះឯងការត្រាស់ដឹងនូវសច្ចៈដោយអាការ ៤ យ៉ាងនេះឯង ព្រះយោគាវចរ កាលត្រាស់ដឹងនូវសច្ចៈដោយអាការទាំង ៤ យ៉ាង ដែលឈ្មោះថា សទ្ធាធិមុត្ត ដោយអំណាចនៃអនិមិត្តវិមោក្ខ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃអប្បណិហិតវិមោក្ខ ឈ្មោះថា ទិដ្ឋិប្បត្តៈ ដោយអំណាចនៃសុញ្ញតវិមោក្ខ ។

ការត្រាស់ដឹងនូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង បុគ្គលត្រាស់ដឹងនូវសច្ចៈ ដោយអាការប៉ុន្មានយ៉ាង ។ ការត្រាស់ដឹងនូវសច្ចៈដោយអាការ ៩ យ៉ាង បុគ្គលត្រាស់ដឹងនូវសច្ចៈដោយអាការ ៩ យ៉ាងដែរ គឺបុគ្គលត្រាស់

ដឹងនូវទុក្ខសច្ច ដែលជាបរិញ្ញាបដិវេធៈ ១ ។បេ។ ការត្រាស់ដឹង ដោយការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ១ នេះឯងការត្រាស់ដឹងនូវសច្ចៈ ដោយអាការ ៩ យ៉ាង នេះឯងយោគាវចរកាលត្រាស់ដឹងនូវសច្ចៈ ដោយអាការ ៩ យ៉ាង ដែលឈ្មោះថា សទ្ធាធិមុត្តដោយអំណាចនៃអនិមិត្តវិមោក្ខ ឈ្មោះថា កាយសក្ខិ ដោយអំណាចនៃអប្បណិហិតវិមោក្ខ ឈ្មោះថា ទិដ្ឋិប្បត្តៈ ដោយអំណាចនៃសុញ្ញតវិមោក្ខ ។

[ ២១៤ ] យោគាវចរកាលធ្វើទុកក្នុងចិត្ត ថាមិនទៀង រមែងដឹង ឃើញតាមពិតនូវធម៌ទាំងឡាយ តើដូចម្តេច ការឃើញប្រពៃ តើដូចម្តេច សង្ខារទាំងពួងដែលយោគាវចរ ឃើញប្រពៃហើយ ថាមិនទៀង ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ តើដូចម្តេច សេចក្តីជឿងធ្ងល់ក្នុងធម៌ដូចម្តេចដែលយោគាវចរលះបង់បាន ។

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ រមែងដឹង ឃើញតាមពិតនូវធម៌ទាំងឡាយ តើដូចម្តេច ការឃើញប្រពៃ តើដូចម្តេច សង្ខារទាំងពួងដែលយោគាវចរឃើញប្រពៃហើយ ថាជាទុក្ខ ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ តើដូចម្តេច សេចក្តីជឿងធ្ងល់ក្នុងធម៌ដូចម្តេច ដែលយោគាវចរលះបង់បាន ។

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន រមែងដឹង ឃើញតាមពិតនូវធម៌ទាំងឡាយ តើដូចម្តេច ការឃើញប្រពៃ តើដូចម្តេច ធម៌ទាំងពួងដែលយោគាវចរ ឃើញប្រពៃហើយ ថាមិនមែនខ្លួន ព្រោះអាស្រ័យ

នូវការឃើញប្រពៃនោះ តើដូចម្តេច សេចក្តីងឿងឆ្ងល់ក្នុងធម៌ដូចម្តេចដែល យោគាវចរលះបង់បាន ។

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង រមែងដឹង ឃើញ តាមពិតនូវនិមិត្ត ព្រោះតែហេតុនោះលោកទើបហៅថា ការឃើញប្រពៃ កាលបើយ៉ាងនេះ សង្ខារទាំងពួង ឈ្មោះថា យោគាវចរឃើញប្រពៃហើយ ថាមិនទៀង ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ ទាំងសេចក្តីងឿងឆ្ងល់ក្នុងសង្ខារទាំងនុ៎ះ ក៏លោកលះបង់បាន ។

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ រមែងដឹង ឃើញតាមពិតនូវបវត្តៈ ( ការប្រព្រឹត្តិទៅ ) ព្រោះតែហេតុនោះលោកទើបហៅថា ការឃើញប្រពៃ កាលបើយ៉ាងនេះ សង្ខារទាំងពួងឈ្មោះថា យោគាវចរឃើញប្រពៃហើយ ថាជាទុក្ខ ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ ទាំងសេចក្តីងឿងឆ្ងល់ក្នុងសង្ខារទាំងនុ៎ះ ក៏លោកលះបង់បាន ។

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន រមែងដឹង ឃើញតាមពិតនូវនិមិត្តផង នូវបវត្តៈផង ព្រោះតែហេតុនោះ លោកទើបហៅថា ការឃើញប្រពៃ កាលបើយ៉ាងនេះ ធម៌ទាំងពួងឈ្មោះថា យោគាវចរ ឃើញប្រពៃហើយ ថាមិនមែនខ្លួន ព្រោះអាស្រ័យនូវការឃើញប្រពៃនោះ ទាំងសេចក្តីងឿងឆ្ងល់ក្នុងធម៌ទាំងនុ៎ះ ក៏លោកលះបង់បាន ។

ការដឹងតាមពិតណាក្តី ការឃើញប្រពៃណាក្តី ការឆ្លងចាកសេចក្តីងឿងឆ្ងល់ណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេង

គ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ ការដឹងតាមពិតណាក្តី ការឃើញប្រពៃណាក្តី ការឆ្លងចាកសេចក្តីងឿងឆ្ងល់ណាក្តី ធម៌ទាំងនេះមានសេចក្តីដូចគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

[ ២១៥ ] កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង តើមានអ្វីប្រាកដឡើងថាជាភ័យ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តើមានអ្វីប្រាកដឡើងថាជាភ័យ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តើមានអ្វីប្រាកដឡើងថាជាភ័យ ។ កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង មាននិមិត្តប្រាកដឡើង ថាជាភ័យ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ មានបវត្តៈប្រាកដឡើងថាជាភ័យ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន មាននិមិត្តផង មានបវត្តៈផងប្រាកដឡើង ថាជាភ័យ ។

បញ្ញាក្នុងការប្រាកដឡើង ថាជាភ័យឯណាក្តី ការដឹងក្នុងទោសឯណាក្តី ការនឿយណាយឯណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ បញ្ញាក្នុងការប្រាកដឡើង ថាជាភ័យឯណាក្តី ការដឹងក្នុងទោសឯណាក្តី ការនឿយណាយឯណាក្តី ធម៌ទាំងនេះមានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

ការយល់ឃើញ ថាមិនមែនខ្លួនឯណាក្តី ការយល់ឃើញ ថាសូន្យឯណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬក៏ មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ ការយល់ឃើញថា មិន

មែនខ្លួនឯណាក្តី ការយល់ឃើញថា សូន្យឯណាក្តី ធម៌ទាំងនេះមានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

[ ២១៦ ] កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ញាណកើតឡើង ព្រោះពិចារណានូវអ្វី កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ញាណកើតឡើងព្រោះពិចារណានូវអ្វី កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ញាណកើតឡើង ព្រោះពិចារណានូវអ្វី ។ កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ញាណកើតឡើង ព្រោះពិចារណានូវនិមិត្ត កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ញាណកើតឡើង ព្រោះពិចារណានូវបវត្តៈ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ញាណកើតឡើង ព្រោះពិចារណានូវនិមិត្តនិងបវត្តៈ ។

មុញ្ចិតុកម្យតាញាណណាក្តី បដិសង្ខានុបស្សនាញាណណាក្តី សង្ខារុបេក្ខាញាណណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ មុញ្ចិតុកម្យតាញាណណាក្តី បដិសង្ខានុបស្សនាញាណណាក្តី សង្ខារុបេក្ខាញាណណាក្តី ធម៌ទាំងនោះមានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

កាលយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង តើចិត្តចេញចាកអ្វី ចិត្តស្ទុះទៅក្នុងអ្វី កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តើចិត្តចេញចាកអ្វី ចិត្តស្ទុះទៅក្នុងអ្វី កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តើចិត្តចេញចាកអ្វី ចិត្តស្ទុះទៅក្នុងអ្វី ។ កាលយោគាវចរ ធ្វើទុកក្នុងចិត្ត ថាមិនទៀង ចិត្តចេញចាកនិមិត្ត ចិត្តស្ទុះទៅក្នុងអនិមិត្ត កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ចិត្តចេញចាក

បវត្តៈ ចិត្តស្ទុះទៅក្នុងអប្បវត្តៈ កាលធ្វើទុកក្នុងចិត្តថា មិនមែនខ្លួន ចិត្តចេញចាកនិមិត្តផង ចេញចាកបវត្តៈផង ចិត្តស្ទុះទៅក្នុងអនិមិត្តផង ក្នុងអប្បវត្តៈ គឺ និរោធនិព្វានធាតុផង ។

បញ្ញាក្នុងការងាកចេញ បែរចេញ ចាកសង្ខារនិមិត្តខាងក្រៅឯណាក្តី គោត្រភូធម៌ទាំងឡាយឯណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ បញ្ញាក្នុងការងាកចេញ បែរចេញ ចាកសង្ខារនិមិត្តខាងក្រៅឯណាក្តី គោ-ត្រភូធម៌ទាំងឡាយឯណាក្តី ធម៌ទាំងនេះមានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀងរមែងរួច ( ចាកកិលេស ) ដោយវិមោក្ខអ្វី កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ រមែងរួច ( ចាកកិលេស ) ដោយវិមោក្ខអ្វី កាលធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន រមែងរួច ( ចាកកិលេស ) ដោយវិមោក្ខអ្វី ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង រមែងរួច ( ចាកកិលេស ) ដោយអនិមិត្តវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ រមែងរួច ( ចាកកិលេស ) ដោយអប្បណិហិតវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន រមែងរួច ( ចាកកិលេស ) ដោយសុញ្ញតវិមោក្ខ ។

បញ្ញាក្នុងការងាកចេញ បែរចេញ ចាកហេតុទាំងពីរណាក្តី ការដឹងក្នុងមគ្គណាក្តី តើធម៌ទាំងនេះ មានសេចក្តីផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។ បញ្ញាក្នុងការងាក

ចេញ បែរចេញ ចាកហេតុទាំងពីរណាក្តី ការជីងក្នុងមគ្គណាក្តី ធម៌ទាំងនេះមានសេចក្តីជាមួយគ្នា តែព្យញ្ជនៈផ្សេងគ្នា ។

[ ២១៧ ] វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា តើដោយអាការប៉ុន្មានយ៉ាង វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា តើដោយអាការប៉ុន្មានយ៉ាង ។ វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអាការ ៤ យ៉ាង វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអាការ ៧ យ៉ាង ។

វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអាការ ៤ យ៉ាង តើអ្វីខ្លះ គឺ ដោយអត្ថថា ជាអធិបតី ១ ដោយអត្ថថា អធិដ្ឋាន ១ ដោយអត្ថថា បង្អោន ១ ដោយអត្ថថា ចេញទៅ ១ ។

វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថា ជាអធិបតី តើដូចម្តេច ។ កាលយោគាវចរធ្វើទុកក្នុងចិត្ត ថាមិនទៀង មានអនិមិត្តវិមោក្ខជាអធិបតី កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ មានអប្បណិហិតវិមោក្ខជាអធិ-បតី កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន មានសុញ្ញតវិមោក្ខ ជាអធិបតី វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថា ជាអធិបតី យ៉ាងនេះឯង ។

វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថា អធិដ្ឋាន តើដូចម្តេច ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង តែងអធិដ្ឋាននូវចិត្តដោយអំណាចនៃអនិមិត្តវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តែងអធិដ្ឋាននូវចិត្តដោយអំណាចនៃអប្បណិហិតវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាមិនមែន

ខ្លួន តែងអធិដ្ឋានទូវចិត្ត ដោយអំណាចនៃសុញ្ញតវិមោក្ខ វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថា អធិដ្ឋាន យ៉ាងនេះឯង ។

វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថា បង្អោន តើដូចម្តេច ។ ព្រះយោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង តែងបង្អោនចិត្ត ដោយអំណាចនៃអនិមិត្តវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តែងបង្អោនចិត្តដោយអំណាចនៃអប្បណិហិតវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តែងបង្អោនចិត្ត ដោយអំណាចនៃសុញ្ញតវិមោក្ខ វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នាដោយអត្ថថា បង្អោន យ៉ាងនេះឯង ។

វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអត្ថថាចេញទៅ តើដូចម្តេច ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង តែងចេញទៅកាន់ព្រះនិព្វាន ជាទីរលត់កិលេស ដោយអំណាចនៃអនិមិត្តវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ តែងចេញទៅកាន់ព្រះនិព្វានជាទីរលត់កិលេស ដោយអំណាចនៃអប្បណិហិតវិមោក្ខ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន តែងចេញទៅកាន់ព្រះនិព្វាន ជាទីរលត់កិលេស ដោយអំណាចនៃសុញ្ញតវិមោក្ខ វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នាដោយអត្ថថា ចេញទៅ យ៉ាងនេះឯង វិមោក្ខទាំង ៣ មានក្នុងខណៈផ្សេងគ្នា ដោយអាការ ៤ យ៉ាងនេះឯង ។

[ ២១៨ ] វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអាការ ៧ យ៉ាង តើអ្វីខ្លះ គឺដោយអត្ថថា ប្រជុំចុះ ១ ដោយអត្ថថា បានលុះ ១ ដោយអត្ថថា បានចំពោះ ១ ដោយអត្ថថា ចាក់ធ្លុះ ១ ដោយអត្ថថា

ធ្វើឲ្យជាក់ច្បាស់ ១ ដោយអត្ថថា ប៉ះពាល់ ១ ដោយអត្ថថា ត្រាស់ដឹង ១ ។

វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអត្ថថា ប្រជុំចុះ ដោយអត្ថថា បានលុះ ដោយអត្ថថា បានចំពោះ ដោយអត្ថថា ចាក់ធ្លុះ ដោយអត្ថថា ធ្វើឲ្យជាក់ច្បាស់ ដោយអត្ថថា ប៉ះពាល់ ដោយអត្ថថា ត្រាស់ដឹង តើដូចម្តេច ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនទៀង រមែងរួចចាកនិមិត្ត ( ដោយសភាវៈណា ) ហេតុនោះសភាវៈនោះ ឈ្មោះថា អនិមិត្តវិមោក្ខ យោគាវចរ រួចចាកនិមិត្តណា មិនតាំងនៅក្នុងនិមិត្តនោះទៀត ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ យោគាវចរមិនតម្កល់នៅក្នុងនិមិត្តណា សូន្យចាកនិមិត្តនោះ ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ យោគាវចរ មិនមាននិមិត្ត ដោយសុញ្ញតនិមិត្តណា ហេតុនោះនិមិត្តនោះ ឈ្មោះថា អនិមិត្តវិមោក្ខ វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអត្ថថា ប្រជុំចុះ ដោយអត្ថថា បានលុះ ដោយអត្ថថា បានចំពោះ ដោយអត្ថថា ចាក់ធ្លុះ ដោយអត្ថថា ធ្វើឲ្យជាក់ច្បាស់ ដោយអត្ថថា ប៉ះពាល់ ដោយអត្ថថា ត្រាស់ដឹង យ៉ាងនេះឯង ។ យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាជាទុក្ខ រមែងរួចចាកទីតម្កល់ ( ដោយសភាវៈណា ) ហេតុនោះ សភាវៈនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ យោគាវចរ មិនតាំងនៅក្នុងនិមិត្តណា សូន្យចាកនិមិត្តនោះ ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ យោគាវចរ មិនមាននិមិត្តដោយសុញ្ញតនិមិត្តណា ហេតុនោះនិមិត្តនោះឈ្មោះថា អនិមិត្តវិមោក្ខ

យោគាវចរ មិនមាននិមិត្តដោយនិមិត្តណា មិនតាំងនៅក្នុងនិមិត្តនោះទៀត ហេតុនោះ និមិត្តនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអត្ថថា ប្រជុំចុះ ដោយអត្ថថា បានលុះ ដោយអត្ថថា បានចំពោះ ដោយអត្ថថា ចាក់ធ្លុះ ដោយអត្ថថា ធ្វើឲ្យជាក់ច្បាស់ ដោយអត្ថថា ប៉ះពាល់ ដោយអត្ថថា ត្រាស់ដឹង យ៉ាងនេះឯង យោគាវចរ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួនរមែងរួចចាកសេចក្ដីប្រកាន់ស្អិត ( ដោយសភាវៈណា ) ហេតុនោះសភាវៈនោះឈ្មោះថា សុញ្ញតវិមោក្ខ យោគាវចរ មិនមាននិមិត្ត ដោយសុញ្ញតនិមិត្តណា ហេតុនោះនិមិត្តនោះ ឈ្មោះថា អនិមិត្តវិមោក្ខ យោគាវចរ មិនមាននិមិត្តដោយនិមិត្តណា មិនតាំងនៅក្នុងនិមិត្តនោះទៀត ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ យោគាវចរមិនតាំងនៅក្នុងនិមិត្តណា ស្ងួនស្បាកនិមិត្តនោះ ហេតុនោះឈ្មោះថា សុញ្ញត-វិមោក្ខ វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នា ដោយអត្ថថា ប្រជុំចុះ ដោយអត្ថថា បានលុះ ដោយអត្ថថា បានចំពោះ ដោយអត្ថថា ចាក់ធ្លុះ ដោយអត្ថថា ធ្វើឲ្យជាក់ច្បាស់ ដោយអត្ថថា ប៉ះពាល់ ដោយអត្ថថា ត្រាស់ដឹង យ៉ាងនេះឯង វិមោក្ខទាំង ៣ មានក្នុងខណៈជាមួយគ្នាដោយអាការ ៧ យ៉ាងនេះឯង ។

[ ២១៩ ] វិមោក្ខក៏មាន មុខក៏មាន វិមោក្ខមុខក៏មាន វិមោក្ខបច្ចនីកៈក៏មាន វិមោក្ខានុលោមក៏មាន វិមោក្ខវិវដ្ដៈក៏មាន វិមោក្ខភាវនាក៏មាន វិ-មោក្ខប្បដិបស្សទ្ធិក៏មាន ។

វិមោក្ខមានប៉ុន្មាន ។ មាន ៣ គឺសុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ ។

សុញ្ញតវិមោក្ខ តើដូចម្តេច ។ អនិច្ចានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាទៀង ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ ទុក្ខានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាសុខ ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ អនត្តានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាខ្លួន ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ និព្វិទានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាគួររីករាយ ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ វិរាគានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថារាគៈ ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ និរោធានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាកើតឡើងព្រម ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ បដិនិស្សគ្គានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាគួរប្រកាន់ ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ អនិមិត្តានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ស្អិត ថាជានិមិត្ត ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ អប្បណិហិតានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាទីតម្កល់ ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ទាំងពួង ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ អនិច្ចានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ ថាទៀងក្នុងរូប ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ ។បេ។ សុញ្ញតានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ទាំងពួងក្នុងរូប ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ អនិច្ចានុបស្សនាញាណ រួច

ចាកសេចក្តីប្រកាន់ ថាទៀងក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ ។បេ។ សុញ្ញតានុបស្សនាញាណ រួចចាកសេចក្តីប្រកាន់ទាំងពួង ក្នុងជរាមរណៈ ហេតុនោះឈ្មោះថា សុញ្ញតវិមោក្ខ នេះឯងសុញ្ញតវិមោក្ខ ។

[ ២២០ ] អនិមិត្តវិមោក្ខ តើដូចម្តេច ។ អនិច្ចានុបស្សនាញាណ រួចចាកនិមិត្ត ថាទៀង ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ ទុក្ខានុបស្សនាញាណ រួចចាកនិមិត្ត ថាជាសុខ ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ អនត្តានុបស្សនាញាណ រួចចាកនិមិត្ត ថាជាខ្លួន ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ និព្វិទានុបស្សនាញាណ រួចចាកនិមិត្ត ថាគួររីករាយ ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ វិរាគានុបស្សនាញាណ រួចចាកនិមិត្ត ថាតម្រេក ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ និរោធានុបស្សនាញាណ រួចចាកនិមិត្ត ថាកើតឡើងព្រម ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ បដិនិស្សគ្គានុបស្សនាញាណ រួចចាកនិមិត្ត ថាគួរប្រកាន់ ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ អនិមិត្តានុបស្សនាញាណ រួចចាកនិមិត្តទាំងពួង ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ អប្បណិហិតានុបស្សនាញាណ រួចចាកនិមិត្ត ថាមានទីតម្កល់ ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកនិមិត្ត ថាគួរប្រកាន់ស្អិត ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ អនិច្ចានុបស្សនាញាណ រួចចាកនិមិត្ត ថាទៀងក្នុងរូប ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ ។បេ។ អនិមិត្តានុបស្សនាញាណ រួចចាកនិមិត្តទាំងពួងក្នុង

រូប ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ អប្បណិហិតានុបស្សនាញាណ រួចចាកនិមិត្ត ថាមានទីតម្កល់ក្នុងរូប ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកនិមិត្ត ថាគួរប្រកាន់ស្អិតក្នុងរូប ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ អនិច្ចានុបស្សនាញាណ រួចចាកនិមិត្ត ថាទៀងក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ ។បេ។ អនិមិត្តានុបស្សនាញាណ រួចចាកនិមិត្តទាំងពួង ក្នុងជរាមរណៈ ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ អប្បណិហិតានុបស្សនាញាណ រួចចាកនិមិត្ត ថាមានទីតម្កល់ក្នុងជរាមរណៈ ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកនិមិត្ត ថាគួរប្រកាន់ស្អិត ក្នុងជរាមរណៈ ហេតុនោះឈ្មោះថា អនិមិត្តវិមោក្ខ នេះឯងអនិមិត្តវិមោក្ខ ។

[ ២២១ ] អប្បណិហិតវិមោក្ខ តើដូចម្តេច ។ អនិច្ចានុបស្សនាញាណ រួចចាកការតម្កល់ ថាទៀង ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ ទុក្ខានុបស្សនាញាណ រួចចាកការតម្កល់ ថាជាសុខ ហេតុនោះ ឈ្មោះថា អប្បណិហិតវិមោក្ខ អនត្តានុបស្សនាញាណ រួចចាកការតម្កល់ ថាជាខ្លួន ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ និព្វិទានុបស្សនាញាណ រួចចាកការតម្កល់ ថាគួររីករាយ ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ វិរាគានុបស្សនាញាណ រួចចាកការតម្កល់ ថាជាតម្រេក ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ និរោធានុបស្សនាញាណ រួចចាកការតម្កល់ ថាកើត

ឡើងព្រម ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ បដិនិស្សគ្គានុបស្ស-នាញាណ រួចចាកការតម្កល់ ថាគួរប្រកាន់ ហេតុនោះឈ្មោះថា អប្ប-ណិហិតវិមោក្ខ អនិមិត្តានុបស្សនាញាណ រួចចាកការតម្កល់ ថាជានិមិត្ត ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ អប្បណិហិតានុបស្សនាញាណរួចចាកការតម្កល់ទាំងពួង ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ សុញ្ញ-តានុបស្សនាញាណរួចចាកការតម្កល់ ថាគួរប្រកាន់ស្អិត ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ អនិច្ចានុបស្សនាញាណ រួចចាកការតម្កល់ក្នុងរូប ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ ។បេ។ អប្បណិហិតានុបស្សនា-ញាណ រួចចាកការតម្កល់ទាំងពួងក្នុងរូប ហេតុនោះឈ្មោះថា អប្បណិហិ-តវិមោក្ខ សុញ្ញតានុបស្សនាញាណ រួចចាកការតម្កល់ ថាគួរប្រកាន់ស្អិត ក្នុងរូប ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ អនិច្ចានុបស្សនាញាណ រួចចាកការតម្កល់ ថាទៀង ក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុង វិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ហេតុនោះឈ្មោះថា អប្បណិហិ-តវិមោក្ខ ។បេ។ អប្បណិហិតានុបស្សនាញាណ រួចចាកការតម្កល់ទាំងពួង ក្នុងជរាមរណៈ ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ សុញ្ញតានុបស្ស-នាញាណ រួចចាកការតម្កល់ ថាគួរក្រាន់ស្អិត ក្នុងជរាមរណៈ ហេតុនោះឈ្មោះថា អប្បណិហិតវិមោក្ខ នេះឯងអប្បណិហិតវិមោក្ខ ។

[ ២២២ ] មុខ ៦ តើដូចម្តេច ។ ពោធិបក្ខិយធម៌ទាំងឡាយណាជាធម្ម-ជាតមិនមានទោស ជាកុសលកើតហើយក្នុងវិមោក្ខទាំងនោះ នេះឯងឈ្មោះ

ជា មុខ ។

វិមោក្ខមុខ តើដូចម្តេច ។ អារម្មណ៍ណា របស់ធម៌ទាំងឡាយនោះៗ គឺនិរោធ និព្វាន នេះឯងឈ្មោះថា វិមោក្ខមុខ ។

វិមោក្ខបច្ចនីកៈ ( ធម៌ជាសត្រូវរបស់វិមោក្ខ ) តើដូចម្តេច ។ អកុសលមូលទាំង ៣ ជាសឹកសត្រូវរបស់វិមោក្ខ ទុច្ចរិតទាំង ៣ ជាសឹកសត្រូវរបស់វិមោក្ខ អកុសលធម៌ទាំងពួង ជាសឹកសត្រូវរបស់វិមោក្ខ នេះឯងឈ្មោះថា វិមោក្ខបច្ចនីកៈ ( ធម៌ជាសត្រូវរបស់វិមោក្ខ ) ។

វិមោក្ខានុលោម តើដូចម្តេច ។ កុសលមូលទាំង ៣ ចាត់ជាវិមោក្ខានុលោម សុចរិតទាំង ៣ ចាត់ជាវិមោក្ខានុលោម កុសលធម៌ទាំងអស់ ចាត់ជាវិមោក្ខានុលោម នេះឯងឈ្មោះថា វិមោក្ខានុលោម ។

[ ២២៣ ] វិមោក្ខវិវដ្តៈ តើដូចម្តេច ។ ( វិវដ្តៈមាន៦ ) គឺសញ្ញាវិវដ្តៈ ១ ចេតោវិវដ្តៈ ១ ចិត្តវិវដ្តៈ ១ ញាណវិវដ្តៈ ១ វិមោក្ខវិវដ្តៈ ១ សច្ចវិវដ្តៈ ១ ។ យោគាវាចរ កាលដឹងច្បាស់ រមែងងាកចេញ ( ចាកសង្ខារនិមិត្ត ) ហេតុនោះឈ្មោះថា សញ្ញាវិវដ្តៈ យោគាវចរ កាលត្រិះរិះរមែងងាកចេញ ហេតុនោះឈ្មោះថា ចេតោវិវដ្តៈ យោគាវចរ កាលដឹងច្បាស់ រមែងងាកចេញ ហេតុនោះឈ្មោះថា ចិត្តវិវដ្តៈ យោគាវចរ កាលធ្វើនូវញាណ រមែងងាកចេញ ហេតុនោះឈ្មោះថា ញាណវិវដ្តៈ កាលលះបង់ រមែងងាកចេញ ហេតុនោះឈ្មោះថា វិមោក្ខវិវដ្តៈ យោគាវចរ ងាកចិត្តទៅក្នុងអត្ថដ៏ពិត ហេតុនោះឈ្មោះថា សច្ចវិវដ្តៈ សញ្ញាវិវដ្តៈមានក្នុងទីណា

ចេតោវិវដ្ដៈក៏មានក្នុងទីនោះ ចេតោវិវដ្ដៈមានក្នុងទីណា សញ្ញាវិវដ្ដៈក៏មានក្នុងទីនោះ សញ្ញាវិវដ្ដៈនិងចេតោវិវដ្ដៈ មានក្នុងទីណា ចិត្តវិវដ្ដៈក៏មានក្នុងទីនោះ ចិត្តវិវដ្ដៈមានក្នុងទីណា សញ្ញាវិវដ្ដៈនិងចេតោវិវដ្ដៈក៏មានក្នុងទីនោះ សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ និងចិត្តវិវដ្ដៈមានក្នុងទីណា ញាណវិវដ្ដៈក៏មានក្នុងទីនោះ ញាណវិវដ្ដៈមានក្នុងទីណា សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ និងចិត្តវិវដ្ដៈក៏មានក្នុងទីនោះ សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ និងញាណវិវដ្ដៈមានក្នុងទីណា វិមោក្ខវិវដ្ដៈក៏មានក្នុងទីនោះ វិមោក្ខវិវដ្ដៈមានក្នុងទីណា សញ្ញា-វិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ និងញាណវិវដ្ដៈក៏មានក្នុងទីនោះ សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ ញាណវិវដ្ដៈ និងវិមោក្ខវិវដ្ដៈមានក្នុងទីណា សច្ចវិវដ្ដៈក៏មានក្នុងទីនោះ សច្ចវិវដ្ដៈមានក្នុងទីណា សញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្ត-វិវដ្ដៈ ញាណវិវដ្ដៈ និងវិមោក្ខវិវដ្ដៈ ក៏មានក្នុងទីនោះដែរ នេះឯងឈ្មោះថា វិមោក្ខវិវដ្ដៈ ។

[ ២២៤ ] វិមោក្ខភាវនា តើដូចម្ដេច ។ ការសេព ការអប់រំ ការធ្វើឲ្យច្រើននូវបឋមជ្ឈាន ការសេព ការអប់រំ ការធ្វើឲ្យច្រើននូវទុតិយជ្ឈាន ការសេព ការអប់រំ ការធ្វើឲ្យច្រើននូវតតិយជ្ឈាន ការសេព ការអប់រំ ការធ្វើឲ្យច្រើននូវចតុត្ថជ្ឈាន ការសេព ការអប់រំ ការធ្វើឲ្យច្រើននូវអា-កាសានញ្ចាយតនសមាបត្តិ ការសេព ការអប់រំ ការធ្វើឲ្យច្រើននូវវិញ្ញា-ណញ្ចាយតនសមាបត្តិ នូវអាកិញ្ចញ្ញាយតនសមាបត្តិ នូវនេវសញ្ញានា-សញ្ញាយតនសមាបត្តិ ការសេព ការអប់រំ ការធ្វើឲ្យច្រើននូវសោតាបត្តិមគ្គ

ការសេព ការអប់រំ ការធ្វើឲ្យច្រើននូវសកទាគាមិមគ្គ ការសេព ការអប់រំ ការធ្វើឲ្យច្រើននូវអនាគាមិមគ្គ ។បេ។ នូវអរហត្តមគ្គ នេះឈ្មោះថា វិមោក្ខ-ភាវនា ។

វិមោក្ខប្បដិប្បស្សទ្ធិ តើដូចម្តេច ។ ការបានចំពោះនូវបឋមជ្ឈាន ឬផល ( របស់បឋមជ្ឈាន ) ការបានចំពោះនូវទុតិយជ្ឈានឬផល ( របស់ទុតិយជ្ឈាន ) ការបានចំពោះនូវតតិយជ្ឈានឬផលរបស់តតិយជ្ឈាន ។បេ។ របស់ចតុត្ថជ្ឈាន របស់អាកាសានញ្ចាយតនសមាបត្តិ របស់វិញ្ញាណញ្ចា-យតនសមាបត្តិ របស់អាកិញ្ចញ្ញាយតនសមាបត្តិ របស់នេវសញ្ញានាសញ្ញាយតនសមាបត្តិ សោតាបត្តិផលរបស់សោតាបត្តិមគ្គ សកទាគាមិផលរបស់សកទាគាមិមគ្គ អនាគាមិផលរបស់អនាគាមិមគ្គ អរហត្តផលរបស់អរហត្តមគ្គ នេះឈ្មោះថា វិមោក្ខប្បដិប្បស្សទ្ធិ ។

## ចប់ ភាណវារទី ៣

## ចប់ វិមោក្ខកថា

# អដ្ឋកថា

## វិមោក្ខុទ្ទេស

[ ១៧៧ ] ឥឡូវនេះ ដល់វារៈដែលនឹងពណ៌នាតាមលំដាប់សេចក្ដីដែលមិនធ្លាប់ពណ៌នានៃវិមោក្ខកថា ដែលលោកពោលក្នុងលំដាប់ ឥន្ទ្រិយកថា ។ វិមោក្ខកថានេះ លោកពោលក្នុងលំដាប់ ឥន្ទ្រិយកថា ព្រោះអ្នកប្រកបដោយឥន្ទ្រិយភាវនាជាអ្នកបានវិមោក្ខ ។ ព្រះសារីបុត្តត្ថេរ កាលពោលវិមោក្ខកថានោះ ពោលធ្វើសុត្តន្តទេសនាដែលខ្លួនស្ដាប់មក ចំពោះព្រះភក្ត្រព្រះមានព្រះភាគ ឲ្យជាខាងដើម ។

បណ្ដាបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រមុន ដូចតទៅនេះថា ក្នុងបទថា **សុញ្ញតោ វិមោក្ខោ** ជាដើម អរិយមគ្គដែលប្រព្រឹត្តទៅ ព្រោះធ្វើនិព្វានឲ្យជាអារម្មណ៍ ដោយអាការនៃភាពជារបស់សូន្យ ឈ្មោះថា សុញ្ញតវិមោក្ខ ។ អរិយមគ្គនោះ ឈ្មោះថា **សុញ្ញត** ព្រោះកើតឡើងក្នុងធាតុដែលសូន្យ ឈ្មោះថា **វិមោក្ខ** ព្រោះផុតចាកកិលេសទាំងឡាយ ។

ដោយន័យនេះឯង គប្បីជ្រាបថា អរិយមគ្គដែលប្រព្រឹត្តទៅ ព្រោះធ្វើនិព្វានឲ្យជាអារម្មណ៍ដោយអាការមិនមាននិមិត្ត ឈ្មោះថា **អនិមិត្តវិមោក្ខ** ។ អរិយមគ្គដែលប្រព្រឹត្តទៅ ព្រោះធ្វើនិព្វានឲ្យជាអារម្មណ៍ ដោយអាការមិនមានទីតាំង ឈ្មោះថា **អប្បណិហិតវិមោក្ខ** ។

ភិក្ខុរូបខ្លះពិចារណាសង្ខារទាំងឡាយ ដោយភាពមិនទៀង តាំងពីដើមនោះឯង ។ តែព្រោះពិចារណាដោយសភាពមិនទៀងប៉ុណ្ណោះ មិនទាន់ជា

ការចេញទៅដោយមគ្គ គួរពិចារណាដោយភាព ជាទុក្ខៈ ដោយភាពជាអនត្តាខ្ៈ ហេតុនោះទើបពិចារណាជាទុក្ខៈ ជាអនត្តាខ្ៈ ។ កាលភិក្ខុនោះបដិបត្តិហើយយ៉ាងនេះ បើក្នុងកាលដែលពិចារណាដោយការមិនទៀង មានការចេញទៅដោយមគ្គ ភិក្ខុនេះឈ្មោះថា នៅដោយភាពមិនទៀង ហើយចេញទៅដោយភាពមិនទៀង ។ មួយវិញទៀត បើក្នុងកាលដែលភិក្ខុនោះពិចារណាដោយភាពជាទុក្ខ ដោយភាពជាអនត្តា មានការចេញទៅដោយមគ្គ ភិក្ខុនេះឈ្មោះថា នៅដោយភាពមិនទៀង ហើយចេញទៅដោយភាពជាទុក្ខ ដោយភាពជាអនត្តា ។ សូម្បីក្នុងការនៅដោយភាពជាទុក្ខ ដោយភាពជាអនត្តាហើយចេញទៅ ក៏មានន័យនេះ ។

មួយវិញទៀត ក្នុងជនទាំងនេះ ជនណានៅដោយភាពមិនទៀង ជនណានៅដោយភាពជាទុក្ខ ជនណានៅដោយភាពជាអនត្តា បើក្នុងវេលាចេញរមែងចេញដោយភាពមិនទៀង ជនទាំង ៣ នេះ ជាអ្នកច្រើនទៅដោយអធិមោក្ខៈ រមែងបានសទ្ធិន្ទ្រិយ រមែងផុតដោយអនិមិត្តវិមោក្ខ ជាសទ្ធានុសារីក្នុងខណៈបឋមមគ្គ ជាសទ្ធាវិមុត្តក្នុងឋានៈ ៧ ។ មួយវិញទៀត បើចេញទៅដោយភាពជាទុក្ខ ជនទាំង ៣ ជាអ្នកច្រើនដោយបស្សទ្ធិ រមែងបានសមាធិន្ទ្រិយ រមែងផុតដោយអប្បណិហិតវិមោក្ខ ជាកាយសក្ខីក្នុងទីទាំងពួង ។ ក្នុងទីនេះជនណាមានអរូបជ្ឈានជាបាទ ជននោះជាឧភតោភាគវិមុត្តក្នុងអគ្គផល បន្ទាប់អំពីនោះ ជនទាំងនោះ រមែងចេញដោយភាពជាអនត្តា ជនទាំង ៣ ជាអ្នកច្រើនដោយបញ្ញា រមែងបានបញ្ញិន្ទ្រិយ រមែង

ផុតដោយសុញ្ញតវិមោក្ខ ជាធម្មានុសារីក្នុងខណៈបឋមមគ្គ ជាទិដ្ឋិប្បត្ត ក្នុងឋានៈ ៦ ជាបញ្ញាវិមុត្តក្នុងអគ្គផល ។

ម្យ៉ាងទៀត ធម្មតា មគ្គ រមែងបានឈ្មោះដោយហេតុ ៥ ប្រការ គឺដោយកិច្ចរបស់ខ្លួន ១ ដោយជាសត្រូវ ១ ដោយគុណរបស់ខ្លួន ១ ដោយអារម្មណ៍ ១ ដោយការមក ១ ។ បើសង្ខារុបេក្ខាញាណ ពិចារណាដោយភាពមិនទៀង ហើយចេញទៅ បុគ្គលរមែងរួចផុតដោយអនិមិត្តវិមោក្ខ បើពិចារណាដោយភាពជាទុក្ខ ហើយចេញទៅ បុគ្គលរមែងរួចផុតដោយអប្បណិហិតវិមោក្ខ ។ បើពិចារណាដោយភាពជាអនត្តាហើយចេញទៅ បុគ្គលរមែងរួចផុតដោយសុញ្ញតវិមោក្ខ នេះឈ្មោះថា ជាឈ្មោះដោយកិច្ចរបស់ខ្លួន ។

ម្យ៉ាងទៀត មគ្គឈ្មោះថា អនិមិត្ត ព្រោះធ្វើការបែកភាពជាឃនៈ ( ដុំ ) របស់សង្ខារទាំងឡាយដោយអនិច្ចានុបស្សនា លះនិមិត្តថាទៀង និមិត្តថាឋិតថេរ និមិត្តថាមាំទាំហើយចេញទៅ ឈ្មោះថា អប្បណិហិតៈ ព្រោះលះសុខសញ្ញាដោយទុក្ខានុបស្សនា ហើយញុំាងសេចក្តីប្រាថ្នាដែលតាំងទុកឲ្យស្ងួតទៅហើយចេញ ឈ្មោះថា សុញ្ញតៈ ព្រោះលះសេចក្តីសម្គាល់ថាខ្លួន សត្វ បុគ្គល ដោយអនត្តានុបស្សនា ហើយឃើញសង្ខារទាំងឡាយដោយភាពជារបស់សូន្យ នេះឈ្មោះថា ជាឈ្មោះដោយភាពជាសត្រូវ ។

ម្យ៉ាងទៀត ឈ្មោះថា សុញ្ញតៈ ព្រោះសូន្យចាករាគៈជាដើម ឈ្មោះថា អនិមិត្ត ព្រោះមិនមានរូបនិមិត្តជាដើម ឬរាគៈនិមិត្តជាដើម ឈ្មោះថា អប្ប-

ណិហិត ព្រោះមិនមានទីតាំងរបស់រាគៈជាដើម នេះឈ្មោះថា ជាឈ្មោះដោយគុណរបស់ខ្លួននៃមគ្គនោះ ។

មគ្គនោះ រមែងធ្វើនិព្វានដែលជារបស់សូន្យ មិនមាននិមិត្ត មិនមានទីតាំង ឲ្យជាអារម្មណ៍ ព្រោះហេតុនោះ ទើបពោលថា សុញ្ញតៈ អនិមិត្តៈ អប្បណិហិតៈ នេះឈ្មោះថា ជាឈ្មោះដោយអារម្មណ៍នៃមគ្គនោះ ។

ម្យ៉ាងទៀត ការមកមាន ២ យ៉ាង គឺវិបស្សនាគមនៈ ( ការមកនៃវិបស្សនា ) ១ មគ្គាគមនៈ ( ការមកនៃមគ្គ ) ១ ។

ក្នុងការមកទាំងនោះ ការមកនៃវិបស្សនា រមែងបានក្នុងមគ្គ ការមកនៃមគ្គ រមែងបានក្នុងផល ព្រោះអនត្តានុបស្សនា ឈ្មោះថា សុញ្ញតៈ មគ្គនៃសុញ្ញតវិបស្សនា ឈ្មោះថា សុញ្ញតៈ ផលនៃសុញ្ញតមគ្គ ឈ្មោះថា សុញ្ញតៈ ។ អនិច្ចានុបស្សនា ឈ្មោះថា អនិមិត្ត មគ្គនៃអនិមិត្តាវិបស្សនា ឈ្មោះថា អនិមិត្ត ។ ឈ្មោះនេះរមែងបានដោយអភិធម្មប្បរិយាយ តែក្នុងសុត្តន្តប្បរិយាយក៏បានផងដែរ ។ ពិតណាស់ អាចារ្យទាំងឡាយពោលទុកក្នុងសុត្តន្តប្បរិយាយនោះថា គោត្រភូញាណធ្វើនិព្វាន ដែលមិនមាននិមិត្តឲ្យជាអារម្មណ៍ ហើយមានឈ្មោះជាអនិមិត្តៈ តាំងនៅក្នុងឋានៈដែលគប្បីដល់ឯង ហើយឲ្យឈ្មោះដល់មគ្គ ដោយហេតុនោះ ទើបលោកពោលថា មគ្គជាអនិមិត្តៈ គួរពោលថា ផលជាអនិមិត្តៈដោយការមកនៃមគ្គ ។ ទុក្ខានុបស្សនា ឈ្មោះថា អប្បណិហិតៈ ព្រោះធ្វើការប្រាថ្នាដែលតាំងទុកក្នុងសង្ខារទាំងឡាយ ឲ្យរីងស្ងួតហើយចេញទៅ មគ្គនៃអប្បណិហិតវិបស្សនា

ឈ្មោះថា អប្បណិហិតៈ ផលនៃអប្បណិហិតមគ្គ ឈ្មោះថា អប្បណិហិតៈ ព្រោះហេតុនោះ វិបស្សនារមែងឲ្យឈ្មោះរបស់ខ្លួនដល់មគ្គ ។ មគ្គរមែងឲ្យឈ្មោះរបស់ខ្លួនដល់ផល ដោយប្រការដូច្នេះ ព្រោះហេតុនោះ នេះឈ្មោះថា ជាឈ្មោះដោយការមក ។ សង្ខារុបេក្ខាញាណ រមែងកំណត់កាត់ពិសេសនៃវិមោក្ខ ដោយប្រការដូច្នេះឯង ។

ព្រះសារីបុត្តត្ថេរ កាលសម្តែងវិមោក្ខ ៣ ដែលជាមហាវត្ថុ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយយ៉ាងនេះ បំណងនឹងចង្អុលបង្ហាញដល់វិមោក្ខដទៃទៀត ដោយអំណាចការចង្អុលបង្ហាញវិមោក្ខនោះ ទើបពោលពាក្យថា **អបិច អជ្ឈត្តវុដ្ឋានោ វិមោក្ខោ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **អបិច** ជាបទសម្តែងដល់បរិយាយដទៃ ។ វិមោក្ខទាំងនោះមាន ៦៨ បានដូចម្តេច មាន ៧៥ មិនមែនឬ ត្រឹមត្រូវមាន ៧៥ ដោយអំណាចតាមដែលហៅ តែព្រោះតាំងវិមោក្ខ ៣ ដែលព្រះមានព្រះភាគ ទ្រង់សម្តែង ហើយចង្អុលបង្ហាញវិមោក្ខដទៃ និងព្រោះវិមោក្ខទាំងនេះ សង្គ្រោះចូលក្នុងវិមោក្ខ ៣ នោះ ទើបមិនគួររាប់វិមោក្ខទាំង ៣ នេះ វិមោក្ខ ៣ មានអជ្ឈត្តវិមោក្ខជាដើម ក៏មិនគួររាប់ ព្រោះសង្គ្រោះចូលខាងក្នុង ក្នុងពាក្យដែលពោលដោយពិស្តារ ៤ ចំណែក អប្បណិហិតវិមោក្ខក្នុងបទនេះថា **បណិហិតោ វិមោក្ខោ អប្បណិហិតោ វិមោក្ខោ** ក៏មិនគួររាប់ ព្រោះមានឈ្មោះដូចគ្នានឹងវិមោក្ខដែលលើកឡើងសម្តែងជាគ្រាដំបូង កាលនាំវិមោក្ខ ៧ យ៉ាងទាំងនេះចេញយ៉ាងនេះ ហើយក៏សល់វិមោក្ខ ៦៨ ។

បើសួរថា កាលបើយ៉ាងនេះ ព្រោះហេតុអ្វីទើបលើកវិមោក្ខ ៣ មាន សុញ្ញតវិមោក្ខជាដើមឡើងសម្ដែង ឆ្លើយថា ដើម្បីសង្គ្រោះជាបទឧទ្ទេស ហើយធ្វើការបង្កុលបង្ហាញវិមោក្ខទាំងនោះ ។ ម្យ៉ាងទៀត វិមោក្ខ ៣ មាន អជ្ឈត្តវុដ្ឋានវិមោក្ខជាដើម លោកលើកឡើង សម្ដែងដោយអំណាច ក្រុម ដែលជាមូលហេតុវៀរប្រភេទចេញ អប្បណិហិតវិមោក្ខគប្បីជ្រាបថា លោក លើកឡើងសម្ដែងទៀត ដោយអំណាចជាបដិបក្ខចំពោះបណិហិតវិមោក្ខ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអជ្ឈត្តវុដ្ឋានវិមោក្ខជាដើម ដូចតទៅនេះថា ឈ្មោះ ថា អជ្ឈត្តវុដ្ឋាន ព្រោះអត្ថថា ចេញចាកខាងក្នុង ។ ឈ្មោះថា អនុលោម ព្រោះអត្ថថា ស្របតាម ។ ការរម្ងាប់ ការទៅប្រាសនូវអជ្ឈត្តវុដ្ឋាន ឈ្មោះ ថា អជ្ឈត្តវុដ្ឋានបដិប្បស្សទ្ធិ ។ បទថា **រូបី** បានដល់ រូបឈាន ដែល ភិក្ខុឲ្យកើតឡើង ក្នុងអវយវៈ មានសក់ជាដើមក្នុងខាងក្នុង ឈ្មោះថា រូប រូបនោះ មានដល់ភិក្ខុនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **រូបី** ។ បទថា **រូបានិ បស្សតិ** បានដល់ ឃើញរូបមានទីលកសិណជាដើមខាងក្រៅដោយ ញាណចក្ខុ ដោយបទនេះ លោកសម្ដែងដល់ការបានឈានក្នុងកសិណទាំង ឡាយដែលមានវត្ថុក្នុងខាងក្នុងនិងខាងក្រៅ ។ បទថា **អជ្ឈត្តំ អរូបសញ្ញី** បានដល់ មិនជាអ្នកសម្គាល់ថា រូបក្នុងខាងក្នុង អធិប្បាយថា ជាអ្នកមាន រូបាវចរជ្ឈានដែលខ្លួនមិនឲ្យកើតក្នុងសក់ជាដើម ដោយបទនេះលោកសម្ដែង ឈានដែលធ្វើបរិកម្មខាងក្រៅ ហើយបានខាងក្រៅនោះឯង ។ បទថា **សុភន្តេវ អធិមុត្តោ** បានដល់ បង្អោនចិត្តទៅក្នុងអារម្មណ៍ថាស្អាតប៉ុណ្ណោះ ។

ក្នុងបទនោះ ការចងចិត្តថាស្អាត មិនមានខាងក្នុងអប្បនាក៏ពិត តែភិក្ខុណា ផ្សាយសត្តារម្មណ៍ទៅដោយអាការមិនគួរខ្ពើម ព្រោះភិក្ខុនោះ ជាអ្នកបង្អោន ចិត្តទៅថា ស្អាតប៉ុណ្ណោះ ហេតុនោះទើបលោកធ្វើឧទ្ទេសយ៉ាងនេះ ។ ឈ្មោះ ថា **សមយវិមោក្ខោ** ព្រោះមានវិក្ខម្ភនវិមុត្តិក្នុងសម័យដែលចុះស៊ប់ហើយ ។

សមយវិមោក្ខនោះឯង ឈ្មោះថា សាមយិកវិមោក្ខ ព្រោះប្រកបហើយ ក្នុងសម័យដែលចុះស៊ប់ហើយនោះឯង ដោយអំណាចធ្វើកិច្ចរបស់ខ្លួន ។ បាឋៈថា សាមាយិកៈ ដូច្នេះក៏មាន ។ ឈ្មោះថា កុប្បៈ ព្រោះបុគ្គលណា មួយអាចធ្វើឲ្យកម្រើកបាន គឺ ទម្លាយបាន ។ ឈ្មោះថា លោកិកៈ ព្រោះ ប្រកបទុកក្នុងលោក ដោយមិនឈានកន្លងលោក ។ បាឋៈថា លោកិយៈ ដូច្នេះក៏មាន ។ ឈ្មោះថា លោកុត្តរៈ ព្រោះឆ្លងលោក ឬឆ្លងផុតលោក បានហើយ ។ ឈ្មោះថា សាសវៈ ព្រោះមានអាសវៈ ដោយការធ្វើឲ្យជា អារម្មណ៍ ។ ឈ្មោះថា អនាសវៈ ព្រោះមិនមានអាសវៈដោយការធ្វើឲ្យ ជាអារម្មណ៍ និងដោយការប្រកបរួម ។ ឈ្មោះថា សាមិសៈ ព្រោះមាន អាមិសៈ ពោលគឺរូប ។ ឈ្មោះថា **និរាមិសា និរាមិសតរោ** ព្រោះអត្ថ ថា មិនមានអាមិសៈក្រៃលែងជាងមិនមានអាមិសៈ ព្រោះលះរូបនិងអរូបបាន ដោយប្រការទាំងពួង ។

បទថា **បណិហិតោ** បានដល់ តាំងទុកហើយ គឺប្រាថ្នាហើយដោយ អំណាចនៃតណ្ហា ។ ឈ្មោះថា សញ្ញុត្តៈ ព្រោះប្រកបហើយដោយសំយោ- ជនៈ ដោយការធ្វើឲ្យជាអារម្មណ៍ ។ បទថា **ឯកត្តវិមោក្ខោ** បានដល់

វិមោក្ខដែលមានសភាពតែមួយ ព្រោះមិនត្រូវកិលេសទាំងឡាយគ្របសង្កត់ ។ បទថា **សញ្ញាវិមោក្ខោ** វិបស្សនាញាណនោះឯង ឈ្មោះថា សញ្ញាវិមោក្ខ ព្រោះផុតចាកសញ្ញាវិបរិត ។ វិបស្សនាញាណនោះឯង ឈ្មោះថា ញាណវិមោក្ខ ព្រោះអត្ថថា វិមោក្ខ គឺញាណដោយអំណាចការផុតចាកសេចក្តីវង្វេង ។ បទថា **សីតិសិយាវិមោក្ខោ** បានដល់ វិបស្សនាញាណនោះឯង វិមោក្ខដែលប្រព្រឹត្តទៅហើយ ថាគប្បីមានសេចក្តីត្រជាក់ ឈ្មោះថា **សីតិសិយាវិមោក្ខ** ។ បាឋៈថា **សីតិសិកាវិមោក្ខោ** ដូច្នេះក៏មាន ។ អាចារ្យទាំងឡាយ ពណ៌នាសេចក្តីនៃបទនោះថា ការរួចផុតដើម្បីជារបស់ត្រជាក់ ។ បទថា **ឈានវិមោក្ខោ** បានដល់ វិមោក្ខ គឺឈាននោះឯង ដែលមានប្រភេទ ជាឧបចារៈនិងអប្បនា និងមានប្រភេទជាលោកិយៈនិងលោកុត្តរៈ ។ បទថា **អនុបាទា ចិត្តស្ស វិមោក្ខោ** បានដល់ ការផុតនៃចិត្ត ព្រោះមិនប្រកាន់មាំ គឺមិនធ្វើការប្រកាន់ ។ បទដ៏សេសគប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។

អដ្ឋកថា វិមោក្ខុទ្ទេស ចប់

# អដ្ឋកថា
# វិមោក្ខនិទ្ទេស

[ ១៧៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃឧទ្ទេសថា **កតមោ** ដូចតទៅនេះថា

បទថា **ឥតិ បដិសញ្ចិក្ខតិ** បានដល់ ពិចារណាឃើញយ៉ាងនេះ ។ បទថា **សុញ្ញមិទំ** បានដល់ ខន្ធបញ្ចកៈនេះទទេ ។ ទទេចាកអ្វី ទទេចាកភាពជាតួខ្លួន ឬចាកវត្ថុជារបស់ខ្លួន ។

ក្នុងបទទាំងនោះ បទថា **អត្តេន វា** បានដល់ ទទេចាកភាពជាតួខ្លួននោះ ព្រោះមិនមានតួខ្លួនដែលពួកបុគ្គលល្ងង់នាំគ្នាកំណត់ ។ បទថា **អត្តនិយេន វា** បានដល់ ទទេចាកវត្ថុដែលជារបស់ខ្លួនដែលកំណត់ទុកនោះ ។ ការមិនមានវត្ថុ ដែលទាក់ទងដោយខ្លួន ក៏ព្រោះការមិនមានខ្លួននោះឯង ។ ឈ្មោះថា វត្ថុដែលទាក់ទងដោយខ្លួន នឹងគប្បីជារបស់ទៀងឬគប្បីជាសេចក្តីសុខ ។ សូម្បីទាំងពីរយ៉ាងនោះ ក៏មិនមាន ។ ដោយពាក្យនោះ ឈ្មោះថាលោកពោលដល់ អនិច្ចានុបស្សនា ដោយបដិសេធវត្ថុ ដែលជារបស់ទៀងនិងដែលពោលដល់ទុក្ខានុបស្សនា ដោយការបដិសេធសេចក្តីសុខ ។ បទថា **សុញ្ញមិទំ អត្តេន វា** លោកពោលដល់ អនត្តានុបស្សនានោះឯង ។ បទថា **សោ** បានដល់ ភិក្ខុនោះឃើញច្បាស់ដោយអនុបស្សនា ៣ យ៉ាងនេះ ។ បទថា **អភិនិវេសំ ន ករោតិ** បានដល់ មិនធ្វើការប្រកាន់មាំថាខ្លួនដោយអំណាចនៃអនត្តានុបស្សនា ។ បទថា **និមិត្តំ ន ករោតិ** បានដល់ មិន

ធ្វើគ្រឿងសម្គាល់ ថាទៀង ដោយអំណាចនៃអនិច្ចានុបស្សនា ។ បទថា **បណិធិំ ន ករោតិ** បានដល់ មិនធ្វើសេចក្ដីប្រាថ្នាដោយអំណាចនៃទុក្ខានុបស្សនា ។

វិមោក្ខទាំង ៣ នេះ ដោយបរិយាយ រមែងបានដោយអំណាចនៃតទង្គប្បហានក្នុងខណៈនៃវិបស្សនា តែដោយនិប្បរិយាយរមែងបានដោយអំណាចនៃសមុច្ឆេទប្បហានក្នុងខណៈនៃមគ្គ ។ ឈាន ៤ ឈ្មោះថា អជ្ឈត្តវុដ្ឋានវិមោក្ខ ព្រោះចេញចាកនីវរណៈជាដើមក្នុងខាងក្នុង ។ អរូបសមាបត្តិ ៤ ឈ្មោះថា ពហិទ្ធាវុដ្ឋានវិមោក្ខ ព្រោះចេញចាកអារម្មណ៍ទាំងឡាយ សូម្បីអារម្មណ៍លោកក៏ពោលថា ខាងក្រៅ ក្នុងបទនេះ ដូចអាយតនៈខាងក្រៅ ។ វិមោក្ខទាំង ២ នេះ ជាវិក្ខម្ភនវិមោក្ខ ចំណែកទុកតោវុដ្ឋានវិមោក្ខ ជាសមុច្ឆេទវិមោក្ខ ។

[ ១៧៩ ] លោកពោលការចេញចាកខាងក្នុងដោយសរុប ដោយបទថា **នីវរណេហិ វុដ្ឋាតិ** ជាដើម ។ ដោយបទថា **រូបសញ្ញាយ** ជាដើម លោកមិនពោលដល់ការចេញចាកនីវរណៈនោះ ព្រោះការឈានកន្លងអារម្មណ៍មានកសិណជាដើមប្រាកដច្បាស់ហើយ តែពោលដល់ការឈានកន្លងរូបសញ្ញាជាដើម ដូចដែលលោកពោលហើយក្នុងព្រះសូត្រទាំងឡាយ ។

បទថា **សក្កាយទិដ្ឋិវិចិកិច្ឆាសីលព្វតបរាមាសា** ជាបទសមាស ។ កាត់បទថា **សក្កាយទិដ្ឋិយា វិចិកិច្ឆាយ សីលព្វតបរាមាសា** ។ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះឯង ។

[ ១៨០ ] ដោយបទថា **វិតក្កោ** ជាដើម លោកពោលដល់ឧបចារៈភូមិនៃឈាននិងសមាបត្តិ ។ ដោយបទថា **អនិច្ចានុបស្សនា** ជាដើម លោកពោលដល់វិបស្សនាដែលជាចំណែកខាងដើមនៃមគ្គ ៤ ។

[ ១៨១ ] បទថា **បដិលោភោ វា** មានវិនិច្ឆ័យដូចតទៅនេះថា ឈ្មោះថា **បដិលោភោ** ព្រោះអត្ថថា ការបានដែលជ្រួតជ្រាបផ្សាយទៅ ដោយការសម្រេចវសី ៥ ។ ពិតហើយ ការខ្វល់ខ្វាយក្នុងឈាននិងការខ្វល់ខ្វាយក្នុងសមាបត្តិទាំងពួង រម្ងាប់ទៅដោយការសម្រេចវសី ព្រោះហេតុនោះ ការបាន ទើបលោកពោលថា បដិបស្សទ្ធិវិមោក្ខ ។ ចំណែកវិបាកជាការរម្ងាប់ឈាននិងសមាបត្តិ ព្រោះហេតុនោះ ទើបជាការរម្ងាប់ដោយត្រង់នោះឯង តែអាចារ្យពួកខ្លះពោលថា ការបានឈាននិងសមាបត្តិ ព្រោះការខ្វល់ខ្វាយក្នុងឧបចារៈស្ងប់ ព្រោះហេតុនោះ ការបានឈាននិងសមាបត្តិ ទើបលោកពោលថា បដិបស្សទ្ធិវិមោក្ខ ។

[ ១៨២ ] បទថា **អជ្ឈត្តំ** បានដល់ ប្រព្រឹត្តទៅព្រោះទាក់ទងនឹងខ្លួន ។ បទថា **បច្ចត្តំ** បានដល់ ប្រព្រឹត្តទៅចំពោះខ្លួន ។ លោកសម្តែងខាងក្នុងទាក់ទងដោយខ្លួន សូម្បីដោយបទទាំងពីរ ។

បទថា **នីលនិមិត្តំ** បានដល់ ពណ៌ខៀវនោះឯង ។ បទថា **នីលសញ្ញំ បដិលភតិ** បានដល់ រមែងបានសញ្ញាថា ពណ៌ខៀវក្នុងនីលនិមិត្តនោះ ។ បទថា **សុគ្គហិតំ ករោតិ** បានដល់ ធ្វើឲ្យជាការកាន់យកដោយល្អក្នុងភូមិនៃបរិកម្ម ។ បទថា **សូបធារិតំ ឧបធារេតិ** បានដល់ ទ្រទ្រង់ចាំ ធ្វើ

ទុកដោយល្អក្នុងភូមិនៃឧបចារៈ ។ បទថា **ស្វាវត្ថិតំ អវត្ថាបេតិ** បានដល់ កាត់ផ្តាច់ដោយល្អក្នុងភូមិនៃអប្បនា ។ បាឋៈថា **វវត្ថាបេតិ** ក៏មាន ។ ពិត ណាស់ ភិក្ខុកាលធ្វើនីលបរិកម្មក្នុងខាងក្នុង រមែងធ្វើត្រង់សក់ដែលខ្មៅល្អ ឬត្រង់កែវភ្នែក ។ បទថា **ពហិទ្ធា នីលនិមិត្តេ** បានដល់ ក្នុងនីលកសិណ ណាមួយនៃផ្កាពណ៌ខៀវ សំពត់ពណ៌ខៀវ ធាតុពណ៌ខៀវ ។ បទថា **ចិត្តំ ឧបសំហរតិ** បានដល់ រមែងបង្អោនចិត្តចូលទៅ ។ សូម្បីក្នុងពណ៌លឿង ជាដើម ក៏មានន័យនេះដូចគ្នា ។

បទថា **អាសេវតិ** បានដល់ សេពសញ្ញានោះឯងអំពីដើម ។ បទថា **ភាវេតិ** បានដល់ ធ្វើឲ្យចម្រើន ។ បទថា **ពហុលីករោតិ** បានដល់ ធ្វើឲ្យរឿយៗ ។ បទថា **រូបំ** បានដល់ រូបមាននិមិត្តពណ៌ខៀវ ។ បទថា **រូបសញ្ញី** មានវិគ្គហៈថា ការសម្គាល់ក្នុងរូបនោះឈ្មោះថា រូបសញ្ញា រូប-សញ្ញានោះមានដល់បុគ្គលនោះ ព្រោះហេតុនោះ ទើបមានសេចក្តីសម្គាល់ ថាជារូប ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អជ្ឈត្តំ បីតនិមិត្តំ** ដូចតទៅនេះថា ភិក្ខុ កាលធ្វើបរិកម្មពណ៌លឿង រមែងធ្វើត្រង់ខ្លាញ់ខាប់ ត្រង់ស្បែកឬត្រង់ពណ៌ លឿងនៃភ្នែក ។ កាលធ្វើបរិកម្មពណ៌ក្រហម រមែងធ្វើត្រង់សាច់ ឈាម អណ្តាត បាតដៃ បាតជើង ឬត្រង់ពណ៌ក្រហមនៃភ្នែក ។ កាលធ្វើបរិកម្ម ពណ៌ស រមែងធ្វើត្រង់ឆ្អឹង ធ្មេញ ក្រចក ឬត្រង់ពណ៌សនៃភ្នែក ។

[ ១៨៣-១៨៤ ] បទថា **អជ្ឈត្តំ អរូបំ** សេចក្តីថា មិនមានរូបនិមិត្ត

ក្នុងខាងក្នុង ។ បទថា **មេត្តាសហគតេន** បានដល់ ប្រកបដោយមេត្តា ដោយអំណាចនៃបឋមជ្ឈាន ទុតិយជ្ឈាន និងតតិយជ្ឈាន ។ បទថា **ចេតសា** បានដល់ មានចិត្ត ។ បទថា **ឯកំ ទិសំ** លោកពោលសំដៅដល់សត្វមួយ ដែលកំណត់គ្រាដំបូងក្នុងទិសមួយ ដោយអំណាចនៃការផ្សាយទៅកាន់សត្វ ដែលទាក់ទងក្នុងទិសមួយ ។ បទថា **ផរិត្វា** បានដល់ ពាល់ត្រូវ គឺធ្វើឲ្យជាអារម្មណ៍ ។ បទថា **វិហរតិ** បានដល់ ញ៉ាំងការនៅដោយឥរិយាបថ ដែលតាំងមាំដោយព្រហ្មវិហារ ឲ្យប្រព្រឹត្តទៅ ។ បទថា **តថា ទុតិយំ** បានដល់ ផ្សាយទៅរហូតទិសណាមួយបណ្ដាទិសទាំងឡាយ មានទិសខាងកើតជាដើមយ៉ាងណា បន្ទាប់អំពីនោះទៅ ក៏ផ្សាយទៅកាន់ទិសទី ២ ទី ៣ ឬទី ៤ ដូចគ្នា ។ បទថា **ឥតិ ឧទ្ធំ** លោកអធិប្បាយថា ទិសខាងលើដោយន័យនេះដូចគ្នា ។ បទថា **អធោ តិរិយំ** បានដល់ សូម្បីទិសខាងក្រោម ទិសខាងទទឹង ក៏យ៉ាងនោះដូចគ្នា ។

ម្យ៉ាងទៀត ក្នុងបទទាំងនោះ បទថា **អធោ** បានដល់ ខាងក្រោម ។ បទថា **តិរិយំ** បានដល់ ទិសទទឹង សេចក្ដីថា ភិក្ខុញ៉ាំងចិត្តសហគតៈដោយមេត្តាឲ្យស្ទុះទៅខ្វះ ឲ្យស្ទុះត្រឡប់ខ្វះក្នុងទិសទាំងពួង ដូចនាយសារថីឲ្យសេះរត់ទៅ រត់ត្រឡប់ត្រង់លានសេះ ដូច្នោះ ។

ដោយហេតុមានប្រមាណប៉ុណ្ណេះ លោកកំណត់កាន់យកទិសនីមួយ ៗ ហើយសម្ដែងការផ្សាយមេត្តាទៅដោយចំពោះ ។ ចំណែកបទថា **សព្វធិ** ជាដើម លោកពោលដើម្បីសម្ដែងដោយមិនចំពោះ ។ ក្នុងបទទាំងនោះ បទថា

**សព្វធិ** បានដល់ ក្នុងទីទាំងពួង ។ បទថា **សព្វត្តតាយ** បានដល់ មានខ្លួនក្នុងប្រភេទសត្វ មានអាក្រក់ កណ្តាល ប្រណីត មិត្ត សត្រូវ និងភាពជាកណ្តាលជាដើមទាំងពួង អធិប្បាយថា ព្រោះមិនធ្វើការបែងចែកថា នេះជាសត្វដទៃ ជាអ្នកស្មើនឹងខ្លួន ។ ម្យ៉ាងវិញទៀត បទថា **សព្វត្តតាយ** បានដល់ ដោយចិត្តទាំងអស់ អធិប្បាយថា មិនរាយមាយទៅខាងក្រៅសូម្បីត្រឹមតិចតួច ។ បទថា **សព្វាវន្តំ** បានដល់ មានសត្វទាំងអស់ អធិ-ប្បាយថា ប្រកបដោយសត្វទាំងពួង ។ បាឋៈថា **សព្វវន្តំ** ដូច្នេះក៏មាន ។ បទថា **លោកំ** បានដល់ សត្វលោកទាំងអស់ ។

ក្នុងនិទ្ទេសនេះលោកពោលថា **មេត្តាសហគតេន** ដដែលទៀត ព្រោះសម្តែងបរិយាយដោយបទថា **វិបុលេន** ជាដើម ឬព្រោះក្នុងនេះ លោកមិនពោល **តថា** សព្វ ប□**្ធតិ** សព្វ ដដែលទៀត ដូចក្នុងការផ្សាយទៅដោយចំពោះ ហេតុនោះ ទើបលោកពោលបទថា **មេត្តាសហគតេន ចេ-តសា** ដដែលទៀតឬលោកពោលពាក្យនេះដោយការសរុប ។ ក្នុងបទថា **វិបុលេន** នេះ គប្បីឃើញការបរិបូណ៌ ដោយអំណាចការផ្សាយទៅ ។ គប្បីឃើញចិត្តនោះដល់នូវភាពជាធំដោយអំណាចភូមិ ។ ពិតណាស់ ចិត្តនោះដល់នូវភាពជាធំ ព្រោះអាចសង្កត់កិលេសបាន ព្រោះមានផលបរិបូណ៌ និងព្រោះជាប់តគ្នាវែង ម្យ៉ាងទៀត ចិត្ត ឈ្មោះថា **មហគ្គតំ** ព្រោះអត្ថថា ដល់ គឺប្រព្រឹត្តទៅដោយឆន្ទៈ វីរិយៈ ចិត្ត និងបញ្ញាដ៏ធំក្រៃលែង ។

ឈ្មោះថា **អប្បមាណំ** ដោយអំណាចនៃភាពជំនាញនិងដោយអំណាច

នៃសត្តារម្មណ៍ដែលប្រមាណមិនបាន ។ ឈ្មោះថា **អវេរំ** ព្រោះលះសត្រូវ គឺព្យាបាទ ។ ឈ្មោះថា **អព្យាបជ្ឈំ** ព្រោះលះទោមនស្សបាន អធិប្បាយថា មិនមានទុក្ខ ។ បទថា **អប្បដិក្កូលា ហោន្តិ** បានដល់ សត្វទាំងឡាយ រមែងប្រាកដ មិនជាទីស្អប់ខ្ពើមដល់ចិត្តរបស់ភិក្ខុ ។ ក្នុងបទដ៏សេសគប្បី ប្រកបដោយអំណាចករុណា មុទិតា និងឧបេក្ខា ដោយន័យដូចពោលហើយ នោះឯង ។ ឈ្មោះថា **អវេរំ** ព្រោះលះសត្រូវ គឺការបៀតបៀន ដោយ ករុណា ព្រោះលះសត្រូវ គឺសេចក្តីប្រណែនដោយមុទិតា ។

បទថា **ឧបេក្ខាសហគតេន** បានដល់ ប្រកបដោយឧបេក្ខា ដោយអំណាចនៃចតុត្ថជ្ឈាន ។ ឈ្មោះថា **អវេរំ** ព្រោះលះសត្រូវ គឺរាគៈ ។ ឈ្មោះថា **អព្យាបជ្ឈំ** ព្រោះលះសោមនស្សដែលអាស្រ័យផ្ទះ ។ អកុសលទាំងអស់ ឈ្មោះថា មានការបៀតបៀន ព្រោះប្រកបដោយសេចក្តីក្តៅក្រហាយ គឺកិលេស នេះជាសេចក្តីពិសេសរបស់បទនោះ ។

[ ១៨៥ ] បទថា **សព្វសោ** បានដល់ ដោយអាការទាំងពួង ឬសញ្ញាទាំងពួង សេចក្តីថា សញ្ញាមិនមានសេសសល់ ។ បទថា **រូបសញ្ញានំ** បានដល់ រូបាវចរឈាន ដូចដែលពោលមកហើយដោយមាតិកាថា សញ្ញា និងអារម្មណ៍របស់រូបាវចរឈាននោះ ។ ពិតណាស់ សូម្បីរូបាវចរឈាន លោកក៏ពោលថា រូប ក្នុងបទថា រូបី រូបានិ បស្សតិ ជាដើម សូម្បីអារម្មណ៍របស់រូបាវចរឈាននោះ លោកក៏ពោលថា រូប ក្នុងបទថា **ពហិទ្ធា រូបានិ បស្សតិ សុវណ្ណទុព្វណ្ណានិ** ជាដើម ព្រោះហេតុនោះ ក្នុងទីនេះ បទ

ថា **រូបសញ្ញានំ** នេះ ជាឈ្មោះរបស់រូបាវចរឈាន ដូចដែលលោកពោល ហើយដោយបំណងដល់សញ្ញាយ៉ាងនេះថា សញ្ញាក្នុងរូប ឈ្មោះថា **រូប-សញ្ញា** ។ ឈ្មោះថា **រូបសញ្ញា** ព្រោះមានរូបជាសញ្ញា អធិប្បាយថា រូប ជាឈ្មោះរបស់ឈាននោះ ។ គប្បីជ្រាបថា បទនេះជាឈ្មោះរបស់អារម្មណ៍ នៃឈាននោះ ដែលមានប្រភេទបឋវីកសិណជាដើម ដោយប្រការដូច្នេះ ។

បទថា **សមតិក្កមា** បានដល់ ព្រោះប្រាសចាកតម្រេក និងព្រោះរលត់ ។ លោកអធិប្បាយទុក ដូចម្ដេច អធិប្បាយទុកថា ព្រោះប្រាសចាកតម្រេក ព្រោះរំលត់ គឺព្រោះហេតុនៃការប្រាសចាកតម្រេក ព្រោះហេតុនៃការរលត់ នូវរូបសញ្ញា ពោលគឺឈាន ១៥ ដោយអំណាចនៃកុសលវិបាកនិងកិរិយា ទាំងនេះ និងនូវរូបសញ្ញា ពោលគឺអារម្មណ៍ ៩ នៃឈានទាំងនោះ ដោយអំណាចបឋវីកសិណជាដើម ដោយអាការទាំងពួង ឬនូវរូបសញ្ញាមិន មានចំណែកសេសសល់ ទើបភិក្ខុចូលដល់អាកាសានញ្ចាយតនៈ ដ្បិតថា ភិក្ខុដែលមិនទាន់ឈានកន្លងរូបសញ្ញាបាន ដោយប្រការទាំងពួង មិនអាច ចូលដល់អាកាសានញ្ចាយតននោះ ។

ព្រោះសមាបត្តិទាំងនេះ គួរសម្រេចដោយការឈានកន្លងអារម្មណ៍ មិន ដូចបឋមជ្ឈានជាដើម ដែលដល់បានព្រោះអារម្មណ៍តែមួយប៉ុណ្ណោះ ។ ការ ឈានកន្លងសញ្ញា រមែងមិនមានដល់បុគ្គលដែលមិនទាន់ប្រាសចាកតម្រេក ក្នុងអារម្មណ៍ ហេតុនោះគប្បីជ្រាបថា លោកធ្វើការពណ៌នាសេចក្ដីនេះដោយ អំណាចនៃការឈានកន្លងអារម្មណ៍ ។

បទថា **បដិឃសញ្ញានំ អត្ថង្គមា** បានដល់ សញ្ញាដែលកើតដោយចក្ខុវត្ថុជាដើម និងរូបារម្មណ៍ជាដើមប៉ះខ្ទប់គ្នា ឈ្មោះថា បដិឃសញ្ញា ។ បទនេះជាឈ្មោះរបស់រូបសញ្ញាជាដើម ។ មានពាក្យអធិប្បាយថា ព្រោះរំលត់ ព្រោះលះ ព្រោះមិនកើតឡើង ព្រោះមិនប្រព្រឹត្តទៅនៃបដិឃសញ្ញាទាំង ១០ នោះ ដោយប្រការទាំងពួង គឺខាងកុសលវិបាក ៥ ខាងអកុសលវិបាក ៥ ។ម្យ៉ាងទៀត សញ្ញាទាំងនេះ រមែងមិនមានដល់អ្នកចូលដល់បឋមជ្ឈានជាដើមក៏ពិត ព្រោះក្នុងសម័យនោះ ចិត្តរមែងមិនប្រព្រឹត្តទៅដោយអំណាចនៃទ្វារ ៥ កាលបើយ៉ាងនេះ គប្បីជ្រាបការពោលដល់សញ្ញាទាំងនេះ ក្នុងឈានទាំងនេះ ដោយអំណាចការសរសើរឈាននេះ ដើម្បីឲ្យកើតឧស្សាហៈក្នុងឈាននេះ ដូចការពោលដល់សុខនិងទុក្ខដែលលះបានហើយក្នុងឈានដទៃទុកក្នុងចតុត្ថជ្ឈាន និងដូចការពោលដល់សក្កាយទិដ្ឋិជាដើម ដែលលះបានហើយក្នុងមគ្គដទៃទុកក្នុងតតិយមគ្គ ។

ម្យ៉ាងទៀត សញ្ញាទាំងនោះ រមែងមិនមានដល់អ្នកចូលដល់រូបាវចរក៏ពិត ដោយពិតសញ្ញាទាំងនេះ ឈ្មោះថា មិនមាន ព្រោះលះបានហើយក៏មិនមែន ព្រោះថា ការចម្រើនរូបាវចរៈ រមែងមិនប្រព្រឹត្តទៅ ដើម្បីការប្រាសចាកតម្រេកក្នុងរូប និងព្រោះនៅជាប់ក្នុងរូបនិងសញ្ញាទាំងនោះប្រព្រឹត្តទៅ ព្រោះទាក់ទងក្នុងរូបនោះឯង ។ ចំណែកការនានេះ រមែងប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេកក្នុងរូប ព្រោះហេតុនោះ ទើបគួរពោលថា សញ្ញាទាំងនោះ លះបានហើយក្នុងអាកាសានញ្ចាយតនៈនេះ ។ មិនមែនពោល

តែម្យ៉ាង ទ្រង់គួរពោលទុកយ៉ាងនេះ ដោយចំណែកមួយប៉ុណ្ណោះ ព្រោះមិនទាន់លះសញ្ញាទាំងនោះបាន មុនអំពីនេះ សម្រាប់បុគ្គលដែលចូលបឋមជ្ឈានទើបព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយទសកនិបាត ) ថា ឈានមានសំឡេងជាបន្លា ។ ម្យ៉ាងទៀត ព្រោះលះសញ្ញាបានហើយក្នុងឈាននេះ ទើបព្រះមានព្រះភាគ ត្រាស់ដល់ភាពដែលអរូបសមាបត្តិទាំងឡាយ ជាអនេញ្ជា ( មិនញាប់ញ័រ ) និងជាសន្តវិមោក្ខ ( រួចផុតយ៉ាងស្ងប់ ) ។

បទថា **នានត្តសញ្ញានំ អមនសិការា** បានដល់ សញ្ញាដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗ ឬសញ្ញាដែលមានសភាពផ្សេងៗ ព្រោះសញ្ញាទាំងនោះប្រព្រឹត្តទៅក្នុងអារម្មណ៍ ដែលមានភាពផ្សេងៗ គឺមានសភាពផ្សេងៗ មានរូបសញ្ញាជាដើម និងព្រោះសញ្ញាទាំង ៤៤ យ៉ាងនេះ គឺកាមាវចរកុសលសញ្ញា ៨ អកុសលសញ្ញា ១២ កាមាវចរកុសលវិបាកសញ្ញា ១១ អកុសលវិបាកសញ្ញា ២ កាមាវចរកិរិយាសញ្ញា ១១ មានភាពផ្សេងគ្នា មានសភាពផ្សេងគ្នា មិនដូចគ្នា ហេតុនោះ ទើបលោកពោលថា **នានត្តសញ្ញា** ។

ព្រោះមិនមនសិការ មិននឹកគិត និងព្រោះមិនឲ្យកើតក្នុងចិត្តនូវនានត្តសញ្ញាទាំងនោះដោយប្រការទាំងពួង ។ មានពាក្យអធិប្បាយថា ព្រោះមិននឹកគិតដល់ មិនឲ្យកើតក្នុងចិត្ត មិនមនសិការ មិនពិចារណានូវនានត្តសញ្ញាទាំងនោះ ។ ម្យ៉ាងទៀត ព្រោះក្នុងសញ្ញាទាំងនេះ រូបសញ្ញានិងបដិឃសញ្ញា

ខាងដើមមិនមាន សូម្បីក្នុងកពដែលកើតដោយឈាននេះ មិនចាំបាច់ពោល ដល់ក្នុងកាលចូលដល់ឈាននេះ ក្នុងកពនោះ ហេតុនោះ ទើបលោកពោល ការមិនមាននៃសញ្ញាទាំងនោះឯង ដោយចំណែកទាំងពីរ គឺព្រោះកន្ទងបង់ ព្រោះសេចក្ដីវិនាស ។

ចំណែកក្នុងនានត្តសញ្ញា គប្បីជ្រាបថា ព្រោះសញ្ញាទាំង ២៧ ប្រការ នេះ គឺកាមាវចរកុសលសញ្ញា ៨ កិរិយាសញ្ញា ៩ អកុសលសញ្ញា ១០ មានក្នុងកពដែលកើតដោយឈាននេះ ហេតុនោះទើបលោកពោលថា ព្រោះ មិនមនសិការសញ្ញាទាំងនោះ ។

ពិតណាស់ ក្នុងបទនោះ ភិក្ខុកាលចូលដល់ឈាននេះ រមែងចូលដល់ បាន ព្រោះមិនមនសិការសញ្ញាទាំងនោះ ។ តែកាលមនសិការដល់សញ្ញា ទាំងនោះ រមែងចូលមិនបាន ។ម្យ៉ាងទៀត ក្នុងឈាននេះ ពោលដោយ សង្ខេប គប្បីជ្រាបថា លោកពោលដល់ការលះរូបាវចរធម៌ទាំងពួង ដោយ បទនេះថា **រូបសញ្ញានំ សមតិក្កមា** ។ ពោលដល់ការលះ និងការមិន មនសិការ ចិត្តនិងចេតសិកដែលជាកាមាវចរទាំងពួង ដោយបទនេះថា **ប-ដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា** ។

ក្នុងបទថា **អនន្តោ អាកាសោ** នេះ គប្បីជ្រាបសេចក្ដីដូចតទៅនេះថា ឈ្មោះថា **អនន្តោ** ព្រោះទីបំផុតនៃការកើតឡើង ឬទីបំផុតនៃការវិនាស របស់អាកាសនោះ មិនប្រាកដ ព្រោះត្រឹមតែជាបញ្ញត្តិ ឈ្មោះថា **អនន្តោ** សូម្បីដោយអំណាចការផ្សាយទៅ មិនមានទីបំផុត ។ ពិតណាស់ ព្រះ

យោគាវចរនោះ រមែងមិនផ្សាយទៅដោយឯកទេស រមែងផ្សាយទូទៅ ។ បទថា **អាកាសោ** បានដល់ អាកាសដែលបើកកសិណ ។ បទថា **អាកាសានញ្ចាយតនំ** ជាដើម មានសេចក្តីដូចបានពោលហើយ ។

បទថា **ឧបសម្បជ្ជ វិហរតិ** បានដល់ ដល់អាយតនៈនោះ គឺឲ្យសម្រេច ហើយនៅដោយឥរិយាបថ ដែលសមគួរដល់សមាបត្តិនោះ ។ អាយតនៈនោះ ៗ ឯង ឈ្មោះថា សមាបត្តិ ព្រោះព្រះយោគាវចរគប្បីចូលដល់ ។

បទថា **អាកាសានញ្ចាយតនំ សមតិក្កម្ម** សេចក្តីថា សូម្បីឈានសូម្បីអារម្មណ៍ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ តាមន័យដូចពោលហើយក្នុងកាលមុន ។ ពិតណាស់ សូម្បីអារម្មណ៍ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ ព្រោះអាកាសានញ្ចៈដោយន័យដែលពោលហើយក្នុងកាលមុននោះឯង និងជាអាយតនៈដោយអត្ថថា ជាទីតាំង ដូច **ទេវានំ ទេវាយតនំ** ( លំនៅរបស់ទេវតាទាំងឡាយ ) ព្រោះជាអារម្មណ៍របស់អរូបជ្ឈានទីមួយម្យ៉ាងទៀត ឈ្មោះថា អាកាសានញ្ចាយតនៈ ព្រោះជាអាកាសានញ្ចៈ និងជាអាយតនៈ ដោយអត្ថថា ជាកន្លែងកើត ដូចបទថា **កម្ពោជា អស្សានំ អាយតនំ** ( កម្ពោជនគរជាកន្លែងកើតរបស់សេះទាំងឡាយ ) ព្រោះហេតុកើតនៃឈាននោះ ។

ព្រះយោគាវចរឈានកន្លងសូម្បីទាំងពីរយ៉ាងនោះ គឺឈាននិងអារម្មណ៍ដោយធ្វើមិនឲ្យប្រព្រឹត្តទៅ និងដោយមិនមនសិការយ៉ាងនេះ ហើយគប្បី

ចូលដល់វិញ្ញាណញ្ចាយតនៈនេះ ហេតុនោះ គប្បីជ្រាបថា លោកធ្វើសូម្បីទាំងពីរយ៉ាងនេះរួមគ្នាហើយពោលបទនេះថា **អាកាសានញ្ចាយតនំ សមតិក្កម្ម** ។ បទថា **អនន្តំ វិញ្ញាណំ** មានពាក្យអធិប្បាយថា ព្រះយោគាវចរ មនសិការវិញ្ញាណនោះៗឯងដែលផ្សាយទៅថា **អនន្តោ អាកាសោ** អាកាសមិនមានទីបំផុត ឬ **អនន្តំ វិញ្ញាណំ** វិញ្ញាណមិនមានទីបំផុត ។ ឬឈ្មោះថា **អនន្តំ** ដោយអំណាចមនសិការ ។ ពិតណាស់ ព្រះយោគាវចរនោះ កាលមនសិការវិញ្ញាណ ដែលមានអាកាសជាអារម្មណ៍នោះ ដោយមិនមានចំណែកសេសសល់ ឈ្មោះថា រមែងមនសិការវិញ្ញាណដែលមិនមានទីបំផុត ។

ម្យ៉ាងទៀត ក្នុងបទនេះថា **វិញ្ញាណញ្ចាយតនំ សមតិក្កម្ម** សូម្បីឈាន សូម្បីអារម្មណ៍ ក៏ជាវិញ្ញាណញ្ចាយតនៈ តាមន័យដូចពោលហើយក្នុងកាលមុននោះឯង ។ ពិតណាស់ សូម្បីអារម្មណ៍ក៏ឈ្មោះថា វិញ្ញាណញ្ចាយតនៈ ព្រោះវិញ្ញាណញ្ចៈ តាមន័យដូចពោលហើយ ក្នុងកាលមុននោះឯង និងជាអាយតនៈ ដោយអត្ថថា ជាទីតាំង ព្រោះជាអារម្មណ៍នៃអរូបឈានទីពីរ ម្យ៉ាងទៀត ឈ្មោះថា វិញ្ញាណញ្ចាយតនៈ ព្រោះជាវិញ្ញាណញ្ចៈ និងជាអាយតនៈ ដោយអត្ថថា ជាកន្លែងកើត ព្រោះជាហេតុកើតនៃឈាននោះៗឯង ។

ព្រោះព្រះយោគាវចរឈានកន្លងសូម្បីទាំងពីរនេះ គឺឈាននិងអារម្មណ៍ ដោយធ្វើមិនឲ្យប្រព្រឹត្តទៅ និងដោយមិនមនសិការយ៉ាងនេះហើយគប្បីចូល

ដល់អាកិញ្ចញ្ញាយតនៈនេះ ហេតុនោះ គប្បីជ្រាបថា លោកធ្វើសូម្បីទាំងពីរ យ៉ាងនោះរួមគ្នាហើយពោលបទនេះថា **វិញ្ញាណញ្ចាយតនំ សមតិក្កម្ម** ។

ក្នុងបទថា **នត្ថិ កិញ្ចិ** មានពាក្យអធិប្បាយថា ព្រះយោគាវចរ មនសិការយ៉ាងនេះថា **នត្ថិ នត្ថិ** មិនមាន មិនមាន **សុញ្ញំ សុញ្ញំ** ទទេ ទទេ **វិវិត្តំ វិវិត្តំ** ស្ងាត់ ស្ងាត់ ។

បទថា **អាកិញ្ចញ្ញាយតនំ សមតិក្កម្ម** សូម្បីឈាន សូម្បីអារម្មណ៍ ក៏ជាអាកិញ្ចញ្ញាយតនៈ តាមន័យដូចពោលហើយ ក្នុងកាលមុននោះឯង ។ ពិតណាស់ សូម្បីអារម្មណ៍ក៏ជាអាកិញ្ចញ្ញាយតនៈ ព្រោះជាអាកិញ្ចញ្ញៈតាមន័យដូចពោលហើយក្នុងកាលមុននោះឯង និងជាអាយតនៈដោយអត្ថថា ជាទីតាំង ព្រោះជាអារម្មណ៍នៃអរូបឈានទី ៣ ម្យ៉ាងទៀត ឈ្មោះថា អាកិញ្ចញ្ញាយតនៈ ព្រោះជាអាកិញ្ចញ្ញៈនិងជាអាយតនៈដោយអត្ថថា ជាកន្លែងកើត ព្រោះជាហេតុកើតនៃឈាននោះៗឯង ។

ព្រោះព្រះយោគាវចរឈានកន្លង សូម្បីទាំងពីរយ៉ាងនោះ គឺឈាននិងអារម្មណ៍ដោយធ្វើមិនឲ្យប្រព្រឹត្តទៅ និងដោយមិនមនសិការយ៉ាងនេះហើយ គប្បីចូលដល់នេវសញ្ញានាសញ្ញាយតនៈនេះ ហេតុនោះគប្បីជ្រាបថា លោកធ្វើសូម្បីទាំងពីរយ៉ាងនោះរួមគ្នា ហើយពោលបទនេះថា **អាកិញ្ចញ្ញាយតនំ សមតិក្កម្ម** ដូច្នេះ ។ សញ្ញាវេទយិតនិរោធកថា ខ្ញុំធ្លាប់ពោលទុកហើយ ។

វិមោក្ខ ៧ មាន **រូបី រូបានិ បស្សតិ** ជាដើម ឈ្មោះថា វិមោក្ខ ដោយអត្ថថា រួចផុតដោយល្អចាកធម៌ជាសត្រូវទាំងឡាយ និងដោយអត្ថថា

រូបផុតដោយល្អ ដោយអំណាចសេចក្ដីត្រេកអរក្រៃលែង ក្នុងអារម្មណ៍ ។ ចំណែកនិរោធសមាបត្តិ ឈ្មោះថា វិមោក្ខ ដោយអត្ថថា រួចផុតហើយចាកចិត្តនិងចេតសិក ។

[ ១៨៦ ] ឈ្មោះថា សមយវិមោក្ខ ព្រោះអត្ថថា រួចផុតក្នុងសម័យចូលដល់សមាបត្តិ មិនរួចផុតក្នុងសម័យចេញហើយ ។

អរិយមគ្គ ឈ្មោះថា អសមយវិមោក្ខ ព្រោះរួចផុតដោយឥតសេសសល់ ដោយអំណាចសមុច្ឆេទវិមុត្តិ សាមញ្ញផល ឈ្មោះថា អសមយ-វិមោក្ខ ព្រោះរួចផុតដោយឥតសេសសល់ ដោយអំណាចបដិប្បស្សទ្ធិវិមុត្តិ និព្វានឈ្មោះថា អសមយវិមោក្ខ ព្រោះរួចផុតដោយឥតសេសសល់ដោយអំណាចនិស្សរណវិមុត្តិ ។ សាមយិកវិមោក្ខនិងអសាមយិកវិមោក្ខ ក៏ដូចគ្នា ។

ឈ្មោះថា កុប្បវិមោក្ខ ព្រោះដល់នូវសេចក្ដីប្រមាទហើយរមែងវិនាសទៅ ។ ឈ្មោះថា អកុប្បវិមោក្ខ ព្រោះមិនវិនាសយ៉ាងនោះ ។ ឈ្មោះថា លោកិយវិមោក្ខ ព្រោះរមែងប្រព្រឹត្តទៅតាមលោក ។ អរិយមគ្គ ឈ្មោះថា លោកុត្តរវិមោក្ខ ព្រោះកំពុងឆ្លងលោក សាមញ្ញផលនិងនិព្វាន ឈ្មោះថា លោកុត្តរវិមោក្ខ ព្រោះឆ្លងផុតលោកហើយ ។ ឈ្មោះថា អនាសវវិមោក្ខ ព្រោះអាសវៈទាំងឡាយ មិនចាប់យកលោកុត្តរធម៌ដ៏ខ្ពង់ខ្ពស់ ដោយតេជះដូចរុយមិនទុំលើដុំដែកដែលក្ដៅដូច្នោះ ។

[ ១៨៧ ] បទថា **រូបប្បដិសញ្ញុត្តោ** បានដល់ រូបឈាន ។ បទថា

**អរូបប្បដិសញ្ញុត្តោ** បានដល់ អរូបសមាបត្តិ ។ វិមោក្ខដែលត្រូវតណ្ហាចាប់យកទុក ឈ្មោះថា បណិហិតវិមោក្ខ វិមោក្ខដែលមិនត្រូវតណ្ហាចាប់យកទុក ឈ្មោះថា អប្បណិហិតវិមោក្ខ ។ មគ្គផលឈ្មោះថា ឯកត្តវិមោក្ខ ព្រោះមានអារម្មណ៍ដូចគ្នា និងព្រោះសម្រេចផលដូចគ្នា និព្វាន ឈ្មោះថា ឯកត្តវិមោក្ខ ព្រោះមិនមានចំណែកពីរ ឈ្មោះថា នានត្តវិមោក្ខ ព្រោះមានអារម្មណ៍ផ្សេងគ្នា និងព្រោះមានវិបាកផ្សេងគ្នា ។

[ ១៨៨ ] បទថា **សិយា** បានដល់ គប្បីកើត អធិប្បាយថា គប្បីមានថា មាន ១០ និងមាន ១ ។ ម្យ៉ាងទៀត បទថា **សិយា** នោះ ជាពាក្យសម្តែងវិធី មិនមែនជាពាក្យសួរ ។ បទថា **វត្ថុវសេន** បានដល់ មាន ១០ ដោយអំណាចនៃវត្ថុ ១០ មាននិច្ចសញ្ញាជាដើម ។ បទថា **បរិយាយេន** បានដល់ មាន ១ ដោយបរិយាយនៃការរួបផុត ។ បទថា **សិយាតិ កថញ្ច សិយា** បានដល់ សួរថា វត្ថុណាតម្កល់ទុកថាគប្បីមាន វត្ថុនោះគប្បីមានដូចម្តេច ។ បទថា **អនិច្ចានុបស្សនញាណំ** ជាបទសមាស ។ បាលីថា **អនិច្ចានុបស្សនាញាណំ** ដូច្នេះក៏មាន ។ សូម្បីក្នុងបទដ៏សេសក៏ដូចគ្នា ។

បទថា **និច្ចតោ សញ្ញាយ** បានដល់ ចាកសញ្ញាដែលប្រព្រឹត្តទៅហើយដោយភាពជារបស់ទៀង អធិប្បាយថា ចាកសញ្ញាដែលប្រព្រឹត្តទៅហើយថាទៀង ។ សូម្បីក្នុងបទនេះថា **សុខតោ អត្តតោ និមិត្តតោ សញ្ញាយ** ក៏មានន័យនេះ ។ ម្យ៉ាងទៀត បទថា **និមិត្តតោ** បានដល់ ចាកនិមិត្តថាទៀង ។ បទថា **នន្ទិយា សញ្ញាយ** បានដល់ ចាកសញ្ញា ដែលប្រព្រឹត្តទៅហើយ

ដោយការត្រេកត្រអាល អធិប្បាយថា ចាកសញ្ញា ដែលសម្បយុត្តហើយដោយការត្រេកត្រអាល ។ ក្នុងបទថា **រាគតោ សមុទយតោ អាទានតោ បណិធិតោ អភិនិវេសតោ សញ្ញាយ** ក៏មានន័យនេះ ។

ម្យ៉ាងទៀត ព្រោះអនុបស្សនា ៣ យ៉ាង គឺខយានុបស្សនា វយានុបស្សនា វិបរិណាមានុបស្សនា ជាសេចក្ដីវិសេសនៃភង្គានុបស្សនា ដែលជាពលវប្បច្ច័យ ដើម្បីឲ្យអនិច្ចានុបស្សនាជាដើមមានកម្លាំង ព្រោះថា អនិច្ចានុបស្សនាមានកម្លាំង ព្រោះឃើញការរលត់ កាលអនិច្ចានុបស្សនាមានកម្លាំងហើយ សូម្បីទុក្ខានុបស្សនា និងអនត្តានុបស្សនា ក៏រមែងមានកម្លាំង ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយខន្ធវារវគ្គ ) ថា របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា ដូច្នេះ ។ កាលលោកពោលដល់អនិច្ចានុបស្សនាជាដើម ក៏ឈ្មោះថាពោលដល់អនុបស្សនាសូម្បីទាំង ៣ នោះផង ។ ម្យ៉ាងទៀត ដោយពាក្យថា សុញ្ញតានុបស្សនាញាណ ផុតស្រឡះចាកសេចក្ដីសម្គាល់ ថាគួរប្រកាន់ស្អិត ឈ្មោះថាលោកពោលថា ផុតចាកសារាទានាភិនិវេសសញ្ញា សម្មោហាភិនិវេសសញ្ញា អាលយាភិនិវេសសញ្ញា សញ្ញោគាភិនិវេសសញ្ញា និងឈ្មោះថា លោកពោលថាផុតចាកអប្បដិសង្ខារសញ្ញា ព្រោះមិនមានអភិនិវេស ព្រោះហេតុនោះគប្បីជ្រាបថា អនុបស្សនា ៥ មានអធិប្បញ្ញាធម្មវិបស្សនាជាដើម[១]

---

១-អធិប្បញាធម្មវិបស្សនា ១ យថាភូតញាណទស្សន ១ អាទីនវានុបស្សនា ១ បដិសង្ខា-នុបស្សនា ១ វិវដ្ដានុបស្សនា ១ ។

លោកមិនបានពោលទុកដោយប្រការដូច្នេះ គប្បីជ្រាបថា ក្នុងមហាវិបស្សនា ១៨ លោកមិនបានពោលដល់អនុបស្សនាទាំង ៨ នោះឡើយ ពោលដល់តែអនុបស្សនា ១០ ប៉ុណ្ណោះ ។

[ ១៨៩ ] បទថា **អនិច្ចានុបស្សនា យថាភូតំ ញាណំ** បានដល់យថាភូតញ្ញាណ គឺអនិច្ចានុបស្សនា ។ បទទាំង ២ ជាបឋមាវិភត្តិ ។ ដោយពាក្យថា យថាភូតញ្ញាណ លោកពោលដល់អត្ថនៃញាណ ។ សូម្បីក្នុងបទដ៏សេស ក៏យ៉ាងនេះ ។ បទថា **សម្មោហា អញ្ញាណា** បានដល់ ចាកការមិនដឹងដែលជាការវង្វេង ។ បទថា **មុច្ចតិ** លោកពោលដល់អត្ថ នៃវិមោក្ខ ។

[ ១៩០ ] បទថា **អនិច្ចានុបស្សនា អនុត្តរំ សីតិភាវញាណំ** សេចក្តីថា ឈ្មោះថា **អនុត្តរំ** ព្រោះអត្ថថា ឧត្តម ដោយមាននៅក្នុងសាសនានេះប៉ុណ្ណោះ ឬឈ្មោះថា **អនុត្តរំ** ព្រោះជាបច្ច័យនៃវត្ថុដ៏កំពូល ញាណគឺការត្រជាក់ចិត្ត ឈ្មោះថា សីតិភាវញ្ញាណ ។ សីតិភាវញ្ញាណនោះ ជាញាណកំពូល ពោលគឺអនិច្ចានុបស្សនា ។ និព្វាន ឈ្មោះថា ជាការត្រជាក់ដ៏ប្រសើរ ដូចព្រះពុទ្ធវចនៈ ( ក្នុងអង្គុត្តរនិកាយឆក្កនិបាត ) នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវសេចក្តីត្រជាក់ចិត្តដ៏ប្រសើរ ដូច្នេះ ។ តែក្នុងទីនេះវិបស្សនា ឈ្មោះថាជាការត្រជាក់ដ៏ប្រសើរ ។

បទថា **និច្ចតោ សន្តាបបរិឡាហទរថា មុច្ចតិ** មានវិនិច្ឆ័យថា កិលេសដែលប្រព្រឹត្តទៅថាទៀង ហៅថា **សន្តាប** ព្រោះអត្ថថា ក្តៅក្រហាយ

ក្នុងលោកនេះនិងលោកខាងមុខ ហៅថា **បរិឡាហា** ព្រោះអត្ថថា ដុតរោល ហៅថា **ទរថ** ព្រោះអត្ថថា ក្តៅ ។

[ ១៩១ ] បទថា **នេក្ខម្មំ ឈាយតិ ឈានំ** ជាដើម មានសេចក្តីដូចជាប់ពោលទុកហើយ ។ ម្យ៉ាងទៀត ក្នុងទីនេះ **នេក្ខម្ម** ជាដើមនិងសមាបត្តិ ៨ ជាចំណែកនៃការចាក់ធ្លុះទាំងអស់ ។

[ ១៩២ ] បទថា **អនុប្បាទា ចិត្តស្ស វិមោក្ខោ** ក្នុងទីនេះ គឺវិបស្សនានោះឯង ។ តែក្នុងព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) នេះថា ការនិយាយ ការប្រឹក្សាគ្នា សុទ្ធតែមានការរួចផុតនៃចិត្ត ព្រោះមិនប្រកាន់មាំ នុ៎ះជាប្រយោជន៍[១] និព្វានគឺអនុបាទាចិត្តវិមោក្ខ ( ការរួចផុតនៃចិត្តព្រោះមិនប្រកាន់ ) ។

[ ១៩៣-១៩៤ ] បទថា **កតិហុបាទានេហិ** បានដល់ ចាកឧបាទានប៉ុន្មាន ។ បទថា **កតមា ឯកុបាទានា** បានដល់ ចាកឧបាទាន ១ ប្រភេទដូចម្តេច ។

បទថា **ឥទំ ឯកុបាទានា** បានដល់ ចាកឧបាទាន ១ នេះ ។ ម្យ៉ាងវិញទៀត បទថា **ឥទំ** ជាពាក្យដែលសម្ដែងដល់ញាណមុន ។ ក្នុងការរួចផុតចាកឧបាទានមានសេចក្តីដូចតទៅនេះថា ព្រោះព្រះយោគាវចរពិចារណាឃើញហើយ ឃើញទៀតនូវការកើតនិងការអស់នៃសង្ខារទាំងឡាយ អំពីខាងដើម រមែងឃើញច្បាស់ដោយអនិច្ចានុបស្សនា ខាងក្រោយ ពិចារណា

---

១-បិដកខ្មែរលេខ ៤១ ឃ្នាប ៦៩ តែក្នុងទីនេះ ព្រះអដ្ឋកថាចារ្យលោកកាត់ចេញខ្លះ ។

ឃើញការរលត់នៃសង្ខារទាំងឡាយ ហើយរមែងឃើញច្បាស់ដោយអនិមិត្តានុបស្សនា ។ ពិតណាស់ អនិមិត្តានុបស្សនា ជាសេចក្តីវិសេសនៃអនិច្ចានុបស្សនា ។ ការមិនមានតួខ្លួនប្រាកដច្បាស់ ដោយការឃើញការកើតនិងការអស់ទៅ និងដោយឃើញការរលត់នៃសង្ខារទាំងឡាយ ដោយហេតុនោះទើបលះទិដ្ឋុបាទាននិងអត្តវាទុបាទានបាន ។ម្យ៉ាងទៀត ព្រោះលះទិដ្ឋិនោះឯង ទើបជាការលះសីលព្វតុបាទានបាន ព្រោះមិនមានការឃើញថា តួខ្លួនរមែងបរិសុទ្ធបានដោយសីលនិងវត្ត ។ ម្យ៉ាងទៀត ព្រោះព្រះយោគាវចរពិចារណាឃើញការមិនមានតួខ្លួនដោយត្រង់ ដោយអនត្តានុបស្សនានិងសុញ្ញតានុបស្សនា ជាសេចក្តីវិសេសនៃអនត្តានុបស្សនានោះឯង ហេតុនោះ ញាណទាំង ៤ នេះ រមែងផុតចាកឧបាទាន ៣ មានទិដ្ឋុបាទានជាដើម ព្រោះតណ្ហាជាសត្រូវដោយត្រង់ដល់អនុបស្សនា ៤ មានទុក្ខានុបស្សនាជាដើម ទើបលោកមិនពោលដល់ការផុតចាកកាមុបាទាននៃអនុបស្សនា៤[១]មានអនិច្ចានុបស្សនាជាដើម ព្រោះកាលព្រះយោគាវចរពិចារណាឃើញថា សង្ខារទាំងឡាយជាទុក្ខ ដោយទុក្ខានុបស្សនាអំពីខាងដើម និងក្នុងកាលជាក្រោយពិចារណាឃើញថា សង្ខារទាំងឡាយជាទុក្ខ ដោយអប្បណិហិតានុបស្សនា រមែងលះការប្រាថ្នាសង្ខារទាំងឡាយចេញបាន ព្រោះថា អប្បណិហិតានុបស្សនា ជាសេចក្តីវិសេសនៃទុក្ខានុបស្សនានោះឯង ។ ម្យ៉ាងទៀត ព្រោះកាលព្រះយោគាវចរនឿយណាយក្នុងសង្ខារទាំងឡាយ ដោយនិព្វិទានុបស្សនា ការប្រាស

១-ក[illegible] ៣ ។

ចាកតម្រេកដោយវិរាគានុបស្សនា រមែងលះការប្រាថ្នាសង្ខារទាំងឡាយចេញបាន ហេតុនោះ ញាណទាំង ៤ នេះ រមែងផុតចាកកាមុបាទាន ព្រោះព្រះយោគាវចររមែងរំលត់កិលេសទាំងឡាយបាន ដោយនិរោធានុបស្សនា រមែងលះកិលេសទាំងឡាយបាន ដោយបដិនិស្សគ្គានុបស្សនា ហេតុនោះ ញាណទាំង ២ នេះ រមែងផុតចាកឧបាទាន ៤ ព្រោះហេតុនោះ ទើបលោកសម្តែងវិមោក្ខ ៦៨ ដោយសេចក្តីផ្សេងគ្នា ដោយសភាវៈ និងដោយសេចក្តីផ្សេងគ្នាដោយអាការ ដោយប្រការដូច្នេះ ។

[ ១៩៥ ] ព្រះសារីបុត្តត្ថេរ កាលសម្តែងដល់ប្រធាននៃវិមោក្ខ ទាំងឡាយ ៣ ដែលលើកឡើងសម្តែងអំពីខាងដើម ហើយឥឡូវនេះ បំណងនឹងសម្តែងឥន្ទ្រិយវិសេស និងបុគ្គលវិសេស ដែលជាប្រធាននៃវិមោក្ខជាសភាវៈដល់មុន ទើបពោលពាក្យថា **តីណិ ខោ បនិមានិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **វិមោក្ខមុខានិ** បានដល់ ប្រធាននៃវិមោក្ខ ៣ ។ បទថា **លោកនិយ្យានាយ សំវត្តន្តិ** បានដល់ រមែងប្រព្រឹត្តទៅដើម្បីការនាំចេញ គឺនាំចេញទៅចាកលោកធាតុ ៣ ។

បទថា **សព្វសង្ខារេ បរិច្ឆេទបរិវដ្ដុមតោ សមនុបស្សនតាយ** បានដល់ ព្រោះពិចារណាឃើញដោយការកំណត់និងដោយការវិលវល់ទៅដោយអំណាចការកើតឡើង និងការអស់ទៅនៃសង្ខារទាំងពួង ។ បាឋៈដ៏សេសថា **លោកនិយ្យានំ ហោតិ** ( ការនាំចេញទៅចាកលោករមែងមាន ) ។

ពិតណាស់ អនិច្ចានុបស្សនាកំណត់ថា មុនអំពីការកើតឡើង សង្ខារ

ទាំងឡាយមិនមាន ហើយតាមស្វែងរកគតិនៃសង្ខារទាំងនោះ ពិចារណាឃើញដោយការវិលវល់ និងដោយទីបំផុតថា ខាងមុខអំពីការវិនាស សង្ខារទាំងឡាយរមែងមិនប្រព្រឹត្តទៅ រមែងអន្តរធានទៅ ក្នុងទីនេះឯង ។ ពិតណាស់ សង្ខារទាំងពួងកំណត់ទីបំផុតខាងដើម ដោយការកើត កំណត់ទីបំផុតខាងចុងដោយការវិនាស ។

បទថា **អនិមិត្តាយ ច ធាតុយា ចិត្តសម្បក្ខន្ទនតាយ** បានដល់ការនាំចេញទៅចាកលោក រមែងមានព្រោះចិត្តស្ទុះទៅក្នុងនិព្វានធាតុ ពោលគឺអនិមិត្ត ដោយប្រាកដដោយអាការមិនមាននិមិត្ត ព្រោះចិត្តបង្អោនទៅក្នុងនិព្វាន សូម្បីក្នុងខណៈវិបស្សនា ។ បទថា **មនោសមុត្តេជនតាយ** បានដល់ ព្រោះការសង្វេគ ព្រោះចិត្តរមែងសង្វេគ ក្នុងសង្ខារទាំងឡាយដោយទុក្ខានុបស្សនា ។

បទថា **អប្បណិហិតាយ ច ធាតុយា** បានដល់ ក្នុងនិព្វានធាតុពោលគឺអប្បណិហិត ដោយប្រាកដដោយអាការមិនមានទីតាំង ព្រោះចិត្តបង្អោនទៅក្នុងនិព្វានសូម្បីក្នុងខណៈវិបស្សនា ។ បទថា **សព្វធម្មេ** លោកមិនពោលថា **សង្ខារេ** តែពោលថា **សព្វធម្មេ** ព្រោះមានសភាពជាអនត្តាសូម្បីក្នុងនិព្វានដែលចូលដល់វិបស្សនាមិនបាន ។ បទថា **បរតោ សមនុបស្សនតាយ** បានដល់ ព្រោះពិចារណាឃើញដោយភាពជាអនត្តា យ៉ាងនេះថា មិនមែនអញ មិនមែនរបស់អញ ព្រោះអាស្រ័យបច្ច័យ ព្រោះមិននៅក្នុងអំណាច និងព្រោះមិនស្តាប់បង្គាប់ ។ បទថា **សុញ្ញតាយ ច**

**ធាតុយា** បានដល់ ក្នុងនិព្វានធាតុ ពោលគឺសុញ្ញតា ដោយប្រាកដដោយអាការទទេ ព្រោះចិត្តបង្អោនទៅក្នុងនិព្វានសូម្បីក្នុងខណៈវិបស្សនា ។ ពាក្យទាំង ៣ នេះ លោកពោលដោយអំណាចនៃអនិច្ចានុបស្សនា ទុក្ខានុបស្សនា និងអនត្តានុបស្សនា ដោយប្រការដូច្នេះ ។

[ ១៩៦ ] ដោយហេតុនោះឯង ទើបលោកពោលបទថា **អនិច្ចតោ មនសិករោតោ** ជាដើម ក្នុងលំដាប់បន្ទាប់អំពីនោះ ។

ក្នុងបទទាំងនោះ បទថា **ខយតោ** បានដល់ ដោយការអស់ទៅ ។ បទថា **ភយតោ** បានដល់ ដោយមានភ័យចំពោះមុខ ។ បទថា **សុញ្ញតោ** បានដល់ ដោយការប្រាសចាកតួខ្លួន ។ បទថា **អធិមោក្ខពហុលំ** បានដល់ ចិត្តច្រើនដោយសទ្ធាក្នុងការជឿ ក្នុងព្រះមានព្រះភាគថា ព្រះមានព្រះភាគត្រាស់ដឹងពិតហ្ន៎ ដោយការឃើញការរលត់គ្រប់ខណៈដោយអនិច្ចានុបស្សនា ដោយប្រចក្សរបស់អ្នកបដិបត្តិដោយសទ្ធាថា សង្ខារទាំងឡាយ រមែងបែកធ្លាយទៅ ដោយអំណាចនៃការរលត់គ្រប់ខណៈ ។ម្យ៉ាងទៀត ចិត្តច្រើនដោយការបង្អោនចិត្តជឿ ព្រោះឃើញការមិនទៀងនៃសង្ខារទាំងឡាយដែលជាចំណែកបច្ចុប្បន្ន ហើយបង្អោនចិត្តទៅថា សង្ខារទាំងពួងដែលជាអតីតអនាគតនិងបច្ចុប្បន្ន សុទ្ធតែមិនទៀង ដោយអាការយ៉ាងនេះ ។ បទថា **បស្សទ្ធិពហុលំ** បានដល់ ចិត្តច្រើនដោយសេចក្តីស្ងប់ព្រោះមិនមានសេចក្តីក្រវល់ក្រវាយនៃចិត្ត ព្រោះលះការប្រាថ្នាដែលតាំងចិត្តទុក ដែលធ្វើឲ្យចិត្តកម្រើក ដោយទុក្ខានុបស្សនា ។ ម្យ៉ាងទៀត ចិត្តច្រើនដោយសេចក្តីស្ងប់

ព្រោះមិនមានសេចក្តីរាយមាយ ព្រោះកើតសេចក្តីសង្វេគ និងព្រោះតាំងចិត្ត ដែលសង្វេគហើយ ទុកដោយឧបាយដោយទុក្ខានុបស្សនា ។ បទថា **វេទ-ពហុលំ** បានដល់ ចិត្តច្រើនដោយញាណនៃអ្នកឃើញអនត្តលក្ខណៈ ដែលជ្រាលជ្រៅ ដែលលទ្ធិខាងក្រៅមិនឃើញ ដោយអនត្តានុបស្សនា ។ ម្យ៉ាងវិញទៀត ចិត្តច្រើនដោយសេចក្តីត្រេកអរនៃអ្នកត្រេកអរថា អាត្មាអញឃើញអនត្តលក្ខណៈ ដែលលោកព្រមទាំងទេវលោកមិនឃើញ ។

បទថា **អធិមោក្ខពហុលោ សទ្ធិន្ទ្រិយំ បដិលភតិ** បានដល់ ការបង្អោនចិត្តជឿក្នុងចំណែកខាងដើម ប្រព្រឹត្តទៅច្រើន ឈ្មោះថា សទ្ធិន្ទ្រិយ ដោយការបរិបូណ៌នៃភាវនា បុគ្គលនោះឈ្មោះថា រមែងបានសទ្ធិន្ទ្រិយនោះ ។ បទថា **បស្សទ្ធិពហុលោ សមាធិន្ទ្រិយំ បដិលភតិ** បានដល់ បុគ្គលអ្នកច្រើនដោយបស្សទ្ធិក្នុងចំណែកខាងដើម រមែងបានសមាធិន្ទ្រិយ ព្រោះមានបស្សទ្ធិជាបច្ច័យ ដោយការបរិបូណ៌នៃភាវនាដោយបាលី ( ក្នុងអង្គុត្តរនិ-កាយបញ្ចកនិបាត ) ថា កាលបើមាននាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលសេចក្តីសុខ ចិត្តរបស់ភិក្ខុដែលប្រកបដោយសេចក្តីសុខ រមែងតម្កល់មាំ ដូច្នេះ បុគ្គលនោះឈ្មោះថា រមែងបានសមាធិន្ទ្រិយនោះ ។ បទថា **វេទពហុលោ បញ្ញិន្ទ្រិយំ បដិលភតិ** បានដល់ វេទៈ ( ការចេះដឹង ) ក្នុងចំណែកខាងដើម ប្រព្រឹត្តទៅច្រើន ឈ្មោះថា បញ្ញិន្ទ្រិយ ដោយការបរិបូណ៌នៃភាវនា បុគ្គលនោះឈ្មោះថា រមែងបានបញ្ញិន្ទ្រិយនោះ ។

[ ១៩៧ ] បទថា **អាធិបតេយ្យំ ហោតិ** បានដល់ សូម្បីកាលឆន្ទៈ

ជាដើមជាធំ ឥន្ទ្រិយរមែងជាធំ ជាប្រធាន ដោយអំណាចធ្វើកិច្ចរបស់ខ្លួនឲ្យសម្រេចបាន ។ បទថា **ភាវនាយ** ជាសត្តមីវិភត្តិ ឬដើម្បីប្រយោជន៍ដល់ការចម្រើនក្រៃលែងៗឡើងទៅ ។ បទថា **តទន្វយានិ ហោន្តិ** បានដល់ទៅតាម គឺអនុលោមទៅតាមឥន្ទ្រិយនោះ ។ បទថា **សហជាតប្បច្ចយា ហោន្តិ** បានដល់ កាលកើត រមែងជាឧបការៈដោយការកើតរួមគ្នា ដូចប្រទីបជាឧបការៈដល់ពន្លឺ ដូច្នោះ ។ បទថា **អញ្ញមញ្ញប្បច្ចយា ហោន្តិ** បានដល់ ជាឧបការៈ ដោយការកើតឡើងនិងការឧបត្ថម្ភដល់គ្នានឹងគ្នា ដូចឈើ ៣ កំណាត់ ( ដែលបុគ្គលលើកឡើងបញ្ឈរ ) ឧបត្ថម្ភដល់គ្នានឹងគ្នា ។ បទថា **និស្សយប្បច្ចយា ហោន្តិ** បានដល់ ជាឧបការៈដោយអាការតាំងមាំ និងដោយអាការជាទីអាស្រ័យ ដូចផែនដីជាដើម ជាឧបការៈដល់ការលូតលាស់នៃដើមឈើ ។ បទថា **សម្បយុត្តបច្ចយតា ហោន្តិ** បានដល់ ជាឧបការៈដោយការសម្បយុត្ត ពោលគឺមានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា កើតព្រមគ្នា រលត់ព្រមគ្នា ។

[ ១៩៨ ] បទថា **បដិវេធកាលេ** បានដល់ ក្នុងកាលចាក់ធ្លុះសច្ចៈនៃមគ្គ ។ បទថា **បញ្ញិន្ទ្រិយំ អាធិបតេយ្យំ ហោតិ** បានដល់ បញ្ញិន្ទ្រិយនោះឯង ធ្វើនិព្វានឲ្យជាអារម្មណ៍ក្នុងខណៈនៃមគ្គ រមែងជាធំដោយអំណាចធ្វើកិច្ច គឺឃើញសច្ចៈ និងដោយអំណាចធ្វើកិច្ច គឺលះកិលេស ។ បទថា **បដិវេធាយ** បានដល់ ដើម្បីត្រូវការចាក់ធ្លុះសច្ចៈ ។ បទថា **ឯករសា** បានដល់ ដោយវិមុត្តិរស ។ បទថា **ទស្សនដ្ឋេន** ព្រោះអត្ថថា ឃើញសច្ចៈ ។

បទថា **ឯវំ បដិវិជ្ឈន្តោបិ ភាវេតិ ភាវេន្តោបិ បដិវិជ្ឈតិ** លោកពោលដើម្បីសម្តែងការប្រព្រឹត្តិទៅទាំងពួងនៃការចម្រើន និងការចាក់ធ្លុះតែម្តងប៉ុណ្ណោះ ក្នុងខណៈនៃមគ្គ ។ លោកប្រកប **អបិ** សព្ទ ក្នុងបទថា **បដិវេធកាលេបិ** ព្រោះបញ្ញិន្ទ្រិយនោះឯងជាធំ សូម្បីក្នុងខណៈនៃវិបស្សនាដោយអនត្តានុបស្សនា ។

[ ១៩៩ ] បទថា **អនិច្ចតោ មនសិការោតោ កតមិន្ទ្រិយំ អធិមត្តំ ហោតិ** លោកពោលដើម្បីសម្តែងភាពវិសេសនៃបុគ្គល ដោយអំណាចភាពវិសេសនៃឥន្ទ្រិយ ។ ក្នុងបទទាំងនោះ បទថា **អធិមត្តំ** បានដល់ ក្រៃលែង ។ ក្នុងបទនោះ គប្បីជ្រាបភាពដែលសទ្ធិន្ទ្រិយ សមាធិន្ទ្រិយនិងបញ្ញិន្ទ្រិយ មានប្រមាណក្រៃលែង ដោយសង្ខារុបេក្ខា ។

ក្នុងបទថា **សទ្ធាវិមុត្តោ** នេះ មានអធិប្បាយថា បុគ្គលជាសទ្ធាវិមុត្តក្នុងឋានៈ ៧ ដ៏សេស វៀរសោតាបត្តិមគ្គ ព្រោះកាលលោកពោលមិនប្លែកគ្នាក្នុងបទនេះ ក៏ពោលប្លែកគ្នាក្នុងបទតទៅ ។ បុគ្គលជាសទ្ធាវិមុត្ត ព្រោះសទ្ធិន្ទ្រិយមានប្រមាណក្រៃលែង មានពាក្យអធិប្បាយថា មិនមែនជាសទ្ធាវិមុត្ត ព្រោះសទ្ធិន្ទ្រិយមានប្រមាណក្រៃលែងក្នុងទីទាំងពួង ។ អាចារ្យទាំងឡាយពោលថា ក្នុងឥន្ទ្រិយដ៏សេស កាលសមាធិន្ទ្រិយនិងបញ្ញិន្ទ្រិយមានប្រមាណក្រៃលែង បុគ្គលក៏ឈ្មោះថាជាសទ្ធាវិមុត្តបានដូចគ្នា ព្រោះសទ្ធិន្ទ្រិយក្នុងខណៈនៃសោតាបត្តិមគ្គ មានប្រមាណក្រៃលែងនោះឯង ។

បទថា **កាយសក្ខី ហោតិ** បានដល់ បុគ្គលឈ្មោះថា ជាកាយសក្ខី

ក្នុងឋានៈទាំង ៨ យ៉ាង ។ បទថា **ទិដ្ឋិប្បត្តោ ហោតិ** គប្បីជ្រាបតាមន័យដូចពោលហើយក្នុងសទ្ធាវិមុត្តនោះឯង ។

[ ២០០ ] បទថា **សទ្ទហន្តោ វិមុត្តោតិ សទ្ធាវិមុត្តោ** បុគ្គលឈ្មោះថា សទ្ធាវិមុត្ត ព្រោះជឿក្នុងខណៈសោតាបត្តិមគ្គក៏រួចផុតក្នុងខណៈនៃផលសូម្បីទាំង ៤ ព្រោះសទ្ធិន្ទ្រិយមានប្រមាណក្រៃលែង ។

ឥឡូវនេះនឹងពោលដល់ភាពជាសទ្ធាវិមុត្តក្នុងខណៈមគ្គ ៣ ខាងលើ តែនឹងពោលភាពជាសទ្ធានុសារី ក្នុងខណៈនៃសោតាបត្តិមគ្គក្នុងខាងក្រោយ ។

បទថា **ផុដ្ឋត្តា សច្ឆិករោតិ កាយសក្ខី** មានវិនិច្ឆ័យថា បុគ្គលឈ្មោះថា កាយសក្ខី ព្រោះអត្ថថា ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ព្រោះកាលជាព្រះសុក្ខវិបស្សកៈ ពាល់ត្រូវនូវឧបចារជ្ឈានផស្សៈ ឬព្រោះកាលជាអ្នកបានរូបជ្ឈាននិងអរូបជ្ឈាន ពាល់ត្រូវរូបជ្ឈាននិងអរូបជ្ឈានផស្សៈ មានអធិប្បាយថា ជាសាក្សីក្នុងផស្សៈនៃឈាននិងក្នុងនិព្វាន មានប្រការដូចពោលហើយដោយនាមកាយ ។

បទថា **ទិដ្ឋត្តា បត្តោតិ ទិដ្ឋិប្បត្តោ** មានវិនិច្ឆ័យថា បុគ្គលឈ្មោះថា ជាទិដ្ឋិបត្ត ព្រោះអត្ថថា សម្រេចនិព្វានដោយអំណាចនៃសោតាបត្តិផលជាដើម ក្នុងខាងក្រោយ ព្រោះឃើញនិព្វានមុនដោយបញ្ញិន្ទ្រិយ ដែលសម្បយុត្តក្នុងខណៈនៃសោតាបត្តិមគ្គ ។ មានអធិប្បាយថា សម្រេចនិព្វានដោយទិដ្ឋិ ពោលគឺបញ្ញិន្ទ្រិយ ។ តែនឹងពោលភាពដែលជាធម្មានុសារី ក្នុងខណៈសោតាបត្តិមគ្គក្នុងខាងក្រោយ ។

បទថា **សទ្ទហន្តោ វិមុច្ចតីតិ សទ្ធាវិមុត្តោ** មានវិនិច្ឆ័យថា បុគ្គលឈ្មោះថា សទ្ធាវិមុត្ត ព្រោះអត្ថថា ជឿ រួចផុតក្នុងខណៈនៃសកទាគាមិមគ្គ អនាគាមិមគ្គនិងអរហត្តមគ្គ ព្រោះសទ្ធិន្ទ្រិយមានប្រមាណក្រៃលែង ។ ក្នុងទីនេះសូម្បីកំពុងរួចផុត លោកក៏ហៅថា រួចផុតហើយ ដោយអំណាចពាក្យដែលសង្ឃឹមផលដែលត្រូវបាន(១) ។ បទថា **ឈានផស្សំ** បានដល់ ពាល់ត្រូវឈាន ៣ យ៉ាង ។ បទថា **ឈានផស្សំ** និងបទថា **ទុក្ខា សង្ខារា** ជាដើម លោកធ្វើអត្ថទាំងពីរ ដែលពោលហើយក្នុងវគ្គដំបូង ឲ្យពិសេសឡើង ។ បទថា **ញាណំ ហោតិ** ជាដើម មានសេចក្តីដូចធ្លាប់ពោលទុកហើយ ។ ម្យ៉ាងទៀត ក្នុងបទនេះអាចារ្យទាំងឡាយ អធិប្បាយថា បុគ្គល

---

១-បុគ្គលណាបានសមាបត្តិ ៨ ធ្វើបញ្ញាឲ្យជាធុរៈ អាស្រ័យសមថាភិនិវេស ធ្វើអរូបសមាបត្តិណានីមួយឲ្យជាបទដ្ឋាន ដើម្បីវិបស្សនាសម្រេចអរហត្ត ក្នុងខណៈសោតាបត្តិមគ្គ ឈ្មោះថា ធម្មានុសារី តាំងនៅក្នុងឋាន ៦ ពីសោតាបត្តិផលដល់អរហត្តមគ្គ ឈ្មោះថា កាយសក្ខី សម្រេចអរហត្តផលហើយ ឈ្មោះថា ឧភតោភាគវិមុត្ត ។

បុគ្គលណាធ្វើបញ្ញាតែម្យ៉ាងប៉ុណ្ណោះឲ្យជាធុរៈ អាស្រ័យវិបស្សនាភិនិវេស ពិចារណាសង្ខារសុទ្ធ បណ្ដារូបាវចរជ្ឈានណាមួយ សម្រេចអរហត្ត បុគ្គលនេះក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា ធម្មានុសារី ក្នុងឋាន ៦ ឈ្មោះថា ទិដ្ឋិប្បត្ត កាលសម្រេចអរហត្តផលហើយ ឈ្មោះថា បញ្ញាវិមុត្ត ។

បុគ្គលណាបានសមាបត្តិ ៨ ធ្វើសទ្ធាឲ្យជាធុរៈ អាស្រ័យអំណាចសមាធិ ធ្វើអរូបសមាបត្តិណាមួយឲ្យជាបទដ្ឋាន ដើម្បីវិបស្សនាសម្រេចអរហត្ត បុគ្គលនេះក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា សទ្ធានុសារី ក្នុងឋាន ៦ ឈ្មោះថា កាយសក្ខីដូចគ្នា កាលសម្រេចអរហត្តផលហើយ ឈ្មោះថា ឧភតោភាគវិមុត្ត ។

បុគ្គលណាធ្វើសទ្ធាឲ្យជាធុរៈ អាស្រ័យអំណាចវិបស្សនា ពិចារណាសង្ខារសុទ្ធ បណ្ដារូបាវចរជ្ឈានណានីមួយ ហើយសម្រេចអរហត្ត បុគ្គលនេះក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា សទ្ធានុសារី ក្នុងឋាន ៦ ឈ្មោះថា សទ្ធាវិមុត្ត សម្រេចអរហត្តផលហើយ ឈ្មោះថា បញ្ញាវិមុត្ត ។

អ្នកបានឈាន លុះចេញហើយដោយទុក្ខានុបស្សនា ដែលឧបត្ថម្ភដល់ស-មាធិន្ទ្រិយ រមែងសម្រេចមគ្គផល ។ បទថា **សិយា** សេចក្ដីថា គប្បីមាន គប្បីកើត ។ បទថា **សិយា** នេះ ជាឈ្មោះរបស់វិធីប៉ុណ្ណោះ ។ បទថា **តយោ បុគ្គលា** បានដល់ បុគ្គល ៣ ពួក ដែលលោកពោលហើយដោយការកំណត់វិបស្សនា និងដោយការកំណត់ឥន្ទ្រិយ ។ បទថា **វត្ថុវសេន** បានដល់ ដោយអំណាចនៃឥន្ទ្រិយវត្ថុនីមួយៗក្នុងអនុបស្សនា ៣ ។ បទថា **បរិយាយេន** បានដល់ ដោយបរិយាយនោះឯង ។ ដោយវារៈនេះលោកសម្ដែងដល់អ្វី ។ លោកសម្ដែងថា លោកពោលដល់ភាពជាធំនៃឥន្ទ្រិយនីមួយៗ ដោយអនុបស្សនានីមួយៗ ក្នុងខាងដើមដោយហេតុយន្ដ័យ និងសម្ដែងថា ភាពជាធំនៃឥន្ទ្រិយនីមួយៗ ក្នុងអនុបស្សនា ៣ រមែងមានបានក្នុងគ្រាខ្លះ ។ ម្យ៉ាងវិញទៀត ឈ្មោះមានសទ្ធាវិមុត្តជាដើម រមែងមានក្នុងខណៈនៃមគ្គនិងផល ដោយសម្ញឹងដល់ភាពជាធំនៃឥន្ទ្រិយទាំងនោះ ក្នុងវិ-បស្សនា ដែលជាចំណែកខាងដើមទាំងនោះ ព្រោះមានអនុបស្សនាទាំង ៣ ក្នុងខណៈនៃវិបស្សនា ដែលជាចំណែកខាងដើម ព្រោះកាលពោលហើយយ៉ាងនេះ ការកំណត់ឥន្ទ្រិយ ភាពជាអធិបតី និងបុគ្គលដែលលោកធ្វើទុកក្នុងវុដ្ឋានគាមិនីវិបស្សនាខាងដើម និងដែលធ្វើទុកតមក ក៏ជាវត្ថុដែលលោកធ្វើល្អហើយ និងមិនញាប់ញ័រឡើយ ។ ក្នុងវារៈបន្ទាប់ បទថា **សិយា** និង **អញ្ញោយេវ** សេចក្ដីថា គប្បីជាយ៉ាងនេះ ។ ក្នុងបទទាំងនេះ អត្ថដែលពោលហើយក្នុងពេលមុនជាបទកំណត់ ។

[ ២០១ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងចែកការផ្សេងគ្នានៃបុគ្គលដោយអំណាចនៃមគ្គនិងផល ទើបពោលថា **អនិច្ចតោ មនសិការោតោ ។បេ។ សោតាបត្តិមគ្គំ បដិលភតិ** ជាដើម ។

ក្នុងបទទាំងនោះ បុគ្គលឈ្មោះថា សទ្ធានុសារី ព្រោះរឭកដល់ គឺទៅតាមសទ្ធា ឬរឭកដល់ទៅតាមព្រះនិព្វានដោយសទ្ធា ។ បទថា **សច្ឆិកតំ** បានដល់ ធ្វើឲ្យប្រចក្ស ។ បទថា **អរហត្តំ** បានដល់ អរហត្តផល ។

[ ២០៣-២០៤ ] ឈ្មោះថា ធម្មានុសារី ព្រោះរឭកដល់ធម៌ ពោលគឺបញ្ញា ឬរឭកដល់និព្វានដោយធម៌នោះ ។

ព្រះសារីបុត្តត្ថេរ បំណងនឹងពណ៌នាការផ្សេងគ្នានៃបុគ្គល ដោយភាពវិសេសនៃឥន្ទ្រិយ ៣ ដោយបរិយាយដទៃទៀត ទើបពោលបទថា **យេ ហិ កេចិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ភាវិតា វា** បានដល់ ចម្រើនហើយក្នុងអតីត ។ បទថា **ភាវេន្តិ វា** បានដល់ ចម្រើនក្នុងបច្ចុប្បន្ន ។ បទថា **ភាវិស្សន្តិ វា** បានដល់ នឹងចម្រើនក្នុងអនាគត ។ បទថា **អធិគតា វា** ជាដើម លោកពោលដើម្បីពង្រីកអត្ថនៃបទមុនៗ ។ បទថា **ផស្សិតា វា** បានដល់ ពាល់ត្រូវហើយ ដោយការពាល់ត្រូវដោយញាណ ។ បទថា **វសិប្បត្តា** បានដល់ ដល់នូវភាពជាធំ ។ បទថា **ចារមិប្បត្តា** បានដល់ ដល់ទីបំផុតហើយ ។ បទថា **វេសារជ្ជប្បត្តា** បានដល់ ដល់នូវភាពក្លាហាន ។ ក្នុងទីទាំងពួង សទ្ធាវិមុត្តបុគ្គលជាដើម រមែងមានក្នុងខណៈដែលពោលទុកហើយ

ក្នុងខាងដើម សតិប្បដ្ឋានជាដើម រមែងមានក្នុងខណៈនៃមគ្គនោះឯង ។

[ ២០៥-២០៧ ] បទថា **អដ្ឋ វិមោក្ខេ** បានដល់ សម្រេចវិមោក្ខ ៨ មាន **រូបី រូបានិ បស្សតិ** ជាដើម ដោយការសម្រេចបដិសម្ភិទាមគ្គនោះឯង ។ បទថា **តិស្សោ សិក្ខា** បានដល់ សម្រេចមគ្គហើយ នៅសិក្សានូវអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ បទថា **ទុក្ខំ បរិជានន្តិ** ជាដើម បានដល់ កំណត់ដឹងក្នុងខណៈនៃមគ្គនោះឯង ។ បទថា **បរិញ្ញាបដិវេធំ បដិវិជ្ឈតិ** បានដល់ ចាក់ធ្លុះដោយការចាក់ធ្លុះដោយការកំណត់ដឹង ម្យ៉ាងទៀត ឈ្មោះថា ចាក់ធ្លុះដោយបរិញ្ញា ព្រោះអត្ថថា គប្បីចាក់ធ្លុះដោយបរិញ្ញា ។ សូម្បីក្នុងបទដ៏សេសក៏យ៉ាងនោះ ។

បទថា **អភិញ្ញាបដិវេធ** ជាដើម លោកពោលឲ្យវិសេសដោយបទថា **សព្វេធម្មា** ជាដើម ។

ចំណែកការចាក់ធ្លុះដោយសច្ឆិកិរិយា គប្បីជ្រាបដោយអំណាចការសម្រេចញាណក្នុងការពិចារណានិព្វាន ក្នុងខណៈនៃមគ្គនោះឯង ។ ក្នុងទីនេះលោកចង្អុលបង្ហាញដល់អរិយបុគ្គល ៥ ទុកយ៉ាងនេះ មិនចង្អុលបង្ហាញដល់អរិយបុគ្គល ២ ទាំងនេះ គឺឧភតោភាគវិមុត្តនិងបញ្ញាវិមុត្ត ។ តែក្នុងទីដទៃ លោកពោលទុកថា បុគ្គលណាមនសិការដោយភាពជាទុក្ខ ច្រើនដោយបសទ្ធិ រមែងបានសមាធិន្ទ្រិយ បុគ្គលនោះឈ្មោះថា កាយសក្ខីក្នុងទីទាំងពួង ចំណែកបុគ្គលសម្រេចអរូបជ្ឈានហើយ សម្រេចផលដ៏ប្រសើរ ឈ្មោះថា ឧភតោភាគវិមុត្ត ។ ម្យ៉ាងទៀត បុគ្គលណាមនសិការដោយភាព

ជាអនត្តា ច្រើនដោយការដឹង រមែងបានបញ្ញិន្ទ្រិយ បុគ្គលនោះឈ្មោះថា ធម្មានុសារី ក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា ទិដ្ឋិប្បត្ត ក្នុងឋានៈ ៦ ឈ្មោះថា បញ្ញាវិមុត្ត ក្នុងអគ្គផល ។ ក្នុងទីនេះលោកសង្គ្រោះបុគ្គលទាំងនោះដោយកាយសក្ខីនិងទិដ្ឋិប្បត្តនោះឯង តែដោយអត្ថ ឈ្មោះថា ឧភតោភាគវិមុត្ត ព្រោះរួចផុតដោយចំណែកពីរ គឺដោយអរូបជ្ឈានទិងដោយអរិយមគ្គ ឈ្មោះថា បញ្ញាវិមុត្ត ព្រោះដឹងហើយទើបរួចផុត ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា លោកចង្អុលបង្ហាញដល់ការផ្សេងគ្នានៃឥន្ទ្រិយនិងបុគ្គល ។

[ ២០៩ ] ឥឡូវនេះព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងដល់ការផ្សេងគ្នានៃវិមោក្ខ និងការផ្សេងគ្នានៃបុគ្គលដែលមានវិមោក្ខ ជាសភាវៈដល់មុននោះឯង ទើបពោលពាក្យថា **អនិច្ចតោ មនសិការោតោ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **ទ្វេ វិមោក្ខា** បានដល់ អប្បណិហិតវិមោក្ខនិងសុញ្ញតវិមោក្ខ ។ មគ្គបានឈ្មោះថា អនិមិត្តវិមោក្ខ ដោយអំណាចដល់អនិច្ចានុបស្សនា រមែងបានសូម្បីឈ្មោះថា អប្បណិហិតវិមោក្ខ ដោយគុណរបស់ខ្លួន ព្រោះមិនមានទីតាំង គឺរាគៈ ទោសៈ មោហៈនិងដោយអារម្មណ៍ ព្រោះធ្វើនិព្វានដែលបានឈ្មោះថា អប្បណិហិត ព្រោះមិនមានទីតាំងទាំងនោះឲ្យជាអារម្មណ៍ ។ ម្យ៉ាងទៀត រមែងបានសូម្បីឈ្មោះថា សុញ្ញតវិមោក្ខ ដោយគុណរបស់ខ្លួន ព្រោះទទេចាករាគៈ ទោសៈនិងមោហៈ និងដោយអារម្មណ៍ ព្រោះធ្វើនិព្វានដែលបានឈ្មោះថា សុញ្ញតៈ ព្រោះទទេចាករាគៈជាដើមនោះឯង ឲ្យជាអារម្មណ៍ ព្រោះហេតុនោះទើបវិមោក្ខទាំង ២ នោះ

ឈ្មោះថា ទៅតាមអនិមិត្តវិមោក្ខ ។ ម្យ៉ាងទៀត គប្បីជ្រាបថា វិមោក្ខទាំង ២ នោះ សូម្បីមិនដទៃអំពីអនិមិត្តមគ្គ ទើបជាសហជាតប្បច្ច័យជាដើមដោយអំណាចនៃអង្គមគ្គនីមួយៗនៃអដ្ឋមគ្គ ៨ ។

បទថា **ទ្វេ វិមោក្ខា** មួយទៀត បានដល់ សុញ្ញតវិមោក្ខនិងអនិមិត្តវិមោក្ខ ។ ពិតណាស់ មគ្គបានឈ្មោះថា អប្បណិហិតវិមោក្ខ ដោយអំណាចដល់ទុក្ខានុបស្សនា រមែងបានឈ្មោះថា អនិមិត្តវិមោក្ខ ដោយគុណរបស់ខ្លួន ព្រោះមិនមានរូបនិមិត្តជាដើម រាគនិមិត្តជាដើម និងនិច្ចនិមិត្តជាដើម និងដោយអារម្មណ៍ ព្រោះធ្វើនិព្វាន ពោលគឺអនិមិត្ត ព្រោះមិនមាននិមិត្តទាំងនោះជាអារម្មណ៍ ។ គប្បីប្រកបបទដ៏សេសដោយន័យដូចពោលហើយនោះឯង ។

បទថា **ទ្វេ វិមោក្ខា** មួយទៀត បានដល់ អនិមិត្តវិមោក្ខនិងអប្បណិហិតវិមោក្ខ ។ ក្នុងបទនេះ ការប្រកបមានន័យដូចពោលហើយនោះឯង ។

[ ២១០ ] បទថា **បដិវេធកាលេ** លោកពោលហើយតាមលំដាប់ដូចបានពោលទុកហើយ ក្នុងវារៈនៃឥន្ទ្រិយទាំងឡាយ ។ ឈ្មោះថា វិមោក្ខក្នុងខណៈនៃវិបស្សនា លះខណៈនៃមគ្គចេញ រមែងមិនមាន ។ តែលោកសម្តែងមគ្គវិមោក្ខ ដែលពោលទុកហើយគ្រាដំបូង ឲ្យវិសេសឡើងដោយពាក្យថា **បដិវេធកាលេ** ។ លោកសង្ខេបវារៈ ២ ថា បុគ្គលណាជាសទ្ធាវិមុត្តនិងវារៈថា **យោ ចាយំ បុគ្គលោ សទ្ធាវិមុត្តោ**[១] ជាដើម និងវារៈថា

---

១-បិដកខ្មែរលេខ ៧០ ទំព័រ ២០០ ។

**អនិច្ចតោ មនសិករោន្តោ សោតាបត្តិមគ្គំ បដិលភតិ**[២] ជាដើម ទុក តែគប្បីប្រកបដោយអំណាចនៃវិមោក្ខ ហើយជ្រាបដោយពិស្តារ ។

[ ២១២-២១៤ ] គប្បីជ្រាបវារៈថា **យេ ហិ កេចិ នេក្ខម្មំ** ជាដើម តាមន័យ ដូចពោលហើយនោះឯង ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា លោកចង្អុលបង្ហាញដល់ការផ្សេងគ្នានៃវិមោក្ខនិងបុគ្គល ។

ព្រះសារីបុត្តត្ថេរ បំណងនឹងចង្អុលបង្ហាញប្រធាននៃវិមោក្ខ និងវិមោក្ខទៀតច្រើនយ៉ាង ទើបពោលពាក្យថា **អនិច្ចតោ មនសិករោន្តោ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **យថាភូតំ** បានដល់ តាមសភាវៈ ។ បទថា **បជានាតិ** បានដល់ ដឹងដោយញាណ ។ បទថា **បស្សតិ** បានដល់ រមែងឃើញដោយញាណនោះៗឯង ដូចឃើញដោយចក្ខុ ។

បទថា **តទន្វយេន** បានដល់ ដោយការប្រព្រឹត្តិទៅតាមសម្មាទស្សនៈនោះ អធិប្បាយថា ទៅតាមសម្មាទស្សនៈនោះ ដែលឃើញហើយ ដោយញាណ ដោយប្រចក្ស ។ បទថា **កង្ខា បហីយតិ** បានដល់ សេចក្តីសង្ស័យថា ទៀង ឬមិនទៀង រមែងលះបានដោយអនិច្ចានុបស្សនា សេចក្តីសង្ស័យក្រៅនេះ រមែងលះបានដោយអនុបស្សនាក្រៅអំពីនេះ ។ បទថា **និមិត្តំ** បានដល់ រមែងដឹងសង្ខារនិមិត្តដែលជាអារម្មណ៍ តាមសេចក្តីពិតព្រោះលះនិច្ចសញ្ញាបានដោយការបែកសន្តិ និងឃនៈ ។ បទថា **តេន វុច្ចតិ សម្មាទស្សនំ** បានដល់ ព្រោះដឹងតាមសេចក្តីពិតនោះ ទើបលោកពោល

---

២-បិដកខ្មែរលេខ ៧០ ឃាប ២០១ ។

ញាណនោះថា សម្មាទស្សនៈ ។ បទថា **បត្តំ** បានដល់ រមែងដឹងការប្រព្រឹត្តទៅដែលជាវិបាក ដែលសន្មតថាសុខតាមសេចក្តីពិត ព្រោះដកនូវការសម្គាល់ក្នុងអាការ ដែលដល់ទុក្ខហើយ ថាជាសុខ ហើយលះតណ្ហាពោលគឺបណិធិ ដោយការលះសេចក្តីសម្គាល់ថាសុខបាន ។ បទថា **និមិត្តញ្ច បវត្តញ្ច** បានដល់ រមែងដឹងសង្ខារនិមិត្ត និងការប្រព្រឹត្តិទៅដែលជាវិបាកតាមសេចក្តីពិត ព្រោះលះអត្តសញ្ញាដោយប្រការទាំងពីរ ដោយការញែកឃនៈដែលរួមគ្នា ដែលកើតអំពីការមនសិការដល់ធាតុផ្សេងៗ ។

ញាណ ៣ មាន **យញ្ច យថាភូតំ ញាណំ** ជាដើម លោកពោលទុកក្នុងបច្ចុប្បន្នប៉ុណ្ណោះ មិនបានពោលដល់ញាណដទៃ ។

[ ២១៥ ] បទថា **ភយតោ ឧបដ្ឋាតិ** បានដល់ និមិត្តនិងការប្រព្រឹត្តិទៅនោះៗ រមែងប្រាកដដោយភាពជារបស់គួរខ្លាចតាមលំដាប់ ព្រោះឃើញការមិនមានការទៀង សេចក្តីសុខនិងអត្តា ។ ដោយបទថា **យា ច ភយតូបដ្ឋានេ បញ្ញា** លោកពោលដល់ញាណ ៣ ដែលមានអត្ថតែមួយដែលផ្សេងគ្នាដោយប្រភេទនៃការកំណត់ ដែលសម្ពន្ធជាមួយភយតូបដ្ឋានញ្ញាណក្នុងវិបស្សនាញាណ ៩ ពោលគឺបដិបទាញាណទស្សនវិសុទ្ធិ ដែលលោកពោលទុកហើយ គឺឧទយព្វយានុបស្សនាញាណ ១ ភង្គានុបស្សនាញាណ ១ ភយតូបដ្ឋានញាណ ១ អាទីនវានុបស្សនាញាណ ១ និព្វិទានុបស្សនាញាណ ១ មុញ្ចិតុកម្យតាញាណ ១ បដិសង្ខានុបស្សនាញាណ ១ សង្ខារុបេក្ខាញាណ ១ អនុលោមញ្ញាណ ១ លោកមិនពោលដល់ញាណដ៏

សេស ។

ដើម្បីសម្តែងភាពដែលសុញ្ញតានុបស្សនានិងអនត្តានុបស្សនា មានអត្ថតែមួយ ដោយសម្ពន្ធជាមួយអនត្តានុបស្សនាដែលជាលំដាប់ ដែលតាំងនៅក្នុងទីបំផុតក្នុងអនុបស្សនា ៣ ទៀត ទើបព្រះសារីបុត្តត្ថេរពោលបទថា **យា ច អនត្តានុបស្សនា យា ច សុញ្ញតានុបស្សនា** ជាដើម ព្រោះថាញាណទាំង ២ នេះ ដោយអត្ថដូចគ្នាតែផ្សេងគ្នាដោយប្រភេទនៃការកំណត់ ។ ញាណទាំង ២ នេះ យ៉ាងណា អនិច្ចានុបស្សនា និងអនិមិត្តានុបស្សនា ដោយអត្ថ ជាញាណដូចគ្នា ទុក្ខានុបស្សនានិងអប្បណិហិតានុបស្សនា ដោយអត្ថ ជាញាណដូចគ្នា ផ្សេងគ្នាដោយប្រភេទនៃការកំណត់ប៉ុណ្ណោះ យ៉ាងនោះ ។ កាលលោកពោលថា អនត្តានុបស្សនានិងសុញ្ញតានុបស្សនា មានអត្ថតែមួយ ឈ្មោះថា លោកពោលដល់ញាណទាំង ២ គូនោះ ថាមានអត្ថតែមួយ ព្រោះមានលក្ខណៈដូចគ្នា ។

[ ២១៦ ] បទថា **និមិត្តំ បដិសង្ខា ញាណំ ឧប្បជ្ជតិ** បានដល់ញាណដឹងដោយអំណាចនៃអនិច្ចលក្ខណៈថា សង្ខារនិមិត្តមិនឋិតថេរ ប្រព្រឹត្តទៅមួយជួរខណៈ រមែងកើតឡើង ។ មិនមែនញាណដឹងមុន ហើយកើតឡើងខាងក្រោយក៏ពិត តែដោយវោហារលោកពោលយ៉ាងនេះ ដូចពាក្យ ( ក្នុងសំយុត្តនិកាយសឡាយតនវគ្គ ) ថា ព្រោះអាស្រ័យចិត្តនិងធម៌ទើបមានោវិញ្ញាណកើតឡើង ជាដើម ។ ម្យ៉ាងទៀត សូម្បីអ្នកដឹងគម្ពីរសព្ទសាស្ត្រ រមែងប្រាថ្នាបទនេះ សូម្បីក្នុងកាលដែលកើតព្រមគ្នា ដូចក្នុងបទ

ថា ការផងនីតរមែងប្រាសទៅ ព្រោះព្រះអាទិត្យរះឡើង ជាដើម ។ ម្យ៉ាង វិញទៀត គប្បីជ្រាបថា លោកពោលយ៉ាងនេះ ព្រោះធ្វើបទដើមនិងបទចុង ឲ្យតែមួយដោយន័យដូចគ្នា ។ ដោយន័យនេះ គប្បីជ្រាបអត្ថក្នុងពីរបទក្រៅ នេះ ។ សេចក្តីដែលញាណ ៣ មានមុញ្ចិតុកម្យតាញាណជាដើម តាំងនៅ ដូចគ្នា មានអត្ថដូចគ្នា មានន័យដូចជាប់ពោលហើយនោះឯង ។

បទថា **និមិត្តា ចិត្តំ វុដ្ឋាតិ** បានដល់ ចិត្តឈ្មោះថា រមែងចេញទៅ ចាកសង្ខារនិមិត្ត ព្រោះមិនជាប់នៅក្នុងសង្ខារនិមិត្តនោះ ដោយឃើញទោស ក្នុងសង្ខារនិមិត្ត ។ បទថា **អនិមិត្តេ ចិត្តំ បក្ខន្ទតិ** បានដល់ ចិត្តរមែងចូល ទៅក្នុងអនិមិត្តនិព្វាន ដោយជាបដិបក្ខចំពោះសង្ខារនិមិត្ត ព្រោះចិត្តបង្អោន ទៅក្នុងនិព្វាននោះ ។ សូម្បីក្នុងអនុបស្សនាទាំងពីរដ៏សេស ក៏គប្បីជ្រាប សេចក្តីដោយន័យនេះ ។

ដោយបទដែលលោកពោលទុក ក្នុងទីនេះថា **និរោធនិព្វានធាតុយា** ឈ្មោះថា លោកពោលដល់អនុបស្សនា ២ ដំបូង ។ បាឋៈថា **និរោធេ** ក៏ មាន ។ បទថា **ពហិទ្ធាវុដ្ឋានវិវដ្ដនេ បញ្ញា** លោកពោលដល់គោត្រភូ- ញាណ ដោយសម្ពន្ធដល់ការចេញ ។ បទថា **គោត្រភូ ធម្មា** បានដល់ គោត្រភូញាណនោះឯង ។ ពិតណាស់ ដោយប្រការដទៃ ភាពដែលញាណ ទាំងពីរមានអត្ថដូចគ្នា រមែងមិនត្រឹមត្រូវ ។ គប្បីជ្រាបថា លោកធ្វើជា ពហុវចនៈដូចក្នុងប្រយោគ ( ក្នុងអភិធម្មធម្មសង្គណិ ) ថា ពួកធម៌ឥត បច្ច័យតាក់តែង ពួកធម៌មិនមានបច្ច័យជាដើម ឬដោយអំណាចនៃមគ្គ ៤ ។

ព្រោះវិមោក្ខក៏គឺមគ្គ និងមគ្គក៏គឺទុកតោវដ្ឋាន ហេតុនោះ ដោយសម្ពន្ធនោះ ទើបលោកពោលពាក្យថា **យា ច ឧភតោវុដ្ឋានវិវដ្ដនេ បញ្ញា** ជាដើម ។

[ ២១៧ ] ព្រះសារីបុត្តត្ថេរ បំណងនឹងសម្ដែងបរិយាយនៃខណៈផ្សេងគ្នា របស់វិមោក្ខទាំងឡាយ ទុកក្នុងខណៈតែមួយទៀត ទើបពោលបទថា **កតិហាការេហិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **អាធិបតេយ្យដ្ឋេន** បានដល់ ដោយភាពជាប្រធាន ។ បទថា **អធិដ្ឋានដ្ឋេន** បានដល់ ដោយការតាំងទុកចំពោះ ។ បទថា **អភិនីហារដ្ឋេន** បានដល់ ដោយការបង្អោនចិត្តទៅដោយវិបស្សនាវិថិ ។ បទថា **និយ្យានដ្ឋេន** បានដល់ ដោយការចូលទៅដល់និព្វាន ។ បទថា **អនិច្ចតោ មនសិការោតោ** បានដល់ ក្នុងខណៈនៃវិបស្សនាដែលជាវុដ្ឋានគាមិនីនោះឯង ។ បទថា **អនិមិត្តោ វិមោក្ខោ** បានដល់ ក្នុងខណៈនៃមគ្គនោះឯង ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។ បទថា **ចិត្តំ អធិដ្ឋាតិ** បានដល់ ធ្វើចិត្តឲ្យក្រៃលែងតាំងមាំទុក អធិប្បាយថា ញុំាងចិត្តឲ្យតាំងមាំ ។ បទថា **ចិត្តំ អភិនីហរតិ** បានដល់ បង្អោនចិត្តទៅដោយវិបស្សនាវិថិ ។

បទថា **និរោធំ និព្វានំ និយ្យាតិ** បានដល់ រមែងចូលដល់និព្វាន ពោលគឺនិរោធ លោកសម្ដែងភាពដែលវិមោក្ខ មានខណៈផ្សេងគ្នា ដោយចំណែក ៤ ដោយការផ្សេងគ្នានៃអាការ ដោយប្រការដូច្នេះ ។

[ ២១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភាពដែលវិមោក្ខ មានក្នុងខណៈតែមួយដូចតទៅនេះថា បទថា **សមោធានដ្ឋេន** បានដល់ ដោយការប្រជុំរួមគ្នា ។

បទថា **អធិគមនដ្ឋេន** បានដល់ ដោយការជួបប្រទះ ។ បទថា **បដិលាភដ្ឋេន** បានដល់ ដោយការសម្រេច ។ បទថា **បដិវេធដ្ឋេន** បានដល់ ដោយការចាក់ធ្លុះដោយញាណ ។ បទថា **សច្ឆិករណដ្ឋេន** បានដល់ ដោយធ្វើឲ្យប្រចក្ស ។ បទថា **ផស្សនដ្ឋេន** បានដល់ ដោយការពាល់ត្រូវដោយញាណសម្ផស្ស ។ បទថា **អភិសមយដ្ឋេន** បានដល់ ដោយការមកដល់ព្រមចំពោះមុខ ។ បណ្ដាបទទាំងនោះ បទថា **សមោធានដ្ឋេន** នេះ ជាមូលបទ បទដ៏សេសជាវេវចនៈនៃការសម្រេច ។ ព្រោះហេតុនោះឯង ទើបលោកធ្វើការឆ្លើយបទទាំងអស់ជាមួយគ្នា ។ បទថា **និមិត្តា មុច្ចតិ** បានដល់ផុតចាកនិមិត្តថា ជាសភាពទៀង ដោយបទនេះ លោកពោលដល់អត្ថ នៃវិមោក្ខ ។ បទថា **យតោ មុច្ចតិ** បានដល់ ផុតចាកនិមិត្តណា ។ បទថា **តត្ថ ន បណិធហតិ** បានដល់ មិនធ្វើសេចក្ដីប្រាថ្នាក្នុងនិមិត្តនោះ ។ បទថា **យត្ថ ន បណិធហតិ** បានដល់ មិនតាំងនៅក្នុងនិមិត្តណា ។ បទថា **តេន សុញ្ញោ** បានដល់ ទទេចាកនិមិត្តនោះ ។ បទថា **យេន សុញ្ញោ** បានដល់ជាអ្នកទទេចាកនិមិត្តណា ដោយបទនេះថា **តេន និមិត្តេន អនិមិត្តោ** លោកពោលដល់ការមិនមាននិមិត្ត ។ បទថា **បណិធិយា មុច្ចតិ** បានដល់ រួចចាកការប្រាថ្នាដែលជាទីតាំង ។ បាឋៈថា **បណិធិ មុច្ចតិ** ក៏មាន ដែលមានអត្ថជាបញ្ចមីវិភត្តិនោះឯង ។ ដោយបទនេះ លោកពោលដល់វិមោក្ខ ។ បទថា **យត្ថ ន បណិធហតិ** បានដល់ មិនតាំងនៅក្នុងទុក្ខណា ។ បទថា **តេន សុញ្ញោ** បានដល់ ទទេចាកទុក្ខនោះ ។ បទថា **យេន សុញ្ញោ** បានដល់

ជាអ្នកទទេចាកទុក្ខនិមិត្តណា ។ បទថា **យេន និមិត្តេន** បានដល់ ព្រោះទុក្ខនិមិត្តណា ។ ដោយបទនេះថា **តត្ថ ច បណិធយាតិ** លោកពោលដល់ការមិនតាំងទុក ។ ដោយបទនេះថា **អភិនិវេសា មុច្ចតិ** លោកពោលដល់វិមោក្ខ ។ បទថា **យេន សុញ្ញោ** បានដល់ ជាអ្នកទទេចាកនិមិត្ត គឺការប្រកាន់មាំណា ។ បទថា **យេន និមិត្តេន** បានដល់ ព្រោះនិមិត្ត គឺការប្រកាន់មាំណា ។ បទថា **យត្ថ ច បណិធយាតិ តេន សុញ្ញោ** បានដល់ មិនតាំងនៅក្នុងនិមិត្ត គឺការប្រកាន់មាំណា ជាអ្នកទទេចាកនិមិត្ត គឺការប្រកាន់មាំនោះ ដោយបទនេះលោកពោលដល់សុញ្ញតៈ ។

[ ២១៩ ] ព្រះសារីបុត្តត្ថេរបំណងនឹងសម្តែងវិមោក្ខ ៨ ជាដើមទៀត ទើបពោលពាក្យថា **អត្ថិ វិមោក្ខោ** ជាដើម ។ ក្នុងបទទាំងនោះ បទមាន **និច្ចតោ អភិនិវេសា** ជាដើម គប្បីជ្រាបដោយន័យ ដែលលោកពោលហើយក្នុងសញ្ញាវិមោក្ខ ។ បទថា **សព្វាភិនិវេសេហិ** បានដល់ ចាកការប្រកាន់មាំ មានប្រការដូចពោលហើយ ដោយប្រការដូច្នេះ វិមោក្ខទាំងនោះឯង ឈ្មោះថា សុញ្ញតវិមោក្ខ ដោយអំណាចនៃការរួចចាកការប្រកាន់មាំ ឈ្មោះថា អនិមិត្តវិមោក្ខ ដោយអំណាចនៃការរួចចាកនិមិត្ត មានភាពទៀងជាដើម ឈ្មោះថា អប្បណិហិតវិមោក្ខ ដោយអំណាចនៃការរួចចាកការប្រាថ្នាដែលជាទីតាំងមានភាពទៀងជាដើម ។

[ ២២១ ]ម្យ៉ាងទៀត ក្នុងបទនេះថា **បណិធិ មុច្ចតិ** គប្បីជ្រាបថា ជាបញ្ចមីវិភត្តិក្នុងទីទាំងពួង ។ បាឋៈថា បណិធិយា មុច្ចតិ ដូច្នេះក៏មាន ។

ដូចក្នុងនិទស្សនៈនេះថា **សព្វបណិធីហិ មុច្ចតិ** ផុតចាកបណិធិទាំងពួង ។ ដោយប្រការដូច្នេះ លោកពោលអនុបស្សនា ៣ យ៉ាងនេះថា វិមោក្ខដោយបរិយាយ ព្រោះជាតទង្គវិមោក្ខ និងព្រោះជាបច្ច័យដល់សមុច្ឆេទវិមោក្ខ ។

[ ២២២-២២៣ ] បទថា **តត្ថ ជាតា** មានពាក្យអធិប្បាយថា កាលវិបស្សនាវិមោក្ខមានក្នុងលំដាប់ បន្ទាប់មកកុសលធម៌ទាំងឡាយ កើតក្នុងមគ្គវិមោក្ខនោះ ព្រោះកថានេះជាអធិការនៃមគ្គវិមោក្ខ ។ បទថា **អនវជ្ជកុសលា** បានដល់ ជាកុសលវៀរចាកទោសមានរាគៈជាដើម ឬបាលីកាត់បទជា **អនវជ្ជា កុសលា** ។ បទថា **ពោធិបក្ខិយា ធម្មា** បានដល់ ពោធិបក្ខិយធម៌ ៣៧ ដែលលោកពោលទុក គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គមានអង្គ ៨ ។ បទថា **ឥទំ មុខំ** នេះ លោកអធិប្បាយថា ធម្មជាតមានប្រការដូចពោលហើយនេះ ឈ្មោះថា ធម៌ជាប្រធាន ព្រោះជាប្រធាននៃការចូលទៅកាន់និព្វានដោយអារម្មណ៍ ។ បទថា **តេសំ ធម្មានំ** បានដល់ នៃពោធិបក្ខិយធម៌ទាំងនោះ ។

បទថា **ឥទំ វិមោក្ខមុខំ** បានដល់ និព្វានជានិស្សរណវិមោក្ខនោះឯងបណ្តាវិក្ខម្ភនវិមោក្ខ តទង្គវិមោក្ខ សមុច្ឆេទវិមោក្ខ បដិបស្សទ្ធិវិមោក្ខ និងនិស្សរណវិមោក្ខ និងនិព្វាន ឈ្មោះថា ជាប្រធាន ដោយអត្ថថា ប្រសើរ ដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មានជាសង្ខតធម៌ក្តី អសង្ខតធម៌ក្តី វិរាគធម៌ ប្រាកដ

ជាប្រសើរជាងពួកធម៌ទាំងនោះ ដូច្នេះ ព្រោះហេតុនោះ ទើបឈ្មោះថា ជាវិមោក្ខផង ជាប្រធានផង ( វិមោក្ខមុខ ) ។ លោកពោលអត្ថនេះ ដោយអំណាចនៃកម្មធារយសមាសថា និព្វាននោះជាវិមោក្ខផង ជាប្រធានផង ទើបឈ្មោះថាជាវិមោក្ខផង ជាប្រធានផង ។ ក្នុងពាក្យថាជាវិមោក្ខផងនេះ លោកធ្វើជាលិង្គវិបល្លាស ។

បទថា **តីណិ អកុសលមូលានិ** បានដល់ រាគៈ ទោសៈ មោហៈ ។ បទថា **តីណិ ទុច្ចរិតានិ** បានដល់ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ។ បទថា **សព្វេបិ អកុសលា ធម្មា** បានដល់ អកុសលធម៌ទាំងអស់ដែលសម្បយុត្តដោយអកុសលមូល ដែលសម្បយុត្តនិងមិនសម្បយុត្ត ដោយទុច្ចរិត វៀរទោមនស្សដែលគួរសេពជាដើម ។ បទថា **កុសលមូលសុចរិតានិ** គប្បីជ្រាបដោយផ្ទុយគ្នានឹងពាក្យដែលពោលហើយ ។

បទថា **សព្វេបិ កុសលា ធម្មា** បានដល់ កុសលធម៌សូម្បីទាំងអស់ដែលជាឧបនិស្សយប្បច្ច័យដល់វិមោក្ខ ដែលសម្បយុត្ត និងមិនសម្បយុត្តតាមន័យដូចពោលហើយ ។ វិវដ្ដកថា ខ្ញុំបាទពោលទុកហើយ តែក្នុងទីនេះពោលដល់វិវដ្ដៈដ៏សេសដោយសម្ពន្ធជាមួយនឹងវិមោក្ខវិវដ្ដៈ ។

[ ២២៤ ] បទថា **អាសេវនា** បានដល់ ការសេពតាំងអំពីខាងដើម ។ បទថា **ភាវនា** បានដល់ ការចម្រើននូវវិមោក្ខនោះឯង ។ បទថា **ពហុលីកម្មំ** បានដល់ ការធ្វើវិមោក្ខនោះឯងរឿយៗដើម្បីសម្រេចវសី ( ភាពជំនាញ ) ។ម៉្យាងទៀត គប្បីជ្រាបការសេពជាដើម ដោយអំណាចញុំាង

កិច្ចឲ្យសម្រេចក្នុងខណៈតែមួយនៃមគ្គនោះឯង ។ បទថា **បដិលាភោ វា វិធាកោ វា** ជាដើម មានអត្ថដូចពោលទុកហើយ ក្នុងខាងដើមនោះឯង ដោយប្រការដូច្នេះ។

អដ្ឋកថា វិមោក្ខនិទ្ទេស ចប់

អដ្ឋកថា វិមោក្ខកថា ចប់

# សុត្តន្តបិដក

## មហាវគ្គ គតិកថា

[ ២២៥ ] ការកើតឡើងនៃគតិសម្បត្តិ ក្នុងញាណសម្បយុត្ត តើព្រោះបច្ច័យនៃហេតុប៉ុន្មាន ការកើតឡើងនៃពួកខត្តិយមហាសាល ព្រាហ្មណមហាសាល គហបតិមហាសាល កាមាវចរទេវតា ក្នុងញាណសម្បយុត្ត តើព្រោះបច្ច័យនៃហេតុប៉ុន្មាន ការកើតឡើងនៃពួករូបាវចរទេវតា តើព្រោះបច្ច័យនៃហេតុប៉ុន្មាន ការកើតឡើងនៃពួកអរូបាវចរទេវតា តើព្រោះបច្ច័យនៃហេតុប៉ុន្មាន ។ ការកើតឡើងនៃគតិសម្បត្តិ ក្នុងញាណសម្បយុត្ត ព្រោះបច្ច័យនៃហេតុ ៨ ការកើតឡើងនៃពួកខត្តិយមហាសាល ព្រាហ្មណមហាសាល គហបតិមហាសាល កាមាវចរទេវតាក្នុងញាណសម្បយុត្ត ព្រោះបច្ច័យនៃហេតុ ៨ ការកើតឡើងនៃពួករូបាវចរទេវតា ព្រោះបច្ច័យនៃហេតុ ៨ ការកើតឡើងនៃពួកអរូបាវចរទេវតា ព្រោះបច្ច័យនៃហេតុ ៨ ។

[ ២២៦ ] ការកើតឡើងនៃគតិសម្បត្តិ ក្នុងញាណសម្បយុត្ត ព្រោះបច្ច័យនៃហេតុ ៨ តើដូចម្តេចខ្លះ ។ ក្នុងខណៈជវននៃកុសលកម្មមានហេតុជាកុសល ៣ ជាសហជាតប្បច្ច័យនៃចេតនាដែលកើតហើយក្នុងខណៈនោះ ហេតុនោះ លោកពោលថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះមានកុសលមូលជាបច្ច័យខ្លះ ក្នុងខណៈនៃសេចក្តីត្រេកអរមានហេតុជាអកុសល ២ ជាសហជាតប្បច្ច័យនៃចេតនាដែលកើតហើយក្នុងខណៈនោះ ហេតុនោះ លោកពោលថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះមានអកុសលមូល

ជាបច្ច័យខ្វះ ក្នុងខណៈបដិសន្ធិ មានហេតុជាអព្យាក្រឹត ៣ ជាសហជាតប្បច្ច័យនៃចេតនា ដែលកើតហើយក្នុងខណៈនោះ ហេតុនោះលោកពោលជា វិញ្ញាណ ( កើតមាន ) ព្រោះមាននាមរូប ជាបច្ច័យខ្វះ នាមរូប ( កើតមាន ) ព្រោះមានវិញ្ញាណជាបច្ច័យខ្វះ ក្នុងខណៈនៃបដិសន្ធិ មានខន្ធ ៥ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានមហាភូតរូប ៤ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានជីវិតសង្ខារ ៣ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មាននាមនិងរូប ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានធម៌ ១៤ នេះ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានខន្ធដែលមិនមានរូប ៤ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានឥន្ទ្រិយ ៥ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានហេតុ ៣ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មាននាមនិងវិញ្ញាណ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈ

នៃបដិសន្ធិ មានធម៌ ១៤ នេះ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានធម៌ទាំង ២៨ នេះ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ នេះឯងការកើតឡើងនៃគតិសម្បត្តិក្នុងញាណសម្បយុត្ត ព្រោះបច្ច័យនៃហេតុទាំង ៨ យ៉ាង ។

[ ២២៧ ] ការកើតឡើងនៃពួកខត្តិយមហាសាល ព្រាហ្មណមហាសាល គហបតិមហាសាល កាមាវចរទេវតាក្នុងញាណសម្បយុត្ត ព្រោះបច្ច័យនៃហេតុ ៨ តើដូចម្តេច ។ ក្នុងខណៈជវននៃកុសលកម្ម មានហេតុជាកុសល ៣ ជាសហជាតប្បច្ច័យនៃចេតនាដែលកើតហើយក្នុងខណៈនោះ ហេតុនោះ លោកពោលថា សង្ខារទាំងឡាយកើតមាន ព្រោះមានកុសលមូលជាបច្ច័យខ្លះ ក្នុងខណៈនៃសេចក្តីត្រេកអរ មានហេតុជាអកុសល ២ ជាសហជាតប្បច្ច័យនៃចេតនា ដែលកើតហើយក្នុងខណៈនោះ ហេតុនោះ លោកពោលថា សង្ខារទាំងឡាយ កើតមាន ព្រោះមានអកុសលមូលជាបច្ច័យខ្លះ ក្នុងខណៈនៃបដិសន្ធិ មានហេតុជាអព្យាក្រឹត ៣ ជាសហជាតប្បច្ច័យនៃចេតនា ដែលកើតហើយក្នុងខណៈនោះ ហេតុនោះលោកពោលថា វិញ្ញាណ ( កើតមាន ) ព្រោះមាននាមរូប ជាបច្ច័យខ្លះ នាមរូប ( កើតមាន ) ព្រោះមានវិញ្ញាណជាបច្ច័យខ្លះ ក្នុងខណៈនៃបដិសន្ធិ មានខន្ធទាំង ៥ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានមហាភូតរូប ៤ ជាសហជា-

តប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានជីវិតសង្ខារ ៣ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្ស-យប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មាននាមនិងរូប ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្ត-ប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានធម៌ទាំង ១៤ នេះ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានខន្ធមិនមានរូប ៤ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានឥន្ទ្រិយ ៥ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានហេតុ ៣ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមាននាមនិងវិញ្ញាណ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានធម៌ទាំង ១៤ នេះ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានធម៌ទាំង ២៨ នេះ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្ត-ប្បច្ច័យ នេះឯងការកើតឡើងនៃពួកខត្តិយមហាសាល ព្រាហ្មណមហា-សាល គហបតិមហាសាល កាមាវចរទេវតាក្នុងញាណសម្បយុត្ត ព្រោះបច្ច័យនៃហេតុទាំង ៨ យ៉ាង ។

[ ២២៨ ] ការកើតឡើងនៃពួករូបាវចរទេវតា ព្រោះបច្ច័យនៃហេតុ ៨ តើដូចម្តេចខ្លះ ។ ក្នុងខណៈជវនៃកុសលកម្ម មានហេតុជាកុសល ៣ ។បេ។ នេះឯងការកើតឡើងនៃពួករូបាវចរទេវតា ព្រោះបច្ច័យនៃហេតុទាំង ៨ យ៉ាង ។

ការកើតឡើងនៃពួកអរូបាវចរទេវតា ព្រោះបច្ច័យនៃហេតុ ៨ តើដូចម្តេចខ្លះ ។ ក្នុងខណៈជវនៃកុសលកម្ម មានហេតុជាកុសល ៣ ជាសហជាតប្បច្ច័យនៃចេតនាដែលកើតហើយ ក្នុងខណៈនោះ ហេតុនោះលោកពោលថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះមានកុសលមូល ជាបច្ច័យខ្លះ ក្នុងខណៈនៃសេចក្តីត្រេកអរ មានហេតុជាអកុសល ២ ជាសហជាតប្បច្ច័យនៃចេតនាដែលកើតហើយក្នុងខណៈនោះ ហេតុនោះលោកពោលថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះមានអកុសលមូល ជាបច្ច័យខ្លះ ក្នុងខណៈនៃបដិសន្ធិ មានហេតុជាអព្យាក្រឹត ៣ ជាសហជាតប្បច្ច័យនៃចេតនាដែលកើតហើយក្នុងខណៈនោះ ហេតុនោះលោកពោលថា វិញ្ញាណ ( កើតមាន ) ព្រោះមាននាមរូបជាបច្ច័យខ្លះ នាមរូប ( កើតមាន ) ព្រោះមានវិញ្ញាណជាបច្ច័យខ្លះ ក្នុងខណៈនៃបដិសន្ធិ មានខន្ធមិនមានរូប ៤ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានឥន្ទ្រិយ ៥ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យក្នុងខណៈនៃបដិសន្ធិ មានហេតុ ៣ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ

ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មាននាម និងវិញ្ញាណ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានធម៌ទាំង ១៤ នេះ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្ត-ប្បច្ច័យ នេះឯងការកើតឡើងនៃពួកអរូបាវចរទេវតា ព្រោះបច្ច័យនៃហេតុ ៨ ។

[ ២២៩ ] ការកើតឡើងនៃគតិសម្បត្តិក្នុងញាណវិប្បយុត្ត តើព្រោះបច្ច័យនៃហេតុប៉ុន្មាន ការកើតឡើងនៃពួកខត្តិយមហាសាល ព្រាហ្មណ-មហាសាល គហបតិមហាសាល កាមាវចរទេវតា ក្នុងញាណវិប្បយុត្ត ព្រោះបច្ច័យនៃហេតុប៉ុន្មាន ។ ការកើតឡើងនៃគតិសម្បត្តិ នៃញាណវិប្បយុត្ត ព្រោះបច្ច័យនៃហេតុ ៦ ការកើតឡើងនៃពួកខត្តិយមហាសាល ព្រាហ្មណ-មហាសាល គហបតិមហាសាល កាមាវចរទេវតា ក្នុងញាណវិប្បយុត្ត ព្រោះបច្ច័យនៃហេតុ ៦ ។

[ ២៣០ ] ការកើតឡើងនៃគតិសម្បត្តិ ក្នុងញាណវិប្បយុត្ត ព្រោះបច្ច័យនៃហេតុ ៦ តើដូចម្តេច ។ ក្នុងខណៈជវនៃកុសលកម្ម មានហេតុជាកុសល ២ ជាសហជាតប្បច្ច័យនៃចេតនាដែលកើតហើយក្នុងខណៈនោះ ហេតុនោះ លោកពោលថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះមានកុសលមូលជាបច្ច័យខ្លះ ក្នុងខណៈនៃសេចក្តីត្រេកអរមានហេតុជាអកុសល ២ ជាសហជាតប្បច្ច័យនៃចេតនាដែលកើតហើយក្នុងខណៈនោះ ហេតុនោះ

លោកពោលថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះមានអកុសលមូលជាបច្ច័យខ្លះ ក្នុងខណៈនៃបដិសន្ធិ មានហេតុជាអព្យាក្រឹត ២ ជាសហជាតប្បច្ច័យនៃចេតនាដែលកើតហើយក្នុងខណៈនោះ ហេតុនោះ លោកពោលថា វិញ្ញាណ ( កើតមាន ) ព្រោះមាននាមរូបជាបច្ច័យខ្លះ នាមរូប ( កើតមាន ) ព្រោះមានវិញ្ញាណជាបច្ច័យខ្លះ ក្នុងខណៈនៃបដិសន្ធិ មានខន្ធ ៥ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានមហាភូតរូប ៤ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានជីវិតសង្ខារ ៣ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមាននាមនិងរូប ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានធម៌ទាំង ១៤ នេះ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិ មានខន្ធមិនមានរូប ៤ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានឥន្ទ្រិយ ៤ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានហេតុ ២ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមាននាមនិងវិញ្ញាណ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ

ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានធម៌ទាំង ១២ នេះ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាសម្បយុត្តប្បច្ច័យ ក្នុងខណៈនៃបដិសន្ធិមានធម៌ ២៦ នេះ ជាសហជាតប្បច្ច័យ ជាអញ្ញមញ្ញប្បច្ច័យ ជានិស្សយប្បច្ច័យ ជាវិប្បយុត្តប្បច្ច័យ នេះឯងការកើតឡើងនៃគតិសម្បត្តិក្នុងញាណវិប្បយុត្តព្រោះបច្ច័យនៃហេតុ ៦ ។ ការកើតឡើងនៃពួកខត្តិយមហាសាល ព្រាហ្មណមហាសាល គហបតិមហាសាល កាមាវចរទេវតា ក្នុងញាណវិប្បយុត្ត ព្រោះបច្ច័យនៃហេតុ ៦ តើដូចម្ដេច ។ ក្នុងខណៈជវននៃកុសលកម្ម មានហេតុជាកុសល ២ ជាសហជាតប្បច្ច័យនៃចេតនាដែលកើតហើយ ក្នុងខណៈនោះ ហេតុនោះលោកពោលថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះមានកុសលមូល ជាបច្ច័យខ្លះ ។បេ។ នេះឯងការកើតឡើងនៃពួកខត្តិយមហាសាល ព្រាហ្មណមហាសាល គហបតិមហាសាល កាមាវចរទេវតា ក្នុងញាណវិប្បយុត្ត ព្រោះបច្ច័យនៃហេតុ ៦ ។

**ចប់ គតិកថា**

# អដ្ឋកថា

## គតិកថា

[ ២២៥ ] ឥឡូវនេះជាការពណ៌នាសេចក្ដីតាមលំដាប់ ដែលមិនធ្លាប់ពណ៌នានៃគតិកថា ដែលព្រះសារីបុត្តត្រេរសម្ដែងដល់ហេតុសម្បត្តិ ដែលជាហេតុនៃការកើតវិមោក្ខនោះ ពោលទុកហើយ ។ សូម្បីឈានក៏មិនកើតឡើង ដល់អ្នកជាទុហេតុកបដិសន្ធិ ព្រោះព្រះបាលី ( ក្នុងធម្មបទ ) ថា **ឧត្ថិ ឈានំ អបញ្ញស្ស** ការពិនិត្យ ( ឈាន ) មិនមានដល់បុគ្គលអ្នកមិនមានប្រាជ្ញា តើវិមោក្ខនឹងកើតបានដូចម្ដេច ។

ក្នុងបទទាំងនោះ បទថា **គតិសម្បត្តិយា** បានដល់ គតិសម្បត្តិដែលបានដល់មនុស្សនិងទេវតា បណ្ដាគតិ ៥ គឺនរក កំណើតតិរច្ឆាន បិត្តិវិស័យ មនុស្ស និងទេវតា ។ ដោយបទនេះ លោកបដិសេធគតិវិបត្តិ ៣ ខាងដើម ។ សម្បត្តិនៃគតិឈ្មោះថា គតិសម្បត្តិ អធិប្បាយថា សុគតិ ។ ម្យ៉ាងទៀត ខន្ធទាំងឡាយមួយអន្លើដោយឱកាស ឈ្មោះថា គតិ ។ ក្នុងគតិទាំង ៥ លោកកាន់យក សូម្បីអសុរកាយដោយសព្ទថា បិត្តិវិស័យ ។

កាមាវចរទេវតា ៦ ជាន់ និងព្រហ្មទាំងឡាយ ឈ្មោះថា **ទេវា** ។ សូម្បីពួកអសុរ លោកក៏សង្គ្រោះដោយសព្ទថា **ទេវ** ( នេះ ) ។ បទថា **ញាណសម្បយុត្តេ** បានដល់ ក្នុងខណៈបដិសន្ធិ ដែលសម្បយុត្តដោយញាណ ។ ពិតណាស់ សូម្បីខណៈក៏គប្បីជ្រាបថា លោកពោលដោយវោហារនោះឯង ព្រោះប្រកបកម្មដែលសម្បយុត្តដោយញាណ ។ បទថា

**កតីនំ ហេតូនំ** បានដល់ នៃហេតុប៉ុន្មានបណ្តាអលោភហេតុ អទោស-ហេតុ អមោហហេតុ ។ បទថា **ឧបបត្តិ** បានដល់ ការកើត អធិប្បាយថា ការកើតឡើង ។

មយ៉ាងទៀត ព្រោះសូម្បីកើតក្នុងត្រកូលសូទ្រៈ ក៏ជា**តិហេតុកៈ**បាន ហេតុនោះពាក្យសួរដំបូង ទើបសំដៅដល់តិហេតុកៈសត្វទាំងនោះ និងព្រោះ បុគ្គលមានបុណ្យច្រើន ដោយច្រើនកើតក្នុងត្រកូលមហាសាល ៣ ត្រកូល ហេតុនោះទើបពាក្យសួរមាន ៣ យ៉ាង ដោយអំណាចនៃត្រកូល ៣ ទាំង នោះ តែលោកសង្ខេបពាក្យទុក ។

ឈ្មោះថា **មហាសាលា** ព្រោះមានសម្បត្តិច្រើន អធិប្បាយថា មាន ផ្ទះធំ មានទ្រព្យសម្បត្តិច្រើន ។ មយ៉ាងវិញទៀត គួរពោលថា **មហាសារា** ព្រោះមានវត្ថុដែលជាសារៈច្រើន លោកពោលថា **មហាសាលា** ព្រោះ ផ្លាស់ រ អក្ខរៈជា ល អក្ខរៈ ។ ឈ្មោះថា **ខត្តិយមហាសាលា** ព្រោះ ជាក្សត្រមហាសាល ឬមហាសាលក្នុងក្សត្រ ។ សូម្បីក្នុងបទដ៏សេស ក៏ មានន័យនេះដូចគ្នា ។ ក្នុងជននោះ ក្សត្រណារក្សាទ្រព្យយ៉ាងតិច ១០០ កោដិទុកក្នុងព្រះរាជវាំង ទ្រង់ប្រើប្រាស់ចាយវាយកហាបណៈ ១ ថ្ងៃ ២០ អម្ពណៈ ក្សត្រអង្គនេះ ឈ្មោះថា ខត្តិយមហាសាល ។ ព្រាហ្មណ៍ណា រក្សាទ្រព្យយ៉ាងតិច ៨០ កោដិ ទុកក្នុងផ្ទះ ប្រើប្រាស់ចាយវាយកហាបណៈ ១ ថ្ងៃ ១០ អម្ពណៈ ព្រាហ្មណ៍នេះឈ្មោះថា ព្រាហ្មណមហាសាល ។ គហបតីណា រក្សាទ្រព្យយ៉ាងតិច ៤០ កោដិ ទុកក្នុងផ្ទះ ប្រើប្រាស់ចាយ

វាយកហាបណៈ ១ ថ្ងៃ ៥ អម្ពណៈ គហបតីនេះឈ្មោះថា គហបតិមហាសាល ។

ទេវតាជាន់រូបាវចរនិងទេវតាជាន់អរូបាវចរ ជា**តិហេតុកៈ**ដោយចំណែកមួយ ទើបលោកមិនពោលថា **ញាណសម្បយុត្តេ** ។ តែក្នុងមនុស្សនិងទេវតាទាំងឡាយដ៏សេស ព្រោះមានទុហេតុកៈនិងអហេតុកៈ ក្នុងមនុស្សទាំងឡាយ និងព្រោះមានទុហេតុកៈក្នុងទេវតាជាន់កាមាវចរទាំងឡាយ ទើបលោកពោល **ញាណសម្បយុត្តេ** ។ ក្នុងទេវតាទាំងនេះ កាមាវចរទេវតាទាំងឡាយ ឈ្មោះថា **ទេវា** ព្រោះត្រេកត្រអាល ដោយការត្រេកអរក្នុងកាមគុណ ៥ និងរុងរឿងដោយរស្មីនៃរាងកាយ ។ រូបាវចរព្រហ្មទាំងឡាយ ឈ្មោះថា **ទេវា** ព្រោះត្រេកត្រអាលដោយការត្រេកអរក្នុងឈាន និងរុងរឿងដោយរស្មីនៃរាងកាយ ។ អរូបាវចរព្រហ្មទាំងឡាយ ឈ្មោះថា **ទេវា** ព្រោះត្រេកត្រអាល ដោយការត្រេកអរក្នុងឈាន និងរុងរឿងដោយការរុងរឿងនៃញាណ ។

[ ២២៦ ] បទថា **កុសលកម្មស្ស ជវនក្ខណេ** បានដល់ ក្នុងខណៈនៃជវនចិត្ត ៧ វារៈនៃកម្មដែលឲ្យតិហេតុកៈបដិសន្ធិ កើតក្នុងភពនេះអំពីអតីតជាតិ និងនៃកម្មដែលជាកាមាវចរកុសលតិហេតុកៈ ដោយអំណាចកើតឡើងរឿយៗក្នុងជវនវីថិចិត្ត អធិប្បាយថា ក្នុងបវត្តិកាល ។ បទថា **តយោ ហេតូ កុសលា** បានដល់ អលោភៈ អទោសៈ អមោហៈ ជាកុសលហេតុ ។ បទថា **តស្មិំ ខណេ ជាតចេតនាយ** បានដល់ នៃកុសល

ចេតនា ដែលកើតក្នុងខណៈដូចពោលហើយនោះឯង ។ បទថា **សហ–ជាតប្បច្ចយា ហោន្តិ** បានដល់ កាលកើត រមែងជាឧបការៈដោយការកើតរួមគ្នា ។ បទថា **តេន វុច្ចតិ** បានដល់ ពោលដោយភាពជាស–ហជាតប្បច្ច័យនោះឯង ។ បទថា **កុសលមូលប្បច្ចយាបិ សង្ខារា** លោកពោលដោយន័យរបស់បច្ចយាការ ដែលប្រព្រឹត្តទៅ ក្នុងខណៈចិត្តមួយ ។ ម្យ៉ាងទៀត គប្បីជ្រាបថា លោកសង្គ្រោះចេតសិកទាំងអស់ដែលសង្គ្រោះដោយសង្ខារក្ខន្ធក្នុងបទនោះ ដោយពហុវចនៈថា **សង្ខារា** ។ ដោយ **អបិ** សព្ទ មានពាក្យអធិប្បាយថា ព្រោះសង្ខារជាបច្ច័យក៏មានកុសលមូល ។ បទថា **និកន្តិក្ខណោ** បានដល់ ក្នុងខណៈនៃការពេញចិត្តនៃសង្ខារ ដែលកើតឡើងក្នុងកម្ម ដែលប្រាកដចំពោះមុខ ដើម្បីឲ្យវិបាករបស់ខ្លួន ឬក្នុងកម្មនិមិត្ត ឬក្នុងគតិនិមិត្តដែលកម្មដែលប្រាកដចំពោះមុខ ឲ្យប្រាកដហើយយ៉ាងនោះ ។ បទថា **និកន្តិ** បានដល់ ការពេញចិត្ត ការប្រាថ្នា ។ ពិតណាស់ ព្រោះបុគ្គលជិតនឹងស្លាប់ មានចិត្តជ្រួលច្របល់ដោយមោហៈ ការពេញចិត្តរមែងកើតឡើង សូម្បីក្នុងអណ្ដាតភ្លើងនៃអវីចិមហានរក នឹងពោលទៅថ្វីក្នុងនិមិត្តដ៏សេស ។ បទថា **ទ្វេ ហេតូ** បានដល់ លោភៈមោហៈជាអកុសលហេតុ ។ ចំណែកការពេញចិត្តក្នុងភពប្រារព្ធខន្ធសន្តានរបស់ខ្លួន ដែលត្រឹមតែចេញទៅ ចាកភវង្គវីថិ ដែលប្រព្រឹត្តទៅហើយក្នុងលំដាប់នៃបដិសន្ធិ រមែងកើតឡើង សូម្បីដល់សង្ខារទាំងពួង ។ ពាក្យ ( ក្នុងអភិធម្មយមកៈ ) យ៉ាងនេះថា ម្យ៉ាងទៀត ពួកអកុសលធម៌របស់

បុគ្គលណា មិនកើតឡើងហើយក្នុងទីណា ពួកកុសលធម៌របស់បុគ្គលនោះ មិនកើតឡើងហើយក្នុងទីនោះឬ ។ អើ ។ លោកពោលសំដៅដល់ពាក្យនោះឯង ។

បទថា **តស្មឹ ខណេ ជាតចេតនាយ** បានដល់ អកុសលចេតនា ។ បទថា **បដិសន្ធិក្ខណេ** បានដល់ ក្នុងខណៈនៃបដិសន្ធិដែលកម្មនោះ ឲ្យផល ។ បទថា **តយោ ហេតូ** បានដល់ អលោភៈ អទោសៈ អមោហៈ ជាអព្យាកតហេតុ ។ បទថា **តស្មឹ ខណេ ជាតចេតនាយ** បានដល់ អព្យាកតចេតនា ដែលជាវិបាក ។ ក្នុងបទនេះថា **នាមរូបប្បច្ចយាបិ វិញ្ញាណំ** អធិប្បាយថា ក្នុងខណៈនៃបដិសន្ធិនោះ វិបាកហេតុ ៣ និងចេតសិកដ៏សេសជានាម ហទយវត្ថុជារូប ព្រោះនាមរូបជាបច្ច័យនោះ បដិសន្ធិវិញ្ញាណរមែងប្រព្រឹត្តទៅ ។ នាមក្នុងបទថា **វិញ្ញាណប្បច្ចយាបិ នាមរូបំ** មានប្រការដូចបានពោលហើយ ចំណែករូបក្នុងបទនេះ បានដល់រូប ៣០ គឺវត្ថុទសកៈ កាយទសកៈ ភាវទសកៈរបស់សត្វដែលនៅក្នុងផ្ទៃ ព្រោះលោកបំណងយកសហេតុកបដិសន្ធិរបស់មនុស្ស ម្យ៉ាងទៀត បានដល់ រូប ៧០ គឺចក្ខុទសកៈ សោតទសកៈ ឃានទសកៈ ជិវ្ហាទសកៈ ( និងរូប ៣០ ខាងដើម ) របស់សត្វសំសេទជៈ និងរបស់ឱបបាតិកៈ ដែលមានអាយតនៈគ្រប់គ្រាន់ នាមរូបមានប្រការដូចពោលហើយនោះ រមែងប្រព្រឹត្តទៅ ព្រោះបដិសន្ធិវិញ្ញាណជាបច្ច័យក្នុងខណៈបដិសន្ធិ ។

ក្នុងបទនេះថា **បញ្ចក្ខន្ធា** បានដល់ រូបដែលបានក្នុងខណៈបដិសន្ធិ

ដោយបដិសន្ធិចិត្តជារូបក្ខន្ធ វេទនាដែលកើតរួមគ្នាជាវេទនាខន្ធ សញ្ញាជាសញ្ញាខន្ធ ចេតសិកដ៏សេសជាសង្ខារក្ខន្ធ បដិសន្ធិចិត្តជាវិញ្ញាណក្ខន្ធ ។ បទថា **សហជាតប្បច្ចយា ហោន្តិ** បានដល់ អរូបខន្ធ ៤ ជាសហជាតប្បច្ច័យនៃគ្នានឹងគ្នា មហាភូតរូប ៤ ក្នុងរូបក្ខន្ធ ជាសហជាតប្បច្ច័យនៃគ្នានឹងគ្នា អរូបខន្ធនិងហទយរូប ជាសហជាតប្បច្ច័យនៃគ្នានឹងគ្នា សូម្បីមហាភូតរូប ក៏ជាសហជាតប្បច្ច័យនៃឧបាទារូប ។ បទថា **អញ្ញមញ្ញប្បច្ចយា ហោន្តិ** បានដល់ បញ្ចក្ខន្ធជាឧបការៈដល់គ្នានឹងគ្នា ដោយការកើតឡើងនិងឧបត្ថម្ភ អរូបខន្ធ ៤ ជាអញ្ញមញ្ញប្បច្ច័យ មហាភូតរូប ៤ ក៏ជាអញ្ញមញ្ញប្បច្ច័យ ។ បទថា **និស្សយប្បច្ចយា ហោន្តិ** បានដល់ បញ្ចក្ខន្ធជាឧបការៈដោយអាការតាំងមាំទុក និងដោយអាការជាទីអាស្រ័យអរូបខន្ធ ៤ ជានិស្សយប្បច្ច័យនៃគ្នានឹងគ្នា ព្រោះហេតុនោះគប្បីឲ្យពិស្តារដូចសហជាតប្បច្ច័យ ។ បទថា **វិប្បយុត្តប្បច្ចយា ហោន្តិ** បានដល់ បញ្ចក្ខន្ធជាឧបការៈដោយភាពជាវិប្បយុត្តប្បច្ច័យ ដោយការមិនចូលដល់ភាវៈ មានវត្ថុតែមួយជាមួយគ្នាជាដើម អរូបខន្ធជាវិប្បយុត្តប្បច្ច័យនៃបដិសន្ធិរូប ហទយរូបជាវិប្បយុត្តប្បច្ច័យនៃអរូបខន្ធ ក្នុងទីនេះ បទថា **បញ្ចក្ខន្ធា** លោកពោលដោយអំណាចតាមដែលមានបានដោយប្រការដូច្នេះ ។

ក្នុងបទថា **ចត្តារោ មហាភូតា** នេះ លោកពោលដល់បច្ច័យ ៣ មុន ។ បទថា **តយោ ជីវិតសង្ខារា** បានដល់ អាយុឧស្មានិងវិញ្ញាណ ។ បទថា **អាយុ** បានដល់ រូបជីវិតិន្ទ្រិយនិងអរូបជីវិតិន្ទ្រិយ ។ បទថា **ឧស្មា**

បានដល់ តេជោធាតុ ។ បទថា **វិញ្ញាណំ** បានដល់ បដិសន្ធិវិញ្ញាណ ។ ពិតណាស់ ឈ្មោះថា ជីវិតសង្ខារ ព្រោះអាយុ ឧស្មានិងវិញ្ញាណទាំងនេះ រមែងតាក់តែងជីវិតសង្ខារ គឺឲ្យប្រព្រឹត្តទៅក្រៃលែងឡើងៗ ។

បទថា **សហជាតប្បច្ចយា ហោន្តិ** គប្បីជ្រាបថា អរូបជីវិតិន្ទ្រិយ និងបដិសន្ធិវិញ្ញាណ ជាអញ្ញមញ្ញប្បច្ច័យនិងសហជាតប្បច្ច័យ ដល់ខន្ធដែលសម្បយុត្តគ្នានឹងហទយរូប តេជោធាតុ ជាអញ្ញមញ្ញប្បច្ច័យនិងសហ-ជាតប្បច្ច័យដល់មហាភូតរូប ៣ ទាំងជាសហជាតប្បច្ច័យ ដល់ឧបាទារូប រូបជីវិតិន្ទ្រិយ ជាសហជាតប្បច្ច័យដោយបរិយាយដល់សហជាតរូប ។

បទថា **អញ្ញមញ្ញប្បច្ចយា ហោន្តិ និស្សយប្បច្ចយា ហោន្តិ** បានដល់ អរូបជីវិតិន្ទ្រិយនិងបដិសន្ធិវិញ្ញាណទាំង ២ ជាអញ្ញមញ្ញប្បច្ច័យដល់ខន្ធដែលសម្បយុត្តគ្នា ។ គប្បីជ្រាបដោយប្រកបតាមន័យដែលលោកពោលទុកថា **អញ្ញមញ្ញនិស្សយប្បច្ចយា ហោន្តិ** ។

បទថា **វិប្បយុត្តប្បច្ចយា ហោន្តិ** បានដល់ អរូបជីវិតិន្ទ្រិយនិងបដិ-សន្ធិវិញ្ញាណ រមែងជាវិប្បយុត្តប្បច្ច័យដល់បដិសន្ធិរូប ។ ចំណែករូបជីវិ-តិន្ទ្រិយមិនសមគួរក្នុងភាពជាអញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យនិងវិប្បយុត្ត-ប្បច្ច័យ ព្រោះហេតុនោះ ទើបលោកពោលដោយអំណាច តាមដែលមានបានថា **តយោ ជីវិតសង្ខារា** ដូច្នេះ ។ គប្បីប្រកបនាមនិងរូបក្នុងភាពជាបច្ច័យ ៤ ដោយន័យដូចពោលហើយនោះឯង ។

បទថា **ចុទ្ទស ធម្មា** បានដល់ ធម៌ ១៤ ប្រការ ដោយការរាប់

យ៉ាងនេះ គឺខន្ធ ៥ មហាភូតរូប ៤ ជីវិតសង្ខារ ៣ នាម ១ រូប ១ ។ ភាពជាបច្ច័យ មានសហជាតប្បច្ច័យជាដើមនៃធម៌ទាំងនោះ និងធម៌ដទៃខាងមុខ មានន័យដូចពោលហើយ ។ បទថា **សម្បយុត្តប្បច្ចយា ហោន្តិ** បានដល់ ជាឧបការៈទៀតដោយសម្បយុត្តគ្នា ពោលគឺមានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា កើតព្រមគ្នា រលត់ព្រមគ្នា ។ បទថា **បញ្ចិន្ទ្រិយា** បានដល់ សទ្ធិន្ទ្រិយជាដើម ។ បទថា **នាមញ្ច** ក្នុងទីនេះបានដល់ ខន្ធ ៣ មានវេទនាខន្ធជាដើម ។ បទថា **វិញ្ញាណញ្ច** បានដល់ បដិសន្ធិវិញ្ញាណ ។ បទថា **ចុទ្ទស ធម្មា** បានដល់ ធម៌ ១៤ ប្រការទៀត ដោយរាប់យ៉ាងនេះ គឺខន្ធ ៤ ឥន្ទ្រិយ ៥ ហេតុ ៣ នាម ១ វិញ្ញាណ ១ ។

បទថា **អដ្ឋវីសតិ ធម្មា** បានដល់ ធម៌ ២៨ ប្រការ គឺធម៌ខាងដើម ១៤ និងធម៌ទាំងនេះ ១៤ ព្រោះសូម្បីរូបក៏រាប់ចូលទៅក្នុងធម៌នេះ ទើបលោកនាំសម្បយុត្តប្បច្ច័យចេញ ហើយពោលដល់វិប្បយុត្តប្បច្ច័យ ។

ព្រះសារីបុត្តត្ថេរ កាលសម្ដែងដល់ប្រភេទនៃបច្ច័យនោះៗនៃធម៌ ដែលកើតឡើងព្រោះបច្ច័យនោះៗ ដែលមាននៅក្នុងបដិសន្ធិយ៉ាងនេះហើយ កាលនឹងសម្ដែងសរុបហេតុ ដែលបង្ហាញទុកពីខាងដើម ទើបពោលថា **ឥមេសំ អដ្ឋន្នំ ហេតូនំ បច្ចយា ឧប្បត្តិ ហោតិ** ដូច្នេះ ។ ហេតុ ៨ ប្រការនេះ

គឺកុសលហេតុ ៣ ក្នុងខណៈប្រមូលកម្មមក អកុសលហេតុ ២ ក្នុង ខណៈការពេញចិត្ត អព្យាកតហេតុ ៣ ក្នុងខណៈបដិសន្ធិ ។ ក្នុងហេតុទាំងនោះ កុសលហេតុ ៣ និងអកុសលហេតុ ២ ជាឧបនិស្សយប្បច្ច័យ ដល់ការប្រព្រឹត្តិទៅក្នុងខណៈបដិសន្ធិក្នុងលោកនេះ អព្យាកតហេតុ ៣ ជាបច្ច័យដោយអំណាចហេតុប្បច្ច័យ និងសហជាតប្បច្ច័យតាមសមគួរ ។ សូម្បីក្នុងវារៈដ៏សេសក៏មានន័យនេះដូចគ្នា ។

[ ២២៨ ] មុ៉្យាងទៀត ព្រោះអរូបាវចរមិនមានរូបទើបលោកពោលថា ព្រោះនាមជាបច្ច័យក៏មានវិញ្ញាណ ព្រោះវិញ្ញាណជាបច្ច័យ ក៏មាននាម ។ ធម៌ ១៤ ប្រការ ដែលលាយឡំជាមួយរូបក៏អន្តរធានទៅ ព្រោះធម៌ ១៤ ប្រការ ដែលលាយឡំដោយរូបនោះអន្តរធានទៅ ទើបវារៈថា ធម៌ ២៨ ប្រការមិនមាន ។

[ ២២៩ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលសម្តែងតិហេតុកបដិសន្ធិដែលជាបច្ច័យនៃវិមោក្ខហើយ ប្រាថ្នានឹងសម្តែងទុហេតុកបដិសន្ធិឲ្យវិសេសដោយសម្ពន្ធគ្នានោះ ទើបពោលពាក្យថា **គតិសម្បត្តិយា ញាណវិប្ប-យុត្តេ** ដូច្នេះ ។

[ ២៣០ ] បទថា **កុសលកម្មស្ស ជវនក្ខណេ** បានដល់ ក្នុងខណៈជវនចិត្តនៃកុសលកម្មដែលជាទុហេតុកៈ ដែលឲ្យបដិសន្ធិកើតក្នុងភពនេះអំពីអតីតជាតិ តាមន័យដូចពោលហើយនោះឯង ។ បទថា **ទ្វេ ហេតូ** បានដល់ អលោភៈ អទោសៈ ជាកុសលហេតុ ព្រោះមិនប្រកបដោយញាណ ។ សូម្បីអព្យាកតហេតុក៏មាន ២ គឺអលោភៈ អទោសៈ ដូចគ្នា ។ បទថា **ចត្តារិ ឥន្ទ្រិយានិ** បានដល់ ឥន្ទ្រិយ ៤ មានសទ្ធិន្ទ្រិយជាដើម វៀរបញ្ញិន្ទ្រិយ ។ បទថា **ទ្វាទស ធម្មា** បានដល់ ធម៌ ១២ ប្រការ ព្រោះបញ្ញិន្ទ្រិយនិងអមោហៈហេតុវៀរចេញទៅ ព្រោះធម៌ ២ ប្រការនោះវៀរចេញ ទើបជាធម៌ ២៦ ។

បទថា **ឆន្នំ ហេតូនំ** បានដល់ នៃហេតុ ៦ ប្រការយ៉ាងនេះ គឺកុសលហេតុ ២ អកុសលហេតុ ២ វិបាកហេតុ ២ ។ តែក្នុងទីនេះមិនកាន់យករូបាវចរនិងអរូបាវចរ ព្រោះជា**តិហេតុកៈ** ដោយចំណែកមួយ ។ គប្បីជ្រាបបទដ៏សេស ដោយន័យដូចពោលហើយ ក្នុងបឋមវារៈនោះឯង ។ ក្នុងវារៈនេះមានពាក្យអធិប្បាយថា បដិសន្ធិដែលជាទុហេតុកៈ រមែងមិនមានដោយកម្មដែលជា**តិហេតុកៈ** ព្រោះកម្មដែលជាទុហេតុកៈ លោកពោលទុកសម្រាប់បដិសន្ធិដែលជាទុហេតុកៈប៉ុណ្ណោះ ។

*ព្រោះហេតុនោះ ក្នុងវាទៈរបស់ព្រះមហាធម្មរក្ខិតត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ពាក្យណាដែលពោលទុក ក្នុងអដ្ឋកថាធម្មសង្គហៈថា បដិសន្ធិដោយតិហេតុកកម្ម ជា**តិហេតុកៈ**ប៉ុណ្ណោះ មិនជាទុហេតុកៈនិងអហេតុកៈ បដិសន្ធិដោយទុហេតុកកម្ម ជាទុហេតុកៈនិងអហេតុកៈ មិនជា**តិហេតុកៈ** ពាក្យនោះសមនឹងបាលីនេះ ។ ចំណែកក្នុងវាទៈរបស់ព្រះចូឡនាគត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក និងព្រះមហាទត្តត្ថេរ អ្នកនៅក្នុងមោរវាបី ពាក្យណាលោកពោលទុកថា បដិសន្ធិជា**តិហេតុកកម្ម** ជា**តិហេតុកៈ**ខ្លះ ជាទុហេតុកៈខ្លះ មិនជាអហេតុកៈ បដិសន្ធិដោយទុហេតុកកម្ម ជាទុហេតុកៈខ្លះ ជាអហេតុកៈខ្លះ មិនជា**តិហេតុកៈ** ពាក្យនោះប្រាកដជាឃ្លៀងឃ្លាត នឹងក្លាត់ទៅចាកបាលីនេះ ព្រោះកថានេះពោលដោយអធិការនៃហេតុទើបមិនពោលដល់អហេតុកៈបដិសន្ធិ ។*

**អដ្ឋកថា គតិកថា ចប់**

# សុត្តន្តបិដក

## មហាវគ្គ កម្មកថា

[ ២៣១ ] កម្មមានរួចហើយ វិបាក ( ផល ) របស់កម្មមានរួចហើយ កម្មមានរួចហើយ ( តែ ) វិបាករបស់កម្មមិនទាន់មានហើយ កម្មមានរួចហើយ វិបាករបស់កម្មកំពុងមាន កម្មមានរួចហើយ វិបាករបស់កម្មមិន មាន កម្មមានរួចហើយ វិបាករបស់កម្មនឹងមាន កម្មមានរួចហើយ វិបាករបស់កម្មនឹងមិនមាន កម្មកំពុងមាន វិបាករបស់កម្មក៏កំពុងមាន កម្មកំពុងមាន វិបាករបស់កម្មមិនមាន កម្មកំពុងមាន វិបាករបស់កម្មនឹងមាន កម្មកំពុងមាន វិបាករបស់កម្មនឹងមិនមាន កម្មនឹងមាន វិបាករបស់កម្មនឹងមាន កម្មនឹងមាន វិបាករបស់កម្មនឹងមិនមាន កម្មជាកុសលមានរួចហើយ វិបាករបស់កម្មជាកុសលមានរួចហើយ កម្មជាកុសលមានរួចហើយ វិបាករបស់កម្មជាកុសល មិនទាន់មាន កម្មជាកុសលមានរួចហើយ វិបាករបស់កម្មជាកុសលកំពុងមាន កម្មជាកុសលមានរួចហើយ វិបាករបស់កម្មជាកុសលមិនមាន កម្មជាកុសលមានរួចហើយ វិបាករបស់កម្មជាកុសលនឹងមាន កម្មជាកុសលមានរួចហើយ វិបាករបស់កម្មជាកុសលនឹងមិនមាន កម្មជាកុសលកំពុងមាន វិបាករបស់កម្មជាកុសលកំពុងមាន កម្មជាកុសលកំពុងមាន វិបាករបស់កម្មជាកុសលមិនមាន កម្មជាកុសលកំពុងមាន វិបាករបស់កម្មជាកុសលនឹងមាន កម្មជាកុសលកំពុងមាន វិបាករបស់កម្មជាកុសលនឹងមិនមាន កម្មជាកុសលនឹងមាន វិបាករបស់កម្មជាកុសលនឹងមាន កម្មជាកុសលនឹងមាន វិបាករបស់កម្មជា

កុសលនឹងមិនមាន កម្មជាអកុសលមានរួចហើយ វិបាករបស់កម្មជាអកុ-សលមិនទាន់មានហើយ កម្មជាអកុសលមានរួចហើយ វិបាករបស់កម្មជាអកុសលកំពុងមាន កម្មជាអកុសលមានរួចហើយ វិបាករបស់កម្មជាអកុ-សលកំពុងមាន កម្មជាអកុសលមានរួចហើយ វិបាករបស់កម្មជាអកុសលនឹងមាន កម្មជាអកុសលមានរួចហើយ វិបាករបស់កម្មជាអកុសលនឹងមិនមាន កម្មជាអកុសលកំពុងមាន វិបាករបស់កម្មជាអកុសលកំពុងមាន កម្មជាអកុសលកំពុងមាន វិបាករបស់កម្មជាអកុសលមិនមាន កម្មជាអកុសលកំពុងមាន វិបាករបស់កម្មជាអកុសលនឹងមាន កម្មជាអកុសលនឹងមាន វិបាករបស់កម្មជាអកុសលនឹងមាន កម្មជាអកុសលនឹងមាន វិបាករបស់កម្មជាអកុសលនឹងមិនមាន ។

[ ២៣២ ] កម្មប្រកបដោយទោសមានរួចហើយ ។បេ។ កម្មមិនមានទោសមានរួចហើយ ។បេ។ កម្មខ្មៅមានរួចហើយ ។បេ។ កម្មសមានរួចហើយ ។បេ។ កម្មចម្រើនដោយសុខមានរួចហើយ ។បេ។ កម្មចម្រើនដោយទុក្ខមានរួចហើយ ។បេ។ កម្មមានសុខជាវិបាកមានរួចហើយ ។បេ។ កម្មមានទុក្ខជាវិបាកមានរួចហើយ វិបាករបស់កម្មមានទុក្ខជាវិបាកមានរួចហើយ កម្មមានទុក្ខ ជាវិបាកមានរួចហើយ វិបាករបស់កម្មមានទុក្ខជាវិបាកមិនទាន់មានហើយ កម្មមានទុក្ខជាវិបាកមានរួចហើយ វិបាករបស់កម្មមានទុក្ខជាវិបាកកំពុងមាន កម្មមានទុក្ខជាវិបាកមានរួចហើយ វិបាករបស់កម្មមានទុក្ខជាវិបាកមិនមាន កម្មមានទុក្ខជាវិបាកមានរួចហើយ វិបាករបស់កម្មមានទុក្ខ

ជាវិបាកនឹងមាន កម្មមានទុក្ខជាវិបាកមានរួចហើយ វិបាករបស់កម្មមានទុក្ខ ជាវិបាកនឹងមិនមាន កម្មមានទុក្ខជាវិបាកកំពុងមាន វិបាករបស់កម្មមានទុក្ខ ជាវិបាកកំពុងមាន កម្មមានទុក្ខជាវិបាកកំពុងមាន វិបាករបស់កម្មមានទុក្ខ ជាវិបាកមិនមាន កម្មមានទុក្ខជាវិបាកកំពុងមាន វិបាករបស់កម្មមានទុក្ខជា វិបាកនឹងមាន កម្មមានទុក្ខជាវិបាកកំពុងមាន វិបាករបស់កម្មមានទុក្ខជាវិបាក នឹងមិនមាន កម្មមានទុក្ខជាវិបាកនឹងមាន វិបាករបស់កម្មមានទុក្ខជាវិបាកនឹង មាន កម្មមានទុក្ខជាវិបាកនឹងមាន វិបាករបស់កម្មមានទុក្ខជាវិបាកនឹងមិនមាន ។

## ចប់ កម្មកថា

## អដ្ឋកថា

## កម្មកថា

[ ២៣១ ] ឥឡូវនេះ ជាការពណ៌នាអត្ថតាមលំដាប់ ដែលមិនធ្លាប់ពណ៌នាក្នុងកម្មកថា ដែលព្រះសារីបុត្តត្ថេរ សម្តែងដល់កម្មដែលជាបច្ច័យនៃហេតុសម្បត្តិនោះ ពោលទុកហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងកម្មកថានោះដូចតទៅនេះថា ក្នុងបទថា **អហោសិ កម្មំ អហោសិ កម្មវិបាកោ** លោកកាន់យកវិបាកដែលឲ្យផល ក្នុងភពអតីតនៃកម្មដែលធ្វើហើយក្នុងភពអតីតនោះឯង ហើយពោលថា កម្មមានរួចហើយ វិបាក ( ផល ) របស់កម្មមានរួចហើយដូច្នេះ ។

លោកកាន់យកវិបាក ដែលមិនឲ្យផលក្នុងភពអតីតនោះឯង ព្រោះការខ្វះខាតនៃបច្ច័យនៃអតីតកម្ម ដែលជាទិដ្ឋធម្មវេទនីយកម្ម និងជាឧបបជ្ជវេទ-នីយកម្មនោះៗឯង និងវិបាកដែលមិនឲ្យផលនៃកម្ម ដែលជាទិដ្ឋធម្មវេទនី-យកម្ម ឧបបជ្ជវេទនីយកម្ម និងអបរាបរិយវេទនីយកម្ម របស់បុគ្គលដែលបរិនិព្វានហើយក្នុងអតីតនោះឯង ទើបពោលថា កម្មមានរួចហើយ ( តែ ) វិបាករបស់កម្មមិនទាន់មានហើយ ។

លោកកាន់យកវិបាកដែលឲ្យផល ព្រោះការដល់ព្រមនៃបច្ច័យ ក្នុងភពបច្ចុប្បន្ននៃអតីតកម្មនោះឯង ដែលមានវិបាកមិនទាន់ឲ្យផលហើយ ទើបពោលថា កម្មមានរួចហើយ វិបាករបស់កម្មកំពុងមាន ។

លោកកាន់យកវិបាក ដែលមិនឲ្យផលនៃអតីតកម្មនោះឯង ដែលហួស

កាលឲ្យផលហើយ និងនៃកម្មរបស់បុគ្គលដែលបរិនិព្វានក្នុងបច្ចុប្បន្នភព ទើបពោលថា កម្មមានរួចហើយ វិបាករបស់កម្មមិនមាន ។

លោកកាន់យកវិបាកដែលគួរឲ្យផល ព្រោះការដល់ព្រមនៃបច្ច័យ ក្នុងអនាគតភពនៃអតីតកម្មនោះឯង ដែលគួរឲ្យផល តែមិនទាន់បានឲ្យផល ទើបពោលថា កម្មមានរួចហើយ វិបាករបស់កម្មនឹងមាន ។

លោកកាន់យកវិបាកដែលមិនគួរឲ្យផលនៃអតីតកម្មនោះឯង ដែលកន្លងពេលឲ្យផលហើយ និងនៃកម្មរបស់បុគ្គលដែលបរិនិព្វានក្នុងអនាគតភព ទើបពោលថា កម្មមានរួចហើយ វិបាករបស់កម្មនឹងមិនមាន ។

ដោយប្រការដូច្នេះលោកសម្តែងអតីតកម្មទុក ៦ យ៉ាង ដោយអំណាចឲ្យផលនិងមិនឲ្យផល ក្នុងអតីត បច្ចុប្បន្ន និងអនាគត ។

លោកកាន់យកវិបាក ដែលឲ្យផលក្នុងបច្ចុប្បន្ននេះនោះឯង នៃទិដ្ឋធម្មវេទនីយកម្មដែលធ្វើហើយក្នុងបច្ចុប្បន្នភព ទើបពោលថា កម្មកំពុងមាន វិបាករបស់កម្មក៏កំពុងមាន ។

លោកកាន់យកវិបាកដែលមិនឲ្យផល ក្នុងភពនេះ ព្រោះការខ្វះខាតនៃបច្ច័យនៃបច្ចុប្បន្នកម្មនោះៗឯង និងមិនឲ្យផលក្នុងភពនេះ របស់បុគ្គលដែលបរិនិព្វានក្នុងបច្ចុប្បន្នទើបពោលថា កម្មកំពុងមាន វិបាករបស់កម្មមិនមាន ។

លោកកាន់យកវិបាក ដែលគួរឲ្យផល ក្នុងអនាគតភពនៃកម្មបច្ចុប្បន្នដែលជាឧបបជ្ជវេទនីយកម្ម និងអបរាបរិយវេទនីយកម្ម ទើបពោលថា កម្មកំពុងមាន វិបាករបស់កម្មនឹងមាន ។

លោកកាន់យកវិបាកដែលមិនគួរឲ្យផល ក្នុងអនាគតកព្រោះការខ្វះខាតនៃបច្ច័យនៃបច្ចុប្បន្នកម្ម ដែលជាឧបបជ្ជវេទនីយកម្ម និងដែលមិនគួរឲ្យផលនៃអបរាបរិយវេទនីយកម្ម របស់បុគ្គលដែលគួរបរិនិព្វាន ក្នុងអនាគតកពថា កម្មកំពុងមាន វិបាករបស់កម្មនឹងមិនមាន ។

ដោយប្រការដូច្នេះ លោកសម្តែងបច្ចុប្បន្នកម្មទុក ៤ យ៉ាង ដោយអំណាចឲ្យផល និងមិនឲ្យផល ក្នុងបច្ចុប្បន្ននិងអនាគត ។

លោកកាន់យកវិបាកដែលគួរឲ្យផល ក្នុងអនាគតកព នៃកម្មដែលគួរធ្វើក្នុងអនាគតកព ទើបពោលថា កម្មនឹងមាន វិបាករបស់កម្មនឹងមាន ។

លោកកាន់យកវិបាកដែលមិនគួរឲ្យផល ព្រោះការខ្វះខាតនៃបច្ច័យ និងដែលមិនគួរឲ្យផល របស់បុគ្គលគួរបរិនិព្វាន ក្នុងអនាគតកពនៃអនាគតកម្មនោះៗឯង ទើបពោលថា កម្មនឹងមាន វិបាករបស់កម្មនឹងមិនមាន ។

ដោយប្រការដូច្នេះ លោកសម្តែងអនាគតកម្មទុក ២ យ៉ាង ដោយអំណាចឲ្យផល និងមិនឲ្យផល ក្នុងអនាគត ។

លោកធ្វើកម្មទាំងអស់នោះរួមជាមួយគ្នាហើយសម្តែងកម្ម ១២ យ៉ាង ។ លោកតាំងនៅក្នុងឋានៈនេះ ហើយនាំកម្មចតុក្កៈ ៣ មកពោល ។ ពិតណាស់ កាលពោលកម្មចតុក្កៈនោះហើយ សេចក្តីនេះនឹងប្រាកដច្បាស់ជាង ។ កម្មមាន ៤ យ៉ាង គឺទិដ្ឋធម្មវេទនីយកម្ម ១ ឧបបជ្ជវេទនីយកម្ម ១ អបរាបរិយវេទនីយកម្ម ១ អហោសិកម្ម ១ ។

ក្នុងកម្មទាំងនោះ ជវនចេតនាទី ១ ជាកុសលក្តី ជាអកុសលក្តីក្នុងចិត្ត

៧ ដួង ក្នុងជវនវីថិចិត្តទី ១ ឈ្មោះថា ទិដ្ឋធម្មវេទនីយកម្ម ។ ទិដ្ឋធម្មវេទនីយកម្មនោះ រមែងឲ្យផលក្នុងអត្តភាពនេះប៉ុណ្ណោះ តែកាលមិនអាចឲ្យផលយ៉ាងនោះ ក៏ជាអហោសិកម្មដោយអំណាចតិកៈថា កម្មមានរួចហើយ ( តែ ) វិបាករបស់កម្មមិនទាន់មានហើយ វិបាករបស់កម្មនឹងមិនមាន វិបាករបស់កម្មមិនមាន ដូច្នេះ ។

ចំណែកជវនចេតនាដួងទី ៧ ដែលឲ្យសម្រេចផល ឈ្មោះថា ឧបបជ្ជវេទនីយកម្ម ។

ឧបបជ្ជវេទនីយកម្មនោះ រមែងឲ្យផលក្នុងអត្តភាពបន្ទាប់ទៅ កាលមិនអាចឲ្យផលយ៉ាងនោះបាន ក៏ជាអហោសិកម្ម តាមន័យដូចពោលហើយនោះឯង ។ ម្យ៉ាងទៀត ជវនចេតនា ៥ ដួង ក្នុងចន្លោះចេតនាទាំងពីរនោះ ឈ្មោះថា អបរាបរិយវេទនីយកម្ម ។ អបរាបរិយវេទនីយកម្មនោះ រមែងបានឱកាសកាលណាក្នុងអនាគត រមែងឲ្យផលក្នុងកាលនោះ កាលនៅមានការវិលវល់នៅក្នុងសង្សារ ឈ្មោះថាអហោសិកម្មមិនមាន ។

កម្ម ៤ យ៉ាងដទៃទៀត គឺជាគរុកម្ម ១ ពហុលកម្ម ១ អាសន្នកម្ម ១ កដត្តាកម្ម ១ ។ ក្នុងកម្មទាំងនោះ ទោះជាកុសលក្តី អកុសលក្តីក្នុងកម្មធ្ងន់និងស្រាល កម្មណាធ្ងន់មានសម្លាប់មាតាជាដើម ឬមហគ្គតកម្ម ( កម្មកើតពីការបានឈាន ) កម្មនោះឯងឲ្យផលមុន ។ ម្យ៉ាងទៀត ក្នុងកម្មដែលធ្វើច្រើននិងមិនធ្វើច្រើន កម្មណាធ្វើច្រើន មានភាពជាអ្នកមានសីលក្តី ជាអ្នកទ្រុស្តសីលក្តី កម្មនោះរមែងឲ្យផលមុន ។ កម្មដែលរឭកដល់ក្តី កម្មដែល

ធ្វើហើយក្តីក្នុងវេលាជិតស្លាប់ ឈ្មោះថា អាសន្នកម្ម ។ ពិតណាស់ អ្នកជិតនឹងស្លាប់ អាចរឭកដល់ ឬធ្វើកម្មណា រមែងកើតឡើងដោយកម្មនោះឯងការបានអាសេវនៈរឿយៗ ផុតចាកកម្ម ៣ ទាំងនេះ ឈ្មោះថា កដត្តាកម្ម ។ ក្នុងកាលមិនមានកម្មទាំង ៣ នោះ កដត្តាកម្មនោះ រមែងឲ្យបដិសន្ធិ ។

កម្ម ៤ យ៉ាងដទៃទៀត គឺជនកកម្ម ( កម្មតាក់តែងឲ្យកើត ) ឧបត្ថម្ភកកម្ម ( កម្មឧបត្ថម្ភ ) ឧបបីឡកកម្ម ( កម្មបៀតបៀន ) ឧបឃាតកកម្ម ( កម្មកាត់ផ្តាច់ ) ។ ក្នុងកម្ម ៤ យ៉ាងនោះ ឈ្មោះថា ជនកកម្មជាកុសលក៏បាន ជាអកុសលក៏បាន ។ ជនកកម្មនោះ រមែងធ្វើរូបវិបាកនិងអរូបវិបាកឲ្យកើតក្នុងបដិសន្ធិកាល សូម្បីក្នុងបវត្តិកាល ។

ចំណែកឧបត្ថម្ភកកម្ម មិនអាចឲ្យវិបាកកើតបាន រមែងឧបត្ថម្ភសុខនិងទុក្ខដែលកើតឡើង ក្នុងវិបាកដែលកើតហើយដោយបដិសន្ធិដែលកម្មដទៃឲ្យរមែងឲ្យប្រព្រឹត្តទៅអស់កាលយូរ ។

ឧបបីឡកកម្ម រមែងបៀតបៀន បៀតបៀនសុខនិងទុក្ខដែលកើតក្នុងវិបាកដែលកើតហើយដោយបដិសន្ធិដែលកម្មដទៃឲ្យ រមែងមិនឲ្យប្រព្រឹត្តទៅអស់កាលយូរបាន ។

ចំណែកឧបឃាតកកម្ម ជាកុសលក៏បាន ជាអកុសលក៏បាន កាត់ផ្តាច់កម្មដែលមានកម្លាំងខ្សោយដទៃ ហើយហាមវិបាករបស់កម្មនោះ ធ្វើឱកាសដល់វិបាករបស់ខ្លួន កាលឱកាសដែលកម្មនោះធ្វើហើយ លោកពោលថាវិបាកនោះកើតឡើងហើយ ។

ដោយប្រការដូច្នេះ សេចក្ដីវិសេសនៃកម្ម និងសេចក្ដីវិសេសនៃវិបាករបស់កម្ម ១២ យ៉ាងនេះ រមែងប្រាកដច្បាស់ដល់កម្មវិបាកញ្ញាណ របស់ព្រះពុទ្ធទាំងឡាយ ដោយសភាវៈតាមសេចក្ដីពិត មិនទូទៅដល់សាវកទាំងឡាយ ។ ចំណែកអ្នកវិបស្សនា គប្បីដឹងភាពវិសេសនៃកម្មនិងភាពវិសេសនៃវិបាកបានដោយចំណែកខ្លះ ព្រោះហេតុនោះ ទើបលោកប្រកាសសេចក្ដីវិសេសនៃកម្មនេះ ដោយសម្ដែងត្រឹមតែជាមាតិកា ។ លោកពោលបឋមវារៈ ដោយអំណាចកម្មសុទ្ធៗយ៉ាងនេះ ហើយចែកកម្មនោះឯងចេញជា ២ ចំណែក ហើយទើបពោលវារៈ ១០ ដទៃទៀតដោយបរិយាយ ១០ ដោយអំណាចជាគូនៃកុសលកម្ម និងអកុសលកម្មជាដើម ។

ក្នុងបទទាំងនោះ ឈ្មោះថា កុសល ព្រោះអត្ថថា មិនមានរោគ ឈ្មោះថា អកុសល ព្រោះអត្ថថា មិនមែនមិនមានរោគ លោកពោលទុកៈនេះដោយអំណាចនៃជាតិ ។

[ ២៣២ ] អកុសលនោះឯង ឈ្មោះថា ប្រកបដោយទោស ព្រោះប្រកបដោយទោស មានរាគៈជាដើម កុសល ឈ្មោះថា មិនមានទោស ព្រោះមិនមានទោស មានរាគៈជាដើមនោះ ។ អកុសល ឈ្មោះថា កម្មខ្មៅ ព្រោះមិនបរិសុទ្ធិ ឬព្រោះជាហេតុកើតធម៌ខ្មៅ ។ កុសល ឈ្មោះថា កម្មស ព្រោះបរិសុទ្ធិ ឬព្រោះជាហេតុកើតធម៌ស កុសល ឈ្មោះថា កម្មចម្រើនដោយសុខ ព្រោះចម្រើនដោយសេចក្ដីសុខ អកុសល ឈ្មោះថា កម្មចម្រើនដោយទុក្ខ ព្រោះចម្រើនដោយទុក្ខ ។ កុសល ឈ្មោះថា កម្មមាន

សុខជាវិបាក ព្រោះមានផលជាសុខ ។ អកុសល ឈ្មោះថា កម្មមានទុក្ខជាវិបាក ព្រោះមានផលជាទុក្ខ ព្រោះហេតុនោះ គប្បីជ្រាបអាការផ្សេងៗនៃកម្មទាំងនោះ ដោយប្រការដូច្នេះឯង ។

## អដ្ឋកថា កម្មកថា ចប់

# សុត្តន្តបិដក

## មហាវគ្គ វិបល្លាសកថា

## បរិបុណ្ណនិទាន

[ ២៣៣ ] ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ( សេចក្តីសម្គាល់ខុស ) ចិត្តវិបល្លាស ( គំនិតខុស ) ទិដ្ឋិវិបល្លាស ( ការយល់ខុស ) នេះ មាន ៤ យ៉ាង ចុះវិបល្លាស ៤ យ៉ាង តើដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស ទិដ្ឋិវិបល្លាស ថាទៀងក្នុងវត្ថុមិនទៀង ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស ទិដ្ឋិវិបល្លាស ថាជាសុខក្នុងវត្ថុជាទុក្ខ ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស ទិដ្ឋិវិបល្លាស ថាខ្លួនក្នុងវត្ថុមិនមែនខ្លួន ១ ម្នាលភិក្ខុទាំងឡាយ សញ្ញាវិបល្លាស ចិត្តវិបល្លាស ទិដ្ឋិវិបល្លាស ថាល្អក្នុងវត្ថុមិនល្អ ១ ម្នាលភិក្ខុទាំងឡាយ នេះឯងសញ្ញាវិបល្លាស ចិត្តវិបល្លាស ទិដ្ឋិវិបល្លាស ៤ យ៉ាង ។

[ ២៣៤ ] ម្នាលភិក្ខុទាំងឡាយ មិនមែនសញ្ញាវិបល្លាស មិនមែនចិត្តវិបល្លាស មិនមែនទិដ្ឋិវិបល្លាស នេះមាន ៤ យ៉ាង ចុះ ៤ យ៉ាង តើដូចម្តេចខ្លះ ម្នាលភិក្ខុទាំងឡាយ មិនមែនសញ្ញាវិបល្លាស មិនមែនចិត្តវិបល្លាស មិនមែនទិដ្ឋិវិបល្លាស ថាមិនទៀង ក្នុងវត្ថុមិនទៀង ១ ម្នាលភិក្ខុទាំងឡាយ មិនមែនសញ្ញាវិបល្លាស មិនមែនចិត្តវិបល្លាស មិនមែនទិដ្ឋិវិបល្លាស ថាជាទុក្ខក្នុងវត្ថុជាទុក្ខ ១ ម្នាលភិក្ខុទាំងឡាយ មិនមែនសញ្ញាវិបល្លាស មិនមែនចិត្តវិបល្លាស មិនមែនទិដ្ឋិវិបល្លាស ថាមិនមែនខ្លួនក្នុង

វត្ថុមិនមែនខ្លួន ១ ម្នាលភិក្ខុទាំងឡាយ មិនមែនសញ្ញាវិបល្លាស មិនមែន ចិត្តវិបល្លាស មិនមែនទិដ្ឋិវិបល្លាស ថាមិនស្អាតក្នុងវត្ថុមិនស្អាត ១ ម្នាល ភិក្ខុទាំងឡាយ នេះឯងមិនមែនសញ្ញាវិបល្លាស មិនមែនចិត្តវិបល្លាស មិន មែនទិដ្ឋិវិបល្លាស ៤ យ៉ាង ។ សត្វទាំងឡាយ មានសេចក្តីសម្គាល់ថាទៀង ក្នុងវត្ថុដែលមិនទៀងផង មានសេចក្តីសម្គាល់ ថាសុខក្នុងវត្ថុដែលជាទុក្ខផង មានសេចក្តីសម្គាល់ ថាខ្លួនក្នុងវត្ថុដែលមិនមែនខ្លួនផង មានសេចក្តីសម្គាល់ ថាល្អក្នុងវត្ថុដែលមិនល្អផង ត្រូវមិច្ឆាទិដ្ឋិកម្ចាត់បង់ហើយ មានចិត្តក្រឡកមាន សេចក្តីសម្គាល់ខុស សត្វទាំងនោះ ឈ្មោះថា ប្រកបខ្លួនក្នុងកិលេសជា គ្រឿងប្រកបរបស់មារ មិនក្សេមក្សាន្តចាកយោគធម៌ឡើយ តែងដល់នូវជាតិ និងមរណៈ រមែងអន្ទោលទៅកាន់សង្សារ លុះកាលណាព្រះពុទ្ធទាំងឡាយ ព្រះអង្គធ្វើនូវរស្មី ទ្រង់ត្រាស់ឡើងក្នុងលោក ព្រះអង្គទ្រង់ប្រកាសធម៌នេះ ជាធម៌ញុំាងសត្វឲ្យដល់នូវឋានស្ងប់ទុក្ខ សត្វទាំងនោះ ប្រកបដោយប្រាជ្ញា បានស្តាប់ធម៌របស់ព្រះពុទ្ធទាំងឡាយនោះ ទើបបានចំពោះនូវចិត្តរបស់ខ្លួន គឺបានឃើញនូវវត្ថុមិនទៀង ថាមិនទៀង បានឃើញនូវវត្ថុជាទុក្ខ ថាជាទុក្ខ បានឃើញនូវវត្ថុមិនមែនខ្លួន ថាមិនមែនខ្លួន បានឃើញនូវវត្ថុមិនល្អ ថាមិន ល្អ ជាអ្នកប្រកាន់ត្រូវដោយសម្មាទិដ្ឋិ បានកន្លងនូវទុក្ខទាំងពួង ។

វិបល្លាសទាំង ៤ នេះ បុគ្គលអ្នកបរិបូរណ៍ដោយទិដ្ឋិ លះបង់បានខ្លះ លះបង់មិនបានខ្លះ គឺវិបល្លាសខ្លះលោកលះបង់បាន វិបល្លាសខ្លះលោកលះ បង់មិនបាន សញ្ញាវិបល្លាស ចិត្តវិបល្លាស ទិដ្ឋិវិបល្លាស ថាទៀងក្នុង

វត្ថុដែលមិនទៀង លោកលះបង់ហើយ តែសញ្ញានៅកើត ចិត្តនៅកើត ថាជាសុខក្នុងវត្ថុជាទុក្ខ លោកលះបង់បានត្រឹមតែទិដ្ឋិវិបល្លាសទេ សញ្ញាវិប-ល្លាស ចិត្តវិបល្លាស ទិដ្ឋិវិបល្លាស ថាជាខ្លួន ក្នុងវត្ថុដែលមិនមែនខ្លួន លោកលះបង់ហើយ តែសញ្ញានៅកើត ចិត្តនៅកើត ថាល្អក្នុងវត្ថុដែលមិនល្អ លះបង់បានតែទិដ្ឋិវិបល្លាសទេ ( គឺថា ) វិបល្លាស ៦ ក្នុងវត្ថុ ២ លោកលះបង់ហើយ វិបល្លាស ២ ក្នុងវត្ថុ ២ លោកលះបង់ហើយ ត្រង់វិបល្លាស ៤ លះមិនបានទេ គឺវិបល្លាស ៨ ក្នុងវត្ថុ ៤ លោកលះបានវិបល្លាស ៤ លះមិនបានទេ ។

**ចប់ វិបល្លាសកថា ។**

# អដ្ឋកថា

# វិបល្លាសកថា

[ ២៣៣-២៣៤ ] ឥឡូវនេះ ជាការពណ៌នាតាមលំដាប់សេចក្តី ដែលមិនធ្លាប់ពណ៌នាក្នុងវិបល្លាសកថា ដែលមានព្រះសូត្រជាបទផ្តើម ដែលព្រះសារីបុត្តត្ថេរសម្តែងទុកក្នុងវិបល្លាស ដែលជាបច្ច័យនៃកម្មនោះ ពោលទុកហើយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រមុន ។ បទថា **សញ្ញាវិបល្លាសា** បានដល់ មានការសម្គាល់ឃ្លៀងឃ្លាត ជាសភាវៈ អធិប្បាយថា មានសញ្ញាវិបរិត ។ សូម្បីក្នុងពីរបទដ៏សេសក៏មានន័យនេះដូចគ្នា ។ សញ្ញា-វិបល្លាស រមែងប្រព្រឹត្តទៅក្នុងកាលដែលជាកិច្ចរបស់ខ្លួននៃអកុសលបញ្ញាដែលប្រាសចាកទិដ្ឋិមានកម្លាំង ក្នុងទីដែលកិច្ចរបស់ចិត្តខ្សោយកម្លាំង ។

ចិត្តវិបល្លាស រមែងប្រព្រឹត្តទៅក្នុងកាលនៃកិច្ចរបស់ខ្លួននៃអកុសលចិត្តដែលប្រាសចាកទិដ្ឋិមានកម្លាំង ។

ទិដ្ឋិវិបល្លាស រមែងប្រព្រឹត្តទៅក្នុងចិត្តដែលសម្បយុត្តដោយទិដ្ឋិ ។

ព្រោះហេតុនោះសញ្ញាវិបល្លាស មានកម្លាំងខ្សោយជាងទាំងអស់ ចិត្ត-វិបល្លាស មានកម្លាំងច្រើនជាងសញ្ញាវិបល្លាសនោះ ទិដ្ឋិវិបល្លាស មានកម្លាំងច្រើនជាងទាំងអស់ ។ ពិតណាស់ សញ្ញាដូចការឃើញកហាបណៈរបស់ទារក ដែលមិនទាន់ដឹងក្តី ព្រោះកាន់យកត្រឹមតែអាការប្រាកដនៃអា-រម្មណ៍ ។ ចិត្ត ដូចការឃើញកហាបណៈរបស់អ្នកស្រុក ព្រោះឲ្យដល់ការដឹងច្បាស់លក្ខណៈ ។ ទិដ្ឋិ ដូចការចាប់ដែកដោយអង្គុំធំ របស់ជាងដែក ព្រោះ

ប្រកាន់ដោយការស្ទាបអង្អែល ។

បទថា **អនិច្ចេ និច្ចន្តិ សញ្ញាវិបល្លាសោ** បានដល់ សញ្ញាដែលកើតឡើង ព្រោះចាប់យកក្នុងវត្ថុដែលមិនទៀងយ៉ាងនេះថា នេះទៀង ជាសញ្ញា-វិបល្លាស ។ គប្បីជ្រាបសេចក្ដីក្នុងបទទាំងពួងដោយន័យនេះ ។

បទថា **ន សញ្ញាវិបល្លាសោ ន ចិត្តវិបល្លាសោ ន ទិដ្ឋិវិបល្លាសោ** លោកពោលដល់ការកាន់យកតាមសេចក្ដីពិត ព្រោះមិនមានការប្រកាន់ខុស ១២ យ៉ាង ក្នុងវត្ថុ ៤ យ៉ាង ។

គប្បីជ្រាបសេចក្ដីក្នុងគាថាទាំងឡាយ ដូចតទៅនេះថា បទថា **អនត្តនិច អត្តា** បានដល់ មានការសម្គាល់យ៉ាងនេះថា តួខ្លួន ក្នុងសភាវៈដែលមិនមែនតួខ្លួន ។ បទថា **មិច្ឆាទិដ្ឋិហតា** បានដល់ មិនត្រឹមតែមានការសម្គាល់តែម្យ៉ាងប៉ុណ្ណោះ ថែមទាំងត្រូវការយល់ខុសដែលកើតឡើង ដូចគ្នានឹងសញ្ញានាំទៅ ។ បទថា **ខិត្តចិត្តា** បានដល់ ប្រកបដោយចិត្តឃ្លេងឃ្លោង វិលទៅ ដែលកើតឡើងដូចសញ្ញានិងទិដ្ឋិ ។ បទថា **វិសញ្ញិនោ** នេះត្រឹមតែជាទេសនា សេចក្ដីថា មានការសម្គាល់ ការគិតនិងការឃើញវិបរិត ។

ម្យ៉ាងវិញទៀត ព្រោះសញ្ញាជាតួនាំ ទើបលោកពោលសញ្ញាវិបល្លាសដោយ ៤ បទ មុនទិដ្ឋិ បន្ទាប់អំពីនោះទើបពោលទិដ្ឋិវិបល្លាសដោយបទថា ត្រូវមិច្ឆាទិដ្ឋិកម្ចាត់បង់ហើយ ពោលចិត្តវិបល្លាស ដោយបទថា មានចិត្តក្រឡុក ។ បទថា **វិសញ្ញិនោ** បានដល់ ប្រាសចាកសញ្ញាប្រក្រតី ដល់

នូវការវង្វេងដោយការកាន់វិបល្លាស ៣ ដូចក្នុងប្រយោគ ( សុវណ្ណសាមជាតក ) នេះថា ក៏ជ្រប់សន្ធប់ដោយកម្លាំងពិស ។ បទថា **តេ យោគយុត្តា មារស្ស** បានដល់ ជន គឺសត្វទាំងនោះ ឈ្មោះថា ជាប់នៅក្នុងអន្ទាក់របស់មារ ។ បទថា **អយោគក្ខេមិនោ** បានដល់ មិនសម្រេចនិព្វានដែលជាទីក្សេមចាកយោគៈ គឺចង្រៃ ៤ ។ បទថា **សត្តា គច្ឆន្តិ សំសារំ** បានដល់ បុគ្គលទាំងនោះឯងត្រូវត្រាច់ទៅកាន់សង្សារ ព្រោះហេតុអ្វី មានអធិប្បាយថា ព្រោះថា សត្វទាំងនោះតែងដល់នូវជាតិនិងមរណៈ ព្រោះហេតុនោះ ទើបត្រូវត្រាច់ទៅ ។ បទថា **ពុទ្ធា** បានដល់ ព្រះសព្វញ្ញូអ្នកត្រាស់ដឹងអរិយសច្ច ៤ ជាពហុវចនៈ ដោយអំណាចទូទៅក្នុងកាល ៣ ។ បទថា **លោកស្មឹ** បានដល់ ក្នុងឱកាសលោក ។ បទថា **បភង្ករា** បានដល់ ធ្វើលោកឲ្យភ្លឺស្វាងដោយបញ្ញា ។ បទថា **ឥមំ ធម្មំ បកាសេន្តិ** បានដល់ ទ្រង់សម្តែងធម៌លះនូវវិបល្លាស ។ បទថា **ទុក្ខូបសមគាមិនំ** បានដល់ ដល់នូវនិព្វាន ដែលជាការស្ងប់រម្ងាប់ទុក្ខ ។ បទថា **តេសំ សុត្វាន** បានដល់ ស្តាប់ហើយនូវធម៌របស់ព្រះពុទ្ធទាំងនោះ ។ បទថា **សប្បញ្ញា** បានដល់ ជាកព្វបុគ្គលដែលមានបញ្ញា ។ បទថា **សចិត្តំ បច្ចលទ្ធុ** បានដល់ ត្រឡប់បាន ( បដិលភិត្វា ) នូវចិត្តរបស់ខ្លួន ដែលវៀរនូវវិបល្លាស ។ កាត់បទថា **បដិអលទ្ធុ** ។ ម្យ៉ាងទៀត បានដល់ **បដិលភឹសុ** កាត់បទថា **បដិអលទ្ធុំ** ។ បទថា **អនិច្ចតោ ទក្ខុំ** បានដល់ បានឃើញដោយអំណាចសភាពមិនទៀងនោះឯង ។ បទថា **អត្តនិ អនត្តា**

បានដល់ បានឃើញសភាវៈមិនមែនតួខ្លួន ។ម្យ៉ាងទៀត បានឃើញថាតួខ្លួន មិនមានវត្ថុដែលមិនមែនតួខ្លួន ។ បទថា **សម្មាទិដ្ឋិសមាទានា** បានដល់ កាន់យកការឃើញប្រពៃ ។ បទថា **សព្វំ ទុក្ខំ បច្ចគុំ** បានដល់ ឈានកន្លងវដ្តទុក្ខទាំងអស់ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យសួរ ដល់វិបល្លាសដែលលះបានហើយ និងមិនទាន់លះបានដូច្នេះ ។ បទថា **ទិដ្ឋិសម្បន្នស្ស** បានដល់ ព្រះសោតាបន្ន ។ បទថា **ទុក្ខេ សុខន្តិ សញ្ញា ឧប្បជ្ជតិ ចិត្តំ ឧប្បជ្ជតិ** បានដល់ ត្រឹមតែការសម្គាល់ ឬត្រឹមតែការគិត រមែងកើតឡើងព្រោះនៅលះការផងឹត គឺមោហៈមិនទាន់បាន រមែងកើតឡើងសូម្បីដល់ព្រះអនាគាមី មិនចាំបាច់និយាយថ្វីដល់ព្រះសោតាបន្ន ។ វិបល្លាសទាំងពីរនេះ ព្រះអរហន្តប៉ុណ្ណោះទើបលះបាន ។

បទថា **អសុភេ សុភន្តិ សញ្ញា ឧប្បជ្ជតិ ចិត្តំ ឧប្បជ្ជតិ** បានដល់ កើតឡើងសូម្បីដល់ព្រះសកទាគាមី មិនចាំបាច់និយាយថ្វីដល់ព្រះសោតា-បន្ន ។ លោកពោលទុកក្នុងអដ្ឋកថាថា វិបល្លាសទាំងពីរនេះ ព្រះអនាគាមីទើបលះបាន ព្រោះហេតុនោះ គប្បីជ្រាបថា ទាំងពីរនេះលោកពោលសំដៅដល់ព្រះសោតាបន្ននិងព្រះសកទាគាមី ។

គប្បីជ្រាបថា លោកពោលដល់ការលះនូវការសម្គាល់ខុស ការគិតខុសក្នុងសភាវៈដែលមិនស្អាត ថាស្អាត ព្រោះព្រះអនាគាមី លះកាមរាគៈបានហើយ ។ ដោយបទថា **ទ្វីសុ វត្ថូសុ** ជាដើម លោកសម្តែងសរុបដល់វិបល្លាស ដែលលះបាននិងមិនទាន់លះបាន ។ ក្នុងបទនោះ ជាការលះ

វិបល្លាស ៦ ក្នុងវត្ថុ ២ ទាំងនេះ គឺក្នុងសភាវៈមិនទៀង ថាទៀង ក្នុងសភាវៈមិនមែនតួខ្លួន ថាតួខ្លួន ជាការលះទិដ្ឋិវិបល្លាស ២ ក្នុងវត្ថុ ២ ទាំងនេះ គឺក្នុងសភាវៈដែលជាទុក្ខ ថាជាសុខ ក្នុងសភាវៈដែលមិនស្អាត ថាស្អាត ។ ក្នុងគម្ពីរខ្លះ លោករចនាពាក្យថា **២** មុន រចនាពាក្យថា **៦** ជាខាងក្រោយ ។ បទថា **ចត្សុ វត្ថូសុ** លោកពោលដល់វត្ថុ ៤ រួមគ្នាទុក ។ បទថា **អដ្ឋ** បានដល់ វិបល្លាស ៦ ក្នុងវត្ថុ ២ វិបល្លាស ២ ក្នុងវត្ថុ ២ ទើបរួមជាវិបល្លាស ៨ ។ បទថា **ចត្តារោ** បានដល់ វិបល្លាស ៤ គឺសញ្ញាវិបល្លាសនិងចិត្តវិបល្លាសទីមួយៗ ២ ក្នុងវត្ថុទីមួយៗបណ្ដាវត្ថុដែលជាទុក្ខ និងមិនស្អាត ក្នុងគម្ពីរខ្លះលោករចនាទុកយ៉ាងនោះដូចគ្នា សូម្បីក្នុងទីដែលលោកពោលថា វិបល្លាស ៦ ក្នុងវត្ថុ ២ ។

## អដ្ឋកថា វិបល្លាសកថា ចប់

# សុត្តន្តបិដក

## មហាវគ្គ មគ្គកថា

[ ២៣៥ ] ពាក្យថា មគ្គ តើមគ្គដោយអត្ថដូចម្តេច ។ ក្នុងខណៈនៃសោតាបត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា យល់ឃើញ ជាមគ្គផង ជាហេតុផង ដើម្បីលះមិច្ឆាទិដ្ឋិ ជាមគ្គផង ជាហេតុផង ដើម្បីឧបត្ថម្ភនូវពួកសហជាតធម៌ ជាមគ្គផង ជាហេតុផង ដើម្បីគ្របសង្កត់នូវពួកកិលេស ជាមគ្គផង ជាហេតុផង ដើម្បីជម្រះនូវគុណវិសេស មានបដិវេធៈជាដើម ជាមគ្គផង ជាហេតុផង ដើម្បីអធិដ្ឋាននៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីផូរផង់នៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីបាននូវគុណវិសេស ជាមគ្គផង ជាហេតុផង ដើម្បីចាក់ធ្លុះតទៅទៀត ជាមគ្គផង ជាហេតុផង ដើម្បីត្រាស់ដឹងនូវសច្ចៈ ជាមគ្គផង ជាហេតុផង ដើម្បីញុំាងសត្វឲ្យឋិតនៅស៊ប់ ក្នុងនិរោធ ។ សម្មាសង្កប្បៈ ដោយអត្ថថា លើកចិត្តឡើងកាន់អារម្មណ៍ ជាមគ្គផង ជាហេតុផង ដើម្បីលះមិច្ឆាសង្កប្បៈ ជាមគ្គផង ជាហេតុផង ដើម្បីឧបត្ថម្ភនូវពួកសហជាតធម៌ ជាមគ្គផង ជាហេតុផង ដើម្បីគ្របសង្កត់នូវពួកកិលេស ជាមគ្គផង ជាហេតុផង ដើម្បីជម្រះនូវគុណវិសេស មានបដិវេធៈជាដើម ជាមគ្គផង ជាហេតុផង ដើម្បីអធិដ្ឋាននៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីផូរផង់នៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីបាននូវគុណវិសេស ជាមគ្គផង ជាហេតុផង ដើម្បីចាក់ធ្លុះតទៅទៀត ជាមគ្គផង ជាហេតុផង ដើម្បីត្រាស់ដឹងនូវសច្ចៈ ជាមគ្គផង ជាហេតុផង ដើម្បីញុំាង

សត្វឲ្យឋិតនៅចំពោះក្នុងនិរោធ ។ សម្មាវាចា ដោយអត្ថថា កំណត់ ជាមគ្គផង ជាហេតុផង ដើម្បីលះបង់មិច្ឆាវាចា ជាមគ្គផង ជាហេតុផង ដើម្បីឧបត្ថម្ភនូវពួកសហជាតធម៌ ជាមគ្គផង ជាហេតុផង ដើម្បីគ្របសង្កត់នូវពួកកិលេស ជាមគ្គផង ជាហេតុផង ដើម្បីជម្រះនូវគុណវិសេសមានបដិវេធៈជាដើម ជាមគ្គផង ជាហេតុផង ដើម្បីអធិដ្ឋាននៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីផូរផង់នៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីបានទូវគុណវិសេស ជាមគ្គផង ជាហេតុផង ដើម្បីចាក់ធ្លុះតទៅទៀត ជាមគ្គផង ជាហេតុផង ដើម្បីត្រាស់ដឹងនូវសច្ចៈ ជាមគ្គផង ជាហេតុផង ដើម្បីញុំាងសត្វឲ្យឋិតនៅចំពោះក្នុងនិរោធ ។ សម្មាកម្មន្តៈ ដោយអត្ថថា ខ្នះខ្នែង ជាមគ្គផង ជាហេតុផង ដើម្បីលះបង់មិច្ឆាកម្មន្តៈ ជាមគ្គផង ជាហេតុផង ដើម្បីឧបត្ថម្ភ នូវសហជាតធម៌ ជាមគ្គផង ជាហេតុផង ដើម្បីគ្របសង្កត់នូវពួកកិលេស ជាមគ្គផង ជាហេតុផង ដើម្បីជម្រះនូវគុណវិសេស មានបដិវេធៈជាដើម ជាមគ្គផង ជាហេតុផង ដើម្បីអធិដ្ឋាននៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីផូរផង់នៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីបានទូវគុណវិសេស ជាមគ្គផង ជាហេតុផង ដើម្បីចាក់ធ្លុះតទៅទៀត ជាមគ្គផង ជាហេតុផង ដើម្បីត្រាស់ដឹងនូវសច្ចៈ ជាមគ្គផង ជាហេតុផង ដើម្បីញុំាងសត្វឲ្យឋិតនៅចំពោះក្នុងនិរោធ ។ សម្មាអាជីវៈ ដោយអត្ថថា ផូរផង់ ជាមគ្គផង ជាហេតុផង ដើម្បីលះបង់មិច្ឆាជីវៈ ។បេ។ សម្មាវាយាមៈ ដោយអត្ថថា ផ្គងឡើង ជាមគ្គផង ជាហេតុផង ដើម្បីលះបង់នូវមិច្ឆាវាយាមៈ ។បេ។ សម្មាសតិ ដោយអត្ថថា ប្រុងប្រយ័ត្ន

ជាមគ្គផង ជាហេតុផង ដើម្បីលះបង់មិច្ឆាសតិ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ ជាមគ្គផង ជាហេតុផង ដើម្បីលះបង់មិច្ឆាសមាធិ ជាមគ្គផង ជាហេតុផង ដើម្បីឧបត្ថម្ភនូវពួកសហជាតធម៌ ជាមគ្គផង ជាហេតុផង ដើម្បីគ្របសង្កត់នូវពួកកិលេស ជាមគ្គផង ជាហេតុផង ដើម្បីជម្រះនូវគុណវិសេស មានបដិវេធៈជាដើម ជាមគ្គផង ជាហេតុផង ដើម្បីអធិដ្ឋាននៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីផូរផង់នៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីបាននូវគុណវិសេស ជាមគ្គផង ជាហេតុផង ដើម្បីចាក់ធ្លុះតទៅទៀត ជាមគ្គផង ជាហេតុផង ដើម្បីត្រាស់ដឹងនូវសច្ចៈ ជាមគ្គផង ជាហេតុផង ដើម្បីញ៉ាំងសត្វឲ្យឋិតនៅចំពោះក្នុងនិរោធ ។

[ ២៣៦ ] ក្នុងខណៈនៃសកទាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា យល់ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ ជាមគ្គផង ជាហេតុផង ដើម្បីលះបង់នូវកាមរាគសំយោជនៈនិងបដិឃសំយោជនៈដ៏គ្រោតគ្រាត នូវកាមរាគានុស័យនិងបដិឃានុស័យដ៏គ្រោតគាត ជាមគ្គផង ជាហេតុផង ដើម្បីឧបត្ថម្ភនូវពួកសហជាតធម៌ ជាមគ្គផង ជាហេតុផង ដើម្បីគ្របសង្កត់នូវពួកកិលេស ជាមគ្គផង ជាហេតុផង ដើម្បីជម្រះនូវគុណវិសេស មានបដិវេធៈជាដើម ជាមគ្គផង ជាហេតុផង ដើម្បីអធិដ្ឋាននៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីផូរផង់នៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីបាននូវគុណវិសេស ជាមគ្គផង ជាហេតុផង ដើម្បីចាក់ធ្លុះតទៅទៀត ជាមគ្គផង ជាហេតុផង ដើម្បីត្រាស់ដឹងនូវសច្ចៈជាមគ្គផង ជាហេតុផងដើម្បី

ញុំាងសត្វឲ្យឋិតនៅចំពោះក្នុងនិរោធ ។

ក្នុងខណៈនៃអនាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា យល់ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ ជាមគ្គផង ជាហេតុផង ដើម្បីលះបង់នូវកាមរាគសំយោជនៈនិងបដិឃសំយោជនៈដ៏សួចស្តើង នូវកាមរាគានុស័យនិងបដិឃានុស័យដ៏សួចស្តើង ជាមគ្គផង ជាហេតុផង ដើម្បីឧបត្ថម្ភនូវសហជាតធម៌ ជាមគ្គផង ជាហេតុផង ដើម្បីគ្របសង្កត់នូវពួកកិលេស ជាមគ្គផង ជាហេតុផង ដើម្បីជម្រះនូវគុណវិសេសមានបដិវេធៈជាដើម ជាមគ្គផង ជាហេតុផង ដើម្បីអធិដ្ឋាននៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីផូរផង់នៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីបានគុណវិសេស ជាមគ្គផង ជាហេតុផង ដើម្បីបាក់ធ្លុះតទៅទៀត ជាមគ្គផង ជាហេតុផង ដើម្បីត្រាស់ដឹងនូវសច្ចៈ ជាមគ្គផង ជាហេតុផង ដើម្បីញុំាងសត្វឲ្យឋិតនៅចំពោះក្នុងនិរោធ ។

ក្នុងខណៈនៃអរហត្តមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា យល់ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ ជាមគ្គផង ជាហេតុផង ដើម្បីលះបង់នូវរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ រាគានុស័យ អវិជ្ជានុស័យ ជាមគ្គផង ជាហេតុផង ដើម្បីឧបត្ថម្ភនូវសហជាតធម៌ ជាមគ្គផង ជាហេតុផង ដើម្បីគ្របសង្កត់នូវពួកកិលេស ជាមគ្គផង ជាហេតុផង ដើម្បីជម្រះនូវគុណវិសេស មានបដិវេធៈជាដើម ជាមគ្គផង ជាហេតុផង ដើម្បីអធិដ្ឋាននៃចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីផូរផង់នៃ

ចិត្ត ជាមគ្គផង ជាហេតុផង ដើម្បីបានទូវគុណវិសេស ជាមគ្គផង ជាហេតុផង ដើម្បីចាក់ធ្លុះតទៅទៀត ជាមគ្គផង ជាហេតុផង ដើម្បីត្រាស់ដឹងនូវសច្ចៈ ជាមគ្គផង ជាហេតុផង ដើម្បីញ៉ាំងសត្វ ឲ្យឋិតនៅចំពោះក្នុងនិរោធ ។

[ ២៣៧ ] សម្មាទិដ្ឋិ មានការយល់ឃើញ ជាមគ្គ សម្មាសង្កប្បៈ មានការលើកចិត្តកាន់អារម្មណ៍ ជាមគ្គ សម្មាវាចា មានការកំណត់ ជាមគ្គ សម្មាកម្មន្តៈ មានការខ្នះខ្នែង ជាមគ្គ សម្មាអាជីវៈ មានការផូរផង់ ជាមគ្គ សម្មាវាយាមៈ មានការផ្គងឹ ជាមគ្គ សម្មាសតិ មានការប្រុងប្រយ័ត្ន ជាមគ្គ សម្មាសមាធិ មានការមិនរាយមាយ ជាមគ្គ សតិសម្ពោជ្ឈង្គ មានការប្រុងប្រយ័ត្ន ជាមគ្គ ធម្មវិចយសម្ពោជ្ឈង្គ មានការពិចារណា ជាមគ្គ វិរិយសម្ពោជ្ឈង្គ មានការផ្គងឡើង ជាមគ្គ បីតិសម្ពោជ្ឈង្គ មានការផ្សាយទៅជាមគ្គ បស្សទ្ធិសម្ពោជ្ឈង្គ មានការស្ងប់រម្ងាប់ ជាមគ្គ សមាធិសម្ពោ-ជ្ឈង្គ មានការមិនរាយមាយ ជាមគ្គ ឧបេក្ខាសម្ពោជ្ឈង្គ មានការពិចារ-ណា ជាមគ្គ សទ្ធាពលៈ មានការមិនកម្រើកព្រោះការមិនជឿ ជាមគ្គ វិរិយ-ពលៈ មានការមិនកម្រើកព្រោះការខ្ជិលច្រអូស ជាមគ្គ សតិពលៈ មានការមិនកម្រើកព្រោះសេចក្តីប្រហែស ជាមគ្គ សមាធិពលៈ មានការមិនកម្រើកព្រោះឧទ្ធច្ចៈ ជាមគ្គ បញ្ញាពលៈ មានការមិនកម្រើក ព្រោះអវិជ្ជា ជាមគ្គ សទ្ធិន្ទ្រិយ មានការជឿស៊ប់ ជាមគ្គ វិរិយិន្ទ្រិយ មានការផ្គងឡើងជាមគ្គ សតិន្ទ្រិយ មានការប្រុងប្រយ័ត្ន ជាមគ្គ សមាធិន្ទ្រិយ មានការមិនរាយមាយ

ជាមគ្គ បញ្ញិន្ទ្រិយ មានការយល់ឃើញ ជាមគ្គ ឥន្ទ្រិយ ឈ្មោះថា មគ្គ ដោយអត្ថថា ជាអធិបតី ពលៈ ឈ្មោះថា មគ្គ ដោយអត្ថថា មិនកម្រើក ពោជ្ឈង្គ ឈ្មោះថា មគ្គ ដោយអត្ថថា ចេញចាក ( វដ្តៈ ) ឈ្មោះថា មគ្គ ដោយអត្ថថា ជាហេតុ សតិប្បដ្ឋាន ឈ្មោះ ថាមគ្គ ដោយអត្ថថា ប្រុងប្រយ័ត្ន សម្មប្បធាន ឈ្មោះថា មគ្គ ដោយអត្ថថា តាំងមាំ ឥទ្ធិបាទ ឈ្មោះថាមគ្គ ដោយអត្ថថា សម្រេច សច្ចៈ ឈ្មោះថា មគ្គ ដោយអត្ថថា ទៀងទាត់ សមថៈ ឈ្មោះថា មគ្គ ដោយអត្ថថា មិនរាយមាយ វិបស្សនា ឈ្មោះថាមគ្គ ដោយអត្ថថា យល់ច្បាស់ សមថវិបស្សនា ឈ្មោះថា មគ្គ ដោយអត្ថថា មានរសតែមួយ យុគនទ្ធធម៌ ( ធម៌អាស្រ័យនឹងគ្នាដូចជានឹមនិងព្រាត់ជ្រាម ) ឈ្មោះថា មគ្គ ដោយអត្ថថា មិនប្រព្រឹត្តកន្លងគ្នា សីលវិសុទ្ធិ ឈ្មោះថា មគ្គ ដោយអត្ថថា សង្រួម ចិត្តវិសុទ្ធិ ឈ្មោះថា មគ្គ ដោយអត្ថថា មិនរាយមាយ ទិដ្ឋិវិសុទ្ធិ ឈ្មោះថា មគ្គ ដោយអត្ថថា យល់ឃើញ វិមោក្ខ ឈ្មោះថា មគ្គ ដោយអត្ថថា រួច ( ចាកកិលេស ) វិជ្ជា ឈ្មោះថា មគ្គ ដោយអត្ថថា ចាក់ធ្លុះ វិមុត្តិ ឈ្មោះថា មគ្គ ដោយអត្ថថា លះបង់ ខយញ្ញាណ ឈ្មោះថា មគ្គ ដោយអត្ថថា ផ្តាច់បង់ ឆន្ទៈ ឈ្មោះថា មគ្គ ដោយអត្ថថា ជាឫស មនសិការ ឈ្មោះថា មគ្គ ដោយអត្ថថា តាំងឡើងព្រម ផស្សៈ ឈ្មោះថា មគ្គ ដោយអត្ថថា រួបរួម វេទនា ឈ្មោះថា មគ្គ ដោយអត្ថថា ប្រជុំចុះ សមាធិ ឈ្មោះថា មគ្គ ដោយអត្ថថា ជាប្រមុខ សតិ ឈ្មោះថា មគ្គ ដោយអត្ថថា ជាអធិបតី បញ្ញា ឈ្មោះថា មគ្គ

ដោយអត្ថថា ក្រៃលែងជាងពួកធម៌ទាំងនោះ វិមុត្តិ ឈ្មោះថា មគ្គ ដោយអត្ថថា ជាទីម អមតនិព្វាន ឈ្មោះថា មគ្គ ដោយអត្ថថា ចប់ស្រេច ( នៃកិច្ចក្នុងសាសនា ) ។

**ចប់ មគ្គកថា ។**

## អដ្ឋកថា

## មគ្គកថា

[ ២៣៥ ] ឥឡូវនេះនឹងពណ៌នាតាមលំដាប់សេចក្តី ដែលនៅមិនធ្លាប់ពណ៌នាក្នុងមគ្គកថា ដែលព្រះសារីបុត្តត្ថេរ សម្តែងដល់អរិយមគ្គដែលមានអាការនៃការលះវិបល្លាស ៣ ទាំងនោះ ពោលទុកហើយ ។

ក្នុងបទទាំងនោះ បទថា **មគ្គោតិ កេនដ្ឋេន មគ្គោ** សេចក្តីថា ក្នុងព្រះពុទ្ធសាសនា សភាវៈដែលលោកពោលថាមគ្គ ឈ្មោះថា មគ្គ ព្រោះអត្ថថា ដូចម្តេច ។ ក្នុងបរិយាយ ១០ មាន **មិច្ឆាទិដ្ឋិយា បហានាយ** ជាដើម លោកពោលដល់បរិយាយទី ១ ដោយអំណាចជាសត្រូវដោយត្រង់នៃអង្គមគ្គនោះៗ ។ បទថា **មគ្គោ ចេវ ហេតុ ច** បានដល់ ជាមគ្គ ដោយអត្ថថា ជាបដិបទា ជាហេតុ ដោយអត្ថថា ឲ្យដល់ដើម្បីធ្វើកិច្ចនោះៗ ។ ដោយពាក្យនោះ ឈ្មោះថាលោកពោលដល់មគ្គដែលមានអត្ថថា ជាបដិបទា និងមានអត្ថថា ឲ្យដល់ ។ មគ្គជាបដិបទាដូចក្នុងប្រយោគ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ជាដើមថា នេះជាមគ្គ នេះជាបដិបទា ហេតុជាគ្រឿងឲ្យដល់ដូចក្នុងប្រយោគជាដើមថា មគ្គសច្ចៈ មានអត្ថថា ស្រោចស្រង់ មានអត្ថថាជាហេតុ ដោយបទទាំងពីរនេះ ឈ្មោះថាលោក ធ្វើការឆ្លើយនូវពាក្យសួរថា ពាក្យថា មគ្គ តើមគ្គដោយអត្ថដូចម្តេច ដោយប្រការដូច្នេះ ។

បទថា **សហជាតានំ ធម្មានំ ឧបត្ថម្ភនាយ** បានដល់ ដើម្បីជាការឧបត្ថម្ភអរូបធម៌ដែលកើតព្រមនឹងខ្លួនដោយភាពជាសហជាតប្បច្ច័យ អញ្ញ-

មញ្ញប្បច្ច័យ និងនិស្សយប្បច្ច័យជាដើម ។ បទថា **កិលេសានំ បរិយាទានាយ** បានដល់ ដើម្បីធ្វើកិលេសដែលសល់ ដូចពោលហើយ ដែលមគ្គនោះៗ គប្បីសម្លាប់ឲ្យអស់ទៅ ។ ក្នុងបទនេះថា **បដិវេធាទិវិសោធនាយ** មានសេចក្ដីដូច្នេះថា ព្រោះសីលនិងទិដ្ឋិជាខាងដើមនៃការចាក់ធ្លុះសច្ចៈដោយព្រះបាលី ( សំយុត្តនិកាយមហាវារវគ្គ ) ថា ចុះអ្វីជាខាងដើមនៃកុសលធម៌ទាំងឡាយ ។ គឺសីលដ៏បរិសុទ្ធ ១ ទិដ្ឋិត្រង់ ១ ឯខាងដើមនោះរមែងបរិសុទ្ធក្នុងខណៈនៃមគ្គ ហេតុនោះ ទើបលោកពោលថា ដើម្បីជម្រះនូវគុណវិសេសមានបដិវេធជាដើមដូច្នេះ ។ បទថា **ចិត្តស្ស អធិដ្ឋានាយ** បានដល់ ដើម្បីការតាំងមាំក្នុងកិច្ចរបស់ខ្លួននៃចិត្តដែលសម្បយុត្តគ្នា ។ បទថា **ចិត្តស្ស វោទានាយ** បានដល់ ដើម្បីសេចក្ដីបរិសុទ្ធិនៃចិត្ត ។ បទថា **វិសេសាធិគមាយ** បានដល់ ដើម្បីបានចំពោះគុណវិសេសជាងធម៌ជា លោកិយៈ ។ បទថា **ឧត្តរិ បដិវេធាយ** បានដល់ ដើម្បីចាក់ធ្លុះធម៌ ដែលក្រៃលែងជាងធម៌ជាលោកិយៈ ។ បទថា **សច្ចាភិសមយាយ** បានដល់ ដើម្បីត្រាស់ដឹងធម៌ឯកនៃអរិយសច្ច ៤ គឺដើម្បីចាក់ធ្លុះធម៌ឯកដោយ អំណាចញុំាងកិច្ចឲ្យសម្រេច ។ បទថា **និរោធេ បតិដ្ឋាបនាយ** បានដល់ ដើម្បីឲ្យចិត្ត ឬបុគ្គលតាំងនៅក្នុងនិព្វាន ។

[ ២៣៦ ] លោកធ្វើអង្គនៃមគ្គ ៨ ជាចំណែកដូចគ្នា ហើយពោលដល់ការលះកិលេសដែលមគ្គនោះៗ គប្បីសម្លាប់ក្នុងខណៈនៃសកទាគាមិមគ្គជាដើម ហេតុក្នុងការពោលយ៉ាងនេះ ខ្ញុំធ្លាប់ពោលហើយនោះឯង ព្រោះការ

ជម្រះខាងដើមដោយល្អ និងការផ្ទុះផង់នៃចិត្តដោយល្អ សូម្បីដោយមគ្គខ្ពស់ៗ ក៏រមែងមានបាន ហេតុនោះទើបលោកពោលពាក្យទាំងឡាយនោះ ។

[ ២៣៧ ] ដោយបទថា **ឧស្សនមគ្គោ** ជាដើម លោកពោលដល់អត្ថនៃមគ្គ ដោយអំណាចនៃលក្ខណៈរបស់ធម៌នោះ រហូតដល់ទីបំផុត ។ បទសូម្បីទាំងអស់នោះ មានសេចក្ដីដូចដែលលោកពោលទុកហើយ ក្នុងអភិញ្ញេយ្យនិទ្ទេស ។ ក្នុងទីនេះ លោកចង្អុលបង្ហាញដល់មគ្គដែលជាលោកិយៈ និងលោកុត្តរៈតាមសភាវៈដែលមាន ដោយប្រការដូច្នេះ ។ លោកចង្អុលបង្ហាញដល់មគ្គ ព្រោះអត្ថថា ជាហេតុ ។ ម្យ៉ាងទៀត ព្រោះមគ្គនោះ ជាមគ្គដោយត្រង់ ទើបលោកមិនពោលថា ជាមគ្គ បន្ថែមចូលមក ។ បទថា **អធិបតេយ្យដ្ឋេន ឥន្ទ្រិយា** លោកពោលដោយអំណាចអត្ថ នៃឥន្ទ្រិយជាដើម ។ ម្យ៉ាងទៀត ក្នុងបទថា **សច្ចានិ** នេះ បានដល់ សច្ចញ្ញាណ ។ ធម៌ទាំងអស់នោះ ឈ្មោះថា មគ្គ ដោយអត្ថថាជាបដិបទាដើម្បីនិព្វាន ។ ម្យ៉ាងទៀត និព្វានដែលលោកពោលទុកចុងក្រោយ គប្បីជ្រាបថា លោកពោលថាជាមគ្គ ព្រោះអត្ថថា សប្បុរសដែលត្រូវសង្សារទុក្ខគ្របសង្កត់ ដែលត្រូវការផុតចាកទុក្ខស្វែងរក ។

**អដ្ឋកថា មគ្គកថា ចប់**

# សុត្តន្តបិដក

## ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

## តតិយភាគ

## មហាវគ្គ មណ្ឌបេយ្យកថា

[ ១ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះសាស្តាគង់នៅក្នុងទីចំពោះមុខ ព្រហ្មចរិយៈនេះ ថាគួរគ្រេបផឹក កាលព្រះសាស្តា គង់នៅក្នុងទីចំពោះមុខ សភាពថាមាន ៣ យ៉ាងគឺ ទេសនាថា ១ អ្នកទទួលថា ១ ព្រហ្មចរិយៈថា ១ ។

ទេសនាថា តើដូចម្តេច ។ ការប្រាប់ ការសម្តែង ការបញ្ញត្តិ ការតាំងទុក ការបើក ការវែកញែក ការធ្វើឲ្យរាក់ នូវអរិយសច្ច ៤ ការប្រាប់ ការសម្តែង ការបញ្ញត្តិ ការតាំងទុក ការបើក ការវែកញែក ការធ្វើឲ្យរាក់នូវសតិប្បដ្ឋាន ៤ ។បេ។ នូវសម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ នេះទេសនាថា ។

អ្នកទទួលថា តើដូចម្តេច ។ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតានិងមនុស្ស ឬពួកជនដទៃណាមួយ ជាអ្នកដឹង នេះអ្នកទទួលថា ។

ព្រហ្មចរិយៈថា តើដូចម្តេច ។ អរិយមគ្គមានអង្គ ៨ នេះឯង ។ ដូចម្តេចខ្លះ ។ គឺសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ នេះព្រហ្មចរិយៈថា ។

[ ២ ] សទ្ធិន្ទ្រិយថា ដោយការជឿស៊ប់ អស្សទ្ធិយៈ ( ការមិនជឿ ) ជាកករល្អក់ បុគ្គលលះបោលនូវអស្សទ្ធិយៈជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការជឿស៊ប់របស់សទ្ធិន្ទ្រិយ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក វីរិយិន្ទ្រិយថា ដោយការផ្គងឡើង កោសជ្ជៈជាកករល្អក់ បុគ្គលលះបោលនូវកោសជ្ជៈជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការផ្គងឡើងរបស់វីរិយិន្ទ្រិយ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សតិន្ទ្រិយថា ដោយការប្រុងបមាទៈជាកករល្អក់ បុគ្គលលះបោលនូវបមាទៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការប្រុងរបស់សតិន្ទ្រិយ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សមាធិន្ទ្រិយថា ដោយការមិនរាយមាយ ឧទ្ធច្ចៈជាកករល្អក់ បុគ្គលលះបោលនូវឧទ្ធច្ចៈជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនរាយមាយរបស់សមាធិន្ទ្រិយ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្ម-ចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក បញ្ញិន្ទ្រិយថា ដោយការឃើញអវិជ្ជាជាកករល្អក់ បុគ្គលលះបោលនូវអវិជ្ជាជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការឃើញរបស់បញ្ញិន្ទ្រិយ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សទ្ធាពលៈថា ដោយការមិនញាប់ញ័រ ព្រោះការមិនជឿ ការមិនជឿជា

កករល្អក់ បុគ្គលលះបោលនូវការមិនជឿជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនញាប់ញ័រ ព្រោះធម្មជាតមិនជឿរបស់សទ្ធាពលៈ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក វីរិយពលៈ ថ្លាដោយការមិនញាប់ញ័រ ព្រោះសេចក្ដីខ្ជិល សេចក្ដីខ្ជិលជាកករល្អក់ បុគ្គលលះបោលនូវសេចក្ដីខ្ជិលជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនញាប់ញ័រ ព្រោះសេចក្ដីខ្ជិល របស់វីរិយពលៈ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សតិពលៈថ្លា ដោយការមិនញាប់ញ័រ ព្រោះបមាទៈ បមាទៈជាកករល្អក់ បុគ្គលលះបោលនូវបមាទៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនញាប់ញ័រ ព្រោះបមាទៈរបស់សតិពលៈ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សមាធិពលៈថ្លា ដោយការមិនញាប់ញ័រ ព្រោះឧទ្ធច្ចៈ ឧទ្ធច្ចៈជាកករល្អក់ បុគ្គលលះបោលនូវឧទ្ធច្ចៈជាកករល្អក់ហើយ ក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនញាប់ញ័រ ព្រោះឧទ្ធច្ចៈរបស់សមាធិពលៈ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក បញ្ញាពលៈថ្លា ដោយការមិនញាប់ញ័រ ព្រោះអវិជ្ជា អវិជ្ជាជាកករល្អក់ បុគ្គលលះបោលនូវអវិជ្ជាជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនញាប់ញ័រ ព្រោះអវិជ្ជារបស់បញ្ញាពលៈ ( ដោយព្រហ្មចរិយៈណា ) ហេតុ

នោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្វាគួរក្រេបផឹក សតិសម្ពោជ្ឈង្គ ថា ដោយការប្រុង បមាទៈជាកករល្អក់ បុគ្គលលះបោលនូវបមាទៈជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយការប្រុងរបស់សតិសម្ពោជ្ឈង្គ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្វាគួរក្រេបផឹក ធម្មវិចយសម្ពោជ្ឈង្គថ្វា ដោយការជ្រើសរើសធម៌ អវិជ្ជាជាកករល្អក់ បុគ្គលលះបោលនូវអវិជ្ជា ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយការជ្រើសរើសរបស់ធម្មវិចយសម្ពោជ្ឈង្គ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្វាគួរក្រេបផឹក វិរិយសម្ពោជ្ឈង្គថ្វា ដោយការផ្គងឡើង សេចក្តីខ្ជិលជាកករល្អក់ បុគ្គលលះបោលនូវសេចក្តីខ្ជិលជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយការផ្គងឡើង របស់វិរិយសម្ពោជ្ឈង្គ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្វាគួរក្រេបផឹក បីតិសម្ពោជ្ឈង្គថ្វា ដោយការផ្សាយ សេចក្តីក្តៅក្រហាយជាកករល្អក់ បុគ្គលលះបោលនូវសេចក្តីក្តៅក្រហាយជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយការផ្សាយរបស់បីតិសម្ពោជ្ឈង្គ ( ដោយព្រហ្មរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្វាគួរក្រេបផឹក បស្សទ្ធិសម្ពោជ្ឈង្គថ្វា ដោយការស្ងប់ម្ងាប់ ធម្មជាតជាទីតាំងនៃសេចក្តីអាក្រក់ ជាកករល្អក់ បុគ្គលលះបោលនូវធម្មជាតជាទីតាំងនៃសេចក្តីអាក្រក់ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្វា ដោយការស្ងប់របស់បស្សទ្ធិសម្ពោជ្ឈង្គ ( ដោយ

ព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លា គួរក្រេបផឹក សមាធិសម្ពោជ្ឈង្គថា ដោយការមិនរាយមាយ ឧទ្ធច្ចៈជាកករល្អក់ បុគ្គលលះបោលនូវឧទ្ធច្ចៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនរាយមាយរបស់សមាធិសម្ពោជ្ឈង្គ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក ឧបេក្ខាសម្ពោជ្ឈង្គថា ដោយការរំពឹង ការមិនរំពឹងជាកករល្អក់ បុគ្គលលះបោលនូវការមិនរំពឹងជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការរំពឹងរបស់ឧបេក្ខាសម្ពោជ្ឈង្គ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សម្មាទិដ្ឋិថាដោយការឃើញមិច្ឆាទិដ្ឋិជាកករល្អក់ បុគ្គលលះបោលនូវមិច្ឆាទិដ្ឋិជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការឃើញរបស់សម្មាទិដ្ឋិ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថាថ្លា គួរក្រេបផឹក សម្មាសង្កប្បៈថា ដោយការលើកចិត្តឡើង ( កាន់អារម្មណ៍ ) មិច្ឆាសង្កប្បៈជាកករល្អក់ បុគ្គលលះបោលនូវមិច្ឆាសង្កប្បៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការលើកចិត្តឡើងរបស់សម្មាសង្កប្បៈ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សម្មាវាចាថាដោយការកំណត់ មិច្ឆាវាចាជាកករល្អក់ បុគ្គលលះបោលនូវមិច្ឆាវាចា ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការកំណត់របស់សម្មាវាចា ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈ

នោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សម្មាកម្មន្តៈ ថ្លាដោយការខ្នះខ្នែង មិច្ឆាកម្មន្តៈជាកករល្អក់ បុគ្គលលះបោលនូវមិច្ឆាកម្មន្តៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការខ្នះខ្នែងរបស់សម្មាកម្មន្តៈ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សម្មាអាជីវៈថ្លា ដោយសេចក្តីផូរផង់ មិច្ឆាអាជីវៈ ជាកករល្អក់ បុគ្គលលះបោលនូវមិច្ឆាអាជីវៈជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយសេចក្តីផូរផង់របស់សម្មាអាជីវៈ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សម្មាវាយាមៈថ្លា ដោយការផ្គងឡើង មិច្ឆាវាយាមៈជាកករល្អក់ បុគ្គលលះបោលនូវមិច្ឆាវាយាមៈ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការផ្គងឡើងរបស់សម្មាវាយាមៈ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សម្មាសតិ ថ្លាដោយការប្រុង មិច្ឆាសតិជាកករល្អក់ បុគ្គលលះបោលនូវមិច្ឆាសតិ ជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការប្រុងរបស់សម្មាសតិ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក សម្មាសមាធិ ថ្លាដោយការមិនរាយមាយ មិច្ឆាសមាធិ ជាកករល្អក់ បុគ្គលលះបោលនូវមិច្ឆាសមាធិជាកករល្អក់ ហើយក្រេបផឹកនូវធម្មជាតដ៏ថ្លា ដោយការមិនរាយមាយរបស់សម្មាសមាធិ ( ដោយព្រហ្មចរិយៈណា ) ហេតុនោះ ( ព្រហ្មចរិយៈនោះ ) ឈ្មោះថា ថ្លាគួរក្រេបផឹក ។

[ ៣ ] សេចក្តីថាក៏មាន ធម្មជាតគួរក្រេបផឹកក៏មាន សភាពកករល្អក់ក៏មាន សទ្ធិន្ទ្រិយថា ដោយការជឿ ការមិនជឿជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសទ្ធិន្ទ្រិយនោះឯណា នេះជាធម្មជាតគួរក្រេបផឹក វីរិយិន្ទ្រិយថា ដោយការផ្គងឡើង សេចក្តីខ្ជិលជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងវីរិយិន្ទ្រិយនោះ ឯណា នេះជាធម្មជាត គួរក្រេបផឹក សតិន្ទ្រិយថា ដោយការប្រុង បមាទៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសតិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក សមាធិន្ទ្រិយ ថាដោយការមិនរាយមាយ ឧទ្ធច្ចៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសមាធិន្ទ្រិយនោះ ឯណា នេះជាធម្មជាតគួរក្រេបផឹក បញ្ញិន្ទ្រិយថា ដោយការឃើញ អវិជ្ជាជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងបញ្ញិន្ទ្រិយនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សទ្ធាពលៈថា ដោយការមិនញាប់ញ័រ ព្រោះការមិនជឿ ការមិនជឿជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសទ្ធាពលៈ នោះឯណា នេះជាធម្មជាតគួរក្រេបផឹក វីរិយពលៈថា ដោយការមិនញាប់ញ័រ ព្រោះសេចក្តីខ្ជិល សេចក្តីខ្ជិលជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងវីរិយពលៈនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សតិពលៈថា ដោយការមិនញាប់ញ័រព្រោះបមាទៈ បមាទៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសតិពលៈនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សមាធិពលៈថា ដោយការមិនញាប់ញ័រព្រោះឧទ្ធច្ចៈ ឧទ្ធច្ចៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុង

សមាធិពលៈនោះឯណា នេះជាធម្មជាតគួរក្រេបផឹក បញ្ញាពលៈថា ដោយការមិនញាប់ញ័រ ព្រោះអវិជ្ជា អវិជ្ជាជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងបញ្ញាពលៈនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សតិសម្ពោជ្ឈង្គថាដោយការប្រុង បមាទៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសតិសម្ពោជ្ឈង្គនោះឯណា នេះជាធម្មជាតគួរក្រេបផឹក ធម្មវិចយ-សម្ពោជ្ឈង្គថា ដោយការជ្រើសរើសធម៌ អវិជ្ជាជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងធម្មវិចយសម្ពោជ្ឈង្គនោះឯណា នេះជាធម្មជាតគួរក្រេបផឹក វីរិយសម្ពោជ្ឈង្គថា ដោយការផ្គងឡើង សេចក្តីខ្ជិលជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងវីរិយសម្ពោជ្ឈង្គនោះឯណា នេះជាធម្ម-ជាតគួរក្រេបផឹក បីតិសម្ពោជ្ឈង្គថា ដោយការផ្សាយទៅ សេចក្តីក្តៅក្រ-ហាយជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងបីតិសម្ពោជ្ឈង្គនោះឯណា នេះជាធម្មជាតគួរក្រេបផឹក បស្សទ្ធិសម្ពោជ្ឈង្គថា ដោយការស្ងប់ ធម្មជាតជាទីតាំងនៃសេចក្តីអាក្រក់ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងបស្សទ្ធិសម្ពោជ្ឈង្គនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សមាធិសម្ពោជ្ឈង្គថា ដោយការមិនរាយមាយ ឧទ្ធច្ចៈ ជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសមាធិសម្ពោជ្ឈង្គនោះឯណា នេះជាធម្មជាតគួរក្រេបផឹក ឧបេក្ខាសម្ពោជ្ឈង្គថា ដោយការទើករំពឹង ការមិនទើករំពឹងជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងឧបេក្ខាសម្ពោ-ជ្ឈង្គនោះឯណា នេះជាធម្មជាតគួរក្រេបផឹក ។

[ ៤ ] សម្មាទិដ្ឋិថា ដោយការឃើញ មិច្ឆាទិដ្ឋិជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសម្មាទិដ្ឋិនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាសង្កប្បៈ ថាដោយការលើកចិត្តឡើង ( កាន់អារម្មណ៍ ) មិច្ឆាសង្កប្បៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសម្មាសង្កប្បៈនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាវាចាថា ដោយការកំណត់ទុក មិច្ឆាវាចាជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសម្មាវាចានោះឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាកម្មន្តៈថា ដោយការខ្នះខ្នែង មិច្ឆាកម្មន្តៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសម្មាកម្មន្តៈនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាអាជីវៈថា ដោយសេចក្តីបរិសុទ្ធិ មិច្ឆាអាជីវៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិ ក្នុងសម្មាអាជីវៈនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាវាយាមៈថា ដោយការផ្គងឡើង មិច្ឆាវាយាមៈជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសម្មាវាយាមៈនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាសតិថា ដោយការប្រុង មិច្ឆាសតិជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសម្មាសតិនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាសមាធិថាដោយការមិនរាយមាយ មិច្ឆាសមាធិជាកករល្អក់ រសនៃអត្ថ រសនៃធម៌ រសនៃវិមុត្តិក្នុងសម្មាសមាធិនោះឯណា នេះជាធម្មជាតគួរក្រេបផឹក សម្មាទិដ្ឋិថា ដោយការឃើញ សម្មាសង្កប្បៈថា ដោយការលើកចិត្តឡើង ( កាន់អារម្មណ៍ ) សម្មាវាចាថា ដោយការកំណត់ សម្មាកម្មន្តៈថា ដោយ

ការខ្នះខ្នែង សម្មាអាជីវៈថា ដោយសេចក្តីបរិសុទ្ធិ សម្មាវាយាមៈថា ដោយការផ្គងឡើង សម្មាសតិថា ដោយការប្រុង សម្មាសមាធិថា ដោយការមិនរាយមាយ សតិសម្ពោជ្ឈង្គថា ដោយការប្រុង ធម្មវិចយសម្ពោជ្ឈង្គថា ដោយការជ្រើសរើសធម៌ វីរិយសម្ពោជ្ឈង្គថា ដោយការផ្គងឡើង បីតិ-សម្ពោជ្ឈង្គថា ដោយការផ្សាយទៅ បស្សទ្ធិសម្ពោជ្ឈង្គថា ដោយការស្ងប់ សមាធិសម្ពោជ្ឈង្គថា ដោយការមិនរាយមាយ ឧបេក្ខាសម្ពោជ្ឈង្គថា ដោយការពិចារណា សទ្ធាពលៈថា ដោយការមិនញាប់ញ័រព្រោះការមិនជឿ វីរិ-យពលៈថា ដោយការមិនញាប់ញ័រព្រោះសេចក្តីខ្ជិល សតិពលៈថា ដោយការមិនញាប់ញ័រ ព្រោះបមាទៈ សមាធិពលៈថា ដោយការមិនញាប់ញ័រព្រោះឧទ្ធច្ចៈ បញ្ញាពលៈថា ដោយការមិនញាប់ញ័រព្រោះអវិជ្ជា សទ្ធិន្ទ្រិយថា ដោយការជឿស៊ប់ វីរិយិន្ទ្រិយថា ដោយការផ្គងឡើង សតិន្ទ្រិយថា ដោយការប្រុង សមាធិន្ទ្រិយថា ដោយការមិនរាយមាយ បញ្ញិន្ទ្រិយថា ដោយការឃើញ ឥន្ទ្រិយថា ដោយអត្ថថា ជាអធិបតី ពលៈថា ដោយអត្ថថា មិនញាប់ញ័រ ពោជ្ឈង្គថា ដោយអត្ថថា ចេញចាក ( វដ្តៈ ) មគ្គថា ដោយអត្ថថា ជាហេតុ សតិប្បដ្ឋានថា ដោយអត្ថថា ប្រុង សម្មប្បធានថា ដោយអត្ថថា តម្កល់ទុក ឥទ្ធិបាទថា ដោយអត្ថថា សម្រេច សមថៈថា ដោយអត្ថថា មិនរាយមាយ វិបស្សនាថា ដោយអត្ថថា ឃើញរឿយៗ សមថៈនិងវិបស្សនាថា ដោយអត្ថថា មានរសតែមួយ ធម៌ដែលជាប់គ្នាជាគូថា ដោយអត្ថថា មិនកន្លង ( នូវគ្នានឹងគ្នា ) សីលវិសុទ្ធិថា ដោយ

អត្ថថា សង្រួម ចិត្តវិសុទ្ធិថា ដោយអត្ថថា មិនរាយមាយ ទិដ្ឋិវិសុទ្ធិថា ដោយអត្ថថា ឃើញ វិមោក្ខថា ដោយអត្ថថា រួច វិជ្ជាថា ដោយអត្ថថា ត្រាស់ដឹង វិមុត្តិថា ដោយអត្ថថា លះចេញស្រឡះ ខយញ្ញាណថា ដោយអត្ថថា ផ្តាច់បង់ស្រឡះ អនុប្បាទញ្ញាណថា ដោយអត្ថថា រម្ងាប់ ឆន្ទៈថា ដោយអត្ថថា ឫសគល់ មនសិការៈថា ដោយអត្ថថា តាំងឡើងព្រម ផស្សៈថា ដោយអត្ថថា ប្រមូល វេទនាថា ដោយអត្ថថា ប្រជុំចុះ សមាធិថា ដោយអត្ថថា ជាប្រធាន សតិថា ដោយអត្ថថា ជាអធិបតី បញ្ញាថា ដោយអត្ថថា ក្រៃលែងជាងធម៌ទាំងនោះ វិមុត្តិថា ដោយអត្ថថា ជាខ្លឹម និព្វានដែលជាពួកអមតៈ ( របស់សត្វ ) ថា ដោយអត្ថថា ចប់ស្រេច ( នៃកិច្ចក្នុងសាសនា ) ។

## ចប់ មណ្ឌបេយ្យកថា ។

## ចប់ ភាណវារៈ ។

## ចប់ មហាវគ្គទី ១ ។

## ឧទ្ទាននៃវគ្គនោះគឺ

ក្នុងវគ្គនោះមាន ញាណ ១ ទិដ្ឋិ ១ ការដកដង្ហើមចេញ ១
ឥន្ទ្រិយ ១ វិមោក្ខជាគម្រប់ប្រាំ ១ គតិ ១ កម្ម ១
វិបល្លាស ១ មគ្គ ១ ជប់ទឹកសភាពថា ។

និកាយដ៏ប្រសើរនេះ លោកតម្កល់ទុកហើយ មិនមានធម៌ដទៃស្មើផង ជាដំបូងផង សំខាន់ផង ជាមគ្គដ៏ប្រសើរផង ។

# អដ្ឋកថា

## មណ្ឌបេយ្យកថា

[ ១ ] ឥឡូវនេះ ជាការពណ៌នាសេចក្តីតាមលំដាប់ ដែលមិនធ្លាប់ពណ៌នាក្នុងមណ្ឌបេយ្យកថា ដែលមានព្រះតម្រាស់របស់ព្រះមានព្រះភាគខ្លះជាចំណែកខាងដើម ដែលព្រះសារីបុត្តត្រេកសម្តែងភាពដែលមគ្គនោះ ជាធម៌ផូរផង់គួរក្រេបផឹក ពោលទុកហើយ ។

ក្នុងបទទាំងនោះ បទថា **មណ្ឌបេយ្យំ** មានអធិប្បាយថា ឈ្មោះថា **មណ្ឌៈ** ដោយអត្ថថា ផូរផង់ ដូចទឹកដោះថ្លាដែលដល់ព្រម ស្អាត ផូរផង់ក៏ហៅថា សប្បិមណ្ឌដូច្នោះ ។ ឈ្មោះថា **បេយ្យំ** ដោយអត្ថថា គប្បីផឹក ។ ជនទាំងឡាយផឹករបស់ណាហើយ ដួលសន្លប់ក្នុងរវាងថ្នល់ សូម្បីសំពត់ជាដើមរបស់ខ្លួន ក៏មិនទៅទីងខ្លួន វត្ថុនោះសូម្បីថ្លាក៏មិនគួរផឹក ។ ចំណែកសាសនព្រហ្មចរិយៈ ដែលសង្គ្រោះចូលក្នុងត្រៃសិក្ខារបស់ព្រះតថាគតឈ្មោះថា ផូរផង់ ព្រោះដល់ព្រម ព្រោះមិនមានមន្ទិល ព្រោះផូរផង់ និងឈ្មោះថា គួរផឹក ព្រោះនាំប្រយោជន៍និងសេចក្តីសុខមកឲ្យ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងថា ជាព្រហ្មចរិយៈដែលថ្លាគួរផឹក ។ ឈ្មោះថា **មណ្ឌបេយ្យំ** ព្រោះមានសភាពថ្លា មានវត្ថុដែលគួរផឹក ។ នោះគឺអ្វី គឺសាសនព្រហ្មចរិយៈ ។ ព្រោះហេតុអ្វី ទើបត្រៃសិក្ខា ឈ្មោះថា ព្រហ្មចរិយៈ ។ និព្វាន ឈ្មោះថា ព្រហ្ម ព្រោះអត្ថថា ឧត្តម ត្រៃសិក្ខាជាការប្រព្រឹត្តិដើម្បីប្រយោជន៍ ដល់ភាពឧត្តម ព្រោះប្រព្រឹត្តទៅដើម្បីប្រ-

យោជន៍ដល់និព្វាន ព្រោះហេតុនោះទើបហៅថា ព្រហ្មចរិយៈ សាសនព្រហ្មចរិយៈ ក៏គឺត្រៃសិក្ខានោះឯង ។

បទថា **សត្ថា សម្មុខីភូតោ** នេះជាពាក្យសម្ដែងដល់ហេតុក្នុងទីនេះ ។ ក៏ព្រោះព្រះសាស្ដាមាននៅចំពោះមុខ ហេតុនោះ អ្នកទាំងឡាយចូរប្រកបព្យាយាមហើយក្រេបផឹកការថ្វានេះចុះ ព្រោះកាលបុគ្គលក្រេបផឹកថ្នាំថ្វាដែលមានខាងក្រៅ មិនបាននៅចំពោះមុខគ្រូ រមែងមានសេចក្ដីសង្ស័យថា អញមិនដឹងប្រមាណ ឬការបន្ថែមឡើងនិងការបន្ថយចុះ តែការនៅចំពោះមុខគ្រូ ក៏អស់សេចក្ដីសង្ស័យដោយគិតថា គ្រូនឹងដឹង ។ ព្រះសាស្ដាជាធម្មសាមីរបស់ពួកយើងមាននៅចំពោះមុខយ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបទ្រង់ដឹកនាំ ក្នុងការក្រេបផឹកព្រហ្មចរិយៈដែលថ្វាថា ពួកអ្នកចូរធ្វើការព្យាយាមហើយក្រេបផឹកចុះ ។ ឈ្មោះថា **សត្ថា** ព្រោះទ្រង់តាមទូន្មានតាមសមគួរនូវទិដ្ឋធម្មិកប្រយោជន៍ សម្បរាយិកប្រយោជន៍និងបរមត្ថប្រយោជន៍ ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងបទនេះ សូម្បីដោយន័យនៃនិទ្ទេស មានពាក្យថា ព្រះមានព្រះភាគជាអ្នកនាំពួក ឈ្មោះថា **សត្ថាវាហោ** ឈ្មោះថា **សម្មុខីភូតោ** ព្រោះមានមុខប្រាកដ ជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងមណ្ឌបេយ្យនិទ្ទេស ដូចតទៅនេះថា បទថា **តិធត្តមណ្ឌោ** បានដល់ ភាពជា ៣ ប្រការ ឈ្មោះថា **តិធត្ត** សេចក្ដីថាដោយភាពជា ៣ ឈ្មោះថា **តិធត្តមណ្ឌោ** អធិប្បាយថា សភាពថ្វាដោយ ៣ យ៉ាង ។ បទថា **សត្ថរិ សម្មុខីភូតេ** នេះ លោកពោលដើម្បីសម្ដែង

គាថា ៣ ប្រការ ដែលបរិបូរណ៍ដោយអាការទាំងពួង កាលព្រះសាស្តា បរិនិព្វានហើយ គាថា ៣ ប្រការ ក៏នៅប្រព្រឹត្តទៅ ដោយចំណែកខ្លះ ប៉ុណ្ណោះ ។ ហេតុនោះឯងក្នុងនិទ្ទេសនៃបទនោះ គប្បីជ្រាបថា លោកមិន បានពោលថា កាលព្រះសាស្តាគង់នៅក្នុងចំពោះមុខ តែពោលថា ទេសនា ថា តើដូចម្តេច ជាដើម ។

បទថា **ទេសនាមយេ្ណា** បានដល់ ការថាគឺធម្មទេសនា ។ បទថា **បដិគ្គហាមយេ្ណា** បានដល់ ការថា គឺអ្នកទទួលទេសនា ។ បទថា **ព្រហ្ម-ចរិយមយេ្ណា** បានដល់ ការថា គឺមគ្គព្រហ្មចរិយៈ ។

បទថា **អាចិក្ខនា** បានដល់ ការពោលដោយឈ្មោះថា ឈ្មោះទាំង ឡាយនេះនៃសច្ចៈជាដើមដែលបុគ្គលគួរសម្តែង ។ បទថា **ទេសនា** បាន ដល់ ការចង្អុលបង្ហាញ ។ បទថា **បញ្ញបនា** បានដល់ ការឲ្យដឹង ឬ ការតាំងទុកចំពោះមុខ គឺញាណ ពិតណាស់ កាលតាំងអាសនៈទុក លោក ពោលថា ក្រាលអាសនៈ ។ បទថា **បដ្ឋបនា** បានដល់ ការបញ្ញត្តិ អធិប្បាយថា ការប្រព្រឹត្តិទៅឬការតាំងទុកចំពោះមុខ គឺញាណ ។ បទថា **វិវរណា** បានដល់ ធ្វើការបើកបង្ហាញ អធិប្បាយថា ការបើកបង្ហាញ ។ បទថា **វិភជនា** បានដល់ ធ្វើការចែក អធិប្បាយថា ការសម្តែង ដោយ ការចែក ។ បទថា **ឧត្តានីកម្មំ** បានដល់ ការធ្វើឲ្យប្រាកដច្បាស់ ។

ម្យ៉ាងវិញទៀត បទថា **អាចិក្ខនា** ជាបទសម្តែងហេតុនៃបទ ៦ មាន បទថា **ទេសនា** ជាដើម ។ លោកពោល ៦ បទ មានបទថា **ទេសនា**

ជាដើម ដើម្បីពង្រីកសេចក្ដីនៃបទថា **អាចិក្ខនា** នោះ ។ ក្នុងបទនោះ បទថា **ទេសនា** បានដល់ ការសម្ដែងដោយលើកមាតិកាឡើងមុនដោយសង្ខេបដោយអំណាចនៃឧគ្ឃដិតញ្ញូបុគ្គល ព្រោះឧគ្ឃដិតញ្ញូបុគ្គល រមែងដឹងច្បាស់ ចាក់ធ្លុះបទដែលលោកពោលដោយសង្ខេបនិងពោលឡើងមុន ។ បទថា **បញ្ញបនា** បានដល់ ការបញ្ញត្តិដោយអំណាចនៃវិបញ្ចិតញ្ញូបុគ្គល គឺដោយអំណាចចង្អុលបង្ហាញបទ ដែលសង្ខេបទុកក្នុងពេលដំបូង ដោយពិស្ដារដោយការពេញចិត្ត និងដោយការមុតស្រួចនៃបញ្ញារបស់វិបញ្ចិតញ្ញូ-បុគ្គលទាំងនោះ ។ បទថា **បដ្ឋបនា** បានដល់ ការបញ្ញត្តិដោយការធ្វើឲ្យពិស្ដារក្រៃលែងឡើង ដោយអំណាចសម្ដែងសរុបនិទ្ទេស ដែលសម្ដែងដល់វិបញ្ចិតញ្ញូបុគ្គលទាំងនោះនោះឯង ។ បទថា **វិវរណា** បានដល់ ការបើកបង្ហាញដោយការពោលពាក្យ ដែលលោកសម្ដែងទុកហើយរឿយៗ ។ បទថា **វិភជនា** បានដល់ ការចែកដោយការធ្វើការចែក សូម្បីពាក្យដែលលោកពោលទុកហើយរឿយៗ ។ បទថា **ឧត្តានីកម្មំ** បានដល់ ការធ្វើឲ្យងាយ ដោយការពោលធ្វើពាក្យដែលលោកបើកផ្ចារហើយ ដោយពិស្ដារ និងដោយការពោលសម្ដែងពាក្យដែលលោកចែកទុកហើយ ។ ទេសនានេះរមែងមានដើម្បីការចាក់ធ្លុះ សូម្បីរបស់នេយ្យបុគ្គលទាំងឡាយ ។

បទថា **យេ វា បនញ្ញេបិ កេចិ** លោកពោលសំដៅដល់វិនិបាតិកៈមានមាតារបស់បិយង្ករៈជាដើម ។ បទថា **វិញ្ញាតារោ** បានដល់ អ្នកដឹងច្បាស់លោកុត្តរធម៌ដោយការចាក់ធ្លុះ ។ ពិតណាស់ លោកអ្នកដឹងច្បាស់

ទាំងនេះ មានភិក្ខុជាដើម ឈ្មោះថា **បដិគ្គហា** ( អ្នកទទួល ) ព្រោះទទួលព្រះធម្មទេសនា ដោយអំណាចការចាក់ធ្លុះ ។ បទថា **អយមេវ** ជាដើម មានសេចក្ដីដូចលោកពោលទុកហើយ ក្នុងនិទ្ទេសនៃបឋមជ្ឈាន ។ អរិយមគ្គ លោកហៅថាជាព្រហ្មចរិយៈ ព្រោះជាការប្រព្រឹត្តិដើម្បីប្រយោជន៍ដល់ធម៌ដ៏ប្រសើរ ព្រោះកំណត់ដោយនិព្វាន ។

[ ២ ] ឥឡូវនេះព្រះសារីបុត្តត្ថេរសម្ដែងប្រកបឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ និងអង្គនៃមគ្គដែលមាននៅក្នុងខណៈនៃមគ្គនោះ ក្នុងវិធីនៃព្រហ្មចរិយៈដែលថ្លាគួរផឹក ដោយបទថា **អធិមោក្ខមណ្ឌោ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **អធិមោក្ខមណ្ឌោ** បានដល់ ការថ្លា ពោលគឺការបង្អោនចិត្តជឿ ។ បទថា **កសដោ** បានដល់ ជារបស់ល្អក់ ប្រាសចាកការជ្រះថ្លា ។ បទថា **ឆឌ្ឌេត្វា** បានដល់ លះដោយអំណាចកាត់ផ្ដាច់ ។ បទថា **សទ្ធិន្ទ្រិយស្ស អធិមោក្ខមណ្ឌំ បិវតីតិ មណ្ឌបេយ្យំ** អធិប្បាយថា កាលការថ្លា គឺការបង្អោនចិត្តជឿ មិនជាដទៃអំពីសទ្ធិន្ទ្រិយ លោកក៏ពោលធ្វើឲ្យជាដទៃដោយអំណាចនៃវោហារ កូនត្បាល់បុកក្នុងលោក សូម្បីខ្លួនត្បាល់បុកមិនជាដទៃមាន លោកក៏ហៅថា ខ្លួននៃកូនត្បាល់បុក ( អង្រែ ) យ៉ាងណា ម្យ៉ាងទៀត ក្នុងបាលីលោកពោលភាវៈមិនជាយ៉ាងដទៃចាកធម៌ក្នុងពាក្យថា ការពាល់ត្រូវ □**ផុសិតត្តំ** □ជាដើម ដូចជាយ៉ាងដទៃយ៉ាងណា ម្យ៉ាងទៀត ក្នុងអដ្ឋកថា លោកពោលដល់លក្ខណៈមិនជាយ៉ាងដទៃចាកធម៌ក្នុងពាក្យថា ផស្សៈមានការពាល់ត្រូវជាលក្ខណៈជាដើម ដូចជា

យ៉ាងដទៃ យ៉ាងណា គប្បីជ្រាបថា សេចក្តីនេះ ក៏យ៉ាងនោះ(១)ក្នុងបទថា **ចិវតិ** នេះ លោកពោលដល់បុគ្គល ដែលដល់ព្រមដោយសទ្ធិន្ទ្រិយជាដើមនោះ ។ មានពាក្យអធិប្បាយថា ព្រោះធ្វើវិគ្គហៈថា បុគ្គលដែលដល់ព្រមដោយសទ្ធិន្ទ្រិយជាដើមនោះ រមែងផឹកនូវការថ្វានោះ ទើបការថ្វានោះឈ្មោះថា ជាព្រហ្មចរិយៈថ្វាគួរផឹក ព្រោះបុគ្គលនោះគប្បីផឹក ។ ម្យ៉ាងទៀត កាលគួរពោលថា **មណ្ឌបេយ្យោ** លោកធ្វើជាលិង្គវិបល្លាសថា **មណ្ឌបេយ្យំ** ។ គប្បីជ្រាបអត្ថនៃពាក្យដ៏សេសដោយន័យនេះ ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងបទដែលមិនធ្លាប់ពោល ដូចតទៅនេះថា បទថា **បរិឡាហោ** បានដល់ ការក្តៅក្រហាយ ព្រោះកិលេសដែលជាបដិបក្ខចំពោះបីតិ ដែលមានលក្ខណៈពេញចិត្ត ។ បទថា **ឧទ្ធច្ចំ** បានដល់ សភាពគ្រោតគ្រាត គឺការមិនស្ងប់ដោយអំណាចកិលេស ដែលជាបដិបក្ខចំពោះសេចក្តីស្ងប់ ។ បទថា **អប្បដិសង្ខា** បានដល់ ការនាំសេចក្តីមិនស្ងប់មកដោយអំណាចកិលេស ដែលជាបដិបក្ខចំពោះការពិចារណា ។

[ ៣ ] ព្រះសារីបុត្តត្ថេរ បំណាងនឹងសម្តែងដល់វិធីនៃព្រហ្មចរិយៈដែលថ្វាគួរផឹក ដោយបរិយាយដទៃទៀត ទើបពោលបទថា **អត្ថិ មណ្ឌោ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **តត្ថ** បានដល់ ក្នុងសទ្ធិន្ទ្រិយនោះ ។

---

១-វោហារក□លោកកាលបើគេពោលថា ចូរយកត្បាល់មក ក□ូចជាឲ្យយកអង្រែមកផង កាលបើគេពោលថា ចូរយកអង្រែមក ក៏ដូចជាឲ្យយកត្បាល់មកផង យ៉ាងណា ក្នុងធម៌កាលបើលោកពោលថា ផស្ស□ក□ូចជាពោលដល់ផុសិតត□□លក□□របស់ផស្ស□□កាលបើលោកពោលថាផុសិតត□ក□ូចជាពោលដល់ផស្ស□ង

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **អត្ថរសោ** ជាដើម ដូចតទៅនេះថា ការបង្អោនចិត្តជឿ ជាអត្ថនៃសទ្ធិន្ទ្រិយ សទ្ធិន្ទ្រិយជាធម៌ សទ្ធិន្ទ្រិយនោះឯងឈ្មោះថា **វិមុត្តិ** ព្រោះផុតចាកកិលេសផ្សេងៗ ការដល់ព្រមនៃអត្ថនោះឈ្មោះថា **អត្ថរសោ** ការដល់ព្រមនៃធម៌នោះ ឈ្មោះថា **ធម្មរសោ** ការដល់ព្រមនៃវិមុត្តិនោះ ឈ្មោះថា **វិមុត្តិរសោ** ។

ម្យ៉ាងវិញទៀត ការត្រេកអរក្នុងការបានអត្ថ ឈ្មោះថា អត្ថរស ។ ការត្រេកអរក្នុងការបានធម៌ ឈ្មោះថា ធម្មរស ។ ការត្រេកអរក្នុងការបានវិមុត្តិ ឈ្មោះថា វិមុត្តិរស ។ បទថា **រតិ** បានដល់ បីតិដែលសម្បយុត្តដោយរសនោះឬមានរសនោះជាអារម្មណ៍ ។ គប្បីជ្រាបអត្ថក្នុងបទដ៏សេសដោយន័យនេះ ។

ក្នុងបរិយាយនេះ លោកពោលអត្ថទុកថា ព្រហ្មចរិយៈថ្វាគួរក្រេបផឹកឈ្មោះថា **មណ្ឌបេយ្យំ** ។

[ ៤ ] ព្រះសារីបុត្តត្ថេរ កាលសម្តែងព្រហ្មចរិយៈដែលថ្វាគួរក្រេបផឹកដោយអំណាចនៃឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈនិងអង្គនៃមគ្គ តាមលំដាប់នៃពោធិបក្ខិយធម៌ មានឥន្ទ្រិយជាដើមយ៉ាងនេះហើយ កាលនឹងសម្តែងភាពថ្វានៃព្រហ្មចរិយៈ ដែលតាំងនៅក្នុងទីបំផុតទៀត ។ ទើបសម្តែងអង្គនៃមគ្គពោជ្ឈង្គៈ ពលៈ និងឥន្ទ្រិយដោយអំណាចបញ្ច្រាស់លំដាប់ ធ្វើមគ្គឲ្យជាធម៌ចាប់ផ្តើម ព្រោះមគ្គជាប្រធាន ។

បទថា **អាធិបតេយ្យដ្ឋេន ឥន្ទ្រិយា មណ្ឌោ** ជាដើម ជាការផ្សំ

ដែលជាលោកិយៈនិងជាលោកុត្តរៈ តាមដែលប្រកបទុក ។ គប្បីជ្រាបបទនោះដោយន័យដូចធ្លាប់ពោលទុកហើយ ។

ម្យ៉ាងទៀត ក្នុងបទនេះថា **តថដ្ឋេន សច្ចា មណ្ណា** គប្បីជ្រាបថា លោកពោលថា សច្ចញ្ញាណជាសច្ចៈ ព្រោះមិនមានទុក្ខសមុទយៈ ជាភាពថ្វា ដូចក្នុងមហាហត្ថិបទសូត្រ ( មហាហត្ថិបទោបមសូត្រ ) ។

អដ្ឋកថា មណ្ឌបេយ្យកថា ចប់

អដ្ឋកថា មហាវគ្គ ចប់

# សុត្តន្តបិដក

## យុគនទ្ធវគ្គ យុគនទ្ធកថា

[ ៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយព្រះអានន្ទមានអាយុគង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ ក្នុងទីនោះឯង ព្រះអានន្ទមាន-អាយុបានហៅពួកភិក្ខុថា ម្នាលអាវុសោទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះអានន្ទមានអាយុថា ករុណាអាវុសោ ។ ព្រះអានន្ទមានអាយុបានពោលពាក្យនេះថា ម្នាលអាវុសោទាំងឡាយ បព្វជិតណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី ព្យាករអរហត្តក្នុងសម្នាក់ខ្ញុំ ដោយមគ្គ ៤ សព្វគ្រប់ ឬដោយមគ្គទាំងនុ៎ះ មគ្គណាមួយ តើមគ្គទាំង ៤ ដូចម្តេចខ្លះ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនវិបស្សនា មានសមថៈជាប្រធាន កាលភិក្ខុនោះចម្រើនវិបស្សនា មានសមថៈជាប្រធាន មគ្គរមែងកើតឡើង ភិក្ខុនោះឈ្មោះថា សេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលភិក្ខុនោះសេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ ភិក្ខុនោះក៏លះបង់សញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស ។

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុចម្រើនសមថៈ មានវិបស្ស-នាជាប្រធាន កាលភិក្ខុនោះចម្រើនសមថៈ មានវិបស្សនាជាប្រធាន មគ្គក៏កើតឡើង ភិក្ខុនោះឈ្មោះថា សេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលភិក្ខុនោះសេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ ភិក្ខុនោះក៏លះសញ្ញោ-ជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស ។

ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា កាលភិក្ខុនោះចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនានោះ មគ្គក៏កើតឡើង ភិក្ខុនោះឈ្មោះថា សេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលភិក្ខុនោះសេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស ។

ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ភិក្ខុមានចិត្តមិនជ្រួលច្រាល់ដោយឧទ្ធច្ចៈក្នុងធម៌ ម្នាលអាវុសោទាំងឡាយ មានសម័យដែលចិត្តឋិតល្អតាំងនៅស៊ប់ ជាចិត្តខ្ពស់ឯក តាំងនៅមាំ មគ្គរបស់ភិក្ខុនោះក៏កើតឡើង ភិក្ខុនោះឈ្មោះថា សេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ កាលភិក្ខុនោះសេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស ។ ម្នាលអាវុសោទាំងឡាយ បព្វជិតណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី តែងព្យាករអរហត្ត ក្នុងសម្នាក់ខ្ញុំដោយមគ្គទាំង ៤ នេះសព្វគ្រប់ ឬដោយមគ្គទាំងនុ៎ះ មគ្គណាមួយ ។

[ ៦ ] ភិក្ខុចម្រើនវិបស្សនា មានសមថៈជាប្រធានតើដូចម្តេច ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយដោយអំណាចនៃនេក្ខម្មៈ ឈ្មោះថា សមាធិ ឈ្មោះថា វិបស្សនា ដោយអត្ថថា ឃើញរឿយ ៗ ថាមិនទៀង ឈ្មោះថា វិបស្សនា ដោយអត្ថថា ឃើញរឿយ ៗ ថាជាទុក្ខ ឈ្មោះថា វិបស្សនា ដោយអត្ថថា ឃើញរឿយ ៗ ថាមិនមែនខ្លួននូវធម៌ទាំងឡាយដែលកើតក្នុងសមាធិនោះ ។ សមថៈ ( កើត ) មុន វិបស្សនា ( កើត )

ក្រោយ ហេតុនោះ លោកពោលថា ភិក្ខុចម្រើនវិបស្សនា មានសមថៈជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចម្រើន បានដល់កាលចម្រើន ( ភាវនា ) ៤ យ៉ាង គឺការចម្រើន ដោយអត្ថថា មិនកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ ១ ការចម្រើន ដោយអត្ថថា មានរសតែមួយនៃឥន្ទ្រិយទាំងឡាយ ១ ការចម្រើន ដោយអត្ថថា នាំទៅដោយវិរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ ១ ការចម្រើន ដោយអត្ថថា ឧស្សាហ៍សេព ១ ។

សំណួរត្រង់ពាក្យថា មគ្គក៏កើតឡើង តើមគ្គកើតឡើងដូចម្តេច មគ្គគឺសម្មាទិដ្ឋិ ដោយអត្ថថា ឃើញកើតឡើង មគ្គគឺសម្មាសង្កប្បៈ ដោយអត្ថថា លើកចិត្តឡើង ( កាន់អារម្មណ៍ ) កើតឡើង មគ្គ គឺសម្មាវាចា ដោយអត្ថថា កំណត់កើតឡើង មគ្គគឺសម្មាកម្មន្តៈ ដោយអត្ថថា ខ្នះខ្នែងកើតឡើង មគ្គគឺសម្មាអាជីវៈ ដោយអត្ថថា ផូរផង់កើតឡើង មគ្គគឺសម្មា-វាយាមៈ ដោយអត្ថថា ផ្គងទុកកើតឡើង មគ្គគឺសម្មាសតិ ដោយអត្ថថា ប្រុងកើតឡើង មគ្គគឺសម្មាសមាធិ ដោយអត្ថថា មិនរាយមាយកើតឡើង មគ្គកើតឡើង យ៉ាងនេះឯង ។

អធិប្បាយពាក្យថា ភិក្ខុនោះឈ្មោះថា សេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ ត្រង់ពាក្យថា សេព តើសេពដូចម្តេច ។ ភិក្ខុកាលនឹករំពឹងរក ( នូវមគ្គ ) ឈ្មោះថា សេព កាលដឹង ឈ្មោះថា សេព កាលឃើញ ឈ្មោះថា សេព កាលពិចារណា ឈ្មោះថា សេព កាលអធិដ្ឋាននូវចិត្ត

ឈ្មោះថា សេព កាលជឿស៊ប់ដោយសទ្ធា ឈ្មោះថា សេព កាលផ្គង នូវព្យាយាម ឈ្មោះថា សេព កាលប្រុងនូវស្មារតី ឈ្មោះថា សេព កាលតម្កល់ទុកនូវចិត្ត ឈ្មោះថា សេព កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថា សេព កាលដឹងចំពោះនូវធម៌ដែលគួរដឹង ឈ្មោះថា សេព កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង ឈ្មោះថា សេព កាលលះ នូវធម៌ដែលគួរលះ ឈ្មោះថា សេព កាលចម្រើននូវធម៌ដែលគួរចម្រើន ឈ្មោះថា សេព ភិក្ខុកាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា សេព ភិក្ខុសេព យ៉ាងនេះឯង ។

សំណួរត្រង់ពាក្យថា ចម្រើន តើចម្រើនដូចម្ដេច ។ ភិក្ខុកាលនឹករំពឹងរក ឈ្មោះថា ចម្រើន កាលដឹង ឈ្មោះថា ចម្រើន កាលឃើញ ឈ្មោះថា ចម្រើន កាលពិចារណា ឈ្មោះថា ចម្រើន កាលអធិដ្ឋាននូវចិត្ត ឈ្មោះថា ចម្រើន កាលជឿស៊ប់ដោយសទ្ធា ឈ្មោះថា ចម្រើន កាលផ្គងព្យាយាម ឈ្មោះថា ចម្រើន កាលប្រុងស្មារតី ឈ្មោះថា ចម្រើន កាលតម្កល់ទុកនូវចិត្ត ឈ្មោះថា ចម្រើន កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថាចម្រើន កាលដឹងចំពោះនូវធម៌ដែលគួរដឹង ឈ្មោះថា ចម្រើន កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង ឈ្មោះថា ចម្រើន កាលលះនូវធម៌ដែលគួរលះ ឈ្មោះថា ចម្រើន កាលចម្រើននូវធម៌ដែលគួរចម្រើន ឈ្មោះថា ចម្រើន កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា ចម្រើន ភិក្ខុចម្រើន យ៉ាងនេះឯង ។

សំណួរត្រង់ពាក្យថា ធ្វើឲ្យច្រើន តើធ្វើឲ្យច្រើនដូចម្តេច ។ ភិក្ខុកាលនឹករំពឹងរក ឈ្មោះថា ធ្វើឲ្យច្រើន កាលដឹង ឈ្មោះថា ធ្វើឲ្យច្រើន កាលឃើញ ឈ្មោះថា ធ្វើឲ្យច្រើន កាលពិចារណា ឈ្មោះថា ធ្វើឲ្យច្រើន កាលអធិដ្ឋាននូវចិត្ត ឈ្មោះថា ធ្វើឲ្យច្រើន កាលជឿស៊ប់ដោយសទ្ធា ឈ្មោះថា ធ្វើឲ្យច្រើន កាលផ្គងព្យាយាម ឈ្មោះថា ធ្វើឲ្យច្រើន កាលប្រុងស្មារតី ឈ្មោះថា ធ្វើឲ្យច្រើន កាលតម្កល់ទុកនូវចិត្ត ឈ្មោះថា ធ្វើឲ្យច្រើន កាលដឹងច្បាស់ដោយបញ្ញា ឈ្មោះថា ធ្វើឲ្យច្រើន កាល ដឹងចំពោះនូវធម៌ដែលគួរដឹង ឈ្មោះថា ធ្វើឲ្យច្រើន កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង ឈ្មោះថា ធ្វើឲ្យច្រើន កាលលះនូវធម៌ដែលគួរលះ ឈ្មោះថា ធ្វើឲ្យច្រើន កាលចម្រើននូវធម៌ដែលគួរចម្រើន ឈ្មោះថា ធ្វើឲ្យច្រើន កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា ធ្វើឲ្យច្រើន ភិក្ខុធ្វើឲ្យច្រើនយ៉ាងនេះឯង ។

សំណួរត្រង់ពាក្យថា កាលភិក្ខុនោះសេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយ ក៏វិនាស តើភិក្ខុលះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយ ក៏វិនាស ដូចម្តេច ។ ភិក្ខុលះសញ្ញោជនៈ ៣ នេះគឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស អនុស័យ ២ នេះគឺ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យក៏វិនាសដោយសោតាបត្តិមគ្គ ។

លះសញ្ញោជនៈ ២ នេះគឺកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏

គ្រោតគ្រាត អនុស័យ ២ នេះគឺ កាមរាគានុស័យ បដិឃានុស័យដ៏គ្រោតគ្រាតក៏វិនាសដោយសកទាគាមិមគ្គ ។

លះសញ្ញោជនៈ ២ នេះគឺកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏ល្អិត អនុស័យ ២ នេះគឺ កាមរាគានុស័យ បដិឃានុស័យដ៏ល្អិត ក៏វិនាសដោយអនាគាមិមគ្គ ។

លះសញ្ញោជនៈ ៥ នេះគឺ រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា អនុស័យ ៣ នេះគឺ មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ក៏វិនាសដោយអរហត្តមគ្គ កិក្ខុលះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស យ៉ាងនេះឯង ។

[ ៧ ] ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយដោយអំណាចឥតព្យាបាទ ឈ្មោះថា សមាធិ ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃការសម្គាល់ពន្លឺ ឈ្មោះថា សមាធិ ។បេ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃដង្ហើមចេញរបស់បុគ្គលអ្នកឃើញរឿយៗក្នុងការរលាស់ខ្លួនចេញ ... ដោយចំណាចនៃដង្ហើមចូលរបស់បុគ្គលអ្នកឃើញរឿយ ៗ ក្នុងការរលាស់ខ្លួនចេញ ឈ្មោះថា សមាធិ ឈ្មោះថា វិបស្សនា ដោយអត្ថថា ឃើញរឿយ ៗ ថាមិនទៀង ឈ្មោះថា វិបស្សនា ដោយអត្ថថា ឃើញរឿយ ៗ ថាជាទុក្ខ ឈ្មោះថា វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ថាមិនមែនខ្លួននូវធម៌ទាំងឡាយដែលកើតក្នុងសមាធិនោះ សមថៈ ( កើត ) មុន វិបស្សនា ( កើត ) ក្រោយ

ហេតុនោះលោកពោលថា ភិក្ខុចម្រើនវិបស្សនា មានសមថៈជាប្រធានដោយប្រការដូច្នេះ ។

ពាក្យថាចម្រើន បានដល់ការចម្រើន ( ភាវនា ) ៤ យ៉ាងគឺ ការចម្រើន ដោយអត្ថថា មិនកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងសមាធិនោះ ១ ការចម្រើន ដោយអត្ថថា មានរសតែមួយនៃឥន្ទ្រិយទាំងឡាយ ១ ការចម្រើន ដោយអត្ថថា នាំទៅដោយវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ ១ ការចម្រើនដោយអត្ថថា ឧស្សាហ៍សេព ១ ។

សំណួរត្រង់ពាក្យថា មគ្គក៏កើតឡើង តើមគ្គកើតឡើងដូចម្តេច ។ មគ្គគឺសម្មាទិដ្ឋិ ដោយអត្ថថា ឃើញកើតឡើង មគ្គគឺសម្មាសង្កប្បៈ ដោយអត្ថថា លើកចិត្តឡើង ( កាន់អារម្មណ៍ ) កើតឡើង ។បេ។ មគ្គ គឺសម្មាសមាធិ ដោយអត្ថថា មិនរាយមាយកើតឡើង មគ្គកើតឡើងយ៉ាងនេះឯង ។

អធិប្បាយពាក្យថា ភិក្ខុនោះឈ្មោះថា សេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ ត្រង់ពាក្យថា សេព តើសេពដូចម្តេច ។ ភិក្ខុកាលនឹករំពឹងរក ឈ្មោះថា សេព កាលដឹង ឈ្មោះថា សេព ។បេ។ កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា សេព ភិក្ខុសេពយ៉ាងនេះឯង ។

សំណួរត្រង់ពាក្យថា ចម្រើន តើចម្រើនដូចម្តេច ។ ភិក្ខុកាលនឹករំពឹងរក ( នូវមគ្គ ) ឈ្មោះថា ចម្រើន កាលដឹង ឈ្មោះថា ចម្រើន ។បេ។ កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា ចម្រើន ភិក្ខុ

ចម្រើន យ៉ាងនេះឯង ។

សំណួរត្រង់ពាក្យថា ធ្វើឲ្យច្រើន តើធ្វើឲ្យច្រើនដូចម្តេច ។ ភិក្ខុកាលនឹករំពឹង ( នូវមគ្គ ) ឈ្មោះថា ធ្វើឲ្យច្រើន កាលដឹង ឈ្មោះថា ធ្វើឲ្យច្រើន ។បេ។ កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាធ្វើឲ្យច្រើន ភិក្ខុធ្វើឲ្យច្រើន យ៉ាងនេះឯង ។

សំណួរត្រង់ពាក្យថា កាលភិក្ខុនោះសេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាស តើភិក្ខុលះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយ ក៏វិនាស ដូចម្តេចខ្លះ ។

ភិក្ខុលះសញ្ញោជនៈ ៣ នេះគឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសដោយសោតាបត្តិមគ្គ អនុស័យ ២ នេះគឺ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យក៏វិនាស ។

ភិក្ខុលះសញ្ញោជនៈ ២ នេះគឺ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏គ្រោតគ្រាតដោយសកទាគាមិមគ្គ អនុស័យ ២ នេះគឺ កាមរាគានុស័យ បដិឃានុស័យដ៏គ្រោតគ្រាតក៏វិនាស ។

ភិក្ខុលះសញ្ញោជនៈ ២ នេះគឺ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈដ៏ល្អិតដោយអនាគាមិមគ្គ អនុស័យ ២ នេះគឺ កាមរាគានុស័យ បដិឃានុស័យដ៏ល្អិតក៏វិនាស ។

ភិក្ខុលះសញ្ញោជនៈ ៥ នេះគឺ រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជាដោយអរហត្តមគ្គ អនុស័យ ៣ នេះគឺ មានានុស័យ ភវរាគានុស័យ

អវិជ្ជានុស័យក៏វិនាស ភិក្ខុលះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាសយ៉ាងនេះ ភិក្ខុចម្រើនវិបស្សនា មានសមថៈជាប្រធានយ៉ាងនេះឯង ។

[ ៨ ] ភិក្ខុចម្រើនសមថៈ មានវិបស្សនាជាប្រធាន តើដូចម្តេច ។ វិបស្សនា ដោយអត្ថថា ឃើញរឿយ ៗ ថាមិនទៀង វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ថាជាទុក្ខ វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ថាមិនមែនខ្លួន មួយទៀត ភាពនៃធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ មានអារម្មណ៍គួរលះ ភាពនៃចិត្តមានអារម្មណ៍តែមួយ កាលមិនរាយមាយ ឈ្មោះថា សមាធិ វិបស្សនា ( កើត ) មុន សមថៈ ( កើត ) ក្រោយ ហេតុនោះលោកពោលថា ភិក្ខុចម្រើនសមថៈមានវិបស្សនាជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន ៤ យ៉ាង ។បេ។ ការចម្រើនដោយអត្ថថា ឧស្សាហ៍សេព ។បេ។ សំណួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើងដូចម្តេច ។បេ។ មគ្គកើតឡើងយ៉ាងនេះ ។បេ។ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាសយ៉ាងនេះ ។ វិ-បស្សនា ដោយអត្ថថា ឃើញរឿយៗនូវរូប ថាមិនទៀង វិបស្សនា ដោយអត្ថថា ឃើញរឿយៗនូវរូប ថាជាទុក្ខ វិបស្សនា ដោយអត្ថថា ឃើញរឿយៗនូវរូប ថាមិនមែនខ្លួន មួយទៀត ភាពនៃធម៌ទាំងឡាយដែលកើតក្នុងសមាធិនោះមានអារម្មណ៍គួរលះ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ ឈ្មោះថា សមាធិ វិបស្សនា ( កើត ) មុន សមថៈ

( កើត ) ក្រោយ ហេតុនោះលោកពោលថា ភិក្ខុចម្រើនសមថៈ មានវិបស្សនាជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន ៤ យ៉ាង ។បេ។ ការចម្រើនដោយអត្ថថាឧស្សាហ៍សេព ។បេ។ សំណួរត្រង់ពាក្យថា មគ្គកើតឡើង ។បេ។ មគ្គកើតឡើងយ៉ាងនេះ ។បេ។ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុ-ស័យទាំងឡាយក៏វិនាស ។ វិបស្សនា ដោយអត្ថថា ឃើញរឿយៗនូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ នូវជរា មរណៈ ថាមិនទៀង វិបស្សនា ដោយអត្ថថា ឃើញរឿយៗនូវជរាមរណៈ ថាជាទុក្ខ ។បេ។ ថាមិនមែនខ្លួន មួយទៀត ភាពនៃធម៌ទាំងឡាយដែលកើតក្នុងសមាធិនោះ មានអារម្មណ៍គួរលះ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ ឈ្មោះថា សមាធិ វិបស្សនា ( កើត ) មុន សមថៈ ( កើត ) ក្រោយ ហេតុនោះលោកពោលថា ភិក្ខុចម្រើនសមថៈ មានវិបស្សនាជាប្រធាន ដោយប្រការដូច្នេះ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន ៤ យ៉ាង ។បេ។ សំណួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើងដូចម្តេច ។បេ។ មគ្គកើតឡើងយ៉ាងនេះ ។បេ។ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាសយ៉ាងនេះ ភិក្ខុចម្រើនសមថៈ មានវិបស្សនាជាប្រធាន យ៉ាងនេះឯង ។

[ ៩ ] ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា តើ

ដូចម្តេច ។ ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនាដោយអាការៈ ១៦ គឺដោយអត្ថថា ជាអារម្មណ៍ ១ ដោយអត្ថថា ជាគោចរ ១ ដោយអត្ថថា លះបង់ ១ ដោយអត្ថថា លះស្រឡះ ១ ដោយអត្ថថា ចេញ ១ ដោយអត្ថថា ប្រែត្រឡប់ ១ ដោយអត្ថថា ស្ងប់ ១ ដោយអត្ថថា ឧត្តម ១ ដោយអត្ថថា រួចស្រឡះ ១ ដោយអត្ថថា មិនមានអាសវៈ ១ ដោយអត្ថថា ឆ្លង ១ ដោយអត្ថថា មិនមាននិមិត្ត ១ ដោយអត្ថថា មិនមានទីតម្កល់ ១ ដោយអត្ថថា សូន្យ ១ ដោយអត្ថថា មានរសតែមួយ ១ ដោយអត្ថថា មិនកន្លងជាប់គ្នាជាគូនឹងគ្នា ១ ។

ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ជាអារម្មណ៍ តើដូចម្តេច ។ កាលបុគ្គលលះឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយគឺសមាធិ មាននិរោធជាអារម្មណ៍ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថា ឃើញរឿយៗក៏មាននិរោធជាអារម្មណ៍ដែរ សមថៈនិងវិបស្សនា ដោយអត្ថថា ជាអារម្មណ៍ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះលោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ជាអារម្មណ៍ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន ៤ យ៉ាង ។បេ។ ការចម្រើនដោយអត្ថថា ឧស្សាហ៍សេព ។បេ។ សំណួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើង ដូចម្តេច ។បេ។ មគ្គកើតឡើងយ៉ាងនេះ ភិក្ខុនោះលះ

សញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាសយ៉ាងនេះ ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ជាអារម្មណ៍យ៉ាងនេះឯង ។

ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថាជាគោចរ តើដូចម្ដេច ។ កាលបុគ្គលលះឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ក៏មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា ជាគោចរ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះលោកទើបពោលថា ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ជាគោចរ ។

[ ១០ ] ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា លះបង់ តើដូចម្ដេច ។ កាលបុគ្គលលះនូវកិលេស ដែលប្រឡំដោយឧទ្ធច្ចៈផង នូវខន្ធផង ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលលះនូវកិលេសដែលប្រឡំដោយអវិជ្ជាផង នូវខន្ធផង វិបស្សនា ដោយអត្ថថា ឃើញរឿយ ៗ ក៏មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា លះបង់ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នា

ជាគូ គឺសមថៈ និងវិបស្សនា ដោយអត្ថថា លះបង់ ។

កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា លះស្រឡះ តើដូចម្តេច ។ កាលបុគ្គលលះស្រឡះនូវកិលេស ដែលប្រឡំដោយឧទ្ធច្ចៈផង នូវខន្ធផង ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលលះស្រឡះនូវកិលេស ដែលប្រឡំដោយអវិជ្ជាផង នូវខន្ធផង វិបស្សនា ដោយអត្ថថា ឃើញរឿយ ៗ ក៏មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា លះស្រឡះ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា កិច្ចចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា លះស្រឡះ ។

កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ចេញ តើដូចម្តេច ។ កាលបុគ្គលចេញចាកកិលេស ដែលប្រឡំដោយឧទ្ធច្ចៈផង ចាកខន្ធផង ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលចេញចាកកិលេស ដែលប្រឡំដោយអវិជ្ជាផង ចាកខន្ធផង វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ក៏មាននិរោធជាគោចរដែរ សមថៈ និងវិបស្សនា ដោយអត្ថថា ចេញ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះលោកទើបពោលថា កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈ និងវិបស្សនា ដោយអត្ថថា ចេញ ។

កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈ និងវិបស្សនា ដោយអត្ថថា ប្រែត្រឡប់ តើដូចម្តេច ។ កាលបុគ្គលប្រែត្រឡប់ចាកកិលេសដែលប្រឡំ ដោយឧទ្ធច្ចៈផង ចាកខន្ធផង ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលប្រែត្រឡប់ចាកកិលេសដែលប្រឡំដោយអវិជ្ជាផង ចាកខន្ធផង វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ក៏មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា ប្រែត្រឡប់ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ប្រែត្រឡប់ ។

[ ១១ ] កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ល្អិត តើដូចម្តេច ។ កាលបុគ្គលលះឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌ដ៏ល្អិត មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ក៏ជាគុណជាតិដ៏ល្អិត មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា ល្អិត ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រ-ការដូច្នេះ ព្រោះហេតុនោះលោកទើបពោលថា កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ល្អិត ។

កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ឧត្តម តើដូចម្តេច ។ កាលបុគ្គលលះឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែ

មួយ ការមិនរាយមាយ គឺសមាធិ ជាធម៌ដ៏ឧត្តម មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ក៏ជាគុណជាតិដ៏ឧត្តម មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា ឧត្តម ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះលោកទើបពោលថា កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ឧត្តម ។

កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា របស្រឡះ តើដូចម្តេច ។ កាលបុគ្គលលះនូវឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌របស្រឡះ មាននិរោធជាគោចរ កាលបុគ្គលលះនូវអវិជ្ជា វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ក៏ជាគុណជាតិរបស្រឡះ មាននិរោធជាគោចរដែរ បន្ទាប់មក ចេតោវិមុត្តិ ព្រោះការរសាយចេញចាករាគៈ បញ្ញាវិមុត្តិ ព្រោះការរសាយចេញចាកអវិជ្ជា ( ក៏កើតមាន ) សមថៈនិងវិបស្សនា ដោយអត្ថថា របស្រឡះ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា កិច្ចចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា របស្រឡះ ។

[ ១២ ] កិច្ចចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈ និងវិបស្សនា ដោយអត្ថថា មិនមានអាសវៈ តើដូចម្តេច ។ កាលបុគ្គលលះនូវឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌មិន

មានអាសវៈ ដោយកាមាសវៈ មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ក៏ជាគុណជាតិ មិនមានអាសវៈ ដោយអវិជ្ជាសវៈ មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា មិនមានអាសវៈ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះលោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា មិនមានអាសវៈ ។

ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ឆ្លង តើដូចម្តេច ។ កាលបុគ្គលឆ្លងចាកកិលេស ដែលប្រទូស្តដោយឧទ្ធច្ចៈផង ចាកខន្ធផង ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ មាននិរោធជាគោចរ កាលបុគ្គលឆ្លងចាកកិលេសដែលប្រទូស្តដោយអវិជ្ជាផង ចាកខន្ធផង វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ក៏មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា ឆ្លង ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះលោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា ឆ្លង ។

ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា មិនមាននិមិត្ត តើដូចម្តេច ។ កាលបុគ្គលលះនូវឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌មិនមាននិមិត្ត ដោយ

និមិត្តទាំងពួង មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថា ឃើញរឿយ ៗ ក៏ជាគុណជាតិមិនមាននិមិត្ត ដោយនិមិត្តទាំងពួងមាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា មិនមាននិមិត្តជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា មិនមាននិមិត្ត ។

ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា មិនមានទីតម្កល់ តើដូចម្តេច ។ កាលបុគ្គលលះនូវឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌មិនមានទីតម្កល់ដោយទីតម្កល់ទាំងពួង មាននិរោធជាគោចរ កាលបុគ្គលលះនូវអវិជ្ជា វិបស្សនា ដោយអត្ថថា ឃើញរឿយៗ ក៏ជាគុណជាតិមិនមានទីតម្កល់ ដោយទីតម្កល់ទាំងពួង មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា មិនមានទីតម្កល់ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះលោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា មិនមានទីតម្កល់ ។

ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា សូន្យ តើដូចម្តេច ។ កាលបុគ្គលលះនូវឧទ្ធច្ចៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ ការមិនរាយមាយ គឺសមាធិ ជាធម៌សូន្យចាកការប្រកាន់ស្អិតទាំងពួង មាននិរោធជាគោចរ កាលបុគ្គលលះអវិជ្ជា វិបស្សនា ដោយអត្ថថា

ឃើញរឿយៗ ក៏ជាគុណជាតិសូន្យ ចាកការប្រកាន់ស្អិតទាំងពួង មាននិរោធជាគោចរដែរ សមថៈនិងវិបស្សនា ដោយអត្ថថា សូន្យ ជាគុណជាតិមានរសតែមួយ ជាប់គ្នាជាគូ មិនកន្លងនូវគ្នានឹងគ្នា ដោយប្រការដូច្នេះ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា សូន្យ ។

ពាក្យថា ចម្រើន បានដល់ការចម្រើន ៤ យ៉ាង គឺការចម្រើន ដោយអត្ថថា មិនកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ ការចម្រើនដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ការចម្រើន ដោយអត្ថថានាំទៅដោយវិរិយៈ ដ៏សមគួរដល់ឥន្ទ្រិយនោះ ការចម្រើន ដោយអត្ថថាឧស្សាហ៍គប់រក ។បេ។ សំណួរត្រង់ពាក្យថា មគ្គកើតឡើង តើមគ្គកើតឡើងដូចម្ដេច ។បេ។ មគ្គកើតឡើងយ៉ាងនេះ ។បេ។ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាសយ៉ាងនេះ ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអត្ថថា សូន្យយ៉ាងនេះ ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ដោយអាការៈ ១៦ យ៉ាងនេះ ភិក្ខុចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា យ៉ាងនេះឯង ។

[ ១៣ ] ចិត្តដែលមិនជ្រួលច្រាល់ដោយឧទ្ធច្ចៈក្នុងធម៌ តើដូចម្ដេច ។ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាមិនទៀង ពន្លឺក៏កើតឡើង ភិក្ខុនោះពិចារណានូវពន្លឺថា ពន្លឺជាធម៌ លំដាប់នោះសេចក្ដីរាយមាយ សេចក្ដីអណ្ដែតអណ្ដូង

( ក៏កើតឡើង ) ភិក្ខុមានចិត្តជ្រួលច្រាល់ ដោយឧទ្ធច្ចៈនោះ រមែងមិនដឹង តាមពិតនូវការប្រាកដ ថាមិនទៀង មិនដឹងតាមពិតនូវការប្រាកដ ថាជា ទុក្ខ មិនដឹងតាមពិតនូវការប្រាកដ ថាមិនមែនខ្លួន ព្រោះហេតុនោះ លោក ទើបពោលថា ចិត្តមិនប្រួលច្រាល់ដោយឧទ្ធច្ចៈក្នុងធម៌ មានសម័យដែលចិត្ត នោះ ឋិតនៅសម្ងំ នៅជាចិត្តខ្ពស់ឯក តាំងនៅនឹងជឹងក្នុងសន្តាន សំណួរ ត្រង់ពាក្យថា មគ្គកើតឡើងដល់ភិក្ខុនោះ តើមគ្គកើតឡើង ដូចម្តេច ។បេ។ មគ្គកើតឡើងយ៉ាងនេះ ។បេ។ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យ ទាំងឡាយក៏វិនាសយ៉ាងនេះឯង កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាមិនទៀង ញាណ កើតឡើង បីតិកើតឡើង បស្សទ្ធិ ( សេចក្តីស្ងប់ ) កើតឡើង សុខ កើតឡើង អធិមោក្ខ ( ការជឿស៊ប់ ) កើតឡើង បគ្គាហៈ ( ការ-ព្យាយាម ) កើតឡើង ឧបដ្ឋានៈ ( សតិដ៏ក្លៀវក្លា ) កើតឡើង ឧបេក្ខា កើតឡើង និកន្តិ ( សេចក្តីត្រេកអរ ) ក៏កើតឡើង ភិក្ខុនោះរមែងពិចា-រណានូវនិកន្តិថា និកន្តិជាធម៌ លំដាប់នោះសេចក្តីរាយមាយ សេចក្តីអណ្តែត អណ្តូង ( ក៏កើតឡើង ) ភិក្ខុមានចិត្តជ្រួលច្រាល់ដោយឧទ្ធច្ចៈនោះ រមែង មិនដឹងតាមពិតនូវការប្រាកដ ថាមិនទៀង មិនដឹងតាមពិតនូវការប្រាកដ ថា ជាទុក្ខ មិនដឹងតាមពិតនូវការប្រាកដ ថាមិនមែនខ្លួន ព្រោះហេតុនោះ លោក ទើបពោលថា ចិត្តមិនជ្រួលច្រាល់ដោយឧទ្ធច្ចៈក្នុងធម៌ មានសម័យដែលចិត្ត នោះឋិតនៅ សម្ងំនៅ ជាចិត្តខ្ពស់ឯក តាំងនៅនឹងជឹងក្នុងសន្តាន សំណួរ ត្រង់ពាក្យថា មគ្គក៏កើតឡើងដល់ភិក្ខុនោះ តើមគ្គកើតឡើងដូចម្តេច ។បេ។

មគ្គកើតឡើងយ៉ាងនេះ ។បេ។ ភិក្ខុនោះក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយ ក៏វិនាសយ៉ាងនេះ កាលភិក្ខុធ្វើទុកក្នុងចិត្ត ថាជាទុក្ខ ។បេ។ កាលធ្វើទុកក្នុងចិត្ត ថាមិនមែនខ្លួន ពន្លឺកើតឡើង ញាណកើតឡើង បីតិកើតឡើង បស្សទ្ធិកើតឡើង សុខកើតឡើង អធិមោក្ខកើតឡើង បគ្គាហៈកើតឡើង ឧបដ្ឋានៈកើតឡើង ឧបេក្ខាកើតឡើង និកន្តិកើតឡើង ភិក្ខុនោះរមែងពិចារណានូវនិកន្តិថា និកន្តិជាធម៌ លំដាប់នោះ សេចក្តីរាយមាយសេចក្តីអណ្តែតអណ្តូង ( ក៏កើតឡើង ) ភិក្ខុមានចិត្តជ្រួលច្រាល់ដោយឧទ្ធច្ចៈនោះ រមែងមិនដឹងតាមពិតនូវការប្រាកដ ថាមិនមែនខ្លួន នូវការប្រាកដថាមិនទៀង នូវការប្រាកដថា ជាទុក្ខ ព្រោះហេតុនោះ លោកទើបពោលថា ចិត្តមិនជ្រួលច្រាល់ដោយឧទ្ធច្ចៈក្នុងធម៌ ។បេ។ ភិក្ខុនោះ ក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយក៏វិនាសយ៉ាងនេះឯង ។

[ ១៤ ] កាលភិក្ខុធ្វើទុកក្នុងចិត្តនូវរូប ថាមិនទៀង ។បេ។ កាលធ្វើទុកក្នុងចិត្តនូវរូប ថាជាទុក្ខ កាលធ្វើទុកក្នុងចិត្តនូវរូប ថាមិនមែនខ្លួន នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ កាលភិក្ខុធ្វើទុកក្នុងចិត្តនូវជរាមរណៈ ថាមិនទៀង កាលធ្វើទុកក្នុងចិត្តនូវជរា មរណៈ ថាជាទុក្ខ កាលភិក្ខុធ្វើទុកក្នុងចិត្តនូវជរា មរណៈ ថាមិនមែនខ្លួន ពន្លឺកើតឡើង ញាណកើតឡើង បីតិកើតឡើង បស្សទ្ធិកើតឡើង សុខកើតឡើង អធិមោក្ខកើតឡើង បគ្គាហៈកើតឡើង ឧបដ្ឋានៈកើតឡើង ឧបេក្ខាកើតឡើង និកន្តិកើតឡើង ភិក្ខុនោះរមែងពិចារណានូវនិកន្តិថា និកន្តិជាធម៌ លំដាប់នោះ

សេចក្តីរាយមាយ សេចក្តីអណ្តែតអណ្តូង ក៏កើតឡើង ភិក្ខុមានចិត្តជ្រួលច្របល់ ដោយឧទ្ធច្ចៈនោះ រមែងមិនដឹងតាមពិតនូវការប្រាកដ គឺជវនិងមរណៈ ជាមិនមែនខ្លួន មិនដឹងតាមពិតនូវការប្រាកដ គឺជវនិងមរណៈ ជាមិនទៀង មិនដឹងតាមពិតនូវការប្រាកដ គឺជវនិងមរណៈ ជាជាទុក្ខ ព្រោះហេតុនោះ លោកទើបពោលថា ចិត្តមិនជ្រួលច្របល់ ដោយឧទ្ធច្ចៈក្នុងធម៌ មានសម័យដែលចិត្តនោះឋិតនៅ សម្ងំនៅ ជាចិត្តខ្ពស់ឯក តាំងនៅនឹងធឹង ជាមិនទៀង សំណួរត្រង់ពាក្យថា មគ្គកើតឡើងដល់ភិក្ខុនោះ តើមគ្គកើតឡើងដូចម្តេច ។បេ។ មគ្គកើតឡើងយ៉ាងនេះ ។បេ។ ភិក្ខុនោះ ក៏លះសញ្ញោជនៈទាំងឡាយ អនុស័យទាំងឡាយ ក៏វិនាសយ៉ាងនេះ ចិត្តមិនជ្រួលច្របល់ ដោយឧទ្ធច្ចៈក្នុងធម៌យ៉ាងនេះឯង ។

ចិត្តរមែងញាប់ញ័រដោយហេតុទាំងឡាយណា ហេតុទាំងនេះមាន ១០ គឺចិត្តញាប់ញ័រព្រោះពន្លឺ ១ ញាណ ១ បីតិ ១ បស្សទ្ធិ ១ សុខ ១ ញាប់ញ័រព្រោះអធិមោក្ខ ១ បគ្គាហៈ ១ ឧបដ្ឋានៈ ១ ការពិចារណាដោយឧបេក្ខា ក្នុងឧបេក្ខា ១ និកន្តិ ១ ភិក្ខុណាសន្សំបញ្ញាហើយ ភិក្ខុនោះ ឈ្មោះថាជាអ្នកឆ្លៀវឆ្លាសចំពោះឧទ្ធច្ចៈក្នុងធម៌ រមែងមិនដល់នូវសេចក្តីវង្វេង ទាំងដឹងច្បាស់នូវការប្រមូលចិត្តនិងការរាយមាយដោយហេតុ ៤ នេះ គឺចិត្តកាវនាញាប់ញ័រ សៅហ្មង ឃាត ១ ចិត្តកាវនាញាប់ញ័រ សៅហ្មង សាបសូន្យ ១ ចិត្តកាវនា

បរិសុទ្ធ មិនសៅហ្មង មិនសាបសូន្យ ១ ចិត្តការនាមិនរាយមាយ មិនសៅហ្មង មិនឃ្លាត ១ និងការជ្រួលច្រាល់ដោយហេតុ ១០ យ៉ាង ។

## ចប់ យុគនទ្ធកថា ។

# យុគនទ្ធវគ្គ

## អដ្ឋកថា យុគនទ្ធកថា

[ ៥ ] ឥឡូវនេះនឹងពណ៌នាតាមលំដាប់ ដែលមិនធ្លាប់ពណ៌នា ក្នុងយុគនទ្ធកថា ដែលមានសូត្រជាបទនាំ ដែលព្រះអានន្ទត្ថេរ សម្តែងដល់គុណរបស់យុគនទ្ធធម៌នៃអរិយមគ្គ ដែលជាគុណធម៌ដូវផង់ គួរក្រេបផឹកពោលហើយ ។

ព្រោះព្រះធម្មសេនាបតីសារីបុត្តត្ថេរ កាលព្រះមានព្រះភាគ ដែលជាព្រះធម្មរាជាទ្រង់មានព្រះជន្មនៅឡើយ លោកបានបរិនិព្វានក្នុងវស្សាដែលព្រះអង្គទ្រង់ជាព្រះធម្មរាជាស្តេចបរិនិព្វាន ហេតុនោះ គប្បីជ្រាបថា កាលព្រះធម្មរាជា ទ្រង់មានព្រះជន្មនៅឡើយនោះឯង ព្រះធម្មសេនាបតីសារីបុត្តបានស្តាប់សូត្រនេះ ដែលព្រះអានន្ទជាធម្មភណ្ឌាគារិកៈ ( ឃ្លាំងព្រះធម៌ ) សម្តែងទុកចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគអង្គនោះ ហើយទើបពោលថា **ឯវម្មេ សុតំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អាយស្មា** ជាពាក្យពោលគួរស្រឡាញ់ ជាពាក្យពោលសម្តែងសេចក្តីគោរព ជាពាក្យពោលសម្តែងនូវគារវៈ និងការកោតក្រែង អធិប្បាយថា អ្នកមានអាយុ ។ បទថា **អានន្ទោ** ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ដ្បិតថាព្រះថេរៈនោះ កាលកើតបានធ្វើសេចក្តីពេញចិត្ត សេចក្តីត្រេកអរយ៉ាងច្រើន ( ដល់ជន ) ក្នុងត្រកូល ព្រោះហេតុនោះ ទើបព្រះញាតិទាំងឡាយថ្វាយព្រះនាមថា អានន្ទ ។ បទថា **កោ–**

**សម្ពិយំ** បានដល់ ក្បែរនគរមានឈ្មោះយ៉ាងនោះ ។ នគរនោះមានដើមសង្ស័រដុះឡើងស្អេកស្កះ ដេរដាសក្នុងទីនោះៗ មានសួនទិនស្រះបោក្ខរណីជាដើម ព្រោះហេតុនោះ ទើបនគរនោះឈ្មោះថា **កោសម្ពី** អាចារ្យពួកមួយពោលថា ព្រោះឥសីកុសម្ពៈ សាងទុកមិនឆ្ងាយពីអាស្រម ។ បទថា **ឃោសិតារាមេ** បានដល់ ក្នុងអារាមដែលឃោសិតសេដ្ឋី សាងទុក ។ ក្នុងក្រុងកោសម្ពីមានសេដ្ឋី ៣ នាក់ គឺឃោសិតសេដ្ឋី ( ឃោសកសេដ្ឋី ) កុក្កុដសេដ្ឋី បាវារិកសេដ្ឋី ។ សេដ្ឋីទាំង ៣ នាក់នោះ បានស្តាប់មកថា ព្រះពុទ្ធទ្រង់កើតហើយក្នុងលោក ទើបឲ្យត្រៀមឧបករណ៍ ក្នុងការឲ្យទានដោយរទេះម្នាក់ ៥០០ បរទៅកាន់នគរសាវត្ថី បោះជំរំក្បែរវិហារជេតពនហើយទៅគាល់ព្រះសាស្តា ថ្វាយបង្គំ ធ្វើបដិសណ្ឋារៈ ហើយអង្គុយស្តាប់ធម្មទេសនារបស់ព្រះសាស្តា តាំងនៅក្នុងសោតាបត្តិផល បាននិមន្តព្រះ-សាស្តា ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់កន្លះខែហើយថ្វាយបង្គំបាទមូលរបស់ព្រះសាស្តា អារាធនាព្រះមានព្រះភាគ ដើម្បីស្តេចយាងទៅកាន់ជនបទរបស់ខ្លួន កាលព្រះមានព្រះភាគ ទ្រង់ត្រាស់ថាម្នាលគហបតីទាំងឡាយ ព្រះតថាគតទាំងឡាយ ត្រេកអរក្នុងសុញ្ញាគារលុះដឹងថា ព្រះមានព្រះភាគ ឲ្យប្តេជ្ញាដល់ពួកយើងហើយ ទើបត្រេកអរក្រៃលែង ថ្វាយបង្គំព្រះទសពល ហើយចេញដំណើរ ឲ្យសាងវិហារដើម្បីជាទីគង់របស់ព្រះមានព្រះភាគ គ្រប់ៗ ១ យោជន៍ ក្នុងរវាងផ្លូវដល់ក្រុងកោសម្ពីដោយលំដាប់ ធ្វើការបរិច្ចាគទ្រព្យជាច្រើន ក្នុងអារាមរៀង ៗ ខ្លួន

ហើយសាងវិហារទាំងឡាយ ថ្វាយដល់ព្រះមានព្រះភាគ ។ បណ្តាសេដ្ឋីទាំងនោះ ឃោសិតសេដ្ឋីសាងអារាមឈ្មោះ ឃោសិតារាម កុក្កុដសេដ្ឋីសាងអារាមឈ្មោះ កុក្កុដារាម បាវារិកសេដ្ឋីសាងក្នុងសួនអម្ពវ័ន ឈ្មោះ បាវារិកម្ពវ័ន ។ ខ្ញុំពោលថា ក្នុងអារាមដែលឃោសិតសេដ្ឋីសាងទុក សំដៅដល់ឃោសិតារាមនោះ ។

ក្នុងបទថា **អាវុសោ ភិក្ខវោ** ព្រះពុទ្ធព្រះមានព្រះភាគទាំងឡាយ កាលត្រាស់ហៅសាវកទាំងឡាយ ទ្រង់រមែងត្រាស់ហៅថា **ភិក្ខវោ** ។ ចំណែកសាវកទាំងឡាយគិតថា យើងចូរកុំដូចព្រះពុទ្ធទាំងឡាយឡើយទើបពោលថា អាវុសោមុន ហើយពោលថា **ភិក្ខវោ** ខាងក្រោយ ។ ម្យ៉ាងទៀត កាលព្រះពុទ្ធទ្រង់ត្រាស់ហៅ ភិក្ខុសង្ឃរមែងទទួលថា **ភទន្តេ** កាលសាវកហៅ ភិក្ខុសង្ឃទទួលថា **អាវុសោ** ។

បទថា **យោ ហិ កោចិ** ជាពាក្យមិនពិតប្រាកដ ។ ដោយបទនេះ ជាការកំណត់ដល់ភិក្ខុទាំងអស់បែបនោះ ។ បទថា **មម សន្តិកេ** បានដល់ក្នុងទីជិតខ្ញុំ ។ បទថា **អរហត្តប្បត្តំ** បានដល់ ខ្លួនឯងសម្រេចអរហត្ត ។ រូបសម្រេចជានបុំសកលិង្គ ។ ឬកាត់បទថា **អរហត្តំ បត្តំ** អធិប្បាយថា នូវអរហត្តដែលខ្លួនសម្រេចហើយ ឬបាឋៈដ៏សេសថា ដែលខ្លួនសម្រេចអរហត្តហើយ ។

បទថា **ចតូហិ មគ្គេហិ** បានដល់ មគ្គប្បដិបទា ៤ ដែលលោកពោលទុកខាងមុខ មិនមែនដោយអរិយមគ្គ ។ ព្រោះលោកពោលញែកទុកថា

**ចតូហិ** ទើបគួរជ្រាបថា មគ្គប្បដិបទាមាន ៤ យ៉ាងនេះ គឺសម្រាប់ព្រះអរហន្តរូបខ្លះ អរិយមគ្គទី ១ ជាមគ្គមានធម្មុទ្ធច្ចៈជាខាងដើម អរិយមគ្គ ១ ( ចាកអរិយមគ្គដ៏សេស ) ជាមគ្គមានសមថៈជាខាងដើម អរិយមគ្គ ១ ជាមគ្គមានវិបស្សនាជាខាងដើម អរិយមគ្គ ១ ជាមគ្គមានយុគនទ្ធធម៌ ជាខាងដើម ។

បទថា **ឯតេសំ វា អញ្ញតរេន** សេចក្ដីថា ឬរមែងព្យាករការសម្រេចអរហត្តដោយមគ្គប្បដិបទា ១ នៃមគ្គប្បដិបទាទាំង ៤ នោះ ។

ពិតណាស់ កាលព្រះអរហន្តជាសុក្ខវិបស្សកៈ សម្រេចសោតាបត្តិមគ្គដែលមានធម្មុទ្ធច្ចៈ ជាខាងដើម ហើយសម្រេចមគ្គ ៣ ដ៏សេស ដោយវិបស្សនាសុទ្ធ ៗ នោះឯង ការសម្រេចអរហត្ត រមែងជាមគ្គមានធម្មុទ្ធច្ចៈជាខាងដើម ។ សម្រាប់ព្រះអរហន្តដែលសម្រេចក្ដី មិនបានសម្រេចក្ដីនូវមគ្គដែលត្រូវឧទ្ធច្ចៈក្នុងធម៌រាំងទុក ហើយសម្រេចមគ្គ ៤ ដោយអំណាចមគ្គតែមួយនៃមគ្គប្បដិបទា ៣ មានសមថៈជាខាងដើមជាដើម ការសម្រេចអរហត្តរមែងមានមគ្គតែមួយក្រៅអំពីនេះ ( ក្រៅអំពីមគ្គដែលមានធម្មុទ្ធច្ចៈជាខាងដើម ) ព្រោះហេតុនោះ ទើបព្រះអានន្ទត្ថេរពោលថា ឬដោយមគ្គទាំងនុ៎ះ មគ្គណាមួយ ។

បទថា **សមថបុព្វង្គមំ វិបស្សនំ ភាវេតិ** បានដល់ រមែងចម្រើនវិបស្សនា ធ្វើសមថៈឲ្យជាខាងដើម គឺឲ្យទៅដល់មុន សេចក្ដីថា ញុំាងសមាធិឲ្យកើតមុនហើយទើបចម្រើនវិបស្សនាខាងក្រោយ ។ បទថា **មគ្គោ**

**សញ្ជាយតិ** បានដល់ លោកុត្តរមគ្គទី ១ រមែងកើតឡើង ។ ក្នុងបទជាដើមថា **សោ តំ មគ្គំ** ឈ្មោះថា ការសេពជាដើមនូវអរិយមគ្គ ដែលមានខណៈចិត្តមួយរមែងមិនមាន តែភិក្ខុដែលធ្វើទុតិយមគ្គជាដើមឲ្យកើតឡើង ហៅថា សេព ចម្រើន ធ្វើឲ្យច្រើននូវមគ្គនោះៗឯង ។

បទថា **សញ្ញោជនានិ បហីយន្តិ អនុសយា ព្យន្តីហោន្តិ** បានដល់ រមែងលះសំយោជនៈទាំងពួង អនុស័យរមែងអស់ទៅតាមលំដាប់រហូតដល់អរហត្តមគ្គ ។

ម្យ៉ាងទៀត បទថា **អនុសយា ព្យន្តីហោន្តិ** សេចក្តីថា អនុស័យមានទីបំផុតប្រាសទៅដោយមិនកើតឡើងទៀត ។ បទថា **បុន ចបរំ** បានដល់ នៅមានហេតុដទៃទៀត ។ បទថា **វិបស្សនាបុព្វង្គមំ សមថំ ភាវេតិ** បានដល់ រមែងចម្រើនសមថៈ ធ្វើវិបស្សនាឲ្យជាខាងដើម គឺឲ្យដល់មុន សេចក្តីថា ញុំាងវិបស្សនាឲ្យកើតមុន ទើបចម្រើនសមាធិជាខាងក្រោយ ។ បទថា **យុគនទ្ធំ ភាវេតិ** បានដល់ រមែងចម្រើនធ្វើឲ្យជាគូគ្នា ។ ក្នុងបទនេះមិនអាចចូលសមាបត្តិដោយចិត្តនោះ ហើយពិចារណាសង្ខារទាំងឡាយដោយចិត្តដដែលនោះឯង តែភិក្ខុនោះ ចូលសមាបត្តិបានត្រឹមណា រមែងពិចារណាដល់សង្ខារទាំងឡាយបានត្រឹមនោះ ។ ពិចារណាដល់សង្ខារបានត្រឹមណា រមែងចូលសមាបត្តិបានត្រឹមនោះ ។ សេចក្តីនេះដូចម្តេច គឺភិក្ខុចូលបឋមជ្ឈាន លុះចេញពីបឋមជ្ឈាននោះហើយ រមែងពិចារណាសង្ខារទាំងឡាយ កាលពិចារណាសង្ខារទាំងឡាយហើយ រមែងចូលទុតិយជ្ឈាន កាល

ចេញពីទុតិយជ្ឈាននោះហើយ រមែងពិចារណាសង្ខារទាំងឡាយ កាលពិ-ចារណាសង្ខារទាំងឡាយហើយរមែងចូលតតិយជ្ឈាន ។ល។ នេវសញ្ញា-នាសញ្ញាយតនសមាបត្តិ កាលចេញពីនេវសញ្ញានាសញ្ញាយតនសមាបត្តិនោះហើយ រមែងពិចារណាដល់សង្ខារទាំងឡាយ ។ ដោយប្រការដូច្នេះ ឈ្មោះថា កិច្ចចម្រើនធម៌ដែលជាប់គ្នាជាគូ គឺសមថៈនិងវិបស្សនា ។

ក្នុងបទនេះថា **ធម្មុទ្ធច្ចវិគ្គហិតំ មានសំ ហោតិ** បានដល់ ឧទ្ធច្ចៈ ពោលគឺការរាយមាយ ព្រោះចិត្តដែលសហគតដោយឧទ្ធច្ចៈ កើតឡើងដោយអំណាចការវិលទៅក្នុងធម៌ ១០ ប្រការ មានឱភាសជាដើម ដែលតែងស្គាល់ថាជាវិបស្សនូបក្កិលេស ព្រោះជាទីតាំងនៃការសៅហ្មង របស់បុគ្គលអ្នកចម្រើនវិបស្សនា ដែលមានបញ្ញាទន់ខ្សោយ ឈ្មោះថា **ធម្មុទ្ធច្ច** មានចិត្ត គឺចិត្តដែលធម្មុទ្ធច្ចៈនោះរារាំងទុក គឺកាន់យកខុស បានដល់ឲ្យដល់នូវការខុសប្រក្រតី ឈ្មោះថា មានចិត្តត្រូវឧទ្ធច្ចៈក្នុងធម៌រារាំងទុក ឬមានចិត្តត្រូវធម្មុទ្ធច្ចៈនោះ ដែលជាហេតុរារាំងទុក ព្រោះការកើតនៃតណ្ហា មានះ ទិដ្ឋិដែលមានធម្មុទ្ធច្ចៈនោះជាមូល ។ បាឋៈថា **ធម្មុទ្ធច្ចវិគ្គហិតមានសំ** ក៏មាន ។ ដោយបទនេះថា **ហោតិ សោ អាវុសោ សមយោ** ព្រះអានន្ទត្ថេរ ហាមធម្មុទ្ធច្ចៈនោះ ដោយកំណត់មគ្គនិងមិនមែនមគ្គហើយសម្ដែងដល់កាលបដិបត្តិទៅកាន់វីថិនៃវិបស្សនាទៀត ។

បទថា **យំ តំ ចិត្តំ** បានដល់ ក្នុងសម័យណា ចិត្តនោះឈានចុះកាន់វីថិនៃវិបស្សនាប្រព្រឹត្តទៅហើយ ។ បទថា **អជ្ឈត្តមេវ សន្តិដ្ឋតិ** បាន

ដល់ ចិត្តឈានចុះកាន់វីថិនៃវិបស្សនាហើយ រមែងតាំងមាំ គឺមាំទាំក្នុងអារម្មណ៍ ពោលគឺខាងក្នុងនៃគោចរក្នុងសម័យនោះ ។ បទថា **សន្និសីទតិ** បានដល់ ស្ងប់ដោយប្រពៃ ដោយការប្រព្រឹត្តិទៅក្នុងអារម្មណ៍នោះ ៗ ឯង ។ បទថា **ឯកោទិ ហោតិ** បានដល់ មានអារម្មណ៍តែមួយ ។ បទថា **សមាធិយតិ** បានដល់ ចិត្តតាំងមាំដោយប្រពៃ គឺតាំងមាំដោយល្អ ។

នេះជាពណ៌នាតាមព្រះសូត្រ

## អដ្ឋកថា

## សុត្តន្តនិទ្ទេស

[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសកថានៃសូត្រនោះ ដូចតទៅនេះថា បទថា **តត្ថ ជាតេ ធម្មេ** បានដល់ ធម៌គឺចិត្តនិងចេតសិក ដែលកើតក្នុងសមាធិនោះ ។ ព្រះសារីបុត្តត្ថេរសម្តែងដល់ប្រភេទនៃវិបស្សនា ដោយបទថា **អនិច្ចតោ អនុបស្សនដ្ឋេន** ជាដើម ។ បទថា **សម្មាទិដ្ឋិ មគ្គោ** បានដល់ មគ្គ ពោលគឺសម្មាទិដ្ឋិ ។ ក្នុងអង្គនៃមគ្គ ៨ សូម្បីអង្គនីមួយ ៗ លោកក៏ហៅថា មគ្គ ។ បទថា **អាសេវតិ** បានដល់ សេពដោយអំណាចនៃសោតាបត្តិមគ្គ ។ បទថា **ភាវេតិ** បានដល់ ចម្រើនដោយការធ្វើសកទាគាមិមគ្គឲ្យកើតឡើង ។ បទថា **ពហុលីករោតិ** បានដល់ ធ្វើឲ្យច្រើនដោយ

អំណាចអនាគាមិមគ្គនិងអរហត្តមគ្គឲ្យកើតឡើង ។

បទទាំង ៣ នេះ មានការកំណត់ផ្សេងគ្នា ព្រះសារីបុត្ត ក៏ធ្វើវិសជ្ជនាដូច ៗ គ្នា ព្រោះមានអាវជ្ជនៈជាដើមស្មើគ្នា ។

[ ៧ ] ក្នុងបេយ្យាលនៃអាលោកសញ្ញា និងភាពជាអ្នកពិចារណាឃើញការលះបង់ លោកសង្ខេបសេចក្តីមិនរាយមាយជាដើម ឈាន សមាបត្តិ កសិណ អនុស្សតិ អសុភៈ និងខ្យល់ដកដង្ហើមចូលវែងជាដើមទុក ព្រោះលោកបានសម្តែងទុកហើយក្នុងអានន្តរិកសមាធិញាណនិទ្ទេស ។

ម្យ៉ាងទៀត ក្នុងបទទាំងនោះ បទថា **អវិក្ខេបវសេន** គប្បីកាន់យកដោយការមិនរាយមាយ ដែលជាចំណែកខាងដើម ។

ក្នុងចតុក្កៈដែលលោកពោលហើយ ដោយអំណាចវិបស្សនាសុទ្ធៗមាន **អនិច្ចានុបស្សី អស្សាសវសេន** ជាដើម ក្នុងវេលាផ្តើមចម្រើនវិបស្សនា គប្បីជ្រាបវិបស្សនាមានកម្លាំង ដែលមានសមាធិសម្បយុត្តដោយវិបស្សនាជាខាងដើម ។

[ ៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈមានវិបស្សនាជាខាងដើម ដូចតទៅនេះថា លោកពោលវិបស្សនាមិនកំណត់អារម្មណ៍ ដោយបទថា **អនិច្ចតោ** ជាដើមមុន ពោលវិបស្សនាកំណត់អារម្មណ៍ ដោយបទថា **រូបំ អនិច្ចតោ** ជាដើមក្នុងកាលជាខាងក្រោយ ។ បទថា **តត្ថ ជាតានំ** បានដល់ ធម៌ គឺចិត្តនិងចេតសិក ដែលកើតក្នុងវិបស្សនានោះ ។ **វោស្សគ្គ** ក្នុងបទនេះថា **វោស្សគ្គារម្មណតា** បានដល់ ព្រះនិព្វាន ព្រោះព្រះនិព្វានលោកពោលថា

វោស្សគ្គៈ ព្រោះលះបង់ចោលសង្ខតធម៌ ព្រោះលះបង់ ។ វិបស្សនានិង ធម៌ដែលសម្បយុត្តដោយវិបស្សនានោះ មាននិព្វានជាទីតាំង មានព្រះនិព្វាន ជាអារម្មណ៍ ព្រោះបង្អោនទៅកាន់ព្រះនិព្វាន និងព្រោះតាំងនៅក្នុងព្រះនិព្វាន ដោយអំណាចនៃអធ្យាស្រ័យ ។ សូម្បីការតាំងនៅ ក៏ឈ្មោះថា អារម្មណ៍ ព្រោះអត្ថថា តោងទុក ឈ្មោះថា មាននិព្វានជាអារម្មណ៍ ដោយអត្ថថា តាំងនៅក្នុងព្រះនិព្វាននោះឯង ។ ពិតណាស់ សូម្បីបាលីក្នុងទីដទៃ ទីតាំង ក៏លោកពោលថា អារម្មណ៍ ។

ដូចព្រះមហាមោគ្គល្លានពោល ( ក្នុងសំយុត្តនិកាយសឡាយតនវគ្គ ) ថា ម្នាលអាវុសោទាំងឡាយ ដូចផ្ទះប្រក់ដោយបបុសឬផ្ទះប្រក់ដោយស្មៅ មានឈើស្ងួតហែងសល់នៅតែរាងទទេ បើបុរសចូលទៅធ្លួលផ្ទះនោះ ដោយ គប់ភ្លើងក៏ឆេះសន្ទោក្នុងទិសខាងកើត ភ្លើងក៏នឹងបានទូវឱកាស នឹងបានទូវ អារម្មណ៍ ដូច្នេះជាដើម ។ ព្រោះហេតុនោះ ការមិនរាយមាយដែលមាន ប្រភេទជាឧបចារ និងអប្បនា ពោលគឺ ភាពដែលចិត្តមានមានអារម្មណ៍តែ មួយ ដែលកិក្ខុឲ្យកើតឡើង ដោយជាហេតុ គឺដោយមាននិព្វានជាទីតាំង ព្រោះចិត្តមានការលែងនូវធម៌ទាំងឡាយ ដែលកើតក្នុងវិបស្សនានោះ ជា អារម្មណ៍ ជាសមាធិ ព្រោះហេតុនោះ ឈ្មោះថា លោកសម្តែងសមាធិ ដែលជាចំណែកនៃការទម្លាយកិលេស ដែលកិក្ខុឲ្យកើតឡើងខាងក្រោយអំពី វិបស្សនា ព្រោះហេតុនោះឯងទើបលោកពោលទុកថា វិបស្សនា ( កើត ) មុន សមថៈ ( កើត ) ក្រោយ ដោយប្រការដូច្នេះ ។

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយុគនទ្ធនិទ្ទេស ដូចតទៅនេះថា ព្រោះលំដាប់នៃធម៌ជាគូ ខ្ញុំពោលទុកហើយក្នុងអដ្ឋកថានៃសូត្រប្រាកដហើយដោយន័យរបស់និទ្ទេសទាំងពីរក្នុងកាលមុន ចំណែកលំដាប់នៃធម៌ដែលជាគូ ក្នុងខណៈនៃមគ្គ មិនទាន់ប្រាកដច្បាស់ ព្រោះហេតុនោះ ព្រះសារីបុត្តត្ថេរ មិនពោលដល់ការចម្រើនធម៌ដែលជាគូ ដែលមានមិនតិច ក្នុងចំណែកខាងដើម កាលនឹងសម្ដែងដល់ការចម្រើនធម៌ជាគូ ដែលបានដោយចំណែកមួយ ក្នុងខណៈនៃមគ្គ ទើបពោលពាក្យថា **សោឡសហិ អាការេហិ** ជាដើម ។

ក្នុងបទទាំងនោះ ធម៌ជាគូ ដែលលោកលើកឡើងសម្ដែងទុកក្នុងទីបំផុតក្នុងអាការ ១៧ យ៉ាង មាន **អារម្មណដ្ឋេន** ជាដើម លោកលះយុគនទ្ធធម៌នោះ ព្រោះតាំងនៅក្នុងទីជាមួយគ្នាដោយជាមូលបទហើយពោលថា **សោ-ឡសហិ** ដោយអំណាចនៃអាការដ៏សេស ។

បទថា **អារម្មណដ្ឋេន** បានដល់ ដោយការគោង អធិប្បាយថា ដោយអំណាចជាអារម្មណ៍ ។ ក្នុងបទដ៏សេសក៏យ៉ាងនេះ ។ បទថា **គោចរដ្ឋេន** បានដល់ កាលភាពជាអារម្មណ៍មាន ទើបបានដល់ដោយភាពជាទីពឹង ទីអាស្រ័យ ។ បទថា **បហានដ្ឋេន** បានដល់ ដោយការលះ ។ បទថា **បរិច្ចាគដ្ឋេន** កាលការលះមាន ទើបបានដល់ដោយការលះបង់ ដោយការមិនប្រកាន់ ។ បទថា **វុដ្ឋានដ្ឋេន** បានដល់ ដោយការចេញទៅ ។ បទថា **វិវដ្ដនដ្ឋេន** កាលការចេញទៅមាន ទើបបានដល់ដោយការត្រឡប់ទៅ មិនវិលត្រឡប់មកទៀត ។ បទថា **សន្តដ្ឋេន** បានដល់ ដោយភាពជា

ធម៌រលត់ ។ បទថា **បណីតដ្ឋេន** កាលមានការរលត់ ទើបបានដល់ដោយភាពជាធម៌ឧត្តម ឬដោយភាពជាធម៌មិនក្តៅក្រហាយ ។

បទថា **វិមុត្តដ្ឋេន** បានដល់ ដោយការប្រាសចាកគ្រឿងចង ។ បទថា **អនាសវដ្ឋេន** បានដល់ កាលមានការរួចផុតពីគ្រឿងចង ទើបបានដល់ដោយភាពជាធម៌ប្រាសចាកអាសវៈដែលធ្វើអារម្មណ៍ប្រព្រឹត្តទៅ ។ បទថា **តរណដ្ឋេន** បានដល់ ដោយការមិនលិចចុះ ហើយលែងទៅ ឬដោយការឆ្លងទៅ ។ បទថា **អនិមិត្តដ្ឋេន** បានដល់ ដោយភាពជាធម៌ប្រាសចាកសង្ខារនិមិត្ត ។

បទថា **អប្បណិហិតដ្ឋេន** បានដល់ ដោយភាពជាធម៌ប្រាសចាកទីតាំង ។ បទថា **សុញ្ញតដ្ឋេន** បានដល់ ដោយភាពជាធម៌ប្រាសចាកការប្រកាន់ ។ បទថា **ឯករសដ្ឋេន** បានដល់ ដោយភាពជាធម៌មានកិច្ចតែមួយ ។ បទថា **អនតិវត្តនដ្ឋេន** បានដល់ ដោយភាពជាធម៌មិនកន្លងគ្នានឹងគ្នា ។

បទថា **យុគនទ្ធដ្ឋេន** បានដល់ ដោយភាពជាគូគ្នា ។ បទថា **ឧទ្ធច្ចំ បជហតោ អវិជ្ជំ បជហតោ** លោកពោលដោយអំណាចការលះធម៌ដែលជាបដិបក្ខនៃធម៌នោះ ៗ របស់ព្រះយោគាវចរ ។ ម្យ៉ាងទៀត និរោធក្នុងទីនេះគឺនិព្វាននោះឯង ។ បទថា **អញ្ញមញ្ញំ នាតិវត្តន្តិ** បានដល់ បើសមថៈកន្លងវិបស្សនា ចិត្តគប្បីប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស ព្រោះសមថៈប្រព្រឹត្តទៅក្នុងចំណែកការរួញរា ។ បើវិបស្សនាកន្លងសមថៈ ចិត្តគប្បីប្រព្រឹត្តទៅដើម្បីការរាយមាយ ព្រោះវិបស្សនាប្រព្រឹត្តទៅក្នុងចំណែកនៃ

សេចក្តីរាយមាយ ព្រោះហេតុនោះសមថៈកាលមិនកន្លងវិបស្សនា រមែងមិនធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស វិបស្សនាកាលមិនកន្លងសមថៈ រមែងមិនធ្លាក់ទៅក្នុងសេចក្តីរាយមាយ សមថៈកាលប្រព្រឹត្តទៅស្មើ រមែងរក្សាវិ-បស្សនា ពីការធ្លាក់ទៅកាន់សេចក្តីរាយមាយ វិបស្សនាកាលប្រព្រឹត្តទៅស្មើ រមែងរក្សាសមថៈ ពីការធ្លាក់ទៅកាន់សេចក្តីខ្ជិលច្រអូស ។ សមថៈនិងវិបស្សនាទាំងពីរមានកិច្ចតែមួយដោយកិច្ច គឺការមិនកន្លងគ្នានឹងគ្នា កាលប្រព្រឹត្តទៅស្មើ មិនកន្លងនូវគ្នានឹងគ្នា រមែងធ្វើប្រយោជន៍ឲ្យសម្រេច ដោយប្រការដូច្នេះ ។ ភាពដែលសមថៈ និងវិបស្សនានោះជាគូគ្នាក្នុងខណៈនៃមគ្គ រមែងមានបាន ព្រោះជាធម៌គូគ្នាក្នុងខណៈនៃវិបស្សនា ដែលជាវុដ្ឋានគាមិនីនោះឯង ។

[ ១០-១២ ] ដើម្បីសម្តែងមគ្គកិច្ចទាំងមូលព្រោះការធ្វើនូវការលះ ការលះបង់ ការចេញនិងការចៀសចេញទៅ លោកពោលដោយអំណាចមគ្គ-កិច្ច ទើបលោកចង្អុលបង្ហាញកិលេស ដែលប្រកបដោយឧទ្ធច្ចៈនិងខន្ធ និងចង្អុលបង្ហាញកិលេស ដែលប្រកបដោយអវិជ្ជា និងខន្ធ ។ ព្រោះពាក្យដ៏សេស លោកមិនបានពោលទុកយ៉ាងនោះ ទើបចង្អុលបង្ហាញដល់ឧទ្ធច្ចៈ និងអវិជ្ជា ដោយអំណាចនៃការសម្តែងត្រឹមតែធម៌ ដែលជាបដិបក្ខ ។ បទថា **វិវដ្ដតោ** បានដល់ កាលចៀសចេញទៅ ។ បទថា **សមាធិ កាមាសវា វិមុត្តោ ហោតិ** លោកពោល ព្រោះសមាធិជាបដិបក្ខចំពោះកាមច្ឆន្ទៈ ។ បទថា **រាគវិរាគា** មានវិគ្គហៈថា ឈ្មោះថា **រាគវិរាគោ** ព្រោះវិមុត្តិនោះ

មានការប្រាស ការឈានកន្លងរាគៈ ឬជាបញ្ចមីវិភត្តិថា **រាគវិរាគតោ** □ចាកការប្រាសចាករាគៈ ) ។ បទថា **អវិជ្ជាវិរាគា** ក៏ដូចគ្នា ។

បទថា **ចេតោវិមុត្តិ** បានដល់ សមាធិដែលសម្បយុត្តដោយមគ្គ ។ បទថា **បញ្ញាវិមុត្តិ** បានដល់ បញ្ញាដែលសម្បយុត្តដោយមគ្គ ។ បទថា **តរតោ** បានដល់ កាលឆ្លង ។ បទថា **សព្វបណិធីហិ** បានដល់ ដោយទីតាំងគឺរាគៈ ទោសៈ មោហៈឬដោយការប្រាថ្នាទាំងពួង ។ ព្រះសារីបុត្តត្ថេរ កាលឆ្លើយអាការ ១៤ យ៉ាងនេះហើយ មិនឆ្លើយភាពជាធម៌មានកិច្ចតែមួយ និងភាពជាធម៌មិនកន្លងគ្នានឹងគ្នា ហើយពោលថា **ឥមេហិ សោឡសហិ អាការេហិ** ។ ព្រោះហេតុអ្វី ព្រោះក្នុងទីបំផុតរបស់អាការនីមួយ ៗ នៃអាការ ១៤ ទាំងនោះ លោកចង្អុលបង្ហាញទុកថា មានកិច្ចតែមួយជាគូគ្នា មិនកន្លងនូវគ្នានឹងគ្នា ទើបឈ្មោះថា លោកសម្ដែងអាការទាំង ២ នោះឯង ។ ព្រោះហេតុនោះ ទើបពោលថា **សោឡសហិ** ។ ចំណែកភាពជាធម៌គូគ្នា លោកមិនបានពោលទុកសូម្បីក្នុងឧទ្ទេស ។

អដ្ឋកថាសុត្តន្តនិទ្ទេស ចប់

# អដ្ឋកថា

# ធម្មុទ្ធច្ចវារនិទ្ទេស

[ ១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មុទ្ធច្ចវារៈ ដូចតទៅនេះថា

បទថា **អនិច្ចតោ មនសិករោតោ ឱភាសោ ឧប្បជ្ជតិ** សេចក្តីថា កាលភិក្ខុតាំងនៅក្នុងឧទយព្វយានុបស្សនា ពិចារណាឃើញនូវសង្ខារទាំង-ឡាយរឿយ ៗ ដោយអនុបស្សនា ៣ កាលវិបស្សនាញាណ ដល់នូវភាពចាស់ក្លាហើយ មានចិត្តបរិសុទ្ធដោយការលះកិលេស ដោយតទង្គប្បហាន ឱភាសរមែងកើតតាមប្រក្រតី ដោយអានុភាពនៃវិបស្សនាញាណ ក្នុងខណៈមនសិការៈដោយភាពជាសភាពមិនទៀង ដោយភាពជាទុក្ខ ឬដោយភាពមិនមែនតួខ្លួន ព្រោះហេតុនោះ ទើបលោកពោលដល់ឱភាសរបស់ភិក្ខុដែលមនសិការៈ ដោយភាពជាសភាវៈមិនទៀងមុន ។

ភិក្ខុមិនឈ្លាស ចម្រើនវិបស្សនា កាលឱភាសនោះកើតឡើងហើយ គិតថា មុននេះ ឱភាសបែបនេះមិនធ្លាប់កើតឡើងដល់អញឡើយ អញជាបុគ្គលសម្រេចមគ្គ សម្រេចផលដោយពិត ទើបកាន់យកវត្ថុដែលមិនមែនមគ្គនោះឯង ថាជាមគ្គ វត្ថុដែលមិនមែនជាផលនោះឯង ថាជាផល ។

កាលភិក្ខុនោះកាន់យកវត្ថុដែលមិនមែនមគ្គ ថាជាមគ្គ វត្ថុដែលមិនមែនផល ថាជាផល វិបស្សនាវិថីរមែងទៅខុសផ្លូវ ។ ភិក្ខុនោះលះវិបស្សនាវិថីរបស់ខ្លួន អង្គុយដល់នូវការរាយមាយ ឬឲ្យការសម្គាល់ឱភាសនោះឯងដោយការសម្គាល់ដែលកើតអំពីតណ្ហា និងទិដ្ឋិ ។ ឱភាសនេះ សម្រាប់ភិក្ខុរូបខ្លះ

កើតឡើងធ្វើត្រឹមតែទីអង្គុយប៉ុណ្ណោះ ឲ្យភ្លឺស្វាង សម្រាប់ភិក្ខុរូបខ្លះ ធ្វើខាងក្នុងបន្ទប់ឲ្យភ្លឺស្វាង សម្រាប់ភិក្ខុរូបខ្លះ ធ្វើទាំងខាងក្រៅបន្ទប់ឲ្យភ្លឺស្វាង សម្រាប់ភិក្ខុរូបខ្លះ ធ្វើបរិវេណវិហារ ១ គាវុត កន្លះយោជន៍ ១ យោជន៍ ២ យោជន៍ឲ្យភ្លឺស្វាង ។បេ។ សម្រាប់ភិក្ខុរូបខ្លះ ធ្វើពន្លឺភ្លឺស្វាងតែមួយ តាំងអំពីផែនដីរហូតដល់អកនិដ្ឋកព្រហ្មលោក ។ តែសម្រាប់ព្រះមានព្រះភាគកើតឡើងធ្វើម៉ឺនលោកធាតុឲ្យភ្លឺស្វាង ។ ឱភាសនេះរមែងកើតឡើង ធ្វើទីនោះៗ ឲ្យភ្លឺស្វាង សូម្បីក្នុងឯនឹតដែលប្រកបដោយអង្គ ៤ បាន ។

បទថា **ឱភាសោ ធម្មោតិ ឱភាសំ អាវជ្ជតិ** បានដល់ ភិក្ខុយល់ឱភាសនោះៗ ថា ឱភាសនេះជាមគ្គធម៌ ឬជាផលធម៌ ។

បទថា **តតោ វិក្ខេបោ ឧទ្ធច្ចំ** សេចក្តីថា ការរាយមាយ កើតឡើងព្រោះឱភាសនោះ ឬព្រោះធ្វើការនឹកដល់ថា ឱភាសជាធម៌ ឈ្មោះថា ឧទ្ធច្ចៈ ។ បទថា **តេន ឧទ្ធច្ចេន វិគ្គហិតមានសោ** សេចក្តីថា មានចិត្តដែលឧទ្ធច្ចៈដែលកើតឡើងយ៉ាងនោះ រាំងទុក ឬមានចិត្តដែលឧទ្ធច្ចៈនោះ ដែលជាហេតុរាំងទុក ព្រោះការកើតឡើងនៃកិលេស ដែលមានឧទ្ធច្ចៈនោះជាមូល ជាអ្នកចម្រើនវិបស្សនា ឈមចុះកាន់វិបស្សនាវិថីហើយ រមែងមិនដឹងនូវការរាយមាយ ឬនូវការប្រាកដដោយភាពជារបស់មិនទៀង ដោយភាពជាទុក្ខ ដោយភាពមិនមែនតួខ្លួន តាមសេចក្តីពិត ព្រោះតាំងនៅក្នុងកិលេសដែលមានការរាយមាយនោះ ជាមូល ។ គប្បីប្រកប **ឥតិ** សព្ទ យ៉ាងនេះថា **តេន វុច្ចតិ ធម្មុទ្ធច្ចវិគ្គហិតមានសោ** ដូច្នេះ ។

បទថា **ហោតិ សោ សមយោ** សេចក្ដីថា បើការពិចារណាកើតឡើងដល់ព្រះយោគាវចរ ដែលមានចិត្តសៅហ្មង ដោយការពេញចិត្តយ៉ាងនេះ ព្រះយោគាវចរនោះ រមែងដឹងយ៉ាងនេះថា ធម្មតាវិបស្សនា មានសង្ខារជាអារម្មណ៍ មគ្គនិងផលមាននិព្វានជាអារម្មណ៍ តែចិត្តទាំងនេះមានសង្ខារជាអារម្មណ៍ ព្រោះហេតុនោះ ឱកាសនេះមិនមែនមគ្គ ឧទយព្វយានុបស្សនាប៉ុណ្ណោះ ជាលោកិយមគ្គរបស់និព្វាន ដូច្នេះហើយកំណត់មគ្គនិងមិនមែនមគ្គ វៀរនូវការរាយមាយនោះ តាំងនៅក្នុងឧទយព្វយានុបស្សនា ពិចារណាសង្ខារទាំងឡាយ ឲ្យល្អ ដោយភាពជាសភាវៈមិនទៀង ដោយភាពជាទុក្ខ ដោយភាពមិនមែនតួខ្លួន ។ កាលព្រះយោគាវចរពិចារណាយ៉ាងនេះ នោះជាសម័យ តែកាលមិនពិចារណាបែបនេះ នឹងជាអ្នកមានសេចក្ដីសម្គាល់ថាសម្រេច ដោយគិតថា អញជាអ្នកសម្រេចមគ្គនិងផលហើយ ។

បទថា **យំ តំ ចិត្តំ** បានដល់ វិបស្សនាចិត្តនោះ ។ បទថា **អជ្ឈត្តមេវ** បានដល់ ក្នុងខាងក្នុងគោចរ ដែលជាអារម្មណ៍នៃអនិច្ចានុបស្សនា ។

បទថា **ញាណំ ឧប្បជ្ជតិ** បានដល់ កាលព្រះយោគាវចរនោះ ពិ-ចារណាយ៉ាងល្អិតល្អន់ដល់រូបធម៌និងអរូបធម៌ វិបស្សនាញាណ ដែលមុតស្រួចក្រៃលែងមានកម្លាំង មិនត្រូវកម្ចាត់ ដូចវជិរាវុធរបស់ព្រះឥន្ទ ដែលលែងចេញទៅ ដូច្នោះ រមែងកើតឡើង ។

បទថា **បីតិ ឧប្បជ្ជតិ** បានដល់ ក្នុងសម័យនោះ បីតិដែលសម្បយុត្តដោយវិបស្សនា ៥ យ៉ាងនេះ គឺខុទ្ទកាបីតិ ( បីតិបន្តិចបន្តួច ) ១

ខណិកាបីតិ ( បីតិមួយជួរខណៈ ) ១ ឱក្កន្តិកាបីតិ ( បីតិជារយៈៗ ) ១ ឧព្វេង្គាបីតិ ( បីតិអាចធ្វើខ្លួនឲ្យអណ្តែតឡើង ) ១ ផរណាបីតិ ( បីតិជ្រួតជ្រាប ) ១ រមែងកើតឡើងធ្វើសរីរៈទាំងមូល របស់ព្រះយោគាវចរនោះឲ្យឆ្អែត ។

បទថា **បស្សទ្ធិ ឧប្បជ្ជតិ** បានដល់ ក្នុងសម័យនោះ កាយនិងចិត្តរបស់ព្រះយោគាវចរនោះ មិនមានការក្រវល់ក្រវាយ មិនមានការធ្ងន់ មិនមានភាពគ្រោតគ្រាត មិនមានភាពមិនគួរដល់ការងារ មិនមានអាពាធ មិនមានការវៀច តែដោយពិត ព្រះយោគាវចរនោះ មានកាយនិងចិត្តស្ងប់ ស្រាលទន់ គួរដល់ការងារ ជំនាញ ផូរផង់ល្អ ត្រង់ ។ ព្រះយោគាវចរនោះ មានកាយនិងចិត្តដែលបស្សទ្ធិជាដើមនេះ អនុគ្រោះហើយ រមែងសោយនូវការត្រេកអរដែលមិនមែនរបស់មនុស្ស ក្នុងសម័យនោះ ដែលព្រះមានព្រះភាគត្រាស់ទុក ( ក្នុងធម្មបទ ) ថា

សេចក្តីត្រេកអរដែលមិនមែនជារបស់មនុស្ស រមែងមានដល់
ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នកឃើញ
ធម៌ដោយប្រពៃ ។ ភិក្ខុពិចារណាការកើតឡើងនិងការវិនាស
ខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះរមែង
បានបីតិនិងបាមោជ្ជៈ បីតិនិងបាមោជ្ជៈនោះ ឈ្មោះថាជា អ-
មតធម៌របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ដូច្នេះ ។

កាយបស្សទ្ធិនិងចិត្តបស្សទ្ធិដែលសម្បយុត្តដោយវិបស្សនា ប្រកបព្រម

ដោយការស្រោលជាដើម ដែលឲ្យសម្រេចនូវការត្រេកអរ ដែលមិនមែនជារបស់មនុស្សនេះ រមែងកើតឡើងដល់ភិក្ខុនោះ ដោយប្រការដូច្នេះ ។ បទថា **សុខំ ឧប្បជ្ជតិ** បានដល់ សុខដែលសម្បយុត្តដោយវិបស្សនាដែលញុំាងសរីរៈទាំងមូលឲ្យស្រស់បស់ រមែងកើតឡើងក្នុងសម័យនោះ ដល់ភិក្ខុនោះ ។ បទថា **អធិមោក្ខោ ឧប្បជ្ជតិ** បានដល់ សទ្ធាដែលសម្បយុត្តដោយវិបស្សនា ដែលជាសេចក្ដីជ្រះថ្លាយ៉ាងខ្លាំង របស់ចិត្ត និងចេតសិក រមែងកើតឡើងក្នុងសម័យនោះ ដល់ភិក្ខុនោះ ។ បទថា **បគ្គហោ ឧប្បជ្ជតិ** បានដល់ សេចក្ដីព្យាយាមដែលសម្បយុត្តដោយវិបស្សនា ដែលផ្គងទុកល្អហើយ មិនធូរពេក មិនតឹងពេក រមែងកើតឡើងក្នុងសម័យនោះ ដល់ភិក្ខុនោះ ។ បទថា **ឧបដ្ឋានំ ឧប្បជ្ជតិ** បានដល់ សតិដែលសម្បយុត្តដោយវិបស្សនាដែលប្រាកដច្បាស់ តាំងទុកដោយល្អហើយ កប់ណែនមិនញាប់ញ័រ ដូចជាស្ដេចភ្នំ រមែងកើតឡើងក្នុងសម័យនោះ ដល់ភិក្ខុនោះ ។ ភិក្ខុនោះរមែងនឹកដល់ រួបរួមធ្វើទុកក្នុងចិត្ត ពិចារណាដល់ឋានៈណា ៗ ឋានៈនោះ ៗ ឈានកន្លងទៅ រមែងប្រាកដដល់ភិក្ខុនោះដោយសតិ ដូចបរលោកប្រាកដដល់អ្នកបានទិព្វចក្ខុ ដូច្នោះ ។ បទថា **ឧបេក្ខា** បានដល់ វិបស្ស-នូបេក្ខានិងអាវជ្ជនូបេក្ខា ( ព្រងើយដោយការពិចារណា ) ។ ពិតណាស់ សូម្បីវិបស្សនូបេក្ខា ដែលជាកណ្ដាល ក្នុងសង្ខារទាំងពួង ដែលមានកម្លាំង រមែងកើតឡើងក្នុងសម័យនោះ ចំណែកអាវជ្ជនូបេក្ខា រមែងកើតឡើងក្នុងមនោទ្វារ ។ ពិតណាស់ ឧបេក្ខានោះ កាលភិក្ខុនោះ ពិចារណាដល់ឋានៈ

នោះ ៗ រមែងជាភាពខ្វាំងក្លានាំទៅ ដូចវជិរាវុធរបស់ព្រះឥន្ទដែលលែងទៅ និងដូចកូនសរដែកដ៏ក្តៅ ដែលស្ទុះចេញទៅត្រង់កន្ទោងស្លឹកឈើ ។ លោកពោលទុកក្នុងវិសុទ្ធិមគ្គយ៉ាងនេះ ។

ម្យ៉ាងទៀត អាចារ្យទាំងឡាយពោលថា ក្នុងពាក្យនេះថា វិបស្សនូ-បេក្ខា បានដល់ តត្រមជ្ឈត្តុបេក្ខាដែលសម្បយុត្តដោយវិបស្សនា ។ ពិតណាស់ កាលកំណត់កាន់យកជាវិបស្សនាញាណ ក៏នឹងមានទោសដោយពាក្យនិយាយដដែលទៀត ព្រោះវិបស្សនាញាណ មកហើយក្នុងពាក្យថា **ញាណំ ឧបជ្ជតិ** ។ ក្នុងការពណ៌នានៃតតិយជ្ឈានលោកពោលថា សូម្បីសង្ខារុបេក្ខា និងវិបស្សនូបេក្ខា ដោយអត្ថក៏តែមួយដូចគ្នា ដ្បិតថា ឧបេក្ខានោះ ក៏គឺ បញ្ញាដែលចែកចេញជា ២ ចំណែក ដោយអំណាចនៃកិច្ច ។ ព្រោះហេតុនោះ កាលពោលដល់តត្រមជ្ឈត្តុបេក្ខា ដែលសម្បយុត្តដោយវិបស្សនា ទើបមិនមានទោសក្នុងការពោលដដែលទៀត និងសមដោយការពណ៌នានៃតតិយជ្ឈាន ។ ព្រោះក្នុងឥន្ទ្រិយ ៥ លោកសម្តែងដល់បញ្ញិ-ន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ និងសតិន្ទ្រិយថា ឈាន អធិមោក្ខ បគ្គហ ឧបដ្ឋាន ចំណែកសមាធិន្ទ្រិយ លោកមិនសម្តែងទុក ។ ម្យ៉ាងទៀត គប្បីសម្តែងសមាធិន្ទ្រិយនោះឯង ដោយអំណាចនៃធម៌ជាគូ ហេតុនោះគប្បីជ្រាបថា សមាធិដែលប្រព្រឹត្តទៅស្មើ លោកពោលថា ជាឧបេក្ខា ព្រោះធ្វើការលះសេចក្តីខ្វល់ខ្វាយក្នុងការតាំងមាំទៀត ។

បទថា **និកន្តិ ឧប្បជ្ជតិ** បានដល់ និកន្តិមិនអាចកំណត់ថាជាកិលេស

ដែលមានអាការៈស្ងប់ ល្អិត ធ្វើនូវអាល័យក្នុងវិបស្សនាដែលប្រដាប់ដោយឱភាសជាដើមយ៉ាងនេះ រមែងកើតឡើង ។ កាលវិបស្សនូបក្កិលេស មានញាណជាដើមឯណានីមួយ ក្នុងវិបស្សនូបក្កិលេសទាំងឡាយនោះកើតឡើងដូចឱភាស ព្រះយោគាវចរគិតថា មុនអំពីនេះ ញាណបែបនេះ មិនធ្លាប់កើតឡើងដល់អញ បីតិ បស្សទ្ធិ អធិមោក្ខៈ បគ្គហៈ ឧបដ្ឋានៈ ឧបេក្ខា និកន្តិក៏មិនធ្លាប់កើតឡើង អញជាបុគ្គលសម្រេចមគ្គ ជាបុគ្គលសម្រេចផលពិតប្រាកដ ហើយកាន់យកវត្ថុមិនមែនមគ្គ ថាជាមគ្គ វត្ថុមិនមែនផល ថាជាផល កាលព្រះយោគាវចរនោះ កាន់យកវត្ថុមិនមែនមគ្គ ថាជាមគ្គ និងវត្ថុមិនមែនផល ថាជាផល វិបស្សនាវិថីរមែងខុសផ្លូវ ។

ព្រះយោគាវចរនោះលះមូលកម្មដ្ឋានរបស់ខ្លួនហើយ អង្គុយត្រេកអរនឹងនិកន្តិនោះឯង ។ ក្នុងបទនេះលោកពោលឱភាសជាដើមថា ជាឧបក្កិលេស ព្រោះជាទីតាំងនៃសេចក្តីសៅហ្មង មិនមែនព្រោះជាអកុសល ។ ចំណែកនិកន្តិជាឧបក្កិលេសផង និងជាទីតាំងនៃសេចក្តីសៅហ្មងផង ។ ឧបក្កិលេសទាំងនោះ មាន ១០ យ៉ាង ដោយអំណាចនៃវត្ថុ តែមាន ៣០ ដោយអំណាចនៃការកាន់យក ។ សេចក្តីនេះដូចម្តេច កាលព្រះយោគាវចរ កាន់យកថា ឱភាសកើតឡើងហើយដល់អញ រមែងជាការប្រកាន់ដោយទិដ្ឋិ កាលកាន់យកថា ឱភាសគួរពេញចិត្ត កើតឡើងហើយហ្ន៎ រមែងជាការប្រកាន់ដោយមានះ កាលត្រេកអរនឹងឱភាស រមែងជាការប្រកាន់ដោយតណ្ហា ។ ដោយប្រការដូច្នេះ ទើបក្នុងឱភាសមានការកាន់យក ៣ យ៉ាង

ដោយអំណាចនៃទិដ្ឋិ មានះ និងតណ្ហា ។ ក្នុងឧបក្កិលេសដ៏សេសក៏ដូច្នោះ ព្រោះហេតុនោះ ទើបឧបក្កិលេសមាន ៣០ ដោយអំណាចនៃការកាន់យក ដោយប្រការដូច្នេះ ។

ក្នុងវារៈទាំងឡាយថា **ឧប្បាទោ មនសិការតោ អនត្តតោ មនសិការតោ** គប្បីជ្រាបអត្ថដោយន័យនេះ ។ ក្នុងអធិការនេះ គប្បីជ្រាបការកើតនៃវិបស្សនូបក្កិលេសទីមួយៗដោយអំណាចនៃអនុបស្សនាទីមួយៗ មិនមែននៃវិបស្សនូបក្កិលេសតែម្យ៉ាងប៉ុណ្ណោះទេ ។

[ ១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនុបស្សនា ៣ ដូចតទៅនេះថា ព្រះសារីបុត្តត្ថេរ លុះសម្តែងឧបក្កិលេសទាំងឡាយ ដោយអំណាចនៃវិបស្សនា ដោយមិនផ្សេងគ្នាយ៉ាងនេះហើយ កាលនឹងសម្តែងដោយអំណាចនៃការផ្សេងគ្នាទៀតទើបពោលពាក្យជាដើមថា **រូបំ អនិច្ចតោ មនសិការតោ** ។

ក្នុងបទទាំងនោះ បទថា **ជរា មរណំ អនិច្ចតោ ឧបដ្ឋានំ** បានដល់ការប្រាកដនៃជរានិងមរណៈ ដោយសភាពមិនទៀង ។

ព្រោះព្រះយោគាវចរអ្នកមិនឈ្លាស មិនមានបដិភាណ រមែងញាប់ញ័រក្នុងឱភាសជាដើម ដោយអំណាចនៃឧបក្កិលេស ៣០ ដូចពោលហើយក្នុងបទមុន រមែងពិចារណាឃើញវិបស្សនូបក្កិលេសទីមួយៗ មានឱភាសជាដើមថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ហេតុនោះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងសេចក្តីនោះ ទើបពោលគាថា ២ ថា **ឱភាសេ ចេវ ញាណេ ច** ជាដើម ។

ក្នុងបទទាំងនោះ បទថា **វិកម្បតិ** បានដល់ រមែងកម្រើកញាប់ញ័រ ដោយអាការផ្សេង ៗ ដោយអំណាចកិលេសផ្សេង ៗ ក្នុងអារម្មណ៍ មានឱកាសជាដើម ។ បទថា **យេហិ ចិត្តំ បវេធតិ** បានដល់ ចិត្តរមែងកម្រើកញាប់ញ័រព្រោះបស្សទ្ធិនិងសុខៈដោយប្រការផ្សេងៗ ដោយអំណាចកិលេសផ្សេង ៗ ។ ព្រោះហេតុនោះ គប្បីជ្រាបសម្ពន្ធថា ព្រះយោគាវចរ រមែងរសេមរសោមក្នុងបស្សទ្ធិនិងសុខៈ ។ បទថា **ឧបេក្ខាវជ្ជនាយ ចេវ** បានដល់ ចិត្តរមែងកម្រើកព្រោះអាវជ្ជនៈ ពោលគឺឧបេក្ខា អធិប្បាយថា រមែងញាប់ញ័រ ព្រោះអាវជ្ជនូបេក្ខា ។ តែក្នុងវិសុទ្ធិមគ្គ លោកពោលទុកថា **ឧ-បេក្ខាវជ្ជនាយញ្ច** ។ បទថា **ឧបេក្ខាយ ច** សេចក្តីថា ចិត្តរមែងកម្រើកព្រោះឧបេក្ខា មានប្រការដូចពោលហើយ និងរមែងកម្រើកព្រោះនិកន្តិ ។ ម្យ៉ាងទៀត ក្នុងបទនេះ ព្រោះលោកចង្អុលបង្ហាញដល់ឧបេក្ខា ២ យ៉ាង ទើបពោលអត្ថដោយប្រការទាំង ២ ក្នុងឋានៈដែលលោកធ្លាប់ពោលហើយថា **ឧបេក្ខា ឧប្បជ្ជតិ** ។ មានពាក្យអធិប្បាយថា ក្នុងអនិច្ចានុបស្សនាជាដើម អនុបស្សនាទីមួយ ៗ មានអាវជ្ជនូបេក្ខា ទើបព្រះយោគាវចរចម្រើនអនុបស្សនាទីមួយៗរឿយៗថា **អនិច្ចំ អនិច្ចំ ទុក្ខំ ទុក្ខំ អនត្តា អនត្តា** ។

ព្រះយោគាវចរជាអ្នកឈ្លាស ជាបណ្ឌិតមានបដិភាណ សម្បូណ៌ដោយការដឹង កាលឱភាសជាដើមកើតឡើងរមែងកំណត់ រមែងពិចារណាឱភាសនោះដោយបញ្ញាដូច្នេះថា ឱភាសនេះកើតឡើងហើយដល់អញ ឱភាសនេះឯងជាសភាវៈមិនទៀង មានបច្ច័យតាក់តែងអាស្រ័យគ្នាកើតឡើង មានការ

អស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការបន្ទោបង់រាគៈ ជាធម្មតា មានការរំលត់កិលេសជាធម្មតា ។

ម្យ៉ាងទៀត ព្រះយោគាវចរនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើឱកាសគប្បីជាតួខ្លួនសោត គួរប្រកាន់ថាជាតួខ្លួន តែឱកាសនេះ មិនមែនតួខ្លួននៅប្រកាន់ថាជាតួខ្លួន ព្រោះហេតុនោះ ព្រះយោគាវចរកាលឃើញថា ឱកាសនេះ មិនមែនតួខ្លួន ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច រមែងដកទិដ្ឋិចេញបាន បើឱកាសគប្បីជាសភាវៈទៀងសោត គួរដើម្បីប្រកាន់ថាជាសភាវៈទៀង តែឱកាសនេះ ជាសភាវៈមិនទៀង នៅប្រកាន់ថាជាសភាវៈទៀង ព្រោះហេតុនោះ ព្រះយោគាវចរ កាលឃើញថា ឱកាសនេះ ជាសភាវៈមិនទៀង ព្រោះមានហើយត្រឡប់ជាមិនមាន រមែងដកមានះចេញបាន ។ បើឱកាសគប្បីជាសុខសោត គួរប្រកាន់ថាជាសុខ តែឱកាសនេះជាទុក្ខ ក៏នៅតែប្រកាន់ថាជាសេចក្តីសុខ ព្រោះហេតុនោះ ព្រះយោគាវចរ កាលឃើញថា ឱកាសនេះជាទុក្ខ ព្រោះត្រូវបៀតបៀនដោយការកើតឡើង និងការវិនាសទៅ រមែងគ្របសង្កត់និកន្តិបាន ។ ក្នុងឱកាសយ៉ាងណា សូម្បីក្នុងវិបស្សនូបក្កិលេសដ៏សេស ក៏យ៉ាងនោះ ។

ព្រះយោគាវចរ លុះពិចារណាយ៉ាងនេះហើយ រមែងពិចារណាឃើញឱកាសថា ទុំះមិនមែនរបស់អញ ទុំះមិនមែនជាអញ ទុំះមិនមែនជាតួខ្លួនរបស់អញ រមែងពិចារណាឃើញញាណ ។បេ។ និកន្តិថា ទុំះមិនមែនជារបស់អញ ទុំះមិនមែនអញ ទុំះមិនមែនខ្លួនរបស់អញ កាលពិចារណាយ៉ាង

នេះ រមែងមិនកម្រើក មិនញាប់ញ័រក្នុងឱកាសជាដើម ព្រោះហេតុនោះព្រះសារីបុត្តត្ថេរ កាលសម្តែងសេចក្តីនោះ ទើបពោលគាថាថា **ឥមានិ ឆស ឋានានិ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឆស ឋានានិ** បានដល់ ឋានៈមានឱកាសជាដើម ។ បទថា **បញ្ញាយស្ស បរិចិត្វា** បានដល់ កិក្ខុកំណត់ ពាល់ត្រូវ អប់រំរឿយៗដោយបញ្ញាដែលផុតចាកឧបក្កិលេស ។ បទថា **ធម្មុទ្ធច្ចកុសលោ ហោតិ** បានដល់ ព្រះយោគាវចរនោះ ជាអ្នកកំណត់ឋានៈ ១០ យ៉ាងដោយបញ្ញា ជាអ្នកឈ្លាសដោយការចាក់ធ្លុះតាមសេចក្តីពិតនូវធម្មុទ្ធច្ចៈដែលមានប្រការដូចពោលហើយ ។

បទថា **ន ច សម្មោហា គច្ឆតិ** បានដល់ មិនដល់នូវការវង្វេងដោយការដកតណ្ហា មានះ និងទិដ្ឋិ ព្រោះជាអ្នកឈ្លាសក្នុងធម្មុទ្ធច្ចៈ ។

ឥឡូវនេះព្រះសារីបុត្តត្ថេរ កាលសម្តែងវិធីដែលពោលទុកហើយ ក្នុងផ្នែកមុនឲ្យជាក់ច្បាស់ដោយបរិយាយដទៃទៀត ទើបពោលគាថាថា **វិក្ខិបតិ ចេវ កិលិស្សតិ ច** ជាដើម ។ ក្នុងបទនោះ ព្រះយោគាវចរ មានបញ្ញាទន់ខ្សោយ រមែងដល់សេចក្តីរាយមាយក្នុងឱកាសជាដើម និងដល់នូវការកើតឡើងនៃកិលេសដ៏សេស ។ ព្រះយោគាវចរ មានបញ្ញាថ្នាក់កណ្តាលរមែងដល់នូវការរាយមាយ មិនដល់នូវការកើតនៃកិលេសដ៏សេស ព្រះយោគាវចរនោះ រមែងសម្គាល់ថា ខ្ញុំនសម្រេច ។ ព្រះយោគាវចរមានបញ្ញាចាស់ក្លា សូម្បីដល់នូវការរាយមាយ ក៏នៅលះការសម្គាល់ថា ខ្ញុំន

សម្រេចនោះ ហើយប្រារព្ធវិបស្សនា ។ ចំណែកព្រះយោគាវចរអ្នកមានបញ្ញាមុតស្រួចក្រៃលែង មិនដល់នូវការរាយមាយ និងមិនដល់នូវការកើតឡើងនៃកិលេសដ៏សេស ។ បទថា **វិក្ខិប្បតិ ចេវ** បានដល់ ក្នុងព្រះយោគាវចរទាំងនោះ ព្រះយោគាវចរដែលមានបញ្ញាទន់ខ្សោយ រមែងដល់នូវការរាយមាយ គឺឧទ្ធច្ចៈ ។ បទថា **កិលិស្សតិ ច** បានដល់ ព្រះយោគាវចរត្រូវកិលេស គឺតណ្ហា មានះនិងទិដ្ឋិធ្វើឲ្យសៅហ្មង អធិប្បាយថា ត្រូវធ្វើឲ្យក្តៅក្រហាយ ត្រូវបៀតបៀន ។ បទថា **ចវតិ ចិត្តភាវនា** បានដល់ ចិត្តភាវនា គឺវិបស្សនារបស់ព្រះយោគាវចរនោះ ដែលមានបញ្ញាទន់ខ្សោយ រមែងឃ្លាត អធិប្បាយថា រមែងធ្លាក់ទៅ ព្រោះមិនកម្ចាត់ធម៌ដែលជាបដិបក្ខ ដោយតាំងនៅក្នុងកិលេសទាំងឡាយនោះឯង ។ បទថា **វិក្ខិបតិ ន កិលិស្សតិ** បានដល់ ព្រះយោគាវចរមានបញ្ញាថ្នាក់កណ្តាល រមែងញាប់ញ័រដោយការរាយមាយ រមែងមិនសៅហ្មងដោយកិលេសទាំងឡាយ ។ បទថា **ភាវនា បរិហាយតិ** បានដល់ វិបស្សនារបស់ព្រះយោគាវចរដែលមានបញ្ញាថ្នាក់កណ្តាលនោះ រមែងវិនាស អធិប្បាយថា មិនប្រព្រឹត្តទៅព្រោះមិនមានការប្រារព្ធវិបស្សនា ព្រោះមានការសម្គាល់ថា បានសម្រេច ។ បទថា **វិក្ខិបតិ ន កិលិស្សតិ** បានដល់ ព្រះយោគាវចរ អ្នកមានបញ្ញាចាស់ក្លាក៏រមែងញាប់ញ័រដោយសេចក្តីរាយមាយ តែមិនសៅហ្មងដោយកិលេស ។ បទថា **ភាវនា ន បរិហាយតិ** បានដល់ កាលនៅមានការរាយមាយ វិបស្សនាភាវនារបស់ព្រះយោគាវចរ ដែលមានបញ្ញាមុតស្រួចនោះ រមែង

មិនវិនាស អធិប្បាយថា រមែងប្រព្រឹត្តទៅ ព្រោះលះការរាយមាយថាខ្លួន បានសម្រេចនោះហើយ មានការប្រារព្ធវិបស្សនា ។

បទថា **ន ច វិក្ខិប្បតេ ចិត្តំ ន កិលិស្សតិ** បានដល់ ចិត្តរបស់ព្រះយោគាវចរដែលមានបញ្ញាមុតស្រួចក្រៃលែង រមែងមិនរាយមាយដោយឧទ្ធច្ចៈ និងមិនសៅហ្មងដោយកិលេសទាំងឡាយ ។ បទថា **ន ចវតិ ចិត្តភាវនា** បានដល់ ចិត្តភាវនា គឺវិបស្សនារបស់ព្រះយោគាវចរនោះ រមែងមិនឃ្លាត អធិប្បាយថា តាំងនៅក្នុងទីដដែល ព្រោះមិនមានកិលេស ដែលធ្វើឲ្យរាយមាយ ។

ក្នុងបទថា **ឥមេហិ ចតូហិ ឋានេហិ** ជាដើម គប្បីជ្រាបការពណ៌នាសេចក្ដីដោយសម្ពន្ធថា ព្រោះឋានៈទាំង ៤ នេះ ដែលជាហេតុ ឬដែលជាករណៈដែលទើងពោលក្នុងឥឡូវនេះ ព្រះយោគាវចរ ពួកទី ៤ ជាអ្នកឈ្លាស មានបញ្ញាច្រើន ប្រាសចាកការកើតឡើងនៃកិលេស ដែលធ្វើឲ្យរាយមាយ រមែងដឹងឋានៈ ១០ មានឱកាសជាដើម គឺចិត្តដែលត្រូវភាពរួញរា និងការរាយមាយនៃចិត្ត រកាំងទុកដោយប្រការផ្សេងៗថា ព្រះយោគាវចរ ៣ ពួក មានព្រះយោគាវចរដែលបញ្ញាទន់ខ្សោយជាដើម រមែងមានចិត្តយ៉ាងនេះឯង ។

បទថា **សង្ខេបោ** គប្បីជ្រាបចិត្តដែលរួញរាដោយអំណាចការកើតឡើងនៃចិត្តដែលរាយមាយនិងនៃកិលេសទាំងឡាយ ។ បទថា **វិក្ខេបោ** គប្បីជ្រាបភាពដែលចិត្តរាយមាយដោយអំណាចនៃសេចក្ដីរាយមាយ ដូចពោល

ហើយក្នុងឋានៈទាំងឡាយ ២ ថា **វិក្ខេបតិ** ឆ **កិលិស្សតិ** ( ចិត្តកាវនា ) ញាប់ញ័រ មិនសៅហ្មងដូច្នេះឯង ។

អដ្ឋកថាធម្មទ្ធច្ចវារៈនិទ្ទេស ចប់

អដ្ឋកថាយុគនទ្ធកថា ចប់

# សុត្តន្តបិដក

## យុគនទ្ធវគ្គ សច្ចកថា

### បរិបុណ្ណកថានិទាន

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ សច្ចៈ ៤ នេះជារបស់ពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត សច្ចៈ ៤ តើអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះទុក្ខ ទុក្ខសច្ចៈនុ៎ះជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះជារបស់មិនឃ្លៀងឃ្លាត ពាក្យថា នេះទុក្ខសមុទ័យ ទុក្ខសមុទយសច្ចនុ៎ះ ជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះជារបស់មិនឃ្លៀងឃ្លាត ពាក្យថានេះទុក្ខនិរោធ ទុក្ខនិរោធ-សច្ចនុ៎ះ ជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះជារបស់មិនឃ្លៀងឃ្លាត ពាក្យថា នេះទុក្ខនិរោធគាមិនីបដិបទា ទុក្ខនិរោធសច្ចៈនុ៎ះ ជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះជារបស់មិនឃ្លៀងឃ្លាត ម្នាលភិក្ខុទាំងឡាយ សច្ចៈ ៤ នេះឯងជារបស់ពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត ។

[ ១៦ ] ទុក្ខ ឈ្មោះថា សច្ចៈ ដោយអត្ថថា ជារបស់ពិត តើដូចម្តេច ។ អត្ថនៃទុក្ខរបស់ទុក្ខជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត មាន ៤ យ៉ាងគឺ ទុក្ខ មានអត្ថថា បៀតបៀន ១ មានអត្ថថា បច្ច័យប្រជុំតាក់តែង ១ មានអត្ថថា ក្តៅក្រហាយ ១ មានអត្ថថា ប្រែប្រួល ១ នេះអត្ថនៃទុក្ខរបស់ទុក្ខ ៤ យ៉ាង ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត ទុក្ខឈ្មោះថា សច្ចៈ ដោយអត្ថថា ជារបស់ពិត យ៉ាងនេះឯង ។

សមុទ័យ ឈ្មោះថា សច្ចៈ ដោយអត្ថថា ជារបស់ពិត តើដូចម្តេច ។

អត្ថនៃសមុទ័យរបស់សមុទ័យជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត មាន ៤ យ៉ាងគឺ សមុទ័យមានអត្ថថា ប្រមូលមក ១ មានអត្ថថាជាហេតុ ១ មានអត្ថថា ប្រកបទុក ១ មានអត្ថថា កង្វល់ ១ នេះអត្ថនៃសមុទ័យរបស់សមុទ័យ ៤ យ៉ាង ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត សមុទ័យ ឈ្មោះថា សច្ចៈ ដោយអត្ថថា ជារបស់ពិត យ៉ាងនេះឯង ។

និរោធ ឈ្មោះថា សច្ចៈ ដោយអត្ថថា ជារបស់ពិត តើដូចម្តេច ។ អត្ថនៃនិរោធរបស់និរោធ ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាតមាន ៤ គឺ និរោធមានអត្ថថា រលាស់ខ្លួនចេញ ១ មានអត្ថថា ស្ងប់ស្ងាត់ ១ មានអត្ថថា មិនមានបច្ច័យប្រជុំតាក់តែង ១ មានអត្ថថា មិនស្លាប់ ១ នេះអត្ថនៃនិរោធរបស់និរោធ ៤ យ៉ាង ជាសភាពពិតមិនប្រែប្រួល មិនឃ្លៀងឃ្លាត និរោធ ឈ្មោះថា សច្ចៈ ដោយអត្ថថា ជារបស់ពិត យ៉ាងនេះឯង ។

មគ្គ ឈ្មោះថា សច្ចៈ ដោយអត្ថថា ជារបស់ពិត តើដូចម្តេច ។ អត្ថនៃមគ្គរបស់មគ្គ ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត មាន ៤ គឺ មគ្គមានអត្ថថា នាំចេញ ១ មានអត្ថថា ជាហេតុ ១ មានអត្ថថា ឃើញ ១ មានអត្ថថា ជាអធិបតី ១ នេះអត្ថនៃមគ្គរបស់មគ្គ ៤ យ៉ាង ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត មគ្គ ឈ្មោះថា សច្ចៈ ដោយអត្ថថា ជារបស់ពិត យ៉ាងនេះឯង ។

[ ១៧ ] សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការប៉ុន្មានយ៉ាង ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយដោយអាការ ៤ យ៉ាងគឺ ដោយអត្ថថា

ជារបស់ពិត ១ ដោយអត្ថថា មិនមែនខ្លួន ១ ដោយអត្ថថា ទៀង ១ ដោយអត្ថថា ត្រាស់ដឹង ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយដោយអាការ ៤ យ៉ាង សច្ចៈណាដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះមានសភាពតែមួយ បុគ្គលត្រាស់ដឹងនូវសច្ចៈមាន ភាពតែមួយដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ជារបស់ពិត តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ជារបស់ពិត ដោយអាការ ៤ យ៉ាងគឺ ទុក្ខមានអត្ថថា លំបាក ជាអត្ថថាពិត ១ សមុទ័យមានអត្ថថាជាដែនកើត ជាអត្ថថាពិត ១ និរោធមានអត្ថថារលត់ជាអត្ថថាពិត ១ មគ្គមានអត្ថថាជាផ្លូវ ជាអត្ថថាពិត ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថា ជារបស់ពិត ដោយអការ ៤ យ៉ាង សច្ចៈណាដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះមានភាពតែមួយ បុគ្គលត្រាស់ដឹងនូវសច្ចៈមានភាពតែមួយ ដោយញាណមួយ ហេតុនោះសច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា មិនមែនខ្លួន តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា មិនមែនខ្លួនដោយអាការ ៤ យ៉ាងគឺ ទុក្ខមានអត្ថថាលំបាក ជាអត្ថថាមិនមែនខ្លួន ១ សមុទ័យមានអត្ថថាជាដែនកើត ជាអត្ថថាមិនមែនខ្លួន ១ និរោធមានអត្ថថារលត់ ជាអត្ថថាមិនមែនខ្លួន ១ មគ្គមានអត្ថថាជាផ្លូវ ជាអត្ថថាមិន

មែនខ្លួន ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថាមិនមែនខ្លួន ដោយអាការ ៤ យ៉ាង សច្ចៈណាដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះមានភាពតែមួយ បុគ្គលត្រាស់ដឹងនូវសច្ចៈមានភាពតែមួយ ដោយញាណមួយ ហេតុនោះសច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ទៀង តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ទៀង ដោយអាការ ៤ យ៉ាង គឺទុក្ខមានអត្ថថាលំបាក ជាអត្ថថាទៀង ១ សមុទ័យមានអត្ថថាជាដែនកើត ជាអត្ថថាទៀង ១ និរោធមានអត្ថថារលត់ ជាអត្ថថាទៀង ១ មគ្គមានអត្ថថាជាផ្លូវ ជាអត្ថថាទៀង ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថា ទៀង ដោយអាការ ៤ យ៉ាង សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលត្រាស់ដឹងនូវសច្ចៈមានភាពតែមួយដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ត្រាស់ដឹង តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ត្រាស់ដឹង ដោយអាការ ៤ យ៉ាង គឺទុក្ខមានអត្ថថាលំបាក ជាអត្ថថាត្រាស់ដឹង ១ សមុទ័យមានអត្ថថាជាដែនកើត ជាអត្ថថាត្រាស់ដឹង ១ និរោធមានអត្ថថារលត់ ជាអត្ថថាត្រាស់ដឹង ១ មគ្គមានអត្ថថាជាផ្លូវ ជាអត្ថថាត្រាស់ដឹង ១

នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថាត្រាស់ដឹង ដោយអាការ ៤ យ៉ាង សច្ចៈណាដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលត្រាស់ដឹងនូវសច្ចៈមានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

[ ១៨ ] សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការប៉ុន្មាន ។ វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ វត្ថុណាមិនទៀងផង ជាទុក្ខផង វត្ថុនោះមិនមែនរបស់ខ្លួន វត្ថុណាមិនទៀងផង ជាទុក្ខផង មិនមែនរបស់ខ្លួនផង វត្ថុនោះពិត វត្ថុណាមិនទៀងផង ជាទុក្ខផង មិនមែនរបស់ខ្លួនផង ពិតផង វត្ថុនោះទៀង វត្ថុណាមិនទៀងផង ជាទុក្ខផង មិនមែនរបស់ខ្លួនផង ពិតផងទៀងផង វត្ថុនោះលោកសង្គ្រោះយកតែមួយ វត្ថុណាដែលលោកសង្គ្រោះយកតែមួយ វត្ថុនោះឈ្មោះថា មានភាពតែមួយ បុគ្គលរមែង ត្រាស់ដឹងនូវវត្ថុមានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយដោយអាការប៉ុន្មាន ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការ ៩ គឺដោយអត្ថថា ពិត ១ ដោយអត្ថថា មិនមែនខ្លួន ១ ដោយអត្ថថា ទៀង ១ ដោយអត្ថថា ត្រាស់ដឹង ១ ដោយអត្ថថា ដឹងច្បាស់ ១ ដោយអត្ថថា កំណត់ដឹង ១ ដោយអត្ថថា លះ ១ ដោយអត្ថថា ចម្រើន ១ ដោយអត្ថថា ធ្វើឲ្យជាក់ច្បាស់ ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយដោយអាការ ៩ យ៉ាង សច្ចៈ

ណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈមានភាពតែមួយដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

[ ១៩ ] សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ពិត តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយដោយអត្ថថា ពិត ដោយអាការ ៩ គឺទុក្ខមានអត្ថថាលំបាក ជាអត្ថថាពិត ១ សមុទ័យមានអត្ថថា ជាដែនកើត ជាអត្ថថាពិត ១ និរោធមានអត្ថថារលត់ ជាអត្ថថាពិត ១ មគ្គមានអត្ថថាជាផ្លូវ ជាអត្ថថាពិត ១ អភិញ្ញាមានអត្ថថាដឹងច្បាស់ ជាអត្ថថាពិត ១ បរិញ្ញាមានអត្ថថាកំណត់ដឹង ជាអត្ថថាពិត ១ បហានៈមានអត្ថថាលះ ជាអត្ថថាពិត ១ ភាវនាមានអត្ថថាចម្រើន ជាអត្ថថាពិត ១ សច្ឆិកិរិយា មានអត្ថថាធ្វើឲ្យជាក់ច្បាស់ ជាអត្ថថាពិត ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថាពិត ដោយអាការ ៩ យ៉ាង សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈមានភាពតែមួយ ដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់តែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា មិនមែនខ្លួន ដោយអត្ថថា ទៀង ដោយអត្ថថា ត្រាស់ដឹង តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ត្រាស់ដឹង ដោយអាការ ៩ គឺទុក្ខ មានអត្ថថាលំបាក ជាអត្ថថាត្រាស់ដឹង ១ សមុទ័យមានអត្ថថាជាដែនកើត ជា

អត្ថថាត្រាស់ដឹង ១ និរោធមានអត្ថថារលត់ ជាអត្ថថាត្រាស់ដឹង ១ មគ្គមានអត្ថថាជាផ្លូវ ជាអត្ថថាត្រាស់ដឹង ១ អភិញ្ញាមានអត្ថថាដឹងច្បាស់ ជាអត្ថថាត្រាស់ដឹង ១ បរិញ្ញាមានអត្ថថាកំណត់ដឹង ជាអត្ថថាត្រាស់ដឹង ១ បហានៈមានអត្ថថាលះ ជាអត្ថថាត្រាស់ដឹង ១ ភាវនាជាអត្ថថាចម្រើន ជាអត្ថថាត្រាស់ដឹង ១ សច្ឆិកិរិយាមានអត្ថថា ធ្វើឲ្យជាក់ច្បាស់ ជាអត្ថថា ត្រាស់ដឹង ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអត្ថថាត្រាស់ដឹង ដោយអាការ ៩ យ៉ាង សច្ចៈណាដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះមានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈ មានភាពតែមួយដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

[ ២០ ] សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអាការប៉ុន្មាន ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយដោយអាការ ១២ គឺដោយអត្ថថាទៀង ១ ដោយអត្ថថា មិនមែនរបស់ខ្លួន ១ ដោយអត្ថថា ពិត ១ ដោយអត្ថថា ត្រាស់ដឹង ១ ដោយអត្ថថា ដឹងច្បាស់ ១ ដោយអត្ថថា កំណត់ដឹង ១ ដោយអត្ថថា ជាធម្មតា ១ ដោយអត្ថថា ទៀង ១ ដោយអត្ថថា ដឹង ១ ដោយអត្ថថា ធ្វើឲ្យជាក់ច្បាស់ ១ ដោយអត្ថថា ពាល់ត្រូវ ១ ដោយអត្ថថា យល់ច្បាស់ ១ នេះសច្ចៈទាំង ៤ ដែលលោកសង្គ្រោះយកតែមួយ ដោយអាការ ១២ សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះមានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈមានភាពតែមួយ ដោយ

ញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយដោយអត្ថថា ទៀង តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា ទៀង ដោយអាការ ១៦ គឺទុក្ខ មានអត្ថថា បៀតបៀន ១ មានអត្ថថា បច្ច័យប្រជុំតាក់តែង ១ មានអត្ថថា ក្តៅក្រហាយ ១ មានអត្ថថា ប្រែប្រួល ១ ជាអត្ថថាទៀង សមុទ័យ មានអត្ថថា ប្រមូលមក ១ មានអត្ថថា ជាហេតុ ១ មានអត្ថថា ប្រកបទុក ១ មានអត្ថថា កង្វល់ ១ ជាអត្ថថាទៀង និរោធ មានអត្ថថា រលាស់ចេញ ១ មានអត្ថថា ស្ងប់ស្ងាត់ ១ មានអត្ថថា មិនមានបច្ច័យ ប្រជុំតាក់តែង ១ មានអត្ថថា មិនស្លាប់ ១ ជាអត្ថថាទៀង មគ្គ មានអត្ថថា ស្រោចស្រង់ ១ មានអត្ថថា ជាហេតុ ១ អត្ថថា ឃើញ ១ មានអត្ថថា ជាអធិបតី ១ ជាអត្ថថាទៀង នេះសច្ចៈទាំង ៤ ដោយអត្ថថាទៀង ដោយអាការ ១៦ ដែលលោកសង្គ្រោះយកតែមួយ សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈមានភាពតែមួយដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា មិនមែនរបស់ខ្លួន ។បេ។ ដោយអត្ថថា ពិត ដោយអត្ថថា ត្រាស់ដឹង ដោយអត្ថថា ដឹងច្បាស់ ដោយអត្ថថា កំណត់ដឹង ដោយអត្ថថា ជាធម្មតា ដោយអត្ថថា ទៀង ដោយអត្ថថា ដឹង ដោយអត្ថថា ធ្វើឲ្យជាក់ច្បាស់ ដោយអត្ថ

ថា ពាល់ត្រូវ ដោយអត្ថថា យល់ច្បាស់ តើដូចម្តេច ។ សច្ចៈទាំង ៤ ជាទីត្រាស់ដឹងតែមួយ ដោយអត្ថថា យល់ច្បាស់ ដោយអាការ ១៦ គឺ ទុក្ខ មានអត្ថថា បៀតបៀន ១ មានអត្ថថា បច្ច័យប្រជុំតាក់តែង ១ មានអត្ថថា ក្តៅក្រហាយ ១ មានអត្ថថា ប្រែប្រួល ១ ជាអត្ថថាយល់ច្បាស់ សមុទ័យ មានអត្ថថា ប្រមូលមក ១ មានអត្ថថា ជាហេតុ ១ មានអត្ថថា ប្រកបទុក ១ មានអត្ថថា កង្វល់ ១ ជាអត្ថថា យល់ច្បាស់ និរោធ មានអត្ថថា រលាស់ចេញ ១ មានអត្ថថា ស្ងប់ស្ងាត់ ១ មានអត្ថថា មិនមានបច្ច័យប្រជុំតាក់តែង ១ មានអត្ថថា មិនស្លាប់ ១ ជាអត្ថថា យល់ច្បាស់ មគ្គ មានអត្ថថា ស្រោចស្រង់ ១ មានអត្ថថា ជាហេតុ ១ មានអត្ថថា ឃើញ ១ មានអត្ថថា ជាអធិបតី ១ ជាអត្ថថាយល់ច្បាស់ នេះ សច្ចៈទាំង ៤ ដោយអត្ថថាយល់ច្បាស់ដោយអាការ ១៦ យ៉ាង ដែលលោកសង្គ្រោះយកតែមួយ សច្ចៈណា ដែលលោកសង្គ្រោះយកតែមួយ សច្ចៈនោះ មានភាពតែមួយ បុគ្គលរមែងត្រាស់ដឹងនូវសច្ចៈមានភាពតែមួយដោយញាណមួយ ហេតុនោះ សច្ចៈទាំង ៤ ឈ្មោះថា ជាទីត្រាស់ដឹងតែមួយ ។

[ ២១ ] លក្ខណៈរបស់សច្ចៈ មានប៉ុន្មាន ។ លក្ខណៈរបស់សច្ចៈមាន ២ គឺសង្ខតលក្ខណៈ ១ អសង្ខតលក្ខណៈ ១ នេះលក្ខណៈ ២ របស់សច្ចៈ ។

លក្ខណៈរបស់សច្ចៈ មានប៉ុន្មាន ។ លក្ខណៈរបស់សច្ចៈមាន ៦ គឺ សច្ចៈទាំងឡាយជាសង្ខតៈ មានការកើតឡើងប្រាកដ ១ មានការសូន្យប្រា-

កដ ១ សច្ចៈទាំងឡាយដែលឋិតនៅមានការប្រែប្រួលប្រាកដ ១ សច្ចៈជាអសង្ខតៈ មានការកើតឡើងមិនប្រាកដ ១ មានការសូន្យមិនប្រាកដ ១ សច្ចៈដែលឋិតនៅ មានការប្រែប្រួលមិនប្រាកដ ១ នេះលក្ខណៈ ៦ របស់សច្ចៈ ។

លក្ខណៈរបស់សច្ចៈ មានប៉ុន្មាន ។ លក្ខណៈរបស់សច្ចៈមាន ១២ គឺទុក្ខសច្ចៈ មានការកើតឡើងប្រាកដ ១ មានការសូន្យប្រាកដ ១ ទុក្ខសច្ចៈដែលឋិតនៅមានការប្រែប្រួលប្រាកដ ១ សមុទយសច្ច មានការកើតឡើងប្រាកដ ១ មានការសូន្យប្រាកដ ១ សមុទយសច្ចដែលឋិតនៅ មានការប្រែប្រួលប្រាកដ ១ មគ្គសច្ច មានការកើតឡើងប្រាកដ ១ មានការសូន្យប្រាកដ ១ មគ្គសច្ចដែលឋិតនៅ មានការប្រែប្រួលប្រាកដ ១ និរោធសច្ចមានការកើតឡើងមិនប្រាកដ ១ មានការសូន្យមិនប្រាកដ ១ មគ្គសច្ច ដែលឋិតនៅ មានការប្រែប្រួលមិនប្រាកដ ១ នេះលក្ខណៈ ១២ របស់សច្ចៈ ។

[ ២២ ] បណ្តាសច្ចៈទាំង ៤ សច្ចៈជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ សមុទយសច្ចជាអកុសល មគ្គសច្ចជាកុសល និរោធសច្ចជាអព្យាក្រឹត ទុក្ខសច្ចជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន សច្ចៈ ៣ សោកសង្គ្រោះ ដោយសច្ចៈមួយ សច្ចៈមួយ សោកសង្គ្រោះដោយសច្ចៈ ៣ តាមបរិយាយដោយអំណាចនៃវត្ថុ ។

សំណួរត្រង់ពាក្យថា ក៏មាន តើមានដូចម្តេច ។ ចម្លើយថា ត្រង់ថាទុក្ខសច្ចជាអកុសល សមុទយសច្ចជាអកុសលយ៉ាងនេះ ឈ្មោះថា សច្ចៈ

២ ដោយអត្ថថា អកុសល លោកសង្គ្រោះដោយសច្ចៈមួយ សច្ចៈមួយលោកសង្គ្រោះដោយសច្ចៈពីរ ត្រង់ថា ទុក្ខសច្ចជាកុសល មគ្គសច្ចជាកុសលយ៉ាងនេះ ឈ្មោះថា សច្ចៈពីរ ដោយអត្ថថា ជាកុសល លោកសង្គ្រោះដោយសច្ចៈមួយ សច្ចៈមួយលោកសង្គ្រោះដោយសច្ចៈពីរ ត្រង់ថា ទុក្ខសច្ចជាអព្យាក្រឹត និរោធសច្ចៈជាអព្យាក្រឹតយ៉ាងនេះ ឈ្មោះថា សច្ចៈពីរ ដោយអត្ថថា ជាអព្យាក្រឹត លោកសង្គ្រោះដោយសច្ចៈមួយ សច្ចៈមួយ លោកសង្គ្រោះដោយសច្ចៈពីរ សច្ចៈ ៣ លោកសង្គ្រោះដោយសច្ចៈមួយ សច្ចៈមួយលោកសង្គ្រោះដោយសច្ចៈ ៣ តាមបរិយាយដោយអំណាចនៃវត្ថុក៏មាន យ៉ាងនេះឯង ។

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹង មុនអំពីការត្រាស់ដឹងនៅឡើយ មានសេចក្តីត្រិះរិះថា រូបមានអានិសង្សដូចម្តេច មានទោសដូចម្តេច មានការរលាស់ចេញដូចម្តេច វេទនាមានអានិសង្សដូចម្តេច មានទោសដូចម្តេច មានការរលាស់ចេញដូចម្តេច សញ្ញាមានអានិសង្សដូចម្តេច មានទោសដូចម្តេច មានការរលាស់ចេញដូចម្តេច សង្ខារទាំងឡាយមានអានិសង្សដូចម្តេច មានទោសដូចម្តេច មានការរលាស់ចេញដូចម្តេច វិញ្ញាណមានអានិសង្សដូចម្តេច មានទោសដូចម្តេច មានការរលាស់ចេញដូចម្តេច ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះដូច្នេះថា សុខ សោមនស្សកើតឡើងព្រោះអាស្រ័យរូប នេះជាអានិសង្សរបស់រូប រូបមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះ

ជាទោសរបស់រូប ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគឯណា ក្នុងរូប នេះជាការរលាស់ចេញនូវរូប សុខ សោមនស្ស កើតឡើង ព្រោះអាស្រ័យវេទនា ព្រោះអាស្រ័យសញ្ញា ព្រោះអាស្រ័យសង្ខារទាំងឡាយ ព្រោះអាស្រ័យវិញ្ញាណ នេះជាអានិសង្សរបស់វិញ្ញាណ វិញ្ញាណមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសរបស់វិញ្ញាណ ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគឯណា ក្នុងវិញ្ញាណ នេះជាការរលាស់ចេញនូវវិញ្ញាណ ។

[ ២៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ដឹងច្បាស់ តាមពិតនូវអានិសង្ស ថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ចេញថាជាការរលាស់ចេញផង របស់ឧបាទានក្ខន្ធទាំង ៥ នេះ យ៉ាងនេះដរាបណា ម្នាលភិក្ខុទាំងឡាយ ដរាបនោះ តថាគតក៏មិនទាន់ប្តេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ម្នាលភិក្ខុទាំងឡាយ លុះតែកាលណាតថាគតបានដឹងច្បាស់ តាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ចេញថាជាការរលាស់ចេញផងរបស់ឧបាទានក្ខន្ធ ៥ នេះ យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលណោះ តថាគតទើបប្តេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំង

មនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មួយទៀត ញាណជាគ្រឿងឃើញកើតហើយដល់តថាគតថា ចេតោវិមុត្តិរបស់តថាគត មិនកម្រើកទេ នេះជាជាតិទីបំផុត ឥឡូវនេះ ភពថ្មីមិនមានឡើយ ។

[ ២៥ ] ការត្រាស់ដឹងដោយអំណាចនៃការលះថា សុខ សោមនស្សកើតឡើង ព្រោះអាស្រ័យរូប នេះជាអានិសង្សរបស់រូបដូច្នេះ ឈ្មោះថាសមុទយសច្ច ការត្រាស់ដឹង ដោយអំណាចនៃការកំណត់ដឹងថា រូបមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា នេះជាទោសរបស់រូបដូច្នេះ ឈ្មោះថា ទុក្ខសច្ច ការត្រាស់ដឹងដោយអំណាចនៃការធ្វើឲ្យជាក់ច្បាស់ថា ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគឯណាក្នុងរូប នេះជាការរលាស់ចេញនូវរូបដូច្នេះ ឈ្មោះថា និរោធសច្ច ការត្រាស់ដឹងដោយអំណាចនៃការអប់រំគឺទិដ្ឋិ សង្កប្បៈ វាចា កម្មន្តៈ អាជីវៈ វាយាមៈ សតិ សមាធិ ក្នុងឋានៈទាំង ៣ នេះឈ្មោះថា មគ្គសច្ច ការត្រាស់ដឹងដោយអំណាចនៃការលះថា សុខ សោមនស្សកើតឡើង ព្រោះអាស្រ័យវេទនា ព្រោះអាស្រ័យសញ្ញា ព្រោះអាស្រ័យសង្ខារទាំងឡាយ ព្រោះអាស្រ័យវិញ្ញាណ នេះជាអានិសង្សរបស់វិញ្ញាណដូច្នេះ ឈ្មោះថា សមុទយសច្ច ការត្រាស់ដឹងដោយអំណាចនៃការកំណត់ដឹងថា វិញ្ញាណមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា នេះជាទោសរបស់វិញ្ញាណដូច្នេះ ឈ្មោះថាទុក្ខសច្ច ការត្រាស់ដឹង ដោយអំណាចនៃការធ្វើឲ្យជាក់ច្បាស់ថា ការបន្ទោបង់នូវឆន្ទរាគ ការលះបង់នូវឆន្ទរាគឯណាក្នុងវិញ្ញាណ នេះជាការរលាស់ចេញនូវវិញ្ញាណ

ដូច្នេះ ឈ្មោះថា និរោធសច្ច ការត្រាស់ដឹង ដោយអំណាចនៃការអប់រំ គឺ ទិដ្ឋិសង្កប្បៈ វាចា កម្មន្តៈ អាជីវៈ វាយាមៈ សតិ សមាធិ ក្នុងឋានៈ ៣ នេះឈ្មោះ មគ្គសច្ច ។

[ ២៦ ] សច្ចៈ ដោយអាការប៉ុន្មានយ៉ាង ។ សច្ចៈ ដោយអាការ ៣ យ៉ាងគឺ ដោយអត្ថថា ស្វែងរក ១ ដោយអត្ថថា ចំណាំទុក ១ ដោយអត្ថថា ត្រាស់ដឹង ១ ។

សច្ចៈ ដោយអត្ថថា ស្វែងរក តើដូចម្តេច ។ ជរា មរណៈមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក ជរា មរណៈមានជាតិជាហេតុ មានជាតិជាទីប្រជុំកើត មានជាតិជាកំណើត មានជាតិជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវជរា មរណៈផង ដឹងច្បាស់នូវទីប្រជុំកើតនៃជរាមរណៈផង ដឹងច្បាស់នូវការរលត់នៃជរាមរណៈផង ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ការរលត់នៃជរាមរណៈផង យ៉ាងនេះឈ្មោះថាសច្ចៈ ដោយអត្ថថា ត្រាស់ដឹង ។

ជាតិមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក ជាតិមានភពជាហេតុ មានភពជាទីប្រជុំកើត មានភពជាកំណើត មានភពជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវជាតិផង ដឹងច្បាស់នូវទីប្រជុំកើតនៃជាតិផង ដឹងច្បាស់នូវការរលត់នៃជាតិ

ផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃជាតិផង យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

ភពមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក ភពមានឧបាទានជាហេតុ មានឧបាទានជាទីប្រជុំកើត មានឧបាទានជាកំណើត មានឧបាទានជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវភពផង ដឹងច្បាស់នូវទីប្រជុំកើតនៃភពផង ដឹងច្បាស់នូវការរលត់នៃភពផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃភពផង យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

ឧបាទានមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក ឧបាទានមានតណ្ហាជាហេតុ មានតណ្ហាជាទីប្រជុំកើត មានតណ្ហាជាកំណើត មានតណ្ហាជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវឧបាទានផង ដឹងច្បាស់នូវទីប្រជុំកើតនៃឧបាទានផង ដឹងច្បាស់នូវការរលត់នៃឧបាទានផង ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ការរលត់នៃឧបាទានផង យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ត្រាស់ដឹង ។

តណ្ហាមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក តណ្ហាមាន

វេទនាជាហេតុ មានវេទនាជាទីប្រជុំកើត មានវេទនាជាកំណើត មានវេទនាជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវតណ្ហាផង ដឹងច្បាស់នូវទីប្រជុំកើតនៃតណ្ហាផង ដឹងច្បាស់នូវការ រលត់នៃតណ្ហាផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃតណ្ហាផង យ៉ាងនេះឈ្មោះ ថាសច្ចៈ ដោយអត្ថថា ត្រាស់ដឹង ។

វេទនាមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក វេទនាមានផស្សៈជាហេតុ មានផស្សៈជាទីប្រជុំកើត មានផស្សៈជាកំណើត មានផស្សៈជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវវេទនាផង ដឹងច្បាស់នូវទីប្រជុំកើតនៃវេទនាផង ដឹងច្បាស់នូវការរលត់នៃវេទនាផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃវេទនាផង យ៉ាងនេះឈ្មោះថាសច្ចៈ ដោយអត្ថថាត្រាស់ដឹង ។

ផស្សៈមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក ផស្សៈ មានសឡាយតនៈជាហេតុ មានសឡាយតនៈជាទីប្រជុំកើត មានសឡាយតនៈជាកំណើត មានសឡាយតនៈជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវផស្សៈផង ដឹងច្បាស់នូវទីប្រជុំកើតនៃផស្សៈផង ដឹងច្បាស់នូវការរលត់នៃផស្សៈផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃផស្សៈផង យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា

ត្រាស់ដឹង ។

សឡាយតនៈមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក សឡាយតនៈមាននាមរូបជាហេតុ មាននាមរូបជាទីប្រជុំកើត មាននាមរូបជាកំណើត មាននាមរូបជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវសឡាយតនៈផង ដឹងច្បាស់នូវទីប្រជុំកើតនៃសឡាយតនៈផងដឹងច្បាស់នូវការរលត់នៃសឡាយតនៈផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃសឡាយតនៈផង យ៉ាងនេះឈ្មោះថាសច្ចៈ ដោយអត្ថថា ត្រាស់ដឹង ។

នាមរូបមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក នាមរូបមានវិញ្ញាណជាហេតុ មានវិញ្ញាណជាទីប្រជុំកើត មានវិញ្ញាណជាកំណើតមានវិញ្ញាណជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវនាមរូបផង ដឹងច្បាស់នូវទីប្រជុំកើតនៃនាមរូបផង ដឹងច្បាស់នូវការរលត់នៃនាមរូបផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃនាមរូបផង យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ត្រាស់ដឹង ។

វិញ្ញាណមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក វិញ្ញាណមានសង្ខារជាហេតុ មានសង្ខារជាទីប្រជុំកើត មានសង្ខារជាកំណើត មាន

សង្ខារជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវវិញ្ញាណផង ដឹងច្បាស់នូវទីប្រជុំកើតនៃវិញ្ញាណផង ដឹងច្បាស់នូវការរលត់នៃវិញ្ញាណផង ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ការរលត់នៃវិញ្ញាណផង យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ត្រាស់ដឹង ។

សង្ខារមានអ្វីជាហេតុ មានអ្វីជាទីប្រជុំកើត មានអ្វីជាកំណើត មានអ្វីជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ស្វែងរក សង្ខារមានអវិជ្ជាជាហេតុ មានអវិជ្ជាជាទីប្រជុំកើត មានអវិជ្ជាជាកំណើត មានអវិជ្ជាជាដែនកើត យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ចំណាំទុក បុគ្គលដឹងច្បាស់នូវសង្ខារទាំងឡាយផង ដឹងច្បាស់នូវទីប្រជុំកើតនៃសង្ខារផង ដឹងច្បាស់នូវការរលត់នៃសង្ខារផង ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់ការរលត់នៃសង្ខារផង យ៉ាងនេះឈ្មោះថា សច្ចៈ ដោយអត្ថថា ត្រាស់ដឹង ។

[ ២៧ ] ជរា មរណៈជាទុក្ខសច្ច ជាតិជាសមុទយសច្ច ការរលាស់ចេញនូវជរា មរណៈនិងជាតិទាំងពីរជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច ជាតិជាទុក្ខសច្ច ភពជាសមុទយសច្ច ការរលាស់ចេញនូវជាតិនិងភពទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច ភពជាទុក្ខសច្ច ឧបាទានជាសមុទយសច្ច ការរលាស់ចេញនូវភពនិងឧបាទានទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច ឧបាទាន ជាទុក្ខសច្ច តណ្ហាជាសមុទយសច្ច ការរលាស់ចេញនូវឧបាទាននិងតណ្ហាទាំងពីរ ជា

និរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច តណ្ហាជាទុក្ខសច្ច វេទនាជាសមុទយសច្ច ការលះចេញនូវតណ្ហានិងវេទនាទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច វេទនាជាទុក្ខសច្ច ផស្សៈជាសមុទយសច្ច ការលះចេញនូវវេទនា និងផស្សៈទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច ផស្សៈជាទុក្ខសច្ច សឡាយតនៈជាសមុទយសច្ច ការលះចេញនូវផស្សៈនិងសឡាយតនៈទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច សឡាយតនៈជាទុក្ខសច្ច នាមរូបជាសមុ-ទយសច្ច ការលះចេញនូវសឡាយតនៈនិងនាមរូបទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច នាមរូបជាទុក្ខសច្ច វិញ្ញាណ ជាសមុ-ទយសច្ច ការលះចេញនូវនាមរូបនិងវិញ្ញាណទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច វិញ្ញាណជាទុក្ខសច្ច សង្ខារជាសមុទយសច្ច ការលះចេញនូវវិញ្ញាណនិងសង្ខារទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច សង្ខារទាំងឡាយជាទុក្ខសច្ច អវិជ្ជាជាសមុទយសច្ច ការលះចេញនូវសង្ខារនិងអវិជ្ជាទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច ។ ជរាមរណៈជាទុក្ខសច្ច ជាតិជាទុក្ខសច្ច ក៏មាន ជាសមុទយសច្ច ក៏មាន ការលះចេញនូវជរាមរណៈ និងជាតិទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច ជាតិជាទុក្ខសច្ច ភពជាទុក្ខសច្ចក៏មាន ជាសមុទយសច្ចក៏មាន ការលះចេញនូវជាតិនិងភពទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធជាមគ្គសច្ច ។បេ។ សង្ខារទាំងឡាយ

ជាទុក្ខសច្ច អវិជ្ជាជាទុក្ខសច្ចក៏មាន ជាសមុទយសច្ចក៏មាន ការរលាស់ចេញនូវសង្ខារនិងអវិជ្ជាទាំងពីរ ជានិរោធសច្ច ឯការដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច ។

ចប់ សច្ចកថា ។

ចប់ ភាណវារៈ ។

# អដ្ឋកថា

## សច្ចកថា

[ ១៥ ] ឥឡូវនេះ នឹងពណ៌នាតាមលំដាប់សេចក្តី ដែលនៅមិនទាន់ពណ៌នាក្នុងសច្ចកថា ដែលមានព្រះសូត្រជាបទនាំ ដែលព្រះសារីបុត្តត្រេរសម្តែងដល់សភាវៈនៃសច្ចៈ ភាពវិសេសនៃការចាក់ធ្លុះសច្ចៈនិងការកំណត់លក្ខណៈនៃសច្ចៈជាដើម ដោយអំណាចនៃអរិយមគ្គដែលជាគុណនៃធម៌គូគ្នាពោលទុកហើយ ។

ក្នុងបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រមុន ដូចតទៅនេះថា

បទថា **តថានិ** បានដល់ ជារបស់ពិតដោយសភាវៈពិត ។ ពិតណាស់ ធម្មជាតទាំងឡាយ ដែលជាសេចក្តីពិតនោះឯង ឈ្មោះថា សច្ចៈ ដោយអត្ថថា ពិត ។ សភាពនៃសច្ចៈ ខ្ញុំពោលទុកហើយក្នុងកាលពណ៌នាបឋមញ្ញាណនិទ្ទេស ។

បទថា **អវិតថានិ** បានដល់ ប្រាសចាកការផ្ទុយគ្នាក្នុងសភាវៈ ដែលពោលហើយ ។ សច្ចៈ ឈ្មោះថា មិនជាសច្ចៈ រមែងមិនមាន ។ បទថា **អនញ្ញថានិ** បានដល់ វៀរចាកសភាវៈដទៃ ។ វត្ថុដែលមិនជាសច្ចៈឈ្មោះថា ជាសច្ចៈ រមែងមិនមាន ។

បទថា **ឥទំ ទុក្ខន្តិ ភិក្ខវេ តថមេតំ** បានដល់ ម្នាលភិក្ខុទាំងឡាយ វត្ថុណាដែលពោលថា នេះជាទុក្ខ វត្ថុនេះឈ្មោះថា ជារបស់ពិត ព្រោះមានសភាវៈពិត ។ ពិតណាស់ ទុក្ខ ក៏គឺទុក្ខ ។ ឈ្មោះថា អវិតថៈ

ព្រោះមិនមានវត្ថុផ្សេងគ្នា ក្នុងសភាវៈដូចពោលហើយ ។ វត្ថុដែលឈ្មោះថា មិនជាទុក្ខមិនមាន ។ ឈ្មោះថា អនញ្ញថៈ ព្រោះប្រាសចាកសភាពដទៃ ។ ពិតណាស់ ទុក្ខមិនមានសភាវៈជាសមុទយៈជាដើម ។ សូម្បីក្នុងសមុទយៈជាដើម ក៏មានន័យនេះដូចគ្នា ។

# អដ្ឋកថា

# បឋមសុត្តន្តនិទ្ទេស

[ ១៦ ] បទថា **តថវេទ្ធន** បានដល់ ដោយអត្ថតាមសេចក្តីពិត ។ បទថា **បីឡនដ្ឋ** ជាដើម មានសេចក្តីដូចពោលហើយក្នុងញាណកថានោះឯង ។

[ ១៧ ] បទថា **ឯកប្បដិវេធានិ** មានវិគ្គហៈថា ឈ្មោះថា **ឯកប្បដិវេធានិ** ព្រោះអត្ថថា សច្ចៈទាំងនោះមានការចាក់ធ្លុះដោយមគ្គញាណមួយ ឬមានការចាក់ធ្លុះព្រមគ្នា ។ បទថា **អនត្តដ្ឋេន** បានដល់ ដោយភាពជាអនត្តា ព្រោះសច្ចៈទាំង ៤ ប្រាសចាកតួខ្លួន ។ ដូចដែលលោកពោលទុកក្នុងវិសុទ្ធិមគ្គថា ដោយបរមត្ថសច្ចៈទាំងអស់នោះឯង គប្បីជ្រាបថា ទទេ ព្រោះមិនមានអ្នកសោយ អ្នកធ្វើ អ្នករលត់ និងអ្នកទៅ ដោយហេតុនោះទើបលោកពោលថា

សេចក្តីពិត ទុក្ខប៉ុណ្ណោះមាន បុគ្គលណាមួយជាអ្នកកើតទុក្ខ
មិនមាន ការធ្វើមាន បុគ្គលអ្នកធ្វើមិនមាន ការរលត់មាន
បុគ្គលអ្នករំលត់មិនមាន ផ្លូវមាន បុគ្គលអ្នកដើរមិនមាន ។

ម្យ៉ាងទៀត

សភាពទទេក្នុងសច្ចៈទាំង ៤ នោះ គប្បីជ្រាបដូច្នេះគឺ សច្ចៈ
២ ខាងដើម ទទេចាកការទៀង ការស្អាត សុខនិងតួខ្លួន
អមតបទ ( និរោធ ) ទទេចាកភាពជាតួខ្លួន មគ្គប្រាសចាក

ការទៀន សុខនិងតួខន ។

បទថា **សច្ចដ្ឋេន** បានដល់ ដោយភាពមិនខុសចាកសេចក្តីពិត ។ បទថា **បដិវេធដ្ឋេន** បានដល់ ដោយសភាវៈគប្បីចាក់ធ្លុះក្នុងខណៈនៃមគ្គ ។ បទថា **ឯកសង្គហិតានិ** បានដល់ សង្គ្រោះដោយអត្ថនីមួយៗ មានភាពជារបស់ពិតជាដើម អធិប្បាយថា ដល់នូវការរាប់ថា មួយ ។ បទថា **យំ ឯកសង្គហិតំ តំ ឯកត្តំ** សេចក្តីថា ព្រោះលោកសង្គ្រោះដោយអត្ថ ១ ហេតុនោះទើបមានសភាវៈជាធម៌មួយ ។ លោកសម្ដែងដល់ភាពដែលសច្ចៈទាំងឡាយមានសភាពជាធម៌មួយ សូម្បីក្នុងភាពដែលមានច្រើនហើយ ធ្វើឲ្យជាឯកវចនៈ ។

បទថា **ឯកត្តំ ឯកេន ញាណេន បដិវិជ្ឈតិ** បានដល់ បុគ្គលកំណត់យ៉ាងល្អនូវភាពដែលសច្ចៈ ៤ មានសភាពផ្សេងគ្នា និងមានសភាពជាធម៌មួយ ក្នុងចំណែកខាងដើម ហើយតាំងមាំ រមែងចាក់ធ្លុះសភាវៈជាធម៌តែមួយនោះៗ មានភាពជារបស់ពិតជាដើម ដោយមគ្គញាណ ១ ក្នុងខណៈនៃមគ្គ ។

សេចក្តីនេះដូចម្តេច កាលចាក់ធ្លុះសភាវៈជាធម៌ ១ មានភាពជារបស់ពិតជាដើមនៃនិរោធសច្ចៈ រមែងជាការចាក់ធ្លុះសភាវៈជាធម៌ ១ មានភាពជារបស់ពិតជាដើម សូម្បីនៃសច្ចៈដ៏សេស ។ កាលព្រះយោគាវចរកំណត់ដោយល្អដល់សេចក្តីផ្សេងគ្នា និងសភាវៈជាធម៌ ១ នៃខន្ធ ៥ ក្នុងចំណែកខាងដើមហើយតាំងមាំ ក្នុងពេលចេញចាកមគ្គ ចេញដោយភាពជាសភាវៈ

មិនទៀង ជាទុក្ខ ជាអនត្តា សូម្បីកាលឃើញខន្ធ ១ ដោយសភាពមិនទៀងជាដើម សូម្បីខន្ធដ៏សេសក៏ឈ្មោះថា ឃើញដោយសភាពជាសភាវៈមិនទៀងជាដើមយ៉ាងណា សូម្បីសេចក្តីនេះក៏គប្បីឃើញមានឧបមាដូច្នោះ ។

បទថា **ទុក្ខស្ស ទុក្ខដ្ឋោ តថដ្ឋោ** បានដល់ អត្ថ ៤ យ៉ាង មានសភាពបៀតបៀនជាដើមនៃទុក្ខសច្ចៈ ជាសភាវៈពិត ដោយភាពជាសេចក្តីពិត ។ សូម្បីក្នុងសច្ចៈដ៏សេសក៏មានន័យនេះដូចគ្នា ។ គប្បីជ្រាបថា អត្ថ ៤ យ៉ាង នោះឯង ហៅថា **អនត្តដ្ឋោ** ព្រោះមិនមានតួខ្លួន ។ ហៅថា **សច្ចដ្ឋោ** ព្រោះមិនខុសអំពីសេចក្តីពិត ដោយសភាវៈដូចពោលហើយ ។ ហៅថា **បដិវេធដ្ឋោ** ព្រោះគួរចាក់ធ្លុះក្នុងខណៈនៃមគ្គ ។

[ ១៨ ] បទថា **យំ អនិច្ចំ** ជាដើម លោកសម្តែងធ្វើសាមញ្ញលក្ខណៈឲ្យជាខាងដើម ។ ក្នុងបទទាំងនោះ បទថា **យំ អនិច្ចំ តំ ទុក្ខំ យំ ទុក្ខំ តំ អនិច្ចំ** លោកសំដៅយកទុក្ខ សមុទយៈនិងមគ្គ ព្រោះសច្ចៈទាំង ៣ នោះជាសភាវៈមិនទៀង និងឈ្មោះថាជាទុក្ខ ព្រោះមិនទៀង ។ បទថា **យំ អនិច្ចញ្ច ទុក្ខញ្ច តំ អនត្តា** លោកសំដៅយកសច្ចៈ ៣ ទាំងនោះឯង ។ បទថា **យំ អនិច្ចញ្ច ទុក្ខញ្ច អនត្តា ច** លោកសង្គ្រោះយកនិរោធសច្ចៈនិងសច្ចៈ ៣ ទាំងនោះ ។ ពិតណាស់ សូម្បីសច្ចៈទាំង ៤ សុទ្ធតែជាអនត្តា ។ បទថា **តំ តថំ** បានដល់ ពួក ៤ នៃសច្ចៈនោះជារបស់ពិត ។ បទថា **តំ សច្ចំ** បានដល់ ពួក ៤ នៃសច្ចៈនោះ ៗ ឯងមិនប្រាសចាកអំពីសេចក្តីពិតក្នុងសភាវៈពិត ។

ក្នុងបទថា **ឆវីហាការេហិ** ជាដើម គប្បីជ្រាបថា ដោយភាពជាធម៌ដែលគួរដឹងក្រៃលែង ព្រោះព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងអស់ បុគ្គលត្រូវដឹងច្បាស់ជាដើម ក្នុងទីនេះ សូម្បីក្នុងភាពពិសេសក្នុងសភាវៈនៃទុក្ខគួរកំណត់ដឹង ក្នុងសភាវៈនៃសមុទយៈគួរលះ ក្នុងសភាវៈនៃមគ្គគួរចម្រើន ក្នុងសភាវៈនៃនិរោធគួរធ្វើឲ្យជាក់ច្បាស់ លោកក៏សម្តែងថា ដោយភាពជាធម៌ដែលគួរកំណត់ដឹង ព្រោះមានញាតបរិញ្ញា ក្នុងសច្ចៈទាំង ៤ ដោយភាពជាធម៌ដែលគួរលះ ព្រោះមានការលះដោយការឃើញសច្ចៈ ៤ ដោយភាពជាធម៌ដែលគួរចម្រើន ព្រោះមានការចម្រើនសច្ចៈ ៤ ដោយភាពជាធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រោះមានការធ្វើឲ្យជាក់ច្បាស់នូវសច្ចៈ ៤ ។

[ ១៩-២១ ] ក្នុងបទថា **ឆវីហាការេហិ តថដ្ឋេន** ជាដើម គប្បីប្រកបសេចក្តីតាមន័យដែលពោលហើយ ខាងដើមនោះឯង ។ ក្នុងបទថា **ទ្វាទសហិ អាការេហិ** ជាដើម ភាពជារបស់ពិតជាដើម មានសេចក្តីដូចពោលហើយក្នុងញាណកថា ។ ក្នុងការអធិប្បាយអាការទាំងនោះ ក៏គប្បីជ្រាបការប្រកបសេចក្តីតាមន័យដូចពោលហើយ ។

ក្នុងបទថា **សច្ចានំ កតិ លក្ខណានិ** ជាដើម ព្រះសារីបុត្តត្ថេរ បែកលក្ខណៈ ៦ ដែលគប្បីពោលតទៅជា ២ ចំណែក គឺសង្ខតៈនិងអសង្ខតៈ ហើយពោលថា **ទ្វេ លក្ខណានិ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **សង្ខតលក្ខណញ្ច អសង្ខតលក្ខណញ្ច** បានដល់ លក្ខណៈនៃសង្ខតធម៌ ថាសង្ខតនិងលក្ខណៈនៃអសង្ខតធម៌ ថាអសង្ខត ដែលព្រះមានព្រះភាគត្រាស់

ទុក ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សង្ខតលក្ខណៈរបស់សង្ខតធម៌នេះ មាន ៣ យ៉ាង គឺការកើតរមែងប្រាកដ ១ ការបែកធ្លាយ រមែងប្រាកដ ១ ការប្រែប្រួលនៃសភាវៈ ដែលតាំងនៅរមែងប្រាកដ ១ ។ ម្នាលភិក្ខុទាំងឡាយ អសង្ខតលក្ខណៈនៃអសង្ខតធម៌នេះ មាន ៣ យ៉ាង គឺការកើតមិនប្រាកដ ១ ការបែកធ្លាយមិនប្រាកដ ១ ការប្រែប្រួលនៃសភាវៈដែលតាំងនៅមិនប្រាកដ ១ ដូច្នេះ ។ តែសង្ខតធម៌មិនមែនលក្ខណៈ លក្ខណៈមិនមែនសង្ខតធម៌ ។ម្យ៉ាងទៀត វៀរសង្ខតធម៌ចេញហើយ មិនអាចបញ្ញត្តលក្ខណៈបាន វៀរលក្ខណៈចេញហើយ ក៏មិនអាចបញ្ញត្តសង្ខតធម៌បាន តែសង្ខតធម៌រមែងប្រាកដបានដោយលក្ខណៈ ។

ព្រះសារីបុត្តត្ថេរ កាលសម្តែងលក្ខណៈទាំង ២ នោះ ដោយពិស្តារទើបពោលថា **ឥ លក្ខណានិ** ដូច្នេះ ។ បទថា **សង្ខតានំ សច្ចានំ** បានដល់ ទុក្ខសច្ចៈ សមុទយសច្ចៈនិងមគ្គសច្ចៈ សច្ចៈទាំងនោះឈ្មោះថា សង្ខតៈ ព្រោះអាស្រ័យបច្ច័យតាក់តែង ។ បទថា **ឧប្បាទោ** បានដល់ ជាតិ ។ បទថា **បញ្ញាយតិ** បានដល់ រមែងឲ្យដឹង ។ បទថា **វយោ** បានដល់ ការរលត់ ។ បទថា **ឋិតានំ អញ្ញថត្តំ** បានដល់ កាលដល់នូវការតាំងនៅភាពជាយ៉ាងដទៃ គឺជរា ( ប្រាកដ ) ព្រោះសង្ខតសច្ចៈទាំង ៣ ជានិប្ផន្នៈ ( ជារបស់ពិត ) ទើបលោកពោលដល់ការកើតឡើង ការវិនាសនិងការប្រែប្រួល តែព្រោះការកើត ការចាស់និងការរលត់នៃសង្ខតសច្ចៈទាំងនោះជាអនិប្ផន្នៈ ( របស់មិនពិត ) ទើបមិនគួរពោលដល់ការកើតឡើង ការ

វិនាស និងការប្រែប្រួល ។ ព្រោះលក្ខណៈមានការកើតឡើងជាដើម អាស្រ័យសង្ខតធម៌ ទើបមិនគួរពោលថា ការកើតឡើង ការវិនាសនិងការប្រែប្រួលមិនប្រាកដ តែព្រោះលក្ខណៈមានការកើតឡើងជាដើម ជាការប្រែប្រួលនៃសង្ខតធម៌ ទើបគួរពោលថា ជាសង្ខតៈ ។ អាចារ្យទាំងឡាយពោលថា ការកើតឡើង ការចាស់និងការរលត់នៃទុក្ខសច្ចៈនិងសមុទយៈសច្ចៈទាក់ទងក្នុងសច្ចៈ ការកើតឡើង ការចាស់ និងការរលត់នៃមគ្គសច្ចៈមិនទាក់ទងក្នុងសច្ចៈ ។

ក្នុងបទនោះ លោកពោលទុកក្នុងអដ្ឋកថានៃខន្ធកវគ្គថា ក្នុងខណៈនៃសង្ខតៈទាំងឡាយកើត សង្ខតៈទាំងឡាយក្តី លក្ខណៈនៃការកើតក្តី ខណៈនៃការកើតនោះ ពោលគឺកាលក្តី រមែងប្រាកដ កាលការកើតកន្លងទៅសង្ខតធម៌ទាំងឡាយក្តី លក្ខណៈជរាក្តី ខណៈនៃជរានោះ ពោលគឺកាលក្តីរមែងប្រាកដ ក្នុងខណៈរលត់សង្ខតធម៌ទាំងឡាយក្តី ជរាក្តី លក្ខណៈរលត់ក្តី ខណៈនៃការរលត់នោះ ពោលគឺកាលក្តី រមែងប្រាកដ ។

បទថា **អសង្ខតស្ស សច្ចស្ស** បានដល់ និរោធសច្ចៈ ។ និរោធសច្ចៈនោះឈ្មោះថា អសង្ខតៈ ព្រោះជានិព្វន្នៈឯង មិនត្រូវអាស្រ័យបច្ច័យតាក់តែង ។ បទថា **ឋិតស្ស** បានដល់ ឈ្មោះថា តាំងនៅ ព្រោះភាពជាសភាវៈទៀង មិនមែនតាំងនៅ ព្រោះដល់ឋានៈ ( ឋិតិ ) ។

ព្រះសារីបុត្តត្ថេរកាលសម្តែងលក្ខណៈទាំង ២ នោះទៀត ដោយពិស្តារទើបពោលថា **ទ្វាទស លក្ខណានិ** ដូច្នេះ ។

[ ២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចតុន្នំ សច្ចានំ កតិ កុសលា** ជាដើម ដូចតទៅនេះថា បទថា អព្យាកតំ បានដល់ និព្វានជាអព្យាកតៈ ក្នុងអព្យាកតៈ ៤ គឺវិបាកជាអព្យាកតៈ កិរិយាជាអព្យាកតៈ រូបជាអព្យា-កតៈ និព្វានជាអព្យាកតៈ ព្រោះថាអព្យាកតៈ សូម្បីទាំង ៤ ឈ្មោះថា អព្យាកតៈ ព្រោះធ្វើឲ្យជាក់ច្បាស់មិនបាន ដោយលក្ខណៈជាកុសល ឬ អកុសល ។

បទថា **សិយា កុសលំ** បានដល់ ជាកុសលដោយអំណាចនៃកាមាវចរៈកុសល រូបាវចរៈកុសលនិងអរូបាវចរៈកុសល ។

បទថា **សិយា អកុសលំ** បានដល់ ជាអកុសល ដោយអំណាចនៃអកុសលដ៏សេស វៀរតណ្ហា ។

បទថា **សិយា អព្យាកតំ** បានដល់ ជាអព្យាកតៈ ដោយអំណាចនៃវិបាកនិងកិរិយាដែលជាកាមាវចរៈ រូបាវចរៈ និងអរូបាវចរៈ និងនៃរូបទាំងឡាយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សិយា តីណិ សច្ចានិ** ជាដើម ដូចតទៅនេះថា បទថា **សង្គហិតានិ** បានដល់ រាប់បញ្ចូល ។ បទថា **វត្ថុវសេន** បានដល់ ដោយអំណាចនៃវត្ថុ ពោលគឺទុក្ខ សមុទយៈ និរោធ មគ្គ ដែលជាអកុសល កុសលនិងអព្យាកតៈ ។ បទថា **យំ ទុក្ខសច្ចំ អកុសលំ** បានដល់ អកុសលដ៏សេស វៀរតណ្ហា ។ បទថា **អកុសលដ្ឋេន ទ្វេ សច្ចានិ ឯកសច្ចេន សង្គហិតានិ** អធិប្បាយថា ទុក្ខសច្ចៈ និងសមុទយសច្ចៈទាំង

២ នេះ លោកសង្គ្រោះដោយសច្ចៈ ១ ដោយភាពជាអកុសល ឈ្មោះថា ជាអកុសលសច្ចៈ ។ បទថា **ឯកសច្ចំ ទ្វីហិ សច្ចេហិ សង្គហិតំ** បានដល់ អកុសលសច្ចៈ ១ លោកសង្គ្រោះដោយសច្ចៈ ២ គឺទុក្ខសច្ចៈនិងសមុទយសច្ចៈ ។ បទថា **យំ ឧក្កសច្ចំ កុសលំ** បានដល់ ជាកុសលប្រព្រឹត្តទៅក្នុងភូមិ ៣ សច្ចៈ ២ គឺទុក្ខសច្ចៈនិងមគ្គសច្ចៈទាំងនេះ លោកសង្គ្រោះដោយសច្ចៈ ១ ដោយភាពជាកុសល ឈ្មោះថា កុសលសច្ចៈ កុសលសច្ចៈ ១ លោកសង្គ្រោះដោយសច្ចៈ ២ គឺទុក្ខសច្ចៈនិងមគ្គសច្ចៈ ។ បទថា **យំ ឧក្កសច្ចំ អព្យាកតំ** បានដល់ វិបាកនិងកិរិយាដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និងរូប ។ សច្ចៈ ២ គឺទុក្ខសច្ចៈនិងនិរោធសច្ចៈ ទាំងនេះ លោកសង្គ្រោះដោយសច្ចៈ ១ ដោយភាពជាអព្យាកតៈ ឈ្មោះថា ជាអព្យាកតសច្ចៈ អព្យាកតសច្ចៈ ១ លោកសង្គ្រោះដោយសច្ចៈ ២ គឺទុក្ខសច្ចៈ និងនិរោធសច្ចៈ ។

បទថា **តីណិ សច្ចានិ ឯកសច្ចេន សង្គហិតានិ** បានដល់ សមុទយសច្ចៈ មគ្គសច្ចៈនិងនិរោធសច្ចៈ លោកសង្គ្រោះដោយទុក្ខសច្ចៈដែលជាអកុសល កុសល និងអព្យាកតៈ ១ ។ បទថា **ឯកំ សច្ចំ តីហិ សច្ចេហិ សង្គហិតំ** បានដល់ ទុក្ខសច្ចៈ ១ លោកសង្គ្រោះដោយសមុទយសច្ចៈ មគ្គសច្ចៈ និងនិរោធសច្ចៈដែលជាអកុសល កុសល និងអព្យាកតៈញែកគ្នា ។ ចំណែកអាចារ្យពួកខ្លះ ពណ៌នាទុកថា ទុក្ខសច្ចៈនិងសមុទយៈសច្ចៈ លោកសង្គ្រោះដោយសមុទយសច្ចៈដោយភាពជាអកុសល ទុក្ខសច្ចៈនិងមគ្គសច្ចៈ

លោកសង្គ្រោះដោយសមុទយសច្ចៈ ដោយភាពជាអកុសល ទុក្ខសច្ចៈនិង មគ្គសច្ចៈ លោកសង្គ្រោះដោយមគ្គសច្ចៈ ដោយភាពជាកុសល មិនមែន ដោយភាពជាទស្សនៈ ។ ទុក្ខសច្ចៈ និងនិរោធសច្ចៈ លោកសង្គ្រោះដោយ និរោធសច្ចៈ ដោយភាពជាអព្យាកតៈ មិនមែនដោយភាពជាអសង្ខតៈ ។

អដ្ឋកថា បឋមសុត្តន្តនិទ្ទេស ចប់

# អដ្ឋកថា

# ទុតិយសុត្តន្តចាលី

[ ២៣ ] ព្រះសារីបុត្តត្ថេរ បំណងសម្ដែងការចាក់ធ្លុះសច្ចៈ ដោយ អំណាចអត្ថនៃព្រះសូត្រដទៃទៀត ទើបនាំព្រះសូត្រមកសម្ដែងថា **បុព្វេ មេ ភិក្ខវេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បុព្វេ មេ ភិក្ខវេ សម្ពោធា** បានដល់ ម្នាល ភិក្ខុទាំងឡាយ មុនអំពីការត្រាស់ដឹង គឺមុនអំពីការសម្រេចសព្វញ្ញុតញ្ញាណ របស់តថាគត ។ បទថា **អនភិសម្ពុទ្ធស្ស** បានដល់ មិនទាន់ចាក់ធ្លុះធម៌ទាំង ពួង ។ បទថា **ពោធិសត្តស្សេវ សតោ** បានដល់ នៅជាព្រះពោធិសត្វ នោះឯង ។ បទថា **ឯតទហោសិ** បានដល់ កាលតថាគតគង់លើពោធិ បល្ល័ង្កមានបរិវិតក្កៈនេះ ។ បទថា **អស្សាទោ** មានវិគ្គហៈថា ឈ្មោះថា

**អស្សាទោ** ព្រោះអត្ថថា ធ្វើឲ្យពេញចិត្ត ។ បទថា **អាទីនវោ** បានដល់ ជាទោសប្រទូស្ត ។ បទថា **និស្សរណំ** បានដល់ ជាឧបាយចៀស ចេញទៅ ។ បទថា **សុខំ** មានវិគ្គហៈថា ឈ្មោះថាសុខ ព្រោះធ្វើឲ្យសប្បាយ អធិប្បាយថា សុខកើតឡើងដល់បុគ្គលណា រមែងធ្វើបុគ្គលនោះ ឲ្យមានសេចក្តីសុខ ។ បទថា **សោមនស្សំ** មានវិគ្គហៈថា ឈ្មោះថា **សុមន** ព្រោះមានចិត្តស្អាត ព្រោះប្រកបដោយបីតិ និងសោមនស្ស ភាពនៃសុមនៈ ឈ្មោះថា **សោមនស្ស** សេចក្តីសុខនោះឯង លោកធ្វើឲ្យវិសេសដោយប្រកបដោយបីតិ ។ បទថា **អនិច្ចំ** បានដល់ មិនឋិតថេរ ។ បទថា **ទុក្ខំ** បានដល់ ឈ្មោះថាទុក្ខ ព្រោះជាទីតាំងនៃសេចក្តីទុក្ខ និងព្រោះជាសង្ខារទុក្ខ ។ បទថា **វិបរិណាមធម្មំ** បានដល់ មិនទៅក្នុងអំណាច មានការប្រែប្រួលទៅដោយជរា និងការលត់ជាប្រក្រតី ដោយបទនេះ លោក ពោលដល់ភាពជាអនត្តា ។ បទថា **ឆន្ទរាគវិនយោ** បានដល់ ការរាភាំង រាគៈគឺឆន្ទៈ មិនមែនរាភាំងវណ្ណរាគៈ ។ បទថា **ឆន្ទរាគប្បហានំ** បានដល់ ការលះឆន្ទរាគៈនោះៗឯង ។

[ ២៤ ] បទថា **យាវកីវញ្ច** ជាដើម គប្បីជ្រាបអត្ថដោយសម្ពន្ធថា តថាគតមិនទាន់ដឹងសច្ច គឺមិនចាក់ធ្លុះដោយញាណដ៏ក្រៃលែងនូវគុណដោយភាពជាគុណ ។បេ។ នៃឧបាទានក្ខន្ធ ៥ ទាំងនេះ តាមសេចក្តីពិតដរាបណា តថាគតក៏នៅមិនទាន់ប្តេជ្ញា គឺមិនធ្វើការប្តេជ្ញាថា តថាគតជាអរហន្ត បានត្រាស់ដឹង គឺត្រាស់ដឹងចំពោះអនុត្តរសម្មាសម្ពោធិញាណ គឺភាពជាសព្វញ្ញូ មិនមានអ្នកដទៃក្រៃលែងជាងដរាបនោះ ។

បទថា **កិរាញ្ញ** ត្រឹមតែជានិបាត ។ បទថា **យតោ** បានដល់ ព្រោះហេតុណា ឬក្នុងកាលណា ។ បទថា **អថ** បានដល់ ក្នុងលំដាប់ ។

បទថា **ញាណញ្ច បន មេ ទស្សនំ ឧទបាទិ** បានដល់ បច្ចវេក្ខ-ណញ្ញាណ គឺទស្សនៈកើតឡើងដល់តថាគតដោយការធ្វើកិច្ច គឺទស្សនៈ ។ បទថា **អកុប្បា** បានដល់ ដែលបុគ្គលណាមួយ មិនអាចឲ្យកម្រើក ឲ្យញាប់ញ័របាន ។ បទថា **វិមុត្តិ** បានដល់ អរហត្តផលវិមុត្តិ សូម្បីការពិចារណាមគ្គ និព្វានក៏ឈ្មោះថា លោកពោលដោយការពិចារណាផលនោះឯង ។ បទថា **អយមន្តិមា ជាតិ** បានដល់ នេះជាការប្រព្រឹត្តិទៅនៃខន្ធចុងក្រោយ ។ បទថា **នត្ថិទានិ បុនព្ភវោ** បានដល់ ឥឡូវនេះ មិនមានការកើតទៀត ដោយបទនេះ លោកពោលដល់ការពិចារណាកិលេស ដែលលះបានហើយ ព្រោះការពិចារណាកិលេសដែលនៅសេសសល់ មិនមានដល់ព្រះអរហន្ត ។

**អដ្ឋកថា ទុតិយសុត្តន្តបាលី ចប់**

# អដ្ឋកថា

# ទុតិយសុត្តន្តនិទ្ទេស

[ ២៥ ] ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងលំដាប់នៃការប្រកបសេចក្តី ក្នុងញាណដែលចាក់ធ្លុះសច្ចៈ ដូចតទៅនេះថា

បទថា **អយំ រូបស្ស អស្សាទោតិ បហានប្បដិវេធោ** បានដល់ ការដឹងក្នុងចំណែកខាងដើមថា សុខសោមនស្សដែលសម្បយុត្តដោយតណ្ហានេះជាគុណនៃរូប ហើយចាក់ធ្លុះសមុទយសច្ចៈ ពោលគឺការលះសមុទយៈ ក្នុងខណៈនៃមគ្គ ។ បទថា **សមុទយសច្ចំ** បានដល់ ញាណដែលចាក់ធ្លុះសមុទយសច្ចៈ ។ ពិតណាស់ សូម្បីញាណដែលមានអរិយសច្ចៈជាអារម្មណ៍ លោកក៏ហៅថាសច្ចៈ ដូចក្នុងប្រយោគ ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ជាដើមថា កុសលធម៌ ទាំងឡាយណានីមួយ កុសលធម៌ទាំងអស់នោះ តែងសង្គ្រោះចូលក្នុងអរិយសច្ចទាំង ៤ ដូច្នោះឯង ។

បទថា **អយំ រូបស្ស អាទីនវោតិ បរិញ្ញាបដិវេធោ** បានដល់ ការដឹងក្នុងចំណែកខាងដើមថា នេះជាទោសនៃរូបហើយចាក់ធ្លុះទុក្ខសច្ចៈ ពោលគឺការកំណត់ដឹងទុក្ខក្នុងខណៈនៃមគ្គ ។ បទថា **ទុក្ខសច្ចំ** បានដល់ ញាណដែលចាក់ធ្លុះទុក្ខសច្ចៈ ។

បទថា **ឥទំ រូបស្ស និស្សរណន្តិ សច្ឆិកិរិយាបដិវេធោ** បានដល់ ការដឹងក្នុងចំណែកខាងដើមថា នេះជាគ្រឿងរលាស់ចេញនៃរូប ហើយចាក់ធ្លុះនិរោធសច្ចៈ ពោលគឺការធ្វើឲ្យជាក់ច្បាស់និរោធ ក្នុងខណៈនៃមគ្គ ។

បទថា **និរោធសច្ចំ** បានដល់ ញាណដែលចាក់ធ្លុះនិរោធសច្ចៈ ដែលមាននិរោធសច្ចៈជាអារម្មណ៍ ។ បទថា **យា តីសុ ឋានេសុ** គប្បីជ្រាបការប្រកបសេចក្ដីថា ទិដ្ឋិ សង្កប្បៈ ដែលប្រព្រឹត្តទៅហើយក្នុងសមុទយៈ ទុក្ខ និងនិរោធទាំង ៣ តាមដែលពោលហើយនេះ ដោយអំណាចការចាក់ធ្លុះ ។ បទថា **ភាវនា បដិវេធោ** បានដល់ ការចាក់ធ្លុះមគ្គសច្ចៈ ពោលគឺការចម្រើនមគ្គនេះ ។ បទថា **មគ្គសច្ចំ** បានដល់ ញាណដែលចាក់ធ្លុះមគ្គសច្ចៈ ។

[ ២៦ ] ព្រះសារីបុត្តត្ថេរ កាលសម្ដែងសច្ចៈ និងការចាក់ធ្លុះសច្ចៈ ដោយបរិយាយដទៃទៀតទើបពោលបទថា **សច្ចន្តិ កតិហាការេហិ សច្ចំ** ជាដើម ។ ក្នុងបទនោះព្រោះព្រះសព្វញ្ញុពោធិសត្វទាំងពួង គង់ត្រង់ពោធិបល្ល័ង្កហើយស្វែងរកសមុទយសច្ចៈ មានជាតិជាដើមនៃទុក្ខសច្ចៈ មានជរានិងមរណៈជាដើមថា អ្វីហ្ន៎ ម្យ៉ាងទៀត កាលស្វែងរកយ៉ាងនោះទើបកំណត់កាន់យកថា សមុទយសច្ចៈ មានជាតិជាដើម ជាបច្ច័យដល់ទុក្ខសច្ចៈ មានជរានិងមរណៈជាដើម ហេតុនោះ ការស្វែងរកនោះ និងការកំណត់នោះលោកធ្វើឲ្យជាសច្ចៈព្រោះស្វែងរក និងព្រោះកំណត់សច្ចៈទាំងឡាយ ហើយទើបពោលថា **ឯសនដ្ឋេន បរិគ្គហដ្ឋេន** ដោយអត្ថថា ស្វែងរក ១ ដោយអត្ថថា ចំណាំទុក ១ ។

វិធីនេះ រមែងបានក្នុងការកំណត់បច្ច័យ សូម្បីរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ តែរមែងបានក្នុងការកំណត់បច្ច័យនៃសាវកទាំងឡាយដោយអំណាច

ការស្តាប់ ។ បទថា **បដិវេធដ្ឋេន** បានដល់ ដោយការចាក់ធ្លុះជាចំណែក ដូចគ្នាក្នុងខណៈនៃមគ្គ របស់អ្នកដែលស្វែងរក និងរបស់អ្នកកំណត់យ៉ាង នោះ ក្នុងចំណែកខាងដើម ។

ពាក្យទាំងអស់មានហេតុជាដើម ក្នុងបទថា **កឹនិទានំ** ជាដើម ជាវេ-វចនៈរបស់ហេតុ ។ ព្រោះហេតុ រមែងប្រគល់ឲ្យនូវផល ដូចប្រាប់ថា អញ្ជើញពួកលោកទទួលរបស់នោះចុះ ហេតុនោះ ទើបហៅថា និទាន ។ ព្រោះផលរមែងតាំងឡើង កើតឡើង ឧប្បត្តិកឡើងអំពីហេតុនោះ ហេតុនោះទើបហៅថា សមុទយៈ កំណើត ដែនកើត ។ ក្នុងបទនេះ មានអធិប្បាយ ដូចតទៅនេះថា ឈ្មោះថា **កឹនិទានំ** ព្រោះជរា និងមរណៈនោះ មានអ្វីជាហេតុ ។ ឈ្មោះថា **កឹសមុទយំ** ព្រោះជរានិងមរណៈនោះ មានអ្វីជាសមុទយៈ ។

ឈ្មោះថា **កឹជាតិកំ** ព្រោះជរានិងមរណៈនោះ មានអ្វីជាកំណើត ។ ឈ្មោះថា **កឹបភវំ** ព្រោះជរានិងមរណៈនោះ មានអ្វីជាដែនកើត ។

ម្យ៉ាងទៀត ព្រោះជរានិងមរណៈនោះ មានជាតិជាហេតុ មានជាតិជាសមុទយៈ មានជាតិជាកំណើត មានជាតិជាដែនកើត ដោយអត្ថតាមដែលពោលហើយ ហេតុនោះទើបព្រះសារីបុត្តពោលថា **ជាតិនិទានំ** ជាដើម ។

បទថា **ជរាមរណំ** បានដល់ ទុក្ខសច្ចៈ ។ បទថា **ជរាមរណសមុ-ទយំ** បានដល់ សមុទយសច្ចៈជាបច្ច័យនៃជរានិងមរណៈនោះ ។ បទថា **ជរាមរណនិរោធំ** បានដល់ និរោធសច្ចៈ ។ បទថា **ជរាមរណនិរោធ-**

**គាមិនីបដិបទំ** បានដល់ មគ្គសច្ចៈ ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួងដោយន័យនេះឯង ។

[ ២៧ ] បទថា **និរោធប្បជាននា** បានដល់ ដឹងការរលត់ដោយធ្វើឲ្យជាអារម្មណ៍ ។ បទថា **ជាតិ សិយា ទុក្ខសច្ចំ សិយា សមុទយសច្ចំ** បានដល់ជាតិ ឈ្មោះថា ទុក្ខសច្ចៈ ដោយអត្ថថា ប្រាកដ ព្រោះកពជាបច្ច័យ ឈ្មោះថា សមុទយសច្ចៈ ដោយអត្ថថា ជាបច្ច័យដល់ជរានិងមរណៈ ។ ក្នុងបទដ៏សេសក៏ន័យនេះ ។

បទថា **អវិជ្ជា សិយា ទុក្ខសច្ចំ** បានដល់ ព្រោះអាសវៈកើតទើបអវិជ្ជាកើត ឈ្មោះថា ទុក្ខសច្ចៈ ដោយអត្ថថា កើតឡើង ។

អដ្ឋកថា ទុតិយសុត្តន្តនិទ្ទេស ចប់

អដ្ឋកថា សច្ចកថា ចប់

# សុត្តន្តបិដក

## យុគនទ្ធវគ្គ ពោជ្ឈង្គកថា

## សាវត្ថីនិទាន

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គនេះ មាន ៧ ពោជ្ឈង្គ ៧ តើដូចម្ដេច សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ម្នាលភិក្ខុទាំងឡាយ នេះឯងពោជ្ឈង្គ ៧ ។

សំណួរត្រង់ពាក្យថា ពោជ្ឈង្គ តើពោជ្ឈង្គ ដោយអត្ថថា ដូចម្ដេច ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុប្រព្រឹត្តទៅព្រមក្នុងការត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងតាម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងចំពោះ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងព្រម ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ត្រាស់ដឹងតាម ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ត្រាស់ដឹងចំពោះ ឈ្មោះថា ពោជ្ឈង្គ ដោយ អត្ថថា ត្រាស់ដឹងព្រម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុញ៉ាំងជនឲ្យត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុញ៉ាំងជនឲ្យត្រាស់ដឹងតាម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុញ៉ាំងជនឲ្យត្រាស់ដឹងចំពោះ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុញ៉ាំងជនឲ្យត្រាស់ដឹងព្រម ឈ្មោះថាពោជ្ឈង្គ ដោយអត្ថថា ញ៉ាំងជនឲ្យត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ញ៉ាំងជនឲ្យត្រាស់ដឹងតាម ឈ្មោះថា ពោជ្ឈង្គ ដោយ

អត្ថថា ញុំាំងជនឲ្យត្រាស់ដឹងចំពោះ ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ញុំាំងជនឲ្យត្រាស់ដឹងព្រម ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹងតាម ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹងចំពោះ ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹងព្រម ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា បានចំពោះនូវប្រាជ្ញា ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា បណ្តុះនូវប្រាជ្ញា ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា បណ្តុះចំពោះនូវប្រាជ្ញា ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ញុំាំងជនឲ្យដល់នូវប្រាជ្ញា ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ញុំាំងជនឲ្យដល់ព្រមនូវប្រាជ្ញា ។

[ ២៩ ] ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថថា ជាមូល ពោជ្ឈង្គ ដោយអត្ថថា ទំនុកបម្រុងមូល ពោជ្ឈង្គ ដោយអត្ថថា ថែទាំមូល ពោជ្ឈង្គ ដោយអត្ថថា បោមពោមមូល ពោជ្ឈង្គ ដោយអត្ថថា បំពេញមូល ពោជ្ឈង្គ ដោយអត្ថថា ធ្វើមូលឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថា ធ្វើមូលឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថា ញុំាំងជនឲ្យដល់នូវមូលប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ចម្រើនវសី ក្នុងមូលប្បដិសម្ភិទា ពោជ្ឈង្គរបស់ជនអ្នកសម្រេចនូវវសីភាព ក្នុងមូលប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ជាហេតុ ពោជ្ឈង្គ ដោយអត្ថថា ទំនុកបម្រុងហេតុ ពោជ្ឈង្គ ដោយអត្ថថា ថែទាំហេតុ ពោជ្ឈង្គ ដោយអត្ថថា បោមពោមហេតុ ពោជ្ឈង្គ ដោយអត្ថថា បំពេញ

ហេតុ ពោជ្ឈង្គ ដោយអត្ថថា ធ្វើហេតុឲ្យបាស់ក្លា ពោជ្ឈង្គ ដោយអត្ថថា ធ្វើហេតុឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថា ញ៉ាំងជនឲ្យដល់នូវហេតុប្បដិ-សម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ចម្រើននូវវសី ក្នុងហេតុប្បដិសម្ភិទា ពោជ្ឈង្គរបស់ជនអ្នកសម្រេចនូវវសីភាព ក្នុងហេតុប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ជាបច្ច័យ ពោជ្ឈង្គ ដោយអត្ថថា ទំនុកបម្រុងបច្ច័យ ពោជ្ឈង្គ ដោយអត្ថថា ថែទាំបច្ច័យ ពោជ្ឈង្គ ដោយអត្ថថា បោមពោមបច្ច័យ ពោជ្ឈង្គ ដោយអត្ថថា បំពេញបច្ច័យ ពោជ្ឈង្គ ដោយអត្ថថា ធ្វើបច្ច័យឲ្យបាស់ក្លា ពោជ្ឈង្គ ដោយអត្ថថា ធ្វើបច្ច័យឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថា ញ៉ាំងជនឲ្យដល់នូវបច្ចយប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ចម្រើននូវវសីក្នុងបច្ចយប្បដិសម្ភិទា ពោជ្ឈង្គរបស់ជនអ្នកសម្រេចនូវវសីភាពក្នុងបច្ចយប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា បរិសុទ្ធិ ពោជ្ឈង្គ ដោយអត្ថថា ទំនុកបម្រុងសេចក្តីបរិសុទ្ធិ ពោជ្ឈង្គ ដោយអត្ថថា ថែទាំសេចក្តីបរិសុទ្ធ ពោជ្ឈង្គ ដោយអត្ថថា បោមពោមសេចក្តីបរិសុទ្ធិ ពោជ្ឈង្គ ដោយអត្ថថា បំពេញសេចក្តីបរិសុទ្ធិ ពោជ្ឈង្គ ដោយអត្ថថា ធ្វើសេចក្តីបរិសុទ្ធិឲ្យបាស់ក្លា ពោជ្ឈង្គ ដោយអត្ថថា ធ្វើសេចក្តីបរិសុទ្ធិឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថា ញ៉ាំងជនឲ្យដល់នូវវិសុទ្ធិប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ចម្រើននូវវសីក្នុងវិសុទ្ធិប្បដិសម្ភិទា ពោជ្ឈង្គរបស់ជនអ្នកសម្រេចនូវវសីភាព ក្នុងវិសុទ្ធិប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ជាអំពើមិនមានទោស ពោជ្ឈង្គ ដោយអត្ថថា ទំនុកបម្រុងអំពើមិនមានទោស ពោជ្ឈង្គ ដោយអត្ថថា ថែ

ទាំអំពើមិនមានទោស ពោជ្ឈង្គ ដោយអត្ថថា ចោមរោមអំពើមិនមានទោស ពោជ្ឈង្គ ដោយអត្ថថា បំពេញនូវអំពើមិនមានទោស ពោជ្ឈង្គ ដោយអត្ថថា ធ្វើអំពើដែលមិនមានទោសឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថា ធ្វើអំពើមិនមានទោសឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថា ញ៉ាំងជនឲ្យដល់អនវជ្ជប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ចម្រើននូវវសីក្នុងអនវជ្ជប្បដិសម្ភិទា ពោជ្ឈង្គ របស់ជនអ្នកសម្រេចនូវវសីភាព ក្នុងអនវជ្ជប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា នេក្ខម្ម: ( ការចេញចាកកាម ) ពោជ្ឈង្គ ដោយអត្ថថា ទំនុកបម្រុងនេក្ខម្ម: ពោជ្ឈង្គ ដោយអត្ថថា ថែទាំនេក្ខម្ម: ពោជ្ឈង្គ ដោយអត្ថថា ចោមរោមនេក្ខម្ម: ពោជ្ឈង្គ ដោយអត្ថថា បំពេញនេក្ខម្ម: ពោជ្ឈង្គ ដោយអត្ថថា ធ្វើនេក្ខម្ម:ឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថា ធ្វើនេក្ខម្ម:ឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថា ញ៉ាំងជនឲ្យដល់នូវនេក្ខម្មប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ចម្រើននូវវសី ក្នុងនេក្ខម្មប្បដិសម្ភិទា ពោជ្ឈង្គរបស់ជនអ្នកសម្រេចនូវវសីភាព ក្នុងនេក្ខម្មប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា វិមុត្តិ ពោជ្ឈង្គ ដោយអត្ថថា ទំនុកបម្រុងវិមុត្តិ ពោជ្ឈង្គ ដោយអត្ថថា ថែទាំវិមុត្តិ ពោជ្ឈង្គ ដោយអត្ថថា ចោមរោមវិមុត្តិ ពោជ្ឈង្គ ដោយអត្ថថា បំពេញវិមុត្តិ ពោជ្ឈង្គ ដោយអត្ថថា ធ្វើវិមុត្តិឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថា ធ្វើវិមុត្តិឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថា ញ៉ាំងជនឲ្យដល់នូវវិមុត្តិប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ចម្រើននូវវសីក្នុង វិមុត្តិប្បដិសម្ភិទា ពោជ្ឈង្គរបស់ជនអ្នកសម្រេចនូវវសីភាព ក្នុងវិមុត្តិប្បដិសម្ភិទា

ពោជ្ឈង្គ ដោយអត្ថថា ការមិនមានអាសវៈ ពោជ្ឈង្គ ដោយអត្ថថា ទំនុកបម្រុងនូវការមិនមានអាសវៈ ពោជ្ឈង្គ ដោយអត្ថថា ថែទាំនូវការមិនមានអាសវៈ ពោជ្ឈង្គ ដោយអត្ថថា បោមពោមនូវការមិនមានអាសវៈ ពោជ្ឈង្គ ដោយអត្ថថា បំពេញនូវការមិនមានអាសវៈ ពោជ្ឈង្គ ដោយអត្ថថា ធ្វើនូវការមិនមានអាសវៈឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថា ធ្វើនូវការមិនមានអាសវៈឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថា ញុំាងជនឲ្យដល់នូវអនាសវប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ចម្រើននូវវសីក្នុងអនាសវប្បដិសម្ភិទា ពោជ្ឈង្គរបស់ជនអ្នកសម្រេចនូវវសីភាពក្នុងអនាសវប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា វិវេក ពោជ្ឈង្គ ដោយអត្ថថា ទំនុកបម្រុងវិវេក ពោជ្ឈង្គ ដោយអត្ថថា ថែទាំវិវេក ពោជ្ឈង្គ ដោយអត្ថថា បោមពោមវិវេក ពោជ្ឈង្គ ដោយអត្ថថា បំពេញនូវវិវេក ពោជ្ឈង្គ ដោយអត្ថថា ធ្វើវិវេកឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថា ធ្វើវិវេកឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថា ញុំាងជនឲ្យដល់នូវវិវេកប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ចម្រើននូវវសីក្នុងវិវេកប្បដិសម្ភិទា ពោជ្ឈង្គរបស់ពួកជនអ្នក សម្រេចនូវវសីភាពក្នុងវិវេកប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ការលះបង់ ពោជ្ឈង្គ ដោយអត្ថថា ទំនុកបម្រុងនូវការលះបង់ ពោជ្ឈង្គ ដោយអត្ថថា ថែទាំនូវការលះបង់ ពោជ្ឈង្គ ដោយអត្ថថា បោមពោមនូវការលះបង់ ពោជ្ឈង្គ ដោយអត្ថថា បំពេញនូវការលះបង់ ពោជ្ឈង្គ ដោយអត្ថថា ធ្វើនូវការលះបង់ឲ្យចាស់ក្លា ពោជ្ឈង្គ ដោយអត្ថថា ធ្វើនូវការលះបង់ឲ្យបែករីក ពោជ្ឈង្គ ដោយអត្ថថា ញុំាងជនឲ្យ

ដល់នូវវោស្សគ្គប្បដិសម្ភិទា ពោជ្ឈង្គ ដោយអត្ថថា ចម្រើននូវវសីក្នុងវោស្ស គ្គប្បដិសម្ភិទា ពោជ្ឈង្គរបស់ពួកជនអ្នកសម្រេចនូវវសីភាពក្នុងវោស្សគ្គប្ប-ដិសម្ភិទា ។

[ ៣០ ] ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃមូល ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃហេតុ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃបច្ច័យ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបរិសុទ្ធិ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃអំពើមិនមានទោស ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃនេក្ខម្មៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិមុត្តិ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនមានអាសវៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិវេក ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការលះបង់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងមូល ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងហេតុ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងបច្ច័យ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងសេចក្តីបរិសុទ្ធិ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងនូវអំពើមិនមានទោស ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងនូវនេក្ខម្មៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងនូវវិមុត្តិ ឈ្មោះថា ពោជ្ឈង្គ

ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងអំពើមិនមានអាសវៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងនូវវិវេក ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទំនុកបម្រុងនូវការលះបង់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការថែទាំនូវមូល ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការថែទាំការលះបង់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបោមរោមនូវមូល ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការបោមរោមនូវការលះបង់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំពេញមូល ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំពេញនូវការលះបង់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការធ្វើមូល ឲ្យចាស់ក្លា ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុ ត្រាស់ដឹងនូវអត្ថនៃការធ្វើនូវការលះបង់ឲ្យចាស់ក្លា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការធ្វើមូលឲ្យបែករីក ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការធ្វើនូវការលះបង់ ឲ្យបែករីក ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការញ៉ាំងជនឲ្យដល់នូវមូលប្បដិសម្ភិទា ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការញ៉ាំងជនឲ្យដល់នូវវោស្សគ្គប្បដិសម្ភិទា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបម្រើននូវវសីក្នុងមូលប្បដិសម្ភិទា ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបម្រើននូវវសី ក្នុងវោស្សគ្គប្បដិសម្ភិទា ។បេ។

[ ៣១ ] ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការទ្រទ្រង់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចោមរោម ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំពេញ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃឯកគ្គតាចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនរាយមាយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការផ្គងឡើង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនរាយមាយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌មិនមានកករល្អក់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនញាប់ញ័រ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃចិត្តតាំងនៅនឹង ដោយអំណាចនៃការប្រុង ដោយភាពនៃចិត្តមានអារម្មណ៍តែមួយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃអារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគោចរ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការលះបង់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបរិច្ចាគ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចេញ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ប្រាសចាកវដ្តៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ស្ងប់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ដ៏ថ្លៃថ្លា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិមុត្តិ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ មិនមានអាសវៈ ឈ្មោះថា ពោជ្ឈង្គ

ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ជាគ្រឿងច្នង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃព្រះនិព្វានមិនមាននិមិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃព្រះនិព្វានមិនមានគ្រឿងតម្កល់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃព្រះនិព្វានដ៏សូន្យ ( ចាកកិលេស ) ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌មានរសតែមួយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនប្រព្រឹត្តលើសគ្នា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ជាប់គ្នាជាគូ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចេញ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃហេតុ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការយល់ឃើញ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ជាអធិបតី ។

[ ៣២ ] ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនរាយមាយរបស់សមថៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការឃើញរឿយៗរបស់វិបស្សនា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃសមថៈនិងវិបស្សនា មានរសតែមួយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ជាប់គ្នាជាគូ មិនប្រព្រឹត្តលើសគ្នា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការសមាទាននូវសិក្ខា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគោចររបស់អារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការផ្គងឡើងនូវចិត្តរួញរា ឈ្មោះ

ថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការសង្កត់សង្កិននូវចិត្តជាឧទ្ធច្ចៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការព្រងើយរបស់វិសុទ្ធិទាំងពីរ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការបាននូវគុណវិសេស ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចាក់ធ្លុះដ៏ក្រៃលែង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការត្រាស់ដឹងនូវសច្ចៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ញ៉ាំងសត្វឲ្យតាំងនូវក្នុងនិរោធ ។

[ ៣៣ ] ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការជឿស៊ប់របស់សទ្ធិន្ទ្រិយ ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការយល់ឃើញរបស់បញ្ញិន្ទ្រិយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនកម្រើក ព្រោះអស្សទ្ធិយៈរបស់សទ្ធាពលៈ ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនកម្រើក ព្រោះអវិជ្ជារបស់បញ្ញាពលៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប្រុងរបស់សតិសម្ពោជ្ឈង្គ ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការពិចារណារបស់ឧបេក្ខាសម្ពោជ្ឈង្គ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការយល់ឃើញរបស់សម្មាទិដ្ឋិ ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុ ត្រាស់ដឹងនូវអត្ថនៃការមិនរាយមាយរបស់សម្មាសមាធិ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃអធិបតីរបស់ឥន្ទ្រិយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនកម្រើក

របស់ពលៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចេញ ( ចាកវដ្តៈ ) របស់ពោជ្ឈង្គ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃហេតុរបស់មគ្គ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប្រុងរបស់សតិប្បដ្ឋាន ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគ្រឿងតាំងរបស់សម្មប្បធាន ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគ្រឿងសម្រេចរបស់ឥទ្ធិបាទ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការពិត របស់សច្ចៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការស្ងប់រម្ងាប់ របស់ធម៌ជាគ្រឿងប្រកប ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការធ្វើឲ្យជាក់ច្បាស់ របស់ផល ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគ្រឿងលើកចិត្ត របស់វិតក្កៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃឧបវិចារៈ របស់វិចារៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការផ្សាយ របស់បីតិ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបង្ហូរ របស់សេចក្តីសុខ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃចិត្ត មានអារម្មណ៍តែមួយ ។

[ ៣៤ ] ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការរំពឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការដឹងច្បាស់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការដឹងទូទៅ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការដឹងព្រម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុ

ត្រាស់ដឹងនូវអត្ថនៃចិត្តមានអារម្មណ៍តែមួយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ ដែលគប្បីត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការពិចារណារបស់បរិញ្ញា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការលះរបស់បហានៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុ ត្រាស់ដឹងនូវអត្ថនៃភាវនា មានរសតែមួយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការពាល់ត្រូវ របស់សច្ចិកិរិយា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគំនររបស់ខន្ធ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគ្រឿងទ្រទ្រង់របស់ធាតុ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃកន្លែងកើតរបស់អាយតនៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃបច្ច័យតាក់តែងរបស់សង្ខតធម៌ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនមានបច្ច័យតាក់តែងរបស់អសង្ខតធម៌ ។

[ ៣៥ ] ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃលំដាប់របស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចេញរបស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការវិលត្រឡប់របស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃហេតុរបស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃបច្ច័យរបស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃទីកើតរបស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃភូមិរបស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង

នូវអត្ថនៃអារម្មណ៍របស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃគោចររបស់ចិត្តវត្ថុ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃចរិយារបស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃដំណើររបស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប៉ុនប៉ងរបស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចេញរបស់ចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង នូវអត្ថនៃការរលាស់ចេញរបស់ចិត្ត ។

[ ៣៦ ] ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការរំពឹងក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការដឹងច្បាស់ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការដឹងទូទៅក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការដឹងព្រមក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃចិត្តមានអារម្មណ៍តែមួយក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការស្ទុះទៅ ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃសេចក្តីជ្រះថ្លាក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការតម្កល់ព្រមក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិមុត្តិ ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការយល់ឃើញ ក្នុងឯកត្តារម្មណ៍ថា នេះជាធម្មជាតស្ងប់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់

ដឹងនូវអត្ថនៃធម៌ ធ្វើឲ្យដូចជាយានក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ ធ្វើទីកើតក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការមិនតាំងមាំ ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការសន្សំក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប្រារព្ធដោយប្រពៃក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការកំណត់ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបោមពោមក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំពេញក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប្រមូលក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការអធិដ្ឋានក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការសេពទូទៅ ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការចម្រើនក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃពហុលីកម្មក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការអណ្តែតឡើងព្រមក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការ រួចចាកកិលេសដោយប្រពៃក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការត្រាស់ដឹងក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការត្រាស់ដឹងតាមក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់

ដឹងនូវអត្ថនៃការត្រាស់ដឹងចំពោះក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការត្រាស់ដឹងព្រម ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការ ញ៉ាំងជនឲ្យត្រាស់ដឹងក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុ ត្រាស់ដឹងនូវអត្ថនៃការញ៉ាំងជនឲ្យត្រាស់ដឹងតាមក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការញ៉ាំងជនឲ្យត្រាស់ដឹងចំពោះក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការញ៉ាំងជនឲ្យត្រាស់ដឹងព្រម ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុ ត្រាស់ដឹងនូវអត្ថនៃធម៌ជាចំណែកនៃការត្រាស់ដឹង ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ ជាចំណែកនៃការត្រាស់ ដឹងតាមក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ ជាចំណែកនៃការត្រាស់ដឹងចំពោះក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ជាចំណែកនៃការត្រាស់ដឹងព្រម ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំភ្លឺក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំភ្លឺខ្ពស់ឡើងក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំភ្លឺតាមក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុ ត្រាស់ដឹងនូវអត្ថនៃការបំភ្លឺចំពោះ ក្នុងឯកត្តារម្មណ៍ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបំភ្លឺព្រមក្នុងឯកត្តា-រម្មណ៍ ។

[ ៣៧ ] ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ជាដើងរបស់វីមំសា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃនិរោធ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការដុតកម្តៅ ( កិលេស ) ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការរុងរឿង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការកម្តៅសព្វនូវកិលេស ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌មិនមានមន្ទិល ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ប្រាសចាកមន្ទិល ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃធម៌ឥតមន្ទិល ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃធម៌ដ៏ស្ងប់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ ជាគ្រឿងត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិវេក ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប្រព្រឹត្តិក្នុងវិវេក ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិរាគធម៌ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប្រព្រឹត្តិក្នុងវិរាគធម៌ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃនិរោធ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប្រព្រឹត្តិក្នុងនិរោធ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការលះបង់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការប្រព្រឹត្តក្នុងការលះបង់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវិមុត្តិ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថ នៃការប្រព្រឹត្តិក្នុងវិមុត្តិ

ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃឆន្ទៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃឫសរបស់ឆន្ទៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃជើងរបស់ឆន្ទៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ ជាប្រធានរបស់ឆន្ទៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការសម្រេចរបស់ឆន្ទៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃអធិមោក្ខរបស់ឆន្ទៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការផ្គងនូវឆន្ទៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការតម្កល់នូវឆន្ទៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនរាយមាយរបស់ឆន្ទៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវីរិយៈ ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃចិត្ត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃវីមំសា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃឫសរបស់វីមំសា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃជើងរបស់វីមំ-សា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ជាប្រធានរបស់វីមំសា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការសម្រេចរបស់វីមំសា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃអធិមោក្ខរបស់វីមំសា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការផ្គងរបស់វីមំសា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការមិនប្រហែសរបស់វីមំសា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃ

ការមិនរាយមាយរបស់វីមំសា ។

[ ៣៨ ] ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការបៀតបៀនរបស់ទុក្ខ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃទុក្ខត្រូវបច្ច័យតាក់តែង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃទុក្ខជាញ៉ាំងសត្វឲ្យក្តៅ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃទុក្ខមានការប្រែប្រួល ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃសមុទ័យ មានការប្រមូលមកនូវអត្ថថាជាហេតុ នូវអត្ថថាសំយោគ នូវអត្ថថាបលិពោធ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃទុក្ខនិរោធថាជាគ្រឿងរលាស់ចេញនូវអត្ថថាវិវេក នូវអត្ថថា មិនមានបច្ច័យតាក់តែង នូវអត្ថថា មិនស្លាប់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃមគ្គថាជាគ្រឿងនាំចេញ នូវអត្ថថាជាហេតុ នូវអត្ថថាយល់ឃើញ នូវអត្ថថាជាអធិបតី ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាពិត ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាជាអនត្តា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាទៀង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាចាក់ធ្លុះ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាដឹងច្បាស់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថាកំណត់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធាតុ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃធម៌ដែលដឹងហើយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង

នូវអត្ថនៃការធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការពាល់ត្រូវ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថនៃការត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវនេក្ខម្មៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអព្យាបាទ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអាលោកសញ្ញា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវការមិនរាយមាយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវការកំណត់ធម៌ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវញាណ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវបាមុជ្ជៈ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងបឋមជ្ឈាន ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអរហត្តមគ្គ ។

[ ៣៩ ] ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសទ្ធិន្ទ្រិយ ដោយអត្ថថា ជឿស៊ប់ ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវបញ្ញិន្ទ្រិយ ដោយអត្ថថាយល់ឃើញ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសទ្ធាពលៈ ដោយអត្ថថា មិនកម្រើក ព្រោះហេតុមិនគួរជឿ ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវបញ្ញាពលៈដោយអត្ថថា មិនកម្រើកព្រោះអវិជ្ជា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសតិសម្ពោជ្ឈង្គ ដោយអត្ថថាប្រុង ។បេ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវឧបេក្ខាសម្ពោជ្ឈង្គ ដោយអត្ថថា ពិចារណា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសម្មាទិដ្ឋិដោយអត្ថថា យល់ឃើញ ។បេ។

ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសម្មាសមាធិ ដោយអត្ថថា មិនរាយមាយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវឥន្ទ្រិយ ដោយអត្ថថា ភាពជាធំ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវពលៈដោយអត្ថថា មិនកម្រើក ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអត្ថថា ចេញ ( ចាកវដ្តៈ ) ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវមគ្គ ដោយអត្ថថា ជាហេតុ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសតិប្បដ្ឋាន ដោយអត្ថថា ប្រុង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសម្មប្បធាន ដោយអត្ថថា តម្កល់ទុក ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវឥទ្ធិបាទ ដោយអត្ថថា សម្រេច ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសច្ចៈ ដោយអត្ថថា ទៀង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសមថៈ ដោយអត្ថថា មិនរាយមាយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវិបស្សនា ដោយអត្ថថា ពិចារណាឃើញរឿយ ៗ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសមថៈនិងវិបស្សនា ដោយអត្ថថា មានរសតែមួយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវយុគនទ្ធធម៌ ដោយអត្ថថា មិនប្រព្រឹត្តលើសគ្នា ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសីលវិសុទ្ធិ ដោយអត្ថថា សង្រួម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវទិដ្ឋិវិសុទ្ធិដោយអត្ថថា យល់ឃើញ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវិមោក្ខ ដោយអត្ថថា រួច ( ចាក

កិលេស ) ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវិជ្ជា ដោយអត្ថថា ចាក់ធ្លុះចំពោះ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវិមុត្តិ ដោយអត្ថថា លះបង់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវខយញ្ញាណ ដោយអត្ថថា ផ្តាច់ផ្តិល ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវអនុប្បាទញ្ញាណ ដោយអត្ថថា ស្ងប់រម្ងាប់ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវឆន្ទៈ ដោយអត្ថថា ជាឫស ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវមនសិការៈ ដោយអត្ថថា តាំងឡើងព្រម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវផស្សៈ ដោយអត្ថថា ប្រជុំ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវេទនា ដោយអត្ថថា ប្រជុំចុះ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសមាធិ ដោយអត្ថថា ជាប្រមុខ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវសតិ ដោយអត្ថថា ភាពជាធំ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវបញ្ញា ដោយអត្ថថា ក្រៃលែងជាងនោះ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវវិមុត្តិ ដោយអត្ថថា ជាខ្លឹម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងនូវនិព្វាន ឈ្មោះអមតៈជាទីពឹង ( របស់សត្វ ) ដោយអត្ថថា ចប់ស្រេច ( នៃកិច្ចក្នុងសាសនា ) ។

## សាវត្ថីនិទាន

[ ៤០ ] ព្រះសារីបុត្តមានអាយុ ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលអាវុសោទាំងឡាយ ។ ពួកភិក្ខុទាំងនោះទទួលស្តាប់ព្រះសារីបុត្តមានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្តមានអាយុបានពោលយ៉ាងនេះថា

ម្នាលអាវុសោទាំងឡាយ ពោជ្ឈង្គនេះមាន ៧ ពោជ្ឈង្គ ៧ តើដូចម្តេច គឺសតិសម្ពោជ្ឈង្គ ធម្មវិចយសម្ពោជ្ឈង្គ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ ម្នាលអាវុសោទាំងឡាយ នេះឯងពោជ្ឈង្គ ៧ ម្នាលអាវុសោទាំងឡាយ បណ្តាពោជ្ឈង្គទាំង ៧ នេះ ខ្ញុំប្រាថ្នានៅអស់បុព្វណ្ហសម័យដោយពោជ្ឈង្គណាៗ ខ្ញុំក៏នៅអស់បុព្វណ្ហសម័យដោយពោជ្ឈង្គនោះ ៗ ខ្ញុំប្រាថ្នានៅអស់មជ្ឈន្តិក-សម័យ ដោយពោជ្ឈង្គណា ៗ ។បេ។ នៅអស់សាយណ្ហសម័យ ខ្ញុំក៏នៅអស់សាយណ្ហសម័យដោយពោជ្ឈង្គនោះ ៗ ម្នាលអាវុសោទាំងឡាយ ប្រ-សិនបើសតិសម្ពោជ្ឈង្គរបស់ខ្ញុំ មានដោយប្រការនោះ ៗ ខ្ញុំក៏មានការដឹងថា និរោធ ជាធម៌ប្រមាណមិនបាន ទាំងខ្ញុំមានការដឹងថា និរោធជាធម៌ប្រារព្ធសេចក្តីស្ងប់ប្រពៃ ខ្ញុំកាលប្រព្រឹត្តនូវសតិសម្ពោជ្ឈង្គ ដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គកំពុងឋិតនៅ បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ ធម្មវិចយសម្ពោជ្ឈង្គ ។បេ។ ម្នាលអាវុសោទាំងឡាយ បើឧបេក្ខា-សម្ពោជ្ឈង្គរបស់ខ្ញុំមានដោយប្រការនោះ ៗ ខ្ញុំក៏មានការដឹងថា និរោធជាធម៌ប្រមាណមិនបាន ទាំងខ្ញុំមានការដឹងថា និរោធ ជាធម៌ប្រារព្ធសេចក្តីស្ងប់ប្រពៃ ខ្ញុំកាលប្រព្រឹត្តនូវឧបេក្ខាសម្ពោជ្ឈង្គដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គកំពុងឋិតនៅ ប្រសិនបើឧបេក្ខាសម្ពោជ្ឈង្គ របស់ខ្ញុំឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ ម្នាលអាវុសោទាំងឡាយ ប្រៀបដូចទូសំពត់របស់ព្រះ

រាជា ឬរបស់រាជមហាមាត្យ ជារបស់ពេញដោយសំពត់ ដែលគេជ្រលក់ដោយពណ៌ផ្សេង ៗ ព្រះរាជានោះប្រាថ្នានឹងទ្រង់នូវគូនៃព្រះពស្ត្រណា អស់បុព្វណ្ហសម័យ ក៏ទ្រង់នូវគូនៃព្រះពស្ត្រនោះឯងអស់បុព្វណ្ហសម័យ ប្រាថ្នានូវគូនៃព្រះពស្ត្រណា អស់មជ្ឈន្តិកសម័យ អស់សាយណ្ហសម័យ ក៏ទ្រង់នូវគូនៃព្រះពស្ត្រនោះឯង អស់សាយណ្ហសម័យ មានឧបមាដូចម្តេចមិញ ម្នាលអាវុសោទាំងឡាយ មានឧបមេយ្យដូចជា បណ្តាពោជ្ឈង្គទាំង ៧ នេះ ខ្ញុំប្រាថ្នានៅអស់បុព្វណ្ហសម័យដោយពោជ្ឈង្គណា ៗ ខ្ញុំក៏នៅអស់បុព្វណ្ហ-សម័យដោយពោជ្ឈង្គនោះ ៗ ខ្ញុំប្រាថ្នានៅអស់មជ្ឈន្តិកសម័យ អស់សា-យណ្ហ សម័យដោយពោជ្ឈង្គណា ៗ ខ្ញុំក៏នៅអស់សាយណ្ហសម័យដោយពោជ្ឈង្គនោះ ៗ ម្នាលអាវុសោទាំងឡាយ បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំមានដោយប្រការនោះៗ ខ្ញុំក៏មានការដឹងថា និរោធជាធម៌ប្រមាណមិនបាន ទាំងខ្ញុំមានការដឹងថា និរោធ ជាធម៌ប្រារព្ធសេចក្តីស្ងប់ប្រពៃ ខ្ញុំកាលប្រព្រឹត្តនូវសតិសម្ពោជ្ឈង្គដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ កំពុងឋិតនៅ បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ ។បេ។ ម្នាលអាវុសោទាំងឡាយ បើឧបេក្ខាសម្ពោជ្ឈង្គ របស់ខ្ញុំមានដោយប្រការនោះៗ ខ្ញុំក៏មានការដឹងថា និរោធ ជាធម៌ប្រមាណមិនបាន ទាំងខ្ញុំមានការដឹងថា និរោធជាធម៌ប្រារព្ធសេចក្តីស្ងប់ប្រពៃ ខ្ញុំកាលប្រព្រឹត្តឧបេក្ខាសម្ពោជ្ឈង្គដែលកំពុងឋិតនៅក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គកំពុងឋិតនៅ បើឧបេក្ខាសម្ពោជ្ឈង្គ

របស់ខ្ញុំឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ ។

[ ៤១ ] ពោជ្ឈង្គ ( អង្គនៃការត្រាស់ដឹង ) ថា បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំមានដោយប្រការនោះៗ តើដូចម្តេច ។ និរោធប្រាកដឡើងត្រឹមណា ពោជ្ឈង្គថា បើសតិសម្ពោជ្ឈង្គរបស់ខ្ញុំមានដោយប្រការនោះៗ ក៏ត្រឹមណោះ ប្រៀបដូចប្រទីបប្រេង ដែលកំពុងឆេះ មានអណ្តាតភ្លើងត្រឹមណា រស្មីក៏ត្រឹមណោះ រស្មីត្រឹមណា អណ្តាតភ្លើងក៏ត្រឹមណោះ មានឧបមាយ៉ាងណា និរោធប្រាកដឡើងត្រឹមណា ពោជ្ឈង្គថា បើសតិសម្ពោជ្ឈង្គ របស់ខ្ញុំមានដោយប្រការនោះៗ ក៏ត្រឹមណោះ មានឧបមេយ្យយ៉ាងនោះឯង ។

ពោជ្ឈង្គ ( អង្គនៃការត្រាស់ដឹង ) ថា ខ្ញុំមានការដឹងថា និរោធ ជាធម៌ប្រមាណមិនបាន តើដូចម្តេច ។ កិលេសទាំងឡាយ មានប្រមាណ កិលេសទាំងអស់ជាគ្រឿងគ្របសង្កត់ សង្ខារទាំងឡាយ ជាធម៌នាំសត្វទៅកើតក្នុងភពថ្មី ឯនិរោធជាធម៌ប្រមាណមិនបានទេ ព្រោះអត្ថថាជាអសង្ខតធម៌ និរោធប្រាកដឡើងត្រឹមណា ពោជ្ឈង្គថា ខ្ញុំមានការដឹងថា និរោធជាធម៌ប្រមាណមិនបាន ក៏ត្រឹមណោះដែរ ។

ពោជ្ឈង្គ ( អង្គនៃការត្រាស់ដឹង ) ថា ខ្ញុំមានការដឹងថា និរោធជាធម៌ប្រាសចាកសេចក្តីស្ងប់ប្រពៃ តើដូចម្តេច ។ កិលេសទាំងឡាយគ្មានការស្ងប់ កិលេសទាំងអស់ជាគ្រឿងគ្របសង្កត់ចិត្ត សង្ខារទាំងឡាយជាគ្រឿងនាំសត្វទៅកើតក្នុងភពថ្មី ឯនិរោធមានការស្ងប់ជាធម្មតា ព្រោះអត្ថថា ជាធម៌ស្ងប់

ព្រោះអត្ថថា ជាធម៌ថ្លៃថ្លា និរោធប្រាកដឡើងត្រឹមណា ពោជ្ឈង្គថា ខ្ញុំមានការដឹងថា និរោធ ជាធម៌ប្រាកដួសេចក្តីស្ងប់ប្រពៃ ក៏ត្រឹមណោះ ។

[ ៤២ ] ខ្ញុំកាលប្រព្រឹត្តនូវសតិសម្ពោជ្ឈង្គដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គកំពុងឋិតនៅ បើសតិសម្ពោជ្ឈង្គឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យតើដូចម្តេច សតិសម្ពោជ្ឈង្គឋិតនៅ ដោយអាការប៉ុន្មាន សតិសម្ពោជ្ឈង្គឃ្លាត ដោយអាការប៉ុន្មាន សតិសម្ពោជ្ឈង្គឋិតនៅដោយអាការ ៨ សតិ-សម្ពោជ្ឈង្គឃ្លាត ដោយអាការ ៨ ។

សតិសម្ពោជ្ឈង្គឋិតនៅដោយអាការ ៨ តើដូចម្តេច ។ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវការមិនកើតឡើង ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវការកើតឡើង ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវការមិនប្រព្រឹត្ត ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវការប្រព្រឹត្តិ ១ សតិ-សម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវអនិមិត្ត ១ សតិសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវនិមិត្ត ១ សតិសម្ពោជ្ឈង្គឋិតនៅព្រោះរំពឹងនូវនិរោធ ១ សតិ-សម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវសង្ខារ ១ នេះសតិសម្ពោជ្ឈង្គឋិតនៅដោយអាការ ៨ យ៉ាង ។

សតិសម្ពោជ្ឈង្គឃ្លាតដោយអាការ ៨ តើដូចម្តេច ។ សតិសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវការកើតឡើង ១ សតិសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវការមិនកើតឡើង ១ សតិសម្ពោជ្ឈង្គឃ្លាតព្រោះរំពឹងនូវការប្រព្រឹត្តិ ១

សតិសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវការមិនប្រព្រឹត្ត ១ សតិសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវនិមិត្ត ១ សតិសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវអនិមិត្ត ១ សតិសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវសង្ខារ ១ សតិសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវនិរោធ ១ នេះសតិសម្ពោជ្ឈង្គ ឃ្លាតដោយអាការ ៨ យ៉ាង ខ្ញុំកាលប្រព្រឹត្តនូវសតិសម្ពោជ្ឈង្គដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គកំពុងឋិតនៅ បើសតិសម្ពោជ្ឈង្គឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ យ៉ាងនេះឯង ។បេ។

[ ៤៣ ] ពោជ្ឈង្គ ( អង្គនៃការត្រាស់ដឹង ) ថា បើឧបេក្ខាសម្ពោជ្ឈង្គរបស់ខ្ញុំមានដោយប្រការនោះៗ តើដូចម្តេច ។ និរោធប្រាកដឡើងត្រឹមណា ពោជ្ឈង្គថា បើឧបេក្ខាសម្ពោជ្ឈង្គ របស់ខ្ញុំមានដោយប្រការនោះៗ ក៏ត្រឹមណោះដែរ ប្រៀបដូចប្រទីបប្រេងដែលកំពុងឆេះ មានអណ្តាតភ្លើងត្រឹមណា រស្មីក៏ត្រឹមណោះ រស្មីត្រឹមណា អណ្តាតភ្លើងក៏ត្រឹមណោះ មានឧបមេយ្យយ៉ាងណា និរោធប្រាកដត្រឹមណា ពោជ្ឈង្គថា បើឧបេក្ខាសម្ពោជ្ឈង្គរបស់ខ្ញុំមានដោយប្រការនោះៗ ក៏ត្រឹមណោះដែរ ។

ពោជ្ឈង្គ ( អង្គនៃការត្រាស់ដឹង ) ថា និរោធជាធម៌ប្រមាណមិនបាន តើដូចម្តេច ។ កិលេសទាំងឡាយមានប្រមាណ កិលេសទាំងអស់ជាគ្រឿងគ្របសង្កត់ចិត្ត សង្ខារទាំងឡាយជាគ្រឿងនាំសត្វទៅកើតក្នុងភពថ្មី ឯនិរោធជាធម៌ប្រមាណមិនបានទេ ព្រោះអត្ថថា ជាអសង្ខតធម៌ និរោធប្រាកដត្រឹម

ណា ពោជ្ឈង្គថា និរោធ ជាធម៌ប្រមាណមិនបានត្រឹមណោះដែរ ។

ពោជ្ឈង្គ ( អង្គនៃការត្រាស់ដឹង ) ថា និរោធ ជាធម៌ប្រាកដសេចក្តីស្ងប់ប្រពៃ តើដូចម្តេច ។ កិលេសទាំងឡាយគ្មានការស្ងប់ កិលេសទាំងអស់ជាគ្រឿងគ្របសង្កត់ចិត្ត សង្ខារទាំងឡាយជាគ្រឿងនាំសត្វទៅកើតក្នុងភពថ្មី ឯនិរោធមានការស្ងប់ជាធម្មតា ព្រោះអត្ថថា ជាធម៌ស្ងប់ ព្រោះអត្ថថា ជាធម៌ថ្លៃថ្លា និរោធប្រាកដត្រឹមណា ពោជ្ឈង្គថា និរោធជាធម៌ប្រាកដសេចក្តីស្ងប់ប្រពៃ ក៏ត្រឹមណោះដែរ ។

ខ្ញុំកាលប្រព្រឹត្តនូវឧបេក្ខាសម្ពោជ្ឈង្គ ដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គកំពុងឋិតនៅ បើឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ តើដូចម្តេច ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ដោយអាការប៉ុន្មាន ឧបេក្ខាសម្ពោជ្ឈង្គឃ្លាតដោយអាការប៉ុន្មាន ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅដោយអាការ ៨ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ដោយអាការ ៨ ។

[ ៤៤ ] ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅដោយអាការ ៨ តើដូចម្តេច ។ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅព្រោះរំពឹងនូវការកើតឡើង ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវការមិនកើតឡើង ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅព្រោះរំពឹងនូវការមិនប្រព្រឹត្តិ ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅព្រោះមិនរំពឹងនូវការប្រព្រឹត្តិ ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះរំពឹងនូវអនិមិត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ ព្រោះមិនរំពឹងនូវនិមិត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឋិតនៅ

ព្រោះមិនរំពឹងនូវនិរោធ ១ ឧបេក្ខាសម្ពោជ្ឈង្គ ឋិតនៅ ព្រោះមិនរំពឹងនូវសង្ខារ ១ នេះឧបេក្ខាសម្ពោជ្ឈង្គឋិតនៅដោយអាការ ៨ យ៉ាង ។

ឧបេក្ខាសម្ពោជ្ឈង្គឃ្លាតដោយអាការ ៨ តើដូចម្តេច ។ ឧបេក្ខាសម្ពោ-ជ្ឈង្គឃ្លាត ព្រោះរំពឹងនូវការកើតឡើង ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវការមិនកើតឡើង ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវការប្រព្រឹត្តិ ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវការមិនប្រព្រឹត្តិ ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវនិមិត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវអនិមិត្ត ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះរំពឹងនូវសង្ខារ ១ ឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ព្រោះមិនរំពឹងនូវនិរោធ ១ នេះឧបេក្ខាសម្ពោជ្ឈង្គឃ្លាតដោយអាការ ៨ យ៉ាង ។ ខ្ញុំកាលប្រព្រឹត្តនូវឧបេក្ខាសម្ពោជ្ឈង្គ ដែលកំពុងឋិតនៅ ក៏ដឹងច្បាស់ថាឧបេក្ខាសម្ពោជ្ឈង្គកំពុងឋិតនៅ បើឧបេក្ខាសម្ពោជ្ឈង្គឃ្លាត ខ្ញុំក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គរបស់អាត្មាអញឃ្លាត ព្រោះដំណើរនេះជាបច្ច័យ យ៉ាងនេះឯង ។

**ចប់ ពោជ្ឈង្គកថា ។**

# អដ្ឋកថា

## ពោជ្ឈង្គកថា

[ ២៨ ] ឥឡូវនេះ នឹងពណ៌នាសេចក្តីតាមលំដាប់ ដែលមិនទាន់ពណ៌នាក្នុងពោជ្ឈង្គកថាដែលមានព្រះសូត្រជាបទនាំ ដែលព្រះសារីបុត្តត្ថេរសម្តែងដល់ភាពពិសេសរបស់ពោជ្ឈង្គៈ ដែលឲ្យសម្រេចនូវការចាក់ធ្លុះសច្ចៈពោលទុកហើយ ។

ក្នុងបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រមុន ដូចតទៅនេះថា បទថា **ពោជ្ឈង្គា** លោកពោលថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃការត្រាស់ដឹងឬនៃបុគ្គលអ្នកត្រាស់ដឹង ។ ធម្មសាមគ្គីនេះ ការត្រាស់ដឹងលោកហៅថា ពោធិ ព្រោះធ្វើវិគ្គហៈថា ព្រះអរិយសាវក រមែងត្រាស់ដឹងដោយធម្មសាមគ្គីណាដែលបានដល់ សតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិនិងឧបេក្ខាដែលកើតឡើងក្នុងខណៈនៃលោកុត្តរមគ្គ ដែលជាបដិបក្ខនៃអន្តរាយទាំងឡាយមិនមែនតិច មានការរួញរា ការរាយមាយ ការតាំងនៅ ការប្រមូលមក ការប្រកបកាមសុខ ការធ្វើខ្លួនឲ្យលំបាក ឧច្ឆេទទិដ្ឋិ សស្សតទិដ្ឋិ និងការប្រកាន់មាំជាដើម ពាក្យថា រមែងត្រាស់ដឹង លោកអធិប្បាយថា ចេញចាកការដេកលក់ដែលជាសន្តានរបស់កិលេស ឬចាក់ធ្លុះអរិយសច្ចៈ ៤ ឬធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ដូចព្រះសារីបុត្តត្ថេរពោលទុក ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា បានចម្រើននូវសម្ពោជ្ឈង្គទាំង ៧ តាមគួរដល់សេចក្តីពិត បានត្រាស់ដឹងនូវ

អនុត្តរសម្មាសម្ពោធិញ្ញាណដែរ ដូច្នេះ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះជាអង្គនៃការត្រាស់ដឹងដែលបានដល់ធម្មសាមគ្គីនោះ ដូចអង្គនៃឈាន និងអង្គនៃមគ្គជាដើម ។ អរិយសាវកនោះ ក៏ហៅថា ពោធិ ព្រោះវិគ្គហៈថា រមែងត្រាស់ដឹងដោយធម្មសាមគ្គីនេះ មានប្រការតាមដែលពោលហើយ ។ ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ជាអង្គនៃសាវកដែលត្រាស់ដឹងនោះ ដូចអង្គនៃសេនាសនៈ និងអង្គនៃរថជាដើម ដោយហេតុនោះ ទើបព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ជាអង្គនៃអ្នកត្រាស់ដឹង ។ អត្ថនៃសតិសម្ពោជ្ឈង្គៈជាដើម ខ្ញុំពោលទុកហើយក្នុងអភិញ្ញេយ្យ-និទ្ទេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពោជ្ឈង្គត្ថនិទ្ទេស ដូចតទៅនេះថា បទថា **ពោធាយ សំវត្តន្តិ** បានដល់ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ការត្រាស់ដឹង ។ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹង ដូចម្តេច ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងនិព្វាន ដោយមគ្គនិងផល របស់បុគ្គលដែលមានកិច្ចធ្វើហើយដោយបច្ចវេក្ខណញ្ញាណ ម្យ៉ាងទៀត មានអធិប្បាយថា ដើម្បីប្រយោជន៍ដល់ការភ្ញាក់អំពីការដេកលក់ គឺកិលេស ដោយមគ្គដើម្បីប្រយោជន៍ដល់ភាពជាអ្នកភ្ញាក់ហើយដោយផល ។ ពោជ្ឈង្គៈ រមែងប្រព្រឹត្តទៅដើម្បីការត្រាស់ដឹង សូម្បីដោយវិបស្សនាដែលមានកម្លាំង ។ ព្រោះហេតុនោះ ទើបសព្ទនេះ មានន័យទូទៅដល់ពោជ្ឈង្គៈ ដែលជាវិបស្សនាមគ្គ និងផល ។ ពោជ្ឈង្គៈទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីការត្រាស់ដឹង គឺដើម្បីការបាក់ចុះ

និព្វានក្នុងឋានៈទាំង ៣ ។ ដោយពាក្យនេះ ឈ្មោះថា លោកពោលដល់ពាក្យថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃការត្រាស់ដឹង ។

ហេតុកើតរបស់ពោជ្ឈង្គៈ ដែលលោកពោលទុកដោយចតុក្កៈ ៥ មាន **ពុជ្ឈន្តីតិ ពោជ្ឈង្គា** ជាដើម លោកពោលទុក ក្នុងអភិញ្ញេយ្យនិទ្ទេស ។ ម្យ៉ាងទៀត បទថា **ពុជ្ឈន្តិ** ជាពាក្យសម្តែងដល់អ្នកធ្វើ ដើម្បីសម្តែងថា ពោជ្ឈង្គៈទាំងឡាយ អាចក្នុងការធ្វើកិច្ចរបស់ខ្លួន ។ បទថា **ពុជ្ឈនដ្ឋេន** ជាពាក្យសម្តែងដល់សភាវៈ ដើម្បីសម្តែងការមិនមានអ្នកធ្វើ ក្នុងកាលពោជ្ឈង្គៈអាចក្នុងការធ្វើកិច្ចរបស់ខ្លួនមាន ។ បទថា **ពោធេន្តិ** ជាពាក្យសម្តែងដល់ហេតុកត្តា ( អ្នកប្រើឲ្យធ្វើ ) នៃពោជ្ឈង្គៈ ព្រោះជាធម៌ដឹកនាំព្រះយោគាវចរដែលត្រាស់ដឹងដោយការចម្រើនពោជ្ឈង្គៈ ។ បទថា **ពោធនដ្ឋេន** ជាពាក្យសម្តែងដល់ភាវៈរបស់ហេតុកត្តា ដែលដឹកនាំតាមន័យដូចពោលហើយ ដំបូងនោះឯង ។ ដោយបទទាំងនេះ ទើបមានពាក្យអធិប្បាយថា ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអត្ថថា ជាអង្គនៃការត្រាស់ដឹង ។ បទថា **ពោធិបក្ខិយដ្ឋេន** បានដល់ ព្រោះប្រព្រឹត្តទៅក្នុងចំណែករបស់ព្រះយោគាវចរដែលបានឈ្មោះថា **ពោធិ** ព្រោះអត្ថថា ត្រាស់ដឹង ។ សព្ទនេះ ជាការចង្អុលបង្ហាញភាពដែលសម្ពោជ្ឈង្គៈទាំងនោះ ជាឧបការៈដល់ព្រះយោគាវចរ ។ ដោយបទទាំងនេះ លោកអធិប្បាយថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះអត្ថថា ជាអង្គនៃការត្រាស់ដឹង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៦ មាន **ពុទ្ធិលភនដ្ឋេន** ជាដើម ដូចតទៅនេះថា បទថា **ពុទ្ធិលភនដ្ឋេន** បានដល់

ព្រោះអត្ថថា ឲ្យយោគាវចរដល់នូវការត្រាស់ដឹង ។ បទថា **ពោធនដ្ឋេន** បានដល់ ព្រោះអត្ថថា ឲ្យសត្វទាំងឡាយតាំងនៅ ។ បទថា **ចាគនដ្ឋេន** បានដល់ ព្រោះអត្ថថា ឲ្យសម្រេចនូវភាពដែលឲ្យសត្វតាំងនៅ ។

អាចារ្យទាំងឡាយពោលថា ពោជ្ឈង្គៈដែលជាវិបស្សនាទាំងនេះ គឺពោជ្ឈង្គៈដែលជាមគ្គផល លោកឲ្យវិសេសដោយឧបសគ្គ ៣ សព្ទ គឺ **បដិ** ( ចំពោះ ) ១ **អភិ** ( ក្រៃលែង ) ១ **សំ** ( ព្រម ) ១ ។ គប្បីជ្រាបថា លោកអធិប្បាយទុកថា ឈ្មោះថា **ពោជ្ឈង្គ** ព្រោះជាអង្គនៃការត្រាស់ដឹងពោជ្ឈង្គៈទាំងឡាយ ដែលលោកចង្អុលបង្ហាញទុកដោយធម្មវោហារ សូម្បីទាំងអស់ ។

# អដ្ឋកថា

## មូលមូលកាទិនសកកថា

[ ២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ១០ ដែលមានមូលសព្ទ ជាមូល មានមូលដ្ឋេនៈជាដើម ដូចតទៅនេះថា បទថា **មូលដ្ឋេន** បានដល់ ព្រោះ ក្នុងវិបស្សនាជាដើម ពោជ្ឈង្គៈមុនៗ ជាមូលរបស់ពោជ្ឈង្គៈក្រោយៗ នៃ សហជាតធម៌ និង នៃគ្នានឹងគ្នា ។ បទថា **មូលចរិយដ្ឋេន** បានដល់ ការ ប្រព្រឹត្តិ ការប្រព្រឹត្តិទៅដែលជាមូល ឈ្មោះថា **មូលចរិយា** ព្រោះអត្ថថា ប្រព្រឹត្តជាមូលនោះ អធិប្បាយថា ព្រោះអត្ថថា ជាមូល ហើយទើប ប្រព្រឹត្តទៅ ។ បទថា **មូលបរិគ្គហដ្ឋេន** បានដល់ ពោជ្ឈង្គៈទាំងនោះឯង ឈ្មោះថា ជាគ្រឿងថែទាំ ព្រោះថែទាំ ដើម្បីត្រូវការឲ្យកើតតាំងអំពីដើម ការថែទាំធម៌ដែលជាមូលនោះឯង ឈ្មោះថា **មូលបរិគ្គហា** ព្រោះអត្ថថា ថែទាំធម៌ដែលជាមូលនោះ ។ ធម៌ទាំងនោះឯងឈ្មោះថា ពោជ្ឈង្គៈ ព្រោះ អត្ថថា ជាបរិវារ ដោយអំណាចជាបរិវារនៃគ្នានឹងគ្នា ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអត្ថថា ជាភាពបរិបូរដោយអំណាចភាពបរិបូរនៃភាវនា ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអត្ថថា ជាភាពចាស់ក្លាដោយអំណាចចាក់ធ្លុះនូវការសម្រេច ។ ពោជ្ឈង្គនោះឯង ឈ្មោះថា មូលប្បដិសម្ភិទា ព្រោះអត្ថថា ជាមូល ដោយ ជាបដិសម្ភិទា ៦ យ៉ាង ព្រោះបែកធ្លាយដោយប្រភេទផងដែរ ។ ព្រោះអត្ថ ថា បែកធ្លាយក្នុងធម៌ដែលជាមូលនោះ ។

បទថា **មូលប្បដិសម្ភិទាចាបនដ្ឋេន** បានដល់ ព្រោះអត្ថថា ធ្វើព្រះ

យោគាវចរដែលខ្វល់ខ្វាយ ក្នុងការចម្រើនពោជ្ឈង្គៈ ឲ្យសម្រេចបដិសម្ភិទា ដោយធម៌ដែលជាមូលនោះ ។

ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអត្ថថា ព្រោះព្រះយោគាវចរនោះឯង ជាអ្នកចម្រើននូវវសី ក្នុងបដិសម្ភិទាក្នុងធម៌ដែលជាមូលនោះ ។ ក្នុងវោហារដ៏សេសដែលពោលដោយបុគ្គលបែបនេះ ក៏គប្បីជ្រាបថា លោកពោលថា ពោជ្ឈង្គៈ ព្រោះអត្ថថា ជាអង្គនៃអ្នកត្រាស់ដឹង ។

ក្នុងបទចុងក្រោយបែបនេះថា **មូលប្បដិសម្ភិទាយ វសីភាវប្បត្តានម្បិ** ក៏គប្បីជ្រាបថា ជាពោជ្ឈង្គៈដែលជាផល ។ បាឋៈថា **វសីភាវំ បត្តានំ** ដូច្នេះក៏មាន ។

## មូលមូលកទសក ចប់

ក្នុងពួកជប់ ៩ ពួក មានហេតុសព្ទជាមូលជាដើម ក៏គប្បីជ្រាបអត្ថនៃពាក្យទូទៅ ដោយន័យនេះឯង ចំណែកក្នុងពាក្យដែលមិនទូទៅ ពោជ្ឈង្គៈតាមដែលពោលហើយ ឈ្មោះថា ជាហេតុ ព្រោះឲ្យកើតធម៌ តាមដែលពោលហើយ ។

ឈ្មោះថា **បច្ចយ** ព្រោះជួយឧបត្ថម្ភ ។ ពោជ្ឈង្គៈទាំងនោះ ឈ្មោះថា **វិសុទ្ធិ** ព្រោះជាសេចក្តីបរិសុទ្ធិដោយតទង្គៈ សមុច្ឆេទនិងបដិបស្សទ្ធិ ។ ឈ្មោះថា **អនវជ្ជា** ព្រោះប្រាសចាកទោស ។ ឈ្មោះថា **នេក្ខម្មំ** ព្រោះបាលីថា កុសលធម៌សូម្បីទាំងអស់ជានេក្ខម្មៈ ។ ឈ្មោះថា **វិមុត្តិ** ដោយ

អំណាចនៃតទង្គវិមុត្តិជាដើមព្រោះផុតចាកកិលេសទាំងឡាយ ។ ពោជ្ឈង្គៈដែលជាមគ្គនិងផល ឈ្មោះថា **អនាសវា** ព្រោះប្រាសចាកវិស័យរបស់អាសវៈ ។ ពោជ្ឈង្គៈសូម្បី ៣ យ៉ាង ឈ្មោះថា **វិវេកា** ដោយអំណាចនៃតទង្គវិវេកជាដើម ព្រោះទទេចាកកិលេសទាំងឡាយ ។ ពោជ្ឈង្គៈដែលជាវិបស្សនានិងមគ្គ ឈ្មោះថា **វោស្សគ្គា** ព្រោះលះបង់ដោយការបរិច្ចាគ ( បរិច្ចាគវោស្សគ្គ ) និងលះបង់ដោយការស្ទុះទៅ ( បក្ខន្ទនវោស្សគ្គ ) ។ ពោជ្ឈង្គៈដែលជាផល ឈ្មោះថា **វោស្សគ្គា** ព្រោះលះបង់ដោយការស្ទុះទៅ ។

[ ៣០ ] ទសកៈ ៩ ពួក ដែលលោកសម្ដែងដោយបទនីមួយៗថា **មូលដ្ឋំ ពុជ្ឈន្តិ** ជាដើម គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។

ចំណែកបទថា **វសីភាវប្បត្តានំ** លោកមិនប្រកបទុកព្រោះមិនជាពាក្យបច្ចុប្បន្នកាល ។

[ ៣១-៣៩ ] បទថា **បរិគ្គហដ្ឋ** ជាដើម មានអត្ថដូចពោលហើយក្នុងអភិញ្ញេយ្យនិទ្ទេសនោះឯង ។

## អដ្ឋកថាមូលមូលកាទិទសកកថា ចប់

[ ៤០ ] ព្រះថេរៈកាលលើកសូត្រដែលខ្ទួនសម្ដែងឡើងហើយ បំណងនឹងសម្ដែងការកំណត់ពោជ្ឈង្គៈ ដោយអំណាចាការចង្អុលបង្ហាញសូត្រនោះទើបពោលនិទាន មានពាក្យថា **ឯកំ សមយំ** ជាដើម ហើយលើកសូត្រ

ឡើងសម្តែងមុន ។ ម្យ៉ាងទៀត ក្នុងសូត្រនេះ ព្រោះជាសូត្រដែលខ្លួនឯងសម្តែងទើបលោកមិនពោលថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ ម្យ៉ាងទៀត ក្នុងបទថា **អាយស្មា សារីបុត្តោ** នេះ លោកពោលធ្វើខ្លួនដូចជាអ្នកដទៃ ដើម្បីភាពជាអ្នកឈ្លាសរបស់អ្នកសម្តែង ។ អាចារ្យទាំងឡាយប្រកបពាក្យបែបនេះទុកច្រើនក្នុងគម្ពីរទាំងឡាយក្នុងលោក ។ បទថា **បុព្វ-ណ្ហសមយំ** បានដល់ អស់វេលាព្រឹកទាំងមូល ។ បទនេះជាទុតិយាវិភត្តិចុះក្នុងអត្ថនៃអច្ចន្តសំយោគ សូម្បីក្នុងពីរបទដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **សតិសម្ពោជ្ឈង្គោ ឥតិ ចេ មេ ហោតិ** បានដល់ ប្រសិនបើ សតិ-សម្ពោជ្ឈង្គៈរបស់ខ្ញុំមានដូច្នេះ គឺយ៉ាងនេះ ។ បទថា **អប្បមាណោតិ មេ ហោតិ** បានដល់ សតិសម្ពោជ្ឈង្គៈរបស់ខ្ញុំ ឈ្មោះថា ប្រមាណមិនបានមានយ៉ាងនេះ ។ បទថា **សុសមារទ្ធោតិ មេ ហោតិ** បានដល់ សតិសម្ពោ-ជ្ឈង្គៈរបស់ខ្ញុំ ឈ្មោះថា បរិបូរណ៍ដោយល្អយ៉ាងនេះ ។ បទថា **តិដ្ឋន្តំ** បានដល់ តាំងនៅ ដោយប្រព្រឹត្តទៅក្នុងនិព្វានារម្មណ៍ ។ បទថា **ចវតិ** បានដល់ ចៀសចេញទៅចាកនិព្វានារម្មណ៍ ។ សូម្បីក្នុងពោជ្ឈង្គៈដ៏សេស ក៏មានន័យនេះ ។ បទថា **រាជមហាមត្តស្ស** បានដល់ របស់មហាអាមាត្យនៃព្រះរាជា ឬរបស់បុគ្គលដែលប្រកបដោយប្រមាណភោគសម្បត្តិ ព្រោះមានប្រមាណនៃភោគសម្បត្តិច្រើន ។ បទថា **នានារត្តានំ** បានដល់ ដែលជ្រលក់ដោយពណ៌ផ្សេង ៗ ។ បទនេះជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថបរិបុណ៌ អធិប្បាយថា ដោយពណ៌ផ្សេងៗ ។ បទថា **ទុស្សករណ្ឌកោ** បានដល់

ទូរក្សាសំពត់ ។ បទថា **ធុរស្សយុគំ** បានដល់ គូនៃសំពត់ ។ បទថា **ចារុបិតុំ** បានដល់ នឹងស្លៀកដណ្តប់ ។ ក្នុងសូត្រនេះលោកពោលដល់ពោជ្ឈង្គៈ ដែលជាផល ។ ពិតណាស់ ក្នុងកាលណាព្រះថេរៈចូលផលសមាបត្តិ ធ្វើសតិសម្ពោជ្ឈង្គៈឲ្យជាធំ ក្នុងកាលនោះ ពោជ្ឈង្គៈក្រៅអំពីនេះក៏អនុលោមតាមសតិសម្ពោជ្ឈង្គៈនោះទៅ ។ ក្នុងកាលណាធ្វើធម្មវិចយសម្ពោជ្ឈង្គៈជាដើម ឯណានីមួយ ឲ្យជាធំ ក្នុងកាលនោះ ពោជ្ឈង្គៈដ៏សេសក៏អនុលោមតាមធម្មវិចយសម្ពោជ្ឈង្គៈជាដើមនោះទៅ ព្រោះហេតុនោះ កាលព្រះថេរៈ សម្តែងភាពដែលខ្លួនមានការជំនាញក្នុងការប្រព្រឹត្តិផលសមាបត្តិយ៉ាងនោះ ទើបពោលសូត្រនេះ ។

# អដ្ឋកថា

## សុត្តន្តនិទ្ទេស

[ ៤១ ] ក្នុងបទថា **កថំ សតិសម្ពោជ្ឈង្គោ ឥតិ មេ ហោតិតី ពោជ្ឈង្គោ** អធិប្បាយថា បើខ្ញុំចូលផលសមាបត្តិធ្វើសតិសម្ពោជង្គៈឲ្យជាធំ កាលពោជ្ឈង្គដទៃមាន សតិសម្ពោជ្ឈង្គនេះរមែងមានយ៉ាងនេះ ព្រោះហេតុនោះ កាលខ្ញុំប្រព្រឹត្តដូច្នេះ សតិសម្ពោជ្ឈង្គនោះដូចម្តេច ។

បទថា **យាវតា និរោធូបដ្ឋាតិ** បានដល់ រមែងប្រាកដដោយកាលមានប្រមាណប៉ុណ្ណា អធិប្បាយថា និព្វានរមែងប្រាកដដោយអារម្មណ៍ ក្នុងកាលមានប្រមាណប៉ុណ្ណា ។ បទថា **យាវតា អច្ចិ** បានដល់ អណ្តាតភ្លើងមានប្រមាណប៉ុណ្ណា ។ បទថា **កថំ អប្បមាណោ ឥតិ មេ ហោតីតិ ពោជ្ឈង្គោ** អធិប្បាយថា ប្រសិនបើកាលសតិសម្ពោជ្ឈង្គៈមិនមានប្រមាណមាន សតិសម្ពោជ្ឈង្គៈនេះរមែងមិនមានប្រមាណដោយអាការយ៉ាងនេះ ព្រោះហេតុនោះកាលខ្ញុំប្រព្រឹត្តដូច្នេះ សតិសម្ពោជ្ឈង្គៈដែលមិនមានប្រមាណនោះដូចម្តេច ។ បទថា **បមាណវន្តា** បានដល់ កិលេសទាំងឡាយ បរិយុដ្ឋានកិលេសនិងសង្ខារដែលឲ្យកើតក្នុងភពថ្មី ឈ្មោះថា ជាសភាវៈមានប្រមាណ ។ រាគៈជាដើម ដោយពាក្យ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា រាគៈជាកិលេសធ្វើនូវប្រមាណ ទោសៈ ជាកិលេសធ្វើនូវប្រមាណ មោហៈ ជាកិលេសធ្វើនូវប្រមាណ ដូច្នេះ ។ រមែងកើតឡើងដល់បុគ្គលណា រាគៈជាដើមដែលធ្វើប្រមាណដល់បុគ្គលនោះថា បុគ្គល នេះមានប្រមាណប៉ុណ្ណេះ

ឈ្មោះថា ប្រមាណ ។ កិលេសជាដើមឈ្មោះថា មានប្រមាណ ព្រោះជាប់ក្នុងប្រមាណនោះ ។ បទថា **កិលេសា** បានដល់ កិលេសដែលជាអនុស័យ ។ បទថា **បរិយុដ្ឋានា** បានដល់ កិលេសដែលដល់នូវការរាយមាយ ។ បទថា **សង្ខារា ពោនោភវិកា** មានវិគ្គហៈថា ការធ្វើឲ្យមានភពរឿយៗ ឈ្មោះថា **បុនភវ** បុនភវៈជាប្រក្រតីនៃសង្ខារទាំងឡាយ ព្រោះហេតុនោះ ទើបសង្ខារទាំងឡាយឈ្មោះថា **ពោនភវិកា ពោនភវិកា** នោះ□ថា **ពោនោភវិកា** ។ សង្ខារទាំងឡាយ ពោលគឺ កុសលកម្មនិងអកុសលកម្ម ។

បទថា **អប្បមាណោ** បានដល់ ឈ្មោះថា អប្បមាណ ព្រោះមិនមានប្រមាណ មានប្រការដូចពោលហើយ ។ ព្រោះសូម្បីមគ្គនិងផល ក៏មិនមានប្រមាណ ទើបលោកពោលដើម្បីភាពវិសេសក្រៃលែងជាងនោះថា **អចលដ្ឋេន អសង្ខតដ្ឋេន** ។ និព្វាន ឈ្មោះថា អចល ព្រោះមិនមានការរលត់ ឈ្មោះថា អសង្ខត ព្រោះមិនមានបច្ច័យ ពិតណាស់ ធម៌ណាមិនញាប់ញ័រផង ជាអសង្ខតៈផង ធម៌នោះរមែងជាធម៌ប្រាសចាកប្រមាណក្រៃលែង ។

បទថា **កថំ សុសមារទ្ធោ ឥតិ ចេ ហោតីតិ ពោជ្ឈង្គោ** គប្បីប្រកបដោយន័យដូចពោលហើយ ក្នុងលំដាប់ ។ បទថា **វិសមា** បានដល់ ឈ្មោះថា **វិសមា** ព្រោះជាសភាពមិនស្មើឯង និងព្រោះជាហេតុនៃការមិនស្មើ ។ បទថា **សមធម្មោ** បានដល់ ឈ្មោះថា **សមធម្មោ** ព្រោះអត្ថថា ជាធម៌ស្ងប់ ព្រោះអត្ថថា ជាធម៌ប្រណីត ឈ្មោះថា ស្ងប់ ព្រោះមិនមានប្រមាណ ឈ្មោះ

ថា ប្រណីត ព្រោះអត្ថថា ជាធម៌ប្រសើរជាងធម៌ទាំងពួង ព្រោះព្រះបាលី ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ជាសង្ខតធម៌ក្តី អសង្ខតធម៌ក្តី វិរាគធម៌ប្រាកដជាប្រសើរជាង ពួកធម៌ទាំងនោះ ដូច្នេះ ។

សតិសម្ពោជ្ឈង្គៈដែលប្រារព្ធហើយក្នុងធម៌ស្មើដោយល្អ ដូចលោកពោលហើយថា មានការស្មើជាធម្មតានោះ ឈ្មោះថា **សុសមារទ្ធោ** ។

[ ៤២ ] បទថា **អាវជ្ជិតត្តា** លោកពោលសំដៅដល់កាលដែលប្រព្រឹត្តទៅហើយដោយផលសមាបត្តិ មានពាក្យអធិប្បាយថា ព្រោះមនោទ្វារាវជ្ជនៈកើតឡើងហើយក្នុងនិព្វាន ពោលគឺការមិនកើតឡើងជាដើម ។ បទថា **តិដ្ឋតិ** បានដល់ រមែងប្រព្រឹត្តទៅ ។

បទថា **ឧប្បាទា** ជាដើម មានអត្ថដូចលោកពោលទុកហើយខាងដើម ។ ក្នុងវារៈដែលមានពោជ្ឈង្គដ៏សេសជាមូល ក៏មានន័យនេះដូចគ្នា ។

អដ្ឋកថា សុត្តន្តនិទ្ទេស ចប់

អដ្ឋកថា ពោជ្ឈង្គកថា ចប់

# សុត្តន្តបិដក
## យុគនទ្ធវគ្គ មេត្តាកថា
### សាវត្ថីនិទាន

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិដែលបុគ្គលបានសេព អប់រំ ធ្វើឲ្យច្រើន ឲ្យដូចជាយាន ធ្វើឲ្យដូចជាទីតាំង តម្កល់មាំ សន្សំដោយហ្មត់ចត់ ប្រារព្ធល្អហើយ នឹងមានអានិសង្ស ១១ ជាប្រាកដ អានិសង្សទាំង ១១ តើដូចម្តេចខ្លះ គឺមេត្តាវិហារិបុគ្គល រមែងដេកលក់ស្រួល ១ ភ្ញាក់ឡើងស្រួល ១ មិនយល់សប្តអាក្រក់ ១ ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ ១ ជាទីស្រឡាញ់នៃអមនុស្សទាំងឡាយ ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្តី ថ្នាំពិសក្តី សស្ត្រាវុធក្តី រមែងមិនប៉ះពាល់ ១ បុគ្គលនោះតម្កល់ចិត្តនៅនឹងដ៏ឆាប់រហ័ស ១ មានសម្បុរមុខស្រស់បស់ ១ មិនវង្វេងធ្វើមរណកាល ១ កាលបើមិនទាន់បានត្រាស់ដឹងនូវមគ្គផលទេ គង់បានទៅកើតឯព្រហ្មលោក ១ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិដែលបុគ្គលបានសេព អប់រំ ធ្វើឲ្យចម្រើន ធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាទីតាំង តម្កល់មាំ សន្សំដោយហ្មត់ចត់ ប្រារព្ធល្អហើយ តែងមានអានិសង្ស ១១ នេះឯងជាប្រាកដ ។

[ ៤៦ ] មេត្តាចេតោវិមុត្តិ ផ្សាយដោយមិនមានចំណែកក៏មាន មេត្តា-ចេតោវិមុត្តិផ្សាយដោយចំណែកក៏មាន មេត្តាចេតោវិមុត្តិផ្សាយកាន់ទិសទាំងឡាយក៏មាន ។ មេត្តាចេតោវិមុត្តិ ផ្សាយដោយមិនមានចំណែក ដោយ

អាការប៉ុន្មាន មេត្តាចេតោវិមុត្តិ ផ្សាយដោយចំណែក ដោយអាការប៉ុន្មាន មេត្តាចេតោវិមុត្តិផ្សាយកាន់ទិសទាំងឡាយ ដោយអាការប៉ុន្មាន ។ មេត្តា-ចេតោវិមុត្តិផ្សាយដោយមិនមានចំណែក ដោយអាការ ៥ មេត្តាចេតោវិមុត្តិផ្សាយដោយចំណែក ដោយអាការ ៧ មេត្តាចេតោវិមុត្តិ ផ្សាយកាន់ទិសទាំងឡាយ ដោយអាការ ១០ ។

មេត្តាចេតោវិមុត្តិផ្សាយដោយមិនមានចំណែក ដោយអាការ ៥ តើដូចម្តេច ។ ការផ្សាយមេត្តាចិត្តថា សូមសត្វទាំងអស់កុំមានពៀរ កុំមានព្យា-បាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ ១ សូមសត្វមានជីវិតទាំងអស់ ។បេ។ ១ សូមសត្វកើតហើយទាំងអស់ ១ សូមបុគ្គលទាំងអស់ ១ សូមសត្វទាំងអស់ដែលរាប់ថាមានអត្តភាព កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ ១ នេះមេត្តាចេតោវិមុត្តិផ្សាយដោយមិនមានចំណែក ដោយអាការ ៥ យ៉ាង ។

មេត្តាចេតោវិមុត្តិផ្សាយដោយចំណែក ដោយអាការ ៧ តើដូចម្តេច ។ ការផ្សាយមេត្តាចិត្តថា សូមស្ត្រីទាំងអស់កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ ១ សូមប្រុសទាំងអស់ ។បេ។ ១ សូមព្រះអរិយៈទាំងអស់ ១ សូមបុគ្គល មិនមែនព្រះអរិយៈទាំងអស់ ១ សូមទេវតាទាំងអស់ ១ សូមមនុស្សទាំងអស់ ១ សូមវិនិបាតទាំងអស់កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ ១ នេះ មេត្តាចេតោវិមុត្តិផ្សាយដោយចំណែក ដោយអាការ ៧ យ៉ាង ។

[ ៤៧ ] មេត្តាចេតោវិមុត្តិផ្សាយកាន់ទិសទាំងឡាយ ដោយអាការ ១០ តើដូចម្តេច ។ ការផ្សាយមេត្តាចិត្តថា សូមសត្វទាំងអស់ក្នុងទិសខាងកើត កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ សូមសត្វទាំងអស់ក្នុងទិសខាងលិច ។បេ។ សូមសត្វទាំងអស់ក្នុងទិសខាងជើង សូមសត្វទាំងអស់ក្នុងទិសខាងត្បូង សូមសត្វទាំងអស់ក្នុងទិសអាគ្នេយ៍ សូមសត្វទាំងអស់ក្នុងទិសពាយ័ព្យ សូមសត្វទាំងអស់ក្នុងទិសឦសាន សូមសត្វទាំងអស់ក្នុងទិសនិរតី សូមសត្វទាំងអស់ក្នុងទិសខាងក្រោម សូមសត្វទាំងអស់ក្នុងទិសខាងលើ កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ សូមសត្វមានជីវិត ។បេ។ សត្វកើតហើយ បុគ្គលដែលរាប់ថាមានអត្តភាពទាំងអស់ ស្រីទាំងអស់ ប្រុសទាំងអស់ ព្រះអរិយៈទាំងអស់ បុគ្គលមិនមែនអរិយៈទាំងអស់ ទេវតាទាំងអស់ មនុស្សទាំងអស់ វិនិបាតទាំងអស់ក្នុងទិសខាងកើត កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ សូមវិនិបាតទាំងអស់ ក្នុងទិសខាងលិច ។បេ។ សូមវិនិបាតទាំងអស់ក្នុងទិសខាងជើង សូមវិនិបាតទាំងអស់ ក្នុងទិសខាងត្បូង សូមវិនិបាតទាំងអស់ក្នុងទិសអាគ្នេយ៍ សូមវិនិបាតទាំងអស់ក្នុងទិសពាយ័ព្យ សូមវិនិបាតទាំងអស់ក្នុងទិសឦសាន សូមវិនិបាតទាំងអស់ក្នុងទិសនិរតី សូមវិនិបាតទាំងអស់ក្នុងទិសខាងក្រោម សូមវិនិបាតទាំងអស់ក្នុងទិសខាងលើ កុំមានពៀរ កុំមានព្យាបាទ កុំបីមានទុក្ខ មានតែសុខ រក្សាខ្លួនចុះ នេះមេត្តាចេតោវិមុត្តិ ផ្សាយកាន់ទិសទាំងឡាយ ដោយអាការ ១០ យ៉ាង ឈ្មោះថា

មេត្តា ព្រោះជាធម្មជាតិប្រព្រឹត្តជាមិត្តចំពោះសត្វទាំងអស់ ដោយអាការ ៨ នេះ គឺដោយការវៀរនូវការបៀតបៀនសត្វទាំងអស់ហើយមិនបៀតបៀន ១ ដោយការវៀរនូវការគំនុំ ហើយមិនគំនុំ ១ ដោយការវៀរនូវការដុតកម្ដៅ ហើយមិនដុតកម្ដៅ ១ ដោយការវៀរនូវការសង្កត់សង្កិន ហើយមិនសង្កត់-សង្កិន ១ ដោយការវៀរនូវការធ្វើឲ្យលំបាក ហើយមិនធ្វើឲ្យលំបាក ១ ដោយការផ្សាយថា សូមសត្វទាំងអស់ជាអ្នកគ្មានពៀរ កុំបីចងពៀរនឹងគ្នា ១ សូមមានសុខ កុំបីមានទុក្ខ ១ សូមមានខ្លួនដល់នូវសុខ កុំបីមានខ្លួនដល់នូវទុក្ខ ១ ឈ្មោះថា ចេតោ ព្រោះជាសភាវៈគិតនូវធម៌នោះ ឈ្មោះថា វិមុត្តិ ព្រោះជាធម្មជាតិរួចចាកបរិយុដ្ឋានកិលេស គឺព្យាបាទ ចំពោះសត្វទាំងអស់ ឈ្មោះថា មេត្តាចេតោវិមុត្តិ ព្រោះមេត្តានិងចេតោវិមុត្តិ ។

[ ៤៨ ] សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលបង្អោនសទ្ធាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះបានអប់រំហើយដោយសទ្ធិន្ទ្រិយ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលផ្គង ( ព្យាយាម ) ដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះបានអប់រំហើយដោយវីរិយិន្ទ្រិយ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសេចក្ដីសុខចុះ បុគ្គលប្រុងស្មារតីដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះបានអប់រំហើយដោយសតិន្ទ្រិយ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលតម្កល់មាំនូវចិត្តដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា

បុគ្គលនោះបានអប់រំហើយ ដោយសមាធិន្ទ្រិយ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលដឹងច្បាស់ដោយប្រាជ្ញាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះបានអប់រំហើយ ដោយបញ្ញិន្ទ្រិយ ឥន្ទ្រិយទាំង ៥ នេះ ជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះតែងសេព ឥន្ទ្រិយទាំង ៥ នេះ ជាទីអប់រំរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវឥន្ទ្រិយទាំង ៥ នេះ តែងអប់រំ ឥន្ទ្រិយទាំង ៥ នេះជាទីធ្វើឲ្យច្រើន របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះតែងធ្វើឲ្យច្រើន ឥន្ទ្រិយទាំង ៥ នេះ ជាគ្រឿងប្រដាប់របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវឥន្ទ្រិយទាំង ៥ នេះ ស្អិតស្អាងល្អហើយ ឥន្ទ្រិយទាំង ៥ នេះជាបរិក្ខាររបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះបិទបាំងហើយដោយប្រពៃ ឥន្ទ្រិយទាំង ៥ នេះ ជាបរិវាររបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះ ចោមរោមហើយ ឥន្ទ្រិយទាំង ៥ នេះជាទីសេព ជាទីអប់រំ ជាទីធ្វើឲ្យច្រើន ជាគ្រឿងប្រដាប់ ជាបរិក្ខារ ជាបរិវារនៃមេត្តាចេតោវិមុត្តិជាទីបំពេញ ជាធម៌ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយផ្សំ ស្មុះទៅ ជាទីជ្រះថ្លា ជាទីតម្កល់ ជាធម្មជាតរួចចាកកិលេស ជាទីឃើញច្បាស់ថា នេះធម្មជាតស្ងប់ ជាធម្មជាតធ្វើឲ្យដូចជាយាន ធ្វើដូចជាទីតាំង ជាគុណជាតិតម្កល់មាំ សន្សំហើយ ប្រារព្ធល្អហើយ អប់រំល្អហើយ អធិដ្ឋានល្អហើយ អណ្តែតឡើងព្រមផុតស្រឡះ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[ ៤៩ ] សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលមិនញាប់ញ័រ ព្រោះហេតុមិនគួរជឿ ដោយគិតដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសទ្ធាពលៈ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលមិនញាប់ញ័រព្រោះកោសជ្ជៈ ដោយគិតដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយវិរិយពលៈ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលមិនញាប់ញ័រ ព្រោះសេចក្តីប្រហែស ដោយគិតដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសតិពលៈ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសេចក្តីសុខចុះ បុគ្គលមិនញាប់ញ័រព្រោះឧទ្ធច្ចៈ ដោយគិតដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសមាធិពលៈ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលមិនញាប់ញ័រព្រោះអវិជ្ជា ដោយគិតដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយបញ្ញាពលៈ ពលៈទាំង ៥ នេះ ជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពលៈទាំង ៥ នេះ តែងសេព ពលៈទាំង ៥ នេះ ជាទីអប់រំរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពលៈទាំង ៥ នេះតែងអប់រំ ពលៈទាំង ៥ នេះជាទី ធ្វើឲ្យច្រើនរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពលៈទាំង ៥ នេះ តែងធ្វើឲ្យច្រើន ពលៈទាំង ៥ នេះជាគ្រឿងប្រដាប់របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពលៈ

ទាំង ៥ នេះ ស្អិតស្អាងល្អហើយ ពលៈទាំង ៥ នេះ ជាបរិក្ខាររបស់មេត្តា-ចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពលៈទាំង ៥ នេះ បិទបាំងហើយដោយប្រពៃ ពលៈទាំង ៥ នេះជាបរិវារនៃមេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពលៈទាំង ៥ នេះចោមរោមល្អហើយ ពលៈទាំង ៥ នេះជាទីសេពជាទីអប់រំ ជាទីធ្វើឲ្យច្រើន ជាគ្រឿងប្រដាប់ ជាទីបិទបាំង ជាបរិវារនៃមេត្តាចេតោវិមុត្តិ ជាទីបំពេញ ជាធម៌ប្រព្រឹត្តទៅជាមួយ កើតជាមួយ លាយផ្សំជាទីស៊ុះទៅ ជាទីជ្រះថ្លា ជាធម៌តាំងនៅមាំ ជាធម្មជាតរួចចាកកិលេស ជាទីឃើញច្បាស់ថា នេះធម្មជាតស្ងប់ ជាធម្មជាតធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាទីតាំង ជាធម្មជាតតម្កល់មាំ សន្សំហើយ ប្រារព្ធល្អហើយ អប់រំល្អហើយ អធិដ្ឋានល្អហើយ អណ្តែតឡើងព្រម ផុតស្រឡះ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[ ៥០ ] សូមសត្វទាំងអស់ កុំបីមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលប្រុងស្មារតីដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសតិសម្ពោជ្ឈង្គ សូមសត្វទាំងអស់ ។បេ។ បុគ្គលពិចារណា ដោយប្រាជ្ញាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយធម្មវិចយសម្ពោជ្ឈង្គ សូមសត្វទាំងអស់ ។បេ។ បុគ្គលផ្គងព្យាយាម ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយវិរិយសម្ពោជ្ឈង្គ សូមសត្វទាំងអស់ ។បេ។ បុគ្គលញុំាងសេចក្តីក្តៅក្រហាយឲ្យស្ងប់ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយបីតិ

សម្ពោជ្ឈង្គ សូមសត្វទាំងអស់ ។បេ។ បុគ្គលញុំាង សេចក្ដីអាក្រក់ឲ្យស្ងប់ ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយបស្សទ្ធិ-សម្ពោជ្ឈង្គ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលតម្កល់ចិត្តមាំដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសមាធិសម្ពោជ្ឈង្គ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលពិចារណានូវពួកកិលេសដោយញាណ ដូច្នេះ មេត្តាចេតោវិមុត្តិឈ្មោះថា បុគ្គលនោះអប់រំហើយដោយឧបេក្ខាសម្ពោ-ជ្ឈង្គ ពោជ្ឈង្គទាំង ៧ នេះ ជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពោជ្ឈង្គទាំង ៧ នេះ តែងសេព ពោជ្ឈង្គទាំង ៧ នេះ ជាទីអប់រំ-របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពោជ្ឈង្គទាំង ៧ នេះតែងអប់រំ ពោជ្ឈង្គទាំង ៧ នេះជាទីធ្វើឲ្យច្រើនរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពោជ្ឈង្គទាំង ៧ នេះ តែងធ្វើឲ្យច្រើន ពោជ្ឈង្គទាំង ៧ នេះ ជាគ្រឿងប្រដាប់របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវពោជ្ឈង្គទាំង ៧ នេះស្អិតស្អាងល្អហើយ ពោជ្ឈង្គទាំង ៧ នេះជាបរិក្ខាររបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពោជ្ឈង្គទាំង ៧ នេះបិទបាំងហើយដោយប្រពៃ ពោជ្ឈង្គទាំង ៧ នេះជាបរិវាររបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពោជ្ឈង្គទាំង ៧ នេះចោមរោមល្អហើយ ពោជ្ឈង្គទាំង ៧ នេះជាទីសេព ជាទីអប់រំ ជាទីធ្វើឲ្យច្រើន ជាគ្រឿងប្រដាប់ ជាបរិក្ខារ ជាបរិវាររបស់មេត្តាចេតោវិមុត្តិ ជាទីបំពេញ ជាធម៌ប្រព្រឹត្តជាមួយ កើតជាមួយ លាយឡំ ជាទីស៊ុះទៅ

ជាទីជ្រះថ្លា ជាធម៌តាំងនៅមាំ ជាធម៌ធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចទីតាំង ជាធម្ម-ជាតតម្កល់មាំ សន្សំហើយ ប្រារព្ធល្អហើយ អប់រំល្អហើយ អធិដ្ឋានល្អហើយ អណ្ដែតឡើងព្រម ផុតស្រឡះ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្ដៅសព្វ ។

[ ៥១ ] សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលឃើញដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះ អប់រំហើយដោយសម្មាទិដ្ឋិ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលលើកចិត្ត ( កាន់អារម្មណ៍ ) ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយសម្មាសង្កប្បៈ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលកំណត់វាចា ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយសម្មាវាចា សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលខ្នះខ្នែងដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយសម្មាកម្មន្តៈ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គល ( ញុំាងការចិញ្ចឹមជីវិត ) ឲ្យផូរផង់ដោយប្រពៃ ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយសម្មាអាជីវៈ សូមសត្វទាំងអស់កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលផ្គង ( ព្យាយាម ) ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថាបុគ្គលនោះ អប់រំហើយដោយសម្មាវាយាមៈ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្ដីក្សេម សូម

មានសុខចុះ បុគ្គលប្រុងស្មារតី ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយសម្មាសតិ សូមសត្វទាំងអស់ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលតាំងចិត្តមាំ ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសម្មាសមាធិ អដ្ឋមគ្គទាំង ៨ នេះ ជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវអដ្ឋមគ្គទាំង ៨ នេះ តែងសេព អដ្ឋមគ្គទាំង ៨ នេះជាទីអប់រំរបស់មេត្តាចេ-តោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវអដ្ឋមគ្គទាំង ៨ នេះតែងសេព អដ្ឋមគ្គទាំង ៨ នេះ ជាទីចម្រើនរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវអដ្ឋមគ្គទាំង ៨ នេះ តែងចម្រើន អដ្ឋមគ្គទាំង ៨ នេះជាទីធ្វើឲ្យច្រើនរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវអដ្ឋមគ្គទាំង ៨ នេះតែងធ្វើឲ្យច្រើនអដ្ឋមគ្គទាំង ៨ នេះជាគ្រឿងប្រដាប់របស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវអដ្ឋមគ្គទាំង ៨ នេះស្អិតស្អាងល្អហើយ អដ្ឋមគ្គទាំង ៨ នេះជាបរិក្ខាររបស់មេត្តាចេតោ-វិមុត្តិ មេត្តាចេតោវិមុត្តិត្រូវអដ្ឋមគ្គទាំង ៨ នេះបិទបាំងហើយ ដោយប្រពៃ អដ្ឋមគ្គទាំង ៨ នេះជាបរិវាររបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវ អដ្ឋមគ្គទាំង ៨ នេះ ចោមរោមល្អហើយ អដ្ឋមគ្គទាំង ៨ នេះជាទីសេព ជាទីអប់រំ ជាទីធ្វើឲ្យច្រើន ជាគ្រឿងប្រដាប់ ជាបរិក្ខារ ជាបរិវាររបស់មេត្តាចេតោវិមុត្តិ ជាទីបំពេញ ជាធម៌ប្រព្រឹត្តជាមួយ កើតជាមួយលាយផ្សំ ជាទីស្ទុះទៅ ជាទីជ្រះថ្លា ជាធម៌តាំងនៅមាំ ជាធម៌រួចចាកកិលេស ជាទីឃើញច្បាស់ថា នេះជាធម្មជាតស្ងប់ ជាធម្មជាតធ្វើឲ្យដូចជាយាន ធ្វើ

ឲ្យដូចជាទីតាំង ជាធម្មជាតតម្កល់មាំ សន្សំហើយ ប្រារព្ធល្អហើយ អប់រំល្អហើយ អធិដ្ឋានល្អហើយ អណ្តែតឡើងព្រម ផុតស្រឡះ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[ ៥២ ] ឈ្មោះថា មេត្តា ព្រោះជាធម្មជាតប្រព្រឹត្តជាមិត្ត ចំពោះវិនិបាតទាំងអស់ ដោយអាការ ៨ នេះ គឺដោយការវៀរនូវការបៀតបៀនហើយមិនបៀតបៀនចំពោះសត្វមានជីវិតទាំងអស់ សត្វកើតហើយទាំងអស់ បុគ្គលទាំងអស់ សត្វដែលរាប់ថាមានអត្តភាពទាំងអស់ ស្រីទាំងអស់ ប្រុសទាំងអស់ អរិយៈទាំងអស់ ជនមិនមែនអរិយៈទាំងអស់ ទេវតាទាំងអស់ មនុស្សទាំងអស់ វិនិបាតទាំងអស់ ១ ដោយការវៀរនូវគំនុំហើយ មិនគំនុំ ១ ដោយការវៀរនូវការដុតកម្តៅ ហើយមិនដុតកម្តៅ ១ ដោយការវៀរនូវការសង្កត់សង្កិនហើយមិនសង្កត់សង្កិន ១ ដោយការវៀរនូវការធ្វើឲ្យលំបាក ហើយមិនធ្វើឲ្យលំបាក ១ ដោយការផ្សាយមេត្តាចិត្តថា សូមវិនិបាតទាំងអស់ ជាបុគ្គលគ្មានពៀរ កុំបីចងពៀរនឹងគ្នា ១ សូមមានសុខកុំបីមានទុក្ខ ១ សូមមានខ្លួនដល់នូវសុខ កុំបីមានខ្លួនដល់នូវទុក្ខ ១ ឈ្មោះថា ចេតោ ព្រោះជាសភាវៈគិតនូវធម៌នោះ ឈ្មោះថា វិមុត្តិ ព្រោះ ជាធម្មជាតរួចចាកបរិយុដ្ឋានកិលេស គឺព្យាបាទចំពោះសត្វទាំងអស់ ឈ្មោះថា មេត្តាចេតោវិមុត្តិ ព្រោះមេត្តានិងចេតោវិមុត្តិ សូមវិនិបាតទាំងអស់កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលជឿស៊ប់ដោយសទ្ធាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសទ្ធិន្ទ្រិយ ។បេ។ ឲ្យកើត ឲ្យភ្លឺ

ច្បាស់ ឲ្យក្តៅសព្វ ។

[ ៥៣ ] ឈ្មោះថា មេត្តា ព្រោះជាធម្មជាតប្រព្រឹត្តជាមិត្ត ចំពោះសត្វទាំងអស់ក្នុងទិសខាងលើ ដោយអាការ ៨ នេះ គឺដោយការវៀរនូវការបៀតបៀនហើយមិនបៀតបៀន ចំពោះសត្វទាំងអស់ ក្នុងទិសខាងកើត សត្វទាំងអស់ក្នុងទិសខាងលិច សត្វទាំងអស់ក្នុងទិសខាងជើង សត្វទាំងអស់ក្នុងទិសខាងត្បូង សត្វទាំងអស់ ក្នុងទិសអាគ្នេយ៍ សត្វទាំងអស់ក្នុងទិសពាយ័ព្យ សត្វទាំងអស់ក្នុងទិសឦសាន សត្វទាំងអស់ក្នុងទិសនិរតី សត្វទាំងអស់ក្នុងទិសខាងក្រោម សត្វទាំងអស់ក្នុងទិសខាងលើ ១ ដោយការវៀរនូវការគំនុំហើយមិនគំនុំ ១ ដោយការវៀរនូវការដុតកម្តៅ ហើយមិនដុតកម្តៅ ១ ដោយការវៀរនូវការសង្កត់សង្កិន ហើយមិនសង្កត់សង្កិន ១ ដោយការវៀរនូវការធ្វើឲ្យលំបាក ហើយមិនធ្វើឲ្យលំបាក ១ ដោយការផ្សាយមេត្តាចិត្តថា សូមសត្វទាំងអស់ក្នុងទិសខាងលើ ជាបុគ្គលគ្មានពៀរ កុំបីចងពៀរនឹងគ្នា ១ សូមមានសុខកុំបីមានទុក្ខ ១ សូមមានខ្លួនដល់នូវសុខ កុំបីមានខ្លួនដល់នូវទុក្ខ ១ ឈ្មោះថា ចេតោ ព្រោះជាសភាវៈគិតនូវធម៌នោះ ឈ្មោះថា វិមុត្តិ ព្រោះជាធម្មជាតរួចចាកបរិយុដ្ឋានក្កិលេស គឺព្យាបាទចំពោះសត្វទាំងអស់ ឈ្មោះថា មេត្តាចេតោវិមុត្តិ ព្រោះមេត្តានិងចេតោវិមុត្តិ សូមសត្វទាំងអស់ក្នុងទិសខាងលើកុំមានពៀរ សូមមានសេចក្តី ក្សេម សូមមានសុខចុះ បុគ្គលជឿស៊ប់ដោយសទ្ធាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសទ្ធិន្ទ្រិយ ។បេ។ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[ ៥៤ ] ឈ្មោះថា មេត្តា ព្រោះជាធម្មជាតប្រព្រឹត្តជាមិត្ត ចំពោះវិនិ-បាតទាំងអស់ ក្នុងទិសខាងលើដោយអាការ ៨ នេះ គឺដោយការវៀរនូវការបៀតបៀន ហើយមិនបៀតបៀនចំពោះសត្វមានជីវិត សត្វកើតហើយ បុគ្គលទាំងអស់ សត្វដែលរាប់ថាមានអត្តភាពទាំងអស់ ស្រីទាំងអស់ប្រុសទាំងអស់ ព្រះអរិយៈទាំងអស់ ជនមិនមែនព្រះអរិយៈទាំងអស់ ពួកទេវតាទាំងអស់ មនុស្សទាំងអស់ វិនិបាតទាំងអស់ ក្នុងទិសខាងកើត វិនិបាតទាំងអស់ក្នុងទិសខាងលិច វិនិបាតទាំងអស់ក្នុងទិសខាងជើង វិនិបាតទាំងអស់ក្នុងទិសខាងត្បូង វិនិបាតទាំងអស់ក្នុងទិសអាគ្នេយ៍ វិនិបាតទាំងអស់ ក្នុងទិសពាយ័ព្យ វិនិបាតទាំងអស់ក្នុងទិសឦសាន វិនិបាត ទាំងអស់ក្នុងទិសនិរតី វិនិបាតទាំងអស់ក្នុងទិសខាងក្រោម វិនិបាតទាំងអស់ក្នុងទិសខាងលើ ១ ដោយការវៀរនូវគំនុំ ហើយមិនគុំ ១ ដោយការ វៀរនូវការដុតកម្តៅហើយមិនដុតកម្តៅ ១ ដោយការវៀរនូវការសង្កត់សង្កិន ហើយមិនសង្កត់សង្កិន ១ ដោយការវៀរនូវការធ្វើឲ្យលំបាក ហើយមិនធ្វើឲ្យលំបាក ១ ដោយការផ្សាយមេត្តាចិត្តថា សូមវិនិបាតទាំងអស់ ក្នុងទិសខាងលើជាបុគ្គលគ្មានពៀរ កុំបីចងពៀរនឹងគ្នា ១ សូមមានសុខកុំបីមានទុក្ខ ១ សូមមានខ្លួនដល់នូវសុខ កុំបីមានខ្លួនដល់នូវទុក្ខ ១ ឈ្មោះថា ចេតោ ព្រោះជាសភាវៈគិតនូវធម៌នោះ ឈ្មោះថា វិមុត្តិ ព្រោះជាធម្មជាតរួចចាកបរិ-យុដ្ឋានក្កិលេសគឺព្យាបាទចំពោះសត្វទាំងអស់ ឈ្មោះថា មេត្តាចេតោវិមុត្តិ ព្រោះមេត្តានិងចេតោវិមុត្តិ ។

[ ៥៥ ] សូមវិនិបាតទាំងអស់ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលជឿស៊ប់ដោយសទ្ធាដូច្នេះ មេត្តា-ចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសទ្ធិន្ទ្រិយ សូមវិនិបាតទាំងអស់ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលផ្គងព្យាយាមដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយវីរិយិន្ទ្រិយ ។បេ។ បុគ្គលប្រុងស្មារតីដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសតិន្ទ្រិយ ។បេ។ បុគ្គល តម្កល់ចិត្តដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសមាធិន្ទ្រិយ ។បេ។ បុគ្គលដឹងច្បាស់ដោយប្រាជ្ញាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយបញ្ញិន្ទ្រិយ ឥន្ទ្រិយទាំង ៥ នេះ ជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិ ត្រូវឥន្ទ្រិយទាំង ៥ នេះ តែងសេព ។បេ។ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្ដៅសព្វ ។

[ ៥៦ ] សូមវិនិបាតទាំងអស់ ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្ដីក្សេម សូមមានសុខចុះ បុគ្គលមិនញាប់ញ័រព្រោះហេតុមិនគួរជឿដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះ អប់រំហើយដោយសទ្ធា-ពលៈ ។បេ។ បុគ្គលមិនញាប់ញ័រព្រោះសេចក្ដីខ្ជិលដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយវីរិយពលៈ ។បេ។ បុគ្គលមិនញាប់ញ័រព្រោះសេចក្ដីប្រហែសដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសតិពលៈ ។បេ។ បុគ្គលមិនញាប់ញ័រព្រោះឧទ្ធច្ចៈដូច្នេះ

មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសមាធិពលៈ ។បេ។ បុគ្គលមិនញាប់ញ័រព្រោះអវិជ្ជាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយបញ្ញាពលៈ ពលៈទាំង ៥ នេះ ជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពលៈទាំង ៥ នេះតែងសេព ។បេ។ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[ ៥៧ ] សូមវិនិបាតទាំងអស់ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលប្រុងស្មារតីដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសតិសម្ពោជ្ឈង្គ ។បេ។ បុគ្គលពិចារណាដោយប្រាជ្ញាដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយធម្មវិចយសម្ពោជ្ឈង្គ ។បេ។ បុគ្គលផ្គងព្យាយាមដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយវីរិយសម្ពោជ្ឈង្គ ។បេ។ បុគ្គលរម្ងាប់សេចក្តីក្តៅក្រហាយដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយបីតិសម្ពោជ្ឈង្គ ។បេ។ បុគ្គលរម្ងាប់សេចក្តីអាក្រក់ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយបស្សទ្ធិសម្ពោជ្ឈង្គ ។បេ។ បុគ្គលតម្កល់ចិត្តមាំដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសមាធិសម្ពោជ្ឈង្គ ។បេ។ បុគ្គលពិចារណានូវកិលេសដោយញាណដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយឧបេក្ខាសម្ពោជ្ឈង្គ ពោជ្ឈង្គទាំង ៧ នេះជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវពោជ្ឈង្គទាំង ៧ នេះតែងសេព ។បេ។ ឲ្យ

កើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

[ ៥៨ ] សូមវិនិបាតទាំងអស់ក្នុងទិសខាងលើ កុំមានពៀរ សូមមានសេចក្តីក្សេម សូមមានសុខចុះ បុគ្គលឃើញដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិឈ្មោះថា បុគ្គលនោះអប់រំហើយដោយសម្មាទិដ្ឋិ ។បេ។ បុគ្គលលើកចិត្តកាន់អារម្មណ៍ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះ អប់រំហើយដោយសម្មាសង្កប្បៈ ។បេ។ បុគ្គលកំណត់វាចាដោយប្រពៃ ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសម្មាវាចា ។បេ។ បុគ្គលខ្នះខ្នែងដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសម្មាកម្មន្តៈ ។បេ។ បុគ្គល ( ញុំាងការចិញ្ចឹមជីវិត ) ឲ្យផូរផង់ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសម្មាអាជីវៈ ។បេ។ បុគ្គលផ្គងព្យាយាមដោយប្រពៃ ដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសម្មាវាយាមៈ ។បេ។ បុគ្គលប្រុង ( ស្មារតី ) ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយ ដោយសម្មាសតិ ។បេ។ បុគ្គល តម្កល់មាំ ( នូវចិត្ត ) ដោយប្រពៃដូច្នេះ មេត្តាចេតោវិមុត្តិ ឈ្មោះថា បុគ្គលនោះអប់រំហើយដោយសម្មាសមាធិ អដ្ឋមគ្គទាំង ៨ នេះ ជាទីសេពរបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវអដ្ឋមគ្គទាំង ៨ នេះ តែងសេព ។បេ។ អដ្ឋមគ្គទាំង ៨ នេះ ជាបរិវាររបស់មេត្តាចេតោវិមុត្តិ មេត្តាចេតោវិមុត្តិត្រូវអដ្ឋមគ្គទាំង ៨ នេះ ចោមរោមហើយ អដ្ឋមគ្គទាំង ៨ នេះ ជាទីសេព ជាទីអប់រំ ជាទីធ្វើឲ្យច្រើន

ជាគ្រឿងប្រដាប់ ជាបរិក្ខារ ជាបរិវាររបស់មេត្តាចេតោវិមុត្តិ ជាទីបំពេញ ជាធម៌ប្រព្រឹត្តទៅជាមួយ កើតជាមួយ លាយផ្សំ ជាទីស្មុះទៅ ជាទីជ្រះថ្លា ជាធម៌តាំងនៅមាំ ជាធម៌រួច ( ចាកកិលេស ) ជាគ្រឿងឃើញច្បាស់ថា នេះជាធម្មជាតស្ងប់ ជាធម្មជាតធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាទីតាំងជាទីតម្កល់នៅមាំ សន្សំហើយ ប្រារព្ធល្អហើយ អប់រំល្អហើយ អធិដ្ឋានល្អហើយ អណ្តែតឡើងព្រម ផុតស្រឡះ ឲ្យកើត ឲ្យភ្លឺច្បាស់ ឲ្យក្តៅសព្វ ។

**ចប់ មេត្តាកថា ។**

# អដ្ឋកថា

## មេត្តាកថា

[ ៤៥ ] ឥឡូវនេះ នឹងពណ៌នាតាមលំដាប់ ដែលនៅមិនទាន់ធ្លាប់ពណ៌នាក្នុងមេត្តាកថា ដែលមានព្រះសូត្រជាបទមាំ ប្រព្រឹត្តតាមពោជ្ឈង្គកថា ដែលព្រះសារីបុត្តត្ថេរពោលទុកក្នុងលំដាប់នៃពោជ្ឈង្គកថា ។

ក្នុងបទនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រមុន ដូចតទៅនេះថា បទថា **អាសេវិតាយ** បានដល់ ដែលបុគ្គលសេពហើយដោយអើពើ ។ បទថា **ភាវិតាយ** បានដល់ ចម្រើនហើយ ។ បទថា **ពហុលីកតាយ** បានដល់ ធ្វើហើយរឿយ ៗ ។ បទថា **យានីកតាយ** បានដល់ ធ្វើឲ្យដូចជាយាន ដែលទឹមហើយ ។ បទថា **វត្ថុកតាយ** បានដល់ ធ្វើឲ្យដូចវត្ថុ ព្រោះអត្ថថា ជាទីតាំង ។ បទថា **អនុដ្ឋិតាយ** បានដល់ ប្រាកដចំពោះហើយ ។ បទថា **បរិចិតាយ** បានដល់ សន្សំអប់រំទុកដោយជុំវិញ ។ បទថា **សុសមារទ្ធាយ** បានដល់ ប្រារព្ធហើយដោយល្អ គឺធ្វើដោយល្អហើយ ។ បទថា **អានិសំសា** បានដល់ គុណ ។ បទថា **ធាដិកង្ខា** បានដល់ គប្បីសង្ឃឹម គប្បីប្រាថ្នាបាន ។

បទថា **សុខំ សុបតិ** បានដល់ ដេកលក់ជាសុខ មិនដេកលក់ ដូចបុគ្គលដទៃៗស្រមុក បម្រះទៅមក ដេកលក់ជាទុក្ខ សូម្បីឈានចុះកាន់និទ្រាក៏ដូចចូលសមាបត្តិ ។ បទថា **សុខំ បដិពុជ្ឈតិ** បានដល់ ភ្ញាក់ជាសុខ មិនខុសប្រក្រតី ដូចផ្កាឈូករីក មិនភ្ញាក់ ដូចអ្នកដទៃដែលថ្ងូរ ពត់

កាយបម្រះទៅមក ភ្ញាក់ជាទុក្ខ ។ បទថា **ន បាបកំ សុបិនំ បស្សតិ** បានដល់ កាលយល់សប្ត រមែងយល់សប្តឃើញរឿងល្អៗ ដូចយល់សប្តឃើញថ្វាយបង្គំព្រះចេតិយ ធ្វើការបូជា ស្តាប់ធម៌ មិនយល់សប្តអាក្រក់ ដូចបុគ្គលដទៃៗដែលយល់សប្តឃើញចោរចោមចាប់ សត្វសាហាវខាំ ធ្លាក់ទៅក្នុងជ្រោះ ។ បទថា **មនុស្សានំ បិយោ ហោតិ** បានដល់ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់មនុស្សទាំងឡាយ ដូចកែវមុក្តាហារដែលពាក់ត្រង់ទ្រូង និងដូចផ្កាប្រដាប់ទុកលើសីសៈ ។ បទថា **អមនុស្សានំ បិយោ ហោតិ** បានដល់ ជាទីស្រឡាញ់សូម្បីរបស់អមនុស្ស ដូចជាទីស្រឡាញ់របស់មនុស្ស ។ បទថា **ទេវតា រក្ខន្តិ** បានដល់ ទេវតារមែងរក្សា ដូចមាតាបិតារក្សាបុត្ត ដូច្នោះ ។

បទថា **នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ** បានដល់ ភ្លើង ថ្នាំពិស សស្ត្រារមែងមិនចូលទៅក្នុងកាយរបស់អ្នកនៅដោយមេត្តា អធិប្បាយថា មិនញ៉ាំងកាយរបស់បុគ្គលនោះឲ្យកម្រើក ។ បទថា **តុវដំ ចិត្តំ សមាធិយតិ** បានដល់ ចិត្តរបស់បុគ្គលដែលនៅដោយមេត្តា រមែងតាំងមាំបានដោយរហ័ស មិនមានការយឺតយូរ ។ បទថា **មុខវណ្ណោ វិប្បសីទតិ** បានដល់ មុខរបស់បុគ្គលនោះ មានពណ៌ស្រស់ថ្លា ដូចផ្លែត្នោតទុំដែលជ្រុះចាកទង ។ បទថា **អសម្មូឡ្ហោ កាលំ ករោតិ** បានដល់ អ្នកនៅដោយមេត្តា មិនវង្វេងក្នុងពេលជិតស្លាប់ មិនវង្វេងក្នុងកាលធ្វើកាលកិរិយា ដូចបុគ្គលឈមចុះកាន់និទ្រា ។ បទថា **ឧត្តរិ អប្បដិវិជ្ឈន្តោ** បាន

ដល់ កាលមិនទាន់អាចសម្រេចអរហត្តដ៏ក្រៃលែង ជាងមេត្តាសមាបត្តិបាន ឃ្លាតចាកលោកនេះ ដូចដេកលក់ហើយភ្ញាក់ឡើង ។ បទថា **ព្រហ្មលោ-កូបគោ ហោតិ** សេចក្តីថា រមែងចូលដល់ព្រហ្មលោក ។

[ ៤៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមេត្តានិទ្ទេស ដូចតទៅនេះថា បទថា **អនោធិសោ ផរណា** បានដល់ ព្រំដែនឈ្មោះថា ឱធិ មិនមានព្រំដែន ឈ្មោះថា អនោធិ ។ ដោយមិនមានព្រំដែននោះ សេចក្តីថា ដោយមិន ចំពោះ លោកអធិប្បាយថា ផ្សាយទៅដោយមិនមានទីកំណត់ ។ បទថា **ឱធិសោ** បានដល់ ដោយមានកំណត់ ។ បទថា **ទិសា ផរណា** បាន ដល់ ផ្សាយទៅក្នុងទិសទាំងឡាយ ។

បទថា **សព្វេ** បានដល់ ជាពាក្យកំណត់ដោយមិនមានសេសសល់ ។ អត្ថនៃបទថា **សត្តា** លោកពោលទុកហើយក្នុងអដ្ឋកថាមាតិកាញាណកថា ។ វោហារនេះ រមែងប្រព្រឹត្តទៅ សូម្បីក្នុងបុគ្គលដែលប្រាសចាករាគៈហើយ ដោយ **រុឡ្ហិ** សព្ទ ដូចវោហារថា ផ្លិតស្លឹកត្នោត រមែងប្រព្រឹត្តទៅក្នុង ផ្លិតវីជនី សូម្បីធ្វើដោយឫស្សី ។ បទថា **អវេរា** បានដល់ ប្រាសចាក ពៀរ ។ បទថា **អព្យាបជ្ជា** បានដល់ វៀរចាកការព្យាបាទ ។ បទថា **អនីឃា** បានដល់ មិនមានទុក្ខ ។ បាឋៈថា **អនិគ្ឃា** ដូច្នេះក៏មាន ។ បទថា **សុខី អត្តានំ បរិហរន្តុ** បានដល់ មានសេចក្តីសុខញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅចុះ ។ គប្បីជ្រាបសេចក្តីសម្ពន្ធនៃពាក្យ ក្នុងបទយ៉ាងនេះថា ដោយពាក្យថា មិនមានពៀរ លោកសម្តែងការមិនមានពៀរចំពោះបុគ្គល

ដទៃក្នុងសន្តានរបស់ខ្លួន និងចំពោះបុគ្គលក្រៅអំពីនេះ ក្នុងសន្តានរបស់អ្នកដទៃ ។ ក្នុងពាក្យថា កុំមានព្យាបាទ លោកសម្តែងការមិនមានព្យាបាទ ដែលមិនមានពៀរនោះជាមូល ព្រោះការមិនមានពៀរ ។ ពាក្យថា កុំបីមានទុក្ខ លោកសម្តែងការមិនមានទុក្ខ ដែលមិនមានព្យាបាទនោះ ជាមូល ព្រោះមិនមានការព្យាបាទ ។ ពាក្យថា មានតែសុខរក្សាខ្លួនចុះ លោកសម្តែងការរក្សាអត្តភាពឲ្យជាសុខ ព្រោះមិនមានទុក្ខ ។

ក្នុងបទទាំង ៤ មានបទថា **អវេរា ហោន្តុ** នេះជាដើម ពាក្យណាមួយប្រាកដ អ្នកចម្រើនមេត្តារមែងផ្សាយមេត្តាដោយអំណាចពាក្យនោះៗ ។

ក្នុងបទថា **បាណា** ជាដើម ឈ្មោះថា **បាណា** ព្រោះមានជីវិត អធិប្បាយថា ព្រោះប្រព្រឹត្តទៅអាស្រ័យខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។ ឈ្មោះថា **ភូតា** ព្រោះរស់នៅ អធិប្បាយថា ព្រោះនៅកើត ។ ឈ្មោះថា **បុគ្គលា** ព្រោះឃ្លាតទៅ គឺទៅក្នុងនរក ដែលហៅថា **បុំ** ។ សរីរៈ ឬខន្ធបញ្ចកៈ ហៅថា អត្តភាព ឈ្មោះថា **អត្តភាវបរិយាបន្នា** ព្រោះអត្តថា ទាក់ទង កំណត់ ឈមចុះក្នុងអត្តភាពនោះ ដោយត្រឹមតែអាស្រ័យខន្ធបញ្ចកៈនោះបញ្ញត្តឡើង ។

ពាក្យទាំងអស់នោះ គប្បីជ្រាបថា ជាវេវចនៈរបស់ពាក្យថា សត្វទាំងពួង ព្រោះលោកលើកពាក្យដ៏សេស ដោយអំណាចនៃ **រុឡ្ហិ** សព្ទ ដូចពាក្យថា **សត្តា** ដូច្នោះ ។

ក្នុងពាក្យថា សត្វទាំងពួងដទៃទៀតថា **សព្វេ ជន្តូ** សត្វដែលកើតទាំង

ពួង **សព្វេជីវា** ជីវៈទាំងពួងជាដើម សូម្បីមានក៏ពិត តែលោកកាន់យកពាក្យទាំង ៥ នេះ ដ្បិតជាពាក្យប្រាកដច្បាស់ ទើបពោលថា មេត្តាចេតោវិមុត្តិ ផ្សាយដោយមិនមានចំណែកដោយអាការ ៥ យ៉ាង ។ ម្យ៉ាងទៀត ជនពួកណាមិនមែនប្រាថ្នាដោយត្រឹមតែវាចា តែម្យ៉ាងប៉ុណ្ណោះ នៃពាក្យថា **សត្តា** សត្វទាំងអស់ **ចាណា** សត្វមានជីវិតទាំងអស់ ជាដើម ដែលពិតគប្បីប្រាថ្នាការផ្សេងគ្នា សូម្បីដោយអត្ថ ការផ្សាយទៅដោយមិនចំពោះរបស់ជនទាំងនោះ រមែងខុស ព្រោះហេតុនោះមិនកាន់យកអត្ថយ៉ាងនោះ ហើយផ្សាយមេត្តាដោយមិនចំពោះ ដោយអាការណាមួយក្នុងអាការទាំង ៥ នេះ ។

ម្យ៉ាងទៀត ក្នុងការផ្សាយទៅដោយចំពោះ លោកពោលដោយអំណាចភេទថា **ឥត្ថិយោ** ស្ត្រីទាំងអស់ **បុរិសា** បុរសទាំងអស់ ដោយអំណាចព្រះអរិយៈនិងបុថុជ្ជនថា **អរិយា** ព្រះអរិយៈទាំងអស់ **អនរិយា** មិនមែនព្រះអរិយទាំងអស់ ដោយអំណាចឧបបត្តិថា **ទេវា** ទេវតាទាំងអស់ **មនុស្សា** មនុស្សទាំងអស់ **វិនិបាតិកា** វិនិបាតទាំអស់ ។

ក្នុងការផ្សាយទៅកាន់ទិស មិនធ្វើការចែកទិស ហើយផ្សាយទៅដោយមិនចំពោះ ព្រោះផ្សាយទៅក្នុងទិសទាំងពួង ដោយន័យថា **សព្វេ សត្តា** ជាដើម ផ្សាយទៅដោយចំពោះព្រោះផ្សាយទៅក្នុងទិសទាំងពួង ដោយន័យថា **សព្វា ឥត្ថិយោ** ជាដើម ។

ម្យ៉ាងទៀត ព្រោះការផ្សាយមេត្តាសូម្បី ៣ យ៉ាង នេះលោកពោល

ដោយអំណាចនៃចិត្តដែលដល់អប្បនា ហេតុនោះគប្បីកាន់យកអប្បនា ក្នុងវារៈទាំង ៣ ។ គប្បីជ្រាបក្នុងការផ្សាយ ដោយមិនចំពោះមុខ ពាក្យថា សូមសត្វទាំងអស់ កុំមានពៀរ ជាអប្បនា ១ ពាក្យថា កុំមានព្យាបាទ ជាអប្បនា ១ ពាក្យថា កុំបីមានទុក្ខ ជាអប្បនា ១ ពាក្យថា មានតែសុខរក្សាខ្លួនចុះ ជាអប្បនា ១ ក្នុងពាក្យទាំង ៤ នោះ លោកពោលដោយអំណាចបង្អោនវត្ថុ ដែលជាប្រយោជន៍ចូលទៅ ព្រោះមេត្តាមានលក្ខណៈបង្អោនវត្ថុដែលជាប្រយោជន៍ចូលទៅ ។ ដោយហេតុនេះ ទើបអប្បនាមាន ២០ ដោយអំណាចអប្បនានីមួយៗ ៤ ក្នុងអាការ ៥ មានពាក្យថា **សព្វេ** ជាដើម ក្នុងការផ្សាយដោយចំពោះ អប្បនាមាន ២៨ ដោយអំណាចអប្បនានីមួយៗ ៤ ក្នុងអាការ ៧ មានពាក្យថា **សព្វា ឥត្ថិយោ** ជាដើម ។ ចំណែកការផ្សាយទៅកាន់ទិស អប្បនាមាន ៤៨០ គឺអប្បនា ២០០ ធ្វើនីមួយៗឲ្យជា ២០ ក្នុងទិសនីមួយៗ ដោយន័យជាដើមថា **សព្វេ បុរត្ថិមាយ ទិសាយ សត្តា** ជាដើម អប្បនា ២៨០ ធ្វើនីមួយ ៗ ឲ្យជា ២៨ ក្នុងទិសនីមួយ ៗ ដោយន័យថា **សព្វា បុរត្ថិមាយ ទិសាយ ឥត្ថិយោ** ជាដើម ។ អប្បនាទាំងអស់ ដែលលោកពោលទុកក្នុងទីនេះ រួមជាអប្បនា ៥២៨ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលការផ្សាយសូម្បីករុណា មុទិតា ឧបេក្ខា ដូចលោកពោលដល់ការផ្សាយមេត្តា ៣ វារៈ ដូច្នោះ ។

## អដ្ឋកថា

## ឥន្ទ្រិយវារៈ

[ ៤៧ ] លំដាប់នោះ ព្រះសារីបុត្តត្ថេរដើម្បីសម្តែងអាការនៃការបង្អោន មេត្តាចូលទៅ និងការអប់រំឥន្ទ្រិយជាដើម ទើបពោលបទថា **សព្វេសំ សត្តានំ បីឡនំវជ្ជេត្វា** ជាដើម ។

ក្នុងបទទាំងនោះ បទថា **បីឡនំ** បានដល់ ការបៀតបៀនសរីរៈខាងក្នុង ។ បទថា **ឧបឃាតំ** បានដល់ ការសម្លាប់សរីរៈខាងក្រៅ ។ បទថា **សន្តាបំ** បានដល់ ធ្វើចិត្តឲ្យក្តៅក្រហាយ ដោយប្រការផ្សេង ៗ ។ បទថា **បរិយាទានំ** បានដល់ ការអស់ជីវិតជាដើម ដោយប្រក្រតី ។ បទថា **វិហេសំ** បានដល់ បៀតបៀនជីវិត ដោយប្រការដទៃ ។ បទថា **វជ្ជេត្វា** បានដល់ នាំអាការនីមួយៗក្នុងការបៀតបៀនជាដើម ចេញទៅអំពីចិត្តរបស់ខ្លួន ។ លោកពោលបទ ៥ មានការបៀតបៀនទាំងនេះជាដើម ដោយវៀវត្ថុដែលជាបដិបក្ខចំពោះការនាំមេត្តាចូលទៅ ពោលបទថា **អបីឡនាយ** ជាដើម ដោយការនាំមេត្តាចូលទៅ ។

បទថា **អបីឡនាយ** គប្បីជ្រាប់សេចក្តីថា ផ្សាយមេត្តាក្នុងសត្វទាំងពួង ដោយការមិនបៀតបៀន ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

សូម្បីបទទាំង ៣ នេះថា **មា វេរិនោ មា ទុក្ខិនោ មា ទុក្ខិតត្តា** ជាពាក្យបដិសេធវត្ថុជាបដិបក្ខនៃការនាំមេត្តាចូលទៅ ។ ពាក្យថា **មា** មានអត្ថថា ចូរកុំមាន ៗ ៣ បទថា **អវេរិនោ សុខិនោ សុខិតត្តា** ជាពាក្យ

នាំមេត្តាចូលទៅ ។ ២ បទនេះថា **អព្យាបជ្ឈា អនីឃា** គប្បីជ្រាបថា លោកសង្គ្រោះចូលដោយពាក្យថា **សុខិនោ** ។

បទថា **សុខិតត្តា** ជាពាក្យសម្តែងសេចក្តីសុខនោះប្រព្រឹត្តទៅជានិច្ច ។ ម្យ៉ាងទៀត បទថា **សុខិតត្តា** និងបទថា **សុខី អត្តានំ បរិហរន្តុ** ដោយអត្ថដូចគ្នានោះឯង ។ ម្យ៉ាងទៀត លោកសង្គ្រោះបទថា **អព្យាបជ្ឈា** និងបទថា **អនីឃា** ដោយបទថា **អបីឡនាយ** ។ បទថា **អដ្ឋហាការេហិ** បានដល់ ដោយអាការទាំង ៨ នេះ គឺអាការនាំមេត្តាចូលទៅ ៥ មានបទថា **អបីឡនាយ** ជាដើម អាការនាំមេត្តាចូលទៅ ៣ មានបទថា **អវេរិនោ ហោន្តុ** ជាដើម ។ បទថា **មេត្តាយតិ** បានដល់ ស្រឡាញ់ ។ បទថា **តំ ធម្មំ ចេតយតិ** បានដល់ គិត ហូរទៅកាន់ការបង្អោននាំវត្ថុដែលជាប្រយោជន៍ចូលទៅនោះ អធិប្បាយថា ឲ្យប្រព្រឹត្តទៅ ។ បទថា **សព្វព្យាបាទបរិយុដ្ឋានេហិ វិមុច្ចតិ** បានដល់ ផុតចាកព្យាបាទនិងកិលេសដែលផ្សាយឡើងទាំងពួង ដែលជាបដិបក្ខចំពោះមេត្តា ដោយការសង្កត់ទោស ។ បទថា **មេត្តា ច ចេតោវិមុត្តិ ច** បានដល់ មេត្តាតែមួយប៉ុណ្ណោះ លោកពណ៌នាទុក ៣ យ៉ាង ។

[ ៤៨ ] បទទាំង ៣ នេះគឺ **អវេរិនោ ខេមិនោ សុខិនោ** លោក

ពោលសង្គ្រោះអាការ ដូចពោលហើយក្នុងបទមុនដោយសង្ខេប ។ ឥន្ទ្រិយ ៥ ដែលលោកពោលដោយន័យជាដើមថា **សទ្ធាយ អធិមុច្ចតិ** ជាឥន្ទ្រិយដែលសម្បយុត្តដោយមេត្តានោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈ ៦ មាន **អាសេវនា** ជាដើម ដូចតទៅនេះថា ឈ្មោះថា **អាសេវនា** ព្រោះជាហេតុឲ្យសេពមេត្តា ។ បទថា **ភាវនា** និង **ពហុលីកម្ម** ក៏យ៉ាងនោះ ។ បទថា **អលង្ការា** បានដល់ គ្រឿងប្រដាប់ ។ បទថា **ស្វាលង្កតា** បានដល់ ប្រដាប់តាក់តែងដោយល្អ ។ បទថា **បរិក្ខារា** បានដល់ គ្រឿងប្រកប ។ បទថា **សុបរិក្ខតា** បានដល់ កើតដោយល្អ ។ ឈ្មោះថា **បរិវារា** ដោយអត្ថថា ជាគ្រឿងរក្សា ។ លោកពោល ២៨ បទ មានអាសេវនៈជាដើមទៀត ដើម្បីពោលដល់គុណរបស់មេត្តា ។ ក្នុងបទទាំងនោះ បទថា **ធារិប្ចូរី** បានដល់ ការបរិបូណ៌ ។ បទថា **សហាគតា** បានដល់ សហគតដោយមេត្តា ។ បទថា **សហជាតា** ជាដើមក៏យ៉ាងនោះ ។ បទថា **បក្ខន្ទនា** បានដល់ ចូលទៅដោយមេត្តាម្យ៉ាងទៀត ឈ្មោះថា **បក្ខន្ទនា** ព្រោះជាហេតុឲ្យមេត្តាស្ទុះទៅ ។ បទថា **សំសីទនា** ជាដើម ក៏យ៉ាងនោះ ។ បទថា **ឯតំ សន្តន្តិ ផស្សនា** បានដល់ ការឃើញ មានដោយឥន្ទ្រិយទាំងនោះថា មេត្តានេះល្អិត ព្រោះហេតុ

នោះទើបឈ្មោះថា **ឯតំ សន្តន្តិ ជស្សន្តា** ជានបុំសកលិង្គ ដូចក្នុងពាក្យថា **ឯតទគ្គំ** នេះប្រសើរជាដើម ។ បទថា **ស្វាធិដ្ឋិតា** បានដល់ តាំងទុកដោយល្អ ។ បទថា **សុសមុគ្គតា** បានដល់ លើកឡើងហើយដោយល្អ ។ បទថា **សុវិមុត្តា** បានដល់ ផុតដោយល្អហើយចាកសត្រូវរៀង ៗ ខ្លួន ។ បទថា **និព្វត្តេន្តិ** បានដល់ ឥន្ទ្រិយ ៥ ប្រការសម្បយុត្តដោយមេត្តា ញ៉ាំងមេត្តាឲ្យកើត ។ បទថា **ជោតេន្តិ** បានដល់ ធ្វើឲ្យប្រាកដ ។ បទថា **បតាបេន្តិ** បានដល់ ឲ្យរុងរោចន៍ ។

អដ្ឋកថា ឥន្ទ្រិយវារៈ ចប់

## អដ្ឋកថា

## ភារៈ ៣ មានពលៈជាដើម

[ ៤៩-៥១ ] គប្បីជ្រាបពលភារៈ ដោយន័យដូចពោលហើយក្នុងឥន្ទ្រិយភារៈនោះឯង ។

លោកពោលពោជ្ឈង្គភារៈ និងមគ្គង្គភារៈ ទុកដោយបរិយាយ មិនបានពោលដោយអំណាចតាមលក្ខណៈ ។ ក្នុងមគ្គង្គភារៈលោកពោលសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ទុកដោយអំណាចនៃចំណែកខាងដើមរបស់មេត្តា មិនមែនដោយអំណាចនៃអប្បនា ព្រោះធម៌ទាំងនោះរមែងមិនកើតរួមដោយមេត្តា ។

[ ៥២ ] គប្បីជ្រាបអត្ថនៃភារៈដ៏សេសថា **សព្វេសំ ធាណានំ** ជាដើម ដោយន័យដូចពោលហើយ ក្នុងភារៈនៃសត្វនោះឯង ។ ចំណែកវិធីចម្រើនមេត្តា គប្បីកាន់យកអំពីវិសុទ្ធិមគ្គ ។

*អដ្ឋកថា ភារៈ ៣ មានពលៈជាដើម ចប់*

*អដ្ឋកថា មេត្តាកថា ចប់*

# សុត្តន្តបិដក

# យុគនទ្ធវគ្គ

# វិរាគកថា

[ ៥៩ ] វិរាគៈជាមគ្គ វិមុត្តិជាផល ។ វិរាគៈជាមគ្គតើដូចម្តេច ។ ក្នុងខណៈនៃសោតាបត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ រមែងណាយចាកមិច្ឆាទិដ្ឋិ ណាយចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះផង ចាកខន្ធទាំងឡាយផង ណាយចាកនិមិត្តទាំងពួងខាងក្រៅផង វិរាគៈមានការណាយជាអារម្មណ៍ មានការណាយជាគោចរ ប្រកបក្នុងការណាយ ឋិតនៅក្នុងការណាយ តម្កល់ស៊ប់ក្នុងការណាយ ។ ពាក្យថា វិរាគៈ បាន ដល់វិរាគៈ ២ យ៉ាង វិរាគៈ គឺនិព្វាន ១ វិរាគៈ គឺពួកធម៌ណាកើតហើយព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះ តែងមានសេចក្តីណាយ ១ វិរាគៈជាមគ្គ ព្រោះអង្គទាំង ៧ ដែលកើតជាមួយគ្នា រមែងដល់នូវការណាយ ផ្លូវប្រកបដោយអង្គ ៨ ឈ្មោះថា មគ្គ ព្រោះព្រះពុទ្ធទាំងឡាយនិងសាវកទាំងឡាយតែងទៅ កាន់ទិសដែលគេមិនធ្លាប់ទៅ គឺនិព្វានដោយសារមគ្គនុ៎ះ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាមគ្គដ៏ខ្ពង់ខ្ពស់ប្រសើរ វិសេសវិសាល ឧត្តម ថ្លៃថ្លា ជាងមគ្គរបស់ពួកសមណព្រាហ្មណ៍ច្រើននាក់ ដែលប្រកាន់លទ្ធិដទៃទាំងអម្បាលមាណ ហេតុនោះ មគ្គប្រកបដោយអង្គ ៨ ប្រសើរជាងមគ្គទាំងឡាយ ។ សម្មាសង្កប្បៈ ដោយអត្ថថា លើកចិត្តឡើង ( កាន់អារម្មណ៍ ) រមែងណាយចាកមិច្ឆាសង្កប្បៈ សម្មា-

វាចា ដោយអត្ថថា កំណត់ រមែងណាយចាកមិច្ឆាវាចា សម្មាកម្មន្តៈ ដោយអត្ថថា ខ្នះខ្នែង រមែងណាយចាកមិច្ឆាកម្មន្តៈ សម្មាអាជីវៈ ដោយអត្ថថា ផូរផង់ រមែងណាយចាកមិច្ឆាអាជីវៈ សម្មាវាយាមៈ ដោយអត្ថថា ផ្គងឡើង រមែងណាយចាកមិច្ឆាវាយាមៈ សម្មាសតិ ដោយអត្ថថា ប្រុងប្រយ័ត្ន រមែងណាយចាកមិច្ឆាសតិ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយរមែងណាយចាកមិច្ឆាសមាធិ រមែងណាយចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាសមាធិនោះផង ចាកខន្ធទាំងឡាយផង រមែងណាយចាកនិមិត្តទាំងពួងខាងក្រៅផង វិរាគៈមានការណាយជាអារម្មណ៍ មានការណាយជាគោចរ ប្រកបក្នុងការណាយ ឋិតនៅក្នុងការណាយ តម្កល់ស៊ប់ក្នុងការណាយ ។ ពាក្យថា វិរាគៈ បានដល់វិរាគៈ ២ យ៉ាង វិរាគៈ គឺនិព្វាន ១ វិរាគៈ គឺពួកធម៌ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះ តែងមានសេចក្ដីណាយ ១ វិរាគៈ ជាមគ្គ ព្រោះអង្គទាំង ៧ ដែលកើតជាមួយគ្នារមែងដល់នូវការណាយ ផ្លូវប្រកបដោយអង្គ ៨ ឈ្មោះថា មគ្គ ព្រោះព្រះពុទ្ធទាំងឡាយ និងសាវកទាំងឡាយ តែងទៅកាន់ទិសដែលគេមិនធ្លាប់ទៅ គឺព្រះនិព្វានដោយសារមគ្គនុ៎ះ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាមគ្គដ៏ខ្ពង់ខ្ពស់ ប្រសើរ វិសេសវិសាល ឧត្តម ថ្លៃថ្លាជាងមគ្គ របស់ពួកសមណព្រាហ្មណ៍ច្រើននាក់ ដែលប្រកាន់លទ្ធិដទៃទាំងអម្បាលមាណ ហេតុនោះ មគ្គប្រកបដោយអង្គ ៨ ប្រសើរជាងមគ្គទាំងឡាយ ។

[ ៦០ ] ក្នុងខណៈនៃសកទាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងណាយចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈដ៏គ្រោតគ្រាត ចាកកាមរាគានុស័យ ចាកបដិឃានុស័យដ៏គ្រោតគ្រាត រមែងណាយចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង រមែងណាយចាកនិមិត្តទាំងពួងខាងក្រៅផង វិរាគៈ មានការណាយជាអារម្មណ៍ មានការណាយជាគោចរ ប្រកបក្នុងការណាយ ឋិតនៅក្នុងការណាយ តម្កល់ស៊ប់ក្នុងការណាយ ។ ពាក្យថា វិរាគៈ បានដល់វិរាគៈ ២ យ៉ាង វិរាគៈ គឺនិព្វាន ១ វិរាគៈ គឺពួកធម៌ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះតែងមានសេចក្តីណាយ ១ វិរាគៈជាមគ្គ ព្រោះអង្គ ៧ ដែលកើតជាមួយគ្នារមែងដល់នូវការណាយ ផ្លូវប្រកបដោយអង្គ ៨ ឈ្មោះថា មគ្គ ព្រោះព្រះពុទ្ធទាំងឡាយ និងសាវកទាំងឡាយ តែងទៅកាន់ទិសដែលគេមិនធ្លាប់ទៅ គឺព្រះនិព្វានដោយសារមគ្គនុ៎ះ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាមគ្គដ៏ខ្ពង់ខ្ពស់ ប្រសើរ វិសេសវិសាល ឧត្តមថ្លៃថ្លា ជាងមគ្គរបស់ពួកសមណព្រាហ្មណ៍ជាច្រើននាក់ ដែលប្រកាន់លទ្ធិដទៃទាំងអម្បាលមាណ ហេតុនោះ មគ្គប្រកបដោយអង្គ ៨ ប្រសើរជាងមគ្គទាំងឡាយ ។

[ ៦១ ] ក្នុងខណៈនៃអនាគាមិមគ្គ សម្មាទិដ្ឋិដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងណាយចាកកាមរាគ

សញ្ញោជនៈ ចាកបដិឃសញ្ញោជនៈដ៏ល្អិត ចាកកាមរាគានុស័យ ចាកបដិ-ឃានុស័យដ៏ល្អិត ណាយចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង ណាយចាកនិមិត្តទាំងពួងខាងក្រៅផង វិវេកៈ មានការណាយជាអារម្មណ៍ ។បេ។ មគ្គប្រកបដោយអង្គ ៨ ប្រសើរជាងមគ្គទាំងឡាយ ។

[ ៦២ ] ក្នុងខណៈនៃអរហត្តមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងណាយចាករូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ណាយចាកកិលេសទាំងឡាយដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង ណាយចាកនិមិត្តទាំងពួងខាងក្រៅផង វិវេកៈ មានការណាយជាអារម្មណ៍ មានការណាយជាគោចរ ប្រកបក្នុងការណាយ ឋិតនៅក្នុងការណាយ តម្កល់ស៊ប់ក្នុងការណាយ ។ ពាក្យថា វិវេកៈ បានដល់វិវេកៈ ២ យ៉ាង វិវេក គឺនិព្វាន ១ វិវេកៈ គឺពួកធម៌ណាកើតហើយព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះតែងមានសេចក្ដីណាយ ១ វិវេកៈជាមគ្គព្រោះអង្គទាំង ៧ ដែលកើតជាមួយគ្នា រមែងដល់នូវការណាយ ផ្លូវប្រកបដោយអង្គ ៨ ឈ្មោះថា មគ្គ ព្រោះព្រះពុទ្ធទាំងឡាយ និងសាវកទាំងឡាយ រមែងទៅកាន់ទិសដែលគេមិនធ្លាប់ទៅ គឺនិព្វានដោយសារមគ្គនុ៎ះ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាមគ្គដ៏ខ្ពង់ខ្ពស់ ប្រសើរវិសេសវិសាល ឧត្តម ថ្លៃថ្លា ជាងមគ្គរបស់ពួកសមណព្រាហ្មណ៍ច្រើននាក់

ដែលប្រកាន់លទ្ធិដទៃទាំងអម្បាលមាណ ហេតុនោះមគ្គប្រកបដោយអង្គ ៨ ប្រសើរជាងមគ្គទាំងឡាយ ។

[ ៦៣ ] សម្មាទិដ្ឋិ មានការឃើញជាវិរាគៈ សម្មាសង្កប្បៈ មានការលើកចិត្តឡើងជាវិរាគៈ សម្មាវាចា មានការកំណត់ជាវិរាគៈ សម្មាកម្មន្តៈ មានការខ្នះខ្នែងជាវិរាគៈ សម្មាអាជីវៈ មានការផូរផង់ជាវិរាគៈ សម្មាវា-យាមៈ មានការផ្គងឡើងជាវិរាគៈ សម្មាសតិ មានការប្រុងប្រយ័ត្នជាវិរាគៈ សម្មាសមាធិ មានការមិនរាយមាយជាវិរាគៈ សតិសម្ពោជ្ឈង្គ មានការប្រុងប្រយ័ត្នជាវិរាគៈ ធម្មវិចយសម្ពោជ្ឈង្គ មានការពិចារណាជាវិរាគៈ វី-រិយសម្ពោជ្ឈង្គ មានការផ្គងឡើងជាវិរាគៈ បីតិសម្ពោជ្ឈង្គ មានការផ្សាយទៅជាវិរាគៈ បស្សទ្ធិសម្ពោជ្ឈង្គ មានការស្ងប់ជាវិរាគៈ សមាធិសម្ពោជ្ឈង្គ មានការមិនរាយមាយជាវិរាគៈ ឧបេក្ខាសម្ពោជ្ឈង្គ មានការពិចារណាជាវិរាគៈ សទ្ធាពលៈ មានការមិនញាប់ញ័រ ព្រោះការណ៍មិនគួរជឿជាវិរាគៈ វីរិយពលៈ មានការមិនញាប់ញ័រព្រោះសេចក្ដីខ្ជិលច្រអូសជាវិរាគៈ សតិ-ពលៈ មានការមិនញាប់ញ័រព្រោះការប្រហែសជាវិរាគៈ សមាធិពលៈ មានការមិនញាប់ញ័រ ព្រោះឧទ្ធច្ចៈជាវិរាគៈ បញ្ញាពលៈ មានការមិនញាប់ញ័រព្រោះអវិជ្ជាជាវិរាគៈ សទ្ធិន្ទ្រិយ មានការជឿស៊ប់ជាវិរាគៈ វីរិយិន្ទ្រិយមានការផ្គងឡើងជាវិរាគៈ សតិន្ទ្រិយ មានការប្រុងប្រយ័ត្នជាវិរាគៈ សមាធិន្ទ្រិយមានការមិនរាយមាយជាវិរាគៈ បញ្ញិន្ទ្រិយ មានការឃើញជាវិរាគៈ ឥន្ទ្រិយទាំងឡាយ ដោយអត្ថថា ជាអធិបតី ឈ្មោះថា វិរាគៈ ពលៈទាំងឡាយ

ដោយអត្ថថា មិនញាប់ញ័រ ឈ្មោះថា វិភគៈ ពោជ្ឈង្គទាំងឡាយ ដោយអត្ថថា ចេញ ( ចាកវដ្តៈ ) ឈ្មោះថា វិភគៈ មគ្គ ដោយអត្ថថា ជាហេតុ ឈ្មោះថា វិភគៈ សតិប្បដ្ឋានទាំងឡាយ ដោយអត្ថថា ប្រុងប្រយ័ត្ន ឈ្មោះថា វិភគៈ សម្មប្បធានទាំងឡាយ ដោយអត្ថថា តម្កល់មាំ ឈ្មោះថា វិភគៈ ឥទ្ធិបាទ ដោយអត្ថថា សម្រេច ឈ្មោះថា វិភគៈ សច្ចៈទាំងឡាយ ដោយអត្ថថា ទៀងទាត់ ឈ្មោះថា វិភគៈ សមថៈ ដោយអត្ថថា មិនរាយមាយ ឈ្មោះថា វិភគៈ វិបស្សនា ដោយអត្ថថា ពិចារណាឃើញ ឈ្មោះថា វិភគៈ សមថៈនិងវិបស្សនា ដោយអត្ថថា មានកិច្ចតែមួយ ឈ្មោះថា វិភគៈ យុគនទ្ធធម៌ ( ធម៌ជាប់គ្នាជាគូ ) ដោយអត្ថថា មិនប្រព្រឹត្តកន្លងគ្នា ឈ្មោះថា វិភគៈ សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ឈ្មោះថា វិភគៈ ចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ឈ្មោះថា វិភគៈ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ ឈ្មោះថា វិភគៈ វិមោក្ខៈ ដោយអត្ថថា រួចស្រឡះ ឈ្មោះថា វិភគៈ វិជ្ជា ដោយអត្ថថា ចាក់ធ្លុះ ឈ្មោះថា វិភគៈ វិមុត្តិ ដោយអត្ថថា លះស្រឡះ ឈ្មោះថា វិភគៈ ខយញ្ញាណ ដោយអត្ថថា កាត់ផ្តាច់ ឈ្មោះថា វិភគៈ ឆន្ទៈ ដោយអត្ថថា ជាមូល ឈ្មោះថា វិភគៈ មនសិការៈ ដោយអត្ថថា តាំងឡើងព្រម ឈ្មោះថា វិភគៈ ផស្សៈ ដោយអត្ថថា ជួបជុំ ឈ្មោះថា វិភគៈ វេទនា ដោយអត្ថថា ប្រជុំចុះ ឈ្មោះថា វិភគៈ សមាធិ ដោយអត្ថថា ជាប្រធាន ឈ្មោះថា វិភគៈ សតិ ដោយអត្ថថា ជាអធិបតី ឈ្មោះថា វិភគៈ បញ្ញា ដោយ

អត្ថថា ក្រៃលែងជាងធម៌ទាំងនោះ ឈ្មោះថា វិភត្ត: វិមុត្តិ ដោយអត្ថថា ជាខ្លឹម ឈ្មោះថា វិភត្ត: សម្មាទិដ្ឋិ មានការឃើញជាមគ្គ សម្មាសង្កប្ប: មានការលើកចិត្តឡើងជាមគ្គ ។បេ។ អមតនិព្វាន ដោយអត្ថថា ជាទីបំផុតនៃកិច្ចក្នុងសាសនា ឈ្មោះថា មគ្គ វិភត្ត:ជាមគ្គយ៉ាងនេះឯង ។

[ ៦៤ ] វិមុត្តិ ជាផលតើដូចម្តេច ។ ក្នុងខណៈនៃសោតាបត្តិផល សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ជាធម្មជាតផុតស្រឡះចាកមិច្ឆាទិដ្ឋិ ផុតស្រឡះចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកបក្នុងការផុតស្រឡះ ឋិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការផុតស្រឡះ ។ ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ យ៉ាង វិមុត្តិ គឺនិព្វាន ១ វិមុត្តិជាផល គឺពួកធម៌ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះតែងរួចស្រឡះ ១ សម្មាសង្កប្ប: ដោយអត្ថថា លើកចិត្តឡើង ជាធម្មជាតផុតស្រឡះចាកមិច្ឆាសង្កប្ប: ផុតស្រឡះចាកកិលេសទាំងឡាយ ដែលប្រ-ព្រឹត្តទៅតាមមិច្ឆាសង្កប្ប:នោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកបក្នុងការផុតស្រឡះ ឋិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការផុតស្រឡះ ។ ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ យ៉ាង វិមុត្តិ គឺនិព្វាន ១ វិមុត្តិជាផល គឺពួកធម៌ណាកើតហើយព្រោះមាននិព្វាន

ជាអារម្មណ៍ ធម៌ទាំងអស់នោះតែងរួបស្រឡះ ១ សម្មាវាចា ដោយអត្ថថា កំណត់ ជាធម្មជាតរួបស្រឡះចាកមិច្ឆាវាចា ។ បេ ។ សម្មាកម្មន្តៈ ដោយអត្ថថា ខ្នះខ្នែង ផុតស្រឡះចាកមិច្ឆាកម្មន្តៈ សម្មាអាជីវៈ ដោយអត្ថថា ផូរផង់ ផុតស្រឡះចាកមិច្ឆាអាជីវៈ សម្មាវាយាមៈ ដោយអត្ថថា ផ្គងឡើង ផុតស្រឡះចាកមិច្ឆាវាយាមៈ សម្មាសតិ ដោយអត្ថថា ប្រុងប្រយ័ត្ន ផុតស្រឡះចាកមិច្ឆាសតិ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ ផុតស្រឡះចាកមិច្ឆាសមាធិ ផុតស្រឡះចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាសមាធិនោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកបក្នុងការផុតស្រឡះ ឋិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការផុតស្រឡះ ។ ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ យ៉ាង វិមុត្តិ គឺនិព្វាន ១ វិមុត្តិជាផល គឺពួកធម៌ណាកើតហើយ ព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះតែងផុតស្រឡះ ១ ។

[ ៦៥ ] ក្នុងខណៈនៃសកទាគាមិផល សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងផុតស្រឡះចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈដ៏គ្រោតគ្រាត ចាកកាមរាគានុស័យ ចាកបដិឃានុស័យដ៏គ្រោតគ្រាត ផុតស្រឡះចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍

មានការផុតស្រឡះជាគោចរ ប្រកបក្នុងការផុតស្រឡះ ឋិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការផុតស្រឡះ ។ ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ យ៉ាង វិមុត្តិ គឺនិព្វាន ១ វិមុត្តិជាផល គឺពួកធម៌ណាកើតហើយព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះតែងផុតស្រឡះ ១ ។

[ ៦៦ ] ក្នុងខណៈនៃអនាគាមិផល សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងផុតស្រឡះចាកកាមរាគសញ្ញោជនៈ ចាកបដិឃសញ្ញោជនៈដ៏ល្អិត ចាកកាមរាគានុស័យ ចាកបដិឃានុស័យដ៏ល្អិត ផុតស្រឡះចាកកិលេសទាំងឡាយដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកបក្នុងការផុតស្រឡះ ឋិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការផុតស្រឡះ ។បេ។

[ ៦៧ ] ក្នុងខណៈនៃអរហត្តផល សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងផុតស្រឡះចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ រមែងផុតស្រឡះចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមអនុស័យនោះផង ចាកខន្ធទាំងឡាយផង ផុតស្រឡះចាកនិមិត្តទាំងពួងខាងក្រៅផង វិមុត្តិ មានការផុតស្រឡះជាអារម្មណ៍ មានការផុតស្រឡះជាគោចរ ប្រកបក្នុងការផុតស្រឡះ ឋិតនៅក្នុងការផុតស្រឡះ តម្កល់ស៊ប់ក្នុងការផុតស្រឡះ ។

ពាក្យថា វិមុត្តិ បានដល់វិមុត្តិ ២ យ៉ាង វិមុត្តិ គឺនិព្វាន ១ វិមុត្តិជាផល គឺពួកធម៌ណាកើតហើយព្រោះមាននិព្វានជាអារម្មណ៍ ធម៌ទាំងអស់នោះតែង រួបស្រឡះ ១ ។

[ ៦៨ ] សម្មាទិដ្ឋិ មានការឃើញជាវិមុត្តិ ។បេ។ សម្មាសមាធិ មានការមិនរាយមាយជាវិមុត្តិ សតិសម្ពោជ្ឈង្គ មានការប្រុងប្រយ័ត្នជាវិមុត្តិ ។បេ។ ឧបេក្ខាសម្ពោជ្ឈង្គ មានការពិចារណាជាវិមុត្តិ សទ្ធាពលៈ មានការមិនញាប់ញ័រ ព្រោះការណ៍មិនគួរជឿជាវិមុត្តិ ។បេ។ បញ្ញាពលៈ មានការមិនញាប់ញ័រព្រោះអវិជ្ជាជាវិមុត្តិ សទ្ធិន្ទ្រិយ មានការជឿស៊ប់ ជាវិមុត្តិ ។បេ។ បញ្ញិន្ទ្រិយ មានការឃើញជាវិមុត្តិ ឥន្ទ្រិយ ដោយអត្ថថា ជាអធិបតី ឈ្មោះថា វិមុត្តិ ពលៈទាំងឡាយ ដោយអត្ថថា មិនញាប់ញ័រ ឈ្មោះថា វិមុត្តិ ពោជ្ឈង្គទាំងឡាយ ដោយអត្ថថា ចេញ ( ចាកវដ្ដៈ ) ឈ្មោះថា វិមុត្តិ មគ្គ ដោយអត្ថថា ជាហេតុ ឈ្មោះថា វិមុត្តិ សតិប្បដ្ឋានទាំងឡាយ ដោយអត្ថថា ប្រុងប្រយ័ត្ន ឈ្មោះថា វិមុត្តិ សម្មប្បធានទាំងឡាយ ដោយអត្ថថា តម្កល់មាំ ឈ្មោះថា វិមុត្តិ ឥទ្ធិបាទទាំងឡាយ ដោយអត្ថថា សម្រេច ឈ្មោះថា វិមុត្តិ សច្ចៈទាំងឡាយ ដោយអត្ថថា ទៀងទាត់ ឈ្មោះថា វិមុត្តិ សមថៈ ដោយអត្ថថា មិនរាយមាយ ឈ្មោះថា វិមុត្តិ វិបស្សនា ដោយអត្ថថា ពិចារណាឃើញ ឈ្មោះថា វិមុត្តិ សមថៈ និងវិបស្សនា ដោយអត្ថថា មានកិច្ចតែមួយ ឈ្មោះថា វិមុត្តិ យុគនទ្ធធម៌ ដោយអត្ថថា មិនប្រព្រឹត្តកន្លងគ្នា ឈ្មោះ

ថា វិមុត្តិ សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ឈ្មោះថា វិមុត្តិ ចិត្តវិ-សុទ្ធិ ដោយអត្ថថា មិនរាយមាយ ឈ្មោះថា វិមុត្តិ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ ឈ្មោះថា វិមុត្តិ វិមោក្ខ ដោយអត្ថថា ផុតស្រឡះ ឈ្មោះថា វិមុត្តិ វិជ្ជា ដោយអត្ថថា ចាក់ធ្លុះ ឈ្មោះថា វិមុត្តិ វិមុត្តិ ដោយអត្ថថា លះស្រឡះ ឈ្មោះថា វិមុត្តិ អនុប្បាទញ្ញាណ ( ការដឹងក្នុងការមិនកើត ) ដោយអត្ថថា រម្ងាប់ ឈ្មោះថា វិមុត្តិ ។ ឆន្ទៈ ដោយអត្ថថា ជាមូល ឈ្មោះថា វិមុត្តិ មនសិការៈ ដោយអត្ថថា តាំងឡើងព្រម ឈ្មោះថា វិមុត្តិ ផស្សៈ ដោយអត្ថថា ជួបជុំ ឈ្មោះថា វិមុត្តិ វេទនា ដោយអត្ថថា ប្រជុំចុះ ឈ្មោះថា វិមុត្តិ សមាធិ ដោយអត្ថថា ជាប្រធាន ឈ្មោះថា វិមុត្តិ សតិ ដោយអត្ថថា ជាអធិបតី ឈ្មោះថា វិមុត្តិ បញ្ញា ដោយអត្ថថា ក្រៃលែងជាងធម៌ទាំងនោះ ឈ្មោះថា វិមុត្តិ វិមុត្តិ ដោយអត្ថថា ជាខ្លឹម ឈ្មោះថា វិមុត្តិ អមតនិព្វាន ដោយអត្ថថា ជាទីបំផុតនៃកិច្ចក្នុងសាសនា ឈ្មោះថា វិមុត្តិ វិមុត្តិជាផលយ៉ាងនេះឯង វិរាគៈជាមគ្គ វិមុត្តិជាផលយ៉ាងនេះឯង ។

**ចប់ វិរាគកថា ។**

# **អដ្ឋកថា**

## **វិរាគកថា**

[ ៥៩ ] ឥឡូវនេះ នឹងពណ៌នាតាមលំដាប់សេចក្តី ដែលមិនធ្លាប់ពណ៌នាក្នុងវិរាគកថាដែលមានមគ្គ ពោលគឺវិរាគៈជាបទនាំ ដែលព្រះសារីបុត្តត្ថេរពោលទុកហើយ ក្នុងលំដាប់នៃមេត្តាកថាដែលមានការប្រកបមគ្គជាទីបំផុត ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិរាគកថានោះមុន ព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងអត្ថនៃបទព្រះសូត្រ ២ បទ ដែលព្រះមានព្រះភាគត្រាស់ទុកហើយថា កាលបើនឿយណាយ ( យ៉ាងនេះហើយ ) ក៏ប្រាសចាកតម្រេកចិត្តក៏ផុតស្រឡះ ( ចាកអាសវៈ ) ទើបតាំងឧទ្ទេសថា **វិរាគោ មគ្គោ វិមុត្តិ ផលំ** ។

ក្នុងបទទាំងនោះ ព្រះសារីបុត្តត្ថេរ បំណងចង្អុលបង្ហាញអត្ថនៃពាក្យទីមួយមុន ទើបពោលបទថា **កថំ វិរាគោ មគ្គោ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **វិរជ្ជតិ** បានដល់ ជាធម្មជាតប្រាសចាក ( តម្រេក ) ហើយ បទដ៏សេសមានអត្ថដូចពោលហើយក្នុងមគ្គញាណនិទ្ទេស ។ បទថា **វិរាគោ** សេចក្តីថា ព្រោះសម្មាទិដ្ឋិរមែងប្រាសចាក ( តម្រេក ) ហេតុនោះ ទើបឈ្មោះថា **វិរាគ** ។

មួយយ៉ាងទៀត គប្បីជ្រាបការភ្ជាប់សេចក្តីនៃបទ ៥ មានបទថា **វិរាគារម្មណោ** ជាដើមយ៉ាងនេះ គឺវិរាគៈ ( មគ្គ ) នោះ ឈ្មោះថា វិរាគៈ

ព្រោះមានវិរាគៈ ( និព្វាន ) ជាអារម្មណ៍ ។បេ។ ប្រតិស្ឋានទៅក្នុងវិរាគៈ ។ ម្យ៉ាងទៀត គប្បីជ្រាបសេចក្ដីសម្ពន្ធរបស់ពាក្យទាំងឡាយ ៥ មានពាក្យថា **វិរាគារម្មណោ** ជាដើម យ៉ាងនេះថា វិរាគៈ ( មគ្គ ) នោះ ឈ្មោះថា វិរាគៈ ព្រោះមានវិរាគៈ ( និព្វាន ) ជាអារម្មណ៍ ។បេ។ ប្រតិស្ឋានទៅក្នុងវិរាគៈ ។ ក្នុងបទទាំងនោះ បទថា **វិរាគារម្មណោ** បានដល់ មាននិព្វាន ជាអារម្មណ៍ ។ បទថា **វិរាគគោចរោ** បានដល់ មាននិព្វានជាវិស័យ ។ បទថា **វិរាគេ សមុទាគតោ** បានដល់ កើតព្រមគ្នាក្នុងនិព្វាន ។ បទថា **វិរាគេ ឋិតោ** បានដល់ តាំងនៅក្នុងនិព្វានដោយអំណាចនៃការប្រព្រឹត្តិទៅ ។ បទថា **វិរាគេ បតិដ្ឋិតោ** បានដល់ ប្រតិស្ឋានក្នុងនិព្វានដោយអំណាចនៃការមិនត្រឡប់ ។ បទថា **និព្វានញ្ច វិរាគោ** បានដល់ និព្វាន ឈ្មោះថា ជាវិរាគៈ ព្រោះមានវិរាគៈជាហេតុ ។ បទថា **និព្វានារម្មណតា ជាតា** បានដល់ ដែលកើតក្នុងធម៌ ដែលមាននិព្វានជាអារម្មណ៍ឬដែលកើតដោយការមាននិព្វានជាអារម្មណ៍ ។ ធម៌ទាំងឡាយមានផស្សៈជាដើម ទាំងពួងដែលសម្បយុត្ត ដោយមគ្គទាំងនោះ ឈ្មោះថា វិរាគៈ ព្រោះអត្ថថា ប្រាសចាកតម្រេក ព្រោះហេតុនេះ ទើបឈ្មោះថា វិរាគៈ ។ បទថា **សហជាតានិ** បានដល់ អង្គនៃមគ្គ ៧ មានសម្មាសង្កប្បៈជាដើមដែលកើតរួមជាមួយសម្មាទិដ្ឋិ ។ បទថា **វិរាគំ គច្ឆន្តីតិ វិរាគោ មគ្គោ** សេចក្ដីថា មែនដល់វិរាគៈ គឺនិព្វានដោយធ្វើឲ្យជាអារម្មណ៍ ព្រោះហេតុនោះទើបឈ្មោះថា វិរាគៈ ព្រោះមានវិរាគៈ ( និព្វាន ) ជាអារម្មណ៍

ឈ្មោះថា មគ្គ ព្រោះអត្ថថា ស្វែងរកអង្គនៃមគ្គ សូម្បីអង្គនីមួយៗ រមែងបានឈ្មោះថា មគ្គ ។ កាលលោកពោលដល់ការៈនៃអង្គនីមួយៗ ជាមគ្គ រមែងឈ្មោះថា ពោលដល់កាពដែលសម្មាទិដ្ឋិក៏ជាមគ្គដូចគ្នា ។

ព្រោះហេតុនោះឯង ទើបលោកកាន់យកអង្គនៃមគ្គ ៨ ហើយពោលថា **ឯតេន មគ្គេន** ។ បទថា **ពុទ្ធា** ច លោកសង្គ្រោះយកព្រះបច្ចេកពុទ្ធផងដែរ ។ ពិតណាស់ សូម្បីព្រះបច្ចេកពុទ្ធទាំងនោះ ក៏ឈ្មោះថា **ពុទ្ធ** ដូចគ្នាព្រោះព្រះមានព្រះភាគទ្រង់ត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយទុកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ព្រះពុទ្ធនេះមានពីរពួក ។ គឺព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ១ បច្ចេកពុទ្ធ ១ ដូច្នេះ ។ បទថា **អគតំ** បានដល់មិនធ្លាប់ទៅ ក្នុងសង្សារដែលមិនដឹងខាងដើម និងទីបំផុត ។ បទថា **ទិសំ** មានវិគ្គហៈថា ឈ្មោះថា ទិស ព្រោះឃើញ អាងដល់ ជាប់តដោយការបដិបត្តិទាំងអស់ ។ ម្យ៉ាងទៀត ឈ្មោះថា ទិស ព្រោះព្រះពុទ្ធទាំងឡាយទ្រង់ឃើញ ទ្រង់អាងដល់ ទ្រង់ពោលថាជាសុខយ៉ាងក្រៃលែង ។ ម្យ៉ាងទៀត ឈ្មោះថា ទិស ព្រោះជាហេតុឃើញ លះបង់ បោះបង់នូវទុក្ខទាំងពួង ។ ដែលជាទិសនោះ ។

បទថា **អដ្ឋង្គិកោ មគ្គោ** លោកពោលទុកដូចម្ដេច លោកពោលទុកថា ប្រជុំនៃធម៌មានអង្គ ៨ ឯណា ប្រជុំនៃធម៌នោះ ឈ្មោះថា មគ្គ ព្រោះអត្ថថា ជាហេតុឲ្យដល់ គឺឲ្យទៅកាន់និព្វាន ។

បទថា **បុថុសមណា ព្រាហ្មណានំ បរប្បវាទានំ** បានដល់ នៃស-

មណៈនិងព្រាហ្មណ៍ផ្សេងៗ ដែលកាន់លទ្ធិដទៃចាកសាសនានេះ ។ បទថា **អគ្គោ** បានដល់ វិសេសជាងមគ្គដ៏សេសទាំងនោះ ។ បទថា **សេដ្ឋោ** បានដល់ គួរសរសើរក្រៃលែងជាងមគ្គដ៏សេស ។ បទថា **វិមោក្ខោ** បានដល់ ល្អក្នុងភាពជាប្រធាន អធិប្បាយថា មគ្គនេះឯងល្អ ព្រោះជាប្រធានរបស់មគ្គដ៏សេស ។ បទថា **ឧត្តមោ** បានដល់ ធ្វងកាត់មគ្គដ៏សេសទៅបានយ៉ាងវិសេស ។ បទថា **បវរោ** បានដល់ បែកចេញពីមគ្គដ៏សេសដោយប្រការផ្សេង ៗ ។ បទថា **ឥតិ** ជានិបាត ចុះក្នុងអត្ថថា ហេតុ ។ ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយថា ព្រះមានព្រះភាគត្រាស់សម្តែងថា អដ្ឋង្គិកមគ្គ ប្រសើរជាងមគ្គទាំងឡាយ សមដូចព្រះតម្រាស់ ( ក្នុងធម្មបទ ) ថា

> ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺអរិយសច្ច ប្រសើរជាងសច្ចទាំងឡាយ វិរាគធម៌ ប្រសើរជាងធម៌ទាំងឡាយ មួយទៀត ព្រះតថាគតមានចក្ខុ ប្រសើរជាងសត្វទ្វិបាទទាំងឡាយ ដូច្នេះ ។

ក្នុងទីនេះព្រះមានព្រះភាគ ទ្រង់កំណត់មគ្គនោះហើយត្រាស់ថា អដ្ឋង្គិកមគ្គ ប្រសើរជាងមគ្គទាំងឡាយដូច្នេះ សូម្បីក្នុងវារៈដ៏សេស គប្បីជ្រាបសេចក្តីដោយន័យនេះ និងដោយន័យដូចពោលហើយ ។

[ ៦៣ ] ក្នុងបទថា **ទស្សនវិរាគោ** មានវិនិច្ឆ័យដូច្នេះថា វិរាគៈ ពោលគឺការឃើញ ឈ្មោះថា ទស្សនវិរាគៈ ។ គប្បីជ្រាបថា ក្នុងទីនេះ

លោកពោលដល់ពលៈមុនឥន្ទ្រិយ ព្រោះពលៈប្រសើរជាងអត្ថនៃឥន្ទ្រិយ ។ បទថា **អាធិបតេយ្យដ្ឋេន ឥន្ទ្រិយានិ** ជាដើម ជាការចង្អុលបង្ហាញអត្ថរបស់ឥន្ទ្រិយជាដើម មិនមែនចង្អុលបង្ហាញអត្ថ របស់វិភគៈ ។ បទថា **តតដ្ឋេន សច្ចា** គប្បីជ្រាបថា ជាសច្ចញ្ញាណ ។ បទថា **សីលវិសុទ្ធិ** បានដល់ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ។

បទថា **ចិត្តវិសុទ្ធិ** បានដល់ សម្មាសមាធិ ។ បទថា **ទិដ្ឋិវិសុទ្ធិ** បានដល់ សម្មាទិដ្ឋិនិងសម្មាសង្កប្បៈ ។ បទថា **វិមុត្តដ្ឋេន** បានដល់ ព្រោះអត្ថថា ផុតចាកកិលេសដែលត្រូវទម្លាយដោយមគ្គនោះ ៗ ។ បទថា **វិជ្ជា** បានដល់ សម្មាទិដ្ឋិ ។ បទថា **វិមុត្តិ** បានដល់ សមុច្ឆេទវិមុត្តិ ។ បទថា **អមតោគធំ និព្វានំ បរិយោសានដ្ឋេន មគ្គោ** ឈ្មោះថា មគ្គ ព្រោះអត្ថថា ស្វែងរកដោយការពិចារណាមគ្គផល ។ ធម៌ទាំងអស់ដែលលោកពោលក្នុងវិភគនិទ្ទេសនេះរមែងបានក្នុងខណៈនៃមគ្គនោះឯង ចំណែកដែលពោលទុកក្នុងវិមុត្តិនិទ្ទេស រមែងបានក្នុងខណៈនៃផល ព្រោះហេតុនោះ សូម្បីឆន្ទៈនិងមនសិការ ក៏សម្បយុត្តដោយមគ្គនិងផល ។ គប្បីជ្រាបអត្ថសូម្បីក្នុងវិមុត្តិនិទ្ទេស ដោយន័យដូចពោលហើយ ក្នុងវិភគនិទ្ទេសនោះឯង ។ ក្នុងវិមុត្តិនិទ្ទេសនេះ ផល ឈ្មោះថា វិមុត្តិ ព្រោះជាបដិប្បស្សទ្ធិវិមុត្តិ ។

និព្វាន ឈ្មោះថា វិមុត្តិ ព្រោះជានិស្សរណវិមុត្តិ ។ បទថា **សហជាតានិ សត្តដ្ឋានិ** រមែងមិនបានក្នុងទីនេះ ព្រោះហេតុនោះទើបលោកមិន

បានពោលទុក ។

[ ៦៨ ] ព្រោះការរួចផុតជាផលដោយខ្លួនឯង ទើបលោកពោលត្រឹមតែប៉ុណ្ណេះថា **បរិច្ចាគដ្ឋេន វិមុត្តិ** ដោយអត្ថថា លះស្រឡះ ឈ្មោះថា វិមុត្តិ ។ បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថាវិរាគកថា ចប់

# សុត្តន្តបិដក

## យុគនទ្ធវគ្គ

## បដិសម្ភិទាកថា

[ ៦៩ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់នឹងបញ្ចវគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អន្តធម៌ ( ធម៌ជាទីបំផុត ឬធម៌អម ) ពីរនេះ បព្វជិតមិនគួរសេពគប់ឡើយ ។ អន្តធម៌ពីរតើដូចម្តេច សេចក្តីព្យាយាមប្រកបខ្លួនទុកក្នុងកាមសុខក្នុងវត្ថុកាមទាំងឡាយ ( កាមសុខល្លិកានុយោគ ) ដែលជាធម៌ថោកទាបជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ១ សេចក្តីព្យាយាមប្រកបខ្លួនឲ្យលំបាក ( អត្តកិលមថានុយោគ ) ជាធម៌នាំមកនូវទុក្ខ មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ១ ម្នាលភិក្ខុទាំងឡាយ ឯមជ្ឈិមាបដិបទា ( សេចក្តីប្រតិបត្តិជាកណ្តាល ) មិនប៉ះពាល់នូវអន្តធម៌ ទាំងពីរនុ៎ះទេ តថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិ ធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងាប់ ( កិលេស ) ដើម្បីស្គាល់ ( នូវអរិយសច្ច ) ដើម្បីត្រាស់ដឹង ( នូវអរិយសច្ច ) ដើម្បីនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ចុះមជ្ឈិមាបដិបទានោះ ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ទាំងធ្វើឲ្យកើតញាណប្រព្រឹត្តទៅដើម្បី

រម្ងាប់ ដើម្បីស្គាល់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន តើដូចម្តេច អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង គឺសេចក្តីឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ស្មារតីត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ ( ឈ្មោះថាមជ្ឈិមាបដិបទា ) ។ ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទានេះឯង ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ទាំងធ្វើឲ្យកើតញាណប្រព្រឹត្តទៅដើម្បីរម្ងាប់ ដើម្បីស្គាល់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។

[ ៧០ ] ម្នាលភិក្ខុទាំងឡាយ នេះឯងឈ្មោះថា ទុក្ខអរិយសច្ច គឺជាតិជាទុក្ខ ១ ជរាជាទុក្ខ ១ ព្យាធិជាទុក្ខ ១ មរណៈជាទុក្ខ ១ ការប្រសព្វចួលនូវសត្វនិងសង្ខារ មិនជាទីស្រឡាញ់ជាទុក្ខ ១ សេចក្តីព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ជាទុក្ខ ១ បុគ្គលប្រាថ្នាវត្ថុណាមិនបាន ការមិនបានវត្ថុនោះ តាមសេចក្តីប្រាថ្នានោះ ក៏ជាទុក្ខ ១ បើពោលដោយសេចក្តីសង្ខេប ឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងឈ្មោះថា ទុក្ខសមុទយអរិយសច្ច គឺតណ្ហាជាធម្មជាតិនាំសត្វឲ្យកើតទៀត ប្រកបដោយសេចក្តីរីករាយនិងសេចក្តីត្រេកត្រអាល ជាធម្មជាតិនាំសត្វឲ្យត្រេកត្រអាល ក្នុងភពនោះៗ ( ឬក្នុងអារម្មណ៍នោះៗ ) បានដល់កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងឈ្មោះថា ទុក្ខនិរោធអរិយសច្ច គឺបានខាងនិព្វាន ធម៌ជាសភាវៈនឿយណាយនិងការរលត់ មិនមានសេសសល់ ជាសភាវៈលះបង់

គ្រវែងចោល ជម្រុះចោល មិនអាល័យនូវតណ្ហានុ៎ះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះឯងឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច បានខាងអរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង គឺសេចក្ដីឃើញត្រូវ ១ ។បេ។ ការតម្កល់ចិត្តត្រូវ ១ ។

[ ៧១ ] ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខអរិយសច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខអរិយសច្ចៈ ដែលតថាគតគួរកំណត់ដឹង ។បេ។ ថា នេះជាទុក្ខអរិយសច្ចៈ ដែលតថាគតកំណត់ដឹងហើយ ។

ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខសមុទយអរិយសច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខសមុទយអរិយសច្ចៈដែលតថាគតគួរលះ ។បេ។ ថា នេះជាទុក្ខសមុទយអរិយសច្ចៈ ដែលតថាគតលះបង់ហើយ ។

ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខនិរោធអរិយសច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខនិរោធអរិយសច្ចៈ ដែលតថាគតគួរធ្វើឲ្យជាក់ច្បាស់ ។បេ។ ថា នេះជាទុក្ខនិរោធអរិយសច្ចៈ ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ។

ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ មានញាណកើតហើយ មានបញ្ញាកើតហើយ មានវិជ្ជាកើតហើយ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ដែលតថាគតគួរចម្រើន ។បេ។ ថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ដែលតថាគតបានចម្រើនហើយ ។

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ តាមការណ៍ពិត តថាគតមានទស្សនកិច្ច គឺការដឹងតាមពិតក្នុងអរិយសច្ចៈទាំង ៤ នេះ ដែលជាញាណមានបរិវដ្ដៈ ៣ មានអាការៈ ១២ យ៉ាងនេះ បើនៅពុំទាន់បរិសុទ្ធិល្អហេតុ កាល

ត្រឹមណា ម្នាលភិក្ខុទាំងឡាយ កាលត្រឹមណោះ តថាគតក៏ពុំទាន់ប្ដេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងចំពោះ នូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសនៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ លុះតែតថាគតមានទស្សនកិច្ច គឺការដឹង តាមពិត ក្នុងអរិយសច្ចៈទាំង ៤ ដែលជាញាណមានបរិវដ្ដៈ ៣ មានអាការៈ ១២ យ៉ាងនេះ បរិសុទ្ធល្អហើយក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ តថាគត ទើបហ៊ានប្ដេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងចំពោះនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ។ មួយទៀត តថាគតមានទស្សនកិច្ច គឺការដឹងកើតឡើងដូច្នេះថា ចេតោវិមុត្តិ ( អរហត្តផល ) របស់តថាគតមិនកម្រើកទេ ជាតិនេះផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មីរបស់តថាគតមិនមានឡើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះហើយ បញ្ចវគ្គិយភិក្ខុក៏ត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ក៏កាលដែលព្រះមានព្រះភាគ កំពុងសម្ដែងវេយ្យាករណ៍នេះ ធម្មចក្ខុ ( សោតាបត្តិមគ្គ ) ដ៏ប្រាសចាកធូលី គឺរាគាទិក្កិលេស ប្រាសចាកមន្ទិល គឺទិដ្ឋិនិងវិចិកិច្ឆាបានកើតហើយដល់កោណ្ឌញ្ញភិក្ខុមានអាយុថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅ

វិញជាធម្មតា ។ សេចក្តីពិសេសថា កាលព្រះធម្មចក្កដែលព្រះមានព្រះភាគឲ្យប្រព្រឹត្តទៅ គឺទ្រង់សម្តែងដូចគេបង្វិលកង់យ៉ាងនេះហើយ ភុម្មទេវតាទាំងឡាយ បានញុំាងសំឡេងឲ្យលាន់ឮឡើងដូច្នេះថា ព្រះធម្មចក្កនោះ មិនមានចក្កដទៃក្រៃលែងជាងទេ ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ជនណានីមួយក្តី ក្នុងលោក មិនអាចនឹងឲ្យប្រព្រឹត្តទៅបានឡើយ ( ឥឡូវ ) ព្រះមានព្រះភាគទ្រង់ឲ្យប្រព្រឹត្តទៅបានហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ ពួកទេវតានៅក្នុងឋានចាតុម្មហារាជិកឮសំឡេងរបស់ពួកភុម្មទេវតា ។បេ។ ពួកទេវតានៅក្នុងឋានតាវត្តិង្ស ពួកទេវតានៅក្នុងឋានយាមៈ ពួកទេវតានៅក្នុងឋានតុសិតៈ ពួកទេវតានៅក្នុងឋាននិម្មានរតី ពួកទេវតានៅក្នុងឋានបរនិម្មិតវសវត្តី ពួកទេវតាក្នុងព្រហ្ម បានញុំាងសំឡេងឲ្យលាន់ឮឡើងដូច្នេះថា ព្រះធម្មចក្កនុ៎ះ មិនមានចក្កដទៃក្រៃលែងជាងទេ ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ជនណានីមួយក្តីក្នុងលោក មិនអាចនឹងឲ្យប្រព្រឹត្តទៅបានឡើយ ( ឥឡូវ ) ព្រះមានព្រះភាគ ទ្រង់ឲ្យប្រព្រឹត្តទៅបានហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។

ក្នុងខណៈនោះ ក្នុងមួយស្របក់នោះ ក្នុងមួយរំពេចនោះ សំឡេង ( កងរំពង ) ក៏លាន់ឮឡើងទៅរហូតដល់ព្រហ្មលោក ដោយអាការលាន់ឮតៗគ្នានោះឯង ។ ឯលោកធាតុទាំងមួយម៉ឺននេះក៏កក្រើក រំពើក ញាប់ញ័រ ទាំងពន្លឺក្លៃធំទូលាយ ប្រមាណមិនបាន កន្លងលើសទេវានុភាពរបស់ទេវតា

ទាំងឡាយ បានកើតប្រាកដឡើងក្នុងលោក ។

លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់បន្លឺឧទានវាចាថា អើហ្ន៎ កោណ្ឌញ្ញបានដឹងហើយ អើហ្ន៎ កោណ្ឌញ្ញបានដឹងហើយ ព្រោះហេតុនោះពាក្យថា អញ្ញាកោណ្ឌញ្ញនេះឯង ក៏បានជាប់មកជានាម របស់ព្រះកោណ្ឌញ្ញភិក្ខុមានអាយុ ។

[ ៧៣ ] ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខអរិយសច្ចៈ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ពាក្យថាញាណកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថា ឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថា ដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថា យល់ច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថា ចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថា ភ្លឺស្វាង ។

ចក្ខុជាធម៌ ញាណជាធម៌ បញ្ញាជាធម៌ វិជ្ជាជាធម៌ ពន្លឺជាធម៌ ធម៌ទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់ធម្មប្បដិសម្ភិទា ធម៌ទាំងឡាយណាជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងឡាយណាជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ហេតុនោះ សេចក្តី

ដឹងក្នុងធម៌ទាំងឡាយ លោកហៅថា ធម្មប្បដិសម្ភិទា ។ សេចក្តីនៃការឃើញជាអត្ថ សេចក្តីនៃការដឹងជាអត្ថ សេចក្តីនៃការដឹងច្បាស់ ជាអត្ថ សេចក្តីនៃការចាក់ធ្លុះជាអត្ថ សេចក្តីនៃការភ្លឺស្វាងជាអត្ថ អត្ថទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផងរបស់អត្ថប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់អត្ថប្បដិ-សម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងអត្ថទាំងឡាយ លោកហៅថា អត្ថប្បដិសម្ភិទា ។ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់នូវធម៌ ៥ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់នូវអត្ថ ៥ និរុត្តិទាំង ១០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់និរុត្តិប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់និរុត្តិ-ប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍ របស់និរុត្តិប្បដិសម្ភិទានោះ ហេតុនោះសេចក្តីដឹងក្នុងនិរុត្តិទាំងឡាយ លោកហៅថា និរុត្តិប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងធម៌ ៥ សេចក្តីដឹងក្នុងអត្ថ ៥ សេចក្តីដឹងក្នុងនិរុត្តិ ១០ សេចក្តីដឹងទាំង ២០ នេះជាអារម្មណ៍ផង ជាគោចរផងរបស់បដិភាណប្បដិ-សម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍ របស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចរ របស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចរ របស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់

បដិភាណប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងបដិភាណទាំងឡាយ លោកហៅថា បដិភាណប្បដិសម្ភិទា ។

[ ៧៤ ] ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខអរិយសច្ចៈ ដែលតថាគតគួរកំណត់ដឹង ។បេ។ នេះជាទុក្ខអរិយ-សច្ចៈ ដែលតថាគតកំណត់ដឹងហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ញាណកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថា ឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថា ដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថា យល់ច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថា ចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថា ភ្លឺស្វាង ។

ចក្ខុជាធម៌ ញាណជាធម៌ បញ្ញាជាធម៌ វិជ្ជាជាធម៌ ពន្លឺជាធម៌ ធម៌ទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់ធម្មប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងឡាយណាជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ហេតុនោះសេចក្តីដឹងក្នុងធម៌ទាំងឡាយ លោកហៅថា ធម្មប្បដិសម្ភិទា ។ សេចក្តីនៃការ

ឃើញជាអត្ថ សេចក្តីនៃការដឹងជាអត្ថ សេចក្តីនៃការដឹងច្បាស់ ជាអត្ថ សេចក្តីនៃការបាក់ធ្លុះជាអត្ថ សេចក្តីនៃការត្រាស់ដឹងជាអត្ថ អត្ថទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់អត្ថប្បដិសម្ភិទា ធម៌ទាំងឡាយណាជា អារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់អត្ថប្បដិ-សម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុង អត្ថទាំងឡាយ លោកហៅថា អត្ថប្បដិសម្ភិទា ។ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់នូវធម៌ ៥ ការពោលនិរុត្តិឲ្យប្រាកដ ដើម្បីពន្យល់នូវអត្ថ ៥ និរុត្តិទាំង ១០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់និរុត្តិប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជា គោចររបស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់និរុត្តិប្ប ដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ហេតុ នោះ សេចក្តីដឹងក្នុងនិរុត្តិទាំងឡាយ លោកហៅថា និរុត្តិប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងធម៌ ៥ សេចក្តីដឹងក្នុងអត្ថ ៥ សេចក្តីដឹងក្នុងនិរុត្តិ ១០ សេចក្តីដឹងទាំង ២០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់បដិភាណប្ប ដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់ បដិភាណប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងបដិភាណទាំងឡាយ

លោកហៅថា បដិភាណប្បដិសម្ភិទា ។ ក្នុងទុក្ខអរិយសច្ចៈមានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ។

[ ៧៥ ] ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខសមុទយអរិយសច្ច ។បេ។ ថា នេះជាទុក្ខសមុទយអរិយសច្ច ដែលតថាគតគួរលះ ។បេ។ ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខសមុទយអរិយសច្ច ដែលតថាគតលះហើយ ។បេ។ ក្នុងទុក្ខសមុទយអរិយសច្ចមានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ។

ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខនិរោធអរិយសច្ច ។បេ។ ថា នេះជាទុក្ខនិរោធ-អរិយសច្ច ដែលតថាគតគួរធ្វើឲ្យជាក់ច្បាស់ ។បេ។ ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខនិរោធអរិយសច្ច ដែលតថាគតធ្វើឲ្យជាក់ច្បាស់ហើយ ។បេ។ ក្នុងទុក្ខ-និរោធអរិយសច្ចមានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ។

ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។បេ។ ថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដែលតថាគតគួរចម្រើន ។បេ។ ចក្ខុ

កើតហើយ ។បេ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចដែលតថាគត ចម្រើនហើយ ។បេ។ ក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ក្នុងអរិយសច្ចទាំង ៤ មានធម៌ ៦០ មានអត្ថ ៦០ មាននិរុត្តិ ១២០ មានញាណ ២៤០ ។

[ ៧៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះកាយេកាយានុបស្សនា ( ការពិចារណាឃើញថាកាយក្នុងកាយ ) ថា នេះកាយេកាយានុបស្សនា ដែលតថាគតគួរចម្រើន ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះកាយេកាយានុបស្សនា ដែលតថាគតចម្រើនហើយ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះវេទនាសុវេទនានុបស្សនា ។បេ។ ថា នេះចិត្តេចិត្តានុបស្សនា ។បេ។ ថា នេះធម្មេសុធម្មានុបស្សនា ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះធម្មេសុធម្មានុបស្សនា ដែលតថាគតគួរចម្រើន ។បេ។ ថា នេះធម្មេសុធម្មានុបស្សនា ដែលតថាគតចម្រើនហើយ ។

ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់

ឮក្នុងកាលមុនថា នេះកាយេកាយានុបស្សនា ថា នេះកាយេកាយានុបស្សនា ដែលតថាគតគួរចម្រើន ។បេ។ ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះកាយេកាយានុបស្សនាដែលតថាគតចម្រើនហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា ញាណកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្ដេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថា ឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថា ដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថា យល់ច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថា ចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថា ភ្លឺស្វាង ។

ចក្ខុជាធម៌ ញាណជាធម៌ បញ្ញាជាធម៌ វិជ្ជាជាធម៌ ពន្លឺជាធម៌ ធម៌ទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់ធម្មប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងឡាយណាជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ហេតុនោះសេចក្ដីដឹងក្នុងធម៌ទាំងឡាយ លោកហៅថា ធម្មប្បដិសម្ភិទា ។ សេចក្ដីនៃការឃើញជាអត្ថ សេចក្ដីនៃការដឹងជាអត្ថ សេចក្ដីនៃការដឹងច្បាស់ ជាអត្ថ សេចក្ដីនៃការចាក់ធ្លុះជាអត្ថ សេចក្ដីនៃការភ្លឺស្វាងជាអត្ថ អត្ថទាំង ៥ នេះ

ជាអារម្មណ៍ផង ជាគោចរផង របស់អត្ថប្បដិសម្ភិទា ធម៌ទាំងឡាយណាជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងអត្ថទាំងឡាយ លោកហៅថា អត្ថប្បដិសម្ភិទា ។ ការពោលនិរុត្តិឲ្យប្រាកដដើម្បីពន្យល់នូវធម៌ទាំង ៥ ការ ពោលនិរុត្តិឲ្យប្រាកដដើម្បីពន្យល់នូវអត្ថទាំង ៥ និរុត្តិទាំង ១០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់និរុត្តិប្បដិសម្ភិទា ធម៌ទាំងឡាយណាជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងឡាយណាជាគោចររបស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងនិរុត្តិទាំងឡាយ លោកហៅថា និរុត្តិប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងធម៌ ៥ សេចក្តីដឹងក្នុងអត្ថ ៥ សេចក្តីដឹងក្នុងនិរុត្តិ ១០ សេចក្តីដឹងទាំង ២០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់បដិភាណប្បដិសម្ភិទា ធម៌ទាំងឡាយណាជាអារម្មណ៍របស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងឡាយណាជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់បដិភាណប្បដិសម្ភិទានោះ ហេតុនោះសេចក្តីដឹងក្នុងបដិភាណទាំងឡាយ លោកហៅថា បដិភាណប្បដិសម្ភិទា ។ ក្នុងកាយេកាយានុបស្សនាសតិប្បដ្ឋានមានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ

៦០ នេះវេទនាសុវេទនានុបស្សនា ។បេ។ នេះចិត្តេចិត្តានុបស្សនា ។បេ។

ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះធម្មេសុធម្មានុបស្សនា ។បេ។ ថា នេះធម្មេសុធម្មានុ-បស្សនាដែលតថាគតគួរចម្រើន ។បេ។ ចក្ខុកើតហើយ ។បេ។ ពន្លឺកើតឡើងហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះធម្មេសុ-ធម្មានុបស្សនាដែលតថាគតចម្រើនហើយ ។បេ។ ក្នុងធម្មេសុធម្មានុបស្សនា សតិប្បដ្ឋានមានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ក្នុងសតិប្បដ្ឋានទាំង ៤ មានធម៌ ៦០ មានអត្ថ ៦០ មាននិរុត្តិ ១២០ មានញាណ ២៤០ ។

[ ៧៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ថានេះឥទ្ធិបាទប្រកបដោយវីរិយសមាធិ ។បេ។ ថានេះឥទ្ធិបាទប្រកបដោយចិត្តសមាធិ ។បេ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយវី-មំសាសមាធិនិងបធានសង្ខារ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ដែលតថាគតគួរចម្រើន ។បេ។ ថា នេះឥទ្ធិបាទប្រកបដោយវីមំសាសមាធិ និង

បធានសង្ខារដែលតថាគតចម្រើនហើយ ។

[ ៧៨ ] ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ។បេ។ ថា នេះឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារដែលតថាគតគួរចម្រើន ។បេ។ ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារដែលតថាគតចម្រើនហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ញាណកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថា ឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថា ដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថា ដឹងច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថា ចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថា ភ្លឺស្វាង ។

ចក្ខុជាធម៌ ញាណជាធម៌ បញ្ញាជាធម៌ វិជ្ជាជាធម៌ ពន្លឺជាធម៌ ធម៌ទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់ធម្មប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់ធម្មប្បដិសម្ភិទានោះ ធម៌ទាំងឡាយណាជាគោចររបស់ធម្មប្បដិសម្ភិទា

នោះធម៌ទាំងនោះ ជាអារម្មណ៍របស់ធម្មប្បដិសម្ភិទានោះ ហេតុនោះ សេចក្ដីដឹងក្នុងធម៌ទាំងឡាយ លោកហៅថា ធម្មប្បដិសម្ភិទា ។ សេចក្ដីនៃការឃើញជាអត្ថ សេចក្ដីនៃការដឹងជាអត្ថ សេចក្ដីនៃការដឹងច្បាស់ ជាអត្ថ សេចក្ដីនៃការចាក់ធ្លុះជាអត្ថ សេចក្ដីនៃការក្លីស្វាងជាអត្ថ អត្ថទាំង ៥ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់អត្ថប្បដិសម្ភិទា ធម៌ទាំងឡាយណាជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងឡាយណា ជាគោចររបស់អត្ថប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់អត្ថប្បដិសម្ភិទានោះ ហេតុនោះ សេចក្ដីដឹងក្នុងអត្ថទាំងឡាយ លោកហៅថា អត្ថប្បដិសម្ភិទា ។ ការពោលនិរុត្តិឲ្យប្រាកដដើម្បីពន្យល់ធម៌ ៥ ការពោលនិរុត្តិឲ្យប្រាកដដើម្បីពន្យល់អត្ថ ៥ និរុត្តិទាំង ១០ នេះ ជាអារម្មណ៍ផង ជាគោចរផង របស់និរុត្តិប្បដិសម្ភិទា ធម៌ទាំងឡាយណាជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាគោចររបស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងឡាយណាជាគោចររបស់និរុត្តិប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់និរុត្តិប្បដិសម្ភិទានោះ ហេតុនោះ សេចក្ដីដឹងក្នុងនិរុត្តិទាំងឡាយ លោកហៅថា និរុត្តិប្បដិសម្ភិទា ។ សេចក្ដីដឹងក្នុងធម៌ ៥ សេចក្ដីដឹងក្នុងអត្ថ ៥ សេចក្ដីដឹងក្នុងនិរុត្តិ ១០ សេចក្ដីដឹងទាំង ២០ នេះជាអារម្មណ៍ផង ជាគោចរផង របស់បដិភាណប្បដិសម្ភិទា ធម៌ទាំងឡាយណា ជាអារម្មណ៍របស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះជាគោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងឡាយណាជា

គោចររបស់បដិភាណប្បដិសម្ភិទានោះ ធម៌ទាំងនោះ ជាអារម្មណ៍របស់បដិ-ភាណប្បដិសម្ភិទានោះ ហេតុនោះ សេចក្តីដឹងក្នុងបដិភាណទាំងឡាយ លោកហៅថា បដិភាណប្បដិសម្ភិទា ។ ក្នុងឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ នេះឥទ្ធិបាទប្រកបដោយវីរិយសមាធិ ។បេ។ នេះឥទ្ធិបាទប្រកបដោយចិត្ត-សមាធិ ។បេ។

ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។បេ។ នេះឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ដែលតថាគតគួរចម្រើន ។បេ។ ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ដែលតថាគតចម្រើនហើយ ។បេ។ ក្នុងឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ មានធម៌ ១៥ មានអត្ថ ១៥ មាននិរុត្តិ ៣០ មានញាណ ៦០ ក្នុងឥទ្ធិបាទទាំង ៤ មានធម៌ ៦០ មានអត្ថ ៦០ មាននិរុត្តិ ១២០ មានញាណ ២៤០ ។

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ វិបស្សីពោធិសត្វមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា ស-មុទ័យ សមុទ័យ ( ហេតុជាដែនកើតឡើង ហេតុជាដែនកើតឡើង ) ម្នាលភិក្ខុទាំងឡាយ វិបស្សីពោធិសត្វមានចក្ខុកើតហើយ ។បេ។ មានពន្លឺ

កើតហើយក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា និរោធ និរោធ ( ការរលត់ ការរលត់ ) ។ ក្នុងវេយ្យាករណ៍របស់វិបស្សីពោធិសត្វមានធម៌ ១០ មានអត្ថ ១០ មាននិរុត្តិ ២០ មានញាណ ៤០ ។

ម្នាលភិក្ខុទាំងឡាយ សិខីពោធិសត្វ ។បេ។ វេស្សភូពោធិសត្វ ។បេ។ កកុសន្ធពោធិសត្វ ។បេ។ កោនាគមនពោធិសត្វ ។បេ។ កស្សបពោធិសត្វមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា សមុទ័យ សមុទ័យ ( ហេតុជាដែនកើត ហេតុជាដែនកើត ) ម្នាលភិក្ខុទាំងឡាយ កស្សបពោធិសត្វ មានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា និរោធ និរោធ ( ការរលត់ ការរលត់ ) ។ ក្នុងវេយ្យាករណ៍របស់កស្សបពោធិសត្វមានធម៌ ១០ មានអត្ថ ១០ មាននិរុត្តិ ២០ មានញាណ ៤០ ។

ម្នាលភិក្ខុទាំងឡាយ គោតមពោធិសត្វមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា សមុទ័យ សមុទ័យ ( ហេតុជាដែនកើត ហេតុជាដែនកើត ) ម្នាលភិក្ខុទាំងឡាយ គោតមពោធិសត្វ មានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា និរោធ និរោធ ( ការរលត់ ការរលត់ ) ។ ក្នុងវេយ្យាករណ៍របស់គោតមពោធិសត្វ មានធម៌ ១០ មានអត្ថ ១០ មាននិរុត្តិ ២០ មានញាណ ៤០ ។ ក្នុងវេយ្យាករណ៍ទាំង ៧ របស់ពោធិសត្វទាំង ៧ អង្គ មានធម៌ ៧០ មានអត្ថ ៧០ មាននិរុត្តិ ១៤០

មានញាណ ២៨០ ។

[ ៨០ ] ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយថា អត្ថនៃអភិញ្ញារបស់អភិញ្ញាទាំងប៉ុន្មាន ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា អត្ថនៃអភិញ្ញា ព្រះមានព្រះភាគមិនបានពាល់ត្រូវហើយ ដោយបញ្ញាមិនមានឡើយ ក្នុងអត្ថនៃអភិញ្ញារបស់អភិញ្ញាមានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយថា អត្ថនៃបរិញ្ញារបស់បរិញ្ញាទាំងប៉ុន្មាន ។បេ។ អត្ថនៃបហានៈរបស់បហានៈទាំងប៉ុន្មាន ។បេ។ អត្ថនៃភាវនារបស់ភាវនាទាំងប៉ុន្មាន ។បេ។ អត្ថនៃសច្ឆិកិរិយារបស់សច្ឆិកិរិយាទាំងប៉ុន្មាន ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អត្ថនៃសច្ឆិកិរិយា ព្រះមានព្រះភាគមិនបានពាល់ត្រូវហើយ ដោយបញ្ញាមិនមានឡើយ ក្នុងអត្ថនៃសច្ឆិកិរិយារបស់សច្ឆិកិរិយា មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ក្នុងអត្ថនៃអភិញ្ញារបស់អភិញ្ញា ក្នុងអត្ថនៃបរិញ្ញារបស់បរិញ្ញា ក្នុងអត្ថនៃបហានៈរបស់បហានៈ ក្នុងអត្ថនៃភាវនារបស់ភាវនា ក្នុងអត្ថនៃសច្ឆិកិរិយារបស់សច្ឆិកិរិយា មានធម៌ ១២៥ មានអត្ថ ១២៥ មាននិរុត្តិ ២៥០ មានញាណ ៥០០ ។

[ ៨១ ] ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជា

កើតហើយ ពន្លឺកើតហើយថា អត្ថនៃខន្ធរបស់ខន្ធទាំងប៉ុន្មាន ព្រះមាន-ព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយបញ្ញា អត្ថនៃខន្ធព្រះមានព្រះភាគ មិនបានពាល់ត្រូវហើយដោយបញ្ញាមិនមានឡើយ ក្នុងអត្ថនៃខន្ធរបស់ខន្ធទាំងឡាយ មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយថា អត្ថនៃធាតុរបស់ធាតុទាំងប៉ុន្មាន ។បេ។ អត្ថនៃអាយតនៈរបស់អាយតនៈទាំងប៉ុន្មាន អត្ថនៃសង្ខតៈរបស់សង្ខតៈទាំងប៉ុន្មាន អត្ថនៃអសង្ខតៈរបស់អសង្ខតៈទាំងប៉ុន្មាន ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា អត្ថនៃអសង្ខតៈ ព្រះមានព្រះភាគទ្រង់មិនបានពាល់ត្រូវហើយ ដោយបញ្ញាមិនមានឡើយ ក្នុងអត្ថនៃអសង្ខតៈរបស់អសង្ខតៈមានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ក្នុងអត្ថនៃខន្ធរបស់ខន្ធទាំងឡាយ ក្នុងអត្ថនៃធាតុរបស់ធាតុទាំងឡាយ ក្នុងអត្ថនៃអាយតនៈ របស់អាយតនៈទាំងឡាយ ក្នុងអត្ថនៃសង្ខតៈរបស់សង្ខតៈទាំងឡាយ ក្នុងអត្ថនៃអសង្ខតៈរបស់អសង្ខតៈ មានធម៌ ១២៥ មានអត្ថ ១២៥ មាននិរុត្តិ ២៥០ មានញាណ ៥០០ ។

[ ៨២ ] ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយថា អត្ថនៃទុក្ខរបស់ទុក្ខសច្ច ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់

ត្រូវហើយដោយបញ្ញា អត្ថនៃទុក្ខ ព្រះមានព្រះភាគមិនបានពាល់ត្រូវហើយដោយបញ្ញាមិនមានឡើយ ក្នុងអត្ថនៃទុក្ខរបស់ទុក្ខសច្ចមានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយថា អត្ថនៃសមុទ័យរបស់សមុទយសច្ចទាំងប៉ុន្មាន ។បេ។ អត្ថនៃនិរោធរបស់និរោធសច្ចទាំងប៉ុន្មាន អត្ថនៃមគ្គរបស់មគ្គសច្ចទាំងប៉ុន្មាន ព្រះមានព្រះភាគ ទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា អត្ថនៃមគ្គ ព្រះមានព្រះភាគ មិនបានពាល់ត្រូវហើយ ដោយបញ្ញាមិនមានឡើយ ក្នុងអត្ថនៃមគ្គរបស់មគ្គសច្ចមានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ក្នុងអរិយសច្ចទាំង ៤ មានធម៌ ១០០ មានអត្ថ ១០០ មាននិរុត្តិ ២០០ មានញាណ ៤០០ ។

[ ៨៣ ] ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយថា អត្ថនៃអត្ថប្បដិសម្ភិទា ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា អត្ថនៃអត្ថប្បដិសម្ភិទា ព្រះមានព្រះភាគមិនបានពាល់ត្រូវហើយ ដោយបញ្ញាមិនមានឡើយ ក្នុងអត្ថនៃអត្ថប្បដិសម្ភិទារបស់អត្ថប្បដិសម្ភិទា មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយថា អត្ថនៃធម្មប្បដិសម្ភិទារបស់ធម្មប្បដិសម្ភិទាទាំងប៉ុន្មាន ។បេ។ អត្ថនៃនិរុត្តិប្បដិសម្ភិទា របស់និរុត្តិប្បដិសម្ភិទាទាំងប៉ុន្មាន អត្ថនៃបដិភាណប្បដិ-

សម្ភិទារបស់បដិភាណប្បដិសម្ភិទាទាំងប៉ុន្មាន ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា អត្ថនៃបដិភាណប្បដិសម្ភិទា ព្រះមានព្រះភាគមិនបានពាល់ត្រូវហើយដោយបញ្ញាមិនមានឡើយ ក្នុងអត្ថនៃបដិភាណប្បដិសម្ភិទារបស់បដិភាណ-ប្បដិសម្ភិទា មានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ក្នុងបដិសម្ភិទាទាំង ៤ មានធម៌ ១០០ មានអត្ថ ១០០ មាននិរុត្តិ ២០០ មានញាណ ៤០០ ។

[ ៨៤ ] ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយថា ឥន្រ្ទិយបរោបរិ-យត្តញាណទាំងប៉ុន្មាន ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយប្រាជ្ញា ឥន្រ្ទិយ-បរោបរិយត្តញាណ ព្រះមានព្រះភាគមិនបានពាល់ត្រូវហើយ ដោយប្រាជ្ញាមិនមានឡើយ ក្នុងឥន្រ្ទិយបរោបរិយត្តញាណមានធម៌ ២៥ មានអត្ថ ២៥ មាននិរុត្តិ ៥០ មានញាណ ១០០ ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយថា សត្តាសយានុស-យញ្ញាណទាំងប៉ុន្មាន ។បេ។ យមកប្បាដិហិរញ្ញាណទាំងប៉ុន្មាន មហាករុណា-សមាបត្តិញាណទាំងប៉ុន្មាន អនាវរណញ្ញាណទាំងប៉ុន្មាន ព្រះមានព្រះភាគទ្រង់ដឹងហើយ ឃើញហើយ ជ្រាបហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា អនាវរណញ្ញាណ ព្រះមានព្រះភាគ មិនពាល់ត្រូវហើយ ដោយបញ្ញាមិនមានឡើយ ក្នុងអនាវរណញ្ញាណ មានធម៌ ១៥

មានអត្ថ ១៥ មាននិរុត្តិ ៥៦ មានញាណ ១០០ ក្នុងធម៌របស់ព្រះពុទ្ធ ទាំង ៦ មានធម៌ ១៥០ មានអត្ថ ១៥០ មាននិរុត្តិ ៣០០ មានញាណ ៦០០ ក្នុងបដិសម្ភិទាបករណ៍ មានធម៌ ៨៥០ មានអត្ថ ៨៥០ មាននិរុត្តិ ១០០០ ផង មាននិរុត្តិ ៧០០ ( និរុត្តិ ១៧០០ ) មានញាណ ៣០០០ ផង មានញាណ ៤០០ ផង ( ញាណ ៣៤០០ ) ។

## ចប់ បដិសម្ភិទាកថា

# អដ្ឋកថា
# បដិសម្ភិទាកថា
# អដ្ឋកថា ធម្មចក្កប្បវត្តនវារៈ

[ ៦៩ ] ឥឡូវនេះ នឹងពណ៌នាតាមលំដាប់សេចក្តី ដែលនៅមិនទាន់ពណ៌នាមកពីមុននៃបដិសម្ភិទាកថា ដែលមានធម្មចក្កប្បវត្តនសូត្រជាបទនាំ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងដល់ប្រភេទនៃបដិសម្ភិទា ដែលសម្រេចដោយអំណាចនៃមគ្គដែលបានដល់វិបាកៈ ត្រាស់ទុកហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រមុន ដូចតទៅនេះថា បទថា **ពារាណសិយំ** គឺមានស្ទឹងឈ្មោះថា ពារណសា ក្រុងពារាណសី ជានគរនៅមិនឆ្ងាយពីស្ទឹងពារណសា ។ ជិតក្រុងពារាណសីនោះ ។ បទថា **ឥសិបតនេ មិគទាយេ** បានដល់ ក្នុងអារាម ឈ្មោះថា មិគទាយវ័ន ព្រោះជាទីឲ្យអភ័យដល់ម្រឹគទាំងឡាយ ទើបបានឈ្មោះយ៉ាងនោះ ដោយអំណាចនៃការចុះនិងការហោះឡើងនៃពួកឥសី ។ ពួកសព្វញ្ញូឥសី កើតឡើងហើយៗក៏ចុះទៅក្នុងព្រៃឥសិបតនមិគទាយវ័ននោះ អធិប្បាយថា អង្គុយប្រជុំគ្នាដើម្បីញ៉ាំងធម្មចក្ក ឲ្យប្រព្រឹត្តទៅ សូម្បីពួកព្រះបច្ចេកពុទ្ធឥសីចេញពីនិរោធសមាបត្តិ ពេលកន្លងទៅ ៧ ថ្ងៃ លុបមុខធ្វើកិច្ចត្រង់អនោតត្តស្រះក៏ហោះមកតាមអាកាសអំពីញកក្ភំនន្ទមូលកៈ ចុះទៅប្រជុំគ្នាក្នុងទីនេះ ប្រជុំគ្នាដើម្បីជាសុខ ដើម្បីឧបោសថ និងមិនមែនដើម្បីឧបោសថ ពេលត្រឡប់ទៅកាន់ភ្នំគន្ធមាទន៍ ក៏ហោះទៅអំពីទីនោះឯង ព្រោះហេតុនោះដោយបទនេះ

ទើបលោកហៅទីនោះថា ឥសិបតនៈ ព្រោះជាទីចុះ ទីហោះឡើងរបស់ឥសី ។ បាលីថា **ឥសិបទនំ** ដូច្នេះក៏មាន ។

បទថា **បញ្ចវគ្គិយេ** បានដល់ ពួករបស់ភិក្ខុ ៥ ដូចដែលលោកពោលទុកយ៉ាងនេះថា

ព្រះមហាថេរៈ ៥ ទាំងនេះ គឺព្រះកោណ្ឌញ្ញៈ ១ ព្រះភទ្ទិយៈ ១ ព្រះវប្បៈ ១ ព្រះមហានាម ១ ព្រះអស្សជិ ១ លោកហៅថា បញ្ចវគ្គ ។

ពួកនៃភិក្ខុទាំងឡាយ ៥ ឈ្មោះថា **បញ្ចវគ្គ** ។ ឈ្មោះថា បញ្ចវគ្គិយ ព្រោះអត្ថថា ទាក់ទងក្នុងពួក ៥ នោះ ព្រោះមានទៅក្នុងពួក ៥ នោះ ។ ( ទ្រង់ត្រាស់ ) នឹងបញ្ចវគ្គិយទាំងនោះ ។ បទថា **ភិក្ខូ អាមន្តេសិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់បំពេញបារមី ចាប់ផ្តើមតាំងអំពីសន្សំអភិនីហារទៀបបាទមូលរបស់ព្រះទសពលព្រះនាមថា ទីបង្ករ រហូតសម្រេចភពចុងក្រោយដោយលំដាប់ ក្នុងភពចុងក្រោយ ស្តេចយាងចេញសាងមហាភិនេស្រ្កមណ៍ ទ្រង់ដល់ពោធិមណ្ឌលដោយលំដាប់ គង់លើអបរាជិតបល្ល័ង្កត្រង់ពោធិមណ្ឌលនោះ ទ្រង់កម្ចាត់មារនិងពលមារក្នុងបឋមយាម ទ្រង់រឭកដល់បុព្វេនិវាសញ្ញាណក្នុងមជ្ឈិមយាម ទ្រង់ញ៉ាំងទិព្វចក្ខុឲ្យបរិសុទ្ធក្នុងទីបំផុតនៃបច្ឆិមយាមទ្រង់ញ៉ាំងម៉ឺនលោកធាតុឲ្យបន្លឺឡើង ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ទ្រង់ឲ្យពេលវេលាកន្លងទៅ ៧ សប្តាហ៍ត្រង់ពោធិមណ្ឌល ដែលមហាព្រហ្មទូលអារាធនាឲ្យទ្រង់សម្តែងធម៌ ទ្រង់ប្រមើលមើល

សត្វលោកដោយទិព្វចក្ខុ ស្តេចយាងទៅកាន់ក្រុងពារាណសី ដើម្បីទ្រង់អនុ-គ្រោះសត្វលោក ទ្រង់មានព្រះបំណងនឹងឲ្យបញ្ចវគ្គិយភិក្ខុស្គាល់ទ្រង់ ហើយទ្រង់ញុំាងធម្មចក្កឲ្យប្រព្រឹត្តទៅ ទើបទ្រង់ត្រាស់ហៅ ។

បទថា **ទ្វេ មេ ភិក្ខវេ អន្តា** បានដល់ ម្នាលភិក្ខុទាំងឡាយ អន្តធម៌ទាំង ២ នេះ ។ ព្រះសូរសៀងដែលបន្លឺចេញ ដោយទ្រង់បន្លឺព្រះតម្រាស់នេះ ខាងក្រោមដល់អវីចិ ខាងលើដល់ភវគ្គព្រហ្ម ហើយផ្សាយទៅរហូតម៉ឺនលោកធាតុ ក្នុងសម័យនោះ ព្រហ្ម ១៨ កោដិមកប្រជុំគ្នា ព្រះអាទិត្យអស្តង្គត ព្រះចន្ទពេញវង់ ប្រកបដោយអាសាឡ្ហនក្ខត្តឫក្ស រះឡើងនាទិសខាងកើត ក្នុងសម័យនោះ ព្រះមានព្រះភាគ ទ្រង់ចាប់ផ្តើមត្រាស់សម្តែងធម្មចក្កប្បវត្តនសូត្រ មានព្រះតម្រាស់ថា **ទ្វេ មេ ភិក្ខវេ អន្តា** ជាដើមដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បព្វជិតេន** បានដល់ អ្នកកាត់វត្ថុកាមដែលទាក់ទងដោយគ្រហស្ថចេញបួស ។ បទថា **ន សេវិតព្វា** បានដល់ មិនគួរប្រើប្រាស់ ។ ព្រះមានព្រះភាគត្រាស់ថា **បព្វជិតេន ន សេវិតព្វា** ព្រោះជាគ្រឿងទទួលការបដិបត្តិយ៉ាងពិសេស របស់បព្វជិតទាំងឡាយនោះឯង ។ បទថា **យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ** បានដល់ ការប្រកបកាមសុខ គឺកិលេស ក្នុងវត្ថុកាម ឬការប្រកបអាស្រ័យកាមសុខ គឺកិលេស ។ បទថា **ហីនោ** បានដល់ អាក្រក់ ។ បទថា **គម្មោ** បានដល់ ជារបស់មាននៃអ្នកស្រុក ។ បទថា **ពោថុជ្ជនិកោ** បាន

ដល់ បុថុជ្ជន គឺអន្ធពាលបុថុជ្ជនប្រព្រឹត្តរឿយ ៗ ។ បទថា **អនរិយោ** បានដល់ មិនមែនរបស់ព្រះអរិយ ។ម្យ៉ាងទៀត មិនមែនជារបស់មាននៃព្រះអរិយៈដែលបរិសុទ្ធឧត្តម ។ បទថា **អនត្ថសញ្ហិតោ** បានដល់ មិនមែនរបស់មានប្រយោជន៍ មិនអាស្រ័យហេតុដែលនាំសេចក្តីសុខមកឲ្យ ។

បទថា **អត្តកិលមថានុយោគោ** បានដល់ ប្រកបសេចក្តីលំបាកដល់ខ្លួន អធិប្បាយថា ធ្វើនូវសេចក្តីទុក្ខឲ្យដល់ខ្លួន ។ បទថា **ទុក្ខោ** បានដល់ នាំសេចក្តីទុក្ខមកឲ្យ ដោយធ្វើខ្លួនឲ្យលំបាក មានដេកលើទីធ្វើដោយបន្លា ជាដើម ។ ក្នុងបទនេះ ទ្រង់មិនត្រាស់ថា **ហីនោ** ដើម្បីរក្សាចិត្តរបស់អ្នកបំពេញតបៈទាំងនោះ ព្រោះអ្នកបំពេញតបៈទាំងនោះ ប្រកាន់ថា ការធ្វើខ្លួនឲ្យលំបាកជាតបៈដ៏ខ្ពង់ខ្ពស់ ។ មិនត្រាស់ថា **គម្មោ** ព្រោះជារបស់ធម្មតានៃបព្វជិតទាំងឡាយ មិនត្រាស់ថា **ពោថុជ្ជនិកោ** ព្រោះមិនទូទៅដល់គ្រហស្ថទាំងឡាយ ។

ម្យ៉ាងទៀត ក្នុងបទថា **កាមសុខល្លិកានុយោគោ** នោះ ទ្រង់មិនត្រាស់ថា **ទុក្ខោ** ដើម្បីរក្សាចិត្តរបស់ពួកបុគ្គលដែលប្តេជ្ញាថា ជាបព្វជិតពួកណាមួយ បុគ្គលមានវាទៈ ( ក្នុងទីឃនិកាយសីលក្ខន្ធវគ្គ ) ថា នៃអ្នកដ៏ចម្រើន កាលណាបើខ្លួននេះឆ្អែតស្កប់ស្កល់ ឲ្យគេបម្រើដោយកាមគុណ ៥ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង ទើបខ្លួននេះឈ្មោះថា ជាអត្តភាពដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន និងព្រោះការសមាទានធម៌នោះ ជាសេចក្តីសុខក្នុងបច្ចុប្បន្ន ។ កាមសុខល្លិកានុយោគ

មិនគួរសេព ព្រោះជាសេចក្ដីសុខ សៅហ្មងដោយតណ្ហានិងទិដ្ឋិក្នុងបច្ចុប្បន្ន ព្រោះមានទុក្ខជាផលតទៅ និងព្រោះជាអ្នកខ្វល់ខ្វាយក្នុងកាមសុខល្លិកានុ-យោគនោះពាក់ព័ន្ធដោយគ្រឿងចងគឺ តណ្ហានិងទិដ្ឋិ អត្តកិលមថានុយោគ មិនគួរសេព ព្រោះជាទុក្ខសៅហ្មង ដោយទិដ្ឋិក្នុងបច្ចុប្បន្ន ព្រោះមានទុក្ខជាផលតទៅ និងព្រោះជាអ្នកខ្វល់ខ្វាយ ក្នុងអត្តកិលមថានុយោគនោះពាក់ព័ន្ធដោយគ្រឿងចង គឺទិដ្ឋិ ។ បទថា **ឯតេ តេ** បានដល់ ទាំងនោះ ។ បទថា **អនុបគម្ម** បានដល់ មិនចូលទៅជិត ។ បទថា **មជ្ឈិមា** ឈ្មោះថា មជ្ឈិម ព្រោះជាផ្លូវកណ្ដាលមិនមានសុខ និងទុក្ខ ដែលសៅហ្មង ។ ឈ្មោះថា **បដិបទា** ព្រោះជាហេតុដល់និព្វាន ។ បទថា **អភិសម្ពុទ្ធា** បានដល់ ចាក់ធ្លុះហើយ ។

ក្នុងបទថា **ចក្ខុករណី** ជាដើម មានសេចក្ដីដូចតទៅនេះថា ឈ្មោះថា **ចក្ខុករណី** ព្រោះធ្វើបញ្ញាចក្ខុ ។ បទថា **ញាណករណី** ជាវេវចនៈរបស់បទថា **ចក្ខុករណី** នោះឯង ។ បទថា **ឧបសមាយ** បានដល់ ដើម្បីស្ងប់កិលេស ។ បទថា **អភិញ្ញាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការដឹងដ៏ក្រៃលែងនូវសច្ចៈ ៤ ។ បទថា **សម្ពោធាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងសច្ចៈ ៤ ទាំងនោះឯង ។ បទថា **និព្វានាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យជាក់ច្បាស់នូវនិព្វាន ។

ម្យ៉ាងទៀត ឈ្មោះថា **ចក្ខុករណី** ព្រោះធ្វើមគ្គញ្ញាណ គឺទស្សនៈ ។ ឈ្មោះថា **ញាណករណី** ព្រោះធ្វើមគ្គញ្ញាណ គឺភាវនា ។ ដើម្បីស្ងប់

កិលេសទាំងពួង ។ ដើម្បីដឹងដ៏ក្រៃលែងនូវធម៌ទាំងពួង ។ ដើម្បីត្រាស់ដឹងអរហត្តផល ។ ដើម្បីរំលត់កិលេស និងខន្ធ ។

[ ៧០ ] សច្ចៈកថា ខ្ញុំពោលទុកហើយ ក្នុងអភិញ្ញេយ្យនិទ្ទេស ។

[ ៧១ ] ព្រះមានព្រះភាគ កាលទ្រង់ប្រកាសសច្ចៈយ៉ាងនេះហើយ កាលទ្រង់ឃើញការញុំាងបដិបទាឲ្យសម្រេច ហើយចាក់ធ្លុះសច្ចៈ នៃបញ្ចវគ្គិយទាំងនោះ ដែលនៅមានមានៈខ្វាំងក្នុងព្រះអង្គ ដោយការស្តាប់លំដាប់នៃការចាក់ធ្លុះរបស់ព្រះអង្គ ហើយដកនូវមានៈខ្វាំងដោយបដិបទា ទើបទ្រង់សម្តែងលំដាប់នៃការចាក់ធ្លុះរបស់ព្រះអង្គ ដោយពាក្យថា **ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **អននុស្សុតេសុ** បានដល់ មិនបានស្តាប់តគ្នាមក អធិប្បាយថា មិនធ្លាប់បានស្តាប់មកអំពីអ្នកដទៃ ។ អត្ថនៃបទជាដើមថា **ចក្ខុំ** នឹងមានជាក់ច្បាស់ខាងមុខ ។ ការចាក់ធ្លុះដោយការឃើញសច្ចៈ ៤ គឺនេះទុក្ខអរិយសច្ចៈ ១ នេះទុក្ខសមុទយអរិយសច្ចៈ ១ នេះទុក្ខនិរោធអរិយសច្ចៈ ១ នេះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ១ រមែងប្រព្រឹត្តទៅក្នុងសេក្ខភូមិ ។

ការចាក់ធ្លុះដោយការនានូវសច្ចៈ ៤ គឺគួរកំណត់ដឹង ១ គួរលះ ១ គួរធ្វើឲ្យជាក់ច្បាស់ ១ គួរចម្រើន ១ រមែងប្រព្រឹត្តទៅក្នុងសេក្ខភូមិដូចគ្នា ។

ការពិចារណាសច្ចៈ ៤ គឺកំណត់ហើយ ១ លះហើយ ១ ធ្វើឲ្យជាក់

ច្បាស់ហើយ ១ ចម្រើនហើយ ១ រមែងប្រព្រឹត្តទៅក្នុងអសេក្ខភូមិ ។

[ ៧២ ] បទថា **តិបរិវដ្ដំ** ឈ្មោះថា តិបរិវដ្ដ ព្រោះវិលជុំវិញ ៣ ជុំ ដោយអំណាចបរិវដ្ដ ៣ គឺសច្ចញ្ញាណ ( ញាណកំណត់ដឹងអរិយសច្ចៈ ) កិច្ចញ្ញាណ ( ញាណកំណត់ដឹងកិច្ចដែលគួរធ្វើ ) កតញ្ញាណ ( ញាណកំណត់ដឹងកិច្ចដែលធ្វើហើយ ) ។ ក្នុងបទថា **តិបរិវដ្ដំ** នេះ ការដឹងតាមសភាពពិតក្នុងសច្ចៈ ៤ យ៉ាងនេះថា នេះទុក្ខអរិយសច្ចៈ នេះទុក្ខសមុទយអរិយសច្ចៈ នេះទុក្ខនិរោធអរិយសច្ចៈ នេះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ឈ្មោះថា សច្ចញ្ញាណ ។ ក្នុងសច្ចញ្ញាណទាំងនោះ ញាណគឺការដឹងកិច្ចដែលគួរធ្វើយ៉ាងនេះថា ទុក្ខគួរកំណត់ដឹង សមុទយៈគួរលះ និរោធគួរធ្វើឲ្យជាក់ច្បាស់ មគ្គគួរចម្រើន ឈ្មោះថា កិច្ចញ្ញាណ ។ ញាណគឺការដឹងដល់ភាព ដែលកិច្ចនោះបានធ្វើហើយយ៉ាងនេះថា ទុក្ខកំណត់ដឹងហើយ សមុទយៈលះបានហើយ និរោធធ្វើឲ្យជាក់ច្បាស់ហើយ មគ្គចម្រើនហើយ ឈ្មោះថា កតញ្ញាណ ។

បទថា **ទ្វាទសាការំ** ឈ្មោះថា **ទ្វាទសាការ** ព្រោះមានអាការ ១២ ដោយអំណាចនៃអាការនីមួយៗ ៣ ក្នុងសច្ចៈនីមួយៗនៃសច្ចៈទាំងនោះ ។ បទថា **ញាណទស្សនំ** បានដល់ ទស្សនៈ គឺញាណដែលកើតឡើងដោយអំណាចនៃសច្ចៈទាំងនោះ មានបរិវដ្ដ ៣ មានអាការ ១២ ។ បទថា **អត្តមនា** បានដល់ មានចិត្តជារបស់ខ្លួន ។ ពិតណាស់ អ្នកមានចិត្តប្រកបដោយបីតិសោមនស្ស ឈ្មោះថា មានចិត្តជារបស់ខ្លួន ។ ព្រោះ

សត្វទាំងឡាយប្រាថ្នាសេចក្ដីសុខ ស្អប់ទុក្ខ អធិប្បាយថា មានចិត្តជារបស់ខ្លួន មានចិត្តកាន់យកហើយ មានចិត្តឆ្អែតហើយដោយបីតិនិងសោមនស្ស ។ បទថា **អភិឆន្ទំ** បានដល់ បែរមុខចូលទៅរក ហើយត្រេកអរក្រៃលែង ។ បទថា **វេយ្យាករណស្មឹ** បានដល់ ព្រះសូត្រដែលមិនមានគាថា ក្នុងព្រះសូត្រ ឈ្មោះថា វេយ្យាករណ៍ ព្រោះធ្វើឲ្យជាក់ច្បាស់អត្ថតែម្យ៉ាង ។ បទថា **ភញ្ញមានេ** បានដល់ កំពុងត្រាស់ ។ ទ្រង់ធ្វើពាក្យបច្ចុប្បន្នជិតបច្ចុប្បន្ន បានដល់ កំពុងត្រាស់ ។ បទថា **វិរជំ** បានដល់ ប្រាសចាកធូលី មានរាគៈជាដើម ។ បទថា **វីតមលំ** បានដល់ ប្រាសចាកមន្ទិលមានរាគៈជាដើម ព្រោះរាគៈជាដើមឈ្មោះថា ធូលី ព្រោះអត្ថថា គ្របសង្កត់ ឈ្មោះថា មន្ទិល ព្រោះអត្ថថា ប្រទូស្ត ។ បទថា **ធម្មចក្ខុំ** ក្នុងទីខ្លះបានដល់ មគ្គញាណទី ១ ក្នុងទីខ្លះបានដល់ មគ្គញាណ ៣ ខាងដើម ក្នុងទីខ្លះបានដល់ សូម្បីមគ្គញាណទី ៤ តែក្នុងទីនេះ បានដល់ មគ្គញាណទី ១ ប៉ុណ្ណោះ ។

បទថា **យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ** អធិប្បាយថា ធម្មចក្ខុកើតឡើង ដល់ព្រះកោណ្ឌញ្ញៈ ដែលប្រព្រឹត្តទៅយ៉ាងនេះ ដោយអំណាចនៃវិបស្សនា ។ បទថា **ធម្មចក្កេ** បានដល់ បដិវេធញ្ញាណ និងទេសនាញាណ ។ ពិតណាស់ បដិវេធញ្ញាណដែលមានអាការ ១២ ក្នុងសច្ចៈ ៤ របស់ព្រះមានព្រះភាគដែលគង់នៅលើពោធិបល្ល័ង្កក្ដី ទេសនាញាណមានអាការ ១២ ដែលប្រព្រឹត្តទៅហើយ ក្នុងការសម្ដែងសច្ចៈរបស់

ព្រះមានព្រះភាគ ដែលប្រថាប់គង់ត្រង់ឥសិបតនមិគទាយវ័នក្តី ឈ្មោះថា ធម្មចក្ក ទាំងពីរយ៉ាងនោះ ក៏ជាញាណដែលប្រព្រឹត្តទៅដល់ព្រះទសពល នោះឯង ។ ធម្មចក្កនោះ ឈ្មោះថា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ សម្តែងដោយទេសនានេះឲ្យប្រព្រឹត្តទៅហើយ ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់ប្រកាសធម្មចក្កនេះ អស់កាលដែលព្រះអញ្ញាកោណ្ឌញ្ញត្ថេរ មួយអន្លើ ដោយព្រហ្ម ១៨ កោដិ មិនទាន់តាំងនៅក្នុងសោតាបត្តិផល តែកាល ព្រះអញ្ញាកោណ្ឌញ្ញៈតាំងនៅក្នុងសោតាបត្តិផលហើយ ទើបធម្មចក្ក ឈ្មោះ ថា ទ្រង់ប្រកាសហើយ ។ លោកសំដៅដល់ហេតុនោះ ទើបពោលថា **បវត្តិតេ ច ភគវតា ធម្មចក្កេ** ដូច្នេះ ។

បទថា **ភុម្មា ទេវា** បានដល់ ទេវតាដែលនៅលើផែនដី ។ បទថា **សទ្ទមនុស្សាវេសុំ** បានដល់ ភុម្មទេវតាឲ្យសាធុការ ជាសំឡេងតែមួយដូច គ្នា ហើយប្រកាសកងរំពងថា **ឯតំ ភគវតា** ជាដើម ។ បទថា **អប្ប-ដិវត្តិយំ** បានដល់ មិនអាចជំទាស់បានថា នេះមិនជាយ៉ាងនោះ ។ ម្យ៉ាង ទៀត ក្នុងបទនេះគប្បីជ្រាបថា ទេវតានិងព្រហ្មទាំងឡាយប្រជុំគ្នា ពេល ចប់ទេសនាបានឲ្យសាធុការជាសំឡេងតែមួយ តែភុម្មទេវតាជាដើម មិន ទាន់មកប្រជុំ លុះបានស្តាប់សំឡេងទេវតានិងព្រហ្មនោះៗ ទើបបានឲ្យសា-ធុការ ។ ក្នុងទេវតាទាំងនោះ ភុម្មទេវតាកើតត្រង់ភ្នំនិងដើមឈើជាដើម ។ សូម្បីភុម្មទេវតាទាំងនោះ នឹងរាប់បញ្ចូលទៅក្នុងពួកទេវតាជាន់ចាតុម្មហារា-ជិកា លោកក៏ពោលធ្វើឲ្យផ្សេងគ្នាក្នុងបទនេះ ។ បទថា **ចាតុម្មហារា-**

**ជិកា** ឈ្មោះថា ចាតុម្មហារាជិកៈ ព្រោះមានទេវតាដែលជាធំ ៤ អង្គ គឺព្រះបាទធតរដ្ឋៈ ១ ព្រះបាទវិរុឡ្ហកៈ ១ ព្រះបាទវិរូបក្ខៈ ១ ព្រះបាទកុវេរៈ ១ ។ ទេវតាទាំងនោះ ឋិតនៅត្រង់ពាក់កណ្តាលភ្នំសិនេរុ ( មិននៅលើកំពូលភ្នំ ) ទេវតាទាំងនោះឋិតនៅលើភ្នំក៏មាន នៅលើអាកាសក៏មាន ។ ទេវតាទាំងនោះនៅបន្តគ្នា ទៅរហូតដល់ភ្នំកណ្តាប់ចក្កវាឡ ។ ទេវតាទាំងអស់នេះគឺ ខិឌ្ឌាបទោសិកា មនោបទោសិកា សីតវលាហកា ឧណ្ហវលាហកា ចន្ទិមទេវបុត្ត សុរិយទេវបុត្ត ក៏ជាទេវតាប្រតិស្ឋាននៅក្នុងទេវលោកជាន់ចាតុម្មហារាជិកានោះឯង ។ ឈ្មោះថា **តាវតឹសា** ព្រោះមានជន ៣៣ នាក់ កើតក្នុងទេវលោកនោះ ។ ម្យ៉ាងទៀត លោកពោលថា ឈ្មោះថា **តាវតឹសា** ជាឈ្មោះរបស់ទេវតាទាំងនោះ សូម្បីទេវតាទាំង នោះប្រតិស្ឋានលើភ្នំក៏មាន លើអាកាសក៏មាន ។

ទេវតាទាំងនោះរស់នៅជាប់តគ្នាទៅរហូតដល់កណ្តាប់ចក្កវាឡ ឯទេវតាជាន់យាមាជាដើម ក៏យ៉ាងនោះ ។ ក្នុងទេវលោកមួយ ទេវតាទាំងឡាយដែលរស់នៅបន្តគ្នាទៅ មិនដល់ភ្នំកណ្តាប់ចក្កវាឡមិនមាន ។

ឈ្មោះថា **យាមា** ព្រោះទៅ ទៅដល់ ដល់ព្រមនូវសុខដែលជាទិព្វ ។ ឈ្មោះថា **តុសិតា** ព្រោះត្រេកអររីករាយ ។ ឈ្មោះថា **និម្មានរតី** ព្រោះនិម្មិតហើយ និម្មិតទៀត ត្រេកអរក្នុងសម្បត្តិតាមគាប់ចិត្ត ក្នុងវេលាប្រាថ្នា និងត្រេកអរដោយចំណែកពិសេស ចាកអារម្មណ៍ដែលតាក់តែងទុកតាមប្រក្រតី ។ ឈ្មោះថា **បរនិម្មិតវសវត្តី** ព្រោះធ្វើអំណាចឲ្យប្រព្រឹត្តទៅក្នុង

សម្បត្តិដែលអ្នកដទៃដឹងវារៈចិត្ត ហើយនិម្មិតឲ្យ ។ ឈ្មោះថា **ព្រហ្មកា-យិកា** ព្រោះរាប់បញ្ចូលក្នុងព្រហ្មកាយក្នុងពួកព្រហ្ម ។ សូម្បីព្រហ្មដែលមានខន្ធ ៥ ទាំងអស់ លោកក៏កាន់យកផងដែរ ។

បទថា **តេន ខណេន** លោកពោលឲ្យវិសេស ចេញទៅថា **តេន មុហុត្តេន** មានអធិប្បាយថា ដោយខណៈ គឺមួយរំពេច មិនមែនខណៈដោយបរមត្ថ ។ បទថា **យាវ ព្រហ្មលោកា** បានដល់ ធ្វើព្រហ្មលោកឲ្យជាទីបំផុត ។ បទថា **សទ្ទោ** បានដល់ សំឡេងសាធុការ ។ បទថា **ទស-សហស្សី** បានដល់ មានម៉ឺនចក្កវាឡ ។ បទថា **សង្កម្បិ** បានដល់ កក្រើកញាប់ញ័រឡើងទៅខាងលើដោយល្អ ។ បទថា **សម្បកម្បិ** បានដល់ រំពើកញាប់ញ័រឡើងទៅខាងលើ ចុះមកក្រោមដោយល្អ ។ បទថា **សម្ប-វេធិ** បានដល់ ញាប់ញ័រទៅកាន់ទិសទាំង ៤ ដោយល្អ ។

កាលព្រះពោធិសត្វទ្រង់យាងចុះកាន់ព្រះឧទរនៃព្រះមាតា ដើម្បីភាពជាព្រះសម្មាសម្ពុទ្ធ និងកាលប្រសូតចាកព្រះឧទរព្រះមាតានោះ មហាប្រឹថពីបានញាប់ញ័រដោយតេជៈនៃបុណ្យ ក្នុងកាលត្រាស់ដឹងបានញាប់ញ័រដោយតេជៈនៃបដិវេធញ្ញាណ ។ ក្នុងកាលប្រកាសព្រះធម្មចក្ក ផែនដីបានញាប់ញ័រដោយទេវានុភាព ដូចឲ្យសាធុការដោយតេជៈនៃទេសនាញាណ ក្នុងកាលទ្រង់ដាក់អាយុសង្ខារនិងក្នុងកាលមហាបរិនិព្វាន ផែនដីញាប់ញ័រដោយទេវានុភាពដូចអត់ធន់ក្នុងការរំភើបចិត្តមិនបាន ដោយសេចក្ដីករុណា ។ បទថា **អប្បមាណោ** បានដល់ មានប្រមាណចម្រើនហើយ ។ បទថា **ឧឡា-**

**ភោ** លោកពោលថា **ឧឡារ** មកក្នុងអត្ថថា ឆ្ងាញ់ ដូចក្នុងប្រយោគជាដើមថា **ឧឡារានិ ឧឡារានិ ខាទនីយានិ ខាទន្តិ** បួនកាលទំពាស៊ីនូវខាទនីយៈទាំងឡាយដ៏ឧត្តមក្រៃលែង ។ លោកពោលថា **ឧឡារ** មកក្នុងអត្ថថាប្រណីត ដូចក្នុងប្រយោគជាដើមថា **ឧឡារាយ វត្ថភោគាយ ចិត្តំ ន នមតិ** ចិត្តមិនឱនទៅដើម្បីប្រើប្រាស់នូវសំពត់ដ៏ថ្លៃថ្លា ។ លោកពោលថា **ឧឡារ** មកក្នុងអត្ថថា ប្រសើរ ដូចក្នុងប្រយោគជាដើមថា **ឧឡារាយ ខលុ ភវំ វច្ឆាយនោ សមណំ គោតមំ បសំសាយ បសំសតិ** ម្តេចក៏វច្ឆាយនៈដ៏ចម្រើន ពោលសរសើរព្រះសមណគោតម ដោយពាក្យសរសើរដ៏ខ្ពង់ខ្ពស់ដល់ម្ល៉េះ ។ តែក្នុងទីនេះលោកពោលថា **ឧឡារ** ដោយអត្ថថា បរិបូរ ។

បទថា **ឱភាសោ** បានដល់ ពន្លឺកើតដោយអានុភាពនៃទេសនាញាណនិងទេវានុភាព ។ បទថា **លោកេ** បានដល់ ក្នុងម៉ឺនចក្កវាឡនោះឯង ។

បទថា **អតិក្កម្មេវ ទេវានំ ទេវានុភាវំ** បានដល់ អានុភាពរបស់ទេវតាទាំងឡាយប្រាកដដូច្នេះ រស្មីសំពត់ដែលស្លៀក ផ្សាយទៅ ១២ យោជន៍ អានុភាពរបស់សរីរៈ គ្រឿងប្រដាប់និងវិមានក៏យ៉ាងនោះ ពន្លឺឈានកន្លងទេវានុភាពរបស់ទេវតាទាំងឡាយ ។ បទថា **ឧទានំ** បានដល់ព្រះតម្រាស់ដែលបន្លឺចេញមកសម្រេចដោយសោមនស្សញ្ញាណ ។ បទថា **ឧទានេសិ** បានដល់ ទ្រង់បន្លឺ ។

ព្រះសូរសៀងដែលបន្លឺឧទាននេះថា **អញ្ញាសិ វត ភោ កោណ្ឌញ្ញោ**

ផ្សាយទៅអស់ម៉ឺនលោកធាតុ ។ បទថា **អញ្ញាកោណ្ឌញ្ញោ** សេចក្ដីថា កោណ្ឌញ្ញៈ ត្រាស់ដឹងហើយយ៉ាងប្រសើរ ។

[ ៧៣-៧៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឧស្បនដ្ឋេន** ជាដើម ក្នុងនិទ្ទេសនៃចក្ខុជាដើមដូចតទៅនេះថា ញាណមួយនោះឯង ឈ្មោះថា **ចក្ខុ** ព្រោះធ្វើកិច្ចដោយការឃើញ ដូចចក្ខុរបស់សត្វដែលគប្បីណែនាំ តាមដែលបានពោលហើយ ។ ឈ្មោះថា **ញាណ** ព្រោះធ្វើកិច្ច ដោយញាណ ។ ឈ្មោះថា **បញ្ញា** ព្រោះធ្វើកិច្ចដឹងដោយប្រការផ្សេង ៗ ។ ឈ្មោះថា **វិជ្ជា** ព្រោះធ្វើការចាក់ធ្លុះដោយមិនមានចំណែកសល់ ។ ឈ្មោះថា **អាលោកោ** ព្រោះធ្វើកិច្ចដោយពន្លឺ ក្នុងកាលទាំងពួង ។

សូម្បីក្នុងបទថា **ចក្ខុំ ធម្មោ** ជាដើម មានសេចក្ដី ដូចតទៅនេះថា ញាណមួយនោះឯង លោកពណ៌នាទុកដោយ ៥ ចំណែក ដោយសេចក្ដីផ្សេងគ្នានៃកិច្ច ។

ឈ្មោះថា **អារម្មណា** ដោយអត្ថថា ឧបត្ថម្ភ ។ ឈ្មោះថា **គោចរា** ដោយអត្ថថា ជាអារម្មណ៍ ។ ក្នុងបទថា **ឧស្បនដ្ឋេន** ជាដើមលោកពោលដល់ញាណកិច្ច ទុកដោយ ៥ ប្រការ ។

ដោយន័យនេះ ធម៌មាន ១៥ អត្ថមាន ១៥ ដោយធ្វើនីមួយៗ ៥ ក្នុងវារៈនីមួយៗ ក្នុង ៣ វារៈ[១] និរុត្តិមាន ៣០ ក្នុងធម៌ ១៥ ក្នុងអត្ថ ១៥ ទាំងពីរ ។ គប្បីជ្រាបញាណ ៦០ គឺក្នុងធម៌ ១៥ ក្នុងអត្ថ ១៥ ក្នុងនិរុត្តិ

១-ញាណ ៣ វារ□គឺសច្ចញាណ□ កិច្ចញាណ□ កតញាណ□ ។

៣០ ។ ក្នុងអរិយសច្ចៈដ៏សេស ក៏មានន័យនេះដូចគ្នា ។ ធម៌មាន ៦០ អត្ថមាន ៦០ ដោយអំណាចនៃធម៌ និងអត្ថនីមួយ ៗ ១៥ ក្នុងអរិយសច្ចៈនីមួយ ៗ ក្នុងអរិយសច្ចៈ ៤ ។ និរុត្តិមាន ១២០ ក្នុងធម៌ ៦០ និងក្នុងអត្ថ ៦០ មានអធិប្បាយថា ១០០ លើស ២០ ។ ញាណ ២៤០ យ៉ាងនេះ គឺក្នុងធម៌ ៦០ ក្នុងអត្ថ ៦០ ក្នុងនិរុត្តិ ១២០ ។

## អដ្ឋកថាធម្មចក្កប្បវត្តនវារៈ ចប់

# អដ្ឋកថា
# សតិប្បដ្ឋានវារជាដើម

[ ៧៦-៧៨ ] គប្បីជ្រាបអត្ថនិងការរាប់ដោយន័យនេះឯងក្នុងបដិសម្ភិ-ទានិទ្ទេស ដែលមានសតិប្បដ្ឋានសូត្រនិងឥទ្ធិបាទសូត្រជាបទនាំ ។

*អដ្ឋកថា សតិប្បដ្ឋានវារជាដើម ចប់*

# អដ្ឋកថា

## សត្តពោជ្ឈង្គវារៈជាដើម

[ ៧៩ ] ក្នុងសូត្រនីមួយៗនៃសូត្រទាំងឡាយ របស់ព្រះពោធិសត្វ ៧ អង្គ មានធម៌ ១០ គឺក្នុងសមុទយៈមាន ៥ មានចក្ខុជាដើម ក្នុងនិរោធមាន ៥ ,មានអត្ថ ១០ គឺក្នុងសមុទយៈមាន ៥ មានការឃើញជាដើម ក្នុងនិរោធមាន ៥ និរុត្តិ ២០ ដោយអំណាចនៃធម៌ ១០ និងអត្ថ ១០ ញាណ ៤០ ។ ការរាប់ពោលធ្វើវេយ្យាករណភាសិត ៧ រួមគ្នាតែមួយ យល់បានងាយ ។

[ ៨០-៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបដិសម្ភិទានិទ្ទេសដែលលោកពោលហើយ ដោយអំណាចនៃព្រះសព្វញ្ញុតញ្ញាណ ដូចតទៅនេះថា ក្នុងមូលកៈនីមួយ ៗ ធម៌មាន ២៥ អត្ថមាន ២៥ ដោយអំណាចបញ្ចកៈ ៥ ពួក គឺធម៌ ៥ មានចក្ខុជាដើម អត្ថ ៥ មានការឃើញជាដើម ក្នុងពាក្យនីមួយៗក្នុង ៥ ពាក្យទាំងនេះ គឺដឹងហើយ ១ ឃើញហើយ ១ ជ្រាបហើយ ១ ធ្វើឲ្យជាក់ច្បាស់ហើយ ១ ពាល់ត្រូវហើយ ១ ដោយបញ្ញា យក ២៥ នោះគុណនឹង ២ ទើបនិរុត្តិមាន ៥០ យក ៥០ នោះ គុណនឹង ២ ទើបញាណមាន ១០០ ក្នុងវារៈដែលពោលធ្វើមូលកៈ ៥ រួមគ្នាតែមួយ ធម៌មាន ១២៥ អត្ថមាន ១២៥ ដោយធ្វើ ២៥ ឲ្យជា ៥ ដង យក

១២៥ នោះគុណនឹង ២ ទើបនិរុត្តិមាន ២៥០ យក ២៥០ នោះគុណនឹង ២ ទើបញាណមាន ៥០០ ។

បទថា **អឌ្ឍតេយ្យានិ** បានដល់ មាននិរុត្តិ ២០០ និង ៥០ ។ សូម្បី ខន្ធជាដើម ក៏មានន័យនេះដូចគ្នា ។ គប្បីជ្រាបការរាប់ធម៌ជាដើមក្នុងសច្ចៈ-វារៈនិងបដិសម្ភិទាវារៈ ដោយន័យនេះឯង ។

## អដ្ឋកថា ពោធិសត្តវារជាដើម ចប់

# អដ្ឋកថា

## ចតុទ្ទធម្មវារ

[ ៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចតុទ្ទធម្មវារៈ ដូចតទៅនេះថា បទថា **និយ្យានស្សតំ** បានដល់ ២៥ ប្រាំមួយដង ជាធម៌ ១៥០ យក ១៥០ នោះគុណនឹង ២ ទើបនិរុត្តិមាន ៣០០ យក ៣០០ គុណនឹង ២ ទើបញាណមាន ៦០០ ។ បទថា **បដិសម្ភិទាធិការណោ** បានដល់ ក្នុងអធិការពោលដោយបដិសម្ភិទា ។ បទថា **អដ្ឋនវធម្មសតានិ** បានដល់ មានធម៌ ៨៥០ គឺក្នុងសច្ចៈ ៤ ដែលពោលហើយដំបូងមាន ៦០ ក្នុងសតិប្បដ្ឋាន ៤ មាន ៦០ ក្នុងសម្មប្បធាន ៤ មាន ៦០ ក្នុងវេយ្យាករណភាសិត របស់ព្រះពោធិសត្វ ៧ អង្គមាន ៧០ ក្នុងធម៌ ៥ មានអត្ថថា **អភិញ្ញដ្ឋ** ( អត្ថនៃអភិញ្ញា ) ជាដើម មាន ១២៥ ក្នុងធម៌ ៥ មានខន្ធជាដើម មាន ១២៥ ក្នុងអរិយសច្ចៈ ៤ ដដែលទៀត មាន ១០០ ក្នុងបដិសម្ភិទា ៤ មាន ១០០ ក្នុងពុទ្ធធម៌ ៦ មាន ១៥០ ។

ដោយប្រការនេះ សូម្បីអត្ថក៏មានចំនួនប៉ុណ្ណោះដូចគ្នា ។ ដោយប្រការនេះឯង និរុត្តិ មាន ១៧០០ យ៉ាងនេះ គឺក្នុងឋានៈ ៣ មានសច្ចៈជាដើម មាននិរុត្តិនីមួយៗ ១២០ ក្នុងវេយ្យាករណភាសិត ៧ មាននិរុត្តិ ១៤០ ក្នុងអត្ថនៃអភិញ្ញាជាដើម និងក្នុងអត្ថនៃខន្ធជាដើម មាននិរុត្តិនីមួយ ៗ ២៥០ ក្នុងអរិយសច្ចៈ និងក្នុងបដិសម្ភិទា មាននិរុត្តិនីមួយៗ ២០០ ក្នុងពុទ្ធធម៌មាននិរុត្តិ ៣០០ ។ ដោយប្រការនេះឯង ញាណមាន ៣៤០០ យ៉ាងនេះ គឺ

ក្នុងឋានៈ ៣ មានសច្ចៈជាដើម មានញាណនីមួយ ៗ ២៤០ ក្នុងវេយ្យាករណភាសិត ៧ មានញាណ ២៨០ ក្នុងអត្ថនៃអភិញ្ញាជាដើម និងក្នុងអត្ថនៃខន្ធជាដើម មានញាណនីមួយ ៗ ៥០០ ក្នុងសច្ចៈនិងក្នុងបដិសម្ភិទា មានញាណនីមួយ ៗ ៤០០ ក្នុងពុទ្ធធម៌ មានញាណ ៦០០ ។

**អដ្ឋកថា ធពុទ្ធធម្មវារ ចប់**

**អដ្ឋកថា បដិសម្ភិទាកថា ចប់**

# សុត្តន្តបិដក

## យុគនទ្ធវគ្គ ធម្មចក្កកថា

[ ៨៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅទៀបក្រុងពារាណសី ។បេ។ ហេតុនោះ ពាក្យថា អញ្ញាកោណ្ឌញ្ញៈនេះ បានមកជាឈ្មោះរបស់ព្រះកោណ្ឌញ្ញៈមានអាយុ ។

ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខអរិយសច្ច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ញាណកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថា ឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថា ដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថា ដឹងច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថា ចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថា ភ្លឺស្វាង ។

ចក្ខុជាធម៌ សេចក្តីនៃការឃើញជាអត្ថ ញាណជាធម៌ សេចក្តីនៃការដឹងជាអត្ថ បញ្ញាជាធម៌ សេចក្តីនៃការដឹងច្បាស់ជាអត្ថ វិជ្ជាជាធម៌ សេចក្តីនៃការចាក់ធ្លុះជាអត្ថ ពន្លឺជាធម៌ សេចក្តីនៃការភ្លឺស្វាងជាអត្ថ នេះឯងធម៌ទាំង ៥ អត្ថទាំង ៥ ដែលមានទុក្ខជាទីតាំង មានសច្ចៈជាទីតាំង មានសច្ចៈជាអារម្មណ៍ មានសច្ចៈជាគោចរ សង្គ្រោះចូលក្នុងសច្ចៈ រាប់ចូល

ក្នុងសច្ចៈ រួបរួមចូលក្នុងសច្ចៈ ឋិតនៅក្នុងសច្ចៈ តាំងនៅស៊ប់ក្នុងសច្ចៈ ។

[ ៨៦ ] សំណួរត្រង់ពាក្យថាធម្មចក្រ តើធម្មចក្រដោយអត្ថដូចម្តេច ។ ឈ្មោះថា ធម្មចក្រ ព្រោះព្រះមានព្រះភាគទ្រង់ញ៉ាំងធម៌និងចក្រឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងចក្រនិងធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យតាំងនៅស៊ប់ក្នុងធម៌ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ដល់នូវការស្ទាត់ក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យដល់នូវការស្ទាត់ក្នុងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ដល់នូវបារមីក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យដល់នូវបារមីក្នុងធម៌ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ដល់នូវសេចក្តីក្លាហានក្នុងធម៌ ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យដល់នូវសេចក្តីក្លាហានក្នុងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ ធ្វើសក្ការៈចំពោះធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ ធ្វើសេចក្តីគោរពចំពោះធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់រាប់អានធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់បូជាធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់កោត

ក្រែងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់មានទង់ជ័យគឺធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងទង់ជ័យគឺធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ជាអធិបតីហេតុធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះធម្មចក្រនោះ បុគ្គលទីមួយក្នុងលោក ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី មិនអាចធ្វើបដិវត្តបានឡើយ ឈ្មោះថា ធម្មចក្រ ព្រោះសទ្ធិន្ទ្រិយជាធម៌ទ្រង់ ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះវីរិយិន្ទ្រិយជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសតិន្ទ្រិយជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសមាធិន្ទ្រិយជាធម៌ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះបញ្ញិន្ទ្រិយជាធម៌ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសទ្ធាពលៈជាធម៌ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះវីរិយពលៈជាធម៌ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសតិពលៈជាធម៌ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសមាធិពលៈជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះបញ្ញាពលៈជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសតិសម្ពោជ្ឈង្គជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះធម្មវិចយសម្ពោជ្ឈង្គជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះវីរិយសម្ពោជ្ឈង្គជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅឈ្មោះ

ថា ធម្មចក្រ ព្រោះបីតិសម្ពោជ្ឈង្គជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះបស្សទ្ធិសម្ពោជ្ឈង្គជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រ-ព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសមាធិសម្ពោជ្ឈង្គជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះឧបេក្ខាសម្ពោជ្ឈង្គជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសម្មាទិដ្ឋិជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសម្មាសង្កប្បៈជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសម្មាវាចាជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសម្មាកម្មន្តៈជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសម្មាអាជីវៈជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសម្មា-វាយាមៈជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសម្មាសតិជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសម្មាសមាធិជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្ម-ចក្រ ព្រោះឥន្ទ្រិយដោយអត្ថថាជាអធិបតីជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រ-ព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះពលៈដោយអត្ថថាមិនកម្រើកជាធម៌ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះពោជ្ឈង្គៈដោយអត្ថថាចេញ ( ចាកវដ្តៈ ) ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះមគ្គដោយអត្ថថាជាហេតុជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសតិប្បដ្ឋានដោយអត្ថថាប្រុងប្រយ័ត្នជាធម៌

ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសម្មប្បធាន ដោយអត្ថថាតម្កល់ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះឥទ្ធិបាទ ដោយអត្ថថាសម្រេចជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសច្ចៈដោយអត្ថថាពិតជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសមថៈដោយអត្ថថាមិនរាយមាយជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះវិបស្សនាដោយអត្ថថាពិចារណាឃើញជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះសមថៈនិងវិបស្សនាដោយអត្ថថាមានរសតែមួយជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះការជាប់គ្នាជាគូដោយអត្ថថាមិនប្រព្រឹត្តលើសគ្នាជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសីលវិសុទ្ធិដោយអត្ថថាសង្រួមជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះចិត្តវិសុទ្ធិដោយអត្ថថាមិនរាយមាយជាធម៌ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទិដ្ឋិវិសុទ្ធិដោយអត្ថថា ឃើញជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះវិមោក្ខដោយអត្ថថារួចជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះវិជ្ជាដោយអត្ថថាចាក់ធ្លុះជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះវិមុត្តិដោយអត្ថថាលះបង់ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះខយញ្ញាណដោយអត្ថថាកាត់ផ្ដាច់ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះ

អនុប្បាទញ្ញាណ ដោយអត្ថថាស្ងប់ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះឆន្ទៈដោយអត្ថថាជាឫសជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះមនសិការៈដោយអត្ថថាកើតឡើងព្រមជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះផស្សៈដោយអត្ថថារួបរួមជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះវេទនាដោយអត្ថថាប្រជុំចុះជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសមាធិដោយអត្ថថាជាប្រមុខជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះសតិដោយអត្ថថាជា អធិបតីជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះបញ្ញាដោយអត្ថថាក្រៃលែងជាងធម៌ទាំងនោះជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះវិមុត្តិដោយអត្ថថាជាខ្លឹមជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះអមតនិព្វានដោយអត្ថថាជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ។

[ ៨៧ ] ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះជាទុក្ខអរិយសច្ច ដែលតថាគតគួរកំណត់ដឹង ។បេ។ ថា នេះជាទុក្ខអរិយសច្ច ដែលតថាគតកំណត់ដឹងហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ។បេ។ ពាក្យថាពន្លឺកើតហើយដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថា ឃើញ ។បេ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថា ភ្លឺស្វាង ។

*ចក្ខុជាធម៌ សេចក្តីនៃការឃើញជាអត្ថ ។បេ។ ពន្លឺជាធម៌ សេចក្តីនៃការណ៍ភ្លឺស្វាងជាអត្ថ ធម៌ទាំង ៥ អត្ថទាំង ៥ នេះ មានទុក្ខជាទីតាំង មានសច្ចៈជាទីតាំង មានសច្ចៈជាអារម្មណ៍ មានសច្ចៈជាគោចរ សង្គ្រោះចូលក្នុងសច្ចៈ រាប់បញ្ចូលក្នុងសច្ចៈ រួបរួមចូលក្នុងសច្ចៈ ឋិតនៅក្នុងសច្ចៈ តាំងនៅស៊ប់ក្នុងសច្ចៈ ។*

*សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្តេច ។ ឈ្មោះថា ធម្មចក្រ ព្រោះព្រះមានព្រះភាគទ្រង់ញ៉ាំងធម៌និងចក្រឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងចក្រនិងធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ។បេ។ ឈ្មោះថា ធម្មចក្រ ព្រោះអមតនិព្វានដោយអត្ថថា ជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ។*

*[ ៨៨ ] ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខសមុទយអរិយសច្ច ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះជាទុក្ខសមុទយអរិយសច្ច ដែលតថាគតគួរលះបង់ ។បេ។ ថា នេះជាទុក្ខសមុទយអរិយសច្ច ដែលតថាគតលះបង់ហើយ ។ ពាក្យថា ចក្ខុកើតហើយ*

ដោយអត្ថដូចម្តេច ។បេ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថា ឃើញ ។បេ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថា ភ្លឺស្វាង ។

ចក្ខុជាធម៌ សេចក្តីនៃការឃើញជាអត្ថ ។បេ។ ពន្លឺជាធម៌ សេចក្តីនៃការណ៍ភ្លឺស្វាងជាអត្ថ ធម៌ទាំង ៥ អត្ថទាំង ៥ នេះ មានសមុទ័យជាទីតាំង មានសច្ចៈជាទីតាំង ។បេ។ មាននិរោធជាទីតាំង មានមគ្គជាទីតាំង មានសច្ចៈជាទីតាំង មានសច្ចៈជាអារម្មណ៍ មានសច្ចៈជាគោចរ សង្គ្រោះចូលក្នុងសច្ចៈ រាប់បញ្ចូលក្នុងសច្ចៈ រួបរួមចូលក្នុងសច្ចៈ ឋិតនៅក្នុងសច្ចៈ តាំងនៅស៊ប់ក្នុងសច្ចៈ ។

សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្តេច ។ ឈ្មោះថា ធម្មចក្រ ព្រោះព្រះមានព្រះភាគទ្រង់ញុំាងធម៌និងចក្រឲ្យប្រព្រឹត្តទៅ ឈ្មោះថាធម្មចក្រ ព្រោះទ្រង់ញុំាងចក្រនិងធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ។បេ។ ឈ្មោះថា ធម្មចក្រ ព្រោះអមតនិព្វានដោយអត្ថថា ជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) ជាធម៌ ទ្រង់ញុំាងធម៌នោះឲ្យប្រព្រឹត្តទៅ ។

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។

មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះកាយេកាយានុបស្សនា ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះកាយេកាយានុបស្សនា ដែលតថាគតគួរចម្រើន ។បេ។ ថា នេះកាយេកាយានុបស្សនា ដែលតថាគតចម្រើនហើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះវេទនាសុវេទនានុបស្សនា ។បេ។ ថា នេះចិត្តេចិត្តានុបស្សនា ។បេ។ ថា នេះធម្មេសុធម្មានុបស្សនា ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះធម្មេសុធម្មានុបស្សនា ដែលតថាគតគួរចម្រើន ។បេ។ ថា នេះធម្មេសុធម្មានុបស្សនា ដែលតថាគតចម្រើនហើយ ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮ ក្នុងកាលមុនថា នេះកាយេកាយានុបស្សនា ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះកាយេកាយានុបស្សនាដែលតថាគតគួរចម្រើន ។បេ។ ថា នេះកាយេកាយានុបស្សនា ដែលតថាគតចម្រើនហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ។បេ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថាដូចម្តេច ។បេ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថា ឃើញ ។បេ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថា ភ្លឺស្វាង ។

ចក្ខុជាធម៌ សេចក្ដីនៃការឃើញជាអត្ថ ។បេ។ ពន្លឺជាធម៌ សេចក្ដីនៃការណ៍ភ្លឺស្វាងជាអត្ថ ធម៌ទាំង ៥ អត្ថទាំង ៥ នេះ មានកាយជាទីតាំង មានសតិប្បដ្ឋានជាទីតាំង ។បេ។ មានវេទនាជាទីតាំង មានសតិប្បដ្ឋានជាទីតាំង មានចិត្តជាទីតាំង មានសតិប្បដ្ឋានជាទីតាំង មានធម៌ជាទីតាំង មានសតិប្បដ្ឋានជាទីតាំង មានសតិប្បដ្ឋានជាអារម្មណ៍ មានសតិប្បដ្ឋានជាគោចរ សង្គ្រោះចូលក្នុងសតិប្បដ្ឋាន រាប់បញ្ចូលក្នុងសតិប្បដ្ឋាន រួបរួមចូលក្នុងសតិប្បដ្ឋាន ឋិតនៅក្នុងសតិប្បដ្ឋាន តាំងនៅស៊ប់ក្នុងសតិប្បដ្ឋាន ។

សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្ដេច ។ ឈ្មោះថា ធម្មចក្រ ព្រោះព្រះមានព្រះភាគទ្រង់ញ៉ាំងធម៌និងចក្រឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងចក្រនិងធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌ហើយ ឲ្យប្រព្រឹត្តទៅ ។បេ។ ឈ្មោះថា ធម្មចក្រ ព្រោះអមតនិព្វានដោយអត្ថថា ជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ។

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ម្នាលភិក្ខុទាំងឡាយ តថា-

គតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ដែលតថាគតគួរចម្រើន ។បេ។ ថា នេះឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ដែលតថាគតចម្រើនហើយ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុកើតហើយ ។បេ។ មានពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយវិរិយសមាធិ ។បេ។ ថា នេះឥទ្ធិបាទប្រកបដោយចិត្តសមាធិ ។បេ។ ថា នេះឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ម្នាលភិក្ខុទាំងឡាយ តថាគតមានចក្ខុ កើតហើយ ។បេ។ មានពន្លឺកើតហើយ ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ដែលតថាគតគួរចម្រើន ។បេ។ ថា នេះឥទ្ធិបាទប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ដែលតថាគតចម្រើនហើយ ។

ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ចក្ខុកើតហើយ ញាណកើតហើយ បញ្ញាកើតហើយ វិជ្ជាកើតហើយ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ដែលតថាគតគួរចម្រើន ។បេ។ ថា នេះឥទ្ធិបាទប្រកបដោយឆន្ទសមាធិនិងបធានសង្ខារដែលតថាគតចម្រើនហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ពាក្យថា ញាណកើតហើយ

ដោយអត្ថដូចម្ដេច ពាក្យថា បញ្ញាកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថដូចម្ដេច ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្ដេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថា ឃើញ ពាក្យថា ញាណកើតហើយ ដោយអត្ថថា ដឹង ពាក្យថា បញ្ញាកើតហើយ ដោយអត្ថថា ដឹងច្បាស់ ពាក្យថា វិជ្ជាកើតហើយ ដោយអត្ថថា ចាក់ធ្លុះ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថា ភ្លឺស្វាង ។

ចក្ខុជាធម៌ សេចក្ដីនៃការឃើញជាអត្ថ ញាណជាធម៌ សេចក្ដីនៃការដឹងជាអត្ថ បញ្ញាជាធម៌ សេចក្ដីនៃការដឹងច្បាស់ជាអត្ថ វិជ្ជាជាធម៌ សេចក្ដីនៃការចាក់ធ្លុះជាអត្ថ ពន្លឺជាធម៌ សេចក្ដីនៃការណ៍ភ្លឺស្វាងជាអត្ថ ធម៌ទាំង ៥ អត្ថទាំង ៥ នេះមានធន្ទៈជាទីតាំង មានឥទ្ធិបាទជាទីតាំង មានឥទ្ធិបាទជាអារម្មណ៍ មានឥទ្ធិបាទជាគោចរ សង្គ្រោះចូលក្នុងឥទ្ធិបាទ រាប់បញ្ចូលក្នុងឥទ្ធិបាទ រួបរួមចូលក្នុងឥទ្ធិបាទ ឋិតនៅក្នុងឥទ្ធិបាទ តាំងនៅស៊ប់ក្នុងឥទ្ធិ-បាទ ។

សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្ដេច ។ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញុំាំងធម៌និងចក្រឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញុំាំងចក្រនិងធម៌ ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញុំាំងឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌

ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យតាំងនៅក្នុងធម៌ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ដល់នូវការស្ទាត់ក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វ ឲ្យដល់នូវការស្ទាត់ក្នុងធម៌ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ដល់នូវបារមីក្នុងធម៌ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងសត្វឲ្យដល់នូវបារមីក្នុងធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់កោតក្រែងចំពោះធម៌ ទើបឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់មានទទង់ជ័យ គឺធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញ៉ាំងទទង់ជ័យ គឺធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់មានធម៌ជាអធិបតី ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះធម្មចក្រ បុគ្គលណានីមួយក្នុងលោក ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី មិនអាចឲ្យប្រព្រឹត្តទៅបានទេ ឈ្មោះថា ធម្មចក្រ ព្រោះសទ្ធិន្ទ្រិយជាធម៌ ទ្រង់ញ៉ាំងធម៌នោះ ឲ្យប្រព្រឹត្តទៅ ។បេ។ ឈ្មោះថា ធម្មចក្រ ព្រោះអមតនិព្វាន ដោយអត្ថថា ជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) ជាធម៌ ទ្រង់ញ៉ាំងធម៌នោះឲ្យប្រព្រឹត្តទៅ ។

ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់

ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ថា នេះឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ដែលតថាគតគួរចម្រើន ចក្ខុកើតហើយ ។បេ។ ពន្លឺកើតហើយក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនថា នេះឥទ្ធិបាទប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ដែលតថាគតចម្រើនហើយ ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថដូចម្តេច ។បេ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថដូចម្តេច ។ ពាក្យថា ចក្ខុកើតហើយ ដោយអត្ថថា ឃើញ ។បេ។ ពាក្យថា ពន្លឺកើតហើយ ដោយអត្ថថា ភ្លឺស្វាង ។

ចក្ខុជាធម៌ សេចក្តីនៃការយល់ឃើញជាអត្ថ ។បេ។ ពន្លឺជាធម៌ សេចក្តីនៃការណ៍ភ្លឺស្វាងជាអត្ថ ធម៌ទាំង ៥ អត្ថទាំង ៥ នេះ មានវីរិយៈជាទីតាំង មានឥទ្ធិបាទជាទីតាំង ។បេ។ មានចិត្តជាទីតាំង មានឥទ្ធិបាទជាទីតាំង មានវីមំសាជាទីតាំង មានឥទ្ធិបាទជាទីតាំង មានឥទ្ធិបាទជាអារម្មណ៍ មានឥទ្ធិបាទជាគោចរ សង្គ្រោះចូលក្នុងឥទ្ធិបាទ រាប់បញ្ចូលក្នុងឥទ្ធិបាទ រួបរួមចូលក្នុងឥទ្ធិបាទ ឋិតនៅក្នុងឥទ្ធិបាទ តាំងនៅស៊ប់ក្នុងឥទ្ធិបាទ ។

សំណួរត្រង់ពាក្យថា ធម្មចក្រ តើធម្មចក្រ ដោយអត្ថដូចម្តេច ។ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ញុំាំងធម៌ និងចក្រឲ្យប្រព្រឹត្តទៅ ឈ្មោះថា

ធម្មចក្រ ព្រោះទ្រង់ញ៉ាំងចក្រ និងធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ ឲ្យប្រព្រឹត្តទៅដោយធម៌ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឲ្យប្រព្រឹត្តទៅដោយធម្មចរិយា ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់ឋិតនៅក្នុងធម៌ ហើយឲ្យប្រព្រឹត្តទៅ ឈ្មោះថា ធម្មចក្រ ព្រោះទ្រង់តាំងនៅស៊ប់ក្នុងធម៌ ហើយឲ្យប្រព្រឹត្តទៅ ។បេ។ ឈ្មោះថា ធម្មចក្រ ព្រោះអមតនិព្វានជាធម៌ ដោយអត្ថថា ជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) ទ្រង់ញ៉ាំងធម៌នោះឲ្យ ប្រព្រឹត្តទៅ ។

**ចប់ ធម្មចក្កកថា ។**

## អដ្ឋកថា

## ធម្មចក្កកថា

## អដ្ឋកថា សច្ចវារៈ

[ ៨៥ ] នឹងពណ៌នាតាមលំដាប់សេចក្តីដែលមិនទាន់បានពណ៌នា ទុកក្នុងធម្មចក្កកថា ដែលព្រះសារីបុត្តត្ថេរ ពោលធ្វើធម្មចក្កប្បវត្តនសូត្រឲ្យជាបទនាំទៀតតទៅ ។

ក្នុងបទទាំងនោះ បទថា **ទុក្ខវត្ថុកា** មានវិគ្គហៈថា ឈ្មោះថា ទុក្ខវត្ថុកៈ ព្រោះមានទុក្ខជាទីតាំង ដោយអំណាចនៃការត្រាស់ដឹងតែម្យ៉ាង ។ ព្រះសារីបុត្តត្ថេរ ញុំាងទុក្ខនោះឲ្យពិសេសថែមទៀត ទើបពោលពាក្យថា **សច្ចវត្ថុកា** ជាដើម ។ ឈ្មោះថា **សច្ចារម្មណា** ព្រោះមានសច្ចៈជាអារម្មណ៍ ជាតួឧបត្ថម្ភ ។ ឈ្មោះថា **សច្ចគោចរា** ព្រោះមានសច្ចៈជាគោចរ ជាវិស័យ ។ បទថា **សច្ចសង្គហិតា** បានដល់ សង្គ្រោះដោយមគ្គសច្ច ។ បទថា **សច្ចបរិយាបន្នា** បានដល់ រាប់ចូលក្នុងមគ្គសច្ចៈ ។ បទថា **សច្ចេ សមុទាគតា** បានដល់ កើតរួមគ្នាក្នុងទុក្ខសច្ចៈ ដោយកំណត់ដឹងទុក្ខ ។ បទថា **ឋិតា បតិដ្ឋិតា** ក្នុងសច្ចៈនោះ ក៏យ៉ាងនោះឯង ។

[ ៨៦ ] ឥឡូវនេះព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងធម្មចក្ក ដែលពោលថា **បវត្តិតេ ច ភគវតា ធម្មចក្កេ** ដូច្នេះ ទើបពោលពាក្យថា **ធម្មចក្កំ** ជាដើម ។ ក្នុងបទថា **ធម្មចក្កំ** នោះធម្មចក្កមាន ២ យ៉ាងគឺ បដិវេធធម្មចក្កនិងទេសនាធម្មចក្ក ។ បដិវេធធម្មចក្កកើតឡើងត្រង់ពោធិ-

បល្ល័ង្ក ទេសនាធម្មចក្កកើតឡើងត្រង់ឥសិបតនមិគទាយវ័ន ។

បទថា **ធម្មញ្ច បវត្តេតិ ចក្កញ្ច** លោកពោលដល់បដិវេធធម្មចក្ក ។ បទថា **ចក្កញ្ច បវត្តេតិ ធម្មញ្ច** លោកពោលដល់ទេសនាធម្មចក្ក ។ សេចក្តីនេះដូចម្តេច ព្រះមានព្រះភាគគង់នៅលើពោធិបល្ល័ង្ក ញ៉ាំងធម៌មានប្រភេទជាដើមថា ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈនិងអង្គនៃមគ្គ ឲ្យប្រព្រឹត្តទៅក្នុងខណៈនៃមគ្គ ធម៌នោះឯង ឈ្មោះថា ចក្ក ព្រោះដូចចក្ក សម្រាប់ប្រហារ ដោយបន្ទិលទៅដើម្បីសម្លាប់សត្រូវ គឺកិលេស ។ ព្រះមានព្រះ-ភាគ ទ្រង់ញ៉ាំងចក្ក គឺធម៌ឲ្យប្រព្រឹត្តទៅ ឈ្មោះថា ទ្រង់ញ៉ាំងចក្កនោះឲ្យប្រព្រឹត្តទៅ ។ ដោយបទនោះ ឈ្មោះថា ពោលជាកម្មធារយសមាសថា ចក្ក គឺធម៌ ។ ព្រះមានព្រះភាគទ្រង់គង់ត្រង់ឥសិបតនមិគទាយវ័ន ទ្រង់ញ៉ាំងចក្ក គឺទេសនា ដែលដូចគ្នានឹងកងចក្កសម្រាប់ប្រហារ ឲ្យប្រព្រឹត្តទៅដោយបន្ទិលទៅដើម្បីសម្លាប់សត្រូវ គឺកិលេសក្នុងសន្តាន របស់វេនេយ្យ-សត្វ នឹងញ៉ាំងចក្ក គឺធម៌ដែលមានប្រភេទជាដើមថា ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ អង្គនៃមគ្គ ឲ្យប្រព្រឹត្តទៅ ក្នុងសន្តានរបស់វេនេយ្យសត្វ ។ ដោយបទនេះ លោកពោលដល់ទ្វន្ទសមាសថា ធម៌ផង ចក្កផង ឈ្មោះថា ធម៌និងចក្ក ព្រោះកាលនៅប្រព្រឹត្តទៅ ក៏ឈ្មោះថា ការប្រព្រឹត្តិទៅនៅមាន ហេតុនោះ សូម្បីក្នុងទីទាំងពួង ទើបពោលថា **បវត្តេតិ** តែគប្បីជ្រាបថា លោកពោលថា **ចក្កំ** ព្រោះអត្ថថា វិលទៅ ។

បទថា **ធម្មេន បវត្តេតីតិ ធម្មចក្កំ** ជាដើម គប្បីជ្រាបថា លោក

ពោល សំដៅដល់ទេសនាធម្មចក្កនោះឯង ។ ក្នុងបទទាំងនោះ បទថា **ធម្មេន បវត្តេតិ** មានពាក្យអធិប្បាយថា ឈ្មោះថា ធម្មចក្ក ព្រោះចក្កប្រព្រឹត្តទៅហើយ ដោយធម៌តាមសភាវៈពិត ។ បទថា **ធម្មចរិយាយ បវត្តេតិ** មានពាក្យអធិប្បាយថា ឈ្មោះថា ធម្មចក្ក ព្រោះចក្កប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ធម៌ ក្នុងសន្តានរបស់វេនេយ្យសត្វ ។ ដោយបទថា **ធម្មេ ឋិតោ** ជាដើម លោកពោលដល់ភាពដែលព្រះមានព្រះភាគទ្រង់ជាធម៌ និងទ្រង់ជាម្ចាស់នៃធម៌ ។ សមដូចដែលព្រះមហាកច្ចានៈ ពោលទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលអាវុសោ ព្រោះថា ព្រះមានព្រះភាគនោះ តែងទ្រង់ជ្រាបនូវហេតុដែលគួរជ្រាប ទ្រង់ឃើញនូវហេតុដែលគួរឃើញ ព្រះតថាគតនោះ មានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌មិនវិបរិត កើតហើយ ព្រះអង្គជាបុរសដ៏ប្រសើរ ព្រះអង្គជាអ្នកពោលនូវធម៌ អ្នកប្រាប់នូវធម៌ អ្នកបង្អោនទូវប្រយោជន៍ អ្នកឲ្យនូវសេចក្តីប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានឈ្មោះអមតៈ ជាម្ចាស់នៃធម៌ ដូច្នេះ ។ ព្រោះហេតុនោះ ដោយបទទាំងនោះ ទើបមានពាក្យ អធិប្បាយថា ឈ្មោះថា ធម្មចក្ក ព្រោះជាចក្កនៃធម៌ ។

បទថា **ឋិតោ** បានដល់ តាំងនៅដោយភាពជាអារម្មណ៍ ។ បទថា **បតិដ្ឋិតោ** បានដល់ ប្រតិស្ឋានដោយការមិនញាប់ញ័រ ។ បទថា **វសិ-ប្បត្តោ** បានដល់ ដល់នូវភាពជាឥស្សរៈ ។ បទថា **ចារមិប្បត្តោ** បានដល់ សម្រេចដល់ទីបំផុត ។ បទថា **វេសារជ្ជប្បត្តោ** បានដល់ សម្រេច

ដល់ភាពជាអ្នកក្មេងក្ដា ។ ដោយបទដែលពោលសំដៅដល់សន្តាន របស់វេនេយ្យសត្វថា **ធម្មំ បតិដ្ឋាបេន្តោ** ជាដើម មានពាក្យអធិប្បាយថា ទ្រង់ញ៉ាំងចក្កឲ្យប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ធម៌ ព្រោះព្រះអង្គជាម្ចាស់នៃធម៌ ។ ដោយបទថា **ធម្មំ សក្ករោន្តោ** ជាដើម មានពាក្យអធិប្បាយថា ទ្រង់ញ៉ាំងឲ្យប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ធម៌ ។ ពិតណាស់ បុគ្គលណាប្រព្រឹត្តធម៌ដោយសក្ការៈជាដើម បុគ្គលនោះឈ្មោះថា ប្រព្រឹត្តដើម្បីធម៌ ។ បទថា **ធម្មំ សក្ករោន្តោ** បានដល់ ទ្រង់ធ្វើដោយប្រការដែលធម៌នោះ ដែលព្រះអង្គធ្វើហើយ ជាការធ្វើហើយដោយល្អ ។ បទថា **ធម្មំ គរុំ ករោន្តោ** បានដល់ ទ្រង់ធ្វើសេចក្ដីគោរពធម៌នោះដោយឲ្យកើតគារវៈក្នុងធម៌នោះ ។ បទថា **ធម្មំ មានេន្តោ** បានដល់ ទ្រង់ធ្វើធម៌នោះឲ្យជាទីស្រឡាញ់ ឲ្យជាទីគួរសរសើរ ។ បទថា **ធម្មំ បូជេន្តោ** បានដល់ ទ្រង់អាងដល់ធម៌នោះហើយ ធ្វើការបូជាដោយបដិបត្តិបូជា គឺ ទេសនា ។ បទថា **ធម្មំ អបចាយមានោ** បានដល់ ទ្រង់ធ្វើសេចក្ដីប្រព្រឹត្តិបន្ទន់បន្ទាបខ្លួនដោយការធ្វើសក្ការៈ និងគោរពធម៌នោះឯង ។ បទថា **ធម្មទ្ធជោ ធម្មកេតុ** សេចក្ដីថា ទ្រង់មានធម៌ជាទង់ និងមានធម៌ជាកំពូល ដោយការប្រព្រឹត្តនាំធម៌នោះទុកខាងមុខដូចទង់ និងលើកឡើងដូចជាកំពូល ។ បទថា **ធម្មាធិបតេយ្យោ** បានដល់ ទ្រង់មកហើយដោយមានធម៌ជាធំ និងទ្រង់ជាអ្នកមានធម៌ជាធំដោយធ្វើកិរិយាទាំងពួងដោយអំណាចនៃធម៌ គឺការភាវនា ។

បទថា **តំ ខោ បន ធម្មចក្កំ អប្បដិវត្តិយំ** លោកពោលដល់ការ

ប្រព្រឹត្តិដែលបុគ្គលណាមួយ ខ្ទាំងខ្ទប់មិនបាន ព្រោះបុគ្គលណាមួយ មិនអាចឲ្យវិលត្រឡប់បាន ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយថា ធម៌នោះឈ្មោះថា ចក្ក ព្រោះអត្ថថា វិលទៅ ។

បទថា **សទ្ធិន្ទ្រិយំ ធម្មោ តំ ធម្មំ បវត្តេតិ** សេចក្ដីថា ញុំាងសទ្ធិន្ទ្រិយដែលជាធម៌នោះឲ្យប្រព្រឹត្តទៅ ដោយញុំាងសទ្ធិន្ទ្រិយដែលសម្បយុត្តដោយមគ្គឲ្យកើតក្នុងសន្តានរបស់វេនេយ្យសត្វ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនោះដូចគ្នា ។ បទថា **សច្ចា** បានដល់ សច្ចញ្ញាណ ។ វិបស្សនានិងវិជ្ជា ក៏គឺមគ្គញ្ញាណនោះឯង ។ បទថា **អនុប្បាទេ ញាណំ** បានដល់ ញាណក្នុងអរហត្តផល ។ ព្រះមានព្រះភាគទ្រង់ញុំាងញាណនោះឲ្យប្រព្រឹត្តទៅក្នុងសន្តានរបស់វេនេយ្យសត្វ កាលទ្រង់ធ្វើការបោក់ផ្ចុះនូវនិព្វាន ឈ្មោះថា ទ្រង់ញុំាងញាណនោះ ឲ្យប្រព្រឹត្តទៅ ។ ក្នុងសមុទយវារៈ ជាដើម លោកសម្ដែងសង្ខេបបទដែលប្លែកថា មានសមុទ័យជាទីតាំង មាននិរោធជាទីតាំង មានមគ្គជាទីតាំង ។ បទដ៏សេសដូចគ្នានឹងបទដែលពោលទុកហើយ ក្នុងវារៈទាំងនេះ គប្បីជ្រាបដោយន័យដូចពោលហើយ ខាងដើមនោះឯង ។

អដ្ឋកថា សច្ចវារៈ ចប់

# អដ្ឋកថា

# សតិប្បដ្ឋានវារៈជាដើម

[ ៨៩ ] *សុមេធវារៈមានសតិប្បដ្ឋាននិងឥទ្ធិបាទជាខាងដើម លោកក៏ពោលទុកហើយ ដោយអំណាចខណៈនៃមគ្គ សុមេធវារៈទាំងនោះ ក៏លោកសម្ដែងសន្ធេបបទដែលប្លែកទុកក្នុងវារៈនោះៗ ដោយប្រការដូច្នេះ ។*

*អដ្ឋកថា សតិប្បដ្ឋានវារៈជាដើម ចប់*

*អដ្ឋកថា ធម្មចក្កកថា ចប់*

# សុត្តន្តបិដក

## យុគនទ្ធវគ្គ លោកុត្តរកថា

[ ៩១ ] ពួកធម៌ជាលោកុត្តរៈ តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្ម-ប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ អរិយមគ្គ ៤ សាមញ្ញផល ៤ និងនិព្វាន នេះពួកធម៌ជាលោកុត្តរ ។

សំណួរត្រង់ពាក្យថា លោកុត្តរៈ តើលោកុត្តរៈ ដោយអត្ថដូចម្តេច ។ ធម៌ទាំងឡាយឆ្លងនូវលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយឆ្លងអំពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយឆ្លងចាកលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយឆ្លងពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយកន្លងនូវលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយកន្លងហើយនូវលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយដ៏ក្រៃលែងក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយរលាស់ចេញចាកលោក ឈ្មោះថា លោ-កុត្តរៈ ធម៌ទាំងឡាយរលាស់ចេញអំពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយរលាស់ចេញពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយលះចេញចាកលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយលះចេញអំពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយលះចេញពីលោក ឈ្មោះថា លោ-កុត្តរៈ ធម៌ទាំងឡាយមិនឋិតនៅក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនឋិតនៅនាលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនប្រឡាក់ក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនប្រឡាក់ព្វដ៏

លោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនជាប់ស្អិត ក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនជាប់ស្អិតដោយលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនជាប់ចំពាក់ដោយលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនបង្អោនទៅក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនបង្អោនទៅតាមលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយរួចស្រឡះចាកលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយរួចស្រឡះអំពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយរួចស្រឡះពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនប្រកបក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយ មិនប្រកបដោយលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនប្រកបក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយឥតប្រកបក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយគ្មានប្រកបក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយស្អាតចាកលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយស្អាតជាងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយស្អាតអំពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយស្អាតវិសេសជាងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយស្អាតវិសេសអំពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយ ស្អាតវិសេសក្រៃលែងជាងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយចេញចាកលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយចេញអំពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយចេញពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយវៀរចាកលោក

ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយវៀរអំពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយវៀរពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនជាប់ក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនប្រកាន់ ក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយ មិនចំពាក់ក្នុងលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយផ្ដាច់បង់នូវលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយ ឈ្មោះថា លោកុត្តរៈ ព្រោះផ្ដាច់បង់នូវលោក ធម៌ទាំងឡាយរម្ងាប់បង់នូវលោក ឈ្មោះថា លោកុត្តរៈ ឈ្មោះថា លោកុត្តរៈ ព្រោះរម្ងាប់បង់នូវលោក ធម៌ទាំងឡាយមានការមិនត្រឡប់មកកាន់លោក ឈ្មោះថាលោកុត្តរៈ ធម៌ទាំងឡាយទៅផុតពីលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនជាវិស័យនៃលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនសាធារណ៍ដល់លោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយខ្ជាក់ចោលនូវលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនត្រឡប់មកកាន់លោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយលះបង់នូវលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនញាំងលោកឲ្យកើត ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនស្រឡាបនូវលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយនាំចេញនូវលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយកម្ចាត់បង់នូវលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយមិនឱបក្រសោបនូវលោក ឈ្មោះថា លោកុត្តរៈ ធម៌ទាំងឡាយប្រព្រឹត្តកន្លងគ្របសង្កត់នូវលោកហើយប្រតិស្ឋាន ឈ្មោះថា លោកុត្តរៈ ។

**ចប់ លោកុត្តរកថា ។**

# អដ្ឋកថា

## លោកុត្តរកថា

[ ៩១ ] ឥឡូវនេះ នឹងពណ៌នាសេចក្តីតាមលំដាប់ ដែលមិនធ្លាប់ពណ៌នាក្នុងលោកុត្តរកថា ដែលព្រះសារីបុត្តត្ថេរ ពោលទុកក្នុងលំដាប់នៃធម្មចក្កកថា ដែលជាគ្រឿងជម្រះទៅកាន់លោកុត្តរធម៌ ។ សេចក្តីនៃបទលោកុត្តរៈក្នុងលោកុត្តរកថានោះ នឹងមានជាក់ច្បាស់ ក្នុងនិទ្ទេសវារៈ ។ ពោធិបក្ខិយធម៌ ៣៧ មាន **ចត្តារោ សតិបដ្ឋានា** ជាដើម សម្បយុត្តដោយមគ្គ និងផលតាមដែលប្រកប ។ ធម៌ទាំងនោះ ឈ្មោះថា ពោធិបក្ខិយធម៌ ព្រោះប្រព្រឹត្តទៅក្នុងចំណែកនៃអរិយៈ ដែលបានឈ្មោះយ៉ាងនេះថា **ពោធិ** ដោយអត្ថថា ត្រាស់ដឹង ។ បទថា **បក្ខេ ភវត្តា** បានដល់ ព្រោះតាំងនៅក្នុងភាពជាឧបការៈ ។ ឈ្មោះថា **ឧបដ្ឋានំ** ព្រោះឈានកន្លង គឺ ស៊ុះទៅក្នុងអារម្មណ៍ទាំងនោះ ហើយប្រាកដ សតិនោះឯងប្រាកដ ទើបឈ្មោះថា សតិប្បដ្ឋាន ប្រភេទរបស់សតិប្បដ្ឋាននោះមាន ៤ យ៉ាង ដោយការប្រព្រឹត្តិទៅដោយអំណាច ការកាន់យកអាការមិនស្អាត ជាទុក្ខ មិនទៀង មិនមែនតួខ្លួន និងដោយអំណាចការញុំាងកិច្ច ឲ្យសម្រេច ដោយការលះសុភសញ្ញា សុខសញ្ញា និច្ចសញ្ញា និងអត្តសញ្ញា ក្នុងកាយ វេទនា ចិត្ត និងធម៌ ព្រោះហេតុនោះ ទើបលោកហៅថា សតិប្បដ្ឋាន ៤ ។

ឈ្មោះថា បធាន ព្រោះជាហេតុតាំង ។ ការតាំងទុកស្អាត ឈ្មោះថា សម្មប្បធាន ។ម្យ៉ាងទៀត ឈ្មោះថា សម្មប្បធាន ព្រោះជាហេតុតាំង

ទុកដោយប្រពៃ ម្យ៉ាងទៀត គុណជាតនោះ ឈ្មោះថា ស្អាត ព្រោះវៀរ ចាកការប្រព្រឹត្តិទៅខុសប្រក្រតីដោយអំណាចកិលេស និងឈ្មោះថា បធាន ព្រោះនាំនូវភាពប្រសើរមកឲ្យ ដោយអត្ថថា ឲ្យសម្រេចប្រយោជន៍ និង សេចក្ដីសុខ ឬធ្វើឲ្យជាប្រធាន ព្រោះហេតុនោះ ទើបឈ្មោះថា សម្មប្ប-ធាន ។ សម្មប្បធាននេះ ជាឈ្មោះរបស់សេចក្ដីព្យាយាម ។ សេចក្ដី ព្យាយាមនេះ មាន ៤ យ៉ាង ឲ្យសម្រេចកិច្ច គឺលះអកុសលដែលកើត ហើយ ១ ឲ្យសម្រេចកិច្ច គឺញ៉ាំងអកុសលដែលមិនទាន់កើត មិនឲ្យកើត ឡើង ១ ឲ្យសម្រេចកិច្ច គឺ ឲ្យកុសលដែលមិនទាន់កើត កើតឡើង ១ ឲ្យសម្រេចកិច្ច គឺ កុសលដែលកើតឡើងហើយឲ្យរឹងរិតតែចម្រើនឡើង ១ ព្រោះហេតុនោះ ទើបសេចក្ដីព្យាយាម ហៅថា សម្មប្បធាន ៤ ។

ឈ្មោះថា ឥទ្ធិ ដោយអត្ថថា ឲ្យសម្រេចដោយបរិយាយនៃការសម្រេច ឬដោយបរិយាយនេះថា ព្រោះជាហេតុឲ្យសត្វសម្រេច គឺសត្វបរិបូរ ចម្រើន ដល់នូវការសម្រេចយ៉ាងឧក្រិដ្ឋ ឈ្មោះថា ឥទ្ធិបាទ ព្រោះជាខាងដើមនៃ ឥទ្ធិនោះដែលសម្បយុត្ត និងព្រោះជាហេតុចំណែកខាងដើមនៃឥទ្ធិ ដែលជា ផល ព្រោះហេតុនោះ ទើបឈ្មោះថា ឥទ្ធិបាទ ។ ឥទ្ធិបាទនោះមាន ៤ យ៉ាង គឺ ឆន្ទះ វិរិយៈ ចិត្ត និងវីមំសា ព្រោះហេតុនោះ ទើបហៅថា ឥទ្ធិបាទ ៤ ។

ឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា ជាធំ ពោលគឺ គ្របសង្កត់ ព្រោះ គ្របសង្កត់ការមិនមានសទ្ធា សេចក្ដីខ្ជិលច្រអូស សេចក្ដីប្រមាទ សេចក្ដី

រាយមាយ និងសេចក្ដីវង្វេង ។ ឈ្មោះថា ពលៈ ព្រោះអត្ថថា មិនញាប់ញ័រ ព្រោះមិនត្រូវភាពមិនមានសទ្ធាជាដើម គ្របសង្កត់ ។

សូម្បីឥន្ទ្រិយ និងពលៈទាំងពីរយ៉ាងនោះ ក៏មាន ៥ យ៉ាង ដូចគ្នា គឺ សទ្ធា វិរិយ សតិ សមាធិ បញ្ញា ព្រោះហេតុនោះ ទើបហៅថា ឥន្ទ្រិយ ៥ ពល ៥ ។ ធម៌ទាំងឡាយ ៧ មានសតិជាដើម ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃសត្វអ្នកត្រាស់ដឹង និងធម៌ទាំងឡាយ ៨ មានសម្មាទិដ្ឋិជាដើម ឈ្មោះថា អង្គនៃមគ្គ ព្រោះអត្ថថា ជាគ្រឿងនាំចេញទៅ ដោយហេតុនោះ ទើបលោកពោលថា ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ ។

ពោធិបក្ខិយធម៌ ៣៧ ប្រការទាំងនេះ កាលវិបស្សនាដែលជាលោកិយៈ ក្នុងចំណែកខាងដើម ប្រព្រឹត្តទៅ កាលកំណត់កាន់យកកាយ ដោយអាការ ១៤ យ៉ាង ជាកាយានុបស្សនាសតិប្បដ្ឋាន កាលកំណត់កាន់យកវេទនា ដោយអាការ ៩ យ៉ាង ជាវេទនានុបស្សនាសតិប្បដ្ឋាន ព្រោះកំណត់កាន់យកចិត្ត ដោយអាការ ១៦ យ៉ាង ជាចិត្តានុបស្សនាសតិប្បដ្ឋាន កាលកំណត់កាន់យកធម៌ ដោយអាការ ៥ យ៉ាង ជាធម្មានុបស្សនាសតិប្បដ្ឋាន ដោយប្រការយ៉ាងនេះ ។

ក្នុងកាលដែលឃើញអកុសលដែលកើតឡើងហើយដល់អ្នកដទៃ ដែលមិនធ្លាប់កើតក្នុងអត្តភាពនេះហើយ ព្យាយាមដើម្បីមិនឲ្យអកុសលនោះកើត ដោយគិតថា អញនឹងមិនបដិបត្តិដោយប្រការដែលអកុសលនោះ កើតដល់អ្នកបដិបត្តិបែបនោះ អកុសលនោះ នឹងមិនកើតដល់អញយ៉ាងនេះ ជា

សម្មប្បធានទី ១ ក្នុងកាលដែលឃើញអកុសលរបស់ខ្លួនដល់នូវការផ្សាយ ( កើត ) ឡើង ហើយព្យាយាមដើម្បីលះអកុសលនោះ ជាសម្មប្បធានទី២ កាលព្យាយាមដើម្បីធ្វើឈាន ឬវិបស្សនាដែលមិនធ្លាប់កើតក្នុងអត្តភាពនេះឲ្យកើតឡើង ជាសម្មប្បធានទី ៣ កាលព្យាយាមធ្វើឈាន ឬ វិបស្សនាឲ្យកើតឡើងរឿយៗ ដោយប្រការដែលមិនឲ្យវិនាស ជាសម្មប្បធានទី ៤ ដោយប្រការដូច្នេះ ។

ក្នុងកាលធ្វើឆន្ទៈឲ្យជាធុរៈ ហើយឲ្យកុសលកើតឡើង ជា **ឆន្ទិទ្ធិបាទ** ក្នុងកាលធ្វើវិរិយ... ចិត្ត... វីមំសាឲ្យជាធុរៈ ហើយឲ្យកុសលកើតឡើង ជា **វីមំសិទ្ធិបាទ** ក្នុងកាលវៀរចាកការនិយាយកុហក ជាសម្មាវាចា ក្នុងកាលវៀរចាកការងារខុស ចិញ្ចឹមជីវិតខុស ជាសម្មាអាជីវៈ ពោធិបក្ខិយធម៌ទាំងឡាយ រមែងបានក្នុងចិត្តផ្សេងៗយ៉ាងនេះ ដោយប្រការដូច្នេះ ។ តែក្នុងខណៈនៃមគ្គ ៤ ពោធិបក្ខិយធម៌ទាំងឡាយរមែងបានក្នុងចិត្តដួងតែមួយ ក្នុងខណៈនៃផល រមែងបានពោធិបក្ខិយធម៌ដ៏សេស ៣៣ វៀរសម្មប្បធាន ៤ ។

មួយវិញទៀត កាលពោធិបក្ខិយធម៌ទាំងនោះបានក្នុងចិត្តតែមួយយ៉ាងនេះ សតិមាននិព្វានជាអារម្មណ៍តែមួយប៉ុណ្ណោះ លោកពោលថា សតិប្បដ្ឋាន ៤ ដោយអំណាចសម្រេចកិច្ចក្នុងការលះសេចក្ដីសម្គាល់ថា ស្អាត ក្នុងកាយជាដើម វិរិយៈតែមួយប៉ុណ្ណោះ លោកពោលថា សម្មប្បធាន ៤ ដោយអំណាចសម្រេចកិច្ច មិនឲ្យអកុសលកើតឡើង លះអកុសល ដែលកើត

ហើយជាដើម ។ ក្នុងពោធិបក្ខិយធម៌ដ៏សេសមិនមានការដកនិងការបន្ថែម ។

ម្យ៉ាងទៀត ក្នុងពោធិបក្ខិយធម៌ទាំងនោះ គប្បីជ្រាបគាថា ដូចតទៅនេះថា

ធម៌ទាំងឡាយនោះ មាន ៦ ពួកដូច្នេះ គឺធម៌ទាំងឡាយ ៩ ប្រការជាធម៌មានដោយពួកមួយ ធម៌ ១ ប្រការមានដោយពួក ២ ម្យ៉ាងទៀត ធម៌មួយមានដោយពួក ៤ ដោយពួក ៥ ដោយពួក ៨ និងដោយពួក ៩ ។

ពាក្យថា ធម៌ទាំងឡាយ ៩ ប្រការជាធម៌មានដោយពួកមួយ បានដល់ធម៌ ៩ ប្រការទាំងនេះ គឺឆន្ទៈ ចិត្ត បីតិ បស្សទ្ធិ ឧបេក្ខា សង្កប្បៈ វាចា កម្មន្តៈ អាជីវៈ មានដោយពួកមួយប៉ុណ្ណោះ ដោយអំណាចឆន្ទិទ្ធិបាទជាដើម មិនរួមបញ្ចូលក្នុងចំណែកដទៃ ។ ពាក្យថា ធម៌ ១ ប្រការ មានដោយពួក ២ បានដល់ សទ្ធាតាំងនៅដោយពួក ២ ដោយអំណាចនៃឥន្ទ្រិយនិងពលៈ ។ ពាក្យថា ម្យ៉ាងទៀត ធម៌មួយ មានដោយពួក ៤ ដោយពួក ៥ បានដល់ ធម៌មួយដទៃតាំងនៅដោយពួក ៤ ដទៃ តាំងនៅដោយពួក ៥ ។

ក្នុងធម៌ទាំងនោះ សមាធិមួយ តាំងនៅដោយពួក ៤ គឺឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ អង្គនៃមគ្គ ។ បញ្ញាតាំងនៅដោយពួក ៥ ដោយពួកនៃធម៌ ៤ ទាំងនោះ និងដោយចំណែកមួយរបស់ឥទ្ធិបាទ ។

ពាក្យថា ដោយពួក ៨ និងដោយពួក ៩ បានដល់ ធម៌មួយដទៃ

ទៀត តាំងនៅដោយពួក ៨ ធម៌ប្រការមួយទៀតតាំងនៅដោយពួក ៩ អធិប្បាយថា សតិ តាំងនៅដោយពួក ៨ គឺសតិប្បដ្ឋាន ៤ ឥន្ទ្រិយ ១ ពលៈ ១ ពោជ្ឈង្គៈ ១ អង្គនៃមគ្គ ១ ។ វិរិយៈតាំងនៅដោយពួក ៩ គឺសម្មប្បធាន ៤ ឥទ្ធិបាទ ១ ឥន្ទ្រិយ ១ ពលៈ ១ ពោជ្ឈង្គៈ ១ អង្គនៃមគ្គ ១ ដោយប្រការដូច្នេះ គប្បីជ្រាបសេចក្ដីក្នុងគាថាដូចតទៅនេះថា

ពោធិបក្ខិយធម៌ទាំងឡាយនោះ រាប់ហើយ មិនរាប់ទៀត
( អង្គធម៌ ) ក៏មាន ១៤ ប៉ុណ្ណោះ ដោយពួកមាន ៧ ពួក
ដោយការចែកមាន ៣៧ កាលអរិយមគ្គកើតឡើង ពោធិ-
បក្ខិយធម៌ទាំងនោះ ក៏កើតឡើងព្រមគ្នាទាំងអស់នោះឯង
ដោយការធ្វើកិច្ចរៀង ៗ ខ្លួនឲ្យសម្រេច និងដោយប្រព្រឹត្តទៅ
តាមរូប ( សភាវៈ ) របស់ខ្លួន ។

ព្រះសារីបុត្តត្ថេរ កាលសម្ដែងពោធិបក្ខិយធម៌ ៣៧ ប្រការ សម្ប-យុត្តដោយមគ្គនិងផលយ៉ាងនេះហើយ ទើបសង្ខេបពោធិបក្ខិយធម៌ទាំងនោះ ចូលក្នុងមគ្គនិងផលទៀត ហើយពោលថា អរិយមគ្គ ៤ និងសាមញ្ញផល ៤ ដូច្នេះ ។

ភាពជាសមណៈ ឈ្មោះថា សាមញ្ញៈ ។ សាមញ្ញៈនេះ ជាឈ្មោះនៃ អរិយមគ្គ ៤ ផលនៃសាមញ្ញៈទាំងឡាយ ឈ្មោះថា សាមញ្ញផល ។ ចំណែកនិព្វាន មិនលាយឡំជាមួយមគ្គនិងផលទាំងពួនឡើយ ព្រោះហេតុ នោះគប្បីជ្រាបថា ដោយពិស្ដារ លោកុត្តរធម៌ទាំងឡាយមាន ៤៦ ដោយ

អំណាចនៃពោធិបក្ខិយធម៌ ៣៧ មគ្គ ៤ ផល ៤ និងនិព្វាន ១ ពោលដោយសង្ខេបជាងនោះ លោកុត្តរធម៌ មាន ៩ ដោយអំណាចនៃមគ្គ ៤ ផល ៤ និព្វាន ១ ពោលដោយសង្ខេបជាងនោះទៀត លោកុត្តរធម៌មាន ៣ ដោយអំណាចមគ្គ ១ ផល ១ និព្វាន ១ ។ ម្យ៉ាងទៀត កាលពោលដល់ភាពដែលមគ្គ និងផល មានសតិប្បដ្ឋានជាដើម ជាលោកុត្តរៈ ក៏ឈ្មោះថា លោកពោលដល់ភាពដែលផស្សៈជាដើមដែលសម្បយុត្តដោយមគ្គផលនោះ ក៏ជាលោកុត្តរៈដូចគ្នា ។ លោកពោលដល់ពោធិបក្ខិយធម៌មានសតិប្បដ្ឋានជាដើម ដោយអំណាចនៃធម៌ជាប្រធាន ។ ម្យ៉ាងទៀត ក្នុងលោកុត្តរធម្មនិទ្ទេស ក្នុងអភិធម្ម លោកពោលដល់ផស្សៈជាដើម ដែលសម្បយុត្តដោយមគ្គនិងផល ជាលោកុត្តរធម៌ ។

បទថា **លោកំ តរន្តិ** បានដល់ ឈានកន្លងលោក ។ ពាក្យជាបច្ចុប្បន្នកាលបែបនេះទាំងអស់ លោកពោលសំដៅដល់អរិយមគ្គ ៤ ដ្បិតថា សោតាបត្តិមគ្គ រមែងឆ្លងអបាយលោកបាន សកទាគាមិមគ្គ រមែងឆ្លងកាមាវចរលោកបានដោយចំណែកខ្លះ អនាគាមិមគ្គ រមែងឆ្លងកាមាវចរលោកបាន អរហត្តមគ្គរមែងឆ្លងរូបាវចរលោក និងអរូបាវចរលោកបាន ។ បទថា **លោកា ឧត្តរន្តិ** បានដល់ ចេញចាកលោក ។ បទថា **លោក-តោតិ ច លោកម្ហាតិ ច** នោះ លោកសម្តែងបញ្ចមីវិភត្តិឲ្យផ្សេងទៅ ។ បទថា **លោកំ សមតិក្កមន្តិ** មានសេចក្តីដូចបានពោលទុកហើយ ខាងដើម ។ ក្នុងបទនោះ លោកពោលមិនសម្ងឹងដល់អត្ថរបស់ឧបសគ្គ ក្នុង

ទីនេះ លោកពោលព្រមដោយអត្ថរបស់ឧបសគ្គ ។ បទថា **លោកំ សម-តិក្កន្តា** បានដល់ ឈានកន្លងលោកតាមដែលពោលហើយដោយប្រពៃ ។ ពាក្យដែលជាអតីតកាលបែបនេះក្នុងទីនេះទាំងអស់ លោកពោលសំដៅដល់ផលនិងនិព្វាន ដ្បិតថា សោតាបត្តិផលជាដើម ឈានកន្លងលោកតាមដែលពោលហើយតាំងនៅ និព្វានឈានកន្លងលោកទាំងអស់សព្វកាល ។ បទថា **លោកេន អតិរេកា** បានដល់ ក្រៃលែងជាងលោក ។ ពាក្យនេះ លោកពោលសំដៅដល់លោកុត្តរធម៌ទាំងអស់ ។ បទថា **និស្សរន្តិ** បានដល់ ចេញទៅ ។ បទថា **និស្សដា** បានដល់ ចេញទៅហើយ ។ បទ ១៨ បទ មានបទថា **លោកេ ន តិដ្ឋន្តិ** ជាដើម រមែងគួរសូម្បីក្នុងលោកុត្តរធម៌ទាំអស់ ។ បទថា **ន តិដ្ឋន្តិ** លោកពោលទុក ព្រោះមិនរាប់បញ្ចូលក្នុងលោក ។ បទថា **លោកេ ន លិម្បន្តិ** បានដល់ សូម្បីប្រព្រឹត្តទៅក្នុងសន្តាន ក៏មិនជាប់ក្នុងលោកនោះ ។ បទថា **លោកេន ន លិម្បន្តិ** សេចក្ដីថា មិនប្រឡាក់ដោយចិត្តណាមួយ របស់បុគ្គលដែលមិនទាន់ចាក់ធ្លុះ និងដោយចិត្តដែលជាអកុសលដែលមិនអាចរបស់បុគ្គលដែលចាក់ធ្លុះហើយ ។ បទថា **អសំលិត្តា អនុបលិត្តា** គប្បីជ្រាបថា បន្ថែមឧបសគ្គ ។ បទថា **វិប្បមុត្តា** បានដល់ ការមិនជាប់នៅនោះឯង លោកធ្វើឲ្យផ្សេងគ្នាដោយព្យញ្ជនៈផ្សេងៗ ព្រោះបុគ្គលណាមិនជាប់ក្នុងវត្ថុណា ឬដោយវត្ថុណា បុគ្គលនោះជាអ្នករួចផុតក្នុងវត្ថុនោះ ឬដោយវត្ថុនោះ ។ បទ ៣ មានបទថា **លោកា វិប្បមុត្តា** ជាដើម លោកពោលជាបញ្ចមីវិភត្តិ ។

បទថា **វិសញ្ញុត្តា** ជាវិសេសនៈនៃការផុតទៅ ។ ព្រោះបុគ្គលណាផុតក្នុងវត្ថុណា ដោយវត្ថុណា ចាកវត្ថុណា បុគ្គលនោះ ជាអ្នកមិនជាប់ចំពាក់ក្នុងវត្ថុនោះ ដោយវត្ថុនោះ ចាកវត្ថុនោះ ។ បទថា **លោកា សុជ្ឈន្តិ** បានដល់ លាងនូវមន្ទិលរបស់លោក ហើយបរិសុទ្ធិចាកលោក ។ បទថា **វិសុជ្ឈន្តិ** នោះ លោកធ្វើឲ្យផ្សេងគ្នាដោយឧបសគ្គ ។ បទថា **វុដ្ឋហន្តិ** បានដល់ ក្រោកឡើង ។ បទថា **វិវដ្ដន្តិ** បានដល់ មិនត្រឡប់ ។ បទថា **ន សជ្ជន្តិ** បានដល់ មិនជាប់ចំពាក់ ។ បទថា **ន គយ្ហន្តិ** បានដល់ មិនប្រកាន់មាំ ។ បទថា **ន ពជ្ឈន្តិ** បានដល់ មិនត្រូវបៀតបៀន ។ បទថា **សមុច្ឆិន្ទន្តិ** បានដល់ ធ្វើមិនឲ្យប្រព្រឹត្តទៅបាន ។ លោកពោលដល់ពាក្យថា ព្រោះបរិសុទ្ធិចាកលោក ដូចបទថា **លោកំ សមុច្ឆិន្ទន្តា** ជាដើម ។ បទថា **បដិប្បស្សម្ភេន្តិ** បានដល់ ឲ្យលោករលត់ ។ បទ ៤ មានបទថា **អបថា**[១] ជាដើមរម្ងែងគួរក្នុងលោកុត្តរៈសូម្បីទាំងពួង ។ បទថា **អបថា**[២] បានដល់ មិនមានផ្លូវ ។ បទថា **អគតិ** បានដល់ មិនជាទីពឹង ។

បទថា **អវិសយា** បានដល់ មិនជាទីអាស្រ័យ ។ បទថា **អសាធារណា** បានដល់ មានមិនទូទៅ ។ បទថា **វមន្តិ** បានដល់ ខ្ជាក់ចេញ ។ បទថា **ន បច្ចាគមន្តិ** លោកពោលដោយន័យផ្ទុយនឹងពាក្យ ដែលពោលហើយ សេចក្ដីថា មិនបរិភោគរបស់ដែលខ្ជាក់ហើយ ។ ដោយបទនេះ លោកពោលដល់ភាពដែលរបស់ខ្ជាក់ហើយ ជាការខ្ជាក់ហើយដោយល្អ ។

---

១-២ បិដកខ្មែរជា អបច្ចាគតិ ។

សូម្បីក្នុងទុកៈ ៣ ពួក ក្នុងលំដាប់បន្ទាប់ទៅ ក៏មានន័យដូចគ្នា ។

បទថា **វិសីនេន្តិ** បានដល់ ខ្ចាត់ខ្ចាយទៅ ផុតទៅ សេចក្តីថា មិនចងទុក ។ បទថា **ន ឧស្សីនេន្តិ** បានដល់ មិនខ្ចាត់ខ្ចាយ មិនផុត ។ បាលីលោកធ្វើឲ្យខ្លីថា **វិសិនេន្តិ** និង **ន ឧស្សិនេន្តិ** ល្អជាង ។ បទថា **វិធូបេន្តិ** បានដល់ ឲ្យរលត់ ។ បទថា **ន សំធូបេន្តិ** បានដល់ មិនរុងរឿង ។ បទថា **លោកំ សមតិក្កម្ម អភិភុយ្យ តិដ្ឋន្តិ** បានដល់ លោកុត្តរធម៌ទាំងអស់ឈានកន្លងនិងគ្របសង្កត់លោក តាំងនៅដោយល្អ ព្រោះហេតុនោះ ទើបឈ្មោះថា លោកុត្តរៈ ។ លោកពោលដល់សភាពដែលលោកុត្តរៈទាំងឡាយ ប្រសើរជាងលោក និងក្រៃលែងជាងលោក ដោយប្រការដូចពោលមកនេះសូម្បីទាំងអស់ ។

## អដ្ឋកថា លោកុត្តរកថា ចប់

# សុត្តន្តបិដក

## យុគនទ្ធវគ្គ ពលកថា

## សាវត្ថីនិទាន

[ ៩២ ] ម្នាលភិក្ខុទាំងឡាយ ពលៈនេះមាន ៥ ពលៈ ៥ តើអ្វីខ្លះ សទ្ធាពលៈ វីរិយពលៈ សតិពលៈ សមាធិពលៈ បញ្ញាពលៈ ម្នាលភិក្ខុទាំងឡាយ នេះពលៈ ៥ ។

មួយទៀត ពលៈមាន ៦៨ គឺ សទ្ធាពលៈ ១ វីរិយពលៈ ១ សតិពលៈ ១ សមាធិពលៈ ១ បញ្ញាពលៈ ១ ហិរិពលៈ ១ ឱត្តប្បពលៈ ១ បដិសង្ខានពលៈ ១ ភាវនាពលៈ ១ អនវជ្ជពលៈ ១ សង្គាហពលៈ ១ ខន្តិពលៈ ១ បញ្ញត្តិពលៈ ១ និជ្ឈត្តិពលៈ ១ ឥស្សរិយពលៈ ១ អធិដ្ឋានពលៈ ១ សមថពលៈ ១ វិបស្សនាពលៈ ១ សេក្ខពលៈ ១០ អសេក្ខពលៈ ១០ ខីណាសវពលៈ ១០ ឥទ្ធិពលៈ ១០ តថាគតពលៈ ១០ ។

[ ៩៣ ] សទ្ធាពលៈតើដូចម្តេច ។ ឈ្មោះថា សទ្ធាពលៈ ព្រោះមិនញាប់ញ័រ ដោយវត្ថុមិនគួរជឿ ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថា ទំនុកបម្រុងនូវសហជាតធម៌ទាំងឡាយ ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថា គ្របសង្កត់នូវពួកកិលេស ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថា ជម្រះនូវគុណ មានកិរិយាត្រាស់ដឹងជាដើម ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថា អធិដ្ឋានចិត្ត ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថា ញ៉ាំងចិត្តឲ្យផូរផង់

ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថា បាននូវគុណវិសេស ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថា ចាក់ធ្លុះនូវគុណដ៏ក្រៃលែង ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថា ត្រាស់ដឹងនូវសច្ចៈ ឈ្មោះថា សទ្ធាពលៈ ដោយអត្ថថា ឲ្យតាំងនៅស៊ប់ក្នុងនិរោធ នេះសទ្ធាពលៈ ។

វិរិយពលៈតើដូចម្តេច ។ ឈ្មោះថា វិរិយពលៈ ព្រោះជាធម្មជាតមិនញាប់ញ័រដោយសេចក្តីខ្ជិល ឈ្មោះថា វិរិយពលៈ ដោយអត្ថថា ទំនុកបម្រុងនូវសហជាតធម៌ទាំងឡាយ ឈ្មោះថា វិរិយពលៈ ដោយអត្ថថា គ្របសង្កត់នូវកិលេសទាំងឡាយ ឈ្មោះថា វិរិយពលៈ ដោយអត្ថថា ជម្រះនូវគុណមានកិរិយាត្រាស់ដឹងជាដើម ឈ្មោះថា វិរិយពលៈ ដោយអត្ថថា អធិដ្ឋានចិត្ត ឈ្មោះថា វិរិយពលៈ ដោយអត្ថថា ញុំាងចិត្តឲ្យផូរផង់ ឈ្មោះថា វិរិយពលៈ ដោយអត្ថថា បាននូវគុណវិសេស ឈ្មោះថា វិរិយពលៈ ដោយអត្ថថា ចាក់ធ្លុះនូវគុណដ៏ក្រៃលែង ឈ្មោះថា វិរិយពលៈ ដោយអត្ថថា ត្រាស់ដឹងនូវសច្ចៈ ឈ្មោះថា វិរិយពលៈ ដោយអត្ថថា ឲ្យតាំងនៅស៊ប់ក្នុងនិរោធ នេះវិរិយពលៈ ។

សតិពលៈតើដូចម្តេច ។ ឈ្មោះថា សតិពលៈ ព្រោះជាធម្មជាតមិនញាប់ញ័រដោយសេចក្តីប្រមាទ ឈ្មោះថា សតិពលៈ ដោយអត្ថថា ទំនុកបម្រុងនូវសហជាតធម៌ទាំងឡាយ ។បេ។ ឈ្មោះថា សតិពលៈ ដោយអត្ថថា ឲ្យតាំងនៅស៊ប់ក្នុងនិរោធ នេះសតិពលៈ ។

សមាធិពលៈតើដូចម្តេច ។ ឈ្មោះថា សមាធិពលៈ ព្រោះជាធម្មជាត

មិនញាប់ញ័រដោយសេចក្តីរាយមាយ ឈ្មោះថា សមាធិពលៈ ដោយអត្ថថា ទំនុកបម្រុងនូវសហជាតធម៌ទាំងឡាយ ។បេ។ ឈ្មោះថា សមាធិពលៈ ដោយអត្ថថា ឲ្យតាំងនៅស៊ប់ក្នុងនិរោធ នេះសមាធិពលៈ ។

បញ្ញាពលៈតើដូចម្តេច ។ ឈ្មោះថា បញ្ញាពលៈ ព្រោះជាធម្មជាតមិនញាប់ញ័រដោយអវិជ្ជា ឈ្មោះថា បញ្ញាពលៈ ដោយអត្ថថា ទំនុកបម្រុងនូវសហជាតធម៌ទាំងឡាយ ។បេ។ ឈ្មោះថា បញ្ញាពលៈ ដោយអត្ថថា ឲ្យតាំងនៅស៊ប់ក្នុងនិរោធ នេះបញ្ញាពលៈ ។

[ ៩៤ ] ហិរិពលៈតើដូចម្តេច ។ ឈ្មោះថា ហិរិពលៈ ព្រោះជាធម្មជាតខ្មើមកាមច្ឆន្ទៈដោយនេក្ខម្មៈ ឈ្មោះថា ហិរិពលៈ ព្រោះខ្មើមព្យាបាទដោយអព្យាបាទ ឈ្មោះថា ហិរិពលៈ ព្រោះខ្មើមថីនមិទ្ធៈដោយអាលោកសញ្ញា ឈ្មោះថា ហិរិពលៈ ព្រោះខ្មើមឧទ្ធច្ចៈដោយសេចក្តីមិនរាយមាយ ឈ្មោះថា ហិរិពលៈ ព្រោះខ្មើមវិចិកិច្ឆាដោយកិរិយាកំណត់នូវធម៌ ឈ្មោះថា ហិរិពលៈ ព្រោះខ្មើមអវិជ្ជាដោយញាណ ឈ្មោះថា ហិរិពលៈ ព្រោះខ្មើមសេចក្តីមិនត្រេកអរដោយបាមោជ្ជៈ ឈ្មោះថា ហិរិពលៈ ព្រោះខ្មើមនីវរណៈដោយបឋមជ្ឈាន ។បេ។ ឈ្មោះថា ហិរិពលៈ ព្រោះខ្មើមកិលេសទាំងពួងដោយអរហត្តមគ្គ នេះហិរិពលៈ ។

ឱត្តប្បពលៈតើដូចម្តេច ។ ឈ្មោះថា ឱត្តប្បពលៈ ព្រោះជាធម្មជាតតក់ស្លុតនឹងកាមច្ឆន្ទៈដោយនេក្ខម្មៈ ឈ្មោះថា ឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងព្យាបាទដោយអព្យាបាទ ឈ្មោះថា ឱត្តប្បពលៈ ព្រោះតក់ស្លុតនឹង

ថីនមិទ្ធៈដោយអាលោកសញ្ញា ឈ្មោះថា ឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងឧទ្ធច្ចៈដោយសេចក្តីមិនរាយមាយ ឈ្មោះថា ឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងវិចិកិច្ឆាដោយកិរិយាកំណត់នូវធម៌ ឈ្មោះថា ឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងអវិជ្ជាដោយញាណ ឈ្មោះថា ឱត្តប្បពលៈព្រោះតក់ស្លុតនឹងសេចក្តីមិនត្រេកអរដោយបាមោជ្ជៈ ឈ្មោះថា ឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងពួកនីវរណៈដោយបឋមជ្ឈាន ។បេ។ ឈ្មោះថា ឱត្តប្បពលៈ ព្រោះតក់ស្លុតនឹងកិលេសទាំងពួងដោយអរហត្តមគ្គ នេះឱត្តប្បពលៈ ។

បដិសង្ខានពលៈតើដូចម្តេច ។ ឈ្មោះថា បដិសង្ខានពលៈ ព្រោះជាធម្មជាតពិចារណាកាមច្ឆន្ទៈដោយនេក្ខម្មៈ ឈ្មោះថា បដិសង្ខានពលៈព្រោះពិចារណាព្យាបាទដោយអព្យាបាទ ឈ្មោះថា បដិសង្ខានពលៈ ព្រោះពិចារណាថីនមិទ្ធៈ ដោយអាលោកសញ្ញា ឈ្មោះថា បដិសង្ខានពលៈ ព្រោះពិចារណាឧទ្ធច្ចៈដោយសេចក្តីមិនរាយមាយ ឈ្មោះថា បដិសង្ខានពលៈ ព្រោះពិចារណាវិចិកិច្ឆា ដោយកិរិយាកំណត់នូវធម៌ ឈ្មោះថា បដិសង្ខានពលៈ ព្រោះពិចារណាអវិជ្ជា ដោយញាណ ឈ្មោះថា បដិសង្ខានពលៈ ព្រោះពិចារណាសេចក្តីមិនត្រេកអរដោយបាមោជ្ជៈ ឈ្មោះថា បដិសង្ខានពលៈ ព្រោះពិចារណាពួកនីវរណៈ ដោយបឋមជ្ឈាន ។បេ។ ឈ្មោះថា បដិសង្ខានពលៈ ព្រោះពិចារណាពួកកិលេសទាំងពួងដោយអរហត្តមគ្គ នេះបដិសង្ខានពលៈ ។

[ ៩៥ ] ភាវនាពលៈតើដូចម្តេច ។ ឈ្មោះថា ភាវនាពលៈ ព្រោះ

លះបង់កាមច្ឆន្ទៈចម្រើននេក្ខម្មៈ ឈ្មោះថា ភាវនាពលៈ ព្រោះលះបង់ព្យា-បាទ ចម្រើនអព្យាបាទ ឈ្មោះថា ភាវនាពលៈ ព្រោះលះបង់ថីនមិទ្ធៈ ចម្រើនអាលោកសញ្ញា ឈ្មោះថា ភាវនាពលៈ ព្រោះលះបង់ឧទ្ធច្ចៈចម្រើន អវិក្ខេបៈ ឈ្មោះថា ភាវនាពលៈ ព្រោះលះបង់វិចិកិច្ឆា ចម្រើននូវកិរិយា កំណត់នូវធម៌ ឈ្មោះថា ភាវនាពលៈ ព្រោះលះបង់អវិជ្ជា ចម្រើនញាណ ឈ្មោះថា ភាវនាពលៈ ព្រោះលះបង់សេចក្តីមិនត្រេកអរ ចម្រើនបាមោជ្ជៈ ឈ្មោះថា ភាវនាពលៈ ព្រោះលះបង់ពួកនីវរណៈចម្រើនបឋមជ្ឈាន ។បេ។ ឈ្មោះថា ភាវនាពលៈ ព្រោះលះបង់កិលេសទាំងពួង ចម្រើនអរហត្តមគ្គ នេះភាវនាពលៈ ។

អនវជ្ជពលៈតើដូចម្តេច ។ ឈ្មោះថា អនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងនេក្ខម្មៈព្រោះលះបង់កាមច្ឆន្ទៈ ឈ្មោះថា អនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងអព្យាបាទព្រោះលះបង់ព្យាបាទ ឈ្មោះថា អន-វជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងអលោកសញ្ញាព្រោះលះបង់ថីនមិទ្ធៈ ឈ្មោះថា អនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងសេចក្តីមិនរាយមាយ ព្រោះលះបង់ឧទ្ធច្ចៈ ឈ្មោះថា អនវជ្ជពលៈ ព្រោះទោសតិចតួចមិនមាន ក្នុងសេចក្តីកំណត់នូវធម៌ ព្រោះលះបង់វិចិកិច្ឆា ឈ្មោះថា អនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងញាណ ព្រោះលះបង់អវិជ្ជា ឈ្មោះថា អន-វជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងបាមោជ្ជៈ ព្រោះលះបង់សេចក្តីមិន ត្រេកអរ ឈ្មោះថា អនវជ្ជពលៈ ព្រោះទោសតិចតួចមិនមានក្នុងបឋមជ្ឈាន

ព្រោះលះបង់ពួកនីវរណៈ ។បេ។ ឈ្មោះថា អនវជ្ជពលៈ ព្រោះទោសតិចតួចមិនមាន ក្នុងអរហត្តមគ្គ ព្រោះលះបង់កិលេសទាំងពួង នេះអនវជ្ជពលៈ ។

សង្គាហពលៈតើដូចម្តេច ។ ឈ្មោះថា សង្គាហពលៈ ព្រោះបុគ្គលលះបង់កាមច្ឆន្ទៈ សង្រ្គោះចិត្តដោយអំណាចនេក្ខម្មៈ ឈ្មោះថា សង្គាហពលៈ ព្រោះលះបង់ព្យាបាទ សង្រ្គោះចិត្តដោយអំណាចអព្យាបាទ ឈ្មោះថា សង្គាហពលៈ ព្រោះលះបង់ថីនមិទ្ធៈ សង្រ្គោះចិត្តដោយអំណាចអាលោកសញ្ញា ។បេ។ ឈ្មោះថា សង្គាហពលៈ ព្រោះលះបង់កិលេសទាំងពួង សង្រ្គោះចិត្តដោយអំណាចអរហត្តមគ្គ នេះសង្គាហពលៈ ។

[ ៩៦ ] ខន្តិពលៈតើដូចម្តេច ។ ឈ្មោះថា ខន្តិពលៈ ព្រោះនេក្ខម្មៈអត់ធន់បានព្រោះលះបង់កាមច្ឆន្ទៈ ឈ្មោះថា ខន្តិពលៈ ព្រោះអព្យាបាទអត់ធន់បានព្រោះលះបង់ព្យាបាទ ឈ្មោះថា ខន្តិពលៈ ព្រោះអាលោកសញ្ញាអត់ធន់បានព្រោះលះបង់ថីនមិទ្ធៈ ឈ្មោះថា ខន្តិពលៈ ព្រោះសេចក្តីមិនរាយមាយអត់ធន់បានព្រោះលះបង់ឧទ្ធច្ចៈ ឈ្មោះថា ខន្តិពលៈ ព្រោះការកំណត់នូវធម៌អត់ធន់បាន ព្រោះលះបង់វិចិកិច្ឆា ឈ្មោះថា ខន្តិពលៈ ព្រោះញាណអត់ធន់បានព្រោះលះបង់នូវអវិជ្ជា ឈ្មោះថា ខន្តិពលៈ ព្រោះបាមោជ្ជៈអត់ធន់បានព្រោះលះបង់សេចក្តីមិនត្រេកអរ ឈ្មោះថា ខន្តិពលៈ ព្រោះបឋមជ្ឈានអត់ធន់បានព្រោះលះបង់ពួកនីវរណៈ ឈ្មោះថា ខន្តិពលៈ ព្រោះអរហត្តមគ្គអត់ធន់បានព្រោះលះបង់កិលេសទាំងពួង នេះខន្តិពលៈ ។

បញ្ញត្តិពលៈតើដូចម្ដេច ។ ឈ្មោះថា បញ្ញត្តិពលៈ ព្រោះបុគ្គលលះបង់កាមច្ឆន្ទៈ បញ្ញត្តចិត្តដោយអំណាចនេក្ខម្មៈ ឈ្មោះថា បញ្ញត្តិពលៈ ព្រោះលះបង់ព្យាបាទ បញ្ញត្តចិត្តដោយអំណាចអព្យាបាទ ឈ្មោះថា បញ្ញត្តិពលៈ ព្រោះបុគ្គលលះបង់ថីនមិទ្ធៈ បញ្ញត្តចិត្តដោយអំណាចអាលោកសញ្ញា ។បេ។ ឈ្មោះថា បញ្ញត្តិពលៈ ព្រោះបុគ្គលលះបង់កិលេសទាំងពួង បញ្ញត្តចិត្តដោយអំណាចអរហត្តមគ្គ នេះបញ្ញត្តិពលៈ ។

និជ្ឈត្តិពលៈ តើដូចម្ដេច ។ ឈ្មោះថា និជ្ឈត្តិពលៈ ព្រោះលះបង់កាមច្ឆន្ទៈ សម្លឹងមើលចិត្តដោយអំណាចនេក្ខម្មៈ ឈ្មោះថា និជ្ឈត្តិពលៈ ព្រោះលះបង់ព្យាបាទ សម្លឹងមើលចិត្តដោយអំណាចអព្យាបាទ ឈ្មោះថា និជ្ឈត្តិពលៈ ព្រោះលះបង់ថីនមិទ្ធៈ សម្លឹងមើលចិត្តដោយអំណាចអាលោកសញ្ញា ។បេ។ ឈ្មោះថា និជ្ឈត្តិពលៈ ព្រោះបុគ្គលលះបង់កិលេសទាំងពួង សម្លឹងមើលចិត្តដោយអំណាចអរហត្តមគ្គ នេះនិជ្ឈត្តិពលៈ ។

ឥស្សរិយពលៈតើដូចម្ដេច ។ ឈ្មោះថា ឥស្សរិយពលៈ ព្រោះបុគ្គលលះបង់កាមច្ឆន្ទៈ ញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច ដោយអំណាចនៃនេក្ខម្មៈ ឈ្មោះថា ឥស្សរិយពលៈ ព្រោះលះបង់ព្យាបាទ ញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចដោយអំណាចនៃអព្យាបាទ ឈ្មោះថា ឥស្សរិយពលៈ ព្រោះលះបង់ថីនមិទ្ធៈ ញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច ដោយអំណាចអាលោកសញ្ញា ។បេ។ ឈ្មោះថា ឥស្សរិយពលៈ ព្រោះលះបង់កិលេសទាំងពួង ញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច ដោយអំណាចអរហត្តមគ្គ នេះឥស្ស-

រិយពលៈ ។

អធិដ្ឋានពលៈតើដូចម្តេច ។ ឈ្មោះថា អធិដ្ឋានពលៈ ព្រោះបុគ្គលលះបង់កាមច្ឆន្ទៈ អធិដ្ឋានចិត្តដោយអំណាចនេក្ខម្មៈ ឈ្មោះថា អធិដ្ឋានពលៈ ព្រោះលះបង់ព្យាបាទ អធិដ្ឋានចិត្តដោយអំណាចអព្យាបាទ ឈ្មោះថា អធិដ្ឋានពលៈ ព្រោះលះបង់ថីនមិទ្ធៈ អធិដ្ឋានចិត្តដោយអំណាច អាលោកសញ្ញា ។បេ។ ឈ្មោះថា អធិដ្ឋានពលៈ ព្រោះលះបង់កិលេសទាំងពួង អធិដ្ឋានចិត្តដោយអំណាចអរហត្តមគ្គ នេះអធិដ្ឋានពលៈ ។

[ ៩៧ ] សមថពលៈតើដូចម្តេច ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ គឺការមិនរាយមាយដោយអំណាចនេក្ខម្មៈ ឈ្មោះថា សមថពលៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ គឺការមិនរាយមាយ ដោយអំណាចអព្យាបាទ ឈ្មោះថា សមថពលៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ គឺការមិនរាយមាយ ដោយអំណាចអាលោកសញ្ញា ឈ្មោះថា សមថពលៈ ។បេ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ គឺការមិនរាយមាយដោយអំណាចការដកដង្ហើមចេញរបស់បុគ្គលអ្នកពិចារណាឃើញនូវអារម្មណ៍ដែលគួរលះ ឈ្មោះថា សមថពលៈ ភាពនៃចិត្តមានអារម្មណ៍តែមួយ គឺការមិនរាយមាយ ដោយអំណាចខ្យល់ដង្ហើមចូលរបស់បុគ្គលអ្នកពិចារណាឃើញនូវអារម្មណ៍ដែលគួរលះ ឈ្មោះថា សមថពលៈ ។

សំណួរត្រង់ពាក្យថា សមថពលៈ តើសមថពលៈ ដោយអត្ថថាដូចម្តេច ។ ឈ្មោះថា សមថពលៈ ព្រោះបុគ្គលមិនញាប់ញ័រ ក្នុងនីវរណៈ

ដោយបឋមជ្ឈាន ឈ្មោះថា សមថពលៈ ព្រោះមិនញាប់ញ័រក្នុងវិតក្កៈនិងវិចារៈដោយទុតិយជ្ឈាន ឈ្មោះថា សមថពលៈ ព្រោះមិនញាប់ញ័រក្នុងបីតិដោយតតិយជ្ឈាន ឈ្មោះថា សមថពលៈ ព្រោះមិនញាប់ញ័រក្នុងសុខនិងទុក្ខដោយចតុត្ថជ្ឈាន ឈ្មោះថា សមថពលៈ ព្រោះមិនញាប់ញ័រ ក្នុងរូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ឈ្មោះថា សមថពលៈ ព្រោះមិនញាប់ញ័រក្នុងអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ឈ្មោះថា សមថពលៈ ព្រោះមិនញាប់ញ័រក្នុងវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ឈ្មោះថា សមថពលៈ ព្រោះមិនញាប់ញ័រក្នុងអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា សមថពលៈ ព្រោះមិនញាប់ញ័រ មិនកម្រើក មិនរំភើបក្នុងឧទ្ធច្ចៈផង ក្នុងកិលេសដែលប្រព្រឹត្តទៅតាមឧទ្ធច្ចៈផង ក្នុងខន្ធផង នេះសមថពលៈ ។

[ ៩៨ ] វិបស្សនាពលៈតើដូចម្តេច ។ ការពិចារណាឃើញថា មិនទៀង ឈ្មោះថា វិបស្សនាពលៈ ការពិចារណាឃើញថា ជាទុក្ខ ឈ្មោះថា វិបស្សនាពលៈ ។បេ។ ការពិចារណាឃើញថា គួរលះ ឈ្មោះថា វិបស្សនាពលៈ ការពិចារណាឃើញថា មិនទៀងក្នុងរូប ឈ្មោះថា វិបស្សនាពលៈ ការពិចារណាឃើញថា ជាទុក្ខក្នុងរូប ឈ្មោះថា វិបស្សនាពលៈ ។បេ។ ការពិចារណាឃើញថា គួរលះក្នុងរូប ឈ្មោះថា វិបស្សនាពលៈ ការពិចារណាឃើញថា មិនទៀងក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ

ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ឈ្មោះថា វិបស្សនាពលៈ ការពិចារណាឃើញថា ជាទុក្ខក្នុងជរាមរណៈ ឈ្មោះថា វិបស្សនាពលៈ ការពិចារណាឃើញថា គួរលះ ក្នុងជរាមរណៈ ឈ្មោះថាវិបស្សនាពលៈ ។

សំណួរត្រង់ពាក្យថា វិបស្សនាពលៈ តើវិបស្សនាពលៈ ដោយអត្ថថា ដូចម្តេច ។ ឈ្មោះថា វិបស្សនាពលៈ ព្រោះមិនញាប់ញ័រក្នុងនិច្ចសញ្ញា ដោយការពិចារណាឃើញថា មិនទៀង ឈ្មោះថា វិបស្សនាពលៈ ព្រោះមិនញាប់ញ័រក្នុងសុខសញ្ញា ដោយការពិចារណាឃើញថា ជាទុក្ខ ឈ្មោះថា វិបស្សនាពលៈ ព្រោះមិនញាប់ញ័រក្នុងអត្តសញ្ញា ដោយការពិចារណាឃើញថា មិនមែនខ្លួន ឈ្មោះថា វិបស្សនាពលៈ ព្រោះមិនញាប់ញ័រក្នុងសេចក្តីរីករាយ ដោយការពិចារណាឃើញថា គួរនឿយណាយ ឈ្មោះថា វិបស្សនាពលៈ ព្រោះមិនញាប់ញ័រក្នុងរាគៈ ដោយការពិចារណាឃើញថា គួររសាយ ឈ្មោះថា វិបស្សនាពលៈ ព្រោះមិនញាប់ញ័រក្នុងការកើតឡើង ដោយការពិចារណាឃើញនូវការរលត់ ឈ្មោះថា វិបស្សនាពលៈ ព្រោះមិនញាប់ញ័រក្នុងសេចក្តីប្រកាន់ ដោយការពិចារណាឃើញថា គួរលះ ឈ្មោះថា វិបស្សនាពលៈ ព្រោះមិនញាប់ញ័រ មិនកម្រើក មិនរំភើបក្នុងអវិជ្ជាផង ក្នុងកិលេសដែលកើតរលត់ជាមួយគ្នានឹងអវិជ្ជាផង ក្នុងខន្ធផង នេះវិបស្សនាពលៈ ។

[ ៩៩ ] សេក្ខពលៈ ១០ និងអសេក្ខពលៈ ១០ តើដូចម្តេច ។ ឈ្មោះថា សេក្ខពលៈ ព្រោះកំពុងសិក្សានូវសម្មាទិដ្ឋិ ឈ្មោះថា អសេក្ខ-

ពលៈ ព្រោះភាពនៃបុគ្គលដែលបានសិក្សាហើយក្នុងសម្មាទិដ្ឋិនោះ ឈ្មោះថា សេក្ខពលៈ ព្រោះកំពុងសិក្សានូវសម្មាសង្កប្បៈ ឈ្មោះថា អសេក្ខពលៈ ព្រោះភាពនៃបុគ្គលដែលបានសិក្សាហើយ ក្នុងសម្មាសង្កប្បៈនោះ ឈ្មោះថា សេក្ខពលៈ ព្រោះកំពុងសិក្សានូវសម្មាវាចា ។បេ។ នូវសម្មាកម្មន្តៈ នូវសម្មាអាជីវៈ នូវសម្មាវាយាមៈ នូវសម្មាសតិ នូវសម្មាសមាធិ នូវសម្មាញាណៈ ។បេ។ នូវសម្មាវិមុត្តិ ឈ្មោះថា អសេក្ខពលៈ ព្រោះភាពនៃបុគ្គលដែលបានសិក្សាហើយ ក្នុងសម្មាវិមុត្តិ នេះសេក្ខពលៈ ១០ អសេក្ខពលៈ ១០ ។

[ ១០០ ] ខីណាសវពលៈ ( កម្លាំងព្រះខីណាស្រព ) ១០ តើដូចម្តេច ។ ភិក្ខុជាព្រះខីណាស្រព ក្នុងសាសនានេះ បានឃើញជាក់តាមពិតដោយប្រាជ្ញាដ៏ប្រពៃនូវសង្ខារទាំងពួងថា មិនទៀង ត្រង់ដែលភិក្ខុជាព្រះខីណាស្រព បានឃើញជាក់តាមពិតដោយប្រាជ្ញាដ៏ប្រពៃនូវសង្ខារទាំងពួងថា មិនទៀង នេះឯងជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ដែលជាកម្លាំង គឺភិក្ខុជាព្រះខីណាស្រពអាស្រ័យហើយ ទើបដឹងច្បាស់នូវការអស់នៃអាសវៈទាំងឡាយថា អាត្មាអញអស់អាសវៈហើយ ។

មួយទៀត ភិក្ខុជាព្រះខីណាស្រព បានឃើញជាក់តាមពិតដោយប្រាជ្ញាដ៏ប្រពៃនូវកាមទាំងឡាយ ថាមានឧបមាដោយរណ្តៅរងើកភ្លើង ត្រង់ដែលភិក្ខុជាព្រះខីណាស្រព បានឃើញជាក់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃនូវកាមទាំងឡាយថា មានឧបមាដោយរណ្តៅរងើកភ្លើង នេះឯងជាកម្លាំងរបស់ភិក្ខុ

ជាព្រះខីណាស្រព ដែលជាកម្លាំង គឺភិក្ខុជាព្រះខីណាស្រពអាស្រ័យហើយ ទើបដឹងច្បាស់នូវការអស់នៃអាសវៈទាំងឡាយថា អាត្មាអញអស់អាសវៈហើយ ។

មួយទៀត ភិក្ខុជាព្រះខីណាស្រព មានចិត្តឱនទៅរកវិវេក ទោរទៅរកវិវេក ឈមទៅរកវិវេក តាំងនៅក្នុងវិវេក ត្រេកអរក្នុងនេក្ខម្មៈ ឃ្លាតចាកធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈទាំងពួង ត្រង់ដែលភិក្ខុជាព្រះខីណា-ស្រពមានចិត្តឱនទៅរកវិវេក ទោរទៅរកវិវេក ឈមទៅរកវិវេក តាំងនៅក្នុងវិវេក ត្រេកអរក្នុងនេក្ខម្មៈ ឃ្លាតចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងពួង នេះឯងជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រពដែលជាកម្លាំង គឺភិក្ខុជាព្រះខីណាស្រពអាស្រ័យហើយ ទើបដឹងច្បាស់នូវការអស់នៃអាសវៈទាំងឡាយថា អាត្មាអញអស់អាសវៈហើយ ។

មួយទៀត ភិក្ខុជាព្រះខីណាស្រព បានអប់រំ អប់រំល្អហើយនូវស-តិប្បដ្ឋាន ៤ ត្រង់ដែលភិក្ខុជាព្រះខីណាស្រព បានអប់រំ អប់រំល្អហើយនូវសតិប្បដ្ឋាន ៤ នេះឯងជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រពដែលជាកម្លាំង គឺ ភិក្ខុជាព្រះខីណាស្រពអាស្រ័យហើយ ទើបដឹងច្បាស់នូវការអស់នៃអា-សវៈទាំងឡាយថា អាត្មាអញអស់អាសវៈហើយ ។

មួយវិញទៀត ភិក្ខុជាព្រះខីណាស្រព បានអប់រំ អប់រំល្អហើយនូវសម្មប្បធាន ៤ ។បេ។ បានអប់រំ អប់រំល្អហើយនូវឥទ្ធិបាទ ៤ បានអប់រំ អប់រំល្អហើយនូវឥន្ទ្រិយ ៥ បានអប់រំ អប់រំល្អហើយនូវពលៈ ៥ បាន

អប់រំហើយនូវពោជ្ឈង្គ ៧ ។បេ។ បានអប់រំ អប់រំល្អហើយនូវមគ្គប្រកប ដោយអង្គ ៨ ដ៏ប្រសើរ ត្រង់ដែលភិក្ខុជាព្រះខីណាស្រព បានអប់រំ អប់រំល្អហើយនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ នេះឯងជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ដែលជាកម្លាំង គឺភិក្ខុជាព្រះខីណាស្រពអាស្រ័យហើយ ទើបដឹងច្បាស់នូវការអស់នៃអាសវៈទាំងឡាយថា អាត្មាអញអស់អាសវៈហើយ នេះខីណាសវពលៈ ១០ ។

[ ១០១ ] ឥទ្ធិពលៈ ( កម្លាំងឫទ្ធិ ) ១០ តើដូចម្តេច ឫទ្ធិ គឺការអធិដ្ឋាន ១ ឫទ្ធិ គឺការធ្វើឲ្យវិសេស ១ ឫទ្ធិ គឺអ្វីដែលសម្រេចដោយចិត្ត ១ ឫទ្ធិ គឺការផ្សាយចេញដោយសារញាណ ១ ឫទ្ធិ គឺការផ្សាយចេញដោយសារសមាធិ ១ ឫទ្ធិ គឺគុណជាតិប្រសើរ ១ ឫទ្ធិកើតអំពីផលកម្ម ១ ឫទ្ធិរបស់បុគ្គលមានបុណ្យ ១ ឫទ្ធិសម្រេចដោយសារវិជ្ជា ១ ឫទ្ធិដោយអត្ថថាសម្រេច ព្រោះការប្រកបត្រូវក្នុងអំពើនោះៗជាបច្ច័យ ១ នេះឥទ្ធិពលៈ ១០ ។

[ ១០២ ] តថាគតពលៈ ( កម្លាំងព្រះតថាគត ) ១០ តើដូចម្តេច ។ ព្រះតថាគតក្នុងលោកនេះ ទ្រង់ជ្រាបច្បាស់តាមពិតនូវហេតុគួរ ថាជាហេតុគួរផង នូវហេតុមិនគួរ ថាជាហេតុមិនគួរផង ត្រង់ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិតនូវហេតុគួរ ថាជាហេតុគួរផង នូវហេតុមិនគួរ ថាជាហេតុមិនគួរផង នេះឯងជាតថាគតពលៈ របស់ព្រះតថាគត ដែលជាពលៈ គឺព្រះតថាគតអាស្រ័យហើយ ទើបទ្រង់ប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបទ្រង់

បន្លឺនូវសីហនាទក្នុងពួកបរិស័ទ ទើបទ្រង់ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។

មួយទៀត ព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិតនូវផលវិបាកនៃកម្ម-សមាទាន ដែលជាអតីត អនាគតនិងបច្ចុប្បន្ន តាមឋានៈនិងតាមហេតុ ត្រង់ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិតនូវផលវិបាកនៃកម្មសមាទាន ដែលជាអតីត អនាគត និងបច្ចុប្បន្ន តាមឋានៈ និងតាមហេតុ នេះឯងជាតថាគតពលៈរបស់ព្រះតថាគតដែលជាពលៈ គឺព្រះតថាគតអាស្រ័យហើយ ទើបទ្រង់ប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបទ្រង់បន្លឺនូវសីហនាទ ក្នុងពួកបរិស័ទ ទើបទ្រង់ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។

មួយទៀត ព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិតនូវបដិបទា ជាដំណើរទៅកាន់ប្រយោជន៍ទាំងពួង ត្រង់ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិតនូវបដិបទា ជាដំណើរទៅកាន់ប្រយោជន៍ទាំងពួង នេះឯងជាតថាគតពលៈរបស់ព្រះតថាគតដែលជាពលៈ គឺព្រះតថាគតអាស្រ័យហើយ ទើបប្តេជ្ញានូវឋានៈដ៏ប្រសើរ ទើបទ្រង់បន្លឺនូវសីហនាទក្នុងពួកបរិស័ទ ទើបទ្រង់ញុំាងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ ។

មួយទៀត ព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិតនូវលោក មានធាតុច្រើន ឬមានធាតុផ្សេងៗ ត្រង់ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិតនូវលោក មានធាតុច្រើន ឬមានធាតុផ្សេងៗ នេះឯងជាតថាគតពលៈរបស់ព្រះតថាគត ។ បេ ។

មួយទៀត ព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិតនូវអធ្យាស្រ័យផ្សេង ៗ

គ្នារបស់ពួកសត្វ ត្រង់ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិត នូវអ-ធ្យាស្រ័យផ្សេង ៗ គ្នារបស់ពួកសត្វ នេះឯងជាតថាគតពលៈ របស់ព្រះត-ថាគត ។ បេ ។

មួយទៀត ព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិតនូវភាពនៃឥន្ទ្រិយទន់ខ្សោយ និងចាស់ក្លារបស់សត្វដទៃ របស់បុគ្គលដទៃ ត្រង់ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិតនូវភាពនៃឥន្ទ្រិយទន់ខ្សោយនិងចាស់ក្លារបស់សត្វដទៃ របស់បុគ្គលដទៃ នេះឯងជាតថាគតពលៈរបស់ព្រះតថាគត ។បេ។

មួយទៀត ព្រះតថាគតទ្រង់ជ្រាបច្បាស់តាមពិតនូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញនៃឈាន វិមោក្ខ សមាធិនិងសមាបត្តិ ត្រង់ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់តាមពិតនូវសេចក្តីសៅហ្មង នូវសេចក្តីផូរផង់ នូវការចេញនៃឈាន វិមោក្ខ សមាធិនិងសមាបត្តិ នេះឯងជាតថា-គតពលៈ របស់ព្រះតថាគត ។បេ។

មួយទៀត ព្រះតថាគតទ្រង់រឭកឃើញនូវខន្ធបញ្ចកៈដែលធ្លាប់អាស្រ័យហើយក្នុងកាលមុន បានច្រើនជាតិ គឺទ្រង់រឭកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ ទ្រង់រឭកឃើញនូវខន្ធបញ្ចកៈដែលធ្លាប់អាស្រ័យហើយក្នុងកាលមុន បានច្រើនជាតិ ព្រមទាំងអាការនិងឧទ្ទេស ដោយប្រការដូច្នេះ ត្រង់ដែលព្រះតថាគត ទ្រង់រឭកឃើញនូវខន្ធបញ្ចកៈ ដែលធ្លាប់អាស្រ័យនៅហើយ ក្នុងកាលមុនបានច្រើនជាតិ គឺទ្រង់រឭកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ នេះឯងជាតថាគតពលៈ របស់ព្រះតថាគត ។បេ។

មួយទៀត ព្រះតថាគតទ្រង់ឃើញនូវពួកសត្វ ដែលច្យុតនិងកើតឡើង ដោយចក្ខុ ដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ត្រង់ដែលព្រះតថាគតទ្រង់ឃើញពួកសត្វ ។បេ។ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា នេះឯងជាតថាគតពលៈរបស់ព្រះតថាគត ។បេ។

មួយទៀត ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម របស់ព្រះអង្គ ក្នុងបច្ចុប្បន្ននូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះការអស់អាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ត្រង់ដែលព្រះតថាគត បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម របស់ព្រះអង្គ ក្នុងបច្ចុប្បន្ននូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះការអស់អាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ នេះឯងជាតថាគតពលៈរបស់ព្រះតថាគតដែលជាពលៈ គឺព្រះតថាគតអាស្រ័យហើយ ទើបទ្រង់ប្ដេជ្ញានូវឋានៈដ៏ប្រសើរ ទើបទ្រង់បន្លឺសីហនាទក្នុងពួកបរិស័ទ ទើបទ្រង់ញ៉ាំងព្រហ្មចក្កឲ្យប្រព្រឹត្តទៅ នេះតថាគតពលៈ ១០ ។

[ ១០៣ ] សទ្ធាពលៈ ដោយអត្ថដូចម្ដេច វីរិយពលៈ ដោយអត្ថដូចម្ដេច សតិពលៈ ដោយអត្ថដូចម្ដេច សមាធិពលៈ ដោយអត្ថដូចម្ដេច

បញ្ញាពលៈ ដោយអត្ថដូចម្តេច ហិរិពលៈ ដោយអត្ថដូចម្តេច ឱត្តប្បពលៈ ដោយអត្ថដូចម្តេច បដិសង្ខានពលៈ ដោយអត្ថដូចម្តេច តថាគតពលៈ ដោយអត្ថដូចម្តេច ។ សទ្ធាពលៈ ដោយអត្ថថា មិនកម្រើក ព្រោះការណ៍មិនគួរជឿ វិរិយពលៈ ដោយអត្ថថា មិនកម្រើក ព្រោះសេចក្តីខ្ជិល សតិពលៈ ដោយអត្ថថា មិនកម្រើក ព្រោះការប្រហែស សមាធិពលៈ ដោយអត្ថថា មិនកម្រើក ព្រោះសេចក្តីរាយមាយ បញ្ញាពលៈ ដោយអត្ថថា មិនកម្រើក ព្រោះអវិជ្ជា ឈ្មោះថា ហិរិពលៈ ព្រោះខ្មាសចំពោះអកុសលធម៌ដ៏លាមក ឈ្មោះថា ឱត្តប្បពលៈ ព្រោះខ្លាចចំពោះអកុសលធម៌ដ៏លាមក ឈ្មោះថា បដិសង្ខានពលៈ ព្រោះពិចារណានូវកិលេស ដោយញាណ ឈ្មោះថា ភាវនាពលៈ ព្រោះធម៌ទាំងឡាយដែលកើតក្នុងទីនោះមានរសតែមួយ ឈ្មោះថា អនវជ្ជពលៈ ព្រោះទោសបន្តិចបន្តួចមិនមានក្នុងធម៌នោះ ឈ្មោះថា សង្គាហពលៈ ព្រោះសង្គ្រោះចិត្តដោយធម៌នោះ ឈ្មោះថា ខន្តិពលៈ ព្រោះនេក្ខម្មៈអត់ធន់បានចំពោះធម្មជាតនោះ ឈ្មោះថា បញ្ញត្តិពលៈ ព្រោះបញ្ញត្តចិត្តដោយធម៌នោះ ឈ្មោះថា និជ្ឈត្តិពលៈ ព្រោះសម្លឹងមើលចិត្តដោយធម៌នោះ ឈ្មោះថា ឥស្សរិយពលៈ ព្រោះញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចដោយធម៌នោះ ឈ្មោះថា អធិដ្ឋានពលៈ ព្រោះ

អធិដ្ឋានចិត្តដោយធម៌នោះ ឈ្មោះថា សមថពលៈ ព្រោះចិត្តមានអារម្មណ៍តែមួយដោយធម៌នោះ ឈ្មោះថា វិបស្សនាពលៈ ព្រោះពិចារណាឃើញនូវធម៌ដែលកើតហើយក្នុងធម៌នោះ ឈ្មោះថា សេក្ខពលៈ ព្រោះកំពុងសិក្សាក្នុងធម៌នោះ ឈ្មោះថា អសេក្ខពលៈ ព្រោះភាពនៃបុគ្គលបានសិក្សាហើយក្នុងធម៌នោះ ឈ្មោះថា ខីណាសវពលៈ ព្រោះលោកអស់អាសវៈហើយដោយធម៌នោះ ឈ្មោះថា ឥទ្ធិពលៈ ព្រោះធម្មជាតនោះសម្រេចដល់បុគ្គលនោះ ឈ្មោះថា តថាគតពលៈ ដោយអត្ថថា មានគុណរាប់មិនបាន ។

## ចប់ ពលកថា ។

# អដ្ឋកថា

## ពលកថា

[ ៩២ ] ឥឡូវនេះនឹងពណ៌នាសេចក្ដីតាមលំដាប់ ដែលមិនធ្លាប់ពណ៌នា ក្នុងពលកថា ដែលមានព្រះសូត្រជាបទនាំ ដែលជាប្រយោជន៍ដល់លោកុត្តរកថា ដែលព្រះសារីបុត្តត្ថេរពោលទុក បន្ទាប់អំពីលោកុត្តរកថា ។ ក្នុងពលកថានោះ ព្រះសារីបុត្តត្ថេរ កាលសម្ដែងពលៈ ៥ ដោយព្រះសូត្រអំពីខាងដើម ហើយបំណងនឹងសម្ដែងពលៈ សូម្បីដទៃពីពលៈ ៥ នោះ ទើបពោលពាក្យថា **អបិច អដ្ឋសដ្ឋិ ពលានិ** ជាដើម ។ សូម្បីពលៈ ៦៨ ទាំងអស់ក៏ឈ្មោះថា ពលៈ ព្រោះអត្ថថា មិនញាប់ញ័រ ដោយភាវៈផ្ទុយគ្នានឹងពលៈនោះ ៗ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ហិរិពលំ** ជាដើម ដូចតទៅនេះថា ឈ្មោះថា ហិរិ ព្រោះជាហេតុឲ្យសត្វខ្មាសចំពោះបាប ។ ពាក្យនោះ ជាឈ្មោះរបស់សេចក្ដីខ្មាស ។ ឈ្មោះថា ឱត្តប្បៈ ព្រោះជាហេតុឲ្យសត្វខ្លាចចំពោះបាប ។ ពាក្យនោះ ជាឈ្មោះរបស់សេចក្ដីតក់ស្លុតចំពោះបាប ។ ហិរិមានវត្ថុខាងក្នុងជាសមុដ្ឋាន ឱត្តប្បៈមានវត្ថុខាងក្រៅជាសមុដ្ឋាន ។ ហិរិមានខ្លួនជាធំ ឱត្តប្បៈមានលោកជាធំ ។ ហិរិតាំងនៅក្នុងសភាពដែលខ្មាស ឱត្តប្បៈតាំងនៅក្នុងសភាពដែលខ្លាច ។ ហិរិមានសេចក្ដីគោរពជាលក្ខណៈ ឱត្តប្បៈមានការឃើញភ័យរបស់បុគ្គលខ្លាចទោសជាលក្ខណៈ ។ ហិរិនោះឯង ឈ្មោះថា ហិរិពលៈ ព្រោះមិនញាប់ញ័រដោយការមិនមានហិរិ ។

ឱត្តប្បៈនោះឯង ឈ្មោះថា ឱត្តប្បពលៈ ព្រោះមិនញាប់ញ័រដោយការមិនមានឱត្តប្បៈ ។

ឈ្មោះថា បដិសង្ខានពល ព្រោះមិនញាប់ញ័រ ដោយការមិនពិចារណា ។ បទនេះ ជាឈ្មោះរបស់បញ្ញាដែលចូលទៅពិចារណា ។

ពលៈដែលកើតឡើងដល់ព្រះយោគាវចរអ្នកចម្រើនពោជ្ឈង្គៈ ៧ ដោយសេចក្ដីព្យាយាមជាគោល ឈ្មោះថា ភាវនាពលៈ ។ បទនេះ ជាឈ្មោះរបស់ខន្ធ ៤ ដែលប្រព្រឹត្តទៅយ៉ាងនោះ ។

សីលជាដើមដែលបរិសុទ្ធ ឈ្មោះថា អនវជ្ជពលៈ ។ សង្គហវត្ថុ ៤ ឈ្មោះថា សង្គាហពល ។ បាឋៈថា **សង្គហោ ពលំ** ដូច្នេះក៏មាន ។ ការអត់ទ្រាំចំពោះទុក្ខ ឈ្មោះថា ខន្តិពល ។ ការធ្វើឲ្យអ្នកដទៃត្រេកអរក្នុងធម្មកថា ឈ្មោះថា បញ្ញត្តិពល ។ ការសម្លឹងដល់ប្រយោជន៍ដែលបានរៀនមក ឈ្មោះថា និជ្ឈត្តិពលៈ ។

ភាពជាអ្នកច្រើនក្នុងកុសលទាំងឡាយ ឈ្មោះថា ឥស្សរិយពលៈ ។ ការតាំងនៅក្នុងកុសលទាំងឡាយ តាមការពេញចិត្ត ឈ្មោះថា អធិដ្ឋានពល ។

អត្ថរបស់ហិរិពលៈជាដើម លោកកាន់យកអត្ថ ដែលប្រកបដោយពិសេសដោយអំណាចព្យញ្ជនៈពោលទុកហើយ ក្នុងបទមាតិកាទាំងឡាយ ។

បទថា **សមថពលំ វិបស្សនាពលំ** បានដល់ សមថៈនិងវិបស្សនាដែលមានកម្លាំងនោះឯង ។

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមាតិកានិទ្ទេស ដូចតទៅនេះថា ព្រះសារីបុត្តត្ថេរ ពោលដល់អត្ថរបស់ពលៈ ដែលជាមូលថា **អស្សទ្ធិយេ ន កម្បតីតិ សទ្ធាពលំ** ហើយសម្តែងសទ្ធាពលៈនោះឲ្យពិសេសដោយបរិយាយ ៩ ដទៃទៀត ។ ពិតណាស់ ធម៌ណាមិនញាប់ញ័រ ជាធម៌មានកម្លាំង ធម៌នោះរមែងឧបត្ថម្ភធម៌ដែលកើតរួមគ្នា រមែងកម្ចាត់កិលេសដែលជាបដិបក្ខរបស់ខ្លួន រមែងជម្រះសីល និងទិដ្ឋិដែលជាខាងដើមនៃការបាក់ធ្លុះឲ្យបរិសុទ្ធ រមែងធ្វើចិត្តឲ្យតាំងមាំក្នុងអារម្មណ៍ កាលធ្វើចិត្តឲ្យផូរផង់ រមែងធ្វើឲ្យផូរផង់ កាលឲ្យសម្រេចនូវភាពជំនាញ រមែងធ្វើឲ្យសម្រេចគុណវិសេស កាលឲ្យសម្រេចគុណវិសេសក្រៃលែងជាងនោះ រមែងឲ្យធ្វើនូវការបាក់ធ្លុះក្រៃលែងឡើង កាលសម្រេចអរិយមគ្គតាមលំដាប់ហើយ រមែងឲ្យធ្វើការសម្រេចសច្ចៈបាន រមែងឲ្យតាំងនៅក្នុងនិរោធដោយការសម្រេចផលបាន ព្រោះហេតុនោះ ទើបលោកធ្វើអត្ថនៃពលៈឲ្យពិសេសដោយអាការ ៩ យ៉ាង ។ ក្នុងពលៈ ៤ មានវីរិយពលៈជាដើម ក៏មានន័យនេះ ។

[ ៩៤ ] បទថា **កាមច្ឆន្ទំ ហិរីយតិ** បានដល់ ព្រះយោគាវចរដែលប្រកបដោយនេក្ខម្មៈ រមែងខ្មាសចំពោះកាមច្ឆន្ទៈ ដោយនេក្ខម្មៈ ។ សូម្បីក្នុងឱត្តប្បៈក៏ន័យនេះដូចគ្នា ។ ដោយពាក្យទាំងនេះ ឈ្មោះថាលោកពោលដល់ការខ្មាស ការខ្លាចចំពោះអកុសលទាំងពួង ( ផងដែរ ) ។

សូម្បីពាក្យថាព្យាបាទជាដើម ក៏គប្បីជ្រាបអត្ថដោយន័យនេះដូចគ្នា ។ បទថា **បដិសង្ខាតិ** បានដល់ ពិចារណាដោយភាពជាទោស ដោយការ

មិនរៀងង ។

[ ៩៥ ] បទថា **ភាវេតិ** បានដល់ រមែងឲ្យចម្រើន ។ បទថា **វដ្ដំ** បានដល់ ទោសមានរាគៈជាដើម ។ បទថា **សង្កណ្ហាតិ** បានដល់ រមែងចង ។

[ ៩៦ ] បទថា **ទមតិ** បានដល់ ព្រះយោគាវចរនោះ រមែងអត់ធន់ រមែងពេញចិត្ត ។ បទថា **បញ្ញាបេតិ** បានដល់ រមែងឲ្យត្រេកអរ ។

បទថា **និជ្ឈាបេតិ** បានដល់ រមែងធ្វើចិត្តឲ្យគិត ។ បទថា **វសំ វត្តេតិ** បានដល់ ធ្វើចិត្តដែលអាចគិតឲ្យប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួន ។ បទថា **អធិដ្ឋាតិ** បានដល់ រមែងចាត់ចែង ។ សូម្បីពលៈទាំងអស់មានភាវនាពលៈជាដើមក៏ជានេក្ខម្មៈជាដើមនោះឯង ។ គប្បីជ្រាបថា ក្នុងអដ្ឋកថានៃមាតិកា លោកពោលទុកដោយប្រការដទៃ តែលោកមិនពោលអត្ថទុកក្នុងទីនេះ ព្រោះប្រាកដច្បាស់ដោយព្យញ្ជនៈហើយ ។

[ ៩៧-៩៨ ] ព្រះសារីបុត្តត្ថេរ សម្ដែងសមថពលៈនិងវិបស្សនាពលៈដោយពិស្ដារ ក្នុងទីបំផុតពោលបទថា **ឧទ្ធច្ចសហគតកិលេសេ ច ខន្ធេ ច ន កម្បតិ** ជាដើម និងបទថា **អវិជ្ជាសហគតក្កិលេសេ ច ខន្ធេ ច ន កម្បតិ** ជាដើម ដើម្បីសម្ដែងដល់លក្ខណៈរបស់សមថពលៈនិងវិបស្សនាពលៈ ។

[ ៩៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសេក្ខពលៈនិងអសេក្ខពលៈ ដូចតទៅនេះថា បទថា **សម្មាទិដ្ឋឹ សិក្ខតីតិ សេក្ខពលំ** សេចក្ដីថា ឈ្មោះថា ព្រះ

សេក្ខៈ ព្រោះព្រះសេក្ខៈបុគ្គលនៅសិក្សាសម្មាទិដ្ឋិ សម្មាទិដ្ឋិនោះ ឈ្មោះថា សេក្ខពលៈ ព្រោះជាកម្លាំងរបស់ព្រះសេក្ខៈនោះ ។ បទថា **តត្ថ សិក្ខិតត្តា អសេក្ខពលំ** សេចក្ដីថា ឈ្មោះថា ព្រះអសេក្ខៈ ព្រោះអសេក្ខបុគ្គល មិនត្រូវសិក្សា ព្រោះសិក្សាសម្មាទិដ្ឋិនោះស្រេចហើយ សម្មាទិដ្ឋិនោះឯង ឈ្មោះថា អសេក្ខពលៈ ព្រោះជាកម្លាំងរបស់ព្រះអសេក្ខនោះ ។ ក្នុងសម្មាសង្កប្បៈ ជាដើម ក៏មានន័យនេះដូចគ្នា ។

បទថា **សម្មាញាណំ** បានដល់ បច្ចវេក្ខណញាណ ។ ពិតណាស់ សូម្បីញាណនោះជាលោកិយៈ ក៏ហៅថា សេក្ខពលៈ ព្រោះព្រះសេក្ខៈនៅប្រព្រឹត្ត ហៅថា អសេក្ខពលៈ ព្រោះព្រះអសេក្ខៈនៅប្រព្រឹត្ត ។ បទថា **សម្មាវិមុត្តិ** បានដល់ ធម៌ដែលសម្បយុត្តដោយផលដ៏សេស វៀរអង្គនៃមគ្គ ៨ តែអាចារ្យពួកខ្លះពោលថា វិមុត្តិដ៏សេស វៀរលោកុត្តរវិមុត្តិ ជាសម្មាវិមុត្តិ ។ សម្មាវិមុត្តិនោះ ជាសេក្ខពលៈនិងអសេក្ខពលៈ មានន័យដូចពោលហើយនោះឯង ។

[ ១០០-១០១ ] ពលៈទាំងអស់ក្នុងខីណាសវពលៈជាញាណពលៈ ។ បទថា **ខីណាសវស្ស ភិក្ខុនោ** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ជា **ខីណាសវេន ភិក្ខុនា** ( ដែលភិក្ខុខីណាស្រព ) ។ បទថា **អនិច្ចតោ** បានដល់ ដោយភាពមិនទៀងដោយអាការមានហើយត្រឡប់ជាមិនមាន ។ បទថា **យថាភូតំ** បានដល់ តាមសភាវៈពិត ។ បទថា **បញ្ញាយ** បានដល់ ដោយមគ្គប្បញ្ញា និងដោយវិបស្សនា ភិក្ខុជាខីណាស្រពឃើញដោយ

ល្អ ដោយភាពជារបស់មិនទៀង រមែងជាអ្នកឃើញដោយល្អ ដោយភាពជាទុក្ខ ដោយមិនមែនតួខ្លួន ព្រោះមានការមិនទៀងនោះជាមូល ។ បទថា **យំ** ជាភាវនបុំសកលិង្គ ឬមានសេចក្តីថា ដោយហេតុណា ។ បទថា **អាគម្ម** បានដល់ អាស្រ័យហើយ ។ បទថា **បដិជានាតិ** បានដល់ រមែងទទួល គឺធ្វើនូវការអះអាង ។ បទថា **អង្គារកាសូបមា** បានដល់ ប្រៀបដោយរណ្តៅរងើកភ្លើង ដោយអត្ថថា ក្តៅខ្លាំង ។ បទថា **កាមា** បានដល់ វត្ថុកាមនិងកិលេសកាម ។ បទថា **វិវេកនិន្នំ** បានដល់ បង្អោនទៅក្នុងនិព្វាន ពោលគឺឧបធិវិវេក ដោយផលសមាបត្តិ ។ ពិតណាស់ វិវេកមាន ៣ គឺកាយវិវេក ១ ចិត្តវិវេក ១ ឧបធិវិវេក ១ ។

បុគ្គលមានកាយតាំងនៅក្នុងការស្ងាត់ ត្រេកអរក្នុងនេក្ខម្មៈ ឈ្មោះថា កាយវិវេក បុគ្គលខ្វល់ខ្វាយក្នុងអធិចិត្ត ឈ្មោះថា ចិត្តវិវេក ។ បុគ្គលអ្នកមិនមានឧបធិ ប្រាសចាកគ្រឿងតាក់តែង ឈ្មោះថា ឧបធិវិវេក ។ ម្យ៉ាងទៀត បង្អោនទៅក្នុងនិព្វាន ពោលគឺនិស្សរណវិវេក ។ ពិតណាស់ វិវេកមាន ៥ យ៉ាង គឺវិក្ខម្ភនវិវេក ១ តទង្គវិវេក ១ សមុច្ឆេទវិវេក ១ បដិបស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។ ម្យ៉ាងទៀត បទថា **វិវេកនិន្នំ** បានដល់ បង្អោនទៅហើយក្នុងវិវេក ។ បទថា **វិវេកបោណំ** បានដល់ ទោរទៅហើយក្នុងវិវេក ។ បទថា **វិវេកបព្ភារំ** បានដល់ ឈមទៅក្នុងវិវេក ។ សូម្បីបទទាំងពីរ ក៏ជាវេវចនៈរបស់បទមុននោះឯង ។ បទថា **វិវេកដ្ឋំ** បានដល់ វៀរ ឬឆ្ងាយចាកកិលេសទាំងឡាយ ។ បទថា **នេក្ខ-**

**ម្នាភិរតំ** បានដល់ ត្រេកអរក្នុងនិព្វាន ឬត្រេកអរក្នុងបព្វជ្ជា ។ បទថា **ព្យន្តីភូតំ** បានដល់ ប្រាសចាកទៅដល់ទីបំផុត គឺមិនត្រូវធ្វើឲ្យប្រឡាក់ផុតទៅ មិនជាប់ចំពាក់ សូម្បីអំពីចំណែកមួយ ។ បទថា **សព្វសោ** បានដល់ ដោយប្រការទាំងពួង ។ បទថា **អាសវដ្ឋានិយេហិ ធម្មេហិ** សេចក្តីថា ចាកកិលេសធម៌ដែលជាហេតុ របស់អាសវៈទាំងឡាយ ដោយអំណាចការប្រកប ។

ម្យ៉ាងទៀត បទថា **ព្យន្តីភូតំ** បានដល់ ប្រាសចាកការជាប់ចិត្ត អធិប្បាយថា អស់តណ្ហា ។ ប្រាសចាកធម៌អ្វី ចាកធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈដោយប្រការទាំងពួង គឺចាកធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងពួង ។ ក្នុងទីនេះលោកពោលដល់លោកិយមគ្គនិងលោកុត្តរមគ្គ របស់ព្រះខីណាស្រពដោយខីណាសវពលៈ ១០ ។ អាចារ្យទាំងឡាយពោលថា បទថា **អនិច្ចតោ សព្វេ សង្ខារា** ជាពលៈកំណត់ដឹងទុក្ខ បទថា **អង្គារកាសូបមា កាមា** ជាពលៈលះសមុទយៈ បទថា **វិវេកនិន្នំ ចិត្តំ ហោតិ** ជាពលៈធ្វើឲ្យជាក់ច្បាស់នូវនិរោធ បទ ៧ មានបទថា **ចត្តារោ សតិប្បដ្ឋានា** ជាពលៈក្នុងការចម្រើនមគ្គ ។ ឥន្ទ្រិយពលៈ ១០ នឹងមានជាក់ច្បាស់ក្នុងឥទ្ធិកថា ។

[ ១០២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតថាគតពលនិទ្ទេស ដូចតទៅនេះថា បទថា **តថាគតពលានិ** បានដល់ កម្លាំងរបស់ព្រះតថាគតប៉ុណ្ណោះដែលមិនទូទៅដល់អ្នកដទៃ ឬមានអធិប្បាយថា ពលៈដែលមកហើយដូចពលៈ

របស់ព្រះពុទ្ធអំពីមុនដែលមកហើយដោយការដល់ព្រមនៃការសន្សំបុណ្យ ។ ក្នុងបទនោះ តថាគតពលៈ មាន ២ យ៉ាងគឺ កាយពល ១ ញាណពល ១ ក្នុងពលៈ ២ យ៉ាងនោះ គប្បីជ្រាបកាយពលៈ ដោយរាប់តាមត្រកូលដំរី ។ សមដូចបោរាណាចារ្យទាំងឡាយពោលទុកថា

ត្រកូលដំរីទាំង ១០ នេះ គឺកាឡាវកៈ ១ គង្គេយ្យៈ ១
បណ្ឌរៈ ១ តម្ពៈ ១ បិង្គលៈ ១ គន្ធៈ ១ មង្គលៈ ១
ហេមៈ ១ ឧបោសថ ១ ឆទ្ទន្ត ១ ។

ទាំងនេះគឺត្រកូលដំរី ១០ ។ ក្នុងពាក្យទាំងនោះពាក្យថា កាឡាវកៈ គប្បីឃើញថា ជាត្រកូលដំរីតាមប្រក្រតី ។ កម្លាំងកាយរបស់បុរស ១០ ស្មើនឹងកម្លាំងរបស់ដំរីត្រកូលកាឡាវកៈ ១ ។ កម្លាំងរបស់ត្រកូលដំរីកាឡាវកៈ ១០ ស្មើនឹងកម្លាំងរបស់ត្រកូលដំរីគង្គេយ្យៈ ១ កម្លាំងរបស់ត្រកូលដំរីគង្គេយ្យៈ ១០ ស្មើនឹងកម្លាំងរបស់ត្រកូលដំរីបណ្ឌរៈ ១ កម្លាំងរបស់ត្រកូលដំរីបណ្ឌរៈ ១០ ស្មើនឹងកម្លាំងរបស់ត្រកូលដំរីតម្ពៈ ១ កម្លាំងរបស់ត្រកូលដំរីតម្ពៈ ១០ ស្មើនឹងកម្លាំងរបស់ត្រកូលដំរីបិង្គលៈ ១ កម្លាំងរបស់ត្រកូលដំរីបិង្គលៈ ១០ ស្មើនឹងកម្លាំងរបស់ត្រកូលដំរីគន្ធៈ ១ កម្លាំងរបស់ត្រកូលដំរីគន្ធៈ ១០ ស្មើនឹងកម្លាំងរបស់ត្រកូលដំរីមង្គលៈ ១ កម្លាំងរបស់ត្រកូលដំរីមង្គលៈ ១០ ស្មើនឹងកម្លាំងរបស់ត្រកូលដំរីហេមវតៈ ១ កម្លាំងរបស់ត្រកូលដំរីហេមវតៈ ១០ ស្មើនឹងកម្លាំងរបស់ត្រកូលដំរីឧបោសថ ១ កម្លាំងរបស់ត្រកូលដំរីឧបោសថ ១០ ស្មើនឹងកម្លាំងរបស់ត្រកូលដំរីឆទ្ទន្ត

១ កម្លាំងរបស់ត្រកូលដំរីឆទ្ទន្ត ១០ ស្មើនឹងកម្លាំងរបស់ព្រះតថាគតមួយព្រះអង្គ ។

ពាក្យនេះលោកពោលដល់សូម្បីពាក្យថា កម្លាំងដែលប្រៀបដូចព្រះនារាយន៍នោះឯង តថាគតពលៈនោះស្មើគ្នានឹងកម្លាំងដំរីធម្មតា ១.០០០ កោដិ ស្មើនឹងកម្លាំងបុរស ១០.០០០ កោដិ នេះគឺកាយពលៈរបស់ព្រះតថាគត ។

ចំណែកញាណពលៈ បានដល់ទសពលញាណដែលមកហើយ ក្នុងពលកថានេះ និងក្នុងបាលីដទៃ ចតុវេសារជ្ជញាណ អកម្បនញាណ ( ញាណដែលមិនញាប់ញ័រ ) ក្នុងបរិស័ទ ៨ ចតុយោនិបរិច្ឆេទកញ្ញាណ ( ញាណកំណត់កំណើត ៤ ) បញ្ចគតិបរិច្ឆេទកញ្ញាណ ( ញាណកំណត់គតិ ៥ ) មកហើយក្នុងមជ្ឈិមនិកាយ ញាណ ៧៣ ញាណ ៧៧ មកហើយក្នុងសំយុត្តនិកាយ ហេតុនោះទើបញាណមានច្រើនពាន់ សូម្បីដទៃយ៉ាងនេះ នេះឈ្មោះថា ញាណពលៈ ។ ក្នុងទីនេះ លោកបំណងយកញាណពលៈនោះឯង ។ ញាណលោកហៅថា ពលៈ ដោយអត្ថថា មិនញាប់ញ័រ និងដោយអត្ថថា ឧបត្ថម្ភ ។

បទថា **ឋានញ្ច ឋានតោ** បានដល់ នូវហេតុដោយជាហេតុ ។ ហេតុហៅថា ឋានៈ ព្រោះជាទីតាំងនៃផល គឺផលរមែងកើតឡើងនិងរមែងប្រព្រឹត្តទៅ ព្រោះប្រព្រឹត្តទៅទាក់ទងដោយហេតុនោះ ។ ព្រះមានព្រះភាគ កាលទ្រង់ជ្រាបធម៌ដែលជាហេតុ ជាបច្ច័យដើម្បីការកើតឡើងនៃធម៌ ថាជាឋានៈ ព្រោះធម៌ដែលមិនជាហេតុ មិនជាបច្ច័យ ដើម្បីការកើតឡើងនៃធម៌ ថាជា

ឋានៈ ឈ្មោះថា ទ្រង់រមែងជ្រាបឋានៈថាជាឋានៈ និងអឋានៈថាជាអឋានៈ តាមសេចក្ដីពិត ។ បទថា **យម្បិ** បានដល់ ដោយញាណណា ។ បទថា **ឥទម្បិ** បានដល់ ឋានាឋានញ្ញាណនេះ ក៏ឈ្មោះថា តថាគតពលៈរបស់ព្រះតថាគត ។ សូម្បីបទដ៏សេសក៏គប្បីជ្រាបការប្រកបយ៉ាងនេះ ។

បទថា **អាសភណ្ឋានំ** បានដល់ ឋានៈដ៏ប្រសើរ ឋានៈដ៏ឧត្ដម អធិប្បាយថា ឋានៈរបស់ព្រះពុទ្ធអំពីមុនទាំងឡាយដ៏អង់អាច ។ម្យ៉ាងទៀត គោឧសភៈ ជាប្រធាននៃគោ ១០០ គោវសភៈ ជាប្រធាននៃគោ ១.០០០ ម្យ៉ាងទៀត គោឧសភៈជាប្រធាននៃគោ ១០០ ក្រោល គោវសភៈជាប្រធាននៃគោ ១.០០០ ក្រោល គោនិសភៈប្រសើរជាងគោទាំងអស់ អត់ទ្រាំចំពោះអន្ដរាយទាំងពួងបាន ពណ៌សគួរស្រឡាញ់ នាំការៈទៅបានច្រើន មិនតក់ស្លុត សូម្បីសំឡេងរន្ទះបាញ់តាំងឡើង ១០០ ដង និសភៈនោះ លោកបំណងយកថា ឧសភៈ ក្នុងទីនេះ ។ ពាក្យថា ឧសភៈ នេះក៏ជាពាក្យហៅដោយអមរបស់និសភៈនោះ ឈ្មោះថា អាសភៈ ព្រោះអត្ថថា ឋានៈនេះរបស់ឧសភៈ ។

បទថា **ឋានំ** បានដល់ យកជើងទាំង ៤ ជាន់លើផែនដី ឲ្យមាំ ។ម្យ៉ាងទៀត ឋានៈនេះ ឈ្មោះថា អាសភៈ ព្រោះដូចអ្នកអង់អាច ដូចជាគោឧសភៈ ពោលគឺគោនិសភៈប្រកបដោយកម្លាំងរបស់គោឧសភៈ យកជើងទាំង ៤ ជាន់ផែនដី ឈរនៅដោយឋានៈមិនញាប់ញ័រយ៉ាងណា សូម្បីព្រះតថាគត ក៏យ៉ាងនោះ ទ្រង់ប្រកបដោយតថាគតពលៈ ១០ យកជើង

គឺវេសារជ្ជញ្ញាណ ៤ ជាន់ផែនដី គឺបរិស័ទ ៨ មិនញាប់ញ័រដោយសឹកសត្រូវណាមួយក្នុងលោកព្រមទាំងទេវលោក តាំងនៅដោយឋានៈដែលមិនញាប់ញ័រ កាលតាំងនៅយ៉ាងនេះ រមែងប្តេជ្ញានូវឋានៈដ៏អង់អាចនោះ គឺចូលទៅជិត មិនលះបង់ឲ្យលើកឡើងទុកក្នុងខ្លួន ។ ដោយហេតុនោះទើបលោកពោលថា **អាសភណ្ឌានំ បដិជានាតិ** ។

បទថា **បរិសាសុ** បានដល់ ក្នុងបរិស័ទ ៨ គឺ ក្សត្រ ព្រាហ្មណ៍ គហបតី សមណៈ ទេវតាជាន់ចាតុម្មហារាជិកៈ ទេវតាជាន់តាវត្តិង្ស មារ និងព្រហ្ម ។ បទថា **សីហនាទំ នទតិ** បានដល់ បន្លឺសំឡេងប្រសើរ សំឡេងមិនតក់ស្លុត ឬបន្លឺសំឡេងគឹកកង ដូចសំឡេងសីហៈ ។

គប្បីសម្តែងអត្ថនេះ ដោយសីហនាទសូត្រ ។ រាជសីហ៍លោកហៅថា សីហៈ ព្រោះអត់ធន់ ព្រោះសម្លាប់សត្វជាអាហារ យ៉ាងណា ព្រះតថាគតក៏យ៉ាងនោះ ។ លោកពោលថា សីហៈ ព្រោះអត់ធន់ចំពោះលោកធម៌និងកម្ចាត់បរប្បវាទ ការបន្លឺរបស់សីហៈ ដូចពោលហើយយ៉ាងនោះ ឈ្មោះថា សីហនាទ ។ ក្នុងសេចក្តីនោះ សីហៈប្រកបដោយសីហពលៈ ក្លៀវក្លាក្នុងទីទាំងពួង ប្រាសចាកការព្រឺរោម ព្រឺស្បែក បន្លឺសីហនាទ យ៉ាងណា សូម្បីព្រះតថាគតសីហៈ ក៏យ៉ាងនោះ ទ្រង់ប្រកបដោយតថាគតពលៈ ទ្រង់ក្លៀវក្លាក្នុងបរិស័ទ ៨ ប្រាសចាកការព្រឺរោម ព្រឺស្បែក ទ្រង់បន្លឺសីហនាទដែលដល់ព្រមដោយលម្អនៃទេសនាច្រើនយ៉ាង ដោយន័យថា **ឥតិ រូបំ** រូបយ៉ាងនេះ ជាដើម ។ ដោយហេតុនោះ ទើបលោកពោលថា **បរិសាសុ**

**សីហនាទំ នទតិ** ដូច្នេះ ។ បទថា **ព្រហ្មំ** ក្នុងបទនេះថា **ព្រហ្មចក្កំ បវត្តេតិ** បានដល់ ប្រសើរ ឧត្តម បរិសុទ្ធ ។ គប្បីជ្រាប **ចក្ក** សព្ទ ដូចតទៅនេះថា

ចក្កសព្ទប្រាកដក្នុងសម្បត្តិ លក្ខណៈ អង្គនៃរថ ឥរិយាបថ ទាន រតនចក្ក ធម្មចក្ក ឧរចក្ក ( ខុរចក្ក ) ជាដើម ក្នុងទីនេះប្រាកដក្នុងធម្មចក្ក ព្រះយោគាវចរគប្បីប្រកាសធម្មចក្កនោះ ដោយអាការ ២ យ៉ាង ។

**ចក្ក** សព្ទ ប្រាកដក្នុងសម្បត្តិ ដូចក្នុងយោគជាដើមថា **ចត្តារីមានិ ភិក្ខវេ ចក្កានិ យេហិ សមន្នាគតានំ ទេវមនុស្សានំ** ម្នាលភិក្ខុទាំងឡាយ ចក្កនេះមាន ៤ យ៉ាង ចក្កនេះតែងប្រព្រឹត្តទៅដល់ពួកទេវតា និងមនុស្ស ដែលប្រកបព្រមចក្ក ... ដូច្នេះ ។ ប្រាកដក្នុងលក្ខណៈ ដូចក្នុងយោគជាដើមថា **ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ** ចក្កទាំងឡាយកើតមានត្រង់ផ្ទៃព្រះបាទានៃព្រះរាជកុមារនេះ ដូច្នេះ ។ ប្រាកដក្នុងអង្គនៃរថ ក្នុងប្រយោគជាដើមថា **ចក្កំវ វហតោ បទំ** ដូចកង់រទេះវិលតាមជានជើងគោ ដែលកំពុងអូសទៅ ដូច្នេះ ។ ប្រាកដក្នុងឥរិយាបថ ដូចក្នុងប្រយោគជាដើមថា **ចតុចក្កំ នវទ្វារំ** សរីរៈមានចក្ក ៤ មានទ្វារ ៩ ដូច្នេះ ។ ប្រាកដក្នុងទាន ដូចក្នុងប្រយោគជាដើមថា **ទទំ ភុញ្ជ មា ច បមាទោ ចក្កំ វត្តយ កោសលាធិប** បពិត្រព្រះអង្គមានព្រះអធ្យាស្រ័យជាកុសល សូមព្រះអង្គទ្រង់ព្រះរាជទាន ហើយសឹមទ្រង់សោយ សូមព្រះអង្គកុំប្រមាទ ( ក្នុង

បុណ្យទាំងឡាយ ) សូមព្រះអង្គញុំាងចក្កធម៌ ឲ្យប្រព្រឹត្តទៅ ដូច្នេះ ។ ប្រាកដក្នុងរតនចក្កដូចក្នុងប្រយោគជាដើមថា **ទិព្វំ ចក្ករតនំ ចាតុរហោសិ** ចក្ករតន៍ជាទិព្វមានកាំ ១០០០ ព្រមទាំងខ្នងនិងដុំ បរិបូរណ៍ដោយអាការទាំងពួង ក៏កើតប្រាកដហើយ ដូច្នេះ ។ ប្រាកដក្នុងធម្មចក្កដូចក្នុងប្រយោគជាដើមថា **មយា បវត្តិតំ ចក្កំ** ញុំាងធម្មចក្ក ជាចក្កដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ដូច្នេះ ។ ប្រាកដក្នុងឧរចក្ក ដូចក្នុងប្រយោគជាដើមថា **ឥច្ឆាហតស្ស បោសស្ស ចក្កំ ភមតិ មត្ថកេ** ចក្កវិលកិនអំបែងក្បាលបុគ្គល ដែលឥច្ឆាគ្របសង្កត់ហើយ ដូច្នេះ ។ ប្រាកដក្នុងបហរណចក្កដូចក្នុងប្រយោគជាដើមថា **ខុរបរិយន្តេន ចេបិ ចក្កេន** ដោយគ្រឿងចក្ក មានខ្នងកង់ដ៏មុត ដូចជាកាំបិតកោរ ដូច្នេះ ។ ប្រាកដក្នុងអសនិមណ្ឌល ដូចក្នុងប្រយោគជាដើមថា **អសនិវិចក្កំ** ( ម្នាលភិក្ខុទាំងឡាយ ) កាំរន្ទះធ្លាក់ចំលើបុគ្គលណា ដូច្នេះ ។ តែក្នុងទីនេះ **ចក្ក** សព្ទនេះ ប្រាកដក្នុងធម្មចក្ក ។

ធម្មចក្កនោះមាន ២ យ៉ាង គឺបដិវេធញ្ញាណនិងទេសនាញាណ ។ ក្នុងញាណទាំងពីរនោះ ញាណដែលអប់រំដោយបញ្ញាដែលនាំមកនូវអរិយផលដល់ព្រះអង្គ ឈ្មោះថា បដិវេធញ្ញាណ ។ ញាណដែលអប់រំដោយករុណាដែលនាំមកនូវអរិយផលដល់សាវកទាំងឡាយ ឈ្មោះថា ទេសនាញាណ ។

ក្នុងញាណទាំងពីរនោះ បដិវេធញ្ញាណមាន ២ យ៉ាងគឺ កំពុងកើត ១ កើតហើយ ១ ។ បដិវេធញ្ញាណនោះ តាំងអំពីចេញមហាភិនេស្រ្កមណ៍

រហូតដល់អរហត្តមគ្គ ឈ្មោះថា កំពុងកើត ក្នុងខណៈនៃផល ឈ្មោះថា កើតហើយ ។ ម្យ៉ាងទៀត តាំងអំពីឃាតចាកតុសិតភពរហូតបានសម្រេចអរហត្តមគ្គ ត្រង់ពោធិបល្ល័ង្ក ឈ្មោះថា កំពុងកើត ក្នុងខណៈនៃផល ឈ្មោះថា កើតហើយ ។ ឬតាំងអំពីសាសនាព្រះទីបង្ករទេសពលរហូតបានសម្រេចអរហត្តមគ្គ ឈ្មោះថា កំពុងកើត ក្នុងខណៈនៃផល ឈ្មោះថា កើតហើយ ។ សូម្បីទេសនាញាណ ក៏មាន ២ យ៉ាងគឺ កំពុងប្រព្រឹត្តទៅ ១ ប្រព្រឹត្តទៅហើយ ១ ។ ទេសនាញាណនោះ ( ចាប់ផ្តើមអំពីទេសនា ) រហូតដល់អរហត្តមគ្គរបស់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ឈ្មោះថា កំពុងប្រព្រឹត្ត-ទៅ ក្នុងខណៈនៃផល ឈ្មោះថា ប្រព្រឹត្តទៅហើយ ។

ក្នុងញាណទាំងនោះ បដិវេធញ្ញាណ ជាលោកុត្តរៈ ទេសនាញាណជាលោកិយៈ ។ សូម្បីញាណទាំង ២ នោះ ក៏មិនទូទៅដល់អ្នកដទៃ ជាឱរសញ្ញាណ ( ញាណកើតអំពីទ្រូង ) របស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ដោយហេតុនោះ ទើបលោកពោលថា **ព្រហ្មចក្កំ បវត្តេតិ** ដូច្នេះ ។

បទថា **កម្មសមាទានានំ** បានដល់ នៃកុសលកម្មនិងអកុសលកម្មដែលសមាទានហើយ ឬកម្មនោះឯង ឈ្មោះថា កម្មសមាទាន ។ បទថា **ឋានសោ ហេតុសោ** បានដល់ ដោយបច្ច័យនិងដោយហេតុ ក្នុងបច្ច័យនិងហេតុនោះ គតិ ឧបធិ កាល និងបយោគ ជាឋានៈនៃវិបាក កម្មជាហេតុ ។ បទថា **សព្វត្ថគាមិនី** បានដល់ បដិបទាជាគ្រឿងឲ្យដល់គតិទាំងពួង និងបដិបទាឲ្យដល់អគតិ ( និព្វាន ) ។ បទថា **បដិបទំ** បានដល់ មគ្គ ។

បទថា **យថាភូតំ បជានាតិ** បានដល់ តថាគត រមែងដឹងសភាពពិត ដោយមិនវិបរិតនៃការបដិបត្តិ ពោលគឺ កុសលចេតនា និងអកុសលចេតនា សូម្បីក្នុងវត្ថុមួយ ដោយន័យនេះថា កាលមនុស្សច្រើន សម្លាប់សត្វមួយ ប៉ុណ្ណោះ ចេតនារបស់បុគ្គលនេះ ក៏នឹងឲ្យដល់នរក របស់បុគ្គលនេះនឹងឲ្យដល់កំណើតសត្វតិរច្ឆាន ។ បទថា **អនេកធាតុំ** បានដល់ ធាតុច្រើន ដោយធាតុទាំងឡាយ មានចក្ខុធាតុជាដើម ឬមានកាមធាតុជាដើម ។ បទថា **នានាធាតុំ** បានដល់ ធាតុមានប្រការផ្សេង ៗ ព្រោះធាតុទាំងនោះ មានលក្ខណៈផ្សេងគ្នា ។ បទថា **លោកំ** បានដល់ ខន្ធលោក អាយតនលោក និងធាតុលោក ។ បទថា **យថាភូតំ បជានាតិ** បានដល់ ចាក់ធ្លុះសភាវៈនៃធាតុនោះៗដោយមិនវិបរិត ។ បទថា **នានាធិមុត្តិកតំ** បានដល់ ធាតុដែលសត្វទាំងឡាយមានអធ្យាស្រ័យផ្សេង ៗ គ្នា ដោយអធ្យាស្រ័យថោកទាបនិងប្រណីតជាដើម ។ បទថា **បរសត្តានំ** បានដល់ របស់សត្វដែលជាប្រធាន ។ បទថា **បរបុគ្គលានំ** បានដល់ របស់សត្វថោកទាបពួកដទៃចាកសត្វដែលជាប្រធាននោះ ។ ទាំង ២ បទនេះ មានអត្ថដូចគ្នា ព្រះមានព្រះភាគទ្រង់ត្រាស់ដោយអាការ ២ យ៉ាង ដោយអំណាចជាវេនេយ្យ-សត្វ សូម្បីក្នុងទីនេះ លោកក៏ពោលតាមន័យដែលព្រះមានព្រះភាគ ត្រាស់ទុកនោះឯង ។

បទថា **ឥន្ទ្រិយបរោបរិយត្តំ** បានដល់ ភាពជាដទៃនិងភាពមិនជាដទៃរបស់ឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើម អធិប្បាយថា សេចក្តីចម្រើននិង

សេចក្តីវិនាស ។

បទថា **ឈានវិមោក្ខសមាធិសមាបត្តីនំ** បានដល់ នៃឈាន ៤ មានបឋមជ្ឈានជាដើម នៃវិមោក្ខ ៨ មានបុគ្គលមានរូបជ្ឈាន រមែងឃើញនូវរូបជាដើម នៃសមាធិ ៣ មានសមាធិដែលមានវិតក្កវិចារៈជាដើម នៃអនុបុព្វសមាបត្តិ ៩ មានបឋមជ្ឈានសមាបត្តិជាដើម ។ បទថា **សង្កិលេសំ** បានដល់ ធម៌ដែលប្រព្រឹត្តទៅ ក្នុងចំណែកវិនាស ។ បទថា **វោទានំ** បានដល់ ធម៌ដែលប្រព្រឹត្តទៅ ក្នុងចំណែកពិសេស ។ បទថា **វុដ្ឋានំ** បានដល់ ហេតុដែលចេញពីឈានជាដើម ។ ម្យ៉ាងទៀត ការចេញនោះដែលត្រាស់ទុក ( ក្នុងអភិធម្មវិភង្គ ) យ៉ាងនេះថា ពាក្យថា ការចេញ គឺសេចក្តីផូរផង់ ឈ្មោះថា ការចេញ ទាំងការចេញចាកសមាធិនោះៗ ក៏ឈ្មោះថា ការចេញដែរ គឺឈានដែលស្ទាត់ជំនាញ និងភវង្គផលសមាបត្តិ ព្រោះឈានដែលស្ទាត់ជំនាញថ្នាក់ទាបៗជាបទដ្ឋាននៃឈានថ្នាក់ខ្ពស់ៗ ព្រោះហេតុនោះទើបទ្រង់ត្រាស់ថា ការចេញ គឺសេចក្តីផូរផង់ ។ ការចេញចាកឈានទាំងពួង រមែងមានបានដោយភវង្គ ការចេញពីនិរោធសមាបត្តិ រមែងមានបានដោយផលសមាបត្តិ ។ ទ្រង់សំដៅយកការចេញនោះទើបត្រាស់ថា ទាំងការចេញចាកសមាធិនោះៗ ក៏ឈ្មោះថា ការចេញដែរ ។

បុព្វេនិវាសញ្ញាណ ទិព្វចក្ខុញ្ញាណនិងអាសវក្ខយញ្ញាណ ខ្ញុំសម្តែងទុកហើយខាងដើមនោះឯង ។ ក្នុងបទទាំងនោះ បទថា **អាសវានំ ខយា** បានដល់ ព្រោះកិលេសទាំងពួង អស់ទៅដោយអរហត្តមគ្គ ។ បទថា

**អនាសវំ** បានដល់ ប្រាសចាកអាសវៈ ។ បទថា **ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ** នេះ លោកពោលដល់សមាធិ ដែលសម្បយុត្តដោយអរហត្តផល ដោយបទថា **ចេតោវិមុត្តិ** ពោលបញ្ញាដែលសម្បយុត្តដោយអរហត្តផល នោះ ដោយបទថា **បញ្ញាវិមុត្តិ** ។ ម្យ៉ាងទៀត ក្នុងបទទាំងនោះគប្បីជ្រាប ថា សមាធិ ឈ្មោះថា ចេតោវិមុត្តិ ព្រោះផុតចាករាគៈ បញ្ញា ឈ្មោះ ថា បញ្ញាវិមុត្តិ ព្រោះផុតចាកអវិជ្ជា ។ សមដូចព្រះមានព្រះភាគ ទ្រង់ ត្រាស់ទុក ( ក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ[១] ព្រោះថា សមាធិឯណា របស់អរិយសាវកនោះ សមាធិនោះ ឈ្មោះថា សមាធិន្ទ្រិយរបស់លោក ។ ម្នាលភិក្ខុទាំងឡាយ[២] ព្រោះថាបញ្ញាឯណា របស់អរិយសាវកនោះ បញ្ញានោះ ឈ្មោះថា បញ្ញិន្ទ្រិយរបស់លោក និង ( ក្នុងអង្គុត្តរនិកាយទុកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ចេតោវិមុត្តិកើត ព្រោះប្រាសចាករាគៈ បញ្ញាវិមុត្តិកើតព្រោះប្រាសចាកអវិជ្ជា ដោយប្រការ ដូច្នេះ ។ ម្យ៉ាងទៀត ក្នុងទីនេះគប្បីជ្រាបថា សមថពលៈ ជាចេតោវិមុត្តិ វិបស្សនាពលៈជាបញ្ញាវិមុត្តិ ។ បទថា **ទិដ្ឋេវ ធម្មេ** បានដល់ ក្នុងអត្តភាព នេះឯង ។ បទថា **សយំ អភិញ្ញា សច្ឆិកត្វា** បានដល់ ធ្វើឲ្យប្រចក្ស ច្បាស់ ដោយបញ្ញាដ៏ក្រៃលែងដោយខ្លួនឯង អធិប្បាយថា ដឹងដោយមិន មានអ្នកដទៃជាបច្ច័យ ។ បទថា **ឧបសម្បជ្ជ** បានដល់ ត្រាស់ដឹងហើយ ឬសម្រេចហើយ ។

---

១-២ បិដកខ្មែរជា បពិត្រព្រះអង្គដ៏ចម្រើន ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្ដីពិស្ដាររបស់ទសពលញ្ញាណ ១០ នេះ ដោយន័យដូចពោលហើយក្នុងអភិធម្ម ។

ក្នុងទីនោះ ពាក្យចំណែកបរវាទីថា ឈ្មោះថា ទសពលញ្ញាណ ជាញាណចំពោះមិនមាន ។ នេះជាប្រភេទរបស់សព្វញ្ញុតញ្ញាណនោះឯង ។ សេចក្ដីនោះមិនគប្បីឃើញយ៉ាងនោះ ។ ព្រោះទសពលញ្ញាណជាយ៉ាងដទៃ សព្វញ្ញុតញ្ញាណ ជាយ៉ាងដទៃ ទសពលញ្ញាណ រមែងដឹងកិច្ចរបស់ខ្លួនប៉ុណ្ណោះ សព្វញ្ញុតញ្ញាណរមែងដឹងកិច្ចនោះខ្លះ កិច្ចដ៏សេសពីនោះខ្លះ ។ ក្នុងទសពលញ្ញាណទាំងឡាយ ទសពលញ្ញាណទី ១ រមែងដឹងហេតុ និងមិនមែនហេតុ ទសពលញ្ញាណទី ២ រមែងដឹងការផ្សេងគ្នានៃវិបាករបស់កម្ម ។ ទសពលញ្ញាណទី ៣ រមែងដឹងកំណត់របស់កម្ម ទសពលញ្ញាណទី ៤ រមែងដឹងហេតុនៃការផ្សេងគ្នានៃធាតុ ទសពលញ្ញាណទី ៥ រមែងដឹងអធិមុត្តិ គឺអធ្យាស្រ័យរបស់សត្វទាំងឡាយ ទសពលញ្ញាណទី ៦ រមែងដឹងភាពចាស់ក្លានិងភាពទន់ខ្សោយនៃឥន្ទ្រិយទាំងឡាយ ទសពលញ្ញាណទី ៧ រមែងដឹងសេចក្ដីសៅហ្មងជាដើម នៃឥន្ទ្រិយទាំងនោះ មួយអន្លើដោយឈានជាដើម ទសពលញ្ញាណទី ៨ រមែងដឹងការបន្តនៃខន្ធដែលនៅអាស្រ័យក្នុងកាលមុន ទសពលញ្ញាណទី ៩ រមែងដឹងចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ ទសពលញ្ញាណទី ១០ រមែងកំណត់ដឹងសច្ចៈប៉ុណ្ណោះ ។

ចំណែកសព្វញ្ញុតញ្ញាណ រមែងដឹងវត្ថុ ដែលទសពលញ្ញាណទាំងនោះគួរដឹង និងក្រៃលែងជាងនោះ តែមិនធ្វើកិច្ចទាំងអស់របស់ញាណទាំងនោះ

ព្រោះទសពលញ្ញាណនោះ ជាឈានក៏មិនអាចឲ្យចុះស៊ប់បាន ជាឫទ្ធិក៏មិនអាចសម្តែងឫទ្ធិបាន ជាមគ្គក៏មិនអាចញ៉ាំងកិលេសឲ្យអស់បាន ។

ម្យ៉ាងទៀត គួរសួរបរវាទីយ៉ាងនេះថា ឈ្មោះថា ទសពលញ្ញាណនេះ មានវិតក្កៈ មានវិចារៈ ឬមិនមានវិតក្កៈ មានតែវិចារៈ ឬមិនមានទាំងវិតក្កៈ មិនមានទាំងវិចារៈ ជាកាមាវចរៈ ឬរូបាវចរៈ ឬអរូបាវចរៈ ជាលោកិយៈ ឬលោកុត្តរៈ ។ កាលដឹងក៏នឹងឆ្លើយថា ញាណ ៧ តាមលំដាប់ មានវិតក្កៈ មានវិចារៈ ។ នឹងឆ្លើយថា ញាណ ២ បន្ទាប់អំពីនោះ មិនមានវិតក្កៈ មិនមានវិចារៈ នឹងឆ្លើយថា អាសវក្ខយញ្ញាណ មានទាំងវិតក្កៈ មានទាំងវិចារៈក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈក៏មាន មិនមានទាំងវិតក្កៈ មិនមានទាំងវិចារៈក៏មាន ។ ម្យ៉ាងទៀត នឹងឆ្លើយថា ញាណ ៧ តាមលំដាប់ ជាកាមាវចរៈ ញាណ ២ បន្ទាប់អំពីនោះ ជារូបាវចរៈ ក្នុងទីបំផុតអំពីនោះ ញាណ ១ ជាលោកុត្តរៈ នឹងឆ្លើយថា ចំណែកសព្វញ្ញុតញ្ញាណ មានទាំងវិតក្កៈ មានទាំងវិចារៈ ជាកាមាវចរៈប៉ុណ្ណោះ ជាលោកិយៈប៉ុណ្ណោះ ។

ឥឡូវនេះ បណ្ឌិតកាលជ្រាបការពណ៌នាតាមលំដាប់ ដែលមិនធ្លាប់ពណ៌នាក្នុងពលកថានេះ យ៉ាងនេះហើយ គប្បីជ្រាបថា លោកពោលពលៈ ១០ ទាំងនេះតាមលំដាប់នេះ ព្រោះដំបូង ព្រះតថាគតទ្រង់ឃើញការមិនមានគ្រឿងរារាំង គឺកិលេស ដែលជាឋានៈ និងអឋានៈនៃការសម្រេចការអស់ទៅនៃអាសវៈ និងនៃការមិនសម្រេចរបស់វេនេយ្យសត្វទាំងឡាយដោយ

ឋានាឋានញ្ញាណ ព្រោះទ្រង់ឃើញឋានៈរបស់សម្មាទិដ្ឋិ ដែលជាលោកិយៈ និងព្រោះទ្រង់ឃើញការមិនមានឋានៈរបស់និយតមិច្ឆាទិដ្ឋិ បន្ទាប់មក ទ្រង់ឃើញការមិនមានគ្រឿងរារាំង គឺវិបាករបស់សត្វទាំងនោះ ដោយកម្មវិបាក-ញ្ញាណ ព្រោះទ្រង់ឃើញបដិសន្ធិដែលជា**តិហេតុកៈ** ។ ទ្រង់ឃើញការមិនមានគ្រឿងរារាំង គឺកម្ម ដោយសព្វត្ថគាមិនីបដិបទាញាណ ( ញាណកំណត់ដឹងផ្លូវជាគ្រឿងឲ្យដល់ប្រយោជន៍ទាំងពួង ) ព្រោះទ្រង់ឃើញការមិនមានអនន្តរិយកម្ម ។ កាលបើយ៉ាងនេះ ទ្រង់ឃើញចរិយាពិសេស ដើម្បីទ្រង់សម្តែងធម៌ អនុគ្រោះដល់ការមិនមានគ្រឿងរារាំង ដោយអនេក-ធាតុនានាធាតុញ្ញាណ ព្រោះទ្រង់ឃើញការផ្សេងគ្នានៃធាតុ បន្ទាប់មកទ្រង់ឃើញអធ្យាស្រ័យវេនេយ្យសត្វទាំងនោះ ដោយនានាធិមុត្តកតាញាណ ( ញាណដឹងអធ្យាស្រ័យផ្សេងៗ ) ដើម្បីមិនទឹកគិតដល់សេចក្តីព្យាយាមប្រកប ទ្រង់ក៏សម្តែងធម៌បាន ដោយអំណាចអធ្យាស្រ័យ ( របស់វេនេយ្យសត្វ ) ។ បន្ទាប់អំពីនោះទ្រង់ឃើញការទន់ខ្សោយនិងការចាស់ក្លានៃឥន្ទ្រិយដោយឥន្ទ្រិយបរោបរិយត្តញ្ញាណ ព្រោះទ្រង់ឃើញការចាស់ក្លានិងការទន់ខ្សោយនៃឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើមទើបទ្រង់សម្តែងធម៌តាមសមត្ថភាព តាមកម្លាំងរបស់បុគ្គលដែលមានអធ្យាស្រ័យ ដែលទ្រង់ឃើញហើយយ៉ាងនេះ ម្យ៉ាងទៀត បើវេនេយ្យសត្វទាំងឡាយនោះ សូម្បីមានការទន់ខ្សោយនិងចាស់ក្លានៃឥន្ទ្រិយដែលទ្រង់កំណត់ដឹងហើយយ៉ាងនេះ មិននៅក្នុងទីឆ្ងាយ ពេលនោះទ្រង់ក៏យាងចូលទៅរកដោយឆាប់រួសរាន់ ដោយ

ឫទ្ធិវិសេស ព្រោះទ្រង់ជំនាញក្នុងឈានជាដើម ដោយឈានាទិញាណ កាលទ្រង់ចូលទៅហើយ កាលទ្រង់ឃើញភាពជាក់ច្បាស់នៃជាតិមុន របស់វេនេយ្យសត្វទាំងនោះ ដោយបុព្វេនិវាសានុស្សតិញាណ កាលទ្រង់ឃើញភាពពិសេសរបស់ចិត្តខណៈនោះ ដោយចេតោបរិយញ្ញាណ ដែលគួរសម្រេចព្រោះអានុភាពនៃទិព្វចក្ខុញ្ញាណ ទ្រង់រមែងសម្តែងធម៌ដើម្បីការអស់អាសវៈ ព្រោះសត្វនោះប្រាសចាកការវង្វេង ដោយបដិបទាដែលនាំទៅកាន់ការអស់អាសវៈ ដោយអនុភាពនៃអាសវក្ខយញ្ញាណ ។

[ ១០៣ ] ឥឡូវនេះព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងពលៈទាំងអស់ដោយលក្ខណៈ ទើបតាំងពាក្យសួរដោយន័យថា **កេនដ្ឋេន សទ្ធាពលំ** ជាដើម ហើយឆ្លើយដោយន័យថា **អស្សទ្ធិយេ អកម្បិយដ្ឋេន** ជាដើម ។

ក្នុងបទទាំងនោះ បទថា **ហិរីយតិ** ជាដើម ជាការសម្តែងដល់បុគ្គលាធិដ្ឋាន ។ ក្នុងពលៈទាំងឡាយ មានភាវនាពលៈជាខាងដើម មានអធិដ្ឋានពលៈជាខាងចុង គប្បីជ្រាបថា បទថា **តត្ថ** បទថា **តេន** និងបទថា **តំ** លោកពោលសំដៅដល់នេក្ខម្មៈជាដើមប៉ុណ្ណោះ ។

បទថា **តេន ចិត្តំ ឯកគ្គំ** លោកអធិប្បាយថា ចិត្តមានអារម្មណ៍តែមួយដោយសមាធិនោះ ។ បទថា **តត្ថ ជាតេ** បានដល់ ដែលកើតក្នុងសមថៈនោះដោយការប្រកប ឬដែលមានវិបស្សនាជាអារម្មណ៍ កើតក្នុងសមថៈនោះ ។ បទថា **តត្ថ សិក្ខតិ** សេចក្តីថា ឈ្មោះថា សេក្ខពលៈ ព្រោះព្រះសេក្ខៈនៅសិក្សាក្នុងសេក្ខពលៈនោះ ។ បទថា **តត្ថ សិក្ខិតត្តា**

សេចក្តីថា ឈ្មោះថា អសេក្ខពលៈ ព្រោះព្រះអសេក្ខៈសិក្សាក្នុងអសេក្ខ-ពលៈនោះស្រេចហើយ ។ បទថា **តេន អាសវា ខីណា** សេចក្តីថា ញាណនោះ ឈ្មោះថា ខីណាសវពលៈ ព្រោះអត្ថថា អាសវៈទាំងឡាយអស់ទៅហើយដោយលោកិយញ្ញាណនិងលោកុត្តរញ្ញាណនោះ ។ ពិតណាស់ អាសវៈទាំងឡាយ ឈ្មោះថា អស់ទៅហើយដោយលោកិយញ្ញាណ ព្រោះកាលមិនមានវិបស្សនា លោកុត្តរធម៌ក៏មានមិនបាន ។ ឈ្មោះថា **ខីណា-សវពល** ព្រោះជាកម្លាំងរបស់ព្រះខីណាស្រពយ៉ាងនេះ ។ បទថា **តំ តស្ស ឥជ្ឈតីតិ ឥទ្ធិពលំ** សេចក្តីថា ឫទ្ធិនោះឯងជាកម្លាំង ទើបឈ្មោះថា ឥទ្ធិ-ពលៈ ព្រោះឫទ្ធិរមែងសម្រេចដល់បុគ្គលមានឫទ្ធិនោះ ។ បទថា **អប្ប-មេយ្យដ្ឋេន** បានដល់ ព្រោះហេតុដែលសាវកទាំងឡាយ រមែងដឹងឋានៈនិងអឋានៈជាដើម ដោយឯកទេស ។ ទើបលោកពោលថា **យថាភូតំ បជានាតិ** សំដៅដល់ការដឹងនោះឯងដោយអាការទាំងពួង ។ សូម្បីលោកមិនពោលថា **យថាភូតំ បជានាតិ** ទុកក្នុងវិជ្ជា ៣ ក៏ពិត តែព្រោះលោកពោលទុកហើយ**ក្នុងទីដទៃ** ទើបឈ្មោះថា ពោលសូម្បីក្នុងវិជ្ជាទាំងនោះផងដែរ ។

ពាក្យថា **ក្នុងទីដទៃ** បានដល់ ក្នុងញាណពលៈ ៧ ដ៏សេសនិងក្នុងពលៈ ១០ ក្នុងអភិធម្ម ។ ម្យ៉ាងទៀត ឥន្ទ្រិយបរោបរិយត្តញ្ញាណមិនទូទៅដល់សាវកទាំងឡាយ សូម្បីដោយប្រការទាំងពួង ព្រោះហេតុនោះ ទើបពលៈ ១០ មិនទូទៅដល់សាវកទាំងឡាយ ។ ពលៈ ១០ ឈ្មោះថា មិន

មានប្រមាណ ព្រោះអត្ថថា មានប្រមាណក្រៃលែង ព្រោះអត្ថថា ប្រឹងមិនបាន ព្រោះហេតុនោះឯង ទើបលោកពោលថា ឈ្មោះថា តថាគតពលៈ ព្រោះអត្ថថា មានគុណរាប់មិនបាន ដោយប្រការដូច្នេះ ។

## អដ្ឋកថា ពលកថា ចប់

# សុត្តន្តបិដក

## យុគនទ្ធវគ្គ សុញ្ញកថា

[ ១០៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុគង់ស៊ប់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែងពោលថា លោកសូន្យ លោកសូន្យ បពិត្រព្រះអង្គដ៏ចម្រើន ដែលព្រះអង្គពោលថា លោកសូន្យ តើដោយហេតុដូចម្តេច ។ ម្នាលអានន្ទ ធម្មជាតដែលសូន្យចាកខ្លួនឬចាកវត្ថុជារបស់ខ្លួន ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា លោកសូន្យ ម្នាលអានន្ទ ចុះធម្មជាតអ្វីដែលសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ម្នាលអានន្ទ ចក្ខុហ្នឹងឯង ជាធម្មជាតសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន រូបសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ចក្ខុវិញ្ញាណសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ចក្ខុសម្ផស្សសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ វេទនានោះ ក៏សូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ត្រចៀកសូន្យ ។បេ។ សំឡេងសូន្យ ច្រមុះសូន្យ ក្លិនសូន្យ អណ្តាតសូន្យ រសសូន្យ កាយសូន្យ ផោដ្ឋព្វៈសូន្យ ចិត្តសូន្យចាកខ្លួន ឬ

បាកវត្ថុជារបស់ខ្លួន ធម្មារម្មណ៍សូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន មនោ-វិញ្ញាណសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន មនោសម្ផស្សសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ វេទនានោះ ក៏សូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ម្នាលអានន្ទ ធម្មជាតដែលសូន្យចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួនព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា លោកសូន្យ ។

[ ១០៥ ] ធម្មជាតត្រូវសូន្យ សូន្យ សង្ខារសូន្យ ធម្មជាតប្រែប្រួលទាំងសូន្យ ធម្មជាតដ៏ប្រសើរសូន្យ លក្ខណៈសូន្យ ធម្មជាតសង្កត់សង្កិនទាំងសូន្យ ធម្មជាតសូន្យដោយអង្គនោះ ធម្មជាតផ្តាច់ផ្តិលទាំងសូន្យ ធម្ម-ជាត ស្ងប់រម្ងាប់ទាំងសូន្យ ធម្មជាតរលាស់ចេញទាំងសូន្យ អាយតនៈខាងក្នុងសូន្យ អាយតនៈខាងក្រៅសូន្យ អាយតនៈទាំងពីរសូន្យ ធម្មជាតមានចំណែកស្មើគ្នាទាំងសូន្យ ធម្មជាតមានចំណែកខុសគ្នាទាំងសូន្យ ការស្វែងរកសូន្យ ការកំណត់សូន្យ ការបានចំពោះទាំងសូន្យ ការចាក់ធ្លុះសូន្យ ធម្មជាតដូចគ្នាទាំងសូន្យ ធម្មជាតផ្សេងគ្នាទាំងសូន្យ ខន្តិសូន្យ ការអធិដ្ឋានសូន្យ ការឈានចុះស៊ប់សូន្យ ការបង្អស់នូវការប្រព្រឹត្តិរបស់បុគ្គលអ្នកដឹងទាន់ ឈ្មោះថា សូន្យដ៏ក្រៃលែងជាងធម្មជាតសូន្យទាំងពួង ។

[ ១០៦ ] ធម្មជាតត្រូវសូន្យ សូន្យ តើដូចម្តេច ។ ចក្ខុសូន្យដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការពិតប្រាកដ

ផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង ត្រចៀកសូន្យ ។បេ។ ច្រមុះសូន្យ អណ្តាតសូន្យ កាយសូន្យ ចិត្តសូន្យដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការពិតប្រាកដផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង នេះធម្មជាតត្រូវសូន្យ សូន្យ ។

[ ១០៧ ] សង្ខារសូន្យ តើដូចម្តេច ។ សង្ខារ ៣ គឺបុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អនេញ្ជាភិសង្ខារ ១ បុញ្ញាភិសង្ខារសូន្យដោយអបុញ្ញាភិសង្ខារផង ដោយអនេញ្ជាភិសង្ខារផង ឯអបុញ្ញាភិសង្ខារសូន្យដោយបុញ្ញាភិសង្ខារផង ដោយអនេញ្ជាភិសង្ខារផង អនេញ្ជាភិសង្ខារសូន្យដោយបុញ្ញាភិសង្ខារផង ដោយអបុញ្ញាភិសង្ខារផង នេះសង្ខារ ៣ ។

សង្ខារ ៣ ដទៃទៀត គឺកាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ កាយសង្ខារសូន្យដោយវចីសង្ខារផង ដោយចិត្តសង្ខារផង វចីសង្ខារសូន្យដោយកាយសង្ខារផង ដោយចិត្តសង្ខារផង ចិត្តសង្ខារសូន្យដោយកាយសង្ខារផង ដោយវចីសង្ខារផង នេះសង្ខារ ៣ ។

សង្ខារ ៣ ដទៃទៀត គឺអតីតសង្ខារ ១ អនាគតសង្ខារ ១ បច្ចុប្បន្នសង្ខារ ១ អតីតសង្ខារសូន្យដោយអនាគតសង្ខារផង ដោយបច្ចុប្បន្នសង្ខារផង ឯអនាគតសង្ខារសូន្យ ដោយអតីតសង្ខារផង ដោយបច្ចុប្បន្នសង្ខារផង បច្ចុប្បន្នសង្ខារសូន្យដោយអតីតសង្ខារផង ដោយអនាគតសង្ខារផង នេះសង្ខារ ៣ នេះសង្ខារសូន្យ ។

[ ១០៨ ] ធម្មជាតប្រែប្រួល ទាំងសូន្យ តើដូចម្តេច ។ រូបដែលកើតហើយ ឈ្មោះថា សូន្យតាមសភាវៈ រូបដែលទៅប្រាសហើយ ឈ្មោះថា ប្រែប្រួលផង ឈ្មោះថា សូន្យផង វេទនាដែលកើតហើយ ឈ្មោះថា សូន្យតាមសភាវៈ វេទនាដែលទៅប្រាសហើយ ឈ្មោះថា ប្រែប្រួលផង ឈ្មោះថា សូន្យផង សញ្ញាដែលកើតហើយ សង្ខារទាំងឡាយដែលកើតហើយ វិញ្ញាណដែលកើតហើយ ចក្ខុដែលកើតហើយ ។បេ។ ភពដែលកើតហើយ ឈ្មោះថា សូន្យតាមសភាវៈ ភពដែលទៅប្រាសហើយឈ្មោះថា ប្រែប្រួលផង ឈ្មោះថា សូន្យផង នេះធម្មជាតប្រែប្រួលទាំងសូន្យ ។

[ ១០៩ ] ធម្មជាតដ៏ប្រសើរសូន្យ តើដូចម្តេច ។ ការរម្ងាប់នូវសង្ខារទាំងពួង ការលះនូវឧបធិទាំងពួង ការអស់នៃតណ្ហា ការប្រាសចាកតម្រេក ការរលត់ ព្រះនិព្វានឯណា នុ៎ះជាបទដ៏ខ្ពង់ខ្ពស់ នុ៎ះជាបទដ៏ប្រសើរ នុ៎ះជាបទដ៏វិសេស នេះឯងធម្មជាតដ៏ប្រសើរសូន្យ ។

[ ១១០ ] លក្ខណៈសូន្យ តើដូចម្តេច ។ លក្ខណៈ ២ គឺពាលលក្ខណៈ ១ បណ្ឌិតលក្ខណៈ ១ ពាលលក្ខណៈសូន្យដោយបណ្ឌិតលក្ខណៈ ឯបណ្ឌិតលក្ខណៈសូន្យដោយពាលលក្ខណៈ ។ លក្ខណៈ ៣ គឺលក្ខណៈនៃការកើត ១ លក្ខណៈនៃការសូន្យ ១ លក្ខណៈនៃការប្រែប្រួលចាកការតាំងនៅ ១ លក្ខណៈនៃការកើត សូន្យដោយលក្ខណៈនៃការសូន្យផង ដោយលក្ខណៈនៃការប្រែប្រួល ចាកការតាំងនៅផង ឯលក្ខណៈនៃការសូន្យ សូន្យដោយលក្ខណៈនៃការកើតផង ដោយលក្ខណៈនៃការប្រែ

ប្រួលចាកការតាំងនៅផង លក្ខណៈនៃការប្រែប្រួលចាកការតាំងនៅសូន្យ ដោយលក្ខណៈនៃការកើតផង ដោយលក្ខណៈនៃការសូន្យផង លក្ខណៈនៃការកើតនៃរូបសូន្យដោយលក្ខណៈនៃការសូន្យផង ដោយលក្ខណៈនៃការប្រែប្រួលចាកការតាំងនៅផង លក្ខណៈនៃការសូន្យនៃរូប សូន្យដោយលក្ខ-ណៈនៃការកើតផង ដោយលក្ខណៈនៃការប្រែប្រួល ចាកការតាំងនៅផង លក្ខណៈនៃការប្រែប្រួល ចាកការតាំងនៅនៃរូបសូន្យដោយលក្ខណៈនៃការកើតផង ដោយលក្ខណៈនៃការសូន្យផង លក្ខណៈនៃការកើតនៃវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ នៃជរាមរណៈសូន្យដោយលក្ខណៈនៃការសូន្យផង ដោយលក្ខណៈនៃការប្រែប្រួលចាកការតាំងនៅផង លក្ខ-ណៈនៃការសូន្យនៃជរាមរណៈសូន្យ ដោយលក្ខណៈនៃការកើតផង ដោយលក្ខណៈនៃការប្រែប្រួលចាកការតាំងនៅផង លក្ខណៈនៃការប្រែប្រួលចាកការតាំងនៅនៃជរាមរណៈសូន្យដោយលក្ខណៈនៃការកើតផង ដោយលក្ខណៈនៃការសូន្យផង នេះលក្ខណៈសូន្យ ។

[ ១១១ ] ធម្មជាតសង្កត់សង្កិនទាំងសូន្យ តើដូចម្តេច ។ កាមច្ឆន្ទៈគេសង្កត់សង្កិនផង សូន្យផង ដោយនេក្ខម្មៈ ព្យាបាទគេសង្កត់សង្កិនផង សូន្យផង ដោយអព្យាបាទ ថីនមិទ្ធៈគេសង្កត់សង្កិនផង សូន្យផង ដោយអាលោកសញ្ញា ឧទ្ធច្ចៈគេសង្កត់សង្កិនផង សូន្យផង ដោយការមិនរាយមាយ វិចិកិច្ឆាគេសង្កត់សង្កិនផង សូន្យផង ដោយការកំណត់នូវធម៌ អវិជ្ជាគេសង្កត់សង្កិនផង សូន្យផង ដោយញាណ អរតិ ( សេចក្តីមិនត្រេកអរ )

គេសង្កត់សង្កិនផង សូន្យផង ដោយបាមុជ្ជៈ នីវរណៈគេសង្កត់សង្កិនផង សូន្យផង ដោយបឋមជ្ឈាន ។បេ។ កិលេសទាំងអស់ គេសង្កត់សង្កិនផង សូន្យផង ដោយអរហត្តមគ្គ នេះធម្មជាតសង្កត់សង្កិនទាំងសូន្យ ។

[ ១១២ ] ធម្មជាតសូន្យដោយអង្គនោះ តើដូចម្តេច ។ កាមច្ឆន្ទៈសូន្យដោយអង្គនោះ គឺដោយនេក្ខម្មៈ ព្យាបាទសូន្យដោយអង្គនោះ គឺដោយអព្យាបាទ ថីនមិទ្ធៈសូន្យដោយអង្គនោះ គឺដោយអាលោកសញ្ញា ឧទ្ធច្ចៈសូន្យដោយអង្គនោះ គឺដោយការមិនរាយមាយ វិចិកិច្ឆាសូន្យដោយអង្គនោះ គឺដោយការកំណត់នូវភូមិ អវិជ្ជាសូន្យដោយអង្គនោះ គឺដោយញាណ អរតិសូន្យដោយអង្គនោះ គឺដោយបាមុជ្ជៈ ពួកនីវរណៈសូន្យដោយអង្គនោះ គឺដោយបឋមជ្ឈាន ។បេ។ ការប្រកាន់មាំដោយសំយោគ សូន្យដោយអង្គនោះ គឺដោយវិវដ្ដនានុបស្សនា នេះធម្មជាតសូន្យដោយអង្គនោះ ។

[ ១១៣ ] ធម្មជាតផ្ដាច់ផ្ដិលទាំងសូន្យ តើដូចម្តេច ។ កាមច្ឆន្ទៈគេផ្ដាច់ផ្ដិលផង សូន្យផង ដោយនេក្ខម្មៈ ព្យាបាទគេផ្ដាច់ផ្ដិលផង សូន្យផង ដោយអព្យាបាទ ថីនមិទ្ធគេផ្ដាច់ផ្ដិលផង សូន្យផង ដោយអាលោកសញ្ញា ឧទ្ធច្ចៈគេផ្ដាច់ផ្ដិលផង សូន្យផង ដោយការមិនរាយមាយ វិចិកិច្ឆាគេផ្ដាច់ផ្ដិលផង សូន្យផង ដោយការកំណត់នូវធម៌ អវិជ្ជាគេផ្ដាច់ផ្ដិលផង សូន្យផង ដោយញាណ អរតិគេផ្ដាច់ផ្ដិលផង សូន្យផង ដោយបាមុជ្ជៈ នីវរណៈទាំងឡាយគេផ្ដាច់ផ្ដិលផង សូន្យផង ដោយបឋមជ្ឈាន ។បេ។ កិលេសទាំងអស់គេផ្ដាច់ផ្ដិលផង សូន្យផង ដោយអរហត្តមគ្គ នេះធម្មជាតផ្ដាច់ផ្ដិល

ទាំងសូន្យ ។

[ ១១៤ ] ធម្មជាតស្ងប់រម្ងាប់ទាំងសូន្យ តើដូចម្តេច ។ កាមច្ឆន្ទៈស្ងប់រម្ងាប់ផង សូន្យផង ដោយនេក្ខម្មៈ ព្យាបាទស្ងប់រម្ងាប់ផង សូន្យផង ដោយអព្យាបាទ ថីនមិទ្ធស្ងប់រម្ងាប់ផង សូន្យផង ដោយអាលោកសញ្ញា ឧទ្ធច្ចៈស្ងប់រម្ងាប់ផង សូន្យផង ដោយការមិនរាយមាយ វិចិកិច្ឆាស្ងប់រម្ងាប់ផង សូន្យផង ដោយការកំណត់នូវធម៌ អវិជ្ជាស្ងប់រម្ងាប់ផង សូន្យផង ដោយញាណ អរតិស្ងប់រម្ងាប់ផង សូន្យផង ដោយបាមុជ្ជៈ ពួកនីវរណៈស្ងប់រម្ងាប់ផង សូន្យផង ដោយបឋមជ្ឈាន ។បេ។ កិលេសទាំងអស់ ស្ងប់រម្ងាប់ផង សូន្យផង ដោយអរហត្តមគ្គ នេះធម្មជាតស្ងប់រម្ងាប់ទាំងសូន្យ ។

[ ១១៥ ] ធម្មជាតលោសចេញទាំងសូន្យ តើដូចម្តេច ។ កាមច្ឆន្ទៈគេលោសចេញផង សូន្យផង ដោយនេក្ខម្មៈ ព្យាបាទគេលោសចេញផង សូន្យផង ដោយអព្យាបាទ ថីនមិទ្ធគេលោសចេញផង សូន្យផង ដោយអាលោកសញ្ញា ឧទ្ធច្ចៈគេលោសចេញផង សូន្យផង ដោយការមិនរាយមាយ វិចិកិច្ឆាគេលោសចេញផង សូន្យផង ដោយការកំណត់នូវធម៌ អវិជ្ជាគេលោសចេញផង សូន្យផង ដោយញាណ អរតិគេលោសចេញផង សូន្យផង ដោយបាមុជ្ជៈ ពួកនីវរណៈគេលោសចេញផង សូន្យផង ដោយបឋមជ្ឈាន ។បេ។ កិលេសទាំងអស់ គេលោសចេញផង សូន្យផង ដោយអរហត្តមគ្គ នេះធម្មជាតលោសចេញទាំងសូន្យ ។

[ ១១៦ ] អាយតនៈខាងក្នុងសូន្យ តើដូចម្តេច ។ ចក្ខុខាងក្នុងសូន្យ

ដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការឋិតថេរផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង ត្រចៀកខាងក្នុងសូន្យ ។បេ។ ច្រមុះខាងក្នុងសូន្យ អណ្តាតខាងក្នុងសូន្យ កាយខាងក្នុងសូន្យ ចិត្តខាងក្នុងសូន្យ ដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការឋិតថេរផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង នេះអាយតនៈខាងក្នុងសូន្យ ។

[ ១១៧ ] អាយតនៈខាងក្រៅសូន្យ តើដូចម្តេច ។ រូបខាងក្រៅសូន្យ ។បេ។ ធម្មារម្មណ៍ខាងក្រៅសូន្យដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការឋិតថេរផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង នេះអាយតនៈខាងក្រៅសូន្យ ។

[ ១១៨ ] អាយតនៈទាំងពីរសូន្យ តើដូចម្តេច ។ ចក្ខុខាងក្នុងណានិងរូបខាងក្រៅណា ធម្មជាតទាំងពីរនោះសូន្យដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការឋិតថេរផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង ត្រចៀកខាងក្នុងណានិងសំឡេងខាងក្រៅណា ។បេ។ ច្រមុះខាងក្នុងណានិងក្លិនខាងក្រៅណា អណ្តាតខាងក្នុងណា និងរសខាងក្រៅណា កាយខាងក្នុងណា និងផោដ្ឋព្វៈខាងក្រៅណា ចិត្តខាងក្នុងណា និងធម្មារម្មណ៍ខាងក្រៅណា ធម្មជាតទាំងពីរនោះសូន្យដោយខ្លួនផង ដោយវត្ថុជារបស់ខ្លួនផង ដោយការទៀងផង ដោយការឋិតថេរផង ដោយការទៀងទាត់ផង ដោយការមិនប្រែប្រួលជាធម្មតាផង

នេះអាយតនៈទាំងពីរសូន្យ ។

[ ១១៩ ] ធម្មជាតមានចំណែកស្មើគ្នាទាំងសូន្យ តើដូចម្តេច ។ អាយតនៈខាងក្នុង ៦ មានចំណែកស្មើគ្នាផង សូន្យផង អាយតនៈខាងក្រៅ ៦ មានចំណែកស្មើគ្នាផង សូន្យផង ពួកនៃវិញ្ញាណ ៦ មានចំណែកស្មើគ្នាផង សូន្យផង ពួកនៃផស្សៈ ៦ មានចំណែកស្មើគ្នាផង សូន្យផង ពួកនៃវេទនា ៦ មានចំណែកស្មើគ្នាផង សូន្យផង ពួកនៃសញ្ញា ៦ មានចំណែកស្មើគ្នាផង សូន្យផង ពួកនៃចេតនា ៦ មានចំណែកស្មើគ្នាផង សូន្យផង នេះធម្មជាតមានចំណែកស្មើគ្នាទាំងសូន្យ ។

[ ១២០ ] ធម្មជាតមានចំណែកខុសគ្នា ទាំងសូន្យ តើដូចម្តេច ។ អាយតនៈខាងក្នុង ៦ មានចំណែកខុសគ្នាពីអាយតនៈខាងក្រៅ ៦ ផង សូន្យផង អាយតនៈខាងក្រៅ ៦ មានចំណែកខុសគ្នាពីពួកនៃវិញ្ញាណ ៦ ផង សូន្យផង ពួកនៃវិញ្ញាណ ៦ មានចំណែកខុសគ្នាពីពួកនៃផស្សៈ ៦ ផង សូន្យផង ពួកនៃផស្សៈ ៦ មានចំណែកខុសគ្នាពីពួកនៃវេទនា ៦ ផង សូន្យផង ពួកនៃវេទនា ៦ មានចំណែកខុសគ្នាពីពួកនៃសញ្ញា ៦ ផង សូន្យផង ពួកនៃសញ្ញា ៦ មានចំណែកខុសគ្នាពីពួកនៃចេតនា ៦ ផង សូន្យផង នេះធម្មជាតមានចំណែកខុសគ្នាទាំងសូន្យ ។

[ ១២១ ] ការស្វែងរកសូន្យ តើដូចម្តេច ។ ការស្វែងរកនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ ការស្វែងរកអព្យាបាទ សូន្យដោយព្យាបាទ ការស្វែងរកអាលោកសញ្ញា សូន្យដោយថីនមិទ្ធៈ ការស្វែងរកសេចក្តីមិនរាយមាយ

សូន្យដោយឧទ្ធច្ចៈ ការស្វែងរកសេចក្តីកំណត់នូវធម៌ សូន្យដោយវិចិកិច្ឆា ការស្វែងរកញាណ សូន្យដោយអវិជ្ជា ការស្វែងរកបាមុជ្ជៈ សូន្យដោយអរតិ ការស្វែងរកបឋមជ្ឈាន សូន្យដោយនីវរណៈ ។បេ។ ការស្វែងរកអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះការស្វែងរកសូន្យ ។

[ ១២២ ] ការកំណត់សូន្យ តើដូចម្តេច ។ ការកំណត់នូវនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ ការកំណត់នូវអព្យាបាទ សូន្យដោយព្យាបាទ ការកំណត់នូវអាលោកសញ្ញា សូន្យដោយថីនមិទ្ធ ការកំណត់នូវសេចក្តីមិនរាយមាយ សូន្យដោយឧទ្ធច្ចៈ ការកំណត់នូវសេចក្តីកំណត់នូវធម៌ សូន្យដោយវិចិកិច្ឆា ការកំណត់នូវញាណ សូន្យដោយអវិជ្ជា ការកំណត់នូវបាមុជ្ជៈ សូន្យដោយអរតិ ការកំណត់នូវបឋមជ្ឈាន សូន្យដោយពួកនីវរណៈ ។បេ។ ការកំណត់នូវអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះការកំណត់សូន្យ ។

[ ១២៣ ] ការបានចំពោះសូន្យ តើដូចម្តេច ។ ការបានចំពោះនូវនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ ការបានចំពោះនូវអព្យាបាទ សូន្យដោយព្យាបាទ ការបានចំពោះនូវអាលោកសញ្ញា សូន្យដោយថីនមិទ្ធៈ ការបានចំពោះនូវសេចក្តីមិនរាយមាយ សូន្យដោយឧទ្ធច្ចៈ ការបានចំពោះនូវសេចក្តីកំណត់នូវធម៌ សូន្យដោយវិចិកិច្ឆា ការបានចំពោះនូវញាណ សូន្យដោយអវិជ្ជា ការបានចំពោះនូវបាមុជ្ជៈ សូន្យដោយអរតិ ការបានចំពោះនូវបឋមជ្ឈាន សូន្យដោយពួកនីវរណៈ ។បេ។ ការបានចំពោះនូវអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះការបានចំពោះសូន្យ ។

[ ១២៤ ] ការចាក់ធ្លុះសូន្យ តើដូចម្ដេច ។ ការចាក់ធ្លុះនូវនេក្ខម្មៈ សូន្យដោយកាមច្ឆន្ទៈ ការចាក់ធ្លុះនូវអព្យាបាទ សូន្យដោយព្យាបាទ ការចាក់ធ្លុះនូវអាលោកសញ្ញា សូន្យដោយថីនមិទ្ធៈ ការចាក់ធ្លុះនូវសេចក្ដីមិនរាយមាយ សូន្យដោយឧទ្ធច្ចៈ ការចាក់ធ្លុះនូវសេចក្ដីកំណត់នូវធម៌ សូន្យដោយវិចិកិច្ឆា ការចាក់ធ្លុះនូវញាណ សូន្យដោយអវិជ្ជា ការចាក់ធ្លុះនូវបាមុជ្ជៈ សូន្យដោយអរតិ ការចាក់ធ្លុះនូវបឋមជ្ឈាន សូន្យដោយនីវរណៈ ។បេ។ ការចាក់ធ្លុះនូវអរហត្តមគ្គសូន្យដោយកិលេសទាំងអស់ នេះការចាក់ធ្លុះសូន្យ ។

[ ១២៥ ] ធម្មជាតដូចគ្នាសូន្យ ធម្មជាតផ្សេងគ្នាសូន្យ តើដូចម្ដេច ។ កាមច្ឆន្ទៈជាសភាពផ្សេងគ្នា នេក្ខម្មៈជាសភាពដូចគ្នា នេក្ខម្មៈជាសភាពដូចគ្នា សូន្យដោយកាមច្ឆន្ទៈរបស់បុគ្គលកាលគិត ព្យាបាទជាសភាពផ្សេងគ្នា អព្យាបាទជាសភាពដូចគ្នា អព្យាបាទជាសភាពដូចគ្នា សូន្យដោយព្យាបាទរបស់បុគ្គលកាលគិត ថីនមិទ្ធជាសភាពផ្សេងគ្នា អាលោកសញ្ញាជាសភាពដូចគ្នា អាលោកសញ្ញាជាសភាពដូចគ្នា សូន្យដោយថីនមិទ្ធ របស់បុគ្គលកាលគិត ឧទ្ធច្ចៈជាសភាពផ្សេងគ្នា វិចិកិច្ឆាជាសភាពផ្សេងគ្នា អវិជ្ជាជាសភាពផ្សេងគ្នា អរតិជាសភាពផ្សេងគ្នា ពួកនីវរណៈជាសភាពផ្សេងគ្នា បឋមជ្ឈានជាសភាពដូចគ្នា បឋមជ្ឈានជាសភាពដូចគ្នា សូន្យដោយពួកនីវរណៈរបស់បុគ្គលកាលគិត ។បេ។ កិលេសទាំងអស់ជាសភាពផ្សេងគ្នា អរហត្តមគ្គជាសភាពដូចគ្នា សូន្យដោយកិលេសទាំងអស់របស់បុគ្គលកាលគិត នេះធម្មជាតដូចគ្នាសូន្យ ធម្មជាតផ្សេងគ្នាសូន្យ ។

[ ១២៦ ] ខន្តិសុញ្ញ តើដូចម្តេច ។ ខន្តិក្នុងនេក្ខម្មៈសុញ្ញដោយកាមច្ឆន្ទៈ ខន្តិក្នុងអព្យាបាទ សុញ្ញដោយព្យាបាទ ខន្តិក្នុងអាលោកសញ្ញា សុញ្ញដោយថីនមិទ្ធៈ ខន្តិក្នុងការមិនរាយមាយ សុញ្ញដោយឧទ្ធច្ចៈ ខន្តិក្នុងការកំណត់នូវធម៌សុញ្ញដោយវិចិកិច្ឆា ខន្តិក្នុងញាណ សុញ្ញដោយអវិជ្ជា ខន្តិក្នុងបាមុជ្ជៈ សុញ្ញដោយអរតិ ខន្តិក្នុងបឋមជ្ឈាន សុញ្ញដោយនីវរណៈ ។បេ។ ខន្តិក្នុងអរហត្តមគ្គសុញ្ញដោយកិលេសទាំងអស់ នេះខន្តិសុញ្ញ ។

[ ១២៧ ] អធិដ្ឋានសុញ្ញ តើដូចម្តេច ។ អធិដ្ឋាននូវនេក្ខម្មៈសុញ្ញដោយកាមច្ឆន្ទៈ អធិដ្ឋាននូវអព្យាបាទ សុញ្ញដោយព្យាបាទ អធិដ្ឋាននូវអាលោកសញ្ញាសុញ្ញដោយថីនមិទ្ធ អធិដ្ឋាននូវការមិនរាយមាយ សុញ្ញដោយឧទ្ធច្ចៈ អធិដ្ឋាននូវការកំណត់នូវធម៌ សុញ្ញដោយវិចិកិច្ឆា អធិដ្ឋាននូវញាណ សុញ្ញដោយអវិជ្ជា អធិដ្ឋាននូវបាមុជ្ជៈ សុញ្ញដោយអរតិ អធិដ្ឋាននូវបឋមជ្ឈាន សុញ្ញដោយពួកនីវរណៈ ។បេ។ អធិដ្ឋាននូវអរហត្តមគ្គ សុញ្ញដោយកិលេសទាំងអស់ នេះអធិដ្ឋានសុញ្ញ ។

[ ១២៨ ] ការឈានចុះស៊ប់សុញ្ញ តើដូចម្តេច ។ ការឈានចុះស៊ប់ក្នុងនេក្ខម្មៈ សុញ្ញដោយកាមច្ឆន្ទៈ ការឈានចុះស៊ប់ក្នុងអព្យាបាទ សុញ្ញដោយព្យាបាទ ការឈានចុះស៊ប់ក្នុងអាលោកសញ្ញា សុញ្ញដោយថីនមិទ្ធៈ ការឈានចុះស៊ប់ក្នុងសេចក្តីមិនរាយមាយ សុញ្ញដោយឧទ្ធច្ចៈ ការឈានចុះស៊ប់ក្នុងសេចក្តីកំណត់នូវធម៌ សុញ្ញដោយវិចិកិច្ឆា ការឈានចុះស៊ប់ក្នុងញាណសុញ្ញដោយអវិជ្ជា ការឈានចុះស៊ប់ក្នុងបាមុជ្ជៈ សុញ្ញដោយអរតិ ការ

ឈានចុះស៊ប់ក្នុងបឋមជ្ឈាន សូន្យដោយនីវរណៈ ។បេ។ ការឈានចុះស៊ប់ក្នុងអរហត្តមគ្គ សូន្យដោយកិលេសទាំងអស់ នេះការឈានចុះស៊ប់សូន្យ ។

[ ១២៩ ] ការបង្អស់នូវការប្រព្រឹត្តិរបស់បុគ្គលអ្នកដឹងច្បាស់ ឈ្មោះថាសូន្យដ៏ក្រៃលែងជាងធម្មជាតសូន្យទាំងអស់ តើដូចម្តេច ។ បុគ្គលអ្នកដឹងច្បាស់ រមែងបង្អស់នូវការប្រព្រឹត្តិនៃកាមច្ឆន្ទៈដោយនេក្ខម្មៈ បង្អស់នូវការប្រព្រឹត្តិនៃព្យាបាទដោយអព្យាបាទ បង្អស់នូវការប្រព្រឹត្តិនៃថីនមិទ្ធៈ ដោយអាលោកសញ្ញា បង្អស់នូវការប្រព្រឹត្តិនៃឧទ្ធច្ចៈ ដោយការមិនរាយមាយ បង្អស់នូវការប្រព្រឹត្តិនៃវិចិកិច្ឆាដោយការកំណត់នូវធម៌ បង្អស់នូវការប្រព្រឹត្តិនៃអវិជ្ជាដោយញាណ បង្អស់នូវការប្រព្រឹត្តិនៃអរតិដោយបាមុជ្ជៈ បង្អស់នូវការប្រព្រឹត្តិនៃពួកនីវរណៈដោយបឋមជ្ឈាន ។បេ។ បង្អស់នូវការប្រព្រឹត្តិនៃកិលេសទាំងអស់ ដោយអរហត្តមគ្គ មួយវិញទៀត កាលបុគ្គលអ្នកដឹងច្បាស់ បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ការប្រព្រឹត្តិនៃចក្ខុនេះឯង រមែងអស់ទៅ ទាំងការប្រព្រឹត្តិនៃចក្ខុដទៃ ក៏មិនកើតឡើង ការប្រព្រឹត្តិនៃសោតៈនេះឯង ។បេ។ ការប្រព្រឹត្តិនៃឃានៈ ការប្រព្រឹត្តិនៃជិវ្ហា ការប្រព្រឹត្តិនៃកាយ ការប្រព្រឹត្តិនៃមនោនេះឯងរមែងអស់ទៅ ទាំងការប្រព្រឹត្តិនៃមនោដទៃ ក៏មិនកើតឡើង នេះការបង្អស់នូវការប្រព្រឹត្តិរបស់បុគ្គលអ្នកដឹងច្បាស់ ឈ្មោះថាសូន្យដ៏ក្រៃលែងជាងធម្មជាតសូន្យទាំងអស់ ។

**ចប់ សុញ្ញកថា ។**

**ចប់ យុគនទ្ធវគ្គទី ២ ។**

## ឧទ្ទាននៃវគ្គនោះគឺ

យុគនទ្ធកថា ១ សច្ចកថា ១ ពោជ្ឈង្គកថា ១ មេត្តាកថា ១ វិរាគកថា ១ ជាគម្រប់ ៥ បដិសម្ភិទាកថា ១ ធម្មចក្កកថា ១ លោកុត្តរកថា ១ ពលកថា ១ សុញ្ញកថា ១ ត្រូវជា ១០ ។ វគ្គទីពីរនុ៎ះជាពួកដ៏ប្រសើរ ឥតមានពួកដទៃស្មើឡើយ ជាមគ្គដ៏ប្រសើថ្លៃថ្លាដែលព្រះសង្គីតិកាចារ្យរចនាទុកហើយ ។

# អដ្ឋកថា

## សុញ្ញកថា

[ ១០៤ ] ឥឡូវនេះ ជាការពណ៌នាសេចក្តី តាមលំដាប់ដែលមិនធ្លាប់ពណ៌នាក្នុងសុញ្ញតាកថា ដែលមានព្រះសូត្រជាបទនាំ មានលោកុត្តរសុញ្ញតាជាទីបំផុត ដែលព្រះសារីបុត្តត្ថេរពោលហើយ បន្ទាប់អំពីពលកថា ដែលមានលោកុត្តរពលៈជាទីបំផុត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រដូចតទៅនេះថា បទថា **អថ** ជានិបាតចុះក្នុងអត្ថកាន់យកនៃពាក្យ ។ ដោយបទនោះ លោកធ្វើការកាន់យកនៃពាក្យថា **អាយស្មា** ជាដើម ។ បទថា **ខោ** ជានិបាត ចុះក្នុងអត្ថនៃបទបូរណ ( ធ្វើបទឲ្យពេញ ) ។ បទថា **យេន ភគវា តេនុបសង្កមិ** ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ ព្រោះហេតុនោះគប្បីឃើញអត្ថក្នុងបទនេះយ៉ាងនេះថា ព្រះមានព្រះភាគគង់ក្នុងទីណា ក៏ចូលទៅគាល់ក្នុងទីនោះ ។ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងបទនេះ យ៉ាងនេះថា ព្រះមានព្រះភាគដែលទេវតា និងមនុស្សគប្បីចូលទៅគាល់ដោយហេតុណា ចូលទៅគាល់ហើយដោយហេតុនោះ ។ ព្រះមានព្រះភាគ ដែលទេវតានិងមនុស្សគប្បីចូលទៅគាល់ ដោយហេតុដូចម្តេច គប្បីចូលទៅដោយបំណងនិងសម្រេចគុណវិសេស មានប្រការផ្សេងៗ ដូចដើមឈើធំមានផ្លែជានិច្ចដែលពួកបក្សីទាំងឡាយ គប្បីចូលទៅដោយបំណងនឹងស៊ីផ្លែឈើ មានរសឆ្ងាញ់ដូច្នោះ ។ គប្បីឃើញអត្ថក្នុងបទនេះយ៉ាងនេះថា ចូលទៅរកហើយដោយ

ហេតុនោះ ។ បទថា **ឧបសង្កមិ** លោកអធិប្បាយថា ចូលទៅហើយ ។ បទថា **ឧបសង្កមិត្វា** ជាពាក្យសម្តែង ដល់ទីបំផុតនៃការចូលគាល់ ។ម្យ៉ាងទៀត មានអធិប្បាយថា ទៅហើយយ៉ាងនេះ ទៅកាន់ទីជិតជាងនោះ ពោលគឺជិតព្រះមានព្រះភាគ ។ បទថា **អភិវាទេត្វា** បានដល់ ថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន ។

ឥឡូវនេះ ព្រះអានន្ទត្រេរបំណងនឹងទូលសួរសេចក្តីដែលខ្លួនមកឧបដ្ឋាក ព្រះមានព្រះភាគ ជាបុគ្គលប្រសើរក្នុងលោក ទើបលើកដៃឡើងថ្វាយបង្គំ លើសិរសា ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ បទថា **ឯកមន្តំ** សម្តែងជាភាវៈនបុំសកលិង្គ ដូចក្នុងប្រយោគជាដើមថា **វិសម ចន្ទិមសូរិយា បរិវត្តន្តិ**[1] ព្រះចន្ទនិងព្រះអាទិត្យ ក៏គោចរទៅមិនស្មើដែរ ព្រោះហេតុនោះគប្បីឃើញអត្ថក្នុងបទនេះយ៉ាងនេះថា បុគ្គលអង្គុយ ជាអ្នកអង្គុយក្នុងទីសមគួរនាចំណែកម្ខាងដោយប្រការណា ព្រះអានន្ទ ក៏អង្គុយហើយដោយប្រការនោះ ។ ម្យ៉ាងទៀត បទនេះជាទុតិយាវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ ។ បទថា **និសីទិ** បានដល់ សម្រេចការអង្គុយ ។ ពិតណាស់ទេវតានិងមនុស្សដែលឈ្លាស កាលចូលទៅរកបុគ្គលដែលគួរគោរព រមែងអង្គុយក្នុងទីដ៏សមគួរ ព្រោះជាអ្នកឈ្លាសក្នុងការអង្គុយ ព្រះថេរៈនេះក៏ជាអ្នកឈ្លាសមួយរូបក្នុងអ្នកឈ្លាសទាំងនោះ ព្រោះហេតុនោះ ទើបអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ បុគ្គលអង្គុយដូចម្តេច ទើបឈ្មោះថា អង្គុយ

---

១-បិដកខ្មែរជាបរិវត្ត

ក្នុងទីសមគួរ ។ គឺវៀរទោសនៃការអង្គុយ ៦ ប្រការ គឺឆ្ងាយពេក ១ ជិតពេក ១ លើខ្យល់ ១ ខ្ពស់ជាង ១ អង្គុយចំពីមុខ ១ អង្គុយខាងក្រោយពេក ១ ។ ព្រោះអង្គុយឆ្ងាយពេក បើបំណងនឹងនិយាយ ក៏ត្រូវនិយាយដោយសំឡេងខ្លាំង ។ អង្គុយជិតពេកក៏រមែងប្រជ្រៀត ។ អង្គុយលើខ្យល់ ក៏រំខានដោយក្លិនខ្លួន ។ អង្គុយក្នុងទីខ្ពស់ រមែងប្រកាសសេចក្តីមិនគោរព ។ អង្គុយចំពីមុខពេក បើបំណងសម្លឹងមើល ភ្នែកនឹងភ្នែកក៏ប៉ះគ្នា ។ អង្គុយក្រោយពេក បើបំណងនឹងឃើញ ក៏ត្រូវអើតកមើល ។ ព្រោះហេតុនោះ ព្រះអានន្ទត្ថេរក៏អង្គុយវៀរទោសនៃការអង្គុយ ៦ ប្រការទាំងនេះ ដោយហេតុនោះ ទើបលោកពោលថា **ឯកមន្តំ និសីទិ** ។ បទថា **ឯតទវោច** កាត់បទជា **ឯតំ អវោច** ។

បទថា **សុញ្ញោ លោកោ សុញ្ញោ លោកោតិ ភន្តេ វុច្ចតិ** សេចក្តីថា ភិក្ខុទាំងនោះ ដែលបដិបត្តិក្នុងសាសនានេះរមែងពោលថា លោកសូន្យ លោកសូន្យ ដូច្នេះ ព្រោះពាក្យនោះនិយាយគ្នាច្រើនក្នុងទីនោះៗ ដើម្បីរួបរួមភិក្ខុទាំងអស់នោះ ទើបនិយាយដដែលៗ កាលពោលយ៉ាងនេះហើយ ក៏ឈ្មោះថា រួបរួមពាក្យទាំងអស់នោះ ។ បទថា **កិត្តាវតា** បានដល់ ដោយប្រមាណប៉ុនណា ។ សព្ទថា **នុ** ជានិបាតចុះក្នុងអត្ថនៃសេចក្តីសង្ស័យ ។ បទថា **សុញ្ញំ អត្តេន វា អត្តនិយេន វា** បានដល់ សូន្យចាកខ្លួនដែលលោកកំណត់ទុកយ៉ាងនេះថា អ្នកធ្វើ អ្នកសោយ អ្នកមានអំណាចឯង និងសូន្យចាកបរិក្ខារដែលជារបស់ខ្លួន ព្រោះការមិនមានខ្លួននោះឯង ។

ចក្ខុជាដើមទាំងអស់ ជាលោកិយធម្មជាត ចក្ខុជាដើមនោះឯង ឈ្មោះថា លោក ព្រោះអត្ថថា បែកធ្លាយទៅ ។ អធិប្បាយថា ព្រោះខ្លួនមិនមានក្នុងលោកនេះ និងវត្ថុដែលទាក់ទងដោយខ្លួន ក៏មិនមានក្នុងលោកនេះ ព្រោះហេតុនោះ ទើបខ្ញុំពោលថា **តស្មា សុញ្ញោ លោកោ វុច្ចតិ** ។ សូម្បីលោកុត្តរធម៌ក៏សូន្យចាកខ្លួន និងរបស់ខ្លួនដូចគ្នា តែត្រាស់ដល់លោកិយធម៌ប៉ុណ្ណោះ ដោយសមគួរដល់ពាក្យសួរ ។

ម្យ៉ាងទៀត បទថា **សុញ្ញោ** ទ្រង់មិនត្រាស់ថា ធម៌មិនមាន ត្រាស់ដល់ការមិនមានខ្លួន និងសារៈដែលជារបស់ខ្លួនក្នុងធម៌នោះ ។ ម្យ៉ាងទៀត កាលសត្វលោកពោលថា ផ្ទះសូន្យ ឆ្នាំងសូន្យ ក៏មិនមែនពោលដល់ការមិនមានផ្ទះ និងមិនមានឆ្នាំង តែពោលដល់ការមិនមានវត្ថុដទៃក្នុងផ្ទះនិងក្នុងឆ្នាំងនោះ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់សេចក្ដីនេះទុកថា ដោយប្រការដូច្នេះ វត្ថុណាមិនមានក្នុងវត្ថុនោះ ភិក្ខុរមែងពិចារណាវត្ថុនោះថាសូន្យ ដោយហេតុនោះ តែវត្ថុណាមានសល់នៅក្នុងវត្ថុនោះ វត្ថុនោះមាន ភិក្ខុរមែងដឹងថា វត្ថុនេះមាន ។ ក្នុងញាយគន្ថៈ ( គម្ពីរដើម្បីការត្រាស់ដឹង ) និងក្នុងសទ្ទគន្ថៈ ( គម្ពីរសព្ទ ) ក៏មានសេចក្ដីយ៉ាងនេះដូចគ្នា ។ ក្នុងព្រះសូត្រនេះ លោកពោលដល់អនត្តលក្ខណសូត្រ ដោយប្រការដូច្នេះ ។

[ ១០៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេស ដូចតទៅនេះថា ព្រះសារីបុត្តលើកបទមាតិកា ២៥ មានបទថា **សុញ្ញំ សុញ្ញំ** ជាដើមដោយភ្ជាប់ពាក្យថា សូន្យ ហើយចង្អុលបង្ហាញបទមាតិកាទាំងនោះ ។

ក្នុងបទទាំងនោះ គប្បីជ្រាបសេចក្តីក្នុងមាតិកាមុនថា ឈ្មោះថា **សុញ្ញំ សុញ្ញំ** ព្រោះសូន្យ គឺទទេ មិនបានធ្វើឲ្យវិសេសឡើង ដោយការប្រកបដោយបទដទៃ ។

ម្យ៉ាងទៀត ក្នុងបទថា **សុញ្ញំ សុញ្ញំ** នេះ ព្រោះមិនសម្តែងថា ជាវត្ថុនោះ ឬព្រោះសម្លឹងដល់ភាពជារបស់សូន្យប៉ុណ្ណោះ ទើបលោកធ្វើឲ្យជាពាក្យនបុំសកលិង្គ ។ បទដ៏សេសក៏យ៉ាងនេះ ។ ឈ្មោះថា **សង្ខារសុញ្ញំ** ព្រោះសង្ខារនោះឯង សូន្យចាកសង្ខារដ៏សេស ។

ការប្រែប្រួលដែលខុសប្រក្រតីទៅ ដោយជរានិងការបែកធ្លាយ ឈ្មោះថា **វិបរិណាម** ការសូន្យដោយវិបរិណាមនោះ ឈ្មោះថា **វិបរិណាមសុញ្ញំ** ។ ឈ្មោះថា **អគ្គសុញ្ញំ** ព្រោះវត្ថុនោះប្រសើរ និងសូន្យចាកខ្លួន និងចាកវត្ថុដែលជារបស់ខ្លួន ឬចាកសង្ខារទាំងពួង ។ ឈ្មោះថា **លក្ខណសុញ្ញំ** ព្រោះលក្ខណៈនោះឯងសូន្យចាកលក្ខណៈដ៏សេស ។ ការសូន្យដោយការសង្កត់ មាននេក្ខម្មៈជាដើម ឈ្មោះថា **វិក្ខម្ភនសុញ្ញំ** ។ សូម្បីក្នុងសុញ្ញៈ ៤ មាន **តទង្គសុញ្ញំ** ជាដើម ក៏មានន័យនេះដូចគ្នា ។ ឈ្មោះថា **អជ្ឈត្តសុញ្ញំ** ព្រោះវត្ថុនោះជាខាងក្នុង និងសូន្យចាកខ្លួននិងចាកវត្ថុដែលជារបស់ខ្លួនជាដើម ។ ឈ្មោះថា **ពហិទ្ធាសុញ្ញំ** ព្រោះវត្ថុនោះជាខាងក្រៅ និងសូន្យចាកខ្លួននិងចាកវត្ថុដែលជារបស់ខ្លួន ជាដើម ។ ឈ្មោះថា **ឧភតោសុញ្ញំ** ព្រោះទាំងពីរនោះ សូន្យចាកខ្លួន និងចាកវត្ថុដែលជារបស់ខ្លួនជាដើម ។ ឈ្មោះថា **សភាគ** ព្រោះមានចំណែកស្មើគ្នា ឈ្មោះថា

**សភាគសុញាំ**□ព្រោះវត្ថុនោះជាសភាគ និងសូន្យចាកខ្លួននិងចាកវត្ថុជារបស់ខ្លួនជាដើម អធិប្បាយថា ស្មើគ្នាសូន្យ ។

ចំណែកស្មើគ្នាទៅប្រាសហើយ ( មិនស្មើគ្នា ) ឈ្មោះថា **វិសភាគ** ឈ្មោះថា **វិសភាគសុញ្ញំ** ព្រោះវត្ថុនោះមិនស្មើ និងសូន្យចាកខ្លួននិងវត្ថុដែលជារបស់ខ្លួន អធិប្បាយថា មិនស្មើគ្នាសូន្យ ។

ក្នុងគម្ពីរខ្លះរបនា ធម្មជាតមានចំណែកស្មើគ្នាទាំងសូន្យ ធម្មជាតមានចំណែកខុសគ្នាទាំងសូន្យទុកក្នុងលំដាប់នៃធម្មជាតរលាស់ចេញទាំងសូន្យ ។ ឈ្មោះថា **ឯសនាសុញ្ញំ** ព្រោះការស្វែងរកនេក្ខម្មៈជាដើម សូន្យចាកកាមច្ឆន្ទៈជាដើម ។ សូម្បីក្នុងសុញ្ញៈ ៣ មានបរិគ្គហសុញ្ញជាដើម ក៏មានន័យនេះដូចគ្នា ។ ឈ្មោះថា **ឯកត្តសុញ្ញំ** ព្រោះអត្ថថា វត្ថុនោះតែមួយដូចគ្នា និងសូន្យចាកភាពផ្សេងគ្នា ព្រោះតាំងនៅក្នុងអារម្មណ៍តែមួយ ព្រោះមិនមានការរាយមាយក្នុងអារម្មណ៍ផ្សេង ៗ ។ ឈ្មោះថា **នានត្តសុញ្ញំ** ព្រោះអត្ថថា វត្ថុនោះមានការផ្សេងគ្នា និងសូន្យចាកភាពតែមួយ ព្រោះផ្ទុយគ្នានឹងឯកត្តសុញ្ញៈនោះ ។ ឈ្មោះថា **ខន្តិសុញ្ញំ** ព្រោះអត្ថថា ពេញចិត្តក្នុងនេក្ខម្មៈជាដើម សូន្យចាកកាមច្ឆន្ទៈជាដើម ។ អធិដ្ឋានសុញ្ញៈ និងបរិយោគាហនសុញ្ញៈ ក៏មានន័យដូចគ្នា ។ បាឋៈថា **បរិយោគាហណសុញ្ញំ** ក៏មាន ។ បទថា **សម្បជានស្ស** បានដល់ នៃព្រះអរហន្តដែលបរិនិព្វានប្រកបដោយសម្បជញ្ញៈ ។ បទថា **បវត្តបរិយាទានំ** បានដល់ អនុបាទាបរិនិព្វាន ។ បទថា **សព្វសុញ្ញតានំ** បានដល់ នៃការសូន្យទាំងអស់ ។ បទថា **បរ-**

**មគ្គសុញ្ញំ** បានដល់ ការសូន្យដែលជាប្រយោជន៍ដ៏ឧត្តម ព្រោះមិនមានសង្ខារទាំងពួង ។

[ ១០៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមាតិកានិទ្ទេស ដូចតទៅនេះថា បទថា **និច្ចេន វា** បានដល់ សូន្យចាកការទៀង ព្រោះមិនមានការទៀងណាមួយដែលឈានកន្លងការបែកធ្លាយ ហើយប្រព្រឹត្តទៅបាន ។ បទថា **ធុវេន វា** បានដល់ សូន្យចាកការឋិតថេរ ព្រោះមិនមានវត្ថុណាមួយដែលមាំទាំ ព្រោះប្រព្រឹត្តទៅទាក់ទងដោយបច្ច័យ សូម្បីក្នុងកាលដែលមាន ។ បទថា **សស្សតេន វា** បានដល់ សូន្យចាកការទៀងទាត់ ព្រោះមិនមានរបស់ណាមួយ ដែលមាននៅក្នុងកាលទាំងពួង ដែលកាត់ផ្តាច់ទៅហើយ ។ បទថា **អវិបរិណាមធម្មេន វា** បានដល់ សូន្យចាកការមិនប្រែប្រួលជាធម្មតា ព្រោះមិនមានរបស់ណាមួយដែលប្រក្រតី និងមិនប្រែប្រួលទៅដោយអំណាចជរា និងការបែកធ្លាយ ។

កាលពោលដល់ការសូន្យចាកខ្លួនដោយព្រះសូត្រហើយ ដើម្បីសម្តែងការសូន្យចាកភាពជារបស់ទៀងនិងសូន្យចាកសេចក្តីសុខ ទើបលោកពោលបទថា **និច្ចេន វា** ជាដើម ទុកក្នុងទីនេះ ។ កាលពោលដល់សេចក្តីសូន្យចាកភាពជារបស់ទៀង ឈ្មោះថា លោកពោលដល់ សូម្បីការសូន្យចាកសេចក្តីសុខផងដែរ ព្រោះការមិនទៀង ជាទុក្ខ ដ្បិតត្រូវបៀតបៀន ។ ម្យ៉ាងទៀត គប្បីជ្រាបថា លោកសង្ខេបវិស័យ ៦ មានរូបជាដើម វិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើម ផស្សៈ ៦ មានចក្ខុសម្ផស្សៈជាដើម និង

វេទនា ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម ទុកក្នុងទីនេះ ។

[ ១០៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **បុញ្ញាភិសង្ខារោ** ជាដើម ដូចតទៅនេះថា ឈ្មោះថា បុញ្ញ ព្រោះជម្រះបុគ្គលដែលធ្វើតាមខ្លួន ញ៉ាំងអធ្យាស្រ័យរបស់បុគ្គលនោះឲ្យពេញ និងញ៉ាំងភពដែលគួរបូជាឲ្យកើត ។ ឈ្មោះថា អភិសង្ខារ ព្រោះតាក់តែងវិបាក និងកដត្តារូប ។ ការតាក់តែងបុណ្យ ឈ្មោះថា បុញ្ញាភិសង្ខារ ការតាក់តែងបាបដោយផ្ទុយនឹងបុញ្ញ ឈ្មោះថា អបុញ្ញាភិសង្ខារ ។ ការញាប់ញ័រមិនមាន ឈ្មោះថា អនេញ្ជ ឈ្មោះថា អានេញ្ជាភិសង្ខារ ព្រោះតាក់តែងភពដែលមិនញាប់ញ័រ ។

បុញ្ញាភិសង្ខារមានចេតនា ១៣ គឺកាមាវចរកុសលចេតនា ៨ ដែលប្រព្រឹត្តទៅដោយអំណាចនៃទាន សីល ភាវនាជាដើម និងរូបាវចរកុសលចេតនា ៥ ដែលប្រព្រឹត្តទៅដោយអំណាចនៃភាវនា ។ អបុញ្ញាភិសង្ខារមានអកុសលចេតនា ១២ ដែលប្រព្រឹត្តទៅដោយអំណាចនៃបាណាតិបាតជាដើម ។ អានេញ្ជាភិសង្ខារ មានអរូបាវចរចេតនា ៤ ដែលប្រព្រឹត្តទៅដោយអំណាចនៃភាវនាប៉ុណ្ណោះ ព្រោះហេតុនោះ ទើបសង្ខារ ៣ មានចេតនា ២៩ ។

ក្នុងកាយសង្ខារជាដើម មានសេចក្ដីដូចតទៅនេះថា ឈ្មោះថា កាយសង្ខារ ព្រោះប្រព្រឹត្តទៅតាមផ្លូវកាយ ឬ តាក់តែងកាយ ។ សូម្បីក្នុងវចីសង្ខារ និងចិត្តសង្ខារ ក៏មានន័យនេះដូចគ្នា ។ ត្រិកៈនេះ លោកពោលដើម្បីសម្ដែងការប្រព្រឹត្តិទៅ តាមទ្វារនៃបុញ្ញាភិសង្ខារជាដើម ក្នុងខណៈ

ប្រមូលកម្មមក ។

ចេតនា ២១ គឺកាមាវចរកុសលចេតនា ៨ អកុសលចេតនា ១២ អភិញ្ញាចេតនា ១ ដែលញុំាងកាយវិញ្ញត្តិឲ្យតាំងឡើងហើយប្រព្រឹត្តទៅតាមកាយទ្វារ ឈ្មោះថា កាយសង្ខារ ។ ចេតនាទាំងនោះឯងដែលញុំាងវចីវិញ្ញត្តិឲ្យតាំងឡើង ឲ្យប្រព្រឹត្តទៅតាមវចីទ្វារ ឈ្មោះថា វចីសង្ខារ ។ ចំណែកចេតនា ២៩ សូម្បីទាំងអស់ដែលប្រព្រឹត្តទៅក្នុងមនោទ្វារ ឈ្មោះថា ចិត្តសង្ខារ ។

ក្នុងបទថា **អតីតា សង្ខារា** ជាដើម មានសេចក្តីដូចតទៅនេះថា សង្ខតធម៌សូម្បីទាំងអស់ដែលដល់ខណៈរបស់ខ្លួនហើយរលត់ទៅ ឈ្មោះថា សង្ខារចំណែកអតីតៈ ។ សង្ខតធម៌ដែលមិនទាន់មកដល់ខណៈ របស់ខ្លួន ឈ្មោះថា សង្ខារចំណែកអនាគត សង្ខតធម៌ដែលដល់ខណៈរបស់ខ្លួនហើយ ឈ្មោះថា សង្ខារចំណែកបច្ចុប្បន្ន ។

[ ១០៨ ] ក្នុងធម្មជាតប្រែប្រួលសូន្យ ព្រះសារីបុត្តត្រូវសម្តែងបច្ចុប្បន្នធម៌មុន ដោយបំណងថា កាលសម្តែងវត្ថុដែលជាបច្ចុប្បន្នហើយ ការប្រែប្រួលនៃវត្ថុនោះៗ អាចពោលបានងាយ ។

ក្នុងបទទាំងនោះ បទថា **ជាតំ រូបំ** បានដល់ រូបចំណែកបច្ចុប្បន្ន ។ គប្បីជ្រាបសេចក្តីក្នុងបទថា **សភាវេន សុញ្ញំ** ដូចតទៅនេះថា ការកើតឯង ឈ្មោះថា សភាវៈ អធិប្បាយថា ការកើតឯងនោះឯង ។ ឬសភាវៈរបស់ខ្លួន ឈ្មោះថា សភាវៈ អធិប្បាយថា ការកើតឡើងនៃខ្លួននោះឯង ។

ឈ្មោះថា **សភាវេន សុញ្ញំ** ព្រោះការកើតឯងឬភាពជារបស់ខ្លួនវៀរបច្ច័យ មិនមានក្នុងសភាវៈនេះ ព្រោះការប្រព្រឹត្តិទៅទាក់ទងដោយបច្ច័យ ។ មានពាក្យអធិប្បាយថា សូន្យចាកការកើតឯង ឬចាកការកើតនៃខ្លួន ។ ម្យ៉ាងទៀត ភាវៈនៃខ្លួន ឈ្មោះថា សភាវៈ ព្រោះថាធម៌នីមួយៗក្នុងរូបធម៌និងអរូបធម៌មិនតិច មានបឋវីធាតុជាដើម ឈ្មោះថា របស់ខ្លួន ព្រោះប្រៀបធៀបនិងអ្នកដទៃ ។ ម្យ៉ាងទៀត បទថា **ភាវោ** នេះ ជាពាក្យហៅធម៌ដោយអម ។ ធម៌ គឺភាវៈដទៃនៃធម៌មួយមិនមាន ព្រោះហេតុនោះ ទើបឈ្មោះថា សូន្យចាកសភាវៈដទៃរបស់ខ្លួន អធិប្បាយថា ខ្លួនសូន្យចាកភាវៈដទៃ ដោយហេតុនោះ ទើបលោកពោលភាពដែលធម៌នោះជាសភាវៈតែមួយ ។

ម្យ៉ាងទៀត បទថា **សភាវេន សុញ្ញំ** បានដល់ សូន្យទៅដោយសភាវៈដែលសូន្យនោះឯង ។ លោកអធិប្បាយទុកដូចម្តេច លោកអធិប្បាយទុកថា សូន្យព្រោះជាសភាវៈសោះសូន្យ មិនមែនសូន្យព្រោះភាពជាសភាវៈសូន្យដោយបរិយាយដទៃ ។

បើអាចារ្យពួកខ្លះ គប្បីពោលថា ភាវៈរបស់ខ្លួន ឈ្មោះថា សភាវៈ សូន្យចាកសភាវៈនោះ ។ អធិប្បាយទុកដូចម្តេច អធិប្បាយថា ឈ្មោះថា ភាវៈ ភាវៈនោះបន្ថែមបទ **ស** ចូលទៅដោយប្រៀបធៀបនឹងអ្នកដទៃ ទើបឈ្មោះថា សភាវៈ ។ ព្រោះធម៌មិនមានដល់បុគ្គលណាមួយ ទើបលោកពោលការមិនមាននៃរូបថា រូបដែលកើតហើយ ឈ្មោះថា សូន្យតាមស-

ភាវៈ ។ កាលបើដូច្នោះរមែងខុស ដោយពាក្យថា **ជាតំ រូបំ** ។ ព្រោះវត្ថុដែលប្រាសចាកការកើតឡើងនឹងឈ្មោះថាកើតហើយមិនបាន ។ និព្វានប្រាសចាកការកើតឡើង ទើបនិព្វាននោះ មិនឈ្មោះថា កើតហើយ ។ម្យ៉ាងទៀត ជាតិ ជរា និងមរណៈ ប្រាសចាកការកើតឡើងទើបមិនឈ្មោះថា កើតហើយ ។ ដោយហេតុនោះឯង ក្នុងបទនេះទើបលោកមិនលើកឡើងសម្តែងយ៉ាងនេះថា ជាតិកើតហើយសូន្យទៅចាកសភាវៈ ជរាមរណៈកើតហើយ សូន្យទៅចាកសភាវៈ ហើយសម្តែងកពប៉ុណ្ណោះ ជាពាក្យចុងក្រោយ ។

បើពាក្យថា **ជាតំ** គប្បីគួរដល់វត្ថុប្រាសចាកការកើត ក៏គួរពោលបានថា ជាតិកើតហើយ ជរាមរណៈកើតហើយ ។ ព្រោះកាលជាតិ ជរា និងមរណៈ ប្រាសចាកការកើតឡើង ទើបលោកមិនពោលពាក្យថា **ជាតិ** ហេតុនោះពាក្យថា សូន្យចាកសភាវៈ គឺមិនមាន ទើបខុសដោយពាក្យថា **ជាតំ** ព្រោះវត្ថុដែលមិនមានប្រាសចាកការកើតឡើង ។ ម្យ៉ាងទៀត ពាក្យថាសូន្យនៃវត្ថុដែលមិនមាន ក៏ខុសដោយពាក្យរបស់សត្វលោក ដែលពោលហើយក្នុងខាងដើម ខុសដោយព្រះតម្រាស់របស់ព្រះមានព្រះភាគ និងខុសដោយពាក្យញាយគន្ថៈនិងសទ្ទគន្ថៈ និងខុសដោយយុត្តិមិនមែនតិច ព្រោះហេតុនោះគប្បីលះបង់ពាក្យនោះដូចចោលសំរាម ។ ក្នុងបទនេះជាការត្រឹមត្រូវថា ធម៌គឺធម៌ទាំងឡាយមាននៅក្នុងខណៈរបស់ខ្លួន ដោយប្រមាណនូវព្រះពុទ្ធវចនៈមិនមែនតិច និងដោយត្រឹមត្រូវមិនមែនតិច ( សំយុត្តនិកាយ

ខន្ធវារវគ្គ ) ថា

ម្នាលភិក្ខុទាំងឡាយ របស់ណាដែលបណ្ឌិតសន្មតហើយថា មានក្នុងលោក តថាគតក៏ពោលនូវរបស់នោះថាមានដែរ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលបណ្ឌិតសន្មតហើយថា មិនមានក្នុងលោក តថាគតក៏ពោលនូវរបស់នោះ ថាមិនមានដែរ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវរបស់ណាថាមាន ចុះរបស់នោះដូចម្ដេចដែលបណ្ឌិតសន្មតថា មានក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង ជាទុក្ខ ប្រែប្រួលជាធម្មតាដែលបណ្ឌិតសន្មតថាមានក្នុងលោក តថាគតក៏ពោលនូវរូបនោះថា មានដែរ ដូច្នេះ ។

បទថា **វិគតំ រូបំ** បានដល់ រូបចំណែកអតីតៈរលត់ ព្រោះកើតហើយដល់នូវការបែកធ្លាយ ។ បទថា **វិបរិណតញ្ចេវ សុញ្ញញ្ច** បានដល់រូបដល់នូវការប្រែប្រួល ខុសប្រក្រតី ដោយអំណាចជរានិងការបែកធ្លាយនិងសូន្យដោយការប្រែប្រួលនោះ ព្រោះប្រាកដការប្រែប្រួលនៃរូប ដែលកំពុងប្រព្រឹត្តទៅ ព្រោះមិនមានការប្រែប្រួលនៃរូបចំណែកអតីតៈ ។

សូម្បីក្នុងបទថា **ជាតា វេទនា** ជាដើម ក៏មានន័យនេះដូចគ្នា ។ ម្យ៉ាងទៀត ជាតិ ជរានិងមរណៈមិនគួរក្នុងទីនេះ ព្រោះមិនគប្បីបានដោយភាវៈរបស់ខ្លួន ព្រោះមិនទាន់សម្រេច ព្រោះហេតុនោះ ទើបលោកលះបង់ន័យទាំងពីរថា ជាតិកើតហើយ ជរានិងមរណៈកើតហើយជាដើម ហើយ

ធ្វើន័យមានកពជាដើមនោះឯង ឲ្យជាទីបំផុត ។

[១០៩] បទថា **អគ្គំ** បានដល់ មានក្នុងភាពប្រសើរ ។ បទថា **សេដ្ឋំ** បានដល់ គួរសរសើរយ៉ាងក្រៃលែង ។ បទថា **វិសិដ្ឋំ** បានដល់ វិសេសក្រៃលែង ។ បាឋៈថា **វិសេដ្ឋំ** ដូច្នេះក៏មាន ។ និព្វានដែលសរសើរហើយសូម្បីដោយអាការ ៣ យ៉ាងនោះ ( គឺ **អគ្គំ សេដ្ឋំ វិសិដ្ឋំ** ) ឈ្មោះថា បទព្រោះគប្បីប្រព្រឹត្តទៅដោយបដិបទាប្រពៃ ។ បទថា **យមិទំ** កាត់បទជា **យំ ឥទំ** ។ ព្រះសារីបុត្តត្ថេរចង្អុលបង្ហាញដល់និព្វាន ដែលគួរពោលក្នុងឥឡូវនេះ ។ ព្រោះការស្ងប់សង្ខារទាំងពួង រមែងមានបាន ការលះឧបធិទាំងឡាយដែលបានដល់ខន្ធូបធិ កិលេសូបធិ អភិសង្ខារូបធិ កាមគុណូបធិរមែងមានបាន ការអស់តណ្ហា វិរាគៈ និងនិរោធ រមែងមានបាន ព្រោះអាស្រ័យនិព្វាន ហេតុនោះទើបលោកពោលថា ការរម្ងាប់នូវសង្ខារទាំងពួង ការលះនូវឧបធិទាំងពួង ការអស់នៃតណ្ហា ការប្រាសចាកតម្រេក ការរលត់ដូច្នេះ ។ បទថា **និព្វានំ** បានដល់ លោកសរុបដោយលក្ខណៈនៃសភាវៈ ។

[ ១១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងលក្ខណៈទាំងឡាយ ដូចតទៅនេះថា ព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ ពាលនិមិត្ត ពាលាបទានរបស់បុគ្គលពាលនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយជនពាលក្នុងលោកនេះ អ្នកគិតគំនិតអាក្រក់ ១ អ្នកនិយាយសម្តីអាក្រក់ ១ អ្នកធ្វើអំពើអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ ពាលនិមិត្ត

ពាលាបទាននៃជនពាល ៣ យ៉ាងនេះឯង ដូច្នេះ ។

ពាលលក្ខណៈ ៣ យ៉ាងរបស់បុគ្គលពាលដោយការកំណត់ថា ពាល ដែលបណ្ឌិតទាំងឡាយពោលហើយ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ បណ្ឌិតលក្ខណៈ បណ្ឌិតនិមិត្ត បណ្ឌិតាបទានរបស់បុគ្គលជាបណ្ឌិតនេះមាន ៣ យ៉ាង ។ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតក្នុងលោកនេះ ជាអ្នកគិតគំនិតល្អ ១ និយាយសម្តីល្អ ១ ធ្វើអំពើល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតលក្ខណៈ បណ្ឌិត-និមិត្ត បណ្ឌិតាបទាន របស់បុគ្គលជាបណ្ឌិត ៣ យ៉ាងនេះឯង ដូច្នេះ ។ បណ្ឌិតលក្ខណៈ ៣ យ៉ាង របស់បណ្ឌិតដោយការកំណត់ថា បណ្ឌិត ដែលបណ្ឌិតទាំងឡាយពោលហើយ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ សង្ខតលក្ខណៈរបស់សង្ខតធម៌នេះ មាន ៣ យ៉ាង ។ សង្ខតលក្ខណៈ ៣ យ៉ាង តើដូចម្តេច ។ គឺការកើតរមែងប្រាកដ ១ ការបែកធ្លាយរមែងប្រាកដ ១ ការប្រែប្រួលនៃសភាវៈដែលតាំងនៅ រមែងប្រាកដ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសង្ខតលក្ខណៈរបស់សង្ខតធម៌ទាំង ៣ យ៉ាង ដូច្នេះ ។ ឈ្មោះថា សង្ខតលក្ខណៈព្រោះអត្ថថា លក្ខណៈដែលតាក់តែង គឺការកើតឡើង ។ គប្បីជ្រាបអត្ថក្នុងបទពីរទៀតក្រៅអំពីនេះយ៉ាងនេះ ។

ដោយបទនេះសម្តែងដល់ការមិនមានលក្ខណៈ ២ ដ៏សេស ក្នុងខណៈកើត លក្ខណៈ ២ ដ៏សេសក្នុងខណៈតាំងនៅ លក្ខណៈ ២ ដ៏សេសក្នុងខណៈរលត់ ។ ម្យ៉ាងទៀត ក្នុងទីនេះ លោកពោលដល់លក្ខណៈណាមានការកើតឡើងជាដើមនៃជាតិ និងជរាមរណៈ ដោយបេយ្យាលមុខ ។ លក្ខណៈនោះរមែងខុសចាកពាក្យ របស់ន័យដែលមានភពជាទីបំផុត ដែលលះនូវជាតិ ជរានិងមរណៈ ហេតុដែលជាវិបរិណាមសូន្យ និងចាកលទ្ធិដែលមិនពោលដល់ការកើតឡើងជាដើមនៃឧប្បាទជាដើម ។ តែព្រោះធ្លាក់ទៅក្នុងក្រសែនៃលក្ខណៈ គប្បីជ្រាបថា លោករចនាធ្វើឲ្យធ្លាក់ទៅក្នុងក្រសែអត្ថ ។ ម្យ៉ាងទៀត លោកពោលទុកក្នុងអភិធម្មថា អង្គនៃឈាន សូម្បីបានក្នុងសង្គហវារៈនៃមនោធាតុនិងមនោវិញ្ញាណធាតុ ដែលជាអហេតុកវិបាកក៏ធ្លាក់ទៅក្នុងក្រសែនៃវិញ្ញាណ ៥ ព្រោះហេតុនោះ ទើបទ្រង់លើកឡើងសម្តែង យ៉ាងណា សូម្បីក្នុងទីនេះក៏គប្បីជ្រាប ភាពដែលជាលក្ខណៈធ្លាក់ទៅក្នុងក្រសែ ក៏យ៉ាងនោះ ។

ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលធ្វើការកើតឡើងជាដើមនៃសង្ខារទាំងឡាយដែលមានជាតិ ជរានិងមរណៈ ឲ្យដូចជាពាក្យថា ជាតិ ជរាមរណៈ ថាមិនទៀងជាដើម និងឲ្យដូចការកើតឡើងនៃជាតិ ជរានិងមរណៈទាំងនោះ ។

[ ១១១ ] បទថា **នេក្ខម្មេន កាមច្ឆន្ទោ វិក្ខម្ភិតោ ចេវ សុញ្ញោ ច** បានដល់ កាមច្ឆន្ទៈដែលនេក្ខម្មៈសង្កត់សង្កិនហើយ និងសូន្យទៅចាកនេក្ខម្មៈ

ពោលគឺ ការសង្កត់សង្កិននោះ ព្រោះមិនមានទេក្ខម្មៈក្នុងកាមច្ឆន្ទៈនោះ ។ សូម្បីក្នុងបទដ៏សេសទាំងឡាយ ក៏គប្បីធ្វើការប្រកបយ៉ាងនេះ ។

ម្យ៉ាងទៀត ក្នុងអធិការនេះ សូម្បីក្នុងតទង្គប្បហាន និងសមុច្ឆេទប្បហាន លោកក៏ពោលដល់ការសង្កត់សង្កិនដោយអត្ថថា ធ្វើឲ្យឆ្ងាយ ដោយពាក្យនេះថា លះដោយអំណាចតទង្គៈ និងអំណាចសមុច្ឆេទហើយ រមែងជាការធ្វើឲ្យឆ្ងាយហើយនោះឯង ។

[ ១១២ ] បទថា **នេក្ខម្មេន កាមច្ឆន្ទោ តទង្គសុញ្ញោ** បានដល់ កាមច្ឆន្ទៈ លះបានដោយនេក្ខម្មៈ សូន្យទៅដោយអង្គ គឺនេក្ខម្មៈនោះ ។ ម្យ៉ាងទៀត កាមច្ឆន្ទៈណាមួយសូន្យទៅចាកអង្គនោះ គឺនេក្ខម្មៈ ព្រោះមិនមាននេក្ខម្មៈក្នុងកាមច្ឆន្ទៈនោះ ។ សូម្បីក្នុងបទដ៏សេសក៏គប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះ ។ ម្យ៉ាងទៀត ក្នុងពាក្យនេះ លោកចង្អុលបង្ហាញភាពសូន្យចាកអង្គនោះៗ ដោយអំណាចឧបចារៈឈាន អប្បនាឈាននិងដោយអំណាចវិបស្សនាត្រឹមតែការមិនមានអង្គនោះៗ ក្នុងធម៌នោះៗ តែព្រោះមិនមានពាក្យសម្តែងដល់ការលះ ទើបលោកសម្តែងវិបស្សនាធ្វើវិវដ្តានុបស្សនាឲ្យជាចុងក្រោយ មិនសម្តែងដល់មគ្គ ៤ ។

[ ១១៣-១១៨ ] ក្នុងបទថា **នេក្ខម្មេន កាមច្ឆន្ទោ សមុច្ឆិន្នោ ចេវ សុញ្ញោ** ៩ ជាដើម គប្បីជ្រាបអត្ថក្នុងបទនេះ ដោយន័យដូចពោលហើយក្នុងវិក្ខម្ភនៈសូន្យនោះឯង ។ លោកពោលដល់សមុច្ឆេទដោយបរិយាយនេះថា នីវរណៈទាំងឡាយ សូម្បីលះហើយដោយតទង្គៈនិងវិក្ខម្ភនៈ ក៏ឈ្មោះ

ថា កាត់ផ្ដាច់ហើយព្រោះមិនមានការប្រាកដឡើងក្នុងឈាននេះ ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលដោយអំណាចឲ្យសម្រេចកិច្ច ក្នុងការកាត់ផ្ដាច់កិលេសនោះ ៗ និងដោយអំណាចនេក្ខម្មៈដែលសម្បយុត្តដោយមគ្គជាដើម ។

ម្យ៉ាងទៀត ក្នុងបដិប្បស្សទ្ធិសុញ្ញ និងនិស្សរណសុញ្ញ គប្បីជ្រាបអត្ថតាមន័យដូចពោលហើយក្នុងបទនេះនោះឯង ។ ចំណែកក្នុងទីនេះ លោកពោលកាន់យកត្រឹមតែការស្ងប់រម្ងាប់ និងត្រឹមតែការរលាស់ចេញក្នុងតទង្គប្បហាន វិក្ខម្ភនប្បហាននិងសមុច្ឆេទប្បហាន ។ ក្នុងសុញ្ញៈ ៥ ទាំងនេះ នេក្ខម្មៈជាដើម លោកពោលដោយឈ្មោះថា វិក្ខម្ភ តទង្គ សមុច្ឆេទ បដិប្បស្សទ្ធិ និងនិស្សរណ ។ បទថា **អជ្ឈត្តំ** បានដល់ មានក្នុងខាងក្នុង ។ បទថា **ពហិទ្ធា** បានដល់ មានក្នុងខាងក្រៅ ។ បទថា **ទុភតោសុញ្ញំ** បានដល់ សូន្យទាំងខាងក្នុងនិងខាងក្រៅទាំងពីរ ។ បទថា **តោ** រមែងមានប្រើសូម្បីក្នុងបច្ចត្តៈ ( បឋមាវិភត្តិ ) ជាដើម ។

[ ១១៩-១២០ ] អាយតនៈខាងក្នុង ៦ ជាដើម ជាចំណែកស្មើគ្នាដោយភាពជាអាយតនៈខាងក្នុង ៦ ជាដើម ជាចំណែកមិនស្មើគ្នាដោយអាយតនៈទាំងឡាយដទៃ ។

ម្យ៉ាងទៀត ក្នុងទីនេះ ក្នុងបទថា **វិញ្ញាណកាយា** ជាដើម លោកពោលវិញ្ញាណជាដើម ដោយពាក្យថា កាយ ( ពួក ) ។

[ ១២១-១២៤ ] ក្នុង **នេក្ខម្មេសនា** ជាដើម ឈ្មោះថា **ឯសនា** ព្រោះវិញ្ញូជនទាំងឡាយអ្នកមានសេចក្ដីត្រូវការនេក្ខម្មៈនោះ រមែងស្វែងរកនេក្ខម្មៈ

ជាដើមនោះឯង ។

ម្យ៉ាងទៀត សូមរ្បីការស្វែងរកនេក្ខម្មៈជាដើម ក្នុងចំណែកខាងដើម ក៏សូន្យទៅចាកកាមច្ឆន្ទៈជាដើម ។ បទថា នេក្ខម្មៈជាដើម មានពាក្យអធិប្បាយទុកដូចម្តេច ក្នុងបរិគ្គហៈជាដើម នេក្ខម្មៈជាដើមនោះឯងលោកពោលថា ឈ្មោះថា បរិគ្គហៈ ព្រោះអត្ថថា ស្វែងរក ក្នុងចំណែកខាងដើមហើយកំណត់យកក្នុងចំណែកខាងចុង ឈ្មោះថា បដិលាភ ព្រោះអត្ថថា កំណត់ហើយបានចំពោះដោយការសម្រេច ឈ្មោះថា បដិវេធ ព្រោះអត្ថថា បានចំពោះហើយចាក់ធ្លុះដោយអំណាចញាណ ។

[ ១២៥ ] ព្រះសារីបុត្តត្ថេរ សួរដល់ឯកត្តសុញ្ញៈ និងនានត្តសុញ្ញៈ ជាមួយគ្នាហើយ ឆ្លើយឯកត្តសុញ្ញ មិនឆ្លើយនានត្តសុញ្ញ ហើយធ្វើការសរុបតែមួយ ។ បើសួរថា ព្រោះហេតុអ្វីទើបលោកមិនឆ្លើយ ឆ្លើយថា គប្បីជ្រាបថា មិនឆ្លើយ ព្រោះលោកសម្ងឹងដល់ការប្រកបអត្ថក្នុងបទនេះដោយផ្ទុយគ្នានឹងពាក្យដែលពោលហើយ ។ ម្យ៉ាងទៀត ក្នុងបទនេះគប្បីជ្រាបការប្រកបសេចក្តីដូច្នេះថា នេក្ខម្មៈដូចគ្នា កាមច្ឆន្ទៈមានសភាពផ្សេងគ្នា កាមច្ឆន្ទៈមានសភាពផ្សេងគ្នា សូន្យចាកសភាវៈដូចគ្នា គឺនេក្ខម្មៈ ។ សូម្បីក្នុងបទដ៏សេស គប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះ ។

[ ១២៦-១២៩ ] ក្នុងបទថា **ខន្តិ** ជាដើម គប្បីជ្រាបសេចក្តី ដូចតទៅនេះថា នេក្ខម្មៈជាដើម លោកពោលថា **ខន្តិ** ព្រោះអត់ធន់ ព្រោះពេញចិត្តពោលថា អធិដ្ឋាន ព្រោះចូលទៅកាន់វត្ថុដែលខ្លួនពេញចិត្តហើយតាំងនៅ

និងពោលថា **បរិយោគាបាធ** ព្រោះចូលទៅតាំងទុក ហើយសេពតាមសេចក្ដីពេញចិត្ត ។ បរមត្ថសុញ្ញនិទ្ទេសក្នុងទីនេះមាន **៩៨ សម្បជានោ** ជាដើម លោកពោលហើយក្នុងបរិនិព្វានញាណនិទ្ទេសនោះឯង ។

ម្យ៉ាងទៀត ក្នុងសុញ្ញៈទាំងអស់នេះគប្បីជ្រាបថា សង្ខារសុញ្ញ វិបរិណាមសុញ្ញនិងលក្ខណសុញ្ញ លោកពោលដើម្បីសម្ដែងការមិនលាយច្រឡំគ្នានឹងគ្នានៃធម៌ទាំងឡាយ តាមដែលបានពោលទុកហើយ ។ ម្យ៉ាងទៀត លោកពោលដល់ការសូន្យ ចាកធម៌ចំណែកកុសលនៃធម៌ចំណែកអកុសល ក្នុងឋានៈណា លោកពោលដើម្បីសម្ដែងទោស ក្នុងអកុសលដោយឋានៈនោះ ។ ម្យ៉ាងទៀត លោកពោលដល់ការសូន្យចាកធម៌ចំណែកអកុសលនៃធម៌ចំណែកកុសលដោយឋានៈណា លោកពោលដើម្បីសម្ដែងអានិសង្សក្នុងកុសលដោយឋានៈនោះ ។ លោកពោលដល់ការសូន្យចាកខ្លួននិងចាកវត្ថុជារបស់ខ្លួនជាដើម ក្នុងឋានៈណា ឋានៈនោះ លោកពោលដើម្បីឲ្យកើតសេចក្ដីនឿយណាយក្នុងសង្ខារទាំងពួង ។ លោកពោលដល់អគ្គសុញ្ញនិងបរមត្ថសុញ្ញ ដើម្បីឲ្យកើតឧស្សាហៈក្នុងនិព្វាន ។

ក្នុងការសូន្យទាំងនោះ ការសូន្យ ២ យ៉ាង គឺអគ្គសុញ្ញៈនិងបរមត្ថសុញ្ញៈដោយអត្ថតែមួយប៉ុណ្ណោះ គឺនិព្វាន លោកពោលធ្វើឲ្យជា ២ យ៉ាង ដោយអំណាចនៃការប្រសើរ និងមានប្រយោជន៍យ៉ាងក្រៃលែង និងដោយអំណាចនៃសឧបាទិសេសនិងអនុបាទិសេស ។ ការសូន្យ ២ យ៉ាងនោះ មានចំណែកស្មើគ្នា ព្រោះសូន្យចាកខ្លួន និងសូន្យចាកវត្ថុជារបស់ខ្លួន និង

ព្រោះសូន្យចាកសង្ខារ ។ ការសូន្យទាំង ៦ យ៉ាងនេះ គឺសុញ្ញសុញ្ញ ១ អជ្ឈត្តសុញ្ញ ១ ពហិទ្ធាសុញ្ញ ១ ទុកតោសុញ្ញ ១ សភាគសុញ្ញ ១ វិសភាគសុញ្ញ ១ ជាសុញ្ញសុញ្ញៈទាំងអស់ ។ តែលោកពោលទុកជា ៦ យ៉ាង ដោយប្រភេទនៃអជ្ឈត្តសុញ្ញជាដើម ។ ម្យ៉ាងទៀត សុញ្ញទាំង ៦ យ៉ាងនោះឈ្មោះថា មានចំណែកស្មើគ្នា ព្រោះសូន្យចាកខ្លួន និងវត្ថុជារបស់ខ្លួនជាដើម ។

សុញ្ញ ១៧ យ៉ាង គឺសង្ខារសុញ្ញៈ ១ វិបរិណាមសុញ្ញៈ ១ លក្ខណ-សុញ្ញៈ ១ វិក្ខម្ភនសុញ្ញៈ ១ តទង្គសុញ្ញៈ ១ សមុច្ឆេទសុញ្ញៈ ១ បដិ-ប្បស្សទ្ធិសុញ្ញៈ ១ និស្សរណសុញ្ញៈ ១ ឯសនាសុញ្ញៈ ១ បរិគ្គហសុញ្ញៈ ១ បដិលាភសុញ្ញៈ ១ បដិវេធសុញ្ញៈ ១ ឯកត្តសុញ្ញៈ ១ នានត្តសុញ្ញៈ ១ ខន្តិសុញ្ញៈ ១ អធិដ្ឋានសុញ្ញៈ ១ បរិយោគាហនសុញ្ញៈ ១ លោកពោលទុកផ្សេងគ្នា ដោយអំណាចនៃធម៌ដែលមិនមាន ព្រោះសូន្យចាកធម៌នោះៗ ដែលមិនមានក្នុងខ្លួន ។

ម្យ៉ាងទៀត សង្ខារសុញ្ញៈ វិបរិណាមសុញ្ញៈ និងលក្ខណសុញ្ញៈ មានចំណែកស្មើគ្នា ដោយការមិនលាយឡំនឹងសុញ្ញៈដទៃៗ ។ សុញ្ញ ៥ មានវិក្ខម្ភនសុញ្ញៈជាដើម ឈ្មោះថា មានចំណែកស្មើគ្នា ព្រោះសូន្យចាកធម៌ចំណែកកុសល ។ សុញ្ញ ៤ មានឯសនាសុញ្ញៈជាដើម និងសុញ្ញៈ ៣ មានខន្តិសុញ្ញៈជាដើម ឈ្មោះថា មានចំណែកស្មើគ្នា ព្រោះសូន្យចាកធម៌ចំណែកអកុសល ឯកត្តសុញ្ញៈនិងនានត្តសុញ្ញៈ ឈ្មោះថា មានចំណែក

ស្មើគ្នាដោយអំណាចធម៌ដែលជាបដិបក្ខចំពោះគ្នានឹងគ្នា ។

បុគ្គលអ្នកដឹងអត្ថនៃការសូន្យ រមែងពណ៌នាទុកក្នុងសាសនា
នេះថា ធម៌ទាំងឡាយទាំងពួងដោយសង្ខេប ជាការសូន្យ ៣
ចំណែក ២ ចំណែកនិង ១ ចំណែក ។

លំដាប់ដំបូងធម៌ទាំងពួងដែលជាលោកិយធម៌ ឈ្មោះថា សូន្យចាកការបិតថេរ ការស្អាត សុខ និងត្តខ្លួន ព្រោះប្រាសចាកការបិតថេរ ស្អាត សុខ និងត្តខ្លួន ។ ធម៌ដែលជាមគ្គនិងផល ឈ្មោះថា សូន្យចាកការបិតថេរ សុខ និងត្តខ្លួន ព្រោះប្រាសចាកការបិតថេរ សេចក្តីសុខនិងត្តខ្លួន ។ ឈ្មោះថា សូន្យចាកសេចក្តីសុខ ព្រោះការមិនទៀងនោះឯង ។ ឈ្មោះថា សូន្យចាកការស្អាត ព្រោះមិនមានអាសវៈ ។ និព្វានធម៌ ឈ្មោះថា សូន្យចាកត្តខ្លួន ព្រោះមិនមានត្តខ្លួន ។ ចំណែកធម៌ដែលជាលោកិយនិងលោកុត្តរ សង្ខតធម៌ទាំងអស់ ឈ្មោះថា សូន្យចាកសត្វ ព្រោះមិនមានសត្វណាមួយ ។ និព្វានធម៌ ជាអសង្ខត ឈ្មោះថា សូន្យចាកសង្ខារ ព្រោះមិនមានសូម្បីសង្ខារទាំងឡាយនោះ ។ ចំណែកធម៌ទាំងអស់ ទាំងសង្ខតធម៌និងអសង្ខតធម៌ ឈ្មោះថា សូន្យចាកត្តខ្លួន ព្រោះមិនមានបុគ្គល ពោលគឺត្តខ្លួន ដោយប្រការដូច្នេះ ។

**អដ្ឋកថា សុញ្ញកថា ចប់**

**អដ្ឋកថា យុគនទ្ធវគ្គ ចប់**

**ការពណ៌នាសេចក្តីតាមលំដាប់ដែលមិនធ្លាប់វណ្ណនានៃមជ្ឈិមវគ្គ ចប់**

# សុត្តន្តបិដក

## មហាវគ្គ [១] មហាបញ្ញាកថា

[ ១៣០ ] អនិច្ចានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ទុក្ខានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច អនត្តានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច និព្វិទានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញា ដូចម្តេច វិរាគានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច និរោធានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច បដិនិស្សគ្គានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ។

អនិច្ចានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ទុក្ខានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវនិព្វេធិកបញ្ញា អនត្តានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវមហាបញ្ញា និព្វិទានុបស្សនា ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវតិក្ខបញ្ញា វិរាគានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវវិបុលបញ្ញា និ-

---

១-ច្បាប់ឆដ្ឋសង្គាយនាជា បញ្ញាវគ្គ ។ អដ្ឋកថាប្រាប់ថា ១០ វគ្គចុងក្រោយនេះឈ្មោះថា ចូឡវគ្គ ។

រោធានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវគម្ភីរប្បញ្ញា បដិនិស្សគ្គានុបស្សនាដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវអសម្បាមន្តប្បញ្ញា ។ បញ្ញាទាំង ៧ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវភាពជាបណ្ឌិត បញ្ញាទាំង ៨ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបុថុប្បញ្ញា បញ្ញាទាំង ៩ នេះដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវហាសប្បញ្ញា ។ ហាសប្បញ្ញា ជាតួបដិភាណប្បដិសម្ភិទា ( ព្រោះថា ) ហាសប្បញ្ញានោះ តែងមានអត្ថប្បដិសម្ភិទា ព្រោះការកំណត់នូវអត្ថ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា តែងមានធម្មប្បដិសម្ភិទា ព្រោះការកំណត់នូវធម៌ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា តែងមាននិរុត្តិប្បដិសម្ភិទា ព្រោះការកំណត់នូវនិរុត្តិ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា តែងមានបដិភាណប្បដិសម្ភិទា ព្រោះការកំណត់នូវបដិភាណ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា នេះឯងហាសប្បញ្ញានោះ ដែលតែងមានបដិសម្ភិទាទាំង ៤ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា ។

[ ១៣១ ] ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការមិនទៀងក្នុងរូបដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ។បេ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការលះក្នុងរូបដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការមិនទៀងក្នុងរូបដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនប្បញ្ញា ។បេ។ បាជ្ញាជាគ្រឿងពិចារណាឃើញនូវការលះក្នុងរូបដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវអស្សាមន្ត-ប្បញ្ញា ។ ប្រាជ្ញាទាំង ៧ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវភាពជាបណ្ឌិត ប្រាជ្ញាទាំង ៨ នេះដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបុថុប្បញ្ញា ប្រាជ្ញាទាំង ៩ នេះដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវហាសប្បញ្ញា ។ ហា-សប្បញ្ញា ជាតួបដិភាណប្បដិសម្ភិទា ( ព្រោះថា ) ហាសប្បញ្ញានោះតែងមានអត្ថប្បដិសម្ភិទា ព្រោះការកំណត់នូវអត្ថ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា តែងមានធម្មប្បដិសម្ភិទា ព្រោះការកំណត់នូវធម៌ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយ ដោយសារប្រាជ្ញា តែងមាននិរុត្តិប្បដិសម្ភិទា ព្រោះការកំណត់នូវនិរុត្តិ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា តែងមានបដិភាណប្បដិសម្ភិទា

ព្រោះការកំណត់នូវបដិភាណ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា នេះឯងហាសប្បញ្ញានោះ ដែលតែងមានបដិសម្ភិទាទាំង ៤ ជាធម្មជាតដែលបុគ្គលត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការមិនទៀងក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ជាធម្មជាតដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ។បេ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការលះក្នុងជរាមរណៈដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការមិនទៀង ក្នុងជរា-មរណៈ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវ-នប្បញ្ញា ។បេ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការលះ ក្នុងជរាមរណៈដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវអស្សាមន្តប្បញ្ញា ។ ប្រាជ្ញាទាំង ៧ នេះដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវភាពជាបណ្ឌិត ប្រាជ្ញាទាំង ៨ នេះ ដែលបុគ្គលបានអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបុថុប្បញ្ញា ប្រាជ្ញាទាំង ៩ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវហាសប្បញ្ញា ។ ហាសប្បញ្ញាជាតួបដិភាណប្បដិសម្ភិទា ( ព្រោះថា ) ហាសប្បញ្ញានោះតែងមានអត្ថ-ប្បដិសម្ភិទា ព្រោះការកំណត់នូវអត្ថ ជាធម្មជាតដែលបុគ្គលចាក់ធ្លុះហើយ

ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា[១] ។ តែងមានធម្មប្បដិសម្ភិទា ព្រោះការកំណត់នូវធម៌ ជាធម្មជាតដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា តែងមាននិរុត្តិប្បដិសម្ភិទា ព្រោះការកំណត់នូវនិរុត្តិ ជាធម្មជាតដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា តែងមានបដិភាណប្បដិសម្ភិទា ព្រោះការកំណត់នូវបដិភាណ ជាធម្មជាតដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា នេះឯងហាសប្បញ្ញានោះដែលតែងមានបដិសម្ភិទាទាំង ៤ ជាធម្មជាត ដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា ។

[ ១៣២ ] ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនទៀងក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនទៀងក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញា ដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាទុក្ខក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យ

---

១-ក្នុងទីនេះលោកប្រែបានត្រឹមតែ ៣ ពាក្យ គឺចាក់ធ្លុះហើយ ១ ធ្វើឲ្យជាក់ច្បាស់ហើយ ១ ពាល់ត្រូវហើយដោយសារប្រាជ្ញា ១ តែក្នុងមហាបញ្ញកថានេះ ក្នុងទីខ្លះលោកប្រែបាន ៤ ពាក្យ គឺត្រាស់ដឹងហើយ ១ ចាក់ធ្លុះហើយ ១ ធ្វើឲ្យជាក់ច្បាស់ហើយ ១ ពាល់ត្រូវហើយដោយសារប្រាជ្ញា ១ តែការប្រែ ៣ ពាក្យ ឃើញថាត្រឹមត្រូវជាង ព្រោះបាលីក៏មាន ៣ ពាក្យដែរ គឺអធិគតា ១ សច្ឆិកតា ១ ផស្សិតា ១ បណ្ឌិតគប្បីពិចារណា ។

ច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញ ថាជាទុក្ខក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនមែនខ្លួនក្នុងរូបដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនមែនខ្លួន ក្នុងរូបជាអតីត អនាគត បច្ចុប្បន្នដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណា ឃើញនូវសេចក្ដីនឿយណាយក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណា ឃើញនូវសេចក្ដីនឿយណាយក្នុងរូបជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការប្រាសចាកតម្រេកក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការប្រាសចាកតម្រេកក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវសេចក្ដីរលត់ក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណា ឃើញនូវការរលត់ក្នុងរូបជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្ដេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវ

ការលះក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការលះក្នុងរូប ជាអតីត អនាគត បច្ចុប្បន្នដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនទៀងក្នុងរូបដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនទៀងក្នុងរូបជាអតីត អនាគត បច្ចុប្បន្នដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណា ឃើញថាជាទុក្ខក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវនិព្វេធិកបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាជាទុក្ខក្នុងរូបជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនមែនខ្លួនក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវមហាបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនមែនខ្លួនក្នុងរូបជាអតីត អនាគត បច្ចុប្បន្នដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណា ឃើញនូវការនឿយណាយ ក្នុងរូបដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវតិក្ខបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណា ឃើញនូវសេចក្តីនឿយណាយក្នុងរូប ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនបញ្ញា ប្រាជ្ញាជាគ្រឿងពិចារណា ឃើញនូវការប្រាសចាកតម្រេក

ក្នុងរូប ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវវិបុ-
លប្បញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការប្រាសចាកតម្រេក ក្នុងរូប
ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ
តែងបំពេញនូវជវនប្បញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវសេចក្តីរលត់
ក្នុងរូបដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវគម្ភីរប្បញ្ញា
ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវសេចក្តីរលត់ ក្នុងរូបជាអតីត អនាគត
បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវ-
នប្បញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការលះក្នុងរូប ដែលបុគ្គលអប់រំ
ហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវអសម្ភាមន្តប្បញ្ញា ប្រាជ្ញាជាគ្រឿង
ពិចារណាឃើញនូវការលះក្នុងរូបជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គល
អប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនប្បញ្ញា ។ ប្រាជ្ញាទាំង ៧
នេះដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវភាពជាបណ្ឌិត
ប្រាជ្ញាទាំង ៨ នេះដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញ
នូវបុថុប្បញ្ញា ប្រាជ្ញាទាំង ៩ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើន
ហើយ តែងបំពេញនូវហាសប្បញ្ញា ។ ហាសប្បញ្ញា ជាតួបដិភាណប្ប-
ដិសម្ភិទា ( ព្រោះថា ) ហាសប្បញ្ញានោះ តែងមានអត្ថប្បដិសម្ភិទា ព្រោះ
ការកំណត់នូវអត្ថ ជាធម្មជាតដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់
ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា តែងមានធម្មប្បដិសម្ភិទា ព្រោះ
ការកំណត់នូវធម៌ ជាធម្មជាតដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់

ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា តែងមាននិរុត្តិប្បដិសម្ភិទា ព្រោះការកំណត់នូវនិរុត្តិ ជាធម្មជាតដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា តែងមានបដិភាណប្បដិសម្ភិទា ព្រោះការកំណត់នូវបដិភាណៈ ជាធម្មជាតដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា នេះឯងហាសប្បញ្ញា នោះដែលតែងមានបដិសម្ភិទាទាំង ៤ ជាធម្មជាតដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសារប្រាជ្ញា ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនទៀងក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ ក្នុងជរាមរណៈ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនទៀងក្នុងជរាមរណៈជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ។បេ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការលះក្នុងជរាមរណៈ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ប្រាជ្ញាជាគ្រឿងពិចារណាឃើញនូវការលះ ក្នុងជរាមរណៈជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវបញ្ញាដូចម្តេច ។ ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនទៀងក្នុងជរាមរណៈ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងបំពេញនូវជវនប្បញ្ញា ប្រាជ្ញាជាគ្រឿងពិចារណាឃើញថាមិនទៀងក្នុងជរាមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែង

បំពេញនូវជវនប្បញ្ញា ។បេ។ នេះឯងហាសប្បញ្ញានោះ ដែលតែងមានបដិ-សម្ភិទាទាំង ៤ ជាធម្មជាតដែលបុគ្គលចាក់ធ្លុះហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយសាប្រាជ្ញា ។

[ ១៣៣ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតា-បត្តិផល ធម៌ទាំង ៤ តើដូចម្តេចខ្លះ គឺការគប់រកសប្បុរស ១ ការស្តាប់ព្រះសទ្ធម្ម ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ ការប្រតិបត្តិនូវធម៌ដ៏សមគួរតាមធម៌ ១ ម្នាលភិក្ខុទាំងឡាយ នេះឯងធម៌ទាំង ៤ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ ប្រការនេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិ-ផល ។បេ។

តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។បេ។ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ធម៌ទាំង ៤ តើដូចម្តេចខ្លះ គឺការគប់រកសប្បុរស ១ ការស្តាប់ព្រះសទ្ធម្ម ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ ការប្រតិបត្តិនូវធម៌ដ៏សមគួរតាមធម៌ ១ ម្នាលភិក្ខុទាំងឡាយ នេះឯងធម៌ ៤ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។

[ ១៣៤ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីបាននូវប្រាជ្ញា ប្រព្រឹត្តទៅដើម្បីលូតលាស់ប្រាជ្ញា ប្រព្រឹត្តទៅដើម្បីភាពធំទូលាយនៃប្រាជ្ញា ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាជាធំ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏ក្រាស់ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏ទូលាយ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏ជ្រាលជ្រៅ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាមិនជិត ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដូចផែនដី ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏ច្រើន ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏ឆាប់ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏រហ័ស ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញានាំឲ្យរីករាយ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាជាគ្រឿងស្ទុះស្ទា ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏មុត ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាជាគ្រឿងទម្លុះទម្លាយនូវកិលេស ធម៌ទាំង ៤ តើដូចម្តេចខ្លះ គឺការសេពគប់សប្បុរស ១ ការស្តាប់ព្រះសទ្ធម្ម ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ ការប្រតិបត្តិនូវធម៌ដ៏សមគួរតាមធម៌ ១ ម្នាលភិក្ខុទាំងឡាយ នេះឯងធម៌ ៤ ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីបាននូវប្រាជ្ញា ប្រព្រឹត្តទៅដើម្បីលូតលាស់ប្រាជ្ញា ។បេ។ ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាជាគ្រឿងទម្លុះទម្លាយនូវកិលេស ។

[ ១៣៥ ] សំណួរត្រង់ពាក្យថា ប្រព្រឹត្តទៅដើម្បីបាននូវប្រាជ្ញា តើការបាននូវប្រាជ្ញាដូចម្តេច ។ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការចូលទៅជិតព្រមនូវមគ្គ-

ញ្ញាណ ៤ ផលញ្ញាណ ៤ បដិសម្ភិទាញាណ ៤ អភិញ្ញា ៦ ញាណ ៧៣ ញាណ ៧៧ នេះឯងការបាននូវប្រាជ្ញាក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីបាននូវប្រាជ្ញា ។

ពាក្យថា ប្រព្រឹត្តទៅដើម្បីលូតលាស់ប្រាជ្ញា តើការលូតលាស់ប្រាជ្ញាដូចម្តេច ។ ប្រាជ្ញារបស់សេក្ខបុគ្គល ៧ ពួក និងរបស់កល្យាណបុថុជ្ជនរមែងលូតលាស់ ប្រាជ្ញារបស់ព្រះអរហន្ត រមែងលូតលាស់ នេះឯងការលូតលាស់ប្រាជ្ញាក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីសេចក្តីលូតលាស់ប្រាជ្ញា ។

ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពធំទូលាយនៃប្រាជ្ញា តើភាពធំទូលាយនៃប្រាជ្ញាដូចម្តេច ។ ប្រាជ្ញារបស់សេក្ខបុគ្គល ៧ ពួក និងរបស់កល្យាណបុថុជ្ជន រមែងដល់នូវភាពធំទូលាយ ប្រាជ្ញារបស់ព្រះអរហន្តក៏ដល់ភាពធំទូលាយ នេះឯងភាពធំទូលាយនៃប្រាជ្ញាក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពធំទូលាយនៃប្រាជ្ញា ។

[ ១៣៦ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាជាធំ តើប្រាជ្ញាជាធំដូចម្តេច ។ ព្រោះប្រាជ្ញាជាធំ ព្រោះកំណត់យកនូវអត្ថជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវធម៌ជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវនិរុត្តិជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវបដិភាណជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសីលក្ខន្ធជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសមាធិក្ខន្ធជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវបញ្ញាខន្ធជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់

យកនូវវិមុត្តិក្ខន្ធជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវវិមុត្តិ-ញ្ញាណទស្សនក្ខន្ធជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវឋានា-ឋានៈជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវវិហារសមាបត្តិជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវអរិយសច្ចៈជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសតិប្បដ្ឋានជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសម្មប្បធានជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវឥទ្ធិបាទជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវឥន្ទ្រិយជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវពលៈជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវពោជ្ឈង្គជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវអរិយមគ្គជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសា-មញ្ញផលជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវអភិញ្ញា ជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវព្រះនិព្វានដែលមានអត្ថដ៏ឧត្តមជាធំ នេះឯងប្រាជ្ញាជាធំ ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាជាធំ ។

[ ១៣៧ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ក្រាស់ តើបញ្ញាដ៏ក្រាស់ដូចម្តេច ។ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងខន្ធផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងធាតុផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងអាយតនៈផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងបដិច្ចសមុប្បាទផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះ

ញាណប្រព្រឹត្តទៅក្នុងធម៌ដ៏សូន្យ និងធម៌ដែលបណ្ឌិតគប្បីបានផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងអត្ថផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងធម៌ផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងនិរុត្តិផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងបដិភាណផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងសីលក្ខន្ធផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងសមាធិក្ខន្ធផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងបញ្ញាខន្ធផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងវិមុត្តិក្ខន្ធផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងវិមុត្តិញាណទស្សនក្ខន្ធផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងហេតុ និងមិនមែនហេតុផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងវិហារសមាបត្តិផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងអរិយសច្ចផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងសតិប្បដ្ឋានផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងសម្មប្បធានផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងឥទ្ធិបាទផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងឥន្ទ្រិយផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់

ព្រោះញាណប្រព្រឹត្តទៅក្នុងពលៈផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងពោជ្ឈង្គផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងអរិយមគ្គផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងសាមញ្ញផលផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងអភិញ្ញាផ្សេងៗដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅ ក្នុងប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន កន្លងនូវធម៌ដែលទូទៅដល់បុថុជ្ជន នេះឯងបញ្ញាដ៏ក្រាស់ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ក្រាស់ ។

[ ១៣៨ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ទូលាយ តើបញ្ញាដ៏ទូលាយដូចម្តេច ។ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវអត្ថដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវធម៌ដ៏ទូ-លាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវនិរុត្តិដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវបដិភាណដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវសីលក្ខន្ធដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវសមាធិក្ខន្ធដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវបញ្ញាខន្ធដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវវិមុត្តិក្ខន្ធដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវវិមុត្តិញាណទស្សនក្ខន្ធដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវហេតុ និងមិនមែនហេតុដ៏ទូលាយ ឈ្មោះថា

បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវវិហារសមាបត្តិដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវអរិយសច្ចដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវសតិប្បដ្ឋានដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវសម្មប្បធានដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូ-លាយ ព្រោះកំណត់យកនូវឥទ្ធិបាទដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវឥន្ទ្រិយដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវពលៈដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវពោជ្ឈង្គដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវអរិយមគ្គដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវសាមញ្ញផលដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវអភិញ្ញាដ៏ទូលាយ ឈ្មោះថា បញ្ញាដ៏ទូលាយ ព្រោះកំណត់យកនូវប្រយោ-ជន៍ដ៏ក្រៃលែងគឺនិព្វានដ៏ទូលាយ នេះឯងបញ្ញាដ៏ទូលាយក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ទូលាយ ។

[ ១៣៩ ] ពាក្យថា ប្រព្រឹត្តទៅ ដើម្បីភាពនៃបញ្ញាដ៏ជ្រាលជ្រៅ តើបញ្ញាដ៏ជ្រាលជ្រៅដូចម្តេច ។ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងធាតុដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងអាយតនៈដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងបដិច្ចសមុប្បាទដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏

ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងធម៌ដ៏សូន្យ និងធម៌ គឺបណ្ឌិតគប្បីបានដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងអត្ថដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងធម៌ដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងនិរុត្តិដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រ-ព្រឹត្តទៅក្នុងបដិភាណដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងសីលក្ខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងសមាធិក្ខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងបញ្ញាខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងវិមុត្តិក្ខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងវិមុត្តិញាណទស្សនក្ខន្ធដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងហេតុ និងមិនមែនហេតុដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងវិហារសមាបត្តិដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងអរិយសច្ចដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងសតិប្បដ្ឋានដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅ ក្នុងសម្មប្បធានដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងឥទ្ធិបាទដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុង

ឥន្ទ្រិយដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងពលៈដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងពោជ្ឈង្គដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងអរិយមគ្គដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងសាមញ្ញផលដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងអភិញ្ញាដ៏ជ្រាលជ្រៅ ឈ្មោះថា បញ្ញាដ៏ជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងប្រយោជន៍ដ៏ក្រៃលែង គឺនិព្វានដ៏ជ្រាលជ្រៅ នេះឯងបញ្ញាដ៏ជ្រាលជ្រៅក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ជ្រាលជ្រៅ ។

[ ១៤០ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាមិនជិត តើបញ្ញាមិនជិតដូចម្តេច ។ បុគ្គលណាចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវហើយនូវអត្ថប្បដិសម្ភិទា ព្រោះការកំណត់នូវអត្ថដោយសារប្រាជ្ញាចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវហើយនូវធម្មប្បដិសម្ភិទា ព្រោះការកំណត់នូវធម៌ដោយសារប្រាជ្ញាចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវហើយនូវនិរុត្តិប្បដិសម្ភិទា ព្រោះការកំណត់នូវនិរុត្តិដោយសារប្រាជ្ញាចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាលត្រូវហើយនូវបដិភាណប្បដិសម្ភិទា ព្រោះការកំណត់នូវបដិភាណដោយសារប្រាជ្ញា បុគ្គលដទៃណាមួយ មិនអាចដើម្បីយល់ច្បាស់ក្នុងអត្ថផង ធម៌ផងនិរុត្តិផង បដិភាណផង របស់បុគ្គលនោះឡើយ មួយទៀត បុគ្គលដទៃនោះគេមិនគួរបំភ្លឺឲ្យយល់បានទេ ហេតុនោះឈ្មោះថា បញ្ញាមិនជិត ។ ( មែន

ពិត ) ប្រាជ្ញារបស់កល្យាណបុថុជ្ជនឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹងប្រាជ្ញារបស់អដ្ឋមកបុគ្គលឡើយ អដ្ឋមកបុគ្គល ឈ្មោះថា អ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងកល្យាណបុថុជ្ជន ឯប្រាជ្ញារបស់អដ្ឋមកបុគ្គល ឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹងប្រាជ្ញារបស់សោតាបន្នបុគ្គលឡើយ សោតាបន្នបុគ្គល ឈ្មោះថា អ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងអដ្ឋមកបុគ្គល ឯប្រាជ្ញារបស់សោតាបន្នបុគ្គល ឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹងប្រាជ្ញា របស់សកទាគាមិបុគ្គលឡើយ សកទាគាមិបុគ្គល ឈ្មោះថា អ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងសោតាបន្នបុគ្គល ឯប្រាជ្ញារបស់សកទាគាមិបុគ្គល ឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹងប្រាជ្ញា របស់អនាគាមិបុគ្គលឡើយ អនាគាមិបុគ្គល ឈ្មោះថា អ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងសកទាគាមិបុគ្គល ឯប្រាជ្ញារបស់អនាគាមិបុគ្គល ឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹងប្រាជ្ញារបស់អរហន្តឡើយ អរហន្ត ឈ្មោះថា អ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងអនាគាមិបុគ្គល ឯប្រាជ្ញារបស់អរហន្តឆ្ងាយ ឆ្ងាយកន្លង ឆ្ងាយដាច់ស្រយាល មិនជិត មិននៅក្បែរនឹងប្រាជ្ញារបស់ព្រះបច្ចេកពុទ្ធឡើយ ព្រះបច្ចេកពុទ្ធ ឈ្មោះថា អ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងព្រះអរហន្ត ចំណែកព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គប្រសើរផុត ឈ្មោះថា អ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងព្រះបច្ចេ-

កពុទ្ធផងនិងមនុស្សលោក ព្រមទាំងទេវលោកផង ទ្រង់ឈ្លាសក្នុងប្រភេទនៃប្រាជ្ញា មានញាណបែកធ្លាយហើយ ចាក់ធ្លុះនូវបដិសម្ភិទា សម្រេចនូវចតុវេសារជ្ជញ្ញាណ ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសអាសភៈ ជាបុរសសីហៈ ជាបុរសនាគៈ ជាបុរសអាជានេយ្យ ជាបុរសគួរដើម្បីនាំនូវធុរៈ មានញាណមិនមានទីបំផុត មានតេជៈមិនមានទីបំផុត មានយសមិនមានទីផុត ព្រះអង្គស្តុកស្តម្ភ មានទ្រព្យច្រើន មានជនជានច្រើន ទ្រង់ជាអ្នកណែនាំ ពន្យល់ដឹកនាំ ប្រញប្ត ពិនិត្យមើល សម្លឹងមើល ញុំាងបុគ្គលដទៃឲ្យជ្រះថ្លាព្រោះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ញុំាងមគ្គដែលមិនទាន់កើតឲ្យកើតឡើង ញុំាងមគ្គដែលមិនទាន់ដុះដាល ឲ្យដុះដាលឡើង ទ្រង់ជាអ្នកប្រាប់ផ្លូវដែលគេមិនដែលប្រាប់ ទ្រង់ជ្រាបផ្លូវ យល់ផ្លូវ ឈ្លាសក្នុងផ្លូវ ឯពួកសាវកក្នុងកាលឥឡូវនេះ គ្រាន់តែដើរទៅតាមផ្លូវ ជាអ្នកដើរទៅតាមក្រោយទេ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបហេតុដែលគួរជ្រាប ទ្រង់ឃើញហេតុដែលគួរឃើញ ទ្រង់មានចក្ខុ មានញាណ មានធម៌ ជាបុគ្គលដ៏ប្រសើរ ទ្រង់ពោល ទ្រង់បន្លឺប ទ្រង់បង្ហាញនូវប្រយោជន៍ ទ្រង់ប្រទាននូវអមតៈនិព្វាន ជាម្ចាស់ហេតុធម៌ ជាព្រះតថាគត ។ ធម្មជាតដែលព្រះមានព្រះភាគនោះមិនបានដឹង មិនបានឃើញ មិនបានជ្រាប មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានប៉ះពាល់ហើយដោយប្រាជ្ញា មិនមានឡើយ ធម៌ទាំងពួងដែលអាស្រ័យនូវហេតុជាអតីត អនាគតនិងបច្ចុប្បន្ន រមែងមកកាន់គន្លងចំមុខព្រះញាណរបស់ព្រះពុទ្ធមានជោគជោយអាការទាំងពួង ។ ធម្ម-

ជាតណាមួយឈ្មោះថា គួរដឹង ព្រោះអាស្រ័យអត្ថនិងធម៌ ដែលគេគប្បីដឹង គឺប្រយោជន៍ខ្លួន ប្រយោជន៍បុគ្គលដទៃ ឬប្រយោជន៍ទាំងពីរ ប្រយោជន៍ក្នុងបច្ចុប្បន្ន ឬប្រយោជន៍ក្នុងបរលោក ប្រយោជន៍រាក់ឬប្រយោជន៍ជ្រាលជ្រៅ ប្រយោជន៍ដែលគេលាក់ ឬប្រយោជន៍កំបាំង ប្រយោជន៍គួរណែនាំ ឬប្រយោជន៍ដែលត្រូវទូន្មាន ប្រយោជន៍ឥតទោស ប្រយោជន៍មិនមានកិលេស ប្រយោជន៍ផូរផង់ ឬប្រយោជន៍ដ៏ក្រៃលែង ធម្មជាតទាំងអស់នោះ ប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញាណ ។ កាយកម្មទាំងអស់ប្រព្រឹត្តទៅតាមញាណរបស់ព្រះពុទ្ធ វចីកម្មទាំងអស់ ប្រព្រឹត្តទៅតាមញាណរបស់ព្រះពុទ្ធ មនោកម្មទាំងអស់ ប្រព្រឹត្តទៅតាមញាណរបស់ព្រះពុទ្ធ ញាណរបស់ព្រះពុទ្ធមិនមានអ្វីរាំងក្នុងអតីតកាល ញាណរបស់ព្រះពុទ្ធមិនមានអ្វីរារាំងក្នុងអនាគតកាល ញាណរបស់ព្រះពុទ្ធមិនមានអ្វីរារាំង ក្នុងបច្ចុប្បន្នកាល ហេតុការណ៍ដែលត្រូវដឹងមានកំណត់ត្រឹមណា ញាណក៏មានកំណត់ត្រឹមនោះ ញាណមានកំណត់ត្រឹមណា ហេតុការណ៍ដែលត្រូវដឹង ក៏មានកំណត់ត្រឹមនោះ ញាណមានហេតុដែលត្រូវដឹងជាទីបំផុត ហេតុដែលត្រូវដឹងក៏មានញាណជាទីបំផុត ញាណមិនប្រព្រឹត្តកន្លងនូវហេតុ ដែលត្រូវដឹងទាំងគន្លងនៃហេតុដែលត្រូវដឹងក៏មិនកន្លងនូវញាណ ធម៌ទាំងនោះឋិតនៅក្នុងទីបំផុតនៃគ្នានឹងគ្នា បាតស្មុគទាំងពីរខាង ដែលជិតស្និទ្ធល្អ បាតស្មុគខាងក្រោមមិនប្រព្រឹត្តកន្លងបាតស្មុគខាងលើ បាតស្មុគខាងលើ មិនប្រព្រឹត្តកន្លងនូវបាតស្មុគខាងក្រោម បាតស្មុគទាំងនោះ ឋិតនៅត្រឹមទីបំផុតនៃគ្នានឹងគ្នា

យ៉ាងណាមិញ របស់ដែលត្រូវដឹងនិងញាណនៃព្រះពុទ្ធដ៏មានជោគ ឋិតនៅត្រឹមទីបំផុតនៃគ្នានឹងគ្នាក៏យ៉ាងនោះដែរ គឺរបស់ដែលត្រូវដឹងមានកំណត់ត្រឹមណា ញាណក៏មានកំណត់ត្រឹមនោះ ញាណមានកំណត់ត្រឹមណា របស់ដែលត្រូវដឹង ក៏មានកំណត់ត្រឹមនោះ ញាណមានរបស់ដែលត្រូវដឹងជាទីបំផុត របស់ដែលត្រូវដឹងក៏មានញាណជាទីបំផុត ញាណមិនប្រព្រឹត្តកន្លងនូវរបស់ដែលត្រូវដឹង គន្លងដែលត្រូវដឹងក៏មិនកន្លងនូវញាណ ធម៌ទាំងនោះឋិតនៅត្រឹមទីបំផុតនៃគ្នានឹងគ្នា ។ ញាណរបស់ព្រះពុទ្ធប្រព្រឹត្តទៅក្នុងធម៌ទាំងអស់ គឺធម៌ទាំងអស់ជាប់ចំពោះដោយការនឹក ជាប់ចំពោះដោយបំណង ជាប់ចំពោះដោយការធ្វើទុកក្នុងចិត្ត ជាប់ចំពោះដោយចិត្តុប្បាទរបស់ព្រះពុទ្ធមានជោគ ។ ញាណរបស់ព្រះពុទ្ធ ប្រព្រឹត្តទៅក្នុងសត្វទាំងអស់ គឺព្រះពុទ្ធទ្រង់ជ្រាបនូវអាសយធម៌ ជ្រាបនូវអនុសយធម៌ ជ្រាបនូវចរិយា ជ្រាបនូវអធ្យាស្រ័យរបស់ពួកសត្វទាំងអស់ ជ្រាបច្បាស់នូវពួកសត្វ ដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ខ្សោយ មានអាការល្អ មានអាការអាក្រក់ គួរឲ្យត្រាស់ដឹងបានដោយងាយ គួរឲ្យត្រាស់ដឹងបានដោយក្រ មានភ័ព្វនិងឥតភ័ព្វ ។ លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញាណ ពួកត្រីនិងអណ្តើកណាមួយ ដោយហោចទៅរាប់យកទាំងត្រីឈ្មោះតិមិតិមិង្គលៈ រមែងប្រព្រឹត្តទៅក្នុងខាងក្នុងនៃមហាសមុទ្

យ៉ាងណាមិញ លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ មនុស្សជាសម្មតិទេព និងមនុស្សដ៏សេស រមែងប្រព្រឹត្តទៅខាងក្នុងនៃពុទ្ធញាណក៏យ៉ាងនោះដែរ ពុំនោះសោត ពួកសត្វស្លាបណាមួយ ដោយទីបំផុតទៅ រាប់យកទាំងសត្វគ្រុឌ ឈ្មោះវេនតេយ្យ រមែងវិលវល់នៅក្នុងប្រទេសនៃអាកាស យ៉ាងណាមិញ ជនទាំងឡាយណា មានប្រាជ្ញាស្មើនឹងព្រះសារីបុត្ត ជនទាំងនោះរមែងប្រព្រឹត្តទៅក្នុងប្រទេសនៃពុទ្ធញាណក៏យ៉ាងនោះឯង ។ ពុទ្ធញាណផ្សាយទៅរហ័សណាស់ កន្លងបញ្ញានៃទេវតា និងមនុស្សទាំងឡាយ ពួកជនណាជាខត្តិយ-បណ្ឌិត ព្រាហ្មណបណ្ឌិត គហបតិបណ្ឌិត ឬសមណបណ្ឌិត មានប្រាជ្ញាល្អិត ស្គាល់បរប្បវាទ ដូចនាយខ្មាន់ធ្នូអ្នកបាញ់នូវរោម ពួកជនទាំងនោះប្រព្រឹត្តហាក់ដូចជាទម្លាយនូវទិដ្ឋិ ( របស់ជនដទៃ ) ដោយប្រាជ្ញា ( របស់ខ្លួន ) ពួកជនទាំងនោះឯង បានចងក្រងនូវប្រស្នា ហើយចូលទៅគាល់ព្រះតថាគត ហើយសួរនូវអាថ៌ដែលគេលាក់ផង ដែលកំបាំងផង ប្រស្នាទាំងនោះ ព្រះមានព្រះភាគបានសម្តែង ដោះស្រាយហើយផង ជាប្រស្នាមានហេតុ ដែលព្រះអង្គអធិប្បាយហើយផង ជាប្រស្នាដែលព្រះអង្គលើកបង្ហាញហើយផង ពួកជនទាំងនោះបានសម្រេច ( សម្បត្តិជាសាវកឬជាឧបាសកដោយការដោះស្រាយ ) របស់ព្រះមានព្រះភាគ លំដាប់នោះព្រះមានព្រះភាគ ទ្រង់រុងរឿងក្រៃលែងក្នុងទីនោះ ដោយប្រាជ្ញា ហេតុនោះព្រះមានជោគ ទ្រង់ប្រសើរលើស ឈ្មោះថា ទ្រង់មានបញ្ញាមិនជិត ។

នេះឯងបញ្ញាមិនជិតក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាមិនជិត ។

[ ១៤១ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដូចផែនដី តើបញ្ញាដូចផែនដីដូចម្តេច ។ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះគ្របសង្កត់នូវរាគៈ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះគ្របសង្កត់ហើយ ( នូវរាគៈ ) ឈ្មោះថា បញ្ញាដូចផែនដី ព្រោះគ្របសង្កត់នូវទោសៈ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះគ្របសង្កត់ហើយនូវទោសៈ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះគ្របសង្កត់នូវមោហៈ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះគ្របសង្កត់ហើយ ( នូវមោហៈ ) ឈ្មោះថា បញ្ញាដូចផែនដី ព្រោះគ្របសង្កត់នូវក្រោធ ។បេ។ នូវការចងគំនុំ ការលុបគុណគេ ការវាយឫកស្មើ ឫស្យា កំណាញ់ មាយា ការអួតអាង ការរឹងត្អឹង ការប្រណាំងប្រជែង ការប្រកាន់ ការមើលងាយ ការស្រវឹង ការធ្វេសប្រហែស កិលេសទាំងអស់ ទុច្ចរិតទាំងអស់ អភិសង្ខារទាំងអស់ ។បេ។ នូវភវគាមិកម្មទាំងអស់ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះគ្របសង្កត់ហើយ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះរាគៈជាសត្រូវ ប្រាជ្ញាជាគ្រឿងញាំញីនូវរាគៈជាសត្រូវនោះ ឈ្មោះថា បញ្ញាដូចផែនដីព្រោះទោសៈជាសត្រូវ ប្រាជ្ញាជាគ្រឿងញាំញីនូវទោសៈជាសត្រូវនោះ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះមោហៈជាសត្រូវ ប្រាជ្ញាជាគ្រឿងញាំញីនូវមោហៈជាសត្រូវនោះ ឈ្មោះថា បញ្ញាដូចផែនដី ព្រោះក្រោធ ។បេ។ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំង

អស់ សង្ខារទាំងអស់ ។បេ។ ភវគាមិកម្មទាំងអស់ជាសត្រូវ ប្រាជ្ញាជាគ្រឿងញាំញីនូវភវគាមិកម្មជាសត្រូវនោះ ។ ប្រឹថពី លោកហៅថា ផែនដី ឈ្មោះថា បញ្ញាដូចផែនដី ព្រោះបុគ្គលប្រកបព្រមដោយប្រាជ្ញាផ្សាយចេញទូលាយស្មើដោយផែនដីនោះ ម្យ៉ាងទៀត ពាក្យថា ផែនដីនេះ ជាឈ្មោះនៃប្រាជ្ញា ឈ្មោះថា បញ្ញាដូចផែនដី ព្រោះបញ្ញាជាគ្រឿងទម្លាយនូវកិលេសជាគ្រឿងណែនាំ ។ នេះឯងបញ្ញាដូចផែនដីក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដូចផែនដី ។

[ ១៤២ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពច្រើនដោយប្រាជ្ញា តើភាពច្រើនដោយប្រាជ្ញាដូចម្តេច ។ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកធ្ងន់ដោយប្រាជ្ញា មានប្រាជ្ញាជាចរិត មានប្រាជ្ញាជាអធ្យាស្រ័យ មានប្រាជ្ញាជាអធិមុត្តិ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការពិនិត្យ ច្រើនដោយការស្ទាបស្ទង់មើល ច្រើនដោយការរិះរមើល មានការរិះរមើលជាធម្មតា មានធម៌ជាគ្រឿងនៅប្រា-កដជាចរិត ធ្ងន់ដោយប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ឱនទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ ចុះចិត្តស៊ប់ក្នុងប្រាជ្ញានោះ មានប្រាជ្ញានោះជាអធិបតី បុគ្គលអ្នកធ្ងន់ក្នុងពួក គេហៅថាអ្នកច្រើនដោយពួក បុគ្គលអ្នកធ្ងន់ក្នុងចីវរ គេហៅថា អ្នកច្រើនដោយចីវរ បុគ្គលអ្នកធ្ងន់ក្នុងបាត្រ គេហៅថា អ្នកច្រើនដោយបាត្រ បុគ្គលអ្នកធ្ងន់ក្នុងសេ-នាសនៈ គេហៅថា អ្នកច្រើនដោយសេនាសនៈ យ៉ាងណា បុគ្គលពួកខ្លះ

ក្នុងលោកនេះ ជាអ្នកធ្ងន់ដោយប្រាជ្ញា មានប្រាជ្ញាជាចរិត មានប្រាជ្ញាជាអធ្យាស្រ័យ មានប្រាជ្ញាជាអធិមុត្តិ មានប្រាជ្ញាជាទង់ មានប្រាជ្ញាជាទង់ជ័យ មានប្រាជ្ញាជាអធិបតី ច្រើនដោយការពិចារណា ច្រើនដោយការរិះរមើល មានការរិះរមើល ជាធម្មតា មានធម៌ជាគ្រឿងនៅប្រាកដ ជាចរិតធ្ងន់ក្នុងប្រាជ្ញានោះ ច្រើនដោយប្រាជ្ញានោះ ឱនទៅរកប្រាជ្ញានោះ ទោរទៅរកប្រាជ្ញានោះ ឈមទៅរកប្រាជ្ញានោះ ចុះចិត្តស៊ប់ក្នុងប្រាជ្ញានោះ មានប្រាជ្ញានោះជាអធិបតី ក៏យ៉ាងនោះដែរ ។ នេះឯងភាពច្រើនដោយបញ្ញា ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពច្រើនដោយប្រាជ្ញា ។

[ ១៨៣ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏ធាប់ តើបញ្ញាដ៏ធាប់ដូចម្តេច ។ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងសីលឲ្យពេញលេញធាប់ ។ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងឥន្ទ្រិយសំវរៈឲ្យពេញលេញធាប់ ។ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងសេចក្តីដឹងប្រមាណក្នុងភោជនឲ្យពេញលេញធាប់ ។ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងការប្រកបរឿយៗក្នុងសេចក្តីភ្ញាក់រឭកឲ្យពេញលេញធាប់ ។ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងសីលក្ខន្ធឲ្យពេញលេញធាប់ ។ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងសមាធិក្ខន្ធឲ្យពេញលេញធាប់ ។ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងបញ្ញាខន្ធឲ្យពេញលេញធាប់ ។ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងវិមុត្តិក្ខន្ធឲ្យពេញលេញធាប់ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងវិមុត្តិញាណទស្សនក្ខន្ធឲ្យពេញលេញធាប់ ។ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះចាក់ធ្លុះនូវហេតុនិងមិន

មែនហេតុធាប់ ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងវិហារសមាបត្តិឲ្យពេញលេញធាប់ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះចាក់ធ្លុះនូវអរិយសច្ចធាប់ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងសតិប្បដ្ឋានឲ្យចម្រើនធាប់ ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងសម្មប្បធានឲ្យចម្រើនធាប់ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងឥទ្ធិបាទ ឲ្យចម្រើនធាប់ ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងឥន្ទ្រិយឲ្យចម្រើនធាប់ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងពលៈឲ្យចម្រើនធាប់ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងពោជ្ឈង្គឲ្យចម្រើនធាប់ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះញុំាងអរិយមគ្គឲ្យចម្រើនធាប់ ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផលធាប់ ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះចាក់ធ្លុះនូវអភិញ្ញាធាប់ៗ ឈ្មោះថា បញ្ញាដ៏ធាប់ ព្រោះធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍ដ៏ក្រៃលែង គឺនិព្វានធាប់ ៗ ។ នេះបញ្ញាដ៏ធាប់ ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញាដ៏ធាប់ ។

[ ១៤៤ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញារហ័ស តើបញ្ញារហ័សដូចម្តេច ។ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងសីលឲ្យពេញលេញរហ័សៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងឥន្ទ្រិយសំវរៈឲ្យពេញលេញរហ័សៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងសេចក្តីដឹងប្រមាណក្នុងភោជនឲ្យពេញលេញរហ័សៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងការប្រកបរឿយៗក្នុងសេចក្តីភ្ញាក់រឭកឲ្យពេញលេញរហ័សៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងសីលក្ខន្ធ ។បេ។ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណ-

ទស្សនក្ខន្ធឲ្យពេញលេញរហ័សៗ ឈ្មោះថា បញ្ញារហ័ស ព្រោះចាក់ធ្លុះនូវហេតុនិងមិនមែនហេតុរហ័សៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងវិហារ-សមាបត្តិឲ្យពេញលេញរហ័ស ៗ ឈ្មោះថា បញ្ញារហ័ស ព្រោះចាក់ធ្លុះនូវអរិយសច្ចរហ័ស ៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងសតិប្បដ្ឋាន ឲ្យចម្រើនរហ័ស ៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងសម្មប្បធានឲ្យចម្រើនរហ័ស ៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងឥទ្ធិបាទ ឲ្យចម្រើនរហ័សៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងឥន្ទ្រិយ ឲ្យចម្រើនរហ័សៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងពលៈឲ្យចម្រើនរហ័ស ៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងពោជ្ឈង្គឲ្យចម្រើនរហ័សៗ ឈ្មោះថា បញ្ញារហ័ស ព្រោះញុំាងអរិយមគ្គឲ្យចម្រើនរហ័សៗ ឈ្មោះថា បញ្ញារហ័ស ព្រោះធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផលរហ័ស ៗ ឈ្មោះថា បញ្ញារហ័ស ព្រោះចាក់ធ្លុះនូវអភិញ្ញារហ័ស ៗ ឈ្មោះថា បញ្ញារហ័ស ព្រោះធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វានរហ័សៗ ។ នេះឯងបញ្ញារហ័សក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃប្រាជ្ញារហ័ស ។

[ ១៤៥ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញានាំឲ្យរីករាយ តើបញ្ញានាំឲ្យរីករាយដូចម្តេច ។ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលពយកខ្លះក្នុងលោកនេះច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយសេចក្តីត្រេកអរ ច្រើនដោយសេចក្តីស្រួលចិត្ត រមែងញុំាងសីលឲ្យពេញលេញ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គល

អ្នកច្រើនដោយសេចក្ដីរីករាយ ច្រើនដោយសេចក្ដីស្រស់ស្រាយ ច្រើនដោយសេចក្ដីត្រេកអរ ច្រើនដោយសេចក្ដីស្រួលចិត្ត រមែងញុំាងឥន្ទ្រិយសំវរៈឲ្យពេញលេញ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្ដីរីករាយ ច្រើនដោយសេចក្ដីស្រស់ស្រាយ ច្រើនដោយការត្រេកអរ ច្រើនដោយការស្រួលចិត្ត រមែងញុំាងសេចក្ដីដឹងប្រមាណ ក្នុងភោជនឲ្យពេញលេញ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្ដីរីករាយ ច្រើនដោយសេចក្ដីស្រស់ស្រាយ ច្រើនដោយសេចក្ដីត្រេកអរ ច្រើនដោយសេចក្ដីស្រួលចិត្ត រមែងញុំាងសេចក្ដីប្រកបរឿយ ៗ ក្នុងសេចក្ដីភ្ញាក់រឭកឲ្យពេញលេញ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយការរីករាយ ច្រើនដោយការស្រស់ស្រាយ ច្រើនដោយការត្រេកអរ ច្រើនដោយការស្រួលចិត្ត រមែងញុំាងសីលក្ខន្ធ ។បេ។ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ឲ្យពេញលេញ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះចាក់ធ្លុះចំពោះនូវហេតុនិងមិនមែនហេតុ ព្រោះញុំាងវិហារសមាបត្តិឲ្យពេញលេញ ព្រោះចាក់ធ្លុះនូវអរិយសច្ច ព្រោះញុំាងសតិប្បដ្ឋានឲ្យចម្រើន ព្រោះញុំាងសម្មប្បធានឲ្យចម្រើន ព្រោះញុំាងឥទ្ធិបាទឲ្យចម្រើន ព្រោះញុំាងឥន្ទ្រិយឲ្យចម្រើន ព្រោះញុំាងពលៈឲ្យចម្រើន ព្រោះញុំាងពោជ្ឈង្គឲ្យចម្រើន ព្រោះញុំាងអរិយមគ្គឲ្យចម្រើន ព្រោះធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផល ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្ដីរីករាយ ច្រើនដោយសេចក្ដីស្រស់ស្រាយ ច្រើន

ដោយសេចក្តីត្រេកអរ ច្រើនដោយសេចក្តីស្រួលចិត្តរមែងចាក់ធ្លុះនូវអភិជ្ឈា ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយសេចក្តីត្រេកអរ ច្រើនដោយសេចក្តីស្រួលចិត្តរមែងធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍ដ៏ក្រៃលែង គឺនិព្វាន ។ នេះឯងបញ្ញានាំឲ្យរីករាយ ក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញានាំឲ្យរីករាយ ។

[ ១៤៦ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាជាគ្រឿងស្ទុះទៅ តើបញ្ញាជាគ្រឿងស្ទុះទៅដូចម្តេច ។ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះរូបណាមួយជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបណាក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី បញ្ញាស្ទុះទៅឆាប់ កាន់រូបទាំងអស់នោះ ថាមិនទៀង ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ ថាជាទុក្ខ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ ថាមិនមែនជារបស់ខ្លួន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះវេទនាណាមួយ ។បេ។ សញ្ញាណាមួយ សង្ខារទាំងឡាយណាមួយ វិញ្ញាណណាមួយជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណណាមួយក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី បញ្ញាស្ទុះទៅឆាប់ កាន់វិញ្ញាណទាំងអស់ ( នោះ ) ថាមិនទៀង ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ ថាជាទុក្ខ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅឆាប់ ថាមិនមែនជារបស់

ខ្លួន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅចាប់កាន់ចក្ខុ ។បេ។ កាន់ជរាមរណៈជាអតីត អនាគត បច្ចុប្បន្ន ថាមិនទៀង ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅចាប់ ថាជាទុក្ខ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅចាប់ ថាមិនមែនជារបស់ខ្លួន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថារូបជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ ឈ្មោះថា ជាទុក្ខ ដោយអត្ថថា ជាភ័យ ឈ្មោះថា ជាអនត្តា ដោយអត្ថថា គ្មានខ្លឹមហើយស្ទុះទៅចាប់ក្នុងទីជាទីរលត់រូប គឺព្រះនិព្វាន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថា វេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ ជរាមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ ឈ្មោះថា ជាទុក្ខ ដោយអត្ថថា ជាភ័យ ឈ្មោះថា អនត្តា ដោយអត្ថថា មិនមានខ្លឹមហើយស្ទុះទៅចាប់ក្នុងទីជាទីរលត់នូវជរាមរណៈ គឺព្រះនិព្វាន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថារូបជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង មានបច្ច័យតាក់តែង អាស្រ័យនូវបច្ច័យហើយកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រាសចាករាគៈជាធម្មតា មានការរលត់ជាធម្មតា ហើយស្ទុះទៅចាប់ក្នុងទីជាទីរលត់រូប គឺព្រះនិព្វាន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថា វេទនា សញ្ញា សង្ខារ

វិញ្ញាណ ចក្ខុ ។បេ។ ជរាមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង មានបច្ច័យប្រជុំតាក់តែង អាស្រ័យនូវបច្ច័យហើយកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រាសចាករាគៈជាធម្មតា មានការរលត់ជាធម្មតា ហើយស្ទុះទៅចាប់ក្នុងទីជាទីរលត់ ជរាមរណៈ គឺព្រះនិព្វាន នេះឯងបញ្ញាជាគ្រឿងស្ទុះទៅក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាជាគ្រឿងស្ទុះទៅ ។

[ ១៤៧ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏មុត តើបញ្ញាដ៏មុតដូចម្តេច ។ ឈ្មោះថា បញ្ញាដ៏មុត ព្រោះទម្លាយនូវកិលេសរហ័ស ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវកាមវិតក្កៈដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវព្យាបាទវិតក្កៈដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួលនូវវិហិង្សាវិតក្កៈដែលកើតឡើងហើយ ។បេ។ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវរាគៈដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវទោសៈដែលកើតឡើងហើយ ។បេ។ នូវមោហៈដែលកើតឡើងហើយ នូវសេចក្តីក្រោធដែលកើតឡើងហើយ នូវ

ការបង់សេចក្តីក្រោធទុក ការលុបគុណគេ ការវាយឫកស្មើ ឫស្យា ការកំណាញ់ ការលាក់ពុត ការអួតអាង ការរឹងត្អឹង ការប្រណាំងប្រជែង ការប្រកាន់ ការមើលងាយ ការស្រវឹង ការប្រហែសធ្វេស កិលេសទាំងអស់ ទុច្ចរិតទាំងអស់ អភិសង្ខារទាំងអស់ ។បេ។ ភវគាមិកម្មទាំងអស់ ដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះអរិយមគ្គ ៤ សាមញ្ញផល ៤ បដិសម្ភិទា ៤ និងអភិញ្ញា ៦ ជាគុណជាតិដែលបុគ្គលចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវហើយដោយប្រាជ្ញាក្នុងអាសនៈ ១ នេះឯងបញ្ញាដ៏មុតក្នុងពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាដ៏មុត ។

[ ១៤៨ ] ពាក្យថា ប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាជាគ្រឿងទម្លុះទម្លាយ តើបញ្ញា ជាគ្រឿងទម្លុះទម្លាយដូចម្តេច ។ ឈ្មោះថា បញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះបុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកច្រើនដោយសេចក្តីរន្ធត់ ច្រើនដោយសេចក្តីតក់ស្លុត ច្រើនដោយសេចក្តីអផ្សុក ច្រើនដោយសេចក្តីមិនត្រេកអរ ច្រើនដោយសេចក្តីនឿយណាយក្នុងសង្ខារទាំងពួង មានមុខងាកចេញក្រៅ មិនត្រេកអរក្នុងសង្ខារទាំងពួង រមែងទម្លុះទម្លាយនូវគំនរលោភៈដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ ឈ្មោះថា បញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះទម្លុះទម្លាយនូវគំនរទោសៈ ដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ ឈ្មោះថា បញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះទម្លុះទម្លាយនូវគំនរមោហៈដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ ឈ្មោះថាបញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះទម្លុះទម្លាយនូវក្រោធ ។បេ។ នូវការ

ចងក្រោធទុក ការលុបគុណគេ ការវាយឫកស្មើ ឫស្យា កំណាញ់ ការលាក់ពុត ការអួតអាង ការរឹងត្អឹង ការប្រណាំងប្រជែង ការប្រកាន់ ការមើលងាយ ការស្រវឹង ការប្រហែសធ្វេស កិលេសទាំងអស់ ទុច្ចរិតទាំងអស់ អភិសង្ខារទាំងអស់ ។បេ។ ភវគាមិកម្មទាំងអស់ ដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ នេះបញ្ញាជាគ្រឿងទម្លុះទម្លាយក្នុងពាក្យថាប្រព្រឹត្តទៅដើម្បីភាពនៃបញ្ញាជាគ្រឿងទម្លុះទម្លាយ នេះបញ្ញា ១៦ ។

[ ១៤៩ ] បុគ្គលប្រកបដោយប្រាជ្ញាទាំង ១៦ នេះ ឈ្មោះថា អ្នកដល់នូវបដិសម្ភិទា ។ បុគ្គលអ្នកដល់នូវបដិសម្ភិទាមាន ២ ពួក គឺពួកមួយបរិបូរណ៍ដោយបុព្វយោគ ( ការប្រកបក្នុងកាលមុន ) ពួកមួយមិនបរិបូរណ៍ដោយបុព្វយោគ បុគ្គលណាបរិបូរណ៍ដោយបុព្វយោគ បុគ្គលនោះជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេសជាងបុគ្គលមួយពួកនោះ ញាណរបស់បុគ្គលនោះបែកធ្លាយជាង នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក ។ ឯបុគ្គលអ្នកបរិបូរណ៍ដោយបុព្វយោគ មាន ២ ពួក គឺបុគ្គលពួកមួយជាពហុស្សូត ពួកមួយមិនមែនជាពហុស្សូត បុគ្គលណាជាពហុ-ស្សូត បុគ្គលនោះជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេសជាងបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះបែកធ្លាយជាង នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលអ្នកបរិបូរណ៍ដោយបុព្វយោគពីរពួក ។ ឯបុគ្គលជាពហុស្សូត មាន ២ ពួក គឺបុគ្គលពួកមួយ ជាអ្នកច្រើនដោយទេសនា ពួកមួយជាអ្នកមិនច្រើនដោយទេសនា បុគ្គលណាច្រើនដោយ

ទេសនា បុគ្គលនោះ ជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេស ជាងបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះបែកធ្លាយជាង នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលអ្នកបរិបូណ៌ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សូតពីរពួក ។ ឯបុគ្គលអ្នកច្រើនដោយទេសនា មាន ២ ពួក គឺបុគ្គលពួកមួយ ជាអ្នកចូលទៅអាស្រ័យនឹងគ្រូ ពួកមួយជាអ្នកមិនចូលទៅអាស្រ័យនឹងគ្រូ បុគ្គលណាដែលចូលទៅអាស្រ័យនឹងគ្រូ បុគ្គលនោះជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេសជាងបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង នេះបុគ្គលអ្នកដល់នូវបដិ-សម្ភិទាពីរពួក អ្នកបរិបូណ៌ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សូតពីរពួក បុគ្គលអ្នកច្រើនដោយទេសនាពីរពួក ។ ឯបុគ្គលអ្នកចូលទៅអាស្រ័យនឹងគ្រូក៏មាន ២ ពួក គឺបុគ្គលពួកមួយជាអ្នកច្រើនដោយវិហារធម៌ ពួកមួយជាអ្នកមិនច្រើនដោយវិហារធម៌ បុគ្គលណាដែលច្រើនដោយវិហារធម៌ បុគ្គលនោះជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេសជាង បុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលអ្នកបរិបូណ៌ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សូតពីរពួក បុគ្គលអ្នកច្រើនដោយទេសនាពីរពួក បុគ្គលអ្នកចូលទៅអាស្រ័យនឹងគ្រូពីរពួក ។ ឯបុគ្គលអ្នកច្រើនដោយវិហារធម៌ក៏មាន ២ ពួក គឺពួកមួយ ជាអ្នកច្រើនដោយការពិចារណា ពួកមួយជាអ្នកមិនច្រើនដោយការពិចារណា បុគ្គលណាច្រើនដោយការពិចារណា បុគ្គលនោះជាអ្នកលើស

លុប ជាអ្នកក្រៃលែង ជាអ្នកវិសេសជាងបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះបែកធ្លាយជាង នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលអ្នកបរិបូណ៌ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សុតពីរពួក បុគ្គលអ្នកច្រើនដោយទេសនាពីរពួក បុគ្គលចូលទៅអាស្រ័យទីងគ្រូពីរពួក បុគ្គលច្រើនដោយវិហារធម៌ពីរពួក ។ ឯបុគ្គលច្រើនដោយការពិចារណាក៏មាន ២ ពួក គឺពួកមួយជាអ្នកដល់នូវសេក្ខប្បដិសម្ភិទា ពួកមួយជាអ្នកដល់នូវអសេក្ខប្បដិសម្ភិទា បុគ្គលណាដែលដល់នូវអសេក្ខប្បដិសម្ភិទា បុគ្គលនោះជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេសជាងបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលបរិបូណ៌ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សុតពីរពួក បុគ្គលអ្នកច្រើនដោយទេសនាពីរពួក បុគ្គលអ្នកចូលទៅអាស្រ័យទីងគ្រូពីរពួក បុគ្គលអ្នកច្រើនដោយវិហារធម៌ពីរពួក បុគ្គលអ្នកច្រើនដោយការពិចារណាពីរពួក ។ ឯបុគ្គលដែលដល់នូវអសេក្ខប្បដិសម្ភិទា មាន ២ ពួក គឺពួកមួយដល់នូវសាវកបារមី ពួកមួយមិនដល់នូវសាវកបារមី បុគ្គលណាដល់នូវសាវកបារមី បុគ្គលនោះជាអ្នកលើសលុប ជាអ្នកក្រៃលែង ជាអ្នកវិសេសជាងបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះ បែកធ្លាយជាង

នេះបុគ្គលអ្នកដល់នូវបដិសម្ភិទាពីរពួក បុគ្គលអ្នកបរិបូណ៌ដោយបុព្វយោគពីរពួក បុគ្គលជាពហុស្សូតពីរពួក បុគ្គលអ្នកច្រើនដោយទេសនាពីរពួក បុគ្គលអ្នកចូលទៅអាស្រ័យនឹងគ្រូពីរពួក បុគ្គលអ្នកច្រើនដោយវិហារធម៌ពីរពួក បុគ្គលអ្នកច្រើនដោយការពិចារណាពីរពួក ឯបុគ្គលអ្នកដល់នូវអសេក្ខប្បដិសម្ភិទា មានពីរពួក គឺពួកមួយជាអ្នកដល់នូវសាវកបារមី ពួកមួយជាបច្ចេកសម្ពុទ្ធ បុគ្គលណាជាបច្ចេកសម្ពុទ្ធ បុគ្គលនោះជាអ្នកលើសលុបជាអ្នកក្រៃលែង ជាអ្នកវិសេសជាងបុគ្គលពួកមួយនោះ ញាណរបស់បុគ្គលនោះបែកធ្លាយជាង ហេតុនោះ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ប្រៀបធៀបនឹងព្រះបច្ចេកពុទ្ធផងនិងមនុស្សលោក ព្រមទាំងទេវលោកផង ព្រះអង្គជាបុគ្គលប្រសើរ ដល់នូវបដិសម្ភិទា ឈ្លាសក្នុងប្រភេទនៃប្រាជ្ញា មានព្រះញាណបែកធ្លាយហើយ បានសម្រេចនូវបដិសម្ភិទា ដល់នូវចតុវេសារជ្ជញ្ញាណ ទ្រទ្រង់នូវកម្លាំង ១០ ជាបុរសអាសភៈ ជាបុរសសីហៈ ។បេ។ ពួកជនណាជាខត្តិយបណ្ឌិត ជាព្រាហ្មណបណ្ឌិត ជាគហបតិបណ្ឌិត ជាសមណបណ្ឌិតដែលមានប្រាជ្ញាល្អិត ស្គាល់បរប្បវាទ មានសភាពដូចនាយខ្មាន់ធ្នូអ្នកបាញ់នូវរោម ពួកជនទាំងនោះ ហាក់ដូចជាទម្លាយនូវទិដ្ឋិ ( របស់ជនដទៃ ) ដោយប្រាជ្ញា ( របស់ខ្លួន ) ពួកជនទាំងនោះ បានចងក្រងនូវ

ប្រស្នាហើយចូលទៅគាល់ព្រះតថាគត ហើយសួរនូវអាថ៌ដែលគេលាក់ផង ដែលកំបាំងផង ប្រស្នាទាំងនោះ ព្រះតថាគតក៏បានសម្តែងដោះស្រាយហើយផង ជាប្រស្នាមានហេតុ ដែលព្រះអង្គអធិប្បាយហើយផង ជាប្រស្នាដែលព្រះអង្គលើកបង្ហាញហើយផង ពួកជនទាំងនោះ បានសម្រេច ( សម្បត្តិជាសាវកឬជាឧបាសកដោយការដោះស្រាយ ) របស់ព្រះមានព្រះភាគ លំដាប់នោះព្រះមានព្រះភាគ ទ្រង់រុងរឿងក្រៃលែងក្នុងទីនោះ ដោយប្រាជ្ញា ហេតុនោះព្រះមានព្រះភាគ ព្រះអង្គប្រសើរ ទ្រង់ដល់នូវបដិសម្ភិទា ។

ចប់ មហាបញ្ញាកថា ។

# បញ្ញាវគ្គ

## អដ្ឋកថា មហាបញ្ញាកថា

[ ១៣០ ] ឥឡូវនេះ ជាការពណ៌នាសេចក្ដីតាមលំដាប់ ដែលនៅមិនទាន់បានពណ៌នាក្នុងបញ្ញាកថា ដែលព្រះសារីបុត្តត្ថេរពោលទុក បន្ទាប់អំពីសុញ្ញកថា ដែលជាបទដ្ឋាននៃបញ្ញាដោយពិសេស ។

ខាងដើមក្នុងបញ្ញាកថានោះ បញ្ញា ៧ មានអនុបស្សនានីមួយៗ ក្នុងអនុបស្សនា ៧ ជាមូល ព្រះសារីបុត្តត្ថេរសម្ដែងធ្វើពាក្យសួរឲ្យជាខាងដើមមុន ។ បញ្ញា ៣ មានអនុបស្សនា ៧ ជាមូល និងមានបញ្ញាបន្ថែមឡើងម្យ៉ាងមួយៗជាមូលដែលព្រះសារីបុត្តត្ថេរសម្ដែងឡើង ដោយមិនធ្វើពាក្យសួរ លោកសម្ដែងភាពបរិបូរនៃបញ្ញា ១០ អំពីខាងដើមដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអនុបស្សនាទាំងនោះ ដូចតទៅនេះថា ព្រោះអនិច្ចានុបស្សនា ( ការពិចារណាឃើញថាមិនទៀង ) ស្ទុះទៅក្នុងសង្ខារដែលឃើញហើយ ថាមិនទៀង ដោយភាពជាទុក្ខ ថារបស់ណាមិនទៀង របស់នោះជាទុក្ខនិងដោយភាពជាអនត្តា ថារបស់ណាជាទុក្ខ របស់នោះជាអនត្តា ហេតុនោះអនិច្ចានុបស្សនានោះ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងញុំាងជវនបញ្ញា ( ប្រាជ្ញាជាគ្រឿងស្ទុះទៅ ) ឲ្យបរិបូរណ៍ ។ ពិតណាស់ បញ្ញានោះឈ្មោះថា **ជវន** ព្រោះស្ទុះទៅក្នុងវិស័យរបស់ខ្លួន ឈ្មោះថា **ជវនបញ្ញា** ព្រោះបញ្ញានោះស្ទុះទៅ ។

ទុក្ខានុបស្សនា ( ការពិចារណាឃើញជាទុក្ខ ) មានកម្លាំង ព្រោះ

អាស្រ័យសមាធិន្ទ្រិយ រមែងជ្រែក រមែងទម្លាយបណិធិ ព្រោះហេតុនោះ ទុក្ខានុបស្សនា រមែងញុំាងនិព្វេធិកប្បញ្ញា ( ប្រាជ្ញាជាគ្រឿងទម្លុះទម្លាយ ) ឲ្យបរិបូរណ៍ ។ ពិតណាស់ បញ្ញានោះ ឈ្មោះថា **និព្វេធិកា** ព្រោះទម្លាយកិលេស ឈ្មោះថា **និព្វេធិកប្បញ្ញា** ព្រោះបញ្ញានោះ ទម្លាយកិលេស ។

អនត្តានុបស្សនា ( ការពិចារណាឃើញថា ជាអនត្តា ) រមែងញុំាងមហាបញ្ញាឲ្យបរិបូរណ៍ ព្រោះការដល់នូវភាពចម្រើន ដោយការឃើញជារបស់សូន្យ ជាការដល់នូវភាពជាធំ ។ ពិតណាស់ បញ្ញានោះ ឈ្មោះថា **មហាបញ្ញា** ព្រោះបញ្ញានោះដល់នូវការចម្រើន ។

ព្រោះនិព្វិទានុបស្សនា ( ការពិចារណាឃើញការនឿយណាយ ) អាចនឿយណាយក្នុងសង្ខារទាំងពួង ព្រោះអនុបស្សនា ៣ នោះឯង ជាទីតាំងនៃការមានកម្លាំងដោយអាសេវនៈសូម្បីពីមុនទើបជាបញ្ញាមុតថ្លា ហេតុនោះ និព្វិទានុបស្សនា រមែងញុំាងតិក្ខប្បញ្ញា ( ប្រាជ្ញាដ៏មុត ) ឲ្យបរិបូរណ៍ ។

ព្រោះវិរាគានុបស្សនា ( ការពិចារឃើញនូវការប្រាសចាកតម្រេក ) អាចប្រាសចាកតម្រេកពីសង្ខារទាំងពួង ព្រោះអនុបស្សនា ៣ នោះឯង ជាទីតាំងដែលចម្រើនជាងការមានកម្លាំងដោយអាសេវនៈ សូម្បីអំពីមុន ទើបជាប្រាជ្ញាដ៏ទូលាយ ហេតុនោះ វិរាគានុបស្សនា រមែងញុំាង វិបុលប្បញ្ញា ( ប្រាជ្ញាដ៏ទូលាយ ) ឲ្យបរិបូរណ៍ ។

ព្រោះនិរោធានុបស្សនា ( ការពិចារណាឃើញការរលត់ ) អាចឃើញការរលត់សង្ខារទាំងពួង ដោយលក្ខណៈនៃការសូន្យទៅ ព្រោះអនុបស្សនា

៣ នោះឯងជាទីតាំងដែលចម្រើនជាងការមានកម្លាំងដោយអាសេវនៈ សូម្បីអំពីមុនទើបជាប្រាជ្ញាដ៏ជ្រាលជ្រៅ ហេតុនោះនិព្វេធានុបស្សនា រមែងញ៉ាំងគម្ភីរបញ្ញា ( ប្រាជ្ញាដ៏ជ្រាលជ្រៅ ) ឲ្យបរិបូរណ៍ ។ ពិតណាស់ **និព្វេធ** ឈ្មោះថា ជ្រាលជ្រៅ ព្រោះជាទីតាំងដែលបុគ្គលមិនគប្បីបានដោយប្រាជ្ញាដែលរាក់ សូម្បីបញ្ញាដែលដល់នូវការឈមចុះក្នុងភាពជ្រាលជ្រៅនោះ ក៏ឈ្មោះថា ជ្រាលជ្រៅ ។

ព្រោះបដិនិស្សគ្គានុបស្សនា ( ការពិចារណាឃើញការលះបង់ ) អាចលះបង់សង្ខារទាំងពួង ដោយលក្ខណៈនៃការសូន្យ ព្រោះអនុបស្សនា ៣ នោះឯង ជាទីតាំងដែលចម្រើនជាងការមានកម្លាំងដោយអាសេវនៈ សូម្បីអំពីមុន ទើបជាប្រាជ្ញាមិនជិត អធិប្បាយថា រមែងនៅឆ្ងាយជាងបញ្ញា ៦ ព្រោះដល់នូវទីបំផុតនៃការដឹងហើយ ហេតុនោះ បដិនិស្សគ្គានុបស្សនា រមែងញ៉ាំង អសាមន្តប្បញ្ញា ( ប្រាជ្ញាមិនជិត ) ឲ្យបរិបូរណ៍ ព្រោះមិនជិតនោះឯង ។ ពិតណាស់ អសាមន្តប្បញ្ញានោះ ឈ្មោះថា **អសាមន្ត** ព្រោះឆ្ងាយចាកបញ្ញាខាងក្រោម ម្យ៉ាងទៀត ឈ្មោះថា **អសាមន្តប្បបញ្ញា** ព្រោះជាបញ្ញាមិនជិត ។

បទថា **បណ្ឌិច្ចំ បរិបូរេន្តិ** បានដល់ រមែងញ៉ាំងភាពជាអ្នកឈ្លាសឲ្យបរិបូរណ៍ ។ ព្រោះអ្នកចម្រើនបញ្ញា ៧ តាមដែលពោលហើយ ឲ្យបរិ-បូរណ៍ហើយដល់លក្ខណៈរបស់បណ្ឌិត ជាបណ្ឌិតដោយសង្ខារុបេក្ខាញាណ អនុលោមញ្ញាណ និងគោត្រភូញាណ ពោលគឺវុដ្ឋានគាមិនីវិបស្សនា ដែល

ដល់កំពូល ជាអ្នកប្រកបដោយភាវៈជាបណ្ឌិត ហេតុនោះទើបលោកពោលថា តែងបំពេញនូវភាពជាបណ្ឌិត ។

បទថា **អដ្ឋ បញ្ញា** បានដល់ បញ្ញា ៨ ប្រការ មួយអន្លើដោយបញ្ញាគឺភាពជាបណ្ឌិត ។ បទថា **បុថុប្បញ្ញំ បរិបូរេន្តិ** សេចក្តីថា ព្រោះបណ្ឌិតនោះជាអ្នកប្រកបដោយភាពជាបណ្ឌិតនោះ ធ្វើនិព្វានឲ្យជាអារម្មណ៍ បន្ទាប់អំពីគោត្រភូញាណ រមែងសម្រេចបញ្ញា គឺមគ្គផលដែលពោលថាបុថុប្បញ្ញា ព្រោះកាលសម្រេចភាពជាលោកុត្តរៈក្រាស់ជាងលោកិយៈ ព្រោះញែកចេញអំពីលោកិយៈ ហេតុនោះ ទើបលោកពោលថា បញ្ញា ៨ តែងបំពេញនូវបុថុប្បញ្ញា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឥមា ឆវ បញ្ញា** ជាដើម ដូចតទៅនេះថា បច្ចវេក្ខណៈ ៥ រមែងប្រព្រឹត្តទៅដល់ព្រះអរិយបុគ្គលនោះ ដែលសម្រេចមគ្គនិងផលហើយតាមលំដាប់ គឺការពិចារណាមគ្គ របស់ព្រះអរិយបុគ្គលដែលមានចិត្តសន្តានប្រព្រឹត្តទៅដោយការប្រកបលោកុត្តរធម៌ដ៏ប្រណីត និងដោយការរីករាយព្រោះមានចិត្តសន្តានប្រណីត ហើយចេញចាកភវគ្គដែលឈមចុះក្នុងលំដាប់នៃផល ការពិចារណាផលរបស់ព្រះអរិយបុគ្គល ដែលឈមចុះកាន់ភវគ្គហើយចេញចាកភវគ្គនោះ ។ ការពិចារណាកិលេសដែលបានលះហើយ ការពិចារណាកិលេសដែលនៅសេសសល់ ការពិចារណានិព្វាន ក៏ដោយន័យនេះឯង ។ ក្នុងការពិចារណាទាំងនោះការពិចារណាមគ្គនិងការពិចារណាផល ជាបដិភាណប្បដិសម្ភិទា ។

សេចក្តីនេះដូចម្តេច លោកអនុលោមតាមបាលីក្នុងអភិធម្មហើយពោលទុកក្នុងអដ្ឋកថានោះថា ធម៌ ៥ ប្រការនេះ គឺធម៌ដែលកើតព្រោះបច្ច័យឯណានីមួយ ១ និព្វាន ១ អត្ថនៃភាសិត ១ វិបាក ១ កិរិយា ១ ឈ្មោះថា អត្ថ ។ ព្រោះព្រះនិព្វានជាអត្ថ មគ្គញាណនិងផលញាណដែលមាននិព្វាននោះជាអារម្មណ៍ទើបជាអត្ថប្បដិសម្ភិទា ព្រោះព្រះតម្រាស់ថា សេចក្តីដឹងក្នុងអត្ថទាំងឡាយ លោកហៅថា អត្ថប្បដិសម្ភិទា ដូច្នេះ ។ បច្ចវេក្ខណញ្ញាណនៃមគ្គញ្ញាណនិងផលញ្ញាណ ដែលជាអត្ថប្បដិសម្ភិទានោះ ជាបដិភាណប្បដិសម្ភិទា ព្រោះព្រះតម្រាស់ថា សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា បដិភាណប្បដិសម្ភិទា ដូច្នេះ ។ បច្ចវេក្ខណញ្ញាណនោះឈ្មោះថា **ហាសបញ្ញា** ( ប្រាជ្ញានាំឲ្យរីករាយ ) នៃចិត្តសន្តានដែលប្រព្រឹត្តទៅដោយអាការរីករាយ ព្រោះហេតុនោះទើបលោកពោលថា បញ្ញាទាំង ៩ នេះ តែងបំពេញនូវហាសបញ្ញា និងពោលថា ហាសបញ្ញាជាតួបដិភាណប្បដិសម្ភិទា ។ បញ្ញាសូម្បីមានប្រការទាំងពួង ឈ្មោះថាបញ្ញា ព្រោះអត្ថថា ឲ្យដឹង ពោលគឺធ្វើអត្ថនោះៗឲ្យប្រាកដ ឈ្មោះថា បញ្ញាព្រោះដឹងធម៌ទាំងឡាយដោយប្រការនោះៗ ។

បទថា **តស្ស** បានដល់ ដែលព្រះអរិយបុគ្គលមានប្រការដូចពោលហើយនោះ ។ បទនោះជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ បទថា **អត្ថវវត្ថានតោ** បានដល់ ដោយការកំណត់អត្ថ ៥ យ៉ាងតាមដែលពោលហើយ ។ ម្យ៉ាងទៀត លោកពោលពាក្យនេះទុកក្នុងសមណករណិយកថា

ថា ញាណដែលមានប្រភេទជាទីបំផុតដំបូងក្នុង ៥ ប្រភេទ ក្នុងអត្ថ គឺហេតុផល ១ និព្វាន ១ អត្ថនៃពាក្យ ១ តមកជាវិបាក ១ កិរិយា ១ ។

បទថា **អធិគតា ហោតិ** បានដល់ បានហើយ ។ បដិសម្ភិទានោះឯង ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ហើយដោយការធ្វើឲ្យជាក់ច្បាស់នូវការបានចំពោះត្រឹមត្រូវហើយដោយបញ្ញា ដោយផស្សៈដែលបានចំពោះនោះឯង ។ បទថា **ធម្មវវត្ថានតោ** បានដល់ ដោយការកំណត់ធម៌ ៥ យ៉ាង ដែលលោកពោលដោយទំនងនៃបាលីក្នុងអភិធម្មថា ធម៌ ៥ យ៉ាងទាំងនេះ គឺហេតុដែលញ៉ាំងផលឲ្យកើត ឯណាមួយ ១ អរិយមគ្គ ១ ភាសិត ១ កុសល ១ អកុសល ១ ឈ្មោះថា ធម៌ ។ សូម្បីបទនេះលោកក៏ពោលទុកក្នុងសមណករណិយកថាថា ញាណដែលមានប្រភេទជាទីបំផុត បែបទី ២ ក្នុង ៥ ប្រភេទ ក្នុងធម៌ គឺហេតុ ១ អរិយមគ្គ ១ ពាក្យនិយាយ ១ កុសល ១ អកុសល ១ ។

បទថា **និរុត្តិវវត្ថានតោ** បានដល់ ដោយការកំណត់និរុត្តិដែលសមគួរដល់អត្ថនិងធម៌នោះៗ ។ បទថា **បដិភាណវវត្ថានតោ** បានដល់ ដោយការកំណត់បដិសម្ភិទាញាណ ៣ ដែលបានដល់បដិភាណ ។ បទថា **តស្មិំ** នេះជាពាក្យសរុប ។

[ ១៣១-១៣២ ] ព្រះសារីបុត្តត្ថេរ កាលសម្តែងគុណវិសេសរបស់អនុបស្សនាទាំងឡាយ ដោយការសង្គ្រោះចូលជាមួយគ្នាទាំងអស់យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងដោយប្រភេទនៃវត្ថុ ទើបពោលពាក្យថា

រូប **អនិច្ចានុបស្សនា** ជាដើម ។ បទនោះមានអត្ថដូចបានពោលហើយនោះឯង ។

ព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងជវនប្បញ្ញា ដោយអំណាចនៃអតីតអនាគតនិងបច្ចុប្បន្នក្នុងរូបជាដើមទៀត ទើបផ្តើមពាក្យសួរដោយអំណាចរូបជាដើមតែម្យ៉ាង និងដោយអំណាចរូបក្នុងអតីត អនាគតនិងបច្ចុប្បន្ន ហើយបានធ្វើការឆ្លើយទៅតាមលំដាប់របស់ពាក្យសួរ ។ ក្នុងការឆ្លើយនោះ បញ្ញាដែលលោកសម្តែងទុកមុន ក្នុងការឆ្លើយរូបសុទ្ធ ៗ ជាដើមនោះឯង លោកសម្តែងថា ជាជវនប្បញ្ញាដោយអំណាចនៃការស្ទុះទៅ ក្នុងអតីតជាដើមនោះក្នុងការឆ្លើយទាំងអស់ដែលមានរូបក្នុងអតីត អនាគត និងបច្ចុប្បន្នជាមូល ។

ព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងប្រភេទនៃបញ្ញាដែលមានព្រះសូត្រមិនតិចជាបទនាំទៀត ទើបសម្តែងព្រះសូត្រទាំងឡាយជាលំដាប់ដំបូងមុន ។

[ ១៣៣ ] ក្នុងបទទាំងនោះ បទថា **សប្បុរិសសំសេវោ** បានដល់ ការសេពគប់សប្បុរសទាំងឡាយ មានប្រការដូចបានពោលហើយ ។ បទថា **សទ្ធម្មស្សវនំ** បានដល់ ការស្តាប់ពាក្យទូន្មាន ដែលសម្តែងពីការបដិបត្តិមានសីលជាដើមក្នុងសម្នាក់របស់សប្បុរសនោះ ។ បទថា **យោនិសោមនសិការោ** បានដល់ ការធ្វើទុកក្នុងចិត្តដោយឧបាយ ដោយការពិចារណាអត្ថនៃធម៌ដែលបានស្តាប់ហើយ ។ បទថា **ធម្មានុធម្មប្បដិបត្តិ** បានដល់ការបដិបត្តិធម៌ដែលជាបដិបទា មានសីលជាដើមដែលប្រាថ្នាលោកុត្តរធម៌ ។

[ ១៣៤ ] បទទាំង ៤ នេះគឺ **បញ្ញាបដិលាភាយ** ( ដើម្បីបានទូវ

ប្រាជ្ញា ) ១ **បញ្ញាវុឌ្ឍិយា** ( ដើម្បីលូតលាស់ប្រាជ្ញា ) ១ **បញ្ញា-វេបុល្លាយ** ( ដើម្បីភាពធំទូលាយនៃប្រាជ្ញា ) ១ **បញ្ញាពាហុល្លាយ** ( ដើម្បីភាពនៃប្រាជ្ញាដ៏ច្រើន ) ១ ជាពាក្យសម្តែងការៈដោយអំណាចនៃបញ្ញា ។ បទ ១២ ដ៏សេស ជាពាក្យសម្តែងការៈដោយអំណាចនៃបុគ្គល ។

# អដ្ឋកថា

## សោតវិសយញាណនិទ្ទេស

[ ១៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេស ដូចតទៅនេះថា បទថា **ជន្នំ អភិញ្ញានំ** បានដល់ ឥទ្ធិវិធ ១ ទិព្វសោត ១ ចេតោបរិយញ្ញាណ ១ បុព្វេនិវាសញ្ញាណ ១ ទិព្វចក្ខុ ១ អាសវក្ខយញ្ញាណ ១ ។ បទថា **តេសត្តតីនំ ញាណានំ** បានដល់ ញាណទូទៅដល់សាវកដែលសម្តែងទុកហើយក្នុងញាណកថា ។

ក្នុងបទថា **សត្តសត្តតីនំ ញាណានំ** មានព្រះបាលី ( ក្នុងសំយុត្ត-និកាយនិទានវគ្គ ) ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងញាណវត្ថុ ៧៧ ប្រការ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរយកចិត្តទុកដាក់ប្រុងចាំស្តាប់ពាក្យនោះឲ្យប្រពៃចុះ តថាគតនឹងពោលឲ្យស្តាប់ ។ ម្នាលភិក្ខុទាំងឡាយ ញាណវត្ថុទាំង ៧៧ ប្រការ តើដូចម្តេច គឺសេចក្តីដឹងថា ជរានិងមរណៈកើតមានព្រោះជាតិជាបច្ច័យ ១ សេចក្តីដឹងថា កាលបើជាតិ

មិនមាន ជរានិងមរណៈក៏មិនមាន ១ សេចក្តីដឹងថា ជរានិងមរណៈជាអតីតកាល កើតមានព្រោះជាតិជាបច្ច័យ ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរានិងមរណៈក៏មិនមាន ១ សេចក្តីដឹងថា ជរានិងមរណៈជាអនាគតកាលកើតមានព្រោះជាតិជាបច្ច័យ ១ សេចក្តីដឹងថា កាលបើជាតិមិនមាន ជរានិងមរណៈក៏មិនមាន ១ សេចក្តីដឹងថា ធម្មដ្ឋិតិញ្ញាណ ( បច្ចយាការញ្ញាណ ) ណាគប្បីមាន ធម្មដ្ឋិតិញ្ញាណនោះ មានកិរិយាអស់ទៅជាធម្មតា មានកិរិយាសូន្យទៅជាធម្មតា មានកិរិយាវិនាសទៅជាធម្មតា មានកិរិយារលត់ទៅជាធម្មតា ១ ។ សេចក្តីដឹងថា ជាតិកើតមាន ព្រោះភពជាបច្ច័យ ១ ។បេ។ សេចក្តីដឹងថា ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ១ ... សេចក្តីដឹងថា ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ១ ... សេចក្តីដឹងថា តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ ១ ... សេចក្តីដឹងថា វេទនាកើតមានព្រោះផស្សៈជាបច្ច័យ ១ ... សេចក្តីដឹងថា ផស្សៈកើតមានព្រោះសឡាយតនៈជាបច្ច័យ ១ ... សេចក្តីដឹងថា សឡាយតនៈកើតមានព្រោះនាមរូបជាបច្ច័យ ១ ... សេចក្តីដឹងថា នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ ១ ... សេចក្តីដឹងថា វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យ ១ ... សេចក្តីដឹងថា សង្ខារទាំងឡាយកើតមានព្រោះអវិជ្ជាជាបច្ច័យ ១ សេចក្តីដឹងថា កាលបើអវិជ្ជាមិនមានហើយសង្ខារទាំងឡាយក៏មិនមាន ១ សេចក្តីដឹងថា សង្ខារទាំងឡាយជាអតីតកាល កើតមានព្រោះអវិជ្ជាជាបច្ច័យ ១ សេចក្តីដឹងថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយក៏មិនមាន ១ សេច-

ក្តីដឹងថា សង្ខារទាំងឡាយជាអនាគតកាល កើតមានព្រោះអវិជ្ជាជាបច្ច័យ ១ សេចក្តីដឹងថា កាលបើអវិជ្ជាមិនមាន សង្ខារទាំងឡាយ ក៏មិនមាន ១ សេចក្តីដឹងថា ធម្មដ្ឋិតិញ្ញាណណាគប្បីមាន ធម្មដ្ឋិតិញ្ញាណនោះ មានកិរិយាអស់ទៅជាធម្មតា មានកិរិយាសូន្យទៅជាធម្មតា មានកិរិយាវិនាសទៅជាធម្មតា មានកិរិយារលត់ទៅជាធម្មតា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ញាណវត្ថុ ៧៧ ប្រការដូច្នេះ ។

ញាណ ៧៧ យ៉ាង ព្រះមានព្រះភាគ ត្រាស់ទុកហើយក្នុងនិទានវគ្គដោយប្រការដូច្នេះ ។ មួយវិញទៀត ញាណវត្ថុ ៤៤ យ៉ាងដែលទ្រង់ត្រាស់នីមួយ ៗ ៤ ក្នុងអង្គ ១១ ដោយន័យ ( ក្នុងសំយុត្តនិកាយនិទានវគ្គ ) នេះថា សេចក្តីដឹងក្នុងជរានិងមរណៈ ១ សេចក្តីដឹងក្នុងហេតុជាទីកើតឡើងនៃជរានិងមរណៈ ១ សេចក្តីដឹងក្នុងទីរលត់នៃជរានិងមរណៈ ១ សេចក្តីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ ១ ដូច្នេះ មិនបានរួមចូលក្នុងទីនេះ ។ មួយវិញទៀត ក្នុងញាណទាំងពីរកន្លែងនោះ ជាវត្ថុនៃប្រយោជន៍និងសេចក្តីសុខ ទើបឈ្មោះថា ញាណវត្ថុ ។

ការបានក្នុងបទថា **លាភោ** ជាដើម លោកពោលថា **បដិលាភោ** ព្រោះបន្ថែមឧបសគ្គធ្វើឲ្យវិសេសឡើង ។ ដើម្បីពង្រីកសេចក្តីនៃពាក្យនោះទៀត ទើបលោកពោលថា **បត្តិ សម្បត្តិ** ដូច្នេះ ។ បទថា **ផស្សនា** បានដល់ ការពាល់ត្រូវដោយការចាក់ធ្លុះ ។ បទថា **សច្ឆិកិរិយា** បានដល់ការធ្វើឲ្យជាក់ច្បាស់ដោយការបានចំពោះ ។ បទថា **ឧបសម្បទា** បានដល់

ការឲ្យសម្រេច ។ បទថា **សត្តន្នញ្ច សេក្ខានំ** បានដល់ របស់ព្រះសេក្ខៈ ៧ ពួក មានលោកដែលតាំងនៅក្នុងសោតាបត្តិមគ្គជាដើម ដែលសន្មតថា ជាព្រះសេក្ខៈ ព្រោះនៅសិក្សាសិក្ខា ៣ នៅឡើយ ។ បទថា **បុថុជ្ជនកល្យាណកស្ស** ច បានដល់ របស់បុថុជ្ជនដែលសន្មតថាជាកល្យាណ ដោយអត្ថថា ជាបុគ្គលល្អ ព្រោះប្រកបបដិបទាដែលញុំាងសត្វ ឲ្យដល់និព្វាន ។ ឈ្មោះថា **វឌ្ឍិតវឌ្ឍនា** បានដល់ ជាហេតុឲ្យនូវការចម្រើន ។ ឈ្មោះថា **បញ្ញាវុឌ្ឍិយា** ដោយអំណាចនៃបញ្ញា ៨ តាមដែលពោលហើយ និងដោយអំណាចនៃបញ្ញា របស់ព្រះអរហន្តដោយពិសេស ។ ក្នុងបទថា **បញ្ញាវេបុល្លាយ** ក៏ន័យនេះដូចគ្នា ។

[ ១៣៦ ] ក្នុងបទថា **មហន្តេ អត្ថេ បរិគ្គណ្ហាតិ** ជាដើម មានសេចក្តី ដូចតទៅនេះថា ព្រះអរិយសាវកដែលចាក់ធ្លុះបដិសម្ភិទា រមែងកំណត់អត្ថជាដើម ដោយធ្វើឲ្យជាអារម្មណ៍ ។ មហាបញ្ញាសូម្បីទាំងអស់ក៏ជារបស់ព្រះអរិយសាវកទាំងឡាយនោះឯង ។ ម្យ៉ាងទៀត ជាវិស័យនៃបញ្ញានោះ មានសេចក្តីដូចបានពោលហើយនោះឯង ។

[ ១៣៧ ] **នានា** សព្ទក្នុងបទថា **បុថុនានាខន្ធេសុ** ជាពាក្យពោលដល់អត្ថរបស់ **បុថុ** សព្ទ ។ បទថា **ញាណំ បវត្តតីតិ បុថុបញ្ញា** សេចក្តីថា ញាណនោះ ឈ្មោះថា **បុថុបញ្ញា** ព្រោះញាណប្រព្រឹត្តទៅក្នុងខន្ធជាដើមតាមដែលពោលហើយនោះ ។ បទថា **នានាបដិច្ចសមុប្បាទេសុ** លោកពោលព្រោះជាបច្ច័យច្រើន ដោយអំណាចនៃធម៌អាស្រ័យគ្នា កើត

ឡើង ។ បទថា **ឆាឆាសុញ្ញតមនុលព្ភេសុ** បានដល់ ការចូលទៅបាន ឈ្មោះថា **ឧបលត្ថ** អធិប្បាយថា ការកាន់យក ។ ការមិនចូលទៅបាន ឈ្មោះថា **អនុបលត្ថ** ព្រោះការមិនចូលទៅបានមានច្រើន ទើបឈ្មោះថា **អនុបលព្ភា** ជាពហុវចនៈ ម្យ៉ាងទៀត ការមិនចូលទៅបាននូវខ្លួននិងវត្ថុជារបស់ខ្លួនក្នុងការសូន្យផ្សេងៗដោយសុញ្ញតា ២៥ ឈ្មោះថា **ឆាឆាសុញ្ញ-តានុបលព្ភា** ។ ក្នុងនានាសុញ្ញតានុបលព្ភានោះ ។ កាលគួរនឹងពោលថា **ឆាឆាសុញ្ញតានុបលព្ភេសុ** លោកពោល **ម** អក្ខរៈ ដោយបទសន្ធិ ដូចក្នុងពាក្យថា **អទុក្ខមសុខា** ( មិនទុក្ខមិនសុខ ) ។ បញ្ញា ៥ យ៉ាងនេះ ទូទៅដល់កល្យាណបុថុជ្ជន ។

បញ្ញាក្នុងបទថា **ឆាឆាអត្ថា** ជាដើម ទូទៅដល់ព្រះអរិយៈប៉ុណ្ណោះ ។ បទថា **បុថុជ្ជនសាធារណោ ធម្មោ** បានដល់ លោកិយធម៌ ។ លោកពោលថា ឈ្មោះថា **បុថុបញ្ញា** ព្រោះបញ្ញាក្រាស់ដោយមាននិព្វានដែលជារបស់ធំជាអារម្មណ៍ និងជាបញ្ញាញែកចេញអំពីលោកិយៈ ដោយបរិយាយក្នុងទីបំផុតនេះ ។

[ ១៣៨ ] បទថា **វិបុលប្បញ្ញា** គប្បីជ្រាបដោយន័យរបស់មហាបញ្ញា ( នោះឯង ) ។ គប្បីជ្រាបភាពដែលធម៌និងបញ្ញាទូលំទូលាយព្រោះកំណត់ធម៌តាមដែលពោលហើយ ជាបុគ្គលមានគុណធំ ព្រោះបញ្ញាកំណត់ធម៌ទាំងនោះធំ ព្រោះធម៌ទាំងនោះធំទូលាយក្រៃលែងដោយខ្លួនឯងនោះឯង ។

[ ១៣៩ ] គម្ភីរប្បញ្ញាគប្បីជ្រាបដោយន័យរបស់បុថុប្បញ្ញា ( នោះ

ឯង ) ។ ធម៌ទាំងនោះ ការមិនគប្បីចូលទៅបាននោះ និងបញ្ញានោះឈ្មោះ ជាជ្រាលជ្រៅ ព្រោះជាទីតាំងដែលបកតិជន ( មនុស្សសាមញ្ញ ) មិន គប្បីបាន ។

[ ១៤០ ] បទថា **យស្ស បុគ្គលស្ស** បានដល់ ដែលព្រះអរិយបុគ្គល នោះឯង ។ បទថា **អញ្ញោ កោចិ** បានដល់ បុថុជ្ជន ។ បទថា **អភិ-សម្ភវិតុំ** បានដល់ ដើម្បីតាមទាន់បាន ( ប្រៀបធៀបបាន ) ។ បទថា **អនភិសម្ភវនីយោ** បានដល់ ដែលបុគ្គលណាមួយមិនអាចតាមទាន់បាន ។ បទថា **អញ្ញេហិ** បានដល់ បុថុជ្ជននោះឯង ។ បទថា **អដ្ឋមកស្ស** បាន ដល់ របស់លោកអ្នកដែលតាំងនៅក្នុងសោតាបត្តិមគ្គ ជាបុគ្គលទី ៨ រាប់ តាំងអំពីលោកអ្នកដែលតាំងនៅក្នុងអរហត្តផល ។ បទថា **ទូរេ** បានដល់ ក្នុងទីឆ្ងាយ ។ បទថា **វិទូរេ** បានដល់ ឆ្ងាយជាពិសេស ។ បទថា **សុវិទូរេ** បានដល់ ឆ្ងាយសែនឆ្ងាយ ។ បទថា **ន សន្តិកេ** បានដល់ មិនជិត ។ បទថា **ន សាមន្តា** បានដល់ ក្នុងចំណែកមិនជិត ។ បទប្រកបពាក្យ បដិសេធទាំងពីរនេះ កំណត់ដល់សភាពឆ្ងាយនោះឯង ។ បទថា **ឧបាទាយ** បានដល់ អាស្រ័យ ។ បទថា **សោតាបន្នស្ស** បានដល់ លោកអ្នកដែល តាំងនៅក្នុងសោតាបត្តិផល ។ ដោយបទនេះ លោកពោលថា មគ្គប្បញ្ញា នោះ ៗ ឆ្ងាយចាកផលប្បញ្ញានោះ ៗ ។ បទថា **បច្ចេកសម្ពុទ្ធោ** ប្រកបគ្នា ដោយឧបសគ្គ ។ ទាំងពីរបទនេះក៏សំដៅដល់បុគ្គលបរិសុទ្ធដូចគ្នា ។

ព្រះសារីបុត្តត្ថេរកាលពោលពាក្យថា ចំណែកព្រះតថាគតអរហន្តសម្មា-

សមុទ្ទ ឈ្មោះថា អ្នកមានបញ្ញាមិនជិត បើប្រៀបធៀបនឹងព្រះបច្ចេកពុទ្ធ ផង និងមនុស្សលោក ព្រមទាំងទេវលោកផង ជាដើម ហើយបំណងនឹងសម្តែងបញ្ញាដែលតាំងនៅឆ្ងាយនោះ ដោយប្រការមិនមែនតិច ទើបពោលពាក្យថា **បញ្ញាបភេទកុសលោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បញ្ញាបភេទកុសលោ** បានដល់ ទ្រង់ឈ្លាសក្នុងប្រភេទនៃបញ្ញា ដែលមានការកំណត់មិនមានទីបំផុត របស់ព្រះអង្គ ។ បទថា **បភិន្នញាណោ** បានដល់ មានព្រះញាណដល់នូវការបែកធ្លាយមិនមានទីបំផុត ។ ដោយបទនេះ សូម្បីមានសេចក្តីឈ្លាសក្នុងប្រភេទនៃបញ្ញាព្រះសារីបុត្តត្ថេរ ក៏សម្តែងសភាពដែលបញ្ញាទាំងនោះ មានប្រភេទមិនមានទីបំផុត ។ បទថា **អធិគតប្បដិសម្ភិទោ** បានដល់ ទ្រង់បានបដិសម្ភិទាញាណ ៤ ដ៏ប្រសើរ ។ បទថា **ចតុវេសារជ្ជប្បត្តោ** បានដល់ ទ្រង់ដល់នូវញាណ ពោលគឺសេចក្តីក្លៀវក្លា ៤ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្ត គឺធម៌ ឬបុគ្គលទុំះថា សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី បុគ្គលណាមួយក្នុងលោកក្តីនឹងចោទតថាគតដោយពាក្យប្រកបដោយធម៌ក្នុងហេតុនោះថា លោកប្តេជ្ញាខ្លួនថា ជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ប៉ុន្តែធម៌ទាំងអម្បាលនេះ លោកមិនបានត្រាស់ដឹងទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនឃើញនូវនិមិត្តទុំះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ។

ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញនូវនិមិត្ត គឺធម៌ ឬបុគ្គលនុ៎ះថា សមណៈក្តី ព្រាហ្មណ៍ក្តី ។បេ។ បុគ្គលណាមួយក្នុងលោកក្តី នឹងចោទតថាគតដោយពាក្យប្រកបដោយធម៌ក្នុងហេតុនោះថា លោកប្តេជ្ញាខ្លួនថា ជាអ្នកអស់អាសវៈហើយ ប៉ុន្តែអាសវៈទាំងអម្បាលនេះ មិនទាន់អស់ទេ ថាធម៌ជាគ្រឿងធ្វើនូវអន្តរាយ ធម៌ទាំងអម្បាលនោះ មិនអាចធ្វើអន្តរាយដល់បុគ្គលអ្នកសេពបានទេ ថាធម៌ដែលលោកសម្តែងហើយ ដើម្បីប្រយោជន៍ដល់គុណវិសេសណា គុណវិសេសនោះមិនអាចស្រោចស្រង់ដើម្បីឲ្យអស់ទៅនៃទុក្ខដោយប្រពៃ ដល់អ្នកធ្វើតាមនូវធម៌នោះទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតមិនឃើញនូវនិមិត្តនុ៎ះឯង ទើបដល់នូវសេចក្តីក្សេម ដល់នូវភាពជាអ្នកមិនមានភ័យ ដល់នូវភាពជាអ្នកក្លៀវក្លា ១ ដូច្នេះ ។

បទថា **ទសពលពលធារី** ឈ្មោះថា ទសពល ព្រោះមានពលៈ ១០ ។ ពលៈរបស់អ្នកមានពលៈ ១០ ឈ្មោះថា **ទសពលពលានិ** ឈ្មោះថា **ទសពលពលធារី** ព្រោះទ្រទ្រង់ពលៈរបស់បុគ្គលអ្នកមានពលៈ ១០ អធិប្បាយថា ទ្រទ្រង់កម្លាំង គឺទសពលញ្ញាណ ។ ដោយបទទាំង ៣ នេះ លោកសម្តែងត្រឹមតែមាតិកានៃប្រភេទរបស់វេនេយ្យសត្វ ដែលមានប្រភេទមិនមានទីបំផុត ។ ព្រះតថាគត ទ្រង់ជាបុរសអាសភៈ ដោយអត្ថថា បានទទួលសន្ទតថាជាមង្គលក្រៃលែង ដោយអំណាចប្រកបដោយបញ្ញា ទ្រង់ជាបុរសសីហៈ ដោយអត្ថថា មិនមានសេចក្តីតក់ស្លុត ទ្រង់ជាបុរសនាគៈ ដោយអត្ថថា ជាធំ ទ្រង់ជាបុរសអាជានេយ្យ ដោយអត្ថថា ជាអ្នកដឹងទូ

ទៅ ទ្រង់ជាបុរសគួរដើម្បីនាំនូវធុរៈ ដោយអត្ថថា នាំធុរៈកិច្ចរបស់សត្វលោកទៅ ។

កាលនោះព្រះសារីបុត្តត្ថេរបំណងនឹងសម្តែងគុណវិសេស មានតេជៈជាដើម ដែលបានអំពីអនន្តញាណ ដើម្បីសម្តែងភាពដែលតេជៈជាដើមទាំងនោះ មានអនន្តញាណជាមូលពោលថា **អនន្តញ្ញាណោ** ហើយទើបពោលបទថា **អនន្តតេជោ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **អនន្តញ្ញាណោ** បានដល់ ទ្រង់មានញាណប្រាសចាកទីបំផុត ដោយអំណាចការរាប់និងដោយអំណាចកម្លាំង ។ បទថា **អនន្តតេជោ** បានដល់ ទ្រង់មានតេជៈដោយព្រះញាណ មិនមានទីបំផុត ដោយការកម្ចាត់ងងឹត គឺមោហៈក្នុងសន្តានរបស់វេនេយ្យសត្វ ។ បទថា **អនន្តយសោ** បានដល់ ទ្រង់មានការប្រកាសកិត្តិគុណមិនមានទីបំផុតផ្សាយទៅក្នុងលោកទាំង ៣ ដោយព្រះបញ្ញាគុណ ។ បទថា **អឌ្ឍោ** បានដល់ ទ្រង់បរិបូរណ៍ដោយទ្រព្យ គឺបញ្ញា ។ បទថា **មហាទ្ធនោ** ឈ្មោះថា **មហាទ្ធនោ** ព្រោះមានទ្រព្យ គឺបញ្ញាច្រើន ដោយភាពជាអ្នកច្រើនដោយអំណាច ព្រោះភាពជាអ្នកចម្រើនដោយទ្រព្យគឺបញ្ញា ។ បាឋៈថា **មហាធនោ** ដូច្នេះក៏មាន ។ បទថា **ធនវា** ឈ្មោះថា **ធនវា** ព្រោះមានទ្រព្យ គឺបញ្ញាដែលគួរសរសើរ ព្រោះមានទ្រព្យ គឺបញ្ញាដែលប្រកបជាមួយជានិច្ច ព្រោះមានទ្រព្យ គឺបញ្ញាដែលដល់កំពូល ។ ក្នុងអត្ថទាំង ៣ នេះ អ្នកដឹងសព្ទទាំងឡាយរមែងប្រាថ្នាពាក្យនេះ ។

ព្រះសារីបុត្តត្ថេរ កាលសម្តែងការសម្រេចនៃអត្តសម្បត្តិ របស់ព្រះ-មានព្រះភាគដោយព្រះបញ្ញាគុណ យ៉ាងនេះហើយ កាលនឹងសម្តែងសេចក្តីសម្រេចនៃសម្បត្តិដែលជាប្រយោជន៍ដល់ ( សត្វ ) លោក ដោយព្រះ-បញ្ញាគុណទៀត ទើបពោលបទថា **នេតា** ជាដើម ។

គប្បីជ្រាបសេចក្តីក្នុងបទទាំងនោះ ដូចតទៅនេះថា ទ្រង់ជាអ្នកនាំវេ-នេយ្យសត្វទាំងឡាយ ទៅកាន់ឋានៈដ៏ក្សេម ពោលគឺនិព្វាន អំពីឋានៈដែលគួរខ្លាច គឺសង្សារ ។

ក្នុងវេលានាំទៅក្នុងនិព្វាននោះ ទ្រង់ជាអ្នកនាំទៅឲ្យវិសេសនូវវេនេយ្យសត្វទាំងឡាយ ដោយអំណាចសំវរវិន័យនិងបហានវិន័យយ៉ាងនេះ ។

ទ្រង់នាំទៅរឿយៗដោយការកាត់សេចក្តីសង្ស័យ ក្នុងខណៈទ្រង់សម្តែងធម៌ ។ ទ្រង់កាត់សេចក្តីសង្ស័យហើយប្រញាប្តអត្ថដែលគួរប្រញាប្ត ។ ទ្រង់ពិនិត្យមើលដោយធ្វើការកាត់សម្រេចសេចក្តី ដែលបញ្ញត្តទុកយ៉ាងនោះ ។ ទ្រង់សម្លឹងមើលអត្ថដែលទ្រង់ពិនិត្យមើលហើយយ៉ាងនោះ ដោយការប្រកបក្នុងការបដិបត្តិ ។ ទ្រង់ឲ្យពួកសត្វដែលបដិបត្តិហើយនោះជ្រះថ្លាដោយផលនៃការបដិបត្តិ ។ **ហិ** អក្ខរៈ ក្នុងបទនេះថា **សោ ហិ ភគវា** ជានិបាតចុះក្នុងការសម្តែង អាងដល់ហេតុនៃអត្ថដែលពោលទុកហើយក្នុងលំដាប់ ។ បទថា **អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា** បានដល់ ញុំាងអរិយមគ្គដែលជាហេតុនៃអសាធារណញ្ញាណ ៦ ដែលមិនធ្លាប់កើត ក្នុងសន្តានរបស់ខ្លួនឲ្យកើតឡើងក្នុងសន្តានរបស់ខ្លួន ដើម្បីប្រយោជន៍ដល់លោក ត្រង់មណ្ឌល

ពោធិព្រឹក្ស ។ បទថា **អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា** បានដល់ ញុំាំងអរិយមគ្គដែលជាហេតុនៃសាវកបារមីញាណ ដែលមិនធ្លាប់កើតព្រម ក្នុងសន្តានរបស់វេនេយ្យសត្វ ឲ្យកើតព្រមក្នុងសន្តាន របស់វេនេយ្យសត្វ តាំងអំពីទ្រង់ប្រកាសធម្មចក្ក ដរាបដល់សព្វថ្ងៃនេះ ។ ពិតណាស់ ព្រះមានព្រះភាគ ឈ្មោះថា **សញ្ជនេតា** ព្រោះទ្រង់ញុំាំងអរិយមគ្គឲ្យកើតព្រម ក្នុងសន្តានរបស់វេនេយ្យសត្វដែលជាសាវក ដោយព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ទុកនោះឯង ។ បទថា **អនក្ខាតស្ស មគ្គស្ស អក្ខាតា** បានដល់ ទ្រង់ឲ្យពាក្យព្យាករណ៍ដើម្បីភាពជាព្រះពុទ្ធដល់ព្រះពោធិសត្វទាំងឡាយ ដែលសន្សំបុណ្យកុសលទុក ដើម្បីភាពជាព្រះពុទ្ធអ្នកប្រកបដោយធម៌ ៨ ប្រការ ហើយទ្រង់ប្រាប់មគ្គ គឺការបំពេញបារមី ដែលមិនធ្លាប់បានប្រាប់ ឬទ្រង់ប្រាប់អរិយមគ្គ ដែលគួរឲ្យកើតឡើងត្រង់មណ្ឌលពោធិព្រឹក្ស ដោយត្រឹមតែព្យាករថា នឹងបានត្រាស់ជាព្រះពុទ្ធ ។ ន័យនេះរមែងបានសូម្បីក្នុងការព្យាករព្រះបច្ចេកពោធិសត្វដូចគ្នា ។

បទថា **មគ្គញ្ញូ** បានដល់ ទ្រង់ដឹងអរិយមគ្គដែលខ្លួនឲ្យកើតឡើងដោយអំណាចបច្ចវេក្ខណញ្ញាណ ។ បទថា **មគ្គវិទូ** បានដល់ ទ្រង់ឈ្លាសក្នុងអរិយមគ្គ ដែលគប្បីឲ្យកើតឡើងក្នុងសន្តានរបស់វេនេយ្យសត្វ ។ បទថា **មគ្គកោវិទោ** បានដល់ ទ្រង់ឃើញច្បាស់នូវមគ្គ ដែលគួរប្រាប់ដល់ព្រះពោធិសត្វទាំងឡាយ ។ម្យ៉ាងវិញទៀត ទ្រង់ដឹងមគ្គដែលជាបដិបទាដើម្បីអភិសម្ពោធិ ទ្រង់ជ្រាបមគ្គដែលជាបដិបទា ដើម្បីបច្ចេកពោធិ ទ្រង់ឈ្លាស

ក្នុងមគ្គដែលជាបដិបទាដើម្បីសាវកពោធិ ។

ម្យ៉ាងវិញទៀត អាចារ្យទាំងឡាយ រមែងធ្វើការប្រកបអត្ថតាមលំដាប់ ដោយអំណាចនៃមគ្គរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកក្នុងអតីត អនាគតនិងបច្ចុប្បន្ន ដោយអំណាចនៃសុញ្ញតមគ្គ អនិមិត្តមគ្គនិងអប្បណិហិតមគ្គ និងដោយអំណាចនៃមគ្គរបស់ឧគ្ឃដិតញ្ញូបុគ្គល វិបញ្ចិតញ្ញូបុគ្គលនិងនេយ្យបុគ្គលតាមសមគួរ ព្រោះបាលី ( ក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា ជនទាំងឡាយឯណា បានចូលហើយក្នុងកាលមុនក្តី ចូលក្នុងកាលឥឡូវនេះក្តី នឹងចូលក្នុងខាងមុខក្តីនូវអន្ទង់ ( មានកាមជាដើម ) តាមផ្លូវនេះឯង ដូច្នេះ ។

បទថា **មគ្គានុគាមី ច បន** បានដល់ ជាអ្នកប្រព្រឹត្តទៅតាមមគ្គ ដែលព្រះមានព្រះភាគទ្រង់ប្រព្រឹត្តទៅហើយ ។ **ច** សព្ទ ក្នុងទីនេះជានិបាត ចុះក្នុងអត្ថនៃហេតុ ។ ដោយបទនេះ ជាការពោលដល់ហេតុនៃការសម្រេច គុណ មានញុំាងមគ្គឲ្យកើតជាដើមរបស់ព្រះមានព្រះភាគ ។ **បន** សព្ទជា និបាតចុះក្នុងអត្ថថា ធ្វើហើយ ។ ដោយបទនោះ ជាការពោលដល់ហេតុនៃ មគ្គដែលព្រះមានព្រះភាគ ទ្រង់ធ្វើហើយ ។ បទថា **បច្ឆា សមន្នាគតា** បានដល់ កាលព្រះមានព្រះភាគស្តេចយាងទៅហើយមុន ព្រះសាវកក៏ប្រកប ដោយគុណមានសីលជាដើមមកក្នុងខាងក្រោយ ។ ដោយហេតុនេះ ព្រោះ គុណ មានសីលជាដើម សូម្បីទាំងអស់របស់ព្រះមានព្រះភាគ អាស្រ័យ អរហត្តមគ្គនោះឯង មកហើយដោយបទថា ទ្រង់ញុំាងមគ្គដែលមិនទាន់កើត ឲ្យកើតឡើងជាដើម ដូច្នេះ ព្រោះហេតុនោះព្រះថេរៈពោលដល់គុណ ព្រោះ

អាស្រ័យអរហត្តមគ្គនោះឯង ។ បទថា **ជានំ ជានាតិ** បានដល់ ទ្រង់រមែងជ្រាបវត្ថុដែលគួរជ្រាប អធិប្បាយថា ធម្មតាវត្ថុដែលគួរជ្រាបដោយបញ្ញាឯណានីមួយនៃព្រះសព្វញ្ញុតញ្ញាណនៅមាន ទ្រង់រមែងជ្រាបវត្ថុដែលគួរជ្រាបទាំងអស់នោះ ដែលជាផ្លូវគួរណែនាំ ៥ ប្រការ ដោយបញ្ញា ។ បទថា **បស្សំ បស្សតិ** បានដល់ ទ្រង់ឃើញវត្ថុដែលគួរឃើញ អធិប្បាយថា ទ្រង់ធ្វើផ្លូវដែលគួរណែនាំនោះឯង ដូចឃើញដោយចក្ខុ ព្រោះឃើញវត្ថុទាំងអស់ ឈ្មោះថា រមែងឃើញដោយបញ្ញាចក្ខុ ឬថា ព្រះមានព្រះភាគមិនមែនដូចមនុស្សពួកខ្លះ សូម្បីកាន់យកវត្ថុវិបរិត កាលដឹងក៏រមែងមិនដឹង សូម្បីឃើញក៏រមែងមិនឃើញ តែព្រះមានព្រះភាគ ទ្រង់កាន់យកតាមសភាវៈពិត ទ្រង់ជ្រាបក៏រមែងទ្រង់ជ្រាប ទ្រង់ឃើញក៏រមែងទ្រង់ឃើញ ។

ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **ចក្ខុភូតោ** ព្រោះអត្ថថា ទ្រង់ជាអ្នកនាំក្នុងការឃើញ ឈ្មោះថា **ញាណភូតោ** ព្រោះអត្ថថា មានភាពជាអ្នកទ្រង់ដឹងច្បាស់ជាដើម ឈ្មោះថា **ធម្មភូតោ** ព្រោះអត្ថថា មានសភាពមិនវិបរិត ឬសម្រេចដោយធម៌ដែលព្រះអង្គទ្រង់គិត ដោយព្រះហឫទ័យហើយទ្រង់បន្លឺដោយវាចា ព្រោះទ្រង់ស្ទាត់ក្នុងបរិយត្តិធម៌ ឈ្មោះថា **ព្រហ្មភូតោ** ព្រោះអត្ថថា ទ្រង់ជាអ្នកប្រសើរបំផុត ។ម្យ៉ាងទៀត ឈ្មោះថា **ចក្ខុភូតោ** ព្រោះទ្រង់ដូចជាចក្ខុ ឈ្មោះថា **ញាណភូតោ** ព្រោះទ្រង់ដូចជាញាណ ឈ្មោះថា **ធម្មភូតោ** ព្រោះទ្រង់ដូចជាធម៌ ឈ្មោះថា **ព្រហ្មភូតោ** ព្រោះទ្រង់ដូចជាព្រហ្ម ។

ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **វត្តា** ព្រោះត្រាស់ប្រាប់ធម៌ ឬ ព្រោះញ៉ាំងព្រះធម៌ឲ្យប្រព្រឹត្តទៅ ។ ឈ្មោះថា **បវត្តា** ព្រោះត្រាស់ប្រាប់ដោយប្រការផ្សេងៗឬឲ្យប្រព្រឹត្តទៅដោយប្រការផ្សេងៗ ។ ឈ្មោះថា **អត្ថស្ស និន្នេតា** ព្រោះទ្រង់នាំអត្ថចេញហើយ ទើបទ្រង់ណែនាំ ។ ឈ្មោះថា **អមតស្ស ទាតា** ព្រោះទ្រង់សម្តែងបដិបទា ដើម្បីសម្រេចអមតធម៌ ឬ ព្រោះទ្រង់ឲ្យសម្រេចអមតធម៌ ដោយការសម្តែងធម៌ ប្រកាសអមតធម៌ ។ ឈ្មោះថា **ធម្មស្សាមី** ព្រោះទ្រង់ជាធំដោយការប្រទានលោកុត្តរធម៌ តាមសប្បាយដោយសមគួរដល់វេនេយ្យសត្វ ព្រោះទ្រង់ឲ្យលោកុត្តរធម៌កើតនិងទ្រង់ជាធំក្នុងធម៌ទាំងឡាយ ។ បទថា **តថាគត** មានអត្ថដូចបានពោលហើយ ។

ឥឡូវនេះព្រះសារីបុត្តត្ថេរបំណាងនឹងសម្តែងគុណ ដូចដែលពោលហើយដោយបទថា ទ្រង់ជ្រាបហេតុដែលគួរជ្រាបជាដើម ឲ្យវិសេសក្រៃលែងឡើងដោយភាពជាព្រះសព្វញ្ញុតញ្ញាណ កាលនឹងញ៉ាំងព្រះសព្វញ្ញុតញ្ញាណ ឲ្យសម្រេច ទើបពោលបទថា **នត្ថិ** ជាដើម ដូច្នេះ ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគអង្គនោះទ្រង់ជាយ៉ាងនោះ មិនបានធ្វើឲ្យជាក់ច្បាស់មិនមានព្រោះទ្រង់កម្ចាត់សេចក្តីវង្វេង ព្រមទាំងវាសនាក្នុងធម៌ទាំងពួង ដោយអរហត្តមគ្គញ្ញាណដែលសម្រេចដោយកម្លាំងបុណ្យ ដែលទ្រង់បំពេញមកហើយ ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគ ទ្រង់មិនជ្រាបមិនមាន ព្រោះទ្រង់ជ្រាបធម៌ទាំងពួងដោយសេចក្តីមិនវង្វេង ឈ្មោះថា បទធម៌ដែលព្រះមាន-

ព្រះភាគ ទ្រង់មិនបានដឹងមិនមាន ព្រោះទ្រង់ជ្រាបធម៌ទាំងពួងដោយការមិនវង្វេង ។ ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគ ទ្រង់មិនបានឃើញមិនមានព្រោះធម៌ទាំងពួងទ្រង់ឃើញដោយញាណចក្ខុ ដូចទ្រង់ឃើញដោយចក្ខុ ។ ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគ មិនបានជ្រាបមិនមាន ព្រោះទ្រង់សម្រេចហើយដោយញាណ ។ ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគ មិនបានធ្វើឲ្យជាក់ច្បាស់មិនមាន ព្រោះទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយការធ្វើជាក់ច្បាស់ដោយការមិនវង្វេង ។ ឈ្មោះថា បទធម៌ដែលព្រះមានព្រះភាគ មិនបានប៉ះពោល់ហើយមិនមាន ព្រោះទ្រង់ពាល់ត្រូវដោយបញ្ញា គឺការមិនវង្វេង ។ បទថា **បច្ចុប្បន្នំ** បានដល់ កាល ឬធម៌ជាបច្ចុប្បន្ន ។ បទថា **ឧបាទាយ** បានដល់ កាន់យក អធិប្បាយថា ធ្វើទុកក្នុងខាងក្នុង សូម្បីនិព្វានផុតចាកកាល លោកក៏កាន់យកដោយពាក្យថា **ឧបាទាយ** នោះឯង ។ បទថា **អតីត** ជាដើម ភ្ជាប់ជាមួយពាក្យថា **ធត្តិ** ឬជាមួយបទថា **សព្វេ** ជាដើម ។ បទថា **សព្វេ ធម្មា** រួមសង្ខតធម៌និងអសង្ខតធម៌ទាំងអស់ ។ បទថា **សព្វាការេន** បានដល់ រួមអាការទាំងពួង មានអាការមិនទៀងជាដើមនៃធម៌នីមួយ ៗ បណ្តាធម៌ទាំងអស់ ។ បទថា **ញាណមុខេ** បានដល់ ចំពោះមុខ គឺព្រះញាណ ។ បទថា **អាបាថំ អាគច្ឆន្តិ** បានដល់ រមែងដល់នូវការរួមចុះ ។ បទថា **ជានិតព្វំ** លោកពោល ដើម្បីអធិប្បាយសេចក្តីនៃបទថា **នេយ្យំ** □គួរណែនាំ ) ។ **វា** សព្ទក្នុងបទថា **អត្តត្ថោ វា** ជាដើម ជាសមុច្ចយត្ថ ( ការរួមគ្នា ) ។ បទថា **អត្តត្ថោ** បានដល់

ប្រយោជន៍របស់ខ្លួន ។ បទថា **បរត្ថោ** បានដល់ ប្រយោជន៍របស់លោក ៣ ដទៃ ។ បទថា **ឧភយត្ថោ** បានដល់ ប្រយោជន៍ទាំងពីរចំណែកក្នុងគ្រាតែមួយ គឺរបស់ខ្លួននិងរបស់អ្នកដទៃ ។ បទថា **ទិដ្ឋធម្មិកោ** បានដល់ ប្រយោជន៍ប្រកបក្នុងភពនេះ ឬប្រយោជន៍បច្ចុប្បន្ន ។ ប្រយោជន៍ប្រកបហើយក្នុងភពខាងមុខ ឬប្រយោជន៍ក្នុងសម្បរាយភព ឈ្មោះថា **សម្បរា-យិកោ** ។

គប្បីជ្រាបក្នុងបទថា **ឧត្តានោ** ជាដើម ដូចតទៅនេះថា ប្រយោជន៍ដែលគប្បីពោលដោយអំណាចវោហារ ឈ្មោះថា **ឧត្តានោ** ព្រោះកើតបានងាយ ។ ប្រយោជន៍ដែលគប្បីពោលកន្លងនូវវោហារ បដិសំយុត្តដោយសុញ្ញតា ឈ្មោះថា **គម្ភីរោ** ព្រោះកើតបានដោយក្រ ។ ប្រយោជន៍ដែលជាលោកុត្តរៈ ឈ្មោះថា **គុឡ្ហោ** ព្រោះពោលតែខាងក្រៅដោយចំណែកមួយ ។ ប្រយោជន៍ មានការមិនទៀងជាដើម ឈ្មោះថា **បដិច្ឆន្នោ** ព្រោះបិទបាំងដោយឃនៈ ( ដុំ ) ជាដើម ។ ប្រយោជន៍ដែលនិយាយដោយប្រើវោហារពិសេស ឈ្មោះថា **នេយ្យោ** ព្រោះមិនកាន់យកត្រឹមតែវាចាអធិប្បាយហើយនាំទៅបាន ។ ប្រយោជន៍ដែលពោលដោយប្រើវោហារទូទៅ ឈ្មោះថា **នីតោ** ព្រោះអធិប្បាយត្រឹមតែវាចាក៏នាំទៅបានហើយ ។ ប្រយោជន៍ គឺសីល សមាធិ និងវិបស្សនាដែលបរិសុទ្ធិដោយល្អ ឈ្មោះថា **អនវជ្ជោ** ព្រោះប្រាសចាកទោសដោយតទង្គៈ និងវិក្ខម្ភនៈ ។ ប្រយោជន៍ គឺអរិយមគ្គ ឈ្មោះថា **និក្កិលេសោ** ព្រោះកាត់កិលេសបានជាសមុច្ឆេទ ។ ប្រយោជន៍

គឺអរិយផល ឈ្មោះថា **សាន្តោ** ព្រោះកិលេសស្ងប់រម្ងាប់ ។ និព្វាន ឈ្មោះថា **បរមត្ថោ** ព្រោះនិព្វានជាធម៌ដ៏ប្រសើរក្នុងសង្ខតធម៌និងអសង្ខ-តធម៌ទាំងឡាយ ។

បទថា **បរិវត្តតិ** បានដល់ ប្រព្រឹត្តទៅជ្រួតជ្រាប ឬដោយជុំវិញ ឬប្រឡូកប្រឡំ ឬដោយវិសេសក្នុងខាងក្នុងពុទ្ធញ្ញាណ ព្រោះមិនជាខាងក្រៅចាកភាពជាវិស័យនៃពុទ្ធញ្ញាណ ។ ព្រះសារីបុត្តត្ថេររមែងសម្តែងភាពដែលកាយកម្មជាដើម សម្រេចមកអំពីព្រះញាណរបស់ព្រះមានព្រះភាគ ដោយបទថា **សព្វំ កាយកម្មំ** ជាដើម ។ បទថា **ញាណានុបរិវត្តតិ** បានដល់ រមែងប្រព្រឹត្តទៅតាមព្រះញាណ អធិប្បាយថា ប្រព្រឹត្តទៅមិនប្រាសចាកព្រះញាណ ។ បទថា **អប្បដិហតំ** លោកសម្តែងដល់ភាពដែលមិនមានអ្វីរាំងទុក ។ ព្រះសារីបុត្តត្ថេរបំណងនឹងញ៉ាំងសព្វញ្ញុតញ្ញាណឲ្យសម្រេចដោយឧបមាទៀត ទើបពោលបទថា **យាវតកំ** ជាដើម ។ ក្នុងបទទាំងនោះ ឈ្មោះថា **ញេយ្យំ** ព្រោះគួរដឹង ឈ្មោះថា **ញេយ្យបរិយន្តិកំ** ព្រោះព្រះញាណមាននេយ្យជាទីបំផុតដោយជុំវិញ មាននេយ្យជាចុងបញ្ចប់ ។

ម្យ៉ាងទៀត អ្នកមិនមែនជាសព្វញ្ញូ មិនមាននេយ្យជាទីបំផុត សូម្បីក្នុងបទថា **ញាណបរិយន្តិកំ** ក៏មានន័យនេះដូចគ្នា ។ ព្រះសារីបុត្តត្ថេរសម្តែងសេចក្តីដែលបានពោលទុកហើយក្នុងគូដើម ឲ្យវិសេសទៅ ដោយគូនេះសម្តែងកំណត់ដោយការបដិសេធដោយគូទី ៣ ។ ម្យ៉ាងទៀត នេយ្យៈក្នុងបទនេះ ឈ្មោះថា **ញេយ្យបថោ** ព្រោះជាគន្លងនៃញាណ ។ បទថា **អញ្ញ-**

**មញ្ចាំបរិយន្តដ្ឋាយិនោ** *បានដល់ មានប្រក្រតីញ៉ាំងនេយ្យៈ និងញាណឲ្យអស់ទៅ ហើយតាំងនៅក្នុងទីបំផុតដោយជុំវិញនៃគ្នានឹងគ្នា ដោយឋានៈ ។ បទថា* **អាវជ្ជនប្បដិពទ្ធា** *បានដល់ ទាក់ទងដោយមនោទ្វារាវជ្ជនៈ អធិប្បាយថា រមែងដឹងលំដាប់នៃសេចក្តីនឹកគិតនោះឯង ។ បទថា* **អាកង្ខប្បដិពទ្ធា** *បានដល់ ទាក់ទងដោយការពេញចិត្ត អធិប្បាយថា រមែងដឹងលំដាប់នៃអាវជ្ជនចិត្តដោយជវនញ្ញាណ លោកពោលបទទាំងពីរក្រៅអំពីនេះ ដើម្បីប្រកាសសេចក្តីតាមលំដាប់បទទាំងពីរនេះ ។*

*បទថា* **ពុទ្ធោ អាសយំ ជានាតិ** *ជាដើម ខ្ញុំពណ៌នាទុកក្នុងញាណកថាហើយ តែក្នុងមហានិទ្ទេសលោកពោលថា* **ភគវា អាសយំ ជានាតិ** *ព្រះមានព្រះភាគទ្រង់ជ្រាបអាសយៈ ។ ក្នុងមហានិទ្ទេសនោះក្នុងអនាគតដ្ឋានថា* **ពុទ្ធស្ស ភគវតោ** *ព្រះពុទ្ធមានព្រះភាគ ។ ក្នុងទីខ្លះថា* **ពុទ្ធស្ស** *( របស់ព្រះពុទ្ធ ) ដូច្នេះ ។*

*បទថា* **អន្តមសោ** *បានដល់ ដោយទីបំផុតខាងលើ ។ ក្នុងបទថា* **តិមិតិមិង្គលំ** *នេះគប្បីជ្រាបដូចតទៅនេះថា ត្រីមួយប្រភេទឈ្មោះថា តិមិ ត្រីមួយប្រភេទឈ្មោះថា តិមិង្គលៈ ព្រោះមានខ្លួនធំជាងត្រីតិមិនោះ អាចលេបត្រីតិមិបាន ត្រីមួយប្រភេទ ឈ្មោះថា តិមិតិមិង្គលៈ មានបណ្តោយ ៥០០ យោជន៍ អាចលេបត្រីតិមិង្គលៈបាន ។ ក្នុងបទនេះគប្បីជ្រាបថាជាឯកវចនៈដោយកាន់យកកំណើត ។*

*ក្នុងបទថា* **គរុឡំ វេនតេយ្យំ** *នេះ គប្បីជ្រាបថា ឈ្មោះថា* **គរុឡំ**

ជាឈ្មោះដោយកំណើត ឈ្មោះថា **ឧបតិស្សោ** ជាឈ្មោះដោយគោត្ត ។ បទថា **បទេសេ** បានដល់ ក្នុងចំណែកខ្លះ ។ បទថា **សារិបុត្តសមា** គប្បីជ្រាបថា លោកពោលសំដៅដល់ព្រះថេរៈ ដែលជាធម្មសេនាបតីរបស់ព្រះពុទ្ធទាំងពួង ព្រោះសាវកដ៏សេសមិនមានអ្នកណាស្មើដល់ព្រះធម្មសេនាបតីថេរៈ ខាងបញ្ញា សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកមានប្រាជ្ញាច្រើន ដែលជាសាវករបស់តថាគត ស្រេចនឹងសារីបុត្តប្រសើរជាងគេ ។ ម្យ៉ាងទៀត លោកពោលទុកក្នុងអដ្ឋកថាថា

*សត្វទាំងឡាយដទៃណាដែលមាននៅ វៀរចាកព្រះលោកនាថ*
*សត្វទាំងនោះរមែងមិនដល់នូវចំណែកទី ១៦ នៃបញ្ញារបស់*
*ព្រះសារីបុត្ត ។*

បទថា **ជិត្វា** បានដល់ ពុទ្ធញាណសម្រេចដល់បញ្ហា សូម្បីរបស់ទេវតា និងមនុស្សទាំងពួង ហើយផ្សាយទៅ ជ្រាបចូលទៅកាន់បញ្ហារបស់ទេវតានិងមនុស្សទាំងនោះដោយឋានៈហើយតាំងនៅ ។ បទថា **អតិយំសិត្វា** បានដល់ ពុទ្ធញាណឈានកន្លងបញ្ហា សូម្បីរបស់ទេវតា និងមនុស្សទាំងពួង កម្ចាត់ ទម្លាយនេយ្យៈទាំងពួង សូម្បីមិនមែនវិស័យរបស់ទេវតានិងមនុស្សទាំងនោះ ហើយតាំងនៅ បាឋៈក្នុងមហានិទ្ទេសថា **អភិភវិត្វា** ( គ្របសង្កត់ហើយ ) អធិប្បាយថា ញាំញីហើយ ។

ដោយបទថា **យេបិ តេ** ជាដើម លោកសម្ដែងហេតុដែលពុទ្ធញាណ

ផ្សាយកម្ចាត់យ៉ាងនេះហើយ ឃើញប្រចក្សនូវឋានៈ ។

ក្នុងបទទាំងនោះ បទថា **បណ្ឌិតា** បានដល់ ដែលប្រកបដោយភាព ជាបណ្ឌិត ។ បទថា **និបុណា** បានដល់ មានបញ្ញាល្អិតសុខុមអាចចាក់ ធ្លុះក្នុងរវាងអត្ថដែលជ្រាលជ្រៅបាន ។ បទថា **កតបរប្បវាទា** បានដល់ ដឹងនូវវាទៈ ឆ្លើយឆ្លង និងវាទៈផ្ចាញ់ផ្ចាលរបស់ជនដទៃ ។ បទថា **វាល-វេធិរូបា** បានដល់ មានបញ្ញា ប្រៀបដូចនាយខ្មាន់ធ្នូ ដែលអាចបាញ់រោម ទ្រាយ ។ បទថា **វោភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ** សេចក្ដីថា ត្រាច់ទៅ ដូចទម្លាយនូវទិដ្ឋិរបស់អ្នកដទៃសូម្បីសុខុម ដោយ បញ្ញារបស់ខ្លួន ដូចនាយខ្មាន់ធ្នូបាញ់រោមទ្រាយដូច្នោះ ។

ម្យ៉ាងទៀត បញ្ញាគតក៏គឺបញ្ញា ទិដ្ឋិគតក៏គឺទិដ្ឋិ ដូចក្នុងពាក្យថា **គូថ-គតំ មុត្តគតំ** ជាក់លាមក ជាក់មូត្រ ជាដើម ។ បទថា **បញ្ហំ អភិ-សង្ខរិត្វា** បានដល់ ចងសំណួរ ២ បទខ្លះ ៣ បទខ្លះ ៤ បទខ្លះ លោក ពោលអស់វារៈ ២ ដង ដើម្បីសង្គ្រោះចូលជាមួយគ្នាទាំងអស់ ព្រោះបញ្ហា ទាំងនោះ មានច្រើនក្រៃលែង ។ បទថា **គូឡ្ហានិ ច បដិច្ឆន្នានិ** មាន បាឋៈដ៏សេសថា អត្ថកំបាំងនិងមិនច្បាស់លាស់ ជនទាំងឡាយឃើញការ ដឹកនាំនូវអត្ថ ( វិន័យ ) ទាំងនោះយ៉ាងនោះហើយ រមែងសួរបញ្ហា ព្រោះ ព្រះមានព្រះភាគ ទ្រង់បំណងយ៉ាងនេះថា ចូរសួរបញ្ហាដែលខ្លួនចងមក ។ ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់មិនប្រទានឱកាសដើម្បីឲ្យអ្នកដទៃសួរ ទ្រង់ រមែងសម្ដែងធម៌ដល់អ្នកចូលទៅគាល់ សមដូចបិលោតិកបរិព្វាជក ពោល

ទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ខត្តិយបណ្ឌិតទាំងនោះ ចង ប្រស្នាដោយគិតថា ពួកយើងនឹងចូលទៅគាល់ព្រះសមណគោតម ហើយ ក្រាបបង្គំទូលសួរប្រស្នានេះ បើយើងក្រាបបង្គំទូលប្រស្នាយ៉ាងនេះហើយ ព្រះអង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណគោ-តមនោះយ៉ាងនេះ បើយើងបានក្រាបបង្គំទូលសួរប្រស្នាយ៉ាងនេះហើយ ព្រះ អង្គមុខជានឹងព្យាករយ៉ាងនេះ ពួកយើងនឹងលើកទោសព្រះសមណគោតម នោះយ៉ាងនេះវិញ ។ ទើបខត្តិយបណ្ឌិតទាំងនោះចូលទៅគាល់ព្រះសមណ-គោតម ។ ព្រះសមណគោតម ទ្រង់ញុំាងខត្តិយបណ្ឌិតទាំងនោះ ឲ្យយល់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថា ពួកខត្តិយបណ្ឌិតនោះ ដែលព្រះសមណគោតមទ្រង់ឲ្យយល់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏មិនអាចទូលសួរប្រស្នានឹងព្រះសមណគោតមបាន ឡើយនឹងលើកទោសព្រះសមណគោតមដូចម្តេចបាន តាមពិតនឹងសម្រេច ទៅជាសាវករបស់ព្រះសមណគោតមវិញ ដូច្នេះ ។

បើសួរថា ព្រោះហេតុអ្វីទើបបណ្ឌិតទាំងឡាយមិនទូលសួរបញ្ហា ឆ្លើយ ថា បានឮថា ព្រះមានព្រះភាគកាលទ្រង់សម្តែងធម៌ក្នុងកណ្តាលបរិស័ទ ទ្រង់ ពិចារណាមើលអធ្យាស្រ័យរបស់បរិស័ទ បន្ទាប់អំពីទ្រង់ឃើញថា បណ្ឌិត ទាំងនេះធ្វើបញ្ហាលាក់កំបាំងសម្ងាត់ឲ្យមានសារៈជាកំណួចហើយមក បណ្ឌិត ទាំងនោះមិនទូលសួរព្រះអង្គឡើយ ទ្រង់ពិចារណាឃើញថា បុគ្គលនេះដឹង ថា មានទោសប្រមាណប៉ុណ្ណេះ ក្នុងការសួរបញ្ហាមានប្រមាណប៉ុណ្ណេះ ក្នុង

ការឆ្លើយបញ្ហាមានប្រមាណប៉ុណ្ណេះក្នុងអត្ថ ក្នុងបទ ក្នុងអក្ខរៈដូច្នេះ កាលនឹងសួរបញ្ហាទាំងនេះ គប្បីសួរយ៉ាងនេះ កាលឆ្លើយបញ្ហា គប្បីឆ្លើយយ៉ាងនេះ ទើបទ្រង់សម្តែងបញ្ចូលបញ្ហាដែលបណ្ឌិតទាំងនោះនាំមក ធ្វើឲ្យមានសារៈដែលជាកំណួច ទុកក្នុងចន្លោះធម្មកថា ។ បណ្ឌិតទាំងនោះរមែងពេញចិត្តថា យើងមិនសួរបញ្ហាទាំងនេះ ជាការប្រសើររបស់យើង ប្រសិនបើយើងសួរព្រះសមណគោតម ទ្រង់គប្បីធ្វើឲ្យពួកយើងតម្កល់ខ្លួន មិនបានឡើយ ( ខ្មាសគេ ) ។ ប្រការមួយទៀត ធម្មតាព្រះពុទ្ធទាំងឡាយកាលទ្រង់សម្តែងធម៌ ទ្រង់រមែងផ្សាយមេត្តាទៅកាន់បរិស័ទ ដោយការផ្សាយមេត្តា មហាជនរមែងមានចិត្តជ្រះថ្លាក្នុងព្រះទសពល ។ ធម្មតាព្រះពុទ្ធទាំងឡាយទ្រង់មានរូបល្អ គួរមើល មានសំឡេងពីរោះ មានអណ្តាតទន់ មានបបូរមាត់បិទជិតល្អ ទ្រង់ពោលធម៌ដូចស្រោចហឫទ័យដោយទឹកអម្រឹត ក្នុងពេលទ្រង់ពោលធម៌នោះ អ្នកមានចិត្តជ្រះថ្លាដោយទ្រង់ផ្សាយមេត្តា រមែងមានការគិតយ៉ាងនេះថា យើងមិនអាចនឹងចាប់វត្ថុផ្ទុយគ្នា ជាមួយព្រះមាន-ព្រះភាគទ្រង់ពោលកថាមិនមានពីរ កថាមិនមែនជាមោឃៈ កថានាំសត្វចេញទៅ មានសភាពបែបនេះបានឡើយ បណ្ឌិតទាំងឡាយ រមែងមិនសួរបញ្ហាព្រោះភាពនៃខ្លួនជ្រះថ្លានោះឯង ។

បទថា **កថិតា វិសជ្ជិតា ច** បានដល់ បញ្ហាទាំងនោះ ឈ្មោះថាព្រះមានព្រះភាគ ទ្រង់ពោលដោយការត្រាស់ដល់បញ្ហា ដែលបណ្ឌិតទាំងឡាយសួរថា ពួកអ្នកចូរសួរយ៉ាងនេះ ឈ្មោះថា ទ្រង់ឆ្លើយដោយប្រការ

ដែលគួរឆ្លើយនោះឯង ។ បទថា **និទ្ទិដ្ឋការណា** បានដល់ បញ្ហាទាំងនោះ រមែងមានហេតុដែលព្រះមានព្រះភាគ ទ្រង់សម្តែងលម្អិតឲ្យឃើញច្បាស់ដោយការឆ្លើយធ្វើឲ្យមានហេតុយ៉ាងនេះថា ការឆ្លើយរមែងមានដោយការណ៍នេះ ដោយហេតុនេះ ។ បទថា **ឧបក្ខិត្តកា ច តេ ភគវតោ សម្បជ្ជន្តិ** សេចក្តីថា បណ្ឌិតទាំងនោះ មានខត្តិយបណ្ឌិតជាដើម ក្រាបចុះទៀបបាទា រមែងប្រាកដដល់ព្រះមានព្រះភាគដោយការឆ្លើយបញ្ហារបស់ព្រះមានព្រះភាគ រមែងសម្រេចជាសាវក ឬជាឧបាសក អធិប្បាយថា បណ្ឌិតទាំងនោះរមែងដល់នូវសាវកសម្បត្តិ ឬឧបាសកសម្បត្តិ ។ បទថា **អថ** ជានិបាត ចុះក្នុងអត្ថថា លំដាប់ អធិប្បាយថា ក្នុងលំដាប់ព្រមដោយសម្បត្តិដែលបណ្ឌិតទាំងនោះចូលទៅគាល់ ។ បទថា **តត្ថ** បានដល់ ក្នុងទីនោះ ឬក្នុងអធិការនោះ ។ បទថា **អតិរោចតិ** បានដល់ រមែងរុងរឿងភ្លឺច្បាស់យ៉ាងក្រៃលែង ។ បទថា **យទិទំ បញ្ញាយ** សេចក្តីថា ព្រះមានព្រះភាគ រមែងរុងរឿងដោយបញ្ញារបស់ព្រះអង្គ ។ **ឥតិ** សព្ទ ចុះក្នុងអត្ថនៃហេតុ សេចក្តីថា ព្រះមានព្រះភាគជាបុគ្គលដ៏កំពូល មានព្រះបញ្ញាមិនជិតដោយហេតុនេះ ។

[ ១៤១ ] បទថា **រាគំ អភិភុយ្យតីតិ ភូរិបញ្ញា** សេចក្តីថា បញ្ញាក្នុងមគ្គនោះ ៗ រមែងគ្របសង្កត់ញាំញីរាគៈដែលជាទោសនឹងខ្លួន ព្រោះហេតុនោះ ទើបឈ្មោះថា **ភូរិបញ្ញា** ។ បទថា **ភូរិ** មានអត្ថថា ប៉ះពាល់បានផូរផង់ ។ ភូរិដែលប៉ះពាល់បាន រមែងគ្របសង្កត់នូវវត្ថុដែលជាបដិបក្ខ ប៉ះ

ពាល់មិនបាន រមែងគ្របសង្កត់មិនបាន ព្រោះហេតុនោះ ទើបលោកពោល អត្ថនៃកុសលបញ្ញាថា គ្របសង្កត់ ។ បទថា **អភិភវិតា** បានដល់ បញ្ញា ក្នុងផលនោះ ៗ គ្របសង្កត់បានហើយ ញាំញីបានហើយនូវរាគៈនោះ ៗ ។ បាឋៈថា **អភិភវតា** ក៏មាន ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។

ក្នុងបទមានរាគៈជាដើម គប្បីជ្រាបសេចក្ដីដូចតទៅនេះថា រាគៈ មាន ការត្រេកត្រអាលជាលក្ខណៈ ។ ទោសៈ មានការប្រទូស្តជាលក្ខណៈ ។ មោហៈ មានការវង្វេងជាលក្ខណៈ ។ កោធៈ មានការខឹងជាលក្ខណៈ ។ ឧបនាហៈ មានការចងសេចក្ដីក្រោធទុក ជាលក្ខណៈ ។ កោធៈកើតមុន ឧបនាហៈកើតជាខាងក្រោយ ។ មក្ខៈ មានការលុបគុណអ្នកដទៃជាលក្ខណៈ ។ បឡាសៈ មានការវាយឫកស្មើជាលក្ខណៈ ។ ឥស្សា មានការធ្វើសម្បត្តិ អ្នកដទៃឲ្យអស់ទៅជាលក្ខណៈ ។ មច្ឆរិយៈ មានការបិទបាំងនូវសម្បត្តិ របស់ខ្លួនជាលក្ខណៈ ។ មាយា មានការបិទបាំងអំពើអាក្រក់ដែលខ្លួនធ្វើ ជាលក្ខណៈ ។ សាថេយ្យៈ មានការប្រកាសគុណដែលមិនមានរបស់ខ្លួន ជាលក្ខណៈ ។ ថម្ភៈ មានការរឹងត្អឹងនៃចិត្តជាលក្ខណៈ ។ សារម្ភៈ មាន ការអួតអាងខ្លួនជាលក្ខណៈ ។ មានះ មានការប្រកាន់ខ្លួនជាលក្ខណៈ ។ អតិមានះ មានការប្រកាន់ខ្លួនខ្លាំងជាលក្ខណៈ ។ មទៈ មានការស្រវឹងជា លក្ខណៈ ។ បមាទៈ មានការបណ្ដោយបណ្ដោយចិត្តទៅក្នុងកាមគុណ ៥ ជាលក្ខណៈ ។

ដោយបទថា **រាគោ អរិ តំ អរឹ មទ្ទនិបញ្ញា** ជាដើម លោក

អធិប្បាយទុកយ៉ាងណា កិលេសមានរាគៈជាដើម ឈ្មោះថា **ភូអរិ** ព្រោះអត្ថថា ជាសត្រូវដែលមានក្នុងចិត្តសន្តាន ។ លោកពោលថា **ភូរិ** ព្រោះលុប **អ** អក្ខរៈដោយបទសន្ធិ ។ គប្បីជ្រាបថា កាលគួរនឹងពោលថា បញ្ញាញាំញី **ភូរិ** នោះឈ្មោះថា **ភូរិមទ្ទនិបញ្ញា** លោកពោលថា **ភូរិ-បញ្ញា** ព្រោះលុប **មទ្ទនិ** សព្ទចេញ ។ បទថា **តំ អរឹ មទ្ទនិ** លោកកំណត់បទថា **តេសំ អរីនំ មទ្ទនី** ( ការញាំញីសត្រូវទាំងនោះ ) ។ បទថា **បថវីសមាយ** បានដល់ ឈ្មោះថា **បថវីសមាយ** ព្រោះអត្ថថា ធំទូលាយនោះឯង ។ បទថា **វិត្ថតាយ** បានដល់ ផ្សាយទៅក្នុងវិស័យដែលគួរដឹងបាន មិនប្រព្រឹត្តទៅក្នុងឯកទេស ។ បទថា **វិបុលាយ** បានដល់ ឧឡារ ។ តែមកក្នុងមហានិទ្ទេសថា **វិបុលាយ វិត្ថតាយ** ( បរិបូរណ៍ទូលំទូលាយ ) ។ បទថា **សមន្នាគតោ** បានដល់ បុគ្គលដែលប្រកបហើយ ។

**ឥតិ** សព្ទ ចុះក្នុងអត្ថថា ហេតុ សេចក្ដីថា ដោយហេតុនេះបញ្ញារបស់បុគ្គលនោះ ឈ្មោះថា **ភូរិបញ្ញា** ព្រោះបុគ្គលជាអ្នកប្រកបដោយភូរិបញ្ញា ព្រោះហេតុនោះ បុគ្គលរមែងត្រេកអរក្នុងអត្ថដែលចម្រើនហើយ ។

កាលគួរនឹងពោលថា **ភូរិបញ្ញស្ស បញ្ញា ភូរិបញ្ញបញ្ញា** លោកក៏ពោលថា **ភូរិបញ្ញា** ព្រោះលុប **បញ្ញា** សព្ទមួយចោល ។ម្យ៉ាងទៀត ឈ្មោះថា **ភូរិបញ្ញា** ព្រោះមានបញ្ញាស្មើដោយផែនដី ។

បទថា **អបិច** លោកពោលដើម្បីសម្ដែងបរិយាយដទៃ ។ បទថា

**បញ្ញាយមេតំ** កាត់បទជា **បញ្ញាយ ឯតំ** ។ បទថា **អធិវចនំ** ជាពាក្យពោលក្រៃលែង ។ បទថា **ភូរិ** ឈ្មោះថា **ភូរិ** ព្រោះអត្ថថា រមែងត្រេកអរក្នុងអត្ថដែលចម្រើនហើយ ។ បទថា **មេធា** បញ្ញា ឈ្មោះថា **មេធា** ព្រោះអត្ថថា ទម្លាយកិលេសទាំងឡាយ ដូចរន្ទះទម្លាយវត្ថុដែលធ្វើដោយថ្មដូច្នោះ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **មេធា** ព្រោះអត្ថថា កាន់យកទុកដោយរហ័ស ។ បទថា **បរិណាយិកា** ឈ្មោះថា បរិណាយិកៈ ព្រោះអត្ថថា បញ្ញារមែងកើតឡើងដល់សត្វណា រមែងនាំសត្វនោះទៅក្នុងធម៌ដែលសម្បយុត្តក្នុងការបដិបត្តិដែលជាប្រយោជន៍ និងក្នុងបដិវេធដែលមានលក្ខណៈពិតប្រាកដ ដោយបទទាំងនេះ គឺលោកពោលដល់ពាក្យដែលបរិយាយនៃបញ្ញាសូម្បីយ៉ាងដទៃផង ។

[ ១៤២ ] បទថា **បញ្ញាពាហុល្លំ** ឈ្មោះថា បញ្ញាពហុល ព្រោះបញ្ញាមានច្រើន ភាពនៃបុគ្គលអ្នកមានបញ្ញាច្រើននោះ ឈ្មោះថា បញ្ញាពាហុល្ល ។ បញ្ញាច្រើននោះ គឺបញ្ញាប្រព្រឹត្តទៅច្រើននោះឯង ។

ក្នុងបទថា **ឥធេកច្ចោ** ជាដើម បានដល់ កល្យាណបុថុជ្ជន ឬអរិយបុគ្គល ។ ឈ្មោះថា **បញ្ញាគរុកោ** ព្រោះជាអ្នកមានបញ្ញាធ្ងន់ ។ ឈ្មោះថា **បញ្ញាចរិតោ** ព្រោះជាអ្នកមានបញ្ញាជាចរិតប្រព្រឹត្តទៅ ។ ឈ្មោះថា **បញ្ញាសយោ** ព្រោះមានបញ្ញាជាទីអាស្រ័យ ។ ឈ្មោះថា **បញ្ញាធិមុត្តោ** ព្រោះបង្អោនចិត្តជឿដោយបញ្ញា ។ ឈ្មោះថា **បញ្ញាធជោ** ព្រោះមានបញ្ញាជាទង់ជ័យ ។ ឈ្មោះថា **បញ្ញាកេតុ** ព្រោះមានបញ្ញាជាកំពូល ។ ភាព

ជាធំគឺបញ្ញា ឈ្មោះថា **បញ្ញាធិបតិ** ឈ្មោះថា **បញ្ញាធិបតេយ្យា** ព្រោះមកអំពីភាពជាអ្នកមានបញ្ញាជាធំ ។ ឈ្មោះថា **វិចយពហុលោ** ព្រោះមានការពិចារណាសភាវធម៌ច្រើន ។ ឈ្មោះថា **បវិចយពហុលោ** ព្រោះមានការពិនិត្យសភាវធម៌ដោយប្រការផ្សេង ៗ ច្រើន ។ ការឈមចុះដោយបញ្ញាហើយ ធ្វើធម៌នោះ ៗ ឲ្យប្រាកដ គឺឲ្យជាក់ច្បាស់ ឈ្មោះថា **ឱក្ខាយន** ឈ្មោះថា **ឱក្ខាយនពហុលោ** ព្រោះមានការពិចារណាច្រើន ។ ការសម្លឹងពិចារណាធម៌នោះៗដោយបញ្ញាដ៏ប្រពៃ ឈ្មោះថា **សមេក្ខ** ។ ដំណើរទៅការប្រព្រឹត្តិទៅ ដោយការសម្លឹងពិចារណាដោយប្រពៃ ឈ្មោះថា **សមេក្ខាយន** ឈ្មោះថា **សមេក្ខាយនធម្មោ** ព្រោះមានការសម្លឹងពិចារណាដោយប្រពៃជាធម្មតា ជាប្រក្រតី ។ ឈ្មោះថា **វិភូតវិហារី** ព្រោះធ្វើធម៌នោះៗឲ្យជាក់ច្បាស់ឲ្យប្រាកដ ។ម្យ៉ាងវិញទៀត ឈ្មោះថា **វិភូតវិហារី** ព្រោះមានធម៌ជាគ្រឿងនៅជាក់ច្បាស់ ។ ឈ្មោះថា **តច្ចរិតោ** ព្រោះមានបញ្ញាជាចរិត ។ ឈ្មោះថា **តគ្គរុកោ** ព្រោះមានបញ្ញាធ្ងន់ ។ ឈ្មោះថា **តព្ពហុលោ** ព្រោះមានបញ្ញាច្រើន ។ ឱនទៅក្នុងបញ្ញានោះ ឈ្មោះថា **តន្និន្នោ** ។ ទោរទៅក្នុងបញ្ញានោះ ឈ្មោះថា **តប្បោណោ** ។ ឈមទៅក្នុងបញ្ញានោះ ឈ្មោះថា **តប្បព្ភារោ** ។ ចុះចិត្តស៊ប់ទៅ ក្នុងបញ្ញានោះ ឈ្មោះថា **តទធិមុត្តោ** ។ បញ្ញានោះជាធំ ឈ្មោះថា **តទធិបតិ** បុគ្គលមកអំពីបញ្ញាជាធំនោះ ឈ្មោះថា **តទធិបតេយ្យោ** ។

បទថា **បញ្ញាគរុកោ** ជាដើម លោកពោលចាប់ផ្ដើមអំពីកើតក្នុងជាតិ

មុន ដូចក្នុងប្រយោគថា ដឹងនូវបុគ្គលអ្នកសេពកាមថា បុគ្គលនេះធ្ងន់ក្នុងកាម ដូច្នេះជាដើម ។ បទថា **តច្ចរិតោ** ជាដើម លោកពោលដល់ក្នុងជាតិនេះ ។

[ ១៨៣-១៨៦ ] **សីឃប្បញ្ញា** ( បញ្ញាដ៏ឆាប់ ) **លហុប្បញ្ញា** □បញ្ញាដ៏រហ័ស ) **ហាសប្បញ្ញា** ( បញ្ញានាំឲ្យរីករាយ ) និង **ជវនប្បញ្ញា** □បញ្ញាជាគ្រឿងស្ទុះទៅ ) ជាបញ្ញាលាយដោយលោកិយៈនិងលោកុត្តរៈ ។

ឈ្មោះថា **សីឃប្បញ្ញា** ដោយអត្ថថា រហ័ស ។ ឈ្មោះថា **លហុ-ប្បញ្ញា** ដោយអត្ថថា ស្រាល ។ ឈ្មោះថា **ហាសប្បបញ្ញា** ដោយអត្ថថា រីករាយ ។ ឈ្មោះថា **ជវនប្បញ្ញា** ដោយអត្ថថា ស្ទុះទៅក្នុងសង្ខារដែលចូលដល់វិបស្សនា និងក្នុងវិសង្ខារ ។ បទថា **សីឃំ សីឃំ** លោកពោលពីរដងដើម្បីសង្គ្រោះសីលជាដើមច្រើន ។ បទថា **សីលានិ** បានដល់បាតិមោក្ខសំវរៈសីល ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តទុកដោយអំណាចនៃចារិត្តសីលនិងវារិត្តសីល ។ បទថា **ឥន្ទ្រិយសំវរំ** បានដល់ ការរារាំងដោយបង្អួច គឺសតិ មិនឲ្យរាគៈ បដិឃៈ ចូលទៅកាន់ឥន្ទ្រិយ ៦ មានចក្ខុន្ទ្រិយជាដើម ។ បទថា **ភោជនេ មត្តញ្ញុតំ** បានដល់ ភាពជាអ្នកដឹងប្រមាណក្នុងការបរិភោគ ដោយពិចារណាហើយទើបបរិភោគ ។ បទថា **ជាគរិយានុយោគំ** មានវិគ្គហៈថា ឈ្មោះថា **ជាគរ** ព្រោះភ្ញាក់ គឺមិនលក់ក្នុង ៣ ចំណែកនៃថ្ងៃ និងក្នុងបឋមយាម មជ្ឈិមយាមនៃរាត្រី បំពេញសមណធម៌តែម្យ៉ាង ការៈ ឬកម្មរបស់អ្នកភ្ញាក់ ឈ្មោះថា **ជាគរិយ** ការ

ប្រកបរឿយ ៗ នៃភាពជាអ្នកភ្ញាក់ ឈ្មោះថា **ជាគរិយានុយោគ** ។ ញ៉ាំង ជាគរិយានុយោគនោះឲ្យបរិបូរណ៍ ។ បទថា **សីលក្ខន្ធំ** បានដល់ សីលក្ខន្ធ ដែលជារបស់ព្រះសេក្ខៈ ឬព្រះអសេក្ខៈ ។ ខន្ធ សូម្បីក្រៅអំពីនេះ ក៏គប្បី ជ្រាបយ៉ាងនេះ ។ បទថា **បញ្ញាក្ខន្ធំ** បានដល់ មគ្គប្បញ្ញានិងលោកិយប្បញ្ញា របស់ព្រះសេក្ខៈនិងព្រះអសេក្ខៈ ។ បទថា **វិមុត្តិក្ខន្ធំ** បានដល់ ផលវិមុត្តិ ។ បទថា **វិមុត្តិញ្ញាណទស្សនក្ខន្ធំ** បានដល់ បច្ចវេក្ខណញ្ញាណ ។ បទថា **បាមោជ្ជពហុលោ** ជាមូលបទ ។ បទថា **វេទពហុលោ** ជាបទចង្អុលបង្ហាញដោយអំណាចការសោយសោមនស្សវេទនាដែលសម្បយុត្តដោយបីតិនោះឯង ។ បទថា **តុដ្ឋិពហុលោ** ជាបទចង្អុលបង្ហាញដោយ ការត្រេកអរនៃបីតិមានកម្លាំងតិច ។ បទថា **បាមោជ្ជពហុលោ** ជាបទ ចង្អុលបង្ហាញដោយអំណាចបាមោជ្ជៈនៃបីតិមានកម្លាំង ។ បទថា **យំ កិញ្ចិ រូបំ** ជាដើម មានសេចក្តីដូចបានពោលហើយក្នុងសម្មសនញ្ញាណនិទ្ទេស ។ បទថា **តុលយិត្វា** បានដល់ ថ្លឹងថ្លែងដោយកលាបសម្មសនៈ ( ការពិចារណាជាដុំ ជាកង ) ។ បទថា **តីរយិត្វា** បានដល់ ពិចារណាដោយ ឧទយព្វយានុបស្សនា ។ បទថា **វិភាវយិត្វា** បានដល់ ធ្វើឲ្យប្រាកដដោយ ភង្គានុបស្សនា ។ បទថា **វិភូតំ កត្វា** បានដល់ ធ្វើឲ្យពាល់ត្រូវដោយ សង្ខារុបេក្ខាញាណ ។

[ ១៤៧ ] **តិក្ខប្បញ្ញា** ( បញ្ញាដ៏មុត ) ជាលោកុត្តរៈតែម្យ៉ាង ។ បទថា **ឧប្បន្នំ** បានដល់ ដែលលះបានហើយដោយអំណាចតទង្គប្បហាន

ដោយអំណាចសមថៈនិងវិបស្សនា លោកក៏ពោលថា កើតឡើងមិនទាន់ដកបាន ព្រោះមិនកន្លងការកើតឡើងជាធម្មតា ព្រោះមិនទាន់ដកបានដោយអរិយមគ្គ ក្នុងទីនេះលោកបំណងយក ( កាមវិតក្កៈ ) ដែលកើតឡើងមិនទាន់ដកបាននោះ ។ បទថា **នាធិវាសេតិ** បានដល់ មិនលើកឡើងកាន់សន្តានហើយឲ្យ ។ បទថា **បជហាតិ** បានដល់ លះជាសមុច្ឆេទ ។ បទថា **វិនោទេតិ** បានដល់ រមែងបន្សាត់ទៅ ។ បទថា **ព្យន្តីករោតិ** បានដល់ ធ្វើឲ្យប្រាសចាកទីបំផុត ។ បទថា **អនភាវំ គមេតិ** បានដល់ ឲ្យដល់នូវការមិនមាន ក្នុងកាលជាខាងក្រោយ អធិប្បាយថា ដល់អរិយមគ្គតាមលំដាប់វិបស្សនា ហើយឲ្យដល់នូវការមិនមានដោយការកាត់ផ្ដាច់ ។

ក្នុងបទទាំងនេះ វិតក្កៈដែលប្រកបដោយកាម ឈ្មោះថា **កាមវិតក្ក** វិតក្កៈប្រកបដោយសេចក្ដីស្លាប់របស់អ្នកដទៃដោយគិតថា សូមឲ្យសត្វទាំងនេះស្លាប់ចុះ ឈ្មោះថា **ព្យាបាទវិតក្ក** ។ វិតក្កៈដែលប្រកបដោយការបៀតបៀនអ្នកដទៃ ដោយគិតថា សូមសត្វទាំងនេះត្រូវបៀតបៀនចុះ ឈ្មោះថា **វិហិំសាវិតក្ក** ។ បទថា **បាបកេ** បានដល់ ដែលអាក្រក់ ។ បទថា **អកុសលេ ធម្មេ** បានដល់ ធម៌ដែលកើតអំពីការមិនឈ្លាស ។

[ ១៤៨ ] បទថា **និព្វេធិកបញ្ញា** ( បញ្ញាជាគ្រឿងទម្លុះទម្លាយ ) បានដល់ មគ្គបញ្ញានោះឯងដែលកើតឡើងដល់បុគ្គលដែលច្រើនដោយការនឿយណាយ ។ បទថា **ឧព្វេគពហុលោ** បានដល់ ជាអ្នកច្រើនដោយការរន្ធត់ព្រោះញាណ ។ បទថា **ឧត្តាសពហុលោ** បានដល់ ច្រើនទៅដោយ

ការតក់ស្លុតយ៉ាងខ្លាំងក្លា ។ បទនេះពង្រីកសេចក្ដីនៃពាក្យមុននោះឯង ។ បទថា **ឧក្កណ្ឋនពហុលោ** បានដល់ ជាអ្នកច្រើនទៅដោយសេចក្ដីអផ្សុក ព្រោះបែរមុខឆ្ពោះវិសង្ខារ ក្រៅអំពីសង្ខារ ។ បទថា **អនភិរតិពហុលោ** លោកសម្ដែងដល់ការមិនមានសេចក្ដីត្រេកអរ ដោយអំណាចការនឿយណាយ ។

ឥឡូវនេះព្រះសារីបុត្តត្ថេរលម្អិតសេចក្ដីនោះដោយពាក្យទាំងពីរ ។ ក្នុងបទទាំងនោះ បទថា **ពហិមុខោ** បានដល់ ឆ្ពោះមុខចំពោះព្រះនិព្វានដែលជាចំណែកក្រៅអំពីសង្ខារ ។ បទថា **ន រមតិ** បានដល់ មិនត្រេកអរខ្លាំង ។ បទថា **អនិព្វិទ្ធបុព្វំ** បានដល់ ដែលមិនធ្លាប់ដល់ទីបំផុតក្នុងសង្សារ ដែលមិនដឹងខាងដើមនិងខាងចុងហើយនឿយណាយ ។ បទថា **អប្បទាលិតបុព្វំ** ជាពាក្យពោលដល់អត្ថរបស់បទនោះ អធិប្បាយថា មិនធ្លាប់ទម្លាយដោយការធ្វើទីបំផុតនោះឯង ។ បទថា **លោភក្ខន្ធំ** បានដល់ គំនរលោភៈ ឬចំណែកនៃលោភៈ ។

[ ១៤៩ ] បទថា **ឥមាហិ សោឡសហិ បញ្ញាហិ សមន្នាគតោ** លោកពោលដល់ព្រះអរហន្តដោយកំណត់យ៉ាងឧក្រិដ្ឋ ។

សូម្បីព្រះសោតាបន្ន ព្រះសកទាគាមីនិងព្រះអនាគាមី ក៏រាប់ចូលផងដែរ ព្រោះលោកពោលទុកក្នុងខាងមុខថា ពួកមួយជាអ្នកដល់នូវសេក្ខប្បដិសម្ភិទា ។

អដ្ឋកថា សោឡសបញ្ញានិទ្ទេស ចប់

# អដ្ឋកថា

## បុគ្គលវិសេសនិទ្ទេស

ព្រះសារីបុត្តត្ថេរ សម្ដែងដល់លំដាប់របស់បុគ្គលវិសេសដែលសម្រេចបដិសម្ភិទាដោយបទថា **ទ្វេ បុគ្គលា** ជាដើម ។ ក្នុងបទទាំងនោះ បទថា **បុព្វយោគោ** បានដល់ បុញ្ញបយោគក្នុងអតីតជាតិដែលជាហេតុឲ្យសម្រេចបដិសម្ភិទា ។ បទថា **តេន** បានដល់ ព្រោះហេតុនៃសេចក្ដីព្យាយាមក្នុងកាលមុននោះ ។ សូម្បីបទដ៏សេស ក៏យ៉ាងនោះ ។ បទថា **អតិរេកោ ហោតិ** បានដល់ ជាអ្នកលើសលុប ម្យ៉ាងទៀត លោកពោលថា **អតិរេក** ព្រោះប្រកបដោយវត្ថុដែលប្រសើរ ។ បទថា **អធិកោ ហោតិ** បានដល់ ជាអ្នកក្រៃលែង ។ បទថា **វិសេសោ ហោតិ** បានដល់ ជាអ្នកវិសេសបំផុត ឬឈ្មោះថា **វិសេស** ព្រោះប្រកបដោយវត្ថុដែលវិសេស ។ បទថា **ញាណំ បភិជ្ជតិ** បានដល់ ដល់នូវការបែកធ្លាយក្នុងបដិសម្ភិទាញាណ ។ បទថា **ពហុស្សុតោ** បានដល់ ជាពហុស្សូតដោយអំណាចនៃពុទ្ធវចនៈ ។ បទថា **ទេសនាពហុលោ** បានដល់ ដោយអំណាចនៃធម្មទេសនា ។ បទថា **គរុបនិស្សិតោ** បានដល់ ចូលទៅអាស្រ័យគ្រូ ដែលក្រៃលែងដោយបញ្ញា ។ បទថា **វិហារពហុលោ** បានដល់ ជាអ្នកមានវិហារធម៌ គឺវិ-

បស្សនាច្រើន ឬជាអ្នកមានវិហារធម៌ គឺផលសមាបត្តិច្រើន ។ បទថា **បច្ច-វេក្ខណាពហុលោ** បានដល់ កាលមានវិហារធម៌ គឺវិបស្សនា រមែងជាអ្នកមានការពិចារណាវិបស្សនាច្រើន កាលមានវិហារធម៌ គឺផលសមាបត្តិ រមែងជាអ្នកមានការពិចារណាផលសមាបត្តិច្រើន ។ បទថា **សេក្ខប្បដិ-សម្ភិទប្បត្តោ** បានដល់ នៅជាព្រះសេក្ខៈនៅឡើយសម្រេចបដិសម្ភិទា ។ បទថា **អសេក្ខប្បដិសម្ភិទប្បត្តោ** ក៏យ៉ាងនោះ ។

ក្នុងបទថា **សាវកបារមិប្បត្តោ** នេះមានវិនិច្ឆ័យដូចតទៅនេះថា ការដល់ត្រើយនៃសាវកញ្ញាណ ៦៧ របស់ព្រះមហាសាវក អ្នកប្រសើរជាងសាវកអ្នកមានបញ្ញាច្រើនទាំងឡាយ ឈ្មោះថា បារមី បារមីរបស់ព្រះសាវក ឈ្មោះថា សាវកបារមី ។ អ្នកដល់សាវកបារមីនោះ ឈ្មោះថា **សាវក-បារមិប្បត្តោ** ។ បាឋៈថា **សាវកបារមិតាប្បត្តោ** ក៏មាន ។ មហាសាវកនោះ ជាអ្នករក្សា និងជាអ្នកបំពេញសាវកញ្ញាណ ៦៧ ឈ្មោះថា បរមៈ ញាណកិរិយា ៦៧ របស់បរមៈនោះ ការៈ ឬកម្មនៃបរមៈនោះ ឈ្មោះថា បារមី បារមីរបស់សាវកៈនោះ ឈ្មោះថា សាវកបារមី ។ អ្នកដល់សាវកបារមីនោះ ឈ្មោះថា **សាវកបារមិប្បត្តោ** ។ បទថា **សាវកបារមិប្ប-ត្តោ** បានដល់ សាវកអង្គណាមួយ មានព្រះមហាមោគ្គល្លានត្ថេរជាដើម ។

ព្រះសារីបុត្តត្ថេរ ពោលថា **ឯកោ បច្ចេកសម្ពុទ្ធោ** ព្រោះពោលដោយសាវកដែលសម្រេចដល់សាវកបារមី មិនមានសាវកដទៃក្រៃលែងជាង ។ ព្រះសារីបុត្តត្ថេរ សម្តែងសរុបសេចក្តីដែលពោលហើយទៀត ដោយបទថា **បញ្ញាបភេទកុសលោ** ជាដើម ញាណមានចំនួនមិនតិច លោកពោលទុកហើយដោយចំណែកច្រើនក្នុងញាណកថា ។ បញ្ញាសូម្បីមានតែមួយលោកក៏ធ្វើឲ្យផ្សេងគ្នា ដោយអំណាចនៃអាការផ្សេងៗ ហើយពោលទុកជាចំណែកច្រើនក្នុងបញ្ញាកថា នេះជាសេចក្តីវិសេសដោយប្រការដូច្នេះ ។

អដ្ឋកថា បុគ្គលវិសេសនិទ្ទេស ចប់

អដ្ឋកថា មហាបញ្ញាកថា ចប់

# សុត្តន្តបិដក

## បញ្ញាវគ្គ ឥទ្ធិកថា

[ ១៥០ ] ឫទ្ធិ ប្រែថាដូចម្តេច ឫទ្ធិមានប៉ុន្មាន ឫទ្ធិមានភូមិប៉ុន្មាន មានបាទប៉ុន្មាន មានបទប៉ុន្មាន មានមូលប៉ុន្មាន ។

ត្រង់សំណួរថា ឫទ្ធិប្រែថាដូចម្តេច ចម្លើយថា ឫទ្ធិប្រែថាការសម្រេច ។ ត្រង់សំណួរថា ឫទ្ធិមានប៉ុន្មាន ចម្លើយថា ឫទ្ធិមាន ១០ ឫទ្ធិមានភូមិ ៤ មានបាទ ៤ មានបទ ៨ មានមូល ១៦ ។

[ ១៥១ ] ឫទ្ធិ ១០ តើដូចម្តេច ។ ឫទ្ធិ គឺការអធិដ្ឋាន ( អធិដ្ឋានឥទ្ធិ ) ១ ឫទ្ធិ គឺការធ្វើឲ្យប្លែក ( វិកុព្វនឥទ្ធិ ) ១ ឫទ្ធិសម្រេចអំពីចិត្ត ( មនោមយឥទ្ធិ ) ១ ឫទ្ធិ គឺការផ្សាយចេញនៃញាណ ( ញាណវិប្ផារឥទ្ធិ ) ១ ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ ( សមាធិវិប្ផារឥទ្ធិ ) ១ ឫទ្ធិ គឺភាពអ្នកខ្ពង់ខ្ពស់ ( អរិយឥទ្ធិ ) ១ ឫទ្ធិកើតអំពីផលកម្ម ( កម្មវិបាកជឥទ្ធិ ) ១ ឫទ្ធិរបស់បុគ្គលអ្នកមានបុណ្យ ( បុញ្ញវន្តឥទ្ធិ ) ១ ឫទ្ធិសម្រេចអំពីវិជ្ជា ( វិជ្ជាមយឥទ្ធិ ) ១ ឫទ្ធិ ដោយអត្ថថា សម្រេច ព្រោះបច្ច័យនៃការប្រកបត្រូវក្នុងកិច្ចនោះៗ ( ឥជ្ឈនដ្ឋឥទ្ធិ ) ១ ។

[ ១៥២ ] ឫទ្ធិមានភូមិ ៤ តើដូចម្តេច ។ ភូមិជាទីកើតនៃវិវេក គឺបឋមជ្ឈាន ១ ភូមិជាទីកើតនៃបីតិនិងសុខៈ គឺទុតិយជ្ឈាន ១ ភូមិជាទីកើតនៃឧបេក្ខានិងសុខៈ គឺតតិយជ្ឈាន ១ ភូមិជាទីកើតនៃវេទនាមិនទុក្ខមិនសុខ គឺចតុត្ថជ្ឈាន ១ នេះឯងភូមិទាំង ៤ របស់ឫទ្ធិ ប្រព្រឹត្តទៅដើម្បីបាននូវ

ឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ដើម្បីការធ្វើឲ្យប្លែកនៃឫទ្ធិ ដើម្បីបង្ហូរទៅនៃឫទ្ធិ ដើម្បីភាពនៃការស្ទាត់ក្នុងឫទ្ធិ ដើម្បីសេចក្តីក្លៀវក្លាក្នុងឫទ្ធិ ។

[ ១៥៣ ] ឫទ្ធិមានបាទ ៤ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទ ប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ១ នេះឯងបាទទាំង ៤ របស់ឫទ្ធិ ប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ដើម្បីការធ្វើឲ្យប្លែកនៃឫទ្ធិ ដើម្បីបង្ហូរទៅនៃឫទ្ធិ ដើម្បីភាពនៃការស្ទាត់ក្នុងឫទ្ធិ ដើម្បីសេចក្តីក្លៀវក្លាក្នុងឫទ្ធិ ។

[ ១៥៤ ] ឫទ្ធិមានបទ ៨ តើដូចម្តេច ។ បើភិក្ខុអាស្រ័យនូវឆន្ទៈហើយបានសមាធិ គឺបាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ១ ឆន្ទៈមិនមែនសមាធិ សមាធិមិនមែនឆន្ទៈ ឆន្ទៈដោយឡែក សមាធិដោយឡែក ១ បើភិក្ខុអាស្រ័យនូវវីរិយៈហើយបានសមាធិ គឺបាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ១ វីរិយៈមិនមែនសមាធិ សមាធិមិនមែនវីរិយៈ វីរិយៈដោយឡែក សមាធិដោយឡែក ១ បើភិក្ខុអាស្រ័យចិត្តហើយបានសមាធិ គឺបាននូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ១ ចិត្តមិនមែនសមាធិ សមាធិមិនមែនចិត្ត ចិត្តដោយឡែក សមាធិដោយឡែក ១ បើភិក្ខុអាស្រ័យនូវវីមំសាហើយបានសមាធិ គឺបាននូវភាពនៃចិត្តមានអារម្មណ៍តែមួយ ១ វីមំសាមិនមែនសមាធិ សមាធិមិនមែនវីមំសា វីមំសាដោយឡែក សមាធិដោយឡែក ១

នេះឯងបទ ៨ របស់ឫទ្ធិ ប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ដើម្បីការធ្វើឲ្យប្លែកនៃឫទ្ធិ ដើម្បីបង្ហូរទៅនៃឫទ្ធិ ដើម្បីកាពនៃការស្ទាត់ក្នុងឫទ្ធិ ដើម្បីសេចក្តីក្លៀវក្លាក្នុងឫទ្ធិ ។

[ ១៥៥ ] ឫទ្ធិមានមូល ១៦ តើដូចម្តេច ។ ចិត្តដែលមិនទ្រោមរមែងមិនញាប់ញ័រក្នុងការខ្ជិលច្រអូស ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ( ទុកជាមូល ) ១ ចិត្តដែលមិនប៉ោងឡើង រមែងមិនញាប់ញ័រក្នុងសេចក្តីរើរវាយ ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ( ទុកជាមូល ) ១ ចិត្តដែលមិនទន់ទោរ រមែងមិនញាប់ញ័រក្នុងរាគៈ ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនបង្អោន រមែងមិនញាប់ញ័រក្នុងព្យាបាទ ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលអាស្រ័យ រមែងមិនញាប់ញ័រក្នុងទិដ្ឋិ ហេតុនោះឈ្មោះថា ជាចិត្តមិនញាប់ញ័រ ១ ចិត្តដែលមិនជាប់ចំពាក់រមែងមិនញាប់ញ័រក្នុងឆន្ទរាគ ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលផុតស្រឡះ រមែងមិនញាប់ញ័រក្នុងកាមរាគ ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលគ្មានគ្រឿងប្រកប រមែងមិនញាប់ញ័រក្នុងកិលេស ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលគ្មានភ្លឺគឺកិលេស រមែងមិនញាប់ញ័រក្នុងភ្លឺ គឺកិលេស ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានអារម្មណ៍តែមួយ រមែងមិនញាប់ញ័រក្នុងកិលេស មានសភាពផ្សេង ៗ ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសទ្ធាថែរក្សា រមែងមិនញាប់ញ័រក្នុងវត្ថុមិនគួរជឿ ហេតុនោះឈ្មោះថា ចិត្តមិនញាប់

ញ័រ ១ ចិត្តដែលមានវីរិយៈថែរក្សា រមែងមិនញាប់ញ័រក្នុងការខ្ជិលច្រអូស ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសតិថែរក្សា រមែងមិនញាប់ញ័រក្នុងប្រមាទ ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានសមាធិថែរក្សា រមែងមិនញាប់ញ័រ ក្នុងសេចក្តីរាយមាយ ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលមានបញ្ញាថែរក្សា រមែងមិនញាប់ញ័រក្នុងអវិជ្ជា ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ ចិត្តដែលភ្លឺស្វាង រមែងមិនញាប់ញ័រក្នុងងងឹត គឺអវិជ្ជា ហេតុនោះឈ្មោះថា ចិត្តមិនញាប់ញ័រ ១ នេះមូល ១៦ របស់ឫទ្ធិ ប្រព្រឹត្តទៅដើម្បីបាននូវឫទ្ធិ ដើម្បីបានចំពោះនូវឫទ្ធិ ដើម្បីធ្វើឲ្យប្លែកនូវឫទ្ធិ ដើម្បីបង្ករទៅនៃឫទ្ធិ ដើម្បីភាពនៃការស្ទាត់ជំនាញក្នុងឫទ្ធិ ដើម្បីសេចក្តីក្លៀវក្លាក្នុងឫទ្ធិ ។

[ ១៥៦ ] ឫទ្ធិ គឺការអធិដ្ឋានតើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ តាក់តែងនូវឫទ្ធិបានច្រើនប្រការ គឺមនុស្សម្នាក់ធ្វើឲ្យទៅជាច្រើននាក់ ក៏បាន មនុស្សច្រើននាក់ធ្វើឲ្យទៅជាម្នាក់វិញក៏បាន ដើរ ( ទម្លុះ ) ទៅកាន់ទីវាល ទីខាងក្រៅ ទីក្រៅជញ្ជាំង ទីក្រៅកំពែង ទីក្រៅភ្នំឥតមានទើសទាក់ ដូចគេដើរក្នុងអាកាសក៏បាន ធ្វើនូវការងើបមុជក្នុងផែនដី ដូចគេងើបមុជក្នុងទឹកក៏បាន ដើរលើទឹកឥតមានបែកធ្លាយ ដូចគេដើរលើផែនដីក៏បាន ទៅទាំងភ្នែនក្នុងអាកាសដូចបក្សីសកុណជាតិក៏បាន យកដៃស្ទាបអង្អែលនូវព្រះចន្ទ និងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅទាំងកាយរហូតដល់ព្រហ្មលោក

ក៏បាន ។

ពាក្យថា ក្នុងសាសនានេះ គឺក្នុងទិដ្ឋិនេះ ក្នុងចំណង់នេះ ក្នុងសេចក្ដីគាប់ចិត្តនេះ ក្នុងសេចក្ដីពេញចិត្តនេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសាសនានៃសាស្ដានេះ ហេតុនោះលោកពោលថា ក្នុងសាសនានេះ ។

ពាក្យថា ភិក្ខុ បានដល់ភិក្ខុជាកល្យាណបុថុជ្ជនក្ដី ភិក្ខុជាសេក្ខៈក្ដី ជាព្រះអរហន្តមានធម៌មិនកម្រើកក្ដី ។

ពាក្យថា តាក់តែងនូវឫទ្ធិបានច្រើនប្រការ គឺតាក់តែងនូវឫទ្ធិមានប្រការផ្សេងៗ ។

ត្រង់ពាក្យថា មនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ គឺភិក្ខុតែមួយរូបទេដោយប្រក្រតី តែនឹកចង់ឲ្យបានច្រើនរូប គឺនឹកចង់ឲ្យទៅជាមួយរយរូបក្ដី មួយពាន់រូបក្ដី មួយម៉ឺនរូបក្ដី លុះនឹកចង់ហើយ ក៏អធិដ្ឋានដោយញាណថា សូមឲ្យអាត្មាអញមានរូបច្រើន ក៏បានរូបច្រើន ដូចព្រះចុល្លបន្ថកៈមានអាយុសូម្បីមានរូបតែមួយ ក៏ធ្វើឲ្យបានច្រើនរូប ឯភិក្ខុដែលមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញក្នុងចិត្តនោះ សូម្បីមានរូបតែមួយ ក៏ធ្វើឲ្យទៅជាច្រើនរូបបានយ៉ាងនោះឯង ។

ត្រង់ពាក្យថា មនុស្សច្រើននាក់ ធ្វើឲ្យទៅជាម្នាក់វិញ គឺភិក្ខុច្រើនរូបដោយប្រក្រតី តែនឹកចង់ឲ្យទៅជាម្នាក់វិញ លុះនឹកចង់ហើយក៏អធិដ្ឋានដោយញាណថា សូមឲ្យអាត្មាអញមានរូបតែមួយវិញ ក៏បានរូបតែមួយ ដូចព្រះ

ចុល្លបន្ថកមានអាយុ សូម្បីមានរូបច្រើនក៏រួមមកតែរូបមួយវិញ ឯភិក្ខុដែលមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញក្នុងចិត្តនោះ សូម្បីមានរូបច្រើនក៏រួមមកតែរូបមួយវិញបាន យ៉ាងនោះឯង ។

ពាក្យថា ទីវាល បានដល់ទីដែលវត្ថុអ្វីមួយមិនរាំង មិនបិទបាំង ជាទីវាល ។

ពាក្យថា ទីខាងក្រៅ បានដល់ទីដែលមានវត្ថុអ្វីមួយរាំង បាំងបិទ គ្រប ។

ពាក្យថា ដើរ ( ទម្លុះ ) ទៅកាន់ទីក្រៅជញ្ជាំង ទីក្រៅកំពែង ទីក្រៅភ្នំ មិនទើសទាក់ដូចគេដើរក្នុងអាកាស គឺភិក្ខុអ្នកបាននូវសមាបត្តិ មានអាកាសកសិណជាអារម្មណ៍ដោយប្រក្រតី តែងនឹកចង់ទៅកាន់ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ លុះនឹកចង់ហើយ ក៏អធិដ្ឋានដោយញាណថា សូមឲ្យប្រទេសនុ៎ះទៅជាអាកាស ទីនោះក៏បានទៅជាអាកាស ភិក្ខុនោះក៏ដើរ ( ទម្លុះ ) ទៅកាន់ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ មិនទើសទាក់ ដូចពួកមនុស្សដែលមិនមានឫទ្ធិដោយប្រក្រតី កាលដើរទៅ មិនជាប់ចំពាក់ក្នុងទីដែលមិនមានវត្ថុអ្វីមួយរាំង បិទបាំងឡើយ ឯភិក្ខុដែលមានឫទ្ធិ ដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះតែងដើរ ( ទម្លុះ ) ទៅកាន់ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំ មិនទើសទាក់ ដូចគេដើរទៅក្នុងអាកាសយ៉ាងនោះឯង ។

ពាក្យថា ធ្វើនូវការងើបមុជក្នុងផែនដីដូចគេងើបមុជក្នុងទឹក គឺភិក្ខុដែលបាននូវសមាបត្តិ មានអាបោកសិណជាអារម្មណ៍ដោយប្រក្រតី តែងនឹកចង់

ដើរក្នុងដី លុះនឹកចង់ហើយ ក៏អធិដ្ឋានដោយញាណថា សូមឲ្យ ( ផែនដីត្រង់ទីនេះ ) ទៅជាទឹក ទីនោះក៏បានទៅជាទឹក ភិក្ខុនោះក៏ធ្វើនូវការងើបមុជក្នុងផែនដី ដូចពួកមនុស្សដែលមិនមានឫទ្ធិដោយប្រក្រតី ធ្វើនូវការងើបមុជក្នុងទឹក ឯភិក្ខុដែលមានឫទ្ធិ បានដល់ហើយនូវការស្ទាត់ជំនាញ ក្នុងចិត្តនោះ តែងធ្វើនូវការងើបមុជក្នុងផែនដី ដូចគេងើបមុជក្នុងទឹកបានយ៉ាងនោះឯង ។

ពាក្យថា ដើរលើទឹកមិនបែកធ្លាយ ដូចគេដើរលើផែនដី គឺភិក្ខុបាននូវសមាបត្តិ មានបឋវីកសិណជាអារម្មណ៍ដោយប្រក្រតី តែងនឹកចង់ដើរលើទឹក លុះនឹកចង់ហើយក៏អធិដ្ឋានដោយញាណថា សូមឲ្យ ( ទឹកត្រង់ទីនេះ ) ទៅជាផែនដីដូច្នេះ ទឹកក៏ទៅជាផែនដី ភិក្ខុនោះដើរទៅលើទឹកមិនបែកធ្លាយ ដូចពួកមនុស្សមិនមានឫទ្ធិដោយប្រក្រតី ដើរលើផែនដីមិនបែកធ្លាយ យ៉ាងណា ឯភិក្ខុដែលមានឫទ្ធិដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ដើរទៅលើទឹកមិនបែកធ្លាយ ដូចគេដើរលើផែនដី យ៉ាងនោះឯង ។

ពាក្យថា ទៅទាំងភ្នែនក្នុងអាកាស ដូចបក្សីសកុណជាតិ គឺភិក្ខុដែលបាននូវសមាបត្តិ មានបឋវីកសិណជាអារម្មណ៍ដោយប្រក្រតី តែងនឹកចង់ដើរក្នុងអាកាស លុះនឹកចង់ហើយ ក៏អធិដ្ឋានដោយញាណថា សូមឲ្យអាកាសទៅជាផែនដីដូច្នេះ អាកាសក៏ទៅជាផែនដី ភិក្ខុនោះដើរក្តី ឈរក្តី អង្គុយក្តី សិងក្តី ក្នុងអាកាសទទេបាន ដូចពួកមនុស្សដែលមិនមានឫទ្ធិដោយប្រក្រតី ដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី លើផែនដីយ៉ាងណា ឯ

ភិក្ខុដែលមានឫទ្ធិ បានដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ដើរក្តី ឈរក្តី អង្គុយក្តី សិងក្តីក្នុងអាកាសទទេដូចបក្សីសកុណជាតិ យ៉ាងនោះឯង ។

ពាក្យថា យកដៃស្ទាបអង្អែលនូវព្រះចន្ទនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ គឺភិក្ខុដែលមានឫទ្ធិក្នុងសាសនានេះ ដែលបានដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ជាអ្នកអង្គុយ ឬសិង នឹកចង់ស្ទាបអង្អែលនូវព្រះចន្ទនិងព្រះអាទិត្យ លុះនឹកចង់ហើយក៏អធិដ្ឋានដោយញាណថា សូមឲ្យ ( ព្រះចន្ទឬព្រះអាទិត្យ ) មកនៅក្នុងហត្ថបាស ( ព្រះចន្ទឬព្រះអាទិត្យ ) ក៏បានមកនៅក្នុងហត្ថបាស ភិក្ខុនោះជាអ្នកអង្គុយ ឬសិង យកដៃទៅពាល់ស្ទាបអង្អែលនូវព្រះចន្ទនិងព្រះអាទិត្យបាន ដូចពួកមនុស្ស ដែលមិនមានឫទ្ធិដោយប្រក្រតី ពាល់ស្ទាបអង្អែលនូវវត្ថុអ្វីនីមួយ ជារបស់មានរូបតាំងនៅក្នុងហត្ថបាសយ៉ាងណា ឯភិក្ខុដែលមានឫទ្ធិ បានដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ជាអ្នកអង្គុយឬសិងយកដៃទៅពាល់ស្ទាបអង្អែលនូវព្រះចន្ទនិងព្រះអាទិត្យយ៉ាងនោះឯង ។

ពាក្យថា ញុំាងអំណាចឲ្យប្រព្រឹត្តទៅទាំងកាយ រហូតដល់ព្រហ្មលោក គឺបើភិក្ខុមានឫទ្ធិ ដែលបានសម្រេចហើយនូវការស្ទាត់ជំនាញ ក្នុងចិត្តនោះ មានប្រាថ្នាដើម្បីទៅកាន់ព្រហ្មលោក ក៏អធិដ្ឋាន ( នូវវត្ថុ ) ក្នុងទីឆ្ងាយឲ្យមកក្នុងទីជិតថា សូមឲ្យ ( វត្ថុនោះ ) មកតាំងនៅក្នុងទីជិត ( វត្ថុនោះ ) ក៏មកតាំងនៅក្នុងទីជិតក៏បាន អធិដ្ឋាន ( នូវវត្ថុ ) ក្នុងទីជិត ឲ្យទៅក្នុងទីឆ្ងាយថា សូមឲ្យ ( វត្ថុនេះ ) តាំងនៅក្នុងទីឆ្ងាយ ( វត្ថុនោះ ) ក៏តាំង

នៅក្នុងទីឆ្ងាយក៏បាន អធិដ្ឋាននូវវត្ថុច្រើនឲ្យទៅជាវត្ថុតិចថា សូមឲ្យវត្ថុនេះមានចំនួនតិច វត្ថុនោះក៏ទៅជាតិចក៏បាន អធិដ្ឋាននូវវត្ថុតិចឲ្យទៅជាវត្ថុច្រើនថា សូមឲ្យវត្ថុនេះទៅជាវត្ថុច្រើន វត្ថុនោះក៏ទៅជាច្រើនក៏បាន ( ភិក្ខុនោះ ) ឃើញច្បាស់នូវរូបនៃព្រហ្មនោះដោយចក្ខុដូចជាទិព្វ ឮសំឡេងនៃព្រហ្មនោះដោយសោតធាតុដូចជាទិព្វ ដឹងច្បាស់នូវចិត្តនៃព្រហ្មនោះ ដោយញាណជាគ្រឿងកំណត់នូវចិត្ត បើភិក្ខុមានឫទ្ធិដែលបានសម្រេចនូវការស្ទាត់ជំនាញក្នុងចិត្តនោះ មានប្រាថ្នាដើម្បីទៅកាន់ព្រហ្មលោកដោយកាយដ៏ប្រាកដក៏បង្អោនចិត្តទៅដោយអំណាចនៃកាយ អធិដ្ឋានចិត្ត ដោយអំណាចនៃកាយ លុះបង្អោនចិត្តទៅដោយអំណាចនៃកាយ អធិដ្ឋានចិត្ត ដោយអំណាចនៃកាយហើយ ទើបចុះទៅកាន់សុខសញ្ញាផង កាន់លហុសញ្ញាផង ហើយទៅកាន់ព្រហ្មលោកដោយកាយដ៏ប្រាកដបាន បើភិក្ខុមានឫទ្ធិបានសម្រេចនូវការស្ទាត់ជំនាញក្នុងចិត្តនោះ ជាអ្នកមានប្រាថ្នាដើម្បីទៅកាន់ព្រហ្មលោក ដោយកាយមិនប្រាកដ ក៏បង្អោនកាយទៅដោយអំណាចនៃចិត្ត អធិដ្ឋាននូវកាយដោយអំណាចនៃចិត្ត លុះបង្អោនកាយទៅដោយអំណាចនៃចិត្ត អធិដ្ឋាននូវកាយដោយអំណាចនៃចិត្តហើយ ទើបចុះកាន់សុខសញ្ញាផង កាន់លហុសញ្ញាផង ហើយទៅកាន់ព្រហ្មលោកដោយកាយមិនប្រាកដ ភិក្ខុនោះ និម្មិតរូបខ្លួនដែលសម្រេចអំពីចិត្តមានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនថោកទាប ទៅខាងមុខនៃព្រហ្មនោះ បើភិក្ខុមានឫទ្ធិនោះចង្ក្រម រូបនិមិត្តក៏ចង្ក្រមក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះឈរ រូបនិមិត្តក៏ឈរក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិ

នោះអង្គុយ រូបនិមិត្តនោះ ក៏អង្គុយក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះសិង រូបនិមិត្តក៏សិងក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះបញ្ចេញផ្សែង រូបនិម្មិតក៏បញ្ចេញផ្សែងក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះឆេះទៅជាភ្លើង រូបនិមិត្តក៏ឆេះទៅជាភ្លើង ក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះសម្តែងធម៌ រូបនិមិត្តក៏សម្តែងធម៌ក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះសួរនូវប្រស្នា រូបនិម្មិតក៏សួរនូវប្រស្នាក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះត្រូវគេសួរប្រស្នា ហើយកំពុងដោះស្រាយ រូបនិមិត្តនោះក៏ត្រូវគេសួរប្រស្នា ហើយកំពុងដោះស្រាយក្នុងទីនោះដែរ បើភិក្ខុមានឫទ្ធិនោះ កំពុងឈរចរចាធ្វើសាកច្ឆាជាមួយព្រហ្មនោះ រូបនិមិត្តក៏ឈរចរចាធ្វើសាកច្ឆាជាមួយនឹងព្រហ្មនោះក្នុងទីនោះដែរ ភិក្ខុមានឫទ្ធិនោះធ្វើនូវការណាបាន រូបនិមិត្តក៏ធ្វើនូវការនោះបានដែរ នេះឫទ្ធិគឺការអធិដ្ឋាន ដូចសេចក្តីដែលពោលមកនេះឯង ។

[ ១៥៧ ] ឫទ្ធិ គឺការធ្វើឲ្យប្លែក តើដូចម្តេច ។ ភិក្ខុនាមអភិភូ ជាសាវ័ករបស់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធទ្រង់ព្រះនាមសិខី លោកឋិតនៅឰដ៏ព្រហ្មលោក អាចញុំាងលោកធាតុទាំងមួយពាន់ ឲ្យដឹងច្បាស់ដោយសំឡេងបាន ព្រះអភិភូនោះ មានកាយប្រាកដសម្តែងធម៌ក៏បាន មានកាយមិនប្រាកដសម្តែងធម៌ក៏បាន មានកាយពាក់កណ្តាលខាងក្រោមប្រាកដសម្តែងធម៌ក៏បាន មានកាយពាក់កណ្តាលខាងលើ មិនប្រាកដសម្តែងធម៌ក៏បាន មានកាយពាក់កណ្តាលខាងលើប្រាកដ សម្តែងធម៌ក៏បាន មានកាយពាក់កណ្តាលខាងក្រោមមិនប្រាកដសម្តែងធម៌ក៏បាន ព្រះអភិភូនោះ លះបង់

ភេទជាប្រក្រតីហើយសម្ដែងភេទជាកុមារខ្លះ សម្ដែងភេទជានាគខ្លះ សម្ដែងភេទជាគ្រុឌខ្លះ សម្ដែងភេទជាយក្ខខ្លះ សម្ដែងភេទជាអសុរខ្លះ សម្ដែងភេទជាព្រះឥន្ទខ្លះ សម្ដែងភេទជាទេវតាខ្លះ សម្ដែងភេទជាព្រហ្មខ្លះ សម្ដែងភេទជាសមុទ្ទខ្លះ សម្ដែងភេទជាភ្នំខ្លះ សម្ដែងភេទជាព្រៃខ្លះ សម្ដែងភេទជាសីហៈខ្លះ សម្ដែងភេទជាខ្លាធំខ្លះ សម្ដែងភេទជាខ្លាដំបងខ្លះ សម្ដែងភេទជាដំរីខ្លះ សម្ដែងភេទជាសេះខ្លះ សម្ដែងភេទជារថខ្លះ សម្ដែងភេទជាពលថ្មើរជើងខ្លះ សម្ដែងភេទជាកងទាហានប្លែកៗគ្នាខ្លះ នេះឫទ្ធិ គឺការធ្វើឲ្យប្លែក ។

[ ១៥៨ ] ឫទ្ធិសម្រេចអំពីចិត្ត តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះនិមិត្តនូវកាយ មានរូបដែលសម្រេចអំពីចិត្ត មានអវយវៈធំតូចសព្វគ្រប់ មានឥន្ទ្រិយមិនថោកថយ ជាកាយដទៃអំពីកាយនេះ ប្រៀបដូចបុរសដកចេញនូវបណ្ដូលអំពីស្មៅយាប្លង បុរសនោះមានសេចក្ដីដឹងយ៉ាងនេះថា នេះឯងស្មៅយាប្លង នេះបណ្ដូល ឯស្មៅយាប្លងដោយឡែក បណ្ដូលដោយឡែក បណ្ដូលគេដកចេញមកអំពីស្មៅយាប្លងហ្នឹងឯង មួយទៀត ប្រៀបដូចបុរស ហូតដាវចេញអំពីស្រោម បុរសនោះមានសេចក្ដីដឹងយ៉ាងនេះថា នេះដាវ នេះស្រោម ឯដាវដោយឡែក ស្រោមដោយឡែក ដាវគេហូតចេញមកអំពីស្រោមហ្នឹងឯង ពុំនោះសោត ប្រៀបដូចបុរសទាញយកពស់ចេញអំពីត្រក បុរសនោះមានសេចក្ដីដឹងយ៉ាងនេះថា នេះពស់ នេះត្រក ឯពស់ដោយឡែក ត្រកដោយឡែក ពស់គេទាញចេញមកអំពីត្រកហ្នឹងឯង

យ៉ាងណាមិញ ភិក្ខុនិម្មិតនូវកាយ មានរូបដែលសម្រេចអំពីចិត្ត មានអវយវៈធំតូចសព្វគ្រប់ មានឥន្ទ្រិយមិនថោកថយ ជាកាយដទៃអំពីកាយនេះ ក៏យ៉ាងនោះដែរ នេះឫទ្ធិសម្រេចអំពីចិត្ត ។

[ ១៥៩ ] ឫទ្ធិ គឺការផ្សាយចេញនៃញាណ តើដូចម្តេច ។ ឈ្មោះថាឫទ្ធិ គឺការផ្សាយចេញនៃញាណ ព្រោះសម្រេចអត្ថនៃការលះបង់នូវសេចក្តីសម្គាល់ ថាទៀង ដោយការពិចារណាឃើញ ថាមិនទៀង ឈ្មោះថាឫទ្ធិ គឺការផ្សាយចេញនៃញាណ ព្រោះសម្រេចអត្ថនៃការលះបង់នូវសេចក្តីសម្គាល់ជាសុខដោយការពិចារណាឃើញថាជាទុក្ខ នូវសេចក្តីសម្គាល់ថាខ្លួនដោយការពិចារណាឃើញ ថាមិនមែនខ្លួន នូវសេចក្តីត្រេកត្រអាលដោយការពិចារណាឃើញថាជាសេចក្តីនឿយណាយ នូវតម្រេកដោយការពិចារណាឃើញនូវវិរាគធម៌ នូវហេតុជាទីកើតដោយការពិចារណាឃើញនូវការរំលត់ នូវសេចក្តីប្រកាន់ដោយការពិចារណាឃើញនូវការលះបង់ ( ដូចជា ) ឫទ្ធិ គឺការផ្សាយចេញ នៃញាណរបស់ព្រះពក្កុលៈមានអាយុ ឫទ្ធិគឺការផ្សាយចេញនៃញាណរបស់ព្រះសំកិច្ចៈមានអាយុ និងឫទ្ធិ គឺការផ្សាយចេញនៃញាណរបស់ព្រះភូតបាលមានអាយុ នេះឫទ្ធិ គឺការផ្សាយចេញនៃញាណ ។

[ ១៦០ ] ឫទ្ធិ គឺការផ្សាយចេញនៃសមាធិតើដូចម្តេច ។ ឈ្មោះថាឫទ្ធិ គឺការផ្សាយចេញនៃសមាធិ ព្រោះសម្រេចអត្ថនៃការលះបង់នូវនីវរណៈដោយបឋមជ្ឈាន ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ ព្រោះ

សម្រេចអត្ថនៃការលះបង់នូវវិតក្កៈនិងវិចារៈដោយទុតិយជ្ឈាន ព្រោះសម្រេចអត្ថនៃការលះបង់នូវបីតិដោយតតិយជ្ឈាន ។បេ។ ព្រោះសម្រេចអត្ថនៃការលះបង់នូវសុខនិងទុក្ខដោយចតុត្ថជ្ឈាន ។បេ។ ព្រោះសម្រេចអត្ថនៃការលះបង់នូវរូបសញ្ញា នូវបដិឃសញ្ញា នូវនានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ។បេ។ ព្រោះសម្រេចអត្ថនៃការលះបង់នូវអាកាសានញ្ចាយតនសញ្ញាដោយវិញ្ញាណញ្ចាយតនសមាបត្តិ ។បេ។ ព្រោះសម្រេចអត្ថនៃការលះបង់នូវវិញ្ញាណញ្ចាយតនសញ្ញាដោយអាកិញ្ចញ្ញាយតនសមាបត្តិ ។បេ។ ឈ្មោះថា ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ ព្រោះសម្រេចអត្ថនៃការលះបង់នូវអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ( ដូចជា ) ឫទ្ធិ គឺការផ្សាយចេញនៃសមាធិរបស់ព្រះសារីបុត្តមានអាយុ ឫទ្ធិ គឺការផ្សាយចេញនៃសមាធិរបស់ព្រះសញ្ជីវៈមានអាយុ ឫទ្ធិ គឺការផ្សាយចេញនៃសមាធិរបស់ព្រះខាណុកោណ្ឌញ្ញៈមានអាយុ ឫទ្ធិ គឺការផ្សាយចេញនៃសមាធិរបស់ឧបាសិកាឈ្មោះឧត្តរា ឫទ្ធិ គឺការផ្សាយចេញនៃសមាធិរបស់ឧបាសិកាឈ្មោះសាមាវតី នេះឫទ្ធិ គឺការផ្សាយចេញនៃសមាធិ ។

[ ១៦១ ] ឫទ្ធិ គឺភាពអ្នកខ្ពង់ខ្ពស់ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ បើប្រាថ្នាថា អាត្មាអញគប្បីមានសេចក្តីសម្គាល់ថា មិនគួរខ្ពើម ក្នុងរបស់គួរខ្ពើម លោកក៏ជាអ្នកសម្គាល់ថា មិនគួរខ្ពើមក្នុងរបស់នោះ បើប្រាថ្នាថា អាត្មាអញគប្បីមានសេចក្តីសម្គាល់ថា គួរខ្ពើម ក្នុងរបស់មិនគួរខ្ពើម លោកក៏ជាអ្នកសម្គាល់ថា គួរខ្ពើមក្នុងរបស់នោះ បើប្រាថ្នាថា អាត្មា

អញគប្បីមានសេចក្តីសម្គាល់ថា មិនគួរខ្ពើមក្នុងរបស់គួរខ្ពើមផង ក្នុងរបស់មិនគួរខ្ពើមផង លោកក៏ជាអ្នកសម្គាល់ថា មិនគួរខ្ពើមក្នុងរបស់នោះ បើប្រាថ្នាថា អាត្មាអញគប្បីមានសេចក្តីសម្គាល់ថា គួរខ្ពើម ក្នុងរបស់មិនគួរខ្ពើមផង ក្នុងរបស់គួរខ្ពើមផង លោកក៏ជាអ្នកសម្គាល់ថា គួរខ្ពើមក្នុងរបស់នោះ បើប្រាថ្នាថា អាត្មាអញគប្បីវៀរបង់នូវបទទាំង ២ នោះ គឺក្នុងរបស់គួរខ្ពើមនិងមិនគួរខ្ពើម ហើយជាអ្នកមានស្មារតីដឹងខ្លួន ប្រកបដោយឧបេក្ខា លោកក៏ជាអ្នកមានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា ក្នុងរបស់នោះ ។

ភិក្ខុមានសេចក្តីសម្គាល់ថា មិនគួរខ្ពើមក្នុងរបស់គួរខ្ពើម តើដូចម្តេច ។ ភិក្ខុផ្សាយមេត្តាចិត្ត ឬពិចារណាថាជាធាតុក្នុងវត្ថុមិនជាទីប្រាថ្នា យ៉ាងនេះឈ្មោះថា អ្នកមានសេចក្តីសម្គាល់ថា មិនគួរខ្ពើមក្នុងវត្ថុគួរខ្ពើម ។

ភិក្ខុមានសេចក្តីសម្គាល់ថា គួរខ្ពើមក្នុងរបស់មិនគួរខ្ពើម តើដូចម្តេច ។ ភិក្ខុផ្សាយចិត្តថាជាអសុភ ឬពិចារណាថា ជារបស់មិនទៀងក្នុងវត្ថុជាទីប្រាថ្នា យ៉ាងនេះឈ្មោះថា អ្នកមានសេចក្តីសម្គាល់ថា គួរខ្ពើមក្នុងរបស់មិនគួរខ្ពើម ។

ភិក្ខុមានសេចក្តីសម្គាល់ថា មិនគួរខ្ពើមក្នុងរបស់គួរខ្ពើមផង ក្នុងរបស់មិនគួរខ្ពើមផង តើដូចម្តេច ។ ភិក្ខុផ្សាយមេត្តាចិត្ត ឬពិចារណាថាជាធាតុក្នុងវត្ថុមិនជាទីប្រាថ្នាផង ក្នុងវត្ថុជាទីប្រាថ្នាផង យ៉ាងនេះឈ្មោះថា អ្នកមានសេចក្តីសម្គាល់ថា មិនគួរខ្ពើម ក្នុងរបស់គួរខ្ពើមផង ក្នុងរបស់មិនគួរខ្ពើម

ផង ។

ភិក្ខុមានសេចក្ដីសម្គាល់ថា គួរខ្ពើមក្នុងរបស់មិនគួរខ្ពើមផង ក្នុងរបស់គួរខ្ពើមផង តើដូចម្ដេច ។ ភិក្ខុផ្សាយចិត្តថាជាអសុភ ឬពិចារណាថាជារបស់មិនទៀង ក្នុងវត្ថុជាទីប្រាថ្នាផង ក្នុងវត្ថុមិនជាទីប្រាថ្នាផង យ៉ាងនេះឈ្មោះថា អ្នកមានសេចក្ដីសម្គាល់ថា គួរខ្ពើម ក្នុងរបស់មិនគួរខ្ពើមផងក្នុងរបស់គួរខ្ពើមផង ។

ភិក្ខុអ្នកវៀរបង់នូវបទទាំងពីរនោះ គឺក្នុងរបស់គួរខ្ពើមនិងមិនគួរខ្ពើម ហើយជាអ្នកមានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា តើដូចម្ដេច ។

ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក ជាអ្នកមិនសោមនស្ស មិនទោមនស្ស មានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្ដាត ពាល់ត្រូវផោដ្ឋព្វារម្មណ៍ដោយកាយ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ជាអ្នកមិនសោមនស្ស មិនទោមនស្ស មានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧ-បេក្ខា យ៉ាងនេះឈ្មោះថា ភិក្ខុវៀរបង់នូវបទទាំងពីរនោះ គឺក្នុងរបស់គួរខ្ពើម និងមិនគួរខ្ពើម ហើយជាអ្នកមានស្មារតីដឹងខ្លួន មានចិត្តប្រកបដោយឧបេក្ខា នេះឫទ្ធិ គឺភាពអ្នកខ្ពង់ខ្ពស់ ។

[ ១៦២ ] ឫទ្ធិកើតអំពីផលកម្ម តើដូចម្តេច ។ ឫទ្ធិរបស់សត្វស្លាបទាំងអស់ របស់ទេវតាទាំងអស់ របស់ពួកមនុស្សខ្លះ របស់សត្វជាវិនិបាតិកៈកំណើតពួកខ្លះ នេះឫទ្ធិកើតអំពីផលកម្ម ។

[ ១៦៣ ] ឫទ្ធិរបស់បុគ្គលមានបុណ្យតើដូចម្តេច ។ ព្រះរាជាចក្កពត្តិទ្រង់ស្តេចទៅកាន់អាកាសបាន មួយអន្លើដោយសេនាប្រកបដោយអង្គ ៤ ដោយហោចទៅរាប់តាំងអំពីបុរសអ្នកចងនិងអ្នករក្សាសេះ ឫទ្ធិរបស់បុគ្គលមានបុណ្យឈ្មោះជោតិយគហបតី ឫទ្ធិរបស់បុគ្គលមានបុណ្យឈ្មោះជដិលគហបតី ឫទ្ធិរបស់បុគ្គលមានបុណ្យឈ្មោះមេណ្ឌកគហបតី ឫទ្ធិរបស់បុគ្គលមានបុណ្យឈ្មោះឃោសិតគហបតី ឫទ្ធិរបស់បុគ្គលអ្នកមានបុណ្យធំទាំង ៥ នាក់ ឈ្មោះថា អ្នកមានបុណ្យ នេះឫទ្ធិរបស់បុគ្គលមានបុណ្យ ។

[ ១៦៤ ] ឫទ្ធិសម្រេចដោយវិជ្ជា តើដូចម្តេច ។ ពួកវិជ្ជាធររាយ ( ឬជប់ ) នូវវិជ្ជា ហោះទៅកាន់អាកាសទទេ ដំណែងខ្លួនជាដំរីខ្លះ ដំណែងខ្លួនជាសេះខ្លះ ដំណែងខ្លួនជារថខ្លះ ដំណែងខ្លួនជាពលថ្មើរជើងខ្លះ ដំណែងខ្លួនជាកងទាហានផ្សេងៗខ្លះ នេះឫទ្ធិសម្រេចដោយវិជ្ជា ។

[ ១៦៥ ] ឫទ្ធិ ដោយអត្ថថា សម្រេច ព្រោះប្រកបត្រូវក្នុងអំពើនោះៗជាបច្ច័យ តើដូចម្តេច ។ ឈ្មោះថា ឫទ្ធិ ដោយអត្ថថា សម្រេច ព្រោះ

ការប្រកបត្រូវក្នុងអំពើនោះ ៗ ជាបច្ច័យ ព្រោះសម្រេចអត្ថនៃការលះបង់នូវកាមច្ឆន្ទៈដោយនេក្ខម្មៈ ។បេ។ ព្រោះសម្រេចអត្ថនៃការលះបង់នូវព្យាបាទដោយអព្យាបាទ ។បេ។ នូវថីនមិទ្ធៈដោយអលោកសញ្ញា ។បេ។ ឈ្មោះថា ឫទ្ធិ ដោយអត្ថថា សម្រេច ព្រោះការប្រកបត្រូវក្នុងអំពើនោះ ៗ ជាបច្ច័យ ព្រោះសម្រេចអត្ថនៃការលះបង់នូវកិលេសទាំងពួង យ៉ាងនេះឯងឈ្មោះថា ឫទ្ធិ ដោយអត្ថថា សម្រេច ព្រោះការប្រកបត្រូវក្នុងអំពើនោះៗ ជាបច្ច័យ នេះឫទ្ធិទាំង ១០ ។

## ចប់ ឥទ្ធិកថា

# អដ្ឋកថា

## ឥទ្ធិកថា

[ ១៥០ ] ឥឡូវនេះ ជាការពណ៌នាសេចក្តីតាមលំដាប់ ដែលមិនធ្លាប់ពណ៌នាក្នុងឥទ្ធិកថា ដែលព្រះសារីបុត្តត្រេរសម្តែងដល់បុញ្ញានុភាពពោលទុក ហើយបន្ទាប់អំពីបញ្ញាកថា ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យសួរទាំងនោះមុន ដូចតទៅនេះថា ពាក្យថា ឫទ្ធិ ប្រែថាដូចម្តេច ជាពាក្យសួរដល់សភាវៈ ។ ពាក្យថា ឫទ្ធិ មានប៉ុន្មានយ៉ាង ជាពាក្យសួរដល់ប្រភេទ ។ ពាក្យថា មានភូមិប៉ុន្មាន ជាពាក្យសួរដល់គ្រឿងប្រកប ។ ពាក្យថា មានបាទប៉ុន្មាន ជាពាក្យសួរដល់ទីតាំង ។ ពាក្យថា មានបទប៉ុន្មាន ជាពាក្យសួរដល់ហេតុជិត ។ ពាក្យថា មានមូលប៉ុន្មាន ជាពាក្យសួរដល់ហេតុខាងដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យឆ្លើយដូចតទៅនេះថា បទថា **ឥជ្ឈនដ្ឋេន ឥទ្ធិ** អធិប្បាយថា ដោយអត្ថថា សម្រេច និងដោយអត្ថថា បានចំពោះ ព្រោះវត្ថុណាសម្រេចនិងបានចំពោះ លោកពោលវត្ថុនោះថា រមែងសម្រេច សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងខុទ្ទកនិកាយសុត្តនិបាត ) ថា កាលសត្វប្រាថ្នាកាមណា បើកាមនោះសម្រេចដល់សត្វនោះ ដូច្នេះ ។ គប្បីជ្រាប ( តាម ) ពាក្យថា ឈ្មោះថា ឥទ្ធិ ព្រោះនេក្ខម្មៈ ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់បង់កាមច្ឆន្ទៈ[១] ជាដើម ។ គប្បីជ្រាបន័យដទៃដូចតទៅ ឈ្មោះ

---

១-បិដក៧១ឃ្នាប១៩៣ ។

ថា **ឥទ្ធិ** ព្រោះអត្ថថា សម្រេច ពាក្យនេះជាឈ្មោះរបស់ឧបាយសម្បទា ( ការដល់ព្រមដោយឧបាយ ) ពិតណាស់ ឧបាយសម្បទា រមែងសម្រេច ព្រោះជួបនូវផលតាមបំណង សមដូចទេវតាពោលទុក ( ក្នុងសំយុត្តនិកាយសឡាយតនវគ្គ ) ថា ចិត្តគហបតីនេះ មានសីល មានធម៌ល្អ បើគាត់នឹងតាំងសេចក្ដីប្រាថ្នាថា អាត្មាអញគប្បីបានជាស្ដេចចក្កពត្តិក្នុងកាលជាអនាគត ( ក៏បាន ) ។ ឯសេចក្ដីប្រាថ្នាក្នុងចិត្តនេះ របស់ចិត្តគហបតីដែលមានសីលនោះនឹងសម្រេច ព្រោះសីលបរិសុទ្ធ ដូច្នេះ ។ គប្បីជ្រាបន័យដទៃតទៅទៀត ឈ្មោះថា **ឥទ្ធិ** ព្រោះ**ជាហេតុសម្រេច**របស់សត្វ ។ ពាក្យថា **ជាហេតុសម្រេច** មានអធិប្បាយថា ជាសេចក្ដីចម្រើនលូតលាស់ដល់ភាពឧក្រិដ្ឋ ។

[ ១៥១ ] ក្នុងឫទ្ធិ ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ឈ្មោះថា **អធិដ្ឋានា ឥទ្ធិ** ព្រោះសម្រេចដោយអំណាចនៃការអធិដ្ឋាន ។ ឈ្មោះថា **វិកុព្វនា ឥទ្ធិ** ព្រោះប្រព្រឹត្តទៅដោយអំណាចការធ្វើឲ្យប្លែកដោយលះពណ៌សម្បុរប្រក្រតី ។ ឈ្មោះថា **មនោមយា ឥទ្ធិ** ព្រោះប្រព្រឹត្តទៅ ដោយអំណាចធ្វើសរីរៈដទៃដែលសម្រេចដោយចិត្តក្នុងខាងក្នុងសរីរៈឲ្យសម្រេច ។ ឈ្មោះថា **ញាណវិប្ផារា ឥទ្ធិ** ជាភាពវិសេស ដែលប្រព្រឹត្តទៅដោយញាណ គឺដែលកើតដោយអានុភាពនៃញាណក្នុងខាងដើម ក្នុងខាងក្រោយ ឬក្នុងខណៈនោះ ។ ឈ្មោះថា **សមាធិវិប្ផារា ឥទ្ធិ** ជាភាពវិសេសកើតដោយអានុភាពរបស់សមថៈក្នុងខាងដើម ក្នុងខាងក្រោយ ឬក្នុងខណៈនោះ

អំពីសមាធិ ។ ឈ្មោះថា **អរិយា ឥទ្ធិ** ព្រោះកើតដល់ព្រះអរិយៈ ដែលដល់នូវភាពជំនាញផ្លូវចិត្ត ។ ឈ្មោះថា **កម្មវិបាកជា ឥទ្ធិ** ជាភាពវិសេសកើតដោយផលកម្ម ។ ឈ្មោះថា **បុញ្ញវតោ ឥទ្ធិ** ជាភាពវិសេសកើតដល់អ្នកមានបុណ្យ ដែលធ្វើទុកក្នុងកាលមុន ។ ឈ្មោះថា **វិជ្ជាមយា ឥទ្ធិ** ជាភាពវិសេសកើតអំពីវិជ្ជា ( មន្ត ) ។

ការសម្រេចនៃធម៌នោះៗដោយការប្រកបត្រូវនោះៗឈ្មោះថា **តត្ថ តត្ថ សម្មាបយោគបច្ចយា ឥជ្ឈនដ្ឋេន ឥទ្ធិ** ។

[ ១៥២ ] បទថា **ឥទ្ធិយា ចតស្សោ ភូមិយោ** កាលលោកពោលមិនឲ្យប្លែកគ្នា លោកក៏ពោលដល់ភូមិនៃឫទ្ធិដែលអធិដ្ឋាន ដែលនិម្មិតបានផ្សេង ៗ និងដែលសម្រេចដោយចិត្តដោយអំណាចតាមតែរកបាន មិនមែនរបស់ឫទ្ធិដ៏វិសេស ។ ក្នុងបទថា **វិវេកជា ភូមិ** ភូមិកើតអំពីវិវេក ឬក្នុងវិវេក ឈ្មោះថា **វិវេកជា ភូមិ** ។ បទថា **បីតិសុខភូមិ** បានដល់ ជាភូមិប្រកបដោយបីតិនិងសុខ ។ បទថា **ឧបេក្ខាសុខភូមិ** បានដល់ ភូមិដែលប្រកបដោយឧបេក្ខា គឺដាក់ខ្លួនជាកណ្តាល ក្នុងអារម្មណ៍នោះ ៗ និងដោយសុខ ។ បទថា **អទុក្ខមសុខភូមិ** បានដល់ ជាភូមិប្រកបដោយអទុក្ខមសុខវេទនា ។

ក្នុងឈានទាំងនោះ បឋមជ្ឈាននិងទុតិយជ្ឈាន ជាការផ្សាយទៅនៃបីតិឈាន ៣ ខាងដើម ជាការផ្សាយទៅនៃសុខ ចតុត្ថជ្ឈានជាការផ្សាយទៅនៃចិត្ត ។ ក្នុងបទនេះ ព្រោះឈានលាភីបុគ្គលដែលឈមចុះកាន់សុខសញ្ញា

និងលហុសញ្ញាដោយការផ្សាយទៅនៃបីតិ និងដោយការផ្សាយទៅនៃសុខៈ ជាអ្នកមានកាយស្រាល ទន់ គួរដល់ការងារ រមែងបានឫទ្ធិ ហេតុនោះ ឈាន ៣ ខាងដើមគប្បីជ្រាបថា ជាសម្ភារភូមិ ព្រោះប្រព្រឹត្តទៅដើម្បីបាន ឫទ្ធិដោយបរិយាយនេះ ។ ចំណែកចតុត្ថជ្ឈាន ជាភូមិប្រកតីដើម្បីបានឫទ្ធិ នោះឯង ។ បទថា **ឥទ្ធិលាភាយ** បានដល់ ដើម្បីបានឫទ្ធិទាំងឡាយដោយ អំណាចប្រាកដក្នុងសន្តានរបស់ខ្លួន ។ បទថា **ឥទ្ធិបដិលាភាយ** បានដល់ ដើម្បីបានឫទ្ធិដែលវិនាសហើយមកវិញ ដោយប្រារព្ធសេចក្តីព្យាយាមទៀត ឬបន្ថែមបទឧបសគ្គចូលទៅ ។ បទថា **ឥទ្ធិវិកុព្វនតាយ** បានដល់ ដើម្បី សម្តែងឫទ្ធិ បានច្រើនយ៉ាង ។ បទថា **ឥទ្ធិវិសវិតាយ** មានវិគ្គហៈថា ឈ្មោះថា **វិសវី** ព្រោះទៅកាន់ភាពវិសេសផ្សេង ៗ គឺឲ្យកើត ឲ្យប្រព្រឹត្ត ទៅ ម្យ៉ាងទៀត ឈ្មោះថា **វិសវី** ព្រោះមានការទៅច្រើនយ៉ាង ភាពជា អ្នកមានការទៅនោះ ឈ្មោះថា **វិសវិតា** ។ ដើម្បីភាពជាអ្នកសម្រេចនៃ ឫទ្ធិនោះ អធិប្បាយថា ដើម្បីសម្តែងភាពពិសេសរបស់ឫទ្ធិបានច្រើនយ៉ាង ។ បទថា **ឥទ្ធិវសីភាវាយ** បានដល់ ដើម្បីភាពជាធំក្នុងឫទ្ធិ ។ បទថា **ឥទ្ធិ-វេសារជ្ជាយ** បានដល់ ដើម្បីភាពជាអ្នកក្លៀវក្លានៃឫទ្ធិ ។

[ ១៥៣-១៥៤ ] ឥទ្ធិបាទមានអត្ថដូចបានពោលទុកហើយក្នុងញាណ-កថា ។ បទថា **ឆន្ទំ ចេ ភិក្ខុ និស្សាយ** បានដល់ បើភិក្ខុអាស្រ័យ ឆន្ទៈហើយធ្វើឆន្ទៈឲ្យជាធំ ។ បទថា **លភតិ សមាធឹ** បានដល់ រមែង បានចំពោះសមាធិ ធ្វើឲ្យសមាធិកើត ។ ក្នុងបទដ៏សេសក៏មានន័យនេះដូច

គ្នា ។ ក្នុងបទទាំងនោះ គប្បីជ្រាបថា បទ ៨ គឺ បទ ៤ គឺឆន្ទៈ វិរិយៈ ចិត្តៈ វីមំសា និងបទ ៤ គឺ សមាធិ ៤ ដែលសម្បយុត្តដោយបទទាំង ៤ នោះ ។ម្យ៉ាងទៀត ព្រោះឆន្ទៈ គឺសេចក្ដីប្រាថ្នាដើម្បីឲ្យឫទ្ធិកើតប្រកប ដោយភាពតែមួយជាមួយសមាធិ រមែងប្រព្រឹត្តទៅដើម្បីបានឫទ្ធិ វិរិយៈជា ដើមក៏យ៉ាងនោះ ហេតុនោះ ទើបលោកពោលដល់បទទាំង ៨ នេះទុក ។

[ ១៥៥ ] ព្រះមានព្រះភាគ កាលទ្រង់សម្ដែងដល់យោគវិធី ដែល ព្រះយោគាវចរប្រាថ្នានឹងញុំាងអភិញ្ញាឲ្យកើតគប្បីធ្វើ ទើបត្រាស់ទុក ( ក្នុង ទីឃនិកាយសីលក្ខន្ធវគ្គ ) ដល់ការមិនញាប់ញ័រនោះនៃចិត្តថា ភិក្ខុនោះ កាលបើចិត្តតាំងមាំ បរិសុទ្ធិ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាស ចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ដល់នូវសេចក្ដី មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះ ដូច្នេះ ព្រះថេរៈកាលសម្ដែងដល់ ការមិនញាប់ញ័រនោះ ១៦ យ៉ាង ទើបពោលពាក្យថា **សោឡសម្ងលានិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **អនោណតំ** បានដល់ មិនស្រុតចុះ ដោយ អំណាចសេចក្ដីខ្ជិលច្រអូស អធិប្បាយថា មិនខ្ជិលច្រអូស ។ បទថា **អនុន្នតំ** បានដល់ មិនឡើងទៅខាងលើ ដោយអំណាចសេចក្ដីរាយមាយ អធិប្បាយថា ចិត្តមិនរាយមាយ ។ បទថា **អនភិនតំ** បានដល់ មិន បង្អោនទៅដោយសេចក្ដីលោភ អធិប្បាយថា មិនជាប់ចំពាក់ ។ លោក អធិប្បាយថា ចិត្តបង្អោនទៅព្រោះការប្រាថ្នាក្រៃលែងទើបឈ្មោះថា បង្អោន

ទៅក្រៃលែង ចិត្តនេះមិនមានសភាពបែបនោះ ។ បទថា **រាគេ** បានដល់ ដោយសេចក្ដីលោកដែលមានសង្ខារជាទីតាំង ។ បទថា **អនបនតំ** បាន ដល់ មិនប្រទូស្ត អធិប្បាយថា មិនខ្ជាំងខ្ជប់ដោយអំណាចទោសៈ ។ បទ ថា **នតំ នតិ** ដោយអត្ថដូចគ្នា ( គឺបង្អោនទៅ ) ។ លោកអធិប្បាយថា ចិត្តប្រាសចាកការបង្អោនទៅ ឈ្មោះថា **អបនតំ** ( មិនប្រទូស្ត ) ចិត្ត នេះមិនមានសភាពបែបនោះ ។ បទថា **អនិស្សិតំ** បានដល់ មិនអាស្រ័យ ( ធម៌ ) ឯណាទីមួយថាជាត្លួខន ឬជារបស់ខ្លួនដោយអំណាចទិដ្ឋិ ព្រោះ ឃើញដោយភាពមិនមែនត្លួខន ។ បទថា **អប្បដិពទ្ធំ** បានដល់ មិនពាក់ ព័ន្ធដោយអំណាចសង្ឃឹមឧបការៈតបស្នង ។ បទថា **ឆន្ទរាគេ** បានដល់ ព្រោះលោកៈមានសត្វជាទីតាំង ។

បទថា **វិប្បមុត្តំ** បានដល់ រួចផុតចាកកាមរាគៈដោយអំណាចវិក្ខម្ភន-វិមុត្តិ ។ម្យ៉ាងទៀត រួចផុតចាកកាមរាគៈ ដោយអំណាចវិមុត្តិ ៥ ។ ម្យ៉ាងទៀត រួចផុតចាកភាពជាបដិបក្ខនោះ ៗ ដោយអំណាចវិមុត្តិ ៥ ។ ពាក្យនេះ លោកពោលដោយកំណត់យ៉ាងឧក្រិដ្ឋដោយន័យដូចពោលហើយ ក្នុងនិរោធសមាបត្តិញាណថា ដោយញាណចរិយា ១៦ ព្រោះការកើត ឡើងនៃអភិញ្ញារបស់បុថុជ្ជននិងសេក្ខៈ ឬអសេក្ខៈ តែគួរកាន់យកតាមដែល មាន ។ បទថា **កាមរាគេ** បានដល់ ព្រោះត្រេកត្រអាលក្នុងមេថុន ។ បទថា **វិសញ្ញុត្តំ** បានដល់ មិនជាប់ចំពាក់ដោយកិលេសដ៏សេស ព្រោះ សង្កត់សង្កិនបាន ឬមិនប្រកប ព្រោះកាត់ផ្ដាច់បានយ៉ាងឧក្រិដ្ឋ ។ បទថា

**កិលេសេ** បានដល់ ព្រោះកិលេសដ៏សេស ។

បទថា **វិមរិយាធិកតំ** បានដល់ ដែលធ្វើហើយឲ្យប្រាសចាកព្រំដែននៃកិលេស ដោយអំណាចព្រំដែននៃកិលេសដែលគួរសង្កត់សង្កិន ឬដោយអំណាចព្រំដែននៃកិលេសដែលគួរលះដោយមគ្គនោះៗ ។ បទថា **កិលេសមរិយាទេ** បានដល់ ព្រោះព្រំដែននៃកិលេសដែលលះបានហើយនោះៗ ។ ក្នុងទីនេះគប្បីឃើញថា ជាលិង្គវិបល្លាស ។ បទថា **ឯកត្តគតំ** បានដល់ ចិត្តមានអារម្មណ៍មួយ ។ បទថា **នានត្តកិលេសេហិ** បានដល់ ព្រោះកិលេសដែលប្រព្រឹត្តទៅ ក្នុងអារម្មណ៍ផ្សេង ៗ ។ ពាក្យនេះលោកពោលសម្ដៅដល់អារម្មណ៍ តែបទថា **អនោនតំ** ( មិនទ្រោមចុះ ) ជាដើមលោកពោលសម្ដៅដល់កិលេសទាំងឡាយនោះឯង ។ បទថា **ឱភាសគតំ** បានដល់ ដែលដល់នូវការភ្លឺស្វាងដោយបញ្ញា ដោយអំណាចការប្រព្រឹត្តិទៅនៃភាពប្រាកដច្បាស់ ដោយបញ្ញា ។ បទថា **អវិជ្ជន្ធការេ** បានដល់ ព្រោះអវិជ្ជាដែលមានកម្លាំង ។ លោកពោលភូមិ ៤ និងមូល ១៦ ដោយអំណាចជាចំណែកខាងដើមនៃឫទ្ធិ ពោលបាទ ៤ និងបទ ៨ ដោយអំណាចជាចំណែកខាងដើម និងដោយអំណាចការប្រកបព្រមដោយប្រការដូច្នេះ ។

## អដ្ឋកថា

## ទសឥទ្ធិនិទ្ទេស

[ ១៥៦ ] ព្រះសារីបុត្តត្ថេរ លុះសម្តែងធម៌ដែលជាភូមិ បាទ បទនិងមូលនៃឫទ្ធិយ៉ាងនេះហើយ ឥឡូវនេះកាលនឹងសម្តែងដល់ឫទ្ធិទាំងនោះ ទើបពោលពាក្យថា **កតមា អធិដ្ឋានា ឥទ្ធិ** ជាដើម ។ ក្នុងបទនោះ ខ្ញុំពោលអត្ថនៃបទឧទ្ទេសទុកក្នុងឥទ្ធិវិធញ្ញាណនិទ្ទេសហើយ ។ បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុក្នុងសាសនានេះ ។ ដោយបទនោះ លោកសម្តែងដល់ការមិនមានអ្នកសម្តែងឫទ្ធិបានដោយប្រការទាំងពួង ទុកក្នុងលទ្ធិដទៃ ។ និទ្ទេសនៃបទទាំងពីរនេះ មានអត្ថដូចដែលខ្ញុំបានពោលទុកហើយ ។ម្យ៉ាងទៀត ដោយបទនោះៗឯង ជាការពោលដល់ភិក្ខុដែលប្រកបហើយដោយធម៌ដែលជាភូមិ បាទ បទ និងមូលនៃឫទ្ធិ ជាការពោលដល់ភាពដែលចិត្តត្រូវទូន្មានហើយដោយអាការ ១៤ ឬ ១៥ ដូចពោលហើយក្នុងវិសុទ្ធិមគ្គ និងជាការពោលដល់ភាពជាអ្នកមានចិត្តទន់ គួរដល់ការងារដោយអំណាចនៃការចូលដល់ភាពជាធំដទៃ ៗ មានឆន្ទៈជាដើម និងដោយអំណាចវសី មានអាវជ្ជនវសីជាដើម ។ ភិក្ខុអ្នកដល់ព្រមដោយការប្រកបខាងដើម ដែលមានកម្លាំង ជាអ្នកមានគុណ មានអភិញ្ញាជាដើម ដោយការបានចំពោះនូវព្រះអរហត្ត ដោយការដល់ព្រមនៃការប្រកប ជាខាងដើមនោះឯង ជាអ្នកប្រកបព្រមហើយដោយធម៌ទាំងឡាយ មានភូមិជាដើម ព្រោះហេតុនោះទើបលោកពោលដល់ភិក្ខុនោះ ។

បទថា **ពហុកំ អាវជ្ជតិ** បានដល់ ភិក្ខុចូលចតុត្ថជ្ឈានដែលជាបាទនៃអភិញ្ញា មានបឋវីកសិណជាអារម្មណ៍ លុះចេញហើយ បើប្រាថ្នាជា ១០០ នាក់ រមែងនឹកដោយធ្វើបរិកម្មថា អាត្មាអញចូរជា ១០០ នាក់ អាត្មាអញចូរជា ១០០ នាក់ ដូច្នេះ ។ បទថា **អាវជ្ជិត្វា ញាណេន អធិដ្ឋាតិ** បានដល់ ធ្វើបរិកម្មយ៉ាងនេះហើយ អធិដ្ឋានដោយអភិញ្ញាញាណ ។ ក្នុងទីនេះ លោកមិនពោលដល់ការធ្វើបរិកម្មហើយចូលឈានដែលជាបាទទៀត លោកមិនពោលទុកក៏ពិត តែក៏គប្បីជ្រាបយ៉ាងនេះឯង ព្រោះលោកពោលទុកក្នុងអដ្ឋកថាថា ពាក្យថា នឹកចង់ លោកពោលដោយអំណាចបរិកម្មនោះឯង ពាក្យថា ហើយក៏អធិដ្ឋានដោយញាណ លោកពោលដោយអំណាចនៃអភិញ្ញាញាណ ព្រោះហេតុនោះ គប្បីជ្រាបអត្ថក្នុងបទនេះយ៉ាងនេះថា ភិក្ខុនឹករំពឹងឲ្យជាច្រើននាក់ បន្ទាប់អំពីនោះក៏ចូលសមាបត្តិក្នុងទីបំផុតនៃបរិកម្មចិត្តទាំងនោះ ចេញអំពីសមាបត្តិហើយ នឹករំពឹងទៀតថា អាត្មាអញ ចូរជាមនុស្សច្រើននាក់ បន្ទាប់អំពីនោះ រមែងអធិដ្ឋានដោយអភិញ្ញាញាណតែម្យ៉ាងប៉ុណ្ណោះ ដែលកើតឡើងក្នុងលំដាប់នៃចិត្តដែលជាចំណែកខាងដើម ៣ ឬ ៤ ដែលប្រព្រឹត្តទៅហើយ និងដែលបានឈ្មោះថា អធិដ្ឋានដោយអំណាចឲ្យសម្រេចដូច្នេះ ។ ដូចកាលពោលថា បរិភោគហើយដេកក៏មិនមែនសំដៅសេចក្តីថា មិនផឹកទឹក មិនលាងដៃជាដើម ហើយដេកពេលបរិភោគស្រេចភ្លាមៗនោះឯង កាលមានកិច្ចដទៃក្នុងរវាង ក៏ពោលថា បរិភោគហើយដេក យ៉ាងណាគប្បីឃើញថា ក្នុងសេចក្តីនេះក៏យ៉ាងនោះ ។ សូម្បីការចូលឈាន

ដែលជាបាទដំបូង លោកក៏មិនបានពោលទុកក្នុងបាលីឡើយ ។

ម្យ៉ាងទៀត ភិក្ខុរមែងជា ១០០ មួយអន្ទើដោយអធិដ្ឋានញាណនោះ សូម្បីក្នុងមនុស្សមួយពាន់ ឬមួយសែន ក៏មានន័យនេះដូចគ្នា ។ ប្រសិនបើមិនសម្រេចយ៉ាងនោះ គប្បីធ្វើបរិកម្មទៀត ហើយចូលសមាបត្តិលើកទី ២ ចេញហើយក៏អធិដ្ឋាន ។ លោកពោលទុកក្នុងអដ្ឋកថាសំយុត្តនិកាយថា គួរចូលសមាបត្តិ ១ ដង ២ ដង ដូច្នេះ ។ ក្នុងចិត្តទាំងនោះ ឈានចិត្តដែលជាបាទមាននិមិត្តជាអារម្មណ៍ បរិកម្មចិត្តមានមនុស្ស ១០០ ជាអារម្មណ៍ ឬមានមនុស្ស ១.០០០ ជាអារម្មណ៍ បរិកម្មចិត្តទាំងនោះ រមែងមានដោយវណ្ណៈ ( វណ្ណរូប ) មិនមែនដោយបញ្ញត្តិ សូម្បីអធិដ្ឋានចិត្ត ក៏មានមនុស្ស ១០០ ឬ ១.០០០ ជាអារម្មណ៍ដូចគ្នានោះឯង អធិដ្ឋានចិត្តនោះជារូបាវចរ-ចតុត្ថជ្ឈាន រមែងកើតយ៉ាងនោះឯងក្នុងលំដាប់គោត្រភូដូចអប្បនាចិត្ត ដូចបានពោលហើយក្នុងកាលមុន ។

ដើម្បីសម្តែងដល់កាយសក្ខីនៃភាពជាបុគ្គលច្រើននាក់ ទើបលោកពោលពាក្យថា ដូចព្រះចុល្លបន្ថកៈមានអាយុ សូម្បីមានរូបតែមួយ ក៏ធ្វើឲ្យបានច្រើនរូប ។ ម្យ៉ាងទៀត ក្នុងសេចក្តីនេះគប្បីជ្រាបថា លោកធ្វើពាក្យជាបច្ចុប្បន្ន ព្រោះព្រះថេរៈជាអ្នកមានប្រក្រតីធ្វើយ៉ាងនោះ និងព្រោះជាពេលដែលព្រះថេរៈនោះនៅមានជីវិតនៅឡើយ ។ ក្នុងវារៈថា ធ្វើឲ្យទៅជាម្នាក់វិញក៏មានន័យដូចគ្នា ។ ក្នុងសេចក្តីនោះមានរឿងមកថា ព្រះថេរៈពីរនាក់បងប្អូនឈ្មោះថា បន្ថកៈ ព្រោះកើតក្នុងផ្លូវ បងប្អូនពីរនាក់នោះ ព្រះមហា-

បន្ថក:ជាបង បានបួសហើយក៏សម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ។ ព្រះមហាបន្ថក:ជាព្រះអរហន្ត ទើបឲ្យចុល្លបន្ថក:បួស នឹងឲ្យគាថា ( សំយុត្តនិកាយសគាថវគ្គ ) នេះថា

ផ្កាឈូក ( ក្រហមប្រាល ) រីកក្នុងវេលាព្រឹក មានក្លិន
ក្រអូប មិនប្រាសចាកក្លិនយ៉ាងណា អ្នកចូរមើលនូវព្រះ-
សម្មាសម្ពុទ្ធ មានរស្មីផ្សាយចេញអំពីព្រះអង្គ កំពុងរុងរឿងដូច
ព្រះអាទិត្យដែលរុងរឿងក្នុងអាកាស យ៉ាងនោះឯង ដូច្នេះ ។

ព្រះចុល្លបន្ថក: មិនអាចទន្ទេញគាថានោះឲ្យចាំបានដោយកាលកន្លងទៅ ៤ ខែ លំដាប់នោះ ទើបព្រះថេរៈពោលនឹងព្រះចុល្លបន្ថក:ថា អ្នកមិនសមគួរនៅក្នុងព្រះសាសនានេះ ចូរចេញអំពីព្រះសាសនានេះចុះ ។ ក្នុងវេលានោះព្រះថេរៈជាភត្តុទ្ទេសក: ( អ្នកចែកភត្ត ) ។ ជីវកកោមារភច្ច កាន់យកកម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាបជាច្រើន ទៅកាន់អម្ពវនវិហាររបស់ខ្លួន បូជាព្រះសាស្តា ស្តាប់ព្រះធម៌ ថ្វាយបង្គំព្រះទសពល រួចចូលទៅរកព្រះថេរៈហើយពោលថា បពិត្រលោកម្ចាស់ ស្អែកនេះ សូមលោកម្ចាស់នាំភិក្ខុ ៥០០ អង្គ មានព្រះពុទ្ធជាប្រធាន ទទួលភិក្ខានៅឯផ្ទះរបស់ខ្ញុំចុះ ។

ចំណែកព្រះថេរៈ ពោលថា អាត្មាទទួលនិមន្តន៍ដល់ភិក្ខុដ៏សេសវៀរតែចុល្លបន្ថក: ។ ព្រះចុល្លបន្ថក:បានស្តាប់ដូច្នោះ ទោមនស្សក្រៃលែង ស្អែកឡើងចេញពីវត្តតាំងអំពីព្រលឹម ឈរយំត្រង់ខ្លោងទ្វារវិហារ ព្រោះជាអ្នក

មានសេចក្តីអាលោះអាល័យក្នុងព្រះសាសនា ។

ព្រះមានព្រះភាគ ទ្រង់ឃើញឧបនិស្ស័យរបស់ព្រះចុល្លបន្ថកៈនោះ ទើបទ្រង់ចូលទៅរក ត្រាស់ថា អ្នកយំព្រោះហេតុអ្វី ។

ព្រះចុល្លបន្ថកៈ ក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាប ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អ្នកមិនអាចធ្វើការស្វាធ្យាយឲ្យចាំបាន មិនមែនអ្នកមិនគួរក្នុងសាសនារបស់តថាគតទេ កុំសោកសៅឡើយបន្ថកៈ ហើយទ្រង់យកព្រះហស្តប្រកបដោយស្នាមចក្ក ស្ទាបសីសៈរបស់ព្រះចុល្លបន្ថកៈនោះ ទ្រង់ដឹកដៃចូលទៅកាន់វិហារ ឲ្យអង្គុយត្រង់យ៉មុខព្រះគន្ធកុដិ ហើយទ្រង់ប្រទានកំណាត់សំពត់ចាស់បរិសុទ្ធ ដែលកើតដោយឫទ្ធិ ដល់ព្រះចុល្លបន្ថកៈនោះត្រាស់ថា ម្នាលបន្ថកៈ អ្នកចូរអង្គុយអង្អែលសំពត់ចាស់នេះ បរិកម្មថា **រជោហរណំ រជោហរណំ** នាំធូលីចេញ នាំធូលីចេញ ដូច្នេះ លុះដល់ពេលវេលា ទ្រង់ចោមរោមដោយភិក្ខុសង្ឃ យាងទៅកាន់លំនៅរបស់ជីវកគង់លើអាសនៈដែលគេក្រាលទុក ។ កាលព្រះចុល្លបន្ថកៈ អង្អែលកំណាត់សំពត់ចាស់យ៉ាងនោះ កំណាត់សំពត់ក៏សៅហ្មងមានពណ៌ខ្មៅដោយលំដាប់ព្រះចុល្លបន្ថកៈបានកើតសញ្ញាថា កំណាត់សំពត់ចាស់នេះបរិសុទ្ធ មិនមានទោស គឺសៅហ្មង តែព្រោះអាស្រ័យអត្តភាពនេះ ទើបមានទោស ញ៉ាំងញាណឲ្យឈមចុះក្នុងខន្ធ ៥ ហើយចម្រើនវិបស្សនា ។ ខណៈនោះព្រះមានព្រះភាគ ទ្រង់បញ្ចេញឱភាស ប្រាកដដូចជាព្រះអង្គគង់នៅទីងមុខព្រះចុល្លបន្ថកៈនោះ បានត្រាស់ឱភាសគាថា ( ក្នុងខុទ្ទកនិកាយមហានិទ្ទេស )

នេះថា

ធូលី គឺរាគៈ មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលី នុ៎ះ ជាឈ្មោះនៃរាគៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលី នុ៎ះ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។ ធូលី គឺទោសៈ ។បេ។ នៅក្នុងសាសនានៃព្រះពុទ្ធដែលប្រាសចាកធូលី ។ ធូលី គឺមោហៈ ។បេ។ នៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ដូច្នេះ ។

សេចក្តីសោកទាំងឡាយ រមែងមិនកើតមានដល់បុគ្គល មានអធិចិត្ត មិនប្រមាទ ជាអ្នកដឹង ជាអ្នកសិក្សាក្នុងផ្លូវនៃការដឹងទាំងឡាយ គឺអរហត្តផលញាណ មានចិត្តមិនញាប់ញ័រ ជាអ្នកនឹងធឹង ជាអ្នកស្ងប់ មានស្មារតីគ្រប់កាល[១] ។

កាលចប់គាថា ព្រះថេរៈក៏បានសម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ព្រះថេរៈនោះជាអ្នកបានឈានសម្រេចអំពីចិត្ត អាចនិម្មិតរូបតែម្នាក់ធ្វើឲ្យជាច្រើននាក់ក៏បាន ច្រើននាក់ធ្វើឲ្យមកជាម្នាក់ក៏បាន ។ បិដកទាំងឡាយ ៣ និងអភិញ្ញា ៦ បានប្រាកដដល់ព្រះថេរៈព្រមនឹងអរហត្តមគ្គនោះឯង ។

សូម្បីជីវក ក៏បង្អោនទក្ខិណោទកថ្វាយដល់ព្រះទសពល ព្រះសាស្តាទ្រង់យកព្រះហស្តបិទបាត្រ ជីវកក្រាបទូលសួរថា មានហេតុដូចម្តេច ព្រះអង្គ ព្រះមានព្រះភាគត្រាស់ថា នៅមានភិក្ខុ ១ អង្គនៅក្នុងវិហារ ជីវកនោះ

---

១-គាថាចុងក្រោយនេះមានក្នុងខុទ្ទកនិកាយ ឧទាន ។

ទើបបញ្ជូនបុរសទៅដោយប្រាប់ថា អ្នកចូរទៅនាំលោកម្ចាស់ មកឲ្យធាប់ព្រះចុល្លបន្ថកត្ថេរ បំណងនឹងឲ្យបងប្រុសដឹងថា ខ្លួនសម្រេចគុណវិសេសហើយ ទើបនិម្មិតជាភិក្ខុ ១.០០០ អង្គ មុនបុរសនោះមកដល់ ធ្វើរូបមួយមិនឲ្យដូចរូបមួយ ធ្វើកិច្ចរបស់សមណៈ មានដេរចីវរជាដើម របស់ភិក្ខុមួយរូបមិនឲ្យដូចរូបដទៃ បុរសនោះ ទៅឃើញភិក្ខុក្នុងវត្តច្រើនអង្គ ទើបត្រឡប់មកប្រាប់ជីវកថា លោកម្ចាស់ ភិក្ខុនៅក្នុងវត្តមានច្រើនណាស់ ខ្ញុំមិនឃើញលោកម្ចាស់ដែលគួរនិមន្តឡើយ ។ ជីវកក្រាបទូលសួរព្រះសាស្តា ប្រាប់ឈ្មោះរបស់ព្រះថេរៈរូបនោះ ហើយបញ្ជូនបុរសទៅម្តងទៀត បុរសនោះទៅសួរថា លោកម្ចាស់អង្គណាឈ្មោះចុល្លបន្ថកៈ ភិក្ខុទាំងមួយពាន់ពោលព្រមគ្នាថា អាត្មាគឺចុល្លបន្ថកៈ អាត្មាគឺចុល្លបន្ថកៈ បុរសនោះក៏ត្រឡប់មកម្តងទៀតពោលថា បានឬថា លោកម្ចាស់ទាំងអស់សុទ្ធតែជាចុល្លបន្ថកៈ ខ្ញុំមិនដឹងនិមន្តលោកម្ចាស់អង្គណាឡើយ ជីវកបានដឹងដោយន័យថា ភិក្ខុមានឫទ្ធិព្រោះចាក់ធ្លុះសច្ចធម៌ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អ្នកចូរទៅ ចូរចាប់ភិក្ខុដែលបានឃើញមុនគេ ត្រង់ជាយចីវរហើយពោលថា ព្រះសាស្តាត្រាស់ហៅលោកម្ចាស់ ហើយនាំលោកមកចុះ បុរសនោះទៅហើយ បានធ្វើតាមនោះ ក្នុងពេលនោះឯង ភិក្ខុដែលនិម្មិតទាំងអស់ក៏អន្តរធានទៅ ព្រះថេរៈបញ្ជូនបុរសនោះឲ្យត្រឡប់ទៅ ធ្វើសរីរៈកិច្ច មានលប់មុខជាដើម ស្រេចហើយបានទៅដល់មុន ( បុរសនោះ ) គង់លើអាសនៈដែលគេក្រាលទុក ។ ក្នុងខណៈនោះ ព្រះសាស្តា ទ្រង់ទទួលទក្ខិណោទក សោយព្រះក្រយាហារ

ស្រេចហើយ ឲ្យព្រះចុល្លបន្ថកត្ថេរ សម្តែងធម្មកថាអនុមោទនាភត្ត ព្រះថេរៈសម្តែងធម្មកថាមានប្រមាណស្មើនឹងគម្ពីរទីឃនិកាយនិងមជ្ឈិមនិកាយ ។

ភិក្ខុអង្គដទៃ ៗ និម្មិតកាយដែលសម្រេចអំពីចិត្តដោយការអធិដ្ឋាន រមែងនិម្មិតបាន ៣ អង្គ ឬ ៤ អង្គ រមែងនិម្មិតច្រើនអង្គឲ្យមកតែមួយអង្គក៏បាន និងធ្វើកម្មបានតែមួយប៉ុណ្ណោះ តែព្រះចុល្លបន្ថកត្ថេរ និម្មិតបាន ១.០០០ អង្គ ដោយនឹកតែម្តងប៉ុណ្ណោះ មិនបានធ្វើ ២ នាក់ឲ្យមកជាម្នាក់ មិនបានធ្វើកម្មតែមួយ ព្រោះហេតុនោះ ទើបព្រះថេរៈជាកំពូលលើសបណ្តាភិក្ខុអ្នកនិម្មិតកាយ ដែលសម្រេចអំពីចិត្ត ។ ឯរូបនិម្មិតដែលកំណត់មិនបានចំនួនច្រើនពួកដទៃ ដូចគ្នានឹងភិក្ខុមានឫទ្ធិនោះឯង រមែងធ្វើកម្មដែលភិក្ខុមានឫទ្ធិធ្វើ មានឈរ អង្គុយជាដើម និងភាពជាអ្នកនៅស្ងៀមជាដើមដូចគ្នា ។ តែបើបំណងនឹងធ្វើវណ្ណៈផ្សេង ៗ គឺជាអ្នកបំណងធ្វើពួកខ្លះ ឲ្យជាបឋមវ័យ ពួកខ្លះ ជាមជ្ឈិមវ័យ ពួកខ្លះជាបច្ឆិមវ័យ ម្យ៉ាងទៀត បំណងនឹងធ្វើឲ្យមានសក់វែង កោរសល់ពាក់កណ្តាល កោរសក់ទាំងអស់ មានសក់ពីរពណ៌ មានចីវរក្រហមពាក់កណ្តាល មានចីវរពណ៌លឿង ឲ្យធ្វើកិច្ចមានការពោលបទ ធម្មកថា សរភញ្ញៈ សួរបញ្ហា ឆ្លើយបញ្ហា ជ្រលក់ ស្ងោរដេរ បោកចីវរជាដើមឬឲ្យមានប្រការផ្សេងៗ ភិក្ខុនោះកាលចេញចាកឈានដែលជាបាទ ហើយធ្វើបរិកម្មដោយន័យជាដើមថា ភិក្ខុប្រមាណប៉ុណ្ណោះ ចូរជាអ្នកមានបឋមវ័យ ហើយចូលសមាបត្តិទៀត លុះចេញហើយគប្បីអធិដ្ឋានរូបនិមិត្តក៏មានប្រការតាមដែលប្រាថ្នាហើយព្រមគ្នានឹងអធិដ្ឋានចិត្តនោះឯង ។

ក្នុងបទថា **ពហុធាបិ ហុត្វា ឯកោ ហោតិ** ជាដើម ក៏មានន័យនេះដូចគ្នា ។

តែសេចក្តីផ្សេងគ្នា មានដូចតទៅនេះថា បទថា **បកតិយា ពហុកោ** បានដល់ ជាច្រើនរូបដោយការនិម្មិតតាមប្រក្រតីក្នុងរវាងពេលដែលនិម្មិត ។ ភិក្ខុនេះលុះនិម្មិតភាពជាច្រើនរូបយ៉ាងនេះ ហើយប្រាថ្នាថា អញនឹងជាបុគ្គលតែមួយរូបក្នុងរវាងនេះឯង ព្រោះគិតទៀតថា អញជាបុគ្គលមួយរូបនោះឯងនឹងចង្ក្រម នឹងស្វាធ្យាយ នឹងសួរបញ្ហា ឬមានការប្រាថ្នាតិចដោយគិតថា វត្តនេះមានភិក្ខុតិច បើភិក្ខុដទៃមក នឹងស្គាល់អញថា ភិក្ខុដូចគ្នាតែមួយមានប្រមាណប៉ុណ្ណោះ នឹងមានអំពីណា នេះជាអានុភាពរបស់ព្រះថេរៈពិតដូច្នេះចូលឈានដែលជាបាទ កាលចេញហើយ ធ្វើបរិកម្មថា អាត្មាអញចូរជារូបតែមួយ ចូលសមាបត្តិទៀត កាលចេញហើយ គប្បីអធិដ្ឋានថា អាត្មាអញចូរជារូបតែមួយ ដំណាលគ្នានឹងអធិដ្ឋានចិត្តនោះឯង ក៏ជាមួយរូបតែកាលមិនធ្វើយ៉ាងនេះ រមែងជាមួយរូបបានឯងដោយអំណាចពេលវេលាតាមដែលកំណត់ទុក ។

លោកពោលអត្ថនៃពាក្យថា ទីវាល ឲ្យប្រាកដច្បាស់ ដោយពាក្យថា ដែលវត្ថុអ្វីមួយមិនរាំង ព្រោះលោកតាំងបទថា ទីវាល ជាមេបទ ហើយពោលអធិប្បាយថា ដែលវត្ថុអ្វីមួយមិនរាំង □**កេនចិ អនាវដំ ហោតិ** □។ ដោយពាក្យថា **ហោតិ** ឈ្មោះថា លោកពោលដល់បាឋៈដ៏សេសថា **ក-រោតិ** ។ ព្រោះវត្ថុដែលប្រាកដច្បាស់ រមែងមានបាន កាលធ្វើឲ្យមាន

ប្រាកដ ។ បទថា **កោរចិ អលាវដំ** បានដល់ មិនមានវត្ថុណាមួយមាន ជញ្ជាំងជាដើម បិទបាំង គឺប្រាសចាកគ្រឿងរាំង ។ បទថា **អប្បដិច្ឆន្នំ** បានដល់ មិនបិទខាងលើ ។ បទថា **អប្បដិច្ឆន្នំ** នោះឯង ឈ្មោះថា **វិវដំ** ព្រោះមិន រាំង ។ ឈ្មោះថា **ចាកដំ** ព្រោះមិនបិទបាំង ។ បទ ថា **តិរោភាវំ** បានដល់ ធ្វើឲ្យអន្តរធានទៅ ។ វត្ថុដែលបិទបាំងនោះឯង ឈ្មោះថា **បិហិតំ** ដោយគ្រឿងរាំងនោះ ។ វត្ថុដែលបិទបាំងនោះឯង ឈ្មោះថា **បដិកុជ្ជិតំ** ដោយគ្រឿងបិទបាំងទុក ។

បទថា **អាកាសកសិណសមាបត្តិយា** បានដល់ ចតុត្ថជ្ឈានសមាបត្តិ ដែលឲ្យកើតឡើងហើយក្នុងបរិច្ឆេទាកាសកសិណ ។ បទថា **លាភី** មាន វិគ្គហៈថា ឈ្មោះថា **លាភី** ព្រោះមានការបាន ។ បទថា **អបរិក្ខិត្តេ** បានដល់ ក្នុងប្រទេសដែលមិនមានអ្វីរាំងទុកដោយជុំវិញ ព្រោះលោកពោល អាកាសកសិណទុកក្នុងទីនេះ ឈានដែលចម្រើនហើយ ក្នុងទីនោះ ៗ ឯង រមែងជាបច្ច័យនៃអាកាសកសិណ មិនគប្បីឃើញយ៉ាងដទៃ ។ គប្បីឃើញ ឈាន មានកសិណនោះជាអារម្មណ៍ បណ្តាអាបោកសិណក្នុងខាងមុខជា ដើម មិនមែនយ៉ាងដទៃ ។ បទថា **បថវី អាវជ្ជតិ ឧទកំ អាវជ្ជតិ អាកាសំ អាវជ្ជតិ** បានដល់ រមែងនឹកដល់ផែនដី ទឹកនិងអាកាសតាម ប្រក្រតី ។ ដោយបទថា **អន្តលិក្ខេ** លោកពោលដល់ភាពដែលអាកាស នោះ ជាអាកាសឆ្ងាយអំពីផែនដី ។

ព្រោះលោកមិនធ្វើការកំណត់កសិណ ក្នុងការស្ទាបអង្អែលព្រះចន្ទ និង

ព្រះអាទិត្យ ទើបពោលដោយមិនផ្សេងគ្នាថា ឯភិក្ខុដែលមានឫទ្ធិដល់ហើយនូវការស្ទាត់ជំនាញក្នុងចិត្ត គប្បីជ្រាបថា ការកំណត់កសិណ សមាបត្តិក្នុងទីនេះរមែងមិនមាន ។

បទថា **និសិន្នកោ វា និបន្នកោ វា** បានដល់ អង្គុយក្តី ដេកក្តី ដោយបទនេះ ឈ្មោះថា លោកពោលដល់ឥរិយាបថទាំងពីរ ក្រៅអំពីនេះផងដែរ ។ បទថា **ហត្ថបាសេ ហោតុ** បានដល់ ចូរមានក្នុងទីជិតដៃ បាឋៈថា **ហត្ថបស្សេ ហោតុ** ដូច្នេះក៏មាន ។ ពាក្យនេះលោកពោលដោយអំណាចរបស់បុគ្គលដែលប្រាថ្នានឹងធ្វើយ៉ាងនោះ ។ម្យ៉ាងទៀត អ្នកមានឫទ្ធិនេះ សូម្បីទៅក្នុងទីនោះ ស្ទាបអង្អែលក៏បាន លាដៃទៅស្ទាបអង្អែលក៏បាន ។

បទថា **អាមសតិ** បានដល់ ពាល់បន្តិចបន្តួច ។ បទថា **បរាមសតិ** បានដល់ ស្ទាបបន្តិចបន្តួច ។ បទថា **បរិមជ្ជតិ** អង្អែលដោយប្រពៃ ។ បទថា **រូបគតំ** បានដល់ រូបដែលតាំងនៅជិតដៃនោះឯង ។ បទថា **ទូរេបិ សន្តិកេ អធិដ្ឋាតិ** សេចក្តីថា អ្នកមានឫទ្ធិចេញអំពីឈានដែលជាបាទហើយ នឹកដល់ទេវលោកក្តី ព្រហ្មលោកក្តី ក្នុងទីឆ្ងាយថា ចូរមានក្នុងទីជិត កាលនឹករំពឹងហើយធ្វើបរិកម្ម ចូលសមាបត្តិទៀត កាលចេញហើយអធិដ្ឋានដោយញាណថា ចូរមានក្នុងទីជិត ទេវលោកឬព្រហ្មលោក រមែងមានក្នុងទីជិត ។ សូម្បីក្នុងពាក្យដ៏សេស ក៏មានន័យនេះ ។ ម្យ៉ាងទៀត ព្រះសារីបុត្តត្ថេរ ពោលដល់ការធ្វើក្នុងទីឆ្ងាយឲ្យមកជាទីជិត ដល់បុគ្គល

ដែលប្រាថ្នានឹងទៅព្រហ្មលោកហើយ កាលសម្តែងដល់ភាពវិសេស ដែលសម្រេចដោយឫទ្ធិនេះ សូម្បីមិនជាឧបការៈដល់ការទៅព្រហ្មលោក ក៏នៅតែពោលពាក្យថា **សន្តិកេបិ** ជាដើម ។

ក្នុងបទនោះមិនមែនជាការធ្វើឲ្យតិច និងឲ្យច្រើនតែម្យ៉ាងប៉ុណ្ណោះទេ វត្ថុទាំងអស់ដែលប្រាថ្នាសូម្បីក្នុងវត្ថុ មានមិនឆ្ងាញ់ ឆ្ងាញ់ជាដើម រមែងសម្រេចដល់អ្នកមានឫទ្ធិ ។ គប្បីជ្រាបន័យដទៃទៀត ។ បទថា **ទូរេបិ សន្តិកេ អធិដ្ឋាតិ** បានដល់ អធិដ្ឋានព្រហ្មលោកក្នុងទីឆ្ងាយឲ្យមានក្នុងទីជិតមនុស្ស-លោក ។ បទថា **សន្តិកេបិ ទូរេ អធិដ្ឋាតិ** បានដល់ អធិដ្ឋានមនុស្សលោកក្នុងទីជិត ឲ្យមានក្នុងព្រហ្មលោកក្នុងទីឆ្ងាយ ។ បទថា **ពហុកម្បិ ថោកំ អធិដ្ឋាតិ** បានដល់ បើព្រហ្មទាំងឡាយមកប្រជុំគ្នាច្រើន ព្រោះពួកព្រហ្មមានរាងកាយធំនឹងលះទស្សនូបចារៈ សវនូបចារៈ អ្នកមានឫទ្ធិអធិ-ដ្ឋានរបស់ច្រើនឲ្យជារបស់តិច ក៏បំប្រួមគ្នាទុកក្នុងទស្សនូបចារៈនិងសវនូប-ចារៈ ។ បទថា **ថោកម្បិ ពហុកំ អធិដ្ឋាតិ** បានដល់ បើអ្នកមានឫទ្ធិបំណងនឹងទៅជាមួយបរិវារច្រើន ព្រោះជាបុគ្គលម្នាក់ឯង ទើបអធិដ្ឋានខ្លួនដែលតិចឲ្យច្រើន ហើយជាអ្នកមានបរិវារច្រើនទៅ គប្បីឃើញអត្ថក្នុងបទនេះដោយប្រការដូច្នេះឯង ។ កាលបើយ៉ាងនោះ សូម្បីទាំង ៤ យ៉ាងនេះរមែងជាឧបការៈក្នុងការទៅព្រហ្មលោក ។ បទថា **ទិព្វេន ចក្ខុនា តស្ស ព្រហ្មុនោ រូបំ បស្សតិ** សេចក្តីថា អ្នកមានឫទ្ធិតាំងនៅក្នុងលោកនេះចម្រើនអាលោកកសិណ រមែងឃើញរូបរបស់ព្រហ្មដែលបំណងនឹងឃើញ ដោយ

ទិព្វចក្ខុ ។ តាំងនៅក្នុងលោកនេះឯង រមែងបានឮសំឡេងរបស់ព្រហ្មនោះ ដែលកំពុងនិយាយគ្នាដោយទិព្វសោតធាតុ ។ រមែងដឹងចិត្តរបស់ព្រហ្មនោះ ដោយចេតោបរិយញ្ញាណ ។ បទថា **ទិស្សមានេន** បានដល់ ដែលសម្លឹង ឃើញដោយចក្ខុ ។ បទថា **កាយវសេន ចិត្តំ បរិណាមេតិ** បានដល់ បង្អោនចិត្តដោយអំណាចនៃរូបកាយ ។ កំណត់ឈានចិត្តដែលជាបាទហើយ លើកឡើងទុកក្នុងកាយ ធ្វើចិត្តឲ្យអនុលោមតាមកាយដោយលហុសញ្ញា ឲ្យ ជាការទៅយ៉ាងយឺត ព្រោះការទៅដោយកាយជារបស់យឺត ។

បទថា **អធិដ្ឋាតិ** ជាវេវចនៈរបស់បទនោះ ៗ ឯង អធិប្បាយថា ឲ្យ សម្រេច ។ បទថា **សុខសញ្ញញ្ច លហុសញ្ញញ្ច ឱក្កមិត្វា** បានដល់ ឈមចុះ ចូលទៅពាល់ត្រូវដល់សុខសញ្ញា និងលហុសញ្ញាដែលកើតព្រម ជាមួយឥទ្ធិចិត្តដែលមានឈានជាបាទជាអារម្មណ៍ ។ សញ្ញាដែលសម្បយុត្ត ដោយឧបេក្ខា ឈ្មោះថា សុខសញ្ញា ព្រោះឧបេក្ខាលោកពោលថា សេចក្តី សុខដែលល្អិត សញ្ញានោះៗឯងគប្បីជ្រាបថាជាលហុសញ្ញា ព្រោះផុតចាក នីវរណៈ និងធម៌ជាសត្រូវ មានវិតក្កៈជាដើម ។

សូម្បីករជកាយរបស់អ្នកមានឫទ្ធិឈមចុះកាន់សញ្ញានោះ ក៏ស្រាលដូច ប៉ុយគ ។ អ្នកមានឫទ្ធិនោះទៅកាន់ព្រហ្មលោក ដោយកាយដែលប្រាកដ ដូចប៉ុយគ ដែលត្រូវខ្យល់បក់ទៅយ៉ាងនេះ ម្យ៉ាងទៀត កាលទៅយ៉ាងនេះ បើប្រាថ្នា ក៏និម្មិតផ្លូវលើអាកាសដោយបឋវីកសិណហើយដើរទៅ បើប្រាថ្នា ក៏និម្មិតផ្កាឈូក គ្រប់ ៗ ជំហានជើងលើអាកាសដោយបឋវីកសិណនោះឯង

ហើយដាក់ជើងលើផ្កាឈូកដើរទៅ ។ បើប្រាថ្នា ក៏អធិដ្ឋានខ្យល់ដោយវាយោកសិណា ហើយទៅជាមួយខ្យល់ដូចប៉ុយគ ។ មួយវិញទៀត ភាពជាអ្នកប្រាថ្នានឹងទៅនោះឯង ជាប្រមាណក្នុងរឿងនេះ ។ កាលមានបំណងនឹងទៅ អ្នកមានឫទ្ធិនោះ ធ្វើអធិដ្ឋានចិត្តយ៉ាងនោះ ក៏ហោះទៅដោយកម្លាំងអធិដ្ឋាន ទៅទាំងដែលប្រាកដ ( អាចមើលឃើញ ) ដូចព្រួញស្ទុះទៅដោយកម្លាំងរបស់ខ្សែធ្នូ ។ បទថា **ចិត្តវសេន កាយំ បរិណាមេតិ** បានដល់ កំណត់ករជកាយ ហើយលើកឡើងទុកក្នុងឈានចិត្តដែលជាបាទ ធ្វើកាយឲ្យអនុលោមតាមចិត្ត ឲ្យជាការទៅយ៉ាងរហ័ស ព្រោះការទៅដោយចិត្ត ជារបស់រហ័ស ។

បទថា **សុខសញ្ញញ្ច លហុសញ្ញញ្ច ឱក្កមិត្វា** បានដល់ ឈមចុះកាន់សុខសញ្ញានិងលហុសញ្ញា ដែលកើតព្រមជាមួយឥទ្ធិចិត្ត ដែលមានរូបកាយជាអារម្មណ៍ ។ បទដ៏សេសគប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។ តែបទនេះជាការទៅដោយចិត្តប៉ុណ្ណោះ បើសួរថា អ្នកមានឫទ្ធិនេះកាលទៅដោយកាយដែលមិនប្រាកដយ៉ាងនេះ រមែងទៅក្នុងឧប្បាទខណៈនៃចិត្តអធិដ្ឋាននោះឬ ឬថាក្នុងឋិតិខណៈ ឬភង្គខណៈ ។ ព្រះថេរៈពោលថា ទៅក្នុងខណៈសូម្បីទាំង ៣ ។ ទៅដោយខ្លួនឯង ឬថាបញ្ជូនរូបនិម្មិតទៅ ធ្វើបានតាមគាប់ចិត្ត តែក្នុងទីនេះ អ្នកមានឫទ្ធិនោះទៅឯង ( ទៅផ្ទាល់ ) នោះឯង ។ បទថា **មនោមយំ** ឈ្មោះថា **មនោមយំ** ព្រោះជារូបនិម្មិតដោយអធិដ្ឋានចិត្ត ។ ឈ្មោះថា **សព្វង្គបច្ចង្គំ** បានដល់ មានអវយវៈតូចធំ

គ្រប់ទាំងអស់ ។ បទថា **អហីនិន្ទ្រិយំ** នេះ លោកពោលដោយអំណាចនៃសណ្ឋានរបស់ចក្ខុនិងសោតៈជាដើម ព្រោះក្នុងរូបនិម្មិតមិនមានបសាទ ។

បទថា **សចេ សោ ឥទ្ធិមា ចង្កមតិ និម្មិតោបិ តត្ថ ចង្កមតិ** ជាដើម លោកពោលសំដៅដល់សាវកនិម្មិតទាំងអស់ ។ ចំណែកព្រះពុទ្ធនិមិត្តទាំងឡាយ រមែងធ្វើវត្ថុដែលព្រះមានព្រះភាគ ទ្រង់ធ្វើសូម្បីយ៉ាងដទៃ ដោយអំណាចចិត្តរបស់ព្រះមានព្រះភាគ ។ បទថា **ធូមាយតិ បជ្ជលតិ** លោកពោលដោយអំណាចតេជោកសិណ ។ ៣ បទថា **ធម្មំ ភាសតិ** ជាដើម លោកពោលមិនកំណត់ ( កសិណ ) ។ បទថា **សន្តិដ្ឋតិ** បានដល់ ឈររួមគ្នា ។ បទថា **សល្លបតិ** បានដល់ សន្ទនារួមគ្នា ។ បទថា **សាកច្ឆំ សមាបជ្ជតិ** បានដល់ ប្រាស្រ័យដោយការដោះដូរការយល់ឃើញដល់គ្នានឹងគ្នា ។ មយ៉ាងទៀត ក្នុងទីនេះ ការដែលអ្នកមានឫទ្ធិនោះតាំងនៅក្នុងលោកនេះឯង រមែងឃើញរូបដោយទិព្វចក្ខុ រមែងបានឮសំឡេងដោយទិព្វសោតធាតុ រមែងដឹងចិត្តដោយចេតោបរិយញ្ញាណ ការដែលអ្នកមានឫទ្ធិនោះ តាំងនៅក្នុងលោកនេះឯង រមែងឈរសន្ទនាប្រាស្រ័យជាមួយព្រហ្មនោះ ការដែលអ្នកមានឫទ្ធិនោះអធិដ្ឋាន ក៏អធិដ្ឋាន ( នូវវត្ថុ ) ក្នុងទីឆ្ងាយឲ្យមកក្នុងទីជិតជាដើម ការដែលអ្នកមានឫទ្ធិនោះ ទៅកាន់ព្រហ្មលោកដោយកាយដែលប្រាកដក្តី មិនប្រាកដក្តី ដោយហេតុមានប្រមាណប៉ុណ្ណោះ អ្នកមានឫទ្ធិមិនឈ្មោះថា ញុំាងអំណាចឲ្យប្រព្រឹត្តទៅផ្លូវកាយបាន ។ ចំណែកការដែលដល់វិធីដូចពោលទុកដោយន័យថា ភិក្ខុនោះនិម្មិតរូបខ្ទង ... នៅខាងមុខនៃ

ព្រហ្មនោះជាដើម ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា រមែងញុំាង អំណាចឲ្យប្រព្រឹត្តទៅផ្លូវកាយបាន ។ ចំណែកបទដ៏សេសលោកពោលទុក ដើម្បីចង្អុលបង្ហាញឲ្យឃើញចំណែកខាងដើមនៃការញុំាងអំណាច ឲ្យប្រព្រឹត្ត ទៅផ្លូវកាយ ។ នេះឫទ្ធិ គឺការអធិដ្ឋាន ។

[ ១៥៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិកុព្វនិទ្ទិនិទ្ទេសដូចតទៅនេះថា លោក ពោលលើកសាវករបស់ព្រះមានព្រះភាគ ព្រះនាមសិខីជាគំរូ ដើម្បីសម្តែង កាយសក្ខីបុគ្គលនៃឫទ្ធិ ដែលប្លែងបានផ្សេង ៗ ។ ព្រះសារីបុត្តត្រេកាល សម្តែងដល់ឫទ្ធិដែលប្លែងបានផ្សេងៗនោះ ទើបសម្តែងឫទ្ធិដែលអធិដ្ឋាន គឺ ការបានឮសំឡេងនៃពាន់លោកធាតុ ដែលគួរអស្ចារ្យយ៉ាងក្រៃលែងមិនធ្លាប់ មានមកអំពីមុនថា ភិក្ខុនាមអភិភូ ... លោកឋិតនៅឰដ៏ព្រហ្មលោក អាច ញុំាងលោកធាតុទាំងមួយពាន់ឲ្យដឹងច្បាស់ដោយសំឡេងបាន ដូច្នេះ ។

ឥឡូវនេះដើម្បីសម្តែងរឿងនោះ ទើបលោកពោលសេចក្តីនេះថា ក្នុង កប្បទី ៣១ រាប់ថយអំពីកប្បនេះ ព្រះមានព្រះភាគព្រះនាមថា សិខី ចុតិ ចាកឋានសួគ៌ជាន់តុសិតក្នុងជាតិជាលំដាប់ កើតក្នុងព្រះឧទររបស់ព្រះមហេសី ព្រះនាមថា បភាវតី របស់ព្រះបាទអរុណៈ ក្នុងអរុណវតីនគរ មានព្រះ ញាណចាស់ក្លា ស្តេចក៏ចេញមហាភិនេស្រ្កមណ៍ ត្រាស់ដឹងព្រះសព្វញ្ញុ- តញ្ញាណនាពោធិមណ្ឌល ទ្រង់ប្រកាសធម្មចក្កដ៏ប្រសើរ ទ្រង់អាស្រ័យអរុ- ណវតីនគរគង់នៅ ។ ថ្ងៃមួយនាពេលព្រលឹម ទ្រង់ជម្រះព្រះកាយ ហើយ ចោមរោមដោយមហាភិក្ខុសង្ឃ ទ្រង់ព្រះតម្រិះថា នឹងចូលទៅកាន់អរុណ-

វតីនគរ ដើម្បីបិណ្ឌបាត ទ្រង់ឈរនៅជិតខ្លោងទ្វារព្រះវិហារ ត្រាស់ហៅអគ្គសាវកឈ្មោះ អភិភូ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុ ពេលវេលានៅព្រឹកពេកដែលនឹងចូលទៅកាន់អរុណវតីនគរដើម្បីបិណ្ឌបាត យើងនឹងចូលទៅកាន់ព្រហ្មលោកជាន់ណាមួយ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ ព្រះសិខីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ បានត្រាស់ហៅភិក្ខុ ឈ្មោះអភិភូថា ម្នាលព្រាហ្មណ៍ មកយើងនឹងចូលទៅកាន់ព្រហ្មលោកណាមួយ ទម្រាំដល់ពេលភត្ត ។ ម្នាលភិក្ខុទាំងឡាយ អភិភូភិក្ខុ ទទួលព្រះពុទ្ធដីកាព្រះសិខីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធថា ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ ព្រះសិខីមានព្រះភាគនិងអភិភូភិក្ខុ បានចូលទៅកាន់ព្រហ្មលោកណាមួយ[១] ដូច្នេះ ។

ក្នុងព្រហ្មលោកនោះ មហាព្រហ្មឃើញព្រះសម្មាសម្ពុទ្ធហើយ មានចិត្តត្រេកអរ ធ្វើនូវការក្រោកទទួល ក្រាលព្រហ្មាសនៈថ្វាយ ក្រាលអាសនៈដ៏សមគួរដល់ព្រះថេរៈផង ។ ព្រះមានព្រះភាគ គង់លើអាសនៈដែលបានក្រាលទុក ព្រះថេរៈក៏គង់លើអាសនៈដែលសមគួរដល់ខ្លួន មហាព្រហ្មថ្វាយបង្គំព្រះទសពលហើយ អង្គុយក្នុងចំណែកម្ខាង ។

ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ទុក ( ក្នុងសំយុត្តនិកាយ-

---

១-ព្រះពុទ្ធដីកានេះដូចគា[illegible]ងដើម [illegible]សេចកី[illegible]ងចុងខុសគា[illegible] ដ្បិតយើងកាន់យកបាលីតាមអដ៏កថា ។

សគាថវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ក្នុងលំដាប់នោះព្រះសិខីមានព្រះ-ភាគអរហន្តសម្មាសម្ពុទ្ធ ត្រាស់នឹងអភិភូភិក្ខុថា ម្នាលព្រាហ្មណ៍ អ្នកចូរសំដែងនូវធម្មីកថាដល់ព្រហ្មផង ដល់បរិស័ទរបស់ព្រហ្មផង ដល់អ្នកបម្រើរបស់ព្រហ្មផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឈ្មោះអភិភូទទួលព្រះពុទ្ធដីកាព្រះសិខីមានព្រះភាគអរហន្តសម្មាសម្ពុទ្ធថា ព្រះករុណាព្រះអង្គ ហើយញុំាងព្រហ្មផង ញុំាងបរិស័ទរបស់ព្រហ្មផង ញុំាងអ្នកបម្រើរបស់ព្រហ្មផង ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ។ ពួកព្រហ្មទាំងឡាយលើកទោសថា យូរហើយ ដែលពួកយើងបានការយាងមកកាន់ព្រហ្មលោករបស់ព្រះសាស្តា ភិក្ខុនេះផ្អាកព្រះសាស្តាទុកហើយសំដែងធម៌ឯង ។

ព្រះសាស្តាទ្រង់ជ្រាបថា ពួកព្រហ្មទាំងនោះមិនពេញចិត្ត ទើបត្រាស់នឹងភិក្ខុអភិភូថា ម្នាលព្រាហ្មណ៍ ព្រហ្មនិងបរិស័ទរបស់ព្រហ្មនិងអ្នកបម្រើរបស់ព្រហ្មទាំងនោះពោលទោស ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរញុំាងព្រហ្មនិងបរិស័ទរបស់ព្រហ្ម និងអ្នកបម្រើរបស់ព្រហ្ម ឲ្យសង្វេគក្រៃលែងជាងប្រមាណចុះ ។ ព្រះថេរៈទទួលព្រះតម្រាស់របស់ព្រះសាស្តាហើយ ក៏ប្លែងឫទ្ធិផ្សេងៗច្រើនយ៉ាង ញុំាងពាន់លោកធាតុឲ្យដឹងច្បាស់ដោយសំឡេងបានពោលគាថា ២ នេះថា

អ្នកទាំងឡាយ ចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកបព្យាយាម
ក្នុងពុទ្ធសាសនា ចូរកម្ចាត់បង់សេនានៃមច្ចុ ដូចជាកុញ្ជរញុំា

ញាំផ្ទះបបុស អ្នកណាមិនប្រហែស ក្នុងធម្មវិន័យនេះ អ្នក
នោះ នឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវទីបំផុតទុក្ខបាន
ដូច្នេះ ។

ព្រះថេរៈធ្វើដូចម្តេច ទើបញ៉ាំងពាន់លោកធាតុឲ្យដឹងច្បាស់ ដោយសំឡេង ។ ព្រះថេរៈចូលនីលកសិណមុន លុះចេញហើយផ្សាយកាពងងឹតទៅក្នុងទីទាំងពួងក្នុងពាន់ចក្កវាឡដោយអភិញ្ញាញាណ បន្ទាប់អំពីនោះកាលសត្វទាំងឡាយកើតសេចក្តីគិតថា ហេតុអ្វីក៏បានជាងងឹត ព្រះថេរៈ ក៏ចូលអាលោកកសិណ លុះចេញហើយក៏ធ្វើពន្លឺឲ្យប្រាកដ ។ កាលសត្វទាំងឡាយកំពុងសម្លឹងមើលថា ពន្លឺនេះជាអ្វី ព្រះថេរៈក៏បង្ហាញខ្លួនឲ្យប្រាកដ ។ ទេវតានិងមនុស្សក្នុងចក្កវាឡមួយពាន់ ផ្គងអញ្ជលី ឈរនមស្ការព្រះថេរៈ ព្រះថេរៈពោលថា សូមមហាជន ស្តាប់សំឡេងរបស់យើងដែលសម្តែងធម៌ ហើយបានពោលគាថាទាំងនេះ ។ ទេវតានិងមនុស្សទាំងឡាយបានឮសំឡេងរបស់ព្រះថេរៈ ដូចអង្គុយសម្តែងធម៌ក្នុងកណ្តាលបរិស័ទដែលប្រជុំគ្នា ។ អត្ថក៏ប្រាកដដល់ទេវតានិងមនុស្សទាំងនោះ ។ លោកពោលថា ឲ្យដឹងច្បាស់ដោយសំឡេងបាន សំដៅដល់ ឲ្យដឹងច្បាស់នូវអត្ថនោះ ។ លោកពោលពាក្យថា **សោ និស្សមានេនបិ** ជាដើមដូច្នេះទៀត សំដៅដល់ ឫទ្ធិដែលប្លែងបានផ្សេងៗ ច្រើនយ៉ាងដែលព្រះថេរៈនោះឃើញ ។

ក្នុងបទទាំងនោះ បទថា **ធម្មំ ទេសេសិ** បានដល់ កាលសម្តែងឫទ្ធិដែលប្លែងបានផ្សេងៗ មានប្រការដូចពោលហើយអំពីមុនទើបសម្តែងធម៌ ។

បន្ទាប់អំពីនោះ គប្បីជ្រាបថា ព្រះថេរៈពោល ២ គាថា ដោយលំដាប់តាមដែលពោលហើយ ទើបធ្វើឲ្យដឹងច្បាស់ដោយសំឡេង ។

ម្យ៉ាងទៀត ក្នុងបទថា **និស្សមានេនបិ កាយេន** ជាតតិយាវិភត្តិចុះក្នុងលក្ខណៈនៃឥត្ថម្ភូតៈ ( ប្រែថា មាន ដោយ ទាំង ) អធិប្បាយថា ជាអ្នកមានកាយយ៉ាងនោះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ លុះសម្ដែងរឿងនោះហើយ កាលសម្ដែងដល់វិធីធ្វើឫទ្ធិដែលប្លែងបានផ្សេង ៗ របស់អ្នកមានឫទ្ធិដទៃទៀត ទើបពោលពាក្យថា **សោ បកតិវណ្ណំ វិជហិត្វា** ជាដើម ។

ក្នុងបទទាំងនោះ បទថា **សោ** បានដល់ ភិក្ខុអ្នកមានឫទ្ធិនោះ ធ្វើចិត្តឲ្យទន់ គួរដល់ការងារ តាមវិធីដូចពោលហើយ ។

បើភិក្ខុអ្នកមានឫទ្ធិបំណងនឹងធ្វើឫទ្ធិដែលប្លែងបានផ្សេង ៗ ភិក្ខុអ្នកមានឫទ្ធិនោះលះបង់ភេទប្រក្រតី គឺសណ្ឋានប្រក្រតីរបស់ខ្លួនហើយ សម្ដែងភេទជាកុមារខ្លះ ។ សេចក្ដីនេះដូចម្ដេច គឺចេញចាកចតុត្ថជ្ឈានមានបឋវីកសិណជាអារម្មណ៍ មានអភិញ្ញាជាបាទហើយ នឹកដល់ភេទកុមារ ដែលគួរនិម្មិតថា អាត្មាអញចូរជាកុមារមានរូបយ៉ាងនេះ ដូច្នេះហើយ កាលធ្វើបរិកម្មស្រេច ទើបចូលសមាបត្តិទៀត លុះចេញហើយ អធិដ្ឋានដោយអភិញ្ញាញាណថា អាត្មាអញចូរជាកុមារមានរូបយ៉ាងនេះ ។ ភិក្ខុអ្នកមានឫទ្ធិនោះ ក៏ជាកុមារព្រមនឹងការអធិដ្ឋាន ។

ឈានដែលជាបាទមានបឋវីជាអារម្មណ៍ក្នុងទីនេះ រមែងត្រឹមត្រូវ សម

និងពាក្យក្នុងកសិណនិទ្ទេសក្នុងវិសុទ្ធិមគ្គថា ឫទ្ធិដែលប្លែងបានផ្សេង ៗ យ៉ាងនេះថា ភាពជាបុគ្គលម្នាក់ ឲ្យទៅជាច្រើននាក់ក៏បានជាដើម ។បេ។ រមែងសម្រេចដោយអំណាចបឋវីកសិណ ដូច្នេះ ។ ម្យ៉ាងទៀត ក្នុងឫទ្ធិដែលនិម្មិតបានផ្សេង ៗ ក្នុងអភិញ្ញានិទ្ទេសក្នុងវិសុទ្ធិមគ្គនោះៗឯង លោកពោលថា ចេញអំពីឈានដែលជាបាទនៃអភិញ្ញា ដែលមានបឋវីកសិណជាដើមឯណានីមួយជាអារម្មណ៍ ។ ម្យ៉ាងទៀត ក្នុងអភិញ្ញានិទ្ទេសនោះឯង លោកពោលថា គួរនឹកគិតដល់ភេទកុមាររបស់ខ្លួន[១]។ ពាក្យពោលនោះ ដូចជាមិនត្រឹមត្រូវក្នុងការនិម្មិតមានភេទនាគជាដើម ។ សូម្បីក្នុងការនិម្មិត មានភេទនាគជាដើម ក៏មានន័យនេះដូចគ្នា ។

ក្នុងបទទាំងនោះ បទថា **នាគវណ្ណំ** បានដល់ មានសណ្ឋានដូចពស់ ។ បទថា **សុបណ្ណវណ្ណំ** បានដល់ មានសណ្ឋានដូចគ្រុឌ ។ បទថា **ឥន្ទវណ្ណំ** បានដល់ មានសណ្ឋានដូចសក្កៈ ។ បទថា **ទេវវណ្ណំ** បានដល់ មានសណ្ឋាន ដូចទេវតាដ៏សេស ។ បទថា **សមុទ្ទវណ្ណំ** ភេទសមុទ្ទ រមែងសម្រេចដោយអំណាចនៃអាបោកសិណ ។ បទថា **បត្តឹ** បានដល់ ពលថ្មើរជើង ។

បទថា **វិវិធម្បិ សេនាព្យូហំ** បានដល់ ពួកទាហានច្រើនប្រភេទមានពលដំរីជាដើម ។ តែក្នុងវិសុទ្ធិមគ្គ លោកពោលថា ក្នុងទីនេះពាក្យថា សម្តែងជាដំរីក៏បានជាដើម លោកពោលដោយអំណាច សម្តែងដំរីជាដើម

---

១-រូបកាលខ្លួននៅពីក្មេង ។

ខាងក្រៅ ក្នុងពាក្យនោះកុំអធិដ្ឋានថា អាត្មាអញចូរជាដីវ គប្បីអធិដ្ឋានថា ដីវចូរមាន ក្នុងសេះជាដើមក៏ន័យនេះដូចគ្នា ។ ពាក្យនោះខុសចាកមូលបទ ដែលពោលថា លះបង់ភេទជាប្រក្រតី និងចាកភាពដែលឫទ្ធិប្លែងបានផ្សេង ៗ ព្រោះថា ការមិនលះបង់ភេទជាប្រក្រតីតាមលំដាប់ដូចពោលក្នុងបាលីហើយ សម្តែងភេទដទៃដោយអំណាចអធិដ្ឋាន ឈ្មោះថា ឫទ្ធិដែលអធិដ្ឋាន ការលះបង់ភេទប្រក្រតីហើយ សម្តែងខ្លួនជាយ៉ាងដទៃ ដោយអំណាចអធិដ្ឋាន ឈ្មោះថា **វិកុព្វនា ឥទ្ធិ** ។

[ ១៥៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមនោមយិទ្ធិនិទ្ទេសដូចតទៅនេះថា ក្នុងបទថា **ឥមម្ហា កាយា អញ្ញំ កាយំ អភិនិម្មិនាតិ** ជាដើម សេចក្តីថា ភិក្ខុអ្នកមានឫទ្ធិបំណងនឹងធ្វើមនោមយិទ្ធិ កាលចេញចាកឈានដែលជាបាទ ដែលមានអាកាសកសិណជាអារម្មណ៍ ហើយនឹកដល់រូបកាយរបស់ខ្លួនជាមុន ហើយអធិដ្ឋានដោយន័យដែលពោលហើយនោះឯងថា ចន្លោះចូរមាន ចន្លោះរមែងមាន រូបកាយរមែងជាប្រហោង ។ បន្ទាប់អំពីនោះ នឹកដល់កាយដទៃដោយអំណាចបរិកសិណ ក្នុងខាងក្នុងប្រហោងនោះ ហើយធ្វើបរិកម្មអធិដ្ឋានដោយន័យដូចពោលហើយនោះឯង កាយដទៃរមែងមានក្នុងប្រហោងនោះ ។ ភិក្ខុនោះខ្ជាក់កាយនោះចេញអំពីមាត់ ហើយតាំងទុកខាងក្រៅ ។ ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងប្រកាសសេចក្តីនោះដោយឧបមាទើបពោលពាក្យថា **សេយ្យថាបិ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **មុញ្ជម្හា** បានដល់ ចាកស្មៅយាប្លង ។ បទថា **ឦសិកំ បវា-**

**ហោយ្យ** បានដល់ ដកបណ្តូល ។ បទថា **កោសិយា** បានដល់ អំពីស្រោមដាវ ។ បទថា **ករណ្ឌា** បានដល់ ត្រក អធិប្បាយថា អំពីសំណកចាស់ ។

ក្នុងបទទាំងនោះ បទថា **ឧទ្ធរេយ្យ** គប្បីជ្រាបការលើកពស់នោះចេញដោយចិត្តប៉ុណ្ណោះ ព្រោះថា ធម្មតាពស់នេះរមែងសកសំណកដោយខ្លួនឯង ដោយហេតុ ៤ ប្រការនេះ គឺតាំងនៅក្នុងជាតិរបស់ខ្លួន ១ អាស្រ័យចន្លោះមែកឈើខ្លះ ចន្លោះដើមឈើខ្លះ ១ ដោយកម្លាំង គឺការសកសំណកអំពីខ្លួន ១ ស្អប់ខ្ពើមស្បែកចាស់ដូចទំពាស៊ីខ្លួន ១ ។ ក្នុងរឿងនេះលោកពោលឧបមាទាំងនេះទុកដើម្បីសម្តែងថា រូបសម្រេចអំពីឫទ្ធិផ្លូវចិត្តនេះ រមែងដូចគ្នានឹងបុគ្គលមានឫទ្ធិដោយអាការទាំងពួង ដូចបណ្តូលស្មៅយាប្លង ជាដើមដូចគ្នានឹងស្មៅយាប្លងដូច្នោះ ។ កាយដែលសម្រេចដោយចិត្ត គឺអភិញ្ញាដូចក្នុងពាក្យ ( ថេរគាថា ) នេះថា យាងមកដោយឫទ្ធិ ដោយព្រះកាយដែលសម្រេចអំពីចិត្ត ឈ្មោះថា **មនោមយកាយ** ។ កាយដែលកើតឡើងដោយចិត្ត គឺឈាន ក្នុងបទ ( វិនយបិដកចុល្លវគ្គ ) នេះថា បានទៅកើតជាទេវកាយដែលសម្រេចដោយចិត្តមួយអង្គ ឈ្មោះថា **មនោ-មយកាយ** ព្រោះចិត្តនោះធ្វើ ។ តែក្នុងទីនេះ កាយកើតឡើងហើយដោយចិត្ត គឺអភិញ្ញា ឈ្មោះថា **មនោមយកាយ** ព្រោះចិត្តនោះធ្វើ ។ កាលបើយ៉ាងនោះ បើសួរថា ឈ្មោះថា **មនោមយកាយ** ដែលអធិដ្ឋានឥទ្ធិនិងវិកុព្វនាឥទ្ធិធ្វើ រមែងមានបានឬ ឆ្លើយថា រមែងមានបាននោះឯង តែក្នុង

ទីនេះការនិម្មិតចាកខាងក្នុងប៉ុណ្ណោះ ឈ្មោះថា **មនោមយិទ្ធិ** ព្រោះលោកធ្វើឲ្យវិសេសដោយឡែកនៃឫទ្ធិទាំងនោះ ហើយពោលទុកថា ដែលឫទ្ធិ គឺអធិដ្ឋាន និងឫទ្ធិ គឺការធ្វើឲ្យប្លែក ។

[ ១៥៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងញាណវិប្ផារិទ្ធិនិទ្ទេស ដូចតទៅនេះថា ឈ្មោះថា **ញាណវិប្ផារា** ព្រោះមានកម្លាំង ដែលផ្សាយទៅនៃញាណ ។ ក្នុងបទនេះ គប្បីជ្រាបថា លោកសម្តែងឫទ្ធិដោយអំណាចអនុបស្សនា ៧ ប៉ុណ្ណោះ ហើយសង្ខេបវិបស្សនាដ៏សេសរហូតដល់អរហត្តមគ្គ ។

ក្នុងបទថា **អាយស្មតោ ពាកុលស្ស ញាណវិប្ផារា ឥទ្ធិ** ជាដើម មានសេចក្តីថា ព្រះពាកុលត្ថេរ បានឈ្មោះយ៉ាងនេះ ព្រោះជាអ្នកចម្រើនក្នុងត្រកូលទាំងពីរ សន្សំបុញ្ញបារមីមកក្នុងព្រះពុទ្ធអង្គមុន ៗ ជាព្រះថេរៈដែលដល់ព្រមដោយបុញ្ញសម្បទា ពិតណាស់ ព្រះថេរៈនោះសោយមហាសម្បត្តិ អន្ទោលទៅក្នុងទេវលោកនិងមនុស្សលោក កើតក្នុងសាសនារបស់ព្រះទសពលនៃយើង លោកកើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងកោសម្ពី ។ ក្នុងវេលាដែលព្រះថេរៈនោះកើត អ្នកបម្រើព្រមទាំងបរិវារក៏នាំទៅកាន់ស្ទឹងយមុនា ព្រមជាមួយបរិវារដ៏ច្រើន ដើម្បីសិរីមង្គល ឲ្យលេងទឹក មុជចុះផុសឡើង ត្រីធំមួយសម្គាល់ថា ទារកនេះជាអាហាររបស់អញទើបហាមាត់ហែលទៅរក ។ ស្ត្រីបម្រើទុកទារកចោលគេចទៅ ។ ត្រីធំក៏លេបទារកនោះ ។ សត្វដែលមានបុណ្យ មិនបានទទួលនូវទុក្ខអ្វីឡើយ ហាក់បីដូចចូលទៅនៅក្នុងបន្ទប់ដេកដូច្នោះ ដោយតេជះរបស់ទារក ត្រីក៏ក្តៅក្រហល់

ក្រហាយ ដូចលេបក្បៀងក្ដៅហើយហែលទៅយ៉ាងលឿនអស់ចម្ងាយ ៣០ យោជន៍ ចូលទៅជាប់សំណាញ់របស់ព្រានប្រម៉ង់អ្នកក្រុងពារាណសី ។ ត្រីនោះពេលព្រានប្រម៉ង់យកចេញអំពីសំណាញ់ប៉ុណ្ណោះ ក៏ស្លាប់ទៅដោយតេជះរបស់ទារកនោះ ។ ព្រានប្រម៉ង់ចងត្រីនោះ ដាក់ត្រង់ចន្លោះដងរែក សែងទៅទាំងមូលគិតថា នឹងលក់ក្នុងតម្លៃ ១.០០០ រូបត្រាច់ទៅក្នុងនគរ ទៅដល់ទ្វារផ្ទះរបស់សេដ្ឋីមិនមានបុត្ត មានទ្រព្យ ៨០ កោដិ បានលក់ ត្រីឲ្យភរិយាសេដ្ឋី ១ កហាបណៈ ។ សេដ្ឋីនីយកត្រីដាក់លើបន្ទះក្ដារដោយខ្លួនឯងហើយវះត្រីនោះអំពីខ្នង លុះឃើញទារកមានពណ៌ដូចមាសនៅក្នុងពោះត្រីទើបបន្លឺកឡើងថា យើងបានបុត្តក្នុងពោះត្រី ហើយពទារកចូលទៅរកស្វាមី ។ ក្នុងពេលនោះឯង សេដ្ឋីឲ្យវាយស្គរប្រកាសហើយនាំទារកទៅគាល់ព្រះរាជាក្រាបទូលសេចក្ដីនោះឲ្យទ្រង់ជ្រាប ។ ព្រះរាជាត្រាស់ថា ទារកមានបុណ្យលោកចូរចិញ្ចឹមទារកឲ្យបានល្អ ។ ត្រកូលសេដ្ឋីដែលជាមាតាបិតាលុះជ្រាបរឿងនោះ ទើបទៅកាន់នគរនោះនិយាយថា បុត្តរបស់យើង ទើបដណ្ដើមគ្នាយកទារកនោះ ។ ទាំងពីរនាក់ក៏បានទៅគាល់ព្រះរាជា ។

ព្រះរាជាត្រាស់ថា យើងមិនអាចធ្វើឲ្យត្រកូលទាំងពីរ មិនឲ្យមានបុត្តបាន ទារកនេះ ចូរជាទាយាទរបស់ត្រកូលទាំងពីរចុះ ។ តាំងអំពីនោះមកត្រកូលទាំងពីរក៏ឧត្ដមសម្បូរដោយលាភច្រើន ។ ព្រោះត្រកូលចិញ្ចឹមទារកនោះឲ្យធំធាត់ ទើបពួកញាតិដាក់ឈ្មោះថា ពាកុលកុមារ ។ កាលពាកុ-លកុមារនោះដឹងក្ដីហើយ មាតាបិតាក៏សាងប្រាសាទមួយកន្លែង មានបីខ្នង

ក្នុងនគរទាំងពីរ រកអ្នកប្រៀនរាំមកសម្តែងជាប្រចាំ ។ ពាកុលកុមាររស់នៅក្នុងនគរនីមួយៗរយៈពេលបួនខែ ។ កាលពាកុលកុមាររស់នៅក្នុងនគរមួយគ្រប់បួនខែ មាតាបិតាឲ្យសាងមណ្ឌបទុកលើទូកធំមួយហើយឲ្យពាកុលកុមារ ព្រមទាំងអ្នករបាំឡើងទៅលើទូកធំនោះ ហើយនាំពាកុលកុមារសោយមហាសម្បត្តិទៅកាន់នគរមួយទៀត ពីរខែបានពាក់កណ្តាលផ្លូវ ។ សូម្បីពួកអ្នកនគរមួយពួកទៀត ក៏ត្រៀមទទួលដូចគ្នា ដោយគិតថា ពីរខែទៀតពាកុលកុមារ នឹងមកដល់ពាក់កណ្តាលផ្លូវ ហើយនាំទៅកាន់នគររបស់ខ្លួនអស់កាលពីរខែ ។ ពួកអ្នករបាំនគរមួយទៀត ត្រឡប់ទៅកាន់នគររបស់ខ្លួនតោះឯងដល់ត្រឹមពាក់កណ្តាលផ្លូវ ។ ពាកុលកុមាររស់នៅក្នុងនគរនោះបួនខែ ហើយត្រឡប់ទៅនគរមួយទៀត ដោយទំនងនោះឯង ។ កាលពាកុលកុមារសោយសម្បត្តិយ៉ាងនេះ អាយុក៏ ៨០ ឆ្នាំបរិបូរណ៍ ។

ក្នុងសម័យនោះ ព្រះពោធិសត្វនៃយើង បានសម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ទ្រង់ប្រកាសព្រះធម្មចក្កដ៏ប្រសើរ ស្តេចចារិកទៅតាមលំដាប់រហូតដល់ក្រុងកោសម្ពី ។ ព្រះមជ្ឈិមភាណកាចារ្យពោលថា នគរពារាណសី ។ ពាកុលសេដ្ឋី ក៏បានឮថា ព្រះទសពលយាងមក ទើបកាន់យកផ្កាកម្រងនិងគ្រឿងក្រអូបជាច្រើនទៅគាល់ព្រះសាស្តាស្តាប់ធម្មកថា មានសទ្ធាហើយក៏បួស ។ ព្រះពាកុលៈនៅជាបុថុជ្ជន ៧ ថ្ងៃប៉ុណ្ណោះ ក្នុងអរុណថ្ងៃទី ៨ ក៏បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ។

លំដាប់នោះ មាតុគ្រាមដែលនៅក្នុងនគរទាំងពីរ មកអំពីត្រកូលរបស់

ខ្ជួន នៅក្នុងទីនោះធ្វើចីវរបញ្ជូនទៅប្រគេនដល់លោក ។ ព្រះថេរៈប្រើប្រាស់ចីវរដែលអ្នកក្រុងកោសម្ពីបញ្ជូនទៅប្រគេនកន្លះខែ ប្រើប្រាស់ចីវរដែលអ្នកក្រុងពារាណសីធ្វើបញ្ជូនទៅប្រគេនកន្លះខែ ។ ដោយទំនងនេះឯង អ្នកនគរទាំងពីរបាននាំវត្ថុដែលល្អបំផុត ក្នុងនគរទាំងពីរមកប្រគេនព្រះថេរៈ ដោយប្រការដូច្នេះ ។ ចំណែកព្រះថេរៈបួសបាន ៨០ វស្សា ដោយសេចក្តីសុខ ។ អាពាធសូម្បីប្រមាណតិចតួច ក៏មិនធ្លាប់មានដល់ព្រះថេរៈនោះ សូម្បីត្រឹមតែមួយស្របក់ក្នុងទីទាំងពីរស្ថាន ។ ព្រះថេរៈពោលពាកុលសូត្រក្នុងទីបំផុតចុងក្រោយ ហើយក៏បរិនិព្វាន ដោយប្រការដូច្នេះ ។ ការមិនមានរោគក្នុងពោះត្រីយ៉ាងនេះ ឈ្មោះថា **ញាណវិប្ផារា ឥទ្ធិ** ព្រោះព្រះពាកុលៈជាអ្នកកើតក្នុងភពចុងក្រោយ កើតដោយអានុភាពនៃអរហត្តញាណ ដែលគួរបានដោយអត្តភាពនោះ ។ អាចារ្យទាំងឡាយពោលថា ដោយអានុភាពនៃបដិសម្ភិទាញាណ ដែលសម្រេចដោយផលនៃសុចរិតកម្មក៏មាន ។

សូម្បីព្រះសំកិច្ចត្ថេរ ក៏ធ្លាប់ធ្វើបុណ្យទុកអំពីមុន បានកើតក្នុងផ្ទៃរបស់ធីតាត្រកូលស្តុកស្តម្ភក្នុងនគរសាវត្ថី ដែលជាឧបដ្ឋាករបស់ព្រះធម្មសេនាបតីថេរៈ ។ ធីតានោះ កាលទារកនៅក្នុងផ្ទៃ ក៏អនិច្ចកម្មយ៉ាងរហ័សនោះឯងដោយរោគឯណានីមួយ ។ កាលសាកសពរបស់ធីតានោះត្រូវដុត វៀរសាច់ត្រង់ផ្ទៃ សាច់ដទៃឆេះអស់ ។ លំដាប់នោះសាច់ត្រង់ផ្ទៃរបស់នាងក៏ធ្លាក់អំពីជើងថ្ករ អ្នកពុកយកឈើស្រួចចាក់ក្នុងទី ២-៣ កន្លែង ។ ចុងឈើក៏ត្រូវកន្ទុយភ្នែករបស់ទារក ។ អ្នកពុកចាក់សាច់ត្រង់ផ្ទៃហើយច្រឹះដាក់ត្រង់

គំនររងើកភ្លើង យករងើកភ្លើងលុបហើយត្រឡប់ទៅ ។ សាច់ត្រង់ផ្ទៃឆេះអស់ តែទៅខាងលើរងើកភ្លើង មានទារកដូចគ្នានឹងបដិមាមាស ដេកលើត្របកឈូក ។ ពិតណាស់ កាលសត្វដែលកើតក្នុងភពចុងក្រោយ សូម្បីត្រូវភ្នំសិនេរុសង្កត់ បើមិនទាន់សម្រេចអរហត្តហើយអស់ជីវិតមុនមិនមាន ។ លុះព្រឹកឡើងអ្នកពួកគិតថា នឹងរំលត់ជើងថ្ករទើបនាំគ្នាមក ឃើញទារកដេកយ៉ាងនោះ កើតអស្ចារ្យក្នុងចិត្តមិនធ្លាប់មាន ទើបនាំទារកទៅកាន់នគរ សួរអ្នកព្យាករណ៍ ។ អ្នកព្យាករណ៍ពោលថា បើទារកនេះនៅគ្រប់គ្រងផ្ទះ ពួកញាតិនឹងកើតសេចក្តីលំបាកអស់ ៧ ជួរត្រកូល បើបួសនឹងមានសមណៈ ៥០០ ចោមរោម ត្រាច់ទៅ ។ ជីតាបានចិញ្ចឹមទារកនោះ រហូតដល់ធំ កាលទារកចម្រើនវ័យ សូម្បីពួកញាតិក៏នាំគ្នាចិញ្ចឹមរក្សា ដោយប្រាថ្នាថា នឹងឲ្យបួសក្នុងសម្នាក់លោកម្ចាស់របស់យើង ។ កាលទារកមានអាយុបាន ៧ ខួប បានឮក្មេងៗនិយាយគ្នាថា មាតារបស់ឯងស្លាប់តាំងអំពីឯងនៅក្នុងគភ៌ កាលបើសពរបស់មាតាត្រូវដុត ឯងក៏មិនឆេះដោយភ្លើង ទើបប្រាប់ដល់ពួកញាតិថា បានឮថា ខ្ញុំផុតចាកភ័យមានសភាពបែបនេះ ខ្ញុំមិននៅជាយរាវាសឡើយ ខ្ញុំនឹងចេញបួស ។ ពួកញាតិពោលថា សាធុ ទើបនាំទារកនោះទៅរកព្រះធម្មសេនាបតីសារីបុត្តប្រគល់ឲ្យថា សូមលោកម្ចាស់ឲ្យកុមារនេះបួសចុះ ។ ព្រះថេរៈឲ្យតចបញ្ចកកម្មដ្ឋានហើយឲ្យទារកបួស ។ ទារកនោះកាលកោរសក់ស្រេចប៉ុណ្ណោះ ក៏បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។ លុះមានអាយុគ្រប់ក៏បានឧបសម្បទា បួសបាន ១០

វស្សា ក៏មានភិក្ខុ ៥០០ ជាបរិវារត្រាច់ទៅ ។ ភាពជាអ្នកមិនមានរោគ លើជើងថ្ករដោយន័យដូចពោលហើយនោះឯងយ៉ាងនេះ ឈ្មោះថា **ញាណ-វិប្ផារា ឥទ្ធិ** របស់ព្រះសំកិច្ចៈ ។

សូម្បីព្រះភូតបាលត្ថេរ ក៏ជាអ្នកដល់ព្រមដោយហេតុ ក្នុងកាលមុន ។ បិតារបស់លោកជាអ្នកក្រីក្ររស់នៅក្នុងក្រុងរាជគ្រឹះ ។ បិតានាំទារកនោះធ្វើដំណើរទៅក្នុងព្រៃជ្រៅដោយរទេះ ដើម្បីរកឧស ដាក់ឧសពេញរទេះហើយក៏ធ្វើដំណើរត្រឡប់ មកដល់ជិតទ្វារនគរក្នុងវេលាល្ងាច ។ លំដាប់នោះគោទាំងឡាយរបស់គាត់ រលាស់នឹមចេញហើយដើរចូលទៅក្នុងនគរ ។ បុរសនោះឲ្យកូនតូច អង្គុយក្រោមរទេះ ហើយដើរតាមស្នាមជើងគោចូលទៅក្នុងនគរដូចគ្នា ។ កាលបុរសនោះមិនទាន់ត្រឡប់មក ទ្វារនគរក៏បិទ ទារកដេកក្រោមរទេះអស់មួយរាត្រី ។ តាមប្រក្រតីនគររាជគ្រឹះ មានអមនុស្សច្រើនទីដែលទារកដេក ជាទីជិតព្រៃស្មសាន តែមិនមានយក្ខណាមួយ អាចធ្វើអន្តរាយដល់ទារក ដែលកើតក្នុងកពចុងក្រោយនោះបាន ។ ក្នុងកាលតមកទារកនោះបួសក៏បានសម្រេចអរហត្ត មានឈ្មោះថា ភូតបាលត្ថេរ ។ ភាពជាអ្នកមិនមានរោគ ដោយន័យដូចពោលហើយ ក្នុងទីកន្លែងសូម្បីជាទីត្រាច់ទៅនៃយក្ខកាចយ៉ាងនេះ ឈ្មោះថា **ញាណវិប្ផារា ឥទ្ធិ** របស់ព្រះភូត-បាលៈ ។

[ ១៦០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមាធិវិប្ផារិទ្ធិនិទ្ទេស ដូចតទៅនេះថា ក្នុងបទថា **អាយស្មតោ សារិបុត្តស្ស សមាធិវិប្ផារា ឥទ្ធិ** ជាដើម សេច-

ក្តីថា កាលព្រះសារីបុត្ត នៅឯកបោតកន្ទរាវិហារជាមួយនឹងព្រះមហាមោគ្គ-
ល្លានត្ថេរ ក្នុងយប់ខែភ្លឺ មានសក់កោរថ្មីៗ អង្គុយក្នុងទីវាល យក្ខកំណាច
ម្នាក់ សូម្បីត្រូវយក្ខជាសម្លាញ់ហាមក៏បានវាយសីសៈរបស់ព្រះថេរៈ មាន
សំឡេងយ៉ាងកងរំពងដូចសំឡេងរន្ទះ ។ ក្នុងខណៈដែលយក្ខប្រហារ ព្រះ
ថេរៈអង្គុយចូលសមាបត្តិ ទើបមិនមានការឈឺចាប់ណាមួយ ដោយការប្រហារ
នោះដល់ព្រះថេរៈនោះ ។ នេះជា **សមាធិវិប្ផារា ឥទ្ធិ** របស់ព្រះសារី-
បុត្តត្ថេរនោះ ។ សមដូចព្រះសង្គីតិកាចារ្យពោលទុក ( ក្នុងខុទ្ទកនិកាយ
ឧទាន ) ថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ
ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថានជិតក្រុងរាជគ្រឹះ ។ សម័យ
នោះឯង ព្រះសារីបុត្តដ៏មានអាយុនិងព្រះមហាមោគ្គល្លានដ៏មានអាយុ នៅ
ក្នុងវត្តកបោតកន្ទរា ។ សម័យនោះ ព្រះសារីបុត្តដ៏មានអាយុមានសក់ទើប
កោរថ្មីៗ អង្គុយក្នុងទីវាល ចូលកាន់សមាធិណាមួយក្នុងរាត្រីខាងខ្នើត ។

សម័យនោះ មានយក្ស ២ នាក់ជាសម្លាញ់នឹងគ្នា មកអំពីទិសខាង
ជើងទៅទិសខាងត្បូងដោយកិច្ចណាមួយ ។ យក្សទាំងនោះបានឃើញព្រះ
សារីបុត្តដ៏មានអាយុ មានសក់ទើបកោរថ្មី ៗ អង្គុយក្នុងទីវាល ក្នុងរាត្រី
ខាងខ្នើត លុះយក្សម្នាក់បានឃើញហើយ និយាយប្រាប់យក្សម្នាក់ទៀតថា
ម្នាលសម្លាញ់ ចិត្តរបស់ខ្ញុំកើតប្រាកដ ដើម្បីប្រហារក្បាលសមណៈនេះ ។
កាលបើយក្សម្នាក់និយាយយ៉ាងនេះហើយ យក្សនោះក៏និយាយទៅនឹងយក្ស
ម្នាក់ទៀតនោះថា កុំសម្លាញ់ អ្នកកុំប្រហារសមណៈឡើយ ម្នាលសម្លាញ់

សមណៈនោះមានគុណដ៏លើសលុប មានឫទ្ធិច្រើន មានអានុភាពច្រើន ។ យក្សម្នាក់នោះបាននិយាយនឹងយក្សនោះជាគម្រប់ ២ ដង ។បេ។ ជាគម្រប់ ៣ ដងទៀតថា ម្នាលសម្លាញ់ ចិត្តរបស់ខ្ញុំកើតប្រាកដ ដើម្បីប្រហារក្បាលសមណៈនេះ ។ យក្សនោះនិយាយទៅនឹងយក្សម្នាក់ទៀតនោះ ជាគម្រប់ ៣ ដងទៀតថា កុំសម្លាញ់ អ្នកកុំប្រហារសមណៈឡើយ ម្នាលសម្លាញ់ សមណៈនោះមានគុណដ៏លើសលុប មានឫទ្ធិច្រើន មានអានុភាពច្រើន ។ លំដាប់នោះយក្សម្នាក់នោះ មិនអើពើនឹងយក្សនោះឡើយ ហើយប្រហារចំព្រះសិរព្រះសារីបុត្តត្ថេរដ៏មានអាយុ ។ មានសេចក្ដីដំណាលថាយក្សនោះ អាចពន្លិចដំរីមានកំពស់ ៧ ហត្ថ ឬ ៨ ហត្ថ ( ឲ្យស្រុតទៅក្នុងផែនដី ) ក៏បាន អាចធ្វើកំពូលភ្នំធំ ឲ្យបែបខ្ទេចខ្ទីក៏បាន ដោយការប្រហារនោះ ។ លំដាប់នោះស្រាប់តែយក្សនោះពោលថា ខ្ញុំក្ដៅណាស់ ដូច្នេះ ហើយធ្លាក់ទៅកាន់មហានរកត្រង់ទីនោះឯង ។

ព្រះមហាមោគ្គល្លានដ៏មានអាយុ បានឃើញយក្សនោះ កំពុងប្រហារចំព្រះសិរៈព្រះសារីបុត្តដ៏មានអាយុ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា លុះឃើញហើយក៏ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយក៏និយាយនឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលអាវុសោ លោកល្មមអត់ធន់បានដែរឬ ល្មមប្រព្រឹត្តទៅបានដែរឬ មិនមានសេចក្ដីទុក្ខតិចតួចទេឬ ។ ព្រះសារីបុត្តដ៏មានអាយុប្រាប់ថា ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមអត់ធន់បាន ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមប្រព្រឹត្តទៅបាន តែថា

មានសេចក្តីទុក្ខបន្តិចត្រង់ក្បាលរបស់ខ្ញុំ ។ ម្នាលអាវុសោសារីបុត្ត អស្ចារ្យណាស់ ម្នាលអាវុសោសារីបុត្ត ចំឡែកណាស់ ព្រោះថា សារីបុត្តដ៏មានអាយុ មានឫទ្ធិច្រើន មានអានុភាពច្រើន ។ ម្នាលអាវុសោសារីបុត្ត ក្នុងទីនេះមានយក្សមួយ ប្រហារចំព្រះសិរ្សៈនៃលោក ( ការប្រហារនោះ ) ពេញជាការប្រហារខ្លាំង ឯយក្សនោះអាចពន្លិចដំរីមានកំពស់ ៧ ហត្ថ ឬ ៨ ហត្ថ[១] ( ឲ្យស្រុតទៅក្នុងផែនដីបាន ) អាចធ្វើកំពូលភ្នំធំឲ្យបែកខ្ទេចខ្ទីបានដោយការប្រហារនោះ ។ ហេតុអ្វីក៏ព្រះសារីបុត្តដ៏មានអាយុ និយាយយ៉ាងនេះថា ម្នាលអាវុសោមោគ្គល្លាន ខ្ញុំល្មមអត់ធន់បាន ម្នាលអាវុសោមោ-គ្គល្លាន ខ្ញុំល្មមប្រព្រឹត្តទៅបាន តែថាមានសេចក្តីទុក្ខបន្តិចត្រង់ក្បាលរបស់ខ្ញុំ ។ ម្នាលអាវុសោមោគ្គល្លាន អស្ចារ្យណាស់ ម្នាលអាវុសោមោគ្គល្លាន ចំឡែកណាស់ ព្រោះថា មហាមោគ្គល្លានដ៏មានអាយុ មានឫទ្ធិច្រើន មានអានុភាពច្រើន មើលយក្សឃើញបាន ចំណែកខាងយើងមិនឃើញ សូម្បីបិសាចដែលអាស្រ័យនឹងអាចម៍ដីសោះឡើយ ។

ព្រះមានព្រះភាគ ទ្រង់ព្រះសណ្តាប់ពាក្យចរចា មានសភាពយ៉ាងនេះរបស់ព្រះមហានាគត្ថេរ ទាំង ២ អង្គនោះ ដោយទិព្វសោតធាតុដ៏បរិសុទ្ធកន្លងសោតធាតុរបស់មនុស្សធម្មតា ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបបន្លឺឧទាននេះក្នុងវេលានោះថា

ចិត្តរបស់បុគ្គលណាមានឧបមាដោយថ្មតាន់ នៅនឹងមិនញាប់

---

១-ច្បាប់ឆដ្ឋសង្គាយនាជា ៨ ហត្ថកន្លះ ។

ញ៉ូវ ប្រាសចាកតម្រេក ក្នុងហេតុគួរីករាយទាំងឡាយ មិន
ក្រោធក្នុងវត្ថុគួរក្រោធ ចិត្តដែលបុគ្គលណាបានចម្រើនយ៉ាង
នេះហើយ សេចក្ដីទុក្ខនឹងមានមកដល់បុគ្គលនោះ អំពីណា
បាន ដូច្នេះ ។

ម្យ៉ាងទៀត ពាក្យក្នុងអដ្ឋកថាថា ដោយការប្រហារនោះមិនមានសេចក្ដីឈឺចាប់ណាមួយឡើយ សមដូចព្រះតម្រាស់របស់ព្រះមានព្រះភាគ ត្រាស់ទុកថា សេចក្ដីទុក្ខនឹងមានមកដល់បុគ្គលនោះអំពីណាបាន ព្រោះហេតុនោះ ទុក្ខវេទនា រមែងមិនមាន ដូចពាក្យព្រះសារីបុត្តត្ថេរពោលថា តែថាមានសេចក្ដីទុក្ខបន្តិចត្រង់ក្បាលរបស់ខ្ញុំ តែលោកពោលថា ទុក្ខ សំដៅដល់សីសៈនោះមិនគួរដល់ការផ្ការ ។ ពិតណាស់ សូម្បីក្នុងលោក លោកក៏ពោលថា ប្រក្រតីនៃសេចក្ដីសុខអាចរក្សាបានដោយមិនលំបាក ប្រក្រតីនៃសេចក្ដីទុក្ខអាចរក្សាបានដោយលំបាក ។ ភាពដែលសីសៈមិនគួរដល់ការ-ផ្ការនោះ គប្បីជ្រាបថា ដែលមាន ព្រោះជាសម័យចេញចាកសមាបត្តិហើយ ។ ក្នុងសម័យដែលចូលសមាបត្តិ ភាពមិនគួរដល់ការផ្ការនោះគប្បីមាន មិនមានឡើយ ។ ព្រះសារីបុត្តពោលថា ចំណែកខាងយើងមិនឃើញសូម្បីបិសាចដែលអាស្រ័យនឹងអាចម៍ដីសោះឡើយ មិនមែនព្រោះមិនអាចនឹងឃើញបាន លោកពោលហើយព្រោះមិនមានសេចក្ដីខ្វល់ខ្វាយក្នុងអភិញ្ញាទាំងឡាយ ។ បានឮថា ព្រះថេរៈកាលអនុគ្រោះដល់ពពួកជនក្នុងកាលជាខាងក្រោយថា ពួកជនក្នុងកាលឯក្រោយ កុំមានការសម្គាល់ឫទ្ធិ ដែលជា

របស់បុថុជ្ជនថា ជាវត្ថុមានសារៈឡើយ ដោយច្រើនទើបមិនប្រើឫទ្ធិ ។ ម្យ៉ាងទៀត ក្នុងថេរគាថាព្រះសារីបុត្តត្រេរពោលទុកថា

ខ្ញុំមិនមានការតាំងចិត្តចំពោះបុព្វេនិវាសានុស្សតិវិជ្ជា ឬទិព្វចក្ខុវិជ្ជាឡើយ ខ្ញុំមិនមានការតាំងចិត្ត ចំពោះចេតោបរិយវិជ្ជា ឥទ្ធិវិធវិជ្ជា ចុតូបបាតវិជ្ជា និងសេចក្ដីបរិសុទ្ធនៃសោតធាតុឡើយ ។

ព្រះថេរពោលដល់ការមិនមានសេចក្ដីប្រាថ្នាក្នុងអភិញ្ញាទាំងឡាយដោយខ្លួនឯង តែព្រះថេរៈបានសម្រេចនូវបារមីក្នុងសាវកបារមីញាណ ៦៧ ប្រការ ។

អ្នកចិញ្ចឹមគោជាដើម យល់ថា ព្រះសញ្ជីវត្ថេរដែលចូលនិរោធ ជាអគ្គសាវកទីពីររបស់ព្រះមានព្រះភាគព្រះនាមថា កកុសន្ធៈ ធ្វើមរណកាលហើយ ទើបអូសយកស្មៅនិងឧសជាដើម មកគរដុត សូម្បីត្រឹមតែសរសៃអំបោះត្រង់ចីវររបស់ព្រះថេរៈក៏មិនឆេះ នេះជាឫទ្ធិដែលផ្សាយទៅ ដោយសមាធិ ព្រោះកើតដោយអានុភាពនៃសមថៈដែលប្រព្រឹត្តទៅហើយ ដោយអំណាចអនុបុព្វសមាបត្តិរបស់ព្រះថេរៈ សមដូចព្រះមានព្រះភាគត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា

ក៏សម័យនោះព្រះមានព្រះភាគទ្រង់ព្រះនាម កកុសន្ធៈ ជាអរហន្តសម្មាសម្ពុទ្ធត្រាស់ឡើងក្នុងលោក ។ ម្នាលមារមានចិត្តបាប ព្រះមានព្រះភាគទ្រង់ព្រះនាម កកុសន្ធៈ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់មានគូមហាសាវក

ឈ្មោះវិធុរៈ ១ ឈ្មោះសញ្ជីវៈ ១ ជាគូដ៏ប្រសើរ ដ៏ចម្រើន ។ ម្នាល មារមានចិត្តបាប ពួកសាវ័ករបស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមកកុសន្ធៈ ជាអរហន្តសម្មាសម្ពុទ្ធ ក្នុងសាសនានេះ មិនមានសាវ័កណាមួយស្មើនឹង វិធុរៈមានអាយុ ក្នុងការសម្តែងធម៌ឡើយ ។ ម្នាលមារមានចិត្តបាប ដោយ ហេតុនេះវិធុរៈមានអាយុ មានឈ្មោះថា វិធុរៈ វិធុរៈ ដូច្នេះ កើតប្រាកដ ឡើង ។ ម្នាលមារមានចិត្តបាប ចំណែកខាងសញ្ជីវៈមានអាយុ នៅក្នុង ព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងតែចូលសញ្ញាវេទ- យិតនិរោធដោយសេចក្តីលំបាកតិច ។ ម្នាលមារមានចិត្តបាប កាលពីដើម មក សញ្ជីវៈមានអាយុ អង្គុយចូលសញ្ញាវេទយិតនិរោធ ក្រោមម្លប់ឈើ មួយដើម ។ ម្នាលមារមានចិត្តបាប ពួកអ្នករក្សាគោ ពួកអ្នករក្សាពពែ ពួកអ្នកភ្ជួររាស់និងពួកអ្នកដំណើរបានឃើញសញ្ជីវៈមានអាយុ កំពុងអង្គុយ ចូលសញ្ញាវេទយិតនិរោធ ក្រោមម្លប់ឈើមួយដើម លុះឃើញហើយពួក ជនទាំងនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អើ នេះអស្ចារ្យណាស់ហ្ន៎ អើ មិនដែលមានទេហ្ន៎ សមណៈនេះអង្គុយធ្វើមរណកាលទៅហើយ បើដូច្នោះ យើងនឹងនាំគ្នាបូជាសពលោក ។ ម្នាលមារមានចិត្តបាប គ្រានោះពួកអ្នក រក្សាគោ ពួកអ្នករក្សាពពែ ពួកអ្នកភ្ជួររាស់និងពួកអ្នកដំណើរនោះ ប្រមូល នូវស្មៅ ឧសនិងអាចម៍គោមករុំកាយព្រះសញ្ជីវៈមានអាយុ ហើយក៏ដុល ភ្លើងហើយចៀសចេញទៅ ។ ម្នាលមារមានចិត្តបាប គ្រានោះព្រះសញ្ជីវៈ មានអាយុ លុះកន្លងរាត្រីនោះទៅទើបចេញអំពីសមាបត្តិនោះ ក៏រលាស់ចីវរ

ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរចូល ទៅកាន់ស្រុកដើម្បីបិណ្ឌបាតក្នុងវេលាព្រឹកព្រហាម ។ ម្នាលមារមានចិត្តបាប ពួកអ្នករក្សាគោ ពួកអ្នករក្សាពពែ ពួកអ្នកភ្ជួររាស់និងពួកអ្នកដំណើរទាំងនោះ បានឃើញព្រះសញ្ជីវៈមានអាយុកំពុងត្រាច់ទៅបិណ្ឌបាតហើយ ពួកជនទាំងនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អើ អស្ចារ្យណាស់ហ្ន៎ អើ មិនដែលមានទេហ្ន៎ សមណៈនេះអង្គុយធ្វើមរណកាលទៅហើយ ឥឡូវសមណៈនេះត្រឡប់មានសញ្ញាឋិតនៅវិញ ។ ម្នាលមារមានចិត្តបាប ដោយហេតុនេះព្រះសញ្ជីវៈមានអាយុ មានឈ្មោះថា សញ្ជីវៈ សញ្ជីវៈ កើតឡើងយ៉ាងនេះឯង ។

ចំណែកព្រះខាណុកោណ្ឌញ្ញត្ថេរ តាមប្រក្រតីជាអ្នកច្រើនដោយសមាបត្តិ ព្រះថេរៈនោះអង្គុយចូលសមាបត្តិអស់រាត្រីក្នុងព្រៃមួយកន្លែង ។ ចោរ ៥០០ នាក់ លួចទ្រព្យ ( អ្នកស្រុក ) ធ្វើដំណើរទៅបំណងនឹងសម្រាកដោយគិតថា ឥឡូវនេះមិនមានមនុស្សដើរតាមស្នាមជើងពួកយើង ទើបដាក់ទ្រព្យចុះ សម្គាល់ថា ជន្ទត់ឈើ ទើបដាក់ទ្រព្យទាំងអស់ទុកលើរាងកាយនៃព្រះថេរៈនោះឯង ។ កាលពួកចោរសម្រាកហើយត្រៀមនឹងដើរទៅក្នុងខណៈដែលនឹងកាន់យកទ្រព្យដែលដាក់ទុកក្នុងគ្រាដំបូង ព្រះថេរៈក្រោកឡើងតាមវេលាដែលកំណត់ទុក ។ ពួកចោរឃើញអាការដែលព្រះថេរៈធ្វើចលនាបានក៏ស្រែកឡើងដោយការភ័យខ្លាច ព្រះថេរៈពោលថា ឧបាសកទាំងឡាយកុំខ្លាចឡើយ អាត្មាជាភិក្ខុ ទើបពួកចោរនាំគ្នាមកថ្វាយបង្គំ បួសដោយសេចក្តីជ្រះថ្លាក្នុងព្រះថេរៈ ហើយសម្រេចអរហត្តមួយអន្លើដោយបដិ-

សម្អិទា ។ ចាប់តាំងអំពីនោះមកទើបព្រះថេរៈបានឈ្មោះថា ខាណុកោណ្ឌញ្ញត្ថេរ ។ កាលដែលព្រះខាណុកោណ្ឌញ្ញត្ថេរនោះ ត្រូវចោរយកទ្រព្យ ៥០០ បង្វេចដាក់សង្កត់ពីលើ ហើយមិនមានការឈឺចាប់ នេះជាឫទ្ធិដែលផ្សាយទៅដោយសមាធិ ។

ចំណែកនាងឧត្តរាឧបាសិកា ធីតារបស់បុណ្ណសេដ្ឋី អ្នកមានទ្រព្យច្រើនក្នុងក្រុងរាជគ្រឹះ ក្នុងវេលាជាកុមារិកានោះឯង បានសម្រេចសោតាបត្តិផលព្រមជាមួយមាតាបិតា នាងចម្រើនវ័យហើយ មាតាបិតាបានលើកនាងឲ្យដល់បុត្តរបស់រាជគហសេដ្ឋី ដែលជាមិច្ឆាទិដ្ឋិដោយសម្ពន្ធមេត្រីគ្នាច្រើន ។ នាងឧត្តរាឧបាសិកា មិនបានឱកាសដើម្បីឃើញព្រះពុទ្ធ ដើម្បីស្តាប់ធម៌និងដើម្បីថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ជាអ្នកខ្វល់ខ្វាយ ទើបហៅស្រីគណិកាឈ្មោះថា សិរិមា ក្នុងនគរនោះឯង ហើយឲ្យកហាបណៈ ១៥.០០០ ដែលនាងនាំមកពីផ្ទះរបស់បិតា ដើម្បីធ្វើបុណ្យតាមឱកាសដល់នាងសិរិមានោះ ហើយប្រាប់ថា នាងចូរកាន់យកកហាបណៈទាំងនេះហើយបម្រើសេដ្ឋីបុត្តរហូតកន្លះខែនេះ ឲ្យនាងសិរិមាស្តប់ស្តល់ជាមួយស្វាមីរបស់ខ្លួន អធិដ្ឋានអង្គឧបោសថ មានចិត្តត្រេកអរថា អាត្មាអញបានឃើញព្រះពុទ្ធជាដើមអស់កាលកន្លះខែនេះ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន រហូតដល់ថ្ងៃបវារណា បានថ្វាយមហាទានអស់កាលកន្លះខែ ខាងក្រោយអាហារឲ្យចាត់ចែងរបស់ទំពាររបស់បរិភោគក្នុងរោងដាំស្ល ។ ចំណែកស្វាមីរបស់នាងគិតថា ស្អែកនេះជាថ្ងៃបវារណា ទើបឈរត្រង់បង្អួចជាមួយនាងសិរិមា

ក្រឡេកមើលទៅខាងក្រៅ ឃើញនាងឧត្តរាដើរយ៉ាងនោះ ញើសជោគពេញទៅដោយធ្យូង ប្រឡាក់ទៅដោយម្រេងក្អើង ទើបសើចដោយគិតថា ស្រីល្ងង់មិនចេះបរិភោគសម្បត្តិរបស់ខ្លួន ធ្វើតែកុសល ។ សូម្បីនាងឧត្តរា ក៏ក្រឡេកមើលស្វាមីសើចគិតថា ប្រុសល្ងង់មិនធ្វើកុសលដើម្បីភពខាងមុខ ។

នាងសិរិមាឃើញកិរិយារបស់ជនទាំងពីរសម្គាល់ថា យើងជាមេផ្ទះទើបកើតសេចក្ដីប្រណែនក្រោធនាងឧត្តរាគិតថា អញនឹងធ្វើឲ្យនាងឧត្តរាលំបាកទើបចុះអំពីប្រាសាទ ។ នាងឧត្តរាដឹងហេតុនោះ ទើបអង្គុយលើតាំង ផ្សាយមេត្តាចិត្តទៅកាន់នាងសិរិមានោះ នាងសិរិមាចុះចាកប្រាសាទ ចូលរោងដាំស្ល យកសប្បិដែលពុះពេញបោយអំពីទីដែលចៀននំស្រោចលើក្បាលរបស់នាងឧត្តរា ។ សប្បិប្រែទៅជាដូចទឹកត្រជាក់ដែលស្រោចលើស្លឹកឈូក ។ ពួកទាសីនាំគ្នាវាយនាងសិរិមាដោយដៃនិងជើង ឲ្យដួលចុះលើផែនដី នាងឧត្តរាចេញចាកមេត្តាឈាន ហើយទើបហាមពួកទាសី ។ នាងសិរិមាសូមខមាទោសនាងឧត្តរា ។ នាងឧត្តរាពោលថា ស្អែកនេះ ចូរនាងមកសូមខមាទោសចំពោះព្រះភក្ត្រនៃព្រះសាស្ដា ហើយប្រាប់ការចម្អិនអាហារ ដល់នាងសិរិមាដែលសូមអង្វរទទួលបម្រើផ្លូវកាយ ។ នាងសិរិមាចម្អិនអាហារហើយមានស្រីគណិកា ៥០០ បរិវាររបស់ខ្លួន អង្គាសព្រះសាស្ដា និងព្រះសង្ឃ ហើយពោលថា ពួកនាងចូរជាមិត្តក្នុងការឲ្យនាងឧត្តរាអត់ទោសចុះ ។ លុះព្រឹកឡើង កាលព្រះសាស្ដាសោយព្រះក្រយាហារស្រេចហើយ មួយអន្លើដោយស្រីគណិកាទាំងនោះ ក៏ថ្វាយបង្គំព្រះសាស្ដាទូលថា បពិត្រព្រះមាន-

ព្រះភាគ ខ្ញុំម្ចាស់បានធ្វើខុសចំពោះនាងឧត្តរា សូមឲ្យនាងឧត្តរាអត់ទោសឲ្យដល់ខ្ញុំម្ចាស់ចុះ ព្រះសាស្តាត្រាស់ថា ម្នាលនាងឧត្តរា ចូរនាងអត់ទោសចុះ កាលនាងទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់អត់ទោសឲ្យហើយ ទ្រង់សម្តែងធម៌ ( ក្នុងធម្មបទ ) ថា **អក្កោធេន ជិនេ កោធំ** ជាដើម ។ នាងឧត្តរានាំស្វាមី ឪពុកក្មេក ម្តាយក្មេក ចូលទៅគាល់ព្រះសាស្តាចំពោះព្រះភក្ត្រ កាលចប់ទេសនា ជនទាំង ៣ នោះនិងស្រីគណិកាទាំងអស់តាំងនៅក្នុងសោតាបត្តិផល ការមិនមានសេចក្តីឈឺចាប់ដោយទឹកដោះថ្លាដ៏ក្តៅនៃនាងឧត្តរាឧបាសិកា ជាឫទ្ធិដែលផ្សាយទៅដោយសមាធិ ។

ឧបាសិកាសាមាវតីអគ្គមហេសីរបស់ព្រះបាទឧទេន ព្រះរាជាក្រុងកោសម្ពី ។ ព្រះបាទឧទេននោះមានអគ្គមហេសី ៣ អង្គ មានស្រីបរិវារមួយអង្គៗ ៥០០ ។ បណ្តាមហេសីទាំងនោះ នាងសាមាវតីជាធីតារបស់ភទ្ទិយសេដ្ឋី ក្នុងភទ្ទិយនគរ កាលបិតាស្លាប់ហើយ មានស្រី ៥០០ ជាបរិវារចម្រើនធំធាត់ ក្នុងផ្ទះរបស់ឃោសិតសេដ្ឋីជាសម្លាញ់របស់បិតា ក្នុងក្រុងកោសម្ពី ។ ព្រះរាជាទតឃើញនាងចម្រើនវ័យហើយទ្រង់កើតសេចក្តីស្នេហាទើបនាំនាងមួយអន្លើដោយបរិវារ ទៅកាន់ព្រះរាជវាំង ទ្រង់បានប្រកបការអភិសេក ។ មហេសីមួយអង្គទៀតឈ្មោះថា វាសុលទត្តា ជាធីតារបស់ព្រះបាទចណ្ឌបជោត ។ ធីតារបស់មាគន្ទិយព្រាហ្មណ៍ ដែលបិតាលើកឲ្យជាបាទបរិចារិការបស់ព្រះមានព្រះភាគ បានស្តាប់គាថាដែលព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយសុត្តនិបាត ) ថា

អើ ក៏សេចក្តីប្រាថ្នាក្នុងមេថុនមិនមាន ( ដល់តថាគត ) ព្រោះឃើញនាងតណ្ហា នាងអរតី និងនាងរាគា ( ដែលជាធីតានៃមារ ) សោះទៅហើយ ធ្វើម្តេចឡើយតថាគតនឹងមានសេចក្តីប្រាថ្នាក្នុងមេថុន ព្រោះឃើញនូវរូបទារិកា ដែលពោរពេញដោយមូត្រនិងករីសនេះ តថាគតមិនគួរត្រូវការ ដើម្បីប៉ះពាល់នូវធីតារបស់អ្នកនោះសូម្បីតែដោយជើង ដូច្នេះ ។

បានចងអាឃាតក្នុងព្រះមានព្រះភាគ ។ ក្នុងកាលចប់មាគណ្ឌិយសុត្តន្តទេសនា មាតាបិតារបស់នាង បានសម្រេចអនាគាមិផល បួសហើយសម្រេចអរហត្ត ។ មាគណ្ឌិយព្រាហ្មណ៍ ឪពុកមារបស់នាង នាំនាងទៅកាន់ក្រុងកោសម្ពី បានថ្វាយនាងដល់ព្រះរាជា ទើបនាងបានជាមហេសីមួយអគ្គរបស់ព្រះរាជា ។

គ្រានោះឯង សេដ្ឋី ៣ នាក់ គឺឃោសិតសេដ្ឋី កុក្កុដសេដ្ឋី បាវារិកសេដ្ឋី បានស្តាប់ដំណឹងថា ព្រះតថាគតទ្រង់ឧប្បត្តិឡើងក្នុងលោកហើយ ទើបទៅគាល់ព្រះសាស្តា ឯវត្តជេតពន ស្តាប់ធម៌ហើយសម្រេចសោតាបត្តិផល ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់កាលកន្លះខែ ទូលអារាធនាព្រះសាស្តាឲ្យយាងទៅកាន់នគរកោសម្ពី ជនទាំង ៣ នាក់ សាងអារាម ៣ កន្លែង គឺឃោសិតារាម កុក្កុដារាម បាវារិការាម និមន្តព្រះសាស្តាយាងមកក្នុងទីនោះ អារាធនាព្រះអង្គឲ្យគង់នៅក្នុងវត្តមួយ មួយថ្ងៃតាមលំដាប់ សេដ្ឋីម្នាក់ៗបានថ្វាយមហាទានដល់ព្រះមានព្រះភាគ មួយអន្ទើ

ដោយព្រះសង្ឃ ។ សម័យថ្ងៃមួយ នាយមាលាការ ឈ្មោះថា សុមនៈ ឧបដ្ឋាករបស់សេដ្ឋីទាំងនោះ បានសូម ( អនុញ្ញាត ) សេដ្ឋី បំណាងឲ្យព្រះសាស្តាមួយអន្លើដោយព្រះសង្ឃគង់ក្នុងផ្ទះរបស់ខ្លួន ដើម្បីឆាន់ភត្តាហារ ។ ខណៈនោះនាងខុជ្ជុត្តរាទាសីរបស់នាងសាមាវតីទទួលកហាបណៈ ៨ បានទៅកាន់ផ្ទះរបស់នាយមាលាការនោះ ។ នាយមាលាការនិយាយថា ចូរនាងជាសម្លាញ់ក្នុងការអង្គាសព្រះសាស្តា មួយអន្លើដោយព្រះសង្ឃសិនចុះ ។ នាងខុជ្ជុត្តរាបានធ្វើយ៉ាងនោះ កាលព្រះសាស្តាសោយស្រេចហើយ ស្តាប់ព្រះធម៌ទេសនាបានជាព្រះសោតាបន្ន ក្នុងកាលដទៃតែបំបាត់យក ៤ កហាបណៈដើម្បីខ្លួន ( តែក្នុងកាលនេះ ) ទិញផ្កាទាំង ៨ កហាបណៈព្រោះមិនគួរកាន់យកទ្រព្យដែលគេមិនបានឲ្យ នាំចូលទៅថ្វាយដល់ព្រះនាងសាមាវតី ។ កាលព្រះនាងសាមាវតី សួរដល់ហេតុដែលផ្កាមានច្រើនទើបនាងពិតទូលតាមសេចក្តីពិត ព្រោះមិនគួរនិយាយកុហក ។ ព្រះនាងសាមាវតីសួរថា ព្រោះហេតុអ្វីថ្ងៃនេះ ទើបនាងមិនតែបំបាត់ ទូលថា ខ្ញុំម្ចាស់ស្តាប់ធម៌របស់ព្រះសម្មាសម្ពុទ្ធ បានធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ហើយ ។ ព្រះនាងសាមាវតីសួរថា នែនាងឧត្តរា ចូរនាងប្រាប់អមតធម៌នោះដល់ពួកខ្ញុំខ្លះ ។ នាងខុជ្ជុត្តរាទូលថា បើដូច្នោះ សូមព្រះនាងឲ្យខ្ញុំងូតទឹក ហើយឲ្យសំពត់បរិសុទ្ធមួយគូ ឲ្យអង្គុយលើអាសនៈខ្ពស់ ព្រះនាងទាំងអស់ ចូរអង្គុយក្នុងអាសនៈទាប ។

ស្ត្រីទាំងអស់នោះបានធ្វើយ៉ាងនោះ នាងខុជ្ជុត្តរាជាអរិយសាវិកាសម្រេច

សេក្ខប្បដិសម្ភិទា ស្មៀកសំពត់មួយផ្ទាំង ដណ្ដប់សំពត់មួយផ្ទាំង កាន់ផ្ចិតវាលវីជនី សម្ដែងធម៌ដល់ស្ត្រីទាំងនោះ ។ ព្រះនាងសាមាវតីនិងស្ត្រី ៥០០ បានសម្រេចសោតាបត្តិផល ។ ស្ត្រីទាំងអស់នោះថ្វាយបង្គំនាងខុជ្ជុត្តរាហើយពោលថា បពិត្រអ្នកម៉ែ តាំងអំពីថ្ងៃនេះទៅនាងមិនចាំបាច់ធ្វើការបម្រើទៀតឡើយ ចូរតាំងនៅក្នុងឋានៈជាមាតា និងអាចារ្យរបស់ពួកយើង ស្ដាប់ធម៌ដែលព្រះសាស្ដាទ្រង់សម្ដែងហើយ ចូរពោលដល់ពួកយើង ។ នាងខុជ្ជុត្តរាធ្វើតាមនោះ តមក ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក បានតំណែងជាឯតទគ្គដែលព្រះសាស្ដា ទ្រង់ស្ថាបនាទុកក្នុងឋានៈជាកំពូល ជាងឧបាសិកាទាំងឡាយដែលជាពហុស្សូត ។ ស្ត្រីទាំងឡាយរួមទាំងនាងសាមាវតី ប្រាថ្នាក្នុងការឃើញព្រះពុទ្ធ កាលព្រះទសពលទ្រង់យាងដល់វាំងផ្ទាល់ កាលបង្អួចមិនល្មមក៏ចោះជញ្ជាំងសម្លឹងមើលព្រះសាស្ដា ធ្វើការថ្វាយបង្គំ និងបូជា ។

នាងមាគន្ទិយាទៅក្នុងទីនោះ ឃើញប្រហោងទាំងនោះហើយ សួរហេតុក្នុងទីនោះ ដឹងថាព្រះសាស្ដាយាងមក ដោយការចងអាឃាតក្នុងព្រះមានព្រះភាគ ទើបក្រោធនឹងស្ត្រីទាំងនោះ បានទូលព្រះរាជាថា បពិត្រមហារាជស្ត្រីដែលនៅជាមួយនាងសាមាវតី មានសេចក្ដីប្រាថ្នាខាងក្រៅ ចោះជញ្ជាំងសម្លឹងមើលព្រះសមណគោតម ក្នុងកាលមិនយូរក៏នឹងសម្លាប់ព្រះអង្គ ព្រះរាជាសូម្បីឃើញប្រហោងក៏មិនជឿពាក្យទូលរបស់នាងមាគន្ទិយា ទ្រង់ត្រាស់បញ្ជាឲ្យធ្វើបង្អួចត្រង់ប្រហោងនោះ ។ នាងមាគន្ទិយាប្រាថ្នានឹងឲ្យព្រះរាជាកម្ចាត់ស្ត្រីទាំងនោះទើបឲ្យនាំមាន់រស់មក ៨ ក្បាល ហើយទូលថា បពិត្រ

មហារាជ ដើម្បីសាកល្បងស្រីទាំងនោះ សូមទ្រង់បញ្ជូនមាន់ទាំងនេះទៅ ដោយព្រះតម្រាស់ថា នាងចូរសម្លាប់មាន់ទាំងនេះ ស្ងួឲ្យយើង ដូច្នេះ ។ ព្រះរាជាទ្រង់បញ្ជូនទៅតាមនោះ កាលព្រះនាងសាមាវតី ត្រាស់ថា ពួកយើងមិនធ្វើបាណាតិបាត ទើបនាងមាគន្ទិយានិយាយទៀតថា ចូរស្ងួបញ្ជូនទៅថ្វាយព្រះសមណៈគោតមនោះ ។ កាលព្រះរាជាទ្រង់បញ្ជូនទៅយ៉ាងនោះ នាងមាគន្ទិយាក៏បញ្ជូនមាន់ឆាប់ទៅ ៨ ក្បាល ដោយពោលយ៉ាងនោះ ។ ព្រះនាងសាមាវតីក៏ស្ងួបញ្ជូនទៅថ្វាយព្រះទសពល ។ នាងមាគន្ទិយាក៏មិនអាចឲ្យព្រះរាជាពិរោធ សូម្បីដោយហេតុនោះបាន ។

ព្រះរាជាប្រថាប់នៅក្នុងដំណាក់របស់មហេសី ៣ អង្គ មួយអង្គ ៗ ៧ ថ្ងៃ ។ ព្រះរាជាយាងទៅកាន់ទីណាទ្រង់កាន់ពិណាហត្ថិកន្ត ( ពិណាហៅដំរី ) ទៅជានិច្ច ក្នុងវេលាព្រះរាជាយាងទៅកាន់ដំណាក់ព្រះនាងសាមាវតី នាងមាគន្ទិយាឲ្យនាំកូនពស់វែកមួយមក យកថ្នាំលាងចង្កូម ហើយឲ្យដាក់ចូលក្នុងបំពង់ឫស្សី ហើយដាក់ក្នុងពិណាយកកម្រងផ្កាបិទប្រហោងទុក ។ ក្នុងវេលាដែលព្រះរាជាយាងទៅក្នុងទីនោះ នាងមាគន្ទិយាធ្វើជាដើរទៅដើរមក ហើយយកកម្រងផ្កានោះចេញ អំពីប្រហោងពិណា ។ ពស់លូនចេញមក ព្រួសពិស បើកពពា ដេកលើទីបន្ទំ នាងមាគន្ទិយាស្រែកដោយសំឡេងខ្លាំង ៗ ថា ប្ដីយ ពស់ ព្រះរាជាទ្រង់ឃើញពស់ហើយទ្រង់ពិរោធ ។ ព្រះនាងសាមាវតីដឹងថា ព្រះរាជាទ្រង់ពិរោធ ទើបបានណាត់ដល់ស្រី ៥០០ ថា ថ្ងៃនេះពួកនាងចូរផ្សាយមេត្តាដោយចំពោះដល់ព្រះរាជា ។ សូម្បីនាង

ខ្លួនឯងក៏បានធ្វើយ៉ាងនោះ ។ ព្រះរាជាទ្រង់ចាប់សហស្សថាមធ្នូ តម្លើងខ្សែហើយ ត្រាស់ឲ្យនាងសាមាវតីឈរខាងមុខ ឲ្យស្រីទាំងអស់ឈររៀងគ្នាតាមលំដាប់ទៅ ទ្រង់ផ្ទាប់ព្រួញដែលលាបដោយថ្នាំពិស ប្រថាប់ឈរយឺតធ្នូ ហើយមិនអាចលែងព្រួញទៅបាន មិនអាចដាក់ចុះបាន ព្រះសេទហូរចេញចាកព្រះវរកាយ ទ្រង់ឈឺចាប់ព្រះវរកាយ ព្រះខេឡៈហូរចេញអំពីព្រះឱស្ឋ មិនឃើញវត្ថុដែលគួរពឹងបាន ។ លំដាប់នោះ ព្រះនាងសាមាវតីទូលសួរព្រះរាជាថា បពិត្រមហារាជ ទ្រង់លំបាកឬ ព្រះរាជាត្រាស់ថា ត្រូវហើយព្រះទេវី យើងលំបាកណាស់ នាងចូរជាទីពឹងរបស់យើងចុះ ។ ព្រះនាងសាមាវតីទូលថា សាធុមហារាជ សូមទ្រង់ធ្វើព្រួញ ឲ្យមានមុខត្រង់ផែនដីចុះ ។ ព្រះរាជាទ្រង់បានធ្វើយ៉ាងនោះ ។ ព្រះនាងសាមាវតីអធិដ្ឋានថា សូមព្រួញរបូតអំពីដៃរបស់ព្រះរាជាចុះ ។ ក្នុងខណៈនោះព្រួញក៏ធ្លាក់ចុះ ។ ក្នុងខណៈនោះឯងព្រះរាជាទ្រង់ចុះទៅក្នុងទឹក មានសំពត់សើម មានសក់សើម ទ្រង់ក្រាបចុះទៀបជើងរបស់ព្រះនាងសាមាវតី ត្រាស់ថា ព្រះទេវីអត់ទោសឲ្យយើងចុះ ។

> យើងវង្វេង ទិសទាំងពួងងងឹតដល់យើង ម្នាលនាងសាមាវតី
> ចូរជួយយើង ចូរជាទីពឹងរបស់យើងចុះ ។

ព្រះនាងសាមាវតីទូលថា

> ព្រះអង្គកុំដល់ខ្ញុំម្ចាស់ជាទីពឹងឡើយ ខ្ញុំម្ចាស់ដល់ព្រះពុទ្ធអង្គ
> ណាជាទីពឹង សូមទ្រង់ដល់ព្រះពុទ្ធអង្គនោះ ជាទីពឹងចុះ និង

សូមព្រះអង្គចូរជាទីពឹងរបស់ខ្ញុំម្ចាស់ផង ។

ព្រះរាជាត្រាស់ថា បើដូច្នោះ យើងនឹងសូមដល់នាងនិងព្រះសាស្តាជាទីពឹង ម្យ៉ាងទៀត យើងនឹងឲ្យពរដល់នាង ។ ព្រះនាងសាមាវតីទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់ទទួលពរ ។ ព្រះរាជាយាងទៅគាល់ព្រះសាស្តា សូមដល់ទីពឹង ហើយនិមន្តថ្វាយមហាទាន ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ត្រាស់នឹងនាងសាមាវតីថា ចូរទទួលពរចុះ ។ ព្រះនាងទូលថា សាធុមហារាជ សូមទ្រង់ឲ្យពរនេះដល់ខ្ញុំម្ចាស់ គឺសូមព្រះសាស្តាយាងមកក្នុងទីនេះព្រមដោយភិក្ខុសង្ឃ ៥០០ ចុះ ខ្ញុំម្ចាស់ នឹងស្តាប់ធម៌ ។ ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គនិមន្តមកក្នុងទីនេះជាមួយភិក្ខុ ៥០០ ជាប្រចាំចុះ ពួកស្រីទាំងឡាយរួមទាំងនាងសាមាវតីក៏ពោលថា ខ្ញុំម្ចាស់នឹងស្តាប់ធម៌ ដូច្នេះ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ការទៅកាន់ទីកន្លែងតែមួយ ជាប្រចាំ មិនសមគួរដល់ព្រះពុទ្ធទាំងឡាយ សូម្បីមហាជនក៏នៅសង្ឃឹមនឹងឲ្យទៅ ។ ព្រះរាជាទូលថា បើដូច្នោះសូមព្រះអង្គត្រាស់បញ្ជូនភិក្ខុទាំងឡាយចុះ ។ ព្រះសាស្តាត្រាស់បញ្ជូនដល់ព្រះអានន្ទត្ថេរ ។ ព្រះថេរៈនាំភិក្ខុ ៥០០ ទៅកាន់រាជត្រកូលជាប្រចាំ ។ ស្ត្រីទាំងឡាយមានព្រះទេវីជាប្រធាននោះ ក៏អង្គាសព្រះថេរៈហើយនាំគ្នាស្តាប់ធម៌ ។ ម្យ៉ាងទៀត ព្រះសាស្តាទ្រង់តាំងព្រះនាងសាមាវតី ទុកក្នុងឋានៈជាឯតទគ្គជាងឧបាសិកាទាំងឡាយ អ្នកមានមេត្តាវិហារធម៌ ។ សេចក្តីដែលព្រះរាជាមិនអាចលែងព្រួញទៅបាន ជាឫទ្ធិដែល

ផ្សាយទៅដោយសមាធិ របស់ព្រះនាងសាមាវតីឧបាសិកា ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ក្នុងទីនេះលោកហៅថា ឧបាសិកា ព្រោះចូលជិតព្រះរតនត្រ័យដោយសេចក្តីជ្រះថ្លា ដែលមិនញាប់ញ័រ ដោយសេចក្តីជ្រះថ្លាដ៏ជ្រាលជ្រៅ ឬដោយការដល់ព្រះរតនត្រ័យជាទីពឹង ។

[ ១៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអរិយិទ្ធិនិទ្ទេស ដូចតទៅនេះថា បទថា **អរិយា ឥទ្ធិ** លោកពោលថា ឫទ្ធិរបស់ព្រះអរិយៈ ព្រោះកើតដល់ព្រះអរិយៈ ជាព្រះខីណាស្រពអ្នកដល់ភាពជំនាញផ្លូវចិត្ត ។ បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុជាព្រះខីណាស្រពក្នុងសាសនានេះ ។ បទថា **អនិដ្ឋេ វត្ថុស្មឹ** បានដល់ ក្នុងវត្ថុ ក្នុងសត្វ ឬក្នុងសង្ខារដែលមិនជាទីគាប់ចិត្តដោយអារម្មណ៍ប្រក្រតី ។ បទថា **មេត្តាយ វា ផរតិ** បានដល់ ប្រសិនបើជាសត្វ រមែងផ្សាយទៅដោយមេត្តាភាវនា ។ បទថា **ធាតុតោ វា ឧបសំហរតិ** បានដល់ ប្រសិនបើជាសង្ខាររមែងបង្អោនចូលទៅនូវធាតុមនសិការថា ត្រឹមតែជាធាតុ ។ ការបង្អោនទៅសូម្បីក្នុងសត្វថា ជាធាតុក៏គួរ ។ បទថា **អសុភាយ វា ផរតិ** បានដល់ ប្រសិនបើជាសត្វ រមែងផ្សាយទៅដោយអសុភភាវនា ។ បទថា **អនិច្ចតោ វា ឧបសំហរតិ** បានដល់ ប្រសិនបើជាសង្ខារ រមែងបង្អោនចូលទៅនូវមនសិការថាជារបស់មិនទៀង ។ បទថា **តទុភយំ** កាត់បទជា **តំ ឧភយំ** បានដល់ ទាំងពីរនោះ ។ បទថា **ឧបេក្ខកោ** បានដល់ មានឧបេក្ខា ដោយឧបេក្ខាមានអង្គ ៦ ( ឆឡង្គុបេក្ខា ) ។ ឈ្មោះថា **សតោ** ព្រោះដល់ភាពជាអ្នកបរិបូរណ៍ដោយសតិ ។

បទថា **សម្បជានោ** ព្រោះជាអ្នកមានប្រក្រតីធ្វើនូវការដឹងខ្លួនដោយបញ្ញា ។ បទថា **ចក្ខុនា រូបំ ទិស្វា** បានដល់ ឃើញរូបដោយចក្ខុវិញ្ញាណដែលអាចឃើញរូបដែលបានវោហារថា ចក្ខុដោយអំណាចនៃហេតុ តែបោរាណាចារ្យពោលថា ក្នុងសេចក្តីនេះ មានពាក្យអធិប្បាយដូច្នេះថា ចក្ខុរមែងមិនឃើញរូប ព្រោះចក្ខុមិនមានចិត្ត ចិត្តរមែងមិនឃើញរូប ព្រោះចិត្តមិនមានចក្ខុ តែកាលទ្វារនិងអារម្មណ៍ប៉ះខ្ទប់គ្នា ទើបបុគ្គលឃើញរូបបានដោយចិត្តដែលមានបសាទជាវត្ថុ ។ ម្យ៉ាងទៀត កថាបែបនេះ ឈ្មោះថា សសម្ភារកថា ( កថាមានអង្គប្រកប ) ដូចក្នុងពាក្យថា ចាក់ដោយធ្នូ ព្រោះហេតុនោះ ឃើញរូបដោយចក្ខុវិញ្ញាណហើយ ... ម្យ៉ាងទៀត ឃើញរូបដោយចក្ខុដែលជាហេតុ ។ បទថា **នេវ សុមនោ ហោតិ** បានដល់ បដិសេធសោមនស្សអាស្រ័យផ្ទះ មិនមែនសោមនស្សវេទនាដែលជាកិរិយា ។ បទថា **ន ទុម្មនោ** បានដល់ បដិសេធទោមនស្សទាំងអស់ ។ បទថា **ឧបេក្ខកោ វិហរតិ** បានដល់ ជាអ្នកព្រងើយកន្តើយដោយតត្រមជ្ឈត្តុបេក្ខា ដែលជាអាការនៃការមិនលះភាពជាប្រក្រតីដែលបរិសុទ្ធិ ក្នុងគន្លងនៃឥដ្ឋារម្មណ៍និងអានិដ្ឋារម្មណ៍ដែលបានឈ្មោះថា ឆឡង្គុបេក្ខា ព្រោះប្រព្រឹត្តទៅក្នុងទ្វារ ៦ ។ សូម្បីក្នុងបទថា **សោតេន សទ្ទំ សុត្វា** ជាដើមក៏មានន័យនេះដូចគ្នា ។

[ ១៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកម្មវិបាកជិទ្ធិនិទ្ទេស ដូចតទៅនេះថា បទថា **សព្វេសំ បក្ខីនំ** បានដល់ ការទៅតាមអាកាសវៀរឈានទិងអភិញ្ញារបស់បក្សីទាំងឡាយគ្រប់ប្រភេទ ។ ការទៅតាមអាកាសនិងការឃើញ

ជាដើម របស់ទេវតាទាំងពួងក៏យ៉ាងនោះ ។ បទថា **ឯកច្ចានំ មនុស្សានំ** បានដល់ មនុស្សអ្នកកើតក្នុងដើមកប្ប ។ បទថា **ឯកច្ចានំ វិនិបាតិកានំ** បានដល់ ការទៅតាមអាកាសជាដើម របស់សត្វដែលឈ្មោះថា វិនិបាតិក ព្រោះធ្លាក់ទៅអំពីកាយ ដែលជាសេចក្តីសុខ គឺប្រេតពួកខ្លះ នាគ និងគ្រុឌ មានបិយង្ករមាតា បុនព្វសុមាតា ផុស្សមិត្តា ធម្មគុត្តា ជាដើម ជាឫទ្ធិដែលកើតអំពីផលកម្ម ។

[ ១៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបុញ្ញវតោឥទ្ធិនិទ្ទេស ដូចតទៅនេះថា បទថា **រាជា** ឈ្មោះថា **រាជា** ព្រោះញ៉ាំងអ្នកដទៃឲ្យត្រេកអរដោយធម៌ ។ ឈ្មោះថា **ចក្កវត្តី** ព្រោះញ៉ាំងចក្ករតន៍ឲ្យប្រព្រឹត្តទៅ ។ បទថា **វេហាសំ គច្ឆតិ** ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃអច្ចន្តសំយោគ ។ បទថា **ចតុរង្គិនិយា** បានដល់ មានអង្គ ៤ គឺដំរី សេះ រថនិងពលថ្មើរជើង ។ បទថា **សេនា** គឺ រួមអង្គទាំង ៤ នោះ ។ បទថា **អន្តមសោ** បានដល់ ដោយហោចមនុស្សថ្នាក់ទាប ។ មនុស្សរក្សាសេះ ឈ្មោះថា **អស្សពន្ធា** ។ មនុស្សរក្សាគោ ឈ្មោះថា **គោបុរិសា** ។ បទថា **ឧបាទាយ** បានដល់ មិនលែង អធិប្បាយថា ការហោះទៅកាន់អាកាសរបស់ជនទាំងនោះ យ៉ាងនេះ ជាឫទ្ធិរបស់អ្នកមានបុណ្យ ។

បទថា **ជោតិយស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ** មានអធិប្បាយថា សេដ្ឋីក្នុងក្រុងរាជគ្រឹះ អ្នកសន្សំបុញ្ញាធិការទុក ក្នុងព្រះបច្ចេកពុទ្ធទាំងឡាយ ក្នុងកាលមុនឈ្មោះ ជោតិកៈ ។ បានឮថា ក្នុងថ្ងៃដែលជោតិកៈនោះកើត

សព្វរុចក្នុងនគរទាំងអស់ ភ្លឺរុងរឿង សូម្បីគ្រឿងអាភរណៈដែលតាក់តែង ទុកត្រង់កាយរបស់ជនទាំងពួង ក៏បញ្ចេញពន្លឺរុងរឿង នគរមានពន្លឺរុងរឿង តែមួយដូចគ្នា ។ លំដាប់នោះ ក្នុងថ្ងៃដែលដាក់ឈ្មោះកុមារនោះ ទើបញាតិ ទាំងឡាយដាក់ឈ្មោះថា ជោតិកៈ ព្រោះនគរទាំងមូលភ្លឺរុងរឿងដូចគ្នាតែ មួយ ។ កាលជោតិកៈចម្រើនវ័យ កាលជម្រះផែនដីធ្វើផ្ទះ សក្កទេវរាជ យាងមកពន្រាបផែនដីក្នុងទីប្រមាណ ១៦ ករីសៈ សាងប្រាសាទ ៧ ជាន់ សម្រេចដោយកែវ ៧ ប្រការ សាងកំពែង ៧ ជាន់ ប្រកបដោយខ្លោង ទ្វារ ៧ សម្រេចដោយកែវ ៧ ប្រការ ព័ទ្ធប្រាសាទទុក ក្នុងចុងកំពែង ដាំដើមកប្បព្រឹក្សទុក ៦៤ ដើម ក្នុងជ្រុងទាំង ៤ របស់ប្រាសាទបានកប់ កំណប់ទ្រព្យប្រមាណមួយយោជន៍ ៣ គាវុត ២ គាវុត ១ គាវុត ។ ក្នុងជ្រុងទាំង ៤ របស់ប្រាសាទដើមអំពៅសម្រេចដោយមាស ៤ ដើមប្រ- មាណប៉ុនដើមត្នោតសាវកើតឡើង ។ ស្លឹករបស់ដើមអំពៅទាំងនោះសម្រេច ដោយកែវមណី ថ្នាំងសម្រេចដោយមាស ។ ត្រង់ខ្លោងទ្វារទាំង ៧ ខ្លោង ទ្វារនីមួយៗមានយក្ស ៧ នាក់ មានបរិវារម្នាក់ ១.០០០ ២.០០០ ៣.០០០ ៤.០០០ ៥.០០០ ៦.០០០ ៧.០០០ ចាំរក្សា ។

ព្រះបាទពិម្ពិសារមហារាជ ទ្រង់ស្តាប់ដល់ការតាំងឡើងនៃប្រាសាទ ជា ដើមហើយ ទើបទ្រង់បញ្ជូនស្វេតច្ឆត្ររបស់សេដ្ឋីទៅឲ្យ ។ សេដ្ឋីនោះទើប ឈ្មោះថា ជោតិកសេដ្ឋី ជាអ្នកប្រាកដទូទៅពេញជម្ពូទ្វីប សោយមហា- សម្បត្តិនៅក្នុងប្រាសាទនោះជាមួយភរិយា ដែលទេវតាទាំងឡាយនាំមកអំពី

ឧត្តរកុរុទ្វីប ហើយឲ្យអង្ករយក្នុងបន្ទប់ដ៏មានសិរី ដែលកាន់យកអង្ករមួយនាឡិនិងដុំថ្មឲ្យកើតភ្លើង ៣ ដុំមកផង កត្តរមែងគ្រប់គ្រាន់ដល់ជនទាំង ២ ដោយអង្ករមួយនាឡិជរាបដល់អស់ជីវិត បានឮថា ប្រសិនបើជនទាំងឡាយបំណងនឹងផ្ទុកអង្ករក្នុងរទេះ ១០០ នាឡិ អង្ករនោះឯង ក៏តាំងនៅដូចដើមក្នុងវេលាដាំបាយ ដាក់អង្ករទៅក្នុងឆ្នាំងបាយហើយទុកខាងលើដុំថ្មទាំងនោះ ដុំថ្មក៏ឆេះជាភ្លើងមួយរំពេច កាលបាយឆ្អិនក៏រលត់ ដោយសញ្ញានោះ ជនទាំងឡាយ ក៏ដឹងថាបាយឆ្អិនហើយ ។ សូម្បីក្នុងវេលាស្លជាដើម ក៏មានន័យនេះដូចគ្នា ។ អាហាររបស់ជនទាំងនោះ រមែងចម្អិនដោយថ្មឲ្យកើតភ្លើងយ៉ាងនេះ ជនទាំងឡាយ រមែងរស់នៅដោយពន្លឺនៃកែវមណី រមែងមិនស្គាល់ពន្លឺនៃភ្លើងឬប្រទីប ។ ជោតិកសេដ្ឋី បានប្រាកដទូទៅក្នុងជម្ពូទ្វីបថាមានសម្បត្តិ មានសភាពបែបនេះ ។ មហាជនឡើងយានជាដើម មកដើម្បីមើល ។ ជោតិកសេដ្ឋីឲ្យកត្តាហារនៃអង្ករមកពីឧត្តរកុរុទ្វីបដល់មនុស្សដែលមកហើយៗប្រាប់ថា ជនទាំងឡាយ ចូរកាន់យកសំពត់និងអាភរណៈ អំពីដើមកប្បព្រឹក្សចុះ ឲ្យបើកមាត់ឆ្នាំងកំណប់មួយគាវុត ហើយប្រាប់ថា ចូរកាន់យកឲ្យគ្រប់គ្រាន់ ដល់ការចិញ្ចឹមជីវិតចុះ ។ កាលអ្នកជម្ពូទ្វីបទាំងមូលកាន់យកទ្រព្យទៅ ឆ្នាំងកំណប់ក៏មិនបានស្រកសូម្បីត្រឹមមួយធ្នាប់ នេះជាឫទ្ធិរបស់អ្នកមានបុណ្យនោះ ដោយប្រការដូច្នេះ ។

បទថា **ជដិលស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ** សេចក្តីថា សេដ្ឋីឈ្មោះ ជដិល ក្នុងនគរតក្កសិលា សន្សំបុញ្ញាធិការត្រង់ធាតុចេតិយ៍របស់

ព្រះមានព្រះភាគព្រះនាមថា កស្សបៈ ។ បានឮថា មាតារបស់ជដិលនោះ ជាធីតារបស់សេដ្ឋីនៅក្នុងនគរពារាណសី មានរូបស្អាតក្រៃលែងណាស់ ។ កាលធីតាមានអាយុ ១៥ ១៦ ឆ្នាំ មាតាបិតាឲ្យនាងនៅខាងលើប្រាសាទ ៧ ជាន់ ដើម្បីថែរក្សា ។ ថ្ងៃមួយវិជាធរហោះទៅតាមអាកាស ឃើញនាងបើកបង្អួច ក្រឡេកមើលខាងក្រៅកើតសេចក្ដីស្រឡាញ់ ទើបចូលទៅតាមបង្អួចធ្វើសន្ថវៈជាមួយនឹងនាង ។ ទើបនាងតាំងគភ៌ដោយហេតុនោះ ។

លំដាប់នោះទាសីឃើញនាង ទើបសួរថា នេះអ្វីអ្នកនាងម្ចាស់ ។ នាងពោលថា នាងកុំប្រាប់នរណាមួយជាដាច់ខាត ។ ទាសីក៏ស្ងៀមព្រោះខ្លាច ។ គ្រប់ ១០ ខែ នាងក៏ប្រសូតបុត្ត ឲ្យទាសីនាំភាជនៈថ្មីមក ឲ្យទារកដេកលើភាជនៈនោះ ហើយបិទភាជនៈនោះដាក់កម្រងផ្កាទុកខាងលើ ប្រាប់ទាសីថា នាងចូរយកភាជនៈនេះទូលដោយក្បាលទៅចោលត្រង់ស្ទឹងគង្គា កាលមានមនុស្សសួរថា នេះអ្វី នាងគប្បីប្រាប់ថា ជាពលិកម្មរបស់ចៅហ្វាយខ្ញុំ ។ ទាសីបានធ្វើតាមនោះ ។ ត្រង់ស្ទឹងគង្គាខាងក្រោមស្រីពីរនាក់ងូតទឹក ឃើញភាជនៈនោះ អណ្ដែតទឹកមក ម្នាក់និយាយថា នោះភាជនៈរបស់ខ្ញុំ ម្នាក់ពោលថា វត្ថុដែលនៅខាងក្នុងភាជនៈនោះជារបស់ខ្ញុំ កាលភាជនៈអណ្ដែតមកដល់ ស្រីម្នាក់លើកភាជនៈនោះមកដាក់លើគោក កាលបើកឃើញទារកទើបពោលថា ទារកត្រូវជារបស់ខ្ញុំ ព្រោះខ្ញុំនិយាយថា ភាជនៈជារបស់ខ្ញុំ ។ ស្រីម្នាក់និយាយថា ទារកជារបស់ខ្ញុំ ព្រោះខ្ញុំនិយាយថា វត្ថុដែលនៅខាងក្នុងភាជនៈនោះជារបស់ខ្ញុំ ។ ស្រីទាំងពីរនោះប្រកែកគ្នានាំគ្នាទៅកាន់សាលា

វិនិច្ឆ័យ កាលអាមាត្យមិនអាចកាត់ក្តីបាន បាននាំគ្នាទៅគាល់ព្រះរាជា ។

ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ស្រីទាំងពីរនោះហើយ ត្រាស់ថា នាងចូរទទួលទារកទៅ នាងចូរទទួលភាជនៈទៅ ស្រីដែលបានទារក ជាឧបដ្ឋាករបស់ព្រះមហាកច្ចាយនត្ថេរ ។ នាងចិញ្ចឹមទារកនោះ ដោយសង្ឃឹមថានឹងឲ្យបួសក្នុងសម្នាក់របស់ព្រះថេរៈ ។ ក្នុងថ្ងៃដែលទារកនោះប្រសូតព្រោះមិនបានលាងមន្ទិលនៃគភ៌ ទើបសក់រួញ ដោយហេតុនោះទើបមានឈ្មោះថាជដិល ។

កាលទារកនោះដើរបាន ព្រះថេរៈចូលទៅបិណ្ឌបាតកាន់ផ្ទះនោះ ។ ឧបាសិកានិមន្តព្រះថេរៈឲ្យគង់ហើយប្រគេនអាហារ ។ ព្រះថេរៈឃើញទារកទើបសួរថា ឧបាសិកា នាងបានទារកមកឬ នាងឆ្លើយថា ករុណាលោកម្ចាស់ ខ្ញុំចិញ្ចឹមមកដោយសង្ឃឹមថានឹងឲ្យបួសក្នុងសម្នាក់របស់លោកម្ចាស់ ។

ព្រះថេរៈទទួលថា សាធុ ក៏នាំទារកនោះទៅ ពិចារណាមើលថា ទារកនេះមានបុញ្ញកម្មដើម្បីសោយសម្បត្តិរបស់គ្រហស្ថទេហ្ន៎ ឃើញថា សត្វនេះមានបុណ្យនឹងបានសោយមហាសម្បត្តិ តែពេលនេះនៅជាកុមារនៅឡើយ សូម្បីញាណរបស់ទារកនេះក៏នៅមិនទាន់ចាស់ក្លា ទើបនាំទារកនោះទៅកាន់ផ្ទះរបស់ឧបដ្ឋាកម្នាក់ក្នុងនគរតក្កសិលា ។

ឧបដ្ឋាកនោះឈរសំពះព្រះថេរៈ ឃើញទារកទើបសួរថា លោកម្ចាស់បានទារកមកឬ ព្រះថេរៈឆ្លើយថា ត្រូវហើយឧបាសក ទារកនេះនឹងបួសតែនៅក្មេងពេក សូមឲ្យនៅជាមួយនឹងអ្នកសិន ឧបាសកទទួលថា សាធុ

លោកម្ចាស់ ទើបចិញ្ចឹមទារកនោះទុកក្នុងឋានៈជាបុត្ត ។ ម្យ៉ាងទៀត ក្នុងផ្ទះរបស់ឧបដ្ឋាកនោះ មានទំនិញសន្សំមកអស់ ១២ ឆ្នាំ ឧបដ្ឋាកនោះទៅក្នុងវាំងស្រុកនាំទំនិញទាំងអស់នោះទៅកាន់ផ្សារ ប្រាប់តម្លៃរបស់ទំនិញនោះដល់ជដិលកុមារ ហើយពោលថា អ្នកគប្បីទទួលទ្រព្យប៉ុណ្ណេះ ៗ ហើយឲ្យទំនិញទៅ ។

ក្នុងថ្ងៃនោះទេវតាអ្នករក្សានគរបណ្តាលឲ្យអ្នកមានសេចក្តីត្រូវការដោយហោចសូម្បីជីរនិងម្រេច ឲ្យបែរមុខឆ្ពោះទៅកាន់រានផ្សារ របស់ជដិលកុមារនោះ ។ ជដិលកុមារនោះ លក់ទំនិញដែលសន្សំមកអស់ ១២ ឆ្នាំ អស់ក្នុងថ្ងៃមួយប៉ុណ្ណោះ កុដុម្ពិកៈ មកមិនឃើញទ្រព្យណាមួយក្នុងផ្សារ ទើបពោលថា នែបា អ្នកធ្វើទំនិញឲ្យវិនាសទៅអស់ហើយឬ ជដិលកុមារប្រាប់ថា មិនបាត់ទេបិតា ខ្ញុំលក់អស់តាមដែលបិតាប្រាប់ទុកថា របស់នោះតម្លៃប៉ុណ្ណេះ របស់នេះតម្លៃប៉ុណ្ណេះ ទើបប្រគល់តម្លៃទាំងអស់ឲ្យដល់កុដុម្ពិកៈនោះ ។ កុដុម្ពិកៈជ្រះថ្លា គិតថា បុរសដែលមានតម្លៃកាត់ថ្លៃមិនបាន អាចតម្កល់ជីវិតបាន មិនថានៅក្នុងទីណាឡើយ ទើបលើកកូនស្រីរបស់ខ្លួនដែលចម្រើនវ័យហើយ ឲ្យដល់ជដិលកុមារនោះ ហើយប្រាប់បុរសអ្នកធ្វើការងារថា ចូរធ្វើផ្ទះឲ្យជដិលកុមារ កាលធ្វើផ្ទះស្រេចហើយ ទើបពោលថា អ្នកទាំងពីរចូរទៅនៅក្នុងផ្ទះរបស់ខ្លួនចុះ ក្នុងខណៈដែលគេចូលផ្ទះ លុះជើងម្ខាងជាន់ធរណីទ្វារ ភ្នំមាសប្រមាណ ៨០ ហត្ថ ផុសឡើងក្នុងផ្ទៃដីត្រង់ចំណែកខាងក្រោយបំផុតរបស់ផ្ទះ ។ បានឮថា ព្រះរាជាទ្រង់ស្តាប់ថា ភ្នំមាស

ទម្លាយផែនដីផុសឡើងក្នុងផ្ទះរបស់ជដិល ទើបទ្រង់បញ្ជូនស្ទេតច្ឆត្រទៅឲ្យជដិលនោះ ទើបជដិលនោះបានឈ្មោះថា ជដិលសេដ្ឋី នេះជាឫទ្ធិរបស់អ្នកមានបុណ្យនោះ ។

បទថា **មេណ្ឌកស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ** សេចក្តីថា សេដ្ឋីឈ្មោះ មេណ្ឌកៈ ក្នុងភទ្ទិយនគរដែនមគធៈ បានសន្សំបុញ្ញាធិការ ក្នុងព្រះមានព្រះភាគព្រះនាមថា វិបស្សី ។ បានឮថា ត្រង់ខាងក្រោយផ្ទះរបស់សេដ្ឋីនោះ មានពពែមាសប្រមាណប៉ុនដំរី សេះនិងគោឧសភៈ ក្នុងទីប្រមាណ ៨ ករីសៈ ទម្លាយផែនដីផុសឡើង ខ្នងនិងខ្នងទល់គ្នា ចុកដោយធ្នុកអំបោះ ៥ ពណ៌ ត្រង់មាត់ពពែមាសទាំងនោះ ។ ជនទាំងឡាយ កាលមានសេចក្តីត្រូវការដោយសប្បិ ប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើមក្តី ដោយសំពត់ស្លៀកដណ្តប់ ប្រាក់និងមាសជាដើមក្តី ទាញធ្នុកអំបោះចេញអំពីមាត់របស់ពពែមាសទាំងនោះ សប្បិ ប្រេង ទឹកឃ្មុំ ស្ករអំពៅ សំពត់ស្លៀកដណ្តប់ ប្រាក់និងមាស គ្រប់គ្រាន់ដល់អ្នកជម្ពូទ្វីបទាំងមូល ចេញអំពីមាត់របស់ពពែសូម្បីតែមួយ តាំងអំពីនោះមកសេដ្ឋីនោះក៏ប្រាកដឈ្មោះថា មេ-ណ្ឌកសេដ្ឋី នេះជាឫទ្ធិរបស់អ្នកមានបុណ្យនោះ ។

បទថា **ឃោសិតស្ស គហបតិស្ស បុញ្ញវតោ ឥទ្ធិ** សេចក្តីថា សេដ្ឋីឈ្មោះ ឃោសិតៈ ក្នុងនគរកោសម្ពីដែនសក្កៈ សន្សំបុញ្ញាធិការក្នុងព្រះបច្ចេកពុទ្ធ ។ បានឮថា សេដ្ឋីនោះ ចុតិចាកទេវលោកកើតក្នុងផ្ទៃរបស់ស្រីនគរសោភិនីក្នុងក្រុងកោសម្ពី ។ ក្នុងថ្ងៃប្រសូត ស្រីនគរសោភិនីនោះឲ្យ

ទារកដេកលើចង្អេរ ហើយឲ្យយកទៅបោលត្រង់គំនរសំរាម ។ ក្អែកនិងសុនខទាំងឡាយ អង្គុយចោមរោមទារកនោះ ។ បុរសម្នាក់ឃើញដូច្នោះ បានសម្គាល់ថាជាបុត្ត គិតថា អញបានកូនហើយទើបនាំទៅផ្ទះ ។ ក្នុងកាលនោះកោសម្ពិកសេដ្ឋីឃើញបុរោហិតទើបសួរថា លោកអាចារ្យ ថ្ងៃនេះលោកពិនិត្យនក្ខត្តឫក្សតិថីជាដើមហើយឬ កាលបុរោហិតឆ្លើយថា លោកមហាសេដ្ឋី ខ្ញុំមើលហើយ ទើបសួរថា នឹងមានអ្វីដល់ជនបទ បុរោហិតឆ្លើយថា ក្នុងនគរនេះក្មេងកើតថ្ងៃនេះនឹងបានជាសេដ្ឋីធំ ។ ក្នុងកាលនោះភរិយារបស់សេដ្ឋីមានគភ៌ចាស់ ព្រោះហេតុនោះទើបសេដ្ឋីនោះ ប្រញាប់បញ្ជូនមនុស្សទៅផ្ទះថា អ្នកចូរទៅ ចូរដឹងថា ភរិយារបស់យើងប្រសូតបុត្ត ឬមិនទាន់ប្រសូត កាលស្ដាប់ថា មិនទាន់ប្រសូតទើបទៅកាន់ផ្ទះហៅនាងកាឡីទាសីមក ឲ្យទ្រព្យ ១.០០០ ប្រាប់ថា នាងចូរទៅ ចូរស៊ើបមើលក្នុងនគរនេះ ហើយនាំទារកដែលកើតក្នុងថ្ងៃនេះមក ទាសីទៅស៊ើបមើលក៏ទៅដល់ផ្ទះនោះ ឃើញទារកដឹងថា កើតក្នុងថ្ងៃនោះទើបឲ្យទ្រព្យ ១.០០០ នាំទារកមកឲ្យដល់សេដ្ឋី ។ សេដ្ឋីគិតថា បើកូនរបស់អញកើតមកជាស្រី អញនឹងរៀបការទារកនោះជាមួយកូនស្រី ហើយឲ្យតាំងនៅក្នុងតំណែងជាសេដ្ឋី បើជាកូនប្រុស អញនឹងសម្លាប់ទារកនោះចោល ហើយចិញ្ចឹមទារកជាកូននោះឲ្យធំជាត់ក្នុងផ្ទះនោះ ។

លំដាប់នោះកន្លងទៅ ២-៣ ថ្ងៃ ភរិយារបស់សេដ្ឋីប្រសូតបុត្ត សេដ្ឋីគិតថា កាលមិនមានទារកនេះ បុត្តរបស់យើងនឹងបានតំណែងសេដ្ឋី ឥឡូវ

នេះ អញគួរសម្លាប់ទារកនោះ ហើយហៅនាងកាឡីទាសីមកប្រាប់ថា នែមេ ក្នុងវេលាគោចេញអំពីក្រោល នាងចូរឲ្យទារកនេះដេកទទឹង ត្រង់កណ្ដាលទ្វារក្រោល មេគោទាំងឡាយនឹងជាន់ទារកនោះឲ្យស្លាប់ នាងដឹងថាទារកនោះត្រូវមេគោជាន់ឬមិនជាន់ហើយចូរត្រឡប់មក នាងកាឡីទាសីទៅហើយ លុះអ្នកចិញ្ចឹមគោបើកទ្វារក្រោល ក៏ឲ្យទារកនោះដេកយ៉ាងនោះ គោឧសភៈមេហ្វូង កាលមុនៗចេញក្រោយគោទាំងអស់ តែថ្ងៃនោះបានចេញមុនគោទាំងអស់ ឈរក្រុងទារកទុកក្នុងចន្លោះជើងទាំង ៤ មេគោទាំងឡាយ ច្រើនរយចេញសងខាងនៃគោឧសភៈនោះ សូម្បីអ្នកចិញ្ចឹមគោក៏គិតថា គោឧសភៈនេះ កាលមុនចេញក្រោយគោទាំងអស់ តែថ្ងៃនេះចេញមុន ឈរស្ងៀមត្រង់កណ្ដាលទ្វារ នេះមានហេតុអ្វីហ្ន៎ ទើបដើរទៅ ឃើញទារកដេកនៅខាងក្រោមគោឧសភៈនោះ ក៏កើតសេចក្ដីស្រឡាញ់ដូចបុត្ត គិតថា អញបានកូនហើយ ទើបនាំទៅផ្ទះ នាងកាឡីទាសីត្រឡប់ទៅត្រូវសេដ្ឋីសួរទើបប្រាប់សេចក្ដីទាំងអស់ សេដ្ឋីប្រាប់ថា នាងចូរទៅ ឲ្យទ្រព្យ ១.០០០ នេះ ហើយនាំទារកនោះមក បាននាំទារកនោះមកឲ្យទៀត ។

កាលនោះសេដ្ឋីក៏ប្រាប់នាងកាឡីទាសីថា នែមេកាឡី ក្នុងក្រុងនេះមានរទេះ ៥០០ ចេញក្នុងពេលព្រលឹមស្រាង ៗ ទៅធ្វើការជួញដូរ នាងចូរនាំទារកនេះដាក់ឲ្យដេកត្រង់ផ្លូវកង់រទេះ គោទាំងឡាយនឹងជាន់ទារកនោះ ឬកង់រទេះនឹងជាន់ នាងដឹងការប្រព្រឹត្តិទៅរបស់ទារកនោះហើយគប្បីត្រឡប់មក ។ ទាសីទៅហើយឲ្យទារកដេកត្រង់ផ្លូវកង់រទេះ ប្រធានឈ្មួញ បានបររទេះទៅ

ខាងមុខ ។

លំដាប់នោះគោរបស់ប្រធានឈ្មួញរទេះ ដល់កន្លែងនោះហើយរលាស់នឹម សូម្បីអ្នកបររទេះលើកឡើងរឿយ ៗ ហើយបរទៅ ក៏មិនព្រមទៅមុខ កាលអ្នកបររទេះនោះព្យាយាមដេញគោទាំងនោះយ៉ាងនេះ ថ្ងៃក៏រះឡើង អ្នកបររទេះគិតថា គោធ្វើអ្វី សម្លឹងមើលផ្លូវឃើញទារកទើបគិតថា កម្មធ្ងន់ហ្ន៎ ត្រេកអរថា អញបានកូនហើយទើបនាំទារកនោះទៅផ្ទះ នាងកាឡីក៏ត្រឡប់មក ត្រូវសេដ្ឋីសួរ តំណាលរឿងឲ្យស្តាប់ កាលសេដ្ឋីពោលថា នាងចូរទៅឲ្យទ្រព្យ ១.០០០ ហើយនាំទារកនោះមក នាងកាឡីក៏បានធ្វើតាមនោះ ។

លំដាប់នោះសេដ្ឋីពោលចំពោះនាងកាឡីនោះថា ឥឡូវនេះ នាងចូរនាំទារកនោះទៅព្រៃខ្មោច ហើយឲ្យដេករវាងគុម្ពឈើ សុនខជាដើមក្នុងទីនោះនឹងទំពាស៊ី ឬអមនុស្សនឹងប្រហារឲ្យស្លាប់ នាងដឹងថា ទារកនោះស្លាប់ឬមិនស្លាប់ហើយគប្បីត្រឡប់ នាងកាឡីនោះនាំទារកនោះទៅឲ្យដេកក្នុងទីនោះ ហើយឈរក្នុងចំណែកម្ខាង ។ សុនខ ឬអមនុស្សជាដើមមិនអាចចូលទៅជិតទារកបាន ។ លំដាប់នោះអ្នកចិញ្ចឹមពពែម្នាក់នាំពពែទៅឃ្វាលក្បែរព្រៃខ្មោច ។

មេពពែមួយស៊ីស្លឹកឈើ ចូលទៅរវាងគុម្ពឈើ ឃើញទារកហើយលុតជង្គង់ឲ្យទារកបៅ កាលអ្នកចិញ្ចឹមពពែដេញថា ហេ ហេ ក៏មិនចេញទៅ អ្នកចិញ្ចឹមពពែគិតថា អញនឹងយកឈើច្រត់វាយពពែនោះនាំចេញទៅ ទើបចូលទៅក្នុងរវាងគុម្ពឈើ ឃើញពពែលុតជង្គង់ឲ្យទារកបៅដោះ បាននូវ

សេចក្តីស្រឡាញ់ដូចបុត្តក្នុងទារក គិតថា អញបានកូនហើយ ទើបនាំចៀស ចេញទៅ ។ នាងកាឡីត្រឡប់ទៅ ត្រូវសេដ្ឋីសួរ ទើបតំណាលរឿងឲ្យស្តាប់ កាលសេដ្ឋីពោលថា នាងចូរទៅ ចូរឲ្យទ្រព្យអ្នកចិញ្ចឹមពពែ ១.០០០ ហើយ នាំទារកមក នាងកាឡីបានធ្វើតាមនោះ ។

លំដាប់នោះសេដ្ឋីនិយាយនឹងនាងកាឡីថា នាងចូរនាំទារកនេះទៅឡើង ភ្នំទម្លាក់ចោរ ហើយបោះចូលក្នុងជ្រោះ ទារកក៏នឹងត្រូវទង្គិចត្រង់ថ្មភ្នំ និង បែកជាលម្អិតតូចធំធ្លាក់លើផែនដី នាងគប្បីដឹងថា ទារកនោះស្លាប់ ឬមិន ស្លាប់ ហើយត្រឡប់មក នាងកាឡីនាំទារកនោះទៅតាមនោះ ឈរលើកំពូល ភ្នំហើយបោះទារកចុះទៅ គុម្ពឫស្សីធំអាស្រ័យជ្រោះភ្នំនោះ លូតលាស់ទៅ តាមភ្នំ គុម្ពទំពាំងបាយជូរដុះគ្របដណ្តប់លើគុម្ពឫស្សីនោះ ទារកកាលធ្លាក់ ទៅ ក៏បានធ្លាក់លើគុម្ពទំពាំងបាយជូរនោះ ដូចធ្លាក់ក្នុងអង្រឹង ដូច្នោះ ។ ក្នុងថ្ងៃនោះមេជាងផែងដល់វេលាកាប់ឫស្សី ទើបទៅជាមួយបុត្ត ចាប់ផ្តើម កាប់គុម្ពឫស្សីនោះ កាលគុម្ពឫស្សីកម្រើក ទារកបានយំ ។ មេជាងគិតថា ដូចសម្លេងទារក ទើបឡើងក្នុងចំណែកម្ខាង ឃើញទារកនោះត្រេកអរថា អញបានកូនហើយ ទើបនាំទារកទៅ ។ នាងកាឡីត្រឡប់ទៅវិញ ត្រូវសេដ្ឋី សួរ ទើបតំណាលរឿងឲ្យស្តាប់ កាលសេដ្ឋីប្រាប់ថា នាងចូរទៅឲ្យទ្រព្យ ១.០០០ ហើយចូរនាំទារកនោះមក នាងកាឡីបានធ្វើតាមនោះ ។

កាលសេដ្ឋីធ្វើហើយធ្វើទៀតយ៉ាងនេះ ទារកក៏ធំឡើង ព្រោះទារកនោះ យំដោយសំឡេងខ្លាំងទើបមានឈ្មោះថា ឃោសិត ។ ឃោសិតនោះប្រាកដ

ដល់សេដ្ឋីដូចបន្ទាក្នុងភ្នែក មិនអាចមើលចំបាន ។ សេដ្ឋីគិតរកឧបាយនឹងសម្លាប់ឃោសិតនោះ ទើបទៅរកជាងស្លូនឆ្នាំងរបស់ខ្លួនសួរថា កាលណាអ្នកនឹងដុតឡ កាលស្លូនឆ្នាំងប្រាប់ថា ថ្ងៃស្អែកនេះ ទើបពោលថា បើដូច្នោះចូរអ្នកទទួលទ្រព្យ ១.០០០ នេះទុក ហើយធ្វើធុរៈម្យ៉ាងដល់យើង ស្លូនឆ្នាំងសួរថា ធ្វើអ្វីលោកម្ចាស់ សេដ្ឋីប្រាប់ថា យើងមានបុត្តជាអវជាតបុត្តម្នាក់ យើងនឹងបញ្ជូនវាមករកអ្នក ពេលនោះអ្នកគប្បីឲ្យបុត្តនោះ ចូលទៅកាន់បន្ទប់ យកកាំបិតដែលមុតកាប់ឲ្យជាចម្រៀកតូចធំ ដាក់ក្នុងថាងហើយបញ្ចូលក្នុងឡ នេះទ្រព្យ ១.០០០ របស់អ្នកជាការកក់ ម្យ៉ាងទៀត ខ្ញុំនឹងដឹងកិច្ចដែលគួរធ្វើដល់អ្នក ក្នុងកាលជាខាងក្រោយ ឲ្យក្រៃលែងជាងនោះ ស្លូនឆ្នាំងទទួលពាក្យហើយ ។

ស្អែកឡើងសេដ្ឋីហៅឃោសិតៈមកប្រាប់ថា ម្សិលមិញ អញបានប្រាប់ស្លូនឆ្នាំងឲ្យធ្វើធុរៈម្យ៉ាង មកចុះកូន ចូរទៅរកស្លូនឆ្នាំងនោះ ហើយប្រាប់ថាបានឮថា ចូរលោកធ្វើធុរៈ ដែលលោកឪពុករបស់ខ្ញុំប្រាប់កាលពីម្សិលមិញឲ្យសម្រេចចុះ ដូច្នេះ ហើយបញ្ជូនទៅ ។ ឃោសិតៈទទួលពាក្យហើយក៏ទៅ ។ ឯបុត្តរបស់សេដ្ឋីកំពុងលេងវ្ញជាមួយនឹងពួកទារក ឃើញឃោសិតៈកំពុងដើរមកដល់ទីនោះទើបស្រែកហៅសួរថា នឹងទៅណា កាលឃោសិតប្រាប់ថា លោកឪពុកប្រាប់ឲ្យទៅរកស្លូនឆ្នាំង ទើបបុត្តសេដ្ឋីប្រាប់ថា ខ្ញុំទៅទីនោះឯង ទារកទាំងនេះឈ្នះខ្ញុំច្រើនពិន្ទុហើយ បងឈ្នះពិន្ទុនោះហើយចូរឲ្យដល់ខ្ញុំ ។ ឃោសិតៈប្រាប់ថា បងខ្លាចលោកឪពុក កូនសេដ្ឋីប្រាប់ថា

បងកុំខ្លាចឡើយ ខ្ញុំនឹងនាំដំណឹងនោះទៅឯង ហើយប្រាប់គេទៅទៀតថា ពួកទារកជាច្រើនឈ្នះខ្ញុំហើយ បងចូរឈ្នះពិន្ទុឲ្យខ្ញុំ ទម្រាំខ្ញុំត្រឡប់មក ។ បានឮថា ឃោសិតៈឈ្លាសក្នុងការលេងវូ ដោយហេតុនោះ ទើបបុត្តសេដ្ឋីរំអុកឃោសិតៈយ៉ាងនោះ ។ ឃោសិតៈប្រាប់ថា បើដូច្នោះប្អូនចូរទៅប្រាប់ដល់ស្មូនឆ្នាំងថា កាលពីម្សិលមិញនេះ លោកឪពុកខ្ញុំប្រាប់ឲ្យលោកធ្វើធុរៈម្យ៉ាង សូមលោកធ្វើធុរៈនោះឲ្យសម្រេចចុះ ដូច្នេះហើយបញ្ជូនបុត្តសេដ្ឋីទៅ ។ បុត្តសេដ្ឋីនោះទៅរកស្មូនឆ្នាំងហើយបានប្រាប់តាមនោះ ។

គ្រានោះស្មូនឆ្នាំងសម្លាប់បុត្តសេដ្ឋីនោះ តាមទំនងដែលសេដ្ឋីប្រាប់ហើយបោះទៅក្នុងឡ ។ ឃោសិតៈលេងអស់មួយថ្ងៃ ពេលល្ងាចទើបត្រឡប់ទៅផ្ទះ កាលសេដ្ឋីសួរថា ឯងមិនបានទៅទេឬ ទើបប្រាប់ហេតុដែលខ្លួនមិនទៅនិងហេតុដែលប្អូនទៅជំនួស ។ សេដ្ឋីស្រែកយំយ៉ាងខ្លាំងថា ថ្វីយ ថ្វីយ ឈាមក្តៅផ្សាយទៅពេញសរីរៈ ផ្គងដើមដៃកន្ទក់កន្ទេញថា ស្មូនឆ្នាំងអើយកុំសម្លាប់កូនខ្ញុំ ស្មូនឆ្នាំងអើយ កុំសម្លាប់កូនខ្ញុំ បានទៅរកស្មូនឆ្នាំង ។ ស្មូនឆ្នាំងឃើញសេដ្ឋីមកយ៉ាងនោះ ទើបពោលថា កុំព្រួយអ្វីឡើយលោកម្ចាស់ការងារសម្រេចហើយ ។ សេដ្ឋីត្រូវសេចក្តីសោកជំ ដូចភ្នំសង្កត់ សោយទោមនស្សមិនមែនតិច ។

កាលបើយ៉ាងនេះសេដ្ឋីក៏មិនអាចសម្លឹងមើលឃោសិតៈត្រង់ ៗ បានគិតថា អញនឹងសម្លាប់ឃោសិតៈនោះបានដូចម្តេច ឃើញឧបាយថា អញនឹងបញ្ជូនទៅរកអ្នកចាត់ចែងទ្រព្យក្នុងស្រុក ១០០ របស់អញ ហើយឲ្យសម្លាប់

ទើបសរសេរសំបុត្របញ្ជូនឲ្យអ្នកចាត់ចែងទ្រព្យ មានសេចក្តីថា បុត្តនេះជាអវជាតបុត្តរបស់យើង សូមឲ្យសម្លាប់ ហើយប្រានចុះក្នុងរណ្តៅលាមក ក៏កាលធ្វើយ៉ាងនេះហើយ យើងនឹងដឹងកិច្ចដែលគួរធ្វើដល់អ៊ំ ហើយពោលនឹងឃោសិតៈថា បាឃោសិតៈ បិតាមានអ្នកចាត់ចែងទ្រព្យក្នុងស្រុក ១០០ អ្នកចូរនាំសំបុត្រនេះទៅឲ្យគេ ហើយចងសំបុត្រត្រង់ជាយសំពត់របស់ឃោសិតៈ ឃោសិតៈមិនចេះអក្ខរៈសម័យ ព្រោះតាំងអំពីនៅក្មេង សេដ្ឋីបំណងនឹងសម្លាប់ម្តងហើយម្តងទៀតក៏មិនអាចសម្លាប់បាន នឹងឲ្យរៀនអក្ខរៈសម័យបានដូចម្តេច ទើបឃោសិតៈចងសំបុត្រមរណៈរបស់ខ្លួនទុកត្រង់ជាយសំពត់កាលចេញទៅពោលថា បពិត្រលោកឪពុក ខ្ញុំមិនមានស្បៀង សេដ្ឋីពោលថា មិនចាំបាច់ស្បៀងទេ សេដ្ឋីសម្លាញ់របស់អញមាននៅត្រង់ស្រុកឯណោះក្នុងវវាងផ្លូវ ចូរបាបរិភោគអាហារព្រឹក ត្រង់ផ្ទះរបស់សេដ្ឋីនោះ ហើយធ្វើដំណើរទៅ ។

ឃោសិតៈទទួលពាក្យហើយថ្វាយបង្គំបិតា ចេញទៅដល់ស្រុកនោះ សួររកផ្ទះសេដ្ឋី បានឃើញភរិយាសេដ្ឋី ។ កាលភរិយាសេដ្ឋីសួរថា បាមកអំពីណា ឃោសិតៈប្រាប់ថា មកអំពីក្នុងក្រុង ភរិយាសេដ្ឋីសួរថា បាជាបុត្តនរណា ឃោសិតៈឆ្លើយថា ជាបុត្តសេដ្ឋីដែលជាសម្លាញ់របស់អ្នកម៉ែ ។ សេដ្ឋិនីសួរថា អ្នកឈ្មោះឃោសិតៈមែនឬ ឃោសិតៈឆ្លើយថា មែន ។ លុះឃើញប៉ុណ្ណោះ ភរិយាសេដ្ឋីក៏កើតសេចក្តីស្រឡាញ់ដូចកូនក្នុងឃោសិតៈ ។ សេដ្ឋីមានកូនស្រីម្នាក់អាយុ ១៥-១៦ ឆ្នាំ មានរូបស្អាត គួរមើល មាតា

បិតាឲ្យទាសីម្នាក់ដើម្បីមើលថៃ ឲ្យដេកក្នុងបន្ទប់ដ៏មានសិរី ជាន់លើនៃប្រាសាទ ៧ ជាន់ ។ ក្នុងខណៈនោះកូនស្រីសេដ្ឋីបញ្ជូនទាសីនោះទៅផ្សារ ។

លំដាប់នោះកិរិយាសេដ្ឋីឃើញទាសីនោះ សួរថា នាងទៅណា កាល ទាសីឆ្លើយថា ធីតារបស់អ្នកម៉ែឲ្យទៅផ្សារ ទើបសេដ្ឋីនីពោលថា ចូរមក នេះសិន វៀរការទៅផ្សារទុកសិន នាងចូរក្រាលតាំងឲ្យបុត្តរបស់យើង រក ទឹកមកលាងជើង លាបប្រេង ក្រាលទីដេកឲ្យ ខាងក្រោយសឹមទៅផ្សារ ទាសីបានធ្វើតាមនោះ ។ កូនស្រីសេដ្ឋីខឹងទាសីមកយឺតទើបទាសីប្រាប់ដល់ សេដ្ឋីធីតាថា កុំក្រោធនឹងខ្ញុំឡើយ ឃោសិតសេដ្ឋីបុត្តមក ខ្ញុំធ្វើនោះខ្លះនេះ ខ្លះឲ្យដល់ឃោសិតៈនោះ ទើបបានទៅផ្សារស្រេចហើយទើបត្រឡប់មកនេះ ឯង ។ កូនស្រីសេដ្ឋី លុះបានស្តាប់ឈ្មោះថា ឃោសិតសេដ្ឋីបុត្តប៉ុណ្ណោះ សេចក្តីស្រឡាញ់ដោយអំណាចបុព្វេសន្និវាសកាត់ស្បែកជាដើម រហូតដល់ ខួរក្នុងឆ្អឹងតាំងនៅ ។ ទើបនាងសួរទាសីនោះថា គេនៅត្រង់ណា ទាសី ឆ្លើយថា ដេកលក់លើទីដេក ។ សេដ្ឋីធីតាសួរថា មានអ្វីត្រង់ដៃរបស់គេខ្លះ ទាសីឆ្លើយថា មានសំបុត្រត្រង់ជាយសំពត់ ។ នាងគិតថា នោះជាសំបុត្រ អ្វីហ្ន៎ កាលឃោសិតៈកំពុងដេកលក់ កាលមាតាបិតាមិនឃើញព្រោះបញ្ជូន ចិត្តទៅទីដទៃ លបចូលទៅរកឃោសិតៈនោះស្រាយសំបុត្រចេញ កាន់ចូល ទៅក្នុងបន្ទប់របស់ខ្លួន បិទទ្វារ បើកបង្អួច ហើយអានសំបុត្រនោះ ព្រោះ នាងឈ្លាសក្នុងអក្ខរៈសម័យ គិតថា ឱប្រុសល្ងង់ ចងសំបុត្រមរណៈរបស់ ខ្លួន ទុកត្រង់ជាយសំពត់ត្រាច់ទៅ បើអញមិនឃើញ គេនឹងមិនមានជីវិត

ទើបហែកសំបុត្រនោះចោល ហើយសរសេរសំបុត្រដទៃជំនួស ដោយពាក្យរបស់សេដ្ឋីថា បុត្តរបស់យើងឈ្មោះឃោសិតៈ អ្នកចាត់ការទ្រព្យ ចូរនាំបណ្ណាការអំពីស្រុក ១០០ មកធ្វើអាវាហមង្គលជាមួយធីតា របស់សេដ្ឋីជនបទនេះ ឲ្យធ្វើផ្ទះ ២ ជាន់ ត្រង់កណ្ដាលស្រុក ដែលជាលំនៅរបស់ខ្លួន ហើយចាត់ចែងការរក្សាឲ្យល្អ ដោយការព័ទ្ធកំពែងនិងតាំងអ្នកយាមការពារ កាលធ្វើគ្រប់យ៉ាងរៀបរយហើយ ចូរបញ្ជូនដំណឹងឲ្យយើងដឹងផង កាលធ្វើយ៉ាងនេះស្រេចហើយ យើងនឹងដឹងកិច្ចដែលគួរធ្វើដល់អ៊ុំ កាលសរសេរស្រេច ទើបមូរសំបុត្រចងទុកត្រង់ជាយសំពត់របស់ឃោសិតៈ ។

ឃោសិតៈដេកលក់អស់ថ្ងៃ ក្រោកឡើងបរិភោគអាហារហើយក៏ចៀសចេញទៅ ស្អែកឡើងដល់ស្រុកនោះអំពីព្រលឹម ឃើញអ្នកចាត់ចែងទ្រព្យកំពុងធ្វើការងារក្នុងស្រុក ។ អ្នកចាត់ការទ្រព្យឃើញឃោសិតៈ ទើបសួរថា មានការអ្វីបា កាលឃោសិតៈប្រាប់ថា បិតារបស់ខ្ញុំបញ្ជូនសំបុត្រមកឲ្យលោក ទទួលសំបុត្រមកអានក៏ត្រេកអរពោលថា មកអ្នក ចូរមើលសេចក្ដីស្រឡាញ់ក្នុងខ្ញុំ របស់ម្ចាស់យើង ម្ចាស់របស់យើង បញ្ជូនអគ្គរាមកដល់ខ្ញុំដោយប្រាប់ថា អ្នកចាត់ចែងទ្រព្យ ចូរធ្វើអាវាហមង្គលដល់បុត្តច្បង ពួកអ្នកចូរប្រញាប់ទៅរកឈើជាដើមមកចុះ ហើយប្រាប់ឲ្យគហបតីទាំងឡាយធ្វើផ្ទះតាមដែលពោលហើយ ត្រង់កណ្ដាលស្រុក ឲ្យនាំគ្រឿងបណ្ណាការមកអំពីស្រុក ១០០ ហើយនាំធីតារបស់សេដ្ឋីជនបទមកធ្វើពិធីមង្គលស្រេចហើយបញ្ជូនដំណឹងទៅឲ្យសេដ្ឋីជ្រាបថា ខ្ញុំបានធ្វើគ្រប់យ៉ាងស្រេចហើយ ។

សេដ្ឋីបានស្តាប់ពាក្យនោះ ក៏កើតទោមនស្សធំថា ធុរៈដែលអញឲ្យធ្វើមិនសម្រេច ធុរៈដែលអញមិនឲ្យធ្វើសម្រេច ។ ព្រមជាមួយការសោកដល់បុត្ត សេចក្តីសោកនោះកាន់តែរុកកួនចូលមកបន្ថែមទៀត ទើបកើតនូវការក្តៅក្នុងផ្ទៃដល់នូវការចុះឈាម ។ សេដ្ឋីធីតាក៏បញ្ជាថា បើមាននរណាមកអំពីសម្នាក់របស់សេដ្ឋី ពួកអ្នកមិនទាន់ប្រាប់យើង កុំប្រាប់ដល់សេដ្ឋីបុត្តមុន ។ ចំណែកសេដ្ឋីក៏គិតថា ឥឡូវនេះយើងនឹងមិនឲ្យបុត្តអាក្រក់ជាម្ចាស់សម្បត្តិរបស់យើង ទើបពោលដល់អ្នកចាត់ការទ្រព្យម្នាក់ទៀតថា លោកអ៊ុំខ្ញុំចង់ឃើញបុត្តរបស់ខ្ញុំ ចូរលោកបញ្ជូនមនុស្សជិតស្និទ្ធម្នាក់ ហើយសរសេរសំបុត្រមួយច្បាប់ បញ្ជូនទៅហៅបុត្តរបស់យើងមក ។

អ្នកចាត់ការទ្រព្យទទួលពាក្យថា សាធុ ឲ្យសំបុត្រហើយបញ្ជូនបុរសម្នាក់ទៅ ។ សេដ្ឋីធីតា បាននាំឃោសិតៈកុមារទៅក្នុងវេលាដែលសេដ្ឋីឈឺធ្ងន់ សេដ្ឋីក៏បានអនិច្ចកម្មហើយ ។ កាលបិតាអនិច្ចកម្មព្រះរាជាទ្រង់ប្រទានសម្បត្តិដែលបិតាប្រើប្រាស់ ទ្រង់ប្រគល់តំណែងសេដ្ឋី ព្រមដោយវត្ថុគ្រប់យ៉ាងមួយមុខ ១០០ ឲ្យ ។ ឃោសិតសេដ្ឋីតាំងនៅក្នុងមហាសម្បត្តិដ៏ធំថា ខ្ញុំផុតចាកពីសេចក្តីស្លាប់ក្នុងឋានៈ ៧ លើក តាំងអំពីដើមតាមពាក្យប្រាប់របស់សេដ្ឋីធីតានិងនាងកាឡី ទើបលះបង់ទ្រព្យមួយថ្ងៃ ១.០០០ បរិច្ចាគទាន ។ ភាពដែលឃោសិតសេដ្ឋីមិនមានរោគក្នុងឋានៈ ៧ លើក យ៉ាងនេះ ជាឫទ្ធិរបស់អ្នកមានបុណ្យ ។ ក្នុងបទទាំងនោះ ផ្ទះ លោកហៅថា គហៈ បុគ្គលជាធំក្នុងគហៈ ឈ្មោះថា គហបតិ ។ បទនេះ ជាឈ្មោះរបស់អ្នក

ជាធំក្នុងត្រកូលមហាសាល ។ ក្នុងគម្ពីរខ្លះ សរសេរមេណ្ឌកសេដ្ឋីទុកក្នុងលំដាប់របស់ឃោសិតសេដ្ឋី ។ ក្នុងបទថា **បញ្ចន្នំ មហាបុញ្ញានំ បុញ្ញវតោ ឥទ្ធិ** សេចក្តីថា គប្បីឃើញឫទ្ធិ របស់អ្នកមានបុណ្យច្រើន ៥ នាក់ ។ ជន ៥ នាក់ទាំងនេះ ឈ្មោះថា អ្នកមានបុណ្យច្រើន ៥ នាក់ គឺមេណ្ឌកសេដ្ឋី ១ នាងចន្ទបទុមាភរិយាមេណ្ឌកសេដ្ឋី ១ ធនញ្ជ័យសេដ្ឋីបុត្ត ១ នាងសុមនាទេវីកូនប្រសារស្រី ១ នាយបុណ្ណទាសៈ ១ បាន សន្សំបុញ្ញាធិការក្នុងព្រះបច្ចេកពុទ្ធ ។ ក្នុងជនទាំងនោះ មេណ្ឌកសេដ្ឋីសាង ជង្រុកស្រូវទុក ១.២៥០ កក់ក្បាលហើយអង្គុយត្រង់ទ្វារ សម្លឹងមើលទៅ លើ ស្រូវសាលីក្រហមធ្លាក់ចុះអំពីអាកាស ពេញជង្រុកទាំងអស់ ។ ភរិយា របស់មេណ្ឌកសេដ្ឋីនោះ យកអង្ករប្រមាណមួយនាឡិដាំបាយ ហើយធ្វើសម្ល មានទឹកតិចណាមួយ ប្រដាប់ដោយគ្រឿងអលង្ការគ្រប់ប្រភេទ អង្គុយលើ អាសនៈដែលក្រាលទុកត្រង់ខ្លោងទ្វារ ឲ្យប្រកាសថា បុគ្គលមានសេចក្តីត្រូវ ការភត្តាហារទាំងពួង ចូរមកចុះ កាន់វែកមាស ដួសឲ្យរហូតពេញភាជនៈ ដែលបុគ្គលមកហើយបង្អោនចូលទៅ កាលនាងឲ្យអស់មួយថ្ងៃក៏ប្រាកដត្រឹម តែស្នាមកាន់យកមួយវែកប៉ុណ្ណោះ ។

បុត្ររបស់មេណ្ឌកសេដ្ឋី កក់ក្បាល ហើយកាន់យកថង់ទ្រព្យ ១.០០០ ឲ្យប្រកាសថា អ្នកមានសេចក្តីត្រូវការកហាបណៈ ចូរមកចុះ ហើយដាក់ឲ្យ ពេញភាជនៈដែលមនុស្សមកហើយបង្អោនចូលមក ។ កហាបណៈ ១.០០០ ក្នុងថង់ ក៏នៅដូចដើម ។

កូនប្រសារស្រីរបស់សេដ្ឋី ប្រដាប់ដោយគ្រឿងអលង្ការគ្រប់ប្រភេទកាន់យកកញ្ជើស្រូវ ៤ នាឡិ អង្គុយលើទីអង្គុយ ឲ្យប្រកាសថា បុគ្គលមានសេចក្តីត្រូវការពូជស្រូវ ចូរមកចុះ ហើយជួសឲ្យរហូតពេញភាជនៈ ដែលបុគ្គលមកហើយបង្អោនចូលមក កញ្ជើក៏នៅពេញដូចដើម ។

ទាសៈរបស់សេដ្ឋី ប្រដាប់ដោយគ្រឿងអលង្ការគ្រប់ប្រភេទ យកខ្សែមាសទឹមគោដោយនឹមមាស កាន់ជន្លជន្ទញមាស ព្រោះក្នុងទី ៥ កន្លែងដោយគ្រឿងក្រអូប ពាក់ចង្កឹមាសត្រង់ស្នែងទាំងសងខាង ចេញទៅភ្ជួរស្រែគន្លងនង្គ័ល ៧ គឺខាងឆ្វេង ៣ ខាងស្តាំ ៣ កណ្តាល ១ ភ្ជួរទៅហើយ ។ អ្នកជម្ពូទ្វីបកាន់យកកត្ត ពូជ ប្រាក់និងមាសជាដើម អំពីផ្ទះសេដ្ឋីតាមគាប់ចិត្ត ។ កាលព្រះមានព្រះភាគយាងដល់ភទ្ទិយនគរដោយលំដាប់ អ្នកមានបុណ្យទាំង ៥ និងនាងវិសាខា ធីតារបស់ធនញ្ជយសេដ្ឋី បានសម្រេចសោតាបត្តិផល ដោយការស្តាប់ធម៌របស់ព្រះមានព្រះភាគ នេះឫទ្ធិរបស់អ្នកមានបុណ្យច្រើន ៥ នាក់នោះ ។ តែដោយសង្ខេបភាពវិសេសនៃការសម្រេច ក្នុងការសន្សំបុណ្យដែលដល់កាពចាស់ក្លា ជាឫទ្ធិរបស់អ្នកមានបុណ្យ ។

[ ១៦៤ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិជ្ជាមយិទ្ធិនិទ្ទេស ដូចតទៅនេះថា ឈ្មោះថា **វិជ្ជាធរា** ព្រោះអត្ថថា ទ្រទ្រង់ទុកនូវវិជ្ជារបស់អ្នកស្រុកគន្ធារៈដែលមានអាការឲ្យសម្រេច ឬវិជ្ជាដទៃដែលសម្រេចមកអំពីឧបចារ ដែលសម្រេចតាមសេចក្តីប្រាថ្នា ។ បទថា **វិជ្ជំ បរិជប្បេត្វា** បានដល់ រាយ

វិជ្ជាតាមឧបចារដោយមាត់ ។ បទដ៏សេស មានអត្ថដូចពោលហើយនោះឯង ។

[ ១៦៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាបយោគិទ្ទិនិទ្ទេស ដូចតទៅនេះថា លោកសួរត្រឹមតែអាការនៃកាសម្រេច មិនសួរថា **កតមា** ( តើដូចម្ដេច ) ព្រោះមិនមានគុណវិសេសដទៃ ហើយសួរត្រឹមតែប្រការប៉ុណ្ណោះ ទើបតាំងសំណួរថា **កថំ** ( ដូចម្ដេច ) ហើយសរុបថា **ឯវំ** ( យ៉ាងនេះ ) ។ ក្នុងនិទ្ទេសនេះ បាលីដែលដូចគ្នានឹងបាលីដែលមានក្នុងកាលមុនមកហើយដោយអំណាចសម្ដែងការប្រកបប្រពៃ ពោលគឺការបដិបត្តិនោះឯងតែមកក្នុងអដ្ឋកថាថា សេចក្ដីវិសេសកើតឡើង ព្រោះធ្វើកម្មនោះ សំដៅដល់ការ ត្រៀមយ៉ាងណាមួយដោយអំណាចធ្វើសកដព្យុហៈ ( ក្បួនចម្បាំងដូចកង់រទេះ ) ជាដើម សិល្បកម្មណាមួយ វេជ្ជកម្មណាមួយ ការរៀនត្រៃវេទ ការរៀនព្រះត្រៃបិដក ដោយហោចការក្ខរ និងការសាបព្រោះជាដើម ឈ្មោះថា ឫទ្ធិ ព្រោះអត្ថថា សម្រេច ព្រោះហេតុនៃការប្រកបប្រពៃក្នុងចំណែកនោះៗដោយប្រការដូច្នេះ ។

**អដ្ឋកថា ទសឥទ្ធិកថា ចប់**

**ឥទ្ធិកថា ចប់**

# សុត្តន្តបិដក

## បញ្ញាវគ្គ អភិសមយកថា

[ ១៦៦ ] សំណួរត្រង់ពាក្យថា ការត្រាស់ដឹង តើបុគ្គលត្រាស់ដឹងដោយធម្មជាតអ្វី ។ បុគ្គលត្រាស់ដឹងដោយចិត្ត ។ បើបុគ្គលត្រាស់ដឹងដោយចិត្តដូច្នោះបុគ្គលមិនមានញាណក៏ត្រាស់ដឹង ។ បុគ្គលមិនមានញាណមិនត្រាស់ដឹងទេ ត្រាស់ដឹងតែដោយញាណ ។ បើបុគ្គលត្រាស់ដឹងដោយញាណដូច្នោះ បុគ្គលមិនមានចិត្ត ក៏ត្រាស់ដឹង ។ បុគ្គលមិនមានចិត្តមិនត្រាស់ដឹងទេ ត្រាស់ដឹងដោយចិត្តផង ដោយញាណផង ។ បើបុគ្គលត្រាស់ដឹងដោយចិត្តផង ដោយញាណផង ដូច្នោះបុគ្គលត្រាស់ដឹងដោយកាមាវចរចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹងដោយកាមាវចរចិត្តផង ដោយញាណផងទេ ។ ដូច្នោះបុគ្គលត្រាស់ដឹងដោយរូបាវចរចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹងដោយរូបាវចរចិត្តផង ដោយញាណផងទេ ។ ដូច្នោះបុគ្គលត្រាស់ដឹងដោយអរូបាវចរចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹងដោយអរូបាវចរចិត្តផង ដោយញាណផងទេ ។ ដូច្នោះបុគ្គលត្រាស់ដឹង ដោយកម្មស្សកតាចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹង ដោយកម្មស្សកតាចិត្តផង ដោយញាណផងទេ ។ ដូច្នោះបុគ្គលត្រាស់ដឹងដោយសច្ចានុលោមិកចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹងដោយសច្ចានុលោមិកចិត្តផង ដោយញាណផងទេ ។ ដូច្នោះបុគ្គលត្រាស់ដឹងដោយអតីតចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់

ដឹងដោយអតីតចិត្តផង ដោយញាណផងទេ ។ ដូច្នោះបុគ្គលត្រាស់ដឹង ដោយអនាគតចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹងដោយអ-នាគតចិត្តផង ដោយញាណផងទេ ។ ដូច្នោះ បុគ្គលត្រាស់ដឹងដោយ បច្ចុប្បន្នលោកិយចិត្តផង ដោយញាណផង ។ បុគ្គលមិនត្រាស់ដឹងដោយ បច្ចុប្បន្នលោកិយចិត្តផង ដោយញាណផង ត្រាស់ដឹងដោយបច្ចុប្បន្នចិត្ត ផង ដោយញាណផង ក្នុងខណៈនៃលោកុត្តរមគ្គ ។

[ ១៦៧ ] បុគ្គលត្រាស់ដឹងដោយបច្ចុប្បន្នចិត្តផង ដោយញាណផង ក្នុងខណៈនៃលោកុត្តរមគ្គ តើដូចម្តេច ។ ក្នុងខណៈនៃលោកុត្តរមគ្គ ចិត្ត មានកិរិយាកើតឡើង ជាអធិបតី ជាហេតុ ជាបច្ច័យនៃញាណ ចិត្តដែល ប្រកបដោយញាណនោះ មានព្រះនិព្វានជាអារម្មណ៍ ញាណមានកិរិយា ឃើញជាអធិបតី ជាហេតុ ជាបច្ច័យនៃចិត្ត ញាណដែលប្រកបដោយចិត្ត នោះ មាននិរោធជាអារម្មណ៍យ៉ាងនេះ ឈ្មោះថា បុគ្គលត្រាស់ដឹងដោយ បច្ចុប្បន្នចិត្តផង ដោយញាណផង ក្នុងខណៈនៃលោកុត្តរមគ្គ ។

[ ១៦៨ ] ការត្រាស់ដឹងមានត្រឹមតែប៉ុណ្ណោះទេឬ ។ មិនមែនមានតែ ប៉ុណ្ណោះទេ ក្នុងខណៈនៃលោកុត្តរមគ្គ មានការត្រាស់ដឹងដោយការឃើញគឺ សម្មាទិដ្ឋិ មានការត្រាស់ដឹងដោយកិរិយាលើកចិត្តកាន់អារម្មណ៍ គឺសម្មា-សង្កប្បៈ ការត្រាស់ដឹងដោយកិរិយាកំណត់ គឺសម្មាវាចា ការត្រាស់ដឹង ដោយការខ្នះខ្នែង គឺសម្មាកម្មន្តៈ ការត្រាស់ដឹងដោយកិរិយាផូរផង់ គឺស-ម្មាអាជីវៈ ការត្រាស់ដឹងដោយកិរិយាផ្គងឡើង គឺសម្មាវាយាមៈ ការត្រាស់

ដឹងដោយការប្រុង គឺសម្មាសតិ ការត្រាស់ដឹងដោយកិរិយាមិនរាយមាយ គឺសម្មាសមាធិ ការត្រាស់ដឹងដោយការប្រុង គឺសតិសម្ពោជ្ឈង្គ ។បេ។ ការត្រាស់ដឹង ដោយការពិចារណា គឺឧបេក្ខាសម្ពោជ្ឈង្គ ការត្រាស់ដឹង ដោយការមិនញាប់ញ័រចំពោះហេតុមិនគួរជឿ គឺសទ្ធាពលៈ ការត្រាស់ដឹង ដោយកិរិយាមិនញាប់ញ័រ ចំពោះសេចក្តីខ្ជិលច្រអូស គឺវីរិយពលៈ ការត្រាស់ដឹងដោយកិរិយាមិនញាប់ញ័រ ចំពោះសេចក្តីប្រហែស គឺសតិពលៈ ការត្រាស់ដឹងដោយកិរិយាមិនញាប់ញ័រចំពោះសេចក្តីរាយមាយ គឺសមាធិ-ពលៈ ការត្រាស់ដឹងដោយកិរិយាមិនញាប់ញ័រ ចំពោះអវិជ្ជា គឺបញ្ញាពលៈ ការត្រាស់ដឹងដោយសេចក្តីជឿស៊ប់ គឺសទ្ធិន្ទ្រិយ ការត្រាស់ដឹងដោយការផ្គងឡើង គឺវីរិយិន្ទ្រិយ ការត្រាស់ដឹងដោយកិរិយាប្រុង គឺសតិន្ទ្រិយ ការត្រាស់ដឹង ដោយការមិនរាយមាយ គឺសមាធិន្ទ្រិយ ការត្រាស់ដឹងដោយកិរិយាយល់ គឺបញ្ញិន្ទ្រិយ ការត្រាស់ដឹង គឺឥន្ទ្រិយ ដោយអត្ថថា ជាអធិ-បតី ការត្រាស់ដឹង គឺពលៈ ដោយអត្ថថា មិនញាប់ញ័រ ការត្រាស់ដឹង គឺពោជ្ឈង្គ ដោយអត្ថថា ចេញចាកវដ្តៈ ការត្រាស់ដឹង គឺមគ្គ ដោយអត្ថថា ជាហេតុ ការត្រាស់ដឹង គឺសតិប្បដ្ឋាន ដោយអត្ថថា ប្រុង ការត្រាស់ដឹង គឺសម្មប្បធាន ដោយអត្ថថា តម្កល់ ការត្រាស់ដឹង គឺឥទ្ធិបាទ ដោយអត្ថថា សម្រេច ការត្រាស់ដឹង គឺសច្ចៈ ដោយអត្ថថា ទៀងទាត់ ការត្រាស់ដឹង គឺសមថៈ ដោយអត្ថថា មិនរាយមាយ ការត្រាស់ដឹង គឺវិបស្សនា ដោយអត្ថថា ពិចារណាឃើញ ការត្រាស់ដឹង គឺសមថៈនិង

វិបស្សនា ដោយអត្ថថា មានរសតែមួយ ការត្រាស់ដឹង គឺធម៌ជាប់គ្នាជាគូ ដោយអត្ថថា មិនប្រព្រឹត្តលើសគ្នា ការត្រាស់ដឹង គឺសីលវិសុទ្ធិ ដោយអត្ថថា សង្រួម ការត្រាស់ដឹង គឺចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ការត្រាស់ដឹង គឺទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ ការត្រាស់ដឹង គឺអធិមោក្ខ ដោយអត្ថថា រួច ការត្រាស់ដឹង គឺវិជ្ជា ដោយអត្ថថា ចាក់ធ្លុះ ការត្រាស់ដឹង គឺវិមុត្តិ ដោយអត្ថថា លះបង់ ការត្រាស់ដឹង គឺខយញ្ញាណ ដោយអត្ថថា កាត់ដាច់ស្រឡះ ការត្រាស់ដឹង គឺឆន្ទៈ ដោយអត្ថថា ជាឫស ការត្រាស់ដឹង គឺមនសិការៈ ដោយអត្ថថា តាំងឡើងព្រម ការត្រាស់ដឹង គឺផស្សៈ ដោយអត្ថថា ប្រមូល ការត្រាស់ដឹង គឺវេទនា ដោយអត្ថថា ជាទីប្រជុំចុះ ការត្រាស់ដឹង គឺសមាធិ ដោយអត្ថថា ជាប្រធាន ការត្រាស់ដឹង គឺសតិ ដោយអត្ថថា ជាអធិបតី ការត្រាស់ដឹង គឺបញ្ញា ដោយអត្ថថា ប្រសើរជាងធម៌ទាំងនោះ ការត្រាស់ដឹង គឺវិមុត្តិ ដោយអត្ថថា ជាខ្លឹម ការត្រាស់ដឹង គឺអមតនិព្វាន ដោយអត្ថថា ជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) ។

[ ១៦៩ ] ការត្រាស់ដឹង មានត្រឹមតែប៉ុណ្ណោះទេឬ ។ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ ក្នុងខណៈនៃសោតាបត្តិមគ្គ មានការត្រាស់ដឹងដោយកិរិយាយល់ គឺសម្មាទិដ្ឋិ ។បេ។ មានការត្រាស់ដឹង គឺអមតនិព្វាន ដោយអត្ថថា ជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) ។

ការត្រាស់ដឹង មានត្រឹមតែប៉ុណ្ណោះទេឬ ។ មិនមែនមានត្រឹមតែប៉ុណ្ណោះ

ទេ ក្នុងខណៈនៃសោតាបត្តិផល មានការត្រាស់ដឹងដោយកិរិយាយល់ គឺសម្មាទិដ្ឋិ ។បេ។ ការត្រាស់ដឹង គឺអនុប្បាទញ្ញាណ ដោយអត្ថថា រម្ងាប់ ការត្រាស់ដឹង គឺធម្មៈ ដោយអត្ថថា ជាឫស ។បេ។ ការត្រាស់ដឹង គឺអមតនិព្វាន ដោយអត្ថថា ជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) ។

ការត្រាស់ដឹង មានតែប៉ុណ្ណេះទេឬ ។ មិនមែនមានតែប៉ុណ្ណេះទេ ក្នុងខណៈនៃសកទាគាមិមគ្គ ។បេ។ ក្នុងខណៈនៃសកទាគាមិផល ក្នុងខណៈនៃអនាគាមិមគ្គ ក្នុងខណៈនៃអនាគាមិផល ក្នុងខណៈនៃអរហត្តមគ្គ ក្នុងខណៈនៃអរហត្តផល មានការត្រាស់ដឹងដោយការយល់ គឺសម្មាទិដ្ឋិ ការត្រាស់ដឹងដោយការលើកចិត្តកាន់អារម្មណ៍ គឺសម្មាសង្កប្បៈ ។បេ។ ការត្រាស់ដឹង គឺអនុប្បាទញ្ញាណ ដោយអត្ថថា ស្ងប់ ការត្រាស់ដឹង គឺធម្មៈ ដោយអត្ថថា ជាឫស ។បេ។ ការត្រាស់ដឹង គឺអមតនិព្វាន ដោយអត្ថថា ជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) ។ ភិក្ខុនោះតែងលះកិលេស ដែលកន្លងហើយ លះកិលេសដែលមិនទាន់មានមក លះកិលេសដែលកើតចំពោះមុខ ។

[ ១៧០ ] ពាក្យថា លះកិលេសដែលកន្លងហើយ សំណួរថា បើលះកិលេសដែលកន្លងហើយ មានតែញ៉ាំងកិលេសដែលអស់ហើយ ឲ្យអស់

ញុំាងកិលេសដែលរលត់ហើយ ឲ្យរលត់ ញុំាងកិលេសដែលសាបសូន្យហើយឲ្យសាបសូន្យ ញុំាងកិលេសដែលវិនាសហើយ ឲ្យវិនាស គឺថាកិលេសជាតណាកន្លងហើយមិនមានទេ លះកិលេសជាតនោះឬ ។ ចម្លើយថា មិនមែនលះកិលេសដែលកន្លងហើយទេ ។

ពាក្យថា លះកិលេសដែលមិនទាន់មក សំណួរថា បើលះកិលេសដែលមិនទាន់មក មានតែលះកិលេសដែលមិនទាន់កើត លះកិលេសដែលមិនទាន់ដុះ លះកិលេសដែលមិនទាន់ផុសឡើង លះកិលេសដែលមិនទាន់កើតប្រាកដ គឺថាកិលេសជាតណាដែលមិនទាន់មកមិនមានទេ លះកិលេសជាតនោះឬ ។ ចម្លើយថា មិនមែនលះកិលេសដែលមិនទាន់មកទេ ។

ពាក្យថា លះកិលេសដែលកើតចំពោះមុខ សំណួរថា បើលះកិលេសដែលកើតចំពោះមុខ មានតែកិក្ខុអ្នកត្រេកអរ លះរាគៈ អ្នកប្រទូស្ត លះទោសៈ អ្នកវង្វេង លះមោហៈ អ្នកប្រកួតប្រកាន់ លះមានះ អ្នកស្ទាបអង្អែល លះទិដ្ឋិ អ្នកមានចិត្តរាយមាយ លះឧទ្ធច្ចៈ អ្នកដល់នូវការមិនដាច់ស្រេច លះវិចិកិច្ឆា អ្នកមានព្យាយាម លះអនុស័យ គឺថាធម៌ខ្មៅនិងធម៌ស តែងជាប់គ្នាជាគូប្រព្រឹត្តទៅ មគ្គភាវនាប្រកបដោយសេចក្តីសៅហ្មងដោយធម៌ទាំងពីរនោះឬ ។ ចម្លើយថា មិនមែនលះកិលេសដែលកន្លង

ហើយ មិនមែនលះកិលេសដែលមិនទាន់មក មិនមែនលះកិលេសដែលកើតចំពោះមុខទេ ។

[ ១៧១ ] បើមិនមែនលះកិលេសដែលកន្លងហើយ មិនមែនលះកិលេសដែលមិនទាន់មក មិនមែនលះកិលេសដែលកើត ចំពោះមុខទេ បើដូច្នោះមានតែមគ្គភាវនាមិនមាន ការធ្វើឲ្យជាក់ច្បាស់នូវផលមិនមាន ការលះកិលេសមិនមាន ការត្រាស់ដឹងធម៌ មិនមានឬ ។ មិនមែនដូច្នោះទេ មគ្គភាវនាមាន ការធ្វើឲ្យជាក់ច្បាស់នូវផលមាន ការលះកិលេសមាន ការត្រាស់ដឹងនូវធម៌មាន ឧបមាដូចជាអ្វី ដូចជាដើមឈើចំទង់មិនទាន់មានផ្លែ បុរសកាត់ផ្តាច់ឈើនុ៎ះត្រង់គល់ ឯអជាតផលណា របស់ឈើនោះដែលមិនទាន់ចេញក៏លែងចេញ ដែលមិនទាន់កើតក៏លែងកើត ដែលមិនទាន់ពកក៏លែងពក ដែលមិនទាន់កើតប្រាកដក៏លែងកើតប្រាកដ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចការកើត ជាហេតុ ការកើត ជាបច្ច័យនៃការកើតកិលេស ចិត្តតែងស្ទុះទៅក្នុងការមិនកើត ព្រោះឃើញទោស ក្នុងការកើត ព្រោះតែចិត្តស្ទុះទៅក្នុងការមិនកើត បានជាកិលេសទាំងឡាយណាដែលមានការកើតឡើងជាបច្ច័យគប្បីកើតឡើង កិលេសទាំងនោះ ដែលមិនទាន់កើតក៏លែងកើត ដែលមិនទាន់ដុះក៏លែងដុះ ដែលមិនទាន់ផុស ក៏លែងផុស

ដែលមិនទាន់កើតប្រាកដក៏លែងកើតប្រាកដ ។ ការរលត់ទុក្ខ ព្រោះការរលត់នៃហេតុយ៉ាងនេះឯង ហេតុគឺការប្រព្រឹត្តិទៅ ហេតុ គឺនិមិត្ត ហេតុ គឺការប្រមូលមក ឯការប្រមូលមកជាបច្ច័យនៃការកើតនូវកិលេស ចិត្តតែងស្ទុះទៅក្នុងការមិនប្រមូល ព្រោះឃើញទោសក្នុងការប្រមូល ព្រោះតែចិត្តស្ទុះទៅក្នុងការមិនប្រមូល បានជាកិលេសទាំងឡាយណា ដែលមានការប្រមូលជាបច្ច័យគប្បីកើតឡើង កិលេសទាំងនោះ ដែលមិនទាន់កើត ក៏លែងកើត ដែលមិនទាន់ដុះក៏លែងដុះ ដែលមិនទាន់ផុសឡើងក៏លែងផុសឡើង ដែលមិនទាន់កើតប្រាកដក៏លែងកើតប្រាកដ ។ ការរលត់ទុក្ខ ព្រោះរលត់ហេតុយ៉ាងនេះ ។ មគ្គភាវនាមាន ការធ្វើឲ្យជាក់ច្បាស់នូវផលមាន ការលះកិលេសមាន ការត្រាស់ដឹងធម៌មានយ៉ាងនេះឯង ។

**ចប់ អភិសមយកថា ។**

## អដ្ឋកថា

## អភិសមយកថា

[ ១៦៦ ] ឥឡូវនេះជាពណ៌នាសេចក្ដីតាមលំដាប់ ដែលមិនធ្លាប់ពោលក្នុងអភិសមយកថា ដែលព្រះសារីបុត្តត្ថេរ កាលសម្ដែងអភិសម័យដែលជាឫទ្ធិយ៉ាងក្រៃលែង ពោលទុកហើយបន្ទាប់អំពីឥទ្ធិកថា ។

ក្នុងបទទាំងនោះ បទថា **អភិសមយោ** បានដល់ ដល់ព្រមដោយធម៌ជាប្រធាននៃសច្ចៈទាំងឡាយ អធិប្បាយថា ចាក់ធ្លុះ អាចារ្យពួកខ្លះពោលថា ការត្រាស់ដឹងអត្ថ ។ បទថា **កេន អភិសមេតិ** មានអធិប្បាយទុកដូចម្ដេច សភាពណាដែលលោកពោលថា ការត្រាស់ដឹង ក្នុងបទនៃព្រះសូត្រ ( សំយុត្តនិកាយនិទានវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ការត្រាស់ដឹងធម៌ មានប្រយោជន៍ច្រើនយ៉ាងនេះ ដូច្នេះជាដើម កាលការត្រាស់ដឹងនោះប្រព្រឹត្តទៅ បុគ្គលអ្នកត្រាស់ដឹងរមែងត្រាស់ដឹងសច្ចៈ គឺបែរមុខចំពោះបានដល់ ប្រជុំព្រម អធិប្បាយថា ចាក់ធ្លុះដោយធម៌អ្វី នេះជាពាក្យសួររបស់អ្នកចោទ ។

បទថា **ចិត្តេន អភិសមេតិ** បានដល់ ឆ្លើយយ៉ាងនោះ ព្រោះវៀរចិត្តចេញហើយ មិនមានការត្រាស់ដឹង ។ បទថា **ហាញ្ចិ** ជាដើម ជាការសួរទៀត ។ **ហាញ្ចិ** មានអត្ថថា បើ ។ ព្រោះលោកពោលថា ដោយចិត្តទើបអ្នកចោទសួរពោលថា ដូច្នោះ បុគ្គលមិនមានញាណក៏ត្រាស់ដឹង ។ បទថា **ន អញ្ញាណី អភិសមេតិ** ជាការបដិសេធព្រោះមិនមានការត្រាស់

ដឹងដោយត្រឹមតែចិត្តប៉ុណ្ណោះ ។ បទថា **ញាណេន អភិសមេតិ** ជាការទទួល ។ បទថា **ហាញ្ចិ** មួយបទទៀតជាដើម ជាការសួរថា បុគ្គលមិនមានញាណ មិនមានចិត្តរមែងត្រាស់ដឹងបាន ព្រោះលោកពោលថា ដោយញាណ ។ បទថា **ន អចិត្តកោ អភិសមេតិ** ជាការបដិសេធ ព្រោះបុគ្គលមិនមានចិត្តត្រាស់ដឹងមិនបាន ។ បទថា **ចិត្តេន ច** ជាដើម ជាការទទួល ។ បទថា **ហាញ្ចិ** មួយបទទៀតជាដើម ជាការសួរដោយអំណាចទូទៅនៃចិត្តនិងញាណទាំងអស់ ។ សូម្បីក្នុងការសួរនិងការឆ្លើយដ៏សេស ក៏មានន័យនេះដូចគ្នា ។

ម្យ៉ាងទៀត ខាងមុខតទៅ បទថា **កម្មស្សកតាចិត្តេន ច ញាណេន ច** បានដល់ ដោយចិត្តដែលប្រព្រឹត្តទៅហើយ ដោយកម្មស្សកតាយ៉ាងនេះថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន និងដោយញាណ ។

បទថា **សច្ចានុលោមិកចិត្តេន ច ញាណេន ច** បានដល់ ដោយចិត្តសម្បយុត្តដោយវិបស្សនា ពោលគឺសច្ចានុលោមិកញ្ញាណព្រោះឧបការដល់ការចាក់ធ្លុះសច្ចៈនិងដោយវិបស្សនាញាណ ។

[ ១៦៧ ] បទថា **កថំ** ជាកថេតុកម្យតាបុច្ឆា ( សួរឯងឆ្លើយឯង ) ដូចអភិសម័យ ។ បទថា **ឧប្បាទាធិបតេយ្យំ** បានដល់ ព្រោះកាលចិត្តមិនកើត ចេតសិកក៏មិនកើត ព្រោះថា ចិត្តជាធម្មជាតកាន់យកអារម្មណ៍ ចេតសិកដែលកើតព្រមជាមួយចិត្តនោះ កាលមិនកាន់យកអារម្មណ៍នឹងកើតឡើងបានដូចម្ដេច សូម្បីក្នុងអភិធម្មលោកក៏ចែកចេតសិកទុកដោយការកើត

ឡើងនៃចិត្តនោះឯង ហេតុនោះ ទើបចិត្តជាធំក្នុងការកើតឡើងនៃមគ្គញ្ញាណ ។ បទថា **ញាណស្ស** បានដល់ នៃមគ្គញ្ញាណ ។ បទថា **ហេតុ បច្ចយោ ច** បានដល់ ជាហេតុឲ្យកើតនិងជាបច្ច័យឧបត្ថម្ភ ។ បទថា **តំសម្បយុត្តំ** បានដល់ ដែលប្រកបដោយញាណនោះ ។ បទថា **និរោធគោចរំ** បានដល់ មាននិព្វានជាអារម្មណ៍ ។ បទថា **ទស្សនាធិបតេយ្យំ** បានដល់ ជាធំក្នុងការឃើញនិព្វាន ព្រោះមិនមានកិច្ចដែលនឹងឃើញវត្ថុដ៏សេស ។ បទថា **ចិត្តស្ស** បានដល់ នៃចិត្តដែលសម្បយុត្តដោយមគ្គ ។ បទថា **តំ-សម្បយុត្តំ** បានដល់ ដែលប្រកបដោយចិត្តនោះ ។

[ ១៦៨ ] ព្រោះបរិយាយនេះ មិនមែនការត្រាស់ដឹងដោយចិត្តនិងដោយញាណប៉ុណ្ណោះ ដែលពិតធម៌ គឺចិត្ត និងចេតសិកដែលសម្បយុត្តដោយមគ្គទាំងអស់ក៏ឈ្មោះថា ជាការត្រាស់ដឹងដោយអំណាចញុំាងកិច្ច គឺការត្រាស់ដឹងសច្ចៈ ឲ្យសម្រេច ហេតុនោះ ព្រះសារីបុត្តត្ថេរបំណងសម្តែងបរិយាយនោះ ទើបសួរថា ការត្រាស់ដឹងមានត្រឹមតែប៉ុណ្ណោះទេឬ ហើយបដិសេធពាក្យនោះថា មិនមែនមានតែប៉ុណ្ណោះទេ ហើយពោលពាក្យជាដើមថា ក្នុងខណៈនៃលោកុត្តរមគ្គ ។ បទថា **ទស្សនាភិសមយោ** បានដល់ ការត្រាស់ដឹងដែលជាការឃើញ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះ ។ បទថា **សច្ចា** បានដល់ សច្ចញ្ញាណ ។ មគ្គញ្ញាណនោះឯង ឈ្មោះថា វិបស្សនា ដោយអត្ថថា ពិចារណាឃើញព្រះនិព្វាន ។ បទថា **វិមោក្ខោ** បានដល់ មគ្គវិមោក្ខ ។ បទថា **វិជ្ជា** បានដល់ មគ្គញ្ញាណនោះឯង ។

បទថា **វិមុត្តិ** បានដល់ សមុច្ឆេទវិមុត្តិ ។ និព្វាន ឈ្មោះថា **អភិសម-យោ** ព្រោះអត្ថថា ត្រាស់ដឹង ។ ធម៌ដ៏សេស ឈ្មោះថា **អភិសមយោ** ព្រោះជាហេតុឲ្យត្រាស់ដឹង ។

[ ១៦៩ ] ព្រះសារីបុត្តត្ថេរដើម្បីសម្តែងចែកអភិសម័យដោយអំណាចនៃមគ្គនិងផលទៀត ទើបពោលថា **កិន្តុ** ជាដើមដូច្នេះ ម្យ៉ាងទៀត ក្នុងសេចក្តីនេះ ក្នុងខណៈនៃផល ព្រោះញាណក្នុងការអស់ទៅដោយកាត់ផ្តាច់រមែងមិនមាន ហេតុនោះ ទើបពោលថា ការត្រាស់ដឹង គឺអនុប្បាទញ្ញាណដោយអត្ថថា រម្ងាប់ ។ គប្បីជ្រាបបទដ៏សេសតាមសមគួរ ។

ឥឡូវនេះ ព្រោះកាលមានការលះកិលេស ការត្រាស់ដឹង ក៏រមែងមាននិងកាលមានការត្រាស់ដឹង ការលះកិលេសក៏រមែងមាន ហេតុនោះ ព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងដល់ការលះកិលេសដែលមានការចោទសួរជាខាងដើម ទើបពោលពាក្យថា **ស្វាយំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ស្វាយំ** បានដល់ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងមគ្គនេះ ។ បទ ៤ មានបទថា **ឃរំ** ជាដើម ជាការសួររបស់អ្នកចោទសួរ ។

[ ១៧០ ] បទនេះថា **អតីតេ កិលេសេ បជហាតិ** ជាពាក្យឆ្លើយដើម្បីឲ្យឱកាសដល់អ្នកសួរ ។

បទថា **ខីណំ** បានដល់ ដែលអស់ទៅហើយដោយការរលត់ ។ បទថា **និរុទ្ធំ** បានដល់ ដែលរលត់ដោយការមិនកើតឡើងរឿយ ៗ ក្នុងសន្តាន ។

បទថា **វិគតំ** បានដល់ ប្រាសទៅចាកខណៈដែលកំពុងប្រព្រឹត្តទៅ ។ បទថា **វិគមេតិ** បានដល់ រមែងធ្វើឲ្យប្រាសទៅ ។ បទថា **អត្ថង្គតំ** បានដល់ ដែលដល់នូវការមិនមាន ។ បទថា **អត្ថង្គមេតិ** បានដល់ ឲ្យដល់នូវការមិនមាន ។ កាលសម្តែងទោសក្នុងសេចក្តីនោះហើយ ទើបព្រះថេរៈពោលបដិសេធថា មិនលះកិលេសដែលកន្លងហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យសួរអំពីកិលេសដែលជាអនាគតដូចតទៅនេះថា បទថា **អជាតំ** បានដល់ ដែលមិនដល់នូវការកើត ។ បទថា **អនិព្វត្តំ** បានដល់ ដែលមិនទាន់ដល់សភាវៈ ។ បទថា **អនុប្បន្នំ** បានដល់ ដែលមិនខ្ពស់ឡើងចាប់តាំងអំពីកើត ។ បទថា **អបាតុភូតំ** បានដល់ ដែលមិនប្រាកដដល់ចិត្ត ដោយភាពជាបច្ចុប្បន្ន ។ កាលលះកិលេសដែលជាអតីតនិងអនាគត សេចក្តីព្យាយាមរមែងឥតផល ព្រោះមិនមានវត្ថុដែលគួរលះ ព្រោះហេតុនោះ ទើបលោកបដិសេធទាំងពីរយ៉ាង ។

បទថា **រត្តោ រាគំ បជហតិ** បានដល់ បុគ្គលដែលត្រេកត្រអាលដោយរាគៈ ដែលកំពុងប្រព្រឹត្តទៅ រមែងលះរាគៈនោះឯង ។ សូម្បីក្នុងកិលេសដែលកំពុងប្រព្រឹត្តទៅ ក៏មានន័យនេះដូចគ្នា ។ បទថា **ថាមគតោ** បានដល់ ដែលដល់សភាពតាំងមាំ ។ បទថា **កណ្ហសុក្កា** បានដល់ មានអធិប្បាយថា ធម៌ដែលជាអកុសលនិងកុសលដែលជាគូគ្នារមែងប្រព្រឹត្តទៅស្មើគ្នា ព្រោះហេតុនោះ ទើបសេចក្តីព្យាយាមឥតផល ។ បទថា **សំកិលេសិកា** សេចក្តីថា កាលសេចក្តីសៅហ្មងដែលសម្បយុត្តមានយ៉ាង

នេះ មគ្គភាវនាដែលប្រកបក្នុងសេចក្ដីសៅហ្មងក៏មាន ព្រោះហេតុនោះ ទើប សេចក្ដីព្យាយាមឥតផល ។ កាលលះកិលេស ដែលជាបច្ចុប្បន្នយ៉ាងនេះ មគ្គភាវនាដែលមានសភាពសៅហ្មងរមែងមាន និងសេចក្ដីព្យាយាម ក៏ឥតផល ព្រោះមានវត្ថុដែលគួរលះព្រមជាមួយសេចក្ដីព្យាយាម ព្រោះថា ឈ្មោះថា កិលេសដែលជាបច្ចុប្បន្នដែលវិប្បយុត្តចាកចិត្តរមែងមាន ។

[ ១៧១ ] បទថា **ន ហិ** ជាការបដិសេធពាក្យដែលលោកពោលទុកហើយ ៤ ចំណែក ។ បទថា **អត្ថិ** ជាការទទួល ។ បទថា **យថា កថំ វិយ** ជាការសួរដើម្បីចង្អុលឲ្យឃើញឧទាហរណ៍នៃការមាន ។ មានដោយប្រការណា គឺវត្ថុនោះមានដោយប្រការដូចម្ដេច អធិប្បាយថា មានដូចអ្វី ។ បទថា **យថាបិ** បានដល់ យ៉ាងណា ។ បទថា **តរុណរុក្ខោ** ជាការប្រារព្ធដើមឈើចំទង់ដើម្បីសម្ដែងភាវៈដែលឲ្យផ្លែ ។ បទថា **អជាតផលោ** ជាការប្រារព្ធវេលាមុនអំពីការចេញផ្លែ កាលភាពដែលដើមឈើចេញផ្លែមាន ។ បទថា **តមេនំ** បានដល់ ដើមឈើនោះ ។ បទថា **ឯនំ** ត្រឹមតែជានិបាត ឬមានអត្ថថា **តំ ឯតំ** ។ បទថា **មូលំ ឆិន្ទេយ្យ** បានដល់ គប្បីកាត់តាំងអំពីឫស ។ បទថា **អជាតផលា** បានដល់ ផ្លែដែលមិនទាន់កើត ។ បទថា **ឯវមេវំ** កាត់បទជា **ឯវំ ឯវំ** ។ លោកពោលដល់ការបន្តនៃខន្ធដែលជាបច្ចុប្បន្នដោយហេតុ ៤ ប្រការ គឺការកើតឡើង ១ ការប្រព្រឹត្តទៅ ១ និមិត្ត ១ កម្ម ១ ។ មគ្គញាណណាមួយកើតឡើងក្នុងសន្តានណា ខន្ធសន្តាននោះ រមែងមិនជាពូជដល់កិលេសទាំងឡាយដែល

គប្បីលះបានដោយមគ្គញាណនោះៗ ព្រោះខន្ធសន្តាននោះ មិនមែនជាពូជកិលេសនោះៗដែលមានខន្ធសន្តាននោះជាបច្ច័យ ដែលមិនទាន់កើតឡើងនោះឯងរមែងកើតឡើងមិនបាន ។ បទថា **អាទីនវំ ទិស្វា** បានដល់ ឃើញទោសដោយភាពជារបស់មិនទៀងជាដើម ។ លោកពោលដល់និព្វាននោះឯងដោយបទ ៤ ថា **អនុប្បាទោ** ជាដើម ។ បទថា **ចិត្តំ បក្ខន្ទតិ** បានដល់ ចិត្តសម្បយុត្តដោយមគ្គ រមែងស្ទុះទៅ ។ បទថា **ហេតុនិរោធា ទុក្ខនិរោធោ** បានដល់ ព្រោះការរលត់ គឺការមិនកើតឡើងនៃសន្តានដែលជាពូជនៃកិលេសទាំងឡាយទើបជាការរលត់ គឺការមិនកើតឡើងនៃកិលេសទាំងឡាយដែលជាហេតុនៃទុក្ខដែលជាខន្ធ ក្នុងអនាគត ។ ព្រោះការរលត់ គឺការមិនកើតឡើងនៃកិលេសដែលជាហេតុនៃទុក្ខយ៉ាងនេះ ទើបជាការរលត់ គឺការមិនកើតឡើងនៃទុក្ខ ។ ព្រះសារីបុត្តត្ថេរពោលពាក្យថា **អត្ថិ មគ្គភាវនា** ជាដើម ព្រោះមានគោលត្រឹមត្រូវក្នុងការលះកិលេសដោយប្រការដូច្នេះ ។

គប្បីជ្រាបការពោលដោយពិស្ដារនៃការលះកិលេស ដែលលោកពោលអធិប្បាយទុកក្នុងអដ្ឋកថាថា ដោយពាក្យនេះថា កិលេសដែលមិនទាន់កើតរមែងមិនកើត លោកសម្ដែងដល់អ្វី លោកសម្ដែងដល់ការលះកិលេសទាំងឡាយដែលជាភូមិលទ្ធ ។ កិលេសទាំងឡាយដែលជាភូមិលទ្ធនោះជាអតីត អនាគត ឬបច្ចុប្បន្ន កិលេសទាំងនោះ ឈ្មោះថា ភូមិលទ្ធុប្បន្ននោះឯង ( កើតឡើងដោយបានភូមិមិនមែនអតីត អនាគត ឬបច្ចុប្បន្ន ) ដោយន័យ

ដូចពោលហើយ ក្នុងអដ្ឋកថាមគ្គសច្ចនិទ្ទេសនៃសុតមយញ្ញាណកថា ។ តែក្នុងទីនេះលោកបំណងយកកិលេសដែលគួរលះ ដោយមគ្គញ្ញាណប៉ុណ្ណោះឯង ។

## អដ្ឋកថា អភិសមយកថា ចប់

# សុត្តន្តបិដក

## បញ្ញាវគ្គ វិវេកកថា

## សាវត្ថីនិទាន

[ ១៧២ ] ម្នាលភិក្ខុទាំងឡាយ ការងារទាំងឡាយណាមួយដែលត្រូវធ្វើដោយកម្លាំង ការងារទាំងអស់នោះ បុគ្គលលុះតែអាស្រ័យផែនដី ឈរលើផែនដីទើបធ្វើបាន ការងារទាំងឡាយ ដែលត្រូវធ្វើដោយកម្លាំងទាំងនុ៎ះ បុគ្គលតែងធ្វើយ៉ាងនេះ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចភិក្ខុលុះតែអាស្រ័យនូវសីល តាំងនៅក្នុងសីល ហើយទើបចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ទើបធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ។

[ ១៧៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុលុះតែអាស្រ័យនូវសីល តាំងនៅក្នុងសីលហើយ ទើបចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន ទើបធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសម្មាទិដ្ឋិដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ចម្រើនសម្មាសង្កប្បៈ ចម្រើនសម្មាវាចា ចម្រើនសម្មាកម្មន្តៈ ចម្រើនសម្មាអាជីវៈ ចម្រើនសម្មាវាយាមៈ ចម្រើនសម្មាសតិ ចម្រើនសម្មាសមាធិដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុលុះតែអាស្រ័យសីល តាំងនៅក្នុងសីលហើយ ទើបចម្រើន

នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបានទើបធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរបានយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ពីជគាមនិងភូតគាមទាំងឡាយណាមួយ ពីជគាមនិងភូតគាមទាំងអស់នោះ តែងអាស្រ័យផែនដី តាំងស៊ប់លើផែនដីហើយទើបដល់នូវការចម្រើនលូតលាស់ ធំទូលាយបាន ពីជគាមនិងភូតគាមទាំងនុ៎ះតែងដល់នូវការចម្រើនលូតលាស់ ធំទូលាយដោយហេតុយ៉ាងនេះ មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចភិក្ខុ កាលអាស្រ័យសីល តាំងនៅក្នុងសីល ហើយចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ហើយធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ទើបដល់នូវការចម្រើនលូតលាស់ ធំទូលាយក្នុងធម៌ទាំងឡាយបាន ។

[ ១៧៤ ] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលអាស្រ័យសីល តាំងនៅក្នុងសីល ហើយចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ហើយធ្វើឲ្យច្រើននូវមគ្គ ប្រកបដោយអង្គ ៨ ដ៏ប្រសើរ ទើបដល់នូវការចម្រើនលូតលាស់ធំទូលាយ ក្នុងធម៌ទាំងឡាយបាន តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះចម្រើនសម្មាទិដ្ឋិដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធបង្អោនទៅដើម្បីលះ ចម្រើនសម្មាសង្កប្បៈ ចម្រើនសម្មាវាចា ម្រើនសម្មាកម្មន្តៈ ចម្រើនសម្មាអាជីវៈ ចម្រើនសម្មាវាយាមៈ ចម្រើនសម្មាសតិ ចម្រើនសម្មាសមាធិ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ។ សម្មាទិដ្ឋិមានវិវេក ៥ មាន

វិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ សម្មា-សង្កប្បៈ ។បេ។ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិមានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។

[ ១៧៥ ] សម្មាទិដ្ឋិមានវិវេក ៥ តើដូចម្តេច ។ វិក្ខម្ភនវិវេក ១ តទង្គវិវេក ១ សមុច្ឆេទវិវេក ១ បដិប្បស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។ ឯវិក្ខម្ភនវិវេក សម្រាប់បុគ្គល ( កាលលះបង់ ) នូវនីវរណៈទាំងឡាយហើយចម្រើនបឋមជ្ឈាន តទង្គវិវេកសម្រាប់បុគ្គល ( កាលលះបង់ ) នូវទិដ្ឋិទាំងឡាយ ហើយចម្រើនសមាធិដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវិវេក សម្រាប់បុគ្គលកាលចម្រើនមគ្គជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវិវេកមានក្នុងខណៈនៃផល និស្សរណវិវេកគឺជានិរោធ និព្វាន ។ នេះសម្មាទិដ្ឋិមានវិវេក ៥ ។ បុគ្គលណាមានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ហើយក្នុងវិវេកទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា អធិដ្ឋានល្អហើយ ។

[ ១៧៦ ] សម្មាទិដ្ឋិមានវិរាគៈ ៥ តើដូចម្តេច ។ វិក្ខម្ភនវិរាគៈ ១ តទង្គវិរាគៈ ១ សមុច្ឆេទវិរាគៈ ១ បដិប្បស្សទ្ធិវិរាគៈ ១ និស្សរណវិរាគៈ ១ ។ វិក្ខម្ភនវិរាគៈសម្រាប់បុគ្គល ( កាលលះបង់ ) នូវនីវរណៈហើយចម្រើននូវបឋមជ្ឈាន តទង្គវិរាគៈសម្រាប់បុគ្គល ( កាលលះបង់ ) នូវទិដ្ឋិហើយចម្រើនសមាធិ ដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវិរាគៈ

សម្រាប់បុគ្គលកាលចម្រើនមគ្គ ជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវិវេកៈមានក្នុងខណៈនៃផល និស្សរណវិវេកៈគឺជានិរោធ និព្វាន នេះសម្មាទិដ្ឋិមានវិវេកៈ ៥ ។ បុគ្គលណាមានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ក្នុងវិវេកៈទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា អធិដ្ឋានល្អហើយ ។

[ ១៧៧ ] សម្មាទិដ្ឋិមាននិរោធ ៥ តើដូចម្តេច ។ វិក្ខម្ភននិរោធ ១ តទង្គនិរោធ ១ សមុច្ឆេទនិរោធ ១ បដិប្បស្សទ្ធិនិរោធ ១ និស្សរណនិរោធ ១ ។ ឯវិក្ខម្ភននិរោធ សម្រាប់បុគ្គល ( កាលលះបង់ ) នូវនីវរណៈ ហើយចម្រើនបឋមជ្ឈាន តទង្គនិរោធសម្រាប់បុគ្គល ( កាលលះបង់ ) នូវទិដ្ឋិ ហើយចម្រើននូវសមាធិដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទនិរោធសម្រាប់បុគ្គលកាលចម្រើនមគ្គ ជាលោកុត្តរៈដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិនិរោធមានក្នុងខណៈនៃផល និស្សរណនិរោធ គឺជាអមតធាតុ នេះសម្មាទិដ្ឋិមាននិរោធ ៥ ។ បុគ្គលណាមានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ក្នុងនិរោធទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា អធិដ្ឋានល្អហើយ ។

[ ១៧៨ ] សម្មាទិដ្ឋិមានវោស្សគ្គៈ ៥ តើដូចម្តេច ។ វិក្ខម្ភនវោស្សគ្គៈ ១ តទង្គវោស្សគ្គៈ ១ សមុច្ឆេទវោស្សគ្គៈ ១ បដិប្បស្សទ្ធិវោស្សគ្គៈ ១ និស្សរណវោស្សគ្គៈ ១ ។ ឯវិក្ខម្ភនវោស្សគ្គៈ សម្រាប់បុគ្គល ( កាលលះបង់ ) នូវនីវរណៈទាំងឡាយហើយចម្រើនបឋមជ្ឈាន តទង្គវោស្សគ្គៈ

សម្រាប់បុគ្គល ( កាលលះបង់ ) នូវទិដ្ឋិទាំងឡាយ ហើយចម្រើនសមាធិដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវោស្សគ្គៈ សម្រាប់បុគ្គលកាលចម្រើនមគ្គ ជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវោស្សគ្គៈ មានក្នុងខណៈនៃផល និរោធវោស្សគ្គៈ គឺជានិរោធ និព្វាន នេះសម្មាទិដ្ឋិមានវោស្សគ្គៈ ៥ ។ បុគ្គលណាមានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ក្នុងវោស្សគ្គៈទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថាអធិដ្ឋានល្អហើយ ។

នេះសម្មាទិដ្ឋិមានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។

[ ១៧៩ ] សម្មាសង្កប្បៈ ។បេ។ សម្មាវាចា ។បេ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ។បេ។ សម្មាវាយាម ។បេ។ សម្មាសតិ ។បេ។

សម្មាសមាធិមានវិវេក ៥ តើដូចម្តេច ។ វិក្ខម្ភនវិវេក ១ តទង្គវិវេក ១ សមុច្ឆេទវិវេក ១ បដិប្បស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។ ឯវិក្ខម្ភនវិវេកសម្រាប់បុគ្គល ( កាលលះបង់ ) នូវនីវរណៈទាំងឡាយហើយចម្រើននូវបឋមជ្ឈាន តទង្គវិវេកសម្រាប់បុគ្គល ( កាលលះបង់ ) នូវទិដ្ឋិទាំងឡាយហើយចម្រើនសមាធិដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវិវេក សម្រាប់បុគ្គលកាលចម្រើនមគ្គ ជាលោកុត្តរៈដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវិវេកមានក្នុងខណៈនៃផល និរោធវិវេក គឺជានិរោធនិព្វាន នេះសម្មាសមាធិមានវិវេក ៥ ។ បុគ្គលណាមានឆន្ទៈកើតហើយជា

អ្នកមានសទ្ធាចុះស៊ប់ក្នុងវិវេកទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា អធិដ្ឋានល្អហើយ ។

[ ១៨០ ] សម្មាសមាធិមានវិរាគៈ ៥ តើដូចម្ដេច ។ វិក្ខម្ភនវិរាគៈ ១ តទង្គវិរាគៈ ១ សមុច្ឆេទវិរាគៈ ១ បដិប្បស្សទ្ធិវិរាគៈ ១ និស្សរណវិរាគៈ ១ ។ វិក្ខម្ភនវិរាគៈ សម្រាប់បុគ្គល ( កាលលះបង់ ) នូវនីវរណៈទាំងឡាយហើយចម្រើនបឋមជ្ឈាន តទង្គវិរាគៈ សម្រាប់បុគ្គល ( កាលលះបង់ ) នូវទិដ្ឋិទាំងឡាយហើយចម្រើនសមាធិដែលជាចំណែកនៃសេចក្ដីទម្លុះទម្លាយ សមុច្ឆេទវិរាគៈ សម្រាប់បុគ្គលកាលចម្រើនមគ្គជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវិរាគៈមានក្នុងខណៈនៃផល និស្សរណវិរាគៈ គឺជានិរោធ និព្វាន នេះសម្មាសមាធិមានវិរាគៈ ៥ ។ បុគ្គលណាមានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ក្នុងវិរាគៈទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា អធិដ្ឋានល្អហើយ ។

[ ១៨១ ] សម្មាសមាធិមាននិរោធ ៥ តើដូចម្ដេច ។ វិក្ខម្ភននិរោធ ១ តទង្គនិរោធ ១ សមុច្ឆេទនិរោធ ១ បដិប្បស្សទ្ធិនិរោធ ១ និស្សរណនិរោធ ១ ។ ឯវិក្ខម្ភននិរោធ សម្រាប់បុគ្គល ( កាលលះបង់ ) នូវនីវរណៈទាំងឡាយហើយចម្រើននូវបឋមជ្ឈាន តទង្គនិរោធ សម្រាប់បុគ្គល ( កាលលះបង់ ) នូវទិដ្ឋិទាំងឡាយ ហើយចម្រើនសមាធិដែលជាចំណែកនៃសេចក្ដីទម្លុះទម្លាយ សមុច្ឆេទនិរោធ សម្រាប់បុគ្គលកាលចម្រើនមគ្គ ជាលោកុត្តរៈ ដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិនិរោធមានក្នុងខណៈនៃផល និស្ស-

រណនិរោធ គឺជានិរោធ និព្វាន នេះសម្មាទិដ្ឋិមាននិរោធ ៥ ។ បុគ្គលណា មានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ក្នុងនិរោធទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា អធិដ្ឋានល្អហើយ ។

[ ១៨២ ] សម្មាសមាធិ មានវោស្សគ្គៈ ៥ តើដូចម្តេច ។ វិក្ខម្ភនវោស្សគ្គៈ ១ តទង្គវោស្សគ្គៈ ១ សមុច្ឆេទវោស្សគ្គៈ ១ បដិប្បស្សទ្ធិវោស្សគ្គៈ ១ និស្សរណវោស្សគ្គៈ ១ ។ ឯវិក្ខម្ភនវោស្សគ្គៈសម្រាប់បុគ្គល ( កាលលះបង់ ) នូវនីវរណៈ ហើយចម្រើនបឋមជ្ឈាន តទង្គវោស្សគ្គៈសម្រាប់បុគ្គល ( កាលលះបង់ ) នូវទិដ្ឋិ ហើយចម្រើនសមាធិ ដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវោស្សគ្គៈសម្រាប់បុគ្គលកាលចម្រើនមគ្គ ជាលោកុត្តរៈដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវោស្សគ្គៈមានក្នុងខណៈនៃផល និរោធវោស្សគ្គៈ គឺជានិរោធ និព្វាន នេះសម្មាសមាធិ មានវោស្សគ្គៈ ៥ ។ បុគ្គលណាមានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ក្នុងវោស្សគ្គៈទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះ ឈ្មោះថា អធិដ្ឋានល្អហើយ ។

នេះសម្មាសមាធិ មានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។

[ ១៨៣ ] ម្នាលភិក្ខុទាំងឡាយ ការងារទាំងឡាយណាមួយដែលត្រូវធ្វើដោយកម្លាំង ការងារទាំងអស់នោះ បុគ្គលលុះតែអាស្រ័យផែនដី ឈរលើផែនដីទើបធ្វើបាន ការងារទាំងឡាយដែលត្រូវធ្វើដោយកម្លាំងនុ៎ះ បុគ្គល

តែងធ្វើយ៉ាងនេះ មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចភិក្ខុលុះតែអាស្រ័យសីល តាំងនៅក្នុងសីលហើយ ទើបចម្រើននូវពោជ្ឈង្គទាំង ៧ ធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ បាន ។បេ។ ភិក្ខុកាលចម្រើននូវពោជ្ឈង្គទាំង ៧ កាលធ្វើឲ្យច្រើននូវពោជ្ឈង្គទាំង ៧ រមែងដល់នូវការចម្រើនលូតលាស់ធំទូលាយក្នុងធម៌ទាំងឡាយ ។បេ។ ភិក្ខុចម្រើននូវពលៈ ៥ ធ្វើឲ្យច្រើននូវពលៈ ៥ ។បេ។ ភិក្ខុ កាលចម្រើននូវពលៈ ៥ កាលធ្វើឲ្យច្រើននូវពលៈ ៥ រមែងដល់នូវការចម្រើនលូតលាស់ធំទូលាយក្នុងធម៌ទាំងឡាយ ។បេ។ ភិក្ខុចម្រើននូវឥន្ទ្រិយ ៥ ធ្វើឲ្យច្រើននូវឥន្ទ្រិយ ៥ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពីជគាមនិងភូតគាមឯណាមួយ ពីជគាមនិងភូតគាមទាំងអស់នោះ តែងអាស្រ័យនូវផែនដី តាំងនៅលើផែនដីទើបដល់នូវការចម្រើនលូតលាស់ធំទូលាយបាន ពីជគាមនិងភូតគាមនុ៎ះ តែងដល់នូវការចម្រើនលូតលាស់ធំទូលាយដោយហេតុយ៉ាងនេះ មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចភិក្ខុកាលអាស្រ័យសីល តាំងនៅក្នុងសីល ហើយចម្រើននូវឥន្ទ្រិយ ៥ ហើយធ្វើឲ្យច្រើននូវឥន្ទ្រិយ ៥ ទើបដល់នូវការចម្រើនលូតលាស់ ធំទូលាយក្នុងធម៌ទាំងឡាយបាន ។

[ ១៨៤ ] ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលអាស្រ័យសីល តាំងនៅក្នុងសីល ហើយចម្រើននូវឥន្ទ្រិយ ៥ ហើយធ្វើឲ្យច្រើននូវឥន្ទ្រិយ ៥ ទើបដល់នូវការចម្រើនលូតលាស់ ធំទូលាយក្នុងធម៌ទាំងឡាយបាន តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសទ្ធិន្ទ្រិយដែល

អាស្រ័យវិវេក អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ចម្រើនវីរិយិន្ទ្រិយ ។បេ។ ចម្រើនសតិន្ទ្រិយ ចម្រើនសមាធិន្ទ្រិយ ចម្រើនបញ្ញិន្ទ្រិយ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះ ។ សទ្ធិន្ទ្រិយមានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។បេ។ វីរិយិន្ទ្រិយ ។បេ។ សតិន្ទ្រិយ ។បេ។ សមាធិន្ទ្រិយ ។បេ។ បញ្ញិន្ទ្រិយមានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។

[ ១៨៥ ] សទ្ធិន្ទ្រិយមានវិវេក ៥ តើដូចម្តេច ។ វិក្ខម្ភនវិវេក ១ តទង្គវិវេក ១ សមុច្ឆេទវិវេក ១ បដិប្បស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។ ឯវិក្ខម្ភនវិវេក សម្រាប់បុគ្គល ( កាលលះបង់ ) នូវនីវរណៈទាំងឡាយ ហើយចម្រើនបឋមជ្ឈាន តទង្គវិវេកសម្រាប់បុគ្គល ( កាលលះបង់ ) នូវទិដ្ឋិទាំងឡាយ ហើយចម្រើនសមាធិ ដែលជាចំណែកនៃសេចក្តីទម្លុះទម្លាយ សមុច្ឆេទវិវេក សម្រាប់បុគ្គលកាលចម្រើនមគ្គ ជាលោកុត្តរៈដែលដល់នូវការអស់ទៅ បដិប្បស្សទ្ធិវិវេកមានក្នុងខណៈនៃផល និស្សរណវិវេក គឺជានិរោធ និព្វាន នេះសទ្ធិន្ទ្រិយមានវិវេក ៥ ។ បុគ្គលណាមានឆន្ទៈកើតហើយ ជាអ្នកមានសទ្ធាចុះស៊ប់ក្នុងវិវេកទាំង ៥ នេះ ចិត្តរបស់បុគ្គលនោះឈ្មោះថា អធិដ្ឋានល្អហើយ ។ នេះសទ្ធិន្ទ្រិយមានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។ វីរិយិន្ទ្រិយ ។បេ។ សតិន្ទ្រិយ ។បេ។ សមាធិន្ទ្រិយ ។បេ។

បញ្ចិន្ទ្រិយមានវិវេក ៥ តើដូចម្តេច ។ វិក្ខម្ភនវិវេក ១ តទង្គវិវេក ១ សមុច្ឆេទវិវេក ១ បដិប្បស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។បេ។ នេះ បញ្ចិន្ទ្រិយមានវិវេក ៥ មានវិរាគៈ ៥ មាននិរោធ ៥ មានវោស្សគ្គៈ ៥ មាននិស្ស័យ ១២ ។

**ចប់ វិវេកកថា ។**

# អដ្ឋកថា

## វិវេកកថា

[ ១៧២ ] ឥឡូវនេះជាការពណ៌នាសេចក្តីតាមលំដាប់ ដែលមិនធ្លាប់ពោលក្នុងវិវេកកថាដែលមានព្រះសូត្រជាបទនាំ ដែលព្រះសារីបុត្តត្ថេរកាលនឹងសម្តែងអាការនៃការលះ ពោលទុកហើយបន្ទាប់អំពីអភិសមយកថាដែលមានការលះជាទីបំផុត ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងព្រះសូត្រនោះមុន បទថា **យេ កេចិ** ជាពាក្យកំណត់មិនមានសេសសល់ ។ បទថា **ពលករណីយា** បានដល់ ដែលគប្បីធ្វើដោយកម្លាំងជើងនិងកម្លាំងដៃ ។ បទថា **កម្មន្តា** បានដល់ ការងារមានការរត់ ការលោត ការភ្ជួរ និងការសាបព្រោះជាដើម ។ បទថា **ករីយន្តិ** បានដល់ ដែលបុគ្គលមានកម្លាំងទើបធ្វើបាន ។ បទថា **សីលំ និស្សាយ** បានដល់ ធ្វើចតុប្បារិសុទ្ធិសីលឲ្យជាទីអាស្រ័យ ។ បទថា **ភាវេតិ** ក្នុងទីនេះលោកបំណងយកមគ្គភាវនា ជាលោកិយផង ជាលោកុត្តរផង ព្រោះបុគ្គលមានសីលដាច់ហើយភាវនាមិនចម្រើន ។

[ ១៧៣-១៧៤ ] បទថា **វិវេកនិស្សិតំ** បានដល់ ដែលអាស្រ័យតទង្គវិវេក សមុច្ឆេទវិវេក និស្សរណវិវេក ។ ការស្ងាត់ ឈ្មោះថា វិវេក ។ ពិតណាស់ ព្រះយោគាវចរនេះ ប្រកបដោយអរិយមគ្គភាវនាក្នុងខណៈនៃវិបស្សនា រមែងចម្រើនអរិយមគ្គដែលអាស្រ័យតទង្គវិវេកដោយកិច្ច ដែលអាស្រ័យនិស្សរណវិវេកដោយអជ្ឈាស្រ័យ ក្នុងខណៈនៃមគ្គ រមែងចម្រើន

អរិយមគ្គដែលអាស្រ័យសមុច្ឆេទវិវេកដោយកិច្ច ដែលអាស្រ័យនិស្សរណ-វិវេកដោយអារម្មណ៍ ។ ក្នុងអរិយមគ្គដែលអាស្រ័យវិរាគៈជាដើម ក៏ន័យនេះដូចគ្នា ។ ពិតណាស់ វិវេកនោះឯង ឈ្មោះថា វិរាគៈ ដោយអត្ថថាប្រាសចាកតម្រេក ឈ្មោះថា និរោធ ដោយអត្ថថា រំលត់ ឈ្មោះថា វោស្សគ្គ ដោយអត្ថថា លះបង់ ។

ម្យ៉ាងទៀត ឈ្មោះថា វិវេក ព្រោះស្ងាត់ចាកកិលេសទាំងឡាយ ឈ្មោះថា វិរាគៈ ព្រោះប្រាសចាកកិលេសទាំងឡាយ ឈ្មោះថា និរោធ ព្រោះរំលត់កិលេសទាំងឡាយ ឈ្មោះថា វោស្សគ្គ ព្រោះលះបង់ គឺលះបង់កិលេសទាំងឡាយ និងព្រោះបន្ទាត់ចិត្តទៅក្នុងនិព្វាន ។ ម្យ៉ាងទៀត ស្សគ្គមាន ២ យ៉ាង គឺបរិច្ចាគវោស្សគ្គ ( លះបង់ដោយបរិច្ចាគ ) ១ បក្ខន្ទន-វោស្សគ្គ ( លះបង់ដោយការស្ទុះទៅ ) ១ ។

ក្នុងវោស្សគ្គ ២ យ៉ាងនោះ ការលះកិលេសដោយអំណាចទតង្គប្បហានក្នុងខណៈនៃវិបស្សនាដោយសមុច្ឆេទប្បហាន ក្នុងខណៈនៃមគ្គ ឈ្មោះថាបរិច្ចាគវោស្សគ្គ ។ ការស្ទុះទៅកាន់និព្វានដោយការបង្អោនទៅក្នុងនិព្វាននោះក្នុងខណៈនៃវិបស្សនា ដោយការធ្វើនិព្វានឲ្យជាអារម្មណ៍ ក្នុងខណៈនៃមគ្គឈ្មោះថា បក្ខន្ទនវោស្សគ្គ ។ ទាំង ២ នោះក៏សមគួរក្នុងន័យនៃការពណ៌នាសេចក្តីដែលមានទាំងលោកិយនិងលោកុត្តរលាយឡំគ្នានេះ ។ សេចក្តីពិតយ៉ាងនោះ ធម៌តែមួយ មានសម្មាទិដ្ឋិជាដើម រមែងលះកិលេសទាំងឡាយដោយប្រការតាមដែលពោលហើយ និងរមែងស្ទុះទៅកាន់និព្វាន ។ បទថា

**វោស្សគ្គបរិណាមី** មានអធិប្បាយថា បង្អោនទៅ អប់រំ បន្ទំឲ្យចាស់ក្លា ដើម្បីការលះបង់ដោយពាក្យទាំងអស់នេះ ។ ភិក្ខុនេះដែលប្រកបដោយអរិយមគ្គភាវនា រមែងចម្រើនអរិយមគ្គនោះដោយប្រការដែលធម៌តែមួយ មានសម្មាទិដ្ឋិជាដើម រមែងអប់រំនិងបន្ទំឲ្យចាស់ក្លា ដើម្បីការលះបង់ដោយការលះកិលេស និងដើម្បីលះបង់ដោយការស្ទុះទៅកាន់និព្វាន ។

ក្នុងបទថា **ពីជគាមភូតគាមា** នេះ មានអធិប្បាយថា ពូជមាន ៥ យ៉ាង គឺពូជកើតពីមើមឬឫស ១ ពូជកើតពីដើម ១ ពូជកើតពីចុងឬគល់ ១ ពូជកើតពីថ្នាំង[១] ១ ពូជកើតពីពូជ ( គឺផ្លែ ) ១ ឈ្មោះថា ពីជគាម អធិប្បាយថា ក្រុមនៃពូជ ។ ពូជនោះឯង ឈ្មោះថា ភូតគាម ចាប់តាំងអំពីការប្រាកដនៃពន្លកខៀវដែលសម្បូរ អធិប្បាយថា ក្រុមពន្លកពណ៌ខៀវដែលមានឫសដុះកើតហើយ កើតឡើងហើយ ។ អាចារ្យពួកខ្លះពោលថា កាលទេវតាហួងហែង រមែងជាពូជតាំងអំពីពេលមានពន្លកពណ៌ខៀវ ព្រោះហេតុនោះ ទើបឈ្មោះថា ភូតគាម ព្រោះជាស្រុករបស់ភូត គឺទេវតាទាំងនោះ ។ បទថា **វុឌ្ឍឹ** បានដល់ ចម្រើនដោយពន្លកជាដើម ។ បទថា **វិរុឡ្ហឹ** បានដល់ ដុះដាលដោយដើមជាដើម ។ បទថា **វេបុល្លំ** បានដល់ បរិបូរណ៍ដោយផ្កាជាដើម ។ម្យ៉ាងទៀត ក្នុងផ្លូវធម៌ បទថា **វុឌ្ឍឹ** បានដល់ ចម្រើនដោយការប្រព្រឹត្តធម៌ដែលមិនទាន់ធ្លាប់ប្រព្រឹត្ត ។ បទថា **វិរុឡ្ហឹ** បានដល់ ដុះដាលដោយការធ្វើកិច្ចឲ្យសម្រេច ។ បទថា **វេបុល្លំ** បានដល់

១-បិដកខ្មែរលោករៀងលំដាប់ថា [illegible] ទុកមុនចុងបា [illegible] ។

បរិបូរណ៍ដ្បិតសម្រេចកិច្ចហើយ ។ បាឋៈថា **វិបុលុត្តំ** ដូច្នេះក៏មាន ។ ម្យ៉ាងវិញទៀត បទទាំង ៣ នេះ ប្រកបដោយសីល សមាធិ បញ្ញា ។

## អដ្ឋកថា

## មគ្គង្គនិទ្ទេស

[ ១៧៥-១៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេស ដូចតទៅនេះថា បទថា **សម្មាទិដ្ឋិយា** ជាឆដ្ឋីវិភត្តិ ។ នៃសម្មាទិដ្ឋិដែលប្រព្រឹត្តទៅដោយការប្រកបតាម និងដោយអារម្មណ៍តាមដែលប្រកបបាន ក្នុងឈានវិបស្សនា មគ្គ ផលនិងនិព្វាន និងក្នុងចិត្តដែលសម្បយុត្តដោយលោកិយវិរតិ គឺនៃសម្មាទិដ្ឋិដែលកើតជាមួយគ្នាដោយជាសាមញ្ញលក្ខណៈ ។ បទថា **វិក្ខម្ភនវិវេកោ** បានដល់ សេចក្ដីស្ងាត់ដោយការគ្របសង្កត់ទុក ដោយអំណាចការធ្វើឲ្យឆ្ងាយ ។ នូវអ្វី នូវនីវរណៈទាំងឡាយ ។ បទថា **បឋមជ្ឈានំ ភាវយតោ** ជាដើម លោកពោលដល់បឋមជ្ឈាននោះឯង ដោយការគ្របសង្កត់ទុក ។ កាលលោកពោលដល់បឋមជ្ឈាននោះ ក៏ជាការពោលដល់សូម្បីឈានដ៏សេសដូចគ្នា ។ សម្មាទិដ្ឋិ ឈ្មោះថា មានវិវេក ព្រោះសម្មាទិដ្ឋិមានសូម្បីក្នុងឈានទាំងឡាយ ។

បទថា **តទង្គវិវេកោ** បានដល់ ការស្ងាត់ដោយវិបស្សនាញាណនោះ ៗ ។ បទថា **និជ្ជិតតានំ** លោកពោលដល់ការស្ងាត់ចាកទិដ្ឋិនោះឯង

ព្រោះការស្ងាត់ចាកទិដ្ឋិធ្វើបានលំបាក និងជាប្រធាន ។ កាលលោកពោលដល់ការស្ងាត់ចាកទិដ្ឋិនោះ ក៏ជាការពោលដល់ការស្ងាត់ មាននិច្ចសញ្ញាជាដើម ។ បទថា **និព្វេធភាគិយំ សមាធឹ** បានដល់ សមាធិសម្បយុត្តដោយវិបស្សនា ។ បទថា **សមុច្ឆេទវិវេកោ** បានដល់ ការស្ងាត់ដោយការកាត់ផ្តាច់កិលេសទាំងឡាយ ។ បទថា **លោកុត្តរំ ខយគាមិមគ្គំ** បានដល់ លោកុត្តរមគ្គដែលឲ្យដល់និព្វាន ពោលគឺការអស់ទៅ ។ បទថា **បដិប្បស្សទ្ធិវិវេកោ** បានដល់ សេចក្តីស្ងាត់ក្នុងការស្ងប់កិលេសទាំងឡាយ ។ បទថា **និស្សរណវិវេកោ** បានដល់ ស្ងាត់ចាកសង្ខារដែលជាការរលាស់ចេញចាកសង្ខតធម៌ទាំងអស់ ។ បទថា **ឆន្ទជាតោ ហោតិ** បានដល់ ជាអ្នកកើតសេចក្តីពេញចិត្តក្នុងធម៌ ក្នុងចំណែកខាងដើម ។ បទថា **សទ្ធាធិមុត្តោ** បានដល់ ជាអ្នកបង្អោនទៅដោយសទ្ធា ក្នុងចំណែកខាងដើម ។ បទថា **ចិត្តញ្ចស្ស ស្វាធិដ្ឋិតំ** បានដល់ ចិត្តរបស់ព្រះយោគាវចរនោះតាំងមាំដោយល្អ គឺមាំទាំដោយល្អ ក្នុងចំណែកខាងដើមនោះឯង ។ ធម៌ ៣ ប្រការទាំងនេះ គឺឆន្ទៈ ១ សទ្ធា ១ ចិត្ត ១ ឈ្មោះថា ជាទីអាស្រ័យ ព្រោះ ជាទីចូលទៅអាស្រ័យនៃវិវេកដែលកើតឡើងហើយ ក្នុងចំណែកខាងដើម ។ តែអាចារ្យពួកខ្លះពោលថា លោកពោលសមាធិដោយពាក្យថា មានចិត្តតាំងមាំដោយល្អ ។ សូម្បីក្នុងវិរាគៈជាដើម ក៏មានន័យនេះដូចគ្នា ។

[ ១៧៧-១៧៨ ] ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងនិរោធវារ ដូចតទៅនេះថា លោកកាលសម្តែងបរិយាយដទៃអំពី **និរោធ** សព្ទ ទើបពោល

ថា **អមតា ធាតុ** ។ ក្នុងវារៈដ៏សេសលោកពោលថា **និរោធោ និព្វានំ** សូម្បីក្នុងបទទាំងពីរគប្បីជ្រាបថាជានិព្វានដូចគ្នា ។ បទថា **ទ្វាធស និស្ស-យា** បានដល់ ព្រោះធ្វើឆន្ទៈ សទ្ធានិងចិត្តនីមួយៗ ៣ ក្នុងធម៌ ៤ នីមួយៗ មានវិវេកជាដើម ទើបជានិស្ស័យ ១២ ។

[ ១៧៩-១៨៥ ] សូម្បីសម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិនិង សម្មាសមាធិ ក៏គប្បីជ្រាបការប្រកបសេចក្ដីដោយន័យនេះដូចគ្នា ។ម្យ៉ាង ទៀត គប្បីជ្រាបថា លោកពោលដល់វិរតិដែលប្រព្រឹត្តទៅ ដោយអំណាច ជាចំណែកខាងដើមនិងចំណែកខាងចុងនៃឈាននិងវិបស្សនា ធ្វើឲ្យអាស្រ័យ ឈាននិងវិបស្សនា ព្រោះមិនមានសម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ ក្នុងខណៈនៃឈាននិងក្នុងខណៈវិបស្សនា ។

ម្យ៉ាងទៀត គប្បីជ្រាបថា វិវេក វិរាគៈ និរោធនិងការលះនីវរណៈ និងទិដ្ឋិទាំងឡាយ ឈ្មោះថា វិវេកជាដើមដែលវិរតិទាំងឡាយដែលប្រព្រឹត្ត ទៅដូចគ្នា ។ ដូចព្រះតម្រាស់ ក្នុងអង្គុត្តរនិកាយអដ្ឋកនិបាតថា ម្នាលភិក្ខុ កាលនោះ អ្នកគួរចម្រើននូវសមាធិនេះ ដែលប្រកបដោយវិតក្កនិងវិចារផង គួរចម្រើននូវសមាធិដែលមិនមានវិតក្កផង មានតែវិចារប៉ុណ្ណោះ គួរចម្រើន នូវសមាធិដែលមិនមានវិតក្ក មិនមានវិចារផង គួរចម្រើននូវសមាធិដែល ប្រកបដោយបីតិផង គួរចម្រើននូវសមាធិដែលមិនមានបីតិផង គួរចម្រើន នូវសមាធិដែលប្រកបដោយសេចក្ដីសប្បាយផង គួរចម្រើននូវសមាធិដែល ប្រកបដោយឧបេក្ខាផង ដូច្នេះ ។

លោកពោលមេត្តាជាដើម និងកាយានុបស្សនាជាដើមដោយអំណាចនៃសមាធិដែលជាមូលខាងក្នុងរបស់ខ្លួន ដូចប្រកបក្នុងឈានពួក ៤ និងឈានពួក ៥ ។ សូម្បីក្នុងបទនេះ ក៏គប្បីជ្រាបថា លោកពោលដល់វិរតិដោយអំណាចនៃចំណែកខាងដើម និងចំណែកខាងចុងយ៉ាងនោះ ។ បុគ្គលកាន់យកត្រឹមតែស្រមោលព្យញ្ជនៈ ហើយមិនគួរពោលបន្ទាប់ព្រះមានព្រះភាគ ព្រោះព្រះពុទ្ធវចនៈជ្រាលជ្រៅណាស់ គប្បីចូលទៅរកអាចារ្យ ហើយរៀនយកអំពីពាក្យអធិប្បាយ ។

សូម្បីក្នុងពោជ្ឈង្គវារៈ ពលវារៈនិងឥន្ទ្រិយវារៈក៏គប្បីជ្រាបសេចក្តីដោយន័យនេះឯង ។

**អដ្ឋកថាមគ្គង្គនិទ្ទេស ចប់**

**អដ្ឋកថាវិវេកកថា ចប់**

# សុត្តន្តបិដក

## បញ្ញាវគ្គ ចរិយាកថា

[ ១៨៦ ] ពាក្យថា ចរិយា បានដល់ចរិយា ៨ គឺឥរិយាបថចរិយា ១ អាយតនចរិយា ១ សតិចរិយា ១ សមាធិចរិយា ១ ញាណចរិយា ១ មគ្គចរិយា ១ បត្តិចរិយា ១ លោកត្ថចរិយា ១ ។

ការប្រព្រឹត្តិក្នុងឥរិយាបថទាំង ៤ ឈ្មោះថា ឥរិយាបថចរិយា ។ ការប្រព្រឹត្តិក្នុងអាយតនៈ ៦ ទាំងខាងក្នុងនិងខាងក្រៅ ឈ្មោះថា អាយតនចរិយា ។ ការប្រព្រឹត្តិក្នុងសតិប្បដ្ឋាន ៤ ឈ្មោះថា សតិចរិយា ។ ការប្រព្រឹត្តិក្នុងឈាន ៤ ឈ្មោះថា សមាធិចរិយា ។ ការប្រព្រឹត្តិក្នុងអរិយសច្ច ៤ ឈ្មោះថា ញាណចរិយា ។ ការប្រព្រឹត្តិក្នុងអរិយមគ្គ ៤ ឈ្មោះថា មគ្គចរិយា ។ ការប្រព្រឹត្តិក្នុងសាមញ្ញផល ៤ ឈ្មោះថា បត្តិចរិយា ។ ការប្រព្រឹត្តិក្នុងព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ក្នុងព្រះបច្ចេកពុទ្ធដោយចំណែកខ្លះ ក្នុងសាវកទាំងឡាយដោយចំណែកខ្លះ ឈ្មោះថា លោកត្ថចរិយា ។ ឯឥរិយាបថចរិយា សម្រាប់បុគ្គលអ្នកបរិបូរណ៍ដោយបណិធិ ( ការប្រាថ្នា ) អាយតនចរិយា សម្រាប់បុគ្គលអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ សតិចរិយា សម្រាប់បុគ្គលអ្នកមានកិរិយានៅដោយមិនប្រមាទ សមាធិចរិយា សម្រាប់បុគ្គលអ្នកប្រកបក្នុងអធិចិត្ត ញាណចរិយា សម្រាប់បុគ្គល អ្នកបរិបូរណ៍ដោយប្រាជ្ញា មគ្គចរិយា សម្រាប់បុគ្គលអ្នកប្រតិបត្តិត្រូវ បត្តិចរិយា សម្រាប់បុគ្គលអ្នកបានសម្រេចផលហើយ លោ-

កត្តចរិយា សម្រាប់ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធទាំងឡាយ សម្រាប់ព្រះបច្ចេកពុទ្ធទាំងឡាយដោយចំណែកខ្លះសម្រាប់សាវកទាំងឡាយដោយចំណែកខ្លះ នេះចរិយា ៨ ។

[ ១៨៧ ] ចរិយាមាន ៨ ដទៃទៀត គឺបុគ្គលកាលជឿស៊ប់ប្រព្រឹត្តដោយសទ្ធា ១ កាលផ្គងប្រព្រឹត្តដោយព្យាយាម ១ កាលប្រុងប្រព្រឹត្តដោយសតិ ១ កាលធ្វើនូវការមិនរាយមាយប្រព្រឹត្តដោយសមាធិ ១ កាលដឹងប្រព្រឹត្តដោយបញ្ញា ១ កាលដឹងច្បាស់ប្រព្រឹត្តដោយវិញ្ញាណ ១ ប្រព្រឹត្តដោយវិសេសចរិយាព្រោះគិតថា បុគ្គលប្រតិបត្តិយ៉ាងនេះ រមែងបាននូវគុណវិសេស ១ ប្រព្រឹត្តដោយអាយតនចរិយាព្រោះគិតថា កុសលធម៌ទាំងឡាយ តែងចម្រើនដល់បុគ្គលអ្នកប្រតិបត្តិយ៉ាងនេះ ១ នេះចរិយាទាំង ៨ ។

[ ១៨៨ ] ចរិយាមាន ៨ ដទៃទៀត គឺទស្សនចរិយានៃសម្មាទិដ្ឋិ ១ អភិរោបនចរិយានៃសម្មាសង្កប្បៈ ១ បរិគ្គហចរិយានៃសម្មាវាចា ១ សមុដ្ឋានចរិយានៃសម្មាកម្មន្តៈ ១ វោទានចរិយានៃសម្មាអាជីវៈ ១ បគ្គហចរិយានៃសម្មាវាយាមៈ ១ ឧបដ្ឋានចរិយានៃសម្មាសតិ ១ អវិក្ខេបចរិយានៃសម្មាសមាធិ ១ នេះចរិយា ៨ ។

**ចប់ ចរិយាកថា ។**

# អដ្ឋកថា
# ចរិយាកថា

[ ១៨៦-១៨៨ ] ឥឡូវនេះ ដើម្បីសម្ដែងឧបាយការធ្វើឲ្យជាក់ច្បាស់នូវនិព្វាន ពោលគឺនិស្សរណវិវេក ដែលជាសេចក្ដីស្ងាត់យ៉ាងក្រៃលែងក្នុងលំដាប់វិវេកកថា និងដើម្បីសម្ដែងការធ្វើកិរិយាដែលជាប្រយោជន៍និងសេចក្ដីសុខដល់សត្វលោកនៃបុគ្គល ដែលធ្វើឲ្យជាក់ច្បាស់នូវនិរោធហើយ ដោយប្រការនោះ ទើបព្រះសារីបុត្តត្ថេរពោលចរិយាកថាដែលសម្ដែងទុកហើយក្នុងឥន្ទ្រិយកថាទៀត ។ ការពណ៌នាសេចក្ដីនៃចរិយាកថានោះ ខ្ញុំពោលទុកហើយក្នុងឥន្ទ្រិយកថានោះឯង ដោយប្រការដូច្នេះ ។

**អដ្ឋកថាចរិយាកថា ចប់**

# សុត្តន្តបិដក

## បញ្ញាវគ្គ ចាដិហារិយកថា

[ ១៨៩ ] ម្នាលភិក្ខុទាំងឡាយ បាដិហារ្យនេះមាន ៣ ។ បាដិហារ្យ ៣ គឺអ្វីខ្លះ គឺឥទ្ធិប្បាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ។

[ ១៩០ ] ម្នាលភិក្ខុទាំងឡាយ ឥទ្ធិប្បាដិហារ្យ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ សម្តែងនូវឫទ្ធិបានច្រើនប្រការ គឺមនុស្សម្នាក់ធ្វើឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ធ្វើឲ្យទៅជាម្នាក់វិញក៏បាន ដើរទម្លុះទៅកាន់ទីវាល ទីខាងក្រៅ ។បេ។ ញុំាងអំណាចឲ្យប្រព្រឹត្តទៅទាំងកាយ រហូតដល់ព្រហ្មលោកក៏បាន ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឥទ្ធិប្បាដិហារ្យ ។

[ ១៩១ ] ម្នាលភិក្ខុទាំងឡាយ អាទេសនាបាដិហារ្យ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះទាយដោយនិមិត្តថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នក មានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ បើបុគ្គលនោះទាយឲ្យច្រើន ការទាយនោះក៏នៅតែយ៉ាងនោះដដែលគ្មានប្លែកទេ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកមួយក្នុងលោកនេះ មិនទាយដោយនិមិត្តទេ គ្រាន់តែឮសំឡេងមនុស្ស ឬអមនុស្ស ឬទេវតា ហើយក៏ទាយថាមនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ បើទុកជាបុគ្គលនោះទាយឲ្យច្រើន ការទាយនោះ

ក៏នៅតែយ៉ាងនោះដដែល គ្មានប្លែកទេ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកមួយក្នុងលោកនេះ មិនទាយដោយនិមិត្តទេ ទាំងមិនបានឮសំឡេងមនុស្ស ឬអមនុស្ស ឬទេវតាហើយទាយទេ តែបានឮសំឡេងនៃការត្រិះរិះ ឬការពិចារណារបស់បុគ្គលកំពុងត្រិះរិះ ឬកំពុងពិចារណា ហើយក៏ទាយថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ប្រសិនបើបុគ្គលនោះទាយឲ្យច្រើន ការទាយនោះ ក៏នៅតែយ៉ាងនោះដដែល គ្មានប្លែកទេ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលពួកមួយក្នុងលោកនេះ មិនទាយដោយនិមិត្តទេ មិនឮសំឡេងមនុស្ស ឬអមនុស្ស ឬទេវតា ហើយទាយទេ មិនឮសំឡេងនៃការត្រិះរិះ ឬការពិចារណារបស់បុគ្គលកំពុងត្រិះរិះ ឬពិចារណា ហើយទាយទេ គ្រាន់តែកំណត់ដឹងដោយចិត្តនូវចិត្តរបស់បុគ្គលដែលចូលកាន់សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ ថាមនោសង្ខារទាំងឡាយដែលលោកដ៏ចម្រើននេះ បានតាំងទុកហើយដោយប្រការណា លោកដ៏ចម្រើននោះ នឹងត្រិះរិះនូវវិតក្កៈបែបនេះក្នុងលំដាប់នៃចិត្តនេះដោយប្រការនោះ បើបុគ្គលនោះទាយឲ្យច្រើន ការទាយនោះក៏នៅតែយ៉ាងនោះដដែល គ្មានប្លែកទេ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាទេសនាបាដិហារ្យ ។

[ ១៩២ ] ម្នាលភិក្ខុទាំងឡាយ អនុសាសនីបាដិហារ្យ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ តែងប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយចូរត្រិះរិះយ៉ាងនេះចុះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើ

ទុកក្នុងចិត្តយ៉ាងនេះចុះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់អំពើនេះ ចូរចូលឈាននេះទៅ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អនុសាសនីបាដិហារ្យ ម្នាលភិក្ខុទាំងឡាយ នេះឯងបាដិហារ្យ ៣ យ៉ាង ។

[ ១៩៣ ] ឈ្មោះថា ឥទ្ធិ ព្រោះនេក្ខម្មៈសម្រេច ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់បង់នូវកាមច្ឆន្ទៈ ឈ្មោះថា អាទេសនាបាដិហារ្យ ព្រោះជនទាំងឡាយណាប្រកបដោយនេក្ខម្មៈនោះ ពួកជនទាំងអស់នោះ ជាអ្នកមានចិត្តបរិសុទ្ធ មានតម្រិះមិនល្អក់ ឈ្មោះថា អនុសាសនីបាដិហារ្យ ព្រោះនេក្ខម្មៈនោះឯង បណ្ឌិតត្រូវសេពយ៉ាងនេះ ត្រូវចម្រើនយ៉ាងនេះ ត្រូវធ្វើឲ្យច្រើនយ៉ាងនេះ ត្រូវតម្កល់ទុកនូវសតិដ៏សមគួរដល់នេក្ខម្មៈនោះយ៉ាងនេះ ឈ្មោះថា ឥទ្ធិ ព្រោះការមិនមានព្យាបាទសម្រេច ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់បង់នូវព្យាបាទ ឈ្មោះថា អាទេសនាបាដិហារ្យ ព្រោះជនទាំងឡាយណាប្រកបដោយការមិនមានព្យាបាទនោះ ពួកជនទាំងអស់នោះ ជាអ្នកមានចិត្តបរិសុទ្ធ មានតម្រិះមិនល្អក់ ឈ្មោះថា អនុសាសនីបាដិហារ្យ ព្រោះការមិនមានព្យាបាទនោះ បណ្ឌិតត្រូវសេពយ៉ាងនេះ ត្រូវចម្រើនយ៉ាងនេះ ត្រូវធ្វើឲ្យច្រើនយ៉ាងនេះ ត្រូវតម្កល់ទុកនូវសតិដ៏សមគួរ ដល់ការមិនមានព្យាបាទនោះយ៉ាងនេះ ឈ្មោះថា ឥទ្ធិ ព្រោះអាលោកសញ្ញាសម្រេច ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់បង់នូវថីនមិទ្ធៈ ឈ្មោះថា អាទេសនាបាដិហារ្យ ព្រោះជនទាំងឡាយណាប្រកបដោយអាលោកសញ្ញានោះ ពួកជនទាំងអស់នោះជាអ្នកមានចិត្តបរិសុទ្ធ មានតម្រិះមិនល្អក់ ឈ្មោះថា អនុសាសនីបាដិ-

ហារ្យ ព្រោះអាលោកសញ្ញានោះឯងបណ្ឌិតត្រូវសេពយ៉ាងនេះ ត្រូវចម្រើន យ៉ាងនេះ ត្រូវធ្វើឲ្យច្រើនយ៉ាងនេះ ត្រូវតម្កល់ទុកនូវសតិដ៏សមគួរដល់អាលោកសញ្ញានោះយ៉ាងនេះ ឈ្មោះថា ឥទ្ធិ ព្រោះការមិនរាយមាយសម្រេច ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់បង់ឧទ្ធច្ចៈ ឈ្មោះថា អាទេសនាបាដិហារ្យ ព្រោះជនទាំងឡាយណាប្រកបដោយការមិនរាយមាយនោះ ពួកជនទាំងអស់ នោះជាអ្នកមានចិត្តបរិសុទ្ធ មានតម្រិះមិនល្អក់ ឈ្មោះថា អនុសាសនីបាដិហារ្យ ព្រោះការមិនរាយមាយនោះ បណ្ឌិតត្រូវសេពយ៉ាងនេះ ត្រូវចម្រើន យ៉ាងនេះ ត្រូវធ្វើឲ្យច្រើនយ៉ាងនេះ ត្រូវតម្កល់ទុកនូវសតិដ៏សមគួរដល់ការ មិនរាយមាយនោះយ៉ាងនេះ ។បេ។ ឈ្មោះថា ឥទ្ធិ ព្រោះអរហត្តមគ្គសម្រេច ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់បង់នូវកិលេសទាំងពួង ឈ្មោះថា អាទេសនាបាដិហារ្យ ព្រោះជនទាំងឡាយណា ប្រកបដោយអរហត្តមគ្គនោះ ពួកជនទាំងអស់នោះ ជាអ្នកមានចិត្តបរិសុទ្ធ មានតម្រិះមិនល្អក់ ឈ្មោះថា អនុសាសនីបាដិហារ្យ ព្រោះអរហត្តមគ្គនោះបណ្ឌិតត្រូវសេពយ៉ាងនេះ ត្រូវចម្រើនយ៉ាងនេះ ត្រូវធ្វើឲ្យច្រើនយ៉ាងនេះ ត្រូវតម្កល់ទុកនូវសតិដ៏សមគួរ ដល់អរហត្តមគ្គនោះយ៉ាងនេះ ឈ្មោះថា ឥទ្ធិ ព្រោះនេក្ខម្មៈសម្រេច ឈ្មោះ ថា បាដិហារ្យ ព្រោះកម្ចាត់បង់នូវកាមច្ឆន្ទៈ ឫទ្ធិនិងបាដិហារ្យ នេះហៅថា ឥទ្ធិប្បាដិហារ្យ ឈ្មោះថា ឫទ្ធិ ព្រោះការមិនមានព្យាបាទសម្រេច ឈ្មោះ ថា បាដិហារ្យ ព្រោះកម្ចាត់បង់នូវព្យាបាទ ឫទ្ធិនិងបាដិហារ្យនេះ ហៅថា ឥទ្ធិប្បាដិហារ្យ ឈ្មោះថា ឥទ្ធិ ព្រោះអាលោកសញ្ញាសម្រេច ឈ្មោះថា

បាដិហារ្យ ព្រោះកម្ចាត់បង់នូវថីនមិទ្ធៈ ។បេ។ ឈ្មោះថា ឫទ្ធិ ព្រោះអរហត្តមគ្គសម្រេច ឈ្មោះថា បាដិហារ្យ ព្រោះកម្ចាត់បង់នូវកិលេសទាំងពួង ឫទ្ធិនិងបាដិហារ្យ នេះហៅថា ឥទ្ធិប្បាដិហារ្យ ។

## ចប់ បាដិហារិយកថា

# អដ្ឋកថា

# ចាដិហារិយកថា

[ ១៨៩ ] ឥឡូវនេះជាការពណ៌នាសេចក្តីតាមលំដាប់ ដែលមិនធ្លាប់ពោលក្នុងបាដិហារិយកថា ដែលមានព្រះសូត្រជាបទនាំដែលព្រះសារីបុត្តត្រេកាលសម្តែងដល់បាដិហារ្យ មានការប្រៀនប្រដៅប្រយោជន៍ដល់លោកជាទីបំផុត ពោលទុកហើយ បន្ទាប់អំពីអរិយកថាដែលមានលោកុត្តរចរិយាជាទីបំផុត ។

ក្នុងព្រះសូត្រនោះ គប្បីជ្រាបសេចក្តីដូចតទៅនេះមុន បទថា **ចាដិហា-រិយានិ** បានដល បាដិហារ្យដោយអំណាចនៃការនាំវត្ថុ ជាសឹកសត្រូវចេញទៅ ។ បទថា **ឥទ្ធិចាដិហារិយំ** ឈ្មោះថា **ឥទ្ធិ** ដោយអំណាចឲ្យសម្រេច ឈ្មោះថា **ចាដិហារិយ** ដោយអំណាចការនាំចេញទៅ បាដិហារ្យគឺ ឥទ្ធិ ឈ្មោះថា ឥទ្ធិប្បាដិហារ្យ ។

ចំណែកក្នុងបាដិហារ្យក្រៅនេះ ឈ្មោះថា **អាទេសនា** ដោយអំណាចការដាក់ចិត្ត ឈ្មោះថា **អនុសាសនី** ដោយអំណាចការប្រៀនប្រដៅ ។ បទដ៏សេសមានន័យដូចពោលហើយនោះឯង ។

[ ១៩០ ] បទថា **ឥធ** បានដល់ ក្នុងលោកនេះ ។ បទថា **ឯកច្ចោ** បានដល់ បុគ្គលមួយ ។ ឥទ្ធិប្បាដិហារិយនិទ្ទេសមានអត្ថដូចពោលទុកហើយខាងដើម ។

[ ១៩១ ] បទថា **និមិត្តេន អាទិសតិ** បានដល់ រមែងពោលដោយ

និមិត្តដែលមកហើយដោយនិមិត្តដែលទៅហើយឬដោយនិមិត្តដែលតាំងនៅ ។

បទថា **ឯវម្បិ តេ មនោ** បានដល់ ចិត្តរបស់លោកជាយ៉ាងនេះ មានសោមនស្ស មានទោមនស្ស ឬសម្បយុត្តដោយកាមវិតក្កៈជាដើម ។ **អបិ** សព្ទ ជាសម្បិណ្ឌនត្ថៈ ( មានសេចក្ដីរួមគ្នា ) ។ បទថា **ឥត្ថម្បិ តេ មនោ** បានដល់ សំដែងប្រការផ្សេងៗក្នុងចិត្ត សូម្បីនីមួយ ៗ អំពីចិត្តមានសោមនស្សជាដើម ។ បទថា **ឥតិបិ តេ ចិត្តំ** បានដល់ ចិត្តរបស់លោកសូម្បីយ៉ាងនេះ អធិប្បាយថា ចិត្តគិតដល់ប្រយោជន៍នេះៗ បានដល់រមែងពោលសូម្បីច្រើនជាងថា រឿងនេះនិងរឿងនេះដទៃអំពីចិត្ត មានហើយ រមែងមាននឹងមាន ។ បទថា **តថេវ តំ ហោតិ នោ អញ្ញថា** បានដល់ ការទាយចិត្ត ក៏ដូចដែលពោលហើយទាំងអស់មិនជាយ៉ាងដទៃ ។ បទថា **ន ហេវ ខោ និមិត្តេន អាទិសតិ** បានដល់ សូម្បីដឹងនិមិត្តក៏នៅមិនពោលតាមនិមិត្តតែម្យ៉ាង ។ បទថា **អបិច** ជាបទសំដែងបរិយាយដទៃទៀត ។ បទថា **មនុស្សានំ** បានដល់ របស់មនុស្សដែលខ្វនដឹងចិត្ត ។ បទថា **អមនុស្សានំ** បានដល់ របស់យក្ស បិសាចជាដើម ដែលបានឮ ឬឮមិនបាន ។ បទថា **ទេវតានំ** បានដល់ ទេវតាជាន់ចាតុម្មហារាជិកាជាដើម ។ បទថា **សទ្ទំ សុត្វា** បានដល់ បុគ្គលដែលដឹងចិត្តរបស់អ្នកដទៃ ស្ដាប់ហើយនូវសំឡេងរបស់ជនទាំងឡាយដែលពោល ។ បទថា **បន** ជានិបាតចុះក្នុងការផ្ដើមប្រារព្ធទៀត ។ បទថា **វិតក្កយតោ** បានដល់ របស់អ្នកត្រិះរិះដោយវិតក្កៈតាមធម្មតា ។ បទថា **វិចារយតោ** បានដល់ របស់អ្នក

ពិចារណាដោយវិចារៈ ដែលសម្បយុត្តដោយវិតក្កៈនោះឯង ។ បទថា **វិ-តក្កវិប្ផារសទ្ទំ សុត្វា** បានដល់ ស្តាប់សំឡេងមមើ របស់មនុស្សដេកលក់ និងរបស់មនុស្សដែលខ្វះស្មារតី ដែលមមើមមាយដល់រឿងដែលកើតឡើង ដោយកម្លាំងរបស់វិតក្កៈ ។ រមែងទាយថា ចិត្តរបស់អ្នកដូច្នេះជាដើម ដោយអំណាចនៃរឿងដែលត្រិះរិះដែលធ្វើឲ្យសំឡេងនោះកើតឡើង ។

បទថា **អវិតក្កំ អវិចារំ សមាធឹ** ព្រះសារីបុត្តត្រេសម្តែងដល់បុគ្គលដែលអាចដឹងសូម្បីចិត្តដែលល្អិតដែលប្រាសចាកការកម្រើកនៃវិតក្កៈ វិចារៈ ។ ក្នុងការដឹងចិត្តដ៏សេសមិនមានពាក្យដែលគប្បីពោល ។ បទថា **ចេតសា ចេតោ បរិច្ច បជានាតិ** បានដល់ អ្នកបានចេតោបរិយញ្ញាណ ។ បទថា **ភោតោ** បានដល់ អ្នកចម្រើន ។ បទថា **មនោសង្ខារា បណិហិតា** បានដល់ តាំងចិត្តសង្ខារទុក ។ បទថា **អមុកំ ណាម វិតក្កំ វិតក្កយិស្សតិ** បានដល់ រមែងដឹងថា នឹងត្រិះរិះ នឹងប្រព្រឹត្តវិតក្កៈ មានកុសលវិតក្កៈជាដើម ។ ម្យ៉ាងទៀត កាលដឹងរមែងដឹងដោយការចូលដល់ រមែងដឹងដោយចំណែកខាងដើម រមែងពិនិត្យមើលចិត្តក្នុងខាងក្នុងសមាបត្តិហើយដឹង ។

រមែងដឹងថា ក្នុងវេលាបរិកម្មកសិណ បុគ្គលនេះ ផ្តើមកសិណភាវនាញុំាងបឋមជ្ឈាន ទុតិយជ្ឈានជាដើម ឬញុំាងសមាបត្តិ ៨ ឲ្យកើតឡើងដោយអាការណា នេះឈ្មោះថា រមែងដឹងដោយការចូលដល់ ។ កាលផ្តើមវិបស្សនាដំបូងនោះឯង រមែងដឹង គឺរមែងដឹងថា បុគ្គលនេះផ្តើមវិ-បស្សនា ហើយនឹងញុំាងសោតាបត្តិមគ្គឲ្យកើត ។បេ។ ឬនឹងញុំាងអរហត្តមគ្គ

ឲ្យកើតដោយអាការណា នេះឈ្មោះថា រមែងដឹងដោយចំណែកខាងដើម ។

រមែងដឹងថា បុគ្គលនេះតាំងមនោសង្ខារ ហើយនិងត្រិះរិះដល់វិតក្កៈឈ្មោះនេះ ក្នុងលំដាប់នៃចិត្តឈ្មោះនេះ កាលភិក្ខុចេញចាកវិតក្កៈនេះ សមាធិដែលជាចំណែកនៃការវិនាស ដែលជាចំណែកនៃការតាំងនៅ ដែលជាចំណែកនៃភាពវិសេស ឬដែលជាចំណែកនៃការទម្លាយ នឹងមាន ឬនឹងញ៉ាំងអភិញ្ញាឲ្យកើតឡើងដោយអាការណា នេះឈ្មោះថា រមែងពិនិត្យមើលចិត្តក្នុងខាងក្នុងសមាបត្តិ ហើយដឹង ។

បទថា **ពហុំ ចេបិ អាទិសតិ** បានដល់ ដល់ សូម្បីនឹងពោលទុកជាចំណែកច្រើន ដោយប្រភេទនៃអាការ ១៦ មានចិត្តប្រកបដោយរាគៈជាដើម ដោយធ្វើចិត្តនិងចេតសិកនោះឯង ឲ្យជាអារម្មណ៍ ដល់ចេតោបរិយញ្ញាណ គប្បីជ្រាបថា មិនមែនពោលដោយអំណាចយ៉ាងដទៃ ។ បទថា **តថេវ តំ ហោតិ** បានដល់ ការដឹងក៏យ៉ាងនោះដោយចំណែកមួយនោះឯង ។ រមែងជាការដឹងដោយចេតោបរិយញ្ញាណ មិនមានដោយប្រការដទៃ ។

[ ១៩២ ] បទថា **ឯវំ វិតក្កេថ** បានដល់ ចូរត្រិះរិះធ្វើនេក្ខម្មវិតក្កៈជាដើម ឲ្យប្រព្រឹត្តទៅយ៉ាងនេះ ។ បទថា **មា ឯវំ វិតក្កយិត្ថ** បានដល់ កុំត្រិះរិះឲ្យកាមវិតក្កៈជាដើមប្រព្រឹត្តទៅយ៉ាងនោះ ។ បទថា **ឯវំ មនសិករោថ** បានដល់ ចូរធ្វើទុកក្នុងចិត្តនូវអនិច្ចសញ្ញា ឬសញ្ញាណាមួយ មានទុក្ខសញ្ញាជាដើមយ៉ាងនេះ ។ បទថា **មា ឯវំ មនសាកត្ថ** បានដល់ កុំធ្វើទុកក្នុងចិត្តដោយន័យថា ទៀងជាដើមយ៉ាងនេះ ។ បទថា **ឥទំ បជហថ**

បានដល់ ចូរលះរាគៈក្នុងកាមគុណ ៥ ជាដើមនេះ ។ បទថា **ឥធំ ឧប-សម្បជ្ជ វិហរថ** បានដល់ ចូរសម្រេចលោកុត្តរធម៌ដែលមានមគ្គ ៤ ផល ៤ ជាប្រភេទនេះ ឲ្យសម្រេចចុះ ។

[ ១៩៣ ] ឥឡូវនេះព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងបរិយាយដទៃក្នុងឥទ្ធិប្បាដិហារ្យដោយពិសេសទើបពោលពាក្យថា **នេក្ខម្មំ ឥជ្ឈតីតិ ឥទ្ធិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **កាមច្ឆន្ទំ បដិហរតិ** សេចក្ដីថា នេក្ខម្មៈជាកម្លាំងចំពោះ រមែងនាំចេញ គឺលះកាមច្ឆន្ទៈដែលជាបដិបក្ខរបស់ខ្លួន ព្រោះហេតុនោះ នេក្ខម្មៈនោះឯង ទើបឈ្មោះថា **ចាដិហារិយ** ។ បទថា **យេ តេន នេក្ខម្មេន សមន្នាគតា** បានដល់ បុគ្គលពួកណាប្រកបដោយនេក្ខម្មៈនោះ ដែលនាំកាមច្ឆន្ទៈចេញទៅយ៉ាងនេះ ដោយអំណាចការបានចំពោះ ។ បទថា **វិសុទ្ធចិត្តា** បានដល់ មានចិត្តបរិសុទ្ធ ព្រោះមិនមានកាមច្ឆន្ទៈ ។ បទថា **អនាវិលសង្កប្បា** បានដល់ មានការត្រិះរិះក្នុងនេក្ខម្មៈមិនល្អក់ដោយការត្រិះរិះដល់កាម ។ បទថា **ឥតិ អាទេសនាចាដិហារិយំ** សេចក្ដីថា នេក្ខម្មៈជាអាទេសនាបាដិហារ្យយ៉ាងនេះ ដល់អ្នកឈ្លាសក្នុងចិត្តរបស់អ្នកដទៃ ដល់អន្យតិត្ថិយ ដល់ព្រះសម្មាសម្ពុទ្ធដទៃ ឬដល់ពុទ្ធសាវកទាំងឡាយ ។ម្យ៉ាងទៀត ការទាយចិត្តយ៉ាងនេះ ដោយប្រការដូច្នេះ ឈ្មោះថា អាទេស-នាបាដិហារិយ ហេតុនោះ គប្បីប្រកបធ្វើ **អាទេសន** សព្ទ ឲ្យជាបាឋៈដ៏សេស ។ បទថា **ឯវំ អាសេវិតព្វំ** បានដល់ គប្បីសេពដោយប្រការនេះៗ

អំពីខាងដើម ។ ក្នុង ៣ បទដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **តទ-ឆុធម្មតា សតិ ឧបដ្ឋបេតព្វា** បានដល់ គប្បីតាំងសតិដែលឧបការដល់នេក្ខម្មៈនោះ ឲ្យក្រៃលែង ។ បទថា **ឥតិ អនុសាសនីបាដិហារិយំ** នេះគប្បីធ្វើការប្រកប ដូចក្នុងការប្រកបនៃអាទេសនាបាដិហារិយៈ ។ សូម្បីក្នុងព្យាបាទជាដើមក៏មានន័យនេះដូចគ្នា ។ តែបាលី លោកសង្ខេបឈានជាដើមហើយសម្តែងអរហត្តមគ្គទុកក្នុងទីបំផុត ។ ក្នុងធម៌ទាំងនោះក្នុងមគ្គទាំងមូលគប្បីជ្រាបថា លោកពោលបទថា **ឃរំ អាសេវិតព្វោ** ជាដើម ដោយអំណាចជាចំណែកខាងដើមនៃមគ្គ ព្រោះប្រព្រឹត្តទៅក្នុងខណៈចិត្តមួយដួង ។ ពិតណាស់ គប្បីជ្រាបថា ដើម្បីធ្វើមគ្គឲ្យកើតឡើងដោយវិបស្សនាដែលជាវុដ្ឋានគាមិនី ពោលគឺលោកិយមគ្គដែលជាចំណែកខាងដើមនៃមគ្គ កាលធ្វើអាសេវនៈជាដើមហើយ សូម្បីដែលមគ្គកើតឡើង ដោយវិបស្សនានោះ ក៏ឈ្មោះថា សេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ។ ចំណែកអាចារ្យដែលជាសព្វត្ថិកវាទ ( មានវាទៈគ្រប់យ៉ាងមានប្រយោជន៍ ) ពោលថា មគ្គនីមួយៗមាន ១៦ ខណៈ តែការតាំងសតិដែលជាធម៌ សមគួរដល់មគ្គនោះ រមែងប្រកបបានក្នុងចំណែកខាងដើមប៉ុណ្ណោះ ។ ដើម្បីសម្តែងពាក្យថា **ឥទ្ធិបាដិហារិយំ** ជាកម្មធារយសមាស ទើបលោកពោល បទថា **នេក្ខម្មំ ឥជ្ឈតីតិ ឥទ្ធិ** ជាដើមម្តងទៀត ។ កាលលោកពោលថា ឥទ្ធិបាដិហារិយៈនោះឯង ជាសមាសក្នុង ៣ បាដិហារ្យ ដូចត្រាស់ទុកហើយក្នុងព្រះសូត្រក៏ជាការពោលដល់អត្ថរបស់បាដិហារ្យ ២ ដ៏សេសផងដែរ ព្រោះហេតុនោះ

គប្បីជ្រាបថា លោកពោលអត្ថនៃសមាសរបស់ឥទ្ធិបាដិហារិយៈ ដែលជាមូលនោះឯងក្នុងបរិយាយនេះ ដោយប្រការដូច្នេះ ។

## អដ្ឋកថា បាដិហារិយកថា ចប់

# សុត្តន្តបិដក

## បញ្ញាវគ្គ សមសីសកថា

[ ១៩៤ ] បញ្ញា គឺការមិនតាំងឡើង ព្រោះការផ្តាច់ផ្តិលដោយប្រពៃ ព្រោះការរលត់នៃធម៌ទាំងពួង ឈ្មោះថា សមសីសដ្ឋញាណ ( ញាណក្នុងអត្ថថា ស្ងប់និងជាប្រធាន ) ។

ពាក្យថាធម៌ទាំងពួង បានដល់ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ កុសលធម៌ អកុសលធម៌ អព្យាកតធម៌ កាមាវចរធម៌ រូបាវចរធម៌ អរូបាវចរធម៌ អបរិយាបន្នធម៌ ។

ពាក្យថា ការផ្តាច់ផ្តិលដោយប្រពៃ អធិប្បាយថា ផ្តាច់ផ្តិលដោយប្រពៃនូវកាមច្ឆន្ទៈដោយនេក្ខម្មៈ ផ្តាច់ផ្តិលដោយប្រពៃនូវព្យាបាទ ដោយមិនមានព្យាបាទ ផ្តាច់ផ្តិលដោយប្រពៃនូវថីនមិទ្ធៈដោយអាលោកសញ្ញា ផ្តាច់ផ្តិលដោយប្រពៃនូវឧទ្ធច្ចៈដោយការមិនរាយមាយ ផ្តាច់ផ្តិលដោយប្រពៃនូវវិចិកិច្ឆាដោយការកំណត់នូវធម៌ ផ្តាច់ផ្តិលដោយប្រពៃនូវអវិជ្ជា ដោយញាណ ផ្តាច់ផ្តិលដោយប្រពៃនូវសេចក្តីមិនត្រេកអរដោយបាមោជ្ជៈ ផ្តាច់ផ្តិលដោយប្រពៃនូវនីវរណៈទាំងឡាយដោយបឋមជ្ឈាន ។បេ។ ផ្តាច់ផ្តិលដោយប្រពៃនូវកិលេសទាំងពួងដោយអរហត្តមគ្គ ។

[ ១៩៥ ] ពាក្យថា ការរលត់ អធិប្បាយថា រំលត់កាមច្ឆន្ទៈដោយនេក្ខម្មៈ រំលត់ព្យាបាទដោយអព្យាបាទ រំលត់ថីនមិទ្ធៈដោយអាលោកសញ្ញា រំលត់ឧទ្ធច្ចៈដោយការមិនរាយមាយ រំលត់វិចិកិច្ឆាដោយការកំណត់នូវធម៌

រំលត់អវិជ្ជាដោយញាណ រំលត់នូវសេចក្តីមិនត្រេកអរដោយបាមុជ្ជៈ រំលត់នូវនីវរណៈទាំងឡាយ ដោយបឋមជ្ឈាន ។បេ។ រំលត់នូវកិលេសទាំងពួងដោយអរហត្តមគ្គ ។

ពាក្យថា ការមិនតាំងឡើង អធិប្បាយថា កាលបុគ្គលបាននូវនេក្ខម្មៈ កាមច្ឆន្ទៈតាំងឡើងមិនបាន កាលបុគ្គលបាននូវអព្យាបាទ ព្យាបាទតាំងឡើងមិនបាន កាលបុគ្គលបាននូវអាលោកសញ្ញា ថីនមិទ្ធៈ តាំងឡើងមិនបាន កាលបុគ្គលបាននូវសេចក្តីមិនរាយមាយ ឧទ្ធច្ចៈតាំងឡើងមិនបាន កាលបុគ្គលបាននូវការកំណត់ធម៌ វិចិកិច្ឆាតាំងឡើងមិនបាន កាលបុគ្គលបាននូវញាណ អវិជ្ជាតាំងឡើងមិនបាន កាលបុគ្គលបាននូវបាមុជ្ជៈ ការមិនត្រេកអរតាំងឡើងមិនបាន កាលបុគ្គលបាននូវបឋមជ្ឈាន នីវរណៈទាំងឡាយ តាំងឡើងមិនបាន ។បេ។ កាលបុគ្គលបាននូវអរហត្តមគ្គ កិលេសទាំងពួងតាំងឡើងមិនបាន ។

[ ១៩៦ ] ពាក្យថា ស្ងប់ គឺនេក្ខម្មៈឈ្មោះថាស្ងប់ ព្រោះបានលះបង់កាមច្ឆន្ទៈ អព្យាបាទឈ្មោះថាស្ងប់ ព្រោះបានលះបង់ព្យាបាទ អាលោក-សញ្ញាឈ្មោះថាស្ងប់ ព្រោះបានលះបង់នូវថីនមិទ្ធ ការមិនរាយមាយឈ្មោះថាស្ងប់ ព្រោះបានលះបង់ឧទ្ធច្ចៈ ការកំណត់ធម៌ឈ្មោះថាស្ងប់ ព្រោះបានលះបង់វិចិកិច្ឆា ញាណឈ្មោះថាស្ងប់ព្រោះបានលះបង់អវិជ្ជា បាមុជ្ជៈឈ្មោះថាស្ងប់ ព្រោះបានលះបង់អរតិ បឋមជ្ឈានឈ្មោះថាស្ងប់ ព្រោះបានលះបង់នីវរណៈទាំងឡាយ ។បេ។ អរហត្តមគ្គឈ្មោះថាស្ងប់ ព្រោះបានលះបង់

កិលេសទាំងពួង ។

ពាក្យថា ជាប្រធាន បានដល់ប្រធាន ១៣ យ៉ាង គឺប្រធានខាងកន្លល់ បានដល់តណ្ហា ១ ប្រធានខាងចំណង បានដល់មានះ ១ ប្រធានខាងការស្ទាបអង្អែល បានដល់ទិដ្ឋិ ១ ប្រធានខាងការរាយមាយ បានដល់ឧទ្ធច្ចៈ ១ ប្រធានខាងការសៅហ្មងបានដល់អវិជ្ជា ១ ប្រធានខាងការជឿបានដល់សទ្ធា ១ ប្រធានខាងការផ្គងឡើង បានដល់វិរិយៈ ១ ប្រធានខាងការប្រុងបានដល់សតិ ១ ប្រធានខាងការមិនរាយមាយ បានដល់សមាធិ ១ ប្រធានខាងការយល់ បានដល់បញ្ញា ១ ប្រធានខាងការប្រព្រឹត្តិទៅ បានដល់ជីវិតិន្ទ្រិយ ១ ប្រធានខាងគោចរ បានដល់វិមោក្ខ ១ ប្រធានខាងសង្ខារ បានដល់និរោធ ១ ។

## ចប់ សមសីសកថា ។

# អដ្ឋកថា
# សមសីសកថា

[ ១៩៤-១៩៦ ] ឥឡូវនេះដើម្បីសម្តែងភាពដែលសមសីសៈសង្គ្រោះចូលក្នុងឥទ្ធិបាដិហារិយៈ ដែលជាបាដិហារ្យខាងដើម ក្នុងលំដាប់នៃបាដិហារិយកថា ថាជាឥទ្ធិបាដិហារិយៈ ទើបព្រះសារីបុត្តត្ថេរ ពោលសមសីសកថា សូម្បីដែលលោកសម្តែងទុកហើយ ក្នុងញាណកថាទៀត ដោយសម្ពន្ធនឹងឥទ្ធិប្បាដិហារិយៈ ។ ការពណ៌នាសេចក្តីរបស់សមសីសកថានោះ ខ្ញុំបានពោលទុកហើយក្នុងញាណកថានោះឯង ដោយប្រការដូច្នេះ ។

អដ្ឋកថា សមសីសកថា ចប់

# សុត្តន្តបិដក

## បញ្ញាវគ្គ សតិប្បដ្ឋានកថា

## សាវត្ថីបរិបុណ្ណនិទាន

[ ១៩៧ ] ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាននេះមាន ៤ សតិប្បដ្ឋាន ៤ តើអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោសមនស្សក្នុងលោក ១ ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ។បេ។ ១ នូវចិត្តក្នុងចិត្ត ១ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី គប្បីកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ១ ម្នាលភិក្ខុទាំងឡាយ នេះឯងសតិប្បដ្ឋាន ៤ ។

[ ១៩៨ ] ជាអ្នកពិចារណាឃើញនូវកាយក្នុងកាយ តើដូចម្តេច ។ បុគ្គលពួកមួយក្នុងលោកនេះ ពិចារណាឃើញនូវពួកដីថា មិនទៀង មិនមែនថា ទៀងទេ ពិចារណាឃើញនូវពួកដីថា ជាទុក្ខ មិនមែនថា ជាសុខទេ ពិចារណាឃើញនូវពួកដីថា មិនមែនខ្លួន មិនមែនថា ជាខ្លួនទេ រមែងនឿយណាយ មិនរីករាយទេ រមែងជិនណាយ មិនត្រេកអរទេ រមែងរំលត់ មិនឲ្យកើតទេ រមែងលះបង់ មិនប្រកាន់ទេ កាលពិចារណាឃើញថា មិនទៀង រមែងលះបង់សេចក្តីសម្គាល់ថា ទៀង កាលពិចារណាឃើញថា ជាទុក្ខ រមែងលះបង់នូវសេចក្តីសម្គាល់ថា ជាសុខ កាលពិចារណាឃើញថា មិន

មែនខ្លួន រមែងលះបង់នូវសេចក្តីសម្គាល់ថាខ្លួន កាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ កាលជិនណាយ រមែងលះបង់តម្រេក កាលរំលត់ រមែងលះបង់នូវការកើត កាលលះបង់ រមែងលះបង់នូវការប្រកាន់ បុគ្គលពិចារណាឃើញនូវកាយដោយអាការទាំង ៧ នេះ កាយឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថា សតិទេ ឯសតិឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញនូវកាយនោះដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោកពោលថា កាយេកាយានុបស្សនាសតិប្បដ្ឋាន-ភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ គឺភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវពួកធម៌ដែលកើតហើយក្នុងទីនោះ ១ ភាវនា ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ភាវនា ដោយអត្ថថា ដឹកនាំនូវសេចក្តីព្យាយាមដ៏សមគួរដល់ធម៌នោះ ១ ភាវនា ដោយអត្ថថា ជាគ្រឿងសេពរឿយ ៗ ១ បុគ្គលពួកមួយក្នុងលោកនេះ ពិចារណាឃើញនូវពួកទឹក ពួកភ្លើង ពួកខ្យល់ ពួកសក់ ពួករោម ពួកសម្បុរថ្ងៃ ពួកស្បែក ពួកសាច់ ពួកសរសៃ ពួកឆ្អឹង ពួកខួរក្នុងឆ្អឹងថា មិនទៀង មិនមែនថា ទៀងទេ ពិចារណាឃើញថា ជាទុក្ខ មិនមែនថា ជាសុខទេ ពិចារណាឃើញថា មិនមែនខ្លួន មិនមែនថា ជាខ្លួនទេ រមែងនឿយណាយ មិនរីករាយទេ រមែងជិនណាយ មិនត្រេកអរទេ រមែងរំលត់មិនឲ្យកើតទេ រមែងលះបង់ មិនប្រកាន់ទេ កាលពិចារណាឃើញថា មិនទៀង រមែងលះបង់នូវសេចក្តី

សម្គាល់ថា ទៀង កាលពិចារណាឃើញថា ជាទុក្ខ រមែងលះបង់នូវសេចក្ដីសម្គាល់ថា ជាសុខ កាលពិចារណាឃើញថា មិនមែនខ្លួន រមែងលះបង់នូវសេចក្ដីសម្គាល់ថា ជាខ្លួន កាលនឿយណាយរមែងលះបង់នូវសេចក្ដីរីករាយ កាលជិនណាយ រមែងលះបង់តម្រេក កាលរំលត់ រមែងលះបង់នូវការកើត កាលលះបង់ រមែងលះបង់នូវការប្រកាន់ បុគ្គលពិចារណាឃើញនូវកាយដោយអាការទាំង ៧ នេះ កាយឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថា សតិទេ ឯសតិឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះលោកពោលថា កាយេកាយានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ ។បេ។ ភាវនា ដោយអត្ថថាសេពរឿយៗ ។បេ។ ភិក្ខុជាអ្នកពិចារណាឃើញនូវកាយក្នុងកាយ យ៉ាងនេះឯង ។

[ ១៩៩ ] ជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ តើដូចម្ដេច ។ បុគ្គលពួកមួយក្នុងលោកនេះ ពិចារណាឃើញនូវសុខវេទនាថា មិនទៀង មិនមែនថា ទៀងទេ ។បេ។ រមែងលះបង់ មិនប្រកាន់ទេ កាលពិចារណាឃើញថា មិនទៀង រមែងលះបង់នូវសេចក្ដីសម្គាល់ថា ទៀង ។បេ។ កាលលះបង់ រមែងលះបង់នូវការប្រកាន់ បុគ្គលពិចារណាឃើញនូវវេទនាដោយអាការទាំង ៧ នេះ វេទនា ឈ្មោះថា ឧបដ្ឋាន មិន

ឈ្មោះថា សតិទេ ឯសតិ ឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញនូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះលោកពោលថា វេទនាសុវេទនានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ ។បេ។ ភាវនា ដោយអត្ថថា សេពរឿយៗ ។បេ។ បុគ្គលពួកមួយក្នុងលោកនេះ ពិចារណាឃើញនូវទុក្ខ-វេទនា ។បេ។ នូវអទុក្ខមសុខវេទនា នូវវេទនាដែលកើតអំពីចក្ខុសម្ផស្ស នូវវេទនាដែលកើតអំពីសោតសម្ផស្ស នូវវេទនាដែលកើតអំពីឃានសម្ផស្ស ។បេ។ កាលលះបង់ រមែងលះបង់នូវការប្រកាន់ បុគ្គលពិចារណាឃើញនូវវេទនា ដោយអាការទាំង ៧ នេះ វេទនា ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ឯសតិ ឈ្មោះថា ឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញនូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះលោកពោលថា វេទនាសុវេទនានុបស្សនាសតិប្បដ្ឋានភាវនាដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ ។បេ។ ភាវនា ដោយអត្ថថា សេពរឿយៗ ។បេ។ ភិក្ខុជាអ្នកពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយយ៉ាងនេះឯង ។

[ ២០០ ] ជាអ្នកពិចារណាឃើញនូវចិត្តក្នុងចិត្ត តើដូចម្តេច ។ បុគ្គលពួកមួយក្នុងលោកនេះ ពិចារណាឃើញចិត្តដែលប្រកបដោយរាគៈថា មិន

ទៀង មិនមែនថា ទៀងទេ ។បេ។ រមែងលះបង់ មិនប្រកាន់ទេ កាល ពិចារណាឃើញថា មិនទៀង រមែងលះបង់សេចក្តីសម្គាល់ថា ទៀង ។បេ។ កាលលះបង់នូវការប្រកាន់ បុគ្គលពិចារណាឃើញចិត្តដោយអាការទាំង ៧ នេះ ចិត្ត ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថា សតិទេ ឯសតិ ឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញចិត្តនោះ ដោយ សតិនោះ ដោយញាណនោះ ព្រោះហេតុនោះលោកពោលថា ចិត្តេចិត្តានុ-បស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ ។បេ។ ភាវនា ដោយអត្ថថា សេពរឿយ ៗ ។បេ។ បុគ្គលពួកមួយ ក្នុងលោកនេះ ពិចារណាឃើញចិត្ត ប្រកបដោយរាគៈ ចិត្តប្រាសចាករាគៈ ចិត្តប្រកបដោយទោសៈ ចិត្តប្រាស ចាកទោសៈ ចិត្តប្រកបដោយមោហៈ ចិត្តប្រាសចាកមោហៈ ចិត្តរួញរា ចិត្ត រាយមាយ ចិត្តដល់នូវភាពជាធំ គឺរូបាវចរ និងអរូបាវចរ ចិត្តមិនដល់នូវ ភាពជាធំ គឺជាកាមាវចរ ចិត្តនៅមានចិត្តដទៃប្រសើរជាង គឺនៅជាកាមា-វចរ ចិត្តមិនមានចិត្តដទៃប្រសើរជាង គឺជារូបាវចរ និងអរូបាវចរ ចិត្តតាំង នៅមាំ គឺជាអប្បនាសមាធិនិងឧបចារសមាធិ ចិត្តមិនតាំងនៅមាំ គឺប្រាសចាក សមាធិទាំងពីរ ចិត្តរួចស្រឡះ ចិត្តមិនទាន់រួចស្រឡះ ចក្ខុវិញ្ញាណ សោត-វិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ថា មិនទៀង មិនមែនថា ទៀងទេ ។បេ។ រមែងលះបង់ មិនប្រកាន់ទេ កាល ពិចារណាឃើញថា មិនទៀង រមែងលះបង់នូវសេចក្តីសម្គាល់ថា ទៀង

។បេ។ កាលលះបង់ រមែងលះបង់នូវការប្រកាន់ បុគ្គលពិចារណា ឃើញចិត្តដោយអាការទាំង ៧ នេះ ចិត្តឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ឯសតិ ឈ្មោះថាឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលពិចារណាឃើញនូវចិត្តនោះដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោកពោលថា ចិត្តេចិត្តានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ ។បេ។ ភាវនា ដោយអត្ថថា សេព ។បេ។ ភិក្ខុជាអ្នកពិចារណាឃើញនូវចិត្តក្នុងចិត្តយ៉ាងនេះឯង ។

[ ២០១ ] ជាអ្នកពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ តើដូចម្តេច ។ បុគ្គលពួកមួយក្នុងលោកនេះលើកទុកកាយ លើកទុកវេទនា លើកទុកចិត្ត ហើយពិចារណាឃើញនូវធម៌ដ៏សេសសល់ អំពីកាយវេទនានិងចិត្តនោះថា មិនទៀង មិនមែនថា ទៀងទេ ពិចារណាឃើញថា ជាទុក្ខ មិនមែនថា ជាសុខទេ ពិចារណាឃើញថា មិនមែនខ្លួន មិនមែនថា ជាខ្លួនទេ រមែងនឿយណាយ មិនរីករាយទេ រមែងជិនណាយ មិនត្រេកអរទេ រមែងរំលត់ មិនឲ្យកើតទេ រមែងលះបង់ មិនប្រកាន់ទេ កាលពិចារណាឃើញថា មិនទៀង រមែងលះបង់សេចក្តីសម្គាល់ថាទៀង កាលពិចារណាឃើញថា ជាទុក្ខ រមែងលះបង់សេចក្តីសម្គាល់ថា ជាសុខ កាលពិចារណាឃើញថា មិនមែនខ្លួន រមែងលះបង់សេចក្តីសម្គាល់ថា ជាខ្លួន កាលនឿយណាយរមែងលះបង់នូវសេចក្តីរីករាយ កាលជិនណាយរមែងលះបង់តម្រេក កាលរំលត់ រមែងលះបង់ការកើត កាលលះបង់ រមែងលះបង់ការប្រកាន់ បុគ្គល

ពិចារណាឃើញធម៌ ដោយអាការទាំង ៧ នេះ ធម៌ ឈ្មោះថា ឧបដ្ឋាន មិនមែនឈ្មោះថា សតិទេ ឯសតិ ឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញនូវធម៌នោះដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ លោកពោលថា ធម្មេសុធម្មានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង គឺភាវនា ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវពួកធម៌ដែលកើតហើយក្នុងទីនោះ ភាវនា ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ភាវនា ដោយអត្ថថា ដឹកនាំនូវព្យាយាមដ៏សមគួរដល់ធម៌នោះ ភាវនា ដោយអត្ថថា សេពរឿយ ៗ ។បេ។ ភិក្ខុជាអ្នកពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយយ៉ាងនេះឯង ។

## ចប់ សតិប្បដ្ឋានកថា ។

## **អដ្ឋកថា**
## **សតិប្បដ្ឋានកថា**

[ ១៩៧ ] ឥឡូវនេះ ជាការពណ៌នាសេចក្ដីតាមលំដាប់ដែលមិនធ្លាប់ពោលក្នុងសតិប្បដ្ឋានកថា ដែលមានព្រះសូត្រជាបទនាំ ដែលព្រះសារីបុត្តត្ថេរសម្ដែងអនុបស្សនាវិសេស ៧ យ៉ាង ដែលធ្វើឥទ្ធិប្បាដិហារ្យដែលខ្ទនពោលទុកហើយឲ្យសម្រេច ពោលទុកហើយក្នុងលំដាប់នៃសមសីសកថា ។

ក្នុងបទទាំងនោះ គប្បីជ្រាបសេចក្ដីក្នុងព្រះសូត្រមុន បទថា **ចត្តារោ** ជាការកំណត់ចំនួន ដោយពាក្យនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងការកំណត់សតិប្បដ្ឋានទុកថា មិនតិចជាងនោះ មិនច្រើនជាងនោះ ។ បទថា **ឥមេ** ជាពាក្យសម្ដែងវត្ថុដែលគួរសម្ដែង ។ បទថា **ភិក្ខវេ** ជាពាក្យត្រាស់ហៅបុគ្គលអ្នកទទួលធម៌ ។ បទថា **សតិប្បដ្ឋានា** បានដល់ ទីតាំងនៃសតិ ៣ យ៉ាង គឺអារម្មណ៍ជាទីត្រាច់ទៅនៃសតិ ១ ភាពដែលសាស្ដាមិនមានការត្រេកអរ មិនត្រេកអរក្នុងសាវកទាំងឡាយដែលបដិបត្តិ ៣ យ៉ាង ១ និងតួសតិឯង ១ ។

អារម្មណ៍ជាទីត្រាច់ទៅនៃសតិហៅថា សតិប្បដ្ឋាន មកក្នុងបាលី ( សំយុត្តនិកាយមហាវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវសេចក្ដីកើតឡើងនិងសូន្យទៅនៃសតិប្បដ្ឋាន ៤ ដូច្នេះជាដើម ។ ពាក្យនោះមានអធិប្បាយថា ឈ្មោះថា បដ្ឋាន ព្រោះអត្ថថា ជាទីតាំង ។ អ្វីតាំង សតិតាំង ។ ទីតាំងនៃសតិ ឈ្មោះថា សតិប្បដ្ឋាន ។

ភាពដែលសាស្តា មិនមានការត្រេកអរ មិនមានការមិនត្រេកអរ ក្នុងសាវកទាំងឡាយដែលបដិបត្តិ ៣ យ៉ាង ហៅថា សតិប្បដ្ឋាន ក្នុងព្រះបាលី ( មជ្ឈិមនិកាយឧបរិបណ្ណាសក ) ថា ឯសតិប្បដ្ឋានមាន ៣ ប្រការ ជាធម៌ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរប្រៀនប្រដៅនូវគណៈបាន ដូច្នេះ ។ បទនោះ មានអធិប្បាយថា ឈ្មោះថាបដ្ឋាន ព្រោះគួរតាំងទុក អធិប្បាយថា គួរប្រព្រឹត្ត គួរតាំងទុក ដោយអ្វី ដោយសតិ ការតាំងទុកដោយសតិ ឈ្មោះថា សតិប្បដ្ឋាន ។

ម្យ៉ាងទៀត សតិនោះឯងហៅថា សតិប្បដ្ឋាន ដូចក្នុងបាលី ( ក្នុងមជ្ឈិមនិកាយឧបរិបណ្ណាសក ) ថា សតិប្បដ្ឋានទាំង ៤ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងពោជ្ឈង្គទាំង ៧ ឲ្យពេញបរិបូរណ៍បាន ដូច្នេះជាដើម ។ ពាក្យនោះមានអធិប្បាយថា ឈ្មោះថា បដ្ឋាន ព្រោះអត្ថថា តាំងទុក អធិប្បាយថា រមែងប្រាកដ រមែងឈានទៅ ស្ទុះទៅហើយ ប្រព្រឹត្តទៅ ។ ការតាំងគឺសតិ ឈ្មោះថា សតិប្បដ្ឋាន ។

ម្យ៉ាងវិញទៀត ឈ្មោះថា សតិ ព្រោះអត្ថថា ជាទីរឭក ឈ្មោះថាឧបដ្ឋាន ដោយអត្ថថាជាទីប្រាកដ ។ សតិនោះផង ការប្រាកដផង ព្រោះហេតុនោះទើបឈ្មោះថា សតិប្បដ្ឋាន ដោយប្រការដូច្នេះ ។ ក្នុងទីនេះលោកបំណងយកសតិប្បដ្ឋាននេះ ។ សួរថា បើយ៉ាងនេះ ព្រោះហេតុអ្វីទើបធ្វើជាពហុវចនៈថា សតិប្បដ្ឋានា ព្រោះមានសតិច្រើន ។ ពិតណាស់ពោលដោយប្រភេទនៃអារម្មណ៍ សតិទាំងនោះមានច្រើន ។ បទថា **ក–**

**ឥមេ ចត្តារោ** ជាកថេតុកម្យតាបុច្ឆា ( សួរឯងឆ្លើយឯង ) ។ បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ។ បទថា **ភិក្ខុ** មានវិគ្គហៈថា ឈ្មោះជាភិក្ខុ ព្រោះឃើញភ័យក្នុងសង្សារ ។ ការពណ៌នាអត្ថនៃបទដ៏សេសក្នុងគាថានេះ ខ្ញុំពោលទុកហើយក្នុងអដ្ឋកថាមគ្គសច្ចនិទ្ទេសក្នុងសុតមយញ្ញាណកថា ។

ព្រោះហេតុអ្វីទើបព្រះមានព្រះភាគត្រាស់សតិប្បដ្ឋាន ៤ ប៉ុណ្ណោះ មិនលើសមិនខ្វះ ។ ព្រោះដើម្បីប្រយោជន៍ ដល់វេនេយ្យសត្វ ព្រោះកាលតណ្ហាចរិត ទិដ្ឋិចរិត សមថយានិក វិបស្សនាយានិក ប្រព្រឹត្តទៅហើយ ពីរចំណែកដោយអំណាចទន់ខ្លី និងចាស់ក្លា កាយានុបស្សនា-សតិប្បដ្ឋានយ៉ាងគ្រោតគ្រាត ជាផ្លូវបរិសុទ្ធរបស់តណ្ហាចរិតទន់ខ្លី វេទនានុ-បស្សនាសតិប្បដ្ឋានដែលល្អិត ជាផ្លូវបរិសុទ្ធរបស់អ្នកមានតណ្ហាចរិតខ្លាំងក្លា ចិត្តានុបស្សនាសតិប្បដ្ឋាន ដែលមានប្រភេទមិនច្រើនពេក ជាផ្លូវបរិសុទ្ធរបស់អ្នកមានទិដ្ឋិចរិតទន់ខ្លី ធម្មានុបស្សនាសតិប្បដ្ឋានដែលមានច្រើនប្រភេទ ជាផ្លូវបរិសុទ្ធរបស់អ្នកមានទិដ្ឋិចរិតខ្លាំងក្លា ។ សតិប្បដ្ឋានប្រការទី ១ ជានិមិត្តគួរដល់ដោយមិនលំបាក ជាផ្លូវបរិសុទ្ធរបស់អ្នកជាសមថយានិកទន់ខ្លី ។ សតិប្បដ្ឋានប្រការទី ២ ជាផ្លូវបរិសុទ្ធ របស់បុគ្គលជាសមថយានិកចាស់ក្លា ព្រោះមិនតាំងនៅក្នុងអារម្មណ៍គ្រោតគ្រាត ។ សតិប្បដ្ឋានប្រការទី ៣ មានអារម្មណ៍មិនច្រើនពេក ជាផ្លូវបរិសុទ្ធរបស់បុគ្គលជាវិបស្សនាយានិកទន់ខ្លី ។ សតិប្បដ្ឋានប្រការទី ៤ មានអារម្មណ៍ច្រើនប្រភេទ ជាផ្លូវបរិសុទ្ធរបស់បុគ្គល

ជាវិបស្សនាយានិកចាស់ក្លា ។ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់សតិប្បដ្ឋាន ៤ ទុកមិនលើសមិនខ្វះ ។

ម្យ៉ាងវិញទៀត ដើម្បីលះការសម្គាល់ខុសថា ជារបស់ស្អាត ជាសុខ ជារបស់ទៀងនិងជាតួខ្លួន ។ ពិតណាស់ កាយជារបស់មិនស្អាត ។ តែសត្វទាំងឡាយមានការសម្គាល់ខុស ដោយការសម្គាល់ខុស ក្នុងកាយនោះថា ជារបស់ស្អាត ។ ដើម្បីលះការសម្គាល់ខុសនោះ ទើបត្រាស់សតិប្បដ្ឋានទី ១ ដោយសម្តែងភាពជារបស់មិនស្អាត ក្នុងកាយនោះដល់សត្វទាំងនោះ ។ ម្យ៉ាងទៀត ក្នុងវេទនាជាដើមដែលសត្វប្រកាន់ថាជាសុខ ជារបស់ទៀង ជាតួខ្លួន វេទនាជាទុក្ខ ចិត្តជារបស់មិនទៀង ធម៌ជាអនត្តា តែសត្វទាំងឡាយ មានការសម្គាល់ខុស ដោយការសម្គាល់ខុសក្នុងវេទនាជាដើមនោះថា ជាសុខ ជារបស់ទៀង ជាតួខ្លួន ។ ដើម្បីលះការសម្គាល់ខុសទាំងនោះ ទើបត្រាស់សតិប្បដ្ឋាន ៣ ដ៏សេស ដើម្បីសម្តែងដល់ភាពជាទុក្ខជាដើម ក្នុងវេទនាជាដើមនោះដល់សត្វទាំងនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់សតិប្បដ្ឋានទុក ៤ ប៉ុណ្ណោះ ដើម្បីលះការសម្គាល់ខុសថា ជារបស់ស្អាត ជាសុខ ជារបស់ទៀង និងជាតួខ្លួន ដោយប្រការដូច្នេះ មិនមែនដើម្បីលះការសម្គាល់ខុសតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត គប្បីជ្រាបថា ត្រាស់សតិប្បដ្ឋានទុក ៤ ប៉ុណ្ណោះ ដើម្បីលះឱឃៈ ៤ យោគៈ ៤ អាសវៈ ៤ គន្ថៈ ៤ ឧបាទាន ៤ និងអគតិ ៤ ខ្វះដើម្បីកំណត់ដឹងអាហារ ៤ យ៉ាងខ្វះ ។

[ ១៩៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេស ដូចតទៅនេះថា បទថា **បឋវីកាយំ** បានដល់ ធាតុដីក្នុងកាយនេះ ។ ដើម្បីសង្គ្រោះបឋវីធាតុទាំងអស់ ព្រោះបឋវីធាតុក្នុងកាយទាំងអស់មានច្រើន ទើបលោកប្រើ **កាយ** សព្ទ ដោយអត្ថថា ជាទីរួម ។

សូម្បីគំនរវាយោធាតុជាដើម ក៏មានន័យនេះដូចគ្នា ។ លោកប្រើគំនរសក់ជាដើម ព្រោះគំនរសក់ជាដើមមានច្រើន ។ តែទាចជាដើម រមែងនាំមកកាន់សព្ទថា គំនរ ព្រោះមានកំណត់ ព្រោះហេតុនោះ គប្បីជ្រាបថា លោកមិនកំណត់ទាចជាដើមនោះទុក ។

[ ១៩៩ ] គប្បីជ្រាបសេចក្ដីក្នុងបទថា **សុខំ វេទនំ** ជាដើម ដូចតទៅនេះថា បទថា **សុខំ វេទនំ** បានដល់ សុខវេទនាផ្លូវកាយ ឬផ្លូវចិត្ត ។ ទុក្ខវេទនាក៏យ៉ាងនោះ ។ ចំណែកបទថា **អទុក្ខមសុខំ វេទនំ** បានដល់ ឧបេក្ខាវេទនាផ្លូវចិត្តប៉ុណ្ណោះ ។ បទថា **សាមិសំ សុខំ វេទនំ** បានដល់ សោមនស្សវេទនាអាស្រ័យផ្ទះ ៦ ។ បទថា **និរាមិសំ សុខំ វេទនំ** បានដល់ សោមនស្សវេទនាអាស្រ័យនេក្ខម្មៈ ៦ ។ បទថា **សាមិសំ ទុក្ខំ វេទនំ** បានដល់ ទោមនស្សវេទនាអាស្រ័យផ្ទះ ៦ ។ បទថា **និរាមិសំ ទុក្ខំ វេទនំ** បានដល់ ទោមនស្សវេទនាអាស្រ័យនេក្ខម្មៈ ៦ ។ បទថា **សាមិសំ អទុក្ខមសុខំ វេទនំ** បានដល់ ឧបេក្ខាវេទនាអាស្រ័យផ្ទះ ៦ ។ បទថា **និរាមិសំ អទុក្ខមសុខំ វេទនំ** បានដល់ ឧបេក្ខាវេទនាអាស្រ័យនេក្ខម្មៈ ៦ ។

[ ២០០-២០១ ] បទថា **សរាគំ ចិត្តំ** ជាដើម មានអត្ថដូចពោលហើយក្នុងញាណកថា ។ បទថា **តទវសេសេ ធម្មេ** បានដល់ ក្នុងធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេសអំពីកាយវេទនា និងចិត្តទាំងនោះ ។ ម្យ៉ាងវិញទៀត ក្នុងបទទាំងពួង បទថា **តេន ញាណេន** បានដល់ ដោយអនុបស្សនាញាណ ៧ យ៉ាងនោះ ។ ម្យ៉ាងទៀត បទពួកណាមានអត្ថមិនបានពោលទុកក្នុងចន្លោះ ៗ ក្នុងកថានេះ បទទាំងនោះមានអត្ថដូចបានពោលហើយក្នុងកថានោះៗ ក្នុងខាងដើមនោះឯង ដោយប្រការដូច្នេះ ។

អដ្ឋកថា សតិប្បដ្ឋានកថា ចប់

# សុត្តន្តបិដក

## បញ្ញាវគ្គ វិបស្សនាកថា

## សាវត្ថីបរិបុណ្ណនិទាន

[ ២០២ ] ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងកាលពិចារណា ឃើញនូវសង្ខារនីមួយថា ទៀង នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះ នុ៎ះ មិនសមហេតុទេ ភិក្ខុនោះមិនប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់ សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះ កាលមិនចុះ កាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិ ផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលពិចារណាឃើញនូវសង្ខារទាំងពួងថា មិន ទៀង នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុ ប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះទើប សមហេតុ ភិក្ខុនោះ កាលចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវ សោតា បត្តិផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យ ដូច្នេះ នុ៎ះទើបសមហេតុ ។

[ ២០៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងកាលពិចារណាឃើញនូវ សង្ខារនីមួយថា ជាសុខ នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះមិន សមហេតុទេ ភិក្ខុនោះ មិនប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់សម្មត្តនិ- យាមធម៌ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះ កាលមិនចុះកាន់សម្ម-

ត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងកាលពិចារណាឃើញនូវសង្ខារទាំងពួងថា ជាទុក្ខ នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុនោះប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះទើបសមហេតុ ភិក្ខុនោះកាលចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវសោ-តាបត្តិផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។

[ ២០៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងកាលពិចារណាឃើញធម៌នីមួយថា ជាខ្លួន នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះមិនប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់សម្មត្ត-និយាមធម៌ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះកាលមិនចុះកាន់ស-ម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងកាលពិចារណាឃើញធម៌នីមួយថាមិនមែនខ្លួន នឹងប្រកបដោយអនុលោមិកខន្តិ ពាក្យដូច្នេះនុ៎ះទើបសមហេតុ ភិក្ខុប្រកបដោយអនុលោមិកខន្តិ នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុនោះ កាលចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិ-ផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ ទើប

សមហេតុ ។

[ ២០៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងកាលពិចារណាឃើញព្រះនិព្វានថា ជាទុក្ខ នឹងប្រកបដោយអនុលោមិកខន្តី ពាក្យដូច្នេះនុ៎ះមិនសមហេតុទេ ភិក្ខុនោះមិនប្រកបដោយអនុលោមិកខន្តី នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ភិក្ខុនោះកាលមិនចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ មិនសមហេតុទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង កាលពិចារណាឃើញព្រះនិព្វានថា ជាសុខ នឹងប្រកបដោយអនុលោមិកខន្តី ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុនោះប្រកបដោយអនុលោមិកខន្តី នឹងចុះកាន់សម្មត្តនិយាមធម៌ ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ភិក្ខុនោះ កាលចុះកាន់សម្មត្តនិយាមធម៌ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល អរហត្តផល ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។

[ ២០៦ ] ភិក្ខុបាននូវអនុលោមិកខន្តី ដោយអាការប៉ុន្មាន ចុះកាន់សម្មត្តនិយាមធម៌ ដោយអាការប៉ុន្មាន ។ ភិក្ខុបាននូវអនុលោមិកខន្តីដោយអាការ ៤០ ចុះកាន់សម្មត្តនិយាមធម៌ ក៏ដោយអាការ ៤០ ដែរ ។

ភិក្ខុបាននូវអនុលោមិកខន្តីដោយអាការ ៤០ តើដូចម្តេចខ្លះ ចុះកាន់សម្មត្តនិយាមធម៌ដោយអាការ ៤០ តើដូចម្តេចខ្លះ ។ ភិក្ខុពិចារណាឃើញនូវខន្ធ ៥ ថាមិនទៀង ១ ថាជាទុក្ខ ១ ជារោគ ១ ជាបូស ១ ជាសរ

១ ជារបស់លំបាក ១ ជាអាពាធ ១ ជារបស់ដទៃ ១ ជារបស់វិនាស ១ ជាចង្រៃ ១ ជាឧបទ្រព ១ ជាភ័យ ១ ជាឧបសគ្គ ១ ជាគ្រឿងញាប់ញ័រ ១ ជាគ្រឿងបែកធ្លាយ ១ ថាមិនទៀង ១ ថាមិនមានទីជ្រកកោន ១ ថាមិនមានទីពួន ១ ថាមិនមានទីពឹង ១ ថាជាវាល ១ ថាទទេ ១ ថាសោះសូន្យ ១ ថាមិនមែនខ្លួន ១ ថាជាទោស ១ ថាមានសេចក្តីប្រែប្រួលជាធម្មតា ១ ថាគ្មានខ្លឹម ១ ថាជាឫសគល់នៃសេចក្តីលំបាក ១ ថាជាអ្នកសម្លាប់ ១ ថាមិនមានសេចក្តីចម្រើន ១ ថាប្រកបដោយអាសវៈ ១ ថាជារបស់ដែលបច្ច័យប្រជុំតាក់តែង ១ ថាជាអាមិសៈនៃមារ ១ ថាមានការកើតជាធម្មតា ១ មានជរាជាធម្មតា ១ មានព្យាធិជាធម្មតា ១ មានមរណៈជាធម្មតា ១ មានសោកជាធម្មតា ១ មានការខ្សឹកខ្សួលជាធម្មតា ១ មានសេចក្តីចង្អៀតចង្អល់ជាធម្មតា ១ មានសេចក្តីសៅហ្មងជាធម្មតា ១ គឺថាកាលពិចារណាឃើញថា ខន្ធ ៥ មិនទៀង រមែងបានអនុលោមិកខន្តីកាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានដ៏ទៀងរមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញថា ខន្ធ ៥ ជាទុក្ខ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានជាឋានសុខ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញថា ខន្ធ ៥ ជារោគ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានរោគ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញថា ខន្ធ ៥ ជាបូស រមែងបានអនុលោមិកខន្តី កាលពិចា-

វណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានបូស រមែង
ចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ជាសរ រមែងបាន
អនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន
ជាឋានមិនមានសរ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញ
ខន្ធ ៥ ថាជាខន្ធលំបាក រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញ
ថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានទុក្ខ រមែងចុះកាន់សម្ម-
ត្តនិយាមធម៌ កាលពិចារណាឃើញនូវខន្ធ ៥ ថាជាអាពាធ រមែងបាន
អនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន
ជាឋានមិនមានអាពាធរមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញ
ខន្ធ ៥ ថាជារបស់ដទៃ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា
ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនជាបច្ច័យរបស់អ្នកដទៃ រមែងចុះកាន់
សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាវិនាស រមែងបានអនុ-
លោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជា
សភាវៈមិនវិនាស រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ
៥ ថាជាចង្រៃ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការ
រំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានចង្រៃ រមែងចុះកាន់សម្មត្តនិយាម
ធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាឧបទ្រព រមែងបានអនុលោមិក
ខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋាន
មិនមានឧបទ្រព រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ

៥ ថាជាភ័យ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានភ័យ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាឧបសគ្គ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានឧបសគ្គ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាគ្រឿងមិនញាប់ញ័រ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានការញាប់ញ័រ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជារបស់បែកធ្លាយ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថាការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានការបែកធ្លាយ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនទៀង រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានទៀង រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនមានទីជ្រកកោន រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមានទីជ្រកកោន រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនមានទីពួន រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមានទីពួន រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនមានទីពឹង រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជា

ឋាន មានទីពឹង រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ជាជាភ័យ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានទីភ័យ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ជាជារបស់ទទេ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនទទេ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ជាសូន្យ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានសូន្យ ( ចាកកិលេស ) ដ៏ក្រៃលែង រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ជាមិនមែនខ្លួន រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមានអត្ថដ៏ឧត្តម រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញនូវខន្ធ ៥ ថាជាទោស រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានទោស រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានការប្រែប្រួលជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានជាឋានមិនមានការប្រែប្រួលជាធម្មតា រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមិនមានខ្លឹម រមែងបាននូវអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមានខ្លឹម រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាឫសគល់នៃការលំបាក

រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនមានឫសគល់នៃសេចក្តីលំបាក រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាអ្នកសម្លាប់ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនជាទីសម្លាប់ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាប្រាសចាកសេចក្តីចម្រើន រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមែនជាទីប្រាសចាកសេចក្តីចម្រើន រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាប្រកបដោយអាសវៈ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានអាសវៈ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាបច្ច័យប្រជុំតាក់តែង រមែងបានអនុលោមិកខន្តី កាលពិ-ចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានបច្ច័យប្រជុំតាក់តែង រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាជាអាមិសនៃមារ រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថាការរំលត់ខន្ធ ៥ គឺព្រះនិព្វានមិនមានអាមិសៈ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានការកើតជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានឈប់កើត រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានជរាជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថាការរំលត់ខន្ធ

៥ គឺព្រះនិព្វានមិនមានជរា រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថា មានព្យាធិជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានព្យាធិជាធម្មតា រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានសេចក្តីស្លាប់ជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន ជាឋានមិនស្លាប់ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានសេចក្តីសោកជាធម្មតា រមែងបាននូវអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានសេចក្តីសោករមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានសេចក្តីខ្សឹកខ្សួលជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានសេចក្តីខ្សឹកខ្សួល រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានសេចក្តីចង្អៀតចង្អល់ ជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វានមិនមានសេចក្តីចង្អៀតចង្អល់ រមែងចុះកាន់សម្មត្តនិយាមធម៌ កាលពិចារណាឃើញខន្ធ ៥ ថាមានសេចក្តីសៅ-ហ្មងជាធម្មតា រមែងបានអនុលោមិកខន្តី កាលពិចារណាឃើញថា ការរំលត់ខន្ធ ៥ គឺព្រះនិព្វាន មិនមានសេចក្តីសៅហ្មង រមែងចុះកាន់សម្មត្តនិយាម-ធម៌ ។

[ ២០៧ ] ពាក្យថា មិនទៀង បានដល់ អនិច្ចានុបស្សនា ។

ពាក្យថា ទុក្ខ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា រោគ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា បូស បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា សរ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា លំបាក បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា អាពាធ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា ជារបស់អ្នកដទៃ បានដល់ អនត្តានុបស្សនា ។

ពាក្យថា វិនាស បានដល់ អនត្តានុបស្សនា ។

ពាក្យថា ចង្រៃ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា ឧបទ្រព បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា ភ័យ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា ឧបសគ្គ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា ញាប់ញ័រ បានដល់ អនិច្ចានុបស្សនា ។

ពាក្យថា បែកធ្លាយ បានដល់ អនិច្ចានុបស្សនា ។

ពាក្យថា មិនទៀង បានដល់ អនិច្ចានុបស្សនា ។

ពាក្យថា មិនមានទីជ្រកកោន បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មិនមានទីពួន បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មិនមានទីពឹង បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា ទីវាល បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា ទទេ បានដល់ អនត្តានុបស្សនា ។

ពាក្យថា សោះសូន្យ បានដល់ អនត្តានុបស្សនា ។

ពាក្យថា មិនមែនខ្លួន បានដល់ អនត្តានុបស្សនា ។

ពាក្យថា ទោស បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មានការប្រែប្រួលជាធម្មតា បានដល់ អនិច្ចានុបស្សនា ។

ពាក្យថា មិនមានខ្លឹម បានដល់ អនត្តានុបស្សនា ។

ពាក្យថា មានការលំបាកជាឫសគល់ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា ជាអ្នកសម្លាប់ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា ប្រាសចាកសេចក្តីចម្រើន បានដល់ អនិច្ចានុបស្សនា ។

ពាក្យថា ប្រកបដោយអាសវៈ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មានបច្ច័យប្រជុំតាក់តែង បានដល់ អនិច្ចានុបស្សនា ។

ពាក្យថា ជាអាមិសៈនៃមារ បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មានការកើតជាធម្មតា បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មានជរាជាធម្មតា បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មានព្យាធិជាធម្មតា បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មានសេចក្តីស្លាប់ជាធម្មតា បានដល់ អនិច្ចានុបស្សនា ។

ពាក្យថា មានសោកជាធម្មតា បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មានសេចក្តីខ្សឹកខ្សួលជាធម្មតា បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មានសេចក្តីចង្អៀតចង្អល់ជាធម្មតា បានដល់ ទុក្ខានុបស្សនា ។

ពាក្យថា មានសេចក្តីសៅហ្មងជាធម្មតា បានដល់ ទុក្ខានុបស្សនា ។

ភិក្ខុបានអនុលោមិកខន្តី ដោយអាការ ៤០ នេះ ចុះកាន់សម្មត្តនិយាម-ធម៌ ដោយអាការ ៤០ នេះ ។

កាលភិក្ខុបានអនុលោមិកខន្តី ដោយអាការ ៤០ នេះ ចុះកាន់សម្មត្តនិ-យាមធម៌ ដោយអាការ ៤០ នេះ តើអនិច្ចានុបស្សនាមានប៉ុន្មាន ទុក្ខានុប-ស្សនាមានប៉ុន្មាន អនត្តានុបស្សនាមានប៉ុន្មាន ។

អនត្តានុបស្សនាមាន ២៥ អនិច្ចានុបស្សនាមាន ៥០ វិប-ស្សនាទាំងឡាយណា ដែលព្រះមានព្រះភាគ សម្តែងចំពោះ ទុក្ខានុបស្សនាវិបស្សនានោះមាន ១២៥ ។

**ចប់ វិបស្សនាកថា ។**

# អដ្ឋកថា

# វិបស្សនាកថា

[ ២០២-២០៥ ] ឥឡូវនេះជាការពណ៌នាសេចក្ដីតាមលំដាប់ដែលមិនធ្លាប់ពោលក្នុងវិបស្សនាកថា ដែលមានព្រះសូត្រជាបទនាំ ដែលព្រះសារីបុត្តត្ថេរ កាលសម្ដែងប្រភេទនៃវិបស្សនា ពោលទុកហើយបន្ទាប់អំពីសតិប្បដ្ឋានកថាដែលប្រកបដោយវិបស្សនា ។

ក្នុងបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងព្រះសូត្រមុន ដូចតទៅនេះថា បទថា **សោ** ជាការសង្គ្រោះភិក្ខុទាំងអស់ ព្រោះជាសព្វនាម ។ បទថា **វត** ជានិបាតចុះក្នុងអត្ថឯកង្ស ( ដោយចំណែកមួយ ) ។ បទថា **កញ្ចិ សង្ខារំ** បានដល់ សង្ខារសូម្បីមានប្រមាណតិច ។ ក្នុងបទថា **អនុលោមិកាយ ខន្តិយា** នេះ មានវិនិច្ឆ័យដូចតទៅនេះថា វិបស្សនាញាណនោះឯង ឈ្មោះថា **អនុលោមិក** ព្រោះអត្ថថា អនុលោមតាមលោកុត្តរមគ្គ វិបស្សនាញាណនោះឯង ឈ្មោះថា **អនុលោមិកា** ព្រោះសម្ព័ន្ធដល់ខន្តិ ។ សង្ខារទាំងពួងរមែងពេញចិត្ត រមែងគាប់ចិត្តដល់វិបស្សនាញាណនោះដោយភាពជារបស់មិនទៀង ដោយភាពជាទុក្ខ ដោយភាពជាអនត្តា ព្រោះហេតុនោះវិបស្សនាញាណនោះ ឈ្មោះថា **ខន្តិ** ( ជាទីគាប់ចិត្ត ) ។ អនុលោមិកខន្តិមាន ៣ យ៉ាង គឺយ៉ាងទន់ ១ យ៉ាងកណ្ដាល ១ យ៉ាងចាស់ក្លា ១ ។ អនុលោមខន្តិដែលមានការពិចារណា ជាកលាបៈ ( កលាបសម្មសនញ្ញាណ ) ជាខាងដើម ជាអនុលោមខន្តិយ៉ាងទន់ ។ អនុលោមខន្តិ

ដែលមានកង្ខានុបស្សនាជាខាងដើម មានសង្ខារុបេក្ខាញាណជាទីបំផុត អ-នុលោមខន្តិយ៉ាងកណ្តាល ។ អនុលោមញាណ ឈ្មោះថា អនុលោមខន្តិយ៉ាងចាស់ក្លា ។ បទថា **សមន្នាគតោ** បានដល់ ចូលដល់ហើយ ។ បទថា **ឆេតំ ឋានំ វិជ្ជតិ** បានដល់ ឋានៈ គឺហេតុតាមដែលពោលហើយរមែងមិនមាន ។ ក្នុងបទនេះថា **សម្មត្តនិយាមំ** មានវិនិច្ឆ័យដូចតទៅនេះថា ឈ្មោះថា សម្មត្ត ព្រោះអត្ថថា ជាសភាពដោយប្រពៃ ព្រោះកាលបុគ្គលប្រាថ្នាយ៉ាងនេះថា វត្ថុនេះនឹងនាំប្រយោជន៍និងសេចក្តីសុខមកឲ្យដល់អញ ក៏កើតឡើងយ៉ាងនេះឯង និងព្រោះមានការប្រព្រឹត្តិទៅដែលមិនវិបរិតក្នុងវត្ថុមិនស្អាតជាដើមថា ជារបស់មិនស្អាត ជាដើម ឈ្មោះថា និយាម អធិប្បាយថា ការកាត់សម្រេច ព្រោះជាភាពពិតប្រាកដដោយការឲ្យផលក្នុងលំដាប់ និងដោយការកើតឡើងនៃព្រះអរហត្ត ។ សម្មត្តៈនោះផង និ-យាមផង ឈ្មោះថា សម្មត្តនិយាម ។ នោះគឺអ្វី គឺលោកុត្តរមគ្គ តែពោលដោយវិសេស ក៏គឺសោតាបត្តិមគ្គ ។ ពិតយ៉ាងនោះ លោកពោលថា នឹងបានត្រាស់ដឹងមគ្គផលតៗទៅទៀតជាប្រាកដ ដូច្នេះ ព្រោះពិតប្រាកដដោយមគ្គនិយាម ។ ចុះកាន់សម្មត្តនិយាមនោះ ។

បទថា **ឱក្កមិស្សតិ** បានដល់ នឹងចូលទៅ អធិប្បាយថា ប្រការនោះមិនមែនឋានៈ ម្យ៉ាងទៀត គប្បីជ្រាបថា ព្រោះគោត្រភូជាទីតាំងនៃអាវជ្ជនៈរបស់មគ្គ ទើបលោកមិនដាក់ចិត្តដល់គោត្រភូនោះ ហើយពោលដល់ការឈានចុះកាន់សម្មត្តនិយាមក្នុងលំដាប់នៃអនុលោមខន្តិ ។

ម្យ៉ាងវិញទៀត ក្នុងមហាវិបស្សនា ១៨ គោត្រភូជាវិវដ្ដនានុបស្សនា ព្រោះហេតុនោះ ទើបជាការសង្គ្រោះចូលក្នុងអនុលោមខន្តីនោះឯង ។ គប្បីជ្រាបអត្ថដោយន័យនេះឯង ក្នុងសូត្រទាំង ៤[១] ទុកក្នុងឆក្កនិបាត ព្រះមានព្រះភាគត្រាស់សូត្រ ៤[២] ទុកក៏ដោយសូត្រទាំងនេះ និងត្រាស់ថាជាធម៌ ៦ ប្រការ ក៏ដោយអំណាចអនុលោមខន្តី សម្មត្តនិយាមនិងអរិយផល ៤ ។ សេចក្ដីពិត សូត្រ ៤ រមែងមានដោយអំណាចទាំងពីរចំណែក គឺចំណែកខ្មៅនិងចំណែកស ។

[ ២០៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុត្តន្តនិទ្ទេសដែលមានពាក្យសួរ ជាបទនាំថា ដោយអាការប៉ុន្មានជាដើមដូចតទៅនេះថា ក្នុងបទថា **បញ្ចក្ខន្ធេ អនិច្ចតោ** ជាដើម សេចក្ដីថា ព្រះយោគាវចរដែលផ្ដើមវិបស្សនា ដោយអំណាចកំណត់នាមរូបនិងបច្ច័យនៃនាមរូបហើយពិចារណាជាកលាបៈ រមែងឃើញខន្ធនីមួយ ៗ ក្នុងខន្ធ ៥ ដោយភាពជារបស់មិនទៀង ព្រោះបញ្ចក្ខន្ធមានការមិនទៀងជាទីបំផុត និងព្រោះមានខាងដើមនិងខាងចុង ។

ជាទុក្ខ ព្រោះមានការកើតឡើងនិងបៀតបៀន និងព្រោះជាទីតាំងនៃទុក្ខ ។

ជារោគ ព្រោះមានជីវិតប្រព្រឹត្តទៅដោយបច្ច័យ និងព្រោះជាហេតុនៃរោគ ។

---

១-បិដក ៧១ យា ២០២ ដល់ យា ២០៥ ។

២-អង្គុនិកាយ ឆកនិាត សូត្រ ៤ គឺអនិច្ចសូត្រ ១ ទុកូត្រ ១ អនតូត្រ ១ និព្វាន-សូត្រ ១ ។

ជាបូស ព្រោះប្រកបដោយសេចក្តីទុក្ខ និងសេចក្តីចាក់ដោត ព្រោះមិនស្អាត គឺកិលេសហូរចេញ និងព្រោះហើមប៉ោង ហើយបែកធ្លាយដោយកើតចាស់ និងបែកធ្លាយ ។

ជាសរ ព្រោះឲ្យកើតការបៀតបៀន ព្រោះចាក់ដោតខាងក្នុង និងព្រោះនាំចេញបានដោយក្រ ។

ជារបស់លំបាក ព្រោះគួរតិះដៀល ព្រោះនាំការមិនចម្រើនមកឲ្យ និងព្រោះជាទីតាំងនៃសេចក្តីលំបាក ។

ជាអាពាធ ព្រោះឲ្យកើតការមិនមានសេរីនិងព្រោះជាទីតាំងនៃអាពាធ ។

ជារបស់ដទៃ ព្រោះមិនមានអំណាច និងព្រោះមិនស្តាប់បង្គាប់ ។

ជារបស់វិនាស ព្រោះទ្រុឌទ្រោមដោយព្យាធិ ជរានិងមរណៈ ។

ជារបស់ចង្រៃ ព្រោះនាំសេចក្តីវិនាសមិនតិចមកឲ្យ ។

ជាឧបទ្រព ព្រោះនាំសេចក្តីវិនាសច្រើនយ៉ាងដែលមិនដឹងហើយមកឲ្យ និងព្រោះជាវត្ថុនៃអន្តរាយទាំងពួង ។

ជាភ័យ ព្រោះជាប្រភពកើតនៃភ័យទាំងពួង និងព្រោះជាបដិបក្ខចំពោះសេចក្តីក្សេមដ៏ក្រៃលែង ពោលគឺស្ងប់ដោយក្រ ។

ជាឧបសគ្គ ព្រោះត្រូវសេចក្តីវិនាស មិនតិចជាប់តាម ព្រោះទាក់ទងដោយទោសៈ និងព្រោះអត់សង្កត់មិនបានដូចឧបសគ្គ ។

ជាគ្រឿងញាប់ញ័រ ព្រោះញាប់ញ័រដោយព្យាធិ ជរានិងមរណៈ និងដោយលោកធម៌ មានលាភជាដើម ។

ជាគ្រឿងបែកធ្លាយ ព្រោះមានប្រក្រតីចូលដល់ការបែកធ្លាយ ដោយសេចក្ដីព្យាយាម និងដោយសការៈរបស់ខ្លួន ។

មិនទៀង ( មិនឋិតថេរ ) ព្រោះត្រូវជកបោលទាំងអស់ និងព្រោះមិនមានការមាំទាំ ។

មិនមានទីជ្រកកោន ព្រោះជ្រកកោនមិនបាន និងព្រោះមិនបានទទួលភាពក្សេមក្សាន្ត ។

មិនមានទីពួន ព្រោះមិនគួរពឹងពាក់ និងព្រោះអ្នកពឹងពាក់ក៏ធ្វើកិច្ចនៃការការពារមិនបាន ។

មិនមានទីពឹង ព្រោះមិនមានវត្ថុជ្រកកោនអំពីភ័យសម្រាប់អ្នកអាស្រ័យ ។

ជារាល ព្រោះទទេចាកការទៀង សុខ ស្អាត និងតួខ្លួនតាមដែលកំណត់ទុក ។

ទទេ ព្រោះជារបស់ទទេនោះឯងឬព្រោះជារបស់តិច ពិតណាស់ របស់តិច លោកក៏ពោលថា ជារបស់ទទេក្នុងលោក ។

សោះសូន្យ ព្រោះប្រាសចាកម្ចាស់ដែលនៅអាស្រ័យ អ្នកសោយ អ្នកធ្វើនិងអ្នកតាំងចិត្ត ។

មិនមែនខ្លួន ព្រោះខ្លួនឯងមិនជាម្ចាស់ជាដើម ។

ជាទោស ព្រោះជាទុក្ខប្រចាំ និងព្រោះភាពដែលទុក្ខជាទោស ។

ម្យ៉ាងទៀត ឈ្មោះថា ទោស ព្រោះអត្ថថា ផ្សាយទូទៅ គឺប្រព្រឹត្តទៅកាន់ភាពខ្វះខាត ។ ពាក្យនេះជាឈ្មោះរបស់មនុស្សខ្វះខាត ម្យ៉ាងទៀត

សូម្បីខន្ធ ៥ ក៏ជាការខ្វះខាតដូចគ្នា ព្រោះហេតុនោះ ឈ្មោះថា ជាទោស ព្រោះដូចគ្នានឹងទោសនោះឯង ។

មានសេចក្តីប្រែប្រួលជាធម្មតា ព្រោះតាមប្រក្រតី ក៏ប្រែប្រួល ដោយចំណែកពីរ គឺដោយជរា និងមរណៈ ។

គ្មានខ្លឹម ព្រោះមិនមានកំលាំង និងព្រោះទម្លាយសេចក្តីសុខដូចក្រមរ ។

ជាឫសគល់នៃសេចក្តីលំបាក ព្រោះជាហេតុនៃសេចក្តីលំបាក ។

ជាអ្នកសម្លាប់ ព្រោះទម្លាយសេចក្តីស្និទ្ធស្នាល ដូចសត្រូវនិយាយថា ជាមិត្ត ។

មិនមានសេចក្តីចម្រើន ព្រោះអស់សេចក្តីចម្រើន និងព្រោះកើតនូវសេចក្តីវិនាស ។

ប្រកបដោយអាសវៈ ព្រោះជាទីតាំងនៃអាសវៈ ។

ជារបស់ដែលបច្ច័យប្រជុំតាក់តែង ព្រោះហេតុបច្ច័យតាក់តែង ។

ជាអាមិសៈនៃមារ ព្រោះជានុយរបស់មច្ចុមារ និងកិលេសមារ ។

មានការកើតជាធម្មតា ជរា ព្យាធិ មរណៈជាធម្មតា ព្រោះមានជាតិ ជរា ព្យាធិ និងមរណៈ ជាប្រក្រតី ។

មានសោកជាធម្មតា ខ្សឹកខ្សួល សេចក្តីចង្អៀតចង្អល់ ព្រោះមានសេចក្តីសោក ខ្សឹកខ្សួល និងការចង្អៀតចង្អល់ជាហេតុ ។

រមែងឃើញដោយភាពជារបស់មានសេចក្តីសៅហ្មងជាធម្មតា ព្រោះជាអារម្មណ៍នៃសេចក្តីសៅហ្មង គឺតណ្ហា ទិដ្ឋិនិងទុច្ចរិតជាធម្មតា ។

ម្យ៉ាងទៀត ក្នុងបទទាំងអស់នេះ គប្បីឃើញបាឋៈដ៏សេសថា រមែងឃើញដូច្នេះ ។ បទថា **បញ្ចក្ខន្ធេ** កាលពោលដោយរួម ក៏គប្បីជ្រាបថា លោកពោលពណ៌នាអត្ថ ដោយខន្ធនីមួយៗ ព្រោះចែកផ្សេងគ្នាក្នុងកលាបសម្មសនញ្ញាណនិទ្ទេស ព្រោះក្នុងទីបំផុតរបស់អនុបស្សនា ដោយអំណាចខន្ធទាំងឡាយចែកផ្សេង ៗ គ្នា និងព្រោះមានការប្រព្រឹត្តិទៅស្មើក្នុងចំណែកប្រកបនៃពាក្យដែលប្រព្រឹត្តទៅក្នុងការរួមគ្នា ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា លោកពោលថា ខន្ធ ៥ ដោយអំណាចការពោលសង្ខេបសម្មសនញ្ញាណដែលប្រព្រឹត្តទៅបែកផ្សេងៗគ្នា ( ឲ្យ ) រួមជាមួយគ្នា ។ ការពិចារណាដែលកើតអំពីពាក្យរបស់អដ្ឋកថាថា រមែងចេញចាកខន្ធ ៥ ព្រមគ្នា ឬការពិចារណាខន្ធ ៥ ដោយភាពជារបស់តែមួយ រមែងគួរនោះឯង ។

បទថា **បញ្ចន្នំ ខន្ធានំ និរោធោ និច្ចំ និព្វានន្តិ បស្សន្តោ** បានដល់ កាលពិចារណាឃើញថា និព្វានទៀង ដោយអំណាចនៃញាណដែលជាផ្លូវស្ងប់ ក្នុងកាលចម្រើនវិបស្សនាដោយន័យដូចពោលហើយក្នុងអាទីនវញ្ញាណនិទ្ទេស ។ បទថា **សម្មត្តនិយាមំ ឱក្កមតិ** បានដល់ រមែងឈមចុះក្នុងខណៈនៃមគ្គ ក៏ឈ្មោះថា ឈមចុះហើយក្នុងខណៈនៃផលផង ។ ក្នុងបរិយាយនៃការឈមចុះក្នុងនិយាមទាំងអស់ ក៏មានន័យនេះដូចគ្នា ។ បទថា **អារោគ្យំ** បានដល់ ការមិនមានរោគ ។ បទថា **វិសល្លំ** បានដល់ ប្រាសចាកសរ ក្នុងបទទាំងឡាយមានសភាពបែបនេះ ក៏មានន័យដូចគ្នា ។ បទថា **អនាពាធំ** បានដល់ ប្រាសចាកអាពាធ ឬជាបដិបក្ខចំពោះអាពាធ ។

ក្នុងបទទាំងឡាយមានសភាពបែបនេះ ក៏ន័យនេះ ។ បទថា **អបរប្បច្ចយំ** បានដល់ ប្រាសចាកបច្ច័យដទៃ អាចារ្យពួកខ្លះធ្វើការត្រួតអក្ខរៈ ពោលថា **ឧបស្សគ្គតោ** និងថា **អនុបស្សគ្គំ** ។ បទថា **បរមសុញ្ញំ** ឈ្មោះថា បរមសុញ្ញៈ ព្រោះសូន្យចាកសង្ខារទាំងអស់ និងព្រោះសូន្យដ៏កំពូល ។ បទថា **បរមត្ថំ** បានដល់ មានប្រយោជន៍ដ៏ឧត្តមព្រោះជារបស់ប្រសើរជាងសង្ខតនិងអសង្ខត ។ ជានបុំលិង្គដោយអំណាចលិង្គវិបល្លាស ។ លោកមិនពោលបរិយាយដោយបដិលោម ក្នុងបទទាំងពីរនេះ ព្រោះនិព្វានជារបស់សូន្យ និងជាអនត្តា ។ បទថា **អនាសវំ** បានដល់ ប្រាសចាកអាសវៈ ។ បទថា **និរាមិសំ** បានដល់ ប្រាសចាកអាមិស ។ បទថា **អជាតំ** បានដល់ មិនកើតឡើងព្រោះប្រាសចាកការកើត ។ បទថា **អមតំ** បានដល់ ប្រាសចាកការស្លាប់ ព្រោះមិនមានការបែកធ្លាយ ។ ពិតណាស់ សូម្បីសេចក្ដីស្លាប់ លោកក៏ពោលថា **មតំ** ដោយអំណាចជាពាក្យនបុំសកលិង្គ ។

[ ២០៧ ] ព្រះសារីបុត្តត្ថេរ ធ្វើការសង្គ្រោះអនុបស្សនា ៣ ក្នុងពេលតែមួយ ដោយអំណាចសង្គ្រោះតាមសភាវធម៌ក្នុងអនុបស្សនា ៤០ ដែលពោលហើយតាមលំដាប់ ដែលផ្សេងគ្នាដោយអាការយ៉ាងនេះ ទើបពោលបទថា **អនិច្ចតោតិ អនិច្ចានុបស្សនា** ជាដើម ។ គប្បីធ្វើការប្រកបក្នុងភាពមិនទៀង ជាទុក្ខ ជាអនត្តា តាមសមគួរក្នុងអនុបស្សនាទាំងនោះ ។

តែក្នុងទីបំផុតលោកសម្ដែងអនុបស្សនាទាំងនោះ ដោយការរាប់ផ្សេង ៗ គ្នា ។ ក្នុងការរាប់ទាំងនោះ ការរាប់អនត្តានុបស្សនាមុន ដោយអំណាច

លំដាប់នៃការរាប់ ( គិតទៅរកច្រើន ) ។ បទថា **បញ្ចវីសតិ** បានដល់ អនត្តានុបស្សនា ២៥ ក្នុងខន្ធ ៥ ដោយធ្វើខន្ធនីមួយ ៗ ជា ៥ គឺជារបស់ដទៃ ១ ជាទីវិាល ១ ទទេ ១ សោះសូន្យ ១ មិនមែនខ្លួន ១ ។

បទថា **បញ្ញាស** បានដល់ អនិច្ចានុបស្សនា ៥០ ក្នុងខន្ធ ៥ ដោយធ្វើខន្ធនីមួយ ៗ ជា ១០ គឺ មិនទៀង ( និច្ចតោ ) ១ ជារបស់វិនាស ១ ជាគ្រឿងញាប់ញ័រ ១ ជាគ្រឿងបែកធ្លាយ ១ មិនទៀង ( អទ្ធុវតោ ) ១ មានសេចក្តីប្រែប្រួលជាធម្មតា ១ គ្មានខ្លឹម ១ មិនមានសេចក្តីចម្រើន ១ ជារបស់ដែលបច្ច័យប្រជុំតាក់តែង ១ មានមរណៈជាធម្មតា ១ ។

បទថា **សតំ បញ្ចវីសតិ ចេវ** បានដល់ ទុក្ខានុបស្សនា ១២៥ ក្នុងខន្ធ ៥ ដោយធ្វើខន្ធនីមួយៗជា ២៥ មានពាក្យថាជាទុក្ខ ជារោគជាដើម ។ បទថា **យានិ ទុក្ខេ បវុច្ចរេ** គប្បីជ្រាបការភ្ជាប់សេចក្តីថា អនុបស្សនាដែលលោកពោលដោយការរាប់ ក្នុងខន្ធបញ្ចកៈ ដែលជាទុក្ខ មាន ១២៥ យ៉ាង ។ ម្យ៉ាងទៀត ក្នុងបទថា **យានិ** នេះ គប្បីឃើញថាជាលិង្គវិបល្លាស ។

## អដ្ឋកថាវិបស្សនាកថា ចប់

# សុត្តន្តបិដក

## បញ្ញាវគ្គ មាតិកាកថា

[ ២០៨ ] ពាក្យថា បុគ្គលមិនមានសេចក្តីស្រេកឃ្លាន រមែងរួច បាន ដល់វិមោក្ខ វិជ្ជា វិមុត្តិ អធិសីល អធិចិត្ត អធិប្បញ្ញា បស្សទ្ធិ ញាណ ទស្សនៈ សុទ្ធិ នេក្ខម្មៈ និស្សរណៈ បវិវេក វោស្សគ្គៈ ចរិយា ឈាន វិមោក្ខ ភាវនា អធិដ្ឋាននិងការរស់នៅ ។

ពាក្យថា មិនមានសេចក្តីស្រេកឃ្លាន គឺមិនមានសេចក្តីស្រេកឃ្លាន រមែងរួចចាកកាមច្ឆន្ទៈដោយនេក្ខម្មៈ មិនមានសេចក្តីស្រេកឃ្លាន រមែងរួចចាកព្យាបាទដោយមិនមានព្យាបាទ ។បេ។ មិនមានសេចក្តីស្រេកឃ្លានរមែងរួចចាកនីវរណៈដោយបឋមជ្ឈាន ។បេ។ មិនមានសេចក្តីស្រេកឃ្លានរមែងរួចចាកកិលេសទាំងពួងដោយអរហត្តមគ្គ ។

ពាក្យថា វិមោក្ខ សេចក្តីថា សភាវៈរួចចាកកាមច្ឆន្ទៈដោយនេក្ខម្មៈ ហេតុនោះឈ្មោះថា វិមោក្ខ សភាវៈរួចចាកព្យាបាទដោយមិនមានព្យាបាទ ហេតុនោះឈ្មោះថា វិមោក្ខ ។បេ។ សភាវៈរួចចាកនីវរណៈដោយបឋមជ្ឈាន ហេតុនោះឈ្មោះថា វិមោក្ខ ។បេ។ សភាវៈរួចចាកកិលេសទាំងពួងដោយអរហត្តមគ្គ ហេតុនោះឈ្មោះថា វិមោក្ខ ។

ពាក្យថា វិជ្ជាវិមុត្តិ គឺឈ្មោះថា វិជ្ជា ព្រោះដឹងនេក្ខម្មៈ ឈ្មោះថា វិមុត្តិ ព្រោះរួចចាកកាមច្ឆន្ទៈ ឈ្មោះថា វិជ្ជាវិមុត្តិ ព្រោះបុគ្គលកាលដឹងរមែងរួច កាលរួចរមែងដឹង ឈ្មោះថា វិជ្ជា ព្រោះដឹងអព្យាបាទ ឈ្មោះថា វិមុត្តិ

ព្រោះរួចចាកព្យាបាទ ឈ្មោះថា វិជ្ជាវិមុត្តិ ព្រោះបុគ្គលកាលដឹងរមែងរួច កាលរួចរមែងដឹង ។បេ។ ឈ្មោះថា វិជ្ជា ព្រោះដឹងអរហត្តមគ្គ ឈ្មោះថា វិមុត្តិ ព្រោះរួចចាកកិលេសទាំងពួង ឈ្មោះថា វិជ្ជាវិមុត្តិ ព្រោះបុគ្គលកាលដឹងរមែងរួច កាលរួចរមែងដឹង ។

[ ២០៩ ] ពាក្យថា អធិសីល អធិចិត្ត អធិប្បញ្ញា សេចក្តីថា សីលវិសុទ្ធិ ដោយអត្ថថា វាំងនូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ ចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ អត្ថនៃសេចក្តីសង្រួមណាក្នុងសីលវិសុទ្ធិនោះ នេះឈ្មោះថា អធិសីលសិក្ខា អត្ថនៃសេចក្តីមិនរាយមាយណាក្នុងចិត្តវិសុទ្ធិនោះ នេះឈ្មោះថា អធិចិត្តសិក្ខា អត្ថនៃសេចក្តីឃើញណា ក្នុងទិដ្ឋិវិសុទ្ធិនោះ នេះឈ្មោះថា អធិប្បញ្ញាសិក្ខា សីលវិសុទ្ធិ ដោយអត្ថថា វាំងនូវព្យាបាទ ដោយមិនមានព្យាបាទ ។បេ។ សីលវិសុទ្ធិ ដោយអត្ថថា វាំងនូវកិលេសទាំងពួងដោយអរហត្តមគ្គ ចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ អត្ថនៃសេចក្តីសង្រួមណា ក្នុងសីលវិសុទ្ធិនោះ នេះឈ្មោះថា អធិសីលសិក្ខា អត្ថនៃសេចក្តីមិនរាយមាយណាក្នុងចិត្តវិសុទ្ធិនោះ នេះឈ្មោះថា អធិចិត្តសិក្ខា អត្ថនៃសេចក្តីឃើញណាក្នុងទិដ្ឋិវិសុទ្ធិនោះ នេះឈ្មោះថា អធិប្បញ្ញាសិក្ខា ។

[ ២១០ ] ពាក្យថា បស្សទ្ធិ សេចក្តីថា បុគ្គលរម្ងាប់កាមច្ឆន្ទៈដោយនេក្ខម្មៈ រម្ងាប់ព្យាបាទដោយមិនមានព្យាបាទ ។បេ។ រម្ងាប់កិលេសទាំងពួងដោយអរហត្តមគ្គ ។

ពាក្យថា ញាណ សេចក្តីថា ឈ្មោះថា នេក្ខម្មៈ ព្រោះលះកាមច្ឆន្ទៈ ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹង ឈ្មោះថា អព្យាបាទ ព្រោះលះព្យាបាទ ។បេ។ ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹង ឈ្មោះថា អរហត្តមគ្គ ព្រោះលះកិលេសទាំងពួង ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹង ។

ពាក្យថា ទស្សនៈ សេចក្តីថា ឈ្មោះថា នេក្ខម្មៈ ព្រោះលះកាមច្ឆន្ទៈ ឈ្មោះថា ទស្សនៈ ព្រោះឃើញ ឈ្មោះថា អព្យាបាទ ព្រោះលះព្យាបាទ ឈ្មោះថា ទស្សនៈ ព្រោះឃើញ ។បេ។ ឈ្មោះថា អរហត្តមគ្គ ព្រោះលះកិលេសទាំងពួង ឈ្មោះថា ទស្សនៈ ព្រោះឃើញ ។

ពាក្យថា វិសុទ្ធិ សេចក្តីថា បុគ្គលកាលលះកាមច្ឆន្ទៈ រមែងបរិសុទ្ធិដោយនេក្ខម្មៈ កាលលះព្យាបាទរមែងបរិសុទ្ធិដោយអព្យាបាទ ។បេ។ កាលលះកិលេសទាំងពួង រមែងបរិសុទ្ធិដោយអរហត្តមគ្គ ។

[ ២១១ ] ពាក្យថា នេក្ខម្មៈ សេចក្តីថា ការរលាស់ចេញនូវកាម គឺនេក្ខម្មៈ ការរលាស់ចេញនូវរូប គឺអារុប្បៈ ធម្មជាតណាទីមួយកើតហើយដែលបច្ច័យប្រជុំតាក់តែង កើតព្រោះបច្ច័យ និងការរលត់វិញ ឈ្មោះថា នេក្ខម្មៈនៃធម្មជាតនោះ អព្យាបាទឈ្មោះថានេក្ខម្មៈនៃព្យាបាទ អាលោកសញ្ញាឈ្មោះថានេក្ខម្មៈនៃថីនមិទ្ធៈ ។បេ។

ពាក្យថា និស្សរណៈ សេចក្តីថា ការរលាស់ចេញនូវកាម គឺនេក្ខម្មៈ ការរលាស់ចេញនូវរូប គឺអារុប្បៈ ធម្មជាតណាទីមួយកើតហើយដែលបច្ច័យប្រជុំតាក់តែង កើតព្រោះបច្ច័យ និងការរលត់វិញ ឈ្មោះថានិស្សរណៈនៃ

ធម្មជាតនោះ នេក្ខម្មៈឈ្មោះថានិស្សរណៈនៃកាមច្ឆន្ទៈ អព្យាបាទឈ្មោះថានិស្សរណៈនៃព្យាបាទ ។បេ។ អរហត្តមគ្គឈ្មោះថានិស្សរណៈនៃកិលេសទាំងពួង ។

ពាក្យថា បវិវេក សេចក្តីថា នេក្ខម្មៈជាបវិវេក ( ការស្ងប់ស្ងាត់ ) នៃកាមច្ឆន្ទៈ អព្យាបាទជាបវិវេកនៃព្យាបាទ ។បេ។ អរហត្តមគ្គជាបវិវេកនៃកិលេសទាំងពួង ។

ពាក្យថា វោស្សគ្គៈ សេចក្តីថា បុគ្គលលះកាមច្ឆន្ទៈដោយនេក្ខម្មៈ លះព្យាបាទដោយមិនមានព្យាបាទ ។បេ។ លះកិលេសទាំងពួង ដោយអរហត្ត-មគ្គ ។

ពាក្យថា ចរិយា ( ការប្រព្រឹត្តិ ) សេចក្តីថា បុគ្គលកាលលះកាមច្ឆន្ទៈប្រព្រឹត្តដោយនេក្ខម្មៈ កាលលះព្យាបាទប្រព្រឹត្តដោយមិនមានព្យាបាទ ។បេ។ កាលលះកិលេសទាំងពួង ប្រព្រឹត្តដោយអរហត្តមគ្គ ។

ពាក្យថា ឈានវិមោក្ខ សេចក្តីថា ឈ្មោះថា ឈាន ព្រោះនេក្ខម្មៈកើត ឈ្មោះថា ឈាន ព្រោះដុតកាមច្ឆន្ទៈ ឈ្មោះថា ឈានវិមោក្ខ ព្រោះកាលកើតរមែងរួច ឈ្មោះថា ឈានវិមោក្ខ ព្រោះកាលដុត រមែងរួច ឈ្មោះថា ធម៌ ព្រោះកើត ព្រោះដុត ឈ្មោះថា ឈានវិមោក្ខ ព្រោះដឹងនូវកិលេសទាំងឡាយដែលកើតហើយផង ដែលឆេះហើយផង ឈ្មោះថា ឈាន ព្រោះអព្យាបាទកើត ឈ្មោះថា ឈាន ព្រោះដុតព្យាបាទ ឈ្មោះថា ឈាន ព្រោះអាលោកសញ្ញាកើត ។បេ។ ឈ្មោះថា ឈាន ព្រោះ

ដុតបីនមិទ្ធៈ ។បេ។ ឈ្មោះថា ឈាន ព្រោះអរហត្តមគ្គកើត ឈ្មោះថា ឈាន ព្រោះដុតកិលេសទាំងពួង ឈ្មោះថា ឈានវិមោក្ខ ព្រោះកាលកើតរមែងរួច ឈ្មោះថា ឈានវិមោក្ខ ព្រោះកាលដុតរមែងរួច ឈ្មោះថា ធម៌ព្រោះកើត ព្រោះដុត ឈ្មោះថា ឈានវិមោក្ខ ព្រោះដឹងកិលេសទាំងឡាយដែលកើតហើយផង ដែលឆេះហើយផង ។

[ ២១២ ] ពាក្យថា ភាវនា អធិដ្ឋាននិងការរស់នៅ សេចក្តីថា បុគ្គលឈ្មោះថាអ្នកបរិបូរណ៍ដោយភាវនា ព្រោះលះកាមច្ឆន្ទៈចម្រើនទេក្ខម្មៈ ឈ្មោះថា អ្នកបរិបូរណ៍ដោយអធិដ្ឋាន ព្រោះអធិដ្ឋានចិត្ត ដោយអំណាចនេក្ខម្មៈ ឈ្មោះថា អ្នកបរិបូរណ៍ដោយអាជីវៈ ព្រោះបុគ្គលដែលបរិបូរណ៍ដោយភាវនា បរិបូរណ៍ដោយអធិដ្ឋាន យ៉ាងនេះនោះឯង រមែងរស់នៅស្មើ មិនមែនមិនស្មើទេ រស់នៅដោយត្រឹមត្រូវ មិនមែនដោយខុសទេ រស់នៅបរិសុទ្ធិ មិនមែនសៅហ្មងទេ បុគ្គលដែលបរិបូរណ៍ដោយភាវនា បរិបូរណ៍ដោយអធិដ្ឋាន បរិបូរណ៍ដោយអាជីវៈ យ៉ាងនេះនោះឯង ចូលទៅរកបរិស័ទណា ទោះខត្តិយ-បរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិបរិស័ទក្តី សមណបរិស័ទក្តី ក៏ជាអ្នកក្លាហានចូលទៅរក មិនមានអៀនអន់ ដំណើរនោះព្រោះហេតុអ្វី ព្រោះថា បុគ្គលនោះបរិបូរណ៍ដោយភាវនា បរិបូរណ៍ដោយអធិដ្ឋាន បរិបូរណ៍ដោយអាជីវៈ ឈ្មោះថា អ្នកបរិបូរណ៍ដោយភាវនា ព្រោះលះព្យាបាទ ចម្រើនអ-ព្យាបាទ ឈ្មោះថា អ្នកបរិបូរណ៍ដោយភាវនា ព្រោះលះថីនមិទ្ធៈ ចម្រើនអាលោកសញ្ញា ឈ្មោះថា អ្នកបរិបូរណ៍ដោយភាវនា ព្រោះលះឧទ្ធច្ចៈចម្រើន

សេចក្តីមិនរាយមាយ ឈ្មោះថា អ្នកបរិបូរណ៍ដោយការនៃ ព្រោះលះវិចិ-កិច្ឆាចម្រើនការកំណត់នូវធម៌ ឈ្មោះថា អ្នកបរិបូរណ៍ដោយការនៃ ព្រោះលះអវិជ្ជាចម្រើនញាណ ឈ្មោះថាអ្នកបរិបូរណ៍ដោយការនៃ ព្រោះលះអរតិចម្រើនបាមុជ្ជៈ ឈ្មោះថា អ្នកបរិបូរណ៍ដោយការនៃ ព្រោះលះនីវរណៈចម្រើនបឋមជ្ឈាន ។បេ។ ឈ្មោះថា អ្នកបរិបូរណ៍ដោយការនៃ ព្រោះលះកិលេសទាំងពួងចម្រើនអរហត្តមគ្គ ឈ្មោះថា អ្នកបរិបូរណ៍ដោយអធិដ្ឋាន ព្រោះអធិដ្ឋានចិត្ត ដោយអំណាចអរហត្តមគ្គ ឈ្មោះថា អ្នកបរិបូរណ៍ដោយអាជីវៈ ព្រោះបុគ្គលដែលបរិបូរណ៍ដោយការនៃ បរិបូរណ៍ដោយអធិដ្ឋានយ៉ាងនេះនោះឯង តែងរស់នៅស្មើ មិនមែនមិនស្មើទេ រស់នៅដោយត្រឹមត្រូវ មិនមែនដោយខុសទេ រស់នៅបរិសុទ្ធិ មិនមែនសៅហ្មងទេ បុគ្គលដែលបរិបូរណ៍ដោយការនៃ បរិបូរណ៍ដោយអធិដ្ឋាន បរិបូរណ៍ដោយអាជីវៈយ៉ាងនេះនោះឯង ចូលទៅរកបរិស័ទណា ទោះខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិបរិស័ទក្តី សមណបរិស័ទក្តី ក៏ជាអ្នកក្លាហានចូលទៅរក មិនមានអៀនអន់ ដំណើរនោះព្រោះហេតុអ្វី ព្រោះថាបុគ្គលនោះបរិបូរណ៍ដោយការនៃ បរិបូរណ៍ដោយអធិដ្ឋាន បរិបូរណ៍ដោយអាជីវៈ ។

**ចប់ មាតិកកថា ។**

**ចប់ បដិសម្ភិទាបករណៈ ។**

## ឧទ្ទានក្នុងបដិសម្ភិទាបករណៈនោះគឺ

ញាណ ១ ទិដ្ឋិ ១ អស្សាសៈ ១ ឥន្ទ្រិយ ១ ជាគម្រប់ ៥ នឹងវិមោក្ខ គតិ ១ កម្ម ១ វិបល្លាស ១ មគ្គ ១ ជាគម្រប់ ១០ នឹងមណ្ឌៈ យុគនទ្ធៈ ១ សច្ចៈ ១ ពោជ្ឈង្គ ១ មេត្តា ១ ជាគម្រប់ ៥ នឹងវិរាគៈ បដិសម្ភិទា ១ ធម្មចក្ក ១ លោកុត្តរៈ ១ ពលៈ ១ ជាគម្រប់ ១០ នឹងសុញ្ញៈ បញ្ញា ១ ឥទ្ធិ ១ អភិសមយៈ ១ វិវេក ១ ជាគម្រប់ ៥ នឹងចរិយា បាដិហារិយៈ ១ សមសីសៈ ១ សតិប្បដ្ឋាន ១ វិបស្សនា ១ ជាគម្រប់ ១០ នឹងមាតិកា ។ វគ្គទាំង ៣ ដែលមានក្នុងបដិសម្ភិទាបរកណៈ ជាវគ្គដ៏ទូលាយជ្រាលជ្រៅ ក្នុងផ្លូវមានន័យ មិនមានទីបំផុត មានឧបមាដោយសាគរ ឬដូចពពកដែលដេរដាសដោយផ្កាយឬក៏ដូចជាតស្រះដ៏ទូលាយ ជាវគ្គបំភ្លឺញាណ របស់ពួកព្រះយោគី ទាំងដើម្បីទូលាយ ( គំនិត ប្រាជ្ញា ស្មារតី ) របស់ពួកលោកអ្នកសម្តែងធម៌ ។

## ចប់ បដិសម្ភិទាតែប៉ុណ្ណេះ

# អដ្ឋកថា

## មាតិកាកថា

[ ២០៨ ] ឥឡូវនេះ ព្រះមហាថេរៈបំណាន់នឹងសរសើរធម៌ គឺសមថៈ វិបស្សនា មគ្គ និព្វាន ដែលលោកសម្តែងទុកហើយក្នុងបដិសម្ភិទាមគ្គទាំងអស់ បន្ទាប់អំពីវិបស្សនាកថាដោយបរិយាយផ្សេងៗ ដោយការផ្សេងគ្នានៃអាការ ទើបលើកបទមាតិកា ១៩ មានបទថា **និច្ឆាតោ** ជាដើម ហើយពោលមាតិកាកថា ដោយចង្អុលបង្ហាញបទមាតិកាទាំងនោះ ។ បន្ទាប់អំពីនេះទៅនឹងពណ៌នាសេចក្តីតាមលំដាប់ ដែលមិនធ្លាប់ពណ៌នានៃមាតិកាកថានោះ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងមាតិកាមុន បទថា **និច្ឆាតោ** បានដល់បុគ្គលមិនមានសេចក្តីស្រេកឃ្លាន ។ ពិតណាស់ កិលេសសូម្បីទាំងអស់ឈ្មោះថា **ឆាតា** ព្រោះប្រកបដោយការបៀតបៀនក្នុងខាងដើម សូម្បីរាគៈដែលប្រព្រឹត្តទៅមិនដាច់ ក៏ដុតរាងកាយ នឹងពោលទៅថ្វីដល់កិលេសដទៃ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់កិលេសទុក ៣ យ៉ាង ដែលជាប្រធានរបស់កិលេស ( ក្នុងខុទ្ទកនិកាយឥតិវុត្តក ) ថា ម្នាលភិក្ខុទាំងឡាយ ភ្លើងនេះមាន ៣ យ៉ាង ។ ភ្លើងគឺរាគៈ ១ ភ្លើងគឺទោសៈ ១ ភ្លើងគឺមោហៈ ១ ដូច្នេះ ។ សូម្បីកិលេសដែលប្រកបដោយរាគៈ ទោសៈ មោហៈនោះ ក៏រមែងដុតរោលដូចគ្នា ។ ឈ្មោះថា **និច្ឆាតោ** ព្រោះមិនមានកិលេសដែលកើតហើយយ៉ាងនេះ ។ បុគ្គលមិនមានការស្រេកនោះ គឺអ្វី ។ គប្បីឃើញថា ជាវិមោក្ខដោយការពាក់ព័ន្ធនិងការរួចផុត ។ ឈ្មោះ

ថា មោក្ខោ ព្រោះអត្ថថា ផុត ឈ្មោះថា វិមោក្ខោ ព្រោះអត្ថថា រួចផុត ។ នេះជាបទមាតិកា ១ បទ ។ បទថា **វិជ្ជាវិមុត្តិ** បានដល់ វិមុត្តិ គឺវិជ្ជា នេះជាបទមាតិកា ១ បទ ។ បទថា **ឈានវិមោក្ខោ** បានដល់ វិមោក្ខ គឺឈាន ។ នេះជាបទមាតិកា ១ បទ ។ បទមាតិកាដ៏សេសជាបទចំពោះមួយបទៗ ព្រោះហេតុនោះទើបជាបទមាតិកា ១៩ បទដោយប្រការដូច្នេះ ។

បទថា **នេក្ខម្មេន កាមច្ឆន្ទតោ និច្ចាតោ** បានដល់ ព្រះយោគាវចរអ្នកមិនមានកិលេស រមែងរួចផុតចាកកាមច្ឆន្ទៈ ព្រោះប្រាសចាកកាមច្ឆន្ទៈដោយនេក្ខម្មៈ សូម្បីនេក្ខម្មៈ ដែលព្រះយោគាវចរនោះបាន ក៏អស់សេចក្តីស្រេកឃ្លាន មិនមានកិលេសជាការរួចផុត ។ សូម្បីក្នុងបទដ៏សេសក៏យ៉ាងនោះ ។

បទថា **នេក្ខម្មេន កាមច្ឆន្ទតោ មុច្ចតីតិ វិមោក្ខោ** សេចក្តីថា ព្រះយោគាវចររមែងផុតចាកកាមច្ឆន្ទៈដោយនេក្ខម្មៈ ព្រោះហេតុនោះ នេក្ខម្មៈនោះ ទើបជាវិមោក្ខ សូម្បីក្នុងបទដ៏សេសក៏យ៉ាងនោះ ។

បទថា **វិជ្ជតីតិ វិជ្ជា** សេចក្តីថា នេក្ខម្មៈឈ្មោះថា វិជ្ជា ព្រោះអត្ថថា មាន នៅមាន រកបានដោយសភាវៈ ។ មួយវិញទៀត សេចក្តីថា នេក្ខម្មៈឈ្មោះថាវិជ្ជា ព្រោះអត្ថថា ដែលព្រះយោគាវចរអ្នកបដិបត្តិដើម្បីដឹងសេចក្តីពិត រមែងដឹងច្បាស់ រមែងដឹងសេចក្តីពិត ។ មួយវិញទៀត ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ដែលព្រះយោគាវចរ អ្នកបដិបត្តិ ដើម្បីបានគុណវិសេស រមែងសោយ រមែងបាន ។ មួយវិញទៀត ឈ្មោះថា វិជ្ជា ព្រោះអត្ថថា

ព្រះយោគាវចររមែងប្រសព្វ រមែងបានកូមិដែលខ្លួនគួរប្រសព្វ ។ម្យ៉ាង ទៀត ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ព្រះយោគាវចររមែងធ្វើការដឹងច្បាស់សភាវធម៌ ព្រោះមានការឃើញសភាវធម៌ជាហេតុ ។

បទថា **វិជ្ជន្តោ មុច្ចតិ មុច្ចន្តោ វិជ្ជតិ** អធិប្បាយថា ឈ្មោះថា វិជ្ជា-វិមុត្តិ ព្រោះអត្ថថា ធម៌តាមដែលពោលហើយ មានដោយអត្ថតាមដែលពោលហើយ រមែងរួចផុតចាកធម៌តាមដែលពោលហើយ កាលរួចផុតចាកធម៌តាមដែលពោលហើយ រមែងមានដោយអត្ថតាមដែលពោលហើយ ។

[ ២០៩ ] បទថា **កាមច្ឆន្ទំ សំវរដ្ឋេន** សេចក្តីថា នេក្ខម្មៈនោះ ឈ្មោះថា សីលវិសុទ្ធិ ព្រោះអត្ថថា ជាគ្រឿងហាមកាមច្ឆន្ទៈ ។ នេក្ខម្មៈ ឈ្មោះថា ចិត្តវិសុទ្ធិ ព្រោះអត្ថថា ជាហេតុមិនរាយមាយ ព្រោះជាហេតុនៃការមិនរាយមាយ ។ ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ព្រោះអត្ថថា ជាគ្រឿងឃើញ ព្រោះហេតុនៃការឃើញ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

[ ២១០ ] បទថា **បដិប្បស្សម្ភេតិ** សេចក្តីថា ធម៌មាននេក្ខម្មៈជាដើម ឈ្មោះថា បស្សទ្ធិ ព្រោះជាគ្រឿងរម្ងាប់កាមច្ឆន្ទៈជាដើមនៃព្រះយោគាវចរ ។ បទថា **បហីនត្តា** បានដល់ ព្រោះជាហេតុ ឲ្យលះដោយការលះនោះៗ ។ បទថា **ញាតដ្ឋេន ញាណំ** សេចក្តីថា នេក្ខម្មៈជាដើម ឈ្មោះថា ញាណ ដោយអត្ថថា ដឹង ដោយអំណាចពិចារណាឈាន វិបស្សនា មគ្គ ។ សូម្បីក្នុងបទនេះថា **ទិដ្ឋត្តា ទស្សនំ** ជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **វិសុជ្ឈន្តិ** សំដៅដល់ព្រះយោគាវចរ ។ គឺការបរិសុទ្ធ មាននេក្ខម្មៈជាដើម ។

[ ២១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនេក្ខម្មនិទ្ទេស ដូចតទៅនេះថា នេក្ខម្មៈ ឈ្មោះថា និស្សរណៈ ព្រោះរលាស់ចេញចាកកាមរាគៈព្រោះមិនមានលោភៈ ឈ្មោះថា នេក្ខម្មៈ ព្រោះចេញចាកកាមរាគៈនោះ ។ កាលគួរពោលថា នេក្ខម្មៈជាគ្រឿងរលាស់រូប លោកត្រឡប់ជាពោលថា អរូបតាមលំដាប់នៃបាលីដែលពោលទុកហើយ ក្នុងទីដទៃនោះឯង ដើម្បីសម្ដែងភាពផ្សេងគ្នា ព្រោះការផ្សេងគ្នានៃអរូបមិនប្រាកដ ។ ម្យ៉ាងទៀត មានអធិប្បាយដោយអំណាចនៃអធិការនោះឯងថា អរូបនោះ ឈ្មោះថា នេក្ខម្មៈ ព្រោះចេញចាករូប ។

បទថា **ភូតំ** ជាពាក្យសម្ដែងដល់ការប្រកបវត្ថុដែលកើតឡើង ។ បទថា **សង្ខតំ** ជាពាក្យសម្ដែងដល់សេចក្ដីវិសេសនៃកម្លាំងបច្ច័យ ។ បទថា **បដិច្ចសមុប្បន្នំ** ជាពាក្យសម្ដែងដល់ភាពដែលបច្ច័យទាំងឡាយ មិនមានសេចក្ដីព្យាយាមក្នុងភាពជាបច្ច័យប្រកប ។ បទថា **និរោធោ តស្ស នេក្ខម្មំ** បានដល់ និព្វាន ឈ្មោះថាជាគ្រឿងចេញចាកវត្ថុដែលតាក់តែងនោះ ព្រោះចេញចាកវត្ថុដែលតាក់តែងនោះ ។ ការប្រារព្ធអរូបនិងនិរោធលោកធ្វើហើយតាមលំដាប់ដែលពោលហើយក្នុងបាលីក្នុងទីដទៃ ។ កាលពោលថា នេក្ខម្មៈជានេក្ខម្មៈចាកកាមច្ឆន្ទៈក៏ជាការពោលដដែលទៀត ។ ដោយពាក្យថា នេ-ក្ខម្មៈនោះឯង រមែងជាការសម្រេចការចេញចាកកាមច្ឆន្ទៈនោះ ព្រោះហេតុនោះ ទើបលោកមិនពោលសេចក្ដីនោះ តែពោលដល់នេក្ខម្មៈដ៏សេស ។ សេចក្ដីនោះត្រឹមត្រូវហើយ ។ ក្នុងនិស្សរណនិទ្ទេស ក៏គប្បីជ្រាបសេចក្ដី

ដោយន័យនេះឯង ។ តែក្នុងនិទ្ទេសនេះលោកពោលថា ធាតុដែលជាគ្រឿងរលាស់ចេញជាទេក្ខម្មៈដោយត្រង់នោះឯង ។

បទថា **បរិវេកោ** បានដល់ ការស្ងាត់គឺនេក្ខម្មៈជាដើមនោះឯង ។ បទថា **វោសជ្ជតិ** បានដល់ យោគី ។ នេក្ខម្មៈជាដើម ជាវោស្សគ្គៈ ។ ព្រះយោគាវចរ ដែលប្រព្រឹត្តនេក្ខម្មៈ លោកហៅថា ប្រព្រឹត្តដោយនេក្ខម្មៈ ។ ម្យ៉ាងទៀត នេក្ខម្មៈនោះជាចរិយា ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។ ពាក្យដែលគួរពោលទុកក្នុងឈានវិមោក្ខនិទ្ទេស ខ្ញុំក៏ពោលទុកក្នុងវិមោក្ខកថាហើយ គ្រាន់តែក្នុងវិមោក្ខកថានោះ លោកពោលថា ឈ្មោះថា ឈានវិមោក្ខោ ព្រោះអត្ថថា រមែងដឹង តែក្នុងនិទ្ទេសនេះ មានសេចក្តីប្លែកថា លោកសម្តែងជាបុគ្គលាធិដ្ឋានថា **ជាយតិ** ( កើត ) ។

[ ២១២ ] ក្នុងភាវនាធិដ្ឋានជីវិតនិទ្ទេស លោកសម្តែងជាបុគ្គលាធិដ្ឋាន ។ តែតាមធម្មតានេក្ខម្មៈជាដើមនោះឯង ឈ្មោះថា ភាវនា ។ ចិត្តដែលតាំងទុកដោយនេក្ខម្មៈជាដើម ឈ្មោះថា អធិដ្ឋាន ។ សម្មាអាជីវៈ របស់អ្នកមានចិត្តតាំងទុកដោយនេក្ខម្មៈជាដើម ឈ្មោះថា ជីវិត ។ សម្មាអាជីវៈនោះតើដូចម្តេច ការវៀរចាកមិច្ឆាជីវៈនិងសេចក្តីព្យាយាម ស្វែងរកបច្ច័យដោយធម៌ស្មើ ។

ក្នុងបទទាំងនោះ បទថា **សមំ ជីវតិ** បានដល់ មានជីវិតយ៉ាងស្ងប់ ឬជាពាក្យនបុំសកលិង្គសម្ដែងការៈ មានពាក្យអធិប្បាយថា រស់នៅដោយស្មើ ។ បទថា **នោ វិសមំ** លោកធ្វើការហាមសេចក្ដីដោយបដិសេធភាព ដែលពោលថា រមែងរស់នៅស្មើ ។ បទថា **សម្មា ជីវតិ** ជាពាក្យបន្ថែមបង្ហាញអាការ ។ បទថា **នោ មិច្ឆា** ជាការកំណត់ការរស់នៅនោះឯង ។ បទថា **វិសុទ្ធំ ជីវតិ** បានដល់ មានជីវិតរស់នៅបរិសុទ្ធិដោយបរិសុទ្ធិតាមសភាវៈ ។ បទថា **នោ កិលិដ្ឋំ** ជាការកំណត់ការរស់នៅនោះឯង ។ ព្រះសារីបុត្តត្ថេរ សម្ដែងអានិសង្សនៃសម្បទា ៣ តាមដែលពោលហើយដោយញាណសម្បត្តិ ដោយមានបទថា **យញ្ញទេវ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **យញ្ញទេវ** កាត់បទថា **យំ យំ ឯវ** ។

បទថា **ខត្តិយបរិសំ** បានដល់ ទីប្រជុំពួកក្សត្រ ។ លោកពោលថា បរិស័ទ ព្រោះជាទីអង្គុយប្រជុំដោយជុំវិញនៃបុគ្គល មិនចាំបាច់ប្រើការជីងអ្វីឡើយ ។ ក្នុងបរិស័ទ ៣ ទៀតក្រៅអំពីនេះ ក៏មានន័យនេះដូចគ្នា ។ ការប្រារព្ធបរិស័ទទាំង ៤ នោះ ព្រោះក្សត្រជាដើមនោះឯងប្រកបដោយអាគមសម្បត្តិនិងញាណសម្បត្តិ មិនបានប្រារព្ធដល់បរិស័ទ របស់ពួកសូទ្រៈ ។

បទថា **វិសារទោ** បានដល់ ដល់ព្រមដោយបញ្ញា ប្រាសចាកការតក់ស្លុត គឺមិនខ្លាច ។ បទថា **អមង្កុភូតោ** បានដល់ មិនអៀនអន់ មានការអាចហ៊ាន ។ បទថា **តំ កិស្ស ហេតុ** អធិប្បាយថា បើសួរថា ភាពជាអ្នកក្លាហាននោះ រមែងកើតព្រោះហេតុអ្វី ព្រោះការណ៍អ្វី ។ ឥឡូវនេះជាការពោលដល់ហេតុនៃការក្លៀវក្លានោះថា **តថា ហិ** ។ ព្រោះជាអ្នកដល់ព្រមដោយសម្បទា ៣ យ៉ាងនេះ ( ភាវនា អធិដ្ឋាន អាជីវៈ ) ហេតុនោះទើបជាអ្នកអង់អាច ព្រោះហេតុនោះទើបព្រះសារីបុត្តត្ថេរ សម្ដែងដល់ហេតុនៃភាពជាអ្នកអង់អាច ហើយញ៉ាំងមាតិកាកថាឲ្យចប់ដោយប្រការដូច្នេះ ។

អដ្ឋកថាមាតិកាកថា ចប់

អដ្ឋកថាបដិសម្ភិទាមគ្គ ឈ្មោះថា សទ្ធម្មប្បកាសិនី ចប់

ការពណ៌នាសេចក្ដីតាមលំដាប់ ដែលមិនធ្លាប់ពណ៌នានៃចូឡវគ្គ ចប់ អដ្ឋកថាបដិសម្ភិទាមគ្គដែលប្រដាប់ដោយកថា ៣០ សង្គ្រោះចូលក្នុង ៣ វគ្គ ចប់ហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

# និគមកថា

ក្នុងបដិសម្ភិទាមគ្គនេះ ព្រះសារីបុត្តត្ថេរពោលទុក ៣ វគ្គ តាមលំដាប់នៃខ្នាតដោយឈ្មោះថា មហាវគ្គ មជ្ឈិមវគ្គ និងចូឡវគ្គ ។ ក្នុងវគ្គនីមួយៗ លោកសម្ដែងទុកមួយវគ្គ ១០ កថា ការពណ៌នាកថាដែលរួមទុកក្នុងវគ្គទាំងនេះ លោកសម្ដែងតាមលំដាប់នៃកថាទាំងនោះ ។

កថាទាំងនេះមាន ១០ គឺ ញាណកថា ១ ទិដ្ឋិកថា ១ អានាបានកថា ១ ឥន្ទ្រិយកថា ១ វិមោក្ខកថាជាគម្រប់ ៥ គតិកថា ១ កម្មកថា ១ វិបល្លាសកថា ១ មគ្គកថា ១ មណ្ឌបេយ្យកថា ១ រួមជា ១០ កថា ។

កថាតទៅនេះ គឺយុគនទ្ធកថា ១ សច្ចកថា ១ ពោជ្ឈង្គកថា ១ មេត្តាកថា ១ វិរាគកថាជាគម្រប់ ៥ បដិសម្ភិទាកថា ១ ធម្មចក្កកថា ១ លោកុត្តរកថា ១ ពលកថា ១ សុញ្ញតាកថា ១ ។

បញ្ញាកថា ១ ឥទ្ធិកថា ១ អភិសមយកថា ១ វិវេកកថា ១ ចរិយាកថាជាគម្រប់ ៥ បាដិហារិយកថា ១ សមសីសកថា ១ សតិប្បដ្ឋានកថា ១ វិបស្សនាកថា ១ មាតិកាកថា ១ ។

ព្រះថេរៈដែលជាធំជាងសាវកដែលស្ដាប់មកអំពីព្រះសុគត អ្នកត្រេកអរក្នុងការធ្វើប្រយោជន៍ដល់សត្វ អ្នកមានគុណដ៏មាំទាំ ពោលបដិសម្ភិទាមគ្គណាទុកហើយ អដ្ឋកថាបដិសម្ភិទាមគ្គនោះ ខ្ញុំផ្ដើមរចនាដោយអាស្រ័យន័យរបស់អដ្ឋកថាមុនៗជាគោលយ៉ាងនោះ ទើបអដ្ឋកថានោះដល់នូវការសម្រេច ។

លោកអ្នកមានបញ្ញាក្រៃលែង ជាអ្នកប្រកបដោយគុណ គឺបញ្ញាប្រកបដោយសទ្ធា បានសាងបរិវេណដែលមានគុណប្រយោជន៍មិនមែនតិច ក្នុង

មហាវិហារនោះឯណា ព្រះថេរៈដែលអាស្រ័យនៅក្នុងវិហារនេះ ជាអ្នកមានឈ្មោះ ពោះសាំឡេង បានរចនាអដ្ឋកថានេះទុកក្នុងឆ្នាំទី ៣ បន្ទាប់អំពីការសោយទិវង្គតរបស់ស្តេចផែនដី ព្រះនាមថា មោគ្គល្លាន ។ អដ្ឋកថានេះអនុលោមតាមលទ្ធិសម័យរបស់ព្រះថេរទាំងឡាយ ដែលជាប្រទីបខាងថេរវាទ ដែលញ៉ាំងប្រយោជន៍ឲ្យកើតដល់សត្វលោក ដល់នូវការសម្រេចហើយដោយប្រការណា សូមមនោរថអនុលោមតាមធម៌ដែលឲ្យសម្រេចប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃ ចូរដល់នូវការសម្រេចដល់សត្វទាំងពួង ដោយប្រការនោះចុះ ។

ចំណែកភាណវារៈ ៥៨ ដែលគួរដឹងច្បាស់ បណ្ឌិតអ្នកឈ្លាសក្នុងការគណនា គណនាទុកក្នុងអដ្ឋកថាសទ្ធម្មប្បកាសិនីនេះហើយ ចំណែកភាណវារៈនៃអដ្ឋកថានោះ ដែលគណនាដោយចងជាធន្ទ យ៉ាងត្រឹមត្រូវ រាប់បាន ១៨៥០០០ គាថា ។

ខ្ញុំជាអ្នកអើពើរចនាអដ្ឋកថានេះ ដើម្បីឲ្យសាសនាតាំងនៅអស់កាលយូរ និងដើម្បីប្រយោជន៍ដល់សត្វលោក បានបុណ្យបរិបូណ៌មិនមែនតិចយ៉ាងណា ដោយបុណ្យនោះ សូមសត្វលោក បានភ្លក្សរសនៃព្រះសទ្ធម្ម របស់ព្រះទសពល ហើយដល់នូវសេចក្តីសុខប្រាសចាកមន្ទិលដោយងាយហោង ។

**អដ្ឋកថា**

**ខុទ្ទកនិកាយបដិសម្ភិទាមគ្គ**

**ឈ្មោះ សទ្ធម្មប្បកាសិនី ចប់**

# ក្បាលទី ៤៨

# សុត្តន្តបិដក បាលីប្រែ -៧០

## មហាវគ្គ

មាតិកា ទំព័រ


សុត្តន្តបិដក ឥន្ទ្រិយកថា .......... .......... .......... .......... .......... ......... ២

សាវត្ថិនិទាន .......... .......... .......... .......... .......... ......... ៧

សាវត្ថិនិទាន .......... .......... .......... .......... .......... .......... ២៤

អដ្ឋកថា ឥន្ទ្រិយកថា .......... .......... .......... .......... .......... ....... ៦៧

បឋមសុត្តន្តនិទ្ទេស .......... .......... .......... .......... .......... ....... ៦៧

ទុតិយសុត្តន្តនិទ្ទេស .......... .......... .......... .......... .......... ....... ៨៩

អស្សាទនិទ្ទេស .......... .......... .......... .......... .......... ...... ៩២

អាទីនវនិទ្ទេស .......... .......... .......... .......... .......... ...... ៩៤

និស្សរណនិទ្ទេស .......... .......... .......... .......... .......... ..... ៩៤

តតិយសុត្តន្តនិទ្ទេស .......... .......... .......... .......... .......... ..... ៩៨

បភេទគណនិទ្ទេស .......... .......... .......... .......... .......... .. ១០០

ចរិយាវារ .......... .......... .......... .......... .......... .. ១០១

ចារវិហារនិទ្ទេស .......... .......... .......... .......... .......... ... ១០២

ចតុត្ថសុត្តន្តនិទ្ទេស .......... .......... .......... .......... .......... ... ១០៩

អាធិបតេយ្យដ្ឋនិទ្ទេស .......... .......... .......... .......... .......... .... ១១០

អាទិវិសោធនដ្ឋនិទ្ទេស .......... .......... .......... .......... .......... ... ១១១

អធិមត្តដ្ឋនិទ្ទេស .......... .......... .......... .......... .......... .... ១១២

អធិដ្ឋានដ្ឋនិទ្ទេស .......... .......... .......... .......... ............ ១១៥

បរិយាទានដ្ឋបតិដ្ឋាបកដ្ឋនិទ្ទេស .......... .......... .......... .......... ............ ១១៦

ឥន្ទ្រិយសមោធាន .......... .......... .......... .......... ............ ១១៧
សុត្តន្តបិដក វិមោក្ខកថា .......... .......... .......... .......... ........... ១២៤
បរិបុណ្ណនិទាន .......... .......... .......... .......... ............ ១២៤
អដ្ឋកថា វិមោក្ខុទ្ទេស .......... .......... .......... .......... ............ ១៩៣
អដ្ឋកថា វិមោក្ខនិទ្ទេស .......... .......... .......... .......... ........... ២០១
សុត្តន្តបិដក គតិកថា .......... .......... .......... .......... ............ ២៤៤
អដ៏កថា គតិកថា .......... .......... .......... .......... ............ ២៥២
សុត្តន្តបិដក កម្មកថា .......... .......... .......... .......... ............ ២៦៣
អដ៏កថា កម្មកថា .......... .......... .......... .......... ............ ២៦៦
សុត្តន្តបិដក វិបល្លាសកថា .......... .......... .......... .......... ........... ២៧៣
បរិបុណ្ណនិទាន .......... .......... .......... .......... ............ ២៧៣
អដ្ឋកថា វិបល្លាសកថា .......... .......... .......... .......... ........... ២៧៦
សុត្តន្តបិដក មគ្គកថា .......... .......... .......... .......... ............ ២៨១
អដ្ឋកថា មគ្គកថា .......... .......... .......... .......... ............ ២៨៨

## សុត្តន្តបិដក បាលីប្រែ –៧១

សុត្តន្តបិដក មណ្ឌបេយ្យកថា .......... .......... .......... .......... ........... ២៩១
អដ្ឋកថា មណ្ឌបេយ្យកថា .......... .......... .......... .......... ........... ៣០២

### មជ្ឈិមវគ្គ

សុត្តន្តបិដក យុគនទ្ធកថា .......... .......... .......... .......... ........ ៣១០
អដ្ឋកថា យុគនទ្ធកថា .......... .......... .......... .......... ........ ៣៣២
អដ្ឋកថា សុត្តន្តនិទ្ទេស .......... .......... .......... .......... ........ ៣៣៨
អដ្ឋកថា ធម្មុទ្ធច្ចវារនិទ្ទេស .......... .......... .......... .......... ........ ៣៤៥
សុត្តន្តបិដក សច្ចកថា .......... .......... .......... .......... ........ ៣៥៩

បរិបុណ្ណកថានិទាន .......... .......... .......... .......... ........ ៣៥៩
អដ្ឋកថា សច្ចកថា .......... .......... .......... .......... ........ ៣៧៩
អដ្ឋកថា បឋមសុត្តន្តនិទ្ទេស .......... .......... .......... .......... ........ ៣៨១
អដ្ឋកថា ទុតិយសុត្តន្តបាលី .......... .......... .......... .......... ........ ៣៨៩
អដ្ឋកថា ទុតិយសុត្តន្តនិទ្ទេស .......... .......... .......... .......... ........ ៣៩២
សុត្តន្តបិដក ពោជ្ឈង្គកថា .......... .......... .......... .......... ........ ៣៩៦
សាវត្ថិនិទាន .......... .......... .......... .......... ........ ៣៩៦
អដ្ឋកថា ពោជ្ឈង្គកថា .......... .......... .......... .......... ........ ៤២៤
អដ្ឋកថា មូលមូលកាទិទសកកថា .......... .......... .......... .......... ... ៤២៨
អដ្ឋកថា សុត្តន្តនិទ្ទេស .......... .......... .......... .......... ........ ៤៣៣
សុត្តន្តបិដក មេត្តាកថា .......... .......... .......... .......... ........ ៤៣៦
សាវត្ថីនិទាន .......... .......... .......... .......... ........ ៤៣៦
អដ្ឋកថា មេត្តាកថា .......... .......... .......... .......... ........ ៤៥៣
អដ្ឋកថា ឥន្ទ្រិយវារៈ .......... .......... .......... .......... ........ ៤៥៩
អដ្ឋកថា វារៈ ៣ មានពលៈជាដើម .......... .......... .......... .......... ..... ៤៦៣
សុត្តន្តបិដក វិរាគកថា .......... .......... .......... .......... ...... ៤៦៤
អដ្ឋកថា វិរាគកថា .......... .......... .......... ........... ៤៧៥
សុត្តន្តបិដក បដិសម្ភិទាកថា .......... .......... .......... ........... ៤៨១
អដ្ឋកថា បដិសម្ភិទាកថា .......... .......... .......... ........... ៥០៥
អដ្ឋកថាធម្មចក្កប្បវត្តនវារៈ .......... .......... .......... ........... ៥០៥
អត្ថរបស់ ឧឡារ សព្ទ .......... .......... .......... ........... ៥១៦
អដ្ឋកថា សតិប្បដ្ឋានវារជាដើម .......... .......... .......... ........... ៥១៩
អដ្ឋកថា សត្តពោធិសត្តវារៈជាដើម .......... .......... .......... ........... ៥២០

អដ្ឋកថា ធាតុទ្វធម្មវារ .......... .......... .......... .......... ៥២២

សុត្តន្តបិដក ធម្មចក្កកថា .......... .......... .......... .......... ៥២៤

អដ្ឋកថា ធម្មចក្កកថា .......... .......... .......... .......... ៥៣៩

អដ្ឋកថា សច្ចវារ .......... .......... .......... .......... ៥៣៩

អដ្ឋកថា សតិប្បដ្ឋានវារៈជាដើម .......... .......... .......... .......... ៥៤៤

សុត្តន្តបិដក លោកុត្តរកថា .......... .......... .......... .......... ៥៤៥

អដ្ឋកថា លោកុត្តរកថា .......... .......... .......... .......... ៥៤៨

សុត្តន្តបិដក ពលកថា .......... .......... .......... .......... ៥៥៨

សាវត្ថីនិទាន .......... .......... .......... .......... ៥៥៨

អដ្ឋកថា ពលកថា .......... .......... .......... .......... ៥៧៦

អត្ថរបស់ ចក្ក សព្ទ .......... .......... .......... .......... ៥៨៧

សុត្តន្តបិដក សុញ្ញកថា .......... .......... .......... .......... ៥៩៩

អដ្ឋកថា សុញ្ញកថា .......... .......... .......... .......... ៦១៣

## ចូឡវគ្គ

សុត្តន្តបិដក មហាបញ្ញាកថា .......... .......... .......... .......... ៦៣៤

អដ្ឋកថា មហាបញ្ញាកថា .......... .......... .......... .......... ........ ៦៧២

អដ្ឋកថា សោឡសបញ្ញានិទ្ទេស .......... .......... .......... .......... ........ ៦៧៩

អដ្ឋកថា បុគ្គលវិសេសនិទ្ទេស .......... .......... .......... .......... ........ ៧១០

សុត្តន្តបិដក ឥទ្ធិកថា .......... .......... .......... .......... ........ ៧១៣

អដ្ឋកថា ឥទ្ធិកថា .......... .......... .......... .......... ........ ៧៣០

អដ្ឋកថា ទសឥទ្ធិនិទ្ទេស .......... .......... .......... .......... ....... ៧៣៧

សុត្តន្តបិដក អភិសមយកថា .......... .......... .......... .......... ........ ៨០៤

អដ្ឋកថា អភិសមយកថា .......... .......... .......... .......... ........ ៨១២

សុត្តន្តបិដក វិវេកកថា .......... .......... .......... ........... ....... ៨២០
សាវត្ថីនិទាន .......... .......... .......... ........... ...... ៨២០
អដ្ឋកថា វិវេកកថា .......... .......... .......... .......... ....... ៨៣០
អដ្ឋកថា មគ្គន្តនិទ្ទេស .......... .......... .......... ........... ...... ៨៣៣
សុត្តន្តបិដក ចរិយាកថា .......... .......... .......... ......... ........ ៨៣៧
អដ្ឋកថា ចរិយាកថា .......... .......... .......... .......... ........ ៨៣៩
សុត្តន្តបិដក បាដិហារិយកថា .......... .......... .......... ......... ........ ៨៤០
អដ្ឋកថា បាដិហារិយកថា .......... .......... .......... .......... ........ ៨៤៥
សុត្តន្តបិដក សមសីសកថា .......... .......... .......... .......... ....... ៨៥២
អដ្ឋកថា សមសីសកថា .......... .......... .......... ......... ....... ៨៥៥
សុត្តន្តបិដក សតិប្បដ្ឋានកថា .......... .......... .......... ......... ....... ៨៥៦
សាវត្ថីបរិបុណ្ណនិទាន .......... .......... .......... ......... ........ ៨៥៦
អដ្ឋកថា សតិប្បដ្ឋានកថា .......... .......... .......... ......... ....... ៨៦៣
សុត្តន្តបិដក វិបស្សនាកថា .......... .......... .......... ......... ....... ៨៦៩
សាវត្ថីបរិបុណ្ណនិទាន .......... .......... .......... ........... ........... ៨៦៩
អដ្ឋកថា វិបស្សនាកថា .......... .......... .......... ........... ............ ៨៨១
សុត្តន្តបិដក មាតិកាកថា .......... .......... .......... ........... ............. ៨៩០
អដ្ឋកថា មាតិកាកថា .......... .......... .......... ........... ............. ៨៩៧